# ព្រះត្រៃបិដក

## ប្រែរួមនឹងព្រះអដ្ឋកថា

## ភាគ៦៨

បាលីប្រែ ៨១

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# អភិធម្មបិដក

## និង

# សម្មោហវិនោទនី អដ្ឋកថា

### សេចក្តីប្រែជាភាសាខ្មែរ

## វិភង្គ

## ទុតិយភាគ

# ៦៨

## បាលីប្រែ ~ ៨១



បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣

# ក្បាលទី ៦៨

# វិភង្គ ទុតិយភាគ

## បច្ចយាការវិភង្គ

[ ១ ] *សង្ខារទាំងឡាយ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ សឡាយតនៈ កើតមាន ព្រោះនាមរូបជាបច្ច័យ ផស្សៈ កើតមាន ព្រោះសឡាយតនៈជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា មរណៈ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាស កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះឯង ។*

[ ២ ] *បណ្តាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្តេច ។ ការមិនដឹងក្នុងទុក្ខ ការមិនដឹងក្នុងហេតុជាទីកើតឡើងនៃទុក្ខ ការមិនដឹងក្នុងធម៌ជាទីរលត់ទៅនៃទុក្ខ ការមិនដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ នេះហៅថា អវិជ្ជា ។*

[ ៣ ] *បណ្តាបច្ចយាការទាំងនោះ សង្ខារទាំងឡាយ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្តេច ។ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អានេញ្ជាភិ-*

សង្ខារ កាយសង្ខារ វចីសង្ខារ ចិត្តសង្ខារ ។ បណ្តាសង្ខារទាំងនោះ បុញ្ញាភិសង្ខារ តើដូចម្តេច ។ ចេតនាជាកុសល ជាកាមាវចរ និងរូបាវចរ ដែលសម្រេចដោយទាន សម្រេចដោយសីល សម្រេចដោយភាវនា នេះហៅថា បុញ្ញាភិសង្ខារ ។ បណ្តាសង្ខារទាំងនោះ អបុញ្ញាភិសង្ខារ តើដូចម្តេច ។ ចេតនាជាអកុសល ជាកាមាវចរ នេះហៅថា អបុញ្ញាភិសង្ខារ ។ បណ្តាសង្ខារទាំងនោះ អានេញ្ជាភិសង្ខារ តើដូចម្តេច ។ ចេតនាជាកុសល ជាអរូបាវចរ នេះហៅថា អានេញ្ជាភិសង្ខារ ។ បណ្តាសង្ខារទាំងនោះ កាយសង្ខារ តើដូចម្តេច ។ កាយសញ្ចេតនា ឈ្មោះថា កាយសង្ខារ វចីសញ្ចេតនា ឈ្មោះថា វចីសង្ខារ មនោសញ្ចេតនា ឈ្មោះថា ចិត្តសង្ខារ ។ ធម៌ទាំងនេះ ហៅថា សង្ខារទាំងឡាយ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។

[ ៤ ] បណ្តាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្តេច ។ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។

[ ៥ ] បណ្តាបច្ចយាការទាំងនោះ នាមរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្តេច ។ នាមក៏មាន រូបក៏មាន ។ បណ្តានាម និងរូបនោះ នាម តើដូចម្តេច ។ វេទនា សញ្ញា ចេតនា ផស្សៈ មនសិការ នេះហៅថា នាម ។ បណ្តានាម និងរូបនោះ រូប តើដូចម្តេច ។ មហាភូតរូប ៤ និងរូបដែលអាស្រ័យមហាភូតទាំង ៤ នេះហៅថា រូប ។ នាមនេះផង រូបនេះផង

នេះហៅថា នាម និងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ដោយប្រការដូច្នេះ ។

[ ៦ ] បណ្តាបច្ចយាការទាំងនោះ សឡាយតនៈ កើតមាន ព្រោះនាម និងរូបជាបច្ច័យ តើដូចម្តេច ។ ចក្ខាយតនៈ សោតាយតនៈ ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ មនាយតនៈ នេះហៅថា សឡាយតនៈ កើតមាន ព្រោះនាម និងរូបជាបច្ច័យ ។

[ ៧ ] បណ្តាបច្ចយាការទាំងនោះ ផស្សៈ កើតមាន ព្រោះសឡាយតនៈជាបច្ច័យ តើដូចម្តេច ។ ចក្ខុសម្ផស្ស សោតសម្ផស្ស ឃានសម្ផស្ស ជិវ្ហាសម្ផស្ស កាយសម្ផស្ស មនោសម្ផស្ស នេះហៅថា ផស្សៈ កើតមាន ព្រោះសឡាយតនៈជាបច្ច័យ ។

[ ៨ ] បណ្តាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្តេច ។ វេទនា កើតអំពីចក្ខុសម្ផស្ស វេទនា កើតអំពីសោតសម្ផស្ស វេទនា កើតអំពីឃានសម្ផស្ស វេទនា កើតអំពីជិវ្ហាសម្ផស្ស វេទនា កើតអំពីកាយសម្ផស្ស វេទនា កើតអំពីមនោសម្ផស្ស នេះហៅថា វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ។

[ ៩ ] បណ្តាបច្ចយាការទាំងនោះ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្តេច ។ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា នេះហៅថា តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ។

[ ១០ ] បណ្តាបច្ចយាការទាំងនោះ ឧបាទាន កើតមាន ព្រោះតណ្ហាជា

បច្ច័យ តើដូចម្តេច ។ កាមុបាទាន ទិដ្ឋុបាទាន សីលព្វតុបាទាន អត្តវាទុបាទាន នេះហៅថា ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ។

[ ១១ ] បណ្តាបច្ចយាការទាំងនោះ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ តើដូចម្តេច ។ ភព មាន ២ គឺកម្មភពក៏មាន ឧបបត្តិភពក៏មាន ។ បណ្តាភពទាំងនោះ កម្មភព តើដូចម្តេច ។ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អានេញ្ជាភិសង្ខារ នេះហៅថា កម្មភព សូម្បីកម្មទាំងអស់ ដែលជាដំណើរទៅកាន់ភព ក៏ឈ្មោះថា កម្មភពដែរ ។ បណ្តាភពទាំងនោះ ឧបបត្តិភព តើដូចម្តេច ។ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព នេះហៅថា ឧបបត្តិភព ។ កម្មភពនេះផង ឧបបត្តិភពនេះផង នេះហៅថា ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ដោយប្រការដូច្នេះ ។

[ ១២ ] បណ្តាបច្ចយាការទាំងនោះ ជាតិ កើតមាន ព្រោះភពជាបច្ច័យ តើដូចម្តេច ។ ការកើត ការកើតព្រម ការចាប់កំណើត ការកើតចំពោះ ការកើតប្រាកដនៃខន្ធទាំងឡាយ ការបានចំពោះនូវអាយតនៈទាំងឡាយណា របស់សត្វទាំងឡាយនោះៗ ក្នុងសត្តនិកាយនោះៗ នេះហៅថា ជាតិ កើតមាន ព្រោះភពជាបច្ច័យ ។

[ ១៣ ] បណ្តាបច្ចយាការទាំងនោះ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ តើដូចម្តេច ។ ជរាក៏មាន មរណៈក៏មាន ។ បណ្តាជរា និងមរណៈនោះ ជរា តើដូចម្តេច ។ សេចក្តីចាស់គ្រាំគ្រា ធ្មេញបាក់ សក់ស្កូវ

ស្បែកជ្រួញជ្រីវ ការរួញថយនៃអាយុ ការចាស់ទុំនៃឥន្ទ្រិយទាំងឡាយណា របស់សត្វទាំងឡាយនោះៗ ក្នុងសត្តនិកាយនោះៗ នេះហៅថា ជរា ។ បណ្តា ជរា និងមរណៈនោះ មរណៈ តើដូចម្តេច ។ ការច្យុត ការឃ្លាត ការបែក ធ្លាយ ការបាត់បង់ មច្ចុ មរណៈ កាលកិរិយា ការបែកធ្លាយនៃខន្ធទាំង ឡាយ ការដាក់ចុះនូវសាកសព ការផ្តាច់ផ្តិលនូវជីវិតិន្ទ្រិយណា ចាកសត្ត-និកាយនោះៗ របស់សត្វទាំងឡាយនោះៗ នេះហៅថា មរណៈ ។ ជរានេះ ឯង មរណៈនេះឯង នេះហៅថា ជរា និងមរណៈ កើតមាន ព្រោះជាតិ ជាបច្ច័យ ដោយប្រការដូច្នេះ ។

[ ១៤ ] បណ្តាបច្ចយាការទាំងនោះ សោក តើដូចម្តេច ។ សេចក្តីសោក អាការសោក ភាពនៃសេចក្តីសោក ការស្ងួតស្ងប់ខាងក្នុង ការក្រៀមក្រំខាង ក្នុង ការជ្រប់ស្រពោននៃចិត្ត ការតូចចិត្ត សរ គឺសេចក្តីសោករបស់បុគ្គល ដែលត្រូវសេចក្តីវិនាសញាតិ ប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសភោគៈ ប៉ះពាល់ ក្តី ត្រូវសេចក្តីវិនាស គឺរោគ ប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសសីល ប៉ះពាល់ក្តី ត្រូវសេចក្តីវិនាស គឺទិដ្ឋិ ប៉ះពាល់ក្តី ឬប្រកបដោយសេចក្តីវិនាសណាមួយ ឬត្រូវទុក្ខធម៌ណាមួយ ប៉ះពាល់ហើយ នេះហៅថា សោក ។

[ ១៥ ] បណ្តាបច្ចយាការទាំងនោះ បរិទេវៈ តើដូចម្តេច ។ សេចក្តី ខ្សឹកខ្សួល ការទួញយំ អាការខ្សឹកខ្សួល អាការទួញយំ ភាពខ្សឹកខ្សួល ភាព ទួញយំ ការពោល ការយំរៀបរាប់ ការយំអណ្តឺតអណ្តក ការពោល ដដែលៗ អាការពោលដដែលៗ ភាពពោលដដែលៗ របស់បុគ្គលដែលត្រូវ

សេចក្ដីវិនាសញាតិ ប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសភោគៈ ប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាស គឺរោគ ប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសសីល ប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាស គឺទិដ្ឋិ ប៉ះពាល់ក្ដី ឬប្រកបដោយសេចក្ដីវិនាសណាមួយ ឬក៏ត្រូវទុក្ខធម៌ណាមួយ ប៉ះពាល់ហើយ នេះហៅថា បរិទេវៈ ។

[ ១៦ ] បណ្ដាបច្ចយាការទាំងនោះ ទុក្ខ តើដូចម្ដេច ។ សេចក្ដីមិនត្រេកអរប្រព្រឹត្តទៅក្នុងកាយ ទុក្ខប្រព្រឹត្តទៅក្នុងកាយ ការទទួលអារម្មណ៍មិនជាទីត្រេកអរ ដែលកើតអំពីកាយសម្ផស្ស វេទនាមិនជាទីត្រេកអរ ជាទុក្ខដែលកើតអំពីកាយសម្ផស្សណា នេះហៅថា ទុក្ខ ។

[ ១៧ ] បណ្ដាបច្ចយាការទាំងនោះ ទោមនស្ស តើដូចម្ដេច ។ សេចក្ដីមិនត្រេកអរប្រព្រឹត្តទៅក្នុងចិត្ត ទុក្ខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនជាទីត្រេកអរ ជាទុក្ខដែលកើតអំពីចេតោសម្ផស្ស វេទនាមិនជាទីត្រេកអរ ជាទុក្ខដែលកើតអំពីចេតោសម្ផស្សណា នេះហៅថា ទោមនស្ស ។

[ ១៨ ] បណ្ដាបច្ចយាការទាំងនោះ ឧបាយាស តើដូចម្ដេច ។ សេចក្ដីតានតឹងចិត្ត សេចក្ដីចង្អៀតចង្អល់ចិត្ត ភាពតានតឹងចិត្ត ភាពចង្អៀតចង្អល់ចិត្ត របស់បុគ្គលដែលត្រូវសេចក្ដីវិនាសញាតិ ប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាស

ភោគៈ ប៉ះពាល់ក្តី ត្រូវសេចក្តីវិនាស គឺរោគ ប៉ះពាល់ក្តី ត្រូវសេចក្តីវិនាស សីល ប៉ះពាល់ក្តី ត្រូវសេចក្តីវិនាស គឺទិដ្ឋិ ប៉ះពាល់ក្តី ឬប្រកបដោយសេចក្តីវិនាសណាមួយ ឬក៏ត្រូវទុក្ខធម៌ណាមួយ ប៉ះពាល់ហើយ នេះហៅថា ឧបាយាស ។

[ ១៩ ] ត្រង់ពាក្យថា ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ គឺការជួបជុំ ការមូលមក ការប្រជុំចុះ ការកើតប្រាកដនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ព្រោះហេតុនោះ ទើបលោកពោលថា ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះឯង ។

## សុត្តន្តភាជនីយ ចប់

# អដ្ឋកថា

# បដិច្ចសមុប្បាទវិភង្គ

## សុត្តន្តភាជនីយ ឧទ្ទេសវារ

[ ១-១៩ ] *ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងបដិច្ចសមុប្បាទវិភង្គ ក្នុងលំដាប់បន្ទាប់អំពីឥន្ទ្រិយវិភង្គតទៅ*

*ព្រះបាលីតន្តិ ( បែបផែន ) នេះ ដែលព្រះមានព្រះភាគ ទ្រង់ចាត់តាំងដោយន័យជាដើមថា* **អវិជ្ជាបច្ចយា សង្ខារា** *ដូច្នេះ ដែលកុលបុត្រអ្នកធ្វើកិច្ចពណ៌នាអត្ថនៃព្រះបាលីតន្តិនោះ គួរចូលទៅកាន់ទីប្រជុំនៃពុទ្ធសាវក ដែលជាវិភជ្ជវាទី គប្បីជាអ្នកមិនពោលលើកទោសអាចារ្យ មិនលម្អៀងទៅកាន់លទ្ធិរបស់ខ្លួន មិនខ្វល់ខ្វាយក្នុងលទ្ធិដទៃ មិនបដិសេធព្រះសូត្រ អនុលោមតាមព្រះវិន័យ ពិនិត្យមើលមហាបទេស សម្តែងធម៌ គឺបដិច្ចសមុប្បាទ រួបរួមអត្ថនិងប្តូរសេចក្តីនោះឯង សម្តែងដោយបរិយាយដទៃបានទៀត ទើបគួរធ្វើកិច្ចពណ៌នាអត្ថនៃព្រះបាលីតន្តិ ។ ម្យ៉ាងវិញទៀត កិច្ចពណ៌នាអត្ថនៃបដិច្ចសមុប្បាទ សូម្បីដោយប្រក្រតី ក៏ជារឿងដែលធ្វើបានដោយលំបាក ដូចបោរាណាចារ្យទាំងឡាយពោលថា*

*ធម៌ ៤ យ៉ាង គឺសច្ចៈ ១ សត្តប្បញ្ញត្តិ ១ បដិសន្ធិ ១ បច្ចយាការ*
*១ ជាធម៌ដែលឃើញបានដោយក្រ និងសម្តែងបានដោយក្រ*
*ដូច្នេះ ។*

ព្រោះហេតុនោះ កិច្ចពណ៌នាអត្ថនៃបដិច្ចសមុប្បាទ ទើបធ្វើមិនបាន ដោយងាយ វៀរតែលោកអ្នកដែលសម្រេចបរិយត្តិ និងសម្រេចមគ្គផល ទាំងឡាយហើយប៉ុណ្ណោះ ។

ខ្ញុំ ( ពុទ្ធឃោសាចារ្យ ) ពិចារណាហើយ បំណងនឹងពោល ពណ៌នាបច្ចយាការក្នុងថ្ងៃនេះ តែមិនទាន់បានទីពឹង ដូចឈានចុះ កាន់សាគរ តែព្រោះព្រះសាសនា គឺបាលីបដិច្ចសមុប្បាទនេះ ប្រដាប់ដោយន័យរបស់ទេសនាផ្សេងៗ និងគន្លងនៃការរចនារបស់ បុព្វាចារ្យ គឺអដ្ឋកថាបុរាណ ក៏នៅប្រព្រឹត្តទៅមិនដាច់ខ្សែ ហេតុ នោះ ខ្ញុំអាស្រ័យសេចក្តីទាំងពីរនោះ ផ្តើមពណ៌នាអត្ថរបស់បដិច្ច- សមុប្បាទនេះ សូមអ្នកទាំងឡាយ តាំងចិត្តស្តាប់កិច្ចពណ៌នានេះ ដូច្នេះ ។

សេចក្តីនេះ សមដូចពាក្យដែលបុព្វាចារ្យពោលហើយថា បុគ្គលឯណាម្នាក់ ដាក់ចិត្តស្តាប់កិច្ចពណ៌នានេះ បុគ្គលនោះ គប្បី បាននូវគុណវិសេសតទៅក្នុងភពខាងមុខ កាលបានគុណវិសេស ក្នុងភពខាងមុខហើយ មច្ចុរាជក៏មើលមិនឃើញ ដូច្នេះ ។

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យជាដើមថា **អវិជ្ជាបច្ចយា សង្ខារា** ដូច្នេះ ចាប់តាំងអំពីខាងដើមនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យដោយការផ្សេងគ្នានៃទេសនា ១ ដោយអត្ថ ១ ដោយលក្ខណៈជាដើម ១ ដោយធម៌ដែលមានតែមួយជាដើម ១ ដោយការកំណត់អង្គទាំងឡាយ ១ ដូច្នេះ ។

បណ្ដាបទវិនិច្ឆ័យទាំងនោះ ពាក្យថា ដោយការផ្សេងគ្នានៃទេសនានោះ អធិប្បាយថា ការសម្ដែងបដិច្ចសមុប្បាទរបស់ព្រះមានព្រះភាគ មាន ៤ ន័យ គឺទ្រង់សម្ដែងតាំងអំពីខាងដើម ទៅដល់ខាងចុងក៏មាន ពីកណ្ដាលទៅខាងចុងក៏មាន ម្យ៉ាងទៀត ទ្រង់សម្ដែងពីខាងចុងទៅខាងដើមក៏មាន ពីកណ្ដាលទៅខាងដើមក៏មាន ដូចការចាប់វល្លិរបស់បុរស ៤ នាក់ ហើយនាំវល្លិទៅដូច្នោះ ។

ឧបមាក្នុងបុរស ៤ នាក់ដែលរកវល្លិ បុរសទី ១ ឃើញគល់វល្លិមុននោះឯង ទើបកាត់គល់វល្លិនោះ ចាប់ទាញវល្លិទាំងអស់ យកទៅប្រើប្រាស់ក្នុងការងារយ៉ាងណា ព្រះមានព្រះភាគក៏យ៉ាងនោះ ទ្រង់សម្ដែងបដិច្ចសមុប្បាទ តាំងអំពីខាងដើម រហូតដល់ខាងចុង ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។បេ។ សេចក្ដីចាស់ ស្លាប់ ( កើតមាន ) ព្រោះជាតិជាបច្ច័យ រមែងមានយ៉ាងនេះ ដូច្នេះឯង ។

ឧបមាក្នុងបុរសទាំងនោះ បុរសម្នាក់ឃើញវល្លិត្រង់កណ្ដាលមុន ទើបកាត់ត្រង់កណ្ដាល កាន់យកចំណែកខាងលើប៉ុណ្ណោះ មកប្រើប្រាស់ក្នុងកិច្ចយ៉ាងណា ព្រះមានព្រះភាគក៏យ៉ាងនោះ ទ្រង់សម្ដែងចាប់ពីកណ្ដាល រហូតដល់ខាងចុង ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា កាលបើកុមារនោះ

គ្រោកអរ និយាយសរសើរ ប្រកាន់វេទនានោះហើយ ក៏កើតទៅជាតម្រេក កាលបើតម្រេកក្នុងវេទនាទាំងឡាយមានហើយ ឧបាទាន ក៏កើតឡើងដល់កុមារនោះ ព្រោះតម្រេកនោះ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ ដូច្នេះ ។

ឧបមាក្នុងបុរសទាំងនោះ បុរសម្នាក់ឃើញចុងវល្លិមុន ទើបចាប់ចុងស្រាវយកមករហូតដល់គល់ តាមគន្លងរបស់ចុងវល្លិ ហើយនាំទៅប្រើប្រាស់យ៉ាងណា ព្រះមានព្រះភាគក៏យ៉ាងនោះ ទ្រង់សម្តែងបដិច្ចសមុប្បាទ តាំងអំពីខាងចុង រហូតដល់ខាងដើម ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ពាក្យថា ជរាមរណៈ កើតមាន ព្រោះជាតិជាបច្ច័យដូច្នេះនេះ តថាគតសម្តែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះជរាមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ មិនមានក្នុងខន្ធបញ្ចកៈនោះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ជរាមរណៈ កើតមាន ព្រោះជាតិជាបច្ច័យមែន ទាំងយើងខ្ញុំព្រះអង្គ ក៏មានសេចក្តីយល់ឃើញក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា ជរាមរណៈ កើតមាន ព្រោះជាតិជាបច្ច័យដែរ ។ ពាក្យថា ជាតិ កើតមាន ព្រោះភពជាបច្ច័យ ដូច្នេះនេះ តថាគតបានសម្តែងហើយមែន ។បេ។ ពាក្យថា សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ដូច្នេះនេះ តថាគតសម្តែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះសង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ មិនមានក្នុងខន្ធ-បញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ដូច្នេះមែន ទាំងយើងខ្ញុំព្រះអង្គ ក៏មាន

សេចក្ដីយល់ឃើញក្នុងខន្ធបញ្ចកៈនុ៎ះ យ៉ាងនេះថា សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យដែរ ដូច្នេះ ។

ឧបមាក្នុងបុរសទាំងនោះ បុរសម្នាក់ឃើញវល្លិត្រង់កណ្ដាលនោះឯងមុន ទើបកាត់ត្រង់កណ្ដាល ស្រាវមកខាងក្រោមរហូតដល់គល់ កាត់នាំយកទៅប្រើប្រាស់ក្នុងការងារយ៉ាងណា ព្រះមានព្រះភាគក៏យ៉ាងនោះ ទ្រង់សម្ដែងតាំងអំពីកណ្ដាលរហូតដល់ខាងដើម ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលភិក្ខុទាំងឡាយ ចុះអាហារទាំង ៤ នេះ មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត ។ អាហារទាំង ៤ នេះ មានតណ្ហាជាហេតុ មានតណ្ហានាំឲ្យកើត មានតណ្ហាជាកំណើត មានតណ្ហាជាដែនកើត ។ ម្នាលភិក្ខុទាំងឡាយ ក៏តណ្ហានេះ មានអ្វីជាហេតុ ... វេទនា ... ផស្សៈ ... សឡាយតនៈ ... នាមរូប ... វិញ្ញាណ ... សង្ខារទាំងឡាយនេះ មានអ្វីជាហេតុ ។បេ។ សង្ខារទាំងឡាយ មានអវិជ្ជាជាហេតុ មានអវិជ្ជានាំឲ្យកើត មានអវិជ្ជាជាកំណើត មានអវិជ្ជាជាដែនកើត ដូច្នេះ ។

សួរថា ព្រោះហេតុអ្វី ទើបទ្រង់សម្ដែងដូច្នេះ ឆ្លើយថា ព្រោះបដិច្ច-សមុប្បាទ ជាធម៌ចម្រើនដោយជុំវិញ ព្រះមានព្រះភាគសោត ទ្រង់ក៏ដល់នូវភាពជាអ្នកស្ទាតដោយទេសនា ។

ពិតហើយ បដិច្ចសមុប្បាទ ជាធម៌ចម្រើនដោយជុំវិញ រមែងប្រព្រឹត្តទៅព្រម ដើម្បីចាក់ធ្លុះនូវញេយ្យធម៌ដោយទេសនានោះឯង មួយវិញទៀត ព្រះមានព្រះភាគ ទ្រង់ដល់នូវភាពជាអ្នកស្ទាតដោយទេសនា ព្រោះទ្រង់ប្រកប

ដោយវេសារជ្ជញ្ញាណ ៤ និងបដិសម្ភិទាញ្ញាណ ៤ ហើយទ្រង់ដល់នូវជម្រៅក្នុងបដិច្ចសមុប្បាទ ៤ យ៉ាង ទ្រង់សម្ដែងធម៌ដោយន័យផ្សេងៗ នោះឯង ព្រោះទ្រង់ដល់នូវភាពជាអ្នកស្អាតដោយទេសនា ។

តែកាលពោលដោយប្លែកគ្នានៃទេសនា បដិច្ចសមុប្បាទនោះ ទេសនាណា ជាទេសនាដោយអនុលោម ចាប់តាំងអំពីដើមទេសនានោះ បណ្ឌិតគប្បីជ្រាបថា ជាទេសនាដែលព្រះមានព្រះភាគ ពិចារណាឃើញវេនេយ្យជនដែលវង្វេងក្នុងការចែកហេតុដែលប្រព្រឹត្តទៅ ទើបទ្រង់ប្រកាស ដើម្បីចង្អុលបង្ហាញការប្រព្រឹត្តទៅតាមហេតុដែលគួរដល់ខ្លួន និងដើម្បីចង្អុលបង្ហាញដល់លំដាប់នៃការកើតឡើង ។ ទេសនាណា ជាទេសនាដោយបដិលោម ចាប់អំពីខាងចុងបញ្ច្រាសមក ទេសនានោះ គប្បីជ្រាបថា ជាទេសនាដែលព្រះអង្គពិចារណាឃើញលោក ដែលដល់នូវសេចក្ដីលំបាកដោយន័យ ( ក្នុងសំយុត្តនិកាយ និទានវគ្គ ) ជាដើមថា ឱហ្ន៎ សត្វលោកនេះ ដល់នូវសេចក្ដីលំបាកណាស់ តែងកើត ចាស់ ស្លាប់ ដូច្នេះ ទើបទ្រង់ប្រកាស ដើម្បីចង្អុលបង្ហាញដល់ហេតុនៃសេចក្ដីទុក្ខ មានជរា និងមរណៈជាដើមនោះៗ ដែលទ្រង់ពិចារណាហើយ ដោយទំនងនៃការចាក់ធ្លុះក្នុងចំណែកខាងដើម ។ម្យ៉ាងទៀត ទេសនាណា ជាទេសនាតាំងអំពីកណ្ដាល ទៅរហូតដល់ខាងដើម ទេសនានោះ គប្បីជ្រាបថា ជាទេសនាដែលទ្រង់ប្រកាសហើយ ដើម្បីនាំអតីតកាលមក ហើយចង្អុលបង្ហាញដោយលំដាប់នៃហេតុ និងផល ចាប់អំពីអតីតកាលទៀត ដោយទំនងនៃការកំណត់តណ្ហា ជាហេតុនៃអាហារ ។ ម្យ៉ាង

ទៀត ទេសនាណា ជាទេសនាដែលប្រព្រឹត្តទៅ ចាប់អំពីកណ្តាលរហូតដល់ចុង ទេសនានោះ គប្បីជ្រាបថា ជាទេសនាដែលទ្រង់ប្រកាស ដើម្បីចង្អុលបង្ហាញអនាគតកាល ចាប់ផ្តើមអំពីសមុដ្ឋាននៃហេតុ របស់អនាគតកាលក្នុងបច្ចុប្បន្នកាល ។

ក្នុងទេសនាទាំង ៤ នោះ ទេសនានេះ ដែលត្រាស់សម្តែងដោយអនុលោម តាំងអំពីខាងដើម ដើម្បីទ្រង់ចង្អុលបង្ហាញនូវការប្រព្រឹត្តទៅតាមហេតុរបស់ខ្លួន ដល់វេនេយ្យជន ដែលជាអ្នកវង្វេងហេតុនៃការប្រព្រឹត្តទៅ និងដើម្បីទ្រង់ចង្អុលបង្ហាញលំដាប់ការកើតឡើងនោះ ទេសនានោះ គប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់ចាត់តាំងហើយ ក្នុងបដិច្ចសមុប្បាទវិភង្គនេះ ។

សួរថា ព្រោះហេតុអ្វី ក្នុងបដិច្ចសមុប្បាទនេះ ព្រះមានព្រះភាគត្រាស់អវិជ្ជាអំពីខាងដើម សូម្បីអវិជ្ជា ក៏មិនមានអ្វីជាហេតុ អវិជ្ជានោះ ជាហេតុដើមរបស់លោក ដូចសស្សតវត្ថុរបស់ពួកបកតិវាទីឬ ឆ្លើយថា អវិជ្ជា មិនមែនមិនមានហេតុ ហេតុនៃអវិជ្ជា ព្រះអង្គត្រាស់ថា **អាសវសមុទយា អវិជ្ជាសមុទយោ** អវិជ្ជាកើត ព្រោះអាសវៈកើត ដូច្នេះ ។

សួរថា បរិយាយនោះ មានហេតុដើម មានដោយសភាវៈណា សភាវៈនោះ បានដល់អ្វី ឆ្លើយថា បានដល់ ភាវៈដែលជាប្រធានរបស់វដ្តកថា ។ ពិតហើយ ព្រះមានព្រះភាគ កាលត្រាស់វដ្តកថា ក៏ត្រាស់ធម៌ ២ យ៉ាង ធ្វើឲ្យជាប្រធាន ឬត្រាស់អវិជ្ជាជាប្រធាន ដូចដែលទ្រង់ត្រាស់ ( ក្នុងអង្គុត្តរនិកាយ ទសកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ ទីបំផុតខាងដើមរបស់អវិជ្ជា

មិនប្រាកដទេ អវិជ្ជាមិនមានក្នុងកាលមុន អំពីកាលនេះ ឬថា កើតឡើងក្នុងខាងក្រោយឡើយ ហេតុនោះ ម្នាលភិក្ខុទាំងឡាយ ពាក្យថា អវិជ្ជានេះ តថាគតពោលយ៉ាងនេះ តែថា អវិជ្ជា រមែងប្រាកដ ព្រោះមានរបស់នេះជាបច្ច័យ ដូច្នេះ ។

ម្យ៉ាងទៀត ទ្រង់ត្រាស់ភវតណ្ហាជាប្រធាន ដូចព្រះតម្រាស់ ( ក្នុងអង្គុត្តរនិកាយ ទសកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ ទីបំផុតខាងដើមរបស់ភវតណ្ហា មិនប្រាកដទេ ភវតណ្ហា ( សេចក្តីប្រាថ្នាក្នុងភព ) មិនមានក្នុងកាលមុន អំពីកាលនេះ ឬថា កើតឡើងក្នុងខាងក្រោយឡើយ ហេតុនោះ ម្នាលភិក្ខុទាំងឡាយ ក៏ពាក្យថា ភវតណ្ហានេះ តថាគតពោលយ៉ាងនេះ តែថា ភវតណ្ហា រមែងប្រាកដ ព្រោះមានរបស់នេះជាបច្ច័យ ដូច្នេះ ។

សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគកាលត្រាស់វដ្តកថា ទើបត្រាស់ធម៌ ២ នេះ ធ្វើឲ្យជាប្រធាន ឆ្លើយថា ព្រោះអវិជ្ជាជាហេតុពិសេសនៃកម្មដែលឲ្យដល់សុគតិ ឬទុគ្គតិ ។ ពិតហើយ អវិជ្ជាជាហេតុពិសេសនៃកម្មដែលឲ្យដល់ទុគ្គតិ ព្រោះហេតុអ្វី ព្រោះបុថុជ្ជនដែលអវិជ្ជាគ្របសង្កត់ហើយ រមែងផ្តើមធ្វើកម្មដែលឲ្យខ្លួនដល់ទុគ្គតិជាច្រើនប្រការ មានបាណាតិបាតជាដើម ដែលមិនមានការត្រេកអរ ព្រោះការក្តៅក្រហាយដោយកិលេសខ្លះ ដែលនាំនូវសេចក្តីវិនាសមកកាន់ខ្លួន ព្រោះត្រូវធ្លាក់ទៅកាន់ទុគ្គតិខ្លះ ដូចមេគោដែលត្រូវសម្លាប់ ត្រូវការបៀតបៀនគ្របសង្កត់ ព្រោះក្តៅក្រហាយដោយភ្លើង និងត្រូវវាយដោយដំបង ផ្តើមផឹកទឹកក្តៅ ដែលមិនមានការត្រេកអរនៃចិត្ត

និងនាំមកនូវសេចក្តីវិនាសដល់ខ្លួន ព្រោះភាពជាសត្វក្រវល់ក្រវាយ ដោយការទ្រុឌទ្រោមនោះ ។

ចំណែកភវតណ្ហា ជាហេតុពិសេសនៃកម្មដែលឲ្យដល់សុគតិ ព្រោះហេតុអ្វី ព្រោះបុថុជ្ជន ត្រូវភវតណ្ហាគ្របសង្កត់ហើយ រមែងផ្តើមធ្វើកម្មដែលឲ្យដល់នូវសុគតិច្រើនប្រការ មានចេតនាជាហេតុនៃការវៀរចាកបាណាតិបាតជាដើម ដែលមានតែសោមនស្ស ព្រោះវៀរចាកការក្តៅក្រហាយដោយកិលេស និងបន្ទោបង់នូវការបៀតបៀនដោយទុក្ខក្នុងទុគ្គតិរបស់ខ្លួន ព្រោះដល់នូវសុគតិ ដូចមេគោមានប្រការតាមដែលពោលហើយ ផ្តើមផឹកទឹកត្រជាក់ មានតែសេចក្តីសុខ ដែលបន្ទោបង់នូវការក្រវល់ក្រវាយរបស់ខ្លួនដោយចំណង់ក្នុងទឹកត្រជាក់ ក៏យ៉ាងនោះ ។

បណ្តាធម៌ដែលជាប្រធាននៃវដ្តកថាទាំងនេះ ក្នុងទីខ្លះ ព្រះមានព្រះភាគទ្រង់សម្តែងទេសនាដែលមានធម៌ ១ ជាមូល ។ សេចក្តីនេះដូចម្តេច ដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ និទានវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ សេចក្តីរបៀបរួម ដូច្នេះ សង្ខារទាំងឡាយ មានអវិជ្ជាជាហេតុ វិញ្ញាណ មានសង្ខារជាហេតុ ដូច្នេះ ។

ម្យ៉ាងទៀត ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុពិចារណាឃើញនូវសេចក្តីត្រេកអរ ក្នុងឧបាទានិយធម៌ទាំងឡាយហើយ តណ្ហា រមែងចម្រើនឡើង ឧបាទាន កើតឡើង ព្រោះតណ្ហាជាបច្ច័យ ដូច្នេះជាដើម ។

ក្នុងទីខ្លះ ទ្រង់សម្តែងធម៌ទាំង ២ ជាមូល ។ សេចក្តីនេះដូចម្តេច គឺ

ដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ និទានវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល ដែលមានអវិជ្ជាជាគ្រឿងរាំង ដែលប្រកបដោយតណ្ហា រមែងមានកាយ គឺបដិសន្ធិនេះ កើតឡើងយ៉ាងនេះឯង ដ្បិតផស្សៈ រមែងកើតឡើង ព្រោះអាស្រ័យនូវធម៌ជាគូៗ នឹងគ្នានុ៎ះយ៉ាងនេះ គឺកាយនេះផង នាមរូបខាងក្រៅផង បុគ្គលពាល ដែលផស្សាយតនៈទាំង ៦ ឬក៏បណ្ដាផស្សាយតនៈទាំងនោះណាមួយ ពាល់ត្រូវហើយ រមែងទទួលនូវសុខ និងទុក្ខដូច្នេះជាដើម ។

បណ្ដាទេសនាទាំងនោះ ទេសនាក្នុងអធិការនេះថា **អវិជ្ជាបច្ចយា សង្ខារា** បណ្ឌិតគប្បីជ្រាបថា ជាទេសនាដែលមានធម៌ ១ ជាមូល ដោយអំណាចអវិជ្ជា ។

គប្បីជ្រាបវិនិច្ឆ័យដោយការផ្សេងគ្នានៃទេសនា ក្នុងបដិច្ចសមុប្បាទនេះ ដោយប្រការដូច្នេះ ។

ពាក្យថា ដោយអត្ថ បានដល់ ដោយអត្ថនៃបទទាំងឡាយ មានអវិជ្ជាជាដើម សួរថា សេចក្ដីនេះដូចម្ដេច ឆ្លើយថា កាយទុច្ចរិតជាដើម ឈ្មោះថាធម្មជាតគប្បីជួប អធិប្បាយថា វត្ថុដែលមិនគួរបាន ដោយអត្ថថា មិនគួរបំពេញ ។ **តំ អវិន្ទិយំ វិន្ទតីតិ អវិជ្ជា** ឈ្មោះថា អវិជ្ជា ព្រោះអត្ថថា រមែងជួបនូវវត្ថុដែលមិនគួរជួបនោះ ។ កាយសុចរិតជាដើម ឈ្មោះថាធម្មជាតដែលគប្បីជួប ព្រោះជាភាវៈផ្ទុយគ្នានឹងកាយទុច្ចរិតជាដើមនោះ ។ ដែលឈ្មោះថា អវិជ្ជា ព្រោះអត្ថថា មិនជួបវត្ថុដែលគួរជួបនោះ ។ **១ឆ្នាំ**

**រាសដ្ឋំ អាយតនដ្ឋានំ អាយតនដ្ឋំ ធាតូនំ សុញ្ញដ្ឋំ សច្ចានំ តថដ្ឋំ ឥន្ទ្រិយានំ អាធិបតេយ្យដ្ឋំ អវិទិតំ ករោតីតិ អវិជ្ជា** *ឈ្មោះថា អវិជ្ជា ព្រោះអត្ថថា រមែងធ្វើ ( បញ្ញា ) មិនឲ្យដឹងច្បាស់នូវអត្ថនៃគំនរខន្ធទាំងឡាយ នូវអត្ថនៃប្រកបកើតរបស់អាយតនៈទាំងឡាយ នូវអត្ថនៃការសោះសូន្យរបស់ធាតុទាំងឡាយ នូវអត្ថដែលពិតរបស់សច្ចៈទាំងឡាយ នូវអត្ថនៃភាពជាអធិបតីរបស់ឥន្ទ្រិយទាំងឡាយ ។* **ទុក្ខាទីនំ បីឡនាទិវសេន វុត្តំ ចតុព្វិធំ ចតុព្វិធំ អត្ថំ អវិទិតំ ករោតីតិបិ អវិជ្ជា** *ឈ្មោះថា អវិជ្ជា ព្រោះអត្ថថា ធ្វើមិនឲ្យដឹងនូវអត្ថនីមួយៗ ៤ យ៉ាង តាមដែលពោលហើយដោយអំណាចការបៀតបៀននៃទុក្ខជាដើម ។* **អន្តវិរហិតេ សំសារេ សព្វយោនិគតិភវ-វិញ្ញាណដ្ឋិតិសត្តាវាសេសុ សត្តេ ជវាបេតីតិ អវិជ្ជា** *ឈ្មោះថា អវិជ្ជា ព្រោះអត្ថថា រមែងញ៉ាំងសត្វឲ្យស្ទុះទៅក្នុងសង្សារ ដែលមិនមានទីបំផុត គឺក្នុងកំណើត គតិ ភព វិញ្ញាណដ្ឋិតិ និងសត្តាវាសទាំងអស់ ។* **បរមត្ថតោ អវិជ្ជមានេសុ ឥត្ថិបុរិសាទីសុ ជវតិ វិជ្ជមានេសុបិ ខន្ធាទីសុ ន ជវតីតិ អវិជ្ជា** *ឈ្មោះថា អវិជ្ជា ព្រោះអត្ថថា រមែងស្ទុះទៅក្នុងបុរសស្ត្រីជាដើម ដែលមិនមានដោយបរមត្ថ មិនស្ទុះទៅក្នុងធម៌ មានខន្ធជាដើមដែលជារបស់មាន ។ម្យ៉ាងទៀត* **ចក្ខុវិញ្ញាណាទីនំ វត្ថារម្មណានំ បដិច្ចសមុប្បាទ-បដិច្ចសមុប្បន្នានញ្ច ធម្មានំ ឆាទនតោបិ អវិជ្ជា** *ឈ្មោះថា អវិជ្ជា ព្រោះបិទបាំងនូវធម៌ដែលអាស្រ័យគ្នានិងគ្នា កើតឡើងនៃបដិច្ចសមុប្បាទ ដោយអំណាចវត្ថុ និងអារម្មណ៍ មានចក្ខុវិញ្ញាណជាដើម ។ ផលអាស្រ័យធម៌ណា*

កើតឡើងប្រព្រឹត្តទៅ ព្រោះហេតុនោះ ទើបធម៌នោះ ឈ្មោះថា បច្ច័យ ។ ពាក្យថា អាស្រ័យ សេចក្តីថា មិនវៀរធម៌នោះ គឺមិនលះបង់ធម៌នោះ ។ ពាក្យថា ប្រព្រឹត្តទៅ សេចក្តីថា រមែងកើតឡើង និងរមែងប្រព្រឹត្តទៅ ។ ម្យ៉ាងទៀត អត្ថនៃបច្ច័យ មានអត្ថថា ជាឧបការៈ ។ អវិជ្ជាផង ជាបច្ច័យផង ព្រោះហេតុនោះ ទើបឈ្មោះថា **អវិជ្ជាបច្ចយា** ។ ព្រោះអវិជ្ជាជាបច្ច័យនោះ ។

**សង្ខតមភិសង្ខរោន្តីតិ សង្ខារា** ធម៌ដែលឈ្មោះថា សង្ខារទាំងឡាយ ព្រោះអត្ថថា តាក់តែងនូវសង្ខតធម៌ ។ ម្យ៉ាងទៀត សង្ខារ មាន ២ យ៉ាង គឺសង្ខារកើតព្រោះអវិជ្ជាជាបច្ច័យ ១ សង្ខារដែលមកដោយសព្ទថា សង្ខារ ១ ។ បណ្តាសង្ខារទាំង ២ នោះ សង្ខារដែលមានព្រោះអវិជ្ជាជាបច្ច័យទាំង ៦ នេះ គឺសង្ខារ ៣ បានដល់ បុញ្ញាភិសង្ខារ ១ អបុញ្ញាភិសង្ខារ ១ អនេញ្ជាភិសង្ខារ ១ និងសង្ខារ ៣ ទៀត គឺកាយសង្ខារ ១ វចីសង្ខារ ១ ចិត្តសង្ខារ ១ ។ សង្ខារទាំងនោះ ត្រឹមតែជាកុសលចេតនា និងអកុសល-ចេតនា ដែលជាលោកិយប៉ុណ្ណោះ ។

សង្ខារដែលមកហើយ ដោយសង្ខារសព្ទទាំងនេះ គឺសង្ខតសង្ខារ ១ អភិសង្ខតសង្ខារ ១ អភិសង្ខរណកសង្ខារ ១ បយោគាភិសង្ខារ ១ ។ បណ្តាសង្ខារទាំងនោះ ធម៌ ព្រមទាំងបច្ច័យ ដែលព្រះមានព្រះភាគត្រាស់ក្នុងប្រយោគជាដើមថា **អនិច្ចា វត សង្ខារា** ទាំងអស់ ឈ្មោះថា សង្ខតសង្ខារ ។ រូបធម៌ អរូបធម៌ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលកើតអំពីកម្ម ដែលពោលហើយក្នុងអដ្ឋកថា ឈ្មោះថា អភិសង្ខតសង្ខារ ។ រូបធម៌ និង អរូបធម៌

ទាំងនោះ រមែងសង្គ្រោះក្នុងបាលីនេះថា **អវិជ្ជា វត សង្ខារា** នោះឯង តែអាគតដ្ឋាននៃរូបធម៌ និងអរូបធម៌ទាំងនោះ ជាផ្នែកមួយមិនប្រាកដ ។

ចេតនាដែលជាកុសល និងអកុសល ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ លោកហៅថា អភិសង្ខរណកសង្ខារ ។ អាគតដ្ឋាននៃអភិសង្ខរណកសង្ខារនោះ រមែងប្រាកដក្នុងប្រយោគ ( សំយុត្តនិកាយ និទានវគ្គ ) ជាដើមថា ម្នាលភិក្ខុទាំងឡាយ បើបុរសបុគ្គល លុះក្នុងអំណាចអវិជ្ជាហើយ រមែងតាក់តែងសង្ខារជាបុណ្យ ដូច្នេះ ។ ម្យ៉ាងទៀត សេចក្តីព្យាយាមដែលប្រព្រឹត្តទៅផ្លូវកាយ និងចិត្ត លោកហៅថា បយោគាភិសង្ខារ ។ បយោគាភិសង្ខារនោះមកក្នុងប្រយោគ ( អង្គុត្តរនិកាយ តិកនិបាត ) ជាដើមថា កាលចក្រនោះវិលទៅ ក៏ទៅកាន់ទីអស់កំណត់ត្រឹមតែកម្លាំងបង្វិលប៉ុណ្ណោះ ហើយក៏នៅនឹងថ្កល់ ហាក់ដូចជាខ្ចាស់ត្រង់ភ្លៅ ដូច្នេះ ។ ម្យ៉ាងទៀត មិនមែនតែសង្ខារទាំងនោះតែម្យ៉ាងប៉ុណ្ណោះទេ សូម្បីសង្ខារដទៃជាច្រើន ដែលមកដោយសង្ខារ-សព្ទ ដោយន័យ ( មជ្ឈិមនិកាយ មូលបណ្ណាសក ) ជាដើមថា ម្នាលអាវុសោវិសាខៈ ភិក្ខុដែលចូលសញ្ញាវេទយិតនិរោធនោះ វចីសង្ខាររលត់មុនតមក ទើបកាយសង្ខារ ( រលត់ ) តពីនោះមកទៀត ទើបចិត្តសង្ខារ ( រលត់ ) ដូច្នេះ ។ បណ្តាសង្ខារទាំងនោះ សង្ខារដែលមិនសង្គ្រោះចូលក្នុងសង្ខតសង្ខារមិនមាន ។

ខាងមុខអំពីនេះទៅ ពាក្យណា ដែលត្រាស់ក្នុងប្រយោគជាដើមថា **សង្ខារប្បច្ចយា វិញ្ញាណំ** ពាក្យនោះ គប្បីជ្រាបដោយន័យដែលពោល

ហើយនោះឯង ។

ចំណែកពាក្យដែលមិនទាន់បានពោលនោះ គប្បីជ្រាបវិគ្គហៈដូចតទៅ

**វិជានាតីតិ វិញ្ញាណំ** ឈ្មោះថា វិញ្ញាណ ព្រោះអត្ថថា រមែងដឹងច្បាស់ ។ **នមតីតិ នាមំ** ឈ្មោះថា នាម ព្រោះអត្ថថា រមែងបង្អោនទៅ ។ **រុប្បតីតិ រូបំ** ឈ្មោះថា រូប ព្រោះអត្ថថា បែកធ្លាយ ។ **អាយេ តនោតិ អាយតញ្ច នយតីតិ អាយតនំ** ដែលឈ្មោះថា អាយតនៈ ព្រោះអត្ថថា រមែងផ្សាយទៅនូវកាយ គឺនាមរូប ដែលជាប្រភពកើតនៃទុក្ខ និងរមែងនាំទៅកាន់សង្សារដ៏វែងឆ្ងាយ ។ **ផុស្សតីតិ ផស្សោ** ឈ្មោះថា ផស្សៈ ព្រោះអត្ថថា ពាល់ត្រូវ ។ **វេទយតីតិ វេទនា** ឈ្មោះថា វេទនា ព្រោះអត្ថថា សោយអារម្មណ៍ ។ **បរិតស្សតីតិ តណ្ហា** ឈ្មោះថា តណ្ហា ព្រោះអត្ថថា ចង់បាន ។ **ឧបាទិយតីតិ ឧបាទានំ** ឈ្មោះថា ឧបាទាន ព្រោះអត្ថថា ប្រកាន់មាំ ។ **ភវតិ ភាវយតិ ចាតិ ភវោ** ឈ្មោះថា ភព ព្រោះអត្ថថា រមែងកើត និងរមែងឲ្យកើត ។ **ជននំ ជាតិ** ការកើត ឈ្មោះថា ជាតិ ។ **ជិរណំ ជរា** ការចាស់គ្រាំគ្រា ឈ្មោះថា ជរា ។ **មរន្តិ ឯតេនាតិ មរណំ** ឈ្មោះថា មរណៈ ព្រោះថា ជាហេតុស្លាប់របស់សត្វទាំងឡាយ ។ **សោចនំ សោកោ** សេចក្តីក្រៀមក្រំ ឈ្មោះថា សោក ។ **បរិទេវនំ បរិទេវោ** ការយំរៀបរាប់ ឈ្មោះថា បរិទេវៈ ។ **ទុក្ខយតីតិ ទុក្ខំ** ឈ្មោះថា ទុក្ខ ព្រោះអត្ថថា ធ្វើឲ្យលំបាក ម្យ៉ាងទៀត **ឧប្បាទដ្ឋិតិ វសេន ទ្វេធា ខណតីតិ ទុក្ខំ** ឈ្មោះថា ទុក្ខ ព្រោះអត្ថថា ជីកដោយចំណែកពីរយ៉ាង ដោយអំណាចនៃឧប្បាទ និង

ឋិតិ ។ **ទុម្មនស្ស ភាវោ ទោមនស្សំ** ភាវៈនៃចិត្តដែលមានទោសប្រទូស្ត ហើយ ឈ្មោះថា ទោមនស្ស ។ **កុសោ អាយាសោ ឧបាយាសោ** ការតានតឹងចិត្តយ៉ាងខ្លាំង ឈ្មោះថា ឧបាយាស ។

បទថា **សម្ភវន្តិ** បានដល់ រមែងកើត បណ្ឌិតគប្បីធ្វើនូវការប្រកប **សម្ភវន្តិ** សព្ទ ដោយពាក្យ មានសោកជាដើមតែម្យ៉ាងប៉ុណ្ណោះ ក៏មិនមែនដោយពិត គួរធ្វើការប្រកបដោយបទទាំងអស់ ព្រោះថា កាលពោលថា **អវិជ្ជាបច្ចយា សង្ខារា** ក្រៅអំពី **សម្ភវន្តិ** សព្ទនេះ ធម៌ គឺអវិជ្ជា និងសង្ខារ ក៏មិនគប្បីប្រាកដថា រមែងធ្វើនូវកិច្ចណាមួយ តែកាលមានការប្រកបដោយបទថា **សម្ភវន្តិ** សព្ទ ក៏ឈ្មោះថា កំណត់ធម៌ដែលជាបច្ច័យ និងធម៌ដែលកើតឡើងព្រោះបច្ច័យថា អវិជ្ជានេះផង ជាបច្ច័យផង ឈ្មោះថា អវិជ្ជាជាបច្ច័យ សង្ខារទាំងឡាយ កើតព្រោះអវិជ្ជាជាបច្ច័យនោះ ។ ក្នុងពាក្យទាំងអស់ ក៏ន័យនេះដូចគ្នា ។

បទថា **ឯវំ** នេះ ជាបទអធិប្បាយន័យរបស់បដិច្ចសមុប្បាទ ដែលទ្រង់សម្ដែងហើយ ។ ដោយពាក្យនេះ ព្រះមានព្រះភាគ ទ្រង់រមែងសម្ដែងថា ធម៌ដែលជាបច្ចយាការទាំងនោះ រមែងកើតព្រោះហេតុទាំងឡាយ មានអវិជ្ជាជាដើមប៉ុណ្ណោះ មិនមែនកើតឡើងដោយហេតុ មានព្រះឥស្សរនិម្មិតជាដើមឡើយ ។ បទថា **ឯតស្ស** បានដល់ តាមដែលពោលហើយ ។ បទថា **កេវលស្ស** បានដល់ ដែលមិនលាយឡំគ្នា ឬប្រែថា ទាំងអស់ ។ បទថា **ទុក្ខក្ខន្ធស្ស** បានដល់ ប្រជុំនៃទុក្ខ មិនមែនប្រជុំនៃសត្វ មិនមែនប្រជុំនៃ

វិបល្លាស មានសុខ និងស្អាតជាដើមនោះឡើយ ។

បទថា **សមុទយោ** បានដល់ ការកើត ។ បទថា **ហោតិ** បានដល់ រមែងកើត គប្បីជ្រាបវិនិច្ឆ័យដោយអត្ថក្នុងបដិច្ចសមុប្បាទនេះ ដោយប្រការដូច្នេះ ។

ពាក្យថា ដោយលក្ខណៈជាដើម បានដល់ ដោយធម៌ ៤ មានលក្ខណៈជាដើមនៃបដិច្ចសមុប្បាទ មានអវិជ្ជាជាដើម សួរថា តើលក្ខណៈជាដើមនោះដូចម្ដេច គឺ

**អញ្ញាណលក្ខណា** អវិជ្ជា មានការមិនដឹងជាលក្ខណៈ **សម្មោហន-រសា** មានការវង្វេងជាកិច្ច **ឆាទនបច្ចុប្បដ្ឋានា** មានការបិទបាំងសភាវៈនៃអារម្មណ៍ជាអាការប្រាកដ **អាសវបទដ្ឋានា** មានអាសវៈជាហេតុជិត ។

**អភិសង្ខរណលក្ខណា** សង្ខារ មានការតាក់តែងជាលក្ខណៈ **អាយូ-ហនរសា** មានការខ្វល់ខ្វាយជាកិច្ច **ចេតនាបច្ចុប្បដ្ឋានា** មានចេតនាជាអាការប្រាកដ **អវិជ្ជាបទដ្ឋានា** មានអវិជ្ជាជាហេតុជិត ។

**វិជានលក្ខណំ** វិញ្ញាណ មានការដឹងអារម្មណ៍ជាលក្ខណៈ **បុព្វង្គម-រសំ** មានភាពជាប្រធានជាកិច្ច **បដិសន្ធិបច្ចុប្បដ្ឋានំ** មានការកើតបន្តជាអាការប្រាកដ **សង្ខារបទដ្ឋានំ** មានសង្ខារជាហេតុជិត ឬ **វត្ថារម្មណ-បទដ្ឋានា** មានវត្ថុ និងអារម្មណ៍ជាហេតុជិត ។

**នមនលក្ខណំ** នាមមានការបង្អោនទៅជាលក្ខណៈ **សម្បយោគរសំ** មានការប្រកបព្រមគ្នាជាកិច្ច **អវិនិព្ភោគបច្ចុប្បដ្ឋានំ** មានការមិនបែកអំពីចិត្ត

ជាអាការប្រាកដ **វិញ្ញាណបទដ្ឋានំ** មានវិញ្ញាណជាហេតុជិត ។

**រុប្បនលក្ខណំ** រូប មានការបែកធ្លាយជាលក្ខណៈ **វិកិរណរសំ** មានការខ្ចាត់ខ្ចាយទៅជាកិច្ច **អព្យាកតបច្ចុប្បដ្ឋានំ** មានភាពជាអព្យាកតជាអាការប្រាកដ **វិញ្ញាណបទដ្ឋានំ** មានវិញ្ញាណជាហេតុជិត ។

**អាយតនលក្ខណំ** សឡាយតនៈ មានការធ្វើវដ្ដៈឲ្យវែងឆ្ងាយជាលក្ខណៈ **ទស្សនាទិរសំ** មានការធ្វើនូវការឃើញជាដើមជាកិច្ច **វត្ថុទ្វារភាវបច្ចុប្បដ្ឋានំ** មានភាពជាវត្ថុ និងជាទ្វារជាអាការប្រាកដ **នាមរូបបទដ្ឋានំ** មាននាមរូបជាហេតុជិត ។

**ផុសនលក្ខណោ** ផស្សៈ មានការប៉ះខ្ទប់អារម្មណ៍ជាលក្ខណៈ **សង្ឃដ្ដនរសោ** មានការផ្សារភ្ជាប់អារម្មណ៍ និងចិត្តជាកិច្ច **សង្គតិបច្ចុប្បដ្ឋានោ** មានការប្រជុំវត្ថុអារម្មណ៍ និងចិត្តជាអាការប្រាកដ **សឡាយតនបទដ្ឋានោ** មានសឡាយតនៈជាហេតុជិត ។

**អនុភវនលក្ខណា** វេទនា មានការសោយអារម្មណ៍ជាលក្ខណៈ **វិសយរសសម្ភោគរសា** មានការបរិភោគរួមគ្នានូវរសនៃអារម្មណ៍ជាកិច្ច **សុខទុក្ខបច្ចុប្បដ្ឋានា** មានសុខ និងទុក្ខជាអាការប្រាកដ **ផស្សបទដ្ឋានា** មានផស្សៈជាហេតុជិត ។

**ហេតុលក្ខណា** តណ្ហា មានភាពជាហេតុជាលក្ខណៈ **អភិនន្ទនរសា** មានការត្រេកអរក្រៃលែងជាកិច្ច **អតិត្តិភាវបច្ចុប្បដ្ឋានា** មានការមិនឆ្អែតក្នុងអារម្មណ៍ជាអាការប្រាកដ **វេទនាបទដ្ឋានា** មានវេទនាជាហេតុជិត ។

**គហណលក្ខណំ** ឧបាទាន មានការប្រកាន់ជាលក្ខណៈ **អមុញ្ចនរសំ** មានការមិនលែងជាកិច្ច **តណ្ហាទឡ្ហត្តទិដ្ឋិបច្ចុប្បដ្ឋានំ** មានការមាំទាំដោយតណ្ហា និងទិដ្ឋិក្នុងអត្តាជាអាការប្រាកដ **តណ្ហាបទដ្ឋានំ** មានតណ្ហាជាហេតុជិត ។

**កម្មកម្មផលលក្ខណោ** ភព មានកម្ម និងផលនៃកម្មជាលក្ខណៈ **ភាវនភវនរសោ** មានការធ្វើឲ្យកើតឡើង និងការកើតឡើងជាកិច្ច **កុសលា-កុសលាព្យាកតបច្ចុប្បដ្ឋានោ** មានភាពជាកុសល អកុសល និងអព្យាកតជាអាការប្រាកដ **ឧបាទានបទដ្ឋានោ** មានឧបាទានជាហេតុជិត ។

ធម៌ មានលក្ខណៈជាដើមនៃបដិច្ចសមុប្បាទ មានជាតិជាដើម គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងសច្ចវិភង្គនោះឯង ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបដិច្ចសមុប្បាទនេះ ដោយលក្ខណៈជាដើម ដោយប្រការដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា ដោយធម៌ដែលមានតែមួយជាដើមនេះ ដូចតទៅ អវិជ្ជា គប្បីជ្រាបថា មានតែមួយ ព្រោះជាអញ្ញាណ គឺមិនដឹង អទស្សនៈ គឺមិនឃើញ និងមោហៈ គឺវង្វេងជាដើម ។ មាន ២ យ៉ាង ដោយការមិនបដិបត្តិ និងបដិបត្តិខុស ម្យ៉ាងទៀត មាន ២ យ៉ាង គឺជាសង្ខារ និងអសង្ខារ ។ មាន ៣ យ៉ាង គឺសម្បយុត្តដោយវេទនា ៣ ។ មាន ៤ យ៉ាង ព្រោះមិនចាក់ធ្លុះសច្ចៈ ៤ ។ មាន ៥ យ៉ាង ព្រោះបិទបាំងដោយទោសនៃគតិ ៥[១] ។ ម្យ៉ាងទៀត ពោលដោយទ្វារ និងអារម្មណ៍ ក្នុងអរូបធម៌ទាំងអស់

---

១- គឺផ្លូវទៅកើតជាសត្វនរក ១ សត្វតិរច្ឆាន ១ បិត្តិវិស័យ ១ មនុស្ស ១ ទេវតា ១ ។

អវិជ្ជា មាន ៦ យ៉ាង ។

សង្ខារ គប្បីជាបថា មាន ១ ព្រោះជាសាសវវិបាកធម្មធម្មៈជាដើម មាន ២ គឺជាកុសល ១ អកុសល ១ ។ ម្យ៉ាងទៀត មាន ២ យ៉ាង គឺជា បរិត្ត និងមហគ្គតធម៌ ហីនៈ និងមជ្ឈិមធម៌ និងដោយជាមិច្ឆត្តនិយតធម៌ និងមិច្ឆត្តអនិយតធម៌ ។ មាន ៣ យ៉ាង ព្រោះជាបុញ្ញាភិសង្ខារជាដើម ។ មាន ៤ យ៉ាង ព្រោះប្រព្រឹត្តទៅក្នុងកំណើត ៤ ។ មាន ៥ យ៉ាង ព្រោះជាផ្លូវឲ្យដល់នូវគតិ ៥ ។

វិញ្ញាណ ឈ្មោះថា មាន ១ ព្រោះជាលោកិយវិបាកជាដើម ។ មាន ២ ព្រោះសហេតុកៈ ១ អហេតុកៈ ១ ។ មាន ៣ ព្រោះទាក់ទងដោយភព ៣ និងព្រោះប្រកបដោយវេទនា ៣ និងព្រោះជាអហេតុកៈ ១ ទុហេតុកៈ ១ តិហេតុកៈ ១ ។ មាន ៤ ដោយអំណាចកំណើត ៤ ។ និងមាន ៥ ដោយអំណាចគតិ ៥ ។

នាមរូប គប្បីជ្រាបថា មាន ១ ព្រោះអាស្រ័យវិញ្ញាណ និងដោយមានកម្មជាបច្ច័យ ។ មាន ២ ព្រោះជាសារម្មណៈ និងអនារម្មណៈ ។ មាន ៣ ព្រោះជាអតីតជាដើម ។ មាន ៤ ដោយអំណាចកំណើត ៤ ។ និងមាន ៥ ដោយអំណាចគតិ ៥ ។

សឡាយតនៈ ឈ្មោះថា មាន ១ ព្រោះទីកើត និងជាទីប្រជុំ ។ មាន ២ ព្រោះជាភូតប្បសាទរូប វិញ្ញាណជាដើម ( ទ្វិបញ្ចវិញ្ញាណ ) ។ មាន ៣ យ៉ាង ព្រោះជាអារម្មណ៍ដែលជាសម្បត្តៈ និងអសម្បត្តៈ និងមិនមែនទាំងពីរ ។ មាន ៤ យ៉ាង ព្រោះរាប់បញ្ចូលក្នុងកំណើត ៤ មាន ៥ ដោយរាប់

*បញ្ចូលក្នុងគតិ ៥ ។ បណ្ឌិតគប្បីជ្រាបធម៌ មានផស្សៈជាដើមថា ជាធម៌មាន ១ ជាដើមដោយន័យនេះ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបដិច្ចសមុប្បាទនេះ ដោយជាធម៌មាន ១ ជាដើម ដោយប្រការដូច្នេះ ។*

*ពាក្យថា ដោយការកំណត់អង្គទាំងឡាយ សេចក្តីថា ក្នុងបដិច្ចសមុប្បាទនេះ សេចក្តីសោកជាដើម ព្រះមានព្រះភាគត្រាស់ដើម្បីសម្តែងការមិនដាច់របស់ភវចក្រ ព្រោះថា សេចក្តីសោកជាដើមនោះ រមែងកើតដល់បុគ្គលពាលល្ងង់ខ្លៅ ដែលត្រូវជរា និងមរណៈបៀតបៀនហើយ ដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ សឡាយតនវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង កាលបើទុក្ខវេទនាប្រព្រឹត្តទៅក្នុងសរីរៈពាល់ត្រូវ ទើបសោយសោក លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេងវង្វាន់ ដូច្នេះជាដើម ។*

*ម្យ៉ាងទៀត អវិជ្ជា នៅប្រព្រឹត្តទៅដរាបដែលសេចក្តីសោកជាដើមនោះ នៅប្រព្រឹត្តទៅ ព្រោះហេតុនោះ ទើបភវចក្រ មានការទាក់ទងគ្នាទៀតថា* **អវិជ្ជាបច្ចយា សង្ខារា** *ដូច្នេះ ព្រោះហេតុនោះ គប្បីជ្រាបអង្គនៃបដិច្ចសមុប្បាទមាន ១២ ប៉ុណ្ណោះ ព្រោះប្រមូលមកនូវសេចក្តីសោកជាដើមទាំងនោះ ចូលជាមួយជរាមរណៈនោះឯង ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបដិច្ចសមុប្បាទនេះ ដោយកំណត់អង្គទាំងឡាយ ដោយប្រការដូច្នេះ ។ នេះជាសេចក្តីសង្ខេបក្នុងបដិច្ចសមុប្បាទនេះ ដោយអំណាចឧទ្ទេសវារ ។៚*

## *អធិប្បាយឧទ្ទេសវារ ចប់*

# អវិជ្ជានិទ្ទេស

[ ២ ] ឥឡូវនេះ ជាកថាពោលដោយពិស្តារ ដោយអំណាចនៃនិទ្ទេសវារ ។ ពិតហើយ ព្រះមានព្រះភាគត្រាស់ថា **អវិជ្ជាបច្ចយា សង្ខារា** ដូច្នេះ ។ ក្នុងព្រះបាលីនោះ កាលទ្រង់សម្តែងសង្ខារទាំងឡាយ ដែលមានអវិជ្ជាជាបច្ច័យ ព្រោះបុគ្គលកាលនឹងពោលដល់បុត្រ ក៏រមែងពោលដល់បិតាមុន ដ្បិតថា កាលបើដូច្នេះ ទើបហៅបុត្របាន ក៏ត្រូវហៅថា កូនរបស់មិត្ត: កូនរបស់ទត្ត: ហេតុនោះ ព្រះសាស្តាទ្រង់ជាបុគ្គលឈ្លាសក្នុងទេសនា ដើម្បីសម្តែងអវិជ្ជាដូចបិតា ដោយអត្ថថា ញុំាំងសង្ខារទាំងឡាយឲ្យកើត ទើបត្រាស់ពាក្យជាដើមថា **តត្ថ កតមា អវិជ្ជា ទុក្ខេ អញ្ញាណំ** ជាដើម ។

ក្នុងព្រះបាលីនោះ ព្រោះអវិជ្ជានេះ រមែងមិនឲ្យដឹង មិនឲ្យឃើញ មិនឲ្យចាក់ធ្លុះនូវលក្ខណ: មួយអន្លើដោយកិច្ច តាមសេចក្តីពិតរបស់ទុក្ខសច្ច គឺបិទបាំង រឹតរុំ ប្រកាន់ ព្រោះហេតុនោះ ទើបត្រាស់ថា **ទុក្ខេ អញ្ញាណំ** មិនដឹងក្នុងទុក្ខ ដូច្នេះ ។ ម្យ៉ាងទៀត ព្រោះអវិជ្ជា រមែងមិនឲ្យដឹង មិនឲ្យឃើញ មិនឲ្យចាក់ធ្លុះនូវលក្ខណ: ព្រមទាំងកិច្ច តាមសេចក្តីពិតនៃទុក្ខសមុទយ: នៃទុក្ខនិរោធ នៃទុក្ខនិរោធគាមិនីបដិបទា គឺបិទបាំង រឹតរុំ ប្រកាន់ ហេតុនោះ ទើបត្រាស់ថា **ទុក្ខនិរោធគាមិនិយា បដិបទាយ អញ្ញាណំ** ការមិនដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរម្ងត់ទុក្ខ ដូច្នេះ ។ ការមិនដឹង ទ្រង់ត្រាស់ថា អវិជ្ជា ក្នុងឋាន:ទាំង ៤ នេះ ដោយបរិយាយនៃព្រះសូត្រ ។

តែដោយបរិយាយនៃព្រះអភិធម្មក្នុងនិក្ខេបកណ្ឌ ទ្រង់កាន់យកអញ្ញាណក្នុងឋាន: ៤ ដទៃទៀតថា **បុព្វន្តេ អញ្ញាណំ** គឺការមិនដឹងក្នុងអតីតជាដើម ។

*ក្នុងព្រះបាលីនោះ បទថា* **បុព្វន្តេ** *បានដល់ អតីតអទ្ធា គឺខន្ធ ធាតុ អាយតនៈទាំងឡាយដែលកន្លងហើយ ។ បទថា* **អបរន្តេ** *បានដល់ អនាគតអទ្ធា គឺខន្ធ ធាតុ អាយតនៈទាំងឡាយដែលមិនទាន់មកដល់ ។ បទថា* **បុព្វន្តាបរន្តេ** *បានដល់ កាលទាំងពីរនៃខន្ធ ធាតុ អាយតនៈដែលកន្លងហើយ និងមិនទាន់មកដល់នោះ ។ បទថា* **ឥទប្បច្ចយាតា** *បានដល់ អង្គទាំងឡាយ មានអវិជ្ជាជាដើម ដែលជាហេតុនៃធម៌ទាំងឡាយ មានសង្ខារជាដើម ។ បទថា* **បដិច្ចសមុប្បន្នធម្មា** *បានដល់ ធម៌ទាំងឡាយ មានសង្ខារជាដើម ដែលកើតឡើងអំពីធម៌ទាំងឡាយ មានអវិជ្ជាជាដើម ។*

*ក្នុងធម៌ទាំងនោះ ព្រោះអវិជ្ជានេះ រមែងមិនឲ្យដឹង មិនឲ្យឃើញ មិនឲ្យចាក់ធ្លុះនូវលក្ខណៈ ព្រមទាំងកិច្ច តាមសេចក្តីពិតនៃខន្ធជាដើមដែលជាអតីត គឺបិទបាំង រឹតរុំ ប្រកាន់ ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា* **បុព្វន្តេ អញ្ញាណំ** *ដូច្នេះ ។ម្យ៉ាងទៀត ព្រោះអវិជ្ជានេះ រមែងមិនឲ្យដឹង មិនឲ្យឃើញ មិនឲ្យចាក់ធ្លុះនូវលក្ខណៈ ព្រមទាំងកិច្ច តាមសេចក្តីពិតនៃខន្ធជាដើមដែលជាអនាគត ។បេ។ នៃខន្ធជាដើម ដែលជាអតីតផង អនាគតផង ។បេ។ រមែងមិនឲ្យដឹង ឃើញ ចាក់ធ្លុះនូវលក្ខណៈ ព្រមទាំងកិច្ច តាមសេចក្តីពិតនៃភាពដែលធម៌នេះជាបច្ច័យ និងធម៌ដែលអាស្រ័យគ្នានិងគ្នាកើតឡើង គឺបិទបាំង រឹតរុំ ប្រកាន់ ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា* **ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ** *សេចក្តីមិនដឹងក្នុងធម៌ទាំងឡាយ ដែលកើតឡើងព្រោះអាស្រ័យធម៌នេះជាបច្ច័យ ដូច្នេះ ។ ត្រាស់*

ភាពដែលមិនដឹងដោយបរិយាយនៃព្រះអភិធម្ម ក្នុងឋានៈទាំង ៨ នេះថា ជាអវិជ្ជា ។

សួរថា ដោយលក្ខណៈយ៉ាងនេះ ទ្រង់ត្រាស់ដល់អ្វី ឆ្លើយថា ឈ្មោះថា ទ្រង់ត្រាស់អវិជ្ជាដោយកិច្ច និងដោយជាតិ សួរថា ត្រាស់ដូចម្ដេច ឆ្លើយថា អវិជ្ជានេះ រមែងមិនឲ្យដឹង ឃើញ ចាក់ធ្លុះនូវឋានៈទាំង ៨ នេះ ព្រោះហេតុនោះ ទើបត្រាស់ដោយកិច្ច អវិជ្ជានេះ កាលកើត រមែងកើតក្នុងឋានៈទាំង ៨ នេះ ព្រោះហេតុនោះ ទើបត្រាស់ដោយជាតិ ។ កាលត្រាស់យ៉ាងនេះហើយ ទ្រង់កាន់យក ២៥ បទ មានជាដើមថា **យំ ឯវរូបំ អញ្ញាណំ អទស្សនំ** សេចក្ដីថា ការមិនដឹងច្បាស់ ការមិនឃើញណា ដែលមានសភាពបែបនេះដូច្នេះទៀត ដើម្បីសម្ដែងលក្ខណៈអវិជ្ជាតទៅ ។

ក្នុងពាក្យនោះ ព្រោះអវិជ្ជានេះ សូម្បីត្រាស់ហើយដោយបទទាំង ៨ នេះ កាលមិនទាន់ត្រាស់ដល់លក្ខណៈ ២៥ បទទៀត ឈ្មោះថា ជាការត្រាស់ល្អហើយមិនទាន់បាន តែកាលត្រាស់ដល់លក្ខណៈ ២៥ បទហើយ ឈ្មោះថា ត្រាស់ល្អហើយ ដូចបុរសកាលកំពុងស្វែងរកគោដែលបាត់ទៅ គប្បីសួរពួកមនុស្សថា នែអ្នក អ្នកឃើញគោ-ស អ្នកឃើញគោក្រហមដែរឬទេ ពួកមនុស្សទាំងនោះ ក៏គប្បីពោលយ៉ាងនេះថា ក្នុងដែននេះមានគោ-ស គោក្រហមច្រើនរាប់មិនអស់ គោរបស់អ្នកមានលក្ខណៈដូចម្ដេច គ្រានោះ កាលបុរសនោះពោលថា គោរបស់ខ្ញុំ មានរូបសញ្ញាដី មានរូបនង្គ័ល ដូច្នេះ ទើបគោ ឈ្មោះថា គេប្រាប់ល្អហើយយ៉ាងណា អវិជ្ជានេះក៏យ៉ាងនោះដូចគ្នា

សូម្បីត្រាស់ទាំង ៨ បទ មិនទាន់ត្រាស់ដល់លក្ខណៈ ២៥ បទ ឈ្មោះថា មិនទាន់ត្រាស់ល្អឡើយ តែកាលត្រាស់ដល់លក្ខណៈហើយនោះឯង ទើបឈ្មោះថា ត្រាស់ល្អហើយ ព្រោះហេតុនោះ ដើម្បីសម្តែងលក្ខណៈនៃអវិជ្ជានោះ គប្បីជ្រាបដោយអំណាចបទ ២៥ បទ ដែលព្រះមានព្រះភាគត្រាស់ហើយទាំងនោះ សេចក្តីនេះដូចម្តេច ឆ្លើយថា បញ្ញា ឈ្មោះថា **ញាណ** បញ្ញានោះ រមែងធ្វើសច្ចធម៌ ៤ ដែលជាផល និងជាផល ដែលជាហេតុ និងជាហេតុ ឲ្យជាក់ច្បាស់ ឲ្យប្រាកដ តែអវិជ្ជានេះ កើតឡើងហើយ រមែងមិនឲ្យធ្វើសច្ចធម៌ ៤ នោះ ឲ្យជាក់ច្បាស់ ព្រោះហេតុនោះ ទើបឈ្មោះថា **អញ្ញាណ** ព្រោះជាសត្រូវចំពោះញាណ ។

បញ្ញា ឈ្មោះថា **ទស្សន** ក៏មាន បញ្ញានោះ រមែងឃើញនូវអាការនៃសច្ចធម៌ ៤ តាមដែលពោលនោះ តែអវិជ្ជាកើតឡើងហើយ រមែងមិនឲ្យឃើញសច្ចធម៌ ៤ នោះ ព្រោះហេតុនោះ ទើបឈ្មោះថា **អទស្សន** ។

បញ្ញា ឈ្មោះថា **អភិសមយ** គឺការត្រាស់ដឹងក៏មាន បញ្ញានោះ រមែងត្រាស់ដឹងនូវអាការនៃសច្ចធម៌ ៤ តាមដែលពោលនោះ តែអវិជ្ជាកើតឡើងហើយ រមែងមិនឲ្យត្រាស់ដឹងសច្ចធម៌ ៤ នោះ ព្រោះហេតុនោះ ទើបឈ្មោះថា **អនភិសមយ** ។

បញ្ញា ឈ្មោះថា **អនុពោធ** គឺការត្រាស់ដឹងតាម **សម្ពោធ** គឺការដឹងតាមសេចក្តីពិត **បដិវេធ** គឺការចាក់ធ្លុះក៏មាន បញ្ញានោះ រមែងដឹងដោយសមគួរ រមែងដឹងតាមសេចក្តីពិត រមែងចាក់ធ្លុះអាការនៃសច្ចធម៌ ៤ តាមដែលពោលហើយនោះ តែអវិជ្ជាកើតឡើងហើយ រមែងមិនឲ្យត្រាស់ដឹង

ដោយសមគួរ ដើម្បីដឹងតាមសេចក្តីពិត ដើម្បីចាក់ធ្លុះនូវសច្ចធម៌ ៤ នោះ ព្រោះហេតុនោះ ទើបឈ្មោះថា **អននុពោធ អសម្ពោធ អបដិវេធ ។**

បញ្ញា ឈ្មោះថា **សង្គាហណា** គឺការកាន់យកត្រូវក៏មាន បញ្ញានោះកាន់យកហើយ ចាក់ធ្លុះហើយ រមែងកាន់យកអាការនោះ តែអវិជ្ជាកើតឡើងហើយ រមែងមិនឲ្យកាន់យក សាកល្បងហើយ កាន់យកអាការនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **អសង្គាហណា ។**

បញ្ញា ឈ្មោះថា **បរិយោគាហណា** គឺការឈមចុះដោយជុំវិញក៏មាន បញ្ញានោះ ឈមចុះហើយ ជ្រែកហើយនូវអាការនោះ រមែងកាន់យក តែអវិជ្ជាកើតឡើងហើយ មិនឲ្យឈមចុះ ជ្រែកហើយកាន់យក ព្រោះហេតុនោះ ទើបឈ្មោះថា **អបរិយោគាហណា ។**

បញ្ញា ឈ្មោះថា **សមបេក្ខណា** គឺការសម្លឹងពិនិត្យក៏មាន បញ្ញានោះ រមែងសម្លឹងអាការនោះដោយស្មើ និងដោយប្រពៃ តែអវិជ្ជាកើតឡើងហើយ រមែងមិនឲ្យសម្លឹងពិនិត្យអាការនោះដោយស្មើ និងដោយប្រពៃ ព្រោះហេតុនោះ ទើបឈ្មោះថា **អសមបេក្ខណា ។**

បញ្ញា ឈ្មោះថា **បច្ចវេក្ខណា** គឺការពិចារណាក៏មាន បញ្ញានោះរមែងពិចារណាអាការនោះ តែអវិជ្ជាកើតឡើងហើយ រមែងមិនឲ្យពិចារណាអាការនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **អបច្ចវេក្ខណា ។**

កម្មឯណាមួយដែលប្រចក្ស រមែងមិនមានដល់អវិជ្ជានេះ ហើយកម្មដែលខ្លួនឯង គឺអវិជ្ជាមិនពិចារណាហើយធ្វើមាន ព្រោះហេតុនោះ ទើបអវិជ្ជានេះ

*ឈ្មោះថា* **អបច្ចវេក្ខណា** *គឺការមិនធ្វើឲ្យប្រចក្ស ។ អវិជ្ជានេះ ឈ្មោះថា* **ទុម្មេជ្ឈ** *គឺការមានបញ្ញាថោកថយ ព្រោះភាពជាអ្នកមានបញ្ញាអាក្រក់ ។ អវិជ្ជានេះ ឈ្មោះថា* **ពាល្យ** *គឺការល្ងង់ខ្លៅ ព្រោះជាធម្មជាតល្ងង់ខ្លៅ ។*

*បញ្ញា ឈ្មោះថា* **សម្បជញ្ញ** *ក៏មាន បញ្ញានោះ រមែងដឹងនូវទៅដោយប្រពៃនូវសច្ចធម៌ ៤ ដែលជាផល និងជាផល ដែលជាហេតុ និងជាហេតុ តែអវិជ្ជាកើតឡើងហើយ រមែងមិនឲ្យដឹងនូវទៅនូវអាការនោះ ព្រោះហេតុនោះ ទើបអវិជ្ជា ឈ្មោះថា* **អសម្បជញ្ញ** ។

*អវិជ្ជា ឈ្មោះថា* **មោហ** *ដោយអំណាចនៃសេចក្តីល្ងង់ ។ អវិជ្ជា ឈ្មោះថា* **បមោហ** *ដោយអំណាចការវង្វេងទូទៅ ។ អវិជ្ជា ឈ្មោះថា* **សម្មោហ** *ដោយអំណាចនៃការវង្វេងព្រម ។ អវិជ្ជា ឈ្មោះថា* **អវិជ្ជា** *ដោយអំណាចអត្ថ មានជាដើមថា ជួបនូវវត្ថុដែលមិនគួរជួប ។ អវិជ្ជា ឈ្មោះថា* **អវិជ្ជោឃ** *ព្រោះរមែងនាំចុះ គឺឲ្យលិចចុះក្នុងវដ្ដៈ ។ អវិជ្ជា ឈ្មោះថា* **អវិជ្ជាយោគ** *ព្រោះអត្ថថា ប្រកបក្នុងវដ្ដៈ ។ អវិជ្ជា ឈ្មោះថា* **អវិជ្ជានុសយ** *ដោយអំណាចការលះមិនទាន់បាន និងព្រោះកើតឡើងរឿយៗ ។ អវិជ្ជា ឈ្មោះថា* **អវិជ្ជាបរិយុដ្ឋាន** *ព្រោះរឹតរុំ រមែងចាប់ រមែងប្លន់កុសលចិត្ត ដូចពួកចោរស្កាត់ត្រង់ផ្លូវ ប្លន់អ្នកនិគមដែលដើរមក ដូច្នោះ ។ អវិជ្ជា ឈ្មោះថា* **អវិជ្ជាលង្គី** *ព្រោះអត្ថថា កាលគេខ្ទាស់គន្លឹះត្រង់ទ្វារនគរហើយ ការចេញទៅមិនបានរបស់មនុស្សខាងក្នុងនគរក្តី ការចូលទៅខាងក្នុងនគររបស់ពួកមនុស្សខាងក្រៅនគរក្តី រមែងកាត់ផ្តាច់ យ៉ាងណា អវិជ្ជានេះ ធ្លាក់ទៅក្នុង*

នគរកាយរបស់បុគ្គលណា រមែងកាត់នូវការសញ្ចរទៅ គឺបញ្ញាដែលឲ្យដល់នូវព្រះនិព្វានរបស់បុគ្គលនោះ រមែងកាត់ផ្តាច់ យ៉ាងនោះ ។

អវិជ្ជា ឈ្មោះថា **អកុសលមូល** ព្រោះអត្ថថា អកុសលនោះផង ជាមូលផង ឬព្រោះអត្ថថា អវិជ្ជាជាមូលនៃអកុសលទាំងឡាយ អកុសលមូលនោះ មិនមែនដទៃ ។ ក្នុងទីនេះ ទ្រង់បំណងយកមោហៈ ព្រោះហេតុនោះទើបឈ្មោះថា **អកុសលមូល** គឺមោហៈ ។ បទថា **អយំ វុច្ចតិ អវិជ្ជា** សេចក្តីថា នេះហៅថា អវិជ្ជាមានលក្ខណៈយ៉ាងនេះ ។ គប្បីជ្រាបលក្ខណៈអវិជ្ជា ដោយអំណាចបទ ២៥[១] ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត អវិជ្ជានេះ មានលក្ខណៈយ៉ាងនេះ សូម្បីត្រាស់ថា ការមិនដឹងក្នុងទុក្ខជាដើម ក៏រមែងជាចំណែកមួយនៃទុក្ខសច្ច ជាធម៌កើតព្រមគ្នា រមែងធ្វើទុក្ខសច្ចនោះឲ្យជាអារម្មណ៍ រមែងបិទបាំងទុក្ខសច្ចនោះ មិនមែនជាចំណែកមួយរបស់សមុទយសច្ច ជាធម៌កើតព្រមគ្នា រមែងធ្វើសមុទយសច្ចនោះឲ្យជាអារម្មណ៍ រមែងបិទបាំងសមុទយសច្ចនោះ ។ មិនជាចំណែកមួយរបស់និរោធសច្ច មិនកើតព្រមគ្នា មិនធ្វើនិរោធសច្ចនោះឲ្យជាអារម្មណ៍ រមែងបិទបាំងតែម្យ៉ាង ។ មិនជាចំណែកមួយនៃមគ្គសច្ច មិនកើតព្រមគ្នា មិនធ្វើមគ្គសច្ចនោះឲ្យជាអារម្មណ៍ រមែងបិទបាំងតែម្យ៉ាង ។

អវិជ្ជារមែងកើតឡើង ព្រោះភាពមានទុក្ខជាអារម្មណ៍ និងរមែងបិទបាំង

---

១- ២៥ បទនេះ ឃើញតែ ២៤ ឯក្នុងបិដកខ្មែរលេខ ៧៨ ទំព័រ ៣០០ ក៏ឃើញតែ ២៤ បទដូចគ្នា ។

ទុក្ខដែលជាអារម្មណ៍នោះ ។ អវិជ្ជារមែងកើតឡើង ព្រោះការមានសមុទយៈជាអារម្មណ៍ និងរមែងបិទបាំងសមុទយៈដែលជាអារម្មណ៍នោះ ។ អវិជ្ជារមែងមិនកើតឡើង ព្រោះការមាននិរោធជាអារម្មណ៍ តែរមែងបិទបាំងនិរោធនោះ អវិជ្ជារមែងមិនកើតឡើង ព្រោះមានមគ្គជាអារម្មណ៍ តែរមែងបិទបាំងមគ្គនោះ ។

សច្ចៈ ២ ឈ្មោះថា ជ្រាលជ្រៅ ព្រោះឃើញបានដោយក្រ សច្ចៈ ២ ឈ្មោះថា ឃើញបានដោយក្រ ព្រោះជារបស់ជ្រាលជ្រៅ ។ ម្យ៉ាងទៀត អរិយសច្ច គឺទុក្ខនិរោធ ជាសភាវៈជ្រាលជ្រៅ និងឃើញបានដោយក្រ ។ បណ្តាសច្ចៈទាំងនោះ ឈ្មោះថា ទុក្ខ ព្រោះជាសភាវៈប្រាកដច្បាស់ តែដែលឈ្មោះថា ជ្រាលជ្រៅ ព្រោះមានលក្ខណៈឃើញបានដោយក្រ ។ ក្នុងសមុទយៈ ក៏មានន័យដូចគ្នា ។ ឧបមាថា ធម្មតាការគូរសមុទ្រ ហើយនាំយកឱជៈចេញមកជារឿងលំបាក ឬធម្មតាការជញ្ជូនខ្សាច់ចេញអំពីជើងភ្នំសិនេរុ ក៏ជារឿងលំបាក ឬធម្មតាការប្រេបាច់ភ្នំនាំយកសេចេញមក ក៏ជារឿងលំបាក យ៉ាងណា សច្ចៈទាំង ២ ក៏យ៉ាងនោះដូចគ្នា ឈ្មោះថា ឃើញបានដោយក្រ ព្រោះជាភាវៈជ្រាលជ្រៅដោយពិត ។ តែនិរោធសច្ច ជ្រាលជ្រៅក្រៃលែងផង ឃើញបានដោយក្រក្រៃលែងផង ព្រោះហេតុនោះ ផងឹត គឺមោហៈដែលបិទបាំងអរិយសច្ច ៤ ដែលឈ្មោះថា ជ្រាលជ្រៅ ព្រោះឃើញបានដោយក្រ និងដែលឈ្មោះថា ឃើញបានដោយក្រ ព្រោះជ្រាលជ្រៅដោយប្រការដូច្នេះ ទើបហៅថា **អវិជ្ជា** ៕៚

**អវិជ្ជានិទ្ទេស ចប់**

# សង្ខារនិទ្ទេស

[ ៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបទនៃសង្ខារដូចតទៅ

ព្រះមានព្រះភាគ កាលទ្រង់សម្តែងចំពោះសង្ខារ ដែលមានអវិជ្ជាជាបច្ច័យប៉ុណ្ណោះ ទ្រង់មិនអាស្រ័យសង្ខារដែលមកដោយសង្ខារសព្ទ ក្នុងសង្ខារតាមដែលត្រាស់ខាងដើម ទើបត្រាស់ពាក្យថា **តត្ថ កតមេ អវិជ្ជាបច្ចយា សង្ខារា បុញ្ញាភិសង្ខារោ** ដូច្នេះជាដើម ។

ក្នុងព្រះបាលីនោះ សភាវៈដែលឈ្មោះថា **បុញ្ញ** ព្រោះអត្ថថា ជម្រះបុគ្គលអ្នកធ្វើ គឺញុំាងអធ្យាស្រ័យរបស់អ្នកធ្វើនោះឲ្យបរិបូណ៌ និងញុំាងភពដែលគួរបូជាឲ្យកើតឡើង ។

ដែលឈ្មោះថា **អភិសង្ខារ** ព្រោះអត្ថថា រមែងតាក់តែងវិបាក និងកដត្តារូប ។ អភិសង្ខារ គឺបុណ្យ ឈ្មោះថា **បុញ្ញាភិសង្ខារ** ។ សភាវៈដែលឈ្មោះថា **អបុញ្ញ** ព្រោះជាបដិបក្ខចំពោះបុញ្ញៈ ។ អភិសង្ខារ គឺអបុញ្ញៈ ឈ្មោះថា **អបុញ្ញាភិសង្ខារ** ។ ដែលឈ្មោះថា **អានេញ្ជ** ព្រោះអត្ថថា រមែងមិនញាប់ញ័រ ។ ដែលឈ្មោះថា **អានេញ្ជាភិសង្ខារ** ព្រោះអត្ថថា អភិសង្ខារ គឺអានេញ្ជៈ និងសភាវៈដែលតាក់តែងភព ដែលមិនញាប់ញ័រ ។ ដែលឈ្មោះថា **កាយសង្ខារ** ព្រោះអត្ថថា ជាសង្ខារដែលកាយឲ្យប្រព្រឹត្តទៅ ឬប្រព្រឹត្តទៅផ្លូវកាយ ឬប្រព្រឹត្តទៅដល់កាយ ក្នុងវចីសង្ខារ និងចិត្តសង្ខារ ក៏ន័យនេះដូចគ្នា ។

ក្នុងសង្ខារទាំងនោះ សង្ខារ ៣ ដំបូង ទ្រង់កាន់យកដោយអំណាចនៃបរិវីមំសនសូត្រ ។ ពិតហើយ ក្នុងសូត្រនោះ ព្រះមានព្រះភាគត្រាស់

( សំយុត្តនិកាយ និទានវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ បើបុរសបុគ្គលលុះក្នុងអំណាចអវិជ្ជាហើយ រមែងតាក់តែងសង្ខារជាបុណ្យ វិញ្ញាណក៏ចូលទៅកៀកនឹងបុណ្យ បើតាក់តែងសង្ខារជាបាប វិញ្ញាណក៏ចូលទៅកៀកនឹងបាប បើតាក់តែងសង្ខារជាអនេជៈ វិញ្ញាណក៏ចូលទៅកៀកនឹងអនេជៈ ដូច្នេះ ។ សង្ខារ ៣ ពួកទី ២ ទ្រង់កាន់យកដោយអំណាចនៃវិភង្គសូត្រ ដែលជាលំដាប់នៃបរិវីមំសនសូត្រនោះ ។ សូម្បីពោលថា ទ្រង់កាន់យកដោយបរិយាយនៃសម្មាទិដ្ឋិសូត្រដូច្នេះ ក៏គួរដូចគ្នា ព្រោះក្នុងវិភង្គសូត្រនោះ ( សំយុត្តនិកាយ និទានវគ្គ ) ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សង្ខារនេះមាន ៣ ។ សង្ខារ ៣ ដូចម្ដេច ។ គឺកាយសង្ខារ ១ វចីសង្ខារ ១ ចិត្តសង្ខារ ១ ដូច្នេះ ។

សួរថា ព្រោះហេតុអ្វី ទើបទ្រង់កាន់យកសង្ខារទាំងនោះ ដោយអំណាចសូត្រទាំងនោះទៅវិញ ឆ្លើយថា ដើម្បីសម្ដែងបទនេះថា ធម្មតាអភិធម្មនេះ មិនមែនបុគ្គលណាម្នាក់ ចងក្រងទុកក្នុងឥឡូវនេះ ទាំងមិនមែនពួកឥសីខាងក្រៅ ពួកសាវក ឬពួកទេវតាសម្ដែង តែព្រះអភិធម្មនេះ ជាភាសិតរបស់ព្រះជិនស្រី ដែលជាសព្វញ្ញុពុទ្ធ ព្រោះក្នុងព្រះអភិធម្មក្ដី ក្នុងព្រះសូត្រក្ដី ទ្រង់សម្ដែងព្រះបាលីដែលជាបែបផែនដូចគ្នានោះឯង ។

ឥឡូវនេះ ដើម្បីសម្ដែងសង្ខារទាំងនោះដោយប្រភេទផ្សេងៗ ទើបទ្រង់ត្រាស់ពាក្យជាដើមថា **តត្ថ កតមោ បុញ្ញាភិសង្ខារោ** ដូច្នេះ ក្នុងព្រះបាលីនោះថា ដោយមិនកំណត់សូម្បីចេតនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ក៏ត្រាស់

ថា កុសលចេតនា ដូច្នេះ ។ តែព្រោះទ្រង់កំណត់ថា **កាមាវចរា រូបាវចរា** ដូច្នេះ ចេតនា ១៣ គឺកាមាវចរកុសលចេតនា ៨ និងរូបាវចរកុសលចេតនា ៥ ទើបឈ្មោះថា **បុញ្ញាភិសង្ខារ** ។

ដោយបទទាំងឡាយថា **ទានមយា** ជាដើម ទ្រង់សម្តែងការប្រព្រឹត្តទៅនៃចេតនាទាំងនោះឯង ដោយអំណាចនៃបុញ្ញកិរិយាវត្ថុ ។ ក្នុងព្រះបាលីនោះ ចេតនា ៨ ជាកាមាវចរ រមែងសម្រេចដោយទាន និងសីល ។ តែចេតនាទាំង ១៣ សម្រេចដោយភាវនា ប្រៀបដូចបុគ្គលស្វាធ្យាយធម៌ ស្ទាត់ជំនាញ រមែងមិនដឹងនូវធម៌ដែលប្រព្រឹត្តទៅសូម្បីសន្ធិ ១ សូម្បីសន្ធិ ២ កាលនឹកដល់ ទើបដឹងក្នុងកាលជាខាងក្រោយ យ៉ាងណា កាលព្រះយោគាវចរធ្វើកសិណបរិកម្ម ពិចារណាឈានដែលកើតឡើងស្ទាត់ជំនាញ កាលមនសិការកម្មដ្ឋានដែលជំនាញ ក៏យ៉ាងនោះដូចគ្នា ចេតនាសូម្បីប្រាសចាកញាណ ក៏រមែងសម្រេចជាភាវនា ដោយហេតុនោះ ទើបខ្ញុំពោលថា ចេតនាទាំង ១៣ សម្រេចដោយភាវនា ដូច្នេះ ។

ក្នុងសេចក្តីនោះ ក្នុងកុសលចេតនាដែលសម្រេចដោយទានជាដើម មានទេសនាដោយសង្ខេបដូចតទៅនេះ ការចងចិត្ត កិរិយាចងចិត្ត ភាពចងចិត្ត ប្រារព្ធទាន ធ្វើទានឲ្យជាធំ កើតឡើងឯណា នេះហៅថា បុញ្ញា-ភិសង្ខារសម្រេចដោយទាន ។ ចេតនា ការចងចិត្ត កិរិយាដែលចងចិត្ត ភាពចងចិត្ត ប្រារព្ធសីល ។បេ។ ប្រារព្ធភាវនា ធ្វើភាវនាឲ្យជាធំកើតឡើងឯណា នេះហៅថា បុញ្ញាភិសង្ខារសម្រេចដោយភាវនា ដូច្នេះ ។

ចំណែកកថាដែលពិស្តារមានដូចតទៅ បណ្តាបច្ច័យ ៤ មានចីវរជាដើម ឬបណ្តាអារម្មណ៍ ៦ មានរូបារម្មណ៍ជាដើម ឬទានវត្ថុ ១០ មានការឲ្យបាយជាដើម ចេតនាដែលប្រព្រឹត្តទៅដល់បុគ្គលអ្នកឲ្យវត្ថុនោះៗ ក្នុងកាលទាំង ៣ គឺក្នុងបុព្វភាគ ចាប់តាំងអំពីការកើតឡើងនៃរបស់នោះៗ ១ ក្នុងពេលបរិច្ចាគ ១ ក្នុងការរឭកដល់ដោយចិត្តសោមនស្ស ក្នុងកាលខាងក្រោយ ១ ឈ្មោះថា **ទានមយ** ។ ចំណែកចេតនាដែលប្រព្រឹត្តទៅដល់បុគ្គលដែលទៅកាន់វិហារបួសដោយតាំងចិត្តថា អញនឹងបួសបំពេញសីល ដូច្នេះ ផ្ដើមនោរថឲ្យដល់ទីបំផុតហើយ ពិចារណាថា អញបួសហើយ ជាការល្អហ្ន៎ ដូច្នេះ សង្រួមក្នុងព្រះបាតិមោក្ខ ពិចារណានូវបច្ច័យទាំងឡាយ មានចីវរជាដើម សង្រួមចក្ខុទ្វារជាដើម ក្នុងរូបារម្មណ៍ជាដើម ដែលមកកាន់គន្លង និងជម្រះអាជីវៈឲ្យបរិសុទ្ធ ឈ្មោះថា **សីលមយ** ។ ចេតនាដែលប្រព្រឹត្តទៅដល់ព្រះយោគាវចរដែលចម្រើននូវចក្ខុ ដោយភាពជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ចម្រើននូវរូបទាំងឡាយ ។បេ។ ចម្រើននូវធម៌ទាំងឡាយ ចម្រើននូវចក្ខុវិញ្ញាណ ។បេ។ ចម្រើននូវមនោវិញ្ញាណ ចម្រើននូវចក្ខុសម្ផស្ស ។បេ។ ចម្រើននូវមនោសម្ផស្ស ចម្រើននូវចក្ខុសម្ផស្សជាវេទនា ។បេ។ ចម្រើនមនោសម្ផស្សជាវេទនា ចម្រើនរូបសញ្ញា ។បេ។ ចម្រើនជរាមរណៈដោយភាពជារបស់មិនទៀង ជាទុក្ខ ជាអនត្តា តាមគន្លងនៃវិបស្សនា ដែលពោលក្នុងបដិសម្ភិទាមគ្គ ឈ្មោះថា **ភាវនាមយ** ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃអបុញ្ញាភិសង្ខារដូចតទៅ

បទថា **អកុសលា ចេតនា** បានដល់ ចេតនាសម្បយុត្តដោយអកុសល-ចិត្ត ១២ ដួង ។ បទថា **កាមាវចរា** សេចក្ដីថា បណ្ដាអកុសលចេតនា ១២ ដួងនោះ វៀរចេតនាដែលសហគតៈដោយទោមនស្ស ២ ដួង ចេតនាដ៏សេស រមែងកើតឡើងក្នុងរូបភព និងអរូបភពក៏ពិត តែក៏មិនទាញបដិសន្ធិមកក្នុងរូបភព និងអរូបភពនោះ រមែងញុំាងវិបាក ឲ្យត្រាច់ទៅក្នុងកាមាវចរដោយអំណាចនៃបដិសន្ធិនោះឯង ព្រោះហេតុនោះ ទើបត្រាស់ថា ជាកាមាវចរប៉ុណ្ណោះ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងអានេញ្ជាភិសង្ខារនិទ្ទេសដូចតទៅ

បទថា **កុសលា ចេតនា អរូបាវចរា** បានដល់ កុសលចេតនាដែលជាអរូបាវចរ ៤ ។ ពិតហើយ កុសលចេតនាជាអរូបាវចរ ៤ នេះ ត្រាស់ហៅថា **អានេញ្ជាភិសង្ខារ** ព្រោះអត្ថថា មិនញាប់ញ័រ និងព្រោះអត្ថថាតាក់តែងនូវការមិនញាប់ញ័រ ព្រោះថា ធម៌ ១៥ គឺចេតនាដែលជាកុសលវិបាក កិរិយា ដែលកើតអំពីចតុត្ថជ្ឈាន ដែលជារូបាវចរ ៣ ចេតនាដែលជាអរូបាវចរ ១២ ឈ្មោះថា **អានេញ្ជា** ព្រោះអត្ថថា មាំទាំ ព្រោះអត្ថថា មិនញាប់ញ័រ ។ បណ្ដាចេតនា ១៥ នោះ រូបាវចរកុសលចេតនា សូម្បីជាសភាវៈមិនញាប់ញ័រ តែក៏ឲ្យកើតរូប និងអរូបដែលដូចគ្នានឹងខ្លួនខ្លះ មិនដូចគ្នានឹងខ្លួនខ្លះ ឲ្យមាននូវការញាប់ញ័រខ្លះ មិនមានការញាប់ញ័រខ្លះ ព្រោះហេតុនោះ ទើបមិនឈ្មោះថា **អានេញ្ជាភិសង្ខារ** ។ ចំណែករូបាវចរវិបាកចេតនា និងរូបាវចរកិរិយាចេតនា រមែងតាក់តែងវិបាកមិនបាន ព្រោះមិនមានវិបាក ទើប

ឈ្មោះថា អានេញ្ជាភិសង្ខារមិនបាន ចេតនាដែលជាអរូបាវចរវិបាក និង កិរិយា ក៏ជាអានេញ្ជាភិសង្ខារមិនបានដូចគ្នា ព្រោះហេតុនោះ ទើបចេតនាទាំង ១១ ដួងនេះ ជាអានេញ្ជាប៉ុណ្ណោះ មិនជាអភិសង្ខារ តែអរូបាវចរកុសល-ចេតនា ៤ ដួងប៉ុណ្ណោះ ទ្រង់ត្រាស់ហៅថា **អានេញ្ជាភិសង្ខារ** ព្រោះអត្ថថា រមែងឲ្យកើតអរូប ដែលមិនញាប់ញ័រដូចគ្នានឹងខ្លួន ដូចស្រមោលរបស់សត្វ មានដីរ សេះជាដើម ក៏ដូចគ្នានឹងសត្វ មានដីរសេះជាដើមដូច្នោះ ចេតនា ទាំងអស់នេះ គឺកាមាវចរកុសលចេតនា ១៣ ដោយអំណាចនៃបុញ្ញាភិសង្ខារ អកុសលចេតនា ១២ ដោយអំណាចអបុញ្ញាភិសង្ខារ អរូបាវចរកុសល-ចេតនា ៤ ដោយអំណាចអានេញ្ជាភិសង្ខារ សរុបមក ជាចេតនា ២៩ ដោយប្រការដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់កំណត់ចេតនាដែលជាកុសល និងអកុសល ដែលកើតឡើងដល់ពួកសត្វប្រមាណមិនបាន ក្នុងចក្កវាឡដែលប្រមាណមិន បាន ដោយព្រះសព្វញ្ញុតញ្ញាណ ទ្រង់សម្ដែងនូវចេតនា ២៩ ប៉ុណ្ណោះ ដូច ទ្រង់ថ្លឹងដោយជញ្ជីងធំ និងដូចទ្រង់វាល់ដោយនាឡិ ដូច្នោះ ដោយប្រការ យ៉ាងនេះ ។

ពួកសត្វប្រមាណមិនបាន ក្នុងចក្កវាឡដែលរាប់មិនបាន កាលប្រកបនូវ កុសលកម្ម និងអកុសលកម្ម រមែងប្រកបដោយទ្វារឯណា ឥឡូវនេះ ព្រះ មានព្រះភាគកាលទ្រង់សម្ដែងទ្វារនៃកម្មទាំង ៣ នោះ ទើបត្រាស់ពាក្យជាដើម ថា **តត្ថ កតមោ កាយសង្ខារោ កាយសញ្ចេតនា** ដូច្នេះ ។

*ក្នុងព្រះបាលីនោះ បទថា* **កាយសញ្ចេតនា** *បានដល់ ចេតនា ២០ គឺកាមាវចរកុសលចេតនា ៨ អកុសលចេតនា ១២ ដែលធ្វើកាយវិញ្ញត្តិឲ្យតាំងឡើងប្រព្រឹត្តទៅតាមកាយទ្វារ និងពោលថា ចេតនាដែលជាកុសល និងអកុសល ២០ ដែលកើតឡើង ឲ្យដល់នូវការប្រកាន់ ការចាប់ និងការកម្រើកកាយទ្វារ ក៏សមគួរ ។*

*បទថា* **វចីសញ្ចេតនា** *បានដល់ សញ្ចេតនា ២០ ដូចនោះឯង ដែលធ្វើវចីវិញ្ញត្តិឲ្យតាំងឡើងប្រព្រឹត្តទៅតាមវចីទ្វារ ទោះបីនឹងពោលថា ចេតនា ២០ ដែលកើតឡើងធ្វើចង្កាឲ្យកម្រើក និងឲ្យដល់នូវការបន្លឺវាចា តាមវចីទ្វារ ក៏គួរ តែក្នុងអធិការនេះ អភិញ្ញាចេតនា រមែងមិនជាបច្ច័យដល់វិញ្ញាណតទៅ ព្រោះហេតុនោះ ទើបមិនប្រារព្ធ ។ ឧទ្ធច្ចចេតនា ក៏មិនជាបច្ច័យដូចអភិញ្ញា-ចេតនា ព្រោះហេតុនោះ ឧទ្ធច្ចចេតនានោះ ក៏គប្បីនាំចេញចាកភាពជាបច្ច័យរបស់វិញ្ញាណ ចេតនាទាំងអស់នោះ រមែងមាន ព្រោះអវិជ្ជាជាបច្ច័យ ។*

*បទថា* **មនោសញ្ចេតនា** *បានដល់ ចេតនាទាំងអស់ ២៩ ដែលកើតឡើងតាមមនោទ្វារ ដោយមិនធ្វើវិញ្ញត្តិទាំងពីរឲ្យតាំងឡើង ។*

*ព្រះមានព្រះភាគ ទ្រង់សម្តែងទ្វារនៃកម្ម ដែលសត្វប្រកបថា សត្វទាំងឡាយមិនមានប្រមាណ ក្នុងចក្កវាឡដែលប្រមាណមិនបាន កាលប្រកបកុសល និងអកុសលកម្ម រមែងប្រកបដោយទ្វារទាំង ៣ នេះ ដោយប្រការដូច្នេះឯង ។*

*ម្យ៉ាងទៀត គប្បីជ្រាបសម្បយោគនៃពួកតិកៈទាំងពីរនេះដូចតទៅ*

សួរថា សម្បយោគដូចម្តេច ឆ្លើយថា បុញ្ញាភិសង្ខារ គប្បីជាកាយសង្ខារ ដល់បុគ្គលដែលវៀរចាកកាយទុច្ចរិតក៏មាន គប្បីជាវចីសង្ខារ ដល់បុគ្គលដែលវៀរចាកវចីទុច្ចរិតក៏មាន ។ គប្បីឃើញដូច្នេះ គឺកុសលចេតនា ៨ ខាងកាមាវចរ ជាបុញ្ញាភិសង្ខារ ជាកាយសង្ខារ និងវចីសង្ខារ ។ ចំណែកចេតនា ១៣ ដែលកើតតាមមនោទ្វារ ជាបុញ្ញាភិសង្ខារ និងចិត្តសង្ខារ ។

អបុញ្ញាភិសង្ខារ ជាកាយសង្ខារក្នុងវេលាប្រព្រឹត្តទៅដោយអំណាចកាយទុច្ចរិតនោះឯងក៏មាន ជាវចីសង្ខារក្នុងពេលដែលប្រព្រឹត្តទៅដោយអំណាចវចីទុច្ចរិតក៏មាន ជាចិត្តសង្ខារក្នុងពេលដែលលះទ្វារពីរ ហើយប្រព្រឹត្តទៅតាមមនោទ្វារក៏មាន អបុញ្ញាភិសង្ខារ ជាកាយសង្ខារខ្លះ ជាវចីសង្ខារខ្លះ ជាចិត្តសង្ខារខ្លះ ដោយប្រការដូច្នេះ ។

កាយសង្ខារ ជាបុញ្ញាភិសង្ខារក៏មាន ជាអបុញ្ញាភិសង្ខារក៏មាន មិនជាអានេញ្ជាភិសង្ខារ ។ វចីសង្ខារក៏ដូចគ្នា តែចិត្តសង្ខារ ជាបុញ្ញាភិសង្ខារក៏មាន ជាអបុញ្ញាភិសង្ខារក៏មាន ជាអានេញ្ជាភិសង្ខារក៏មាន ព្រោះហេតុនោះ ទើបសង្ខារទាំងនេះ ឈ្មោះថា សង្ខារកើត ព្រោះអវិជ្ជាជាបច្ច័យ ។

សួរថា សេចក្តីនេះ គប្បីជ្រាបបានដូចម្តេច ថាសង្ខារទាំងនេះ មានព្រោះអវិជ្ជាជាបច្ច័យ ឆ្លើយថា ដឹងបានព្រោះអវិជ្ជាមាន ទើបសង្ខារមាន ពិតហើយ បុគ្គលណាមិនទាន់លះអញ្ញាណ ពោល គឺអវិជ្ជាក្នុងសច្ចៈ ៤ មានទុក្ខជាដើមបាន បុគ្គលនោះក៏នឹងប្រកាន់សង្សារទុក្ខ ដោយសេចក្តីសម្គាល់ថា ជាសុខ ដោយការមិនដឹងក្នុងទុក្ខ និងក្នុងចំណែកដែលជាអតីតជាដើម រមែង

ប្រារព្ធសង្ខារទាំង ៣ ដែលជាហេតុនៃសង្សារទុក្ខនោះ ដោយការមិនដឹងក្នុងទុក្ខសមុទយៈ បុគ្គលនោះ ក៏ប្រារព្ធសង្ខារទាំងឡាយដែលជាបរិវាររបស់តណ្ហា ជាហេតុនៃទុក្ខ ដោយភាពជាហេតុនៃសុខ ។ ម្យ៉ាងទៀត ដោយការមិនដឹងក្នុងនិរោធ និងមគ្គ ទើបជាអ្នកមានសេចក្ដីសម្គាល់ក្នុងគតិពិសេសមិនការរលត់ទុក្ខថា ជាការរលត់ទុក្ខ និងជាអ្នកមានសេចក្ដីសម្គាល់ក្នុងពិធីកម្មទាំងឡាយ មានការបូជាយញ្ញ និងបំពេញតបៈដើម្បីបានជាទេវតាជាដើម មិនជាផ្លូវនៃការរម្ងត់ទុក្ខថា ជាផ្លូវរម្ងត់ទុក្ខ កាលប្រាថ្នាទុក្ខនិរោធ ក៏រមែងប្រារព្ធសង្ខារ ៣ យ៉ាង ដោយបែរមុខចូលក្នុងពិធីកម្ម មានការបូជាយញ្ញ និងបំពេញតបៈដើម្បីភាពជាទេវតាជាដើម ។

ម្យ៉ាងទៀត បុគ្គលនោះ ព្រោះមិនទាន់លះអវិជ្ជាក្នុងសច្ចៈ ៤ បាន កាលមិនដឹងទុក្ខ ដោយសេចក្ដីពិសេស ពោល គឺផលនៃបុណ្យ លាយឡំដោយទោសជាអនេក មានជាតិ ជរា ព្យាធិ និងមរណៈជាដើម ដោយភាពជាទុក្ខ រមែងប្រារព្ធនូវបុញ្ញាភិសង្ខារ មានកាយសង្ខារ វចីសង្ខារ និងចិត្តសង្ខារដើម្បីដល់ទុក្ខនោះ ដូចជាបុគ្គលត្រូវការស្រីទេពអប្សរ ប្រាថ្នាកើតជាទេវបុត្រ ដូច្នោះ ។ ម្យ៉ាងទៀត បុគ្គលនោះមិនឃើញផលបុណ្យនោះ ដែលសន្មតថាជាសុខ ជាសេចក្ដីទុក្ខ ព្រោះប្រែប្រួល ដែលធ្វើនូវការក្ដៅក្រហាយធំ ឲ្យកើតឡើងខាងចុង និងមិនឃើញថា ផលបុណ្យនោះ មានសេចក្ដីសុខតិច រមែងប្រារព្ធបុញ្ញាភិសង្ខារ មានប្រការតាមដែលពោលហើយនោះឯង ដែលមានផលបុណ្យនោះជាបច្ច័យ ដូចមមាចបែរមុខទៅកាន់អណ្ដាត

ប្រទីប និងដូចបុគ្គលជាប់ចិត្តក្នុងដំណក់ទឹកឃ្មុំ លិទ្ធនូវមុខសស្រ្តាដែលលាប ដោយទឹកឃ្មុំ ដូច្នោះ ។

ម្យ៉ាងទៀត កាលមិនឃើញទោសក្នុងធម៌ដែលមានវិបាក មានការសេពកាមជាដើម រមែងប្រារព្ធអបុញ្ញាភិសង្ខារ ប្រព្រឹត្តទៅដោយទ្វារ ៣ ព្រោះសម្គាល់ថាជាសុខ និងព្រោះត្រូវកិលេសគ្របសង្កត់ហើយ ដូចទារកលេងលាមក និងដូចបុគ្គលចង់ស្លាប់ទំពាស៊ីថ្នាំពុល ដូច្នោះ ។ ម្យ៉ាងទៀត កាលមិនដឹងនូវសេចក្តីទុក្ខ ព្រោះការប្រែប្រួលនៃសង្សារ សូម្បីក្នុងវិបាកនៃអរូបក៏រមែងប្រារព្ធអានេញ្ជាភិសង្ខារ ដែលជាចិត្តសង្ខារ ដោយវិបល្លាសថាទៀងជាដើម ដូចបុគ្គលវង្វេងទិស ផ្តើមដើរបែរមុខទៅកាន់នគរបិសាច ដូច្នោះ ព្រោះភាពដែលអវិជ្ជាមាននោះឯង ទើបសង្ខារមាន មិនមែនព្រោះការមិនមាន ហេតុនោះ គប្បីជ្រាបសេចក្តីនោះយ៉ាងនេះថា សង្ខារទាំងនេះ រមែងមានព្រោះអវិជ្ជាជាបច្ច័យ ។ ព្រះមានព្រះភាគក៏ត្រាស់ពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ បុគ្គលល្ងង់ខ្លៅ ធ្លាក់ក្នុងអវិជ្ជាហើយ រមែងតាក់តែងបុញ្ញាភិសង្ខារខ្លះ រមែងតាក់តែងអបុញ្ញាភិសង្ខារខ្លះ រមែងតាក់តែងអានេញ្ជាភិសង្ខារខ្លះ ម្នាលភិក្ខុទាំងឡាយ កាលដែលភិក្ខុលះបង់អវិជ្ជាចោលហើយ វិជ្ជាក៏កើតឡើង ។ ព្រោះតែការបាត់ទៅនៃអវិជ្ជា ព្រោះតែការកើតឡើងនៃវិជ្ជា បានជាភិក្ខុនោះ លែងតាក់តែងបុញ្ញាភិសង្ខារ ដូច្នេះ ។

សួរថា ក្នុងអធិការនេះ បើមានបុគ្គលពោលថា ពួកយើងរមែងទទួលថា អវិជ្ជាជាបច្ច័យនៃសង្ខារទាំងឡាយ តែលោកគួរពោលសេចក្តីនេះថា

អវិជ្ជាជាបច្ច័យដូចម្ដេចដល់សង្ខារពួកណា ដូច្នេះ ។ ក្នុងបញ្ហាកម្មនេះ លោករមែងពោលពាក្យនេះថា

អវិជ្ជានោះ ជាបច្ច័យ ២ យ៉ាង ដល់បុញ្ញាភិសង្ខារ ជាបច្ច័យច្រើនយ៉ាង ដល់អបុញ្ញាភិសង្ខារដទៃ ជាបច្ច័យតែម្យ៉ាង ដល់អនេញ្ជាភិសង្ខារចុងក្រោយ ដូច្នេះ ។

ក្នុងការឆ្លើយបញ្ហានោះ ពាក្យថា អវិជ្ជាជាបច្ច័យ ២ យ៉ាង ដល់បុញ្ញាភិសង្ខារ បានដល់ ជាបច្ច័យ ២ យ៉ាង គឺដោយអារម្មណប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ។ ពិតហើយ អវិជ្ជានោះ ជាបច្ច័យដោយអារម្មណប្បច្ច័យដល់បុញ្ញាភិសង្ខារដែលជាកាមាវចរ ក្នុងកាលពិចារណាសង្ខារ ដោយការអស់ទៅ សូន្យទៅ និងជាបច្ច័យដល់បុញ្ញាភិសង្ខារដែលជារូបាវចរ ក្នុងកាលចិត្តមានមោហៈ ដោយអភិញ្ញាចិត្ត ។ ម្យ៉ាងទៀត កាលបុគ្គលបំពេញនូវបុញ្ញកិរិយាវត្ថុ ដែលជាកាមាវចរ មានការឲ្យទានជាដើម និងកាលបុគ្គលញុំាងរូបាវចរជ្ឈានទាំងឡាយឲ្យកើតឡើង ដើម្បីប្រយោជន៍ដល់ការឈានកន្លងអវិជ្ជា អវិជ្ជាក៏ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យដល់បុញ្ញាភិសង្ខារដែលជាកាមាវចរ និងរូបាវចរទាំង ២ នោះ ។ កាលបុគ្គលប្រាថ្នាសម្បត្តិក្នុងកាមភព និងរូបភព ហើយធ្វើនូវបុណ្យទាំងនោះឯង ព្រោះការវង្វេងដោយអវិជ្ជា អវិជ្ជាក៏ជាបច្ច័យដោយឧបនិស្សយប្បច្ច័យដូចគ្នា ។

ម្យ៉ាងទៀត ពាក្យថា អវិជ្ជាជាបច្ច័យច្រើនយ៉ាង ដល់អបុញ្ញាភិសង្ខារដទៃ បានដល់ អវិជ្ជា ជាបច្ច័យច្រើនយ៉ាងដល់អបុញ្ញាភិសង្ខារ សេចក្ដីនេះ

ដូចម្ដេច សេចក្ដីថា ជាបច្ច័យច្រើនយ៉ាង គឺក្នុងវេលាប្រារព្ធអវិជ្ជា កើតកិលេស មានរាគៈជាដើម អវិជ្ជាក៏ជាបច្ច័យដោយអារម្មណប្បច្ច័យ ។ ក្នុងវេលាដែលគ្រេកអរខ្លាំង ក៏ជាបច្ច័យដោយអារម្មណាធិបតិប្បច្ច័យ និងអារម្មណូបនិស្សយប្បច្ច័យ ។ កាលបុគ្គលវង្វេងដោយអវិជ្ជា មិនឃើញទោស ធ្វើនូវបាណាតិបាតជាដើម ក៏ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ជាបច្ច័យដល់ជវនទី ២ ជាដើម ដោយអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ឧបនិស្សយប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ។ កាលធ្វើអកុសលណាមួយ ក៏ជាបច្ច័យដោយហេតុប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។

ពាក្យថា ជាបច្ច័យតែម្យ៉ាង ដល់អនេញ្ជាភិសង្ខារចុងក្រោយ បានដល់ អវិជ្ជា ជាបច្ច័យតែម្យ៉ាងប៉ុណ្ណោះ ដោយឧបនិស្សយប្បច្ច័យដល់អានេញ្ជាភិសង្ខារ ។ ភាពដែលអវិជ្ជាជាឧបនិស្សយប្បច្ច័យនោះ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងបុញ្ញាភិសង្ខារនោះឯង ។

ក្នុងទីនេះ មានបុគ្គលសង្ស័យសួរថា អវិជ្ជានេះតែម្យ៉ាងប៉ុណ្ណោះ ជាបច្ច័យដល់សង្ខារទាំងឡាយ ឬធម៌ដទៃជាបច្ច័យក៏មាន គប្បីឆ្លើយថា ក្នុងសេចក្ដីនេះ មានពាក្យពោលដូចម្ដេច បើមានអវិជ្ជាតែម្យ៉ាងប៉ុណ្ណោះ ក៏ប្រពៃដែលនឹងពោលហេតុតែម្យ៉ាង បើធម៌ដទៃដែលជាបច្ច័យមាន ការសម្ដែងដល់ហេតុតែម្យ៉ាងថា សង្ខារកើតព្រោះអវិជ្ជាជាបច្ច័យ ដូច្នេះ ក៏មិនកើតឡើង ។

តែមិនកើតឡើងក៏មិនមែន ។ ព្រោះអ្វី ព្រោះថា

ក្នុងលោកនេះ ផលតែម្យ៉ាង រមែងមានព្រោះហេតុតែម្យ៉ាងក៏មិនមែន ផលច្រើនយ៉ាង រមែងមានព្រោះហេតុតែម្យ៉ាងក៏មិនមែន ផលតែម្យ៉ាង រមែងមានព្រោះហេតុច្រើនយ៉ាងក៏មិនមែន តែប្រយោជន៍ក្នុងការសម្តែងហេតុ និងផលតែម្យ៉ាងមាន ដូច្នេះ ។

អធិប្បាយថា ក្នុងលោកនេះ ផលតែម្យ៉ាង រមែងមានព្រោះហេតុតែម្យ៉ាងក៏មិនមែន ផលច្រើនយ៉ាង រមែងមានព្រោះហេតុតែម្យ៉ាងក៏មិនមែន ផលតែម្យ៉ាង រមែងមានព្រោះហេតុច្រើនយ៉ាងក៏មិនមែន តែផលច្រើនយ៉ាងប៉ុណ្ណោះ រមែងមានព្រោះហេតុច្រើនយ៉ាង ពិតហើយ ផល ពោល គឺពន្លក មានរូប ( ពណ៌ ) ក្លិន រសជាដើម ដែលកើតឡើងមិនមែនតិច រមែងប្រាកដបាន ព្រោះហេតុទាំងឡាយជាច្រើន គឺឧតុ ផែនដី ពូជ និងទឹក តែសេចក្តីត្រូវការ គឺប្រយោជន៍ក្នុងការសម្តែងហេតុ និងផលតែម្យ៉ាងនេះថា **អវិជ្ជាបច្ចយា សង្ខារា សង្ខារប្បច្ចយា វិញ្ញាណំ** ដែលទ្រង់ធ្វើហើយ មាន ។

ព្រោះថា ព្រះមានព្រះភាគទ្រង់រមែងសម្តែងហេតុ ឬផលតែម្យ៉ាងប៉ុណ្ណោះ ដោយសមគួរដល់ទេសនាវិលាស និងដល់ពួកវេនេយ្យសត្វ ១ ព្រោះក្នុងទីខ្លះ មានហេតុ និងផលជាប្រធាន ២ ព្រោះក្នុងទីខ្លះ មានហេតុ និងផលប្រាកដហើយ ៣ ព្រោះក្នុងទីខ្លះ មានហេតុ និងផលជាអសាធារណៈ ។

ពិតហើយ ក្នុងបទថា **ផស្សប្បច្ចយា វេទនា** នេះ ព្រះសាស្តាត្រាស់ហេតុ និងផលតែម្យ៉ាងប៉ុណ្ណោះ ដ្បិតថា ផស្សៈជាប្រធានហេតុរបស់វេទនា

ព្រោះទ្រង់កំណត់វេទនាតាមផស្សៈ វេទនាក៏ជាប្រធានផលរបស់ផស្សៈ ព្រោះទ្រង់កំណត់ផស្សៈតាមវេទនា ។

ក្នុងពាក្យ ( អង្គុត្តរនិកាយ ទសកនិបាត ) ថា អាពាធបណ្ដាលអំពីស្លេស្ម នេះទ្រង់ត្រាស់ហេតុតែម្យ៉ាង ព្រោះជារបស់ប្រាកដហើយ ក្នុងអធិការនេះ **សេម្ហ** ជាហេតុប្រាកដច្បាស់ មិនមែនកម្មជាដើមជាហេតុឡើយ ។

ក្នុងពាក្យថា ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ពួកណាមួយ មានអកុសលធម៌ទាំងអស់នោះ មានអយោនិសោមនសិការជាមូល ដូច្នេះ ទ្រង់ត្រាស់ហេតុមួយ ព្រោះជាហេតុមិនទូទៅ ។ ពិតហើយ អកុសលធម៌ទាំងឡាយ មានអយោនិសោមនសិការ ជាអសាធារណហេតុ តែមានវត្ថុ និងអារម្មណ៍ជាដើម ជាសាធារណហេតុ ដូច្នេះឯង ។

ព្រោះហេតុនោះ ក្នុងអធិការនេះ កាលធម៌ដទៃៗ មានវត្ថុ អារម្មណ៍ និងសហជាតធម៌ជាដើម ដែលជាហេតុនៃសង្ខារមាន អវិជ្ជានេះ បណ្ឌិតគប្បីជ្រាបថា ទ្រង់សម្ដែងដោយភាពជាហេតុនៃសង្ខារទាំងឡាយ ព្រោះជាហេតុ ជាប្រធាន គឺហេតុនៃហេតុរបស់សង្ខារពួកដទៃ មានតណ្ហាជាដើម ដោយព្រះបាលីថា កាលភិក្ខុពិចារណាឃើញនូវសេចក្ដីត្រេកអរ តណ្ហារមែងចម្រើន ដូច្នេះ និងព្រះបាលីថា សេចក្ដីកើតឡើងនៃអាសវៈ ព្រោះសេចក្ដីកើតឡើងនៃអវិជ្ជា ដូច្នេះ និងព្រោះជាហេតុប្រាកដ និងជាអសាធារណហេតុ ដោយព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ បុគ្គលល្ងង់ខ្លៅ ធ្លាក់ក្នុងអវិជ្ជាហើយ រមែងតាក់តែងនូវបុញ្ញាភិសង្ខារខ្លះ ដូច្នេះជាដើម ។ ដោយពាក្យឆ្លើយការ

សម្តែងហេតុ និងផលតែម្យ៉ាងនេះឯង គប្បីជ្រាបប្រយោជន៍ក្នុងការសម្តែងហេតុ និងផលនីមួយៗ ក្នុងទីទាំងពួង ដោយប្រការដូច្នេះឯង ។

ក្នុងសេចក្តីនេះ បើមានបុគ្គលសួរថា កាលបើដូច្នោះ អវិជ្ជាជាធម៌មានទោស មានផល មិនគួរប្រាថ្នាដោយចំណែកមួយ រមែងគួរជាបច្ច័យដល់បុញ្ញាភិសង្ខារ និងអានេញ្ជាភិសង្ខារបានដូចម្តេច ។ ព្រោះអំពៅ រមែងមិនកើតអំពីពូជស្តៅ ឆ្លើយថា អវិជ្ជានោះ នឹងមិនគួរជាបច្ច័យដល់បុញ្ញាភិសង្ខារ និងអានេញ្ជាភិសង្ខារបានដូចម្តេច ព្រោះក្នុងលោកនេះ

ធម៌ទាំងឡាយ មានបច្ច័យសម្រេចហើយ ខុសឋានៈគ្នាក៏មាន
មិនខុសគ្នាក៏មាន ម្យ៉ាងទៀត ដូចគ្នា និងមិនដូចគ្នាក៏មាន ធម៌
ទាំងនោះ មិនមែនវិបាកតែម្យ៉ាងឡើយ ដូច្នេះ ។

អធិប្បាយថា បច្ច័យនៃធម៌ទាំងឡាយ ដែលសម្រេចហើយក្នុងលោក ជាធម៌ដែលខុសប្លែកគ្នាដោយឋានៈ ដោយសភាវៈ និងដោយកិច្ចជាដើមក៏មាន ដែលមិនខុសប្លែកគ្នាក៏មាន ពិតហើយ ចិត្តដួងដំបូង ជាបច្ច័យដែលខុសឋានៈរបស់ចិត្តដួងក្រោយ និងការសិក្សាសិប្បៈគ្រាដំបូងជាដើម ជាបច្ច័យដែលខុសឋានៈដល់ការធ្វើសិប្បៈជាដើម ដែលកំពុងប្រព្រឹត្តទៅខាងក្រោយ ។ កម្មជាបច្ច័យដែលខុសសភាវៈរបស់រូប ទឹកដោះស្រស់ជាដើម ជាបច្ច័យដែលខុសសភាវៈដល់ទឹកដោះជូរជាដើម ពន្លឺជាបច្ច័យដែលខុសកិច្ចដល់ចក្ខុវិញ្ញាណ

និងទឹកអំពៅជាដើម ជាបច្ច័យដែលខុសកិច្ចដល់មេរ័យ[១] ជាដើម ។

ចំណែកចក្ខុ និងរូបជាដើមជាបច្ច័យមិនខុសឋានៈ ដល់ចក្ខុវិញ្ញាណជាដើម ជវនចិត្តដួងទី ១ ជាដើម ជាបច្ច័យមិនខុសសភាវៈ និងមិនខុសកិច្ចដល់ជវនក្រោយជាដើម ម្យ៉ាងទៀត បច្ច័យដែលសម្រេចហើយ ខុសឋានៈគ្នា និងមិនខុសឋានៈគ្នាមាន យ៉ាងណា បច្ច័យដែលសម្រេចហើយ ដែលដូចគ្នា និងមិនដូចគ្នាមានក៏យ៉ាងនោះ ។ ពិតហើយ រូប ពោល គឺឧតុ និងអាហារ ដូចគ្នានោះឯង ជាបច្ច័យដល់រូប ពូជស្រូវសាលីជាដើម ក៏ជាបច្ច័យដល់ផ្លែនៃស្រូវសាលីជាដើម ។ រូបដែលមិនដូចគ្នា ជាបច្ច័យដល់អរូប អរូបជាបច្ច័យដល់រូបក៏បាន ។ រោមគោ រោមចៀម ស្នែងសត្វ ទឹកដោះជូរ ល្ង និងម្សៅជាដើម រមែងជាបច្ច័យដល់ស្បូវភ្លាំង និងស្លឹកគ្រៃ[២] ជាដើម ម្យ៉ាងទៀត ធម៌ទាំងឡាយជាវិបាកប៉ុណ្ណោះនៃធម៌ទាំងឡាយ ដែលជាបច្ច័យខុសគ្នា និងមិនខុសគ្នា ដូចគ្នា និងមិនដូចគ្នា ក៏មិនមែន ។ អវិជ្ជា ជាធម៌មានទោស ដោយអំណាចនៃការឲ្យផល និងដោយអំណាចសភាវៈ ដែលមានផលមិនគួរប្រាថ្នាដោយចំណែកមួយ ក៏គប្បីជ្រាបថា ជាបច្ច័យដល់បុញ្ញាភិសង្ខារជាដើមទាំងអស់នេះតាមគួរ ដោយអំណាចនៃបច្ច័យដែលខុសគ្នា និងមិនខុសគ្នាដោយឋានៈ ដោយកិច្ច ដោយសភាវៈ និងដោយអំណាចនៃបច្ច័យដែលដូចគ្នា និងមិនដូចគ្នា ដោយប្រការដូច្នេះ ។

---

១- ទឹកអំពៅជារបស់ផ្អែម តែកាលទុកយូរទៅ ក៏ក្លាយជាមេរ័យ នេះហៅថា បច្ច័យដែលខុសកិច្ច ( អ្នកប្រែ ) ។ ២- ស្នែងគោ រោមចៀមជាដើម អាចយកធ្វើជាជីរសម្រាប់ឲ្យស្បូវភ្លាំង និងស្លឹកគ្រៃជាដើម លូតលាស់បានល្អ ( អ្នកប្រែ ) ។

ភាពដែលអវិជ្ជាជាបច្ច័យនោះ ខ្ញុំពោលដោយន័យជាដើមថា ពិតហើយ បុគ្គលណាមិនទាន់លះអញ្ញាណ ពោល គឺអវិជ្ជាក្នុងសច្ចៈ ៤ មានទុក្ខជាដើមបាន បុគ្គលនោះ ក៏នឹងប្រកាន់នូវសង្សារទុក្ខ ដោយការសម្គាល់ថាជាសុខ ដោយការមិនដឹងក្នុងទុក្ខ និងក្នុងចំណែកដែលជាអតីតជាដើម រមែងប្រារព្ធសង្ខារ ៣ មានបុញ្ញាភិសង្ខារជាដើម ដែលជាហេតុនៃសង្សារទុក្ខនោះ ដូច្នេះ ។

ម្យ៉ាងទៀត គប្បីជ្រាបបរិយាយដទៃដូចតទៅ

បុគ្គលណាវង្វេងក្នុងការស្លាប់ និងការកើត គឺចុតិ និងបដិសន្ធិក្នុងសង្សារ ក្នុងលក្ខណៈនៃសង្ខារទាំងឡាយ និងក្នុងធម៌ដែលអាស្រ័យគ្នា និងគ្នាកើតឡើង បុគ្គលនោះ រមែងតាក់តែងសង្ខារទាំង ៣ នេះ ហេតុនោះ ទើបអវិជ្ជា ជាបច្ច័យដល់សង្ខារទាំង ៣ នេះ ។

ម្យ៉ាងទៀត បើមានបុគ្គលសួរថា បុគ្គលអ្នកវង្វេងក្នុងធម៌ទាំងនោះ រមែងធ្វើសង្ខារទាំង ៣ នេះដូចម្ដេច ឆ្លើយថា បុគ្គលដែលវង្វេងក្នុងចុតិ កាលបុគ្គលនោះមិនកាន់យកចុតិក្នុងទីទាំងពួងថា ការបែកធ្លាយនៃខន្ធទាំងឡាយ ឈ្មោះថា មរណៈ រមែងកំណត់ថា សត្វរមែងស្លាប់ គឺឈានទៅកាន់កាយដទៃនៃសត្វជាដើម ។ បុគ្គលវង្វេងក្នុងការកើត កាលមិនកាន់យកការកើតក្នុងទីទាំងពួងថា ការប្រាកដនៃខន្ធទាំងឡាយ ឈ្មោះថា ជាតិ រមែងកំណត់ថា សត្វកើត គឺភាពដែលសត្វប្រាកដមានសរីរៈថ្មីជាដើម ។ បុគ្គលវង្វេងក្នុងសង្សារ កាលមិនប្រកាន់នូវសង្សារដែលលោកពណ៌នាយ៉ាងនេះថា

លំដាប់នៃខន្ធទាំងឡាយ និងនៃធាតុ អាយតនៈទាំងឡាយ ប្រព្រឹត្ត ទៅមិនដាច់ខ្សែ ហៅថា សង្សារ ដូច្នេះ ។

រមែងកំណត់ហេតុថា សត្វនេះ រមែងទៅកាន់លោកដទៃអំពីលោកនេះ រមែងមកលោកនេះអំពីលោកដទៃជាដើម ។ បុគ្គលវង្វេងក្នុងលក្ខណៈនៃសង្ខារទាំងឡាយ កាលមិនកាន់យកសភាវលក្ខណៈ និងសាមញ្ញលក្ខណៈរបស់សង្ខារទាំងឡាយ រមែងកំណត់សង្ខារទាំងឡាយដោយភាពជារបស់ខ្លួន ដោយភាពជារបស់ទាក់ទងដោយខ្លួន ដោយការស្ថិតស្ថេរ ដោយការស្អាត និងដោយសេចក្តីសុខ ។ បុគ្គលវង្វេងក្នុងធម៌ ដែលអាស្រ័យគ្នានិងគ្នាកើតឡើង កាលមិនកាន់យកការប្រព្រឹត្តទៅនៃធម៌ មានសង្ខារជាដើម ព្រោះបច្ច័យ មានអវិជ្ជាជាដើម រមែងកំណត់ថា អត្តារមែងដឹងខ្លះ រមែងមិនដឹងខ្លះ អត្តានោះឯង រមែងធ្វើ និងញុំាងអ្នកដទៃឲ្យធ្វើ អត្តានោះ រមែងកើតក្នុងបដិសន្ធិ អណុ និងព្រះឥសូរជាដើម សាងសរីរៈរបស់អត្តានោះ ដោយភាពជាកលលៈជាដើម ហើយញុំាងឥន្ទ្រិយទាំងឡាយឲ្យបរិបូណ៌ អត្តានោះសម្បូរដោយឥន្ទ្រិយ រមែងពាល់ត្រូវ រមែងសោយ រមែងកាន់យក រមែងប្រកាន់ រមែងបន្ត អត្តានោះ នឹងមានក្នុងភពដទៃទៀតដូច្នេះក៏មាន រមែងកំណត់ថា សត្វទាំងពួង ជាបុគ្គលប្រែប្រួលទៅតាមជោគល្អ ជោគអាក្រក់ តាមការជួប តាមការកើតឯងៗ ដូច្នេះក៏មាន ។ បុគ្គលនោះ ដែលអវិជ្ជាធ្វើឲ្យខ្វាក់ហើយ កាលកំណត់យ៉ាងនេះ រមែងតាក់តែងអភិសង្ខារ គឺបុណ្យខ្លះ បាបខ្លះ អានេញ្ជខ្លះ ដូចបុគ្គលខ្វាក់ កាលត្រាច់ទៅលើផែនដី រមែងដើរត្រូវផ្លូវខ្លះ ខុសផ្លូវ

ខ្លះ ឡើងទួលខ្លះ ធ្លាក់រណ្តៅខ្លះ ក្នុងទីស្មើខ្លះ មិនស្មើខ្លះ ដូច្នេះ ដោយហេតុនោះ ទើបបណ្ឌិតពោលគាថានេះថា

ធម្មតា បុគ្គលខ្វាក់អំពីកំណើត មិនមានអ្នកនាំទៅ ក្នុងកាលខ្លះ រមែងទៅតាមផ្លូវ ក្នុងកាលខ្លះ រមែងដើរទៅក្រៅផ្លូវយ៉ាងណា ។ បុគ្គលពាលក៏យ៉ាងនោះ កាលអន្ទោលទៅក្នុងសង្សារ មិនមានបុគ្គលដឹកនាំ ក្នុងកាលខ្លះ រមែងធ្វើបុណ្យ ក្នុងកាលខ្លះ រមែងធ្វើបាប ។ម្យ៉ាងទៀត កាលណាបុគ្គលពាលនោះដឹងធម៌ ហើយនឹងត្រាស់ដឹងសច្ចៈទាំងឡាយ កាលនោះ បុគ្គលនោះ នឹងស្ងប់រម្ងាប់ ព្រោះអវិជ្ជាស្ងប់ហើយ ត្រាច់ទៅ ដូច្នេះ ។

នេះជាកថាពិស្តារ ក្នុងបទថា **អវិជ្ជាបច្ចយា សង្ខារា** ។

## និទ្ទេសនៃអវិជ្ជាជាបច្ច័យនៃសង្ខារ ចប់

# វិញ្ញាណនិទ្ទេស

[ ៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ចក្ខុវិញ្ញាណំ** ជាដើម ក្នុងនិទ្ទេសនៃបទថា **សង្ខារប្បច្ចយា វិញ្ញាណំ** ដូចតទៅ

ចក្ខុវិញ្ញាណមាន ២ យ៉ាង ជាកុសលវិបាក ១ អកុសលវិបាក ១ ។ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ និងកាយវិញ្ញាណក៏មាន ២ យ៉ាងដូចគ្នា ( ហៅថា ទ្វិបញ្ចវិញ្ញាណ ១០ ) ចំណែកមនោវិញ្ញាណ មាន ២២ គឺមនោធាតុដែលជាកុសល និងអកុសលវិបាក ២ អហេតុកមនោវិញ្ញាណធាតុ ៣ សហេតុកកាមាវចរវិបាកចិត្ត ៨ រូបាវចរវិបាកចិត្ត ៥ អរូបាវចរវិបាកចិត្ត ៤ ។

លោកិយវិញ្ញាណទាំងអស់មាន ៣២ ដែលសង្គ្រោះដោយវិញ្ញាណ ៦ យ៉ាងនោះ ដោយប្រការដូច្នេះ ចំណែកលោកុត្តរវិញ្ញាណទាំងឡាយ មិនគួរក្នុងវដ្តកថា ព្រោះហេតុនោះ ទើបមិនកាន់យក ។

ក្នុងនិទ្ទេសសង្ខារជាបច្ច័យដល់វិញ្ញាណនោះ បើមានពាក្យសួរថា សេចក្តីនេះ គប្បីពោលបានដូចម្តេច ថាវិញ្ញាណមានប្រការតាមដែលពោលមកនេះ រមែងមាន ព្រោះសង្ខារជាបច្ច័យ ឆ្លើយថា ដឹងបានព្រោះកាលមិនមានកម្មដែលសាង វិបាកក៏មិនមាន ។ ពិតហើយ វិញ្ញាណនេះជាវិបាក វិបាករមែងមិនកើត ព្រោះមិនមានកម្មដែលសាង បើគប្បីកើតសោត វិបាកទាំងអស់ក៏គប្បីកើតដល់សត្វគ្រប់ពួក តែមិនកើតឡើយ ព្រោះហេតុនោះ សេចក្តីនេះក៏គប្បីជ្រាបបានថា វិញ្ញាណនេះ រមែងមាន ព្រោះសង្ខារជាបច្ច័យ ដូច្នេះ ។

បើមានពាក្យសួរថា វិញ្ញាណណា មានព្រោះសង្ខារណាជាបច្ច័យ

ធ្វើយថា វិញ្ញាណ ១៦ ដួង គឺចក្ខុវិញ្ញាណជាដើម ដែលជាកុសលវិបាក ៥ ដួង មនោធាតុដែលជាកុសលវិបាក ១ មនោវិញ្ញាណធាតុ ២ ដួង កាមាវចរមហាវិបាក ៨ ដួង មានព្រោះបុញ្ញាភិសង្ខារដែលជាកាមាវចរជាបច្ច័យ ។

ដូចព្រះតម្រាស់ថា ចក្ខុវិញ្ញាណជាវិបាក ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ កើតឡើងហើយ ព្រោះហេតុបានធ្វើ បានសន្សំ នូវកម្មជាកាមាវចរកុសល សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ ក៏កើតឡើងដូចគ្នា ។ មនោធាតុ ជាកុសលវិបាក កើតឡើងហើយ ។ មនោវិញ្ញាណធាតុជាវិបាក ប្រកបដោយសោមនស្ស កើតឡើងហើយ មនោវិញ្ញាណធាតុជាវិបាក ប្រកបដោយឧបេក្ខា កើតឡើងហើយ មនោវិញ្ញាណធាតុជាវិបាក ប្រកបដោយសោមនស្ស ប្រកបដោយញាណ កើតឡើងហើយ ប្រកបដោយសោមនស្ស ប្រកបដោយញាណ ប្រកបដោយសង្ខារ ប្រកបដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសង្ខារ ប្រកបដោយឧបេក្ខា ប្រកបដោយញាណ ប្រកបដោយឧបេក្ខា ប្រកបដោយញាណ ប្រកបដោយសង្ខារ ប្រកបដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ ដូច្នេះ ។

ម្យ៉ាងទៀត រូបាវចរវិបាកចិត្ត ៥ កើតព្រោះបុញ្ញាភិសង្ខារ ដែលជារូបាវចរជាបច្ច័យ ដូចព្រះតម្រាស់ថា ពួកធម៌ជាកុសលទាំងនេះ ជាវិបាក ព្រោះហេតុបានធ្វើ បានសន្សំ នូវកម្មជារូបាវចរកុសលនោះឯង បានស្ងាត់ចាក

កាមទាំងឡាយ ។បេ។ បានដល់ បឋមជ្ឈាន ។បេ។ បានដល់ បញ្ចមជ្ឈាន ក៏កើតមាន ដូច្នេះ ។

វិញ្ញាណមាន ២១ ដួង មានព្រោះបុញ្ញាភិសង្ខារជាបច្ច័យដោយប្រការ ដូច្នេះ ។

ម្យ៉ាងទៀត វិញ្ញាណ ៧ គឺចក្ខុវិញ្ញាណជាដើម ៥ ដួង អកុសលវិបាកមនោធាតុ ១ ដួង មនោវិញ្ញាណធាតុ ១ ដួង មានព្រោះអបុញ្ញាភិសង្ខារជាបច្ច័យ ដូចព្រះតម្រាស់ថា ចក្ខុវិញ្ញាណជាវិបាក កើតឡើងហើយ ព្រោះហេតុបានធ្វើ បានសន្សំ នូវកម្មជាអកុសល សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោធាតុជាវិបាក មនោវិញ្ញាណធាតុជាវិបាក កើតឡើងហើយ ដូច្នេះ ។

វិញ្ញាណ ៤ គឺអរូបាវចរវិបាកចិត្ត ៤ ដួង មានព្រោះអានេញ្ជាភិសង្ខារជាបច្ច័យ ដូចព្រះតម្រាស់ថា ពួកធម៌ជាកុសលទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានសន្សំ នូវកម្មជាអរូបាវចរកុសលនោះឯង ព្រោះកន្លងនូវពួករូបសញ្ញា ដោយប្រការទាំងពួង ប្រកបដោយអាកាសានញ្ចាយតនសញ្ញា ។បេ។ ប្រកបដោយវិញ្ញាណញ្ចាយតនសញ្ញា ។បេ។ ប្រកបដោយអាកិញ្ចញ្ញាយតនសញ្ញា ។បេ។ ប្រកបដោយនេវសញ្ញានាសញ្ញាយតនសញ្ញា លះបង់នូវសុខផង ។បេ។ បានដល់ ចតុត្ថជ្ឈាន ក៏កើតមាន ដូច្នេះ ។

វិញ្ញាណណាមានព្រោះសង្ខារជាបច្ច័យ បណ្ឌិតជ្រាបវិញ្ញាណនោះតាមដែលពណ៌នាមកដូច្នេះហើយ ឥឡូវនេះ គប្បីជ្រាបបវត្តិ គឺការប្រព្រឹត្តទៅរបស់

វិញ្ញាណនោះដូចតទៅ

ពិតហើយ វិញ្ញាណទាំងអស់នេះ រមែងប្រព្រឹត្តទៅពីរយ៉ាង ដោយអំណាចបវត្តិកាល និងបដិសន្ធិកាល ។ ក្នុងវិញ្ញាណទាំងពីរនោះ ទ្វិបញ្ចវិញ្ញាណ ១០ មនោធាតុ ២ អហេតុកមនោវិញ្ញាណធាតុ ដែលសហគតៈដោយសោមនស្ស១ រួមជា១៣ រមែងប្រព្រឹត្តទៅក្នុងបវត្តិកាល ក្នុងបញ្ចវោការភពប៉ុណ្ណោះ វិញ្ញាណដ៏សេស ១៩ រមែងប្រព្រឹត្តទៅក្នុងបវត្តិកាលខ្លះ ក្នុងបដិសន្ធិកាលខ្លះ តាមគួរក្នុងភពទាំង ៣ ។ សេចក្ដីនេះ ដូចម្ដេច ។

វិញ្ញាណ ៥ មានចក្ខុវិញ្ញាណជាដើម ដែលជាកុសលវិបាក សម្រាប់បុគ្គលដែលកើតដោយកុសលវិបាក ឬអកុសលវិបាក បុគ្គលមានឥន្ទ្រិយដែលចូលដល់ការចាស់ដោយជុំវិញតាមលំដាប់ ប្រារព្ធរូបារម្មណ៍ជាដើម ដែលជាឥដ្ឋារម្មណ៍ក្ដី ដែលជាឥដ្ឋមជ្ឈត្តារម្មណ៍ក្ដី ដែលមកកាន់គន្លងនៃចក្ខុទ្វារជាដើម អាស្រ័យបសាទ មានចក្ខុជាដើម ទើបឲ្យសម្រេចទស្សនកិច្ច សវនកិច្ច ឃាយនកិច្ច សាយនកិច្ច ផុស្សនកិច្ច ប្រព្រឹត្តទៅ ។ វិញ្ញាណ ៥ ដែលជាអកុសលវិបាក ក៏ដូចគ្នា ។ វិញ្ញាណ ៥ ដែលជាអកុសលវិបាកទាំងនោះ មានរូបារម្មណ៍ជាដើម ដែលជាអនិដ្ឋារម្មណ៍ក្ដី ដែលជាអនិដ្ឋមជ្ឈត្តារម្មណ៍ក្ដី ត្រឹមតែម្យ៉ាង ។ សេចក្ដីនេះប៉ុណ្ណោះដែលប្លែកគ្នា ។ ម្យ៉ាងទៀត វិញ្ញាណទាំង ១០ នេះ មានទ្វារ អារម្មណ៍ វត្ថុ និងឋានៈ ដែលពិតប្រាកដ និងមានកិច្ចដែលពិតប្រាកដដូចគ្នា ។

បន្ទាប់អំពីនោះ មនោធាតុដែលជាកុសលវិបាក ក្នុងលំដាប់នៃចក្ខុវិញ្ញាណ

ជាដើម ដែលជាកុសលវិបាក ប្រារព្ធអារម្មណ៍នៃចក្ខុវិញ្ញាណជាដើមទាំងនោះឯង អាស្រ័យហទយវត្ថុ ញុំាងសម្បដិច្ឆន្នកិច្ច គឺកិច្ចទទួលអារម្មណ៍ឲ្យសម្រេចប្រព្រឹត្តទៅ មនោធាតុដែលជាអកុសលវិបាក ក្នុងលំដាប់នៃចក្ខុវិញ្ញាណជាដើម ដែលជាអកុសលវិបាក ក៏ដូចគ្នា ។ តែមនោធាតុទាំងពីរ គឺអកុសលវិបាក និងកុសលវិបាក មានទ្វារ និងអារម្មណ៍មិនពិតប្រាកដ មានវត្ថុ និងឋានៈពិតប្រាកដ និងមានកិច្ចពិតប្រាកដ ។

ចំណែកមនោវិញ្ញាណធាតុដែលជាអហេតុកៈ សហគតៈដោយសោមនស្ស ក្នុងលំដាប់នៃមនោធាតុដែលជាកុសលវិបាក ប្រារព្ធអារម្មណ៍របស់មនោធាតុ ដែលជាកុសលវិបាកនោះឯង អាស្រ័យហទយវត្ថុ ញុំាងសន្តីរណកិច្ចឲ្យសម្រេច និងកាត់ផ្តាច់វីថិដោយកវគ្គ ក្នុងទីបំផុតនៃជវនដែលសម្បយុត្តដោយលោភៈដោយច្រើន របស់សត្វក្នុងកាមាវចរ ក្នុងអារម្មណ៍ដែលមានកម្លាំងក្នុងទ្វារ ៦ រមែងប្រព្រឹត្តទៅម្តងខ្លះ ពីរដងខ្លះ ដោយអំណាចតទាលម្ពណៈក្នុងអារម្មណ៍ ដែលជវនទទួលហើយ ។ តែក្នុងការរាប់ ការប្រព្រឹត្តទៅរបស់ចិត្ត ក្នុងតទាលម្ពណៈ ក្នុងទ្វារទាំងអស់ វារៈនៃចិត្តមាន ២ វារៈប៉ុណ្ណោះ ។ ចិត្តនេះ បានឈ្មោះ ២ យ៉ាង គឺតទាលម្ពណៈ និងបិដ្ឋិកវគ្គ មានទ្វារ និងអារម្មណ៍មិនពិតប្រាកដ មានវត្ថុពិតប្រាកដ មានឋានៈ និងកិច្ចមិនពិតប្រាកដ ចិត្ត ១៣ ដួង គប្បីជ្រាបថា រមែងប្រព្រឹត្តទៅក្នុងបវត្តិកាលក្នុងបញ្ចវោការភព ដោយប្រការដូច្នេះ ។

បណ្តាចិត្ត ១៩ ដួងដ៏សេស ចិត្តណាមួយ រមែងមិនប្រព្រឹត្តទៅក្នុង

បដិសន្ធិតាមសមគួររៀងៗ ខ្លួន មិនមាន តែក្នុងបវត្តិកាល មនោវិញ្ញាណធាតុដែលជាអហេតុកៈ ២ ដួង ដែលជាកុសលវិបាក និងអកុសលវិបាក ឲ្យសម្រេចកិច្ច ៤ យ៉ាង គឺសន្តីរណកិច្ច ក្នុងលំដាប់នៃមនោធាតុ ដែលជាកុសលវិបាក ឬអកុសលវិបាកក្នុងទ្វារប្រាំ ១ ជាតទារម្មណកិច្ចក្នុងទ្វារ ៦ ដោយន័យដែលពោលខាងដើមនោះឯង ១ ជាភវង្គកិច្ច ក្នុងកាលផុតទៅអំពីបដិសន្ធិដែលខ្លួនឲ្យហើយ មិនមានចិត្តុប្បាទដែលចូលទៅកាត់នូវភវង្គ ១ និងជាចុតិកិច្ចក្នុងទីបំផុត ១ មានហទយវត្ថុពិតប្រាកដ មានទ្វារ អារម្មណ៍ ឋានៈ និងកិច្ចមិនពិតប្រាកដ ប្រព្រឹត្តទៅ ។

សហេតុកវិបាកចិត្តដែលជាកាមាវចរ ៨ រមែងញុំាងកិច្ច ៣ ឲ្យសម្រេច គឺជាតទារម្មណកិច្ចក្នុងទ្វារ ៦ ដោយន័យដែលពោលក្នុងបវត្តិកាលនោះឯង ១ ជាភវង្គកិច្ច ក្នុងកាលផុតអំពីបដិសន្ធិកិច្ចដែលខ្លួនឲ្យហើយ មិនមានចិត្តុប្បាទ ដែលចូលទៅកាត់នូវភវង្គ ១ និងជាចុតិកិច្ច ក្នុងកាលជាទីបំផុត ១ មានវត្ថុពិតប្រាកដ មានទ្វារ អារម្មណ៍ ឋានៈ និងកិច្ចមិនពិតប្រាកដ ប្រព្រឹត្តទៅ ។

រូបាវចរវិបាកចិត្ត ៥ និងអរូបាវចរវិបាកចិត្ត ៤ រមែងញុំាងកិច្ច ២ យ៉ាង ឲ្យប្រព្រឹត្តទៅ គឺជាភវង្គកិច្ច ក្នុងកាលផុតអំពីបដិសន្ធិកិច្ចជាដើម ឲ្យហើយ មិនមានចិត្តុប្បាទដែលចូលទៅកាត់នូវភវង្គ ១ និងចុតិកិច្ច ក្នុងកាលជាទីបំផុត ១ បណ្តាវិបាកចិត្តទាំង ៩ នោះ រូបាវចរវិបាកចិត្ត មានវត្ថុ និងអារម្មណ៍ពិតប្រាកដ មានឋានៈ និងកិច្ចមិនពិតប្រាកដ ។ អរូបាវចរវិបាកចិត្ត

ក្រៅអំពីនេះ មិនមានវត្ថុ មានអារម្មណ៍ពិតប្រាកដ មានឋានៈ និងកិច្ចមិនពិតប្រាកដប្រព្រឹត្តទៅ ។ វិញ្ញាណ ៣២ រមែងប្រព្រឹត្តទៅ ព្រោះសង្ខារជាបច្ច័យក្នុងបវត្តិកាល ដោយប្រការដូច្នេះ ។ ក្នុងបវត្តិកាលនោះ សង្ខារទាំងនោះរមែងជាបច្ច័យដល់វិញ្ញាណ ៣២ នោះ ដោយកម្មប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ។

ក្នុងវិញ្ញាណ ៣២ ដូងនោះ ទ្រង់ត្រាស់តទារម្មណចិត្ត ១១ ពួកណាវិបាកចិត្តសូម្បី ១ ក្នុងតទារម្មណចិត្ត ១១ ដូងនោះ ជាតទារម្មណចិត្តប្រព្រឹត្តទៅក្នុងរូបកព និងអរូបកព មិនមាន ព្រោះហេតុអ្វី ព្រោះមិនមានពូជ ពិតហើយ ក្នុងរូបភូមិ និងអរូបភូមិនោះ ពូជ គឺបដិសន្ធិ ពោល គឺកាមាវចរវិបាក ដែលឲ្យកើតតទារម្មណកិច្ច ក្នុងបវត្តិកាល ក្នុងអារម្មណ៍មានរូបជាដើម រមែងមិនមាន បើមានអ្នកជំទាស់ថា បើដូច្នោះ ចក្ខុវិញ្ញាណជាដើម ក៏មិនមានប្រាកដក្នុងរូបកពទៅហើយ សូមឆ្លើយថា មិនមែនដូច្នោះឡើយ ព្រោះអានុភាពនៃការប្រព្រឹត្តទៅនៃឥន្ទ្រិយ និងព្រោះចិត្តនិយមក្នុងភាពផ្សេងគ្នានៃទ្វារវីថិ ។

តទារម្មណៈនេះ រមែងមិនប្រព្រឹត្តទៅក្នុងរូបកព និងអរូបកពដោយពិតប្រាកដយ៉ាងណា រមែងមិនជាប់តាមធម៌ ដែលមិនមែនកាមាវចរទាំងអស់ក៏យ៉ាងនោះ ព្រោះហេតុអ្វី ព្រោះធម៌ដែលមិនមែនកាមាវចរ ធ្វើឲ្យតទារម្មណៈ កើតមិនបាន និងព្រោះមិនដូចគ្នានឹងធម៌ ដែលជាតួឲ្យកំណើត ។ ពិតហើយ តទារម្មណៈនោះ ប្រៀបដូចកុមារចេញអំពីផ្ទះ ត្រូវការទៅខាង

ក្រៅ ក៏គោរពម្រាមដៃរបស់ឪពុក ដែលជាអ្នកឲ្យកំណើតរបស់ខ្លួន ឬញាតិដទៃដែលប្រាថ្នានូវប្រយោជន៍ ដូចគ្នានឹងបិតា មិនជាប់តាមអ្នកដទៃ មានរាជបុរសជាដើមទៅឡើយ យ៉ាងណា តទារម្មណៈនេះក៏យ៉ាងនោះ បំណងនឹងចេញចេញទៅខាងក្រៅអំពីអារម្មណ៍ ដែលជាភវង្គ រមែងជាប់តាមកាមាវចរជវនៈប៉ុណ្ណោះ ដែលជាបិតាអ្នកឲ្យកំណើតរបស់ខ្លួន ឬបុគ្គលជាញាតិដូចគ្នានឹងបិតារបស់ខ្លួន ព្រោះជាធម៌មានចំណែកដូចគ្នា រមែងមិនជាប់តាមចិត្តដទៃ គឺមហគ្គតចិត្ត ឬលោកុត្តរចិត្តឡើយ ។

មយ៉ាងទៀត តទារម្មណៈនេះ រមែងមិនជាប់តាមមហគ្គតធម៌ និងលោកុត្តរធម៌ យ៉ាងណា សូម្បីកាមាវចរធម៌ទាំងនេះ ក៏យ៉ាងនោះ កាលណាជាធម៌មានមហគ្គតៈជាអារម្មណ៍ប្រព្រឹត្តទៅ កាលនោះ តទារម្មណៈនេះ ក៏មិនជាប់តាមកាមាវចរធម៌ ដែលមានមហគ្គតៈជាអារម្មណ៍ប្រព្រឹត្តទៅ ព្រោះហេតុអ្វី ព្រោះជាដែនដែលមិនធ្លាប់ស្និទ្ធស្នាល និងព្រោះភាពដែលខ្លួនជាបរិត្តារម្មណ៍ ដោយចំណែកមួយ ។ ពិតហើយ តទារម្មណៈនោះ ប្រៀបដូចកុមារ កាលនឹងជាប់តាមឪពុក ឬញាតិដែលដូចគ្នានឹងបិតាទៅ រមែងជាប់តាមទៅក្នុងទឹកដីដែលធ្លាប់ទៅ មានទ្វារផ្ទះ និងក្នុងរវាងវិថិ ផ្លូវបែកជា ៤ ជាដើមប៉ុណ្ណោះ រមែងមិនទៅតាមបុគ្គលទៅកាន់ព្រៃ ឬលានចម្បាំង យ៉ាងណា តទារម្មណៈក៏យ៉ាងនោះ កាលជាប់តាមកាមាវចរធម៌ទាំងឡាយទៅ ក៏រមែងជាប់តាមធម៌ទាំងនោះ ដែលប្រព្រឹត្តទៅក្នុងទឹកដីដែលធ្លាប់ស្និទ្ធស្នាល មានធម៌ដែលមិនមែនជាមហគ្គតៈជាដើមប៉ុណ្ណោះ មិនជាប់តាម គឺប្រារព្ធ

មហគ្គតធម៌ និងលោកុត្តរធម៌ទាំងនោះទៅឡើយ ។

ព្រោះតទារម្មណៈនោះ លោកពោលថា ជាបរិត្តារម្មណ៍ដោយចំណែកមួយប៉ុណ្ណោះ យ៉ាងនេះថា កាមាវចរវិបាកទាំងអស់ កិរិយាមនោធាតុ អហេតុកកិរិយាមនោវិញ្ញាណធាតុ ដែលសហគតៈដោយសោមនស្ស ធម៌ទាំងនេះ ជាបរិត្តារម្មណ៍ ហេតុនោះ តទារម្មណៈនេះ បណ្ឌិតគប្បីជ្រាបថា មិនជាប់តាមកាមាវចរធម៌ ដែលមានមហគ្គតធម៌ និងលោកុត្តរធម៌ ជាអារម្មណ៍ ដូច្នេះ ។

ម្យ៉ាងទៀត មិនមានប្រយោជន៍អ្វីដោយយុត្តិកថា គឺកថាប្រកបនេះ ព្រោះព្រះអដ្ឋកថាចារ្យពោលក្នុងអដ្ឋកថា ដោយចំណែកមួយប៉ុណ្ណោះថា តទារម្មណចិត្ត ១១ រមែងមិនទទួលតទារម្មណៈ ក្នុងកាលជវនប្រារព្ធនាម និងគោត្រស្មុះទៅ ។ តទារម្មណៈ រមែងមិនបានក្នុងកាលជវនប្រារព្ធបញ្ញត្តិស្មុះទៅ ។ តទារម្មណៈ រមែងមិនបានក្នុងវិបស្សនា ដែលមានត្រៃលក្ខណ៍ជាអារម្មណ៍ ។ តទារម្មណៈ រមែងមិនបានក្នុងពលវិបស្សនាដែលជាវុដ្ឋានគាមិនី ។ តទារម្មណៈ រមែងមិនបានក្នុងកាលជវនដែលប្រារព្ធធម៌ដែលជារូប និងអរូប ស្មុះទៅ ។ តទារម្មណៈ រមែងមិនបានក្នុងធម៌ដែលជាមិច្ឆត្តនិយតៈ ។ តទារម្មណៈ រមែងមិនបានក្នុងធម៌ដែលជាសម្មត្តនិយតៈ ។ តទារម្មណៈ រមែងមិនបានក្នុងកាលជវនប្រារព្ធលោកុត្តរធម៌ ស្មុះទៅ ។ តទារម្មណៈ រមែងមិនបានក្នុងកាលជវនប្រារព្ធអភិញ្ញាញាណ ស្មុះទៅ ។ តទារម្មណៈ រមែងមិនបានក្នុងកាលជវនប្រារព្ធបដិសម្ភិទាញាណ ស្មុះទៅ ។ តទារម្មណៈ រមែង

មិនបានក្នុងកាមាវចរដែលមានអារម្មណ៍ទុព្វល រមែងបានក្នុងអារម្មណ៍ដែលមានកម្លាំងមកកាន់គន្លងក្នុងទ្វារ ៦ ប៉ុណ្ណោះ ។ តទារម្មណៈនោះ កាលបាន រមែងបានក្នុងកាមាវចរតែម្យ៉ាង ឈ្មោះថា តទារម្មណៈក្នុងរូបកព និង អរូបកពនោះ រមែងមិនមាន ដូច្នេះ ។

ម្យ៉ាងទៀត ពាក្យណាដែលខ្ញុំពោលថា បណ្តាចិត្ត ១៩ ដ៏សេស ចិត្តណាមួយ រមែងមិនប្រព្រឹត្តទៅក្នុងបដិសន្ធិ តាមសមគួរដល់ខ្លួន មិនមាន ពាក្យនោះ បុគ្គលណាម្នាក់ ក៏យល់បានដោយលំបាក ព្រោះសង្ខេបពេក ព្រោះហេតុនោះ ដើម្បីសម្តែងន័យដោយពិស្តារនៃពាក្យនោះ ខ្ញុំនឹងពោល ពាក្យសួរថា បដិសន្ធិមានប៉ុន្មាន បដិសន្ធិចិត្តមានប៉ុន្មាន បដិសន្ធិមានក្នុង ភូមិណា ដោយចិត្តណា អារម្មណ៍របស់បដិសន្ធិមានដូចម្តេច ដូច្នេះ ។

ក្នុងបញ្ហាកម្មនោះ វិសជ្ជនាថា បដិសន្ធិរួមទាំងអសញ្ញីបដិសន្ធិ មាន ២០ ប្រភេទ ។ បដិសន្ធិចិត្តមាន ១៩ ដួង មានប្រការដូចពោលហើយនោះ ឯង ។ បណ្តាបដិសន្ធិទាំងនោះ បដិសន្ធិក្នុងអបាយភូមិ រមែងមានដោយ អហេតុកមនោវិញ្ញាណធាតុដែលជាអកុសលវិបាក ១ ដួង បដិសន្ធិចិត្តរបស់ សត្វដែលខ្វាក់អំពីកំណើត ថ្លង់អំពីកំណើត ឆ្កួតអំពីកំណើត បុគ្គលទាំងថ្លង់ ទាំង-គអំពីកំណើត និងជាខ្ទើយជាដើមក្នុងមនុស្សលោក រមែងមានដោយ អហេតុកកុសលវិបាកមនោវិញ្ញាណធាតុ ១ ដួង បដិសន្ធិរបស់បុគ្គលអ្នក មានបុណ្យទាំងឡាយ ក្នុងពួកទេវតាជាន់កាមាវចរ និងក្នុងពួកមនុស្ស រមែង មានដោយសហេតុកមហាវិបាក ៨ ដួង បដិសន្ធិរបស់បុគ្គលអ្នកមានបុណ្យ

ក្នុងរូបព្រហ្ម រមែងមានដោយរូបាវចរវិបាក ៥ ដួង បដិសន្ធិរបស់បុគ្គលអ្នកមានបុណ្យក្នុងអរូបព្រហ្ម រមែងមានដោយអរូបាវចរវិបាក ៤ ដួង ។ បដិសន្ធិរមែងមានក្នុងភូមិណា ដោយចិត្តណា បដិសន្ធិនោះឯង ឈ្មោះថា បដិសន្ធិសមគួរដល់ចិត្តដួងនោះ ។

ពោលដោយសង្ខេប អារម្មណ៍របស់បដិសន្ធិ មាន ៣ គឺ កម្ម ១ កម្មនិមិត្ត ១ គតិនិមិត្ត ១ ។

បណ្ដាអារម្មណ៍ទាំង ៣ នោះ ចេតនាដែលជាកុសល និងអកុសលដែលធ្វើហើយ ឈ្មោះថា **កម្ម** កម្ម រមែងប្រកបវត្ថុណាធ្វើឲ្យជាអារម្មណ៍ វត្ថុនោះ ឈ្មោះថា **កម្មនិមិត្ត** ក្នុងកម្ម និងកម្មនិមិត្តនោះ កាលកម្មដែលសត្វធ្វើទុកក្នុងអតីត សូម្បីក្នុងទីបំផុតនៃសែនកោដិកប្ប កម្មនោះ រមែងមកប្រាកដជាកម្ម ឬជា កម្មនិមិត្តក្នុងខណៈនោះ ។

ក្នុងសេចក្ដីនោះ មានរឿងប្រៀបធៀបរបស់កម្មនិមិត្តដូចតទៅ បានឮថា បុរសឈ្មោះនាយគោបកសីវលី ញុំាងបុគ្គលឲ្យសាងចេតិយ ក្នុងវិហារ ឈ្មោះ តាលបិដ្ឋិកៈ កាលគាត់ដេកលើគ្រែសម្រាប់ស្លាប់ ចេតិយប្រាកដហើយ គាត់កាន់យកចេតិយនោះឯងជានិមិត្ត ធ្វើកាលកិរិយាហើយទៅកើតក្នុងទេវលោក ។

នៅមានការស្លាប់មួយបែបទៀត ឈ្មោះថា **សម្មុឡ្ហកាលកិរិយា** គឺការស្លាប់របស់អ្នកវង្វេង ពិតហើយ កាលបុគ្គលដើរទៅខាងមុខ បុគ្គលយកដាវដ៏មុតកាត់ក្បាលអំពីខាងក្រោយក្ដី បុគ្គលដេកលក់ ត្រូវគេយកដាវដ៏មុត

កាត់ក្បាលក្តី ត្រូវគេសង្កត់ឲ្យលិចទឹកស្លាប់ក្តី ក្នុងកាលបែបនេះ កម្ម ឬ កម្មនិមិត្តណាមួយ ក៏រមែងប្រាកដ ។

នៅមានការស្លាប់ម្យ៉ាងទៀត ឈ្មោះថា **លហុកមរណា** គឺការស្លាប់ដោយរហ័ស ពិតហើយ បុគ្គលយកញញួរវាយរុយដែលទំនៅលើជងពន្លាក ក្នុងកាលបែបនេះ កម្ម និងកម្មនិមិត្ត ក៏រមែងប្រាកដ ម្យ៉ាងទៀត កាលរុយត្រូវញញួរដំយ៉ាងនេះ ភវង្គមិនទាន់ប្តូរមកជាអាវជ្ជនៈតាមកាយទ្វារ រមែងប្តូរមកចំពោះមនោទ្វារាវជ្ជនៈ រំពេចនោះ ជវនក៏ស្ទុះទៅហើយ ធ្លាក់ចុះកាន់ភវង្គ ក្នុងវារៈទី ២ ទើបភវង្គប្តូរមកកាន់អាវជ្ជនៈតាមកាយទ្វារ បន្ទាប់អំពីនោះ វីថិចិត្តទាំងឡាយ គឺកាយវិញ្ញាណ សម្បដិច្ឆន្នៈ សន្តីរណៈ វោដ្ឋព្វនៈ ទើបប្រព្រឹត្តទៅ ជវនក៏ស្ទុះទៅហើយ ធ្លាក់ចុះកាន់ភវង្គ ក្នុងវារៈទី ៣ ភវង្គក៏ប្តូរមកកាន់មនោទ្វារាវជ្ជនៈ លំដាប់នោះ ជវនក៏ស្ទុះទៅ ធ្លាក់ចុះកាន់ភវង្គ រុយរមែងធ្វើកាលកិរិយាក្នុងឋានៈនេះ ។ សេចក្តីនេះ លោកនាំមកដើម្បីអ្វី ដើម្បីសម្តែងថា ឈ្មោះថា អារម្មណ៍របស់អរូបធម៌ទាំងឡាយ ប្រព្រឹត្តទៅរហ័សយ៉ាងនេះ ។

ភាវៈ ( វណ្ណៈ ) ណាមួយប្រាកដក្នុងភូមិ ( ឱកាស ) របស់សត្វដែលនឹងកើតឡើង ឈ្មោះថា **គតិនិមិត្ត** ក្នុងគតិនិមិត្តនោះ កាលត្រូវកើតក្នុងនរក រមែងប្រាកដជាភាវៈដូចគ្នានឹងថ្នាំងលោហៈ កាលនឹងកើតក្នុងមនុស្ស-លោក ឧទរមាតា សំពត់កម្ពល និងយាន រមែងប្រាកដ កាលត្រូវកើតក្នុងទេវលោក ដើមកប្បព្រឹក្ស វិមាន និងសេយ្យនាជាដើម រមែងប្រាកដ

បដិសន្ធិ មានអារម្មណ៍ ៣ យ៉ាង ដោយសង្ខេប គឺកម្ម កម្មនិមិត្ត គតិនិមិត្ត ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត បដិសន្ធិ មានអារម្មណ៍ ៣ យ៉ាង គឺអារម្មណ៍អតីត ១ អារម្មណ៍បច្ចុប្បន្ន ១ អារម្មណ៍ដែលជានវត្តព្វៈ ១ ។

អសញ្ញីបដិសន្ធិ មិនមានអារម្មណ៍ បណ្តាបដិសន្ធិទាំងនោះ វិញ្ញាណញ្ចាយតនបដិសន្ធិ និងនេវសញ្ញានាសញ្ញាយតនបដិសន្ធិ មានអារម្មណ៍ជាអតីតតែម្យ៉ាង កាមាវចរវិបាក ១០ មានអារម្មណ៍ជាអតីតខ្លះ ជាបច្ចុប្បន្នខ្លះ បដិសន្ធិដ៏សេស មានអារម្មណ៍ជានវត្តព្វៈ ( អារម្មណ៍ដែលគប្បីពោលមិនបាន ) ។ បដិសន្ធិដែលកំពុងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៣ ប្រការយ៉ាងនេះ រមែងប្រព្រឹត្តទៅក្នុងលំដាប់នៃចុតិចិត្តដែលជាអតីតារម្មណ៍ ឬមានអតីតនវត្តព្វារម្មណ៍ តែឈ្មោះថា ចុតិចិត្តដែលមានអារម្មណ៍ជាបច្ចុប្បន្នមិនមាន ព្រោះហេតុនោះ គប្បីជ្រាបអាការដែលប្រព្រឹត្តទៅដោយអំណាចសុគតិ និងទុគ្គតិនៃបដិសន្ធិ មានអារម្មណ៍ណាមួយ ក្នុងអារម្មណ៍ ៣ ក្នុងលំដាប់នៃចុតិដែលមានអារម្មណ៍ណាមួយក្នុងអារម្មណ៍ ២ យ៉ាង ។ សេចក្តីនេះដូចម្តេច ។ គឺខាងដើម សម្រាប់បុគ្គលដែលតាំងនៅក្នុងកាមាវចរ សុគតិដែលមានបាបកម្ម បាបកម្មតាមដែលខ្លួនបានសន្សំ ឬកម្មនិមិត្ត រមែងមកកាន់គន្លងមនោទ្វារដល់បុគ្គលដែលដេកលើគ្រែសម្រាប់ស្លាប់ ព្រោះព្រះបាលី ( ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក ) ថា អំពើអាក្រក់ទាំងនោះឯង តែងគ្របដណ្តប់ក្នុងសម័យនោះ ដូច្នេះ ។ ចុតិចិត្តធ្វើកវត្តវិស័យឲ្យជាអារម្មណ៍ រមែងកើត

ឡើងក្នុងលំដាប់នៃជវនវិថិ ដែលមានតទារម្មណៈជាទីបំផុត ឬជវនវិថិសុទ្ធៗ ដែលកើតឡើងប្រារព្ធបាបកម្ម ឬកម្មនិមិត្តនោះ កាលចុតិចិត្តនោះរលត់ហើយ បដិសន្ធិចិត្តដែលទាក់ទងក្នុងទុគ្គតិភូមិ ដែលកម្លាំងនៃកិលេសមិនទាន់កាត់ផ្តាច់ ឲ្យបង្អោនទៅ រមែងកើតឡើង ប្រារព្ធកម្ម ឬកម្មនិមិត្តដែលមកកាន់គន្លងនោះឯង ។ នេះជាបដិសន្ធិមានអារម្មណ៍អតីត បន្តអំពីចុតិដែលមានអារម្មណ៍អតីត ។

ក្នុងមរណសម័យរបស់បុគ្គលដទៃទៀត និមិត្តក្នុងទុគ្គតិភូមិ មានការៈជាអណ្តាតភ្លើងជាដើម ក្នុងនរកជាដើម មកកាន់គន្លងមនោទ្វារដោយអំណាចនៃកម្មតាមដែលពោលហើយ ។ កាលភវង្គចិត្តរបស់បុគ្គលនោះ កើតរលត់អស់ ៦ ដងហើយ វីថិចិត្ត ៣ គឺអាវជ្ជនចិត្ត ១ ដួង ជវនចិត្ត ៥ ដួង ព្រោះមានកម្លាំងខ្សោយ ដ្បិតជិតចំពោះមរណៈ ១ តទារម្មណៈ ២ ដួង ១ រមែងកើតឡើង ប្រារព្ធអារម្មណ៍នោះ បន្ទាប់អំពីនោះ ចុតិចិត្ត ១ ដួង ធ្វើភវង្គវិស័យឲ្យជាអារម្មណ៍កើតឡើង ។ ដោយលំដាប់នៃពាក្យមានប្រមាណប៉ុណ្ណោះ ខណៈចិត្តរមែងកន្លងទៅ ១១ ខណៈ ។ ក្នុងលំដាប់នោះ ទើបបដិសន្ធិចិត្ត កើតឡើងក្នុងអារម្មណ៍ដែលមានអាយុនៃខណៈចិត្ត ដែលនៅសេសសល់ ៥ ខណៈនោះឯង ។ នេះជាបដិសន្ធិមានអារម្មណ៍បច្ចុប្បន្ន បន្តអំពីចុតិមានអារម្មណ៍អតីត ។

ក្នុងមរណសម័យរបស់បុគ្គលដទៃទៀត ហីនារម្មណ៍ មានរាគៈជាដើមជាហេតុ រមែងមកកាន់គន្លងទ្វារ ក្នុងទ្វារ ៥ ណាមួយ ក្នុងទីបំផុតនៃវោដ្ឋព្វនចិត្ត

ដែលកើតឡើងតាមលំដាប់ជវន ៥ ដួង ព្រោះមានកម្លាំងខ្សោយ ជ្រិតជិតចំពោះសេចក្តីស្លាប់ និងតទារម្មណចិត្ត ២ ដួង របស់បុគ្គលនោះ រមែងកើតឡើង បន្ទាប់អំពីនោះ ចុតិចិត្ត ១ ដួង ក៏ធ្វើភវង្គវិស័យឲ្យជាអារម្មណ៍កើតឡើង ដោយពាក្យមានប្រមាណប៉ុណ្ណេះ ខណៈចិត្ត រមែងកន្លងទៅ ១៥ ខណៈ គឺភវង្គចិត្ត ២ ដួង អាវជ្ជនចិត្ត ១ ដួង ទស្សនៈ ១ ដួង សម្បដិច្ឆន្នចិត្ត ១ ដួង សន្តីរណចិត្ត ១ ដួង វោដ្ឋព្វនចិត្ត ១ ដួង ជវនចិត្ត ៥ ដួង តទារម្មណចិត្ត ២ ដួង និងចុតិចិត្ត ១ ដួង ។ ក្នុងលំដាប់នោះ បដិសន្ធិចិត្តក៏កើតឡើងក្នុងអារម្មណ៍ ដែលមានអាយុនៃខណៈចិត្ត ដែលនៅសល់ ១ ខណៈនោះឯង ។ បដិសន្ធិនេះ ក៏មានអារម្មណ៍បច្ចុប្បន្ន បន្តអំពីចុតិមានអារម្មណ៍អតីត ។ នេះជាអាការការប្រព្រឹត្តទៅនៃបដិសន្ធិក្នុងទុគ្គតិភូមិមានអារម្មណ៍អតីត និងបច្ចុប្បន្ន បន្ទាប់អំពីចុតិ ក្នុងសុគតិភូមិដែលមានអារម្មណ៍អតីត ។

ចំណែកកម្មដែលប្រាសចាកទោស ឬកម្មនិមិត្តនោះ រមែងមកកាន់គន្លងមនោទ្វាររបស់បុគ្គលដែលតាំងនៅក្នុងសុគតិភូមិ ដែលមានកម្មដែលប្រាសចាកទោស ដែលសន្សំហើយដោយន័យដែលពោលហើយនោះឯង ព្រោះហេតុនោះ គប្បីតាំងធម៌ដែលជាចំណែកសុក្កបក្ខ ក្នុងធម៌ដែលជាចំណែកកាឡបក្ខហើយជ្រាបពាក្យទាំងអស់ដោយន័យមុននោះឯង នេះជាអាការនៃការប្រព្រឹត្តទៅរបស់បដិសន្ធិក្នុងសុគតិភូមិ ដែលមានអារម្មណ៍អតីត និងបច្ចុប្បន្ន បន្ទាប់អំពីចុតិក្នុងទុគ្គតិភូមិ ដែលមានអារម្មណ៍ជាអតីត ។

ម្យ៉ាងទៀត កម្មដែលប្រាសចាកទោស តាមដែលខ្ជួនសន្សំ ឬកម្មនិមិត្ត រមែងមកកាន់គន្លងមនោទ្វាររបស់បុគ្គល ដែលតាំងនៅក្នុងសុគតិភូមិ ដែលមានកម្មប្រាសចាកទោស ដែលបានសន្សំហើយ បុគ្គលដេកលើគ្រែសម្រាប់ស្លាប់ ដោយមានព្រះបាលីជាដើមថា អំពើល្អទាំងនោះឯង តែងគ្របដណ្តប់ក្នុងសម័យនោះ ដូច្នេះ ។ ឯកម្មដែលប្រាសចាកទោស ឬកម្មនិមិត្តនោះ មកកាន់គន្លងមនោទ្វាររបស់បុគ្គល ដែលមានកម្មប្រាសចាកទោស ដែលជាកាមាវចរ ដែលសន្សំហើយនោះឯង ។ ចំណែកកម្មនិមិត្តតែម្យ៉ាង រមែងមកកាន់គន្លងមនោទ្វាររបស់បុគ្គល ដែលមានមហគ្គតកម្ម ដែលសន្សំហើយ ។ ចុតិចិត្ត ធ្វើកវត្ថុវិស័យឲ្យជាអារម្មណ៍ រមែងកើតឡើងក្នុងលំដាប់នៃជវនវិថិ ដែលមានតទារម្មណៈជាទីបំផុត ឬជវនវិថិសុទ្ធៗ ដែលកើតឡើងប្រារព្ធកម្មប្រាសចាកទោស ឬកម្មនិមិត្តនោះ ។ កាលចុតិចិត្តនោះរលត់ បដិសន្ធិចិត្ត ដែលទាក់ទងក្នុងសុគតិភូមិ ដែលកម្លាំងកិលេសមិនទាន់កាត់ផ្តាច់ ឲ្យបង្អោនទៅ រមែងកើតឡើងប្រារព្ធកម្ម ឬកម្មនិមិត្តដែលមកកាន់គន្លងនោះឯង ។ នេះជាបដិសន្ធិមានអារម្មណ៍អតីត ឬអារម្មណ៍នវត្តព្វៈ បន្ទាប់អំពីចុតិមានអារម្មណ៍អតីត ។

ក្នុងមរណសម័យរបស់បុគ្គលដទៃទៀត សុគតិនិមិត្ត ពោល គឺផ្ទៃមាតាក្នុងមនុស្សលោក ឬឧទ្យាន និងដើមកប្បព្រឹក្សក្នុងទេវលោក រមែងមកកាន់គន្លងមនោទ្វារ ដោយអំណាចកម្មដែលប្រាសចាកទោស ដែលជាកាមាវចរ បដិសន្ធិចិត្ត រមែងកើតឡើងដល់បុគ្គលនោះ ក្នុងលំដាប់នៃចុតិចិត្ត ដោយ

លំដាប់ដែលសម្ដែងក្នុងទុគ្គតិនិមិត្តនោះឯង នេះជាបដិសន្ធិមានអារម្មណ៍ជាបច្ចុប្បន្ន បន្ទាប់អំពីចិត្តមានអារម្មណ៍អតីត ។

ក្នុងមរណសម័យរបស់បុគ្គលដទៃទៀត ពួកញាតិនាំគ្នាពោលថា នែបា នេះជាការបូជាព្រះពុទ្ធ ចូរបាធ្វើដើម្បីប្រយោជន៍ចំពោះខ្លួនបា ចូរបាញុំាងចិត្តឲ្យជ្រះថ្លា ហើយបង្ហាញរូបារម្មណ៍ ដោយអំណាចនៃកម្រងផ្កា ទង់ជ័យ និងទង់ផ្កាលាជាដើម ឬសម្ដែងសទ្ទារម្មណ៍ ដោយអំណាចនៃការស្ដាប់ធម៌ និងតូរ្យតន្ត្រីបូជាជាដើម ឬសម្ដែងគន្ធារម្មណ៍ ដោយអំណាចក្លិនធូប ក្លិនគ្រឿងអប់ដែលក្រអូបជាដើម ឬពោលថា នែបា ចូរបាភ្លក្សទេយ្យធម៌នេះ ដែលគេថ្វាយដើម្បីប្រយោជន៍ដល់បា ហើយសម្ដែងរសារម្មណ៍ ដោយអំណាចនៃទឹកឃ្មុំ និងទឹកអំពៅជាដើម ឬពោលថា នែបា ចូរបាស្ទាបទេយ្យធម៌នេះ ដែលគេប្រគេនដើម្បីប្រយោជន៍ដល់បា ហើយសម្ដែងផោដ្ឋព្វារម្មណ៍ ដោយអំណាចសំពត់ចីនៈ និងសំពត់សោមារៈជាដើម បង្អោនចូលក្នុងទ្វារ ៥ ។ ជវ៍ន ៥ ខណៈ រមែងកើតដល់បុគ្គលនោះ ព្រោះមានកម្លាំងខ្សោយ ដោយគៀកចំពោះសេចក្ដីស្លាប់ ក្នុងទីបំផុតនៃវោដ្ឋព្វនចិត្ត ដែលកើតឡើងតាមលំដាប់ក្នុងរូបារម្មណ៍ជាដើម ដែលមកកាន់គន្លងនោះ និងតទារម្មណចិត្ត ២ ដួង រមែងកើត ។ លំដាប់នោះ ចុតិចិត្ត ១ ដួង ធ្វើកវង្គវិស័យឲ្យជាអារម្មណ៍ កើតឡើង ក្នុងទីបំផុតនៃចុតិចិត្តនោះ នេះជាបដិសន្ធិចិត្ត កើតឡើងក្នុងអារម្មណ៍ ដែលតាំងនៅក្នុងខណៈនៃចិត្ត ១ ដួងនោះឯង ។ នេះក៏ជាបដិសន្ធិមានអារម្មណ៍បច្ចុប្បន្ន បន្ទាប់អំពីចុតិមានអារម្មណ៍អតីត ។

ម្យ៉ាងទៀត ក្នុងមរណសម័យរបស់បុគ្គលដទៃទៀត ដែលតាំងនៅក្នុងសុគតិភូមិដែលបានចំពោះមហគ្គតៈដោយអំណាចនៃឈាន មានបឋវីកសិណជាដើម បណ្ដាកុសលកម្ម កម្មនិមិត្ត គតិនិមិត្ត ដែលជាកាមាវចរណាមួយ ឬនិមិត្ត មានបឋវីកសិណជាដើម ឬមហគ្គតចិត្ត រមែងមកកាន់គន្លងមនោទ្វារ ឬអារម្មណ៍ដែលប្រណីត ដែលមានការកើតឡើងនៃកុសលជាហេតុ រមែងមកកាន់គន្លងចក្ខុទ្វារ ឬសោតទ្វារណាមួយ ។ ក្នុងទីបំផុតនៃវោដ្ឋព្វនចិត្ត ដែលកើតឡើងតាមលំដាប់ជវនចិត្ត ៥ ដួង ព្រោះមានកម្លាំងខ្សោយ ដ្បិតជិតចំពោះមរណៈ រមែងកើតដល់បុគ្គលនោះ ។ តែតទារម្មណចិត្ត រមែងមិនមានដល់ពួកសត្វ ដែលមានមហគ្គតចិត្តជាគតិ ហេតុនោះ ទើបចុតិចិត្ត ១ ដួង ធ្វើកវត្ថុវិស័យឲ្យជាអារម្មណ៍ កើតឡើងក្នុងលំដាប់នៃជវនចិត្តនោះឯង ។ ក្នុងទីបំផុតនៃចុតិចិត្តនោះ រមែងកើតបដិសន្ធិចិត្តដែលមានអារម្មណ៍ណាមួយ ក្នុងអារម្មណ៍ទាំងឡាយតាមដែលប្រាកដ ដែលទាក់ទងក្នុងសុគតិណាមួយ នៃសុគតិរបស់កាមាវចរ ឬមហគ្គតៈ ។ នេះជាបដិសន្ធិ មានអារម្មណ៍អតីត បច្ចុប្បន្ន នវត្តព្វៈណាមួយ បន្ទាប់អំពីចុតិ ដែលមានអារម្មណ៍ជានវត្តព្វៈ ។

គប្បីជ្រាបបដិសន្ធិបន្ទាប់អំពីចុតិក្នុងអរូបភូមិដោយទំនងនេះ ។ នេះជាអាការប្រព្រឹត្តទៅនៃបដិសន្ធិមានអារម្មណ៍អតីត មានអារម្មណ៍នវត្តព្វៈ មានអារម្មណ៍បច្ចុប្បន្ន បន្ទាប់អំពីចុតិក្នុងសុគតិភូមិ មានអារម្មណ៍អតីត និងនវត្តព្វារម្មណ៍ ។

ចំណែកបុគ្គលមានបាបកម្ម ដែលតាំងនៅក្នុងទុគ្គតិភូមិ កម្មក្តី កម្ម-

និមិត្តក្តី គតិនិមិត្តក្តី រមែងមកកាន់គន្លងមនោទ្វារ ដោយន័យដែលពោល ហើយនោះឯង តែអារម្មណ៍ដែលជាហេតុកើតអកុសល រមែងមកកាន់គន្លង បញ្ចទ្វារ ។ លំដាប់នោះ បដិសន្ធិចិត្តរបស់បុគ្គលនោះ ដែលមានអារម្មណ៍ ណាមួយ ក្នុងអារម្មណ៍ទាំង ៣ នោះ ដែលទាក់ទងក្នុងទុគ្គតិភូមិ ក៏កើត ឡើងក្នុងទីបំផុតនៃចុតិចិត្តតាមលំដាប់ ។ នេះជាការប្រព្រឹត្តទៅនៃបដិសន្ធិ មានអារម្មណ៍អតីត និងបច្ចុប្បន្ន បន្ទាប់អំពីចុតិក្នុងទុគ្គតិភូមិ មានអារម្មណ៍ អតីត ដូច្នេះឯង ។ ដោយលំដាប់នៃពាក្យមានប្រមាណប៉ុណ្ណេះ ឈ្មោះថា សម្តែងការប្រព្រឹត្តទៅនៃវិញ្ញាណ ១៩ ដោយអំណាចបដិសន្ធិ ។ ម្យ៉ាងទៀត វិញ្ញាណ ១៩ នោះ

កាលប្រព្រឹត្តទៅក្នុងបដិសន្ធិ រមែងប្រព្រឹត្តទៅដោយកម្ម ២ យ៉ាង
យ៉ាងនេះ និងការផ្សេងគ្នានៃវិញ្ញាណនោះ មានពីរយ៉ាងជាដើម
ដោយការផ្សេងគ្នានៃធម៌ ដែលលាយឡំគ្នាជាដើម ។

ពិតហើយ វិបាកវិញ្ញាណ ១៩ ដូងនេះ កាលប្រព្រឹត្តទៅក្នុងបដិសន្ធិ រមែងប្រព្រឹត្តទៅដោយកម្ម ២ យ៉ាង ដ្បិតថា កម្មដែលឲ្យកំណើតវិបាកវិញ្ញាណ ១៩ ដូងនោះ រមែងជាបច្ច័យដោយនានាខណិកកម្មប្បច្ច័យ និងឧប- និស្សយប្បច្ច័យតាមសមគួរដល់ខ្លួន សេចក្តីនេះ សមដូចព្រះតម្រាស់ ( ក្នុង មហាបដ្ឋាន ) ថា កុសល និងអកុសល ជាបច្ច័យនៃកម្មវិបាក ដោយឧប- និស្សយប្បច្ច័យ ដូច្នេះ ។ កាលវិញ្ញាណនោះប្រព្រឹត្តទៅយ៉ាងនេះ ក៏គប្បីជ្រាប ការផ្សេងគ្នា មាន ២ យ៉ាងជាដើម ដោយការផ្សេងគ្នានៃធម៌ដែលលាយគ្នា

ជាដើម ។ សេចក្តីនេះដូចម្តេច គឺវិញ្ញាណនេះ ទោះបីប្រព្រឹត្តទៅតែម្យ៉ាង ដោយអំណាចបដិសន្ធិ ឈ្មោះថា មាន ២ យ៉ាង ដោយការផ្សេងគ្នានៃធម៌ ដែលលាយឡំគ្នា និងមិនលាយឡំគ្នាជាមួយរូប មាន ៣ យ៉ាង ព្រោះការ ផ្សេងគ្នានៃកាមភព រូបភព អរូបភព មាន ៤ យ៉ាង ដោយអំណាចនៃ កំណើត គឺអណ្ឌជៈ ជលាពុជៈ សំសេទជៈ និងឱបបាតិកៈ មាន ៥ យ៉ាង ដោយអំណាចគតិ មាន ៧ យ៉ាង ដោយអំណាចវិញ្ញាណដ្ឋិតិ មាន ៨ យ៉ាង ( វៀរអសញ្ញីបដិសន្ធិ ) ដោយអំណាចសត្តាវាស ។

បណ្តាវិញ្ញាណទាំងនោះ

វិញ្ញាណដែលលាយឡំជាមួយរូប មាន ២ យ៉ាង ព្រោះការ ផ្សេងគ្នានៃភាវៈ និងក្នុងវិញ្ញាណទាំងពីរនោះ វិញ្ញាណដែលមាន ភាវៈ មាន ២ យ៉ាង ២ ទសកៈខ្លះ ៣ ទសកៈខ្លះ ដោយ កំណត់យ៉ាងទាប កើតព្រមជាមួយវិញ្ញាណ ដែលលាយឡំ ជាមួយរូបដែលជាខាងដើម ។

ពាក្យថា វិញ្ញាណដែលលាយឡំជាមួយរូប មាន ២ យ៉ាង ព្រោះការ ផ្សេងគ្នានៃភាវៈ សេចក្តីថា ពិតហើយ បណ្តាវិញ្ញាណទាំងនោះ បដិសន្ធិ-វិញ្ញាណនោះ លាយឡំដោយរូប កើតឡើងក្នុងភពដទៃអំពីអរូបភព បដិ-សន្ធិវិញ្ញាណនោះ មាន ២ យ៉ាង គឺមានភាវៈ ១ មិនមានភាវៈ ១ ព្រោះ ក្នុងរូបភពកើតឡើង វៀរចាកភាវៈ គឺឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយ ព្រោះក្នុង កាមភព កើតព្រមជាមួយភាវៈ វៀរតែបដិសន្ធិរបស់ខ្ទើយអំពីកំណើត ។

ពាក្យថា ក្នុងវិញ្ញាណទាំង ២ នោះ វិញ្ញាណដែលមានភាវៈ មាន ២ យ៉ាង សេចក្តីថា ក្នុងវិញ្ញាណទាំងនោះ វិញ្ញាណដែលមានភាវៈ ២ យ៉ាង ព្រោះការកើតព្រមជាមួយឥត្ថីភាវៈ ឬបុរិសភាវៈណាមួយនោះឯង ។

ពាក្យថា ទសកៈ ២ ខ្វះ ទសកៈ ៣ ខ្វះ ដោយកំណត់យ៉ាងទាប កើតព្រមជាមួយវិញ្ញាណដែលលាយឡំជាមួយរូបដែលជាខាងដើម សេចក្តីថា ក្នុងវិញ្ញាណ ២ យ៉ាងនេះ វិញ្ញាណដែលលាយឡំជាមួយរូប និងមិនលាយឡំជាមួយរូប បដិសន្ធិវិញ្ញាណដែលលាយឡំជាមួយរូប ដែលជាខាងដើមនេះ ២ ទសកៈ គឺកាយទសកៈ និងវត្ថុទសកៈ ឬ ៣ ទសកៈ គឺវត្ថុទសកៈ កាយទសកៈ ភាវទសកៈ ដោយកំណត់យ៉ាងទាប រមែងកើតឡើងព្រមជាមួយបដិសន្ធិវិញ្ញាណនោះ មិនមានរូបថយចុះជាងនោះ ។

បដិសន្ធិវិញ្ញាណនេះ ដែលមានកំណត់រូបយ៉ាងទាបយ៉ាងនេះ កាលកើតឡើង រមែងកើតឡើង ជាធម្មជាតដែលបានទូវការរាប់ថា ជាកលលៈ ដែលមានប្រមាណប៉ុនតំណក់ប្រេងដែលថ្លា ដូចសប្បិដែលគេយកសរសៃរោមទ្រាយមួយសរសៃជ្រលក់លើកឡើង ក្នុងកំណើតទាំងពីរ ដែលមានឈ្មោះថា អណ្ឌជៈ និងជលាពុជៈ ។ ក្នុងបដិសន្ធិវិញ្ញាណនោះ បណ្ឌិតគប្បីជ្រាបការផ្សេងគ្នានៃការកើតឡើង ដោយអំណាចគតិនៃកំណើតទាំងឡាយ ។

ពិតហើយ បណ្តាការកើតដោយអំណាចនៃគតិទាំងនោះ

កំណើត ៣ ខាងដើម រមែងមិនមានក្នុងនរកផង និងមិនមានក្នុងពួកទេវតាទាំងឡាយផង វៀរកុម្មទេវតា កំណើត ៤ រមែងមានក្នុងគតិ ៣ ។

ក្នុងគាថានោះ ពាក្យថា ផង ក្នុងពាក្យថា ពួកទេវតាទាំងឡាយផង នេះ កំណើត ៣ ខាងដើម គប្បីជ្រាបថា មិនមានក្នុងនិជ្ឈាមតណ្ហិកប្រេត ដូចមិនមានក្នុងនរក និងក្នុងទេវតាទាំងឡាយ វៀរកុម្មទេវតា ព្រោះថា សត្វទាំងនោះ ជាឱបបាតិកកំណើតតែម្យ៉ាង តែកំណើត ៤ មានក្នុងគតិ ៣ ដ៏សេសពោល គឺសត្វតិរច្ឆាន បិត្តិវិស័យ និងមនុស្ស និងពួកកុម្មទេវតា ដែលវៀរខាងដើម ។

បណ្តាកំណើតទាំងនោះ

ក្នុងរូបព្រហ្ម រមែងកើតរូប ៣៩ កលាបៈ ក្នុងសំសេទជកំណើត និងឱបបាតិកកំណើត រមែងកើតរូប ៧០ កលាបៈ ដោយកំណាត់យ៉ាងខ្ពស់ ឬយ៉ាងទាប មាន ៣០ កលាបៈ ។

ក្នុងរូបព្រហ្ម កំណើតជាឱបបាតិកៈ រូប ៣៩ កលាបៈ រមែងកើតព្រមនឹងបដិសន្ធិវិញ្ញាណ ដោយអំណាចនៃកលាបៈ ៤ គឺចក្ខុទសកកលាបៈ សោតទសកកលាបៈ វត្ថុទសកកលាបៈ និងជីវិតនវកកលាបៈ ចំណែកក្នុងសំសេទជកំណើត និងឱបបាតិកកំណើតពួកដទៃ វៀរចាកពួករូបព្រហ្ម រមែងបានរូប ៧០ កលាបៈយ៉ាងខ្ពស់ ដោយអំណាចនៃចក្ខុទសកកលាបៈ សោតទសកកលាបៈ ឃានទសកកលាបៈ ជិវ្ហាទសកកលាបៈ កាយទសកកលាបៈ

ភាវទសកកលាបៈ និងវត្ថុទសកកលាបៈ ។ រូបទាំង ៧០ កលាបៈនោះ រមែងកើតក្នុងពួកទេវតាជានិច្ច ក្នុងរូបដែលជាទសកៈទាំងនោះ គំនររូប ១០ គឺវណ្ណៈ ១ គន្ធៈ ១ រសៈ ១ ឱជា ១ និងធាតុ ៤ គឺដី ទឹក ភ្លើង ខ្យល់ ចក្ខុបសាទ ១ ជីវិតិន្ទ្រិយ ១ ឈ្មោះថា ចក្ខុទសកៈ ។ សោតទសកៈ ជាដើមដ៏សេស ក៏គប្បីជ្រាបយ៉ាងនេះ ។ ម្យ៉ាងទៀត ដោយកំណត់យ៉ាងទាប រូប ៣០ កលាបៈ រមែងកើតព្រមជាមួយបដិសន្ធិវិញ្ញាណ ដោយអំណាច នៃជិវ្ហាទសកកលាបៈ កាយទសកកលាបៈ វត្ថុទសកកលាបៈ ដល់បុគ្គល ខ្វាក់ ថ្លង់អំពីកំណើត ។ បុគ្គលមិនមានឃានបសាទ និងជាខ្ទើយអំពីកំណើត ។ បណ្ឌិតគប្បីជ្រាបការកំណត់ដោយសមគួរ ក្នុងរវាងរូបដែលកំណត់យ៉ាងខ្ពស់ និងយ៉ាងទាប កាលជ្រាបយ៉ាងនេះហើយ

គប្បីកំណត់ដឹងធម្មវិសេសនៃការផ្សេងគ្នា និងមិនផ្សេងគ្នារបស់ ចុតិ និងបដិសន្ធិដោយខន្ធ ដោយអារម្មណ៍ ដោយគតិ ដោយ ហេតុ ដោយវេទនា ដោយបីតិ ដោយវិតក្ក និងដោយវិចារ តទៅ ។

អធិប្បាយថា បដិសន្ធិ ២ យ៉ាងលាយឡំដោយរូប និងមិនលាយឡំ ដោយរូបឯណា ចុតិក្នុងលំដាប់នៃអតីតរបស់បដិសន្ធិនោះឯណា បណ្ឌិតគប្បី ជ្រាបធម៌វិសេសនៃការផ្សេងគ្នា និងមិនផ្សេងគ្នានៃបដិសន្ធិ និងចុតិទាំងនោះ ដោយខន្ធជាដើមទាំងនេះ ។

សួរថា សេចក្តីនេះ ដូចម្តេច ឆ្លើយថា ជួនកាល ខន្ធ ៤ ប៉ុណ្ណោះ

ជាបដិសន្ធិដោយមិនផ្សេងគ្នា សូម្បីដោយអារម្មណ៍ បន្ទាប់ពីចុតិក្នុងអរូបភូមិ ដែលមានខន្ធ ៤ ជួនកាល ជាបដិសន្ធិក្នុងអរូបភូមិ ដែលមានអារម្មណ៍ជាមហគ្គតៈ និងមានអារម្មណ៍ខាងក្នុង បន្ទាប់ពីចុតិដែលមានអារម្មណ៍មិនមែនមហគ្គតៈ និងមានអារម្មណ៍ខាងក្រៅ ។ នេះជាន័យក្នុងអរូបភូមិតែម្យ៉ាង ។ ម្យ៉ាងទៀត ក្នុងកាលខ្លះ ខន្ធ ៥ ជាបដិសន្ធិដែលជាកាមាវចរបន្ទាប់ពីចុតិក្នុងអរូបភូមិ ដែលមានខន្ធ ៤ ក្នុងកាលខ្លះ អរូបក្ខន្ធ ៤ ជាបដិសន្ធិក្នុងអរូបភូមិ បន្ទាប់ពីចុតិក្នុងកាមាវចរ ឬចុតិក្នុងរូបាវចរដែលមានខន្ធ ៥ ។ ដោយអាការយ៉ាងនេះ បដិសន្ធិក៏មានអារម្មណ៍បច្ចុប្បន្ន បន្ទាប់ពីចុតិមានអារម្មណ៍អតីត ។ បដិសន្ធិក្នុងទុគ្គតិណាមួយ បន្ទាប់ពីចុតិក្នុងសុគតិភូមិណាមួយ ។ បដិសន្ធិដែលជាសហេតុកៈ បន្ទាប់ពីចុតិដែលជាអហេតុកៈ ។ បដិ-សន្ធិដែលជាតិហេតុកៈ បន្ទាប់ពីចុតិដែលជាទុហេតុកៈ បដិសន្ធិដែលជាសោមនស្សសហគតៈ បន្ទាប់ពីចុតិដែលជាឧបេក្ខាសហគតៈ ។ បដិសន្ធិដែលមានបីតិ បន្ទាប់ពីចុតិដែលមិនមានបីតិ ។ បដិសន្ធិដែលមានវិតក្កៈ បន្ទាប់ពីចុតិដែលមិនមានវិតក្កៈ ។ បដិសន្ធិដែលមានវិចារ បន្ទាប់ពីចុតិដែលមិនមានវិចារ ។ បដិសន្ធិដែលមានវិតក្កៈ មានវិចារ បន្ទាប់ពីចុតិដែលមិនមានវិតក្កៈ មិនមានវិចារ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីប្រកបតាមគួរ ដោយផ្ទុយគ្នានឹងវិញ្ញាណនោះៗ ចុះ ។

វិញ្ញាណនេះ ត្រឹមតែជាធម៌ដែលមានបច្ច័យដែលបានហើយ រមែងចូលដល់ភពដទៃដោយប្រការដូច្នេះ វិញ្ញាណនោះ មិនមានការ

ឃ្លាតទៅអំពីភពនេះ វៀរហេតុអំពីភពអតីតនោះហើយ វិញ្ញាណ ក៏មិនប្រាកដ ។

ព្រោះហេតុនេះ វិញ្ញាណនេះ មានបច្ច័យដែលបានហើយ ត្រឹមតែជាធម៌អាស្រ័យរូប និងអរូប កាលកើតឡើង ហៅថា រមែងចូលដល់ភពដទៃ វិញ្ញាណនេះ មិនមែនសត្វ មិនមែនជីវៈ ទើបវិញ្ញាណនោះ មិនមានការឈានចាកអតីតភព មកកាន់ភពនេះ វៀរហេតុអំពីអតីតភពនោះហើយ វិញ្ញាណនោះ ក៏មិនប្រាកដក្នុងភពនេះ ខ្ញុំនឹងប្រកាសវិញ្ញាណនេះដោយលំដាប់នៃចុតិ និងបដិសន្ធិរបស់មនុស្ស តាមដែលប្រាកដតទៅ ។

សេចក្តីពិត កាលសត្វជិតចំពោះសេចក្តីស្លាប់ដោយសភាវៈតាមប្រក្រតី ឬដោយសេចក្តីព្យាយាមក្នុងអតីតភព អត់ធន់មិនបានចំពោះការបោមរោមនៃ ( ទុក្ខ ) វេទនា ដែលជិតចំពោះសេចក្តីស្លាប់ ដែលគ្របសង្កត់ដែលកាត់នូវសរសៃ ទី-តនៃអវយវៈតូចធំទាំងពួង ដែលបុគ្គលណាម្នាក់ក៏អត់ធន់មិនបាន កាលសរីរៈទ្រុឌទ្រោមដោយលំដាប់ ដូចស្លឹកត្នោតដែលហាលត្រង់កម្តៅថ្ងៃ កាលចក្ខុន្ទ្រិយជាដើមរលត់ហើយ កាយិន្ទ្រិយ មនិន្ទ្រិយ និងជីវិតិន្ទ្រិយដែលតាំងនៅត្រឹមតែហទយវត្ថុ វិញ្ញាណអាស្រ័យហទយវត្ថុដ៏សេស ក្នុងខណៈនោះ ប្រារព្ធគរុកម្ម អាចិណ្ណកម្ម អាសន្នកម្ម និងកម្មដែលធ្លាប់ធ្វើណាមួយ ពោល គឺសង្ខារដែលមានបច្ច័យនៅសេសសល់ដែលបានហើយ ឬប្រារព្ធអារម្មណ៍ ពោល គឺកម្មនិមិត្ត គតិនិមិត្ត ដែលកម្មនោះឲ្យប្រាកដហើយប្រព្រឹត្តទៅ ។ វិញ្ញាណនោះឯង កាលប្រព្រឹត្តទៅយ៉ាង

នេះ ព្រោះលះតណ្ហា និងអវិជ្ជាមិនទាន់បាន ទើបតណ្ហាឲ្យបង្អោនទៅ ទើបសង្ខារដែលជាសហជាតធម៌ បន្សាត់ទៅក្នុងអារម្មណ៍នោះ ដែលមានទោស ដែលអវិជ្ជាបិទបាំងហើយ វិញ្ញាណនោះ ត្រូវតណ្ហាឲ្យបង្អោនទៅ ត្រូវសង្ខារទាំងឡាយបន្សាត់ទៅ ដោយអំណាចនៃការបន្ត រមែងលះហទយៈដែលជាទីអាស្រ័យ ដែលមានមកអំពីមុន ត្រេកអរក្តី មិនត្រេកអរក្តី នូវហទយៈដែលជាទីអាស្រ័យ ដែលកម្មឲ្យតាំងឡើងដទៃទៀត រមែងប្រព្រឹត្តទៅដោយបច្ច័យទាំងឡាយ មានអារម្មណ៍ជាដើម ដូចបុរសតោងខ្សែត្រង់ដើមឈើត្រើយអាយ ឆ្លងអូរទៅ ដូច្នោះ ។

ម្យ៉ាងទៀត ក្នុងវិញ្ញាណទាំងឡាយនេះ វិញ្ញាណដួងមុន ហៅថា ចុតិ ព្រោះឃ្លាតទៅ ដួងក្រោយ ហៅថា បដិសន្ធិ ព្រោះបន្តភពដទៃជាដើម បដិសន្ធិវិញ្ញាណនោះ បណ្ឌិតគប្បីជ្រាបថា មិនមែនមកអំពីភពមុន មកកាន់ភពនេះ សូម្បីវៀរហេតុ មានកម្ម សង្ខារ គតិ និងអារម្មណ៍ជាដើម អំពីភពមុននោះ ក៏មិនប្រាកដ ។

សំឡេងរំពងជាដើម គប្បីជាឧទាហរណ៍បានក្នុងរឿងនេះ សំឡេង
រំពងនោះ មិនមែនជាសំឡេងតែមួយ មិនមែនជាសំឡេង ដែល
ផ្សេងគ្នាជាមួយសំឡេងដើម ព្រោះទាក់ទងគ្នាដោយការបន្ត ។

ធម៌ដែលកំណត់ដោយសំឡេងរំពង ពន្លឺប្រទីប ស្នាមបោះត្រា និងស្រមោល គប្បីជាឧទាហរណ៍ក្នុងរឿងនេះ គឺក្នុងរឿងដែលវិញ្ញាណនេះ មិនមកអំពីភពមុនកាន់ភពនេះ និងក្នុងរឿងដែលវិញ្ញាណនេះកើតឡើង ព្រោះ

ហេតុដែលទាក់ទងក្នុងអតីតភព ។ ឧបមាដូចសំឡេងរំពង ពន្លឺប្រទីប ស្នាម ត្រា និងស្រមោល មានហេតុ មកត្រឹមតែសំឡេងជាដើម មិនបានចែកគ្នា ទៅយ៉ាងណា ចិត្តនេះក៏យ៉ាងនោះដូចគ្នា ក្នុងឋានៈនេះ ចិត្តនេះ មិនមែនតែ មួយដួង មិនមែនដួងផ្សេងគ្នា ព្រោះទាក់ទងគ្នាដោយការបន្ត ។ ពិតហើយ បើមានការបន្តគ្នាដោយការបន្តភាពតែមួយ គប្បីមានដោយចំណែកមួយសោត ទឹកដោះជូរ ក៏មិនគប្បីកើតអំពីទឹកដោះស្រស់ បើការផ្សេងគ្នា គប្បីមាន ដោយចំណែកមួយសោត ទឹកដោះជូរ ក៏មិនគប្បីមានព្រោះទឹកដោះស្រស់ ជាធំ ។ ធម៌ដែលជាហេតុ និងអាស្រ័យហេតុកើតឡើងទាំងអស់ ក៏មាន ន័យនេះ ។ កាលបើយ៉ាងនេះ គប្បីជាការលុបវោហារនៃលោកទាំងអស់ ចេញ ។ ហើយការលុបវោហាររបស់លោកទាំងអស់នោះ មិនគួរប្រាថ្នា ព្រោះហេតុនោះ ក្នុងរឿងនេះ មិនគួរចូលទៅជិតភាពតែមួយ ឬការផ្សេងគ្នា ដោយចំណែកមួយ ដូច្នេះឯង ។

ក្នុងអធិការនេះ បើមានបុគ្គលសួរថា កាលការមិនឃ្លាតទៅក្នុងភពមុន និងការប្រាកដមានយ៉ាងនេះ ព្រោះខន្ធក្នុងអត្តភាពមនុស្សនេះរលត់ហើយ និងព្រោះកម្មដែលជាបច្ច័យដល់ផល មិនទៅក្នុងទីដែលកើតផលនោះ ផល នោះ គប្បីមានដល់បុគ្គលដទៃ និងគប្បីមានអំពីកម្មដទៃមិនមែនឬ ។ កាល មិនមានបុគ្គលចូលទៅសោយ ផលនោះ គប្បីមានដល់អ្នកណា ព្រោះហេតុ នោះ វិធីនេះមិនល្អ ក្នុងសេចក្តីនោះ ទើបលោកចងគាថានេះថា

ផលណា ក្នុងការបន្ត ផលនេះ មិនមែនមានដល់បុគ្គលដទៃ និង មិនមែនមានអំពីកម្មដទៃ សភាពតាក់តែងពូជទាំងឡាយ ជាគ្រឿងសាធកៈ ក្នុងសេចក្ដីនេះ ។

ពិតហើយ ផល កាលកើតឡើងក្នុងការបន្តគ្នាតែមួយ ព្រោះភាពតែមួយ និងភាពផ្សេងគ្នា ដោយចំណែកមួយ ត្រូវបដិសេធហើយ ក្នុងផលនោះ ទើបមិនមានថា មានដល់បុគ្គលដទៃ ឬមានអំពីកម្មដទៃ ។ ឯសភាវៈតាក់តែងពូជទាំងឡាយ ជាគ្រឿងសាធកៈក្នុងសេចក្ដីនេះ ព្រោះកាលបុគ្គលដាំពូជស្វាយជាដើម ផលផ្សេងៗ ក្នុងកាលតមក ដែលបានបច្ច័យក្នុងការបន្តនៃពូជនោះៗ កាលកើត រមែងមិនកើតអំពីពូជដទៃ រមែងមិនកើតអំពីបច្ច័យគ្រឿងតាក់តែងដទៃ ។ម្យ៉ាងទៀត ពូជទាំងនោះ ឬគ្រឿងតាក់តែងនោះ មិនដល់ឋានៈថាផលបាន ។ គប្បីជ្រាបឧបមេយ្យនេះយ៉ាងនោះ ។ គប្បីជ្រាបសេចក្ដីនេះ ដោយវិជ្ជាសិប្បៈ និងឱសថជាដើម ដែលប្រើប្រកបក្នុងរាងកាយកុមារ ដែលឲ្យផលក្នុងរាងកាយធាត់ធំជាដើមក្នុងកាលតមក ។ ក្នុងពាក្យដែលពោលថា កាលមិនមានបុគ្គលចូលទៅសោយ ផលនោះ គប្បីមានដល់បុគ្គលណា មានអធិប្បាយថា

ការសន្មតថា អ្នកសោយសម្រេចបាន ព្រោះការកើតនៃផល ដូចគ្នានឹងសន្មតថា ដើមឈើរមែងមានផ្លែ ព្រោះការកើតឡើងនៃផល ដូច្នោះ ។

ឧបមាដូចដើមឈើ សត្វលោក រមែងហៅថា រមែងចេញផ្លែ ឬចេញ

ផ្លែហើយ ព្រោះការកើតឡើងនៃផ្លែរបស់ដើមឈើដែលជាចំណែកមួយរបស់ធម្មជាតិ ដែលហៅថាដើមឈើនោះឯងយ៉ាងណា ទេវតា ឬមនុស្ស លោកក៏ហៅថា អ្នកចូលទៅសោយ ឬហៅថា បុគ្គលមានសុខ បុគ្គលមានទុក្ខ ព្រោះការកើតឡើងនៃផល គឺសុខ និងទុក្ខ ដែលរាប់ថា ជាវត្ថុដែលចូលទៅសោយ ដែលជាចំណែកមួយនៃខន្ធទាំងឡាយ ពោល គឺទេវតា និងមនុស្ស ក៏យ៉ាងនោះ ព្រោះហេតុនោះ ទើបក្នុងទីនេះ អត្តណាមួយ ដោយបុគ្គលដទៃដែលឈ្មោះថា អ្នកចូលទៅសោយ មិនមាន ។

បុគ្គលណាគប្បីពោលថា កាលបើដូច្នោះ សង្ខារទាំងនេះ មានក្តី មិនមានក្តី គប្បីជាបច្ច័យដល់ផលបាន ។ បើសង្ខារទាំងនោះមាន វិបាកនៃសង្ខារទាំងនោះក៏គប្បីមាន ក្នុងខណៈនៃការប្រព្រឹត្តទៅនោះឯង ។ បើសង្ខារទាំងនោះមិនមាន សង្ខារក៏គប្បីនាំមកនូវផលជានិច្ច ទាំងមុន និងក្រោយអំពីការប្រព្រឹត្តទៅ ។ បញ្ហាកម្មនោះ គប្បីឆ្លើយយ៉ាងនេះថា

សង្ខារទាំងនេះជាបច្ច័យ ព្រោះជាអ្នកធ្វើ និងមិនមែននាំផល មកឲ្យជានិច្ច ក្នុងសេចក្តីនោះ គប្បីជ្រាបរឿងអ្នកធានាជាដើម ជាឧទាហរណ៍ ។

ពិតហើយ សង្ខារទាំងឡាយ រមែងជាបច្ច័យដល់ផលរបស់ខ្លួន ព្រោះជាអ្នកធ្វើកម្ម មិនមែនព្រោះមាន ឬមិនមាន ដូចព្រះតម្រាស់ ( ក្នុងអភិធម្ម ធម្មសង្គណី ) ថា ចក្ខុវិញ្ញាណជាវិបាក កើតឡើងហើយ ព្រោះហេតុបានធ្វើ បានសន្សំ នូវកម្មជាកាមាវចរកុសល ដូច្នេះជាដើម ។ និងជាបច្ច័យដល់ផល

របស់ខ្លួនតាមគួរ មិនមែននាំផលមកឲ្យជដែលទៀតឡើយ ព្រោះមានវិបាកដែលឲ្យផលហើយ ។ ក្នុងការអធិប្បាយសេចក្តីនេះឲ្យជាក់ច្បាស់ គប្បីនាំរឿងអ្នកជានាជាឧទាហរណ៍ដូច្នេះថា មានអ្នកជានាណាម្នាក់ក្នុងលោក ដើម្បីប្រគល់ប្រយោជន៍ដល់បុគ្គលណាម្នាក់ រមែងទិញទំនិញខ្លះ រមែងខ្ចីខ្លះ ការធ្វើនោះ ក៏ត្រឹមតែជាអ្នកជានានោះឯង ជាបច្ច័យក្នុងការប្រគល់ប្រយោជន៍នោះជាដើម កិរិយាមាន ឬមិនមាន ក៏មិនមែន ។ ក្រោយអំពីការប្រគល់ប្រយោជន៍នោះជាដើមហើយ បុគ្គលនោះ មិនជាអ្នកជានាទៀតឡើយ ព្រោះហេតុអ្វី ព្រោះបានធ្វើការប្រគល់ហើយយ៉ាងណា សង្ខារទាំងឡាយក៏យ៉ាងនោះ រមែងជាបច្ច័យដល់ផលរបស់ខ្លួន ព្រោះខ្លួនធ្វើ និងរមែងមិននាំផលជាងការឲ្យផលតាមគួរ ដូច្នេះ ។

ដោយពាក្យប្រមាណប៉ុណ្ណេះ ឈ្មោះថា ការសម្តែងនូវការប្រព្រឹត្តទៅនៃបដិសន្ធិវិញ្ញាណ ដែលកំពុងប្រព្រឹត្តទៅទាំងពីរយ៉ាង ដោយអំណាចធម៌ដែលលាយឡំដោយរូប និងមិនលាយឡំដោយរូប ព្រោះសង្ខារជាបច្ច័យ ។

ឥឡូវនេះ ដើម្បីការពារការវង្វេងក្នុងវិញ្ញាណ ៣២ នោះឯង
បណ្ឌិតគប្បីជ្រាបសង្ខារទាំងនោះថា ជាបច្ច័យដល់វិញ្ញាណពួកណា និងជាបច្ច័យដោយប្រការណា ដោយអំណាចនៃបដិ-
សន្ធិកាល និងបវត្តិកាល ក្នុងឋានៈទាំងឡាយ មានភពជាដើម ។

ក្នុងគាថានោះ មានអធិប្បាយថា ធម៌ទាំងនេះ គឺភព ៣ កំណើត ៤ គតិ ៥ វិញ្ញាណដ្ឋិតិ ៧ សត្តាវាស ៩ ឈ្មោះថា ភពជាដើម ក្នុងភព

ជាដើមនេះ សង្ខារទាំងនេះ ជាបច្ច័យដល់វិបាកវិញ្ញាណពួកណា និងជាបច្ច័យដោយប្រការណា ក្នុងបដិសន្ធិកាល និងបវត្តិកាល បណ្ឌិតគប្បីជ្រាបដោយប្រការនោះ ។

បណ្ដាសង្ខារទាំងនោះ គប្បីជ្រាបវិនិច្ឆ័យបុញ្ញាភិសង្ខារមុន ។ បុញ្ញាភិសង្ខារដែលចែកដោយចេតនា ៨ ក្នុងកាមាវចរ បានបច្ច័យ ២ គឺនានាខណិកកម្មប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ដល់វិបាកវិញ្ញាណ ៩ ដួង ក្នុងបដិសន្ធិក្នុងកាមសុគតិភូមិ ដោយមិនផ្សេងគ្នា ។ បុញ្ញាភិសង្ខារដែលចែកជាកុសលចេតនា ៥ ក្នុងរូបាវចរ ក៏ជាបច្ច័យដល់វិបាកវិញ្ញាណ ៥ ក្នុងបដិសន្ធិក្នុងរូបភពក៏ដូចគ្នា តែបុញ្ញាភិសង្ខារដែលជាកាមាវចរ មានប្រភេទតាមដែលពោលហើយ ជាបច្ច័យ ២ យ៉ាង ដល់បរិត្តវិបាកវិញ្ញាណ ៧ ដួង វៀរអហេតុកមនោវិញ្ញាណធាតុដែលសហគតៈដោយឧបេក្ខា ដោយន័យតាមដែលពោលហើយនោះឯង ក្នុងកាមសុគតិភូមិក្នុងបវត្តិកាល មិនមែនក្នុងបដិសន្ធិកាល ។ បុញ្ញាភិសង្ខារនោះឯង ជាបច្ច័យក្នុងបវត្តិកាល មិនមែនក្នុងបដិសន្ធិកាល ដល់វិបាកវិញ្ញាណ ៥ ដួង ក្នុងរូបភព យ៉ាងនោះដូចគ្នា ។

ក្នុងកាមភពទុគ្គតិភូមិ បុញ្ញាភិសង្ខារក៏ជាបច្ច័យដល់បរិត្តវិបាកវិញ្ញាណទាំង ៨ ក្នុងបវត្តិកាល មិនមែនក្នុងបដិសន្ធិកាលយ៉ាងនោះដូចគ្នា ក្នុងកាមភពទុគ្គតិភូមិនោះ បុញ្ញាភិសង្ខារនោះជាបច្ច័យ ដោយការជួបឥដ្ឋារម្មណ៍ក្នុងនរក ក្នុងកាលត្រាច់ទៅក្នុងនរកជាដើមរបស់ព្រះមហាមោគ្គល្លានត្ថេរ តែឥដ្ឋារម្មណ៍ រមែងបានក្នុងពួកសត្វតិរច្ឆាន និងក្នុងពួកនាគ គ្រុឌ និងប្រេត

ដែលមានឫទ្ធិច្រើននោះឯង បុញ្ញាភិសង្ខារនោះឯង ជាបច្ច័យក្នុងបវត្តិកាល និងក្នុងបដិសន្ធិកាលដល់កុសលវិបាកវិញ្ញាណទាំង ១៦ ដួង ក្នុងកាមសុគតិភូមិ ។ ពោលដោយមិនប្លែកគ្នា បុញ្ញាភិសង្ខារ ជាបច្ច័យក្នុងបវត្តិកាល និងបដិសន្ធិកាលដល់វិបាកវិញ្ញាណ ១០ ដួង ក្នុងរូបភពយ៉ាងនោះដូចគ្នា ។

អបុញ្ញាភិសង្ខារ ចែកដោយអកុសលចេតនា ១២ យ៉ាង ក្នុងកាមភព ទុគ្គតិភូមិ ជាបច្ច័យដូចគ្នានោះឯង ក្នុងបដិសន្ធិកាល មិនជាបច្ច័យក្នុងបវត្តិកាល ដល់វិញ្ញាណ ១ ដួង ជាបច្ច័យក្នុងបវត្តិកាល មិនជាបច្ច័យក្នុងបដិសន្ធិកាល វិញ្ញាណ ៦ ដួង ជាបច្ច័យទាំងក្នុងបវត្តិកាល និងបដិសន្ធិកាលយ៉ាងនោះឯង ដល់អកុសលវិបាកវិញ្ញាណ ៧ ដួង តែក្នុងកាមភពសុគតិភូមិ ជាបច្ច័យដូចគ្នានោះឯងក្នុងបវត្តិកាល មិនជាបច្ច័យក្នុងបដិសន្ធិកាល ដល់អកុសលវិបាកវិញ្ញាណ ៧ ដួងនោះ ។ ជាបច្ច័យក្នុងបវត្តិកាល មិនជាបច្ច័យក្នុងបដិសន្ធិកាលយ៉ាងនោះឯង ដល់វិញ្ញាណ ៤ ដួងក្នុងរូបភព ។ អបុញ្ញាភិសង្ខារនោះឯង ជាបច្ច័យដល់វិញ្ញាណក្នុងកាមាវចរ ដោយអំណាចការឃើញរូប ស្តាប់សំឡេងដែលមិនគួរប្រាថ្នា តែឈ្មោះថា រូបជាដើម ដែលមិនគួរប្រាថ្នាក្នុងព្រហ្មលោក មិនមាន ក្នុងកាមាវចរទេវលោក ក៏មិនមានរូបជាដើម ដែលមិនគួរប្រាថ្នាដូចគ្នា ។

អានេញ្ជាភិសង្ខារជាបច្ច័យដូចគ្នានោះឯង ក្នុងបវត្តិកាល និងបដិសន្ធិកាល ដល់វិបាកវិញ្ញាណ ៤ ដួង ក្នុងអរូបភព ។

ម្យ៉ាងទៀត ពោលដោយកុសល និងអកុសលក្នុងកាមាវចរ កាយសង្ខារ

ដែលចែកដោយចេតនាទាំង ២០ ដោយសព្វសង្គាហិកន័យ ជាបច្ច័យ ២ យ៉ាង ដោយនានាខណិកកម្មប្បច្ច័យ និងដោយឧបនិស្សយប្បច្ច័យក្នុងបដិសន្ធិកាល ដល់វិបាកវិញ្ញាណ ១០ ក្នុងកាមភព ។ កាយសង្ខារនោះឯង ជាបច្ច័យយ៉ាងនោះដូចគ្នាក្នុងបវត្តិកាល មិនមែនក្នុងបដិសន្ធិកាល ដល់វិបាកវិញ្ញាណ ១៣ ក្នុងកាមភព ដល់វិបាកវិញ្ញាណ ៩ ក្នុងរូបភព ។ កាយសង្ខារនោះឯង ជាបច្ច័យយ៉ាងនោះ ទាំងក្នុងបវត្តិកាល និងបដិសន្ធិកាលដល់វិបាកវិញ្ញាណ ២៣ ក្នុងកាមភព សូម្បីក្នុងវចីសង្ខារ ក៏ន័យនេះដូចគ្នា ។

ចំណែកចិត្តសង្ខារដែលចែកជាចេតនា ២៩ ជាបច្ច័យយ៉ាងនោះឯង ក្នុងបដិសន្ធិកាល មិនមែនក្នុងបវត្តិកាល ដល់វិបាកវិញ្ញាណ ១៩ ដួង ក្នុងភពទាំង ៣ ។ ចិត្តសង្ខារនោះឯង ជាបច្ច័យក្នុងបវត្តិកាល មិនមែនក្នុងបដិសន្ធិកាល ដល់វិបាកវិញ្ញាណ ២២ គឺដល់វិបាកវិញ្ញាណ ១៣ ក្នុងកាមភព និងដល់វិបាកវិញ្ញាណ ៩ ក្នុងរូបភព តាមដែលពោលមកហើយខាងដើមក្នុងភពទាំងពីរ ម្យ៉ាងទៀត ចិត្តសង្ខារនោះ ជាបច្ច័យយ៉ាងនោះឯង ទាំងក្នុងបវត្តិកាល និងបដិសន្ធិកាល ដល់វិបាកវិញ្ញាណ ៣២ ក្នុងភព ៣ ។

បណ្ឌិតគប្បីយល់សង្ខារទាំងនោះថា ជាបច្ច័យដល់វិបាកវិញ្ញាណពួកណា និងជាបច្ច័យដោយប្រការណា ដោយអំណាចនៃបដិសន្ធិកាល និងបវត្តិកាល ក្នុងភពទាំងឡាយយ៉ាងនេះ សូម្បីក្នុងកំណើតជាដើម ក៏គប្បីជ្រាបដោយន័យនេះដូចគ្នា ។

ក្នុងនិទ្ទេសនៃសង្ខារ ជាបច្ច័យដល់វិញ្ញាណនោះ ពាក្យដែលប្រកាស

ល្មមជាមាតិកាតាំងអំពីដើមមានដូចតទៅនេះ បណ្ដាសង្ខារទាំងនេះ បុញ្ញាភិ-សង្ខារឲ្យបដិសន្ធិ ហើយញ៉ាំងវិបាកទាំងអស់របស់ខ្លួនឲ្យកើត ក្នុងភពទាំងពីរយ៉ាងនេះដូចគ្នា រមែងឲ្យបដិសន្ធិ ហើយញ៉ាំងវិបាកទាំងឡាយរបស់ខ្លួនឲ្យកើតក្នុងកំណើត ៤ មានអណ្ឌជៈជាដើម ក្នុងគតិ ២ ពោល គឺទេវគតិនិងមនុស្សគតិ ក្នុងវិញ្ញាណដ្ឋិតិ ៤ ពោល គឺមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ១ មានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ១ មានកាយដូចគ្នា មានសញ្ញាផ្សេងគ្នា ១ មានកាយដូចគ្នា មានសញ្ញាដូចគ្នា ១ ដោយអំណាចនៃមនុស្សទាំងឡាយ និងនៃបឋមជ្ឈានភូមិ ទុតិយជ្ឈានភូមិ និងតតិយជ្ឈាន-ភូមិ ។ មយ៉ាងទៀត បុញ្ញាភិសង្ខារនេះឲ្យបដិសន្ធិ ញ៉ាំងវិបាកទាំងអស់របស់ខ្លួនឲ្យកើតក្នុងសត្តាវាស ៩ ប៉ុណ្ណោះ ព្រោះថា ក្នុងអសញ្ញសត្តាវាសបុញ្ញាភិសង្ខារនេះ រមែងតាក់តែងត្រឹមតែរូបប៉ុណ្ណោះ ព្រោះហេតុនោះ ទើបបុញ្ញាភិសង្ខារនេះ ជាបច្ច័យទាំងក្នុងបដិសន្ធិកាល និងបវត្តិកាល ដល់វិបាក-វិញ្ញាណ ២១ ដួង តាមគួរដល់ការកើតឡើង ក្នុងភព ២ កំណើត ៤ គតិ ២ វិញ្ញាណដ្ឋិតិ ៤ និងសត្តាវាស ៤ ទាំងនោះ ដោយន័យតាមដែលពោលហើយនោះឯង ។

មយ៉ាងទៀត អបុញ្ញាភិសង្ខារ រមែងឲ្យវិបាក ដោយអំណាចបដិសន្ធិក្នុងកាមភព ១ តែមយ៉ាងប៉ុណ្ណោះ ក្នុងកំណើត ៤ ក្នុងគតិ ៣ ដ៏សេស ក្នុងវិញ្ញាណដ្ឋិតិ ១ គឺដែលមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា និងក្នុងសត្តាវាស ១ ដូចគ្នានឹងវិញ្ញាណដ្ឋិតិនោះឯង ព្រោះហេតុនោះ ទើបអបុញ្ញាភិសង្ខារនេះ

ជាបច្ច័យទាំងក្នុងបដិសន្ធិកាល និងក្នុងបវត្តិកាលដល់វិបាកវិញ្ញាណ ៧ ក្នុងភព ១ កំណើត ៤ គតិ ៣ វិញ្ញាណដ្ឋិតិ ១ និងក្នុងសត្តាវាស ១ ដោយន័យដែលពោលហើយនោះឯង ។

ឯអានេញ្ជាភិសង្ខាររមែងឲ្យវិបាក ដោយអំណាចបដិសន្ធិ ក្នុងអរូបភពតែម្យ៉ាង ក្នុងឱបបាតិកកំណើត ១ ក្នុងទេវគតិ ១ ក្នុងវិញ្ញាណដ្ឋិតិ ៣ មានអាកាសានញ្ចាយតនៈជាដើម ក្នុងសត្តាវាស ៤ មានអាកាសានញ្ចាយតនៈជាដើម ព្រោះហេតុនោះ ទើបអានេញ្ជាភិសង្ខារនេះ ជាបច្ច័យទាំងក្នុងបដិសន្ធិកាល និងក្នុងបវត្តិកាល ដល់វិបាកវិញ្ញាណ ៤ ដួង ក្នុងភព ១ ប៉ុណ្ណោះ ក្នុងកំណើត ១ ក្នុងគតិ ១ ក្នុងវិញ្ញាណដ្ឋិតិ ៣ ក្នុងសត្តាវាស ៤ តាមន័យដែលពោលហើយនោះឯង ។

កាយសង្ខាររមែងឲ្យបដិសន្ធិ ឲ្យវិបាករបស់ខ្លួនទាំងអស់កើតឡើងក្នុងកាមភព ១ ក្នុងកំណើត ៤ ក្នុងគតិ ៥ ក្នុងវិញ្ញាណដ្ឋិតិ ២ និងក្នុងសត្តាវាស ២ ព្រោះហេតុនោះ ទើបកាយសង្ខារនោះ ជាបច្ច័យយ៉ាងនោះឯង ទាំងក្នុងបដិសន្ធិកាល និងបវត្តិកាល ដល់វិបាកវិញ្ញាណ ២៣ ដួង ក្នុងភព ១ ក្នុងកំណើត ៤ ក្នុងគតិ ៥ ក្នុងវិញ្ញាណដ្ឋិតិ ២ និងក្នុងសត្តាវាស ២ ។ ក្នុងវចីសង្ខារ ក៏ន័យនេះដូចគ្នា ។

ចំណែកចិត្តសង្ខារ វៀរសត្តាវាស ( អសញ្ញីសត្វ ) តែម្យ៉ាង នឹងមិនឲ្យផលក្នុងទីណាមិនមាន ព្រោះហេតុនោះ ទើបចិត្តសង្ខារនេះ ជាបច្ច័យដូចគ្នានោះឯង ទាំងក្នុងបដិសន្ធិកាល និងក្នុងបវត្តិកាល ដល់វិបាកវិញ្ញាណ ៣២ ដួងតាមសមគួរ ក្នុងភព ៣ កំណើត ៤ គតិ ៥ វិញ្ញាណដ្ឋិតិ ៧ និងក្នុងសត្តាវាស ៨ ។ ម្យ៉ាងទៀត ក្នុងសត្តាវាសដែលមិនមានវិញ្ញាណ វិញ្ញាណក៏មិនកើតព្រោះសង្ខារជាបច្ច័យ ។

ម្យ៉ាងទៀត បុញ្ញាភិសង្ខារជាបច្ច័យដល់កដត្តារូបទាំងឡាយ ក្នុងពួកអសញ្ញីសត្វដោយកម្មប្បច្ច័យ ដែលកើតផ្សេងខណៈគ្នា ដោយប្រការដូច្នេះឯង ។

បណ្ឌិតគប្បីជ្រាបសង្ខារទាំងនោះថា ជាបច្ច័យដល់វិញ្ញាណទាំងឡាយណា និងជាបច្ច័យដោយប្រការណា ដោយអំណាចបដិសន្ធិកាល និងបវត្តិកាល ក្នុងឋានៈទាំងឡាយ មានភពជាដើម ។៚

**និទ្ទេសនៃសង្ខារជាបច្ច័យនៃវិញ្ញាណ ចប់**

# នាមរូបនិទ្ទេស

[ ៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃនាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យដូចតទៅ

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យ ដោយប្រភេទទេសនា ដោយការប្រព្រឹត្តទៅក្នុងឋានៈទាំងអស់ មានភពជាដើម ដោយសង្គហៈនិងដោយបច្ច័យន័យ ។

ពាក្យថា ដោយប្រភេទទេសនា អធិប្បាយថា ព្រះមានព្រះភាគទ្រង់ធ្វើទេសនាដល់ពាក្យថា រូប ឲ្យដូចគ្នា ដោយមិនផ្សេងគ្នា ទាំងក្នុងព្រះសូត្រនិងក្នុងនាមរូបនិទ្ទេសយ៉ាងនេះថា ចុះនាមរូប តើដូចម្ដេច ។ មហាភូតរូប ៤ និងឧបាទាយរូប របស់មហាភូតរូប ៤ ដូច្នេះ ។ តែបទថា **នាម** ទ្រង់ធ្វើទេសនាផ្សេង ព្រោះក្នុងព្រះសូត្រ ( សំយុត្តនិកាយ និទានវគ្គ ) ត្រាស់ថា ចុះនាមរូប តើដូចម្ដេច ។ វេទនា ១ សញ្ញា ១ ចេតនា ១ ផស្សៈ ១ មនសិការ ១ ដូច្នេះ ។ ក្នុងនាមរូបនិទ្ទេសនេះ ត្រាស់ថា វេទានខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ ព្រោះថា ក្នុងព្រះសូត្រនោះ នាមឯណា រមែងកើតឡើងព្រោះចក្ខុវិញ្ញាណជាបច្ច័យ និងនាមណា ដែលកើតហើយ កាលទ្រង់សម្ដែងនាមនោះ ដែលប្រាកដដោយភាពមិនគួរកាន់យក ដោយអាស្រ័យធម៌ដទៃយ៉ាងនេះថា ការតាំងនៅនៃចិត្ត ជាអាយុរបស់អរូបធម៌ទាំងឡាយ ដូច្នេះទើបទ្រង់សម្ដែងចែកសង្ខារក្ខន្ធ ៣ យ៉ាង ដោយអំណាចនៃចេតនា ផស្សៈមនសិការ មួយអន្លើដោយខន្ធ ២ ( វេទនាខន្ធ សញ្ញាខន្ធ ) ។ តែក្នុងនាមរូបនិទ្ទេសនេះ កាលទ្រង់សង្គ្រោះនាមទាំងអស់ ដែលត្រាស់ហើយក្តី មិន

ទាន់ត្រាស់ក្តី ក្នុងព្រះសូត្រនោះ ទើបត្រាស់ថា ខន្ធ ៣ គឺវេទានខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ ដូច្នេះ ។

សួរថា ខន្ធទាំង ៣ នេះប៉ុណ្ណោះ ឈ្មោះថា នាម វិញ្ញាណ មិនឈ្មោះថា ជានាមទេឬ ឆ្លើយថា វិញ្ញាណមិនមែនមិនជានាម តែកាលកាន់យកវិញ្ញាណនោះ វិញ្ញាណទាំង ២ គឺវិញ្ញាណដែលជានាម និងវិញ្ញាណដែលជាបច្ច័យ ក៏នឹងប្រាកដរួមគ្នា ព្រោះហេតុនោះ ទើបត្រាស់ខន្ធ ៣ ដើម្បីទ្រង់សម្តែងនាមដែលកើតឡើងព្រោះបច្ច័យ វៀរវិញ្ញាណក្នុងឋានៈជាបច្ច័យ ។ គប្បីជ្រាបវិនិច្ឆ័យដោយប្រភេទនៃទេសនា ដោយប្រការដូច្នេះ ។

ក្នុងពាក្យថា ដោយការប្រព្រឹត្តទៅក្នុងឋានៈទាំងពួង មានភពជាដើមនេះ អធិប្បាយថា វៀរសត្តាវាស ( អសញ្ញីសត្តភូមិ ) មួយហើយ នាមរមែងប្រព្រឹត្តទៅក្នុងភព ក្នុងកំណើត ក្នុងគតិ ក្នុងវិញ្ញាណដ្ឋិតិ និងក្នុងសត្តាវាសដ៏សេសទាំងពួង រូប រមែងប្រព្រឹត្តទៅក្នុងភព ២ ក្នុងកំណើត ៤ ក្នុងគតិ ៥ ក្នុងវិញ្ញាណដ្ឋិតិ ៤ ខាងដើម និងក្នុងសត្តាវាស ៥ ខាងដើម ។ កាលនាម និងរូបនេះ ប្រព្រឹត្តទៅយ៉ាងនេះ ក៏ព្រោះក្នុងបដិសន្ធិក្ខណៈរបស់គព្ភសេយ្យកៈក្តី របស់អណ្ឌជៈក្តី ដែលមិនមានភាវៈ សន្តតិរូបដែលជាប្រធាន ២ យ៉ាង គឺវត្ថុទសកៈ និងកាយទសកៈ មួយអន្លើដោយអរូបក្ខន្ធ ៣ រមែងប្រាកដ ហេតុនោះ ពោលដោយពិស្តាររបស់ធម៌ទាំងនោះ ធម៌ ២៣ ទាំងរូប និងអរូប គឺធម៌ ២០ ( ដែលជារូប ) ខន្ធដែលជាអរូប ៣ គប្បីជ្រាបថា នាមរូបកើត ព្រោះវិញ្ញាណជាបច្ច័យ ដូច្នេះ ។

តែពោលដោយការកាន់យកចំនួន ដែលមិនទាន់បានកាន់យក ក៏បានធម៌ ១៤ ព្រោះកាត់រូបធម៌ ៩ ចេញអំពីសន្តតិរូបដែលប្រធាន ១ សម្រាប់សត្វដែលមានភាវៈ ក៏បន្ថែមភាវទសកៈចូលទៅជា ៣៣ ម្យ៉ាងទៀត កាលពោលដោយការកាន់យកចំនួន ដែលមិនទាន់បានកាន់យករបស់សត្វទាំងនោះ ក៏បានធម៌ ១៥ ព្រោះកាត់រូបធម៌ ១៨ ចេញអំពីសន្តតិរូបដែលជាប្រធានទាំងពីរ ។ ព្រោះក្នុងបដិសន្ធិក្ខណៈរបស់រូបព្រហ្មជាដើម ក្នុងសត្វជាឱបបាតិកៈ សន្តតិរូបដែលជាប្រធាន ៤ ដោយជារូបរូប[១] ដោយអំណាចនៃចក្ខុទសកៈ សោតទសកៈ វត្ថុទសកៈ និងជីវិតិន្ទ្រិយនវកៈ និងអរូបក្ខន្ធ ៣ រមែងប្រាកដ ហេតុនោះ កាលពោលដោយពិស្តារនៃធម៌ទាំងនោះ ធម៌ ៤២ គឺរូបធម៌ ៣៩ ដោយជារូបរូប និងអរូបក្ខន្ធ ៣ គប្បីជ្រាបថា នាមរូបកើតព្រោះវិញ្ញាណជាបច្ច័យ ដូច្នេះ តែបើពោលដោយការកាន់យកចំនួនដែលមិនទាន់កាន់យក ក៏បានធម៌ ១៥ យ៉ាង ព្រោះដកធម៌ ២៧ ចេញអំពីសន្តតិរូបដែលជាប្រធានទាំង ៣ ។

ក៏ព្រោះក្នុងកាមភព ក្នុងបដិសន្ធិក្ខណៈរបស់ឱបបាតិកៈដ៏សេស ឬសំសេទជៈដែលមានសភាវៈ និងអាយតនៈបរិបូណ៌ សន្តតិរូបដែលជាប្រធាន ៧ ដោយជារូបរូប និងអរូបក្ខន្ធ ៣ រមែងប្រាកដ ព្រោះហេតុនោះ ពោលដោយពិស្តារនៃធម៌ទាំងនោះ ក៏បានធម៌ ៧៣ គឺធម៌ ៧០ ដែលជារូបរូប និងអរូបក្ខន្ធ ៣ គប្បីជ្រាបថា នាមរូបកើតព្រោះវិញ្ញាណជាបច្ច័យ តែបើ

---

១- រូបដែលគប្បីបែកធ្លាយ ( អ្នកប្រែ ) ។

ពោលដោយការកាន់យកចំនួនដែលមិនកាន់យក ក៏បានធម៌ ១៩ ព្រោះដក ធម៌ ៥៤ ចេញអំពីសន្តតិរូបដែលជាប្រធាន ៦ នេះពោលដោយកំណត់យ៉ាងឧក្រិដ្ឋ ។

តែបើពោលដោយឱមកៈ បណ្ឌិតគប្បីបន្ថយចំនួននៃធម៌ គឺសន្តតិរូបដែលជាប្រធាន ដែលខ្វះខាតនោះៗ ដោយអំណាចនៃសត្វនោះៗ ហើយជ្រាបធម៌ ពោល គឺនាមរូបដែលកើតព្រោះបដិសន្ធិវិញ្ញាណជាបច្ច័យ ទាំងដោយសង្ខេប និងដោយពិស្តារ ។ សម្រាប់បុគ្គលដែលជាអរូបព្រហ្ម មានអរូបក្ខន្ធ ៣ កើតព្រោះបដិសន្ធិវិញ្ញាណជាបច្ច័យ សម្រាប់អសញ្ញីសត្វទាំងឡាយ មានជីវិតិន្ទ្រិយនវកៈ ដោយរូបណាមួយប៉ុណ្ណោះ ។ នេះជាន័យក្នុងបដិសន្ធិកាល ។

ចំណែកក្នុងបវត្តិកាល សុទ្ធដ្ឋកៈ ( អវិនិព្ភោគរូប ៨ សុទ្ធ ) ដែលមានឧតុជាសមុដ្ឋាន រមែងប្រាកដជាកឧតុដែលប្រព្រឹត្តទៅជាមួយបដិសន្ធិចិត្តក្នុងឋិតិក្ខណៈរបស់បដិសន្ធិចិត្ត ដែលជាចំណែកនៃការប្រព្រឹត្តទៅនៃរូបទាំងអស់ តែបដិសន្ធិចិត្ត រមែងញ៉ាំងរូបឲ្យកើតឡើងមិនបាន បដិសន្ធិចិត្តនោះមិនអាចញ៉ាំងរូបឲ្យកើតឡើងបាន ព្រោះហទយវត្ថុមានកម្លាំងខ្សោយ ដូចបុរសធ្លាក់ក្នុងជ្រោះ មិនអាចជួយអ្នកដទៃបាន ដូច្នោះ ។ កាលផុតបដិ-សន្ធិចិត្តទៅហើយ ចាប់អំពីបឋមភវង្គ សុទ្ធដ្ឋករូបដែលមានចិត្តជាសមុដ្ឋានក៏តាំងឡើង ក្នុងកាលប្រាកដផុតបដិសន្ធិចិត្តទៅហើយ សទ្ទនវករូប ក៏ប្រាកដអំពីឧតុដែលប្រព្រឹត្តទៅ និងប្រាកដអំពីចិត្ត ។ គព្ភសេយ្យកសត្វពួកណា

ដែលរស់នៅដោយកពឡិង្ការាហារ ក្នុងសរីរៈរបស់សត្វទាំងនោះ ដែលជ្រួតជ្រាបទៅដោយអាហារដែលមាតាបរិភោគចូលទៅហើយ ដោយព្រះបាលីថា

ឯមាតារបស់សត្វនោះ បរិភោគភោជនណា ទោះបាយក្តី ទឹកក្តី សត្វនោះ ដែលស្ថិតនៅក្នុងផ្ទៃនៃមាតានោះ ក៏ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយភោជននោះ ដូច្នេះ ។

សម្រាប់ឱបបាតិកកំណើត ក្នុងពេលដែលខ្ទួនលេបទឹកមាត់ដែលនៅក្នុងមាត់ដំបូងមួយដុំ សុទ្ធដ្ឋករូបដែលមានអាហារជាសមុដ្ឋានក៏ប្រាកដ ព្រោះហេតុនោះ កាលពោលដោយសង្ខេប ក៏បានធម៌ ៩៩ យ៉ាង គឺរូប ២៦ ដោយអំណាចនៃសុទ្ធដ្ឋករូបដែលមានអាហារជាសមុដ្ឋាន និងដោយអំណាចនវករូបទាំងពីរ ដោយកំណត់យ៉ាងឧក្រិដ្ឋ ដែលមានឧតុ និងចិត្តជាសមុដ្ឋាន និងរូប ៧០ មានកម្មជាសមុដ្ឋាន ដែលកើតឡើង ៣ ដង ក្នុងខណៈនៃចិត្តតែមួយដួង ដែលពោលហើយខាងដើម រួមជារូបមាន ៩៦ និងអរូបក្ខន្ធ ៣ ។ ម្យ៉ាងទៀត សំឡេងមិនពិតប្រាកដ ព្រោះប្រាកដក្នុងកាលខ្លះប៉ុណ្ណោះ ព្រោះហេតុនោះ ធម៌ ៩៧ នេះ គប្បីជ្រាបថា នាមរូបកើតព្រោះវិញ្ញាណជាបច្ច័យដល់សត្វទាំងឡាយ តាមដែលកើតឡើង ព្រោះដកសំឡេងទាំងពីរនោះចេញ ។ ធម៌ទាំងនេះ រមែងប្រព្រឹត្តទៅ ព្រោះវិញ្ញាណជាបច្ច័យ ដល់សត្វទាំងនោះដែលប្រមាទខ្លះ ដែលកំពុងដើរខ្លះ ដែលកំពុងទំពាស៊ីខ្លះ ដែលកំពុងផឹកខ្លះ ទាំងពេលថ្ងៃ និងពេលយប់ ។ ភាវៈដែលធម៌ទាំងនេះ ប្រព្រឹត្តទៅ ព្រោះវិញ្ញាណជាបច្ច័យ ខ្ញុំនឹងពណ៌នាខាងមុខ ។

ម្យ៉ាងទៀត ក្នុងអធិការនេះ កម្មជរូបនេះ សូម្បីតាំងនៅដំបូងក្នុងទីទាំងពួង គឺក្នុងភព កំណើត គតិ វិញ្ញាណដ្ឋិតិ និងសត្តាវាស ដែលសមុដ្ឋានិករូបទាំង ៣ មិនឧបត្ថម្ភហើយ រមែងមិនអាចតាំងនៅបាន សូម្បីសមុដ្ឋានិករូបទាំង ៣ នោះ ដែលកម្មជរូបនោះមិនឧបត្ថម្ភហើយ ក៏តាំងនៅមិនបាន ដោយពិត រូបទាំងនេះ បើឧបត្ថម្ភ ក៏ឧបត្ថម្ភនូវគ្នានិងគ្នាមិនឲ្យធ្លាក់ទៅ ទើបតាំងនៅបាន ១ ឆ្នាំខ្លះ ២ ឆ្នាំខ្លះ ។បេ។ ១០០ ឆ្នាំខ្លះ រហូតដល់អស់អាយុ ឬអស់បុណ្យរបស់សត្វទាំងនោះ ដូចគុម្ពបបុសជាដើម ដែលចាក់ស្រែះគ្នាទាំង ៤ ទិស ត្រូវខ្យល់បក់ហើយក៏រស់បាន ឬប្រៀបដូចបុគ្គលមានពាហនៈ គឺសំពៅលិចខ្លះ បានទីពឹងក្នុងកន្លែងខ្លះ ក្នុងសមុទ្រហើយ សូម្បីត្រូវកម្លាំងរលកបក់បោកហើយ ក៏រស់នៅបាន ព្រោះហេតុនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងអធិការនេះ ដោយការប្រព្រឹត្តទៅក្នុងឋានៈទាំងឡាយ មានភពជាដើម ដោយប្រការដូច្នេះ ។

ក្នុងពាក្យថា ដោយសង្គហៈ មានអធិប្បាយថា បណ្ឌិតគប្បីសង្គ្រោះដោយសរុបឯកទេសន័យយ៉ាងនេះថា នាមតែម្យ៉ាងឯណាកើតព្រោះវិញ្ញាណជាបច្ច័យក្នុងបវត្តិកាល និងក្នុងបដិសន្ធិកាល ក្នុងអរូបភពក្តី ក្នុងបវត្តិកាលក្នុងបញ្ចវោការភពក្តី រូបតែម្យ៉ាងឯណា កើតព្រោះវិញ្ញាណជាបច្ច័យក្តី ក្នុងបដិសន្ធិកាល និងក្នុងបវត្តិកាលទាំងអស់ ក្នុងពួកអសញ្ញីភព និងក្នុងបវត្តិ-កាល ក្នុងបញ្ចវោការភព នាមរូបឯណា ដែលកើតព្រោះវិញ្ញាណជាបច្ច័យក្នុងកាលទាំងអស់ ក្នុងបញ្ចវោការភព នាមផង រូបផង នាមរូបផងទាំងអស់នោះ ឈ្មោះថា នាមរូប ដូច្នេះហើយ ជ្រាបថា នាមរូបកើតព្រោះវិញ្ញាណ

ជាបច្ច័យ ។

បើមានអ្នកសង្ស័យសួរថា ព្រោះអសញ្ញីសត្វមិនមានវិញ្ញាណ នាមរូបកើតព្រោះវិញ្ញាណជាបច្ច័យមិនគួរ ឆ្លើយថា មិនមែនមិនគួរ ពិតហើយ វិញ្ញាណនេះ លោកពោលថា

វិញ្ញាណនោះ ជាហេតុនៃនាមរូប វិញ្ញាណនោះ លោកពោល ២
យ៉ាង គឺវិញ្ញាណដែលជាវិបាក និងវិញ្ញាណដែលមិនជាវិបាក ទើប
វិញ្ញាណនេះ សមគួរជាបច្ច័យដល់រូបក្នុងអសញ្ញិកពនោះឯង ។

ពិតហើយ វិញ្ញាណណា ជាហេតុនៃនាមរូប វិញ្ញាណនោះ លោកពោល ២ យ៉ាង ដោយចែកជាវិបាក និងមិនជាវិបាក ។ម្យ៉ាងទៀត ក្នុងអសញ្ញីសត្វទាំងឡាយ ក៏កើតព្រោះវិញ្ញាណដែលជាអភិសង្ខារ ដែលប្រព្រឹត្តទៅក្នុងបញ្ចវោការភពជាបច្ច័យ ព្រោះរូបទាំងនោះ មានកម្មជាសមុដ្ឋាន ។ ក្នុងបញ្ចវោការភព ក្នុងបវត្តិកាល ក្នុងខណៈនៃកុសលចិត្តជាដើម រូបក៏មានកម្មជាសមុដ្ឋានដូចគ្នា ព្រោះហេតុនោះ ទើបវិញ្ញាណនេះ សមគួរជាបច្ច័យបាន ។ គប្បីជ្រាបវិនិច្ឆ័យដោយសង្គហៈក្នុងអធិការនេះ ដោយប្រការដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា ដោយបច្ច័យន័យនេះដូចតទៅ
វិបាកវិញ្ញាណជាបច្ច័យដល់នាម ៩ យ៉ាង ជាបច្ច័យដល់វត្ថុរូប
៩ យ៉ាង ជាបច្ច័យដល់រូបដ៏សេស ៨ យ៉ាង អភិសង្ខារវិញ្ញាណ
ជាបច្ច័យដល់រូប ១ យ៉ាង ចំណែកវិញ្ញាណដទៃក្រៅអំពីនេះ ជា
បច្ច័យដល់នាមរូបនោះៗ តាមសមគួរ ។

ពិតហើយ នាម ពោល គឺវិបាកក្នុងបដិសន្ធិកាល ឬក្នុងបវត្តិកាលនេះ បដិសន្ធិវិញ្ញាណ ឬវិបាកវិញ្ញាណដទៃជាបច្ច័យ ៩ យ៉ាងដល់នាមនោះ ដែលលាយឡំដោយរូបខ្ធ មិនលាយឡំដោយរូបខ្ធ ដោយសហជាតបច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ជាបច្ច័យដល់វត្ថុរូបក្នុងបដិសន្ធិកាល ៩ បច្ច័យ ដោយសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ។ វៀរវត្ថុរូប ជាបច្ច័យដល់រូបដ៏សេស ៨ បច្ច័យ វៀរអញ្ញមញ្ញប្បច្ច័យ ក្នុងបច្ច័យ ៩ នេះចេញ ។

ចំណែកអភិសង្ខារវិញ្ញាណ ជាបច្ច័យដល់អសញ្ញសត្តរូប ឬដល់កម្មជរូបក្នុងបញ្ចវោការភព ដោយអំណាចឧបនិស្សយប្បច្ច័យតែម្យ៉ាងប៉ុណ្ណោះ ដោយបរិយាយដែលមកក្នុងព្រះសូត្រ ។ វិញ្ញាណទាំងអស់ដ៏សេស ចាប់អំពីបឋមកវគ្គ គប្បីជ្រាបថា ជាបច្ច័យដល់នាមរូបនោះៗ តាមគួរ ។ ម្យ៉ាងទៀត កាលសម្តែងន័យរបស់បច្ច័យនៃនាមរូបនោះដោយពិស្តារ បណ្ឌិតគប្បីញុំាងបដ្ឋានកថាទាំងអស់ឲ្យពិស្តារ ព្រោះហេតុនោះ ខ្ញុំមិនទាន់ផ្តើមបដ្ឋានកថានោះ ។

ក្នុងសេចក្តីនោះ បើមានអ្នកសួរថា សេចក្តីនេះគប្បីដឹងបានដូចម្តេចថា នាមរូបក្នុងបដិសន្ធិកាល មានវិញ្ញាណជាបច្ច័យ ឆ្លើយថា ដឹងបានដោយព្រះសូត្រ និងដោយយុត្តិ គឺភាពប្រពៃដោយហេតុផល ព្រោះថា ក្នុងព្រះសូត្រភាពដែលធម៌ មានវេទនាជាដើម មានវិញ្ញាណជាបច្ច័យ សម្រេចហើយ

*ដោយច្រើន ដោយន័យជាដើមថា* **ចិត្តានុបរិវត្តិនោ ធម្មា** *ពួកធម៌ប្រព្រឹត្ត ទៅតាមចិត្ត ដូច្នេះ ចំណែកយុត្តិដូច្នេះថា*

*សេចក្តីពិត វិញ្ញាណរមែងសម្រេចបានដោយចិត្តជួររូបដែលឃើញ បាន ក្នុងលោកនេះ វិញ្ញាណក៏ជាបច្ច័យដល់រូបដែលឃើញមិន បាន ។*

*ពិតហើយ កាលចិត្តជួរផង់ក្តី មិនជួរផង់ក្តី រូបទាំងឡាយដែលគួរដល់ ចិត្តនោះ កាលកើតឡើង ទើបវិញ្ញាណឃើញ ឯការគិតឃ្មេរ រូបដែលឃើញ មិនបាន រមែងមានដោយរូបដែលឃើញបាន ព្រោះហេតុនោះ សេចក្តីនេះ គប្បីដឹងបានដោយបទនេះថា វិញ្ញាណ រមែងជាបច្ច័យដល់រូបក្នុងបដិសន្ធិ ទោះបីឃើញមិនបាន ដោយចិត្តជួររូបដែលឃើញបានក្នុងលោកនេះ ។ ពិត ហើយ កាតដែលរូបក្នុងបដិសន្ធិនោះ មានកម្មជាសមុដ្ឋាន ដូចដែលមានចិត្ត ជាសមុដ្ឋាន ក៏មានវិញ្ញាណជាបច្ច័យ មកហើយក្នុងបដ្ឋាននោះឯង ។ ក្នុង អធិការនេះ គប្បីជ្រាបវិនិច្ឆ័យដោយបច្ច័យន័យ ដោយប្រការដូច្នេះ ។*

*ព្រះមានព្រះភាគ ត្រាស់ក្នុងបទនេះថា* **វិញ្ញាណប្បច្ចយា នាមរូបំ** *ឈ្មោះថា ទ្រង់ប្រកាសធម្មចក្រដ៏ប្រសើរ ដែលសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬបុគ្គលណាម្នាក់ក្នុងលោកក្តី ជំទាស់មិនបាន ព្រោះកាលពួកបណ្ឌិតចូលទៅពិចារណា ត្រឹមតែនាមរូបប៉ុណ្ណោះ កំពុង ប្រព្រឹត្តទៅ រមែងប្រាកដដោយបរមត្ថ មិនមែនសត្វ មិនបុគ្គល ដូច្នេះ ៕*

**និទ្ទេសនៃវិញ្ញាណជាបច្ច័យនៃនាមរូប ចប់**

# សឡាយតននិទ្ទេស

[ ៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃនាមរូប ជាបច្ច័យនៃសឡាយតនៈ ដូចតទៅ

*នាម គឺខន្ធ ៣ រូប បានដល់ រូបដែលពោលថា ភូត និងវត្ថុ ជាដើម នាមរូបនោះ លោកធ្វើឯកសេសន័យថា ជាបច្ច័យដល់សឡាយតនៈ ដូច្នោះឯង ។*

*ពិតហើយ ក្នុងនាមរូបដែលជាបច្ច័យដល់សឡាយតនៈនោះ ខន្ធ ៣ មានវេទនាខន្ធជាដើម ឈ្មោះថា នាម ចំណែករូបដែលទាក់ទងដោយសន្តតិរបស់ខ្លួន គប្បីជ្រាបថា លោកហៅដោយនិយមថា ភូត និងវត្ថុយ៉ាងនេះ គឺភូតរូប ៤ វត្ថុរូប ៦ និងជីវិតិន្ទ្រិយនាមរូបនោះ លោកធ្វើឯកសេសន័យយ៉ាងនេះថា នាមផង រូបផង នាមរូបផង ឈ្មោះថា នាមរូប ។ នាមរូបនោះ គប្បីជ្រាបថា ជាបច្ច័យដល់សឡាយតនៈ ដែលលោកធ្វើជាឯកសេសន័យយ៉ាងនោះឯងថា អាយតនៈទី ៦ ផង អាយតនៈ ៦ ផង ឈ្មោះថា សឡាយតនៈ ដូច្នេះ ព្រោះហេតុអ្វី ព្រោះក្នុងអរូបភព នាមតែម្យ៉ាងជាបច្ច័យ នាមនោះក៏ជាបច្ច័យដល់អាយតនៈទី ៦ ប៉ុណ្ណោះ មិនជាបច្ច័យដល់អាយតនៈដទៃ ព្រោះក្នុងអព្យាកតវារៈ ព្រះមានព្រះភាគត្រាស់ថា* **នាមប្បច្ចយា ឆដ្ឋាយតនំ** *អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ដូច្នេះ នាមដែលទ្រង់សង្គ្រោះក្នុងទីនេះ គប្បីជ្រាបថា ទ្រង់ចែកក្នុងអព្យាកតវារៈនោះឯង ។*

*ក្នុងសេចក្តីនោះ បើមានបុគ្គលសួរថា សេចក្តីនេះ គប្បីជ្រាបបានដូច*

ម្ដេចថា នាមរូបជាបច្ច័យដល់សឡាយតនៈនោះ ឆ្លើយថា ជ្រាបបាន ព្រោះកាលនាមរូបមាន សឡាយតនៈក៏មាន ។ ពិតហើយ កាលនាម និងរូបនោះមាន អាយតនៈនោះ ក៏រមែងមាន មិនមែនដោយប្រការដទៃ ។ ភាពដែលសឡាយតនៈនោះមាន ព្រោះនាមរូបមាននោះ នឹងជាក់ច្បាស់ក្នុងន័យរបស់បច្ច័យនោះឯង ព្រោះហេតុនោះ

នាមរូបណា ជាបច្ច័យដល់អាយតនៈណា និងជាបច្ច័យដោយប្រការណាក្នុងបដិសន្ធិកាល ឬក្នុងបវត្តិកាល បណ្ឌិតគប្បីជ្រាបនាមរូបនោះ អាយតនៈនោះ ដោយប្រការនោះ ។

បណ្ដានាមរូបដែលជាបច្ច័យនោះ មានអធិប្បាយដូច្នេះថា សេចក្ដីពិត ពោលដោយការកំណត់យ៉ាងទាប នាមតែម្យ៉ាងនោះជាបច្ច័យ ៧ យ៉ាង ដល់អាយតនៈទី ៦ ក្នុងអរូបភពផង ក្នុងបដិសន្ធិកាលផង ក្នុងបវត្តិកាលផង ។

នាមជាបច្ច័យដូចម្ដេច គឺក្នុងបដិសន្ធិកាល ពោលដោយកំណត់យ៉ាងទាប នាមជាបច្ច័យ ៧ យ៉ាងដល់អាយតនៈទី ៦ ដោយសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ វិបាកប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ។ ម្យ៉ាងទៀត ក្នុងបដិសន្ធិកាលនេះ ក៏មានបច្ច័យដោយប្រការដទៃយ៉ាងនេះ គឺនាមខ្លះ ជាបច្ច័យដោយហេតុប្បច្ច័យ នាមខ្លះ ជាបច្ច័យដោយអាហារប្បច្ច័យ បណ្ឌិតគប្បីជ្រាបការកំណត់យ៉ាងខ្ពស់ និងយ៉ាងទាប ដោយអំណាចនៃបច្ច័យ មានហេតុប្បច្ច័យជាដើមនោះចុះ ។

ក្នុងបវត្តិកាល នាម គឺវិបាកជាបច្ច័យ ដោយន័យដែលពោលហើយនោះឯង ។ តែនាមក្រៅអំពីនេះ ដែលមិនមែនវិបាកជាបច្ច័យ ៦ យ៉ាង ដោយកំណត់យ៉ាងទាប វៀរវិបាកប្បច្ច័យ ក្នុងបណ្ដាបច្ច័យទាំងឡាយ តាមដែលពោលហើយ ។ម្យ៉ាងទៀត ក្នុងបវត្តិកាលនោះ ក៏មានបច្ច័យដោយប្រការដទៃយ៉ាងនេះ គឺនាមខ្លះ ជាបច្ច័យដោយហេតុប្បច្ច័យ នាមខ្លះ ជាបច្ច័យដោយអាហារប្បច្ច័យ បណ្ឌិតគប្បីជ្រាបការកំណត់យ៉ាងខ្ពស់ និងយ៉ាងទាប ដោយអំណាចនៃបច្ច័យ មានហេតុប្បច្ច័យជាដើមនោះ ។

ក្នុងភពដទៃ នាមជាបច្ច័យដល់អាយតនៈទី ៦ ក្នុងបដិសន្ធិកាល
យ៉ាងនោះឯង នាមនោះនៅជាបច្ច័យដោយអាការ ៦ យ៉ាង ដល់
អាយតនៈទាំងឡាយ ក្រៅអំពីអាយតនៈទី ៦ នេះ ។

ពិតហើយ ក្នុងភពដទៃក្រៅអំពីរូបភព គឺក្នុងបញ្ចវោការភព នាមដែលជាវិបាកនោះ ជាសម្ពាញ់របស់ហទយវត្ថុ ជាបច្ច័យ ៧ យ៉ាងដល់អាយតនៈទី ៦ គឺមនាយតនៈ ដោយកំណត់យ៉ាងទាប ដូចបានពោលក្នុងអរូបភពនោះឯង ។ ម្យ៉ាងទៀត នាមនោះជាសម្ពាញ់ជាមួយមហាភូតរូប ៤ ជាបច្ច័យដល់អាយតនៈ ៥ មានចក្ខាយតនៈជាដើម ក្រៅអំពីអាយតនៈទី ៦ ដោយអាការ ៦ យ៉ាង ដោយអំណាចនៃសហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ក្នុងបដិសន្ធិកាលនេះ មានបច្ច័យដទៃយ៉ាងនេះ គឺនាមខ្លះ ជាបច្ច័យដោយហេតុប្បច្ច័យ នាមខ្លះ ជាបច្ច័យដោយអាហារប្បច្ច័យ ។ បណ្ឌិតគប្បីជ្រាបការកំណត់យ៉ាងខ្ពស់ និងយ៉ាង

ទាប ដោយអំណាចនៃហេតុប្បច្ច័យជាដើមនោះ ។

ក្នុងបវត្តិកាល នាមដែលជាវិបាក ក៏ជាបច្ច័យដល់អាយតនៈដែលជាវិបាកដូចគ្នា នាមដែលមិនមែនជាវិបាក ក៏ជាបច្ច័យ ៦ យ៉ាងដល់អាយតនៈទី ៦ ដែលមិនមែនជាវិបាក ។

ពិតហើយ ក្នុងបវត្តិកាល ក្នុងបញ្ចវោការភព នាមដែលជាវិបាក ក៏ជាបច្ច័យដល់អាយតនៈទី ៦ ដែលជាវិបាក ដោយកំណត់យ៉ាងទាប ៧ បច្ច័យដូចក្នុងបដិសន្ធិកាលនោះឯង ចំណែកនាមដែលមិនមែនជាវិបាក ក៏ជាបច្ច័យដល់អាយតនៈទី ៦ ដែលមិនមែនជាវិបាក ដោយកំណត់យ៉ាងទាប ៦ បច្ច័យ ដោយដកវិបាកប្បច្ច័យអំពីបច្ច័យទាំង ៧ នោះ ។ ក្នុងបវត្តិកាលនេះគប្បីជ្រាបការកំណត់យ៉ាងខ្ពស់ និងយ៉ាងទាប ដោយន័យដែលពោលហើយដូចគ្នា ។

ក្នុងបវត្តិកាលនោះឯង នាមដែលជាវិបាក ក៏ជាបច្ច័យ ៤ យ៉ាងដល់អាយតនៈ ៥ ដ៏សេស សូម្បីនាមដែលមិនមែនជាវិបាក ក៏ទ្រង់ប្រកាសហើយយ៉ាងនោះឯង ។

ពិតហើយ ក្នុងបវត្តិកាលនោះ នាមដែលជាវិបាកអាស្រ័យវត្ថុ មានចក្ខុបសាទជាដើមខ្លះ វត្ថុក្រៅពីនេះខ្លះ ជាបច្ច័យ ៤ យ៉ាង ដល់អាយតនៈដ៏សេស ៥ មានចក្ខាយតនៈជាដើម ដោយបច្ឆាជាតប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ សូម្បីនាមដែលមិនមែនជាវិបាក ក៏ទ្រង់ប្រកាសដូចនាមដែលជាវិបាកនោះឯង ព្រោះហេតុនោះ សូម្បីនាម មានកុសលជាដើម

ក៏គប្បីជ្រាបថា ជាបច្ច័យ ៤ យ៉ាង ដល់អាយនតនៈទាំង ៥ នេះ នាមតែម្យ៉ាង ជាបច្ច័យដល់អាយតនៈណាមួយ និងដោយប្រការណាមួយ ក្នុងបដិសន្ធិ-កាលក្តី ក្នុងបវត្តិកាលក្តី គប្បីជ្រាបអាយតនៈនោះៗ ដោយប្រការនោះៗ យ៉ាងនេះ ។

ក្នុងអាយតនៈទាំងនេះ រូបមិនជាបច្ច័យដល់អាយតនៈ ១ ក្នុងអរូបភព តែជាបច្ច័យក្នុងភពដែលមានខន្ធ ៥ ពោលដោយរូប វត្ថុរូប ក្នុងបដិសន្ធិកាល ជាបច្ច័យ ៦ យ៉ាង ដល់អាយតនៈទី ៦ ភូតរូបទាំងឡាយជាបច្ច័យ ៤ យ៉ាង ដល់អាយតនៈ ៥ ដោយមិនប្លែកគ្នា ។

ពិតហើយ ពោលដោយរូប វត្ថុរូបក្នុងបដិសន្ធិកាល ជាបច្ច័យដល់អាយតនៈទី ៦ គឺមនាយតនៈ ៦ យ៉ាង ដោយសហជាតប្បច្ច័យ អញ្ញមញ្ញ-ប្បច្ច័យ និស្សយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ឯភូតរូប ៤ ជាបច្ច័យ ៤ យ៉ាងដល់អាយតនៈទាំង ៥ មានចក្ខាយតនៈជាដើម ដោយសហជាតប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដោយអំណាចនៃអាយតនៈដែលកើតឡើងនោះៗ ទាំងក្នុងបដិសន្ធិកាល និងបវត្តិ-កាល ដោយមិនប្លែកគ្នា ។

ជីវិតរូប ជាបច្ច័យ ៣ យ៉ាងដល់វត្ថុរូបទាំងនេះ អាហាររូប ជាបច្ច័យ ៣ យ៉ាង ក្នុងបវត្តិកាល អាយតនៈទាំង ៥ នោះជាបច្ច័យ ៦ យ៉ាង ដល់អាយតនៈទី ៦ វត្ថុរូបជាបច្ច័យ ៥ យ៉ាង

ដល់អាយតនៈទី ៦ នោះឯង ។

ជីវិតរូបក្នុងបដិសន្ធិកាល និងបវត្តិកាល ជាបច្ច័យ ៣ យ៉ាង ដល់វត្ថុទាំង ៥ មានចក្ខុវត្ថុជាដើម ដោយអំណាចអត្ថិប្បច្ច័យ អវិគតប្បច្ច័យ និងឥន្ទ្រិយប្បច្ច័យ ។

ពាក្យថា អាហាររូប បានដល់ អាហាររូបក៏ជាបច្ច័យ ៣ យ៉ាងនោះឯង ដោយអំណាចអត្ថិប្បច្ច័យ អវិគតប្បច្ច័យ អាហារប្បច្ច័យ ។ អាហារនោះឯង ជាបច្ច័យក្នុងកាយដែលមានអាហារជ្រួតជ្រាបរបស់សត្វ ដែលមានអាហារចិញ្ចឹមជីវិតទាំងនោះ ក្នុងបវត្តិកាលប៉ុណ្ណោះ មិនមែនក្នុងបដិសន្ធិ-កាល ។ម្យ៉ាងទៀត អាយតនៈ ៥ មានចក្ខាយតនៈជាដើមនោះ ជាបច្ច័យក្នុងបវត្តិកាល មិនមែនក្នុងបដិសន្ធិកាល ដល់មនាយតនៈដែលជាអាយតនៈទី ៦ ពោល គឺចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ និងកាយវិញ្ញាណ ដោយអាការ ៦ យ៉ាង ដោយអំណាចនិស្សយប្បច្ច័យ បុរេ-ជាតប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគ-តប្បច្ច័យ ។ ចំណែកវត្ថុរូប ជាបច្ច័យ ៥ យ៉ាង ក្នុងបវត្តិកាល មិនមែនក្នុងបដិសន្ធិកាល ដល់មនាយតនៈដ៏សេស វៀរតែវិញ្ញាណ ៥ នោះឯង ដោយអំណាចនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ រូបណាមួយ ជាបច្ច័យដល់អាយតនៈណាមួយ ក្នុងបដិ-សន្ធិកាលក្តី ក្នុងបវត្តិកាលក្តី ដោយប្រការណាមួយ គប្បីជ្រាបអាយតនៈនោះៗ ដោយប្រការដូច្នេះ ។

*នាមរូបទាំងពីរឯណា ជាបច្ច័យដល់អាយតនៈណា និងដោយប្រការណា បណ្ឌិតគប្បីជ្រាបនាមរូបនោះ និងអាយតនៈនោះដោយប្រការនោះ ក្នុងទីគ្រប់អន្លើ ។*

*សួរថា គប្បីជ្រាបដូចម្ដេច គឺខាងដើម នាមរូប ពោល គឺនាមក្ខន្ធ ៣ និងវត្ថុរូបក្នុងបដិសន្ធិកាល ក្នុងបញ្ចវោការភព ជាបច្ច័យដល់សឡាយតនៈដោយសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ វិបាកប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យជាដើម ។*

*ពាក្យដែលពោលនេះ ល្មមជាមាតិកាក្នុងពាក្យថា នាមរូបជាបច្ច័យដល់អាយតនៈ តែបុគ្គលអ្នកឈ្លាស អាចប្រកបអត្ថទាំងអស់ដោយទំនងន័យដែលពោលហើយ ព្រោះហេតុនោះ ទើបខ្ញុំមិនសម្ដែងពិស្ដារក្នុងសេចក្ដីនេះដោយប្រការដូច្នេះឯង ៕*

## និទ្ទេសនៃនាមរូបជាបច្ច័យនៃសឡាយតនៈ ចប់

# ផស្សនិទ្ទេស

[ ៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃសឡាយតនៈ ជាបច្ច័យដល់ផស្សៈដូចតទៅ

ពោលដោយសង្ខេប ផស្សៈមាន ៦ យ៉ាងប៉ុណ្ណោះ មាន
ចក្ខុសម្ផស្សជាដើម ពោលដោយពិស្តារ ផស្សៈទាំងនោះ ក៏មាន
៣២ យ៉ាង ដូចគ្នានឹងវិញ្ញាណ ។

ពិតហើយ ដោយសង្ខេប ផស្សៈមាន ៦ យ៉ាងប៉ុណ្ណោះ មានពាក្យជាដើមថា **ចក្ខុសម្ផស្សោ** ដូច្នេះ មកហើយក្នុងបាលី ។ តែដោយពិស្តារ ផស្សៈទាំងអស់ មាន ៣២ ដូចវិញ្ញាណដែលពោលព្រោះសង្ខារជាបច្ច័យយ៉ាងនេះ គឺផស្សៈទាំងឡាយ មានចក្ខុសម្ផស្សជាដើម ដែលជាកុសលវិបាក ៥ ដែលជាអកុសលវិបាក ៥ ព្រោះហេតុនោះ ទើបរួមជា ១០ ផស្សៈដ៏សេស ២២ បានដល់ ផស្សៈដែលសម្បយុត្តដោយវិបាកវិញ្ញាណដែលជាលោកិយ ២២ ។

ក្នុងសឡាយតនៈជាបច្ច័យដល់ផស្សៈទាំង ៣២ នោះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅ

បណ្ឌិតទាំងឡាយ រមែងប្រាថ្នាអាយតនៈខាងក្នុង មាន
ចក្ខាយតនៈជាដើម មួយអន្លើដោយអាយតនៈទី ៦ មួយអន្លើ
ដោយអាយតនៈខាងក្រៅ ៦ ថា ឈ្មោះថា សឡាយតនៈ ។

ក្នុងព្រះបាលីថា សឡាយតនៈជាបច្ច័យដល់ផស្សៈនោះ មានអធិប្បាយថា បណ្ឌិតពួកណា រមែងសម្តែងបច្ច័យ និងបច្ចយុប្បន្ន ( ធម៌

ដែលកើតព្រោះបច្ច័យ ) ដែលទាក់ទងដោយសន្តតិមួយប៉ុណ្ណោះថា នេះជាកថាសម្តែងការប្រព្រឹត្តទៅនៃឧបាទិន្នកសង្ខារ បណ្ឌិតទាំងនោះ រមែងប្រាថ្នាអាយតនៈខាងក្នុង ៦ មានចក្ខាយតនៈជាដើម និងអាយតនៈទី ៦ ថាឈ្មោះថា សឡាយតនៈ ព្រោះធ្វើសរូបឯកសេសន័យដោយឯកទេសថា អាយតនៈទី ៦ ក្នុងអរូបកព និងអាយតនៈ ៦ ដោយរួមទាំងអស់ក្នុងទីដទៃជាបច្ច័យដល់ផស្សៈ ដោយទំនងនៃព្រះបាលីថា ផស្សៈកើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ដូច្នេះ ពិតហើយ អាយតនៈនោះ ព្រោះធ្វើបទទាំងនេះ ឲ្យជាឯកសេសសមាសថា អាយតនៈទី ៦ ផង សឡាយតនៈផង រមែងដល់នូវការរាប់ថា សឡាយតនៈនោះឯង ឯបណ្ឌិតពួកណា សម្តែងបច្ចុប្បន្នធម៌ គឺធម៌ដែលកើតអំពីបច្ច័យប៉ុណ្ណោះថា ជាធម៌ដែលទាក់ទងដោយសន្តតិ ១ តែសម្តែងបច្ច័យដែលមានសន្តានផ្សេងគ្នា បណ្ឌិតទាំងនោះកាលសម្តែងអាយតនៈទាំងអស់ ដែលជាបច្ច័យដល់ផស្សៈ ក៏កំណត់យកអាយតនៈខាងក្រៅ ហើយរមែងប្រាថ្នាអាយតនៈខាងក្នុង ជាមួយអាយតនៈទី ៦ នោះឯង មួយអន្លើដោយអាយតនៈខាងក្រៅ មានរូបាយតនៈជាដើមថា សឡាយតនៈ ព្រោះថា អាយតនៈខាងក្រៅនោះ រមែងដល់នូវការរាប់ថា សឡាយតនៈដូចគ្នា ព្រោះលោកធ្វើឯកសេសសមាសនៃបទទាំងនេះថា អាយតនៈទី ៦ ផង សឡាយតនៈផង ឈ្មោះថា សឡាយតនៈ ដូច្នេះ ។

ក្នុងសេចក្តីនេះ បើមានបុគ្គលសួរថា ផស្សៈ ១ រមែងកើតអំពីអាយតនៈទាំងអស់មិនបាន សូម្បីផស្សៈទាំងអស់ ក៏រមែងកើតអំពីអាយតនៈ

តែមួយមិនបាន ផស្សៈនេះ ព្រះមានព្រះភាគ ត្រាស់តែម្យ៉ាងប៉ុណ្ណោះ **សឡាយតនប្បច្ចយា ផស្សោ** ដូច្នេះ ផស្សៈនោះ ទ្រង់ត្រាស់តែម្យ៉ាងប៉ុណ្ណោះ ព្រោះហេតុអ្វី ក្នុងបញ្ហាកម្មនេះ មានវិសជ្ជនាដូចតទៅ សេចក្តីនេះជាការពិត ផស្សៈ ១ រមែងមិនកើតអំពីអាយតនៈទាំងអស់ ឬផស្សៈទាំងអស់ រមែងមិនកើតអំពីអាយតនៈ ១ តែផស្សៈ ១ រមែងកើតអំពីអាយតនៈច្រើនយ៉ាង ដូចចក្ខុសម្ផស្ស កើតអំពីចក្ខាយតនៈ អំពីរូបាយតនៈ តែមនាយតនៈ ពោល គឺចក្ខុវិញ្ញាណ និងអំពីធម្មាយតនៈដែលសម្បយុត្តគ្នាដ៏សេសយ៉ាងណា ក្នុងផស្សៈទាំងពួងក៏យ៉ាងនោះ គប្បីប្រកបតាមសមគួរដោយប្រការដូច្នេះ ។

ព្រោះហេតុនោះឯង

ផស្សៈនេះ ព្រះមានព្រះភាគ ជាតាទិបុគ្គល ទ្រង់សម្តែងថា
ផស្សៈ ១ មានអាយតនៈច្រើនយ៉ាងជាដែនកើត ដោយនិទ្ទេស
ជាឯកវចនៈ ក្នុងនិទ្ទេសនេះ ។

ពាក្យថា ដោយនិទ្ទេសជាឯកវចនៈនោះ សេចក្តីថា ព្រះមានព្រះភាគជាតាទិបុគ្គល ទ្រង់សម្តែងថា ផស្សៈ ១ រមែងកើតអំពីអាយតនៈច្រើនយ៉ាង ដូច្នេះ ដោយនិទ្ទេសជាឯកវចនៈយ៉ាងនេះថា **សឡាយតនប្បច្ចយា ផស្សោ** ផស្សៈកើតមានព្រោះសឡាយតនៈជាបច្ច័យ ។ ចំណែកក្នុងអាយតនៈទាំងឡាយ

អាយតនៈខាងក្នុង ៥ ជាបច្ច័យ ៦ យ៉ាង បន្ទាប់អំពីនោះ
អាយតនៈ ១ គឺមនាយតនៈ ជាបច្ច័យ ៩ យ៉ាង នឹងគប្បីចន្លុល

បង្ហាញអាយតនៈខាងក្រៅទាំងឡាយ ក្នុងភាពជាបច្ច័យដល់ផស្សៈនេះ តាមដែលកើតឡើង ។

ក្នុងគាថានោះ មានអធិប្បាយដូច្នេះថា អាយតនៈខាងក្នុង មានចក្ខាយតនៈជាដើមជាបច្ច័យ ៦ យ៉ាង ដល់ផស្សៈ ៥ យ៉ាង មានផស្សៈ ៥ មានចក្ខុសម្ផស្សជាដើម ដោយអំណាចនៃនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ ខាងមុខអំពីនោះ អាយតនៈ ១ គឺមនាយតនៈដែលជាវិបាក ជាបច្ច័យ ៩ យ៉ាង ដល់មនោសម្ផស្ស ដែលជាវិបាកមានច្រើនប្រភេទ ដោយអំណាចសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ តែគប្បីអធិប្បាយអាយតនៈខាងក្រៅ ៦ ក្នុងភាពជាបច្ច័យដល់ផស្សៈនេះ តាមដែលកើតឡើងយ៉ាងនេះថា បណ្តាអាយតនៈខាងក្រៅទាំងឡាយ រូបាយតនៈជាបច្ច័យដល់ចក្ខុសម្ផស្ស ដោយអំណាចអារម្មណប្បច្ច័យ បុរេជាតប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ សទ្ទាយតនៈជាដើម ក៏ជាបច្ច័យដល់សោតសម្ផស្សជាដើមយ៉ាងនោះ តែអាយតនៈខាងក្រៅទាំងនោះ និងធម្មាយតនៈជាបច្ច័យដល់មនោសម្ផស្សដោយប្រការនោះ និងដោយត្រឹមតែជាអារម្មណប្បច្ច័យប៉ុណ្ណោះ ដោយប្រការដូច្នេះឯង ៕

## និទ្ទេសនៃសឡាយតនៈជាបច្ច័យនៃផស្សៈ ចប់

# វេទនានិទ្ទេស

[ ៨ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងនិទ្ទេសនៃផស្សៈជាបច្ច័យដល់វេទនា ដូចតទៅ

ពោលដោយទ្វារ ព្រះមានព្រះភាគត្រាស់វេទនា ៦ យ៉ាង ប៉ុណ្ណោះ មានវេទនាកើតអំពីចក្ខុសម្ផស្សជាដើម ពោលដោយ ប្រភេទវេទនាទាំងនោះ ត្រាស់ ៨៩ យ៉ាង ។

ពិតហើយ ពោលដោយទ្វារ វេទនា ៦ ប៉ុណ្ណោះ មានវេទនាកើតអំពីចក្ខុសម្ផស្សទាំងនេះជាដើម ត្រាស់ក្នុងព្រះបាលីដោយន័យជាដើមថា ចក្ខុ-សម្ផស្សជាវេទនា គឺវេទនាកើតអំពីចក្ខុសម្ផស្ស ដូច្នេះ តែដោយប្រភេទវេទនាទាំងនោះ ទ្រង់ត្រាស់ថា មាន ៨៩ ព្រោះសម្បយុត្តដោយចិត្ត ៨៩ ដូងនោះឯង ។

បណ្តាវេទនាទាំង ៨៩ ប្រភេទនេះ លោកពោលថា វេទនា ដែលប្រកបដោយវិបាកចិត្ត ៣២ ដួងប៉ុណ្ណោះ ទ្រង់បំណងយក ក្នុងនិទ្ទេសនេះ ។

ក្នុងវេទនាទាំងឡាយនោះ ក្នុងបញ្ចទ្វារ ផស្សៈជាបច្ច័យ ៨ ដល់វេទនា ៥ ជាបច្ច័យ ១ ដល់វេទនាដ៏សេស ក្នុងមនោទ្វារ ផស្សៈនោះ ក៏ជាបច្ច័យយ៉ាងនោះ ។

ពិតហើយ ក្នុងគាថានោះ ក្នុងបញ្ចទ្វារ ផស្សៈមានចក្ខុសម្ផស្សជាដើម ជាបច្ច័យ ៨ យ៉ាង ដល់វេទនា ៥ មានចក្ខុបសាទជាដើមជាទីតាំង កើត ដោយអំណាចសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ

អាហារប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ ម្យ៉ាងទៀត ផស្សៈ មានចក្ខុសម្ផស្សជាដើម ជាបច្ច័យតែម្យ៉ាងប៉ុណ្ណោះ ដោយអំណាចឧបនិស្សយប្បច្ច័យ ដល់កាមាវចរវិបាក វេទនាដ៏សេសដែលប្រព្រឹត្តទៅ ដោយអំណាចសម្បដិច្ឆន្នៈ សន្តីរណៈ និងតទារម្មណៈ ក្នុងទ្វារតែមួយទ្វារ ។

ពាក្យថា ក្នុងមនោទ្វារ ផស្សៈនោះ ក៏ជាបច្ច័យយ៉ាងនោះ សេចក្ដីថា ក្នុងមនោទ្វារ ផស្សៈនោះ គឺសហជាតមនោសម្ផស្ស ជាបច្ច័យ ៨ យ៉ាងដូចគ្នានោះឯងដល់កាមាវចរវិបាកវេទនា ដែលប្រព្រឹត្តទៅដោយអំណាចនៃតទារម្មណៈ និងជាបច្ច័យដល់វិបាកវេទនាក្នុងភូមិ ៣ ដែលប្រព្រឹត្តទៅដោយអំណាចបដិសន្ធិ ភវង្គ និងចុតិ ។ ម្យ៉ាងទៀត ក្នុងមនោទ្វារ មនោផស្សៈដែលសម្បយុត្តដោយអាវជ្ជនៈ ជាបច្ច័យតែម្យ៉ាង ដោយអំណាចឧបនិស្សយប្បច្ច័យដល់កាមាវចរវេទនា ដែលប្រព្រឹត្តទៅដោយអំណាចតទារម្មណៈ ក្នុងមនោទ្វារ ដូច្នេះឯង ។៙

## និទ្ទេសនៃផស្សៈជាបច្ច័យដល់វេទនា ចប់

# តណ្ហានិទ្ទេស

[ ៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃវេទនា ជាបច្ច័យនៃតណ្ហាដូចតទៅ តណ្ហា ៦ យ៉ាង ទ្រង់សម្តែងក្នុងនិទ្ទេសនេះ ដោយការផ្សេងគ្នានៃរូបតណ្ហាជាដើម ក្នុងតណ្ហាទាំង ៦ នោះ តែតណ្ហា ១ ទ្រង់ត្រាស់ ៣ យ៉ាង ដោយអាការដែលប្រព្រឹត្តទៅ ។

ក្នុងនិទ្ទេសនៃវេទនាជាបច្ច័យដល់តណ្ហានេះ មានអធិប្បាយថា តណ្ហា ៦ យ៉ាងទ្រង់សម្តែងហើយ គឺទ្រង់ប្រកាសហើយ ត្រាស់ហើយដោយអំណាចនៃឈ្មោះ ដោយអារម្មណ៍ថា រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ដូច្នេះ ដូចបុត្រដែលគេប្រកាសឈ្មោះតាមបិតាថា សេដ្ឋីបុត្ត ព្រាហ្មណបុត្ត ដូច្នោះ ។ ក្នុងពាក្យទាំងនោះ គប្បីជ្រាបអត្ថនៃពាក្យដោយន័យនេះថា តណ្ហាក្នុងរូប ឈ្មោះថា រូបតណ្ហា ដូច្នេះ ។

បណ្តាតណ្ហាទាំងនោះ តណ្ហា ១ ទ្រង់ត្រាស់ ៣ គឺកាមតណ្ហា ភវ-តណ្ហា វិភវតណ្ហា ដោយអាការដែលប្រព្រឹត្តទៅ ពិតហើយ ក្នុងកាលណា រូបតណ្ហានោះឯង ត្រេកអរក្នុងរូបារម្មណ៍ ដែលមកកាន់គន្លងចក្ខុ ដោយអំណាចការត្រេកអរក្នុងកាមប្រព្រឹត្តទៅ ក្នុងកាលនោះ ឈ្មោះថា កាមតណ្ហា ក្នុងកាលណា រូបតណ្ហាប្រព្រឹត្តទៅព្រមជាមួយទិដ្ឋិដែលប្រព្រឹត្តទៅថា រូបា-រម្មណ៍នោះឯងទៀង ស្ថិតស្ថេរ ដូច្នេះ ក្នុងកាលនោះ ឈ្មោះថា ភវតណ្ហា ព្រោះរាគៈកើតរួមជាមួយនឹងសស្សតទិដ្ឋិ ហៅថា ភវតណ្ហា ក្នុងកាលណា រូបតណ្ហានោះ ប្រព្រឹត្តទៅព្រមជាមួយឧច្ឆេទទិដ្ឋិដែលប្រព្រឹត្តទៅថា រូបារម្មណ៍នោះឯងដាច់សូន្យ រមែងវិនាស ដូច្នេះ ក្នុងកាលនោះ ឈ្មោះថា វិភវតណ្ហា ។

រាគៈកើតរួមជាមួយឧច្ឆេទទិដ្ឋិ ហៅថា វិភវតណ្ហា ។ សូម្បីក្នុងសទ្ទតណ្ហាជាដើម ក៏ន័យនេះដូចគ្នា ព្រោះហេតុនោះ ទើបតណ្ហានេះ រួមជា ១៨ ។

តណ្ហាទាំងនោះ ក្នុងរូបខាងក្នុងជាដើម មាន ១៨ យ៉ាង ក្នុងរូបខាងក្រៅ មាន ១៨ យ៉ាង ព្រោះហេតុនោះ ទើបជាតណ្ហា ៣៦ យ៉ាង តណ្ហាទាំងនោះជាអតីត ៣៦ អនាគត ៣៦ បច្ចុប្បន្ន ៣៦ រួមជាតណ្ហា ១០៨ ដោយប្រការដូច្នេះ ។

តណ្ហាទាំង ១០៨ នោះ បើសង្ខេប គប្បីជ្រាបថា ជាតណ្ហា ៦ ដោយអំណាចនៃរូបារម្មណ៍ជាដើម ឬជាតណ្ហា ៣ ប៉ុណ្ណោះ ដោយអំណាចកាមតណ្ហាជាដើម ។

ព្រោះសត្វទាំងនេះត្រេកអរ វេទនាដែលកើតឡើងដោយអំណាចរូបារម្មណ៍ ទើបធ្វើសក្ការៈធំដល់ចិត្រករ គឺជាងគំនូរ គន្ធព្វៈ គឺអ្នកតន្ត្រី អ្នកធ្វើគ្រឿងក្រអូប ចុងភៅ ជាងតម្បាញ និងគ្រូពេទ្យដែលធ្វើវិធីផ្សេងៗ ឲ្យកើតនូវការត្រេកអរជាដើម ដែលឲ្យនូវអារម្មណ៍ មានរូបជាដើម ដោយប្រកាន់វេទនាថាជារបស់អញ ដូចបុគ្គលស្រឡាញ់បុត្រ ដោយការប្រកាន់បុត្រថាជារបស់អញ ធ្វើសក្ការៈធំដល់មេដោះ ដូច្នោះ តណ្ហាទាំងអស់នេះ គប្បីជ្រាបថា កើតព្រោះវេទនាជាបច្ច័យ ។

*តែព្រោះក្នុងនិទ្ទេសថា វេទនាជាបច្ច័យនៃតណ្ហានេះ ទ្រង់បំណាងយកសុខវេទនា ដែលជាវិបាកតែម្យ៉ាងប៉ុណ្ណោះ ព្រោះហេតុនោះ ទើបវេទនាជាបច្ច័យតែម្យ៉ាងប៉ុណ្ណោះដល់តណ្ហា ។*

ពាក្យថា ជាបច្ច័យតែម្យ៉ាង បានដល់ ជាបច្ច័យដោយឧបនិស្ស-យប្បច្ច័យ ។

ម្យ៉ាងទៀត

ព្រោះបុគ្គលមានទុក្ខ រមែងប្រាថ្នាសុខ បុគ្គលមានសុខ ក៏រមែងប្រាថ្នាសុខក្រៃលែងឡើងទៅ ចំណែកឧបេក្ខាទ្រង់ត្រាស់ថាជាសុខនោះឯង ព្រោះជាធម៌ស្ងប់ ។ ហេតុនោះ ទើបវេទនាទាំង ៣ ជាបច្ច័យដល់តណ្ហា ទើបព្រះមហាឥសីត្រាស់ថា តណ្ហាកើតមានព្រោះវេទនាជាបច្ច័យ ។ ម្យ៉ាងទៀត ព្រោះវៀរអនុស័យហើយ តណ្ហា រមែងមិនកើត ព្រោះវេទនាជាបច្ច័យ ហេតុនោះ ទើបតណ្ហានោះ មិនមានដល់ព្រាហ្មណ៍ អ្នកមានព្រហ្មចរិយៈចប់ហើយ ។ល។

## និទ្ទេសនៃវេទនាជាបច្ច័យនៃតណ្ហា ចប់

# ឧបាទាននិទ្ទេស

[ ១០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃតណ្ហាជាបច្ច័យដល់ឧបាទាន ដូចតទៅ

បណ្ឌិតគប្បីចង្អុលបង្ហាញឧបាទាន ៤ ប៉ុណ្ណោះ ដោយចែកដោយអត្ថ ដោយសង្ខេប និងដោយពិស្តារនៃធម៌ និងដោយលំដាប់ ។

ពិតហើយ ក្នុងព្រះបាលី ទ្រង់លើកឧបាទាន ៤ ឡើង ដោយព្រះតម្រាស់ថា ពាក្យថា ឧបាទាន បានដល់ កាមុបាទាន ទិដ្ឋុបាទាន សីលព្វតុបាទាន អត្តវាទុបាទាន ។

ការចែកដោយអត្ថនៃឧបាទាន ៤ នោះ មានដូចតទៅ

ធម៌ដែលឈ្មោះថា កាមុបាទាន ព្រោះអត្ថថា ប្រកាន់មាំនូវកាម ពោលគឺវត្ថុកាម ម្យ៉ាងទៀត កាមនោះផង ជាឧបាទានផង ព្រោះហេតុនោះ ទើបឈ្មោះថា កាមុបាទាន ។

ពាក្យថា ឧបាទាន បានដល់ ការប្រកាន់មាំ ព្រោះ **ឧប** សព្ទ ក្នុងពាក្យថា **ឧបាទាន** នេះ មានអត្ថថា មាំ ដូចក្នុងសព្ទជាដើមថា **ឧបាយាស** ការចង្អៀតចង្អល់ចិត្តខ្លាំង **ឧបកដ្ឋ** ពេលវេលាខិតចូលមកជិតណាស់ហើយជាដើម ម្យ៉ាងទៀត ទិដ្ឋិនោះផង ជាឧបាទានផង ទើបឈ្មោះថា **ទិដ្ឋុបាទាន**។ ម្យ៉ាងទៀត ដែលឈ្មោះថា ទិដ្ឋុបាទាន ព្រោះអត្ថថា ប្រកាន់មាំនូវទិដ្ឋិ ។

ព្រោះទិដ្ឋិក្រោយ រមែងប្រកាន់មាំក្នុងទិដ្ឋិមុន ដូចក្នុងប្រយោគជាដើមថា អត្តា និងលោកទៀងជាដើម ។ ម្យ៉ាងទៀត ដែលឈ្មោះថា **សីលព្វតុបាទាន** ព្រោះអត្ថថា ប្រកាន់មាំក្នុងសីល និងវត្ត សីល និងវត្តនោះផង

ជាឧបាទានផង ឈ្មោះថា សីលព្វតុបាទាន ព្រោះគោសីល គោវត្តជាដើម ជាតួឧបាទានឯង ព្រោះប្រកាន់មាំថា សេចក្តីបរិសុទ្ធមានដោយអាការយ៉ាង នេះ ។ ម្យ៉ាងទៀត ដែលឈ្មោះថា **វាទ** ព្រោះជាហេតុពោលរបស់មនុស្ស ទាំងឡាយ ដែលឈ្មោះថា **ឧបាទាន** ព្រោះហេតុប្រកាន់មាំរបស់មនុស្ស ទាំងឡាយ សួរថា រមែងពោលដូចម្តេច ឬប្រកាន់មាំនូវអ្វី ឆ្លើយថា ពោល អត្តា ប្រកាន់មាំអត្តា គឺការប្រកាន់មាំនូវវាទៈរបស់ខ្លួន ឈ្មោះថា **អត្តវាទុបាទាន** ។ ម្យ៉ាងទៀត អត្តា ក៏ត្រឹមតែជាការពោលដល់មនុស្សប៉ុណ្ណោះ ព្រោះហេតុនោះ ទើបឈ្មោះថា **អត្តវាទុបាទាន** ព្រោះអត្តថា ជាហេតុ ប្រកាន់មាំរបស់មនុស្សទាំងឡាយ ។ នេះជាការចែកអត្ថនៃឧបាទាន ៤ ទាំង នោះប៉ុណ្ណោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសេចក្តីសង្ខេប និងពិស្តារនៃធម៌ដូចតទៅ

កាមុបាទាន ដោយសង្ខេបទ្រង់ត្រាស់ថា ការប្រកាន់មាំដោយតណ្ហា ព្រោះព្រះបាលី ( ក្នុងអភិធម្ម ធម្មសង្គណី ) មកហើយថា បណ្តាឧបាទាន ទាំងនោះ កាមុបាទាន តើដូចម្តេច ។ សេចក្តីប្រាថ្នាចំពោះកាម ការត្រេកអរ ចំពោះកាម ការរីករាយចំពោះកាម ការអន្ទះសាចំពោះកាម សេចក្តីស្រឡាញ់ ចំពោះកាម ការរោលរាលចំពោះកាម ការជ្រុលជ្រប់ចំពោះកាម ការងុលងប់ចំពោះកាមណា ក្នុងកាមទាំងឡាយ នេះហៅថា កាមុបាទាន ដូច្នេះ ។ តណ្ហាក្រោយ កើតឡើងប្រកាន់មាំនូវតណ្ហាមុននោះឯង ដោយឧបនិស្សយប្បច្ច័យ ឈ្មោះថា ការប្រកាន់មាំដោយតណ្ហា ។

តែអាចារ្យពួកខ្លះពោលថា ការប្រាថ្នាអារម្មណ៍ ដែលមិនទាន់មកដល់ ឈ្មោះថា តណ្ហា ដូចចោរលាដៃទៅដើម្បីលួចរបស់ក្នុងទីងងឹត ការទទួលនូវអារម្មណ៍ដែលមកដល់ហើយ ឈ្មោះថា ឧបាទាន ដូចចោរនោះឯងចាប់កណ្ឌ ឯធម៌ គឺតណ្ហា និងឧបាទានទាំងនោះ ជាបដិបក្ខចំពោះការប្រាថ្នាតិច និងការសន្តោស ។ ម្យ៉ាងទៀត ធម៌ទាំងនេះគង់ជាមូលនៃទុក្ខ ព្រោះត្រូវស្វែងរក និងត្រូវរក្សា ដូច្នេះ ឯឧបាទាន ៣ ដ៏សេស ដោយសង្ខេប ក៏ត្រឹមតែជាទិដ្ឋិប៉ុណ្ណោះ ។ តែបើពោលដោយពិស្តារ ការប្រកាន់មាំដោយតណ្ហាទាំង ១០៨ តាមដែលពោលក្នុងអារម្មណ៍ មានរូបជាដើមមុន ឈ្មោះថា កាមុបាទាន ។

មិច្ឆាទិដ្ឋិមានវត្ថុ ១០ ឈ្មោះថា **ទិដ្ឋុបាទាន** ដូចព្រះតម្រាស់ ( ក្នុងអភិធម្ម ធម្មសង្គណី ) ថា បណ្តាឧបាទានទាំងនោះ ទិដ្ឋុបាទាន តើដូចម្តេច ។ ការយល់ថា ទានដែលបានឲ្យហើយមិនមានផល បូជាធំមិនមានផល ។បេ។ ពួកសមណព្រាហ្មណ៍ក្នុងលោក ជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិល្អ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងហើយសម្តែងប្រាប់បាន ក៏មិនមាន និងទិដ្ឋិ ដំណើរ គឺទិដ្ឋិ ។បេ។ ភាពនៃចិត្តខុស លទ្ធិដូចជាកំពង់ សេចក្តីប្រកាន់ក្នុងការស្វែងរកខុសណា ដែលមានសភាពបែបនេះ នេះហៅថា ទិដ្ឋុបាទាន ដូច្នេះ ។

ម្យ៉ាងទៀត ការប្រកាន់មាំថា សេចក្តីបរិសុទ្ធមានដោយសីល និងវត្តឈ្មោះថា សីលព្វតុបាទាន ដូចព្រះតម្រាស់ ( ក្នុងអភិធម្ម ធម្មសង្គណី ) ថា បណ្តាឧបាទានទាំងនោះ សីលព្វតុបាទាន តើដូចម្តេច ។ ពួកសមណ-

ព្រាហ្មណ៍ខាងក្រៅ អំពីសាសនានេះ ( ប្រកាន់ថា ) សេចក្តីបរិសុទ្ធដោយសីល បរិសុទ្ធដោយវត្ត បរិសុទ្ធដោយសីល និងវត្ត ។បេ។ ភាពនៃចិត្តខុសលទ្ធិដូចជាកំពង់ សេចក្តីប្រកាន់ក្នុងការស្វែងរកខុសណា ដែលមានសភាពបែបនេះ នេះហៅថា សីលព្វតុបាទាន ដូច្នេះ ។

សក្កាយទិដ្ឋិ មានវត្ថុ ២០ ឈ្មោះថា អត្តវាទុបាទាន ដូចព្រះតម្រាស់ ( ក្នុងអភិធម្ម ធម្មសង្គណី ) ថា បណ្តាឧបាទានទាំងនោះ អត្តវាទុបាទាន តើដូចម្តេច ។ បុថុជ្ជន ជាអ្នកមិនចេះដឹង ក្នុងលោកនេះ មិនធ្លាប់ឃើញពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងអរិយធម៌ មិនទូន្មានខ្លួនក្នុងអរិយធម៌ មិនធ្លាប់ឃើញពួកសប្បុរស ។បេ។ ភាពនៃចិត្តខុស លទ្ធិដូចជាកំពង់ សេចក្តីប្រកាន់ក្នុងការស្វែងរកខុសណា ដែលមានសភាពបែបនេះ នេះហៅថា អត្តវាទុបាទាន ដូច្នេះ ។ នេះជាសេចក្តីសង្ខេប និងសេចក្តីពិស្តារនៃធម៌ក្នុងអធិការនេះ ។

ក្នុងពាក្យថា ដោយលំដាប់នេះ លំដាប់មាន ៣ យ៉ាង គឺលំដាប់នៃការកើត ១ លំដាប់នៃការលះ ១ លំដាប់នៃទេសនា ១ ។

បណ្តាលំដាប់ទាំង ៣ នោះ លំដាប់នៃការកើតរបស់កិលេសទាំងឡាយ មិនត្រាស់ដោយនិប្បរិយាយ ព្រោះមិនមានពាក្យថា ឧបាទាននេះកើតឡើងមុនក្នុងសង្សារ ដែលមានខាងដើម និងទីបំផុត ដែលបុគ្គលដឹងមិនបាន តែក៏ត្រាស់ដោយបរិយាយថា ជាការប្រកាន់មាំក្នុងសស្សតៈ និងឧច្ឆេទៈ ដែលមានការប្រកាន់អត្តាជាធំ ក្នុងភពមួយដោយច្រើន បន្ទាប់អំពីនោះ កាលប្រកាន់ថា អត្តានេះទៀង ដូច្នេះ ទើបកើតសីលព្វតុបាទាន ដើម្បីកិច្ចបដិបត្តិ

ដ៏បរិសុទ្ធនៃអត្តា កាលប្រកាន់ថា អត្តារមែងដាច់សូន្យ ក៏នឹងកើតកាមុបាទានដល់បុគ្គលដែលមិនមានអាល័យក្នុងលោកដទៃ ព្រោះហេតុនោះ ទើបអត្តវាទុបាទានកើតឡើងមុន បន្ទាប់អំពីនោះ ក៏កើតទិដ្ឋុបាទាន សីលព្វតុបាទាន និងកាមុបាទាន នេះជាលំដាប់នៃការកើតឡើងរបស់ឧបាទានទាំងនោះក្នុងភពមួយ ដោយប្រការដូច្នេះ ។

ក្នុងពាក្យថា លំដាប់នៃការលះនេះ ទិដ្ឋុបាទានជាដើមដែលបុគ្គលរមែងលះមុន ព្រោះជាកិលេស ដែលសោតាបត្តិមគ្គគប្បីលះ ខាងក្រោយ ទើបលះកាមុបាទាន ព្រោះជាកិលេស ដែលអរហត្តមគ្គគប្បីលះ នេះជាលំដាប់នៃការលះឧបាទានទាំងនោះ ដោយប្រការដូច្នេះ ។

បណ្តាឧបាទានទាំង ៤ នេះ ទ្រង់សម្តែងកាមុបាទានមុន ព្រោះកិលេសមានអារម្មណ៍ច្រើន និងព្រោះកិលេសប្រាកដហើយ ពិតហើយ កាមុបាទាននោះ ឈ្មោះថា មានអារម្មណ៍ច្រើន ព្រោះប្រកបដោយលោភមូលចិត្ត ៨ ដួង ឧបាទានក្រៅអំពីនេះ មានអារម្មណ៍តិច ព្រោះប្រកបដោយ ( លោភមូលដែលសម្បយុត្តដោយទិដ្ឋិ ) ចិត្ត ៤ ដួង ។ ម្យ៉ាងទៀត កាមុបាទានប្រាកដដល់ពួកសត្វ ព្រោះសេចក្តីអាល័យ និងត្រេកអរដោយច្រើន ឧបាទានក្រៅអំពីនេះ មិនដូច្នោះឡើយ ។ ម្យ៉ាងទៀត កាមុបាទាន ជារបស់មានច្រើនដល់បុគ្គលដែលជឿនូវមង្គលភ្ញាក់ផ្អើលជាដើម ដើម្បីសម្រេចវត្ថុកាមទាំងឡាយ សស្សតទិដ្ឋិ មិនដូច្នោះឡើយ ព្រោះហេតុនោះ ទើបទ្រង់សម្តែងទិដ្ឋុបាទានក្នុងលំដាប់បន្តអំពីកាមុបាទាននោះ ទិដ្ឋុបាទាននោះ កាលចែកជាពីរ

*ដោយអំណាចនៃសីលព្វតុបាទាន និងអត្តវាទុបាទាន ក្នុងឧបាទាន ២ នោះ ទ្រង់សម្តែងសីលព្វតុបាទានថា មានអារម្មណ៍គ្រោតគ្រាតមុន ព្រោះបុគ្គលឃើញកិរិយារបស់គោ ឬកិរិយារបស់សុនខហើយក៏ដឹងបាន ហើយទ្រង់សម្តែងអត្តវាទុបាទានក្នុងទីបំផុត ព្រោះជាធម៌មានអារម្មណ៍ល្អិត ។ នេះជាលំដាប់នៃទេសនារបស់ឧបាទានទាំងឡាយ ដោយប្រការដូច្នេះ ។*

*បណ្តាឧបាទានទាំងនេះ តណ្ហាជាបច្ច័យតែម្យ៉ាងដល់ឧបាទានដំបូង តណ្ហានោះ ជាបច្ច័យ ៧ យ៉ាងខ្លះ ៨ យ៉ាងខ្លះ ដល់ឧបាទាន ៣ ដ៏សេស ។*

*ក្នុងឧបាទាន ៤ ដែលទ្រង់សម្តែងក្នុងនិទ្ទេសនេះ ដោយអាការយ៉ាងនេះ កាមតណ្ហា រមែងជាបច្ច័យតែម្យ៉ាង ដោយអំណាចឧបនិស្សយប្បច្ច័យដល់កាមុបាទានដំបូង ព្រោះកើតក្នុងអារម្មណ៍ទាំងឡាយដែលពេញចិត្តដោយតណ្ហា តែតណ្ហានោះរមែងជាបច្ច័យ ៧ យ៉ាង ដោយអំណាចសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ និងហេតុប្បច្ច័យ ឬជាបច្ច័យ ៨ យ៉ាង មួយអន្លើដោយឧបនិស្សយប្បច្ច័យ ដល់ឧបាទាន ៣ ដ៏សេស ម្យ៉ាងទៀត កាលណាតណ្ហានោះជាបច្ច័យដោយអំណាចឧបនិស្សយប្បច្ច័យ កាលនោះ តណ្ហានោះ រមែងកើតព្រមគ្នានោះឯង ។ល។*

**និទ្ទេសនៃតណ្ហាជាបច្ច័យនៃឧបាទាន ចប់**

# ភវនិទ្ទេស

[ ១១ ] ក្នុងនិទ្ទេសនៃឧបាទានជាបច្ច័យដល់ភព មានដូចតទៅ គប្បីជ្រាបវិនិច្ឆ័យដោយអត្ថ ដោយធម៌ ដោយពិចារណាឡើងវិញ នូវបទដែលមានប្រយោជន៍ ដោយការញែកភព និងរួមភព ដោយឧបាទានណា ជាបច្ច័យដល់ភពណា ។

ក្នុងព្រះបាលីនោះ គប្បីជ្រាបវិនិច្ឆ័យថា ដែលឈ្មោះថា ភព ព្រោះអត្ថថា មាន ។ បទថា **ទុវិធេន** មានអធិប្បាយថា កំណត់ដោយអាការពីរយ៉ាង ។ម្យ៉ាងទៀត បទថា **ទុវិធេន** ជាតតិយាវិភត្តិ ចុះក្នុងបឋមាវិភត្តិ អធិប្បាយថា ស្មើជាមួយ **ទុវិធោ** ប្រែថា ២ យ៉ាង ។ បទថា **អត្ថិ** បានដល់ មានព្រម ។

ភព គឺកម្ម ឈ្មោះថា កម្មភព ។ ភព គឺការកើតឡើង ឈ្មោះថា ឧបបត្តិភព ។ ក្នុងកម្មភព និងឧបបត្តិភពនេះ ការកើតឡើង ឈ្មោះថា ភព ព្រោះអត្ថថា មាន ។ ចំណែកកម្មគប្បីជ្រាបថា ឈ្មោះថា ភព ដោយវោហារថា ជាផល ព្រោះកម្មជាហេតុរបស់ភព ដូចព្រះតម្រាស់ ( ក្នុងខុទ្ទកនិកាយ ធម្មបទ ) ថា ការកើតឡើងនៃព្រះពុទ្ធ ជាសុខ ដូច្នេះ ព្រោះជាហេតុនាំមកនូវសេចក្តីសុខ ។

ពាក្យថា **តត្ថ កតមោ កម្មភវោ** សេចក្តីថា បណ្តាភពទាំងពីរនោះ កម្មភពដែលត្រាស់ហើយនោះ ដូចម្តេច ។ បុញ្ញាភិសង្ខារជាដើម មានអត្ថតាមដែលពោលហើយនោះឯង ។

បទថា **សព្វំ** បានដល់ មិនមានចំណែកសេសសល់ ។ កម្មដែលឈ្មោះថា ជាហេតុឲ្យទៅកាន់ភព ព្រោះអត្ថថា ទៅ គឺឲ្យសត្វដល់ភព ។ ដោយ

បទថា កម្មជាហេតុឲ្យទៅកាន់ភពនេះ លោកបដិសេធលោកុត្តរ ព្រោះកថានេះជាវដ្តកថា ឯលោកុត្តរនោះ លោកពោលថា ជាធម៌អាស្រ័យវិវដ្ដៈ ។ ដែលឈ្មោះថា **កម្ម** ព្រោះអត្ថថា ជារបស់ដែលសត្វធ្វើ ។

បណ្ដាកាមភពជាដើម ភព ពោល គឺកាម ឈ្មោះថា **កាមភវោ** ។ ក្នុងរូបភព និងអរូបភព ក៏ន័យនេះឯង ។ ដែលឈ្មោះថា **សញ្ញាភវោ** ព្រោះអត្ថថា ជាភពរបស់សត្វដែលមានសញ្ញា ឬសញ្ញាមានក្នុងភពនេះ ។ ដែលឈ្មោះថា **អសញ្ញាភវោ** ដោយបរិយាយដែលផ្សេងគ្នា ។ ដែលឈ្មោះថា **នេវសញ្ញានាសញ្ញាភវោ** ដោយអត្ថថា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ព្រោះមិនមានសញ្ញាគ្រោតគ្រាត និងព្រោះមានសញ្ញាល្អិតក្នុងភពនេះ ។ ភពដែលដេរដាសដោយរូបក្ខន្ធតែម្យ៉ាង ឈ្មោះថា **ឯកវោការភព** ។ ម្យ៉ាងទៀត ឈ្មោះថា **ឯកវោការភព** ព្រោះអត្ថថា ភពនេះមានខន្ធ ១ ។ ក្នុងចតុវោការភព និងបញ្ចវោការភព ក៏ន័យនេះឯង ។

បទថា **អយំ វុច្ចតិ ឧប្បត្តិភវោ** បានដល់ ភពទាំង ៩ យ៉ាង ត្រាស់ហៅថា **ឧបបត្តិភព** ដូច្នេះ ។ គប្បីជ្រាបវិនិច្ឆ័យដោយអត្ថក្នុងអធិការនេះយ៉ាងនេះសិន ។

ចំណែកបទវិនិច្ឆ័យដោយធម៌ក្នុងនិទ្ទេសនេះ ពោលដោយធម៌ បុញ្ញាភិ-សង្ខារ បានដល់ ចេតនា ១៣ ដួង អបុញ្ញាភិសង្ខារ បានដល់ ចេតនា ១២ ដួង អានេញ្ជាភិសង្ខារ បានដល់ ចេតនា ៤ ដួង ។

ដោយបទថា **សព្វម្បិ ភវគាមិកម្មំ** នេះ ទ្រង់សង្គ្រោះធម៌ទាំងអស់

នេះ ឬធម៌ដែលសម្បយុត្តដោយចេតនា ដែលជាអាចយគាមី ពោល គឺកម្មចូលផងដែរ អធិប្បាយថា កាមភព បានដល់ ខន្ធ ៥ ដែលជាឧបាទិន្ន ( ខន្ធដែលមានកម្ម និងកិលេសគ្រប់គ្រង ) រូបភពក៏ដូចគ្នា ។ អរូបភព បានដល់ ខន្ធ ៤ ដែលជាឧបាទិន្ន ។ សញ្ញាភព បានដល់ ខន្ធ ១ និងខន្ធ ៥ ដែលជាឧបាទិន្ន ។ នេវសញ្ញានាសញ្ញាភព បានដល់ ខន្ធ ៤ ដែលជាឧបាទិន្ន ។ ឯកវោការភពជាដើម បានដល់ ខន្ធ ១ ខន្ធ ៤ និងខន្ធ ៥ ដែលជាឧបាទិន្ន ។ គប្បីជ្រាបវិនិច្ឆ័យដោយធម៌ ក្នុងអធិការនេះ ដោយប្រការដូច្នេះ ។

ពាក្យថា ដោយពិចារណាឡើងវិញនូវបទមានប្រយោជន៍នេះ សេចក្ដីថា បុញ្ញាភិសង្ខារជាដើមនោះឯង ត្រាស់ក្នុងនិទ្ទេសនៃសង្ខារ គឺកម្ម ដូចក្នុងនិទ្ទេសនៃភពនោះឯង កាលបើដូច្នោះ អភិសង្ខារដែលកើតមុន ត្រាស់ជាអតីតកម្ម ព្រោះភាពជាបច្ច័យដល់បដិសន្ធិក្នុងភពនេះ អភិសង្ខារទាំងនេះត្រាស់ដោយអំណាចកម្មក្នុងបច្ចុប្បន្ន ព្រោះភាពជាបច្ច័យដល់បដិសន្ធិក្នុងភពតទៅ ព្រោះហេតុនោះ ការត្រាស់ដដែលទៀត ទើបឈ្មោះថា មានប្រយោជន៍នោះឯង ។ម្យ៉ាងទៀត ខាងដើម ទ្រង់ត្រាស់ចេតនាប៉ុណ្ណោះថា ជាសង្ខារដោយន័យជាដើមយ៉ាងនេះថា បុញ្ញាភិសង្ខារ តើដូចម្ដេច កុសលជាចេតនាជាកាមាវចរ ដូច្នេះ ។ តែក្នុងនិទ្ទេសនៃឧបាទានជាបច្ច័យដល់ភពនេះ ធម៌សម្បយុត្តដោយចេតនា ក៏ត្រាស់ថាជាសង្ខារ ព្រោះបាលីថា **សព្វម្បិ ភវ-គាមិកម្មំ**សូម្បីកម្មទាំងអស់ ដែលជាដំណើរទៅកាន់ភព ដូច្នេះ ។ ម្យ៉ាងទៀត

ខាងដើមត្រាស់កម្មដោយចំពោះ ដែលមានវិញ្ញាណជាបច្ច័យប៉ុណ្ណោះថា ជាសង្ខារ ក្នុងឥឡូវនេះ សូម្បីកម្មដែលមានវិញ្ញាណជាបច្ច័យ ដែលឲ្យកើតឡើងក្នុងអសញ្ញាភព ក៏ត្រាស់ថាជាសង្ខារ ។ ឯការនិយាយច្រើនមិនមានប្រយោជន៍អ្វី ព្រោះកម្ម ដែលជាកុសល និងអកុសល គឺបុញ្ញាភិសង្ខារជាដើមនោះឯងត្រាស់ក្នុងបទនេះថា **អវិជ្ជាបច្ចយា សង្ខារា** ម្យ៉ាងទៀត ត្រាស់ធម៌ទាំងឡាយដែលជាកុសល អកុសល អព្យាកត ព្រោះឧបបត្តិភព ក៏ទ្រង់សង្គ្រោះក្នុងបទថា **ឧបាទានបច្ចយា ភវោ** ព្រោះហេតុនោះ ទើបព្រះតម្រាស់នេះឈ្មោះថា មានប្រយោជន៍ដោយប្រការទាំងពួង ព្រោះហេតុនោះ គប្បីជ្រាបវិនិច្ឆ័យ ដោយពិចារណាឡើងវិញនូវបទដែលមានប្រយោជន៍ ក្នុងអធិការនេះ ដោយប្រការដូច្នេះ ។

ពាក្យថា ដោយការចែកភព និងរួមភព បានដល់ ដោយការចែក និងការរួមនៃភព ព្រោះឧបាទានជាបច្ច័យ ។ ពិតហើយ កម្មដែលឲ្យកើតឡើងក្នុងកាមភពដែលសត្វធ្វើ ព្រោះកាមុបាទានជាបច្ច័យ ឈ្មោះថា **កម្មភព** ។ ខន្ធទាំងឡាយដែលកើតឡើងអំពីកម្មនោះ ឈ្មោះថា **ឧបបត្តិភព** ។ ក្នុងរូបនិងអរូបភព ក៏មានន័យដូចគ្នា ។ ដោយប្រការដូច្នេះ ព្រោះកាមុបាទានជាបច្ច័យដល់កាមភពមានពីរយ៉ាង សញ្ញាភព និងបញ្ចវោការភព សង្គ្រោះចូលក្នុងកាមភពនោះឯង រូបភព មាន ២ យ៉ាង សញ្ញាភព អសញ្ញាភព ឯកវោការភព បញ្ចវោការភព សង្គ្រោះចូលក្នុងរូបភពនោះឯង ។ អរូបភពក៏មាន ២ យ៉ាង សញ្ញាភព នេវសញ្ញានាសញ្ញាភព ចតុវោការភព សង្គ្រោះ

ចូលក្នុងអរូបភពនោះឯង ព្រោះហេតុនោះ ទើបភពដែលមានកាមុបាទានជាបច្ច័យ មាន ៦ ភព មួយអន្លើដោយភពទាំងឡាយដែលបន្ថែមចូលគ្នា ។ ភព ៦ មួយអន្លើដោយភពទាំងឡាយ ដែលបន្ថែមចូលជាមួយគ្នា មាន ព្រោះកាមុបាទានជាបច្ច័យ យ៉ាងណា ភពទាំងឡាយ មាន ព្រោះឧបាទាន ( ៣ ) ដ៏សេសជាបច្ច័យក៏យ៉ាងនោះ ព្រោះហេតុនោះ ភពទាំងឡាយ មួយអន្លើដោយភព ដែលបន្ថែមចូល ទើបជា ២៤ ដោយការចែក ព្រោះឧបាទានជាបច្ច័យយ៉ាងនេះ ។

ចំណែកដោយការរួមគ្នា មានអធិប្បាយថា រួមកម្មភព និងឧបបត្តិភពចូលគ្នា មួយអន្លើដោយភពដែលបន្ថែមចូលគ្នាជាកាមភពមួយ កើតព្រោះកាមុបាទានជាបច្ច័យ រូបភព និងអរូបភពក៏ដូចគ្នា ព្រោះហេតុនោះ ទើបជា ៣ ភព ភពទាំងឡាយ មានព្រោះឧបាទាន ( ៣ ) ដ៏សេស ជាបច្ច័យក៏ដូចគ្នា ព្រោះហេតុនោះ ទើបជា ១២ មួយអន្លើដោយភពដែលបន្ថែមចូលគ្នា ដោយសង្ខេប ព្រោះឧបាទានជាបច្ច័យយ៉ាងនេះ ។

ម្យ៉ាងទៀត ពោលដោយមិនផ្សេងគ្នា កម្មដែលឲ្យសត្វចូលដល់កាមភព ព្រោះឧបាទានជាបច្ច័យ ឈ្មោះថា **កម្មភព** ។ ខន្ធទាំងឡាយដែលកើតឡើងក្នុងកាមភពនោះ ឈ្មោះថា **ឧបបត្តិភព** ។ ក្នុងរូបភព និងអរូប-ភពក៏ដូចគ្នា ដោយប្រការដូច្នេះ ទើបជា ៦ ភព ដោយការសង្ខេប ។ បរិយាយមួយទៀត គឺកាមភព ២ រូបភព ២ អរូបភព ២ មួយអន្លើដោយភពដែលបន្ថែមចូលជាមួយគ្នា មាន ព្រោះឧបាទានជាបច្ច័យ ។

ម្យ៉ាងទៀត ចាត់ជា ៣ ភព ដោយអំណាចកាមភពជាដើម មួយអន្លើ ដោយភពដែលបន្ថែមចូលជាមួយគ្នា ដោយមិនចែកកម្មភព និងឧបបត្តិភព ចេញអំពីគ្នា និងចាត់ជា ២ ភព ដោយអំណាចកម្មភព និងឧបបត្តិភព ដោយមិនញែកកាមភពជាដើម និងចាត់ជាភព ១ ដោយអំណាចនៃភពជា ឧបាទានជាបច្ច័យនៃភព ដោយមិនញែកកម្មភព និងឧបបត្តិភព ព្រោះហេតុ នោះ គប្បីជ្រាបវិនិច្ឆ័យក្នុងអធិការនេះដោយការចែក និងរួមគ្នានៃភព មាន ឧបាទានជាបច្ច័យ ដោយប្រការដូច្នេះ ។

ពាក្យថា ដោយឧបាទានណា ជាបច្ច័យដល់ភពណា អធិប្បាយថា ក្នុងអធិការនេះ គប្បីជ្រាបវិនិច្ឆ័យដោយឧបាទានណា ជាបច្ច័យដល់ភពណា ឆ្លើយថា ឧបាទានឯណាមួយ រមែងជាបច្ច័យដល់ភពណាមួយបានទាំងអស់ ។ ព្រោះបុថុជ្ជនប្រៀបដូចមនុស្សឆ្កួត ។ បុថុជ្ជននោះ មិនបានពិចារណាថា វត្ថុ នេះគួរ វត្ថុនេះមិនគួរ ដូច្នេះ ប្រាថ្នាភពណាមួយ ដោយអំណាចឧបាទាន ណាមួយ រមែងធ្វើកម្មណាមួយនោះឯង ព្រោះហេតុនោះ ពាក្យដែលអាចារ្យ ពួកខ្លះពោលថា រូបភព និងអរូបភព រមែងមិនមានព្រោះសីលព្វតុបាទាន នោះ បណ្ឌិតមិនគួរកាន់យក តែពាក្យថា ភពទាំងអស់ រមែងកើតព្រោះ ឧបាទានទាំងអស់ គួរកាន់យក ។

សួរថា កាន់យកដូចម្តេច ឆ្លើយថា បុគ្គលខ្លះក្នុងលោកនេះ គិតថា ឈ្មោះថា កាមទាំងនេះ ជារបស់សម្រេចក្នុងត្រកូលខត្តិយមហាសាលជាដើម ក្នុងមនុស្សលោក និងក្នុងទេវលោក កាមាវចរ ៦ ជាន់ ដោយអំណាចដែល

បានស្តាប់មក ឬដោយទំនងដែលឃើញមក ត្រូវបោកបញ្ឆោតដោយឲ្យសេព អសទ្ធម្មជាដើម ដើម្បីសម្រេចកាមទាំងនោះ ទើបសម្គាល់ថា កាមទាំងឡាយ រមែងសម្រេចដោយកម្មនេះ ទើបធ្វើកាយទុច្ចរិតជាដើម ដោយអំណាច កាមុបាទាន ទើបបុគ្គលនោះ កើតឡើងក្នុងអបាយ ព្រោះដល់ព្រមដោយ ទុច្ចរិត កាលប្រាថ្នាកាមទាំងឡាយដែលខ្លួនជួបហើយ ឬកាលរក្សាកាមដែល បានមកហើយ រមែងធ្វើកាយទុច្ចរិតជាដើម ដោយអំណាចកាមុបាទាន បុគ្គលនោះ រមែងកើតក្នុងអបាយ ព្រោះដល់ព្រមដោយទុច្ចរិត ។ កម្មដែល ជាហេតុឲ្យបុគ្គលនោះកើតក្នុងអបាយនោះ ឈ្មោះថា **កម្មភព** ។ ខន្ធដែល កើតឡើងអំពីកម្មនោះ ឈ្មោះថា **ឧបបត្តិភព** ។ ចំណែកសញ្ញាភព និង បញ្ចវោការភព រួមចូលក្នុងកម្មភព និងឧបបត្តិភពនោះឯង ។

ចំណែកបុគ្គលម្នាក់ទៀត មានការដឹងចម្រើនឡើង ព្រោះស្តាប់ព្រះធម៌ ជាដើម សម្គាល់ថា កាមទាំងឡាយរមែងសម្រេចដោយកម្មនេះ ដូច្នេះ ទើប ធ្វើកាយសុចរិតជាដើម ដោយអំណាចកាមុបាទាន បុគ្គលនោះ រមែងកើត ឡើងក្នុងស្ថានសួគ៌ទាំងឡាយ ឬក្នុងមនុស្សទាំងឡាយ ព្រោះដល់ព្រមដោយ សុចរិត ។ កម្មដែលជាហេតុឲ្យកើតក្នុងសុគតិ មានទេវតាជាដើមនោះ ឈ្មោះ ថា **កម្មភព** ខន្ធទាំងឡាយដែលកើតអំពីកម្ម ឈ្មោះថា **ឧបបត្តិភព** ។ សញ្ញាភព និងបញ្ចវោការភព ក៏សង្គ្រោះក្នុងកម្មភព និងឧបបត្តិភពនោះ ឯង ។ កាមុបាទានជាបច្ច័យដល់កាមភព ព្រមទាំងប្រភេទ ព្រមទាំងភព ដែលបន្ថែមចូលមក ដោយប្រការដូច្នេះ ។ បុគ្គលម្នាក់ទៀត ស្តាប់មក ឬ

ត្រិះរិះឯងថា ក្នុងរូបភព និងអរូបភព កាមទាំងឡាយ សម្រេចល្អជាង កាមភពនោះ ទើបញុំាងរូបសមាបត្តិ និងអរូបសមាបត្តិឲ្យកើតឡើងដោយ អំណាចកាមុបាទាននោះឯង ហើយកើតឡើងក្នុងលោកនៃរូបព្រហ្ម ឬអរូប- ព្រហ្មដោយកម្លាំងនៃសមាបត្តិ ។ កម្មដែលជាហេតុឲ្យបុគ្គលនោះកើតក្នុង រូបព្រហ្ម ឬអរូបព្រហ្មនោះ ឈ្មោះថា **កម្មភព** ខន្ធទាំងឡាយដែលកើត អំពីកម្ម ឈ្មោះថា **ឧបបត្តិភព** ។ ចំណែកសញ្ញាភព អសញ្ញាភព នេវ- សញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព និងបញ្ចវោការភព ក៏ សង្គ្រោះចូលក្នុងរូបភព ឬអរូបភពនោះឯង ។ កាមុបាទាន ជាបច្ច័យដល់ រូបភព និងអរូបភព ព្រមទាំងប្រភេទ ព្រមទាំងភពដែលបន្ថែមចូលជាមួយ គ្នា ដោយប្រការដូច្នេះ ។

បុគ្គលម្នាក់ទៀត អាស្រ័យឧច្ឆេទទិដ្ឋិថា ឈ្មោះថា អត្តា នេះ ដាច់ សូន្យហើយ ក្នុងកាមាវចរសម្បត្តិភព ឬក្នុងរូបភព អរូបភព ភពណាមួយ រមែងដាច់សូន្យដោយពិត ទើបធ្វើកម្មដែលចូលដល់ភពនោះ ។ កម្មនោះ របស់បុគ្គលនោះ ឈ្មោះថា **កម្មភព** ។ ខន្ធទាំងឡាយដែលកើតអំពីកម្ម ឈ្មោះថា **ឧបបត្តិភព** ។ ចំណែកភព មានសញ្ញាភពជាដើម ក៏សង្គ្រោះចូល ក្នុងកម្មភព និងឧបបត្តិភពនោះឯង ។ ទិដ្ឋុបាទានជាបច្ច័យដល់កាមភព រូបភព និងអរូបភពទាំង ៣ ព្រមទាំងប្រភេទ ព្រមទាំងភពដែលបន្ថែមចូលជាមួយ គ្នា ដោយប្រការដូច្នេះ ។

បុគ្គលម្នាក់ទៀតកំណត់ថា ឈ្មោះថា អត្តានេះ រមែងមានសេចក្តីសុខ

ប្រាសចាកការក្ដៅក្រហាយក្នុងកាមាវចរសម្បត្តិភព ឬក្នុងរូបភព និងអរូបភព ភពណាមួយ ទើបធ្វើកម្មដែលចូលដល់ភពនោះ ដោយអត្តវាទុបាទាន កម្មនោះរបស់បុគ្គលនោះ ឈ្មោះថា **កម្មភព** ខន្ធទាំងឡាយ ដែលកើតអំពីកម្មភពនោះ ឈ្មោះថា **ឧបបត្តិភព** ។ ចំណែកសញ្ញាភពជាដើម ក៏សង្គ្រោះចូលក្នុងកម្មភព និងឧបបត្តិភពនោះឯង ។ អត្តវាទុបាទាន ជាបច្ច័យដល់ភព ៣ ព្រមទាំងប្រភេទ ព្រមទាំងភពដែលបន្ថែមចូលជាមួយគ្នា ដោយប្រការដូច្នេះ ។

បុគ្គលម្នាក់ទៀត មានការឃើញថា ឈ្មោះថា សីល និងវត្តនេះ រមែងដល់នូវសេចក្ដីសុខដ៏បរិបូណ៌ដល់បុគ្គល ដែលបំពេញក្នុងកាមាវចរ-សម្បត្តិភព ឬក្នុងរូបភព អរូបភព ភពណាមួយ ទើបធ្វើកម្មដែលចូលដល់ភពនោះ ដោយអំណាចសីលព្វតុបាទាន ។ កម្មនោះរបស់បុគ្គលនោះ ឈ្មោះថា **កម្មភព**។ ខន្ធទាំងឡាយដែលកើតអំពីកម្មនោះ ឈ្មោះថា **ឧបបត្តិភព**។ ចំណែកសញ្ញាភពជាដើម ក៏សង្គ្រោះចូលក្នុងកម្មភព និងឧបបត្តិភពនោះឯង ។ សីលព្វតុបាទាន ជាបច្ច័យដល់ភព ៣ ព្រមទាំងប្រភេទ មួយអន្លើដោយភពដែលបន្ថែមចូលជាមួយគ្នា ដូច្នេះឯង ។ ហេតុនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងអធិការនេះ ដោយឧបាទានណា ជាបច្ច័យដល់ភពណា ដោយប្រការដូច្នេះ ។

បើមានបុគ្គលសង្ស័យសួរថា ក្នុងនិទ្ទេសនេះ ឧបាទានអ្វី ជាបច្ច័យដូចម្ដេច ដល់ភពណា ដូច្នេះសោត ឆ្លើយថា

បញ្ហាកម្មនោះ គប្បីជ្រាបថា ឧបាទាន ជាឧបនិស្សយប្បច្ច័យ ដល់រូបភព និងអរូបភព ឧបាទាននោះ ជាបច្ច័យដល់កាមភព ដោយសហជាតប្បច្ច័យជាដើមផងដែរ ។

ពិតហើយ ឧបាទានទាំង ៤ នេះ ជាបច្ច័យប្រភេទតែមួយ ដោយជាឧបនិស្សយប្បច្ច័យនៃរូបភព អរូបភព និងឧបបត្តិភព គឺកម្មចំពោះដែលជាកុសលក្នុងកម្មភព ដែលទាក់ទងដោយកាមភព និងរបស់ឧបបត្តិភពផងដែរ ។ ឧបាទាន ៤ នោះ ជាបច្ច័យដល់អកុសលកម្មភព ដែលសម្បយុត្តដោយខ្លួនក្នុងកាមភព ដោយសហជាតប្បច្ច័យជាដើម គឺសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ និងហេតុប្បច្ច័យ តែជាបច្ច័យដល់ភពដែលជាវិប្បយុត្តដល់គ្នានិងគ្នា ដោយឧបនិស្សយប្បច្ច័យតែម្យ៉ាងប៉ុណ្ណោះ ។ល។

**និទ្ទេសនៃឧបាទានជាបច្ច័យនៃភព ចប់**

# ជាតិជរាមរណាទិនិទ្ទេស

[ ១២-១៨ ] គប្បីជ្រាបវិនិច្ឆ័យបដិច្ចសមុប្បាទ មានជាតិជាដើម ក្នុងនិទ្ទេសនៃភពជាបច្ច័យដល់ជាតិជាដើម ដោយន័យដែលពោលក្នុងសច្ចវិភង្គនោះឯង តែពាក្យថា ភពក្នុងទីនេះ ទ្រង់បំណងយកកម្មភពប៉ុណ្ណោះ ព្រោះកម្មភពនោះ ជាបច្ច័យដល់ជាតិ ឧបបត្តិភព មិនជាបច្ច័យដល់ជាតិឡើយ កម្មភពនោះ ជាបច្ច័យ ២ យ៉ាងប៉ុណ្ណោះ ដោយអំណាចកម្មប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ។ បើមានបុគ្គលសួរថា សេចក្តីនេះគប្បីដឹងបានដូចម្តេចថា ភព ជាបច្ច័យដល់ជាតិ ឆ្លើយថា ដឹងបាន ព្រោះមានបច្ច័យខាងក្រៅដែលស្មើគ្នា ក៏សម្តែងការផ្សេងគ្នានៃភាវៈ មានថោកទាប និងប្រណីតជាដើម ។

ពិតហើយ កាលបច្ច័យខាងក្រៅ មានមាតាបិតា ទឹកសុក្កៈ ឈាមរដូវ និងអាហារជាដើម មានស្មើគ្នា សត្វសូម្បីជាកូនភ្លោះ ក៏គង់ប្រាកដការផ្សេងគ្នានៃភាវៈ មានថោកទាប និងប្រណីតជាដើម ។ ការផ្សេងគ្នានៃសត្វដែលជាកូនភ្លោះនោះ មិនមែនមិនមានហេតុ ព្រោះការផ្សេងគ្នាមិនគ្រប់កាល និងមិនកើតដល់សត្វទាំងអស់ និងមិនមែនហេតុដទៃក្រៅអំពីកម្មភព ព្រោះមិនមានហេតុដទៃ ក្នុងសន្តានដែលមានក្នុងខាងក្នុងរបស់ពួកសត្វ ដែលកើតអំពីកម្មភពនោះ ព្រោះហេតុនោះ ទើបការផ្សេងគ្នានៃសត្វទាំងឡាយ មានកម្មភពជាហេតុដោយពិត ។ ពិតហើយ កម្មដែលជាហេតុផ្សេងគ្នាក្នុងហីនៈ និងប្រណីតជាដើមនៃសត្វទាំងឡាយ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក ) ថា កម្ម តែងចែកសត្វទាំងឡាយ ដើម្បីឲ្យថោកទាប និងខ្ពង់ខ្ពស់ ដូច្នេះ ។ ព្រោះហេតុនោះ ទើប

*សេចក្តីនោះ គប្បីជ្រាបបានថា ភពជាបច្ច័យដល់ជាតិ ។ ម្យ៉ាងទៀត កាល ជាតិមិនមាន ឈ្មោះថា ជរាមរណៈក៏មិនមាន ហើយធម៌ មានសេចក្តីសោក ជាដើមក៏មិនមាន តែកាលជាតិមាន ជរាមរណៈ និងធម៌ មានសោកជាដើម ដែលទាក់ទងដោយជរាមរណៈរបស់បុគ្គលពាល ដែលត្រូវទុក្ខធម៌ គឺជរា-មរណៈពាល់ត្រូវហើយ ឬមិនទាក់ទងដោយជរាមរណៈរបស់បុគ្គលពាល ដែល ហេតុនៃទុក្ខនោះៗ ពាល់ត្រូវហើយ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបថា ជាតិនេះ ជាបច្ច័យដល់ជរាមរណៈ និងដល់ធម៌ មានសោកជាដើម ។ ជាតិ នោះ ជាបច្ច័យតែម្យ៉ាងប៉ុណ្ណោះ ដោយឧបនិស្សយប្បច្ច័យ ដូច្នេះឯង ៕*

## និទ្ទេសនៃភពជាបច្ច័យដល់ជាតិជរាមរណជាដើម ចប់

# អធិប្បាយ ភវចក្ក ១២

[ ១៩ ] គប្បីជ្រាបអត្ថនៃបទជាដើមថា **ឋវមេតស្ស** ដោយន័យដែលពោលហើយក្នុងឧទ្ទេសវារ ។ បទថា **សន្តតិ** ជាដើម ជាវេវចនៈរបស់បទថា **សមុទយោ** នោះឯង ។

ព្រោះក្នុងបដិច្ចសមុប្បាទវិភង្គនេះ ធម៌ មានសោកជាដើម ត្រាស់ចុងក្រោយ ហេតុនោះ អវិជ្ជាណា ដែលត្រាស់ខាងដើមនៃភវចក្រនេះ យ៉ាងនេះថា **អវិជ្ជាបច្ចយា សង្ខារា** អវិជ្ជានោះ សម្រេចហើយអំពីធម៌ មានសោកជាដើម ។

ភវចក្រនេះ មានខាងដើមមិនប្រាកដ វៀរចាកអ្នកសាង អ្នកសោយ ទទេចាកភាពទទេ ១២ យ៉ាង បណ្ឌិតគប្បីជ្រាបថា ប្រព្រឹត្តទៅរួមគ្នាដូច្នេះ ។

បើមានបុគ្គលសង្ស័យសួរថា ក្នុងភវចក្រនេះ អវិជ្ជាសម្រេចអំពីធម៌មានសោកជាដើមដូចម្តេច ភវចក្រ ឬខាងដើមមិនប្រាកដដូចម្តេច វៀរចាកអ្នកសាង អ្នកសោយដូចម្តេច ទទេចាកភាពទទេ ១២ យ៉ាងដូចម្តេច ។ ចម្លើយក្នុងទីនេះ គឺសោក ទុក្ខ ទោមនស្ស និងឧបាយាស មិនផុតទៅអំពីអវិជ្ជា ឈ្មោះថា **បរិទេវ** រមែងមានដល់បុគ្គលវង្វេង ព្រោះហេតុនោះ កាលសោក ទុក្ខ ទោមនស្ស ឧបាយាស និងបរិទេវៈ ទាំងនោះសម្រេចហើយ អវិជ្ជាក៏សម្រេចហើយដោយពិត ។ មួយវិញទៀត ព្រោះព្រះតម្រាស់ ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ការកើតឡើងនៃអវិជ្ជា ព្រោះការកើតឡើងនៃអាសវៈ ដូច្នេះ ធម៌ មានសោកជាដើមនេះ ទើបមានព្រោះអាសវៈជាហេតុកើត សេចក្តីនេះដូចម្តេច គឺសោក ព្រោះការព្រាត់ប្រាសចាកវត្ថុកាម

*រមែងកើតឡើងចាកកាមាសវៈ ដូចព្រះតម្រាស់ ( ក្នុងខុទ្ទកនិកាយ សុត្ត-និបាត ) ថា កាលបើសត្វនោះប្រាថ្នា មានឆន្ទៈកើតហើយ កាមនោះសាបសូន្យទៅ សត្វក៏សុបសៅទៅ ដូចជាមុតដោយសរ ដូច្នេះ ។ និងដូចព្រះតម្រាស់ ( ខុទ្ទកនិកាយ ធម្មបទ ) ថា សេចក្ដីសោកកើតអំពីកាម ដូច្នេះ សេចក្ដីសោកជាដើមទាំងអស់នេះ រមែងកើតអំពីទិដ្ឋាសវៈ ដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ ) ថា កាលបើបុគ្គលនោះ មានចិត្តប្រកាន់ថា រូប គឺអញ រូបរបស់អាត្មាអញ លុះដល់រូបនោះប្រែប្រួលទៅ បែកធ្លាយទៅ សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្ដីចង្អៀតចង្អល់ចិត្ត រមែងកើតឡើងដល់បុគ្គលនោះ ព្រោះតែរូបប្រែប្រួល បែកទៅ ដូច្នេះ ។ម្យ៉ាងទៀត ធម៌ មានសោកជាដើម រមែងកើត ព្រោះអាសវៈកើត ដូចទិដ្ឋាសវៈកើត ដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ពួកទេវតាណា ដែលមានអាយុវែង មានពណ៌សម្បុរច្រើនដោយសេចក្ដីសុខ ស្ថិតនៅលើវិមានដ៏ខ្ពស់ អស់កាលយូរ ពួកទេវតានោះ បានស្ដាប់ធម៌ទេសនារបស់ព្រះតថាគតហើយ ច្រើនតែដល់នូវសេចក្ដីភិតភ័យ តក់ស្លុត ញ័ររំភប់ ដូច្នេះ ។ ដូចពួកទេវតាឃើញបុព្វនិមិត្ត ៥ ហើយ នាំគ្នាតក់ស្លុត ព្រោះមរណភ័យ ដូច្នោះ ។*

*ម្យ៉ាងទៀត ធម៌ មានសោកជាដើម រមែងកើតឡើងអំពីអវិជ្ជា ដូចកើតអំពីភវាសវៈ ដូចព្រះតម្រាស់ ( ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក ) ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលនោះឯង តែងទទួលទុក្ខ ទោមនស្ស ៣*

យ៉ាង ក្នុងបច្ចុប្បន្ននេះ ដូច្នេះ ។ ព្រោះធម៌ទាំងនេះ រមែងកើតអំពីអាសវៈ ហេតុនោះ ធម៌ទាំងនោះ កាលសម្រេច ទើបញុំាងអាសវៈទាំងឡាយ ដែលជាហេតុនៃអវិជ្ជាឲ្យសម្រេច កាលអាសវៈទាំងឡាយសម្រេចហើយ អវិជ្ជាក៏ជាការសម្រេចនោះឯង ព្រោះកាលមានទូវបច្ច័យ ទើបមាន ។ ក្នុងទីនេះ គប្បីជ្រាបថា អវិជ្ជាសម្រេចហើយដោយធម៌ មានសេចក្តីសោកជាដើមយ៉ាងនេះ ។

កាលអវិជ្ជាសម្រេចហើយ ព្រោះកាលបច្ច័យមាន ទើបមានយ៉ាងនេះ ការបន្តគ្នានៃហេតុ និងផលយ៉ាងនេះថា សង្ខារទាំងឡាយកើត ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើត ព្រោះសង្ខារជាបច្ច័យ មិនមានទីបំផុត ព្រោះហេតុនោះ ភវចក្រមានអង្គ ១២ ដែលប្រព្រឹត្តទៅដោយអំណាចការទាក់ទងគ្នានៃហេតុ និងផលនោះ ទើបសម្រេចថា មានខាងដើមមិនប្រាកដ ។

បើមានអ្នកសង្ស័យសួរថា កាលមានខាងដើមមិនប្រាកដយ៉ាងនេះ ការពោលពាក្យថា អវិជ្ជាជាធម៌ខាងដើមថា សង្ខារកើតមានព្រោះអវិជ្ជាជាបច្ច័យ ដូច្នេះ មិនខុសទៅហើយឬ ឆ្លើយថា សេចក្តីនេះ មិនមែនការពោលអវិជ្ជាត្រឹមតែជាធម៌ខាងដើម តែសេចក្តីនេះ ជាការពោលធម៌ដែលជាប្រធាន ពិតហើយ អវិជ្ជាជាប្រធាននៃវដ្តៈ ៣ ព្រោះថា ដោយការប្រកាន់អវិជ្ជា កិលេសវដ្តៈដ៏សេស និងកម្មវដ្តៈជាដើម រមែងរួបរឹតបុគ្គលពាល ដូចការចាប់ក្បាលពស់ សរីរៈពស់ដ៏សេសក៏រុំដៃ តែកាលកាត់អវិជ្ជាដាច់ហើយ រមែងផុតចាកវដ្តៈទាំងអស់ ដូចបុគ្គលកាត់ក្បាលពស់ហើយ នឹងផុតចាកការត្រូវរុំដៃ ដូច្នោះ

ដូចព្រះតម្រាស់ ( ក្នុងវិនយបិដក មហាវគ្គ ) ថា សេចក្ដីរលត់សង្ខារកើតមាន ព្រោះវិនាស និងរលត់មិនមានសេសសល់នៃអវិជ្ជា ដូច្នេះជាដើម ។ កាលបុគ្គលប្រកាន់នូវធម៌ណា ការជាប់ជំពាក់រមែងមាន កាលលែងនូវធម៌ណា ការរួចផុតរមែងមាន ការពោលនេះ ជាការពោលធម៌ដែលជាប្រធានគឺអវិជ្ជានោះ មិនមែនការពោលថា អវិជ្ជាធម៌ខាងដើម ព្រោះហេតុនោះគប្បីជ្រាបភវចក្រនេះថា មានខាងដើមមិនប្រាកដ ដោយប្រការដូច្នេះ ។

ភវចក្រនេះ ព្រោះហេតុទាំងឡាយ មានអវិជ្ជាជាដើមជាបច្ច័យដល់ធម៌មានសង្ខារជាដើម ព្រោះហេតុនោះ ក្រៅអំពីអវិជ្ជាជាដើមនោះ ទើបវៀរចាកអ្នកសាងសង្សារ មានព្រះព្រហ្មជាដើម ដែលគេត្រិះរិះយក ( ក្នុងទីឃនិកាយ សីលក្ខន្ធវគ្គ ) យ៉ាងនេះថា ព្រហ្ម មហាព្រហ្មជាចំបងជាងសត្វលោក ជាអ្នកបញ្ញត្តលោក ដូច្នេះ ឬថា វៀរចាកអត្តាជាអ្នកសោយសុខ និងទុក្ខ ដែលគេសន្មត ( ក្នុងព្រះអភិធម្ម វិភង្គ ) យ៉ាងនេះថា ខ្លួនរបស់អញនេះជាអ្នកពោល អ្នកទទួលផល ដូច្នេះ បណ្ឌិតគប្បីជ្រាបថា ភវចក្រ វៀរចាកអ្នកសាង និងអ្នកសោយ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ព្រោះក្នុងភវចក្រនេះ អវិជ្ជា ឈ្មោះថា វៀរចាកការស្ថិតស្ថេរ ព្រោះជាធម៌កើតឡើង និងមានការវិនាសទៅជាធម្មតា ឈ្មោះថា វៀរចាកការស្អាត ព្រោះជាធម៌សៅហ្មង និងព្រោះប្រកបដោយសង្កិលេស ឈ្មោះថា វៀរចាកសេចក្ដីសុខ ព្រោះត្រូវការកើត និងការវិនាសបៀតបៀន ឈ្មោះថា ទទេចាកអត្តភាពដែលគ្រប់គ្រងអំណាច ព្រោះមានការប្រព្រឹត្តទៅ

ទាក់ទងដោយបច្ច័យ ។ អង្គទាំងឡាយ មានសង្ខារជាដើមក៏ដូចគ្នា ។

ម្យ៉ាងទៀត ព្រោះអវិជ្ជាមិនមែនអត្តា មិនមែនរបស់អត្តា មិនមែនមានក្នុងអត្តា មិនមែនមានអត្តា អង្គទាំងឡាយ មានសង្ខារជាដើមក៏ដូចគ្នា ព្រោះហេតុនោះ គប្បីជ្រាបថា ភវចក្រនេះទទេ ដោយភាពទទេ ១២ យ៉ាងដោយប្រការដូច្នេះ ។

កាលជ្រាបយ៉ាងនេះហើយ គប្បីជ្រាបទៀតថា

ភវចក្រនោះ មានអវិជ្ជា និងតណ្ហាជាមូល មានកាល ៣ មានអតីតកាលជាដើម ក្នុងកាលទាំងនោះ ដោយសង្ខេប បានអង្គ ២ គឺអវិជ្ជា និងសង្ខារ អង្គ ៨ មានវិញ្ញាណជាដើម និងអង្គ ២ គឺជាតិ និងមរណៈប៉ុណ្ណោះ ។

អធិប្បាយថា ធម៌ ២ គឺអវិជ្ជា និងតណ្ហា គប្បីជ្រាបថា ជាមូលនៃភវចក្រនេះឯង ទើបភវចក្រនេះមាន ២ យ៉ាង គឺអវិជ្ជាជាមូល មានវេទនាជាទីបំផុត ព្រោះស្រាវមកអំពីចំណែកខាងដើម តណ្ហាជាមូល មានជរា និងមរណៈជាទីបំផុត ព្រោះស្រាវមកអំពីចំណែកខាងចុង ។ បណ្តាភវចក្រទាំង ២ នោះ ភវចក្រដំបូង ត្រាស់ដោយអំណាចនៃបុគ្គលដែលមានទិដ្ឋិចរិត ភវចក្រក្រោយ ត្រាស់ដោយអំណាចនៃបុគ្គលដែលមានតណ្ហាចរិត ព្រោះថា បុគ្គលទាំងឡាយ ដែលមានទិដ្ឋិចរិត អវិជ្ជាជាធម៌នាំទៅកាន់សង្សារ តែបុគ្គលដែលមានតណ្ហាចរិត តណ្ហាជាធម៌នាំទៅកាន់សង្សារ ។

ម្យ៉ាងទៀត ភវចក្រដំបូង ត្រាស់ដើម្បីដកនូវឧច្ឆេទទិដ្ឋិ ព្រោះទ្រង់

ប្រកាសការមិនកាត់ផ្តាច់នៃហេតុទាំងឡាយ នៃការកើតឡើងនៃផល ភវចក្រទី ២ ត្រាស់ដើម្បីជកសស្សតទិដ្ឋិ ព្រោះទ្រង់ប្រកាសជរាមរណៈរបស់ពួកសត្វ ដែលកើតឡើង ។

ម្យ៉ាងទៀត ភវចក្រដំបូង ត្រាស់ដោយអំណាចនៃសត្វដែលកើតក្នុងគភ៌ ព្រោះទ្រង់សម្តែងការប្រព្រឹត្តទៅដោយលំដាប់ ( អាយតនៈដែលកើត ) ភវចក្រក្រោយ ត្រាស់ដោយអំណាចនៃសត្វដែលជាឱបបាតិកៈ ព្រោះទ្រង់សម្តែងការកើតឡើងព្រមគ្នានៃអាយតនៈ ។

ម្យ៉ាងទៀត កាលរបស់ភវចក្រនោះ មាន ៣ គឺអតីត បច្ចុប្បន្ន និងអនាគត ក្នុងកាលទាំងនោះ ពោលដោយអំណាចកាល ដែលមកក្នុងព្រះបាលីដោយសរុប គប្បីជ្រាបថា មានអង្គ ២ គឺអវិជ្ជា និងសង្ខារ ដែលជាអតីតកាល ។ អង្គ ៨ មានវិញ្ញាណជាដើម មានភពជាទីបំផុត ជាបច្ចុប្បន្នកាល ឯអង្គ ២ គឺជាតិ និងជរាមរណៈ ជាអនាគតកាល និងគប្បីជ្រាបទៀតថា

ភវចក្រនេះ មានសន្ធិ ៣ គឺហេតុផលសន្ធិ ១ ផលហេតុសន្ធិ ១
ហេតុបុព្វកផលសន្ធិ ១ និងមានសង្គហៈ ៤ ប្រភេទ គឺអាការ
២០ មានវដ្តៈ ៣ រមែងវិលទៅ មិនមានកំណត់ ដូច្នេះ ។

បណ្តាចក្រទាំងនោះ ក្នុងចន្លោះសង្ខារទាំងឡាយ និងបដិសន្ធិវិញ្ញាណជាសន្ធិ ១ ឈ្មោះថា **ហេតុផលសន្ធិ** ត្រង់ចន្លោះវេទនា និងតណ្ហា ជាសន្ធិ ១ ឈ្មោះថា **ផលហេតុសន្ធិ** ត្រង់ចន្លោះភព និងជាតិ ជាសន្ធិ ១ ឈ្មោះថា

**ហេតុបុព្វកផលសន្ធិ** ព្រោះហេតុនោះ ភវចក្រនេះ បណ្ឌិតគប្បីជ្រាបថា មានសន្ធិ ៣ គឺហេតុផលសន្ធិ ១ ផលហេតុសន្ធិ ១ ហេតុបុព្វកផលសន្ធិ ១ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ភវចក្រនេះ មានសង្គហៈ ៤ ដែលកំណត់កាន់យកភវចក្រ តាំងអំពីខាងដើម គឺអវិជ្ជា និងទីបំផុត គឺជរាមរណៈនៃសន្ធិទាំងឡាយ សេចក្តីនេះដូចម្តេច គឺអវិជ្ជា និងសង្ខារ ជាសង្គហៈទី ១ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ និងវេទនា ជាសង្គហៈទី ២ តណ្ហា ឧបាទាន និងភព ជាសង្គហៈទី ៣ ជាតិជរាមរណៈ ជាសង្គហៈទី ៤ គប្បីជ្រាបថា ភវចក្រ មានសង្គហៈ ៤ ប្រភេទ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត គប្បីជ្រាបថា ភវចក្រ មានអាការ ២០ ដោយអាការ ២០ ទាំងនេះ គឺ

ក្នុងអតីត មានហេតុ ៥ ក្នុងបច្ចុប្បន្ន មានផល ៥ ក្នុងបច្ចុប្បន្ន មានហេតុ ៥ ក្នុងអនាគត មានផល ៥ ។

បណ្តាភវចក្រទាំងនោះ ពាក្យថា ក្នុងអតីត មានហេតុ ៥ សេចក្តីថា អង្គ ២ គឺអវិជ្ជា និងសង្ខារ ត្រាស់មុននោះឯង តែព្រោះបុគ្គលល្ងង់ខ្លៅ រមែងតក់ស្លុត បុគ្គលដែលតក់ស្លុត រមែងប្រកាន់មាំ ទើបភពកើតព្រោះឧបាទាន ជាបច្ច័យដល់បុគ្គលនោះ ហេតុនោះ ទើបទ្រង់កាន់យកតណ្ហា ឧបាទាន និងភពផងដែរ ព្រោះហេតុនោះ ទើបព្រះធម្មសេនាបតីសារីបុត្តពោល ( ក្នុងខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ) ថា ក្នុងកម្មភពមុន មោហៈ គឺអវិជ្ជា ការ

ប្រមូលមក គឺសង្ខារ សេចក្តីប្រាថ្នា គឺតណ្ហា កិរិយាប្រកាន់មាំ គឺឧបាទាន ចេតនា គឺភព ធម៌ទាំង ៥ យ៉ាងនេះ ក្នុងកម្មភពមុន ជាបច្ច័យនៃបដិសន្ធិ ក្នុងបច្ចុប្បន្នភពនេះ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា ក្នុងកម្មភពមុន បានដល់ កម្មភពដែលកើតមុន គឺកម្មភពដែលបានធ្វើក្នុងអតីតជាតិ ។ ពាក្យថា មោហៈ គឺអវិជ្ជា អធិប្បាយថា មោហៈក្នុងសច្ចៈ មានទុក្ខជាដើម ក្នុងកាលនោះយ៉ាងណា សត្វនោះវង្វេងហើយ រមែងធ្វើកម្មដោយមោហៈណា នុ៎ះជាអវិជ្ជា ។ ពាក្យថា ការប្រមូលមក គឺសង្ខារ បានដល់ បុរិមចេតនារបស់បុគ្គលដែលធ្វើកម្មនោះ ដូចបុរិមចេតនាដែលកើតឡើងដល់បុគ្គល ដែលញ៉ាំងចិត្តឲ្យកើតឡើងដោយគិតថា អញនឹងថ្វាយទាន ហើយនឹងចាត់ចែងគ្រឿងឧបភោគបរិភោគនៃការឲ្យទាន ១ ខែខ្លះ ១ ឆ្នាំខ្លះ ចេតនារបស់បុគ្គលដែលញ៉ាំងទក្ខិណាឲ្យតាំងឡើងក្នុងដៃរបស់បដិគ្គាហកទាំងឡាយ លោកហៅថា ភព ។ម្យ៉ាងទៀត ចេតនាក្នុងជវនចិត្ត ៦ ដួង ដែលមានអាវជ្ជនៈជាមួយគ្នា ឈ្មោះថា **អាយុ-ហានសង្ខារ** ( កម្មដែលប្រមូល គឺសង្ខារ ) ចេតនាដួងទី ៧ ឈ្មោះថា ភព ។ ម្យ៉ាងទៀត ចេតនាណាមួយ ឈ្មោះថា ភព ធម៌ដែលសម្បយុត្តដោយចេតនានោះ ឈ្មោះថា **អាយុហានសង្ខារ** ។ ពាក្យថា សេចក្តីប្រាថ្នា គឺតណ្ហា សេចក្តីថា ការប្រាថ្នា គឺការប្រាថ្នាក្នុងឧបបត្តិភព ដែលជាផលរបស់បុគ្គលដែលធ្វើកម្មនោះ ឈ្មោះថា តណ្ហា ។ ពាក្យថា ការចូលដល់ គឺឧបាទាន សេចក្តីថា ការចូលដល់ ការប្រកាន់ ការកាន់យក ដែលប្រព្រឹត្តទៅដោយ

ន័យជាដើមថា អញធ្វើកម្មនេះឲ្យជាបច្ច័យដល់ភព ហើយនឹងសេពកាមក្នុងឋានៈឈ្មោះនោះ នឹងជាប់សួនឡដូច្នេះយ៉ាងណា នេះឈ្មោះថា ឧបាទាន ។ ពាក្យថា ចេតនា គឺភព បានដល់ ចេតនាដែលប្រព្រឹត្តទៅក្នុងទីបំផុតនៃកម្មដែលប្រមូលមក ឈ្មោះថា ភព គប្បីជ្រាបអត្ថនេះ ដោយប្រការដូច្នេះ ។

ពាក្យថា ក្នុងបច្ចុប្បន្នមានផល ៥ បានដល់ ភវចក្រ មានវិញ្ញាណជាដើម មានវេទនាជាទីបំផុត មកក្នុងព្រះបាលីនោះឯង ដូចព្រះធម្មសេនាបតីសារីបុត្តពោល ( ក្នុងខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ) ថា បដិសន្ធិក្នុងបច្ចុប្បន្នភពនេះ ជាតួវិញ្ញាណ ការចុះកាន់គភ៌ គឺនាម និងរូប បសាទ គឺអាយតនៈ សភាពដែលបុគ្គលពាល់ត្រូវ គឺផស្សៈ ការទទួលអារម្មណ៍ គឺវេទនា ធម៌ទាំង ៥ យ៉ាងនេះ ក្នុងឧបបត្តិភពនេះ ប្រព្រឹត្តទៅ ព្រោះបច្ច័យរបស់កម្ម ដែលបុគ្គលធ្វើហើយក្នុងកាលមុន ដូច្នេះ ។ ក្នុងធម៌ ៥ នោះ ពាក្យថា បដិសន្ធិក្នុងបច្ចុប្បន្នភពនេះ ជាតួវិញ្ញាណ សេចក្ដីថា លោកពោលថា ឈ្មោះថា **បដិសន្ធិ** ព្រោះការកើតឡើងដោយអំណាចការបន្តក្នុងភពដទៃ ដូច្នេះ យ៉ាងណា នោះ ឈ្មោះថា **វិញ្ញាណ** ។ ពាក្យថា ការចុះកាន់គភ៌ គឺនាម និងរូប សេចក្ដីថា ការឈមចុះក្នុងគភ៌របស់រូបធម៌ និងអរូបធម៌ ដូចមកហើយចូលទៅ យ៉ាងណា នេះ ឈ្មោះថា **នាមរូប** ។ ពាក្យថា បសាទ គឺអាយតនៈ លោកពោលដោយអំណាចអាយតនៈ ៥ មានចក្ខាយតនៈជាដើម ពាក្យថា សភាពដែលបុគ្គលពាល់ត្រូវ គឺផស្សៈ បានដល់ ភាវៈដែលពាល់ត្រូវហើយ ឬកំពុងពាល់ត្រូវនូវអារម្មណ៍កើតឡើងឯណា នេះហៅថា **ផស្សៈ** ។ ពាក្យថា

ការទទួលអារម្មណ៍ គឺវេទនា បានដល់ ការសោយវិបាកដែលកើតឡើង មួយអន្លើដោយបដិសន្ធិវិញ្ញាណ ឬផស្សៈ ដែលមានសឡាយតនៈជាបច្ច័យឯណា នេះហៅថា **វេទនា** ព្រោះហេតុនោះ គប្បីជ្រាបសេចក្តី ដោយប្រការដូច្នេះ ។

ពាក្យថា ក្នុងបច្ចុប្បន្ន មានហេតុ ៥ បានដល់ ហេតុទាំងឡាយ មានតណ្ហាជាដើម មកហើយក្នុងព្រះបាលីនោះឯង គឺតណ្ហា ឧបាទាន និងភព កាលកាន់យកភពហើយ ក៏ឈ្មោះថា កាន់យកសង្ខារដែលជាបុព្វភាគនៃភពនោះ ឬធម៌ដែលសម្បយុត្តដោយភពនោះដូចគ្នា និងដោយការកាន់យកតណ្ហា មួយអន្លើដោយឧបាទាន ក៏ជាការកាន់យកអវិជ្ជា ដែលសម្បយុត្តដោយតណ្ហា និងឧបាទាននោះ ឬថា ជាហេតុធ្វើកម្មរបស់បុគ្គលវង្វេង ព្រោះហេតុនោះ ទើបអង្គនៃភវចក្រនោះមាន ៥ ដោយប្រការដូច្នេះ ដោយហេតុនោះ ទើបព្រះធម្មសេនាបតីសារីបុត្តពោល ( ក្នុងខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ) ថា ព្រោះតែអាយតនៈចាស់ក្នុងបច្ចុប្បន្ននេះ មោហៈ គឺអវិជ្ជា ការប្រមូល គឺសង្ខារ សេចក្តីប្រាថ្នា គឺតណ្ហា ការប្រកាន់មាំ គឺឧបាទាន ចេតនា គឺភព ធម៌ទាំង ៥ យ៉ាងនេះ ក្នុងកម្មភពជាបច្ចុប្បន្ននេះ ជាបច្ច័យនៃបដិសន្ធិក្នុងអនាគត ដូច្នេះ ។ បណ្តាពាក្យទាំងនោះ ពាក្យថា ព្រោះតែអាយតនៈចាស់ក្នុងបច្ចុប្បន្ននេះ សម្តែងការវង្វេងដោយល្អ ក្នុងវេលាធ្វើកម្មរបស់បុគ្គលដែលមានអាយតនៈបរិបូណ៌ជុំវិញហើយ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។

ពាក្យថា ក្នុងអនាគតមានផល ៥ បានដល់ ផល ៥ មានវិញ្ញាណ

ជាដើម ។ ផល ៥ មានវិញ្ញាណជាដើមនោះ ខ្ញុំពោលដោយសព្ទថា ជាតិ ចំណែកជរាមរណៈ ក៏ជាជរាមរណៈរបស់ផល ៥ មានវិញ្ញាណជាដើមទាំងនោះឯង ដោយហេតុនោះ ទើបព្រះធម្មសេនាបតីសារីបុត្តពោល ( ក្នុងខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ) ថា បដិសន្ធិក្នុងអនាគត ជាតួវិញ្ញាណ ការចុះកាន់គភ៌ គឺនាម និងរូប បសាទ គឺអាយតនៈ ធម៌ដែលបុគ្គលពាល់ត្រូវ គឺផស្សៈ ការទទួលអារម្មណ៍ គឺវេទនា ធម៌ទាំង ៥ យ៉ាងនេះ ក្នុងឧបបត្តិភពជាអនាគត ប្រព្រឹត្តទៅព្រោះបច្ច័យនៃកម្ម ដែលបុគ្គលធ្វើហើយក្នុងបច្ចុប្បន្នភពនេះ ដូច្នេះ ។ ភវចក្រនេះ មានអាការ ២០ ដោយប្រការយ៉ាងនេះ ។

បណ្តាភវចក្រ មានអាការ ២០ នោះ ក្នុងភពមុន មានអង្គប្រកប គឺកម្មដែលជាហេតុ ៥ យ៉ាង ក្នុងបច្ចុប្បន្ន មានធម៌ជាវិបាក ៥ យ៉ាង ក្នុងបច្ចុប្បន្ន មានអង្គប្រកប គឺកម្ម ៥ យ៉ាង ក្នុងអនាគត មានធម៌ដែលជាវិបាក ៥ យ៉ាង ព្រោះហេតុនោះ ទើបរួមជាធម៌ដែលជាកម្ម ១០ យ៉ាង ជាវិបាក ១០ យ៉ាង ដោយអាការដែលពោល ទើបកម្មក្នុងឋានៈទាំង ២ ឈ្មោះថា **កម្ម** ។ វិបាកក្នុងឋានៈទាំងពីរ ឈ្មោះថា **វិបាក** ។ ភវចក្រទាំងអស់នេះ ជាកម្មផង ជាវិបាកផង វិលទៅដោយបច្ចយាការ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត កម្មក្នុងឋានៈទាំងពីរ ឈ្មោះថា **កម្មសង្ខេប** វិបាកក្នុងឋានៈទាំងពីរ ឈ្មោះថា **វិបាកសង្ខេប** ព្រោះហេតុនោះ ទើបភវចក្រទាំងអស់នេះ ជាកម្មសង្ខេបផង ជាវិបាកសង្ខេបផង ។ កម្មក្នុងឋានៈទាំងពីរ ឈ្មោះថា **កម្មវដ្ដ** វិបាកក្នុងឋានៈទាំងពីរ ឈ្មោះថា **វិបាកវដ្ដ** ព្រោះហេតុនោះ ទើប

ភវចក្រទាំងអស់នេះ ជាកម្មវដ្តៈផង ជាវិបាកវដ្តៈផង ។ ម្យ៉ាងទៀត កម្មក្នុងឋានៈទាំងពីរ ឈ្មោះថា **កម្មភព** វិបាកក្នុងឋានៈទាំងពីរ ឈ្មោះថា **វិបាកភព** ព្រោះហេតុនោះ ទើបភវចក្រទាំងអស់នេះ ជាកម្មភពផង វិបាកភពផង ។ កម្មក្នុងឋានៈទាំងពីរ ឈ្មោះថា **កម្មបវត្ត** វិបាកក្នុងឋានៈទាំងពីរ ឈ្មោះថា **វិបាកបវត្ត** ព្រោះហេតុនោះ ទើបភវចក្រទាំងអស់នេះ ជាកម្មបវត្តផង ជាវិបាកបវត្តផង ។ ម្យ៉ាងទៀត កម្មក្នុងឋានៈទាំងពីរ ឈ្មោះថា **កម្មសន្តតិ** វិបាកក្នុងឋានៈទាំងពីរ ឈ្មោះថា **វិបាកសន្តតិ** ព្រោះហេតុនោះ ទើបភវចក្រទាំងអស់នេះ ជាកម្មសន្តតិផង ជាវិបាកសន្តតិផង ។ ម្យ៉ាងទៀត កម្មក្នុងឋានៈទាំងពីរ ឈ្មោះថា **កិរិយា** វិបាកក្នុងឋានៈទាំងពីរ ឈ្មោះថា ផលរបស់កិរិយា ព្រោះហេតុនោះ ទើបភវចក្រទាំងអស់នេះ ជាកិរិយាផង ជាផលរបស់កិរិយាផង ដោយប្រការដូច្នេះ ។

ភវចក្រនេះ កើតឡើងព្រមហើយ ប្រកបដោយហេតុជាទុក្ខ មិនទៀង មានការញាប់ញ័រ ប្រែប្រួល មិនស្ថិតស្ថេរ ធម៌ទាំងឡាយ រមែងកើតអំពីធម៌ទាំងឡាយ ដោយភាពជាហេតុ ព្រោះក្នុងធម៌ទាំងនេះ មិនមានតួខ្លួន និងអ្នកដទៃ ។

ធម៌ទាំងឡាយ រមែងញ៉ាំងធម៌ទាំងឡាយឲ្យកើតឡើងឯង ព្រោះបច្ច័យ គឺហេតុជាអង្គប្រកប ឯធម៌ដែលព្រះសម្ពុទ្ធទ្រង់សម្តែង ដើម្បីការរម្ងាត់នូវហេតុទាំងឡាយ ។

កាលហេតុទាំងឡាយរលត់ហើយ វដ្តៈក៏ដាច់ មិនវិលទៅ បុគ្គល

ប្រព្រឹត្តព្រហ្មចរិយៈ ក្នុងធម្មវិន័យនេះ រមែងប្រព្រឹត្តទៅដើម្បីធ្វើនូវទីបំផុតនៃទុក្ខ ដោយប្រការដូច្នេះ ម្យ៉ាងទៀត កាលរកសត្វបុគ្គលមិនបាន ការដាច់សូន្យ និងការទៀង រមែងមិនមាន ។

ក្នុងពាក្យថា មានវដ្ដៈ ៣ រមែងវិលទៅមិនមានកំណត់នេះ អធិប្បាយថា ភវចក្រនេះ មានវដ្ដៈ ៣ ដោយវដ្ដៈទាំង ៣ នេះ គឺសង្ខារ និងភព ជាកម្មវដ្ដៈ អវិជ្ជា តណ្ហា និងឧបាទាន ជាកិលេសវដ្ដៈ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ និងវេទនា ជាវិបាកវដ្ដៈ គប្បីជ្រាបថា រមែងវិលទៅដោយការវិលទៅជុំវិញរឿយៗ ដែលមិនមានកំណត់ ព្រោះមានបច្ច័យមិនទាន់ដាច់ អស់កាលដែលកិលេសវដ្ដៈមិនទាន់ដាច់នោះឯង ភវចក្រនេះកាលវិលយ៉ាងនេះ

គប្បីជ្រាបដោយភាពជាសច្ចៈ និងជាដែនកើត ១ ដោយកិច្ច ១ ដោយការឃាត់ ១ ដោយការឧបមា ១ ដោយប្រភេទនៃជម្រៅ ១ និងដោយប្រភេទរបស់ន័យ ១ តាមសមគួរ ។

ក្នុងគាថានោះ ព្រោះពាក្យដែលត្រាស់ក្នុងសច្ចវិភង្គថា កុសល និងអកុសលកម្ម ជាសមុទយសច្ច ដោយមិនប្លែកគ្នា ដូច្នេះ ព្រោះហេតុនោះពាក្យថា **អវិជ្ជាបច្ចយា សង្ខារា** បានដល់ សង្ខារទាំងឡាយ កើតព្រោះអវិជ្ជា ចាត់ជាសច្ចៈទី ២ មានសច្ចៈទី ២ ជាដែនកើត ។ វិញ្ញាណកើតព្រោះសង្ខារទាំងឡាយ ចាត់ជាសច្ចៈទី ១ មានសច្ចៈទី ២ ជាដែនកើតនាមរូបជាដើម មានវិបាកវេទនាជាទីបំផុត កើតព្រោះវិញ្ញាណជាដើម ចាត់

ជាសច្ចៈទី ១ មានសច្ចៈទី ១ ជាដែនកើត តណ្ហាកើតព្រោះវេទនា ចាត់ជាសច្ចៈទី ២ មានសច្ចៈទី ១ ជាដែនកើត ឧបាទានកើតព្រោះតណ្ហា ចាត់ជាសច្ចៈទី ២ មានសច្ចៈទី ២ ជាដែនកើត ភពកើតព្រោះឧបាទាន ចាត់ជាសច្ចៈពីរ គឺទី ១ និងទី ២ មានសច្ចៈទី ២ ជាដែនកើត ។ ជាតិកើតព្រោះភព ចាត់ជាសច្ចៈទី ១ មានសច្ចៈទី ២ ជាដែនកើត ។ ជរាមរណៈ កើតព្រោះជាតិ ចាត់ជាសច្ចៈទី ១ មានសច្ចៈទី ១ ជាដែនកើត ព្រោះហេតុនោះ ភវចក្រនេះ គប្បីជ្រាបដោយភាពជាសច្ចៈ និងជាដែនកើត តាមសមគួរដូចពណ៌នាមក ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ព្រោះក្នុងភវចក្រនេះ អវិជ្ជារមែងញ៉ាំងសត្វឲ្យវង្វេងក្នុងវត្ថុទាំងឡាយ និងរមែងជាបច្ច័យ ដល់ការប្រាកដនៃសង្ខារទាំងឡាយ ។ ម្យ៉ាងទៀត សង្ខារទាំងឡាយ រមែងតាក់តែងសង្ខតធម៌ និងរមែងជាបច្ច័យដល់វិញ្ញាណ សូម្បីវិញ្ញាណក៏រមែងដឹងច្បាស់នូវវត្ថុ និងរមែងជាបច្ច័យដល់នាមរូប សូម្បីនាមរូបក៏ឧបត្ថម្ភនូវគ្នានិងគ្នា និងរមែងជាបច្ច័យដល់សឡាយតនៈ សូម្បីសឡាយតនៈ ក៏រមែងប្រព្រឹត្តទៅក្នុងវិស័យរបស់ខ្លួន និងរមែងជាបច្ច័យដល់ផស្សៈ សូម្បីផស្សៈក៏ពាល់ត្រូវនូវអារម្មណ៍ និងរមែងជាបច្ច័យដល់វេទនា សូម្បីវេទនាក៏សោយនូវរសនៃអារម្មណ៍ និងរមែងជាបច្ច័យដល់តណ្ហា សូម្បីតណ្ហាក៏ត្រេកត្រអាលក្នុងធម៌ ដែលជាទីតាំងនៃតម្រេក និងរមែងជាបច្ច័យដល់ឧបាទាន សូម្បីឧបាទានក៏កាន់យកធម៌ដែលជាទីតាំងនៃការប្រកាន់ និងរមែងជាបច្ច័យដល់ភព សូម្បីភពក៏រសាត់ទៅក្នុងគតិផ្សេងៗ និង

រមែងជាបច្ច័យដល់ជាតិ ។ ជាតិក៏ញុំាងខន្ធទាំងឡាយឲ្យកើត ព្រោះខន្ធទាំងនោះ ប្រព្រឹត្តទៅដោយភាវៈ គឺការកើតដោយចំពោះ រមែងជាបច្ច័យដល់ជរាមរណៈ សូម្បីជរាមរណៈ ក៏ធ្វើការចាស់ និងការបែកធ្លាយនៃខន្ធទាំងឡាយ និងរមែងជាបច្ច័យដល់ការប្រាកដក្នុងភពដទៃ ព្រោះជាទីតាំងនៃសេចក្ដីសោកជាដើម ហេតុនោះ ភវចក្រនេះ បណ្ឌិតគប្បីជ្រាបដោយកិច្ចដែលប្រព្រឹត្តទៅពីរយ៉ាង ក្នុងបទទាំងពួង តាមសមគួរ ។

ម្យ៉ាងទៀត ក្នុងភវចក្រនេះ ពាក្យថា **អវិជ្ជាបច្ចយា សង្ខារា** ដូច្នេះ ជាការឃាត់នូវការឃើញថា មានអ្នកសាង ។ ពាក្យថា **សង្ខារប្បច្ចយា វិញ្ញាណំ** ជាការឃាត់នូវការយល់ឃើញថា អត្តាឃ្លាតចាកទីមួយ ទៅកាន់ទីមួយបាន ។ ពាក្យថា **វិញ្ញាណប្បច្ចយា នាមរូបំ** ជាការឃាត់នូវការសម្គាល់ថា ជាឃនៈ គឺដុំ ព្រោះឃើញនូវការបែកធ្លាយទៅនៃវត្ថុដែលកំណត់ថា អត្តា ។ ក្នុងពាក្យថា **នាមរូបប្បច្ចយា សឡាយតនំ** ជាដើម ជាការឃាត់នូវការឃើញយ៉ាងនេះថា អត្តា រមែងឃើញ ។បេ។ រមែងដឹង រមែងពាល់ត្រូវ រមែងសោយ រមែងប្រកាន់ រមែងប្រកាន់មាំ រមែងមាន រមែងកើត រមែងចាស់ រមែងស្លាប់ ដូច្នេះជាដើម ព្រោះហេតុនោះ គប្បីជ្រាបភវចក្រនេះ ដោយការឃាត់នូវទិដ្ឋិ តាមសមគួរចុះ ។

ក្នុងភវចក្រនេះ អវិជ្ជាប្រៀបដូចមនុស្សខ្វាក់ ព្រោះមិនឃើញធម៌ទាំងឡាយ ដោយអំណាចនៃសភាវលក្ខណៈ និងសាមញ្ញលក្ខណៈ សង្ខារទាំងឡាយ ដែលកើតព្រោះអវិជ្ជាជាបច្ច័យ ប្រៀបដូចការរអិលរបស់មនុស្ស

ខ្វាក់ ។ វិញ្ញាណដែលកើតព្រោះសង្ខារជាបច្ច័យ ប្រៀបដូចការដួលរបស់មនុស្សខ្វាក់ដែលរអិលនោះ នាមរូបដែលកើតព្រោះវិញ្ញាណជាបច្ច័យ ប្រៀបដូចការប្រាកដដំបៅរបស់មនុស្សខ្វាក់ដែលដួលហើយ សឡាយតនៈដែលកើតព្រោះនាមរូបជាបច្ច័យ ប្រៀបដូចពកដែលបែករបស់បូស ។ ផស្សៈដែលកើតព្រោះសឡាយតនៈជាបច្ច័យ ប្រៀបដូចការប៉ះខ្ទប់ត្រង់បូស វេទនាដែលកើតព្រោះផស្សៈជាបច្ច័យ ប្រៀបដូចសេចក្តីទុក្ខព្រោះការប៉ះពាល់នោះ តណ្ហាដែលកើតព្រោះវេទនាជាបច្ច័យ ប្រៀបដូចបុគ្គលត្រូវការបំបាត់ទុក្ខ ឧបាទានដែលកើតព្រោះតណ្ហាជាបច្ច័យ ប្រៀបដូចការកាន់យកភេសជ្ជៈដែលជាអសប្បាយមកដោយប្រាថ្នានឹងបំបាត់រោគ ភពដែលកើតព្រោះឧបាទានជាបច្ច័យ ប្រៀបដូចការដាក់ថ្នាំដែលជាអសប្បាយដែលខ្ជួនបានមក ជាតិកើតព្រោះភពជាបច្ច័យ ប្រៀបដូចការប្រាកដនៃដំបៅក្លាយ ដោយការដាក់ថ្នាំដែលជាអសប្បាយ ជរាមរណៈដែលកើតព្រោះជាតិជាបច្ច័យ ប្រៀបដូចការបែកនៃបូស ព្រោះក្លាយនោះ ។

ក្នុងភវចក្រនេះ អវិជ្ជារមែងគ្របសង្កត់សត្វទាំងឡាយ ដោយភាវៈដែលមិនបដិបត្តិ និងភាវៈដែលបដិបត្តិខុស ដូចសំពត់រុំភ្នែក ឯបុគ្គលពាលត្រូវអវិជ្ជាគ្របសង្កត់ហើយ រមែងចងខ្លួនដោយសង្ខារទាំងឡាយ ដែលឲ្យកើតក្នុងភពថ្មី ដូចដង្កូវនាងរុំខ្លួនដោយចំណែកនៃសម្បុក ។ វិញ្ញាណដែលសង្ខារកំណត់កាន់យកហើយ រមែងបានទីអាស្រ័យក្នុងគតិទាំងឡាយ ដូចព្រះរាជកុមារដែលបរិនាយកដឹកនាំហើយ រមែងបានសោយរាជសម្បត្តិ ។

វិញ្ញាណរមែងញុំាងនាមរូប មានប្រការជាអនេក ឲ្យកើតក្នុងបដិសន្ធិ ព្រោះកំណត់និមិត្តនៃការកើតឡើង ដូចនាយមាយាករ ញុំាងមាយាឲ្យកើត ( ធ្វិនភ្នែក ) ។ សឡាយតនៈអាស្រ័យនាមរូបហើយ រមែងដល់នូវភាពចម្រើនដុះដាលបរិបូណ៌ ដូចគុម្ពឈើអាស្រ័យភូមិភាគដែលល្អ ។ ផស្សៈរមែងកើតព្រោះការប៉ះខ្ទប់នៃអាយតនៈ ដូចភ្លើងកើតព្រោះការកួតគ្នានៃឈើពំនួត ។ វេទនារមែងប្រាកដដល់បុគ្គលដែលត្រូវប៉ះខ្ទប់ដោយផស្សៈ ដូចការក្តៅរបស់បុគ្គលដែលពាល់ត្រូវភ្លើង ។ តណ្ហារមែងចម្រើនដល់បុគ្គលដែលសោយអារម្មណ៍ ដូចការស្រេករបស់បុគ្គលដែលផឹកទឹកប្រៃបន្ថែមឡើង បុគ្គលដែលស្រេកហើយ រមែងធ្វើសេចក្តីប្រាថ្នាក្នុងភពទាំងឡាយ ដូចបុគ្គលស្រេកប្រាថ្នាក្នុងការផឹកទឹក ។ ការធ្វើនូវការចង់បាននោះ ជាឧបាទានរបស់បុគ្គលនោះ រមែងប្រកាន់ភពដោយឧបាទាន ដូចត្រីជាប់សន្ទូច ព្រោះសេចក្តីលោភក្នុងនុយ ។ កាលភពមាន ជាតិក៏រមែងមាន ដូចកាលគ្រាប់ពូជមាន ពន្លកក៏ត្រូវមាន ។ បុគ្គលកើតហើយ រមែងចូលដល់ជរាមរណៈពិតប្រាកដ ដូចដើមឈើកើតឡើងហើយ ក៏ត្រូវដួលទៅ ដូច្នោះ ភវចក្រនេះ បណ្ឌិតគប្បីជ្រាបដោយឧបមាទាំងឡាយតាមសមគួរ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ព្រោះព្រះមានព្រះភាគទ្រង់សំដៅយកការជ្រាលជ្រៅដោយអត្ថខ្លះ ដោយធម៌ខ្លះ ដោយទេសនាខ្លះ ដោយការចាក់ធ្លុះខ្លះ ទើបត្រាស់ ( ក្នុងទីឃនិកាយ មហាវគ្គ ) ថា ម្នាលអានន្ទ អ្នកកុំពោលយ៉ាងនេះឡើយ បដិច្ចសមុប្បាទនេះជ្រៅផង ប្រាកដជាជ្រៅផង ដូច្នេះ ហេតុនោះ

ភវចក្រនេះ បណ្ឌិតគប្បីជ្រាបដោយប្រភេទនៃជម្រៅ តាមគួរ ។

ក្នុងជម្រៅដោយអត្ថជាដើមនោះ ព្រោះជរាមរណៈ នឹងមិនមានអំពីជាតិក៏មិនមែន និងព្រោះវៀរជាតិហើយ រមែងមិនកើតអំពីវត្ថុដទៃ និងរមែងប្រាកដព្រោះជាតិពិត ព្រោះហេតុនោះ អត្ថថា កើត និងប្រាកដ ព្រោះជាតិជាបច្ច័យដល់ជរាមរណៈ ទើបឈ្មោះថា ជ្រាលជ្រៅ ព្រោះអត្ថថា ប្រាកដឡើងព្រោះជាតិជាបច្ច័យ ដែលសត្វឈមចុះបានដោយក្រ ដោយប្រការដូច្នេះ ។ អត្ថថា កើត និងប្រាកដ ព្រោះភពជាបច្ច័យដល់ជាតិ ។បេ។ ព្រោះអវិជ្ជាជាបច្ច័យដល់សង្ខារទាំងឡាយ ក៏ឈ្មោះថា ជ្រាលជ្រៅយ៉ាងនោះ ទើបភវចក្រនេះ ឈ្មោះថា ជ្រាលជ្រៅដោយអត្ថ នេះជាការជ្រាលជ្រៅដោយអត្ថ ក្នុងភវចក្រនេះប៉ុណ្ណោះ ។

ផលដែលកើតអំពីហេតុ ទ្រង់ត្រាស់ហៅថា អត្ថ ដូចព្រះតម្រាស់ ( ក្នុងអភិធម្ម វិភង្គ ) ថា សេចក្តីដឹងផលនៃហេតុ ឈ្មោះថា អត្ថប្បដិ-សម្ភិទា ដូច្នេះ ។

ម្យ៉ាងទៀត ព្រោះអវិជ្ជា មានកិរិយាដែលតាំងចុះឯណា ដោយអាការណា ទើបជាបច្ច័យដល់សង្ខារនោះៗ អត្ថថា អវិជ្ជាជាបច្ច័យដល់សង្ខារទាំងឡាយ ឈ្មោះថា ជ្រាលជ្រៅ ព្រោះជាកិរិយា និងអាការនោះ ដែលសត្វត្រាស់ដឹងបានលំបាក អត្ថថា សង្ខារទាំងឡាយជាបច្ច័យដល់វិញ្ញាណ ។បេ។ អត្ថថា ជាតិជាបច្ច័យដល់ជរាមរណៈ ក៏ឈ្មោះថា ជ្រាលជ្រៅ ហេតុនោះ ទើបភវចក្រនេះ ឈ្មោះថា ជ្រាលជ្រៅដោយធម៌ នេះជាការជ្រាលជ្រៅ

ដោយធម៌ក្នុងភវចក្រនេះ ។

ពាក្យថា ធម៌ ជាឈ្មោះរបស់ហេតុ ដូចព្រះតម្រាស់ ( ក្នុងអភិធម្មវិភង្គ ) ថា សេចក្ដីដឹងហេតុ ឈ្មោះថា ធម្មប្បដិសម្ភិទា ដូច្នេះ ។ម្យ៉ាងទៀត ព្រោះការសម្ដែងភវចក្រនោះ ឈ្មោះថា ជ្រាលជ្រៅ ព្រោះទ្រង់ឲ្យប្រព្រឹត្តទៅដោយហេតុនោះៗ ដោយប្រការនោះៗ ញាណដទៃៗ ក្រៅអំពីសព្វញ្ញុតញ្ញាណហើយ រមែងមិនបានទូវការមាំទាំក្នុងការសម្ដែងនោះ ពិតហើយ ភវចក្រនេះ ក្នុងព្រះសូត្រកន្លែងខ្លះ ទ្រង់សម្ដែងដោយអនុលោម កន្លែងខ្លះ ទ្រង់សម្ដែងដោយបដិលោម កន្លែងខ្លះ ទ្រង់សម្ដែងដោយអនុលោមផងបដិលោមផង កន្លែងខ្លះ ទ្រង់សម្ដែងដោយអនុលោមខ្លះ ដោយបដិលោមខ្លះ តែចាប់ពីកណ្ដាលទៅ កន្លែងខ្លះ ក៏ទ្រង់សម្ដែងជាសន្ធិ ៣ និងសង្ខេប ៤ កន្លែងខ្លះ ទ្រង់សម្ដែងសន្ធិ ២ និងសង្ខេប ៣ កន្លែងខ្លះ ទ្រង់សម្ដែងសន្ធិ ១ និងសង្ខេប ២ ហេតុនោះ ទើបភវចក្រនេះ ឈ្មោះថា ជ្រាលជ្រៅដោយទេសនា នេះជាការជ្រាលជ្រៅដោយទេសនា ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ព្រោះក្នុងភវចក្រនេះ សភាវៈនៃធម៌ មានអវិជ្ជាជាដើមឯណា ធម៌មានអវិជ្ជាជាដើម រមែងជាធម៌ដែលបុគ្គលចាក់ធ្លុះដោយលក្ខណៈរបស់ខ្លួន ដោយសភាវៈដែលបុគ្គលចាក់ធ្លុះហើយឯណា សភាវៈនោះ ឈ្មោះថា ជ្រាលជ្រៅ ព្រោះឈមចុះបានដោយលំបាក ហេតុនោះ ទើបភវចក្រនេះ ឈ្មោះថា ជ្រាលជ្រៅដោយការចាក់ធ្លុះ ។ ពិតហើយ ក្នុងភវចក្រនេះ អត្ថនៃអវិជ្ជា ជាអញ្ញាណៈ ជាអទស្សនៈ និងការមិនចាក់ធ្លុះសច្ចៈ ជាធម៌ជ្រាលជ្រៅ

អត្ថនៃសង្ខារទាំងឡាយថា ជាសភាវៈតាក់តែង ជាការប្រកបកម្ម ប្រព្រឹត្តទៅជាមួយរាគៈ និងប្រាសចាករាគៈ ជាអត្ថជ្រាលជ្រៅ ។ អត្ថនៃវិញ្ញាណថា ជាសុញ្ញតៈ មិនខ្វល់ខ្វាយ មិនឃ្លាតទៅ និងប្រាកដជាបដិសន្ធិ ជាអត្ថជ្រាលជ្រៅ ។ អត្ថនៃនាមរូបថា ជាសភាវៈកើតព្រមគ្នា បែកគ្នាបាន បែកគ្នាមិនបាន បង្អោនទៅ និងប្រែប្រួល ជាអត្ថជ្រាលជ្រៅ ។ អត្ថនៃសឡាយតនៈថា ជាអធិបតី ជាលោក ជាទ្វារ ជាខេត្ត និងជាអារម្មណ៍ ជាអត្ថជ្រាលជ្រៅ ។ អត្ថនៃផស្សៈថា ជាការត្រូវប៉ះខ្ទប់ ការប្រសព្វ ការប្រជុំ ជាអត្ថជ្រាលជ្រៅ ។ អត្ថនៃវេទនាថា ជាការសោយរសនៃអារម្មណ៍ ជាសុខ ជាទុក្ខ ជាការព្រងើយ និងសោយអារម្មណ៍ដែលមិនមានជីវៈ ជាអត្ថជ្រាលជ្រៅ ។ អត្ថនៃតណ្ហាថា ជាការត្រេកអរ ជាការប្រាថ្នា ជាការត្រេកត្រអាលនោះ ជាតណ្ហា ដូចក្រសែទឹកស្ទឹង ជារបស់ឲ្យពេញបានដោយក្រ ដូចសមុទ្រ ជាអត្ថជ្រាលជ្រៅ ។ អត្ថនៃឧបាទានថា ជាការទាញ ការកាន់ ការប្រកាន់មាំ ការស្ទាបអង្អែល ឈានកន្លងបានដោយក្រ ជាអត្ថជ្រាលជ្រៅ ។ អត្ថនៃភពថា ជាការបន្សាត់ទៅក្នុងកំណើត គតិ វិញ្ញាណដ្ឋិតិ សត្តាវាស ព្រោះការតាក់តែងនៃការធ្វើកម្ម ជាអត្ថជ្រាលជ្រៅ ។ អត្ថនៃជាតិថា ជាការកើត ការកើតព្រម ការឈមចុះ ការកើតឡើង និងការប្រាកដ ជាអត្ថជ្រាលជ្រៅ ។ អត្ថនៃជរាមរណៈថា ជាការអស់ ជាការវិនាស ជាការបែកធ្លាយ និងការប្រែប្រួល ជាអត្ថជ្រាលជ្រៅ នេះជាការជ្រាលជ្រៅដោយការចាក់ធ្លុះក្នុងភវចក្រនេះ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ក្នុងភវចក្រនេះ មានអត្ថ ៤ គឺ **ឯកត្តន័យ** គឺន័យដែលមានអត្ថតែមួយ ១ **នានត្តន័យ** គឺន័យដែលមានអត្ថផ្សេងគ្នា ១ **អព្យាបារ-ន័យ** គឺន័យដែលមិនមានការខ្វល់ខ្វាយ ១ **ឯវំធម្មតាន័យ** គឺន័យដែលមានយ៉ាងនេះជាធម្មតា ១ ព្រោះហេតុនោះ គប្បីជ្រាបភវចក្រនេះ ដោយប្រភេទរបស់ន័យ តាមគួរ ។

បណ្ដាន័យទាំង ៤ នោះ ការមិនដាច់នៃសន្តាន ដូចភាពដែលគ្រាប់ពូជកើតជាដើមឈើ ដោយការមានពន្លកជាដើមយ៉ាងនេះ គឺព្រោះអវិជ្ជាជាបច្ច័យ ទើបកើតសង្ខារទាំងឡាយ ព្រោះសង្ខារជាបច្ច័យ ទើបកើតវិញ្ញាណ ដូច្នេះជាដើម ឈ្មោះថា **ឯកត្តន័យ** ។

កាលព្រះយោគាវចរឃើញភវចក្រដោយប្រពៃ រមែងលះឧច្ឆេទទិដ្ឋិបាន ព្រោះឈមចុះនូវការមិនដាច់ខ្សែនៃការបន្ត ដែលប្រព្រឹត្តទៅដោយការជាប់ទាក់ទងគ្នាទាំងហេតុ និងផល កាលឃើញខុស រមែងកាន់យកដោយសស្សតទិដ្ឋិ ព្រោះប្រកាន់ភាពតែមួយនៃការមិនដាច់នៃការបន្ត ដែលកំពុងប្រព្រឹត្តទៅ ដោយការប្រទាក់គ្នានូវហេតុ និងផល ។

ចំណែកការកំណត់លក្ខណភវចក្រ មានអវិជ្ជាជាដើម តាមភាវៈរបស់ខ្លួន ឈ្មោះថា **នានត្តន័យ** ។ កាលព្រះយោគាវចរឃើញភវចក្រដោយប្រពៃ រមែងលះសស្សតទិដ្ឋិបាន ព្រោះឃើញនូវការកើតឡើងនៃសភាវៈថ្មីៗ កាលឃើញខុស រមែងប្រកាន់ឧច្ឆេទទិដ្ឋិ ព្រោះប្រកាន់នូវការផ្សេងគ្នានៃការបន្តដែលផ្សេងគ្នា ដែលធ្លាក់ទៅក្នុងការបន្តជាមួយគ្នានោះឯង ។

ភាពដែលអវិជ្ជាមិនមានការខ្វល់ខ្វាយថា សង្ខារទាំងឡាយ អញគប្បី ឲ្យកើតឡើង ឬភាពដែលសង្ខារទាំងឡាយ មិនមានសេចក្តីខ្វល់ខ្វាយថា វិញ្ញាណដែលពួកយើងគប្បីឲ្យកើតឡើងដូច្នេះ ឈ្មោះថា **អព្យាបារន័យ** ។

កាលព្រះយោគាវចរឃើញដោយប្រពៃ រមែងលះអត្តទិដ្ឋិ ព្រោះឃើញនូវការមិនមានអ្នកសាង កាលឃើញខុស រមែងប្រកាន់អកិរិយទិដ្ឋិ ព្រោះមិនប្រកាន់ភាពជាហេតុដែលដល់សូម្បីមិនមានព្យាយាម ក៏សម្រេចដោយការកំណត់ភាវៈនៃអវិជ្ជាជាដើម ។

ម្យ៉ាងទៀត ការកើតឡើងនៃធម៌ មានសង្ខារជាដើម ព្រោះហេតុទាំងឡាយ មានអវិជ្ជាជាដើម មិនមែនធម៌ដទៃ ដូចភាពដែលទឹកដោះជូរជាដើម កើតអំពីទឹកដោះស្រស់ជាដើម ដូច្នេះ នេះឈ្មោះថា **ឯវំធម្មតាន័យ** ។ កាលព្រះយោគាវចរឃើញដោយប្រពៃ រមែងលះអហេតុកទិដ្ឋិ និងអកិរិយទិដ្ឋិបាន ព្រោះដឹងផលដោយសមគួរដល់បច្ច័យ កាលយល់ខុស រមែងកាន់យកអហេតុកទិដ្ឋិ និងនិយតវាទ ព្រោះមិនប្រកាន់នូវការប្រព្រឹត្តទៅនៃផលដែលគួរដល់បច្ច័យ មិនប្រកាន់នូវការកើតរបស់សភាវៈណាមួយ អំពីទីណាមួយឡើយ ព្រោះហេតុនោះ ភវចក្រនេះ បណ្ឌិត

គប្បីជ្រាបដោយភាពជាសច្ចៈ និងជាដែនកើត ១ ដោយកិច្ច ១
ដោយការឃាត់ ១ ដោយឧបមា ១ ដោយប្រភេទដែលជ្រៅ
១ ដោយប្រភេទរបស់ន័យ ១ តាមគួរ ដោយប្រការដូច្នេះ ។

ពិតហើយ ភវចក្រនេះ ឈ្មោះថា ឈមចុះមិនដល់ ព្រោះជ្រាលជ្រៅ

ឈ្មោះថា ឈានកន្លងបានដោយក្រ ព្រោះត្រូវសិក្សាដោយន័យផ្សេងៗ បុគ្គលណាម្នាក់មិនទម្លាយកវចក្រ ដែលញាំញីជានិច្ច ដូចអសនីបាត ដោយដាវគឺញាណ ដែលសំលៀងល្អហើយលើថ្ម គឺសមាធិដ៏ប្រសើរហើយ នឹងឆ្លងផុតភ័យ គឺសង្សារមិនមាន សូម្បីក្នុងយល់សប្តិ ។ សេចក្តីនេះ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ថា

ម្នាលអានន្ទ អ្នកកុំពោលយ៉ាងនេះឡើយ បដិច្ចសមុប្បាទនេះជ្រៅផង ប្រាកដជាជ្រៅផង ។ ម្នាលអានន្ទ ព្រោះមិនបានត្រាស់ដឹង ព្រោះមិនបានចាក់ធ្លុះនូវធម៌នុ៎ះឯង ទើបពួកសត្វនេះកើតទៅជាស្មុគស្មាញ ដូចជាតម្បាញ ( ដែលកណ្តុរកាត់ ) ដូចជាអំបោះត្រូវទឹកបាយរបស់ជាងតម្បាញ ឬដូចជាសម្បុកសត្វស្វាប ដូចជាស្មៅយាប្លង និងស្មៅជំណោកទន្សាយដែលជំពាក់គ្នាយ៉ាងនេះ ទើបមិនកន្លងនូវអបាយ ទុគ្គតិ វិនិបាត និងសង្សារបាន ដូច្នេះ ។

ព្រោះហេតុនោះ បណ្ឌិតក្នុងលោកនេះ ជាអ្នកបដិបត្តិដើម្បីប្រយោជន៍ដើម្បីសេចក្តីសុខដល់ខ្លួន ឬដល់បុគ្គលដទៃ លះកិច្ចដ៏សេសហើយ

គប្បីជាអ្នកមានសតិសព្វកាល ប្រកបសេចក្តីព្យាយាមរឿយៗ ដោយប្រការដែលគប្បីបាននូវការឈមចុះ ក្នុងប្រភេទនៃបច្ចយាការដ៏ជ្រាលជ្រៅបាន ដូច្នេះ ៕

**សុត្តន្តភាជនីយឧទ្ទេសវារ ចប់**

# អភិធម្មបិដក

## អភិធម្មភាជនីយ

[ ២០ ] សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈកើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈកើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ២១ ] សង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ នាមកើតមាន ព្រោះវិញ្ញាណជាបច្ច័យ ផស្សៈកើតមាន ព្រោះនាមជាបច្ច័យ វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈកើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ២២ ] សង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ នាម និងរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាម និងរូបជាបច្ច័យ ផស្សៈកើតមាន ព្រោះអាយតនៈ

ទី ៦ ជាបច្ច័យ វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈកើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានដោយអាការយ៉ាងនេះ ។

[ ២៣ ] សង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ នាម និងរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈ ៦ កើតមាន ព្រោះនាម និងរូបជាបច្ច័យ ផស្សៈកើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈកើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានដោយអាការយ៉ាងនេះ ។

## បច្ចយចតុក្កៈ ចប់

[ ២៤ ] សង្ខារមានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណមានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមមានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ មាននាមជាហេតុ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ មានអាយតនៈទី ៦ ជាហេតុ កើតមាន

ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនាមានផស្សៈជាហេតុ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាមានវេទនាជាហេតុ កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន មានតណ្ហាជាហេតុ កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ២៥ ] សង្ខារ មានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណមានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមមានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ផស្សៈមាននាមជាហេតុ កើតមាន ព្រោះនាមជាបច្ច័យ វេទនាមានផស្សៈជាហេតុ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាមានវេទនាជាហេតុ កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានមានតណ្ហាជាហេតុ កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ២៦ ] សង្ខារមានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណមានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម និងរូបមានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ មាននាម និងរូបជាហេតុ កើតមាន ព្រោះនាម និងរូបជាបច្ច័យ ផស្សៈមានអាយតនៈ

ទី ៦ ជាហេតុ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនាមានផស្សៈជាហេតុ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា មានវេទនាជាហេតុ កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន មានតណ្ហាជាហេតុ កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ២៧ ] សង្ខារ មានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ មានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម និងរូប មានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈ ៦ មាននាម និងរូបជាហេតុ កើតមាន ព្រោះនាម និងរូបជាបច្ច័យ ផស្សៈ មានអាយតនៈ ៦ ជាហេតុ កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ វេទនា មានផស្សៈជាហេតុ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា មានវេទនាជាហេតុ កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន មានតណ្ហាជាហេតុ កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

ហេតុចតុក្កៈ ចប់

[ ២៨ ] សង្ខារ ប្រកបដោយអវិជ្ជា កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមប្រកបដោយវិញ្ញាណ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ ប្រកបដោយនាម កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈប្រកបដោយអាយតនៈទី ៦ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនាប្រកបដោយផស្សៈ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាប្រកបដោយវេទនា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានប្រកបដោយតណ្ហា កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ២៩ ] សង្ខារប្រកបដោយអវិជ្ជា កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមប្រកបដោយវិញ្ញាណ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ផស្សៈប្រកបដោយនាម កើតមាន ព្រោះនាមជាបច្ច័យ វេទនាប្រកបដោយផស្សៈ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាប្រកបដោយវេទនា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានប្រកបដោយតណ្ហា កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៣០ ] សង្ខារប្រកបដោយអវិជ្ជា កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម និងរូប ប្រកបដោយវិញ្ញាណ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ ប្រកបដោយនាម និងរូប កើតមាន ព្រោះនាម និងរូបជាបច្ច័យ ផស្សៈប្រកបដោយអាយតនៈទី ៦ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនាប្រកបដោយផស្សៈ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាប្រកបដោយវេទនា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានប្រកបដោយតណ្ហា កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៣១ ] សង្ខារប្រកបដោយអវិជ្ជា កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម និងរូបប្រកបដោយវិញ្ញាណ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ នាម និងអាយតនៈ ៦ ប្រកបដោយនាម កើតមាន ព្រោះនាម និងរូបជាបច្ច័យ ផស្សៈប្រកបដោយអាយតនៈ ៦ កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ វេទនាប្រកបដោយផស្សៈ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាប្រកបដោយវេទនា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានប្រកបដោយតណ្ហា កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំង

អស់ទាំងអស់ រមែងមាន ដោយអាការយ៉ាងនេះ ។

សម្បយុត្តចតុក្កៈ ចប់

[ ៣២ ] សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ សង្ខារ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះនាមជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ នាម កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះផស្សៈជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ផស្សៈកើតមាន ព្រោះវេទនាជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ វេទនា កើតមាន ព្រោះតណ្ហាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ តណ្ហា កើតមាន ព្រោះឧបាទានជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៣៣ ] សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ សង្ខារ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ

វិញ្ញាណ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះនាមជាបច្ច័យ នាម កើតមាន ព្រោះផស្សៈជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ផស្សៈ កើតមាន ព្រោះវេទនាជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ វេទនា កើតមាន ព្រោះតណ្ហាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ តណ្ហា កើតមាន ព្រោះឧបាទានជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៣៤ ] សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ សង្ខារ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ នាម និងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះនាម និងរូបជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាម និងរូបជាបច្ច័យ នាម និងរូប កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះផស្សៈជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ផស្សៈ កើតមាន ព្រោះវេទនាជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ វេទនា កើតមាន ព្រោះតណ្ហាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ តណ្ហា កើតមាន ព្រោះឧបាទានជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ

កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៣៥ ] សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ សង្ខារ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ នាម និងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ វិញ្ញាណកើតមាន ព្រោះនាម និងរូបជាបច្ច័យ អាយតនៈ ៦ កើតមាន ព្រោះនាម និងរូបជាបច្ច័យ នាម និងរូប កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ អាយតនៈ ៦ កើតមាន ព្រោះផស្សៈជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ផស្សៈ កើតមាន ព្រោះវេទនាជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ វេទនា កើតមាន ព្រោះតណ្ហាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ តណ្ហា កើតមាន ព្រោះឧបាទានជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

## អញ្ញមញ្ញចតុក្កៈ ចប់

[ ៣៦ ] អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ ។បេ។ អវិជ្ជា កើត

មាន ព្រោះវិញ្ញាណជាបច្ច័យ ។បេ។ អវិជ្ជា កើតមាន ព្រោះនាមជាបច្ច័យ ។បេ។ អវិជ្ជា កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ ។បេ។ អវិជ្ជា កើតមាន ព្រោះផស្សៈជាបច្ច័យ ។បេ។ អវិជ្ជា កើតមាន ព្រោះវេទនាជាបច្ច័យ ។បេ។ អវិជ្ជា កើតមាន ព្រោះតណ្ហាជាបច្ច័យ ។បេ។ អវិជ្ជា កើតមាន ព្រោះឧបាទានជាបច្ច័យ ។បេ។ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម និងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈ ៦ កើតមាន ព្រោះនាម និងរូបជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

**មាតិកា ចប់**

# អដ្ឋកថា

## អភិធម្មភាជនីយ

[ ២០ ] ព្រះសាស្តា ទ្រង់មានញាណមិនទើសទាក់ក្នុងធម៌ទាំងពួង កាលទ្រង់សម្តែងបច្ចយាការ ដែលប្រាសចាកកំណួច មិនសាំញ៉ាំ ក្នុងសុត្តន្តភាជនីយ ដោយអំណាចចិត្តផ្សេងៗ ដូចទ្រង់ប្របាច់ផ្ទៃមហាប្រឹថពី និងដូចទ្រង់ពង្រីកនភាកាស ដោយប្រការដូច្នេះហើយ ឥឡូវនេះ ព្រោះបច្ចយាការនេះ នឹងមានក្នុងចិត្តផ្សេងៗ តែម្យ៉ាងប៉ុណ្ណោះក៏មិនមែន រមែងមានក្នុងចិត្តមួយដួងនោះឯង ព្រោះហេតុនោះ ដើម្បីទ្រង់សម្តែងបច្ចយាការ ដែលកើតក្នុងខណៈចិត្តដួងតែមួយ ដោយប្រការផ្សេងៗ ដោយអំណាចអភិធម្ម-ភាជនីយ ទើបទ្រង់តាំងមាតិកាមុនដោយន័យជាដើមថា **អវិជ្ជាបច្ចយា សង្ខារោ** ដូច្នេះ ឯមាតិកា ទ្រង់តាំងទុកយ៉ាងនេះថា

បណ្ឌិតគប្បីសម្តែងចតុក្កៈ និងប្រភេទនៃវារៈក្នុងន័យទាំង ៩ ដែល
មានបទនៃមូល ៩ ដោយមូលទាំងឡាយ មានអវិជ្ជាជាដើម ។
ក្នុងគាថានេះ មានអធិប្បាយដូចតទៅ

ពិតហើយ ក្នុងបដិច្ចសមុប្បាទនេះ មាន ៩ ន័យ មានបទដែលជាមូលទាំង ៩ បទនេះ គឺមានអវិជ្ជាជាបទដើម ១ មានសង្ខារជាបទដើម ១ មានវិញ្ញាណជាបទដើម ១ មាននាមជាបទដើម ១ មានអាយតនៈទី ៦ ជាបទដើម ១ មានផស្សៈជាបទដើម ១ មានវេទនាជាបទដើម ១ មានតណ្ហាជាបទដើម ១ មានឧបាទានជាបទដើម ១ ដោយបទដែលជាមូល ៩ បទ មានអវិជ្ជាជាដើម គឺដោយប្រភេទនៃអវិជ្ជា សង្ខារ វិញ្ញាណ នាម ឆដ្ឋាយតនៈ

ផស្សៈ វេទនា តណ្ហា និងឧបាទាន ។

បណ្ដានំយទាំង ៩ នោះ ន័យ មានអវិជ្ជាជាបទដើមក្នុងន័យដែលមាន អវិជ្ជាជាបទដើមនោះ មានចតុក្កៈ ៤ គឺបច្ចយចតុក្កៈ ១ ហេតុចតុក្កៈ ១ សម្បយុត្តចតុក្កៈ ១ អញ្ញមញ្ញចតុក្កៈ ១ ។ ន័យដ៏សេស ក៏ដូចក្នុងន័យ មានអវិជ្ជានេះដូចគ្នា ព្រោះហេតុនោះ ទើបន័យនីមួយៗ រួមជា ៣៦ ចតុក្កៈ ដោយអំណាចនៃចតុក្កៈ ៤ ក្នុងមួយន័យ ។ បណ្ដាចតុក្កៈទាំងនោះ ព្រោះរួម វារៈនីមួយៗ ៤ ដោយចតុក្កៈ ១ ក្នុងមួយន័យ ទើបមាននីមួយៗ ១៦ វារៈ ដោយអំណាចនៃចតុក្កៈទាំង ៤ ហេតុនោះ គប្បីជ្រាបថា ជា ១៤៤ វារៈ ។

## បច្ចយចតុក្កៈ

បណ្ដាចតុក្កៈទាំង ៤ នោះ បច្ចយចតុក្កៈ ក្នុងន័យ មានអវិជ្ជាជាមូល ក្នុងបច្ចយចតុក្កៈនោះ វារៈទី ១ ឈ្មោះថា **ទ្វានសង្គិកវារ** គឺវារៈប្រកបដោយ អង្គ ១២ ប្រកបដោយអង្គ ២ មិនបរិបូណ៌ ព្រោះត្រាស់នាមក្នុងទីនៃនាមរូប និងត្រាស់អាយតនៈទី ៦ ក្នុងទីនៃសឡាយតនៈ វារៈទី ២ ឈ្មោះថា **ឯកកានសង្គិកវារ** គឺវារៈប្រកបដោយអង្គ ១១ ដែលប្រកបដោយអង្គ ១ មិនបរិបូណ៌ ព្រោះត្រាស់នាមតែម្យ៉ាង ក្នុងទីនៃនាមរូប និងមិនត្រាស់អង្គ ណាមួយ ក្នុងទីនៃសឡាយតនៈ ។ វារៈទី ៣ ឈ្មោះថា **ទ្វានសង្គិកវារ** ប្រកបដោយអង្គមួយបរិបូណ៌ ព្រោះត្រាស់ឆដ្ឋាយតនៈ ក្នុងទីនៃសឡាយតនៈ តែវារៈទី ៤ មានអង្គ ១២ បរិបូណ៌ហើយដោយពិត ។

ក្នុងសេចក្ដីនោះ បើមានសេចក្ដីសង្ស័យថា សូម្បីវារៈទី ៤ នេះក៏ប្រកប

ដោយអង្គមួយដែលមិនបរិបូណ៌ដូចគ្នា ព្រោះត្រាស់ថា **ឆដ្ឋាយតនប្បច្ចយា ផស្សោ** ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ដូច្នេះ ។ សេចក្តីនោះ សូមឆ្លើយថា មិនមែនដូច្នោះទេ ព្រោះអាយតនៈទី ៦ នោះ មិនមែនជាអង្គ សេចក្តីពិត ក្នុងវារៈទី ៤ នេះ ផស្សៈតែម្យ៉ាងជាអង្គ មិនមែនអាយតនៈទី ៦ ជាអង្គទេ ព្រោះហេតុនោះ វារៈទី ៤ នេះ មិនមែនប្រកបដោយអង្គ ១ មិនបរិបូណ៌ ព្រោះអាយតនៈទី ៦ នោះ មិនមែនជាអង្គដូច្នេះឯង ។ ម្យ៉ាងទៀត ក្នុងអដ្ឋកថាពោលថា វារៈទី ១ ទ្រង់កាន់យកដោយអត្ថថា ទ្រង់រួបរួមអង្គទាំងអស់ វារៈទី ២ ទ្រង់កាន់យកដោយអត្ថថា ជាការផ្សេងគ្នានៃបច្ច័យ វារៈទី ៣ ទ្រង់កាន់យកដោយអំណាចនៃសត្វដែលកើតក្នុងផ្ទៃ វារៈទី ៤ ទ្រង់កាន់យកដោយអំណាចនៃសត្វដែលជាឱបបាតិកៈ ។ ម្យ៉ាងទៀត វារៈទី ១ ទ្រង់កាន់យកដោយអត្ថថា ការរួបរួមអង្គទាំងអស់ វារៈទី ២ ទ្រង់កាន់យកដោយអត្ថថា ជាការផ្សេងគ្នានៃបច្ច័យ វារៈទី ៣ ទ្រង់កាន់យកដោយអំណាចនៃសត្វ មានអាយតនៈមិនបរិបូណ៌ វារៈទី ៤ ទ្រង់កាន់យកដោយអំណាចនៃសត្វ មានអាយតនៈបរិបូណ៌ ។ ម្យ៉ាងទៀត វារៈទី ១ ទ្រង់កាន់យកដោយអត្ថថា រួបរួមអង្គទាំងអស់នោះឯង វារៈទី ២ ទ្រង់កាន់យកដោយអំណាចមហានិទានសូត្រ វារៈទី ៣ ទ្រង់កាន់យកដោយអំណាចរូបកត វារៈទី ៤ ទ្រង់កាន់យកដោយអំណាចកាមកត ។

បណ្តាវារៈទាំង ៤ នោះ វារៈទី ១ ត្រាស់ថា **សព្វសង្គាហិក** គឺរួបរួមអង្គទាំងអស់ ព្រោះក្នុងវារៈទាំង ៣ មានវារៈទី ២ ជាដើមនេះ នឹងមិនរួម

ចូលក្នុងទីណាមួយមិនមាន ការផ្សេងគ្នានៃវារៈដ៏សេស នឹងមានច្បាស់ខាងមុខ ។ ដើម្បីការជាក់ច្បាស់នៃវារៈទី ១ នោះ គប្បីជ្រាបថា

អង្គបដិច្ចសមុប្បាទណា ក្នុងវារៈណាដែលត្រាស់ដោយប្រការដទៃ និងអង្គបដិច្ចសមុប្បាទណា ដែលមិនត្រាស់ក្នុងវារៈណា អង្គបដិច្ចសមុប្បាទណា ជាបច្ច័យដល់អង្គបដិច្ចសមុប្បាទណា ដោយប្រការណា គប្បីចូលទៅកំណត់អង្គបដិច្ចសមុប្បាទទាំងអស់នោះ ដោយប្រការដូច្នេះ ។

ក្នុងគាថានោះ មានន័យដូចតទៅនេះ ពោលដោយការមិនផ្សេងគ្នាមុនថា សួរថា បណ្ដាវារៈទាំង ៤ នេះ ព្រះមានព្រះភាគមិនបានត្រាស់ថា **សង្ខារា** ដូចក្នុងសុត្តន្តភាជនីយ តែត្រាស់ថា **សង្ខារោ** ដូច្នេះ ព្រោះហេតុអ្វី ។

ឆ្លើយថា ព្រោះសង្ខារប្រកបដោយខណៈនៃចិត្តមួយដួង ពិតហើយក្នុងសុត្តន្តភាជនីយនោះ ទ្រង់ចែកបច្ចយាការ ដែលប្រព្រឹត្តទៅក្នុងខណៈនៃចិត្តផ្សេងៗ គ្នា ក្នុងអភិធម្មភាជនីយនេះ ទ្រង់ប្រារព្ធបច្ចយាការដែលប្រព្រឹត្តទៅក្នុងខណៈចិត្តដួងជាមួយគ្នា ក្នុងខណៈនៃចិត្តមួយដួង រមែងមិនមានចេតនាគឺសង្ខារច្រើន ព្រោះហេតុនោះ ទើបមិនត្រាស់ថា **សង្ខារា** ( សង្ខារទាំងឡាយ ) តែត្រាស់ថា **សង្ខារោ** ( សង្ខារ ) ដូច្នេះ ។

ម្យ៉ាងទៀត បណ្ដាវារៈទាំងនេះ វារៈទី ១ ទ្រង់ចោលរូប ត្រាស់ថា **វិញ្ញាណប្បច្ចយា នាមំ** ប្រែថា នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ប៉ុណ្ណោះ ព្រោះទ្រង់រួបរួមធម៌ ដែលទាក់ទងក្នុងខណៈនៃចិត្តមួយដួង និង

ព្រោះជាធម៌សាធារណៈក្នុងទីគ្រប់ស្ថាន ។ ពិតហើយ នាមធម៌នោះ ទាក់ទង ក្នុងខណៈនៃចិត្តដួងតែមួយ និងជាធម៌សាធារណៈទៅក្នុងទីទាំងអស់ រមែង មិនប្រព្រឹត្តទៅក្នុងឋានៈនៃការប្រព្រឹត្តទៅរបស់វិញ្ញាណក្នុងទីណាមួយ ក៏មិន មែន ព្រោះវារៈទី ១ នេះ ផស្សៈក៏មាន ១ ប៉ុណ្ណោះ រាប់បញ្ចូលក្នុងខណៈ នៃចិត្តដួងជាមួយគ្នា ដូច្នោះ កាលទ្រង់កាន់យកអាយតនៈដែលជាបច្ច័យ សមគួរដល់ផស្សៈនោះ ទើបត្រាស់មនាយតនៈ ១ ដួងប៉ុណ្ណោះ ក្នុងឋានៈនៃ សឡាយតនៈថា **នាមប្បច្ចយា ឆដ្ឋាយតនំ** ប្រែថា អាយតនៈទី ៦ កើត មាន ព្រោះនាមជាបច្ច័យ ដូច្នេះ ។ មនាយតនៈនោះ ជាបច្ច័យដ៏សមគួរដល់ ផស្សៈ ដែលជាអកុសលតែម្យ៉ាង ។

ម្យ៉ាងទៀត មនាយតនៈនេះ ក៏ត្រាស់ក្នុងសេចក្ដីនេះថា **សង្ខារប្បច្ចយា វិញ្ញាណំ** ដូច្នេះក៏ពិត តែដើម្បីទ្រង់សម្ដែងការផ្សេងគ្នានៃហេតុ និងផល និង ដើម្បីគម្រប់អង្គ ទើបទ្រង់កាន់យកក្នុងទីនេះទៀត ព្រោះក្នុងសុត្តន្តភាជនីយ នោះ សង្ខារជាហេតុដោយភាពផ្សេងគ្នាដល់មនាយតនៈនេះ នាមជាផល ដោយមិនផ្សេងគ្នា តែក្នុងអភិធម្មភាជនីយនេះ នាមជាហេតុ ដោយភាពមិន ផ្សេងគ្នាដល់មនាយតនៈនេះ ផស្សៈជាផល ដោយភាពផ្សេងគ្នាដូច្នេះឯង ។

ចំណែកធម៌ទាំងអស់ មានសោកជាដើម ព្រោះមិនកើតក្នុងខណៈនៃ ចិត្ត ១ ដួង មិនប្រព្រឹត្តទៅក្នុងទីដែលចិត្តប្រព្រឹត្តទៅទាំងអស់ និងក្នុងចិត្ត គ្រប់ដួង ហេតុនោះ ទើបទ្រង់មិនកាន់យក តែជាតិ ជរា មរណៈ សូម្បី មានប្រមាណខណៈនៃចិត្តមិនបាន ក៏ទ្រង់កាន់យកដើម្បីគម្រប់អង្គនៃបច្ចយាការ

ព្រោះបន្ថែមចូលខាងក្នុងខណៈចិត្ត ក្នុងវារៈទី ១ នេះ អង្គបដិច្ចសមុប្បាទណា ត្រាស់ដោយប្រការដទៃ អង្គនៃបដិច្ចសមុប្បាទណា មិនត្រាស់ គប្បីជ្រាបអង្គបដិច្ចសមុប្បាទនោះ ដោយប្រការដូច្នេះមុន ។

ម្យ៉ាងទៀត ក្នុងវារៈទាំងនេះ អង្គបដិច្ចសមុប្បាទណា ដែលត្រាស់ក្នុងវារៈដទៃអំពីវារៈទី ១ នេះ គប្បីជ្រាបអត្ថនៃអង្គបដិច្ចសមុប្បាទនោះ ដោយន័យដែលពោលហើយនោះឯង តែការផ្សេងគ្នាណាមួយ មកហើយក្នុងវារៈណាមួយ ខ្ញុំនឹងប្រកាសអត្ថដែលផ្សេងគ្នានោះៗ ក្នុងវារៈនោះៗ ឯង ។

ចំណែកក្នុងពាក្យថា អង្គបដិច្ចសមុប្បាទណា ជាបច្ច័យដល់អង្គបដិច្ចសមុប្បាទណា ដោយប្រការណា នេះមានអធិប្បាយថា អវិជ្ជាជាបច្ច័យ ៧ យ៉ាងដល់សង្ខារ គឺដោយបច្ច័យ ៦ មានសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ដែលទូទៅដល់សម្បយុត្តធម៌ និងដោយហេតុប្បច្ច័យ ។ បណ្តាបច្ច័យទាំងនោះ ព្រោះចតុក្កៈ ៣ ដទៃទៀត មានហេតុចតុក្កៈជាដើម ត្រាស់ដោយអំណាចអវិគតប្បច្ច័យ សម្បយុត្តប្បច្ច័យ និងអញ្ញមញ្ញប្បច្ច័យ ហេតុនោះ ក្នុងបច្ចយ-ចតុក្កៈនេះ នាំបច្ច័យទាំង ៣ នោះចេញហើយ គប្បីជ្រាបថា អវិជ្ជាជាបច្ច័យ ៤ យ៉ាងដល់សង្ខារ ដោយអំណាចបច្ច័យដ៏សេស ។

សង្ខារជាបច្ច័យ ៨ យ៉ាង គឺដោយបច្ច័យដែលជាសាធារណៈ ៦ បច្ច័យ និងដោយកម្មប្បច្ច័យ ១ អាហារប្បច្ច័យ ១ តែក្នុងបច្ចយចតុក្កៈនេះ គប្បីនាំបច្ច័យទាំង ៣ នោះចេញ គប្បីបានបច្ច័យ ៥ ។

វិញ្ញាណជាបច្ច័យ ៩ យ៉ាងដល់នាម គឺដោយបច្ច័យដែលជាសាធារណៈ ៦ បច្ច័យ និងដោយឥន្ទ្រិយប្បច្ច័យ ១ អាហារប្បច្ច័យ ១ និងអធិបតិប្បច្ច័យ ១ តែក្នុងបច្ចយចតុក្កៈនេះ ដកបច្ច័យទាំង ៣ នោះចេញ នៅសល់បច្ច័យ ៦ ។

នាម ជាបច្ច័យដល់ឆដ្ឋាយតនៈ ដោយបច្ច័យដែលជាសាធារណៈ ៦ បច្ច័យ តែក្នុងទីនេះ នាមខ្លះជាបច្ច័យដោយអធិបតិប្បច្ច័យ នាមខ្លះជាបច្ច័យដោយអាហារប្បច្ច័យជាដើម ព្រោះហេតុនោះ ទើបនាមជាបច្ច័យបានច្រើនយ៉ាង តែក្នុងបច្ចយចតុក្កៈនេះ គប្បីនាំយកបច្ច័យទាំង ៣ នោះឯងចេញហើយ នៅសល់បច្ច័យ ៣ យ៉ាងខ្លះ ៤ យ៉ាងខ្លះ ៥ យ៉ាងខ្លះ ។

អាយតនៈទី ៦ ជាបច្ច័យដល់ផស្សៈ ដូចវិញ្ញាណជាបច្ច័យដល់នាម ។ ផស្សៈជាបច្ច័យ ៧ យ៉ាងដល់វេទនា គឺដោយសាធារណប្បច្ច័យ ៦ យ៉ាង និងដោយអាហារប្បច្ច័យ ១ តែក្នុងបច្ចយចតុក្កៈនេះ នាំបច្ច័យទាំង ៣ នោះចេញ នៅសល់បច្ច័យ ៤ យ៉ាង ។ វេទនាជាបច្ច័យ ៨ យ៉ាងដល់តណ្ហា គឺដោយសាធារណប្បច្ច័យ ៦ ដោយឈានប្បច្ច័យ ១ និងឥន្ទ្រិយប្បច្ច័យ ១ តែក្នុងបច្ចយចតុក្កៈនេះ ដកបច្ច័យទាំង ៣ នោះចេញ នៅសល់បច្ច័យ ៥ ។

តណ្ហា ជាបច្ច័យដល់ឧបាទាន ដូចអវិជ្ជាជាបច្ច័យដល់សង្ខារ ។ ឧបាទានជាបច្ច័យ ៧ យ៉ាងដល់ភព គឺដោយសាធារណប្បច្ច័យ ៦ យ៉ាង និងដោយមគ្គប្បច្ច័យ ១ តែក្នុងបច្ចយចតុក្កៈនេះ នាំបច្ច័យ ៣ នោះចេញ នៅសល់បច្ច័យ ៤ យ៉ាង ។

ភព ជាបច្ច័យដល់ជាតិដោយឧបនិស្សយប្បច្ច័យប៉ុណ្ណោះ ដោយបរិយាយ គឺដោយអម ព្រោះក្នុងពាក្យថា ជាតិនេះ បំណងយកសង្ខតលក្ខណៈ ជាតិជាបច្ច័យដល់ជរាមរណៈដោយឧបនិស្សយប្បច្ច័យតែម្យ៉ាងដូចគ្នា ។

ចំណែកអាចារ្យពួកណាពោលយ៉ាងនេះថា ក្នុងចតុក្កៈនេះ អវិជ្ជាជាដើម ជាបច្ច័យដល់សង្ខារជាដើមទាំងអស់ ដោយសហជាតប្បច្ច័យ ព្រោះវារៈទី ១ ទ្រង់ផ្ដើមដោយអំណាចសហជាតប្បច្ច័យប៉ុណ្ណោះ អាចារ្យទាំងនោះ ដែលបុគ្គលណាម្នាក់ សម្ដែងភាពមិនយ៉ាងនោះនៃភពជាដើម និងសម្ដែងការកើតឡើងនៃបច្ច័យដ៏សេស ហើយគប្បីជំទាស់ ព្រោះភពមិនជាសហជាតប្បច្ច័យដល់ជាតិ ជាតិក៏មិនជាសហជាតប្បច្ច័យដល់ជរាមរណៈ ចំណែកបច្ច័យដ៏សេសពួកណា ត្រាស់ដល់សង្ខារជាដើមទាំងនោះ សូម្បីបច្ច័យទាំងនោះ មានដោយពិត ព្រោះហេតុនោះ ទើបមិនអាចបោះបង់ចោល ។

អង្គបដិច្ចសមុប្បាទណា ក្នុងវារៈណា ដែលត្រាស់ទុកដោយ
ប្រការដទៃ សូម្បីអង្គបដិច្ចសមុប្បាទណា ដែលមិនត្រាស់ទុកក្នុង
វារៈណា អង្គបដិច្ចសមុប្បាទណា ជាបច្ច័យដល់អង្គបដិច្ចសមុប្បាទ
ណា ដោយប្រការណា គប្បីជ្រាបថា អង្គនៃបដិច្ចសមុប្បាទនោះ
ជាបច្ច័យដល់អង្គបដិច្ចសមុប្បាទនោះ ដោយប្រការនោះ ។

ក្នុងវារៈទី ១ មានប្រមាណប៉ុណ្ណោះ សូម្បីក្នុងវារៈទី ២ ជាដើមក៏មានន័យដូចគ្នា ។

[ ២១ ] ចំណែកការផ្សេងគ្នា គប្បីជ្រាបដូច្នេះថា សួរថា ក្នុងវារៈទី ២

ត្រាស់ថា **នាមប្បច្ចយា ផស្សោ** មិនបានត្រាស់ពាក្យណាមួយក្នុងទីនៃសឡាយតនៈ សេចក្តីនោះ ដើម្បីអ្វី ឆ្លើយថា ដើម្បីសម្តែងការផ្សេងគ្នានៃបច្ច័យ និងដើម្បីសង្គ្រោះចូលដោយទេសនា ក្នុងមហានិទានសូត្រ ។

ពិតហើយ ផស្សៈ មានសឡាយតនៈជាបច្ច័យតែម្យ៉ាងប៉ុណ្ណោះ ក៏មិនមែន ដែលពិត មានខន្ធ ៣ គឺវេទនាខន្ធជាដើមជាបច្ច័យផងដែរ ក្នុងមហានិទានសូត្រ ព្រះមានព្រះភាគ ទ្រង់ត្រាស់បដិច្ចសមុប្បាទមានអង្គ ១១ ទ្រង់លះសឡាយតនៈចោលយ៉ាងនេះថា ម្នាលអានន្ទ បើមានគេសួរថា ផស្សៈកើតមាន ព្រោះធម៌នេះជាបច្ច័យ មានដែរឬ គប្បីប្រាប់គេថា មាន ។ បើគេសួរទៀតថា ផស្សៈ កើតមាន ព្រោះអ្វីជាបច្ច័យ គប្បីប្រាប់គេថា ផស្សៈកើតមានព្រោះនាម[១] ជាបច្ច័យ ដូច្នេះ ។ ព្រោះហេតុនោះ ដើម្បីទ្រង់សម្តែងការផ្សេងគ្នានៃបច្ច័យនេះ និងដើម្បីទ្រង់កំណត់ទេសនា ក្នុងមហានិទានសូត្រនេះ ទើបត្រាស់ថា **នាមប្បច្ចយា ផស្សោ** ក្នុងវារៈទី ២ មិនបានត្រាស់ពាក្យណាមួយ ក្នុងទីនៃសឡាយតនៈ នេះជាការផ្សេងគ្នាក្នុងវារៈទី ២ ។

[ ២២ ] ចំណែកក្នុងវារៈទី ៣ ទ្រង់ត្រាស់អង្គទី ៤ ដែលមកក្នុងសុត្តន្តភាជនីយថា **វិញ្ញាណប្បច្ចយា នាមរូបំ** ដូច្នេះ ។ បើមានបុគ្គលសួរថា អង្គទី ៤ នោះ មិនគួរក្នុងបច្ចយចតុក្កៈនេះ ព្រោះបច្ចយាការ ប្រព្រឹត្តទៅក្នុងខណៈចិត្ត ១ គប្បីឆ្លើយថា អង្គទី ៤ គឺនាមរូបនោះមិនគួរ ក៏មិនមែន

---

១- បិដកខ្មែរថា ព្រោះនាមរូបជាបច្ច័យ ។

ព្រោះហេតុអ្វី ព្រោះភាពជាបច្ច័យក្នុងលក្ខណៈរបស់ខ្លួន ពិតហើយ បើក្នុងនាមរូបនោះ រូបនឹងតាំងនៅលើសខណៈរបស់ចិត្ត តែវិញ្ញាណនោះ ក៏ជាបច្ច័យដល់រូបនោះ ក្នុងលក្ខណៈរបស់ខ្លួន សេចក្តីនេះដូចម្តេច គឺខាងដើមវិញ្ញាណជាបច្ច័យ ដោយជាបច្ច័យដល់រូបដែលមានចិត្តជាសមុដ្ឋាន ដែលកើតមុនខ្លះ ដល់រូបដែលកើតខាងក្រោយខ្លះ សេចក្តីនេះ សមដូចព្រះតម្រាស់ ( ក្នុងមហាបដ្ឋាន ) ថា ពួកចិត្តចេតសិកធម៌ដែលកើតក្រោយ ជាបច្ច័យនៃកាយនេះដែលកើតមុនដោយបច្ឆាជាតប្បច្ច័យ ដូច្នេះ ។ម្យ៉ាងទៀត វិញ្ញាណជាបច្ច័យដល់រូបដែលកើតព្រមគ្នា ដែលមានចិត្តជាសមុដ្ឋាន ដោយនិស្សយប្បច្ច័យ ដូចព្រះតម្រាស់ ( ក្នុងមហាបដ្ឋាន ) ថា ពួកចិត្តចេតសិកធម៌ជាបច្ច័យនៃរូបទាំងឡាយដែលមានចិត្តជាសមុដ្ឋាន ដោយនិស្សយប្បច្ច័យ ដូច្នេះ ។

សួរថា បើយ៉ាងនោះ ព្រោះហេតុអ្វីក្នុងវារៈដំបូង ទើបមិនត្រាស់យ៉ាងនេះ ឆ្លើយថា ព្រោះទ្រង់សម្តែងសំដៅដល់ទីដែលរូបប្រព្រឹត្តទៅ ។

ពិតហើយ បច្ចយាការនេះ ទ្រង់សម្តែងក្នុងកាមភព ជាទីដែលរូបប្រព្រឹត្តទៅ ដោយអំណាចនៃសត្វដែលកើតក្នុងផ្ទៃនៃឱបបាតិកៈ ដែលមានអាយតនៈមិនបរិបូណ៌ និងនៃទេវតាក្នុងរូបាវចរ ដោយហេតុនោះឯង ទើបក្នុងវារៈទី ៣ នេះ មិនត្រាស់ថា **នាមរូបប្បច្ចយា សឡាយតនំ** តែត្រាស់ថា **ឆដ្ឋាយតនំ** ដូច្នេះ ក្នុងនាមរូបនោះ នាមមានន័យតាមដែលពោលហើយខាងដើមនោះឯង ចំណែករូបគប្បីជ្រាបថា ហទយរូប ។ ហទយរូបនោះ ជា

បច្ច័យ ២ យ៉ាង ដល់ធម្មាយតនៈនេះ គឺដោយនិស្សយប្បច្ច័យ និងបុរេ-ជាតប្បច្ច័យ នេះជាវារៈដែលផ្សេងគ្នាក្នុងវារៈទី ៣ ។

[ ២៣ ] វារៈទី ៤ ត្រាស់ដោយអំណាចពួកសត្វដែលជាសំសេទជៈ និងឱបបាតិកៈ ដោយអំណាចកំណើតនៃសត្វដែលមានអាយតនៈបរិបូណ៌ ដោយអំណាចអាយតនៈនៃសត្វក្នុងកាមាវចរ ដោយអំណាចនៃភព ដោយហេតុនោះឯង ទើបក្នុងវារៈទី ៤ នេះ ត្រាស់ថា **នាមរូបប្បច្ចយា សឡាយតនំ** ដូច្នេះ ក្នុងនាមរូបនោះ នាមជាបច្ច័យដល់ធម្មាយតនៈដោយសហជា-តប្បច្ច័យជាដើម ជាបច្ច័យដល់អាយតនៈ មានចក្ខាយតនៈជាដើម ដោយបច្ឆាជាតប្បច្ច័យ បណ្តារូប ហទយរូបជាបច្ច័យដល់ធម្មាយតនៈ ដោយនិស្សយប្បច្ច័យ និងបុរេជាតប្បច្ច័យ ។ មហាភូតរូប ៤ ជាបច្ច័យដល់ចក្ខាយតនៈជាដើម ដោយសហជាតប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ក៏ព្រោះបច្ចយាការនេះ ប្រព្រឹត្តទៅក្នុងខណៈចិត្ត ១ ហេតុនោះ ទើបមិនត្រាស់ក្នុងវារៈទី ៤ នេះថា **សឡាយតនប្បច្ចយា** តែត្រាស់ថា **ឆដ្ឋាយតនប្បច្ចយា** នេះជាការផ្សេងគ្នាក្នុងវារៈទី ៤ ដោយប្រការដូច្នេះ ។

បណ្ឌិត កាលជ្រាបហេតុផ្សេងគ្នានៃវារៈទាំង ៤ នេះ យ៉ាងនេះហើយ គប្បីជ្រាបទៀតថា ក្នុងវារៈទាំង ៤ នោះ ពោលដោយការផ្សេងគ្នា ២ វារៈខាងដើម ត្រាស់ដើម្បីសម្តែងបច្ចយាការក្នុងអរូបភព ព្រោះអង្គបដិច្ចសមុប្បាទដែលមិនលាយឡំដោយរូប រមែងប្រព្រឹត្តទៅក្នុងអរូបភព ។ វារៈទី ៣ ត្រាស់ដើម្បីសម្តែងបច្ចយាការក្នុងរូបភព ព្រោះថា ទោះមានការប្រឡូកប្រឡំ

ដោយរូប សឡាយតនៈ ក៏មិនប្រព្រឹត្តទៅក្នុងរូបភព ។ វារៈទី ៤ ត្រាស់ដើម្បីសម្តែងបច្ចយាការក្នុងកាមភព ព្រោះថា សឡាយតនៈទាំងអស់ រមែងប្រព្រឹត្តទៅក្នុងកាមភព ។ ម្យ៉ាងទៀត វារៈទី ៣ ត្រាស់សំដៅយកខណៈអកុសល ប្រព្រឹត្តទៅដល់ពួកសត្វ ដែលមានអាយតនៈខ្វះខាត ក្នុងរូបភព និងក្នុងកាមភព ។ វារៈទី ៤ ត្រាស់សំដៅដល់សត្វដែលមានអាយតនៈគ្រប់គ្រាន់ក្នុងកាមភព ។

ម្យ៉ាងទៀត វារៈទី ១ ត្រាស់សំដៅយកចិត្តដែលប្រព្រឹត្តទៅក្នុងទីទាំងអស់ ព្រោះថា វារៈទី ១ នោះ នឹងមិនប្រព្រឹត្តទៅក្នុងទីដែលចិត្តប្រព្រឹត្តទៅក្នុងទីណាមួយក៏មិនមែន វារៈទី ២ ត្រាស់សំដៅយកការផ្សេងគ្នានៃបច្ច័យ ព្រោះថា ក្នុងវារៈទី ២ នេះ ភាពដែលវារៈមានអង្គ ១១ និងភាពដែលផស្សៈ មាននាមជាបច្ច័យជាការផ្សេងគ្នានៃបច្ច័យ ។ វារៈទី ៣ ត្រាស់សំដៅយកកំណើត ២ ខាងដើម ព្រោះថា វារៈទី ៣ នោះ រមែងមានក្នុងកំណើត ២ ខាងដើម ព្រោះសឡាយតនៈមិនកើតសព្វកាល ក្នុងកំណើត ២ ខាងដើមនោះ ។ វារៈទី ៤ ត្រាស់សំដៅយកកំណើត ២ ខាងក្រោយ ព្រោះថា វារៈទី ៤ នោះ មានក្នុងកំណើត ២ ខាងក្រោយ ព្រោះសឡាយតនៈ កើតឡើងសព្វកាល ក្នុងកំណើត ២ ខាងក្រោយនោះឯង ។

ដោយលំដាប់ពាក្យមានប្រមាណប៉ុណ្ណេះ អត្ថណាដែលពោលក្នុងវារៈទាំង ៤ ថា

អង្គបដិច្ចសមុប្បាទណា ក្នុងវារៈណា ដែលត្រាស់ដោយប្រការដទៃ និងសូម្បីអង្គបដិច្ចសមុប្បាទណា ដែលមិនត្រាស់ក្នុងវារៈណា អង្គបដិច្ចសមុប្បាទណា ជាបច្ច័យដល់អង្គបដិច្ចសមុប្បាទណា ដោយប្រការណា គប្បីចូលទៅកំណត់អង្គបដិច្ចសមុប្បាទទាំងអស់នោះ ដោយប្រការដូច្នេះ ។

ការសម្តែងអត្ថនៃគាថា ឈ្មោះថា ខ្ញុំធ្វើហើយ ដោយប្រការដូច្នេះ ។ បន្ទាប់អំពីចតុក្កៈនេះទៅ បណ្ឌិតគប្បីជ្រាបន័យទាំងអស់នេះ និងការផ្សេងគ្នាក្នុងចតុក្កៈដទៃ ដោយទំនងនេះឯង ។

## ហេតុចតុក្កៈ

[ ២៤ ] បណ្តាចតុក្កៈទាំងនោះ ន័យដែលត្រាស់ក្នុងបច្ចយចតុក្កៈមុននោះ ប្រាកដច្បាស់ហើយក្នុងចតុក្កៈទាំងអស់នោះឯង ចំណែកការផ្សេងគ្នា គប្បីជ្រាបយ៉ាងនេះ ។ ក្នុងហេតុចតុក្កៈ អវិជ្ជាជាហេតុនៃសង្ខារនេះ ព្រោះហេតុនោះ ទើបសង្ខារនេះ ឈ្មោះថា **អវិជ្ជាហេតុកោ** អធិប្បាយថា សង្ខារនេះ មានអវិជ្ជាប្រព្រឹត្តទៅ គឺដំណើរទៅ ដោយប្រព្រឹត្តទៅព្រមគ្នា រហូតដល់រលត់ ។

មួយ៉ាងទៀត ទ្រង់សម្តែងថា អវិជ្ជាជាបច្ច័យដល់សង្ខារ ដោយសាធារណប្បច្ច័យ ដោយអំណាចនៃបច្ច័យ មានសហជាតប្បច្ច័យជាដើម ដោយព្រះតម្រាស់ត្រឹមប៉ុណ្ណោះថា **អវិជ្ជាបច្ចយា** ហើយ ទើបទ្រង់សម្តែងភាពដែលអវិជ្ជាជាអវិគតប្បច្ច័យដោយពិសេស ដោយព្រះតម្រាស់ថា

**អវិជ្ជាហេតុកោ** *ទៀត ។ ក្នុងពាក្យជាដើមថា* **សង្ខារប្បច្ចយា វិញ្ញាណំ សង្ខារហេតុកំ** *ដូច្នេះ ក៏មានន័យនេះដូចគ្នា ។*

*សួរថា ព្រោះហេតុអ្វី ទើបក្នុងអង្គ មានភពជាដើម ទ្រង់មិនធ្វើសព្ទថា* **ហេតុកំ** *ឆ្លើយថា ព្រោះអង្គ មានភពជាដើមនោះ មិនមានសេចក្តីកំណត់ដោយអវិគតប្បច្ច័យ និងព្រោះមិនមានអវិគតប្បច្ច័យ ព្រោះពាក្យថា ភពក្នុងហេតុចតុក្កៈនេះជាឈ្មោះរបស់ខន្ធ ៤ មានឧបាទានជាបច្ច័យ ដោយព្រះបាលី ( ក្នុងអភិធម្ម វិភង្គ ) ថា បណ្តាបច្ចយាការទាំងនោះ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ វៀរលែងតែឧបាទានចេញ នេះហៅថា ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ដូច្នេះ ។ ម្យ៉ាងទៀត ជាតិ ជរា មរណៈ ក៏សង្គ្រោះចូលក្នុងសង្ខារក្ខន្ធ ដោយព្រះបាលី ( ក្នុងអភិធម្ម ធាតុកថា ) ជាដើមថា ជាតិសង្គ្រោះដោយខន្ធ ២ ដូច្នេះ ។*

*ក្នុងព្រះបាលីនោះ ឧបាទាន រមែងមិនជាអវិគតប្បច្ច័យដល់ភពដោយពិតប្រាកដ ព្រោះការមិនបានជាតិ ជរា មរណៈសព្វកាល ដែលមានឧបាទានភាពជាអវិគតប្បច្ច័យ រមែងមិនកើតដល់ជាតិ ក្នុងសង្ខតលក្ខណៈទាំងឡាយ ព្រោះភព ពោល គឺជរាមរណៈ មិនមានត្រឹមខណៈនៃជាតិនោះឯង ដោយព្រះបាលីជាដើមថា ជាតិនៃធម៌នោះៗ ឯណា ដូច្នេះ ។ ភាពជាអវិគតប្បច្ច័យ រមែងមិនកើតដល់ជាតិ ព្រោះជាតិមិនមានក្នុងខណៈជរា និងមរណៈ ។ ម្យ៉ាងទៀត ភពជាបច្ច័យដល់ជាតិ និងជាតិជាបច្ច័យដល់ជរាមរណៈ ដោយឧប-*

និស្សយបច្ច័យតែម្យ៉ាង ព្រោះហេតុនោះ គប្បីជ្រាបថា ទ្រង់មិនបានធ្វើសព្វថា **ហេតុកំ** ក្នុងអង្គទាំងឡាយ មានភពជាដើម ព្រោះមិនមានកំណត់ដោយអវិគតបច្ច័យ និងព្រោះការមិនមានអវិគតបច្ច័យ ដោយប្រការទាំងពួង ។

ចំណែកអាចារ្យពួកខ្លះពោលថា ភពដែលលាយឡំដោយឧបត្តិ ដោយព្រះបាលីថា ភពមាន ២ យ៉ាង និងឧបាទានមិនជាអវិគតបច្ច័យដល់ឧបបត្តិភព ព្រោះហេតុនោះ ទើបព្រះមានព្រះភាគមិនត្រាស់ថា ភព មានឧបាទានជាហេតុកើត ព្រោះឧបាទានជាបច្ច័យ តែត្រាស់ថា ភពកើត ព្រោះឧបាទានជាបច្ច័យ ដូច្នេះ ព្រោះទ្រង់កាត់ចេញហើយ ក្នុងហេតុចតុក្កៈនេះសូម្បីខាងមុខក៏មិនបានត្រាស់ ។ ឧបាទាននោះ មិនសមគួរ ព្រោះក្នុងទីនេះទ្រង់មិនបំណាងយកភពដែលលាយឡំដោយឧបបត្តិ ព្រោះថា អរូបក្ខន្ធមកក្នុងទីនេះថា ភព ។

ក្នុងបទថា **ភវប្បច្ចយា ជាតិ** នេះ ភពដ៏សេស វៀរជាតិ និងជរាមរណៈហើយ គប្បីជ្រាបថា ជាបច្ច័យដល់ជាតិ ព្រោះហេតុអ្វី ព្រោះជាតិជាដើម មិនជាបច្ច័យដល់ជាតិ ដូច្នេះ បើយ៉ាងនោះ វៀរជាតិ ជរា មរណៈហើយ ភពក៏គួរត្រាស់ថា ជាបច្ច័យដល់ជាតិ ។ គួរឆ្លើយថា ត្រឹមត្រូវហើយ តែព្រះមានព្រះភាគមិនបានត្រាស់ ព្រោះមិនមានគោលអាងដែលគួរត្រាស់ ។ ក្នុងនិទ្ទេសនៃអង្គទី ១០ គួរត្រាស់ភពដែលកើតព្រោះឧបាទានជាបច្ច័យ ។ ក្នុងនិទ្ទេសនៃអង្គទី ១១ គួរត្រាស់ដល់ជាតិ តែភពដែលជាបច្ច័យដល់ជាតិ មិនមានទីដែលគួរពោល ព្រោះហេតុនោះ ទើបមិនត្រាស់ ព្រោះមិនមានទីដែល

គប្បីត្រាស់ សូម្បីមិនបានត្រាស់ ក៏គួរកាន់យក ដោយគួរនោះឯង ។

[ ២៦ ] ក្នុងបទថា **វិញ្ញាណប្បច្ចយា នាមរូបំ** ជាដើម ទ្រង់ធ្វើពាក្យថា **វិញ្ញាណហេតុកំ** ជាដើម ព្រោះវិញ្ញាណជាដើម កើតព្រមជាមួយភាពជាអវិគតប្បច្ច័យ ។ នេះជាការផ្សេងគ្នាក្នុងហេតុចតុក្កៈ ។

## សម្បយុត្តចតុក្កៈ

[ ២៨ ] ក្នុងសម្បយុត្តចតុក្កៈ ទ្រង់សម្តែងភាពដែលសង្ខារ មានអវិជ្ជាជាបច្ច័យ ដោយអំណាចសហជាតប្បច្ច័យជាដើម ដោយត្រាស់ត្រឹមប៉ុណ្ណេះថា **អវិជ្ជាបច្ចយា** ហើយទ្រង់សម្តែងភាពដែលអវិជ្ជាជាសម្បយុត្តប្បច្ច័យថា **អវិជ្ជាសម្បយុត្តោ** ដូច្នេះ ។ ក្នុងបទដ៏សេស ក៏ន័យនេះដូចគ្នា តែព្រោះអរូបធម៌ មិនសម្បយុត្តជាមួយរូបធម៌ទាំងឡាយ ហេតុនោះសូម្បីបទក្នុងវារៈទី ៣ និងក្នុងវារៈទី ៤ មានពាក្យថា **វិញ្ញាណប្បច្ចយា នាមរូបំ** ជាដើម ទើបទ្រង់កាន់យកចំពោះអង្គដែលបានប៉ុណ្ណោះ ដោយន័យជាដើមថា **វិញ្ញាណសម្បយុត្តំ នាមំ** ។ នេះជាការផ្សេងគ្នាក្នុងសម្បយុត្តចតុក្កៈ ។

## អញ្ញមញ្ញចតុក្កៈ

[ ៣២ ] ម្យ៉ាងទៀត ក្នុងអញ្ញមញ្ញចតុក្កៈ ទ្រង់សម្តែងភាពដែលសង្ខារ មានអវិជ្ជាជាបច្ច័យ ដោយអំណាចសហជាតប្បច្ច័យជាដើមថា **អវិជ្ជាបច្ចយា** ហើយទ្រង់សម្តែងភាពដែលអវិជ្ជាជាអញ្ញមញ្ញប្បច្ច័យថា **សង្ខារប្បច្ចយាបិ អវិជ្ជា** ដូច្នេះ ។ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា តែ

ព្រោះភពជានិប្បទេស គឺទ្រង់សម្ដែងដោយសព្វគ្រប់ ។ ឧបាទានជាសប្បទេស គឺទ្រង់សម្ដែងបន្តិចបន្តួច ហើយធម៌ដែលជាសប្បទេស ជាបច្ច័យដល់ធម៌ដែលជានិប្បទេស ធម៌ដែលជានិប្បទេស មិនជាបច្ច័យដល់ធម៌ ដែលជាសប្បទេស ហេតុនោះ ក្នុងអញ្ញមញ្ញចតុក្កៈនេះ ទើបមិនត្រាស់ថា **ភវប្ប-ច្ចយាបិ ឧបាទានំ** ដូច្នេះ ។ ន័យម្យ៉ាងទៀត មិនបានត្រាស់យ៉ាងនេះ ព្រោះទ្រង់កាត់ចេញហើយ ដោយទេសនាខាងដើម តែសឡាយតនៈមាន ព្រោះនាមរូបជាបច្ច័យ នាមរូបក្នុងខណៈនៃចិត្តដួងមួយ រមែងមិនមាន ព្រោះសឡាយតនៈជាបច្ច័យ សឡាយតនៈគប្បីជាអញ្ញមញ្ញប្បច្ច័យដល់នាមរូបណា ព្រោះហេតុណា ព្រោះហេតុនោះ ទើបក្នុងវារៈទី ៤ ទ្រង់កាន់យកចំពោះអង្គដែលបានក្នុងបទថា **សឡាយតនប្បច្ចយាបិ នាមរូបំ** ដូច្នេះ ។ នេះជាការផ្សេងគ្នាក្នុងអញ្ញមញ្ញចតុក្កៈ ។

អវិជ្ជាមូលកនយមាតិកា ចប់

# សង្ខារាទិមូលកនយមាតិកា

[ ៣៦ ] ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ផ្ដើមន័យ មានសង្ខារជាមូលថា **សង្ខារប្បច្ចយា អវិជ្ជា** ដូច្នេះ ។ សូម្បីក្នុងព្រះបាលី មានសង្ខារជាមូលជាដើមនោះ ក៏គប្បីជ្រាបចតុក្កៈ ៤ និងវារៈ ១៦ ដូចក្នុងន័យដែលមានអវិជ្ជាជាមូល ។

ក្នុងចតុក្កៈទី ១ ទ្រង់សម្ដែងចំពោះវារៈទី ១ ប៉ុណ្ណោះ ហើយទ្រង់

សន្ធេបទេសនា ។ ក្នុងន័យដែលមានវិញ្ញាណជាមូលជាដើម ក៏ដូចក្នុងន័យដែលមានសង្ខារជាមូលនេះ ។ បណ្តាន័យទាំងនោះ ទ្រង់សម្តែងកាលដែលអវិជ្ជាមានសង្ខារជាដើមជាបច្ច័យ ដោយអំណាចសហជាតប្បច្ច័យជាដើម ដោយន័យជាដើមថា **សង្ខារប្បច្ចយា អវិជ្ជា** ក្នុងន័យទាំង ៨ ដែលមានសង្ខារជាមូលជាដើមទាំងអស់នោះឯង ហើយទើបទ្រង់សម្តែងការប្រព្រឹត្តទៅនៃចក្រ គឺបច្ចយាការ ក្នុងខណៈនៃចិត្តដួងជាមួយគ្នា ដោយន័យជាដើមថា **អវិជ្ជាបច្ចយា សង្ខារោ** ដូច្នេះទៀត ។

សួរថា ព្រោះហេតុអ្វី ទើបមិនត្រាស់ន័យទាំងឡាយ មានភពជាមូល ឬមានជាតិ និងជរាមរណៈជាមូល អវិជ្ជារមែងមិនមានព្រោះភពជាបច្ច័យឬ ។ ឆ្លើយថា មិនមានក៏មិនមែន តែកាលត្រាស់ពាក្យជាដើមយ៉ាងនេះថា **សង្ខារប្បច្ចយា អវិជ្ជា** ក៏មិនបានត្រាស់ធម៌ដែលទាក់ទងដោយភពណាមួយដែលជាបច្ច័យដល់អវិជ្ជាក៏មិនមែន ព្រោះហេតុនោះ ទើបមិនត្រាស់ន័យមានភពជាមូល ព្រោះមិនមានធម៌ដទៃ ដែលមិននៅខាងដើម ដែលជាបច្ច័យដល់អវិជ្ជាដែលគួរត្រាស់ ។ សូម្បីអវិជ្ជា ក៏រមែងដល់នូវការសង្គ្រោះដោយសព្ទថា ភព ព្រោះហេតុនោះ កាលទ្រង់ត្រាស់ថា **ភវប្បច្ចយា អវិជ្ជា** ។

ក៏គប្បីជាការត្រាស់ថា **អវិជ្ជាបច្ចយា អវិជ្ជា** ព្រោះថា ក្នុងខណៈនៃចិត្ត ១ ដួង អវិជ្ជារមែងមិនឈ្មោះថាជាបច្ច័យដល់អវិជ្ជា ។ ន័យ មានជាតិ ជរា មរណៈជាមូល ក៏ទ្រង់មិនកាន់យក ព្រោះទ្រង់កាត់បេញក្នុងភពនោះឯង ។ ន័យម្យ៉ាងទៀត សូម្បីជាតិ ជរា មរណៈ ក៏ទ្រង់បន្ថែមចូលក្នុងភព ។ ជាតិ ជរា មរណៈទាំងនេះ ជាបច្ច័យដល់អវិជ្ជា ក្នុងខណៈនៃចិត្តដួងតែមួយ ក៏មិនមែន ព្រោះហេតុនោះ ទើបមិនត្រាស់ន័យដែលមានភពជាមូល ឬមានជាតិ ជរា មរណៈជាមូល ដូច្នេះឯង ៕

## អធិប្បាយអភិធម្មមាតិកា ចប់

# អភិធម្មបិដក

## អកុសលនិទ្ទេស

[ ៣៧ ] ធម៌ទាំងឡាយ ជាអកុសល តើដូចម្តេច ។ ក្នុងសម័យណា អកុសលចិត្ត ដែលច្រឡំដោយសោមនស្ស ប្រកបដោយទិដ្ឋិ មានរូបជាអារម្មណ៍ក្តី មានសំឡេងជាអារម្មណ៍ក្តី មានក្លិនជាអារម្មណ៍ក្តី មានរសជាអារម្មណ៍ក្តី មានផ្សព្វជាអារម្មណ៍ក្តី មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៣៨ ] បណ្តាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្តេច ។ ការមិនដឹង មិនឃើញ ។បេ។ គន្លឹះ គឺអវិជ្ជា មោហៈជាអកុសលមូលណា នេះហៅថា អវិជ្ជា ។

[ ៣៩ ] បណ្តាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។

[ ៤០ ] បណ្ដាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ហទយៈ ធម្មជាតដ៏ផូរផង់ ( គឺភវង្គចិត្ត ) ហៅថា មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។

[ ៤១ ] បណ្ដាបច្ចយាការទាំងនោះ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។

[ ៤២ ] បណ្ដាបច្ចយាការទាំងនោះ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ហទយៈ ធម្មជាតដ៏ផូរផង់ ( គឺភវង្គចិត្ត ) ហៅថា មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ។

[ ៤៣ ] បណ្ដាបច្ចយាការទាំងនោះ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ តើដូចម្ដេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា នេះហៅថា ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ។

[ ៤៤ ] បណ្ដាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្ដេច ។ សេចក្ដីឆ្ងាញ់ពិសា ប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីសុខ

ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសា ជាសុខ ដែលកើតអំពីចេតោសម្ផស្ស វេទនា ដ៏ឆ្ងាញ់ពិសា ជាសុខ ដែលកើតអំពីចេតោសម្ផស្សណា នេះហៅថា វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ ។

[ ៤៥ ] បណ្ដាបច្ចយាការទាំងនោះ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្ដេច ។ តម្រេក តម្រេកខ្លាំង ការត្រេកអរ ការក្ដួចកាន់ ការរីករាយ ការស្រើបស្រាល តម្រេកដ៏ខ្លាំងណានៃចិត្ត នេះហៅថា តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ។

[ ៤៦ ] បណ្ដាបច្ចយាការទាំងនោះ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ តើដូចម្ដេច ។ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ។បេ។ លទ្ធិដូចជាកំពង់ គឺទិដ្ឋិ ការប្រកាន់ក្នុងការស្វែងរកខុសណា នេះហៅថា ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ។

[ ៤៧ ] បណ្ដាបច្ចយាការទាំងនោះ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ វៀរលែងតែឧបាទានចេញ នេះហៅថា ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ។

[ ៤៨ ] បណ្ដាបច្ចយាការទាំងនោះ ជាតិ កើតមាន ព្រោះភពជាបច្ច័យ តើដូចម្ដេច ។ ការកើត ការកើតព្រម ការផ្ដួចឡើង ការកើតចំពោះ ការកើតប្រាកដណា នៃធម៌ទាំងឡាយនោះ នេះហៅថា ជាតិ កើតមាន ព្រោះភពជាបច្ច័យ ។

[ ៤៩ ] បណ្ដាបច្ចយាការទាំងនោះ ជរា និងមរណៈ កើតមាន ព្រោះ

ជាតិជាបច្ច័យ តើដូចម្តេច ។ ជរាក៏មាន មរណៈក៏មាន ។ បណ្តាជរា និង មរណៈនោះ ជរា តើដូចម្តេច ។ ការចាស់គ្រាំគ្រា ការរួញថយទៅនៃអាយុ ណា នៃធម៌ទាំងឡាយនោះ នេះហៅថា ជរា ។ បណ្តាជរា និងមរណៈនោះ មរណៈ តើដូចម្តេច ។ ការអស់ទៅ ការសូន្យទៅ ការបែកធ្លាយ ការបែក ខ្ចាត់ខ្ចាយ ការមិនទៀង ការបាត់បង់ណា នៃធម៌ទាំងឡាយនោះ នេះហៅថា មរណៈ ។ ជរានេះផង មរណៈនេះផង នេះហៅថា ជរា និងមរណៈ កើត មាន ព្រោះជាតិជាបច្ច័យ ដោយប្រការដូច្នេះ ។

[ ៥០ ] ត្រង់ពាក្យថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែង មាន ដោយអាការយ៉ាងនេះ គឺការជួបជុំ ការមូលមក ការប្រជុំចុះ ការកើត ប្រាកដនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ព្រោះហេតុ នោះ ទើបលោកពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែង មាន ដោយអាការយ៉ាងនេះ ។

[ ៥១ ] ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជា បច្ច័យ ផស្សៈ កើតមាន ព្រោះនាមជាបច្ច័យ វេទនា កើតមាន ព្រោះ ផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជា ទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៥២ ] បណ្ដាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្ដេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្លឹះ គឺអវិជ្ជា មោហៈ ជាអកុសលមូលណា នេះហៅថា អវិជ្ជា ។ បណ្ដាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្ដេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។ អធិប្បាយត្រង់ពាក្យថា ផស្សៈ កើតមាន ព្រោះនាមជាបច្ច័យ ។ ចុះបណ្ដាធម៌ទាំងនោះ នាម តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ លើកលែងតែផស្សៈចេញ នេះហៅថា នាម ។ បណ្ដាបច្ចយាការទាំងនោះ ផស្សៈ កើតមាន ព្រោះនាមជាបច្ច័យ តើដូចម្ដេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា នេះហៅថា ផស្សៈ កើតមាន ព្រោះនាមជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបលោកហៅថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៥៣ ] ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ

វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម និងរូប កើតមាន ព្រោះ វិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាម និងរូបជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះ ផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុ ជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៥៤ ] បណ្តាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្តេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្លឹះ គឺអវិជ្ជា មោហៈ ជាអកុសលមូលណា នេះ ហៅថា អវិជ្ជា ។ បណ្តាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះអវិជ្ជា ជាបច្ច័យ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ បណ្តាបច្ចយាការ ទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពី វិញ្ញាណនោះណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ នាម និងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្តេច ។ នាមក៏មាន រូបក៏មាន ។ បណ្តានាម និងរូបទាំងនោះ នាម តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្តា នាម និងរូបទាំងនោះ រូប តើដូចម្តេច ។ ការសន្សំនៃចក្ខាយតនៈ ការសន្សំ

នៃសោតាយតនៈ ការសន្សំនៃឃានាយតនៈ ការសន្សំនៃជិវ្ហាយតនៈ ការសន្សំនៃកាយាយតនៈ ឬក៏រូបដទៃណា ដែលកើតអំពីចិត្ត មានចិត្តជាហេតុ មានចិត្តជាសមុដ្ឋាន នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាម និងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ដោយប្រការដូច្នេះ ។ អធិប្បាយត្រង់ពាក្យថា អាយតនៈទី ៦ កើតមាន ព្រោះនាម និងរូបជាបច្ច័យ នាមក៏មាន រូបក៏មាន ។ បណ្តានាម និងរូបនោះ នាម តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្តានាម និងរូបនោះ រូប តើដូចម្តេច ។ មនោវិញ្ញាណធាតុ ប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវរូបណា នេះហៅថា រូប ។ នាមនេះឯង រូបនេះឯង នេះហៅថា នាម និងរូប ។ បណ្តាបច្ចយាការទាំងនោះ អាយតនៈទី ៦ កើតមាន ព្រោះនាម និងរូបជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោ-វិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា អាយតនៈទី ៦ កើតមាន ព្រោះនាម និងរូបជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា នេះហៅថា ផស្សៈ កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបលោកថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៥៥ ] ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម និងរូប កើតមាន ព្រោះ

វិញ្ញាណជាបច្ច័យ អាយតនៈ ៦ កើតមាន ព្រោះនាម និងរូបជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៥៦ ] បណ្ដាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្ដេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្លឹះ គឺអវិជ្ជា មោហៈ ជាអកុសលមូលណា នេះហៅថា អវិជ្ជា ។ បណ្ដាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្ដេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ នាម និងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្ដេច ។ នាមក៏មាន រូបក៏មាន ។ បណ្ដានាម និងរូបទាំងនោះ នាម តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្ដានាម និងរូបទាំងនោះ រូប តើដូចម្ដេច ។ ការសន្សំនៃចក្ខាយតនៈ ។បេ។ ការសន្សំនៃកាយាយតនៈ ឬក៏រូបដទៃណា ដែលកើតអំពីចិត្ត មានចិត្តជាហេតុ

មានចិត្តជាសមុដ្ឋាន នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាម និងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ដោយប្រការដូច្នេះ ។ អធិប្បាយត្រង់ពាក្យថា អាយតនៈ ៦ កើតមាន ព្រោះនាម និងរូបជាបច្ច័យ ។ នាមក៏មាន រូបក៏មាន ។ បណ្តានាម និងរូបនោះ នាម តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្តានាម និងរូបទាំងនោះ រូប តើដូចម្តេច ។ មហាភូតរូបទាំង ៤ ក្តី មនោវិញ្ញាណធាតុប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវរូបណាក្តី នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាម និងរូប ដោយប្រការដូច្នេះ ។ បណ្តាបច្ចយាការទាំងនោះ អាយតនៈ ៦ កើតមាន ព្រោះនាម និងរូបជាបច្ច័យ តើដូចម្តេច ។ ចក្ខាយតនៈ ១ សោតាយតនៈ ១ ឃានាយតនៈ ១ ជិវ្ហាយតនៈ ១ កាយាយតនៈ ១ មនាយតនៈ ១ នេះហៅថា អាយតនៈ ៦ កើតមាន ព្រោះនាម និងរូបជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ ផស្សៈ កើតមាន ព្រោះសឡាយតនៈជាបច្ច័យ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា នេះហៅថា ផស្សៈ កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបលោកពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

បច្ចយចតុក្កៈ ចប់

[ ៥៧ ] ក្នុងសម័យនោះ សង្ខារមានអវិជ្ជាជាហេតុ កើតមាន ព្រោះ

អវិជ្ជាជាបច្ច័យ វិញ្ញាណមានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមមានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ មាននាមជាហេតុ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈមានអាយតនៈទី ៦ ជាហេតុ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនាមានផស្សៈជាហេតុ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាមានវេទនាជាហេតុ កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានមានតណ្ហាជាហេតុ កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៥៨ ] បណ្តាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្តេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្លឹះ គឺអវិជ្ជា មោហៈ ជាអកុសលមូលណា នេះហៅថា អវិជ្ជា ។ បណ្តាបច្ចយាការទាំងនោះ សង្ខារ មានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារមានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ វិញ្ញាណមានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណមានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ នាមមានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្តេច ។

វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាមមានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ អាយតនៈទី ៦ មាននាមជាហេតុ កើតមាន ព្រោះនាមជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា អាយតនៈទី ៦ មាននាមជាហេតុ កើតមាន ព្រោះនាមជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ ផស្សៈមានអាយតនៈទី ៦ ជាហេតុ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា នេះហៅថា ផស្សៈមានអាយតនៈទី ៦ ជាហេតុ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ វេទនាមានផស្សៈជាហេតុ កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្តេច ។ សេចក្តីត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលនូវអារម្មណ៍ ជាទីត្រេកអរជាសុខ កើតអំពីចេតោសម្ផស្ស វេទនាជាទីត្រេកអរ ជាសុខ ដែលកើតអំពីចេតោសម្ផស្សណា នេះហៅថា វេទនាមានផស្សៈជាហេតុ កើតមាន ព្រោះផស្សៈជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ តណ្ហាមានវេទនាជាហេតុ កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្តេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងណានៃចិត្ត នេះហៅថា តណ្ហា មានវេទនាជាហេតុ កើតមាន ព្រោះវេទនាជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ ឧបាទានមានតណ្ហាជាហេតុ កើតមាន ព្រោះតណ្ហាជាបច្ច័យ តើដូចម្តេច ។ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ព្រៃស្បាត គឺទិដ្ឋិ ផ្លូវឆ្ងាយ គឺទិដ្ឋិ ចម្រូង គឺទិដ្ឋិ សេចក្តី

ញាប់ញ័រ គឺទិដ្ឋិ សញ្ញោជនៈ គឺទិដ្ឋិ ការប្រកាន់ ការប្រកាន់មាំ ការជាប់ជំពាក់ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស សភាពខុស លទ្ធិដូចជាកំពង់ ការប្រកាន់ក្នុងការស្វែងរកខុសណា នេះហៅថា ឧបាទាន មានតណ្ហាជាហេតុ កើតមាន ព្រោះតណ្ហាជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបលោកពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់ទុំះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៥៩ ] ក្នុងសម័យនោះ សង្ខារ មានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ មានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមមានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ផស្សៈ មាននាមជាហេតុ កើតមាន ព្រោះនាមជាបច្ច័យ វេទនា មានផស្សៈជាហេតុ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាមានវេទនាជាហេតុ កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន មានតណ្ហាជាហេតុ កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់ទុំះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៦០ ] បណ្តាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្តេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្លឹះ គឺអវិជ្ជា មោហៈ ជាអកុសលមូលណា នេះហៅថា អវិជ្ជា ។ បណ្តាបច្ចយាការទាំងនោះ សង្ខារមានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារមានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជា

ជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ វិញ្ញាណ មានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណ មានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ នាម មានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាមមានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។ អធិប្បាយត្រង់ពាក្យថា ផស្សៈមាននាមជាហេតុ កើតមាន ព្រោះនាមជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ នាម តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ លើកលែងតែផស្សៈចេញ នេះហៅថា នាម ។ បណ្ដាបច្ចយាការទាំងនោះ ផស្សៈមាននាមជាហេតុ កើតមាន ព្រោះនាមជាបច្ច័យ តើដូចម្ដេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា នេះហៅថា ផស្សៈ មាននាមជាហេតុ កើតមាន ព្រោះនាមជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបលោកពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៦១ ] ក្នុងសម័យនោះ សង្ខារមានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណមានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម និងរូប មានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ មាននាម និងរូបជាហេតុ កើតមាន ព្រោះនាម និងរូបជាបច្ច័យ ផស្សៈ

មានអាយតនៈទី ៦ ជាហេតុ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនាមានផស្សៈជាហេតុ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាមានវេទនាជាហេតុ កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានមានតណ្ហាជាហេតុ កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៦២ ] បណ្ដាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្ដេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្លឹះ គឺអវិជ្ជា មោហៈ ជាអកុសលមូលណា នេះហៅថា អវិជ្ជា ។ បណ្ដាបច្ចយាការទាំងនោះ សង្ខារមានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្ដេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារមានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ វិញ្ញាណមានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណមានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ នាម និងរូបមានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្ដេច ។ នាមក៏មាន រូបក៏មាន ។ បណ្ដានាម និងរូបនោះ នាម តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្ដានាម និងរូបនោះ រូប តើដូចម្ដេច ។ ការសន្សំនៃចក្ខាយតនៈ ។បេ។ ការសន្សំនៃកាយាយតនៈ

ឬក៏រូបដទៃណា ដែលកើតអំពីចិត្ត មានចិត្តជាហេតុ មានចិត្តជាសមុដ្ឋាន នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាម និងរូប មានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ដោយប្រការដូច្នេះ ។ អធិប្បាយត្រង់ពាក្យថា អាយតនៈទី ៦ មាននាម និងរូបជាហេតុ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ។ នាមក៏មាន រូបក៏មាន ។ បណ្តានាម និងរូបទាំងនោះ នាមតើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្តានាម និងរូបទាំងនោះ រូប តើដូចម្តេច ។ មនោវិញ្ញាណធាតុ ប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវរូបណា នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាម និងរូប ដោយប្រការដូច្នេះ ។ បណ្តាបច្ចយាការទាំងនោះ អាយតនៈទី ៦ មាននាម និងរូបជាហេតុ កើតមាន ព្រោះនាម និងរូបជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា អាយតនៈទី ៦ មាននាម និងរូបជាហេតុ កើតមាន ព្រោះនាម និងរូបជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ ផស្សៈមានអាយតនៈទី ៦ ជាហេតុ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា នេះហៅថា ផស្សៈមានអាយតនៈទី ៦ ជាហេតុ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបលោកពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៦៣ ] ក្នុងសម័យនោះ សង្ខារមានអវិជ្ជាជាហេតុ កើតមាន ព្រោះ

អវិជ្ជាជាបច្ច័យ វិញ្ញាណមានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម និងរូប មានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈ ៦ មាននាម និងរូបជាហេតុ កើតមាន ព្រោះនាម និងរូបជាបច្ច័យ ផស្សៈ មានអាយតនៈ ៦ ជាហេតុ កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ វេទនា មានផស្សៈជាហេតុ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាមានវេទនាជាហេតុ កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានមានតណ្ហាជាហេតុ កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៦៤ ] បណ្តាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្តេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្លឹះ គឺអវិជ្ជា មោហៈ ជាអកុសលមូលណា នេះហៅថា អវិជ្ជា ។ បណ្តាបច្ចយាការទាំងនោះ សង្ខារមានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារមានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ វិញ្ញាណមានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណមានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ នាម និងរូប មានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណ

ជាបច្ច័យ តើដូចម្តេច ។ នាមក៏មាន រូបក៏មាន ។ បណ្តានាម និងរូបទាំងនោះ នាម តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្តានាម និងរូបទាំងនោះ រូប តើដូចម្តេច ។ ការសន្សំនៃចក្ខាយតនៈ ។បេ។ ការសន្សំនៃកាយាយតនៈ ឬក៏រូបដទៃណា ដែលកើតអំពីចិត្ត មានចិត្តជាហេតុ មានចិត្តជាសមុដ្ឋាន នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាម និងរូប មានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ដោយប្រការដូច្នេះ ។ អធិប្បាយត្រង់ពាក្យថា អាយតនៈ ៦ មាននាម និងរូបជាហេតុ កើតមាន ព្រោះនាម និងរូបជាបច្ច័យ ។ នាមក៏មាន រូបក៏មាន ។ បណ្តានាម និងរូបទាំងនោះ នាម តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្តានាម និងរូប ទាំងនោះ រូប តើដូចម្តេច ។ មហាភូតរូបទាំង ៤ និងមនោវិញ្ញាណធាតុ ប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវរូបណា នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាម និងរូប ដោយប្រការដូច្នេះ ។ បណ្តាបច្ចយាការទាំងនោះ អាយតនៈ ៦ មាននាម និងរូបជាហេតុ កើតមាន ព្រោះនាម និងរូបជាបច្ច័យ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ មនាយតនៈ នេះហៅថា អាយតនៈ ៦ មាននាម និងរូបជាហេតុ កើតមាន ព្រោះនាម និងរូបជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ ផស្សៈមានអាយតនៈ ៦ ជាហេតុ កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ សេចក្តីទង្គិកទង្គិចណា នេះហៅថា ផស្សៈមានអាយតនៈ ៦ ជាហេតុ កើតមាន ព្រោះអាយតនៈ

៦ ជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបលោកពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

## ហេតុចតុក្កៈ ចប់

[ ៦៥ ] ក្នុងសម័យនោះ សង្ខារប្រកបដោយអវិជ្ជា កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមប្រកបដោយវិញ្ញាណ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ ប្រកបដោយនាម កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈប្រកបដោយអាយតនៈទី ៦ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនាប្រកបដោយផស្សៈ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាប្រកបដោយវេទនា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានប្រកបដោយតណ្ហា កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៦៦ ] បណ្ដាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្ដេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្លឹះ គឺអវិជ្ជា មោហៈ ជាអកុសលមូលណា នេះហៅថា អវិជ្ជា ។ បណ្ដាបច្ចយាការទាំងនោះ សង្ខារប្រកបដោយអវិជ្ជា កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្ដេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារប្រកបដោយអវិជ្ជា កើតមាន ព្រោះអវិជ្ជា

ជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ វិញ្ញាណប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ នាមប្រកបដោយវិញ្ញាណ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាមប្រកបដោយវិញ្ញាណ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ អាយតនៈទី ៦ ប្រកបដោយនាម កើតមាន ព្រោះនាមជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោ-វិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា អាយតនៈទី ៦ ប្រកបដោយនាម កើតមាន ព្រោះនាមជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ ផស្សៈប្រកបដោយអាយតនៈទី ៦ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា នេះហៅថា ផស្សៈប្រកបដោយអាយតនៈទី ៦ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ វេទនាប្រកបដោយផស្សៈ កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្តេច ។ សេចក្តីត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ជាទីត្រេកអរ ជាសុខ ដែលកើតអំពីចេតោសម្ផស្ស វេទនាជាទីត្រេកអរ ជាសុខ ដែលកើតអំពីចេតោសម្ផស្ស នេះហៅថា វេទនាប្រកបដោយផស្សៈ កើតមាន ព្រោះផស្សៈ

ជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ តណ្ហាប្រកបដោយវេទនា កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្តេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំង ណានៃចិត្ត នេះហៅថា តណ្ហាប្រកបដោយវេទនា កើតមាន ព្រោះវេទនា ជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ ឧបាទានប្រកបដោយតណ្ហា កើតមាន ព្រោះតណ្ហាជាបច្ច័យ តើដូចម្តេច ។ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ។បេ។ លទ្ធិដូច ជាកំពង់ ការប្រកាន់ក្នុងការស្វែងរកខុសណា នេះហៅថា ឧបាទានប្រកប ដោយតណ្ហា កើតមាន ព្រោះតណ្ហាជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើប លោកពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយ អាការយ៉ាងនេះ ។

[ ៦៧ ] ក្នុងសម័យនោះ សង្ខារប្រកបដោយអវិជ្ជា កើតមាន ព្រោះ អវិជ្ជាជាបច្ច័យ វិញ្ញាណប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមប្រកបដោយវិញ្ញាណ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ផស្សៈប្រកប ដោយនាម កើតមាន ព្រោះនាមជាបច្ច័យ វេទនាប្រកបដោយផស្សៈ កើត មាន ព្រោះផស្សៈជាបច្ច័យ តណ្ហាប្រកបដោយវេទនា កើតមាន ព្រោះវេទនា ជាបច្ច័យ ឧបាទានប្រកបដោយតណ្ហា កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំង អស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៦៨ ] បណ្តាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្តេច ។ ការមិនដឹង

ការមិនឃើញ ។បេ។ គន្លឹះ គឺអវិជ្ជា មោហៈ ជាអកុសលមូលណា នេះហៅថា អវិជ្ជា ។ បណ្ដាបច្ចយាការទាំងនោះ សង្ខារប្រកបដោយអវិជ្ជា កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្ដេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំណា នេះហៅថា សង្ខារប្រកបដោយអវិជ្ជា កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ វិញ្ញាណប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោ-វិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ នាមប្រកបដោយវិញ្ញាណ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាមប្រកបដោយវិញ្ញាណ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។ អធិប្បាយត្រង់ពាក្យថា ផស្សៈប្រកបដោយនាម កើតមាន ព្រោះនាមជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ នាម តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ លើកតែផស្សៈចេញ នេះហៅថា នាម ។ បណ្ដាបច្ចយាការទាំងនោះ ផស្សៈប្រកបដោយនាម កើតមាន ព្រោះនាមជាបច្ច័យ តើដូចម្ដេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា នេះហៅថា ផស្សៈប្រកបដោយនាម កើតមាន ព្រោះនាម ជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបលោកពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៦៩ ] ក្នុងសម័យនោះ សង្ខារប្រកបដោយអវិជ្ជា កើតមាន ព្រោះ

អវិជ្ជាជាបច្ច័យ វិញ្ញាណប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម និងរូប ជានាមប្រកបដោយវិញ្ញាណ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ ប្រកបដោយនាម កើតមាន ព្រោះនាម និងរូបជាបច្ច័យ ផស្សៈប្រកបដោយអាយតនៈទី ៦ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនាប្រកបដោយផស្សៈ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាប្រកបដោយវេទនា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានប្រកបដោយតណ្ហា កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៧០ ] បណ្ដាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្ដេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្លឹះ គឺអវិជ្ជា មោហៈ ជាអកុសលមូលណា នេះហៅថា អវិជ្ជា ។ បណ្ដាបច្ចយាការទាំងនោះ សង្ខារប្រកបដោយអវិជ្ជា កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្ដេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារប្រកបដោយអវិជ្ជា កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ វិញ្ញាណប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ នាម និងរូប ជានាមប្រកបដោយវិញ្ញាណ កើតមាន

ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្តេច ។ នាមក៏មាន រូបក៏មាន ។ បណ្តានាម និងរូបនោះ នាម តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្តានាម និងរូបនោះ រូប តើដូចម្តេច ។ ការសន្សំនៃចក្ខាយតនៈ ។បេ។ ការសន្សំនៃកាយាយតនៈ ឬក៏រូបដទៃណា ដែលកើតអំពីចិត្ត មានចិត្តជាហេតុ មានចិត្តជាសមុដ្ឋាន នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាម និងរូប ជានាមប្រកបដោយវិញ្ញាណ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។ អធិប្បាយត្រង់ពាក្យថា អាយតនៈទី ៦ ប្រកបដោយនាម កើតមាន ព្រោះនាម និងរូបជាបច្ច័យ ។ នាមក៏មាន រូបក៏មាន ។ បណ្តានាម និងរូបនោះ នាម តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្តានាម និងរូបនោះ រូប តើដូចម្តេច ។ មនោវិញ្ញាណធាតុ ប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវរូបណា នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាម និងរូប ដោយប្រការដូច្នេះ ។ បណ្តាបច្ចយាការទាំងនោះ អាយតនៈទី ៦ ប្រកបដោយនាម កើតមាន ព្រោះនាម និងរូបជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា អាយតនៈទី ៦ ប្រកបដោយនាម កើតមាន ព្រោះនាម និងរូបជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ ផស្សៈប្រកបដោយអាយតនៈទី ៦ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា នេះហៅថា ផស្សៈប្រកបដោយអាយតនៈទី ៦ កើតមាន

ព្រោះអាយតនៈទី ៦ ជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបលោកពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៧១ ] ក្នុងសម័យនោះ សង្ខារប្រកបដោយអវិជ្ជា កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម និងរូប ជានាមប្រកបដោយវិញ្ញាណ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈ ៦ ប្រកបដោយនាម កើតមាន ព្រោះនាម និងរូបជាបច្ច័យ ផស្សៈប្រកបដោយអាយតនៈ ៦ កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ វេទនាប្រកបដោយផស្សៈ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាប្រកបដោយវេទនា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានប្រកបដោយតណ្ហា កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៧២ ] បណ្តាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្តេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្លឹះ គឺអវិជ្ជា មោហៈ អកុសលមូលណា នេះហៅថា អវិជ្ជា ។ បណ្តាបច្ចយាការទាំងនោះ សង្ខារប្រកបដោយអវិជ្ជា កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារប្រកបដោយអវិជ្ជា កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ វិញ្ញាណប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តី

ប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ នាម និងរូប ជានាមប្រកបដោយវិញ្ញាណ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្ដេច ។ នាមក៏មាន រូបក៏មាន ។ បណ្ដានាម និងរូបនោះ នាម តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្ដានាម និងរូបនោះ រូប តើដូចម្ដេច ។ ការសន្សំនៃចក្ខាយតនៈ ។បេ។ ការសន្សំនៃកាយាយតនៈ ឬក៏រូបដទៃណា ដែលកើតអំពីចិត្ត មានចិត្តជាហេតុ មានចិត្តជាសមុដ្ឋាន នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាម និងរូប ជានាមប្រកបដោយវិញ្ញាណ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ដោយប្រការដូច្នេះ ។ អធិប្បាយត្រង់ពាក្យថា អាយតនៈ ៦ ប្រកបដោយនាម កើតមាន ព្រោះនាម និងរូបជាបច្ច័យ ។ នាមក៏មាន រូបក៏មាន ។ បណ្ដានាម និងរូបនោះ នាម តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្ដានាម និងរូបនោះ រូប តើដូចម្ដេច ។ មហាភូតរូប ៤ និងមនោវិញ្ញាណធាតុ ប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវរូបណា នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាម និងរូប ដោយប្រការដូច្នេះ ។ បណ្ដាបច្ចយាការទាំងនោះ អាយតនៈ ៦ ប្រកបដោយនាម កើតមាន ព្រោះនាម និងរូបជាបច្ច័យ តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ មនាយតនៈ នេះហៅថា អាយតនៈ ៦ ប្រកបដោយនាម កើតមាន ព្រោះនាម និងរូបជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ ផស្សៈប្រកបដោយអាយតនៈ ៦ កើតមាន

ព្រោះអាយតនៈ ៦ ជាបច្ច័យ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា នេះហៅថា ផស្សៈប្រកបដោយអាយតនៈ ៦ កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

សម្បយុត្តចតុក្កៈ ចប់

[ ៧៣ ] ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ សង្ខារ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះនាមជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ នាម កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ អាយតនៈ ៦ កើតមាន ព្រោះផស្សៈជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ផស្សៈ កើតមាន ព្រោះវេទនាជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ វេទនា កើតមាន ព្រោះតណ្ហាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ តណ្ហា កើតមាន ព្រោះឧបាទានជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៧៤ ] បណ្ដាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្ដេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្ថីៈ គឺអវិជ្ជា មោហៈ អកុសលមូលណា នេះ ហៅថា អវិជ្ជា ។

[ ៧៥ ] បណ្ដាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជា បច្ច័យ តើដូចម្ដេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ បណ្ដាបច្ចយាការ ទាំងនោះ អវិជ្ជាកើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្ដេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្ថីៈ គឺអវិជ្ជា មោហៈ អកុសលមូលណា នេះហៅថា អវិជ្ជាកើតមាន ព្រោះសង្ខារជាបច្ច័យ ។

[ ៧៦ ] បណ្ដាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជា បច្ច័យ តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាជ្ញា ។បេ។ មនោ-វិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះ វិញ្ញាណជាបច្ច័យ តើដូចម្ដេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវ អារម្មណ៍ ) ណា នេះហៅថា សង្ខារកើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។

[ ៧៧ ] បណ្ដាបច្ចយាការទាំងនោះ នាម កើតមាន ព្រោះវិញ្ញាណជា បច្ច័យ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាមកើត មាន ព្រោះវិញ្ញាណជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ វិញ្ញាណ កើត មាន ព្រោះនាមជាបច្ច័យ តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដី

ប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះនាមជាបច្ច័យ ។

[ ៧៨ ] បណ្តាបច្ចយាការទាំងនោះ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ នាម កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ។

[ ៧៩ ] បណ្តាបច្ចយាការទាំងនោះ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា នេះហៅថា ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ អាយតនៈទី ៦ កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា អាយតនៈទី ៦ កើតមាន ព្រោះផស្សៈជាបច្ច័យ ។

[ ៨០ ] បណ្តាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្តេច ។ សេចក្តីត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ ជាទីត្រេកអរ ជាសុខ ដែលកើតអំពីចេតោ-សម្ផស្ស វេទនាជាទីត្រេកអរ ជាសុខ ដែលកើតអំពីចេតោសម្ផស្ស នេះហៅ

ថា វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ ផស្សៈ កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ទង្គុកទង្គិចណា នេះហៅថា ផស្សៈ កើតមាន ព្រោះវេទនាជាបច្ច័យ ។

[ ៨១ ] បណ្តាបច្ចយាការទាំងនោះ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្តេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងណា នៃចិត្ត នេះហៅថា តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះតណ្ហាជាបច្ច័យ តើដូចម្តេច ។ សេចក្តីត្រេកអរប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ជាទីត្រេកអរ ជាសុខ ដែលកើតអំពីចេតោសម្ផស្ស វេទនា ជាទីត្រេកអរជាសុខ ដែលកើតអំពីចេតោសម្ផស្សណា នេះហៅថា វេទនា កើតមាន ព្រោះតណ្ហាជាបច្ច័យ ។

[ ៨២ ] បណ្តាបច្ចយាការទាំងនោះ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ តើដូចម្តេច ។ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ។បេ។ លទ្ធិដូចជាកំពង់ ការប្រកាន់ក្នុងការស្វែងរកខុសណា នេះហៅថា ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ តណ្ហា កើតមាន ព្រោះឧបាទានជាបច្ច័យ តើដូចម្តេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងណា នៃចិត្ត នេះហៅថា តណ្ហា កើតមាន ព្រោះឧបាទានជាបច្ច័យ ។

[ ៨៣ ] បណ្តាបច្ចយាការទាំងនោះ ភព កើតមាន ព្រោះឧបាទាន

ជាបច្ច័យ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ លើកតែឧបាទានចេញ នេះហៅថា ភព កើតមាន ព្រោះឧបាទានជាបច្ច័យ។

[ ៨៤ ] បណ្ដាបច្ចយាការទាំងនោះ ជាតិ កើតមាន ព្រោះភពជាបច្ច័យ តើដូចម្ដេច ។ ជាតិ ការកើតព្រម ការផ្ចួចផ្ដើមឡើង ការកើតចំពោះ ការកើតប្រាកដណា នៃធម៌ទាំងឡាយនោះ នេះហៅថា ជាតិ កើតមាន ព្រោះភពជាបច្ច័យ ។

[ ៨៥ ] បណ្ដាបច្ចយាការទាំងនោះ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ តើដូចម្ដេច ។ ជរាក៏មាន មរណៈក៏មាន ។ បណ្ដាជរា និងមរណៈទាំងនោះ ជរា តើដូចម្ដេច ។ ការចាស់ ការគ្រាំគ្រា ការរួញថយអាយុណា នៃធម៌ទាំងឡាយនោះ នេះហៅថា ជរា ។ បណ្ដាជរា និងមរណៈនោះ មរណៈ តើដូចម្ដេច ។ ការអស់ ការសូន្យ ការបែកធ្លាយ ការខ្ចាត់ខ្ចាយ ការមិនទៀង ការបាត់បង់ណា នៃធម៌ទាំងឡាយនោះ នេះហៅថា មរណៈ ។ ជរានេះផង មរណៈនេះផង នេះហៅថា ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ដោយប្រការដូច្នេះ ។

[ ៨៦ ] សេចក្ដីត្រង់ពាក្យថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ដូចតទៅនេះ ។ ការជួបជុំ ការមូលមក ការប្រជុំចុះ ការកើតប្រាកដនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៨៧ ] ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ សង្ខារ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះនាមជាបច្ច័យ នាម កើតមាន ព្រោះផស្សៈជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ផស្សៈ កើតមាន ព្រោះវេទនាជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ វេទនា កើតមាន ព្រោះតណ្ហាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ តណ្ហា កើតមាន ព្រោះឧបាទានជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៨៨ ] បណ្តាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្តេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្ថីៈ គឺអវិជ្ជា មោហៈ អកុសលមូលណា នេះហៅថា អវិជ្ជា ។ បណ្តាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្តេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្ថីៈ គឺអវិជ្ជា មោហៈ អកុសលមូលណា នេះហៅថា អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ វិញ្ញាណ

*កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះនាមជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះនាមជាបច្ច័យ ។ អធិប្បាយត្រង់ពាក្យថា ផស្សៈ កើតមាន ព្រោះនាមជាបច្ច័យ ។ បណ្តាធម៌ទាំងនោះ នាម តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ លើកតែផស្សៈចេញ នេះហៅថា នាម ។ បណ្តាបច្ចយាការទាំងនោះ ផស្សៈ កើតមាន ព្រោះនាមជាបច្ច័យ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា នេះហៅថា ផស្សៈ កើតមាន ព្រោះនាមជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ នាម កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ នេះហៅថា នាម កើតមាន ព្រោះផស្សៈជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើត*

ឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៨៩ ] ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ សង្ខារ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ នាម និងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះនាម និងរូបជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាម និងរូបជាបច្ច័យ នាម និងរូប កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះផស្សៈជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ផស្សៈ កើតមាន ព្រោះវេទនាជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ វេទនា កើតមាន ព្រោះតណ្ហាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ តណ្ហា កើតមាន ព្រោះឧបាទាន ជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកង ទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៩០ ] បណ្ដាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្ដេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្លឹះ គឺអវិជ្ជា មោហៈ អកុសលមូលណា នេះហៅថា អវិជ្ជា ។ បណ្ដាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្ដេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ បណ្ដាបច្ចយាការទាំង

*នោះ អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្ដេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្លឹះ គឺអវិជ្ជា មោហៈ អកុសលមូលណា នេះហៅថា អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្ដេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ នាម និងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្ដេច ។ នាមក៏មាន រូបក៏មាន ។ បណ្ដានាម និងរូបនោះ នាម តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្ដានាម និងរូបនោះ រូប តើដូចម្ដេច ។ ការសន្សំនៃចក្ខាយតនៈ ។បេ។ ការសន្សំនៃកាយាយតនៈ ឬក៏រូបដទៃណា ដែលកើតអំពីចិត្ត មានចិត្តជាហេតុ មានចិត្តជាសមុដ្ឋាន នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាម និងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ដោយប្រការដូច្នេះ ។ សេចក្ដីត្រង់ពាក្យថា វិញ្ញាណ កើតមាន ព្រោះនាម និងរូបជាបច្ច័យ ដូចតទៅនេះ ។ នាមក៏មាន រូបក៏មាន ។ បណ្ដានាម និងរូបនោះ នាម តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្ដានាម និងរូបនោះ រូប តើដូចម្ដេច ។ មនោវិញ្ញាណធាតុ ប្រព្រឹត្តទៅ ព្រោះអាស្រ័យ*

នូវរូបណា នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាម និងរូប ដោយប្រការដូច្នេះ ។ បណ្តាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះនាម និងរូបជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះនាម និងរូប ជាបច្ច័យ ។ សេចក្តីត្រង់ពាក្យថា អាយតនៈទី ៦ កើតមាន ព្រោះនាម និងរូបជាបច្ច័យ ដូចតទៅនេះ ។ នាមក៏មាន រូបក៏មាន ។ បណ្តានាម និងរូបនោះ នាម តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្តានាម និងរូបនោះ រូប តើដូចម្តេច ។ មនោវិញ្ញាណធាតុ ប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវរូបណា នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាម និងរូប ដោយប្រការដូច្នេះ ។ បណ្តាបច្ចយាការទាំងនោះ អាយតនៈទី ៦ កើតមាន ព្រោះនាម និងរូប ជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា អាយតនៈទី ៦ កើតមាន ព្រោះនាម និងរូបជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ នាម និងរូប កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ តើដូចម្តេច ។ នាមក៏មាន រូបក៏មាន ។ បណ្តានាម និងរូបនោះ នាម តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្តានាម និងរូបនោះ រូប តើដូចម្តេច ។ ការសន្សំនៃចក្ខាយតនៈ ។បេ។ ការសន្សំនៃកាយាយតនៈ ឬក៏រូបដទៃណា ដែលកើតអំពីចិត្ត មានចិត្តជាហេតុ មានចិត្ត

ជាសមុដ្ឋាន នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាម និងរូប កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ដោយប្រការដូច្នេះ ។ បណ្តាបច្ចយាការទាំងនោះ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា នេះហៅថា ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ អាយតនៈទី ៦ កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោ-វិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា អាយតនៈទី ៦ កើតមាន ព្រោះផស្សៈជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៩១ ] ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ សង្ខារ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ នាម និងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះនាម និងរូបជាបច្ច័យ អាយតនៈ ៦ កើតមាន ព្រោះនាម និងរូបជាបច្ច័យ នាម និងរូប កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ អាយតនៈ ៦ កើតមាន ព្រោះផស្សៈជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ផស្សៈ កើតមាន ព្រោះវេទនាជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ វេទនា កើតមាន ព្រោះតណ្ហាជាបច្ច័យ ឧបាទាន កើតមាន

ព្រោះតណ្ហាជាបច្ច័យ តណ្ហា កើតមាន ព្រោះឧបាទាន ជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៩២ ] បណ្ដាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្ដេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្លឹះ គឺអវិជ្ជា មោហៈ អកុសលមូលណា នេះហៅថា អវិជ្ជា ។ បណ្ដាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្ដេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំណា នេះហៅថា សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្ដេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្លឹះ គឺអវិជ្ជា មោហៈ អកុសលមូលណា នេះហៅថា អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្ដេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំណា នេះហៅថា សង្ខារ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ នាម និងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្ដេច ។ នាមក៏មាន រូបក៏មាន ។ បណ្ដានាម និងរូបនោះ នាម តើដូចម្ដេច ។

វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្ដានាម និងរូបនោះ រូប តើដូចម្ដេច ។ ការសន្សំនៃចក្ខាយតនៈ ។បេ។ ការសន្សំនៃកាយាយតនៈ ឬក៏រូបដទៃណា ដែលកើតអំពីចិត្ត មានចិត្តជាហេតុ មានចិត្តជាសមុដ្ឋាន នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាម និងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។ អធិប្បាយត្រង់ពាក្យថា វិញ្ញាណ កើតមាន ព្រោះ នាម និងរូបជាបច្ច័យ ។ នាមក៏មាន រូបក៏មាន ។ បណ្ដានាម និងរូបនោះ នាម តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្ដានាម និងរូបទាំងនោះ រូប តើដូចម្ដេច ។ មនោវិញ្ញាណធាតុ ប្រព្រឹត្ត ទៅ ព្រោះអាស្រ័យនូវរូបណា នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាម និងរូប ដោយប្រការដូច្នេះ ។ បណ្ដាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះនាម និងរូបជាបច្ច័យ តើដូចម្ដេច ។ ចិត្ត សេចក្ដី ដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណ នោះណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះនាម និងរូបជាបច្ច័យ ។ សេចក្ដីត្រង់ពាក្យថា អាយតនៈ ៦ កើតមាន ព្រោះនាម និងរូបជាបច្ច័យ ដូចតទៅនេះ ។ នាមក៏មាន រូបក៏មាន ។ បណ្ដានាម និងរូបទាំងនោះ នាម តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្ដា នាម និងរូបទាំងនោះ រូប តើដូចម្ដេច ។ មហាភូតរូប ៤ និងមនោវិញ្ញាណធាតុ ប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវរូបណា នេះហៅថា រូប ។ នាមនេះផង រូប នេះផង នេះហៅថា នាម និងរូប ដោយប្រការដូច្នេះ ។ បណ្ដាបច្ចយាការ

ទាំងនោះ អាយតនៈ ៦ កើតមាន ព្រោះនាម និងរូប ជាបច្ច័យ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ មនាយតនៈ នេះហៅថា អាយតនៈ ៦ កើតមាន ព្រោះនាម និងរូបជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ នាម និងរូប កើតមានក៏ព្រោះអាយតនៈ ៦ ជាបច្ច័យ តើដូចម្តេច ។ នាមក៏មាន រូបក៏មាន ។ បណ្តានាម និងរូបទាំងនោះ នាម តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្តានាម និងរូបនោះ រូប តើដូចម្តេច ។ ការសន្សំនៃចក្ខាយតនៈ ។បេ។ ការសន្សំនៃកាយាយតនៈ ឬក៏រូបដទៃណា ដែលកើតអំពីចិត្ត មានចិត្តជាហេតុ មានចិត្តជាសមុដ្ឋាន នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាម និងរូប កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ ដោយប្រការដូច្នេះ ។ បណ្តាបច្ចយាការទាំងនោះ ផស្សៈ កើតមានព្រោះអាយតនៈ ៦ ជាបច្ច័យ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា នេះហៅថា ផស្សៈ កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ អាយតនៈ ៦ កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ មនាយតនៈ នេះហៅថា អាយតនៈ ៦ កើតមាន ព្រោះផស្សៈជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

អញ្ញមញ្ញចតុក្កៈ ចប់

[ ៩៣ ] ពួកធម៌ជាអកុសល តើដូចម្តេច ។ ក្នុងសម័យណា អកុសលចិត្ត ប្រទូវ្យដោយសោមនស្ស ប្រកបដោយទិដ្ឋិ ប្រកបដោយសង្ខារ ។បេ។ ប្រទូវ្យដោយសោមនស្ស ប្រាសចាកទិដ្ឋិ ។បេ។ ប្រទូវ្យដោយសោមនស្ស ប្រាសចាកទិដ្ឋិ ប្រកបដោយសង្ខារ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ ( ការចុះចិត្តស៊ប់ ) កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៩៤ ] បណ្តាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្តេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្លឹះ គឺអវិជ្ជា មោហៈ អកុសលមូលណា នេះហៅថា អវិជ្ជា ។ បណ្តាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។បេ។ បណ្តាបច្ចយាការទាំងនោះ អធិមោក្ខ កើតមាន ព្រោះតណ្ហាជាបច្ច័យ តើដូចម្តេច ។ ការចុះ

ស៊ប់ អាការចុះស៊ប់ ភាពចុះស៊ប់នៃចិត្តក្នុងអារម្មណ៍នោះណា នេះហៅថា អធិមោក្ខ កើតមាន ព្រោះតណ្ហាជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារ-ក្ខន្ធ វិញ្ញាណក្ខន្ធ លើកតែអធិមោក្ខចេញ នេះហៅថា ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។បេ។

[ ៩៥ ] ពួកធម៌ជាអកុសល តើដូចម្ដេច ។ ក្នុងសម័យណា អកុ-សលចិត្ត ប្រកបដោយឧបេក្ខា ប្រកបដោយទិដ្ឋិ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៩៦ ] បណ្ដាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្ដេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្លឹះ គឺអវិជ្ជា មោហៈ អកុសលមូលណា នេះហៅថា

អវិជ្ជា ។បេ។ បណ្តាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្តេច ។ សេចក្តីត្រេកអរក៏មិនមែន សេចក្តីមិនត្រេកអរក៏មិនមែន ដែលប្រព្រឹត្តទៅក្នុងចិត្ត ការទទួលនូវអារម្មណ៍មិនមែនទុក្ខមិនមែនសុខ ដែលកើតអំពីចេតោសម្ផស្ស អទុក្ខមសុខវេទនា ដែលកើតអំពីចេតោសម្ផស្សណា នេះហៅថា វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។បេ។

[ ៩៧ ] ពួកធម៌ជាអកុសល តើដូចម្តេច ។ ក្នុងសម័យណា អកុសលចិត្ត ប្រឡំដោយឧបេក្ខា ប្រកបដោយទិដ្ឋិ ប្រកបដោយសង្ខារ ។បេ។ ប្រឡំដោយឧបេក្ខា ប្រាសចាកទិដ្ឋិ ។បេ។ ប្រឡំដោយឧបេក្ខា ប្រាសចាកទិដ្ឋិ ប្រកបដោយសង្ខារ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។បេ។

[ ៩៨ ] ពួកធម៌ជាអកុសល តើដូចម្តេច ។ ក្នុងសម័យណា អកុសលចិត្ត ប្រទូស្តដោយទោមនស្ស ប្រកបដោយបដិឃៈ ។បេ។ ប្រទូស្តដោយទោមនស្ស ប្រកបដោយបដិឃៈ ប្រកបដោយសង្ខារ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាម ជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ បដិឃៈ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបដិឃៈជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៩៩ ] បណ្តាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្តេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្លឹះ គឺអវិជ្ជា មោហៈ អកុសលមូលណា នេះហៅថា អវិជ្ជា ។បេ។ បណ្តាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្តេច ។ សេចក្តីមិនត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីទុក្ខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ មិនជាទីត្រេកអរ ជាទុក្ខ ដែលកើតអំពីចេតោសម្ផស្ស វេទនា មិនជាទីត្រេកអរ ជាទុក្ខ ដែលកើតអំពីចេតោ-

សម្ផស្សជា នេះហៅថា វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ។ បណ្ដា បច្ចយាការទាំងនោះ បដិឃៈ កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្ដេច ។ ការចង្អៀតចង្អល់ ការថ្នាំងថ្នាក់នៃចិត្ត ។បេ។ ភាពកាច ការមិនស្រស់ស្រាយ ភាពនៃសេចក្ដីមិនត្រេកអរណានៃចិត្ត នេះហៅថា បដិឃៈ កើតមាន ព្រោះ វេទនាជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ អធិមោក្ខ កើតមាន ព្រោះ បដិឃៈជាបច្ច័យ តើដូចម្ដេច ។ ការចុះស៊ប់ អាការចុះស៊ប់ ភាពនៃការចុះ ស៊ប់នៃចិត្ត ក្នុងអារម្មណ៍នោះណា នេះហៅថា អធិមោក្ខ កើតមាន ព្រោះ បដិឃៈជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ ភព កើតមាន ព្រោះអធិមោក្ខ ជាបច្ច័យ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ លើកតែអធិមោក្ខចេញ នេះហៅថា ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំង អស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។បេ។

[ ១០០ ] ពួកធម៌ជាអកុសល តើដូចម្ដេច ។ ក្នុងសម័យណា អកុ- សលចិត្ត ប្រកបដោយឧបេក្ខា ប្រកបដោយវិចិកិច្ឆា មានរូបជាអារម្មណ៍ក្ដី ។បេ។ មានធម៌ជាអារម្មណ៍ក្ដី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណ ជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ វិចិកិច្ឆា កើតមាន ព្រោះ

វេទនាជាបច្ច័យ ភព កើតមាន ព្រោះវិចិកិច្ឆាជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១០១ ] បណ្ដាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្ដេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្លឹះ គឺអវិជ្ជា មោហៈ អកុសលមូលណា នេះហៅថា អវិជ្ជា ។បេ។ បណ្ដាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្ដេច ។ សេចក្ដីត្រេកអរ ក៏មិនមែន សេចក្ដីមិនត្រេកអរ ក៏មិនមែន ដែលប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ មិនមែនទុក្ខ មិនមែនសុខ ដែលកើតអំពីចេតោសម្ផស្ស អទុក្ខមសុខវេទនា ដែលកើតអំពីចេតោសម្ផស្ស នេះហៅថា វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ វិចិកិច្ឆា កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្ដេច ។ ការងឿងឆ្ងល់ អាការងឿងឆ្ងល់ ភាពងឿងឆ្ងល់ ការប្រាសចាកបញ្ញា ការតេងតាងគំនិត ការបែកគំនិតជាពីរ ផ្លូវពីរ ការសង្ស័យ ការកាន់យកចំណែកច្រើន ការអន្ដឹអន្ដែ ការអល់ឯក ការមិនចុះចិត្តស៊ប់ ភាពរឹងរូស ការរសេមរសាមណា នៃចិត្ត នេះហៅថា វិចិកិច្ឆា កើតមាន ព្រោះវេទនាជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ ភព កើតមាន ព្រោះវិចិកិច្ឆាជាបច្ច័យ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ លើកតែវិចិកិច្ឆាចេញ នេះហៅថា ភព កើតមាន ព្រោះវិចិកិច្ឆាជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែង

មាន ដោយអាការយ៉ាងនេះ ។បេ។

[ ១០២ ] ពួកធម៌ជាអកុសល តើដូចម្តេច ។ ក្នុងសម័យណា អកុសលចិត្ត ប្រឡំដោយឧបេក្ខា ប្រកបដោយឧទ្ធច្ចៈ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ឧទ្ធច្ចៈ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះឧទ្ធច្ចៈជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១០៣ ] បណ្តាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្តេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្លឹះ គឺអវិជ្ជា មោហៈ អកុសលមូលណា នេះហៅថា អវិជ្ជា ។បេ។ បណ្តាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្តេច ។ សេចក្តីត្រេកអរ ក៏មិនមែន សេចក្តីមិនត្រេកអរ ក៏មិនមែន ដែលប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ មិនមែនទុក្ខ មិនមែនសុខ ដែលកើតអំពីចេតោសម្ផស្ស អទុក្ខមសុខវេទនា ដែលកើតអំពីចេតោសម្ផស្សណា នេះហៅថា វេទនា កើតមាន ព្រោះផស្សៈជា

*បច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ ឧទ្ធច្ចៈ កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្ដេច ។ ការរវើរវាយនៃចិត្ត ការមិនស្ងប់ ការរាយមាយចិត្ត ភាពនៃចិត្តភ្ញាក់ផ្អើលណា នេះហៅថា ឧទ្ធច្ចៈ កើតមាន ព្រោះវេទនាជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ អធិមោក្ខ កើតមាន ព្រោះឧទ្ធច្ចៈជាបច្ច័យ តើដូចម្ដេច ។ ការចុះស៊ប់ អាការចុះស៊ប់ ភាពចុះស៊ប់នៃចិត្ត ក្នុងអារម្មណ៍នោះណា នេះហៅថា អធិមោក្ខ កើតមាន ព្រោះឧទ្ធច្ចៈជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ លើកតែអធិមោក្ខចេញ នេះហៅថា ភពកើតមាន ព្រោះអធិមោក្ខជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។បេ។*

## *អកុសលនិទ្ទេស ចប់*

# អដ្ឋកថា

## អធិប្បាយ អកុសលនិទ្ទេស

[ ៣៧-៥៦ ] ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់មិនបានកាន់យកកុសលមុន ព្រោះមិនបានតាំងមាតិកា ក្នុងបដិច្ចសមុប្បាទនេះ ដូចដែលទ្រង់ចែកកុសលមុន តាមលំដាប់នៃមាតិកាដែលទ្រង់ធ្វើកុសលត្តិកៈជាខាងដើមក្នុងចត្តុប្បាទកណ្ឌខាងដើម តែទ្រង់ត្រាស់ថា ធម៌ទាំងឡាយ ជាអកុសលតើដូចម្ដេចជាដើម ដើម្បីទ្រង់ចែកសម្ដែងអង្គនៃបដិច្ចសមុប្បាទ មានអវិជ្ជាជាដើម តាមលំដាប់នៃការតាំងទុកនោះឯង ព្រោះទ្រង់តាំងមាតិកាដោយអំណាចអកុសលធម៌ថា **អវិជ្ជាបច្ចយា សង្ខារោ** ដូច្នេះ ។ អត្ថនៃព្រះបាលីនោះ គប្បីជ្រាបដោយន័យ ដែលត្រាស់ក្នុងចិត្តុប្បាទកណ្ឌខាងដើមនោះឯង ។ ម្យ៉ាងទៀត ព្រោះតណ្ហា និងកាមុបាទាន រមែងមិនកើតក្នុងខណៈនៃចិត្តដួងតែមួយ ហេតុនោះ ក្នុងទីនេះ ដើម្បីទ្រង់សម្ដែងឧបាទាន ដែលបានព្រោះតណ្ហាជាបច្ច័យនោះឯង ទើបត្រាស់ពាក្យជាដើមថា **ទិដ្ឋិ ទិដ្ឋិគតំ** ទិដ្ឋិដំណើរ គឺទិដ្ឋិ ដូច្នេះ ។

ម្យ៉ាងទៀត ព្រោះក្នុងនិទ្ទេសនៃភព ឧបាទានដល់នូវការសង្គ្រោះចូលក្នុងសង្ខារក្ខន្ធ ហេតុនោះ ទើបត្រាស់ថា វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ វៀរលែងតែឧបាទានចេញ ដូច្នេះជាដើម ព្រោះកាលត្រាស់យ៉ាងនេះ គប្បីប្រាកដភាពដែលឧបាទានជាបច្ច័យដល់ឧបាទាន ។ ឯឧបាទាននោះឯង រមែងមិនជាបច្ច័យដល់ឧបាទាននោះ ។

ក្នុងនិទ្ទេសនៃជាតិជាដើម ព្រោះធម៌ទាំងនោះ មានជាតិជាដើម ជាការកើតជាដើមរបស់អរូបធម៌ទាំងឡាយ ហេតុនោះ ទើបមិនត្រាស់ ( ក្នុងសំយុត្តនិកាយ និទានវគ្គ ) ថា ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញជ្រីវ ចុតិឃាតបាក ដូច្នេះ ។

ព្រះអង្គទ្រង់តាំងវារៈទី ១ យ៉ាងនេះហើយ ក្នុងវារៈទី ២ ទ្រង់សម្តែងបច្ចយាការដោយវារៈទី ១ ក្នុងសម័យណា ក្នុងសម័យនោះឯង ដើម្បីទ្រង់សម្តែងនូវបច្ចយាការដោយន័យដទៃទៀត ទើបមិនត្រាស់វារៈកំណត់សម័យដោយឡែក ហើយទ្រង់ធ្វើទេសនាដោយន័យជាដើមថា **តស្មឹ សមយេ អវិជ្ជាបច្ចយា សង្ខារោ** ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឋបេត្វា ផស្សំ** នេះ ត្រាស់ដើម្បីទ្រង់នាំផស្សៈចេញអំពីនាម ព្រោះផស្សៈក៏ទាក់ទងដោយនាម ។

ក្នុងវារៈទី ៣ វិញ្ញាណជាបច្ច័យដល់រូប ដែលមានចិត្តជាសមុដ្ឋានណា កាលរូបដែលមានចិត្តជាសមុដ្ឋាននោះ កំពុងប្រព្រឹត្តទៅ ព្រោះភាពដែលចក្ខាយតនៈជាដើម ដែលរូបមានចិត្តជាសមុដ្ឋាននោះ ឧបការៈហើយ កើតឡើង រមែងប្រាកដ ហេតុនោះ ទើបត្រាស់ថា **ចក្ខាយតនស្ស ឧបចយោ** ជាដើម ម្យ៉ាងទៀត ព្រោះវិញ្ញាណជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យដល់កម្មជរូប ដែលកំពុងប្រព្រឹត្តទៅក្នុងសម័យនោះ ព្រោះហេតុនោះ ទើបត្រាស់យ៉ាងនេះ ក្នុងវារៈទី ៣ នោះ ទ្រង់កាន់យកសន្តតិ ២ គឺសន្តតិរូបកើតអំពី

*កម្ម និងសន្តតិរូបដែលមានចិត្តជាសមុដ្ឋានក៏ពិត តែសន្តតិ ២ ក្រៅអំពីនេះ ក៏គប្បីកាន់យក ព្រោះវិញ្ញាណជាបច្ច័យដល់សន្តតិ ២ ក្រៅអំពីនេះដូចគ្នា ។*

*ចំណែកក្នុងវារៈទី ៤ ព្រោះក្នុងខណៈចិត្តដួងតែមួយ ចក្ខាយតនៈជាដើម កើតព្រោះមហាភូតរូបជាបច្ច័យ សឡាយតនៈ កើតព្រោះហទយរូបជាបច្ច័យ និងអាយតនៈទាំងអស់ កើតព្រោះនាមជាបច្ច័យ ប្រព្រឹត្តទៅដោយអំណាចបច្ឆាជាតប្បច្ច័យ និងសហជាតប្បច្ច័យជាដើមតាមគួរ ហេតុនោះ ទើបត្រាស់ពាក្យជាដើមថា* **តត្ថ កតមំ នាមរូបប្បច្ចយា សឡាយតនំ ចក្ខាយតនំ** *អាយតនៈ ៦ កើតមាន ព្រោះនាម និងរូបជាបច្ច័យ តើដូចម្តេច ។ ចក្ខាយតនៈ ១ ... ។ល។*

## បឋមចតុក្កនិទ្ទេស ចប់

*[ ៥៧-៦៤ ] ពាក្យទាំងអស់ក្នុងចតុក្កៈទី ២ ( ហេតុចតុក្កៈ ) មានអត្ថងាយយល់ហើយ ។*

*[ ៦៥-៧២ ] ក្នុងចតុក្កៈទី ៣ ( សម្បយុត្តចតុក្កៈ ) ភាពជាសម្បយុត្តប្បច្ច័យ មិនមានដល់បច្ចយាការណា និងមានដល់បច្ចយាការណា ដើម្បីទ្រង់សម្តែងបច្ចយាការនោះៗ មួយផ្នែក ទើបត្រាស់ថា* **ឋធំ វុច្ចតិ វិញ្ញាណប្បច្ចយា នាមរូបំ វិញ្ញាណសម្បយុត្តំ នាមំ** *ដូច្នេះជាដើម ។*

[ ៧២-៩២ ] និទ្ទេសនៃនាមកើត ព្រោះផស្សៈជាបច្ច័យ ក្នុងចតុក្កៈទី ៤ សូម្បីមិនបានត្រាស់ថា វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ វៀរផស្សៈ នេះ ហៅថា នាមកើត ព្រោះផស្សៈជាបច្ច័យដូច្នេះក៏ពិត តែព្រោះបានត្រាស់ ក្នុងនិទ្ទេសនៃបទដែលជាប់គ្នា ដែលបន្ថែមមកថា វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ វៀរផស្សៈ ដូច្នេះ ពាក្យក្នុងនិទ្ទេសនៃនាមកើត ព្រោះផស្សៈជាបច្ច័យនោះ សូម្បីមិនបានត្រាស់ហើយដោយពិត ព្រោះនាមណា ជាបច្ច័យដល់ផស្សៈ សូម្បីផស្សៈ ក៏ជាបច្ច័យដល់នាមនោះដូចគ្នានោះឯង ។

ម្យ៉ាងទៀត គប្បីជ្រាបន័យ ៨ ដែលមានសង្ខារជាមូលជាដើម ដូចន័យទី ១ មានអវិជ្ជាជាមូល ដែលចែក ១០ វារៈក្នុងចតុក្កៈ ៤ ដែលទ្រង់ប្រកាសក្នុងអកុសលចិត្តដួងទី ១ នេះ ចំណែកព្រះបាលីទ្រង់សង្ខេប និងគប្បីជ្រាបថា ក្នុងអកុសលចិត្តដួងទី ១ នោះឯង មាន ៩ ន័យ ៣៦ ចតុក្កៈ និង ១៤៤ វារៈ ដោយប្រការដូច្នេះ ។

[ ៩៣-១០៣ ] ឥឡូវនេះ ដើម្បីសម្តែងបច្ចយាការ ក្នុងអកុសលចិត្ត ដ៏សេស ដោយន័យនេះឯង ទើបផ្តើមពាក្យជាដើមថា **កតមេ ធម្មា អកុសលា** ពួកធម៌ជាអកុសល តើដូចម្តេច ។

ក្នុងព្រះបាលីនោះ ព្រោះក្នុងចិត្តដែលប្រាសចាកទិដ្ឋិ ឧបាទានកើត ព្រោះតណ្ហាជាបច្ច័យ មិនមាន ហេតុនោះ ទើបទ្រង់បន្ថែមអធិមោក្ខ ដែលជានិបាតធ្វើឲ្យមាំទាំ ដូចឧបាទានកើតក្នុងទីនៃឧបាទាន និងព្រោះក្នុងចិត្តដែលសហគតៈដោយទោមនស្ស សូម្បីតណ្ហាដែលកើតព្រោះវេទនាជាបច្ច័យ ក៏

មិនមាន ហេតុនោះ ទើបទ្រង់បន្ថែមបដិឃៈ ដែលជាកិលេសមានកម្លាំង ដូចតណ្ហាកើតក្នុងទីនៃតណ្ហា ទ្រង់បន្ថែមបទអធិមោក្ខនោះឯង ក្នុងទីនៃឧបាទាន ។

ចំណែកក្នុងអកុសលចិត្ត ដែលសម្បយុត្តដោយវិចិកិច្ឆា រមែងមិនមានក្នុងអធិមោក្ខ ព្រោះមិនមានការកាត់សម្រេច ហេតុនោះ ទើបទ្រង់បន្ថែមវិចិកិច្ឆា ដែលជាកិលេសមានកម្លាំងក្នុងទីនៃតណ្ហា បន្ថយឋានៈនៃឧបាទានចេញ តែក្នុងអកុសលចិត្តដែលសម្បយុត្តដោយឧទ្ធច្ចៈ ព្រោះមានអធិមោក្ខ ហេតុនោះ ទើបទ្រង់បន្ថែមឧទ្ធច្ចៈ ដែលជាកិសេលមានកម្លាំងក្នុងទីនៃតណ្ហា ។ ទ្រង់បន្ថែមអធិមោក្ខនោះឯងក្នុងទីនៃឧបាទាន ព្រះមានព្រះភាគ ទ្រង់សម្តែងហេតុត្រឹមតែការផ្សេងគ្នាក្នុងអកុសលទាំងអស់នោះឯង ហើយទ្រង់សង្ខេបព្រះបាលី ឯការផ្សេងគ្នា ដែលទ្រង់សម្តែងនិទ្ទេសនៃអធិមោក្ខតែម្យ៉ាងប៉ុណ្ណោះ មិនធ្លាប់សម្តែងមកអំពីមុន ។ ពាក្យដ៏សេស មកហើយខាងដើមនោះឯង ។

ក្នុងនិទ្ទេសនៃអធិមោក្ខ មានវិនិច្ឆ័យថា ដែលឈ្មោះថា អធិមោក្ខ ព្រោះកាត់សម្រេចនូវអារម្មណ៍ ។ ម្យ៉ាងទៀត ដែលឈ្មោះថា អធិមោក្ខ ព្រោះអត្ត

ថា បង្អោនចិត្តទៅក្នុងអារម្មណ៍ គឺដល់នូវការសម្រេចចិត្ត ព្រោះមិនមានសេចក្ដីសង្ស័យ ។ អាការដែលកាត់សម្រេច ឈ្មោះថា **អធិមុច្ចនា** ដែលឈ្មោះថា **តទធិមុត្តតា** ព្រោះអត្ថថា បង្អោនចិត្តទៅក្នុងអារម្មណ៍នោះ ក្នុងចិត្តគ្រប់ដួង គប្បីជ្រាបប្រភេទនៃចតុក្កៈ និងវារៈដោយន័យដែលពោលក្នុងបឋមចិត្ត ( អកុសល ) នោះឯង ព្រោះក្នុងអកុសលចិត្តដែលសម្បយុត្តដោយវិចិកិច្ឆា មិនមានន័យដែលមានឧបាទានជាមូល ទើបមាន ៨ ន័យ ៣២ ចតុក្កៈ និង ១២៨ វារៈ ដូច្នេះឯង ៕

**អកុសលនិទ្ទេស ចប់**

# អភិធម្មបិដក

## កុសលនិទ្ទេស

[ ១០៤ ] ពួកធម៌ជាកុសល តើដូចម្តេច ។ ក្នុងសម័យណា កាមាវចរកុសលចិត្ត ប្រកបដោយសោមនស្ស ប្រកបដោយញាណ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណា ហើយកើតឡើង ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ បសាទ ( សេចក្តីជ្រះថ្លា ) កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១០៥ ] បណ្តាធម៌ទាំងនោះ កុសលមូល តើដូចម្តេច ។ អលោភៈ អទោសៈ អមោហៈ ។ បណ្តាកុសលមូលទាំងនោះ អលោភៈ តើដូចម្តេច ។ ការមិនលោភ អាការមិនលោភ ភាពមិនលោភ ការមិនត្រេកអរខ្លាំង អាការមិនត្រេកអរ ភាពមិនត្រេកអរ ការមិនរំពៃ ( ចំពោះទ្រព្យអ្នកដទៃ ) អលោភៈ កុសលមូលណា នេះហៅថា អលោភៈ ។ បណ្តាកុសលមូលទាំងនោះ អទោសៈ តើដូចម្តេច ។ ការមិនប្រទូស្ត អាការមិនប្រទូស្ត ភាពមិនប្រទូស្ត

ការមិនព្យាបាទ ការមិនគុំកួន អទោសៈ កុសលមូលណា នេះហៅថា អទោសៈ ។ បណ្តាកុសលមូលទាំងនោះ អមោហៈ តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ សេចក្តីមិនវង្វេង ការពិចារណាធម៌ ការឃើញដោយប្រពៃណា នេះហៅថា អមោហៈ ។ នេះហៅថា កុសលមូល ។ បណ្តាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ ។បេ។ បណ្តាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្តេច ។ សេចក្តីត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ជាទីត្រេកអរ ជាសុខ ដែលកើតអំពីចេតោសម្ផស្ស សុខវេទនាជាទីត្រេកអរ ដែលកើតអំពីចេតោសម្ផស្សណា នេះហៅថា វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ។ បណ្តាធម៌ទាំងនោះ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្តេច ។ សទ្ធា ការជឿ ការជឿជាក់ សេចក្តីជ្រះថ្លាក្រៃលែងណា នេះហៅថា បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ ។ បណ្តាធម៌ទាំងនោះ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ តើដូចម្តេច ។ ការចុះស៊ប់ អាការចុះស៊ប់ ភាពចុះស៊ប់នៃចិត្ត ក្នុងអារម្មណ៍នោះណា នេះហៅថា អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ លើកលែងតែអធិមោក្ខចេញ នេះហៅថា ភព កើតមាន ព្រោះ

អធិមោក្ខជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបហៅថា ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១០៦ ] ពួកធម៌ជាកុសល តើដូចម្តេច ។ ក្នុងសម័យណា កាមាវចរ-កុសលចិត្ត ប្រឡំដោយសោមនស្ស ប្រកបដោយញាណ ប្រកបដោយសង្ខារ ។បេ។ ប្រឡំដោយសោមនស្ស ប្រាសចាកញាណ ។បេ។ ប្រឡំដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសង្ខារ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១០៧ ] បណ្តាធម៌ទាំងនោះ ពួកកុសលមូល តើដូចម្តេច ។ អលោភៈ អទោសៈ ។ បណ្តាកុសលមូលទាំងនោះ អលោភៈ តើដូចម្តេច ។ ការមិនលោភ អាការមិនលោភ ភាពមិនលោភ ការមិនត្រេកអរខ្លាំង អាការមិនត្រេកអរ ភាពមិនត្រេកអរ ការមិនរំពៃ ( ចំពោះទ្រព្យអ្នកដទៃ ) អលោភៈ

កុសលមូលណា នេះហៅថា អលោភៈ ។ បណ្តាធម៌ទាំងនោះ អទោសៈ តើដូចម្តេច ។ ការមិនប្រទូស្ត អាការមិនប្រទូស្ត ភាពមិនប្រទូស្ត ការមិនព្យាបាទ ការមិនគុំកួន អទោសៈ កុសលមូលណា នេះហៅថា អទោសៈ ។ នេះហៅថា កុសលមូល ។ បណ្តាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១០៨ ] ពួកធម៌ជាកុសល តើដូចម្តេច ។ ក្នុងសម័យណា កាមាវចរ-កុសលចិត្ត ប្រឡំដោយឧបេក្ខា ប្រកបដោយញាណ ។បេ។ ប្រឡំដោយឧបេក្ខា ប្រកបដោយញាណ ប្រកបដោយសង្ខារ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើងក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ

រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១០៩ ] បណ្ដាធម៌ទាំងនោះ កុសលមូល តើដូចម្ដេច ។ អលោភៈ អទោសៈ អមោហៈ ។បេ។ នេះហៅថា កុសលមូល ។ បណ្ដាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ តើដូចម្ដេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ ។បេ។ បណ្ដាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្ដេច ។ សេចក្ដីត្រេកអរក៏មិនមែន សេចក្ដីមិនត្រេកអរក៏មិនមែន ដែលប្រព្រឹត្តទៅក្នុងចិត្ត គឺការទទួលអារម្មណ៍ មិនជាទុក្ខ មិនជាសុខ ដែលកើតអំពីចេតោសម្ផស្ស អទុក្ខមសុខវេទនា ដែលកើតអំពីចេតោសម្ផស្សណា នេះហៅថា វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១១០ ] ពួកធម៌ជាកុសល តើដូចម្ដេច ។ ក្នុងសម័យណា កាមាវចរកុសលចិត្ត ប្រកបដោយឧបេក្ខា ប្រាសចាកញាណ ។បេ។ ប្រកបដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ មានរូបជាអារម្មណ៍ក្ដី ។បេ។ មានធម៌ជាអារម្មណ៍ក្ដី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជា

បច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១១១ ] បណ្ដាធម៌ទាំងនោះ ពួកកុសលមូល តើដូចម្ដេច ។ អលោភៈ អទោសៈ ។បេ។ នេះហៅថា កុសលមូល ។ បណ្ដាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ តើដូចម្ដេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១១២ ] ពួកធម៌ជាកុសល តើដូចម្ដេច ។ ក្នុងសម័យណា បុគ្គលចម្រើននូវមគ្គ ដើម្បីកើតក្នុងរូបភព ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន មានបឋវីកសិណ ( ជាអារម្មណ៍ ) ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះ

ភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១១៣ ] បណ្ដាធម៌ទាំងនោះ ពួកកុសលមូល តើដូចម្ដេច ។ អលោភៈ អទោសៈ អមោហៈ ។បេ។ នេះហៅថា កុសលមូល ។ បណ្ដាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ តើដូចម្ដេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១១៤ ] ពួកធម៌ជាកុសល តើដូចម្ដេច ។ ក្នុងសម័យណា បុគ្គលចម្រើននូវមគ្គ ដើម្បីកើតក្នុងអរូបភព កន្លងនូវអាកិញ្ចញ្ញាយតនៈ ដែលប្រឡំដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ដោយប្រការទាំងពួង ព្រោះលះបង់សុខផង ។បេ។ ហើយចូលកាន់ចតុត្ថជ្ឈាន ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន

ដោយអាការយ៉ាងនេះ ។

[ ១១៥ ] បណ្តាធម៌ទាំងនោះ ពួកកុសលមូល តើដូចម្តេច ។ អលោភៈ អទោសៈ អមោហៈ ។បេ។ នេះហៅថា កុសលមូល ។ បណ្តាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ ។បេ។ បណ្តាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្តេច ។ សេចក្តីត្រេកអរក៏មិនមែន សេចក្តីមិនត្រេកអរក៏មិនមែន ដែលប្រព្រឹត្តទៅក្នុងចិត្ត ការទទួលនូវអារម្មណ៍ មិនជាទុក្ខ មិនជាសុខ ដែលកើតអំពីចេតោសម្ផស្ស អទុក្ខមសុខវេទនា ដែលកើតអំពីចេតោសម្ផស្សណា នេះហៅថា វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១១៦ ] ពួកធម៌ជាកុសល តើដូចម្តេច ។ ក្នុងសម័យណា បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាធម្មជាតដល់នូវការមិនសន្សំ ( នូវកិលេសវដ្ត ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទា ទន្ធាភិញ្ញា ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះ

អាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃធម៌ទាំងនុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១១៧ ] បណ្តាធម៌ទាំងនោះ ពួកធម៌ជាកុសលមូល តើដូចម្តេច ។ អលោភៈ អទោសៈ អមោហៈ ។បេ។ បណ្តាកុសលមូលទាំងនោះ អមោហៈ តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ សេចក្តីមិនវង្វេង ការពិចារណានូវធម៌ ការឃើញដោយប្រពៃ ធម្មវិចយសម្ពោជ្ឈង្គ ជាអង្គមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា អមោហៈ ។ នេះហៅថា កុសលមូល ។ បណ្តាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ ។បេ។ បណ្តាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្តេច ។ សេចក្តីត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ ជាទីត្រេកអរជាសុខដែលកើតអំពីចេតោសម្ផស្ស វេទនាជាទីត្រេកអរ ជាសុខ ដែលកើតអំពីចេតោសម្ផស្សណា នេះហៅថា វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ។ បណ្តាធម៌ទាំងនោះ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្តេច ។ សទ្ធា ការជឿ ការជឿជាក់ សេចក្តីជ្រះថ្លាដ៏ក្រៃលែងណា នេះហៅថា បសាទ

កើតមាន ព្រោះវេទនាជាបច្ច័យ ។ បណ្តាធម៌ទាំងនោះ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ តើដូចម្តេច ។ ការចុះស៊ប់ អាការចុះស៊ប់ ភាពចុះស៊ប់នៃចិត្ត ក្នុងអារម្មណ៍នោះ នេះហៅថា អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ លើកតែអធិមោក្ខចេញ នេះហៅថា ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ។បេ។ អធិប្បាយត្រង់ពាក្យថា ហេតុជាទីកើតឡើងនៃធម៌ទាំងនុ៎ះ រមែងមាន ដោយប្រការដូច្នេះ ដូចតទៅនេះ ។ ការជួបជុំ ការមូលមក ការប្រជុំចុះ ការកើតប្រាកដ នៃធម៌ទាំងនុ៎ះ រមែងមានយ៉ាងនេះ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃធម៌ទាំងនុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

កុសលនិទ្ទេស ចប់

# អដ្ឋកថា

## កុសលនិទ្ទេស

[ ១០៤-១១៧ ] ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់បំណងដើម្បីសម្តែងបច្ចយាការក្នុងកុសលចិត្តជាដើម ដោយន័យនេះឯង ទើបផ្តើមពាក្យជាដើមថា **កតមេ ធម្មា កុសលា** ដូច្នេះ ។

ក្នុងអកុសលចិត្ត ទ្រង់តាំងមាតិកាមុនហើយ ទ្រង់ធ្វើនិទ្ទេសខាងក្រោយដោយប្រការណា តែក្នុងកុសលនិទ្ទេសនេះ ទ្រង់មិនបានធ្វើដោយប្រការដូច្នោះ ព្រោះហេតុអ្វី ព្រោះការផ្សេងគ្នា ក្នុងវារៈពោលដោយអប្បនា ព្រោះថា ក្នុងលោកិយកុសលចិត្តជាដើម មានពាក្យសរុប ដោយព្រះបាលីថា **ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស** ព្រោះធម៌ទាំងនោះ ទាក់ទងក្នុងទុក្ខសច្ច ក្នុងលោកុត្តរកុសលជាដើម មានពាក្យសរុប ដោយព្រះបាលីថា **ឯវមេតេសំ ធម្មានំ** ព្រោះហេតុនោះ ក្នុងកុសលជាដើមនេះ ទើបទ្រង់មិនតាំងមាតិកាដោយសាធារណៈ ទើបទ្រង់លើកមាតិកានៃកុសលជាដើមនោះៗ ឡើងសម្តែងតែម្យ៉ាង ហើយទ្រង់ធ្វើនិទ្ទេស ។ ក្នុងកុសលទាំងនោះ ព្រោះមិនមានអវិជ្ជារួមជាមួយកុសលសង្ខារ ក្នុងខណៈនៃចិត្តដូចជាមួយគ្នា ហេតុ

នោះ ទើបមិនត្រាស់អវិជ្ជានោះ តែត្រាស់កុសលមូល ជាឫសគល់នៃកុសលទាំងឡាយ ដូចត្រាស់អវិជ្ជាជាឫសគល់នៃអកុសលទាំងឡាយ និងព្រោះតណ្ហា ឧបាទាន មិនមាន បសាទ ( សទ្ធា ) ដែលឈមចុះខាងក្នុងអារម្មណ៍ដូចតណ្ហា ទើបត្រាស់ក្នុងទីតាំងនៃតណ្ហា អធិមោក្ខ ឈ្មោះថា ការសម្រេចចិត្តយ៉ាងមាំទាំ ដូចគ្នានឹងឧបាទាន ទើបត្រាស់ក្នុងឋានៈនៃឧបាទាន ពាក្យដ៏សេស គប្បីជ្រាបដោយន័យដែលពោលខាងដើមនោះឯងដូច្នេះ ៕

## កុសលនិទ្ទេស ចប់

# អភិធម្មបិដក

## អព្យាកតនិទ្ទេស

[ ១១៨ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា ចក្ខុវិញ្ញាណជាវិបាក ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ កើតឡើង ព្រោះភាពនៃកាមាវចរកុសលកម្ម ដែលសត្វធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ភព កើតមាន ព្រោះវេទនាជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១១៩ ] បណ្តាបច្ចយាការទាំងនោះ សង្ខារ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ ។ បណ្តាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្តេច ។ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ ចក្ខុវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តី

ប្រាថ្នា ។បេ។ ចក្ខុវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ តើដូចម្ដេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា នេះហៅថា ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្ដេច ។ សេចក្ដីត្រេកអរក៏មិនមែន សេចក្ដីមិនត្រេកអរក៏មិនមែន ដែលប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ មិនជាទុក្ខ មិនជាសុខ ដែលកើតអំពីចេតោសម្ផស្ស អទុក្ខមសុខវេទនា ដែលកើតអំពីចេតោសម្ផស្សណា នេះហៅថា វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ ភព កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្ដេច ។ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ លើកតែវេទនាចេញ នេះហៅថា ភព កើតមាន ព្រោះវេទនាជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១២០ ] ក្នុងសម័យនោះ វិញ្ញាណ មានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម មានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ មាននាមជាហេតុ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ មានអាយតនៈទី ៦ ជាហេតុ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា មានផស្សៈជាហេតុ កើតមាន ព្រោះផស្សៈជាបច្ច័យ ភព កើតមាន ព្រោះវេទនាជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា

និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១២១ ] ក្នុងសម័យនោះ វិញ្ញាណ ប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម ប្រកបដោយវិញ្ញាណ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ ប្រកបដោយនាម កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ ប្រកបដោយអាយតនៈទី ៦ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា ប្រកបដោយផស្សៈ កើតមាន ព្រោះផស្សៈជាបច្ច័យ ភព កើតមាន ព្រោះវេទនាជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១២២ ] ក្នុងសម័យនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ សង្ខារ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះនាមជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ នាម កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះផស្សៈជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ផស្សៈ កើតមាន ព្រោះវេទនាជាបច្ច័យ ភព កើតមាន ព្រោះវេទនាជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១២៣ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា សោតវិញ្ញាណជាវិបាក ប្រកបដោយឧបេក្ខា មានសំឡេងជាអារម្មណ៍ កើតឡើង ព្រោះភាពនៃកាមាវចរកុសលកម្ម ដែលសត្វធ្វើហើយ សន្សំហើយ ។បេ។ ឃានវិញ្ញាណ ប្រកបដោយឧបេក្ខា កើតឡើង ។បេ។ ជិវ្ហាវិញ្ញាណ ប្រកបដោយឧបេក្ខា មានរសជាអារម្មណ៍ កើតឡើង ។បេ។ កាយវិញ្ញាណ ប្រកបដោយសុខ មានផ្សព្វជាអារម្មណ៍ កើតឡើង ក្នុងសម័យនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ភព កើតមាន ព្រោះវេទនាជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១២៤ ] បណ្តាបច្ចយាការទាំងនោះ សង្ខារ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ ។បេ។ បណ្តាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្តេច ។ សេចក្តីត្រេកអរ ប្រព្រឹត្តទៅក្នុងកាយ សេចក្តីសុខ ប្រព្រឹត្តទៅក្នុងកាយ ការទទួលអារម្មណ៍ ជាទីត្រេកអរជាសុខ ដែលកើតអំពីកាយសម្ផស្ស សុខវេទនា ជាទីត្រេកអរ ដែលកើតអំពីកាយសម្ផស្ស នេះហៅថា វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ ភព កើតមាន

ព្រោះវេទនាជាបច្ច័យ តើដូចម្តេច ។ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ លើកតែវេទនាចេញ នេះហៅថា ភព កើតមាន ព្រោះវេទនាជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១២៥ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា មនោធាតុជាវិបាក ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ក្តី ។បេ។ មានផ្សព្វជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាមួយ ហើយកើតឡើង ព្រោះភាពនៃកាមាវចរកុសលកម្ម ដែលសត្វធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះវេទនាជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១២៦ ] បណ្តាបច្ចយាការទាំងនោះ សង្ខារ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ ។ បណ្តាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោធាតុ ដែលកើត

អំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។បេ។ បណ្ដាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្ដេច ។ សេចក្ដីត្រេកអរក៏មិនមែន សេចក្ដីមិនត្រេកអរក៏មិនមែន ដែលប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ មិនជាទុក្ខ មិនជាសុខ ដែលកើតអំពីចេតោសម្ផស្ស អទុក្ខមសុខវេទនា ដែលកើតអំពីចេតោសម្ផស្សណា នេះហៅថា វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ។ បណ្ដាធម៌ទាំងនោះ អធិមោក្ខ កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្ដេច ។ ការចុះស៊ប់ អាការចុះស៊ប់ ភាពចុះស៊ប់នៃចិត្តក្នុងអារម្មណ៍នោះណា នេះហៅថា អធិមោក្ខ កើតមាន ព្រោះវេទនាជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ ភព កើតមាន ព្រោះអធិមោក្ខ ជាបច្ច័យ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ លើកតែអធិមោក្ខចេញ នេះហៅថា ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១២៧ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ ក្នុងសម័យណា មនោវិញ្ញាណធាតុជាវិបាក ប្រកបដោយសោមនស្ស មានរូបជាអារម្មណ៍ក្ដី ។បេ។ មានធម៌ជាអារម្មណ៍ក្ដី ឬក៏ប្រារព្ធនូវអារម្មណ៍ណាមួយ ហើយកើតឡើង ព្រោះភាពនៃកាមាវចរកុសលកម្ម ដែលសត្វធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជា

បច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះវេទនាជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១២៨ ] បណ្តាបច្ចយាការទាំងនោះ សង្ខារ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ ។ បណ្តាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។បេ។ បណ្តាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្តេច ។ សេចក្តីត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ជាទីត្រេកអរ ជាសុខ ដែលកើតអំពីចេតោសម្ផស្ស សុខវេទនាជាទីត្រេកអរ ដែលកើតអំពីចេតោសម្ផស្សណា នេះហៅថា វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ។ បណ្តាធម៌ទាំងនោះ អធិមោក្ខ កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្តេច ។ ការចុះស៊ប់ អាការចុះស៊ប់ ភាពចុះស៊ប់នៃចិត្តក្នុងអារម្មណ៍នោះណា នេះហៅថា អធិមោក្ខ កើតមាន ព្រោះវេទនាជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ

វិញ្ញាណក្ខន្ធ លើកតែអធិមោក្ខចេញ នេះហៅថា ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១២៩ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា មនោវិញ្ញាណធាតុជាវិបាក ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាមួយ ហើយកើតឡើង ព្រោះភាពនៃកាមាវចរកុសលកម្ម ដែលសត្វធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះវេទនាជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៣០ ] បណ្តាបច្ចយាការទាំងនោះ សង្ខារ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ ។ បណ្តាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារ

ជាបច្ច័យ ។បេ។ បណ្តាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្តេច ។ សេចក្តីត្រេកអរក៏មិនមែន សេចក្តីមិនត្រេកអរក៏មិនមែន ដែលប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ មិនជាទុក្ខ មិនជាសុខ ដែលកើតអំពីចេតោសម្ផស្ស អទុក្ខមសុខវេទនា ដែលកើតអំពីចេតោ-សម្ផស្សណា នេះហៅថា វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ។ បណ្តាធម៌ទាំងនោះ អធិមោក្ខ កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្តេច ។ ការចុះស៊ប់ អាការចុះស៊ប់ ភាពចុះស៊ប់នៃចិត្តក្នុងអារម្មណ៍នោះណា នេះហៅថា អធិមោក្ខ កើតមាន ព្រោះវេទនាជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ លើកតែអធិមោក្ខចេញ នេះហៅថា ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៣១ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា មនោវិញ្ញាណធាតុជាវិបាក ប្រកបដោយសោមនស្ស ប្រកបដោយញាណ កើតឡើង ព្រោះភាពនៃកាមាវចរកុសលកម្ម ដែលសត្វធ្វើហើយ សន្សំហើយ ។បេ។ ច្រឡំដោយសោមនស្ស ប្រកបដោយញាណ ប្រកបដោយសង្ខារ ។បេ។ ច្រឡំដោយសោមនស្ស ប្រាសចាកញាណ ។បេ។ ច្រឡំដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសង្ខារ ។បេ។ ច្រឡំដោយឧបេក្ខា ប្រកបដោយញាណ ។បេ។ ច្រឡំដោយឧបេក្ខា ប្រកបដោយ

ញាណ ប្រកបដោយសង្ខារ ។បេ។ ប្រទ្បំដោយឧបេក្ខា ប្រាសចាកញាណ ។បេ។ ប្រទ្បំដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាមួយ ហើយកើតឡើង ក្នុងសម័យនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៣២ ] បណ្តាបច្ចយាការទាំងនោះ សង្ខារ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ ។ បណ្តាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។បេ។ បណ្តាធម៌ទាំងនោះ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្តេច ។ សទ្ធា ការជឿ ការជឿជាក់ សេចក្តីជ្រះថ្លាដ៏ក្រៃលែង ណា នេះហៅថា បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ ។ បណ្តាធម៌

ទាំងនោះ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ តើដូចម្តេច ។ ការចុះស៊ប់ អាការចុះស៊ប់ ភាពចុះស៊ប់នៃចិត្តក្នុងអារម្មណ៍នោះណា នេះហៅថា អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ លើកតែអធិមោក្ខចេញ នេះហៅថា ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៣៣ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា បុគ្គលចម្រើននូវមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន មានបឋវីកសិណ ( ជាអារម្មណ៍ ) ក្នុងសម័យនោះ ផស្សៈក៏មាន ។បេ។ អវិក្ខេបៈ ( សេចក្តីមិនរាយមាយ ) ក៏មាន ធម៌ទាំងនេះជាកុសល បុគ្គលស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន មានបឋវីកសិណ ( ជាអារម្មណ៍ ) ជាវិបាក ព្រោះភាពនៃរូបាវចរកុសលកម្មនោះឯង ដែលខ្លួនធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះ

ភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៣៤ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា បុគ្គលចម្រើននូវមគ្គ ដើម្បីកើតក្នុងអរូបភព កន្លងនូវអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង ដែលប្រឡំដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ព្រោះលះបង់សុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះជាកុសល បុគ្គលកន្លងនូវអាកិញ្ចញ្ញាយតនៈជាវិបាក ព្រោះភាពនៃអរូបាវចរកុសលកម្មនោះឯង ដែលសត្វធ្វើហើយសន្សំហើយ ដោយប្រការទាំងពួង ដែលប្រឡំដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ព្រោះលះបង់សុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ក្នុងសម័យនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈកើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៣៥ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកៈ ជាគ្រឿងដល់នូវការមិនសន្សំ

ដើម្បីលះបង់នូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទា ទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈក៏មាន ។បេ។ អវិក្ខេបៈក៏មាន ធម៌ទាំងនេះជាកុសល បុគ្គលស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈានជាវិបាក ជាទុក្ខាបដិបទា ទន្ធាភិញ្ញា ជាសុញ្ញតៈ ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលខ្លួនធ្វើហើយ ចម្រើនហើយ ក្នុងសម័យនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃធម៌ទាំងនុ៎ះ រមែងមានដោយអាការយ៉ាងនេះ ។

[ ១៣៦ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ ក្នុងសម័យណា ចក្ខុវិញ្ញាណជាវិបាក ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ កើតឡើងហើយ ព្រោះភាពនៃអកុសលកម្ម ដែលសត្វធ្វើហើយ សន្សំហើយ ។បេ។ សោតវិញ្ញាណ ប្រកបដោយឧបេក្ខា មានសំឡេងជាអារម្មណ៍ កើតឡើង ។បេ។ ឃានវិញ្ញាណ ប្រកបដោយឧបេក្ខា មានក្លិនជាអារម្មណ៍ កើតឡើង ។បេ។ ជិវ្ហាវិញ្ញាណ ប្រកបដោយឧបេក្ខា មានរសជាអារម្មណ៍ កើតឡើង ។បេ។

កាយវិញ្ញាណ ប្រកបដោយទុក្ខ មានផ្សព្វជាអារម្មណ៍កើតឡើង ក្នុងសម័យនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ភព កើតមាន ព្រោះវេទនាជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៣៧ ] បណ្តាបច្ចយាការទាំងនោះ សង្ខារ តើដូចម្តេច ។ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ ។ បណ្តាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ កាយវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។បេ។ បណ្តាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្តេច ។ សេចក្តីមិនត្រេកអរ ប្រព្រឹត្តទៅក្នុងកាយ សេចក្តីទុក្ខ ប្រព្រឹត្តទៅក្នុងកាយ ការទទួលអារម្មណ៍ មិនជាទីត្រេកអរ ជាទុក្ខ ដែលកើតអំពីកាយសម្ផស្ស ទុក្ខវេទនា មិនជាទីត្រេកអរ ដែលកើតអំពីកាយសម្ផស្សណា នេះហៅថា វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ ភព កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្តេច ។ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ លើកតែវេទនាចេញ នេះហៅថា ភព

កើតមាន ព្រោះវេទនាជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៣៨ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ ក្នុងសម័យណា មនោធាតុជាវិបាក ប្រទាំដោយឧបេក្ខា មានរូបជាអារម្មណ៍ក្ដី ។បេ។ មានផ្សព្វជាអារម្មណ៍ក្ដី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ព្រោះភាពនៃអកុសលកម្ម ដែលសត្វធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះវេទនាជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៣៩ ] បណ្ដាបច្ចយាការទាំងនោះ សង្ខារ តើដូចម្ដេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ ។ បណ្ដាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោធាតុដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។បេ។ បណ្ដាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ

តើដូចម្តេច ។ សេចក្តីត្រេកអរ ក៏មិនមែន សេចក្តីមិនត្រេកអរ ក៏មិនមែន ដែលប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ មិនជាទុក្ខ មិនជាសុខ ដែលកើតអំពីចេតោសម្ផស្ស អទុក្ខមសុខវេទនា ដែលកើតអំពីចេតោសម្ផស្ស ណា នេះហៅថា វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ។ បណ្តាធម៌ទាំងនោះ អធិមោក្ខ កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្តេច ។ ការចុះស៊ប់ អាការចុះស៊ប់ ភាពចុះស៊ប់នៃចិត្តក្នុងអារម្មណ៍នោះណា នេះហៅថា អធិមោក្ខ កើតមាន ព្រោះវេទនាជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ លើកតែអធិមោក្ខចេញ នេះហៅថា ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៤០ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា មនោវិញ្ញាណធាតុជាវិបាក ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ព្រោះភាពនៃអកុសលកម្ម ដែលសត្វធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះវេទនាជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខ

ជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៤១ ] បណ្តាបច្ចយាការទាំងនោះ សង្ខារ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ ។ បណ្តាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារ ជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃ កងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៤២ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា មនោធាតុ គ្រាន់តែជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិន មែនជាកម្មវិបាក ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ក្តី ។បេ។ មានផ្សព្វ ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាមួយ ហើយកើតឡើង ។បេ។ មនោវិញ្ញាណធាតុ គ្រាន់តែជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនកម្មវិបាក ប្រកបដោយសោមនស្ស មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ។បេ។ មនោវិញ្ញាណធាតុ គ្រាន់តែជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនកម្មវិបាក ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ក្តី ។បេ។

មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះវេទនាជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៨៣ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា មនោវិញ្ញាណធាតុ គ្រាន់តែជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនកម្មវិបាក ប្រកបដោយសោមនស្ស ប្រកបដោយញាណ កើតឡើង ។បេ។ ប្រកបដោយសោមនស្ស ប្រកបដោយញាណ ប្រកបដោយសង្ខារ ។បេ។ ប្រកបដោយសោមនស្ស ប្រាសចាកញាណ ។បេ។ ប្រកបដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសង្ខារ ។បេ។ ប្រកបដោយឧបេក្ខា ប្រកបដោយញាណ ។បេ។ ប្រកបដោយឧបេក្ខា ប្រកបដោយញាណ ប្រកបដោយសង្ខារ ។បេ។ ប្រកបដោយឧបេក្ខា ប្រាសចាកញាណ ។បេ។ ប្រកបដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារ

ជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៨៤ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា បុគ្គលចម្រើននូវរូបាវចរជ្ឈាន ជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនកម្មវិបាក មានការនៅជាសុខ ក្នុងបច្ចុប្បន្ន ស្ងប់ស្ងាត់ចាកកាម ទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន មានបឋវីកសិណ ( ជាអារម្មណ៍ ) ក្នុងសម័យនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈ ជាបច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៨៥ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា

បុគ្គលចម្រើននូវអរូបាវចរជ្ឈាន ដែលជាកិរិយា មិនមែនកុសល មិនមែន អកុសល ទាំងមិនមែនកម្មវិបាក មានការនៅជាសុខ ក្នុងបច្ចុប្បន្ន កន្លង នូវអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង ដែលប្រកបដោយនេវសញ្ញានា-សញ្ញាយតនសញ្ញា ព្រោះលះបង់សុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ក្នុង សម័យនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជា បច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះ បសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុ ជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

អព្យាកតនិទ្ទេស ចប់

# អដ្ឋកថា

## អព្យាកតនិទ្ទេស

[ ១១៨-១៤៥ ] ចិត្តដែលជាអព្យាកត ទ្រង់ចែកដោយលំដាប់ ដែលមកក្នុងចិត្តុប្បាទកណ្ឌខាងដើមហើយនោះឯង ក្នុងវារៈទាំងអស់ ទ្រង់បន្ថយន័យ មានអវិជ្ជាជាមូល ព្រោះហេតុអ្វី ព្រោះមិនមានធម៌ដែលគួរតាំងទុកក្នុងឋានៈនៃអវិជ្ជា ។ ពិតហើយ ក្នុងកុសលចិត្តទាំងឡាយ មានកុសលមូលដែលគប្បីតាំងទុកក្នុងឋានៈនៃអវិជ្ជា ក្នុងអហេតុកចិត្ត មានចក្ខុវិញ្ញាណជាដើម ក៏មិនមាន តែក្នុងសហេតុកចិត្តទាំងឡាយ ទោះបីមានកុសលមូល កាលបើដូច្នោះ ក្នុងអព្យាកតនិទ្ទេសនេះ ទ្រង់ក៏មិនកាន់យកកុសលមូលក្នុងសហេតុកចិត្តនោះ ទ្រង់មិនកាន់យកកុសលមូល ក្នុងសហេតុកចិត្តនោះ ព្រោះទ្រង់កាត់កុសលមូលចេញ ក្នុងក្រសែនៃវិញ្ញាណ ៥ គប្បីជ្រាបថា ទ្រង់ធ្វើទេសនាឲ្យធ្លាក់ទៅតាមក្រសែនោះឯង គឺសម្តែងដោយលំដាប់ ។

ម្យ៉ាងទៀត ពោលដោយការផ្សេងគ្នាក្នុងអព្យាកតនិទ្ទេសនេះ ទ្រង់បន្ថយឋានៈនៃតណ្ហា និងឋានៈនៃឧបាទានក្នុងអហេតុកចិត្ត មានចក្ខុវិញ្ញាណជាដើម ព្រោះហេតុអ្វី ព្រោះមិនមានធម៌ដែលមានកម្លាំង ដែលគួរដល់ឋានៈនៃតណ្ហា និងព្រោះវៀរចាកអធិមោក្ខ តែក្នុងអហេតុកចិត្តដ៏សេស ទ្រង់បន្ថយឋានៈនៃតណ្ហាប៉ុណ្ណោះ ។

ក្នុងសហេតុកចិត្តទាំងឡាយ ទ្រង់បន្ថែមបទបសាទក្នុងទីនៃតណ្ហា ព្រោះជាសភាវៈនៃការផូរផង់ ។ បណ្ដាអព្យាកតទាំងនេះ ក្នុងអហេតុកចិត្ត មានចក្ខុវិញ្ញាណជាដើម ដែលជាកុសលវិបាក និងអកុសលវិបាក គប្បីជ្រាបន័យ

នីមួយៗ ៦ ដែលមានសង្ខារ វិញ្ញាណ នាម ឆដ្ឋាយតនៈ ផស្សៈ និង វេទនាជាមូល ក្នុងអហេតុកចិត្តដ៏សេស គប្បីជ្រាបថា មានន័យនីមួយៗ ៧ ជាមួយន័យដែលមានអធិមោក្ខជាមូល ។ ចំណែកក្នុងសហេតុកចិត្តទាំងឡាយ គប្បីជ្រាបន័យនីមួយៗ ៨ ជាមួយន័យដែលមានបសាទជាមូល ។

បណ្តាអព្យាកតទាំងនោះ ទ្រង់ត្រាស់វារៈខាងដើមរបស់ចតុក្កៈទាំង ៤ តែម្យ៉ាង ក្នុងចក្ខុវិញ្ញាណជាដើម ។ វារៈទី ២ សូម្បីបានដោយអត្ថថា ការផ្សេងគ្នានៃបច្ច័យ ក៏មិនត្រាស់ ។ វារៈទី ៣ និងទី ៤ មិនត្រាស់ ព្រោះមិនមាននោះឯង ។ វារៈទី ៣ ទី ៤ លាយឡំដោយរូប និងចក្ខុវិញ្ញាណជាដើម រមែងញ៉ាំងរូបឲ្យតាំងឡើងមិនបាន សូម្បីក្នុងចតុក្កៈដ៏សេស ក៏បាន ២ វារៈ ដូចក្នុងចតុក្កៈទី ១ ដែលបាន ២ វារៈ ព្រោះហេតុនោះ ទុតិយវារៈក្នុងបឋមចតុក្កៈ និងវារៈក្នុងចតុក្កៈដ៏សេស ចតុក្កៈនីមួយៗ ២ វារៈ សូម្បីមិនបានត្រាស់ គប្បីជ្រាបថា ត្រាស់ហើយនោះឯង ។ ក្នុងអព្យាកតអហេតុកៈដ៏សេស បានវារៈទាំងពួង ក្នុងចតុក្កៈទាំងអស់ តែព្រោះកាត់ចេញ ក្នុងអហេតុកអព្យាកត មានចក្ខុវិញ្ញាណជាដើមនេះ ទើបទ្រង់មិនប្រារព្ធខាងមុខ ។ ទេសនាដែលធ្លាក់ទៅតាមក្រសែ ទ្រង់ធ្វើហើយដោយប្រការដូច្នេះ ។ ក្នុងសហេតុកវិបាកដ៏សេស វៀរអរូបាវចរវិបាក ក៏មានន័យនេះដូចគ្នា ព្រោះក្នុងអរូបាវចរវិបាក បាន ២ វារៈប៉ុណ្ណោះ ដូច្នេះ ។

**អព្យាកតនិទ្ទេស ចប់**

# អភិធម្មបិដក

## អវិជ្ជាមូលកកុសលនិទ្ទេស

[ ១៤៦ ] ពួកធម៌ជាកុសល តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រឡំដោយសោមនស្ស ប្រកបដោយញាណ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៤៧ ] បណ្តាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។បេ។ បណ្តាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្តេច ។ សេចក្តីត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ ជាទីត្រេកអរ ជាសុខ ដែលកើតអំពីចេតោសម្ផស្ស សុខ-វេទនា ជាទីត្រេកអរ ដែលកើតអំពីចេតោសម្ផស្សណា នេះហៅថា វេទនា

កើតមាន ព្រោះផស្សៈជាបច្ច័យ ។ បណ្ដាធម៌ទាំងនោះ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្ដេច ។ សទ្ធា ការជឿជាក់ ការជឿស៊ប់ សេចក្ដីជ្រះថ្លាដ៏ក្រៃលែងណា នេះហៅថា បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ ។ បណ្ដាធម៌ទាំងនោះ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ តើដូចម្ដេច ។ ការចុះស៊ប់ អាការចុះស៊ប់ ភាពចុះស៊ប់នៃចិត្ត ក្នុងអារម្មណ៍នោះណា នេះហៅថា អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ លើកតែអធិមោក្ខចេញ នេះហៅថា ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៤៨ ] ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ផស្សៈ កើតមាន ព្រោះនាមជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៤៩ ] ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម និងរូប កើតមាន ព្រោះ

វិញ្ញាណ ជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាម និងរូបជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៥០ ] ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម និងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈ ៦ កើតមាន ព្រោះនាម និងរូបជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៥១ ] ពួកធម៌ជាកុសល តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស ប្រកបដោយញាណ ប្រកបដោយសង្ខារកើតឡើង ។បេ។ ច្រឡំដោយសោមនស្ស ប្រាសចាកញាណ ។បេ។ ច្រឡំដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសង្ខារ ។បេ។ ច្រឡំដោយឧបេក្ខា ប្រកបដោយញាណ ។បេ។ ច្រឡំដោយឧបេក្ខា ប្រកបដោយ

ញាណ ប្រកបដោយសង្ខារ ។បេ។ ប្រកបដោយឧបេក្ខា ប្រាសចាកញាណ ។បេ។ ប្រកបដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៥២ ] ពួកធម៌ជាកុសល តើដូចម្តេច ។ ក្នុងសម័យណា បុគ្គលចម្រើននូវមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន មានបឋវីកសិណ ( ជាអារម្មណ៍ ) ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារ ជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខ

ជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៥៣ ] ពួកធម៌ជាកុសល តើដូចម្ដេច ។ ក្នុងសម័យណា បុគ្គល ចម្រើននូវមគ្គ ដើម្បីកើតក្នុងអរូបភព កន្លងនូវអាកិញ្ចញ្ញាយតនៈ ដោយប្រការ ទាំងពួង ដែលប្រកបដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ព្រោះលះបង់នូវ សុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះ អវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជា បច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះ បសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុ ជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៥៤ ] ពួកធម៌ជាកុសល តើដូចម្ដេច ។ ក្នុងសម័យណា បុគ្គល ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដ ) ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទា ទន្ធាភិញ្ញា ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ

នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃធម៌ទាំងនុ៎ះ រមែងមាន ដោយអាការយ៉ាងនេះឯង ។

**អវិជ្ជាមូលកកុសលនិទ្ទេស ចប់**

[ ១៥៥ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា ចក្ខុវិញ្ញាណជាវិបាក ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ កើតឡើង ព្រោះភាពនៃកាមាវចរកុសលកម្ម ដែលសត្វធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ភព កើតមាន ព្រោះវេទនាជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៥៦ ] បណ្តាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ )

ណា នេះហៅថា សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៥៧ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា សោតវិញ្ញាណជាវិបាក ប្រកបដោយឧបេក្ខា មានសំឡេងជាអារម្មណ៍ កើតឡើង ព្រោះភាពនៃកាមាវចរកុសលកម្ម ដែលសត្វធ្វើហើយ សន្សំហើយ ។បេ។ ឃានវិញ្ញាណ ប្រកបដោយឧបេក្ខា មានក្លិនជាអារម្មណ៍ កើតឡើង ។បេ។ ជិវ្ហាវិញ្ញាណ ប្រកបដោយឧបេក្ខា មានរសជាអារម្មណ៍ កើតឡើង ។បេ។ កាយវិញ្ញាណ ប្រកបដោយសុខ មានផ្សព្វជាអារម្មណ៍ កើតឡើង ។បេ។ មនោធាតុ ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ក្តី ។បេ។ មានផ្សព្វជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ។បេ។ មនោវិញ្ញាណធាតុ ប្រកបដោយសោមនស្ស មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ។បេ។ មនោវិញ្ញាណធាតុ ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះ

វេទនាជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៥៨ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា មនោវិញ្ញាណធាតុជាវិបាក ច្រឡំដោយសោមនស្ស ប្រកបដោយញាណ កើតឡើង ព្រោះភាពនៃកាមាវចរកុសលកម្ម ដែលសត្វធ្វើហើយ សន្សំហើយ ។បេ។ ច្រឡំដោយសោមនស្ស ប្រកបដោយញាណ ប្រកបដោយសង្ខារ ។បេ។ ច្រឡំដោយសោមនស្ស ប្រាសចាកញាណ ។បេ។ ច្រឡំដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសង្ខារ ។បេ។ ច្រឡំដោយឧបេក្ខា ប្រកបដោយញាណ ។បេ។ ច្រឡំដោយឧបេក្ខា ប្រកបដោយញាណ ប្រកបដោយសង្ខារ ។បេ។ ច្រឡំដោយឧបេក្ខា ប្រាសចាកញាណ ។បេ។ ច្រឡំដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន

ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៥៩ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ ក្នុងសម័យណា បុគ្គលចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន មានបឋវីកសិណ ( ជាអារម្មណ៍ ) ក្នុងសម័យនោះ ផស្សៈក៏មាន ។បេ។ អវិក្ខេបៈ ក៏មាន ធម៌នេះជាកុសល បុគ្គលស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈានជាវិបាក មានបឋវីកសិណជាអារម្មណ៍ ព្រោះភាពនៃរូបាវចរកុសលកម្មនោះឯង ដែលខ្លួនធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៦០ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ ក្នុងសម័យណា បុគ្គលចម្រើនមគ្គ ដើម្បីកើតក្នុងអរូបភព កន្លងនូវអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង ដែលប្រឡំដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ព្រោះលះបង់នូវ

សុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ក្នុងសម័យនោះ ផស្សៈ ក៏មាន ។បេ។ អវិក្ខេបៈ ក៏មាន ធម៌ទាំងនេះជាកុសល បុគ្គលកន្លងនូវអាកិញ្ចញ្ញាយតនៈជាវិបាក ដែលប្រកបដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ដោយប្រការទាំងពួង ព្រោះភាពនៃអរូបាវចរកុសលនោះឯង ដែលខ្លួនធ្វើហើយ សន្សំហើយ ព្រោះលះបង់នូវសុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៦១ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា បុគ្គលចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្តៈ ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទា ទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈ ក៏មាន ។បេ។ អវិក្ខេបៈ ក៏មាន ធម៌ទាំងនេះជាកុសល បុគ្គលស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈានជាវិបាក ជា

ទុក្ខាបដិបទា ទន្ធាភិញ្ញា ជាសុញ្ញតៈ ព្រោះភាពនៃលោកុត្តរកុសលជ្ឈាន នោះឯង ដែលខ្លួនធ្វើហើយ ចម្រើនហើយ ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជា បច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ បសាទ កើតមាន ព្រោះវេទនាជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះបសាទជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះ ជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃធម៌ទាំងនុ៎ះ រមែងមាន ដោយ អាការយ៉ាងនេះ ។

កុសលមូលកវិបាកនិទ្ទេស ចប់

# អដ្ឋកថា

## អវិជ្ជាមូលកកុសលនិទ្ទេស

[ ១៤៦-១៦១ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់បំណងនឹងសម្តែងបច្ចយាការក្នុងខណៈនៃចិត្តមួយដោយបរិយាយដទៃ ទើបទ្រង់ផ្តើមជាដើមថា **កតមេ ធម្មា កុសលា** ដូច្នេះ ។

ក្នុងព្រះបាលីនោះ បទថា **អវិជ្ជាបច្ចយា** នេះ ត្រាស់សំដៅយកភាពជាឧបនិស្សយប្បច្ច័យ ដោយហេតុនោះ ទើបក្នុងនិទ្ទេសវារ ទ្រង់មិនបានចែកថា ក្នុងបច្ចយាការនោះ អវិជ្ជា តើដូចម្តេច ទ្រង់ចែកថា បណ្តាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្តេច ។ ព្រោះសង្ខារ ពោល គឺកុសលចេតនាតែម៉្យាងប៉ុណ្ណោះ កើតរួមជាមួយនឹងចិត្តក្នុងសម័យនោះ មិនមែនអវិជ្ជាឡើយ ។

ក្នុងព្រះបាលីនោះ អវិជ្ជាជាបច្ច័យដល់លោកិយកុសល ដោយន័យដែលពោលក្នុងសុត្តន្តភាជនីយនោះឯង ព្រោះបុគ្គលដែលមិនទាន់លះអវិជ្ជាបាន ទើបចម្រើនលោកុត្តរកុសលដើម្បីលះអវិជ្ជា ហេតុនោះ សង្ខារ គឺកុសលចេតនានោះ ទើបជាបច្ច័យបាន ដោយអំណាចការឈានកន្លងអវិជ្ជានោះ ។ ពិតហើយ កាលបុគ្គលនៅមានអវិជ្ជានោះឯង ទើបមានការប្រកបកុសល ការប្រកបកុសលរបស់បុគ្គលក្រៅអំពីនេះ មិនមាន ។ ក្នុងការប្រកបកុសលនោះ រមែងបាននូវការប្រកបកុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយអំណាចនៃការវង្វេងខ្លះ ដោយអំណាចនៃការចម្រើន ដើម្បីឈានកន្លងខ្លះ ។ រមែងបានការប្រកបលោកុត្តរកុសល ដោយអំណាចភាវនា ដើម្បី

កាត់ផ្តាច់ដូច្នេះ ។ ពាក្យដ៏សេស មានន័យតាមដែលពោលហើយនោះឯង ។

ចំណែកការផ្សេងគ្នា មានដូច្នេះថា ក្នុងកុសលនីមួយៗ ខាងដើម បាន កុសលពួកជប់ប្រាំមួយ ៩ ពួក ដោយអំណាចចតុក្កៈ ៤ ក្នុងទីនេះ មិន បានយ៉ាងនោះ ព្រោះហេតុអ្វី ព្រោះអវិជ្ជា មិនជាអវិគតប្បច្ច័យ សម្ប-យុត្តប្បច្ច័យ និងអញ្ញមញ្ញប្បច្ច័យ ។ ក្នុងកុសល មានអវិជ្ជាជាមូលនេះ រមែងបាននូវចតុក្កៈទី ១ ប៉ុណ្ណោះ ដោយអំណាចឧបនិស្សយប្បច្ច័យ សូម្បី ចតុក្កៈទី ១ នោះ ក៏ទ្រង់សម្តែងសង្ខេបចំពោះ ១ វារៈប៉ុណ្ណោះ តែបណ្ឌិត គួរនាំចេញសម្តែង ដូច្នេះឯង ។៕

## អវិជ្ជាមូលកកុសលនិទ្ទេស ចប់

# អភិធម្មបិដក

## កុសលមូលកវិបាកនិទ្ទេស

[ ១៦២ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា ចក្ខុ-វិញ្ញាណជាវិបាក ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ កើតឡើង ព្រោះភាពនៃអកុសលកម្មដែលសត្វធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអកុសលមូលជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ភព កើតមាន ព្រោះវេទនាជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៦៣ ] បណ្តាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះអកុ-សលមូលជាបច្ច័យ តើដូចម្តេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ កើតមាន ព្រោះអកុសលមូលជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៦៤ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា សោតវិញ្ញាណជាវិបាក ប្រកបដោយឧបេក្ខា មានសំឡេងអារម្មណ៍ កើតឡើង ព្រោះភាពនៃអកុសលកម្ម ដែលសត្វធ្វើហើយ សន្សំហើយ ។បេ។ ឃាន-វិញ្ញាណ ប្រកបដោយឧបេក្ខា មានក្លិនជាអារម្មណ៍ កើតឡើង ។បេ។ ជិវ្ហា-

វិញ្ញាណ ប្រឡំដោយឧបេក្ខា មានរសជាអារម្មណ៍ កើតឡើង ។បេ។ កាយ-វិញ្ញាណ ប្រឡំដោយទុក្ខ មានផ្សព្វជាអារម្មណ៍ កើតឡើង ។បេ។ មនោធាតុ ប្រឡំដោយឧបេក្ខា មានរូបជាអារម្មណ៍ក្តី ។បេ។ មានផ្សព្វជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអកុសលមូលជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះវេទនាជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៦៥ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ក្នុងសម័យណា មនោ-វិញ្ញាណធាតុជាវិបាក ប្រឡំដោយឧបេក្ខា មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ព្រោះភាពនៃអកុសលកម្ម ដែលសត្វធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអកុសលមូលជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះវេទនាជាបច្ច័យ

ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ១៦៦ ] បណ្ដាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះអកុសលមូលជាបច្ច័យ តើដូចម្ដេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ ( នូវអារម្មណ៍ ) ណា នេះហៅថា សង្ខារ កើតមាន ព្រោះអកុសលមូលជាបច្ច័យ ។

[ ១៦៧ ] បណ្ដាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។

[ ១៦៨ ] បណ្ដាបច្ចយាការទាំងនោះ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។

[ ១៦៩ ] បណ្ដាបច្ចយាការទាំងនោះ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ។

[ ១៧០ ] បណ្ដាបច្ចយាការទាំងនោះ ផស្សៈ កើតមាន ព្រោះ

អាយតនៈទី ៦ ជាបច្ច័យ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា នេះហៅថា ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ។

[ ១៧១ ] បណ្តាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈ ជាបច្ច័យ តើដូចម្តេច ។ សេចក្តីត្រេកអរ ក៏មិនមែន សេចក្តីមិនត្រេកអរ ក៏មិនមែន ដែលប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ មិនជាទុក្ខ មិនជាសុខ ដែលកើតអំពីចេតោសម្ផស្ស អទុក្ខមសុខវេទនា ដែលកើតអំពីចេតោសម្ផស្ស ណា នេះហៅថា វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ។

[ ១៧២ ] បណ្តាធម៌ទាំងនោះ អធិមោក្ខ កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្តេច ។ ការចុះស៊ប់ អាការចុះស៊ប់ ភាពចុះស៊ប់នៃចិត្ត ក្នុងអារម្មណ៍នោះណា នេះហៅថា អធិមោក្ខ កើតមាន ព្រោះវេទនាជាបច្ច័យ ។

[ ១៧៣ ] បណ្តាបច្ចយាការទាំងនោះ ភព កើតមាន ព្រោះអធិមោក្ខ ជាបច្ច័យ តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ លើកតែអធិមោក្ខចេញ នេះហៅថា ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ។

[ ១៧៤ ] បណ្តាបច្ចយាការទាំងនោះ ជាតិ កើតមាន ព្រោះភពជាបច្ច័យ តើដូចម្តេច ។ ជាតិ ការកើតព្រម ការផ្តួចឡើង ការកើតចំពោះ ការកើតប្រាកដណា នៃធម៌ទាំងនោះ នេះហៅថា ជាតិ កើតមាន ព្រោះភព ជាបច្ច័យ ។

[ ១៧៥ ] បណ្តាបច្ចយាការទាំងនោះ ជរា និងមរណៈ កើតមាន

ព្រោះជាតិជាបច្ច័យ តើដូចម្តេច ។ ជរា ក៏មាន មរណៈ ក៏មាន ។ បណ្តា ជរា និងមរណៈនោះ ជរា តើដូចម្តេច ។ ការចាស់ ការគ្រាំគ្រា ការរួញថយអាយុណា នៃធម៌ទាំងនោះ នេះហៅថា ជរា ។ បណ្តាជរា និង មរណៈនោះ មរណៈ តើដូចម្តេច ។ ការអស់ ការសូន្យ ការបែកធ្លាយ ការបែកខ្ចាត់ខ្ចាយ ការមិនទៀង ការបាត់បង់ណា នៃធម៌ទាំងនោះ នេះហៅថា មរណៈ ។ ជរានេះផង មរណៈនេះផង នេះហៅថា ជរា និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ដោយប្រការដូច្នេះ ។

[ ១៧៦ ] សេចក្តីត្រង់ពាក្យថា ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ដូចតទៅនេះ ។ ការជួបជុំ ការមូលមក ការប្រជុំចុះ ការកើតប្រាកដ នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះឯង ។

*អកុសលមូលកវិបាកនិទ្ទេស ចប់*

*អភិធម្មភាជនីយ ចប់*

*បច្ចយាការវិភង្គ ចប់*

# អដ្ឋកថា

## កុសលមូលកវិបាកនិទ្ទេស

[ ១៦២-១៧៦ ] ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់បំណងសម្ដែងបច្ចយាការក្នុងអព្យាកតទាំងឡាយ ដោយន័យដទៃទៀតនោះឯង ទើបទ្រង់ផ្ដើមពាក្យជាដើមថា **កតមេ ធម្មា អព្យាកតា** ដូច្នេះ ។

ក្នុងព្រះបាលីនោះ បទថា **កុសលមូលបច្ចយា** នេះ ត្រាស់សំដៅយកភាពជាឧបនិស្សយប្បច្ច័យ ពិតហើយ កុសលមូល រមែងជាឧបនិស្សយប្បច្ច័យដល់កុសលវិបាក អកុសលមូលជាឧបនិស្សយប្បច្ច័យដល់អកុសលវិបាក តែមិនគួរពោលដល់នានាខណិកកម្មប្បច្ច័យ ដូច្នោះ បច្ច័យដែលកុសលមូល និងអកុសលនេះ ទើបជាបច្ច័យដោយឧបនិស្សយប្បច្ច័យ និងកម្មប្បច្ច័យដែលកើតផ្សេងខណៈគ្នា ដោយហេតុនោះឯង ទើបក្នុងនិទ្ទេសវារមិនចែកថា ក្នុងបច្ចយាការនោះ កុសលមូល តើដូចម្ដេច ទ្រង់ចែកថា បច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះកុសលមូលជាបច្ច័យ តើដូចម្ដេច ដូច្នេះ ។ ក្នុងអកុសលវិបាក ក៏ន័យនេះដូចគ្នា ។

ម្យ៉ាងទៀត ក្នុងវិបាកនិទ្ទេសនេះ រមែងបានចំពោះនូវបច្ចយចតុក្កៈទី ១ ប៉ុណ្ណោះ ដូចក្នុងនិទ្ទេសនៃអកុសល មានអវិជ្ជាមូល សូម្បីបច្ចយចតុក្កៈនោះក៏ទ្រង់សម្ដែងបឋមវារ ហើយទ្រង់សង្ខេប ព្រោះហេតុនោះ គប្បីជ្រាបប្រភេទនៃវារៈក្នុងន័យដែលមានកុសលជាមូល និងអកុសលជាមូល ដោយចំណាចចតុក្កៈតែមួយចតុក្កៈ ក្នុងវិបាកចិត្តតែមួយដួង តែព្រោះអវិជ្ជាកុសលមូល និងអកុសលមូល រមែងមិនបានភាពជាឧបនិស្សយប្បច្ច័យ

ដល់ធម៌ដែលជាកិរិយា ហេតុនោះ ទើបមិនគួរពោលបច្ចយាការ ដោយអំណាចកិរិយាឡើយ ។

ដោយប្រការដូច្នេះ

ព្រះមានព្រះភាគ ទ្រង់មានវាទៈដ៏ប្រសើរ ត្រាស់បច្ចយាការនេះ ដោយប្រភេទ មិនមែនតិច ក្នុងធម៌ដែលជាអកុសល កុសល និងអព្យាក្រឹត ចំណែកក្នុងវិបាកនៃកុសល និងអកុសល ត្រាស់បច្ចយាការតែម្យ៉ាងប៉ុណ្ណោះ ដោយអំណាចឧបនិស្សយប្បច្ច័យ ដើម្បីការបែកធ្លាយនូវញាណ ក្នុងការផ្សេងគ្នានៃធម៌ដែលជាបច្ច័យ ព្រោះកាលវៀរលំដាប់នៃបរិយត្តិ ការស្តាប់ ការគិត កិច្ចបដិបត្តិ រមែងមិនបែកធ្លាយនូវញាណ ក្នុងបច្ចយាការនេះ រមែងមិនមានក្នុងកាលណាឡើយ ហេតុនោះ អ្នកប្រាជ្ញគួរធ្វើដោយលំដាប់នៃបរិយត្តិ ការស្តាប់ ការគិត និងកិច្ចបដិបត្តិ ក្នុងបច្ចយាការនោះ ក្នុងកាលសព្វកាល ព្រោះកិច្ចដទៃដែលគួរធ្វើក្រៃលែងជាងលំដាប់ គឺការឲ្យកើតនូវការបែកធ្លាយនៃញាណនោះ មិនមាន ដូច្នេះ ។

បច្ចយាការនេះ ទ្រង់នាំចេញចែកសម្តែងជា ២ បរិវដ្តប៉ុណ្ណោះ គឺដោយអំណាចសុត្តន្តភាជនីយ និងអភិធម្មភាជនីយ ដូច្នេះឯង ។៚

**អភិធម្មភាជនីយ ចប់**

**បដិច្ចសមុប្បាទវិភង្គនិទ្ទេស ចប់**

# អភិធម្មបិដក

## សតិប្បដ្ឋានវិភង្គ

[ ១៧៧ ] សតិប្បដ្ឋាន ៤ គឺភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយ ក្នុងកាយខាងក្នុង ពិចារណានូវកាយក្នុងកាយខាងក្រៅ ពិចារណានូវកាយ ក្នុងកាយខាងក្នុង និងខាងក្រៅ សម្រេចឥរិយាបថ មានព្យាយាមជាគ្រឿង ដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី ( ជាគ្រឿងកំណត់ ) កម្ចាត់ បង់អភិជ្ឈា និងទោមនស្ស ក្នុងលោក ១ ។ ភិក្ខុពិចារណានូវវេទនា ក្នុង វេទនាទាំងឡាយខាងក្នុង ពិចារណានូវវេទនា ក្នុងវេទនាទាំងឡាយខាងក្រៅ ពិចារណានូវវេទនា ក្នុងវេទនាទាំងឡាយខាងក្នុង និងខាងក្រៅ សម្រេច ឥរិយាបថ មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មាន ស្មារតី ( ជាគ្រឿងកំណត់ ) កម្ចាត់បង់អភិជ្ឈា និងទោមនស្ស ក្នុងលោក ១ ។ ភិក្ខុពិចារណានូវចិត្ត ក្នុងចិត្តខាងក្នុង ពិចារណានូវចិត្ត ក្នុងចិត្តខាង ក្រៅ ពិចារណានូវចិត្ត ក្នុងចិត្តខាងក្នុង និងខាងក្រៅ សម្រេចឥរិយាបថ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី ( ជា គ្រឿងកំណត់ ) កម្ចាត់បង់អភិជ្ឈា និងទោមនស្ស ក្នុងលោក ១ ។ ភិក្ខុ ពិចារណានូវធម៌ ក្នុងធម៌ទាំងឡាយខាងក្នុង ពិចារណានូវធម៌ ក្នុងធម៌ទាំង ឡាយខាងក្រៅ ពិចារណានូវធម៌ ក្នុងធម៌ទាំងឡាយ ខាងក្នុង និងខាងក្រៅ សម្រេចឥរិយាបថ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី ( ជាគ្រឿងកំណត់ ) កម្ចាត់បង់អភិជ្ឈា និងទោមនស្ស ក្នុង លោក ១ ។

[ ១៧៨ ] ចុះភិក្ខុពិចារណានូវកាយ ក្នុងកាយខាងក្នុង តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយខាងក្នុង ( កាយរបស់ខ្លួន ) គឺខាងលើ តាំងអំពីបាតជើងឡើងទៅ ខាងក្រោម តាំងអំពីចុងសក់ចុះមក ដែលមានស្បែកបិទបាំងជុំវិញ ពេញដោយវត្ថុមិនស្អាត មានប្រការផ្សេងៗ ដូច្នេះថា ក្នុងកាយនេះ មានសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល ទឹកមូត្រ ។ ភិក្ខុនោះ រមែងគប់រក អប់រំ ធ្វើឲ្យច្រើន នូវកាយនោះឲ្យជានិមិត្ត កំណត់ចុះនូវកាយ ដែលខ្លួនកំណត់ទុកដោយល្អ ភិក្ខុនោះ លុះគប់រក អប់រំ ធ្វើឲ្យច្រើន នូវកាយនោះឲ្យជានិមិត្ត កំណត់នូវកាយ ដែលខ្លួនកំណត់ទុកដោយល្អហើយ រមែងប្រមូលមក នូវចិត្តក្នុងកាយខាងក្រៅ ។

[ ១៧៩ ] ចុះភិក្ខុ ពិចារណានូវកាយក្នុងកាយ ខាងក្រៅ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយខាងក្រៅ ( កាយរបស់គេ ) គឺខាងលើ តាំងអំពីបាតជើងឡើងទៅ ខាងក្រោម តាំងអំពីចុងសក់ចុះមក ដែលមានស្បែកបិទបាំងជុំវិញ ពេញដោយវត្ថុមិនស្អាត មានប្រការផ្សេងៗ ដូច្នេះថា ក្នុងកាយរបស់បុគ្គលនោះ មានសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម

ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល ទឹកមូត្រ ។ ភិក្ខុនោះ រមែងគប់រក អប់រំ ធ្វើឲ្យច្រើន នូវកាយនោះឲ្យជានិមិត្ត កំណត់នូវកាយ ដែលខ្លួនកំណត់ទុកដោយល្អ ភិក្ខុនោះ លុះគប់រក អប់រំ ធ្វើឲ្យច្រើន នូវកាយនោះឲ្យជានិមិត្ត កំណត់នូវកាយ ដែលខ្លួនកំណត់ទុកដោយល្អហើយ រមែងប្រមូលមកនូវចិត្តក្នុងកាយ ខាងក្នុងទាំងខាងក្រៅ ។

[ ១៨០ ] ចុះភិក្ខុ ពិចារណានូវកាយ ក្នុងកាយខាងក្នុង និងខាងក្រៅតើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយ ខាងក្នុង និងខាងក្រៅ ( កាយរបស់ខ្លួន ទាំងកាយរបស់គេ ) គឺខាងលើ តាំងអំពីបាតជើងឡើងទៅ ខាងក្រោម តាំងអំពីចុងសក់ចុះមក ដែលមានស្បែកបិទបាំងជុំវិញពេញដោយវត្ថុមិនស្អាត មានប្រការផ្សេងៗ ដូច្នេះថា ក្នុងកាយ មានសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល ទឹកមូត្រ ភិក្ខុពិចារណា នូវកាយក្នុងកាយ ខាងក្នុង និងខាងក្រៅ សម្រេចឥរិយាបថ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី ( ជាគ្រឿងកំណត់ ) កម្ចាត់បង់អភិជ្ឈា និងទោមនស្ស ក្នុងលោក យ៉ាងនេះឯង ។

[ ១៨១ ] សេចក្តីត្រង់ពាក្យថា ភិក្ខុពិចារណា ។ សំណួរថា ចុះបណ្តា

ពាក្យទាំងនោះ ការពិចារណា តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ សេចក្តីមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា នេះហៅថា ការពិចារណា ភិក្ខុជាអ្នកព្រមព្រៀង មូលមិត្រ ចូលទៅជិត អែបនែប កៀកកើយ ប្រជិតប្រជី ប្រកបព្រម ដោយបញ្ញាជាគ្រឿងពិចារណានេះ ព្រោះហេតុនោះ ទើបពោលថា ភិក្ខុពិចារណា ។

[ ១៨២ ] ពាក្យថា សម្រេចឥរិយាបថ គឺសម្រេច ប្រព្រឹត្ត រក្សា រស់នៅ ញ៉ាំងអត្តភាពឲ្យរស់នៅ ត្រាច់ទៅ សម្រាក ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[ ១៨៣ ] សេចក្តីត្រង់ពាក្យថា មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ។ សំណួរថា ចុះបណ្តាពាក្យទាំងនោះ សេចក្តីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស តើដូចម្តេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សេចក្តីព្យាយាមត្រូវណា នេះហៅថា សេចក្តីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ភិក្ខុ ជាអ្នកព្រមព្រៀង មូលមិត្រ ចូលទៅជិត អែបនែប កៀកកើយ ប្រជិតប្រជី ប្រកបព្រម ដោយព្យាយាមជាគ្រឿងដុតកម្តៅកិលេសនេះ ព្រោះហេតុនោះ ទើបពោលថា មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ។

[ ១៨៤ ] សេចក្តីត្រង់ពាក្យថា ជាអ្នកដឹងខ្លួន ។ សំណួរថា ចុះបណ្តាពាក្យទាំងនោះ ពាក្យថា ការដឹងខ្លួន តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ សេចក្តីមិនវង្វេង ការពិចារណានូវធម៌ ការឃើញត្រូវណា នេះហៅថា ការដឹងខ្លួន ភិក្ខុ ជាអ្នកព្រមព្រៀង មូលមិត្រ ចូលទៅជិត អែបនែប កៀកកើយ

ប្រជិតប្រជី ប្រកបព្រម ដោយការជីនខ្ជួននេះ ព្រោះហេតុនោះ ទើបពោលថា ជាអ្នកជីនខ្ជួន ។

[ ១៨៥ ] សេចក្តីត្រង់ពាក្យថា មានស្មារតី ។ សំណួរថា ចុះបណ្តាពាក្យទាំងនោះ ពាក្យថា ស្មារតី តើដូចម្តេច ។ ការរឭក ការនឹកឃើញ ។បេ។ ការរឭកត្រូវណា នេះហៅថា ស្មារតី ភិក្ខុ ជាអ្នកព្រមព្រៀង មូលមិត្រ ចូលទៅជិត អែបនែប កៀកកើយ ប្រជិតប្រជី ប្រកបព្រម ដោយស្មារតីនេះ ព្រោះហេតុនោះ ទើបពោលថា មានស្មារតី ។

[ ១៨៦ ] សេចក្តីត្រង់ពាក្យថា កម្ចាត់បង់អភិជ្ឈា និងទោមនស្ស ក្នុងលោក ។ សំណួរថា បណ្តាពាក្យទាំងនោះ លោក តើដូចម្តេច ។ កាយនោះឯង ឈ្មោះថា លោក ឧបាទានក្ខន្ធទាំង ៥ ឈ្មោះថា លោក នេះហៅថា លោក ។ បណ្តាពាក្យទាំងនេះ អភិជ្ឈា តើដូចម្តេច ។ តម្រេកតម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្តណា នេះហៅថា អភិជ្ឈា ។ បណ្តាពាក្យទាំងនេះ ទោមនស្ស តើដូចម្តេច ។ សេចក្តីមិនត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីទុក្ខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ មិនជាទីត្រេកអរជាទុក្ខ ដែលកើតអំពីចេតោសម្ផស្ស ទុក្ខវេទនា មិនជាទីត្រេកអរ ដែលកើតអំពីចេតោសម្ផស្សណា នេះហៅថា ទោមនស្ស ។ ភិក្ខុជាអ្នកទូន្មាន កម្ចាត់បង់ ស្ងប់រម្ងាប់ ស្ងប់ឈឹង ធ្វើឲ្យវិនាស ធ្វើឲ្យសាបសូន្យ ឲ្យដល់នូវការខូចខាត ឲ្យដល់នូវការហិនហោច ឲ្យរីងស្ងួត ឲ្យហួតហែង ធ្វើឲ្យបាត់បង់ នូវអភិជ្ឈា និងទោមនស្សនេះ ក្នុងលោកនេះ ដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើប

ពោលថា កម្ចាត់បង់អភិជ្ឈា និងទោមនស្ស ក្នុងលោក ។

កាយានុបស្សនានិទ្ទេស ចប់

[ ១៨៧ ] ចុះភិក្ខុ ពិចារណានូវវេទនា ក្នុងវេទនាទាំងឡាយ ខាងក្នុង តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ កាលទទួលសុខវេទនា ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខវេទនា កាលទទួលទុក្ខវេទនា ក៏ដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនា កាលទទួលអទុក្ខមសុខវេទនា ក៏ដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខមសុខវេទនា កាលទទួលសុខវេទនា ប្រកបដោយអាមិសក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខវេទនា ប្រកបដោយអាមិស កាលទទួលសុខវេទនា មិនប្រកបដោយអាមិសក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខវេទនា មិនប្រកបដោយអាមិស កាលទទួលទុក្ខវេទនា ប្រកបដោយអាមិសក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនា ប្រកបដោយអាមិស កាលទទួលទុក្ខវេទនា មិនប្រកបដោយអាមិសក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនា មិនប្រកបដោយអាមិស កាលទទួលអទុក្ខម-សុខវេទនា ប្រកបដោយអាមិសក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខម-សុខវេទនា ប្រកបដោយអាមិស កាលទទួលអទុក្ខមសុខវេទនា មិនប្រកបដោយអាមិសក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខមសុខវេទនា មិនប្រកបដោយអាមិស ។ ភិក្ខុនោះ រមែងគប់រក អប់រំ ធ្វើឲ្យច្រើន នូវវេទនានោះឲ្យជានិមិត្ត កំណត់នូវវេទនាដែលខ្លួនកំណត់ទុកដោយល្អ ភិក្ខុនោះ លុះ

គប់រក អប់រំ ធ្វើឲ្យច្រើន នូវវេទនានោះឲ្យជានិមិត្ត កំណត់នូវវេទនា ដែលខ្លួនកំណត់ទុកដោយល្អហើយ រមែងប្រមូលមកនូវចិត្ត ក្នុងវេទនាខាងក្រៅ ។

[ ១៨៨ ] ចុះភិក្ខុ ពិចារណានូវវេទនា ក្នុងវេទនាទាំងឡាយ ខាងក្រៅ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់នូវបុគ្គល កាលទទួលសុខ-វេទនាថា បុគ្គលនេះ ទទួលសុខវេទនា ដឹងច្បាស់នូវបុគ្គល កាលទទួលទុក្ខវេទនាថា បុគ្គលនេះ ទទួលទុក្ខវេទនា ដឹងច្បាស់នូវបុគ្គល កាលទទួលអទុក្ខមសុខវេទនាថា បុគ្គលនេះ ទទួលអទុក្ខមសុខវេទនា ដឹងច្បាស់នូវបុគ្គល កាលទទួលសុខវេទនា ប្រកបដោយអាមិសក្តី ថាបុគ្គលនេះ ទទួលសុខវេទនា ប្រកបដោយអាមិស ដឹងច្បាស់នូវបុគ្គល កាលទទួលសុខវេទនា មិនប្រកបដោយអាមិសក្តីថា បុគ្គលនេះ ទទួលសុខវេទនា មិនប្រកបដោយអាមិស ដឹងច្បាស់នូវបុគ្គល កាលទទួលទុក្ខវេទនា ប្រកបដោយអាមិសក្តីថា បុគ្គលនេះ ទទួលទុក្ខវេទនា ប្រកបដោយអាមិស ដឹងច្បាស់នូវបុគ្គល កាលទទួលវេទនា មិនប្រកបដោយអាមិសក្តីថា បុគ្គលនេះ ទទួលទុក្ខវេទនា មិនប្រកបដោយអាមិស ដឹងច្បាស់នូវបុគ្គល កាលទទួលអទុក្ខមសុខវេទនា ប្រកបដោយអាមិសក្តីថា បុគ្គលនេះ ទទួលអទុក្ខមសុខវេទនា ប្រកបដោយអាមិស ដឹងច្បាស់នូវបុគ្គល កាលទទួលអទុក្ខមសុខវេទនា មិនប្រកបដោយអាមិសក្តីថា បុគ្គលនេះ ទទួលអទុក្ខមសុខវេទនា មិនប្រកបដោយអាមិស ។ ភិក្ខុនោះ រមែងគប់រក អប់រំ ធ្វើឲ្យច្រើន នូវវេទនានោះ ឲ្យជានិមិត្ត កំណត់នូវវេទនា ដែលខ្លួនកំណត់ទុកដោយល្អ ភិក្ខុនោះ លុះគប់រក អប់រំ ធ្វើឲ្យ

ច្រើន នូវវេទនានោះ ឲ្យជានិមិត្ត កំណត់នូវវេទនា ដែលខ្លួនកំណត់ទុក ដោយល្អហើយ រមែងប្រមូលមកនូវចិត្ត ក្នុងវេទនាទាំងឡាយ ទាំងខាងក្នុង ទាំងខាងក្រៅ ។

[ ១៨៩ ] ចុះភិក្ខុ ពិចារណានូវវេទនា ក្នុងវេទនាទាំងឡាយខាងក្នុង និងខាងក្រៅ តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់នូវសុខវេទនា ជាសុខវេទនា ដឹងច្បាស់នូវទុក្ខវេទនា ជាទុក្ខវេទនា ដឹងច្បាស់នូវអទុក្ខមសុខ-វេទនា ជាអទុក្ខមសុខវេទនា ដឹងច្បាស់នូវសុខវេទនា ប្រកបដោយអាមិស ជាសុខវេទនាប្រកបដោយអាមិស ដឹងច្បាស់នូវសុខវេទនា មិនប្រកបដោយ អាមិស ជាសុខវេទនាមិនប្រកបដោយអាមិស ដឹងច្បាស់នូវទុក្ខវេទនាប្រកប ដោយអាមិស ជាទុក្ខវេទនាប្រកបដោយអាមិស ដឹងច្បាស់នូវទុក្ខវេទនាមិន ប្រកបដោយអាមិស ជាទុក្ខវេទនាមិនប្រកបដោយអាមិស ដឹងច្បាស់នូវ អទុក្ខមសុខវេទនា ប្រកបដោយអាមិស ជាអទុក្ខមសុខវេទនា ប្រកបដោយ អាមិស ដឹងច្បាស់នូវអទុក្ខមសុខវេទនា មិនប្រកបដោយអាមិស ជាអទុក្ខ-មសុខវេទនាមិនប្រកបដោយអាមិស ភិក្ខុពិចារណានូវវេទនា ក្នុងវេទនាទាំង ឡាយខាងក្នុង និងខាងក្រៅ សម្រេចឥរិយាបថ មានព្យាយាមជាគ្រឿង ដុតកម្ដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី ( ជាគ្រឿងកំណត់ ) កម្ចាត់បង់ អភិជ្ឈា និងទោមនស្ស ក្នុងលោក យ៉ាងនេះឯង ។

[ ១៩០ ] សេចក្ដីត្រង់ពាក្យថា ភិក្ខុពិចារណា ។បេ។ ពាក្យថា សម្រេច ឥរិយាបថ ។បេ។ សេចក្ដីត្រង់ពាក្យថា មានព្យាយាម ជាគ្រឿងដុតកម្ដៅ

កិលេស ។បេ។ សេចក្ដីត្រង់ពាក្យថា អ្នកដឹងខ្លួន ។បេ។ សេចក្ដីត្រង់ពាក្យថា មានស្មារតី ។បេ។ សេចក្ដីត្រង់ពាក្យថា កម្ចាត់បង់អភិជ្ឈា និងទោមនស្ស ក្នុងលោក ។ សំណួរថា ចុះបណ្ដាពាក្យទាំងនោះ លោក តើដូចម្ដេច ។ វេទនានោះឯង ឈ្មោះថា លោក ឧបាទានក្ខន្ធទាំង ៥ ឈ្មោះថា លោក នេះហៅថា លោក ។ បណ្ដាពាក្យទាំងនេះ អភិជ្ឈា តើដូចម្ដេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្តណា នេះហៅថា អភិជ្ឈា ។ បណ្ដាពាក្យទាំងនេះ ទោមនស្ស តើដូចម្ដេច ។ សេចក្ដីមិនត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីទុក្ខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនជាទីត្រេកអរ ជាទុក្ខ ដែលកើតអំពីចេតោសម្ផស្ស ទុក្ខវេទនា មិនជាទីត្រេកអរ ដែលកើតអំពីចេតោ-សម្ផស្ស នេះហៅថា ទោមនស្ស ។ ពួកជនក្នុងលោកនេះ ភិក្ខុជាអ្នកទូន្មាន កម្ចាត់បង់ ស្ងប់រម្ងាប់ ស្ងប់ឈឹង ធ្វើឲ្យវិនាស ធ្វើឲ្យសាបសូន្យ ឲ្យដល់នូវការខូចខាត ឲ្យដល់នូវការហិនហោច ឲ្យរីងស្ងួត ឲ្យហួតហែង ធ្វើឲ្យបាត់បង់នូវអភិជ្ឈា និងទោមនស្សនេះ ក្នុងលោកនេះ ដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើបពោលថា កម្ចាត់បង់អភិជ្ឈា និងទោមនស្ស ក្នុងលោក ។

**វេទនានុបស្សនានិទ្ទេស ចប់**

[ ១៩១ ] ចុះភិក្ខុ ពិចារណានូវចិត្តក្នុងចិត្តខាងក្នុង តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ ទោះចិត្តប្រកបដោយរាគៈ ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញប្រកបដោយរាគៈ ទោះចិត្តប្រាសចាករាគៈ ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មា

អញប្រាសចាករាគៈ ទោះចិត្តប្រកបដោយទោសៈ ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញប្រកបដោយទោសៈ ទោះចិត្តប្រាសចាកទោសៈ ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញប្រាសចាកទោសៈ ទោះចិត្តប្រកបដោយមោហៈ ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញប្រកបដោយមោហៈ ទោះចិត្តប្រាសចាកមោហៈ ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញប្រាសចាកមោហៈ ទោះចិត្តរួញរា ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញរួញរា ទោះចិត្តរាយមាយ ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញរាយមាយ ទោះចិត្តជាមហគ្គតៈ ( រូបាវចរ និងអរូបាវចរ ) ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញជាមហគ្គតៈ ទោះចិត្តមិនមែនជាមហគ្គតៈ ( កាមាវចរ ) ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញ មិនមែនជាមហគ្គតៈ ទោះចិត្តជាសឧត្តរៈ ( កាមាវចរ ) ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញជាសឧត្តរៈ ទោះចិត្តជាអនុត្តរៈ ( រូបាវចរ និងអរូបាវចរ ) ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញ ជាអនុត្តរៈ ទោះចិត្តតាំងនៅមាំ ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញតាំងនៅមាំ ទោះចិត្តមិនតាំងនៅមាំ ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញ មិនតាំងនៅមាំ ទោះចិត្តរួចស្រឡះ ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញ រួចស្រឡះ ទោះចិត្តមិនទាន់រួចស្រឡះ ( ចាកអាសវក្កិលេស ) ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញ មិនទាន់រួចស្រឡះ ។ ភិក្ខុនោះ គប់រក អប់រំ ធ្វើឲ្យច្រើននូវចិត្តនោះ ឲ្យជានិមិត្ត កំណត់នូវចិត្តដែលខ្លួនកំណត់ទុកដោយល្អ ភិក្ខុនោះលុះគប់រក អប់រំ ធ្វើឲ្យច្រើន នូវចិត្តនោះ ឲ្យជានិមិត្ត កំណត់នូវចិត្តដែលខ្លួនកំណត់ទុកដោយល្អហើយ រមែងប្រមូលមកនូវចិត្ត ក្នុងចិត្តខាងក្រៅ ។

[ ១៩២ ] ចុះភិក្ខុ ពិចារណានូវចិត្ត ក្នុងចិត្តខាងក្រៅ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ទោះចិត្តរបស់គេប្រកបដោយរាគៈ ក៏ដឹងច្បាស់ថា ចិត្តរបស់គេប្រកបដោយរាគៈ ទោះចិត្តរបស់គេ ប្រាសចាករាគៈ ក៏ដឹងច្បាស់ថា ចិត្តរបស់គេប្រាសចាករាគៈ ទោះចិត្តរបស់គេប្រកបដោយទោសៈ ក៏ដឹងច្បាស់ថា ចិត្តរបស់គេប្រកបដោយទោសៈ ទោះចិត្តរបស់គេប្រាសចាកទោសៈ ក៏ដឹងច្បាស់ថា ចិត្តរបស់គេប្រាសចាកទោសៈ ទោះចិត្តរបស់គេប្រកបដោយមោហៈ ក៏ដឹងច្បាស់ថា ចិត្តរបស់គេប្រកបដោយមោហៈ ទោះចិត្តរបស់គេប្រាសចាកមោហៈ ក៏ដឹងច្បាស់ថា ចិត្តរបស់គេប្រាសចាកមោហៈ ទោះចិត្តរបស់គេរួញរា ក៏ដឹងច្បាស់ថា ចិត្តរបស់គេរួញរា ទោះចិត្តរបស់គេរាយមាយ ក៏ដឹងច្បាស់ថា ចិត្តរបស់គេរាយមាយ ទោះចិត្តរបស់គេជាមហគ្គតៈ ក៏ដឹងច្បាស់ថា ចិត្តរបស់គេជាមហគ្គតៈ ទោះចិត្តរបស់គេមិនមែនជាមហគ្គតៈ ក៏ដឹងច្បាស់ថា ចិត្តរបស់គេមិនមែនជាមហគ្គតៈ ទោះចិត្តរបស់គេជាសឧត្តរៈ ក៏ដឹងច្បាស់ថា ចិត្តរបស់គេជាសឧត្តរៈ ទោះចិត្តរបស់គេជាអនុត្តរៈ ក៏ដឹងច្បាស់ថា ចិត្តរបស់គេជាអនុត្តរៈ ទោះចិត្តរបស់គេតាំងនៅមាំ ក៏ដឹងច្បាស់ថា ចិត្តរបស់គេតាំងនៅមាំ ទោះចិត្តរបស់គេ មិនតាំងនៅមាំ ក៏ដឹងច្បាស់ថា ចិត្តរបស់គេ មិនតាំងនៅមាំ ទោះចិត្តរបស់គេរួចស្រឡះ ក៏ដឹងច្បាស់ថា ចិត្តរបស់គេរួចស្រឡះ ទោះចិត្តរបស់គេមិនទាន់រួចស្រឡះ ក៏ដឹងច្បាស់ថា ចិត្តរបស់គេមិនទាន់រួចស្រឡះ ។ ភិក្ខុនោះ រមែងគប់រក អប់រំ ធ្វើឲ្យច្រើន នូវចិត្តនោះ ឲ្យជានិមិត្ត កំណត់នូវចិត្តដែលខ្លួនកំណត់ទុកដោយល្អ ភិក្ខុនោះ លុះ

គប់រក អប់រំ ធ្វើឲ្យច្រើន ចំពោះចិត្តនោះ ឲ្យជានិមិត្ត កំណត់នូវចិត្តដែល ខ្លួនកំណត់ទុកដោយល្អហើយ រមែងប្រមូលមក នូវចិត្ត ក្នុងចិត្តខាងក្នុង និងខាងក្រៅ ។

[ ១៩៣ ] ចុះភិក្ខុ ពិចារណានូវចិត្តក្នុងចិត្តខាងក្នុង និងខាងក្រៅ តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ ទោះចិត្តប្រកបដោយរាគៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ទោះចិត្តប្រាសចាករាគៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ ទោះចិត្តប្រកបដោយទោសៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ ទោះចិត្តប្រាសចាកទោសៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈ ទោះចិត្តប្រកបដោយមោហៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ទោះចិត្តប្រាសចាកមោហៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈ ទោះចិត្តរួញរា ក៏ដឹងច្បាស់ថា ចិត្តរួញរា ទោះចិត្តរាយមាយ ក៏ដឹងច្បាស់ថា ចិត្តរាយមាយ ទោះចិត្តជាមហគ្គតៈ ក៏ដឹងច្បាស់ថា ចិត្តជាមហគ្គតៈ ទោះចិត្តមិនមែនជាមហគ្គតៈ ក៏ដឹងច្បាស់ថា ចិត្តមិនមែនជាមហគ្គតៈ ទោះចិត្តជាសឧត្តរៈ ក៏ដឹងច្បាស់ថា ចិត្តជាសឧត្តរៈ ទោះចិត្តជាអនុត្តរៈ ក៏ដឹងច្បាស់ថា ចិត្តជាអនុត្តរៈ ទោះចិត្តតាំងនៅមាំ ក៏ដឹងច្បាស់ថា ចិត្តតាំងនៅមាំ ទោះចិត្តមិនតាំងនៅមាំ ក៏ដឹងច្បាស់ថា ចិត្តមិនតាំងនៅមាំ ទោះចិត្តរួចស្រឡះ ក៏ដឹងច្បាស់ថា ចិត្តរួចស្រឡះ ទោះចិត្តមិនទាន់រួចស្រឡះ ក៏ដឹងច្បាស់ថា ចិត្តមិនទាន់រួចស្រឡះ ភិក្ខុពិចារណានូវចិត្តក្នុងចិត្តខាងក្នុង និងខាងក្រៅ សម្រេចឥរិយាបថ មានព្យាយាមជាគ្រឿងដុតកម្ដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់

អភិជ្ឈា និងទោមនស្ស ក្នុងលោក យ៉ាងនេះឯង ។

[ ១៩៤ ] សេចក្តីត្រង់ពាក្យថា ភិក្ខុ ពិចារណា ។បេ។ សេចក្តីត្រង់ពាក្យថា សម្រេចឥរិយាបថ ។បេ។ សេចក្តីត្រង់ពាក្យថា មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ។បេ។ សេចក្តីត្រង់ពាក្យថា ជាអ្នកដឹងខ្លួន ។បេ។ សេចក្តីត្រង់ពាក្យថា មានស្មារតី ។បេ។ សេចក្តីត្រង់ពាក្យថា កម្ចាត់បង់អភិជ្ឈា និងទោមនស្ស ក្នុងលោក ។ សំណួរថា បណ្តាពាក្យទាំងនោះ លោក តើដូចម្តេច ។ ចិត្តនោះឯង ឈ្មោះថា លោក ឧបាទានក្ខន្ធទាំង ៥ ឈ្មោះថា លោក នេះហៅថា លោក ។ បណ្តាពាក្យទាំងនោះ អភិជ្ឈា តើដូចម្តេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្តណា នេះហៅថា អភិជ្ឈា ។ បណ្តាពាក្យទាំងនោះ ទោមនស្ស តើដូចម្តេច ។ សេចក្តីមិនត្រេកអរប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីទុក្ខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនជាទីត្រេកអរ ជាទុក្ខ ដែលកើតអំពីចេតោសម្ផស្ស ទុក្ខវេទនា មិនជាទីត្រេកអរ ដែលកើតអំពីចេតោសម្ផស្សណា នេះហៅថា ទោមនស្ស ។ អភិជ្ឈានេះផង ទោមនស្សនេះផង រមែងមាន ដោយប្រការដូច្នេះ ពួកជនក្នុងលោកនេះ ជាអ្នកទូន្មាន កម្ចាត់បង់ ស្ងប់រម្ងាប់ ស្ងប់ឈឹង ធ្វើឲ្យវិនាស ធ្វើឲ្យសាបសូន្យ ឲ្យដល់នូវការខូចខាត ឲ្យដល់នូវការហិនហោច ឲ្យរីងស្ងួត ឲ្យហួតហែង ធ្វើឲ្យបាត់បង់ ព្រោះហេតុនោះ ទើបពោលថា កម្ចាត់បង់អភិជ្ឈា និងទោមនស្ស ក្នុងលោក ។

**ចិត្តានុបស្សនានិទ្ទេស ចប់**

[ ១៩៥ ] ចុះភិក្ខុ ពិចារណានូវធម៌ ក្នុងធម៌ទាំងឡាយខាងក្នុង តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់នូវកាមច្ឆន្ទៈខាងក្នុង កាលមាន ថាកាមច្ឆន្ទៈខាងក្នុងរបស់អាត្មាអញមាន ឬដឹងច្បាស់នូវកាមច្ឆន្ទៈខាងក្នុង កាលមិនមាន ថាកាមច្ឆន្ទៈខាងក្នុងរបស់អាត្មាអញមិនមាន ការកើតឡើងនៃកាមច្ឆន្ទៈ ដែលមិនទាន់កើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់នូវកាមច្ឆន្ទៈ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការមិនកើតតទៅនៃកាមច្ឆន្ទៈ ដែលខ្លួនលះបង់ហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ភិក្ខុដឹងច្បាស់ នូវព្យាបាទខាងក្នុង កាលមាន ។បេ។ នូវថីនមិទ្ធៈខាងក្នុង កាលមាន ។បេ។ នូវឧទ្ធច្ចកុក្កុច្ចៈខាងក្នុង កាលមាន ។បេ។ នូវវិចិកិច្ឆាខាងក្នុង កាលមាន ថាវិចិកិច្ឆាខាងក្នុងរបស់អាត្មាអញមាន ឬដឹងច្បាស់នូវវិចិកិច្ឆាខាងក្នុង កាលមិនមាន ថាវិចិកិច្ឆាខាងក្នុងរបស់អាត្មាអញមិនមាន ការកើតឡើងនៃវិចិកិច្ឆា ដែលមិនទាន់កើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់នូវវិចិកិច្ឆា ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការមិនកើតតទៅ នៃវិចិកិច្ឆាដែលខ្លួនលះបង់ហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ភិក្ខុ ដឹងច្បាស់នូវសតិសម្ពោជ្ឈង្គខាងក្នុង កាលមាន ថាសតិសម្ពោជ្ឈង្គខាងក្នុង របស់អាត្មាអញមាន ឬដឹងច្បាស់ នូវសតិសម្ពោជ្ឈង្គខាងក្នុង កាលមិនមាន ថាសតិសម្ពោជ្ឈង្គខាងក្នុង របស់អាត្មាអញមិនមាន ការកើតឡើងនៃសតិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើងហើយ ដោយហេតុ

ណា ក៏ដឹងច្បាស់ នូវហេតុនោះផង ការពេញលេញដោយភាវនា នៃសតិ-សម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ដឹងច្បាស់ នូវធម្មវិចយសម្ពោជ្ឈង្គខាងក្នុង កាលមាន ។បេ។ នូវវិរិយសម្ពោជ្ឈង្គខាងក្នុង កាលមាន ។បេ។ នូវបីតិសម្ពោជ្ឈង្គខាងក្នុង កាលមាន ។បេ។ នូវបស្សទ្ធិសម្ពោជ្ឈង្គខាងក្នុង កាលមាន ។បេ។ នូវសមាធិ-សម្ពោជ្ឈង្គខាងក្នុង កាលមាន ។បេ។ នូវឧបេក្ខាសម្ពោជ្ឈង្គខាងក្នុង កាលមាន ថាឧបេក្ខាសម្ពោជ្ឈង្គខាងក្នុងរបស់អាត្មាអញមាន ឬដឹងច្បាស់ នូវឧបេក្ខាសម្ពោជ្ឈង្គខាងក្នុង កាលមិនមាន ថាឧបេក្ខាសម្ពោជ្ឈង្គខាងក្នុងរបស់អាត្មាអញមិនមាន ការកើតឡើងនៃឧបេក្ខាសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ការពេញលេញដោយភាវនា នៃឧបេក្ខាសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ។ ភិក្ខុនោះ រមែងគប់រក អប់រំ ធ្វើឲ្យច្រើន នូវធម៌នោះ ឲ្យជានិមិត្ត កំណត់នូវធម៌ដែលខ្លួនកំណត់ទុកដោយល្អ ភិក្ខុនោះលុះគប់រក អប់រំ ធ្វើឲ្យច្រើន នូវធម៌នោះ ឲ្យជានិមិត្ត កំណត់នូវធម៌ ដែលខ្លួនកំណត់ទុកដោយល្អហើយ រមែងប្រមូលមកនូវចិត្ត ក្នុងធម៌ទាំងឡាយជាខាងក្រៅ ។

[ ១៩៦ ] ចុះភិក្ខុ ពិចារណានូវធម៌ ក្នុងធម៌ទាំងឡាយជាខាងក្រៅ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់នូវកាមច្ឆន្ទៈរបស់គេ កាលមាន ថាកាមច្ឆន្ទៈរបស់គេមាន ឬដឹងច្បាស់នូវកាមច្ឆន្ទៈរបស់គេ កាលមិនមាន ថា

កាមច្ឆន្ទៈរបស់គេ មិនមាន ការកើតឡើងនៃកាមច្ឆន្ទៈ ដែលមិនទាន់កើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់នូវកាមច្ឆន្ទៈ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការមិនកើតតទៅនៃកាមច្ឆន្ទៈ ដែលគេលះបង់ហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ដឹងច្បាស់នូវព្យាបាទរបស់គេ កាលមាន ។បេ។ នូវថីនមិទ្ធៈរបស់គេ កាលមាន ។បេ។ នូវឧទ្ធច្ចកុក្កុច្ចៈរបស់គេ កាលមាន ។បេ។ នូវវិចិកិច្ឆារបស់គេ កាលមាន ថាវិចិកិច្ឆារបស់គេមាន ឬដឹងច្បាស់នូវវិចិកិច្ឆារបស់គេ កាលមិនមាន ថាវិចិកិច្ឆារបស់គេមិនមាន ការកើតឡើងនៃវិចិកិច្ឆាដែលមិនទាន់កើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់នូវវិចិកិច្ឆា ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការមិនកើតតទៅនៃវិចិកិច្ឆា ដែលគេលះបង់ហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ភិក្ខុ ដឹងច្បាស់នូវសតិសម្ពោជ្ឈង្គរបស់គេ កាលមាន ថាសតិសម្ពោជ្ឈង្គរបស់គេមាន ឬដឹងច្បាស់ នូវសតិ-សម្ពោជ្ឈង្គរបស់គេ កាលមិនមាន ថាសតិសម្ពោជ្ឈង្គរបស់គេ មិនមាន ការកើតឡើងនៃសតិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការពេញលេញដោយភាវនា នៃសតិ-សម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ភិក្ខុដឹងច្បាស់ នូវធម្មវិចយសម្ពោជ្ឈង្គរបស់គេ កាលមាន ។បេ។ នូវវីរិយសម្ពោជ្ឈង្គរបស់គេ កាលមាន ។បេ។ នូវបីតិសម្ពោជ្ឈង្គរបស់គេ កាល

មាន ។បេ។ នូវបស្សទ្ធិសម្ពោជ្ឈង្គរបស់គេ កាលមាន ។បេ។ នូវសមាធិ-សម្ពោជ្ឈង្គរបស់គេ កាលមាន ។បេ។ ដឹងច្បាស់ នូវឧបេក្ខាសម្ពោជ្ឈង្គរបស់គេ កាលមាន ថាឧបេក្ខាសម្ពោជ្ឈង្គរបស់គេមាន ឬដឹងច្បាស់នូវឧបេក្ខាសម្ពោជ្ឈង្គរបស់គេ កាលមិនមាន ថាឧបេក្ខាសម្ពោជ្ឈង្គរបស់គេ មិនមាន ការកើតឡើង នៃឧបេក្ខាសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការពេញលេញដោយភាវនា នៃឧបេក្ខាសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ភិក្ខុនោះ រមែងគប់រក អប់រំ ធ្វើឲ្យច្រើន នូវធម៌នោះឲ្យជានិមិត្ត កំណត់នូវធម៌ ដែលខ្លួនកំណត់ទុកដោយល្អ ភិក្ខុនោះ លុះគប់រក អប់រំ ធ្វើឲ្យច្រើន នូវធម៌នោះ ឲ្យជានិមិត្ត កំណត់នូវធម៌ដែលខ្លួនកំណត់ទុកដោយល្អហើយ រមែងប្រមូលមកនូវចិត្ត ក្នុងធម៌ទាំងឡាយ ខាងក្នុង និងខាងក្រៅ ។

[ ១៩៧ ] ចុះភិក្ខុ ពិចារណានូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្នុង និងខាងក្រៅ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់នូវកាមច្ឆន្ទៈ កាលមាន ថាកាមច្ឆន្ទៈមាន ឬដឹងច្បាស់នូវកាមច្ឆន្ទៈ កាលមិនមាន ថាកាមច្ឆន្ទៈមិនមាន ការកើតឡើងនៃកាមច្ឆន្ទៈ ដែលមិនទាន់កើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់នូវកាមច្ឆន្ទៈ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ការមិនកើតតទៅនៃកាមច្ឆន្ទៈ ដែលលះបង់ហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះ

ផង ភិក្ខុដឹងច្បាស់នូវព្យាបាទ កាលមាន ។បេ។ នូវថីនមិទ្ធៈ កាលមាន ។បេ។ នូវឧទ្ធច្ចកុក្កុច្ចៈ កាលមាន ។បេ។ នូវវិចិកិច្ឆា កាលមាន ថាវិចិកិច្ឆាមាន ឬដឹងច្បាស់នូវវិចិកិច្ឆា កាលមិនមាន ថាវិចិកិច្ឆាមិនមាន ការកើតឡើងនៃវិចិកិច្ឆា ដែលមិនទាន់កើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ការលះបង់នូវវិចិកិច្ឆា ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការមិនកើតតទៅ នៃវិចិកិច្ឆា ដែលលះបង់ហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ភិក្ខុដឹងច្បាស់ នូវសតិសម្ពោជ្ឈង្គ កាលមាន ថាសតិសម្ពោជ្ឈង្គមាន ឬដឹងច្បាស់ នូវសតិ-សម្ពោជ្ឈង្គ កាលមិនមាន ថាសតិសម្ពោជ្ឈង្គ មិនមាន ការកើតឡើងនៃសតិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការពេញលេញដោយភាវនា នៃសតិសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ភិក្ខុដឹងច្បាស់នូវធម្មវិចយសម្ពោជ្ឈង្គ កាលមាន ។បេ។ នូវវីរិយសម្ពោជ្ឈង្គ កាលមាន ។បេ។ នូវបីតិសម្ពោជ្ឈង្គ កាលមាន ។បេ។ នូវបស្សទ្ធិសម្ពោជ្ឈង្គ កាលមាន ។បេ។ នូវសមាធិសម្ពោជ្ឈង្គ កាលមាន ។បេ។ នូវឧបេក្ខាសម្ពោជ្ឈង្គ កាលមាន ថាឧបេក្ខាសម្ពោជ្ឈង្គ មាន ឬដឹងច្បាស់ នូវឧបេក្ខាសម្ពោជ្ឈង្គ កាលមិនមាន ថាឧបេក្ខាសម្ពោជ្ឈង្គ មិនមាន ការកើតឡើង នៃឧបេក្ខា-សម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការពេញលេញដោយភាវនានៃឧបេក្ខាសម្ពោជ្ឈង្គ ដែលកើតឡើង

ហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ភិក្ខុ ពិចារណានូវធម៌ ក្នុងធម៌ទាំងឡាយខាងក្នុង និងខាងក្រៅ សម្រេចឥរិយាបថ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់អភិជ្ឈា និងទោមនស្ស ក្នុងលោក យ៉ាងនេះឯង ។

[ ១៩៨ ] សេចក្តីត្រង់ពាក្យថា ភិក្ខុពិចារណា ។ ប្រស្នាថា ចុះបណ្តាពាក្យទាំងនោះ ការពិចារណា តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ សេចក្តីមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា នេះហៅថា ការពិចារណា ភិក្ខុជាអ្នកព្រមព្រៀង មូលមិត្រ ចូលទៅជិត អែបនែប កៀកកើយ ប្រជិតប្រជី ប្រកបព្រម ដោយបញ្ញាជាគ្រឿងពិចារណានេះ ព្រោះហេតុនោះ ទើបពោលថា ភិក្ខុពិចារណា ។

[ ១៩៩ ] សេចក្តីត្រង់ពាក្យថា សម្រេចឥរិយាបថ គឺសម្រេច ប្រព្រឹត្ត រក្សា រស់នៅ ញុំាងអត្តភាពឲ្យរស់នៅ ត្រាច់ទៅ នៅ សម្រាក ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[ ២០០ ] សេចក្តីត្រង់ពាក្យថា អ្នកមានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ។ សំណួរថា ចុះបណ្តាពាក្យទាំងនោះ ការព្យាយាមជាគ្រឿងដុតកម្តៅកិលេស តើដូចម្តេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សេចក្តីព្យាយាមត្រូវណា នេះហៅថា សេចក្តីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ភិក្ខុ ជាអ្នកព្រមព្រៀង ។បេ។ ប្រកបដោយព្យាយាមជាគ្រឿងដុតកម្តៅកិលេសនេះ ព្រោះហេតុនោះ ទើបពោលថា មានព្យាយាមជាគ្រឿងដុត

កម្តៅកិលេស ។

[ ២០១ ] សេចក្តីត្រង់ពាក្យថា ជាអ្នកដឹងខ្លួន ។ សំណួរថា ចុះបណ្តាពាក្យទាំងនោះ ការដឹងខ្លួន តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ សេចក្តីមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា នេះហៅថា ការដឹងខ្លួន ភិក្ខុជាអ្នកព្រមព្រៀង ។បេ។ ប្រកបដោយការដឹងខ្លួននេះ ព្រោះហេតុនោះ ទើបពោលថា ជាអ្នកដឹងខ្លួន ។

[ ២០២ ] សេចក្តីត្រង់ពាក្យថា មានស្មារតី ។ សំណួរថា ចុះបណ្តាពាក្យទាំងនោះ ស្មារតី តើដូចម្តេច ។ គឺការនឹករឭក ការនឹករឿយៗ ។បេ។ ការរឭកត្រូវណា នេះហៅថា ស្មារតី ភិក្ខុជាអ្នកព្រមព្រៀង ។បេ។ ប្រកបដោយស្មារតីនេះ ព្រោះហេតុនោះ ទើបពោលថា មានស្មារតី ។

[ ២០៣ ] សេចក្តីត្រង់ពាក្យថា កម្ចាត់បង់អភិជ្ឈា និងទោមនស្ស ក្នុងលោក ។ សំណួរថា ចុះបណ្តាពាក្យទាំងនោះ លោក តើដូចម្តេច ។ ធម៌ទាំងឡាយនោះឯង ហៅថា លោក ឧបាទានក្ខន្ធទាំង ៥ ហៅថា លោក នេះហៅថា លោក ។ បណ្តាពាក្យទាំងនោះ អភិជ្ឈា តើដូចម្តេច ។ តម្រេកតម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្តណា នេះហៅថា អភិជ្ឈា ។ បណ្តា

ពាក្យទាំងនោះ ទោមនស្ស តើដូចម្តេច ។ សេចក្តីមិនត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីទុក្ខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ មិនជាទីត្រេកអរជាទុក្ខ ដែលកើតអំពីចេតោសម្ផស្ស ទុក្ខវេទនាមិនជាទីត្រេកអរ ដែលកើតអំពីចេតោសម្ផស្សណា នេះហៅថា ទោមនស្ស ។ ភិក្ខុ ជាអ្នកទូន្មានកម្ចាត់បង់ ស្ងប់ រម្ងាប់ ស្ងប់ឈឹង ធ្វើឲ្យវិនាស ធ្វើឲ្យសាបសូន្យ ឲ្យដល់នូវការខូចខាត ឲ្យដល់នូវការហិនហោច ឲ្យរីងស្ងួត ឲ្យហួតហែង ធ្វើឲ្យបាត់បង់ នូវអភិជ្ឈា និងទោមនស្សនេះ ដោយប្រការដូច្នេះ ក្នុងលោកនេះ ព្រោះហេតុនោះ ទើបពោលថា កម្ចាត់បង់អភិជ្ឈា និងទោមនស្ស ក្នុងលោក ។

ធម្មានុបស្សនានិទ្ទេស ចប់

សុត្តន្តភាជនីយ ចប់

# អដ្ឋកថា
# សតិប្បដ្ឋានវិភង្គ

## សុត្តន្តភាជនីយ

### ឧទ្ទេសវារ

[ ១៧៧-១៨៦ ] ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងសតិប្បដ្ឋានវិភង្គ ដែលជាលំដាប់បន្ទាប់អំពីបដិច្ចសមុប្បាទវិភង្គនោះដូចតទៅ

បទថា **ចត្តារោ** ជាពាក្យកំណត់ចំនួន ។ ដោយពាក្យនោះ ព្រះមានព្រះភាគ ទ្រង់កំណត់សតិប្បដ្ឋានថា មានចំនួនមិនទាបជាងនោះ មិនច្រើនជាងនោះ ។

បទថា **សតិប្បដ្ឋានា** បានដល់ សតិប្បដ្ឋាន ៣ យ៉ាង គឺសតិគោចរ ១ ការៈ ៣ យ៉ាង ដែលព្រះសាស្តាទ្រង់ប្រព្រឹត្តកន្លងនូវការត្រេកអរ និងការមិនត្រេកអរ ក្នុងពួកសាវកដែលបដិបត្តិ ១ ដោយសតិ ១ ។

ពិតហើយ សតិគោចរ គឺអារម្មណ៍របស់សតិ ហៅថា សតិប្បដ្ឋាន ដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវសេចក្តីកើតឡើង និងសូន្យទៅនៃសតិប្បដ្ឋាន ៤ ចូរអ្នកទាំងឡាយស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីកើតឡើងនៃកាយ ដូចម្តេច ។ សេចក្តីកើតឡើងនៃកាយ ព្រោះកើតឡើងនៃ

អាហារជាដើម ។ម្យ៉ាងទៀត អារម្មណ៍របស់សតិ ក៏ហៅថា សតិប្បដ្ឋាន ដូចព្រះតម្រាស់ ( ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ) កាយ ឈ្មោះថា ឧបដ្ឋាន មិនមែនឈ្មោះថាសតិទេ សតិ ឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង ដូច្នេះ ។

សេចក្ដីនៃពាក្យនោះ គប្បីជ្រាបថា ឈ្មោះថា **បដ្ឋាន** ព្រោះអត្ថថា ជាទីតាំងមាំ សួរថា អ្វីតាំងមាំ ឆ្លើយថា សតិ ដែលជាទីតាំងមាំនៃសតិ ឈ្មោះថា **សតិប្បដ្ឋាន** ។ ម្យ៉ាងទៀត ទីតាំងមាំដែលជាប្រធាន ឈ្មោះថា **បដ្ឋាន** ទីតាំងដែលជាប្រធាននៃសតិ ឈ្មោះថា **សតិប្បដ្ឋាន** ដូចពាក្យថា ទីដែលជាទីតាំងនៅរបស់ដំរី និងរបស់សេះជាដើម ដូច្នោះ ។

ការៈ ៣ យ៉ាង ដែលព្រះសាស្ដាទ្រង់ប្រព្រឹត្តកន្លងនូវការត្រេកអរ និង មិនត្រេកអរ ក្នុងពួកសាវកដែលបដិបត្តិ ហៅថា **សតិប្បដ្ឋាន** ដូចព្រះ តម្រាស់ ( ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក ) ថា ឯសតិប្បដ្ឋាន មាន ៣ ប្រការ ជាធម៌ដែលសាស្ដាដ៏ប្រសើរតែងសេព កាលសាស្ដាដ៏ប្រសើរសេព ហើយ ទើបគួរប្រៀនប្រដៅនូវគណៈបាន ដូច្នេះ ។ អត្ថនៃពាក្យនោះ គប្បី ជ្រាបថា ឈ្មោះថា **បដ្ឋាន** ព្រោះជាធម៌គួរឲ្យតាំងទុក អធិប្បាយថា ព្រោះ គួរឲ្យប្រព្រឹត្តទៅ ។ សួរថា គួរឲ្យតាំងទុកដោយធម៌អ្វី ឆ្លើយថា ដោយសតិ ការឲ្យតាំងទុកដោយសតិ ឈ្មោះថា **សតិប្បដ្ឋាន** ។

តួសតិនោះឯង ហៅថា **សតិប្បដ្ឋាន** ដូចព្រះតម្រាស់ ( ក្នុងមជ្ឈិម- និកាយ ឧបរិបណ្ណាសក ) ថា សតិប្បដ្ឋានទាំង ៤ ដែលបុគ្គលបានចម្រើន

*បានធ្វើឲ្យរឿយៗ ហើយ រមែងញ៉ាំងពោជ្ឈង្គទាំង ៧ ឲ្យពេញបរិបូណ៌បាន ដូច្នេះ ។ អត្ថនៃពាក្យនោះ គប្បីជ្រាបថា ឈ្មោះថា* **បដ្ឋាន** *ព្រោះអត្ថថា តាំងនៅ អធិប្បាយថា ប្រាកដ គឺឈានកន្លងហើយ រមែងស្ទុះទៅ រមែង ប្រព្រឹត្តទៅ ។ សតិនោះឯង ឈ្មោះថា* **សតិប្បដ្ឋាន** *ព្រោះអត្ថថា តាំងនៅ ឬតាំងមាំ ។ម្យ៉ាងទៀត ឈ្មោះថា* **សតិ** *ព្រោះអត្ថថា ការរឭក ។ ឈ្មោះថា* **បដ្ឋាន** *ព្រោះអត្ថថា ចូលទៅតាំងមាំ ដោយប្រការដូច្នេះ សតិនោះផង បដ្ឋាន នោះផង ទើបឈ្មោះថា* **សតិប្បដ្ឋាន ។** *សតិប្បដ្ឋាននេះ ព្រះមានព្រះភាគ ទ្រង់បំណងយកក្នុងទីនេះ ។*

*សួរថា កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបទ្រង់ធ្វើពាក្យថា* **សតិប្បដ្ឋាន** *ឲ្យជាពហុវចនៈទៅវិញ ឆ្លើយថា ព្រោះសតិមានច្រើន ។ ពិតហើយ ទ្រង់ធ្វើ សតិទុកច្រើន ក៏ព្រោះការផ្សេងគ្នានៃអារម្មណ៍ សួរថា ព្រោះហេតុអ្វី ទើប ព្រះមានព្រះភាគត្រាស់សតិប្បដ្ឋាន ៤ ប៉ុណ្ណោះ មិនខ្វះមិនលើស ឆ្លើយថា ព្រោះនឹងឲ្យជាប្រយោជន៍ដល់វេនេយ្យសត្វ ។ ពិតហើយ បណ្តាសត្វទាំង ឡាយ ដែលមានតណ្ហាចរិត និងទិដ្ឋិចរិត ឬសមថយានិក និងវិបស្សនា- យានិក ដែលប្រព្រឹត្តទៅ ២ យ៉ាង ដោយអំណាចមន្ទបុគ្គល និងតិក្ខបុគ្គល ។ កាយានុបស្សនាសតិប្បដ្ឋានដែលគ្រោតគ្រាត ជាផ្លូវនៃសេចក្តីបរិសុទ្ធរបស់ បុគ្គលដែលមានតណ្ហាចរិតយ៉ាងទន់ ។ វេទនានុបស្សនាសតិប្បដ្ឋានដ៏ល្អិត ជា ផ្លូវនៃសេចក្តីបរិសុទ្ធរបស់បុគ្គលដែលមានតណ្ហាចរិតយ៉ាងចាស់ក្លា ។ ចិត្តា- នុបស្សនាសតិប្បដ្ឋាន ដែលមានអារម្មណ៍បែកចេញមិនច្រើន ជាផ្លូវនៃសេចក្តី*

បរិសុទ្ធរបស់បុគ្គលដែលមានទិដ្ឋិចរិតយ៉ាងទន់ ។ ធម្មានុបស្សនាសតិប្បដ្ឋាន ដែលមានអារម្មណ៍បែកចេញច្រើន ជាផ្លូវនៃសេចក្តីបរិសុទ្ធរបស់បុគ្គល ដែលមានទិដ្ឋិចរិតយ៉ាងក្លា ។

ម្យ៉ាងទៀត សតិប្បដ្ឋានទី ១ មាននិមិត្តដែលបុគ្គលគប្បីសម្រេចបាន ដោយមិនលំបាក ជាផ្លូវនៃសេចក្តីបរិសុទ្ធរបស់បុគ្គល ដែលជាសមថយានិក យ៉ាងទន់ សតិប្បដ្ឋានទី ២ ជាផ្លូវនៃសេចក្តីបរិសុទ្ធរបស់បុគ្គលដែលជា សមថយានិកយ៉ាងចាស់ក្លា ព្រោះមិនកើតក្នុងអារម្មណ៍ដែលគ្រោតគ្រាត ។ សតិប្បដ្ឋានទី ៣ មានអារម្មណ៍ដែលញែកចេញមិនច្រើន ជាផ្លូវនៃសេចក្តី បរិសុទ្ធរបស់បុគ្គលដែលជាវិបស្សនាយានិកយ៉ាងទន់ សតិប្បដ្ឋានទី ៤ មាន អារម្មណ៍ដែលចែកចេញច្រើន ជាផ្លូវនៃសេចក្តីបរិសុទ្ធរបស់បុគ្គល ដែលជា វិបស្សនាយានិកចាស់ក្លា ។

ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់សតិប្បដ្ឋាន ៤ ដោយ មិនខ្វះ មិនលើស ដោយប្រការដូច្នេះឯង ។

ម្យ៉ាងទៀត ព្រះមានព្រះភាគត្រាស់សតិប្បដ្ឋាន ៤ ដើម្បីលះសុភ-វិបល្លាស សុខវិបល្លាស និច្ចវិបល្លាស អត្តវិបល្លាស ។ ពិតហើយ កាយ ជាអសុភ តែសត្វទាំងឡាយដែលយល់ខុស ដោយសុភវិបល្លាសក្នុងកាយ នោះមាន ។ ទើបព្រះមានព្រះភាគ ត្រាស់សតិប្បដ្ឋានទី ១ ដើម្បីឲ្យសត្វទាំង នោះ លះវិបល្លាសនោះ ដោយការសម្តែងដល់ភាពជាអសុភក្នុងកាយនោះ ។ ម្យ៉ាងទៀត បណ្តាធម៌ទាំងឡាយ មានវេទនាជាដើម ដែលសត្វកាន់យក

*ហើយថា ជាសុខ ជារបស់ទៀង ជាអត្តា ដែលពិត វេទនាជាទុក្ខ ចិត្តក៏មិនទៀង ធម៌ទាំងឡាយក៏ជាអនត្តា តែសត្វទាំងឡាយ ដែលយល់ខុស មានការឃើញឃ្លៀងឃ្លាតក្នុងធម៌ទាំងឡាយ មានវេទនាជាដើមនោះ ថាជាសុខ ជារបស់ទៀង ជាអត្តា ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សតិប្បដ្ឋាន ៣ ដ៏សេស ក៏ដើម្បីឲ្យសត្វទាំងនោះលះវិបល្លាសនោះ ដោយការសម្តែងដល់ភាពជាទុក្ខជាដើមក្នុងធម៌ មានវេទនាជាដើមទាំងនោះ ព្រោះហេតុនោះ គប្បីជ្រាបថា បានត្រាស់នូវសតិប្បដ្ឋាន ៤ ប៉ុណ្ណោះ មិនខ្វះ មិនលើស ដើម្បីលះវិបល្លាសក្នុងការឃើញថា ស្អាត សុខ ទៀង ជាអត្តា ដោយប្រការដូច្នេះ ។ ដើម្បីការលះវិបល្លាសប៉ុណ្ណោះ ក៏មិនមែន ដោយពិត គប្បីជ្រាបថា ព្រះអង្គត្រាស់សតិប្បដ្ឋាន ៤ ដើម្បីលះឱឃៈ ៤ យោគៈ ៤ អាសវៈ ៤ គន្ថៈ ៤ ឧបាទាន ៤ អគតិ ៤ និងដើម្បីឲ្យកំណត់ដឹងអាហារ ៤ ផងដែរ ។ ន័យរបស់បករណ៍ មានប្រមាណប៉ុណ្ណោះ ។*

*ក្នុងអដ្ឋកថា លោកពោលពាក្យត្រឹមប៉ុណ្ណោះថា* **សតិប្បដ្ឋាន** *មានមួយប៉ុណ្ណោះ ដោយអំណាចនៃការរឭក និងដោយអំណាចនៃការប្រជុំដោយភាពតែមួយជាមួយគ្នា តែមាន ៤ ដោយអំណាចនៃអារម្មណ៍ ដូចក្នុងនគរ ១ មានទ្វារ ៤ ជនទាំងឡាយដែលមកអំពីទិសខាងកើត កាន់យកទ្រព្យ ដែលមានក្នុងទិសខាងកើត ហើយក៏ចូលទៅកាន់នគរ តាមទ្វារទិសខាងកើតនោះឯង ។ បុគ្គលមកអំពីទិសខាងត្បូង ... បុគ្គលដែលមកអំពីទិសខាងលិច ... បុគ្គលដែលមកអំពីទិសខាងជើង កាន់យកទ្រព្យដែលមានក្នុងទិសខាងជើង*

ហើយចូលទៅកាន់នគរតាមទិសខាងជើងនោះឯង យ៉ាងណា ពាក្យឧបមាជាគ្រឿងញ៉ាំងឧបមេយ្យឲ្យដល់ព្រមនេះ បណ្ឌិតគប្បីជ្រាបយ៉ាងនោះចុះ ។ ពិតហើយ ព្រះនគរ គឺ ព្រះនិព្វាន ប្រៀបដូចនគរ លោកុត្តរមគ្គ ដែលប្រកបដោយអង្គ ៨ ប្រៀបដូចទ្វារ កាយជាដើមប្រៀបដូចទិសខាងកើតជាដើម ។ ជនទាំងឡាយដែលមកអំពីទិសខាងកើត កាន់យកទ្រព្យ ដែលមានក្នុងទិសខាងកើត ហើយក៏ចូលទៅកាន់នគរតាមទ្វារទិសខាងកើតនោះឯង យ៉ាងណា ព្រះយោគាវចរទាំងឡាយ ដែលមកដោយកាយានុបស្សនាជាប្រធាន ក៏យ៉ាងនោះ ចម្រើនកាយានុបស្សនាដោយបព្វៈ ១៤ ហើយឈមចុះកាន់ព្រះនិព្វានតែមួយ ដោយអរិយមគ្គដែលកើតឡើង ដោយអានុភាពនៃការចម្រើនកាយានុបស្សនា ។

ជនទាំងឡាយដែលមកអំពីទិសខាងត្បូង កាន់យកទ្រព្យដែលមានក្នុងទិសខាងត្បូងហើយ ក៏ចូលទៅកាន់នគរ ដោយទ្វារទិសខាងត្បូងនោះឯង យ៉ាងណា ព្រះយោគាវចរទាំងឡាយ ដែលមកដោយវេទនានុបស្សនាជាប្រធាន ក៏យ៉ាងនោះ ចម្រើនវេទនានុបស្សនាដោយបព្វៈ ៩ ហើយឈមចុះកាន់ព្រះនិព្វានមួយនោះឯង ដោយអរិយមគ្គកើតឡើង ដោយអានុភាពនៃការចម្រើនវេទនានុបស្សនា ។

ជនទាំងឡាយដែលមកអំពីទិសខាងលិច កាន់យកទ្រព្យដែលមានក្នុងទិសខាងលិច ហើយចូលទៅកាន់នគរ តាមទ្វារទិសខាងលិចនោះឯង យ៉ាងណា ព្រះយោគាវចរទាំងឡាយ ដែលមកដោយចិត្តានុបស្សនាជាប្រធាន ក៏

យ៉ាងនោះ ចម្រើនចិត្តានុបស្សនា ១៦ បទៈ ហើយឈមចុះកាន់ព្រះនិព្វាន មួយនោះឯង ដោយអរិយមគ្គដែលកើតឡើង ដោយអានុភាពនៃការចម្រើន ចិត្តានុបស្សនា ។

ជនទាំងឡាយដែលមកអំពីទិសខាងជើង កាន់យកទ្រព្យដែលមានក្នុង ទិសខាងជើងហើយ ចូលទៅកាន់នគរ តាមទ្វារទិសខាងជើងនោះឯង យ៉ាង ណា ព្រះយោគាវចរទាំងឡាយ ដែលមកដោយធម្មានុបស្សនាជាប្រធាន ក៏ យ៉ាងនោះ ចម្រើនធម្មានុបស្សនាដោយបទៈ ៥ ហើយ ឈមចុះកាន់ព្រះ និព្វានមួយនោះឯង ដោយអរិយមគ្គដែលកើតឡើង ដោយអានុភាពនៃការ ចម្រើនធម្មានុបស្សនា ។

គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់សតិប្បដ្ឋាន ១ ប៉ុណ្ណោះ ដោយ អំណាចនៃការរឭក និងដោយអំណាចនៃការប្រជុំ ដោយភាពតែមួយជាមួយ គ្នា តែត្រាស់សតិប្បដ្ឋាន ៤ ដោយអំណាចនៃអារម្មណ៍ ដោយប្រការដូច្នេះ ។

ក្នុងបទថា **ឥធ ភិក្ខុ** នេះ ព្រះមានព្រះភាគប្រថាប់គង់ក្នុងទេវលោក ត្រាស់សតិប្បដ្ឋានវិភង្គនេះ សូម្បីភិក្ខុមួយរូបឈ្មោះថាអង្គុយក្នុងសម្នាក់របស់ ព្រះអង្គក្នុងទេវលោកនោះ មិនមានក៏ពិត តែភិក្ខុទាំងឡាយ រមែងចម្រើន សតិប្បដ្ឋានទាំង ៤ នេះ ដ្បិតថា សតិប្បដ្ឋានទាំង ៤ នេះ ជាអារម្មណ៍ របស់ភិក្ខុ ហេតុនោះ ទើបត្រាស់ថា ភិក្ខុក្នុងសាសនានេះ ។ សួរថា ពួកភិក្ខុ ប៉ុណ្ណោះឬ រមែងចម្រើនសតិប្បដ្ឋានទាំងនេះ ភិក្ខុនីជាដើម មិនចម្រើនទេឬ ឆ្លើយថា ជនដទៃ មានភិក្ខុនីជាដើម ក៏ចម្រើន តែភិក្ខុទាំងឡាយ ជាបរិស័ទ

ដ៏កំពូល ទើបព្រះមានព្រះភាគត្រាស់ថា ភិក្ខុក្នុងសាសនានេះ ព្រោះភាពជាបរិស័ទដ៏ប្រសើរ ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត ទ្រង់ត្រាស់យ៉ាងនោះ ក៏ព្រោះសម្តែងភាពជាភិក្ខុដោយកិច្ចបដិបត្តិ ។ ពិតហើយ បុគ្គលណា ប្រព្រឹត្តទៅកាន់កិច្ចបដិបត្តិនេះ បុគ្គលនោះ ឈ្មោះថា ភិក្ខុ ព្រោះថា បុគ្គលដែលបដិបត្តិ ទោះជាទេវតាក្តី មនុស្សក្តី រមែងដល់នូវការរាប់ថា ជាភិក្ខុទាំងអស់ ដូចព្រះតម្រាស់ ( ក្នុងខុទ្ទកនិកាយ ធម្មបទ ) ថា

បើបុគ្គលណា មានខ្លួនប្រដាប់ស្អិតស្អាងហើយ ( ដោយគ្រឿងអម្ពរ ) តែគប្បីប្រព្រឹត្តស្មើ អ្នកស្ងប់រម្ងាប់ ទូន្មាន ( ឥន្ទ្រិយ ) ជាបុគ្គលទៀង ( ចំពោះមគ្គផល ) អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ទម្លាក់ចោលនូវអាជ្ញា ក្នុងសត្វទាំងពួងចេញហើយ បុគ្គលនោះ ហៅថា ព្រាហ្មណ៍ក៏បាន ជាសមណៈក៏បាន ជាភិក្ខុក៏បាន ដូច្នេះ ។

បទថា **អជ្ឈត្តំ** លោកបំណងយកខាងក្នុងដែលជារបស់ខ្លួន ព្រោះហេតុនោះ បទថា **អជ្ឈត្តំ កាយេ** ទើបបានសេចក្តីថា ក្នុងកាយរបស់ខ្លួន ។ បណ្តាបទទាំងនោះ បទថា **កាយេ** បានដល់ ក្នុងរូបកាយ ។ ពិតហើយ ក្រុមនៃរូប បំណងយកថា កាយ ក្នុងទីនេះ ដូចជាក្រុមដំរី ក្រុមសេះ និងក្រុមរថជាដើម ព្រោះអត្ថថា ជាទីប្រជុំនៃធម៌ គឺអវយវៈតូចធំទាំងឡាយ និងនៃធម៌ទាំងឡាយ មានសក់ជាដើម ។ ឯរូបកាយ លោកបំណងយកថា កាយ ព្រោះអត្ថថា ជាទីប្រជុំ យ៉ាងណា រូបកាយ លោកក៏បំណងយកថា កាយ ព្រោះអត្ថថា ជាប្រភពកើតនៃវត្ថុមិនស្អាតក៏យ៉ាងនោះ ។ ពិតហើយ ដែល

ឈ្មោះថា **កាយ** ព្រោះអត្ថថា ជាប្រភពកើតនៃធម៌ទាំងឡាយ មានសក់ជាដើមដែលគួរខ្ពើម គួររង្កៀសក្រៃលែង ។ ប្រទេសដែលជាប្រភពកើត ឈ្មោះថា **អាយ** ។ គប្បីជ្រាបវចនត្ថៈក្នុងពាក្យថា **អាយ** នោះ ដូចតទៅ

កាយ ឈ្មោះថា **អាយ** ព្រោះអត្ថថា ជាដែនកើតនៃធម៌ទាំងឡាយ ( ឬថា ធម៌ទាំងឡាយ រមែងកើតអំពីកាយនេះ ហេតុនោះ ទើបកាយនេះឈ្មោះថា **អាយ** ) ។ សួរថា ធម៌ពួកណា រមែងកើត ឆ្លើយថា ធម៌ទាំងឡាយ មានសក់ជាដើម ដែលគួររង្កៀស រមែងកើត ។ ព្រោះហេតុនោះ កាយ គឺប្រភពកើតនៃធម៌ទាំងឡាយ មានសក់ជាដើម ដែលគួររង្កៀស ដោយប្រការដូច្នេះ ។

បទថា **កាយានុបស្សី** បានដល់ មានប្រក្រតីតាមឃើញកាយ ឬថា ឃើញកាយរឿយៗ ។ ពាក្យនេះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគសូម្បីត្រាស់ពាក្យថា **កាយេ** ដូច្នេះហើយ ទ្រង់ធ្វើសព្ទកាយទី ២ ថា **កាយានុបស្សី** ដូច្នេះទៀត ដើម្បីសម្ដែងការកំណត់ និងការបែកឃនៈជាដើម មិនឲ្យលាយឡំគ្នា ដោយហេតុនោះ ទើបមិនបានត្រាស់ថា ពិចារណាឃើញវេទនា ក្នុងកាយរឿយៗ ឬថា ពិចារណាឃើញចិត្ត ពិចារណាឃើញធម៌ក្នុងកាយឡើយ ដោយពិត ទ្រង់សម្ដែងការកំណត់មិនឲ្យលាយឡំគ្នា ដោយការសម្ដែងអាការ គឺការតាមឃើញកាយរឿយៗ ក្នុងវត្ថុ ពោល គឺកាយក្នុងពាក្យថា ពិចារណានូវកាយក្នុងកាយនោះឯង ដូច្នេះ ។ ដោយទំនងដូចគ្នា ក៏មិនត្រាស់ថា ពិចារណាឃើញធម៌ណាមួយរឿយៗ ក្រៅអំពីអវយវៈ

តូចធំក្នុងកាយ ទាំងមិនត្រាស់ថា ពិចារណាឃើញស្រីប្រុសរឿយៗ ក្រៅអំពីសក់ រោមជាដើមឡើយ ។

ឯកាយណា ពោល គឺទីប្រជុំនៃមហាភូតរូប និងឧបាទាយរូប មានសក់ រោមជាដើម មានក្នុងកាយនេះ ទើបមិនបានត្រាស់ថា ពិចារណាឃើញធម៌ណាមួយរឿយៗ ក្រៅអំពីភូតរូប និងឧបាទាយរូបក្នុងកាយនោះ ។ ការពិត ទ្រង់សម្ដែងចែកយនៈ ដោយការសម្ដែងវត្ថុ ពោល គឺកាយ ដោយអំណាចនៃកាយ គឺទីប្រជុំនោះឯង ដោយប្រការផ្សេងៗ ថា ជាអ្នកពិចារណាឃើញការប្រជុំនៃអវយវៈតូចធំទាំងឡាយរឿយៗ ប្រៀបដូចបុគ្គលពិនិត្យមើលចំណែកប្រកបនៃរថផង ជាអ្នកពិចារណាឃើញការប្រជុំនៃធម៌ទាំងឡាយ មានសក់រោមជាដើមរឿយៗ ប្រៀបដូចបុគ្គលដែលពិនិត្យមើលចំណែកប្រកបតូចធំរបស់នគរផង ជាអ្នកពិចារណាឃើញការប្រជុំរបស់ភូតរូប និងឧបាទាយរូបទាំងឡាយរឿយៗ ប្រៀបដូចបុគ្គលញែកស្លឹកចេក ស្រទបចេកចេញអំពីដើមចេក និងប្រៀបដូចបុគ្គលផ្ទារបាតដៃទទេផង ដូច្នោះ ។ ពិតហើយ ក្នុងអធិការនេះ កាយក្ដី ស្រីក្ដី ប្រុសក្ដី ឬធម៌ណាមួយដទៃក្ដី ដែលក្រៅអំពីកាយ គឺទីប្រជុំតាមដែលពោលហើយ រមែងមិនប្រាកដ តែសត្វទាំងឡាយ រមែងធ្វើនូវការប្រកាន់មាំព្រោះការយល់ខុស ក្នុងហេតុត្រឹមតែការប្រជុំនៃធម៌តាមដែលពោលហើយ ដោយប្រការនោះៗ ដោយហេតុនោះទើបបោរាណាចារ្យពោលថា

បុគ្គលឃើញនូវវត្ថុណា វត្ថុនោះ ឈ្មោះថា បុគ្គលនោះ ឃើញហើយក៏មិនមែន វត្ថុណា ដែលបុគ្គលនោះ ឃើញហើយ បុគ្គលនោះ ឈ្មោះថា រមែងមិនឃើញនូវវត្ថុនោះ បុគ្គលដែលវង្វេង កាលមិនឃើញ រមែងជាប់ កាលជាប់ ក៏រមែងមិនរួចផុត ។

ពាក្យនេះ លោកពោលថា ដើម្បីសម្តែងការបែកយនៈជាដើម ។ ម្យ៉ាងទៀត ក្នុងអធិការនេះ បណ្ឌិតគប្បីជ្រាបអត្ថនេះ ដោយ **អាទិ** សព្ទ ។ ពិតហើយ ព្រះយោគាវចរនេះ មានប្រក្រតីតាមឃើញកាយ ក្នុងកាយនេះប៉ុណ្ណោះ មិនមែនមានប្រក្រតីតាមឃើញធម៌ដទៃឡើយ ។ សួរថា សេចក្តីនេះ លោកអធិប្បាយដូចម្តេច ឆ្លើយថា លោកអធិប្បាយថា ជនទាំងឡាយដែលមានប្រក្រតីតាមឃើញថ្ងៃបណ្តើរកូន ដែលមិនមានទឹក ថាជាទឹក យ៉ាងណា ព្រះយោគាវចរមានប្រក្រតីតាមឃើញកាយនេះ ដែលជារបស់មិនទៀងជាទុក្ខ ជាអនត្តា ជាអសុភនោះឯងថា ជារបស់ទៀង ជាសុខ ជាអត្តា ជាសុភដូច្នោះ ក៏មិនមែន ដោយពិត មានប្រក្រតីតាមឃើញកាយ គឺមានប្រក្រតីតាមឃើញការប្រជុំនៃអាការមិនទៀង ជាទុក្ខ ជាអនត្តា ជាអសុភប៉ុណ្ណោះ ដូច្នេះ ។

ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបអត្ថយ៉ាងនេះថា កាយនេះ មានខ្យល់អស្សាសៈ បស្សាសៈជាខាងដើម និងមានឆ្អឹងដែលបែកទៅជាលម្អិតតូចធំជាទីបំផុត ដែលព្រះមានព្រះភាគត្រាស់ក្នុងមហាសតិប្បដ្ឋាន ដោយន័យថា ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្តី ។បេ។ មានសតិដកដង្ហើមចូលជាដើម

កាយណាដែលព្រះធម្មសេនាបតីសារីបុត្ត ពោលក្នុងបដិសម្ភិទាមគ្គថា បុគ្គល ពួកមួយ ក្នុងលោកនេះ ពិចារណាឃើញនូវពួកដី ថាមិនទៀង ពិចារណា ឃើញនូវពួកទឹក ពួកភ្លើង ពួកខ្យល់ ពួកសក់ ពួករោម ពួកសម្បុរថ្ងៃ ពួក ស្បែក ពួកសាច់ ពួកសរសៃ ពួកឆ្អឹង ពួកខួរក្នុងឆ្អឹង ដូច្នេះ ព្រោះការតាម ឃើញនូវកាយទាំងពួង ក្នុងកាយនេះឯង ទើបឈ្មោះថា ពិចារណានូវកាយ ក្នុងកាយ ដូច្នេះ ។

ម្យ៉ាងទៀត គប្បីជ្រាបអត្ថយ៉ាងនេះថា ឈ្មោះថា មានប្រក្រតីតាម ឃើញកាយ ពោល គឺទីប្រជុំនៃធម៌ មានសក់ជាដើមក្នុងកាយ ដោយការ មិនតាមឃើញណាមួយ ដែលគប្បីកាន់យកក្នុងកាយយ៉ាងនេះថា ជាអញ ឬ ថាជារបស់អញដូច្នេះ តែព្រោះការតាមឃើញទីប្រជុំនៃធម៌ផ្សេងៗ មានសក់ រោមជាដើមនោះឯង ទើបឈ្មោះថា **កាយេ កាយានុបស្សី** ដូច្នេះ ។

ម្យ៉ាងទៀត គប្បីជ្រាបអត្ថយ៉ាងនេះថា ឈ្មោះថា ពិចារណានូវកាយ-ក្នុងកាយ ព្រោះការតាមឃើញកាយ ពោល គឺទីប្រជុំនៃអាការដែលមាន អនិច្ចលក្ខណៈជាដើមទាំងពួង ដែលមានន័យមកហើយ ក្នុងបដិសម្ភិទាមគ្គ ដោយលំដាប់ថា ភិក្ខុរមែងតាមឃើញក្នុងកាយនេះ ថាមិនទៀង មិនមែន ជាទៀងទេ ដូច្នេះជាដើម ។

ពិតហើយ គប្បីជ្រាបថា ភិក្ខុនេះដែលប្រព្រឹត្តបដិបទា គឺការពិចារណា ឃើញកាយក្នុងកាយរឿយៗ រមែងតាមឃើញកាយនេះ ដោយភាពជារបស់ មិនទៀង ដោយអំណាចអនុបស្សនា ៧ មានអនិច្ចានុបស្សនាជាដើម មិនមែន

តាមឃើញដោយភាពជារបស់ទៀង រមែងតាមឃើញដោយភាពជាទុក្ខ មិនមែនតាមឃើញដោយភាពជាសុខ រមែងតាមឃើញដោយភាពជាអនត្តា មិនមែនតាមឃើញដោយភាពជាអត្តា រមែងនឿយណាយ មិនមែនត្រេកអរ រមែងប្រាសចាកតម្រេក មិនមែនត្រេកត្រអាល រមែងឲ្យរលត់ មិនមែនឲ្យកើត រមែងលះបង់ មិនមែនប្រកាន់ ភិក្ខុនោះ កាលតាមឃើញកាយនោះដោយភាពជារបស់មិនទៀង រមែងលះនូវនិច្ចសញ្ញា កាលតាមឃើញដោយភាពជាទុក្ខ រមែងលះសុខសញ្ញា កាលតាមឃើញដោយភាពជាអនត្តា រមែងលះអត្តសញ្ញា កាលនឿយណាយ រមែងលះនូវការត្រេកអរ កាលប្រាសចាកតម្រេក រមែងលះនូវរាគៈ កាលរលត់ រមែងលះសមុទយៈ កាលលះបង់ រមែងលះការប្រកាន់ ដូច្នេះ ។

បទថា **វិហរតិ** នោះ ជាពាក្យសម្ដែងការប្រកប ការនៅដោយឥរិយាបថណាមួយ បណ្ដាការនៅដោយឥរិយាបថ ៤ អធិប្បាយថា កាត់ផ្ដាច់នូវការបៀតបៀននូវឥរិយាបថមួយដោយឥរិយាបថដទៃហើយ ទើបនាំអត្តភាពដែលមិនទាន់ធ្លាក់ចុះទៅ គឺឲ្យប្រព្រឹត្តទៅ ។

បទថា **ពហិទ្ធា កាយេ** បានដល់ ក្នុងកាយរបស់អ្នកដទៃ ។ បទថា **អជ្ឈត្តពហិទ្ធា កាយេ** បានដល់ ក្នុងកាយរបស់ខ្លួនតាមកាលសមគួរ ក្នុងកាយរបស់អ្នកដទៃ តាមកាលសមគួរ ។ ដោយន័យដំបូង លោកពោលការកំណត់កាយក្នុងកាយរបស់ខ្លួន ដោយន័យទី ២ លោកពោលការកំណត់កាយក្នុងកាយរបស់អ្នកដទៃ ក្នុងន័យទី ៣ លោកពោលការកំណត់កាយក្នុងកាយ

របស់ខ្លួនតាមកាលសមគួរ ក្នុងកាយរបស់បុគ្គលដទៃតាមកាលសមគួរ ។ ឈ្មោះថា អារម្មណ៍ដែលប៉ះខ្ទប់ទាំងឡាយ ទាំងខាងក្នុង ទាំងខាងក្រៅ ព្រមគ្នា រមែងមិនមាន តែលោកពោលកាលជាទីត្រាច់ទៅរបស់កម្មដ្ឋាន ដែលស្ទាត់ជំនាញ ត្រឡប់ទៅ ត្រឡប់មក ក្នុងបទថា **អជ្ឈត្តពហិទ្ធា** ដូច្នេះ ។

បទថា **អាតាបី** នោះ ជាពាក្យសម្ដែងការប្រកបការព្យាយាមរបស់បុគ្គលអ្នកកំណត់កាយជាអារម្មណ៍ ។ ព្រោះហេតុដែលភិក្ខុនោះប្រកបសេចក្ដីព្យាយាម ដែលលោកឲ្យឈ្មោះថា **អាតាប** ព្រោះជាគ្រឿងដុតបំផ្លាញកិលេសទាំងឡាយក្នុងភពទាំង ៣ ក្នុងសម័យនោះ ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **អាតាបី** ។

បទថា **សម្បជានោ** បានដល់ ដែលប្រកបដោយញាណ ពោល គឺ សម្បជញ្ញៈ ដែលកំណត់យកនូវកាយជាអារម្មណ៍ ។

បទថា **សតិមា** បានដល់ ប្រកបដោយសតិដែលកំណត់កាយ ។ ព្រោះភិក្ខុនេះ កំណត់អារម្មណ៍ដោយសតិ ហើយតាមឃើញដោយបញ្ញា ។ ពិតហើយ ឈ្មោះថា អនុបស្សនារបស់ភិក្ខុដែលវៀរចាកសតិ មិនមាន ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សតិជាគ្រឿងសម្រេចប្រយោជន៍គ្រប់យ៉ាង ដូច្នេះ ហេតុនោះ កម្មដ្ឋាន គឺកាយានុបស្សនាសតិប្បដ្ឋាន ដោយពាក្យមានប្រមាណប៉ុណ្ណេះថា **កាយេ កាយានុបស្សី វិហរតិ** នេះ រមែងជាពាក្យអធិប្បាយ ដែលព្រះមានព្រះភាគត្រាស់ហើយ

ក្នុងពាក្យថា **សតិមា** នេះ ។

ម្យ៉ាងទៀត គប្បីជ្រាបថា ព្រោះការរួញរាខាងក្នុង ជាធម៌ធ្វើអន្តរាយដល់ភិក្ខុដែលមិនមានអាតាបី ដែលមិនមានសម្បជញ្ញៈ រមែងវង្វេងក្នុងការកំណត់ធម៌ដែលជាឧបាយ និងក្នុងការវៀរចាកវត្ថុដែលមិនមែនឧបាយ ។ ភិក្ខុដែលមិនមានសតិ រមែងជាអ្នកលះបង់ឧបាយពិតប្រាកដ និងត្រូវកំណត់វត្ថុដែលមិនមែនឧបាយពិតប្រាកដ ព្រោះហេតុនោះ ទើបកម្មដ្ឋានរបស់បុគ្គលនោះ មិនសម្រេច ព្រោះហេតុនោះ កម្មដ្ឋាននោះ រមែងសម្រេចដោយអានុភាពនៃធម៌ទាំងឡាយណា ដើម្បីសម្តែងធម៌ទាំងឡាយនោះ ទើបព្រះមានត្រាស់ពាក្យនេះថា **អាតាបី សម្បជានោ សតិមា** ដូច្នេះ ។

កាលទ្រង់សម្តែងកាយានុបស្សនាសតិប្បដ្ឋាន និងសម្បយោគ គឺការប្រកបព្រមដោយប្រការដូច្នេះហើយ ឥឡូវនេះ ដើម្បីសម្តែងអង្គដែលលះទើបត្រាស់ថា **វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិនេយ្យ** បានដល់ នាំចេញហើយដោយតទង្គវិន័យ ឬដោយវិក្ខម្ភនវិន័យ ។ ក្នុងបទថា **លោកេ** នេះ កាយនេះ មានកាយខាងក្នុងជាដើម ដែលទ្រង់កំណត់កាយនោះឯង ឈ្មោះថា **លោក** ក្នុងទីនេះ អធិប្បាយថា បណ្តេញបង់នូវអភិជ្ឈា និងទោមនស្ស ក្នុងលោកនេះ តែព្រោះក្នុងទីនេះ កាមច្ឆន្ទៈ រមែងដល់នូវការសង្គ្រោះដោយ **អភិជ្ឈា** សព្ទ ព្យាបាទ រមែងដល់នូវការសង្គ្រោះដោយ **ទោមនស្ស** សព្ទ ហេតុនោះ គប្បីជ្រាបថា ការលះនីវរណៈ ជាពាក្យដែលព្រះមានព្រះភាគត្រាស់ហើយ ដោយ

ការសម្ដែងធម៌ ២ យ៉ាង ដែលមានកម្លាំងទាក់ទងក្នុងនីវរណៈ ដូច្នេះ ។

ម្យ៉ាងទៀត ពោលដោយពិសេសក្នុងទីនេះ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ការលះនូវការត្រេកអរ ដែលមានកាយសម្បត្តិជាមូល ដោយការនាំអភិជ្ឈាចេញ ត្រាស់ការលះសេចក្ដីមិនត្រេកអរ ដែលមានកាយវិបត្តិជាមូល ដោយការនាំទោមនស្សចេញ ។ ត្រាស់ការលះនូវការត្រេកអរក្រៃលែងក្នុងកាយដោយការនាំអភិជ្ឈាចេញ ត្រាស់ការលះនូវការមិនត្រេកអរក្រៃលែងដោយកាយភាវនា ក្នុងកាយភាវនា ដោយការនាំទោមនស្សចេញ និងត្រាស់ការលះនូវការបន្ថែមក្នុងវត្ថុដែលមិនមានក្នុងកាយ ដែលមានការស្អាត សេចក្ដីសុខជាដើម ដោយការនាំអភិជ្ឈាចេញ ត្រាស់ការលះនូវការនាំចេញនូវវត្ថុដែលមិនមានក្នុងកាយ ដែលមានការមិនស្អាត មិនសុខជាដើម ដោយការនាំទោមនស្សចេញ ។ ដោយពាក្យនោះ អានុភាពនៃសេចក្ដីព្យាយាម និងភាពជាអ្នកអាចក្នុងសេចក្ដីព្យាយាមនៃព្រះយោគាវចរឈ្មោះថា ព្រះមានព្រះភាគសម្ដែងហើយ ពិតហើយ អានុភាពនៃសេចក្ដីព្យាយាមនោះ រមែងរួចផុតចាកការត្រេកអរ មិនត្រេកអរ អត់ធន់ចំពោះការមិនត្រេកអរ និងការត្រេកអរ ទាំងវៀរចាកការបន្ថែមក្នុងវត្ថុដែលមិនមាន និងវៀរចាកការនាំវត្ថុដែលមានចេញទៅ ។ ព្រះយោគាវចរនោះ ផុតចាកការត្រេកអរ មិនត្រេកអរ អត់ធន់ចំពោះការមិនត្រេកអរ និងការត្រេកអរ កាលមិនបន្ថែមក្នុងវត្ថុដែលមិនមាន និងមិននាំវត្ថុដែលមានចេញទៅ ទើបឈ្មោះថា ជាអ្នកមានការអាចក្នុងសេចក្ដីព្យាយាមនោះ ។

ន័យម្យ៉ាងទៀត ក្នុងបទថា **កាយេ កាយានុបស្សី** នេះ ព្រះមានព្រះភាគត្រាស់កម្មដ្ឋានដោយអនុបស្សនា ។ ក្នុងបទថា **វិហរតិ** នេះ ត្រាស់ការបរិហារកាយរបស់បុគ្គលដែលបដិបត្តិកម្មដ្ឋានដោយការនៅ តាមដែលពោលហើយ ។ ក្នុងបទថា **អាតាបី** ជាដើម ទ្រង់ត្រាស់សម្មប្បធានដោយអាតាបៈ ត្រាស់កម្មដ្ឋានដែលមានប្រយោជន៍ទាំងពួង ឬឧបាយជាគ្រឿងរក្សាកម្មដ្ឋានដោយសតិសម្បជញ្ញៈ ។ ម្យ៉ាងទៀត ត្រាស់សមថៈដែលបានហើយ ដោយអំណាចកាយានុបស្សនាដោយសតិ ត្រាស់វិបស្សនាដោយសម្បជញ្ញៈ និងត្រាស់ផលនៃភាវនា ដោយការនាំអភិជ្ឈា និងទោមនស្សចេញ ។ អធិប្បាយឧទ្ទេសនៃកាយានុបស្សនាសតិប្បដ្ឋាន មានប្រមាណប៉ុណ្ណេះ ។

## អធិប្បាយ ឧទ្ទេសនៃវេទនានុបស្សនាជាដើម

គប្បីជ្រាបវិនិច្ឆ័យក្នុងឧទ្ទេសនៃវេទនានុបស្សនាសតិប្បដ្ឋានជាដើមតទៅ បទថា **អជ្ឈត្តំ** ជាដើម ដោយន័យដែលពោលហើយនោះឯង បណ្តាវេទនាជាដើមនេះ ព្រះមានព្រះភាគត្រាស់ការកំណត់ ៣ យ៉ាង គឺក្នុងវេទនាជាដើមរបស់ខ្លួន ១ ក្នុងវេទនាជាដើមរបស់អ្នកដទៃ ១ ក្នុងវេទនាជាដើមរបស់ខ្លួនតាមកាលសមគួរ របស់អ្នកដទៃតាមកាលសមគួរ ១ ។ ប្រយោជន៍ក្នុងការពោលត្រួតសេចក្តីទូវធម៌ មានវេទនាជាដើម ក្នុងពាក្យទាំងឡាយ មានពាក្យថា **វេទនាសុ វេទនានុបស្សី** ជាដើម គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងកាយានុបស្សនានោះឯង ។

ក្នុងបទថា **វេទនាសុ វេទនានុបស្សី ចិត្តេ ចិត្តានុបស្សី ធម្មេសុ ធម្មានុបស្សី** នេះ ពាក្យថា **វេទនា** បានដល់ វេទនា ៣ ហើយវេទនាទាំងនោះ ក៏ត្រឹមតែជាលោកិយប៉ុណ្ណោះ ។ សូម្បីចិត្ត ក៏ជាលោកិយ ។ ធម៌ទាំងឡាយក៏យ៉ាងនោះ ។ ការចែកធម៌ទាំងនោះ នឹងប្រាកដក្នុងនិទ្ទេសវារៈ តែក្នុងទីនេះ វេទនាដែលភិក្ខុគប្បីតាមឃើញបានដោយប្រការណា កាលតាមឃើញទាំងអស់ដោយប្រការនោះ គប្បីជ្រាបថា ពិចារណាឃើញវេទនាក្នុងវេទនាទាំងឡាយ ដូច្នេះ ។ ក្នុងចិត្ត និងធម៌ទាំងឡាយ ក៏មានន័យដូចគ្នា ។

សួរថា ព្រះយោគាវចរគប្បីតាមឃើញវេទនាដូចម្តេច ឆ្លើយថា សុខវេទនា គប្បីតាមឃើញដោយភាពជាទុក្ខ ទុក្ខវេទនា គប្បីតាមឃើញដូចកូនសរ អទុក្ខមសុខវេទនា គប្បីតាមឃើញដោយភាពជាសភាវៈមិនទៀង ដូចព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ សឡាយតនវគ្គ ) ថា

អ្នកឯណា បានឃើញសុខវេទនាថា ជាទុក្ខវេទនាវិញ បានឃើញ
ទុក្ខវេទនាថាជាកូនសរ បានឃើញអទុក្ខមសុខវេទនានោះថា ជា
សភាវៈមិនទៀងទៅវិញ ។ បើភិក្ខុបានឃើញដោយប្រពៃ នឹងជា
អ្នកស្ងប់ ត្រាច់ទៅ ដូច្នេះ ។

ម្យ៉ាងទៀត វេទនាទាំងអស់នោះ គប្បីតាមឃើញថា ជាទុក្ខប៉ុណ្ណោះក៏បាន សេចក្តីនេះ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ សឡាយតនវគ្គ ) ថា តថាគតបានពោលថា អារម្មណ៍ឯណានីមួយដែលបុគ្គលបានសោយហើយ អារម្មណ៍នោះក៏ជាទុក្ខ ដូច្នេះ ។

សុខវេទនា គប្បីតាមឃើញដោយភាពជាទុក្ខក៏បាន ដូចព្រះតម្រាស់ ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលអាវុសោវិសាខៈ សុខវេទនាមានកិរិយាស្ថិតនៅដែលជាសុខ មានការប្រែប្រួលទៅវិញជាទុក្ខ ដូច្នេះ បណ្ឌិតគប្បីញ៉ាំងពាក្យទាំងអស់ឲ្យពិស្តារ ។

ម្យ៉ាងទៀត គប្បីតាមឃើញវេទនា ដោយអំណាចនៃអនុបស្សនា ៧ មានអនិច្ចានុបស្សនាជាដើមក៏បាន ។ ពាក្យដ៏សេស នឹងមានច្បាស់ក្នុងនិទ្ទេសវារ ។

ក្នុងចិត្ត និងធម៌ទាំងឡាយ ជំបូង ចិត្ត គប្បីតាមឃើញដោយអំណាចនៃអនុបស្សនា ៧ មានអនិច្ចានុបស្សនាជាដើម ដែលមានប្រការផ្សេងៗ គ្នា ដោយជាអារម្មណ៍ អធិបតី សហជាត ភូមិ កម្ម វិបាក និងកិរិយាជាដើម និងដោយអំណាចនៃការផ្សេងគ្នានៃចិត្ត មានរាគៈជាដើម ដែលមកហើយក្នុងនិទ្ទេសវារ ។ ធម៌ទាំងឡាយ គប្បីតាមឃើញដោយអំណាចនៃសលក្ខណៈ និងសាមញ្ញលក្ខណៈ សុញ្ញតាធម៌ អនុបស្សនា ៧ មានអនិច្ចានុបស្សនាជាដើម និងដោយអំណាចនៃការផ្សេងគ្នានៃធម៌ដែលស្ងប់ និងមិនស្ងប់ជាដើម ដែលមកហើយក្នុងនិទ្ទេសវារ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។ ក្នុងអធិការនេះ អភិជ្ឈា និងទោមនស្ស ក្នុងលោក ពោល គឺកាយដែលបុគ្គលណាលះបានហើយ អភិជ្ឈា និងទោមនស្សនោះ សូម្បីក្នុងលោក ពោល គឺវេទនាជាដើម ក៏ឈ្មោះថា បុគ្គលនោះលះបានហើយ ដូចគ្នាក៏ពិត តែព្រះមានព្រះភាគក៏ត្រាស់ក្នុងសតិប្បដ្ឋានទាំងអស់ ដោយ

*អំណាចនៃបុគ្គលផ្សេងៗ និងដោយអំណាចនៃការចម្រើនសតិប្បដ្ឋាន ដែលកើតឡើងក្នុងខណៈនៃចិត្តដែលផ្សេងគ្នា ។ ម្យ៉ាងទៀត បុគ្គលលះអភិជ្ឈា និងទោមនស្ស ក្នុងលោក មួយបានហើយ ក៏ឈ្មោះថា លះអភិជ្ឈា និងទោមនស្ស ក្នុងលោកដ៏សេសបាន ។ ដោយហេតុនោះឯង គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ពាក្យនោះ ក៏ដើម្បីសម្តែងការលះអភិជ្ឈា និងទោមនស្ស ក្នុងលោកទាំងនោះ របស់បុគ្គលនោះឯង ។*

**ឧទ្ទេសវារ ចប់**

# អធិប្បាយ កាយានុបស្សនានិទ្ទេស

*[ ១៧៨-១៨៦ ] ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់បំណងធ្វើសត្វទាំងឡាយឲ្យសម្រេចគុណវិសេសផ្សេងៗ មានប្រការមិនមែនតិច ដោយសតិប្បដ្ឋានទេសនា ទើបទ្រង់ចែកសម្មាសតិនោះឯងជា ៤ ចំណែក ជាសតិប្បដ្ឋាន ៤ ដោយអំណាចនៃអារម្មណ៍ ដោយន័យថា ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយក្នុងកាយខាងក្នុងជាដើម កាលទ្រង់កាន់យកសតិប្បដ្ឋានទីមួយៗ អំពីសតិប្បដ្ឋាន ៤ នោះ ចែកចេញទៅ ទើបផ្តើមត្រាស់និទ្ទេសវារ ដោយន័យជាដើមថា ចុះភិក្ខុពិចារណានូវកាយក្នុងកាយខាងក្នុង តើដូចម្តេច ដូច្នេះ ប្រៀបដូចជាងផែងអ្នកឈ្លាស ត្រូវការធ្វើឧបករណ៍ទាំងឡាយ មានកន្ទេលផែងប្រភេទគ្រោតគ្រាត និងល្អិត តៀប*

ត្រក និងជាលជាដើម បានឫស្សីដើមធំមកមួយដើម ហើយកាត់ជា ៤ កំណាត់ កាន់យកកំណាត់មួយអំពី ៤ កំណាត់នោះ ពុះហើយធ្វើឧបករណ៍នោះៗ ឬប្រៀបដូចជាងមាសដ៏ឈ្លាស ត្រូវការធ្វើគ្រឿងប្រដាប់ផ្សេងៗ បានដុំមាសដែលបរិសុទ្ធយ៉ាងល្អ កាត់ជា ៤ ចំណែក ហើយកាន់យកចំណែកមួយអំពី ៤ ចំណែកនោះ ធ្វើគ្រឿងប្រដាប់នោះៗ ដូច្នោះ ។

បណ្ដាបទទាំងនោះ បទថា **កថញ្ច** ជាដើម ជាពាក្យសួរដោយបំណងនឹងពោលឲ្យពិស្ដារ ។ ក្នុងអធិការនេះ មានអត្ថដោយសង្ខេបដូចតទៅនេះថា ដោយអាការដូចម្ដេច ដោយប្រការដូចម្ដេច ភិក្ខុ ឈ្មោះថា ពិចារណានូវកាយក្នុងកាយ ដូច្នេះ ក្នុងវារៈនៃពាក្យសួរដ៏សេស ក៏មានន័យនេះដូចគ្នា ។

បទថា **ឥធ ភិក្ខុ** បានដល់ ភិក្ខុក្នុងសាសនានេះ ។ សព្ទថា **ឥធ** ក្នុងទីនេះ ជាពាក្យសម្ដែងដល់សាសនា ដែលជាទីអាស្រ័យរបស់បុគ្គលអ្នកញ៉ាំងកាយានុបស្សនាដោយប្រការទាំងពួង ដោយអំណាចនៃកាយខាងក្នុងជាដើមឲ្យកើតឡើង និងបដិសេធភាពជាយ៉ាងនោះរបស់សាសនាដទៃ ដូចព្រះតម្រាស់ ( ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ សមណៈទី ១ ក៏មានក្នុងធម្មវិន័យនេះ ។បេ។ បរប្បវាទ ( លទ្ធិ ) ទាំងឡាយសូន្យចាកពួកសមណៈដទៃ ដូច្នេះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ភិក្ខុក្នុងសាសនានេះ ដូច្នេះ ។

បទថា **អជ្ឈត្តំ កាយំ** បានដល់ កាយរបស់ខ្លួន ។ បទថា **ឧទ្ធំ បាទតលា** បានដល់ ខាងលើអំពីបាតជើងឡើងមក ។ បទថា **អធោ**

**កេសមត្ថកា** *បានដល់ ខាងក្រោមអំពីចុងសក់ចុះមក ។ បទថា* **តច-បរិយន្តំ** *បានដល់ ជុំវិញត្រឹមស្បែក ។ បទថា* **បូរំ នានប្បការស្ស អសុចិនោ បច្ចវេក្ខតិ** *សេចក្តីថា ព្រះយោគាវចររមែងឃើញថា កាយនេះ ពេញទៅដោយរបស់មិនស្អាត មានសក់ជាដើម ដែលមានប្រការផ្សេងៗ ។ សេចក្តីនេះដូចម្តេច គឺ* **អត្ថិ ឥមស្មឹ កាយេ កេសា លោមា ។បេ។ មុត្តំ** *ដូច្នេះ ។*

*បណ្តាបទទាំងនោះ បទថា* **អត្ថិ** *ប្រែថា មាននៅ ។ បទថា* **ឥមស្មឹ** *បានដល់ ក្នុងកាយដែលលោកពោលថា ខាងលើ តាំងអំពីបាតជើងឡើងទៅ ខាងក្រោម តាំងអំពីចុងសក់ចុះមក ជុំវិញត្រឹមស្បែក ពេញទៅដោយរបស់មិនស្អាត មានប្រការផ្សេងៗ នេះ ។ បទថា* **កាយេ** *បានដល់ ក្នុងសរីរៈ ។ ពិតហើយ សរីរៈ លោកហៅថា* **កាយ** *ព្រោះសន្សំរបស់មិនស្អាត ជាប្រភពកើតនៃកោដ្ឋាសទាំងឡាយ មានសក់ជាដើមដែលគួរខ្ពើស ទាំងជាប្រភពកើតនៃរោគច្រើនរយ មានរោគភ្នែកជាដើម ។ បទថា* **កេសា លោមា** *ជាដើមនេះ គឺអាការ ៣២ មានសក់ជាដើម ។*

*គប្បីជ្រាបការសម្ពន្ធក្នុងកោដ្ឋាសទាំងនោះយ៉ាងនេះ គឺសក់មាននៅក្នុងកាយនេះ រោមមាននៅក្នុងកាយនេះ ពិតហើយ ក្នុងកឡេវរៈ គឺអត្តភាពប្រមាណមួយព្យាយាមនេះ ខាងលើ ចាប់អំពីបាតជើងឡើងទៅ ខាងក្រោម ចាប់អំពីចុងសក់ចុះមក ទីបំផុតជុំវិញ ចាប់អំពីស្បែកចូលទៅ កាលពិចារណាដោយអាការសព្វយ៉ាង បុគ្គលរមែងមិនជួបរបស់ណាមួយ មានកែវ*

មុត្តា កែវមណី កែវពិទូរ្យ ក្រស្នា ចន្ទន៍ក្រហម កប្បូរ ឬលម្អិតសម្រាប់អប់ជាដើមឡើយ ឬវត្ថុដែលជារបស់ស្អាត សូម្បីតិចតួច ដោយពិត រមែងជួបតែវត្ថុដែលមិនស្អាតទាំងអស់ មានសក់ រោមជាដើម មានប្រការផ្សេងៗ ដែលមានក្លិនស្អុយគួរខ្ពើមយ៉ាងក្រៃលែង ទាំងការមើល ក៏មិនជាសិរី ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **អត្ថិ ឥមស្មឹ កាយេ កេសា លោមា ។បេ។ មុត្តំ** ដូច្នេះ នេះជាកិច្ចពណ៌នាបទសម្ពន្ធក្នុងអធិការនេះ ។

កុលបុត្រប្រាថ្នានឹងចម្រើនកម្មដ្ឋាននេះ ដើម្បីសម្រេចអរហត្ត ខាងដើមត្រូវជម្រះសីល ៥ ឲ្យបរិសុទ្ធ តាំងនៅក្នុងសីលដែលបរិសុទ្ធល្អហើយ កាត់នូវបលិពោធ ដែលមានបណ្ដាបលិពោធ ១០ យ៉ាង បំពេញបឋមជ្ឈានឲ្យកើតឡើង ដោយការចម្រើនបដិកូលមនសិការកម្មដ្ឋាន ធ្វើឈានឲ្យជាបាទផ្ដើមវិបស្សនា គប្បីរៀនយកក្នុងសម្នាក់របស់កល្យាណមិត្រដែលសម្រេចអរហត្ត ឬដែលសម្រេចផលឯណានីមួយ ក្នុងអនាគាមិផលជាដើម ដោយកំណត់យ៉ាងទាបបំផុត សូម្បីជាតន្តិអាចារ្យ គឺអាចារ្យអ្នកបង្រៀនព្រះពុទ្ធ-វចនៈ ដែលជំនាញក្នុងព្រះបាលី មួយអន្ទើដោយអដ្ឋកថា តែកាលមិនបាននូវកល្យាណមិត្របែបនោះក្នុងវិហារជាមួយគ្នា គប្បីទៅកាន់លំនៅរបស់លោកហើយរៀនយកចុះ ។ ក្នុងវិធីទាំងនោះ ការជម្រះសីល ៤ ឲ្យបរិសុទ្ធ បលិពោធ ការកាត់បលិពោធ និងវិធីចូលទៅកាន់សម្នាក់របស់អាចារ្យទាំងអស់នោះ ខ្ញុំពោលដោយពិស្ដារហើយក្នុងបករណវិសុទ្ធិមគ្គ ព្រោះហេតុនោះ គប្បីជ្រាបកិច្ចនោះ ដោយន័យដែលពោលហើយ ក្នុងបករណវិសុទ្ធិមគ្គ

នោះឯង ។

អាចារ្យអ្នកប្រាប់កម្មដ្ឋាន គប្បីប្រាប់ដោយវិធី ៣ យ៉ាង គឺសម្រាប់ភិក្ខុដែលរៀនកម្មដ្ឋានតាមប្រក្រតី អាចារ្យគប្បីឲ្យលោកធ្វើការស្វាធ្យាយ ក្នុងពេលាដែលមករៀន មួយដង ឬពីរដង ហើយសឹមប្រាប់ ។ សម្រាប់ភិក្ខុដែលត្រូវការនៅក្នុងសម្នាក់ជិតហើយរៀនយកកម្មដ្ឋាន អាចារ្យគប្បីប្រាប់ក្នុងពេលដែលលោកមកហើយ ។ សម្រាប់ភិក្ខុដែលត្រូវការរៀន ហើយចេញទៅក្នុងទីដទៃ អាចារ្យគប្បីប្រាប់កម្មដ្ឋានកុំឲ្យស្មុគស្មាញ កុំឲ្យសង្ស័យ ដោយមិនធ្វើឲ្យពិស្តារពេក និងមិនជាសង្ខេបពេក ។

សួរថា កាលប្រាប់ អាចារ្យគប្បីប្រាប់ដូចម្ដេច ឆ្លើយថា គប្បីប្រាប់ឧគ្គហកោសល ៧ យ៉ាង និងមនសិការកោសល ១០ យ៉ាង ។ ក្នុងពីរយ៉ាងនោះ អាចារ្យគប្បីប្រាប់ឧគ្គហកោសល ៧ យ៉ាងនេះ គឺ **វចសា** ដោយវាចា ១ **មនសា** ដោយចិត្ត ១ **វណ្ណតោ** ដោយពណ៌ ១ **សណ្ឋានតោ** ដោយសណ្ឋាន ១ **ទិសតោ** ដោយទិស ១ **ឱកាសតោ** ដោយឱកាស ១ **បរិច្ឆេទតោ** ដោយបរិច្ឆេទ ១ ។

ក្នុងបដិកូលមនសិការកម្មដ្ឋាននេះ ភិក្ខុទោះបីជាអ្នកទ្រទ្រង់ព្រះត្រៃបិដកក៏គប្បីធ្វើការស្វាធ្យាយដោយវាចាមុន ក្នុងពេលដែលមនសិការ ។

ព្រោះកាលភិក្ខុនោះតែម្នាក់ធ្វើការស្វាធ្យាយ កម្មដ្ឋានរមែងប្រាកដ ដូចព្រះថេរៈ ២ រូប អ្នករៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះមហាទេវត្ថេរ ដែលនៅក្នុងមលយប្រទេស ។

បានឮថា ព្រះមហាទេវត្ថេរ កាលព្រះថេរៈពីររូបនោះសូមកម្មដ្ឋានហើយ បានឲ្យទ្វត្តឹសាការបាលី ដោយប្រាប់ថា ចូរលោកទាំងឡាយធ្វើនូវការស្វាធ្យាយយ៉ាងនេះ អស់ ៤ ខែ ព្រះថេរៈទាំងពីរអង្គនោះ សូម្បីមាន ២ និកាយ ៣ និកាយ ស្ទាត់ជំនាញហើយក៏ពិត តែព្រោះភាពដែលខ្លួនមានប្រក្រតីទទួលឱវាទដោយសេចក្ដីគោរព ទើបបានស្វាធ្យាយទ្វត្តឹសាការ អស់កាល ៤ ខែ បានជាព្រះសោតាបន្នហើយ ។

ព្រោះហេតុនោះ អាចារ្យកាលនឹងប្រាប់កម្មដ្ឋាន គប្បីប្រាប់អន្តេវាសិកថា ដំបូង ចូរលោកស្វាធ្យាយដោយវាចាមុន ដូច្នេះ កាលធ្វើការស្វាធ្យាយ គប្បីកំណត់តចបញ្ចកកម្មដ្ឋានជាដើម ហើយធ្វើនូវការស្វាធ្យាយ ដោយអំណាចអនុលោម និងបដិលោម ។

ពិតហើយ ភិក្ខុនោះ កាលពោលថា សក់ រោម ក្រចក ធ្មេញ ស្បែក ហើយគប្បីពោលដោយបដិលោមទៀតថា ស្បែក ធ្មេញ ក្រចក រោម សក់ ដូច្នេះ ។

កាលពោលថា សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ ក្នុងវក្កបញ្ចកៈ ដែលជាលំដាប់នៃតចបញ្ចកៈនោះហើយ គប្បីពោលដោយបដិលោមទៀតថា តម្រងបស្សាវៈ ខួរក្នុងឆ្អឹង ឆ្អឹង សរសៃ សាច់ ស្បែក ធ្មេញ ក្រចក រោម សក់ ដូច្នេះ ។

លំដាប់នោះ កាលពោលក្នុងបប្ផាសបញ្ចកៈថា បេះដូង ថ្លើម វាវ ក្រពះ សួត ហើយគប្បីពោលដោយបដិលោមទៀតថា សួត ក្រពះ វាវ

ថ្លើម បេះដូង តម្រងបស្សាវៈ ខ្លួរក្នុងឆ្អឹង ឆ្អឹង សរសៃ សាច់ ស្បែក ធ្មេញ ក្រចក រោម សក់ ដូច្នេះ ។

លំដាប់នោះ គប្បីលើកមត្ថលុង្គំ ដែលមកក្នុងបដិសម្ភិទាមគ្គ សូម្បីមិនបានលើកឡើងកាន់បាលីនេះ ឲ្យឡើងកាន់បាលីក្នុងទីបំផុតនៃអាហារចាស់ ហើយពោលក្នុងមត្ថលុង្គបញ្ចកៈនេះថា ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ខួរក្នុងក្បាល ហើយគប្បីពោលដោយបដិលោមទៀតថា ខួរក្នុងក្បាល អាហារចាស់ អាហារថ្មី ពោះវៀនតូច ពោះវៀនធំ សួត ក្រពះ វាវ ថ្លើម បេះដូង តម្រងបស្សាវៈ ខួរក្នុងឆ្អឹង ឆ្អឹង សរសៃ សាច់ ស្បែក ធ្មេញ ក្រចក រោម សក់ ដូច្នេះ ។ លំដាប់នោះ គប្បីពោលក្នុងមេទឆក្កៈថា ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ហើយគប្បីពោលដោយបដិលោមទៀតថា ខ្លាញ់ខាប់ ញើស ឈាម ខ្ទុះ ស្លេស្ម ប្រមាត់ ខួរក្នុងក្បាល អាហារចាស់ អាហារថ្មី ពោះវៀនតូច ពោះវៀនធំ សួត ក្រពះ វាវ ថ្លើម បេះដូង តម្រងបស្សាវៈ ខួរក្នុងឆ្អឹង ឆ្អឹង សរសៃ សាច់ ស្បែក ធ្មេញ ក្រចក រោម សក់ ដូច្នេះ ។ លំដាប់នោះ គប្បីពោលក្នុងមុត្តឆក្កៈថា ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល ទឹកមូត្រ ហើយគប្បីពោលដោយបដិលោមទៀតថា ទឹកមូត្រ ទឹករំអិល ទឹកសំបោរ ទឹកមាត់ ខ្លាញ់រាវ ទឹកភ្នែក ខ្លាញ់ខាប់ ញើស ឈាម ខ្ទុះ ស្លេស្ម ប្រមាត់ ខួរក្នុងក្បាល អាហារចាស់ អាហារថ្មី ពោះវៀនតូច ពោះវៀនធំ សួត ក្រពះ វាវ ថ្លើម បេះដូង តម្រងបស្សាវៈ ខួរក្នុងឆ្អឹង ឆ្អឹង សរសៃ សាច់ ស្បែក

ធ្មេញ ក្រចក រោម សក់ ដូច្នេះ ។

គប្បីធ្វើការស្វាធ្យាយមួយរយដងខ្លះ មួយពាន់ដងខ្លះ មួយសែនដងខ្លះ ដោយវាចាដូចពណ៌នាមក ដូច្នេះ ។ ពិតហើយ បែបផែននៃកម្មដ្ឋាន រមែងជាការស្ទាត់ជំនាញ ដោយការស្វាធ្យាយដោយវាចា ចិត្តរមែងមិនស្ទុះទៅក្នុងទីផ្សេងៗ កោដ្ឋាសទាំងឡាយរមែងប្រាកដ ដូចខ្សែសម្រាប់ពាក់កដៃ រមែងប្រាកដដូចជួរបង្គោលរបង ដូច្នោះ ។

ព្រះយោគាវចរ គប្បីធ្វើការស្វាធ្យាយដោយវាចាយ៉ាងណា សូម្បីការស្វាធ្យាយដោយចិត្តក៏យ៉ាងនោះឯង ព្រោះការស្វាធ្យាយដោយវាចា ជាបច្ច័យដល់ការស្វាធ្យាយដោយចិត្ត ការស្វាធ្យាយដោយចិត្ត ជាបច្ច័យដល់ការចាក់ធ្លុះនូវលក្ខណៈ ការចាក់ធ្លុះដោយលក្ខណៈ ជាបច្ច័យដល់ការចាក់ធ្លុះមគ្គ និងផល ។

ពាក្យថា ដោយពណ៌ សេចក្ដីថា គប្បីកំណត់ពណ៌នៃកោដ្ឋាសទាំងឡាយ មានសក់ជាដើម ។

ពាក្យថា ដោយសណ្ឋាន បានដល់ គប្បីកំណត់សណ្ឋាននៃកោដ្ឋាសទាំងឡាយ មានសក់ជាដើមនោះឯង ។

ពាក្យថា ដោយទិស សេចក្ដីថា ក្នុងសរីរៈនេះ ទិសខាងលើ ចាប់ពីផ្ចិតឡើងទៅ ទិសខាងក្រោម ចាប់ពីផ្ចិតចុះមក ហេតុនោះ គប្បីកំណត់ទិសថា កោដ្ឋាសនេះ នៅក្នុងទិសឈ្មោះនេះ ។

ពាក្យថា ដោយឱកាស សេចក្ដីថា គប្បីកំណត់ឱកាសនៃកោដ្ឋាស

នោះៗ យ៉ាងនេះថា កោដ្ឋាសនេះ តាំងនៅក្នុងឱកាសឈ្មោះនេះ ។

ពាក្យថា ដោយការកំណត់ បានដល់ ការកំណត់ពីរយ៉ាង គឺសភាគ-បរិច្ឆេទ និងវិសភាគបរិច្ឆេទ ។ ក្នុងការកំណត់ពីរយ៉ាងនោះ គប្បីជ្រាបសភាគបរិច្ឆេទ គឺកំណត់ចំណែកដែលស្មើគ្នាយ៉ាងនេះថា កោដ្ឋាសនេះ កំណត់ដោយកោដ្ឋាសឈ្មោះនេះ ទាំងខាងក្រោម ខាងលើ ខាងទទឹង ។ គប្បីជ្រាបវិសភាគបរិច្ឆេទ គឺកំណត់ចំណែកដែលមិនស្មើគ្នា ដោយអំណាចការមិនលាយឡំគ្នានៃកោដ្ឋាសយ៉ាងនេះថា សក់ មិនមែនរោម រោម ក៏មិនមែនសក់ជាដើម ។

អាចារ្យកាលនឹងប្រាប់ឧគ្គហកោសល ៧ យ៉ាង យ៉ាងនេះ គួរជ្រាបថា កម្មដ្ឋាននេះ ព្រះមានព្រះភាគត្រាស់ក្នុងសូត្រនោះ ដោយអំណាចនៃបដិកូល-កម្មដ្ឋាននេះ ត្រាស់ក្នុងព្រះសូត្រនោះដោយអំណាចនៃធាតុ ដូច្នេះហើយសឹមប្រាប់ ។

ពិតហើយ កាយានុបស្សនាសតិប្បដ្ឋាននេះ ព្រះមានព្រះភាគត្រាស់ក្នុងមហាសតិប្បដ្ឋាន ដោយអំណាចនៃបដិកូលប៉ុណ្ណោះ តែក្នុងមហាហត្ថិ-បទោបមសូត្រ មហារាហុលោវាទសូត្រ និងធាតុវិភង្គ ត្រាស់ដោយអំណាចនៃធាតុ ក្នុងកាយគតាសតិសូត្រ កាយានុបស្សនាសតិប្បដ្ឋាន រមែងប្រាកដដោយពណ៌នៃកោដ្ឋាសណា ត្រាស់ចែកឈាន ៤ សំដៅយកកោដ្ឋាសនោះ ។ បណ្ដាកម្មដ្ឋាន ២ យ៉ាងនោះ វិបស្សនាកម្មដ្ឋាន ត្រាស់ដោយអំណាចនៃធាតុ សមថកម្មដ្ឋាន ត្រាស់ដោយអំណាចនៃបដិកូល ។ អាចារ្យពួកខ្លះ ពោលថា

សមថកម្មដ្ឋាននេះ ព្រះមានព្រះភាគត្រាស់ក្នុងសតិប្បដ្ឋានវិភង្គ ដោយអំណាចនៃសាធារណកម្មដ្ឋានទាំងពួង ដោយមិនបែកគ្នាដូច្នេះ ។

អាចារ្យកាលប្រាប់ឧគ្គហកោសល ៧ យ៉ាង យ៉ាងនេះហើយ ទើបប្រាប់មនសិការកោសល ១០ យ៉ាងនេះ គឺ **អនុបុព្វតោ** គឺដោយលំដាប់ ១ **នាតិសីឃតោ** គឺដោយមិនប្រញាប់រូសរាន់ ១ **នាតិសណិកតោ** ដោយមិនយឺតយូរពេក ១ **វិក្ខេបបដិពាហនតោ** ដោយការហាមនូវការរាយមាយ ១ **បណ្ណត្តិសមតិក្កមនតោ** ដោយការឈានកន្លងបញ្ញត្តិ ១ **អនុបុព្វមុញ្ចនតោ** ដោយការកន្លងលំដាប់ ១ **អប្បនាតោ** ដោយអប្បនា ១ **តយោ ច សុត្តន្តា** ដោយសុត្តន្ត ៣ ។

បណ្តាកោសលទាំង ១០ នោះ ពាក្យថា ដោយលំដាប់ សេចក្តីថា ព្រះយោគាវចរ គប្បីធ្វើកម្មដ្ឋាននោះក្នុងចិត្តដោយលំដាប់ គឺតាំងអំពីការស្វាធ្យាយ មិនគប្បីវៀរកម្មដ្ឋានណាមួយក្នុងចន្លោះ ព្រោះកាលមនសិការវៀរកម្មដ្ឋានមួយក្នុងចន្លោះ ចិត្តក៏គប្បីហត់នឿយ រមែងធ្លាក់ទៅអំពីអារម្មណ៍ ព្រោះការមិនសម្រេចតាមគាប់ចិត្តដែលគប្បីបាន ដោយអំណាចនៃភាវនាសម្បត្តិ រមែងមិនធ្វើភាវនាឲ្យសម្រេច ប្រៀបដូចបុរសដែលមិនឈ្លាសឡើងជណ្តើរដែលមានកាំ ៣២ ដោយរំលងមួយកាំក្នុងចន្លោះ មានកាយហត់នឿយ រមែងធ្លាក់ចុះ រមែងឡើងជណ្តើរមិនសម្រេច ដូច្នោះ ។

ម្យ៉ាងទៀត កាលមនសិការទៅដោយលំដាប់ មិនគប្បីមនសិការដោយប្រញាប់រូសរាន់ ព្រោះថា កាលមនសិការដោយប្រញាប់រូសរាន់ពេក

កម្មដ្ឋានដល់ទីបំផុតតែម្យ៉ាង តែមិនជាក់ច្បាស់ ទាំងមិននាំមកនូវគុណវិសេស ប្រៀបដូចបុរសដើរផ្លូវ ៣ យោជន៍ មិនបានកំណត់ផ្លូវបត់ និងផ្លូវបំបែក ដើរទៅដើរមកដោយរហ័ស សូម្បី ៧ ដង ផ្លូវរមែងអស់ទៅដោយរហ័សក៏ពិត តែក៏ត្រូវសួរអ្នកដទៃរាល់ដង ទើបដើរទៅបាន ព្រោះហេតុនោះ ព្រះយោគាវចរមិនគប្បីមនសិការដោយរួសរាន់ពេកឡើយ ។

ព្រះយោគាវចរ មនសិការដោយមិនប្រញាប់យ៉ាងណា គប្បីមនសិការដោយមិនយឺតពេក ដូច្នោះ ព្រោះថា កាលមនសិការដោយយឺតយូរពេក កម្មដ្ឋានរមែងមិនដល់ទីបំផុត ទាំងមិនជាបច្ច័យដល់ការសម្រេចគុណវិសេស ប្រៀបដូចបុរសដែលត្រូវការដើរផ្លូវ ៣ យោជន៍នោះឯង រវល់តែដើរយឺតឈប់សម្រាកតាមគល់ឈើ ជើងភ្នំជាដើមក្នុងរវាងផ្លូវ ការដើរក៏រមែងមិនដល់ទីបំផុត ត្រូវដើរ ២-៣ ថ្ងៃ ទើបដល់ទីបំផុតផ្លូវបាន ។

ពាក្យថា ដោយការហាមនូវការរាយមាយ សេចក្តីថា គប្បីហាមចិត្តដែលលះនូវកម្មដ្ឋាន រាយមាយទៅក្នុងអារម្មណ៍ខាងក្រៅចេញ ព្រោះកាលមិនហាមចិត្ត កាលចិត្តរាយមាយខាងក្រៅ កម្មដ្ឋានរមែងសាបសូន្យទៅ ប្រៀបដូចកាលបុគ្គលធ្វើដំណើរឆ្លងជ្រោះ ដែលជាផ្លូវដើរបានតែម្នាក់ មិនកំណត់ផ្លូវដែលជាន់ រវល់តែសម្លឹងមើលក្នុងទីផ្សេងៗ រមែងភ្លាត់ ឬធ្លាក់ចូលទៅក្នុងជ្រោះ ដែលមានជម្រៅមួយរយជួរបុរស ព្រោះហេតុនោះ គប្បីមនសិការដោយការហាមនូវការរាយមាយ ។

ពាក្យថា ដោយការឈានកន្លងបញ្ញត្តិ សេចក្តីថា ព្រះយោគាវចរ

គប្បីឈានកន្លងបញ្ញត្តិថា សក់ រោមជាដើម ហើយគប្បីតាំងចិត្តថា នុ៎ះជារបស់បដិកូល គឺក្នុងគ្រាដំបូង ភាពជាបដិកូលរមែងប្រាកដដល់អ្នកមនសិការដោយអំណាចបញ្ញត្តិថា សក់ រោមជាដើម លំដាប់នោះ គប្បីឈានកន្លងបញ្ញត្តិថា សក់ រោមជាដើម ហើយតាំងចិត្តក្នុងភាពជាបដិកូលប៉ុណ្ណោះ ប្រៀបដូចក្នុងពេលដែលទឹករកបានដោយក្រ ពួកមនុស្សឃើញទីដែលមានទឹកក្នុងព្រៃ ទើបចងរបស់ណាមួយ មានស្លឹកត្នោតជាដើមធ្វើជាសញ្ញាក្នុងទីនោះ ពួកជនទាំងនោះរមែងមកងូត និងមកផឹកដោយសញ្ញានោះ ។ ក្នុងកាលណាស្នាមជើងរបស់ពួកបុគ្គលដែលសញ្ចរមករឿយៗ ប្រាកដហើយ ក្នុងកាលនោះ មិនមានការចាំបាច់ដោយសញ្ញានោះទៀតឡើយ បុគ្គលរមែងទៅងូត និងផឹកបានក្នុងខណៈដែលត្រូវការ ។

ពាក្យថា ដោយការកន្លងលំដាប់ សេចក្តីថា កោដ្ឋាសណាមួយមិនប្រាកដ កាលរំលងកោដ្ឋាសនោះៗ ក៏គប្បីមនសិការទៅដោយការរំលងតាមលំដាប់ គឺព្រះយោគាវចរដែលជាអាទិកម្មិកមនសិការថា សក់ ក៏មនសិការទៅដល់កោដ្ឋាសចុងក្រោយថា ទឹកមូត្រ និងកាលមនសិការថា ទឹកមូត្រ ក៏មនសិការទៅទល់នឹងកោដ្ឋាសដើមថា សក់ ។ ពេលនោះ កាលមនសិការដោយកោដ្ឋាសនោះ កោដ្ឋាសខ្លះរមែងប្រាកដ កោដ្ឋាសខ្លះមិនប្រាកដ កោដ្ឋាសណាមួយប្រាកដ ព្រះយោគាវចរនោះ គប្បីធ្វើកម្មដ្ឋានក្នុងកោដ្ឋាសនោះៗ ក្នុងកោដ្ឋាសទាំង ២ យ៉ាង ដែលប្រាកដកោដ្ឋាសមួយណាប្រាកដល្អជាង កោដ្ឋាសទាំងនោះ ព្រះយោគាវចរ គប្បីមនសិការដោយកោដ្ឋាសនោះឯង ដែលប្រាកដ

ហើយយ៉ាងនោះដដែលៗ គប្បីឲ្យអប្បនាកើតឡើងបាន ។ ក្នុងសេចក្ដីនេះ មានឧបមាដូច្នេះថា ឧបមាដូចព្រានព្រៃ ត្រូវការចាប់ស្វាក្នុងព្រៃត្នោត ដែលមានដើមត្នោត ៣២ ដើម យកព្រួញបាញ់ស្លឹកត្នោតដើមទី ១ ហើយបន្លឺលទីនោះឯង ស្វានោះ គប្បីលោតទៅកាន់ដើមត្នោតមួយទៀត ដោយលំដាប់រហូតដល់ដើមត្នោតចុងក្រោយ កាលព្រានទៅកាន់ដើមត្នោតចុងក្រោយ បាញ់បន្លឺលយ៉ាងនោះឯង ស្វានោះ គប្បីមកកាន់ដើមត្នោតដំបូងវិញ ដោយន័យនោះឯង ស្វានោះ កាលទៅមកៗ យ៉ាងនេះ ក៏បង្ហាញខ្លួនក្នុងទីដែលនាយព្រានបន្លឺលប៉ុណ្ណោះ ហើយសម្ងំត្រង់ដើមត្នោតមួយដើម ដោយលំដាប់ទៀត ហើយចាប់កំពូលត្នោតខ្ចី ត្រង់ដើមត្នោតនោះឯងយ៉ាងមាំ សូម្បីត្រូវព្រានបាញ់ក៏មិនគេចទៅយ៉ាងណា ពាក្យឧបមានេះ ក៏គប្បីជ្រាបយ៉ាងនោះ ។ ក្នុងសេចក្ដីនោះ មានពាក្យប្រៀបធៀបឧបមា និងឧបមេយ្យដូចតទៅនេះ

កោដ្ឋាស ៣២ ក្នុងកាយនេះ ប្រៀបដូចដើមត្នោត ៣២ ដើម ក្នុងព្រៃត្នោត ចិត្ត ប្រៀបដូចស្វា ព្រះយោគាវចរ ប្រៀបដូចព្រាន ។ កាលដែលចិត្តរបស់ព្រះយោគាវចរស្ទុះទៅរឿយៗ ក្នុងកាយដែលមានកោដ្ឋាស ៣២ ដោយអំណាចនៃអារម្មណ៍ ប្រៀបដូចការដែលស្វានៅក្នុងព្រៃត្នោតដែលមានដើមត្នោត ៣២ ។ ការដែលព្រះយោគាវចរមនសិការថា សក់ជាដើម ចិត្តក៏ត្រាច់ទៅតាមលំដាប់ ហើយឈប់ត្រង់កោដ្ឋាសចុងក្រោយ ដូចកាលនាយព្រានយកព្រួញបាញ់ស្លឹកត្នោតដើមទីមួយ ហើយបន្លឺល ស្វាក៏លោតពីដើមមួយទៅដើមមួយ ហើយឈប់ត្រង់ដើមត្នោតខាងចុង ។ សូម្បី

ក្នុងការដែលស្វាលោតត្រឡប់មកវិញ ក៏ន័យនេះដូចគ្នា ការដែលព្រះយោគាវចរមនសិការរឿយៗ កាលកោដ្ឋាសណាមួយប្រាកដហើយ លះកោដ្ឋាសដែលមិនប្រាកដ ធ្វើបរិកម្មក្នុងកោដ្ឋាសដែលប្រាកដ ប្រៀបដូចការប្រាកដខ្លួនរបស់ស្វា ដែលទៅដោយលំដាប់ម្តងហើយម្តងទៀត ក្នុងទីដែលនាយព្រានបន្អើលហើយ កាលដែលកោដ្ឋាស ២ ប្រាកដ កោដ្ឋាសណាប្រាកដល្អជាងព្រះយោគាវចរមនសិការកោដ្ឋាសនោះឯងរឿយៗ ហើយញុំាងអប្បនាឲ្យកើតឡើងក្នុងទីបំផុត ប្រៀបដូចការដែលស្វាសម្ងំត្រង់កំពូលត្នោតមួយដើមដោយលំដាប់ ហើយឱបបណ្តូលត្នោតនោះឯងយ៉ាងមាំ សូម្បីត្រូវព្រានបាញ់ ក៏មិនគេច ដូច្នោះ ។

គប្បីជ្រាបឧបមាន័យដទៃទៀតថា ប្រៀបដូចភិក្ខុបិណ្ឌបាតជាវត្ត អាស្រ័យផ្ទះ ៣២ ត្រកូល បានភិក្ខា ២ សម្រាប់ ក្នុងផ្ទះមួយហើយ គប្បីវៀរផ្ទះមួយខ្ទង់ខាងមុខ ស្អែកឡើង បានភិក្ខា ៣ សម្រាប់ គប្បីវៀរផ្ទះ ២ ខ្ទង់ខាងមុខក្នុងថ្ងៃទី ៣ បានភិក្ខាពេញបាត្រក្នុងផ្ទះដំបូងនោះឯង ហើយទៅកាន់អាសនសាលា ឆាន់ភិក្ខា យ៉ាងណា ឧបមាឧបមេយ្យនេះ គប្បីជ្រាបយ៉ាងនោះ ។ ពិតហើយ អាការ ៣២ ប្រៀបដូចផ្ទះ ៣២ ត្រកូល ព្រះយោគាវចរប្រៀបដូចភិក្ខុអ្នកមានបិណ្ឌបាតជាវត្ត ការដែលព្រះយោគាវចរធ្វើបរិកម្មក្នុងអាការ ៣២ ប្រៀបដូចភិក្ខុនោះ ចូលទៅអាស្រ័យផ្ទះនោះ ការដែលព្រះយោគាវចរមនសិការទៅមក លះកោដ្ឋាសទាំងឡាយដែលមិនប្រាកដ ធ្វើបរិកម្មក្នុងកោដ្ឋាសទាំង ២ ដែលប្រាកដ ប្រៀបដូចភិក្ខុនោះ បានភិក្ខា ២ សម្រាប់

ក្នុងផ្ទះដំបូងហើយ វៀរផ្ទះមួយខ្នងខាងមុខ និងប្រៀបដូចក្នុងថ្ងៃទី ២ បាន ភិក្ខា ៣ សម្រាប់ ហើយវៀរផ្ទះពីរខ្នងខាងមុខ ។ ការដែលកោដ្ឋាស ២ ប្រាកដហើយ កោដ្ឋាសណាល្អជាង ក៏មនសិការនូវកោដ្ឋាសនោះឯងរឿយៗ ហើយញ៉ាំងអប្បនាឲ្យកើតបាន ប្រៀបដូចថ្ងៃទី ៣ បានភិក្ខាពេញបាត្រក្នុងផ្ទះទីមួយនោះឯង ហើយក៏ទៅអង្គុយឆាន់ក្នុងអាសនសាលា ។

ពាក្យថា ដោយអប្បនា បានដល់ ដោយកោដ្ឋាសដែលជាអប្បនា ក្នុងសេចក្តីនេះ មានអធិប្បាយថា គប្បីជ្រាបថា អប្បនាកើតឡើងបាន ក្នុងកោដ្ឋាសមួយ ក្នុងកោដ្ឋាសទាំងឡាយ មានសក់ជាដើម ។

ក្នុងពាក្យថា ដោយសុត្តន្ត: ៣ នេះ មានអធិប្បាយដូចតទៅនេះថា គប្បីជ្រាបសុត្តន្ត: ៣ យ៉ាងនេះ គឺអធិចិត្តសូត្រ សីតិភាវសូត្រ ពោជ្ឈង្គ-កោសលសូត្រ ដើម្បីប្រយោជន៍ដល់វីរិយៈ និងសមាធិ ។

បណ្តាសូត្រទាំងនោះ គប្បីជ្រាបអធិចិត្តសូត្រ ( សមុគ្គតសូត្រ ) ដូចតទៅនេះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រកបនូវអធិចិត្តហើយ ត្រូវធ្វើទុកក្នុងចិត្តនូវនិមិត្ត ៣ យ៉ាង ក្នុងកាលដ៏គួរ គឺត្រូវធ្វើទុកក្នុងចិត្តនូវសមាធិនិមិត្តក្នុងកាលដ៏គួរ ១ ត្រូវធ្វើទុកក្នុងចិត្តនូវបគ្គាហនិមិត្តក្នុងកាលដ៏គួរ ១ ត្រូវធ្វើទុកក្នុងចិត្តនូវឧបេក្ខានិមិត្តក្នុងកាលដ៏គួរ ១ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកប្រកបរឿយៗ នូវអធិចិត្ត គប្បីធ្វើទុកក្នុងចិត្តនូវសមាធិនិមិត្តតែមួយចំណែក ហេតុនោះ គប្បីនាំចិត្តឲ្យប្រព្រឹត្តទៅ ដើម្បីសេចក្តីខ្ជិលច្រអូស ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកប្រកបរឿយៗ នូវអធិចិត្ត គប្បីធ្វើទុកក្នុងចិត្តនូវ

បគ្គាហនិមិត្តតែមួយចំណែក ហេតុនោះ គប្បីនាំចិត្តឲ្យប្រព្រឹត្តទៅ ដើម្បីសេចក្តីរាយមាយ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកប្រកបរឿយៗ នូវអធិចិត្ត គប្បីធ្វើទុកក្នុងចិត្តនូវឧបេក្ខានិមិត្តតែមួយចំណែក ហេតុនោះ គប្បីនាំចិត្តមិនឲ្យតាំងមាំដោយប្រពៃ ដើម្បីការអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ កាលណា ភិក្ខុអ្នកប្រកបនូវអធិចិត្ត រមែងធ្វើទុកក្នុងចិត្តនូវសមាធិនិមិត្តក្នុងកាលដ៏គួរ ធ្វើទុកក្នុងចិត្តនូវបគ្គាហនិមិត្តក្នុងកាលដ៏គួរ ធ្វើទុកក្នុងចិត្តនូវឧបេក្ខានិមិត្តក្នុងកាលដ៏គួរ ទើបចិត្តនោះ ក៏ទន់ គួរដល់ការងារកម្ម ជាចិត្តភ្លឺផ្លេក មិនរឹង តាំងមាំដោយប្រពៃ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយបាន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាជាងមាសក្តី កូនសិស្សជាងមាសក្តី ចាត់ចែងបាវ លុះចាត់ចែងបាវរួចហើយ ក៏ដុតមាត់បាវ កាលដុតមាត់បាវ ក៏យកដង្កៀបចៀបមាស ដាក់ក្នុងមាត់បាវ ហើយសប់ក្នុងកាលដ៏គួរ បំព្រំទឹកក្នុងកាលដ៏គួរ សម្លឹងមើលក្នុងកាលដ៏គួរ ។ ម្នាលភិក្ខុទាំងឡាយ បើជាងមាសក្តី កូនសិស្សជាងមាសក្តី គប្បីសប់តែមាសនោះមួយចំណែក ទុំះជាហេតុធ្វើឲ្យមាសឆេះរលួយទៅ ។ ម្នាលភិក្ខុទាំងឡាយ បើជាងមាសក្តី កូនសិស្សជាងមាសក្តី បំព្រំតែមាសនោះដោយទឹកមួយចំណែក ទុំះជាហេតុធ្វើមាសឲ្យត្រជាក់ ។ ម្នាលភិក្ខុទាំងឡាយ បើជាងមាសក្តី កូនសិស្សជាងមាសក្តី សម្លឹងមើលតែមាសនោះមួយចំណែក ទុំះជាហេតុធ្វើមិនឲ្យមាសផ្តិនសព្វសាច់បាន ។ ម្នាលភិក្ខុទាំងឡាយ កាលណា ជាងមាសក្តី កូនសិស្សជាងមាសក្តី សប់មាសនោះក្នុងកាលដ៏គួរ បំព្រំដោយទឹកក្នុងកាលដ៏គួរ សម្លឹង

មើលក្នុងកាលដ៏គួរហើយ ទើបមាសនោះ ទៅជាមាសទន់ គួរដល់ការងារ ជាមាសមានសម្បុរភ្លឺផ្លេក មិនស្រួយ គួរបង្អោនទៅដើម្បីការងារដោយប្រពៃ ផង បើគេប្រាថ្នាគ្រឿងប្រដាប់ប្លែកៗ ណាៗ ទោះជាជំបារមាសក្តី កុណ្ឌលក្តី គ្រឿងប្រដាប់កក្តី កម្រងមាសក្តី រមែងសម្រេចប្រយោជន៍នោះៗ បាន ( យ៉ាង ណាមិញ ) ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រកបរឿយៗ នូវអធិចិត្ត ។បេ។ តាំងមាំដោយប្រពៃ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយ បុគ្គលបង្អោនទៅ នូវចិត្ត ដើម្បីធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមណាៗ កាល បើហេតុមាន រមែងដល់នូវភាពគួរជាបន្ទាល់ក្នុងធម៌នោះៗ ដើម្បីធ្វើឲ្យជាក់ ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម ដូច្នេះ ។

គប្បីជ្រាបសីតិភាវសូត្រដូចតទៅនេះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកប ដោយធម៌ ៦ យ៉ាង ជាអ្នកគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវសេចក្តីត្រជាក់ចិត្ត ដ៏ប្រសើរ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនា នេះ ចិត្តដែលគួរសង្កត់សង្កិនក្នុងពេលណា ក៏សង្កត់សង្កិនចិត្តក្នុងពេលនោះ ១ ចិត្តដែលគួរផ្គងឡើងក្នុងពេលណា ក៏ផ្គងចិត្តឡើងក្នុងពេលនោះ ១ ចិត្ត ដែលគួរធ្វើឲ្យរីករាយក្នុងពេលណា ក៏ធ្វើចិត្តឲ្យរីករាយក្នុងពេលនោះ ១ ចិត្ត ដែលគួរធ្វើឲ្យព្រងើយក្នុងពេលណា ក៏ធ្វើចិត្តឲ្យព្រងើយក្នុងពេលនោះ ១ ជា អ្នកស្ទុងចុះក្នុងធម៌ដ៏ថ្លៃថ្លា ១ ត្រេកអរក្នុងព្រះនិព្វាន ១ ។ ម្នាលភិក្ខុទាំង ឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកគួរដើម្បីធ្វើឲ្យជាក់ ច្បាស់នូវសេចក្តីត្រជាក់ចិត្តដ៏ប្រសើរ ដូច្នេះ ។

ពោជ្ឈង្គកោសល្លសូត្រ មកហើយក្នុងពោជ្ឈង្គសំយុត្តនោះឯង ក្នុងសំយុត្តនិកាយ មហាវារវគ្គនោះឯងថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះដែរ ចិត្តដែលរួញរាក្នុងសម័យណា សម័យនោះ ជាកាលមិនគួរនឹងចម្រើនបស្សទ្ធិសម្ពោជ្ឈង្គ ដូច្នេះជាដើម ។

ព្រះយោគាវចរនោះ កាលធ្វើនូវការរៀនឧគ្គហកោសល ៧ យ៉ាងនេះបានល្អហើយ និងកំណត់មនសិការកោសល ១០ យ៉ាងនេះបានល្អហើយ គប្បីរៀនកម្មដ្ឋានឲ្យល្អដោយអំណាចនៃកោសលទាំងពីរ បើលោកមានផាសុកក្នុងវិហារជាមួយគ្នានឹងអាចារ្យសោត ក៏មិនចាំបាច់ឲ្យអាចារ្យប្រាប់នូវកម្មដ្ឋានដោយពិស្តារយ៉ាងនោះ គប្បីប្រកបរឿយៗ នូវកម្មដ្ឋាន កាលមិនបានគុណវិសេសហើយ សឹមឲ្យលោកប្រាប់ឲ្យក្រៃលែងថែមទៀត ។

ព្រះយោគាវចរដែលប្រាថ្នានឹងទៅកាន់ទីដទៃ គប្បីឲ្យអាចារ្យប្រាប់ដោយពិស្តារ ដោយវិធីតាមដែលពោលហើយ ពិចារណារឿយៗ ទម្លាយបទដែលជាទីតាំងនៃសេចក្ដីសង្ស័យទាំងពួង លះសេនាសនៈដែលមិនសមគួរដល់ការចម្រើនកម្មដ្ឋាន នៅក្នុងវិហារដែលសមគួរ វៀរវិហារដែលជាទោស ១៨ មានភាពជាអាវាសធំជាដើម កាត់បលិពោធបន្តិចបន្តួច ព្រះយោគាវចរណា មានរាគចរិត គប្បីលះរាគៈមុន ហេតុនោះ គប្បីធ្វើបរិកម្មក្នុងបដិកូលមនសិការ ។ កាលនឹងធ្វើ គប្បីកាន់យកនិមិត្តក្នុងសក់ទាំងឡាយមុន គប្បីកាន់យកដូចម្ដេច គឺគប្បីដកសក់មួយសរសៃ ឬពីរសរសៃដាក់លើបាតដៃហើយ គប្បីកំណត់ពណ៌មុន ឬមើលសក់ទាំងឡាយ ត្រង់ទីដែលកោរសក់ក៏បាន ឬមើលសក់

ដែលធ្លាក់ក្នុងទឹក ឬធ្លាក់ក្នុងបបរក៏បានដូចគ្នា ឃើញក្នុងពេលដែលសក់ពណ៌ខ្មៅ ក៏គប្បីមនសិការថា ខ្មៅ ឃើញក្នុងពេលដែលសក់ពណ៌ស គប្បីមនសិការថា ស តែក្នុងពេលដែលសក់មានពណ៌លាយគ្នា គប្បីមនសិការដោយអំណាចពណ៌ណាច្រើនជាង ។ ក្នុងសក់ទាំងឡាយយ៉ាងណា ក្នុងតចបញ្ចកៈទាំងអស់ក៏យ៉ាងនោះ ឃើញហើយ គប្បីកាន់យកនិមិត្តនោះឯង កាលកាន់យកនិមិត្តយ៉ាងនេះហើយ គប្បីកំណត់ក្នុងកោដ្ឋាសទាំងពួង ដោយអំណាចនៃពណ៌ សណ្ឋាន ទិស ឱកាស និងការកំណត់ ហើយគប្បីកំណត់ដោយភាពជាបដិកូល ៥ យ៉ាង ដោយអំណាចនៃពណ៌ សណ្ឋាន ក្លិន ទីអាស្រ័យ និងឱកាស ។ តទៅនេះ ជាអនុបុព្វីកថាក្នុងកោដ្ឋាសទាំងពួងនោះ ។

សក់ទាំងឡាយ ពោលដោយពណ៌ តាមប្រក្រតីមានពណ៌ខ្មៅ ដូចគ្រាប់ផ្កាំដោះក្របី ពោលដោយសណ្ឋាន វែងមូល មានសណ្ឋានដូចជញ្ជីង ពោលដោយទិស កើតក្នុងទិសខាងលើ ពោលដោយឱកាសសងខាងកំណត់ដោយគុម្ពត្រចៀក ខាងមុខកំណត់ដោយថ្ងាស ខាងក្រោយកំណត់ដោយដងក ស្បែកស្រស់ដែលស្រោបលលាដ៍ក្បាល ជាឱកាស គឺជាទីតាំងនៃសក់ទាំងឡាយ ពោលដោយការកំណត់ សក់ទាំងឡាយខាងក្រោម កំណត់ដោយឫសរបស់សក់ដែលចាក់ចុះក្នុងស្បែកក្បាល ប្រមាណមួយគ្រាប់ស្រូវ ខាងលើ កំណត់ដោយអាកាស ដោយទទឹង កំណត់ដោយសរសៃសក់ផងគ្នា ។ ការកំណត់ថា សក់ ២ សរសៃ មិនបានរួមគ្នាជាមួយសរសៃនេះ ឈ្មោះថា **សភាគបរិច្ឆេទ** ។ ការកំណត់ថា សក់មិនលាយឡំដោយ

កោដ្ឋាស ៣១ ដ៏សេសយ៉ាងនេះថា សក់ មិនមែនរោម រោម មិនមែនសក់ ធម្មតាសក់ រមែងជាកោដ្ឋាសមួយ នេះឈ្មោះថា **វិសភាគបរិច្ឆេទ ។** នេះជាការកំណត់សក់ទាំងឡាយ ដោយពណ៌ជាដើម ។

គប្បីជ្រាបការកំណត់សក់ទាំងនោះ ដោយភាពជាបដិកូល ៥ យ៉ាង ដោយអំណាចនៃពណ៌ជាដើមដូចតទៅនេះថា ពិតហើយ ឈ្មោះថា សក់ទាំងឡាយនេះ ដោយពណ៌ ក៏ជាបដិកូល ដោយសណ្ឋាន ដោយក្លិន ដោយទីអាស្រ័យ និងដោយឱកាស ក៏ជារបស់បដិកូល ព្រោះថា ជនទាំងឡាយឃើញរបស់អ្វីមួយ ដែលមានសណ្ឋានស្រដៀងសក់ក្នុងកាជនៈដែលដាក់បបរ ឬភាជនៈដែលដាក់កត្ត សូម្បីជារបស់គាប់ចិត្ត ក៏រមែងរង្កៀស ដោយពោលថា នេះជាសក់ ចូរនាំវាចេញទៅ ។ សក់ជារបស់បដិកូល ដោយពណ៌យ៉ាងនេះ ។

ជនទាំងឡាយ បរិភោគអាហារក្នុងពេលយប់ ពាល់ត្រូវសម្បកព្រោល ឬសម្បកធ្មៃដែលមានសណ្ឋានដូចសក់ ក៏រង្កៀសយ៉ាងនោះឯង សក់ជារបស់បដិកូល ដោយសណ្ឋានយ៉ាងនេះ ។

ម្យ៉ាងទៀត ក្លិនរបស់សក់ វៀរចាកការតាក់តែង មានការលាបដោយប្រេង និងអប់ដោយផ្កាជាដើម រមែងមានក្លិនគួររង្កៀសក្រៃលែង សក់ដែលដាក់ចូលទៅក្នុងភ្លើង រមែងមានក្លិនគួររង្កៀសច្រើនជាងនោះ ។ មែនហើយ សក់ បើពោលដោយពណ៌ និងសណ្ឋាន គប្បីជារបស់មិនបដិកូលក៏បាន តែបើពោលដោយក្លិនហើយ រមែងជាបដិកូលនោះឯង ។ ឧបមាដូចដុំឧច្ចារៈ

របស់កុមារ បើពោលដោយពណ៌ ក៏មានពណ៌ដូចរមៀត បើពោលដោយសណ្ឋាន មានសណ្ឋានដូចខ្នែងរមៀត និងឧបមាដូចសាកសពឆ្កែខ្មៅដែលហើមប៉ោង ដែលគេបោលត្រង់គំនរសំរាម ដោយពណ៌ មានពណ៌ដូចផ្លែត្នោតទុំ ដោយសណ្ឋាន មានសណ្ឋានដូចស្គរសម្ភោរដែលគេប្រមៀលទៅសូម្បីចង្កូមរបស់វា ដូចគ្នានឹងផ្កាម្ទេះក្រពុំ ព្រោះហេតុនោះ ឧច្ចាររបស់កុមារ និងសាកសពឆ្កែខ្មៅ របស់ទាំងពីរ បើពោលដោយពណ៌ និងសណ្ឋាន មិនគប្បីជារបស់បដិកូលក៏បាន តែបើពោលដោយក្លិនហើយ រមែងជារបស់បដិកូលពិត យ៉ាងណា សក់ទាំងឡាយ ក៏យ៉ាងនោះ បើពោលដោយពណ៌ និងសណ្ឋាន មិនគប្បីជារបស់បដិកូលក៏បាន តែបើពោលដោយក្លិនហើយ រមែងជារបស់បដិកូលពិត ។

បន្លែសម្រាប់ស្លដែលកើតឡើងក្នុងទីមិនស្អាត ដោយការហូរទៅនៃទឹកជ្រាំអំពីស្រុក រមែងជារបស់គួរខ្ពើម មិនគួរបរិភោគសម្រាប់អ្នកនគរទាំងឡាយយ៉ាងណា សូម្បីសក់ទាំងឡាយក៏យ៉ាងនោះ ឈ្មោះថា គួរខ្ពើមក្រៃលែង ព្រោះកើតឡើងដោយទឹកដែលហូរជ្រួតជ្រាបចេញអំពីខ្ទុះ ឈាម ទឹកឧច្ចារៈ ទឹកបស្សាវៈ ទឹកប្រមាត់ និងស្លេស្មជាដើម នេះជាបដិកូលនៃសក់ទាំងនោះដោយទីអាស្រ័យ ។

ម្យ៉ាងទៀត សក់ទាំងនេះ កើតឡើងត្រង់គំនរនៃកោដ្ឋាស ៣១ ដែលមិនស្អាត ដូចបន្លែ និងស្មៅកើតឡើងត្រង់គំនរលាមក សក់ទាំងនោះ ឈ្មោះថា គួរខ្ពើមក្រៃលែង ព្រោះកើតក្នុងទីដែលមិនស្អាត ដូចបន្លែដែលកើតឡើង

*ត្រង់ព្រៃខ្មោច ឬត្រង់គំនរសំរាមជាដើម និងដូចផ្កា មានផ្កាឈូកក្រហម ព្រលិតជាដើម ដែលកើតឡើងក្នុងទីមិនស្អាត មានស្នាមភ្លោះនគរជាដើម ព្រោះហេតុនោះ នេះជាភាពបដិកូលនៃសក់ទាំងនោះដោយឱកាស ។ ភាពជាបដិកូលនៃសក់ទាំងឡាយយ៉ាងណា គប្បីកំណត់ភាពជាបដិកូលនៃកោដ្ឋាសទាំង ៥ យ៉ាង ដោយអំណាចភាពបដិកូលដោយពណ៌ សណ្ឋាន ក្លិន ទីអាស្រ័យ និងឱកាសក៏យ៉ាងនោះចុះ តែបើពោលដោយពណ៌ សណ្ឋាន ទិស ឱកាស និងការកំណត់ សូម្បីកោដ្ឋាសទាំងពួង គប្បីកំណត់ ១ អាការមួយផ្នែក ។*

*បណ្ដាកោដ្ឋាសទាំងនោះ គប្បីកំណត់រោមទាំងឡាយមុន ពោលដោយពណ៌តាមប្រក្រតី មិនខ្មៅដូចសក់ តែជាពណ៌ខ្មៅលាយលឿង ពោលដោយសណ្ឋាន មានសណ្ឋានខាងចុង រាងកោងដូចឫសត្នោត ពោលដោយទិស កើតក្នុងទិសទាំងពីរ ពោលដោយឱកាស វៀរឱកាសដែលសក់ទាំងឡាយតាំងនៅ និងបាតដៃបាតជើងហើយ ដោយច្រើនកើតតាមស្បែកដែលស្រោបសរីរៈដ៏សេស ពោលដោយការកំណត់ ខាងក្រោម កំណត់ដោយឫសរបស់រោម ដែលចាក់ចូលទៅក្នុងស្បែក ដែលស្រោបសរីរៈប្រមាណ ១ លិក្ខា ( មួយពងចៃ )[១] ខាងលើ កំណត់ដោយអាកាស ទទឹងកំណត់ដោយរោមផងគ្នា ការកំណត់ថា រោមពីរសរសៃមិនបានរួមជាសរសៃ ១ នេះជាសភាគបរិច្ឆេទនៃរោមទាំងនោះ ចំណែកវិសភាគបរិច្ឆេទ ដូចគ្នានឹងសរសៃសក់នោះ*

*១- យកគ្រាប់ស្រូវចែកជា ៤៩ ចំណែក មួយចំណែក ហៅថា ១ លិក្ខា ។*

ឯង ។

ពាក្យថា ក្រចក ជាឈ្មោះរបស់បន្ទះក្រចក ២០ ក្រចកទាំងពួងនោះ ពោលដោយពណ៌ មានពណ៌ស ពោលដោយសណ្ឋាន មានសណ្ឋានដូចស្រកាត្រី ពោលដោយទិស កើតក្នុងទិសទាំងពីរ គឺក្រចកជើង កើតក្នុងទិសខាងក្រោម ក្រចកដៃ កើតក្នុងទិសខាងលើ ពោលដោយឱកាស តាំងនៅត្រង់ខ្នងនៃចុងម្រាមដៃទាំងឡាយ ពោលដោយការកំណត់ក្នុងទិសទាំងពីរ កំណត់ដោយសាច់ចុងម្រាម ខាងក្នុងកំណត់ដោយសាច់ខ្នងម្រាម ខាងក្រៅនិងខាងចុង កំណត់ដោយអាកាស ទទឹងកំណត់ដោយក្រចកផងគ្នា ។ ការកំណត់ថា ក្រចកពីរ មិនបានរួមជាមួយគ្នា នេះជាសភាគបរិច្ឆេទ ចំណែកវិសភាគបរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។

ពាក្យថា ធ្មេញ គឺឆ្អឹងធ្មេញ ៣២ សម្រាប់បុគ្គលដែលមានធ្មេញបរិបូណ៌ ធ្មេញទាំងនោះ ពោលដោយពណ៌ មានពណ៌ស ពោលដោយសណ្ឋាន មានសណ្ឋានមិនមែនតិច ពិតហើយ បណ្តាធ្មេញទាំងនោះ ធ្មេញ ៤ ត្រង់កណ្តាល ខាងក្រោម មានសណ្ឋានដូចគ្រាប់ឃ្លោក ដែលដោតតម្រៀបគ្នាត្រង់ដីឥដ្ឋ ។ សងខាងធ្មេញកណ្តាល ៤ នោះ ធ្មេញម្ខាងមួយ មានឫស ១ មានចុង ១ មានសណ្ឋានដូចផ្កាម្លិះក្រពុំ ។ បន្ទាប់អំពីនោះ ធ្មេញម្ខាងមួយទៀត មានឫស ២ មានចុង ២ មានសណ្ឋានដូចចន្ទល់យានតូច បន្ទាប់អំពីនោះទៅ ធ្មេញម្ខាង ២ ទៀត មានឫស ៣ មានចុង ៣ បន្ទាប់ពីនោះទៅ ធ្មេញម្ខាង ២ ទៀត មានឫស ៤ មានចុង ៤ ។ សូម្បីធ្មេញជួរខាងលើ

ក៏ន័យនេះឯង ពោលដោយទិស កើតក្នុងទិសខាងលើ ពោលដោយឱកាស តាំងនៅត្រង់ឆ្អឹងថ្គាមទាំងពីរ ពោលដោយការកំណត់ ខាងក្រោម កំណត់ដោយឫសរបស់ធ្មេញ ដែលតាំងនៅលើឆ្អឹងថ្គាម ខាងលើ កំណត់ដោយអាកាស ទទឹង កំណត់ដោយធ្មេញផងគ្នា ។ ការកំណត់ថា ធ្មេញពីរ មិនបានរួមគ្នាតែមួយ នេះជាសភាគបរិច្ឆេទ ចំណែកវិសភាគបរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។

ពាក្យថា ស្បែក គឺស្បែកស្រោបសរីរៈទាំងមូល លើស្បែកនោះ មានពណ៌ខ្មៅ លឿងជាដើម ស្បែកនោះ កាលបកចេញអំពីសរីរៈ មានប្រមាណប៉ុនគ្រាប់ពុទ្រា ។ ស្បែកនោះ ពោលដោយពណ៌ មានពណ៌សប៉ុណ្ណោះ ឯស្បែកដែលពណ៌សនោះ រមែងប្រាកដ កាលដែលស្បែករបកព្រោះអណ្ដាតភ្លើង ឬត្រូវប្រហារដោយគ្រឿងប្រហារជាដើម ពោលដោយសណ្ឋាន មានសណ្ឋានដូចរាងកាយនោះឯង នេះជាសេចក្ដីសង្ខេបក្នុងពាក្យថា ពោលដោយសណ្ឋាន ។

បើពោលដោយពិស្ដារ ស្បែកម្រាមជើង មានសណ្ឋានដូចសម្បុកដង្កូវនាង ស្បែកខ្នងជើង មានសណ្ឋានដូចទ្រនាប់ជើងក្រវាត់កែង ស្បែកស្មង មានសណ្ឋានដូចស្លឹកត្នោតដែលគេខ្ចប់បាយ ស្បែកភ្លៅ មានសណ្ឋានដូចថង់ដែលគេប្រកអង្ករ ស្បែកត្រគាក មានសណ្ឋានដូចសំពត់តម្រងទឹក ដែលពេញដោយទឹក ស្បែកខ្នង មានសណ្ឋានដូចស្រោមខែល ស្បែកពោះ មានសណ្ឋានដូចស្រោមពិណ ស្បែកទ្រូង មានសណ្ឋាន ៤ ជ្រុង ស្បែកដៃទាំងពីរ

មានសណ្ឋានដូចស្រោមធ្នូ ស្បែកខ្នងដៃ មានសណ្ឋានដូចស្រោមកាំបិត ឬ ថង់ខែល ស្បែកម្រាមដៃ មានសណ្ឋានដូចស្រោមសោ ស្បែក-ក មាន សណ្ឋានដូចអាវបិទ-ក ស្បែកមុខ មានប្រហោងតូចធំ មានសណ្ឋានដូច សម្បុកកណ្ដូប ស្បែកក្បាល មានសណ្ឋានដូចស្មោកបាត្រ ។

ព្រះយោគាវចរដែលកំណត់ស្បែកជាអារម្មណ៍ គប្បីបញ្ជូនញាណទៅ ខាងលើ តាំងអំពីបបូរមាត់ឡើងទៅ ហើយកំណត់ស្បែក ដែលស្រោបមាត់ ជាមុន បន្ទាប់អំពីនោះ គប្បីកំណត់ស្បែកថ្ងាស បន្ទាប់អំពីនោះ ក៏បញ្ជូន ញាណទៅក្នុងរវាងលលាដ៍ក្បាល និងស្បែកក្បាល ដូចស៊កដៃចូលទៅក្នុង រវាងបាត្រ និងស្មោកបាត្រដែលពាក់ ដូច្នោះ ដោយញែកភាពដែលស្បែក ជាប់គ្នាជាមួយលលាដ៍ក្បាលចេញ កំណត់តែស្បែកក្បាល ។ បន្ទាប់មក កំណត់ត្រង់ស្បែក-ក បន្ទាប់មក កំណត់ស្បែកដៃខាងស្ដាំ ទាំងដោយអនុ-លោម ( ចាប់អំពីស្មារហូតដល់កដៃ ) ទាំងដោយបដិលោម ( អំពីកដៃ រហូតដល់ស្មា ) ។ លំដាប់នោះ គប្បីកំណត់ស្បែកដៃខាងឆ្វេង ដោយន័យ នោះឯង បន្ទាប់មក កំណត់ស្បែកខ្នង កាលកំណត់ស្បែកនោះៗ ហើយ គប្បីកំណត់ស្បែកជើងខាងស្ដាំ ទាំងដោយអនុលោម ទាំងដោយបដិលោម ។ បន្ទាប់អំពីនោះ គប្បីកំណត់ស្បែកជើងខាងឆ្វេង ដោយន័យទាំងនោះឯង បន្ទាប់អំពីនោះ គប្បីកំណត់ស្បែកពោះខាងក្រោម ( ស្បែកថ្ងាស អង្គជាត ) ស្បែកពោះខាងលើ ស្បែកទ្រូង ស្បែក-ក ដោយលំដាប់នោះឯង ។ លំដាប់ នោះ គប្បីកំណត់ស្បែកក្រោមចង្កា បន្ទាប់អំពីស្បែក-កឡើងទៅ រហូតដល់

បបូរមាត់ខាងក្រោមជាទីបំផុត ទើបសម្រេច ។ កាលព្រះយោគាវចរកំណត់ស្បែកគ្រោតគ្រាតយ៉ាងនេះ សូម្បីស្បែកល្អិត ក៏រមែងប្រាកដ ។

ពោលដោយទិស កើតក្នុងទិសទាំងពីរ ពោលដោយឱកាស ដណ្តប់សរីរៈទាំងមូល ពោលដោយការកំណត់ ខាងក្រោម កំណត់ដោយផ្ទៃដែលតាំងនៅ ខាងលើ កំណត់ដោយអាកាស នេះជាសភាគបរិច្ឆេទ ចំណែកវិសភាគបរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។

ពាក្យថា សាច់ គឺដុំសាច់ ៩០០ ដុំ ។ ដុំសាច់ទាំងឡាយនោះ ពោលដោយពណ៌ មានពណ៌ក្រហមដូចគ្នានឹងផ្កាចារ ពោលដោយសណ្ឋាន សាច់កំភួនជើង មានសណ្ឋានដូចបាយដែលខ្ចប់ដោយស្លឹកត្នោត សាច់ភ្លៅ មានសណ្ឋានដូចកូនក្បាល សាច់ត្រគាក មានសណ្ឋានដូចសសរ សាច់ខ្នង មានសណ្ឋានដូចបន្ទះស្ករត្នោត សាច់ឆ្អឹងជំនីរទាំងពីរ មានសណ្ឋានដូចការបូកលាបដោយដីឥដ្ឋស្តើងៗ ក្នុងជង្រុកស្រូវ សាច់ដោះទាំងពីរ មានសណ្ឋានដូចដុំដីឥដ្ឋ ដែលគេច្បូសំយុង សាច់ដើមដៃទាំងពីរ មានសណ្ឋានដូចកណ្តុរធំដែលគេពន្លាត់ស្បែកធ្វើជាពីរចំណែក ។ កាលព្រះយោគាវចរកំណត់សាច់គ្រោតគ្រាតយ៉ាងនេះ សូម្បីដុំសាច់ដែលល្អិត ក៏រមែងប្រាកដ ។ ពោលដោយទិស កើតក្នុងទិសទាំងពីរ ពោលដោយឱកាស បូកលាបជាប់ឆ្អឹងទាំង ៣០០ កំណាត់ ពោលដោយការកំណត់ ខាងក្រោម កំណត់ដោយផ្ទៃដែលតាំងនៅត្រង់រាងឆ្អឹង ខាងលើ កំណត់ដោយស្បែក ទទឹង កំណត់ដោយសាច់ផងគ្នា នេះជាសភាគបរិច្ឆេទ ចំណែកវិសភាគបរិច្ឆេទ ដូចគ្នានឹងសក់

*នោះឯង ។*

*ពាក្យថា សរសៃ គឺសរសៃ ៩០០ ដោយពណ៌ សរសៃទាំងអស់ មានពណ៌ស ដោយសណ្ឋាន មានសណ្ឋានផ្សេងៗ ពិតហើយ សរសៃទាំងនោះ សរសៃធំចងរឹតសរីរៈតាំងអំពីខាងលើនៃ-ក ចុះទៅកាន់ខាងមុខហទយៈ ៥ សរសៃ ខាងក្រោយ ៥ សរសៃ ខាងស្តាំ ៥ សរសៃ ខាងឆ្វេង ៥ សរសៃ ចងរឹតដៃស្តាំខាងមុខ ៥ សរសៃ ខាងខ្នងដៃ ៥ សរសៃ ឯដៃឆ្វេងក៏យ៉ាងនោះ រឹតត្រង់ជើងស្តាំខាងមុខ ៥ សរសៃ ខាងក្រោយ ៥ សរសៃ ឯជើងឆ្វេងក៏យ៉ាងនោះ សរសៃធំ ៦០ ចងរឹតរួតពេញកាយយ៉ាងនេះ ដោយប្រការដូច្នេះ ទើបឈ្មោះថា* **សរីរធារកា** *ប្រែថា ទ្រទ្រង់នូវសរីរៈ លោកហៅថា* **កណ្ឌរា** *ដូច្នេះក៏មាន សរសៃទាំងអស់នោះ មានសណ្ឋានដូចដើម* **កន្ទលមកុឡ** *។ ចំណែកសរសៃដទៃ ដែលចងរឹតចំណែកនោះៗ ដែលតូចជាងសរីរធារកានោះ មានសណ្ឋានដូចខ្សែអំបោះ សរសៃដទៃដែលតូចជាងនោះ មានសណ្ឋានដូចវល្លិផោម សរសៃដទៃដែលតូចជាងនោះ មានសណ្ឋានដូចខ្សែពិណធំ សរសៃដទៃទៀត មានសណ្ឋានដូចសរសៃអំបោះធំ សរសៃខ្នង ខ្នងដៃ និងខ្នងជើង មានសណ្ឋានដូចជើងបក្សី សរសៃក្បាល មានសណ្ឋានដូចបណ្តាញគ្របក្បាលកុមារ សរសៃខ្នងមានសណ្ឋានដូចអួនសើម ដែលគេសំដិលថ្ងៃ សរសៃដ៏សេសដែលចាក់ទៅតាមអវយវៈតូចធំនោះៗ មានសណ្ឋានដូចអាវសំណាញ់ដែលគេដណ្តប់សរីរៈ ។ ពោលដោយទិស សរសៃកើតក្នុងទិសទាំងពីរ ពោលដោយឱកាស ចងធ្អឹង*

ទាំងឡាយក្នុងសរីរៈទាំងមូល ពោលដោយការកំណត់ខាងក្រោម កំណត់ដោយផ្ទៃដែលតាំងនៅលើឆ្អឹង ៣០០ កំណាត់ ខាងលើកំណត់ដោយប្រទេសដែលតាំងនៅទល់គ្នានឹងសាច់ និងស្បែក ទទឹងកំណត់ដោយសរសៃផងគ្នា នេះជាសភាគបរិច្ឆេទរបស់សរសៃទាំងនោះ ចំណែកវិសភាគបរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។

ពាក្យថា ឆ្អឹង សេចក្តីថា វៀរឆ្អឹងធ្មេញ ៣២ ឆ្អឹងដ៏សេស មានប្រមាណ ៣០០ កំណាត់យ៉ាងនេះ គឺឆ្អឹងដៃ ៦៤ កំណាត់ ឆ្អឹងជើង ៦៤ កំណាត់ ឆ្អឹងខ្ចីជាប់សាច់ ៦៤ កំណាត់ ឆ្អឹងកែងជើង ២ កំណាត់ ឆ្អឹង-កជើងម្ខាង ២ កំណាត់ ឆ្អឹងស្មងម្ខាង ២ កំណាត់ ឆ្អឹងជង្គង់ ២ កំណាត់ ឆ្អឹងភ្លៅ ២ កំណាត់ ឆ្អឹងចង្កេះ ២ កំណាត់ ឆ្អឹងទ្រនង់ខ្នង ១៨ កំណាត់ ឆ្អឹងជំនីរ ២៤ កំណាត់ ឆ្អឹងទ្រូង ១៤ កំណាត់ ឆ្អឹងចុងដង្ហើម ១ កំណាត់ ឆ្អឹងដងកាំបិត ២ កំណាត់ ឆ្អឹងស្លាបប្រចៀវ ២ កំណាត់ ឆ្អឹងដើមដៃ ២ កំណាត់ ឆ្អឹងដៃកំណាត់ខាងក្រោមម្ខាង ២ កំណាត់ ឆ្អឹង-ក ៧ កំណាត់ ឆ្អឹងចង្កា ២ កំណាត់ ឆ្អឹងក្តោងច្រមុះ ១ កំណាត់ ឆ្អឹងប្រឡង់ភ្នែក ២ កំណាត់ ឆ្អឹងត្រចៀក ២ កំណាត់ ឆ្អឹងថ្ងាស ១ កំណាត់ ឆ្អឹងបង្ហើយ ១ កំណាត់ ឆ្អឹងលលាដ៍ក្បាល ៩ កំណាត់ ។

ឆ្អឹងទាំងអស់នោះ ពោលដោយពណ៌ មានពណ៌ស ពោលដោយសណ្ឋាន មានសណ្ឋានផ្សេងៗ ពិតហើយ បណ្តាឆ្អឹងទាំងនោះ ឆ្អឹងម្រាមជើងខាងចុង មានសណ្ឋានដូចគ្រាប់ឈូក ឆ្អឹងកំណាត់បន្ទាប់អំពីខាងចុង មាន

សណ្ឋានដូចគ្រាប់ខ្នុរ ឆ្អឹងកំណាត់គល់ មានសណ្ឋានដូចស្គរតូច ឆ្អឹងខ្នងជើង មានសណ្ឋានដូចគំនរដើមកន្ទុលមកុឡ ដែលគេដំ ៗ ឆ្អឹងកែងជើង មានសណ្ឋានដូចកំពឹងត្នោតមួយកំណាត់ ឆ្អឹង-កជើង មានសណ្ឋានដូចគូនៃផ្លែអង្គញ់ ឆ្អឹងស្មងត្រង់ទីដែលជាប់នឹងឆ្អឹង-កជើង មានសណ្ឋានដូចទំពាំងខ្ចីដែលបកសម្បក ឆ្អឹងស្មង ចម្រៀកតូច មានសណ្ឋានដូចដងធ្នូ ចម្រៀកធំ មានសណ្ឋានដូចខ្នងពស់ដែលក្រៀមហើយ ឆ្អឹងជង្គង់ មានសណ្ឋានដូចដុំពពុះទឹកដែលផ្ដាប់ទៅម្ខាង ត្រង់ទីដែលឆ្អឹងស្មងទល់នឹងឆ្អឹងជង្គង់នោះ មានសណ្ឋានដូចស្នែងគោកាត់ចុង ឆ្អឹងភ្លៅ មានសណ្ឋានដូចដងកាំបិតព្រា ឬដងពូថៅដែលគេចាំងប្បោលៗ ត្រង់ឆ្អឹងភ្លៅដែលទល់នឹងឆ្អឹងចង្កេះនោះ មានសណ្ឋានដូចអង្គញ់ដែលគេលេង ត្រង់ទីដែលឆ្អឹងចង្កេះទល់នឹងឆ្អឹងភ្លៅនោះ មានសណ្ឋានដូចផ្លែក្រូចព្រៃធំ ដែលគេចិតខាងចុង ឆ្អឹងចង្កេះ មាន ២ កំណាត់ មានសណ្ឋានដូចចង្ក្រានរបស់នាយស្ទូនផ្ទាំង បើបំបែកចេញពីគ្នា មានសណ្ឋានដូចអង្គំរបស់ជាងមាស ឆ្អឹងត្រគាកខាងចុង មានសណ្ឋានដូចពស់បើកពពារដែលគេចាប់ឲ្យផ្កាប់មុខ មានប្រហោងតូចធំ ៧ កន្លែង ឆ្អឹងទ្រនង់ខ្នងខាងមុខ មានសណ្ឋានដូចរង្វង់បន្ទះសំណដែលគេដាក់ត្រួតលើគ្នា ខាងក្រោយ មានសណ្ឋានដូចគ្រាប់ផ្គាំ ចន្លោះៗ នៃឆ្អឹងទាំងនោះ មានពន្លួញ ២-៣ ដូចគ្នានឹងធ្មេញរណា ។ បណ្ដាឆ្អឹងជំនីរ ២៤ ឆ្អឹងជំនីរផុត មានសណ្ឋានដូចកណ្ដៀវដែលមិនពេញ ឆ្អឹងជំនីរក្រៅពីនោះ មានសណ្ឋានដូចផ្លែកណ្ដៀវដែលពេញលេញ ឆ្អឹងជំនីរទាំងអស់ មានសណ្ឋានដូចស្លាបដែលបើករបស់មាន់សំឡី ។

ឆ្អឹងទ្រូង ១៤ កំណាត់ មានសណ្ឋានដូចគ្រែស្នែងបុរាណ ឆ្អឹងចុងដង្ហើម មានសណ្ឋានដូចវែក ឆ្អឹងដងកាំបិត មានសណ្ឋានដូចដងកាំបិតតូច ឆ្អឹងស្លាបប្រចៀវ មានសណ្ឋានដូចចបកាប់អ្នកសីហឡៈ ដែលបែរទៅម្ខាង ឆ្អឹងដើមដៃ មានសណ្ឋានដូចដងកញ្ចក់ កំណាត់ខាងចុង មានសណ្ឋានដូចគូទៃឫសត្នោត ឆ្អឹង-កដៃ មានសណ្ឋានដូចរនូងបន្ទះសំណដែលគេផ្សារភ្ជាប់គ្នាតាំងទុក ឆ្អឹងខ្នងដៃ មានសណ្ឋានដូចបាច់ដើមកន្ទួលមកុឡដែលត្រូវដុំហើយ ឆ្អឹងគល់ម្រាមដៃ មានសណ្ឋានដូចស្គរតូច ឆ្អឹងកំណាត់កណ្ដាល មានសណ្ឋានដូចគ្រាប់ខ្នុរដែលមិនពេញ ឆ្អឹងខាងចុង មានសណ្ឋានដូចគ្រាប់ល្មៀង ឆ្អឹង-ក ៧ កំណាត់ មានសណ្ឋានដូចសម្បកទំពាំងដែលគេប្រើឈើដោតតម្កល់ដោយលំដាប់ ឆ្អឹងចង្កាខាងក្រោម មានសណ្ឋានដូចដង្កាប់តូចរបស់ជាងដែក កំណាត់ខាងលើ មានសណ្ឋានដូចដែកអង្រួស ឆ្អឹងប្រឡង់ភ្នែក និងឆ្អឹងច្រមុះ មានសណ្ឋានដូចប្រឡង់គ្រាប់ត្នោតខ្ចី ដែលគេក្ដិះចេញហើយ ឆ្អឹងថ្ងាស មានសណ្ឋានដូចបន្ទះអំបែង ឬសម្បកស័ង្ខដែលគេផ្កាប់ ឆ្អឹងត្រចៀក មានសណ្ឋានដូចស្រោមកាំបិតកោររបស់ជាងកោរកាត់ ឆ្អឹងដែលតាំងជាប់គ្នាខាងលើរបស់ឆ្អឹងថ្ងាស និងឆ្អឹងត្រចៀក មានសណ្ឋានដូចដុំសំពត់ពេញផ្ទាំងដែលញក់ញី ឆ្អឹងបង្ហើយ មានសណ្ឋានដូចត្រឡោកដូង ដែលគេចិតត្រង់មុខហើយ ឆ្អឹងអំបែងក្បាល មានសណ្ឋានដូចសម្បកឃ្លោក ដែលគេដេរតគ្នាដាក់តម្កល់ ។

ពោលដោយទិស កើតក្នុងទិសទាំងពីរ ពោលដោយឱកាស តាំងនៅ

*ក្នុងសរីរៈទាំងមូលដោយមិនប្លែកគ្នា តែបើពោលដោយប្លែកគ្នាក្នុងទីនេះ ឆ្អឹងក្បាល តាំងនៅលើឆ្អឹង-ក ឆ្អឹង-ក តាំងនៅលើឆ្អឹងទ្រូងខ្នង ឆ្អឹងទ្រូងខ្នង តាំងនៅលើឆ្អឹងចង្កេះ ឆ្អឹងចង្កេះ តាំងនៅលើឆ្អឹងភ្លៅ ឆ្អឹងភ្លៅតាំងនៅលើឆ្អឹងជង្គង់ ឆ្អឹងជង្គង់ តាំងនៅលើឆ្អឹងស្មង ឆ្អឹងស្មង តាំងនៅលើឆ្អឹង-កជើង ឆ្អឹង-កជើងតាំងនៅលើឆ្អឹងខ្នងជើង បើពោលដោយការកំណត់ ខាងក្នុងកំណត់ដោយខួរក្នុងឆ្អឹង ខាងលើកំណត់ដោយសាច់ ខាងចុង និងគល់ កំណត់ដោយឆ្អឹងផងគ្នា នេះជាសភាគបរិច្ឆេទរបស់ឆ្អឹងទាំងនោះ ចំណែកវិសភាគបរិច្ឆេទដូចគ្នានឹងសក់នោះឯង ។*

*ពាក្យថា ខួរក្នុងឆ្អឹង គឺខួរដែលនៅខាងក្នុងឆ្អឹងទាំងនោះ ខួរក្នុងឆ្អឹងនោះ ពោលដោយពណ៌ មានពណ៌ស ពោលដោយសណ្ឋាន ខួរដែលនៅក្នុងឆ្អឹងធំៗ មានសណ្ឋានដូចបណ្តូលផ្តៅធំដែលគេរោលភ្លើង ញាត់ក្នុងបំពង់ឫស្សី ខួរដែលនៅខាងក្នុងឆ្អឹងកំណាត់តូចៗ មានសណ្ឋានដូចផ្តៅតូច ដែលគេរោលភ្លើង ញាត់ក្នុងបំពង់ឫស្សី ( ទីខ្លះថា ញាត់ក្នុងបំពង់ដើមបបុស ) ពោលដោយទិស កើតក្នុងទិសទាំងពីរ ពោលដោយឱកាស តាំងនៅខាងក្នុងឆ្អឹងទាំងឡាយ ពោលដោយការកំណត់ កំណត់ដោយផ្ទៃខាងក្នុងនៃឆ្អឹងទាំងឡាយ នេះជាសភាគបរិច្ឆេទរបស់ខួរក្នុងឆ្អឹង ចំណែកវិសភាគបរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។*

*ពាក្យថា ទាច[១] គឺជាដុំសាច់ពីរដុំដែលមានទងតែមួយ ទាចនោះ*

---

*១- បិដកខ្មែរថា តម្រងបស្សាវៈ ។*

ពោលដោយពណ៌ មានពណ៌ក្រហមខ្ចី ដូចពណ៌នៃគ្រាប់ល្ហុសផ្អុង ពោលដោយសណ្ឋាន មានសណ្ឋានដូចគូនៃផ្លែអង្គញ់ សម្រាប់លេងរបស់កុមារ ឬមានសណ្ឋានដូចគូនៃផ្លែស្វាយ ដែលមានទងតែមួយ ។ ពោលដោយទិស កើតក្នុងទិសខាងលើ ពោលដោយឱកាស តាំងនៅជាទងតែមួយជាមួយសរសៃធំ មានឫសជាមួយគ្នា ចេញចាកពីរណ្ដៅសំយុងបន្តិចហើយ ក៏បែកជាពីរអែមសាច់បេះដូង ។ ពោលដោយការកំណត់ ទាចកំណត់បានដោយចំណែកដែលជាទាច នេះជាសភាគបរិច្ឆេទរបស់ទាច ចំណែកវិសភាគ-បរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។

ពាក្យថា បេះដូង គឺសាច់បេះដូង សាច់បេះដូងនោះ ពោលដោយពណ៌ មានពណ៌ក្រហម ដូចត្របកផ្កាបទុម ពោលដោយសណ្ឋាន មានសណ្ឋានដូចផ្កាឈូកក្រពុំដែលគេបកត្របកខាងក្រៅ ហើយដាក់សំយុងចុះខាងក្រៅ មានសភាពរលោង តែខាងក្នុង ដូចគ្នានឹងផ្នែកខាងក្នុងរបស់ផ្លែននោងព្រៃ សាច់បេះដូងរបស់បុគ្គលអ្នកមានបញ្ញា រីកបន្តិច របស់បុគ្គលដែលឥតបញ្ញា ដូចផ្កាឈូកក្រពុំនោះឯង ខាងក្នុងហទយៈនោះ ប្រហោងមានប្រមាណដាក់ផ្លែបុន្នាគ លោហិតមានប្រមាណកន្លះទូកដៃ ដក់ក្នុងទីណា មនោធាតុ និងមនោវិញ្ញាណធាតុអាស្រ័យទីណាប្រព្រឹត្តទៅ ទីនោះៗ របស់បុគ្គលមានរាគចរិត ជាពណ៌ក្រហម របស់បុគ្គលទោសចរិត មានពណ៌ខ្មៅ របស់បុគ្គលមោហចរិត មានពណ៌ដូចទឹកលាងសាច់ របស់បុគ្គលដែលជាវិតក្កចរិត មានពណ៌ដូចគ្នានឹងទឹកផ្លែពពាយជ្រូង របស់បុគ្គលសទ្ធាចរិត មាន

ពណ៌ដូចផ្កាកណិការ របស់បុគ្គលមានបញ្ញាចរិត ថាផូរផង់ មិនល្អក់ សបរិសុទ្ធ រមែងប្រាកដរុងរឿង ដូចកែវមណីបរិសុទ្ធដែលឆ្នៃហើយ ពោលដោយទិស កើតក្នុងទិសខាងលើ ពោលដោយឱកាស តាំងនៅត្រង់កណ្ដាលរវាងដោះទាំងពីរ ខាងក្នុងសរីរៈ ពោលដោយការកំណត់ កំណត់ដោយចំណែកដែលជាសាច់បេះដូង នេះជាសភាគបរិច្ឆេទរបស់បេះដូង ចំណែកវិសភាគបរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។

ពាក្យថា ថ្លើម គឺបន្ទះសាច់ដែលចែកជាពីរ ថ្លើមនោះពោលដោយពណ៌ មានពណ៌ក្រហមលាយលឿង មិនក្រហមខ្លាំង ដូចពណ៌នៃត្របកឈូក ពោលដោយសណ្ឋាន ត្រង់គល់ជាបន្ទះតែមួយ ត្រង់ចុងបែកជាពីរបន្ទះ មានសណ្ឋានដូចស្លឹករលួសផ្អុង ។ មួយាងទៀត ថ្លើមនោះ សម្រាប់បុគ្គលមានបញ្ញាតិច ជាបន្ទះធំតែមួយប៉ុណ្ណោះ របស់បុគ្គលអ្នកមានបញ្ញាជាបន្ទះតូចៗ ២ ឬ ៣ ។ ពោលដោយទិស កើតក្នុងទិសខាងលើ ពោលដោយឱកាស អាស្រ័យនៅខាងស្ដាំ ក្នុងរវាងដោះទាំងពីរ ពោលដោយការកំណត់ ថ្លើមក៏កំណត់ដោយចំណែកដែលជាថ្លើម នេះជាសភាគបរិច្ឆេទរបស់ថ្លើម ចំណែកវិសភាគបរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។

ពាក្យថា ភាវ គឺជាសាច់សម្រាប់ស្រោប មាន ២ ប្រភេទ ដោយចែកជាភាវប្រភេទបិទ និងភាវប្រភេទមិនបិទ ។ ភាវទាំង ២ នោះ ពោលដោយពណ៌ មានពណ៌ស ដូចពណ៌នៃសំពត់ទុកូលចាស់ ។ ពោលដោយសណ្ឋាន មានសណ្ឋានតាមទីដែលតាំងនៅរបស់ខ្លួន ពោលដោយទិស ភាវប្រភេទបិទ

កើតក្នុងទិសខាងលើ វាវក្រៅអំពីនេះ កើតក្នុងទិសទាំងពីរ ពោលដោយឱកាស វាវប្រភេទបិទ ស្រោបសាច់បេះដូង និងទាច វាវដែលមិនបិទ ទាញសាច់ខាងក្រោមស្បែកក្នុងសរីរៈទាំងមូល ពោលដោយការកំណត់ ខាងក្រោមកំណត់ដោយសាច់ ខាងលើ កំណត់ដោយស្បែក ទទឹង កំណត់ដោយវាវផងគ្នា នេះជាសភាគបរិច្ឆេទរបស់វាវ ចំណែកវិសភាគបរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។

ពាក្យថា ក្រពះ សាច់ដែលតាំងនៅក្នុងពោះ ក្រពះនោះ ពោលដោយពណ៌ មានពណ៌និល គឺពណ៌ទឹកប្រាក់ចាស់ ដូចផ្កាកន្ទិស ពោលដោយសណ្ឋាន មានសណ្ឋានដូចអណ្តាតកូនគោខ្មៅលៀនចេញប្រមាណ ៧ ធ្នាប់ ពោលដោយទិស កើតក្នុងទិសខាងលើ ពោលដោយឱកាស អាស្រ័យតាំងនៅខាងលើផ្ទៃពោះផ្នែកខាងឆ្វេងនៃបេះដូង កាលក្រពះចេញមកខាងក្រៅ ព្រោះត្រូវប្រហារដោយគ្រឿងប្រហារ សត្វទាំងឡាយរមែងអស់ជីវិត ពោលដោយការកំណត់ កំណត់ដោយចំណែកដែលជាក្រពះ នេះជាសភាគបរិច្ឆេទរបស់ក្រពះ ចំណែកវិសភាគបរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។

ពាក្យថា សួត គឺសួត បែកចេញជាដុំសាច់ ៣២ បន្ទះ សួតនោះ ពោលដោយពណ៌ មានពណ៌ដូចផ្លែល្វាស្រគាល ពោលដោយសណ្ឋាន មានសណ្ឋានដូចដុំនំដែលក្រាស់ ដែលគេកាត់មិនស្មើគ្នា ចំណែកខាងក្នុងរបស់វា មានសភាពទុះមិនមានរសជាតិ និងមិនមានឱជៈ ដូចស្លឹកឈើដែលគេទំពាហើយ ព្រោះត្រូវភ្លើងធាតុដែលកើតអំពីកម្មដុតរោល ដោយ

មិនមានវត្ថុដែលបរិភោគ និងផឹកចូលទៅ ពោលដោយទិស កើតក្នុងទិសខាងលើ ពោលដោយឱកាស សំយុងគ្របបេះដូង និងថ្លើម នៅក្នុងរវាងដោះទាំងពីរខាងក្នុងសរីរៈ ពោលដោយការកំណត់ កំណត់ដោយចំណែកដែលជាសួត នេះជាសភាគបរិច្ឆេទរបស់សួត ចំណែកវិសភាគបរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។

ពាក្យថា ពោះវៀនធំ គឺផ្នត់ពោះវៀនធំ សម្រាប់បុរស ប្រវែង ៣២ ហត្ថ ពោះវៀនធំរបស់មនុស្សស្រី ប្រវែង ២៨ ហត្ថ បត់ទៅបត់មកជា ២១ ផ្នត់ ។ ពោះវៀនធំនោះ ដោយពណ៌ មានពណ៌សដូចដុំក្រួសពណ៌ស ពោលដោយសណ្ឋាន មានសណ្ឋានដូចពស់ ឬសត្វអន្ទង់ស ដែលគេកាត់ក្បាលបត់ដាក់ក្នុងស្នូកឈាម ពោលដោយទិស កើតក្នុងទិសទាំងពីរ ពោលដោយឱកាស តាំងនៅក្នុងសរីរៈ មាន-ក និងទ្វារធំជាព្រំប្រទល់ គឺតជាប់គ្នា ខាងលើ ចាប់ពីបំពង់ក ខាងក្រោម តាំងនៅត្រង់ទ្វារធំ ។ ពោលដោយការកំណត់ កំណត់ចំណែកដែលជាពោះវៀនធំ នេះជាសភាគបរិច្ឆេទរបស់ពោះវៀនធំ ចំណែកវិសភាគបរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។

ពាក្យថា ពោះវៀនតូច គឺពោះវៀនតូចដែលជាខ្សែចងព័ទ្ធព័ន្ធពោះវៀនធំ ពោះវៀនតូចនោះ ពោលដោយពណ៌ មានពណ៌សដូចឫសចង្កុលនី ពោលដោយសណ្ឋាន មានសណ្ឋានដូចឫសចង្កុលនីនោះឯង ពោលដោយទិស កើតក្នុងទិសទាំងពីរ ពោលដោយឱកាស ពោះវៀនតូចនោះ ចងពោះវៀនធំមួយកន្ទែង ដូចខ្សែយន្តដែលទាញយន្ត ក្នុងវេលាដែលជាងទាំងឡាយធ្វើ

ការងារ មានការជាប់ និងចាំងជាដើម ទាញខ្សែយន្ត ពោះវៀនតូច តាំងនៅក្នុងរវាងផ្នត់ពោះវៀនធំក្នុងទី ២១ កន្លែង ដូចខ្សែដែលដេរក្នុងរវាងមណ្ឌលអំបោះសម្រាប់ជូតជើង ដូច្នោះ ពោលដោយការកំណត់ កំណត់ដោយទីដែលជាពោះវៀនតូច នេះជាសភាគបរិច្ឆេទរបស់ពោះវៀនតូច ចំណែកវិសភាគ-បរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។

ពាក្យថា អាហារថ្មី បានដល់ របស់ដែលបរិភោគ ដែលផឹក ដែលទំពា ដែលលិឍចូលទៅក្នុងផ្ទៃ ។ អាហារថ្មីនោះ ពោលដោយពណ៌ មានពណ៌ដូចអាហារដែលលេបចូលទៅ ពោលដោយសណ្ឋាន មានសណ្ឋានដូចអង្ករដែលដាក់ក្នុងថង់ស្ដើងៗ ពោលដោយទិស កើតក្នុងទិសខាងលើ ពោលដោយឱកាស តាំងនៅក្នុងឧទរ ។ អវយវៈដែលជារម្អិលពោះវៀន ដូចគ្នានឹងសំពត់ដែលប៉ោងឡើងត្រង់កណ្ដាលនៃសំពត់សើម ដែលគេក្ដោបជាយសងខាង ហៅថា ឧទរ ។ ឧទរនោះ ខាងក្រៅ រលោង ខាងក្នុង ដូចគ្នានឹងសំពត់ជូតរជូវ ដែលប្រឡាក់ហើយ ខ្ជប់សំណល់សាច់ និងពោលថា ដូចគ្នានឹងខាងក្នុងនៃផ្ទៃខ្នុរបាយស្រាក៏គួរ ។ ក្នុងឧទរនោះសោត មានពួកជន្លេនទាំងឡាយ ៣២ ត្រកូល គឺក្រុណទំពក់ ក្រុណខ្ជួនមូល ក្រុណជក់ត្នោត ក្រុណមាត់ម្ជុល ក្រុណសំប៉ែត ក្រុណសរសៃអំបោះជាដើម ពពាក់ពពូនគ្នាអាស្រ័យនៅ ត្រាច់ទៅជាពួកៗ កាលទឹក និងបាយជាដើម មិនមាន ជន្លេនទាំងនោះក៏ពពាក់ពពូនជញ្ជក់បេះដូងក្នុងវេលាដែលលេបអាហារ មានទឹក និងបាយជាដើមចូលទៅ ក្រុណទាំងនោះ ក៏នាំគ្នាបញ្ឈរមាត់ឡើងលើ ទទួលពពាក់

ពពូនជណ្តើមជុំបាយដែលលេបចូលទៅ ២-៣ មាត់ដំបូង ៗ ឧទរនោះឯង ដូចជាផ្ទះប្រសូត បន្ទន់ មន្ទីរពេទ្យ និងព្រៃស្មសានរបស់ជន្លូវទាំងនោះ ។ អាហារទាំងឡាយ មានទឹក និងបាយជាដើម មានប្រការផ្សេងៗ ដែលបុក ដោយអង្រែ គឺធ្មេញ បង្វិលទៅមកដោយដៃ គឺអណ្តាត ផ្សំមដោយទឹក មាត់ ខណៈនោះឯង ក៏ក្លាយជាវត្ថុប្រាសចាកគុណសម្បត្តិនៃពណ៌ ក្លិន រស ជាដើម ដូចគ្នានឹងបាយម៉ានជ្រលក់អំបោះរបស់ជាងតម្បាញ និងដូចកម្អួតឆ្កែ កាលធ្លាក់ទៅក្នុងបំពង់ក ក៏ប្រឡូកប្រឡំដោយទឹកប្រមាត់ ទឹកស្លេស្ម ខ្យល់ កម្តៅ ដោយកម្លាំងនៃការដុតរបស់ភ្លើងក្នុងផ្ទៃ រវើកទៅដោយហ្វូងជន្លូវ បែក ជាពពុះតូចធំដោយលំដាប់ ដល់នូវភាពជារបស់ស្មោកគ្រោក មានក្លិនស្អុយ គួរខ្ពើមក្រៃលែង តាំងនៅក្នុងឧទរនោះ ប្រៀបដូចភ្លៀងធំ ធ្លាក់ចុះមកក្នុងរដូវ ប្រាំង សាកសពសត្វផ្សេងៗ មានមូត្រ លាមក កំណាត់ស្បែក ឆ្អឹង សរសៃ ទឹកមាត់ ទឹកសំបោរ ឈាមជាដើម ដែលទឹកនាំទៅធ្លាក់ចុះត្រង់ស្រះទឹក ស្មោកគ្រោក ក្បែរទ្វារស្រុករបស់មនុស្សចណ្ឌាល និងផ្សំចូលជាមួយភក់ ២-៣ ថ្ងៃ ក៏មានពួកជន្លូវកើតឡើង ហើយស្រះទឹកនោះ ក្តៅដោយចំហាយ ព្រះអាទិត្យ បែកជាពពុះ ខាងលើជារបស់មានពណ៌ខៀវចាស់ ជារបស់ ស្អុយ គួរខ្ពើមក្រៃលែង ដល់នូវភាពជារូបដែលមិនគួរចូលទៅជិត មិនគួរ ឃើញ នឹងពោលថ្វីដល់នូវភាពជាវត្ថុគួរស្រង់ក្លិន គួរលិឍភក្ស ព្រោះស្តាប់ រឿងឧទរ ការមិនពេញចិត្តក្នុងបាយទឹកជាដើម ក៏កើតឡើងបាន នឹងពោល ទៅថ្វីដល់ការពេញចិត្តក្នុងបាយ និងទឹកជាដើម ព្រោះការសម្លឹងមើលដោយ

បញ្ញាចក្ខុ ។ មួយ៉ាងទៀត ក្នុងឧទរនោះ ដែលមានរបស់បរិភោគ មានបាយ និងទឹកជាដើម ធ្លាក់ចូលទៅហើយ រមែងដល់នូវការចែកចេញជា ៥ ចំណែក គឺសត្វទាំងឡាយទំពាស៊ីមួយចំណែក ភ្លើងធាតុដុតមួយចំណែក ក្លាយជាទឹកមូត្រមួយចំណែក ក្លាយជាលាមកមួយចំណែក មួយចំណែកដល់នូវភាពជាអាហារទៅជំនួយដល់កោដ្ឋាស មានឈាម និងសាច់ជាដើមឲ្យចម្រើន ពោលដោយការកំណត់ កំណត់ដោយផ្ទៃឧទរ និងចំណែកដែលជាឧទរិយៈ នេះជាសភាគបរិច្ឆេទរបស់អាហារថ្មី ចំណែកវិសភាគបរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។

ពាក្យថា អាហារចាស់ គឺឧច្ចារៈ ឧច្ចារៈនោះដោយពណ៌ ពោលដោយពណ៌ដូចអាហារដែលលេបចូលទៅនោះឯងដោយច្រើន ពោលដោយសណ្ឋាន មានសណ្ឋានតាមទីដែលតាំងនៅ ពោលដោយទិស កើតក្នុងទិសខាងក្រោម ពោលដោយឱកាស តាំងនៅក្នុងទីសម្រាប់ផ្ទុកឧច្ចារៈ ។ ឈ្មោះថា ឋង់ឧច្ចារៈ ដូចគ្នានឹងបំពង់ឫស្សី ប្រវែងប្រមាណ ៨ អង្គុលី នៅខាងចុងពោះវៀនធំក្នុងរវាងនាភី គឺផ្ចិត ខាងក្រោមឆ្អឹងខ្នងទ្រនង់ខ្នង ។ អាហារណាមួយ មានបាយ និងទឹកជាដើម ធ្លាក់ទៅហើយក្នុងក្រពះ ក្តៅដោយភ្លើងធាតុក្នុងឧទរ ភ្លើងធាតុចម្អិនល្អិតខ្ទេចខ្ទីហើយ ហាក់បីដូចបុកដោយត្បាល់ រំកិលទៅតាមប្រហោងពោះវៀនធំ ធ្លាក់ទៅសង្កត់លើគ្នា ដូចដីឥដ្ឋពណ៌លឿងដែលគេច្របាច់ញាត់ចូលក្នុងបំពង់ឫស្សី ប្រៀបដូចភ្លៀងធ្លាក់ខាងលើៗ ហូរមកកាន់ទីទាបដក់នៅពេញ ដូច្នោះ ។

បើពោលដោយការកំណត់ កំណត់ដោយថង់ឧច្ចារៈ និងដោយចំណែកដែលជាឧច្ចារៈ នេះជាសភាគបរិច្ឆេទរបស់ករីសៈ ចំណែកវិសភាគបរិច្ឆេទដូចគ្នានឹងសក់នោះឯង ។

ពាក្យថា ខួរក្នុងក្បាល គឺគំនរកាកសំណល់ ដែលតាំងនៅក្នុងលលាដ៍ក្បាល ខួរក្បាលនោះពោលដោយពណ៌ មានពណ៌សដូចផ្សិតក្បាលពស់ ទោះពោលថា មានពណ៌ដូចទឹកដោះស្រស់ ដែលមិនទាន់ប្រែទៅជាទឹកដោះជូរក៏គួរ ពោលដោយសណ្ឋាន មានសណ្ឋានតាមទីដែលតាំងនៅ ពោលដោយទិស កើតក្នុងទិសខាងលើ ពោលដោយឱកាស អាស្រ័យជួរផ្សារភ្ជាប់គ្នា ៤ កន្លែងរួមគ្នាក្នុងលលាដ៍ក្បាល ដូចដុំម្សៅ ៤ ដុំ ដែលគេដាក់ផ្គុំរួមគ្នា ។ ពោលដោយការកំណត់ កំណត់ដោយផ្ទៃខាងក្នុងលលាដ៍ក្បាល និងដោយចំណែកដែលជាខួរ នេះជាសភាគបរិច្ឆេទរបស់ខួរក្នុងក្បាល ចំណែកវិសភាគបរិច្ឆេទដូចគ្នានឹងសក់នោះឯង ។

ពាក្យថា ទឹកប្រមាត់ បានដល់ ប្រមាត់ពីរប្រភេទ គឺប្រមាត់មានស្រោម និងប្រមាត់មិនមានស្រោម ក្នុងប្រមាត់ទាំងពីរនោះ ប្រមាត់ដែលនៅក្នុងស្រោមពោលដោយពណ៌ មានពណ៌ដូចប្រេងស្រគំខាប់ ប្រមាត់មិនមានស្រោម មានពណ៌ដូចផ្កាពុលក្រៀម ពោលដោយសណ្ឋាន ប្រមាត់ទាំងពីរ មានសណ្ឋានតាមដែលតាំងនៅ ពោលដោយទិស ប្រមាត់មានស្រោមកើតក្នុងទិសខាងលើ ប្រមាត់ក្រៅអំពីនេះ កើតក្នុងទិសទាំងពីរ ពោលដោយឱកាស វៀរសក់ រោម ក្រចក ធ្មេញ និងស្បែកក្រាស់ ឬស្បែកក្រិនហើយ តាំងនៅជ្រួតជ្រាបក្នុង

សរីរៈដ៏សេស ដូចតំណក់ប្រេងក្នុងទឹក ជ្រួតជ្រាបផ្សាយទៅ ដូច្នោះ ។ កាល ប្រមាត់កម្រើក ភ្នែករបស់សត្វ រមែងលឿង រមែងវិលមុខ រាងកាយញាប់ ញ័រ ។ ប្រមាត់មានស្រោម ដក់នៅក្នុងស្រោមប្រមាត់ តាំងនៅក្នុងស្រោម ប្រមាត់ ដូចគ្នានឹងស្រោមរបស់ននោងធំ ប្រមាត់នេះ ជាប់នៅត្រង់សាច់ ថ្លើម ចន្លោះបេះដូង និងសួត កាលប្រមាត់នេះកម្រើក សត្វទាំងឡាយរមែង ឆ្កួត មានចិត្តវិបល្លាស លះបង់ហិរិឱត្តប្បៈ រមែងធ្វើវត្ថុដែលមិនគួរធ្វើ រមែង ពោលដោយវត្ថុដែលមិនគួរពោល គិតក្នុងវត្ថុដែលមិនគួរគិត ពោលដោយ ការកំណត់ កំណត់ដោយចំណែកដែលជាប្រមាត់ នេះជាសភាគបរិច្ឆេទរបស់ ប្រមាត់ ចំណែកវិសភាគបរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។

ពាក្យថា ស្លេស្ម គឺស្លេស្មមានប្រមាណ ១ កម្បង់ នៅក្នុងរាងកាយ ស្លេស្មនោះ ដោយពណ៌ មានពណ៌ស ដូចពណ៌នៃទឹកស្លឹកពពាយជ្រុង ដោយសណ្ឋាន មានសណ្ឋានតាមទីដែលតាំងនៅ ដោយទិស កើតក្នុងទិស ខាងលើ ដោយឱកាស តាំងនៅត្រង់ផ្ទៃឧទរ ក្នុងពេលដែលលេបទឹក និង បាយជាដើម កាលទឹក និងបាយជាដើមធ្លាក់ចូលទៅ ស្លេស្មក៏ញែកចេញ ពីគ្នា ហើយជិតមកវិញ ប្រៀបដូចចកក្នុងទឹក កាលអង្កត់ឧស ឬអំបែងធ្លាក់ ចូលទៅ ចកក៏ញែកចេញអំពីគ្នា ហើយក៏ត្រឡប់ចូលមកវិញដូចមុន ដូច្នោះ ម្យ៉ាងទៀត កាលស្លេស្មមានប្រមាណតិច ឧទរក៏បញ្ចេញក្លិនស្អុយ សាក សពសត្វដែលគួរខ្ពើមក្រៃលែង ដូចបូស ឬស៊ុតស្អុយដែលបែក ដូច្នោះ ។ ព្រោះក្លិនផ្សាយឡើងអំពីឧទរនោះ ខ្យល់កើតក្តី មាត់ក្តី រមែងមានក្លិនស្អុយដូច

សាកសពសត្វ ទាំងបុគ្គលនោះ រមែងត្រូវបណ្តេញថា ចេញទៅ ឯងមានក្លិនស្អុយ ។ម្យ៉ាងទៀត ស្លេស្មនោះមានច្រើន ហើយក៏បិទបាំងក្លិនសាកសពខាងក្នុងឧទរនោះឯង ដូចបន្ទះក្តារបិទបង្គន់ ដូច្នោះ ពោលដោយការកំណត់ កំណត់ចំណែកដែលជាស្លេស្ម នេះជាសភាគបរិច្ឆេទរបស់ស្លេស្ម ចំណែកវិសភាគបរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។

ពាក្យថា ខ្ទុះ ដោយពណ៌ មានពណ៌ដូចស្លឹកឈើទុំ តែក្នុងរាងកាយរបស់អ្នកស្លាប់ មានពណ៌ដូចទឹកបាយខាប់ដែលផ្អូម ពោលដោយសណ្ឋាន មានសណ្ឋានតាមទីដែលតាំងនៅ ពោលដោយទិស កើតក្នុងទិសទាំងពីរ ពោលដោយឱកាស ឈ្មោះថា ឱកាសរបស់ខ្ទុះ មិនបានដក់នៅជានិច្ច លុះណាតែចំណែករាងកាយត្រូវប៉ះដោយដង្គត់ឈើ បន្លាស្រួច គ្រឿងប្រហារនិងអណ្តាតភ្លើងជាដើម លោហិតក៏ពុះពង ឬថា បូសជាដើម កើតឡើងក្នុងទីណាមួយ ខ្ទុះនោះ ក៏គប្បីកើតឡើងក្នុងទីនោះៗ ។ ពោលដោយការកំណត់ កំណត់ដោយចំណែកដែលជាខ្ទុះ នេះជាសភាគបរិច្ឆេទរបស់ខ្ទុះ ចំណែកវិសភាគបរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។

ពាក្យថា ឈាម បានដល់ ឈាម ២ ប្រភេទ គឺសន្និចិតលោហិត គឺឈាមដែលដក់នៅ ១ សំសរណលោហិត ឈាមដែលធ្វើចលនា ១ ក្នុងឈាម ២ យ៉ាងនោះ សន្និចិតលោហិត ពោលដោយពណ៌ មានពណ៌ដូចទឹកល័ក្តខាប់ដែលខះដោយភ្លើង សំសរណលោហិត មានពណ៌ដូចទឹកល័ក្តថ្លាៗ ពោលដោយសណ្ឋាន ឈាមទាំងពីរ មានសណ្ឋានតាមទីដែលតាំងនៅ ពោល

ដោយទិស សន្និចិតលោហិត កើតក្នុងទិសខាងលើ ឈាមក្រៅអំពីនោះ កើតក្នុងទិសទាំងពីរ ពោលដោយឱកាស វៀរសក់ រោម ធ្មេញ ក្រចក ដែលផុតចាកសាច់ និងក្នុងទីដែលមានស្បែកក្រិន សំសរណលោហិត ផ្សាយទៅកាន់ឧបាទិន្នកសរីរៈទាំងមូលតាមសរសៃឈាម ។ សន្និចិតលោហិត មានប្រមាណ ១ បាត្រ[1] តាំងនៅពេញចំណែកខាងក្រោមនៃទីតាំងរបស់ថ្លើម ហូរទៅខាងលើទាច បេះដូង ថ្លើម សួត ធ្វើឲ្យទាច បេះដូង ថ្លើម សួតសើមជានិច្ច ព្រោះថា កាលលោហិត មិនធ្វើទាច បេះដូងជាដើមឲ្យសើម សត្វទាំងឡាយ រមែងស្រេក ។ ពោលដោយការកំណត់ កំណត់ចំណែកដែលជាលោហិត នេះជាសភាគបរិច្ឆេទរបស់លោហិត ចំណែកវិសភាគ-បរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។

ពាក្យថា ញើស គឺអាបោធាតុហូរចេញតាមរន្ធរោមជាដើម ។ ញើសនោះដោយពណ៌ មានពណ៌ដូចប្រេងល្ង ពោលដោយសណ្ឋាន មានសណ្ឋានតាមទីដែលតាំងនៅ ពោលដោយទិស កើតក្នុងទិសទាំងពីរ ពោលដោយឱកាស ឈ្មោះថា ឱកាសរបស់ញើស មិនមានជានិច្ចដូចឈាមឡើយ លុះតែកាលណារាងកាយត្រូវកម្តៅ មានកម្តៅរបស់ភ្លើង កម្តៅថ្ងៃ និងការប្រែប្រួលនៃឧតុជាដើម កាលនោះ ញើសក៏ហូរចេញអំពីរន្ធសក់ និងរន្ធរោមទាំងពួង ដូចក្រអៅឈូកដែលដាច់មិនស្មើគ្នា ដែលដកឡើងផុតអំពីទឹក ទឹកក៏ហូរចេញទៅ ដូច្នោះ សូម្បីសណ្ឋានរបស់ញើសនោះ ក៏គប្បីជ្រាបដោយ

---

១- ក្នុងបដិសម្ភិទាមគ្គ ជាមួយកម្បង់ ។

អំណាចនៃរន្ធសក់ និងរន្ធរោមនោះឯង ។ ព្រះយោគីកំណត់ញើសជាអារម្មណ៍ គប្បីមនសិការញើស តាមដែលដក់នៅពេញក្នុងរន្ធសក់ និងរន្ធរោមនោះឯង ។ ពោលដោយការកំណត់ កំណត់ដោយចំណែកដែលជាញើស នេះជាសភាគបរិច្ឆេទរបស់ញើស ចំណែកវិសភាគបរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។

ពាក្យថា ខ្លាញ់ខាប់ ខ្លាញ់ខាប់នោះ ពោលដោយពណ៌ មានពណ៌ដូចរមៀតដែលពុះចេញហើយ ពោលដោយសណ្ឋាន បុគ្គលដែលមានរាងកាយធាត់ មានសណ្ឋានដូចសំពត់ទុកូលចាស់ មានពណ៌ដូចរមៀត តាំងនៅរវាងស្បែក និងសាច់ ចំណែកបុគ្គលដែលមានរាងកាយស្គម មានសណ្ឋានដូចសំពត់ទុកូលចាស់ មានពណ៌ដូចរមៀតដែលធ្វើជា ២-៣ ជាន់ អាស្រ័យសាច់ទាំងនេះ គឺសាច់ដៃ សាច់ជើង សាច់ខ្នងដែលជាប់នឹងឆ្អឹងខ្នង និងសាច់ខាងក្រោមពោះ ពោលដោយទិស កើតក្នុងទិសទាំងពីរ ពោលដោយឱកាស សម្រាប់អ្នកធាត់ ផ្សាយទៅកាន់សរីរៈទាំងមូល សម្រាប់អ្នកស្គម អាស្រ័យសាច់ដៃជាដើមតាំងនៅ ។ ខ្លាញ់ខាប់នេះ ដល់នូវការរាប់ថា ជាខ្លាញ់បាន ព្រោះភាពជារបស់គួរខ្ពើមក្រៃលែង ជនទាំងឡាយ មិនបានកាន់យកមកធ្វើជាប្រេងលាបក្បាល ឬធ្វើជាប្រេងបន្តក់ច្រមុះជាដើមឡើយ ។ បើពោលដោយការកំណត់ ខាងក្រោម កំណត់ដោយសាច់ ខាងលើ កំណត់ដោយស្បែក ទទឹង កំណត់ដោយចំណែកដែលជាខ្លាញ់ខាប់ នេះជាសភាគ-បរិច្ឆេទរបស់ខ្លាញ់ខាប់ ចំណែកវិសភាគបរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។

ពាក្យថា ទឹកភ្នែក គឺអាបោធាតុដែលហូរចេញអំពីភ្នែក ។ ទឹកភ្នែកនោះ

ពោលដោយពណ៌ មានពណ៌ដូចប្រេងល្ង ពោលដោយសណ្ឋាន មានសណ្ឋានតាមទីដែលតាំងនៅ ពោលដោយទិស កើតក្នុងទិសខាងលើ ពោលដោយឱកាស តាំងនៅត្រង់ប្រឡង់ភ្នែក តែទឹកភ្នែកនោះ មិនបានដក់នៅក្នុងប្រឡង់ភ្នែកសព្វកាល ដូចប្រមាត់មានស្រោមឡើយ កាលណាសត្វទាំងឡាយ កើតសោមនស្សស្រើចខ្លាំង កើតទោមនស្សយំរៀបរាប់ បរិភោគអាហារដែលជាវិសភាគយ៉ាងនោះ សេចក្តីថា បរិភោគអាហារប្រភេទដែលនាំឲ្យទឹកភ្នែកហូរ និងកាលណាភ្នែករបស់សត្វទាំងឡាយប៉ះផ្សែង ឬល្អងធូលីជាដើម ទឹកភ្នែក រមែងមកតាំងនៅត្រង់ប្រឡង់ភ្នែក ឬរមែងហូរចេញ ព្រោះការកើតឡើងដោយសោមនស្ស ទោមនស្ស អាហារ ដែលជាវិសភាគ នឹងឧតុទាំងនោះ ។

ព្រះយោគីដែលកំណត់ទឹកភ្នែកជាអារម្មណ៍ គប្បីកំណត់ដោយអំណាចនៃទឹកភ្នែកដែលតាំងនៅពេញប្រឡង់ភ្នែកនោះឯង ពោលដោយការកំណត់ កំណត់ដោយចំណែកដែលជាទឹកភ្នែក នេះជាសភាគបរិច្ឆេទរបស់ទឹកភ្នែក ចំណែកវិសភាគបរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។

ពាក្យថា ខ្លាញ់រាវ ខ្លាញ់រាវនោះ ពោលដោយពណ៌ មានពណ៌ដូចប្រេងដូង សូម្បីពោល នឹងពោលថា ដូចគ្នានឹងប្រេងដែលលាបលើបាយក្តាំងក៏គួរ ។ ពោលដោយសណ្ឋាន មានសណ្ឋានផ្សាយទៅដូចដំណក់ប្រេងដែលដក់នៅលើទឹកថ្លា ក្នុងពេលដែលធ្វើការលាងជម្រះ ពោលដោយទិស កើតក្នុងទិសទាំងពីរ ពោលដោយឱកាស ដោយច្រើន តាំងនៅត្រង់បាតដៃ ខ្នង

ដៃ បាតជើង ខ្នងជើង ចុងច្រមុះ ថ្ងាស និងចង្កេះស្មា តែខ្លាញ់រាវនោះមិនបានរលាយក្នុងទីនោះសព្វកាល កាលណា ចំណែករបស់រាងកាយទាំងនោះក្តៅដោយភ្លើង កម្តៅថ្ងៃ ឧតុ ធាតុប្រែប្រួល កាលនោះ ទើបជ្រួតជ្រាបទៅកាន់ទីផ្សេងៗ ដូចការផ្សាយទៅរបស់ដំណក់ប្រេងលើផ្ទៃទឹកថ្លា ក្នុងវេលាដុសលាង ដូច្នោះ ។ ពោលដោយការកំណត់ កំណត់ដោយចំណែកដែលជាខ្លាញ់រាវ នេះជាសភាគបរិច្ឆេទរបស់ខ្លាញ់រាវ ចំណែកវិសភាគបរិច្ឆេទដូចគ្នានឹងសក់នោះឯង ។

ពាក្យថា ទឹកមាត់ គឺអាបោធាតុដែលកើតឡើងជាពពុះខាងក្នុងមាត់ ទឹកមាត់នោះ ពោលដោយពណ៌ មានពណ៌ដូចពពុះទឹក ពោលដោយសណ្ឋានមានសណ្ឋានតាមដែលតាំងនៅ ទោះបីពោលថា មានសណ្ឋានដូចដុំពពុះទឹកក៏គួរ ពោលដោយទិស កើតក្នុងទិសខាងលើ ពោលដោយឱកាស ចេញអំពីថ្ពាល់ទាំងពីរ តាំងនៅត្រង់អណ្តាត តែមិនបានដក់ក្នុងទីនោះសព្វកាល កាលណាសត្វទាំងឡាយឃើញ ឬទឹកដល់អាហារបែបនោះ ឬដាក់វត្ថុណាមួយ មានរសក្តៅ ល្វីង ហឹរ ប្រៃ និងជូរចូលទៅក្នុងមាត់ ឬកាលណាហទយៈរបស់សត្វទាំងនោះទន់ខ្សោយ ឬកើតនូវការស្រេកឃ្លាន កាលនោះទឹកមាត់កើតឡើង ហើយក៏ហូរចេញអំពីថ្ពាល់ទាំងពីរ មកតាំងនៅត្រង់អណ្តាត ។ ម្យ៉ាងទៀត ទឹកមាត់នោះ ត្រង់ចុងអណ្តាតមានតិច ត្រង់គល់អណ្តាតមានច្រើន មិនចេះអស់ ទាំងអាចញ៉ាំងរបស់ណាមួយ មានអំបុក ឬអង្ករ ឬរបស់ដែលគួរទំពា ដែលដាក់ចូលទៅក្នុងមាត់ឲ្យសើម ដូចអណ្តូងទឹក

ដែលគេជីកក្បែរធ្នេរខ្សាច់ ដូច្នោះ ។ ពោលដោយការកំណត់ កំណត់ដោយចំណែកដែលជាទឹកមាត់ នេះជាសភាគបរិច្ឆេទរបស់ទឹកមាត់ ចំណែកវិសភាគបរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។

ពាក្យថា ទឹកសម្បោរ បានដល់ ទឹកមិនស្អាត ដែលហូរចេញអំពីខួរក្បាល ទឹកសម្បោរនោះពោលដោយពណ៌ មានពណ៌ដូចខ្ទុះក្នុងផ្លែត្នោតខ្ចី ពោលដោយសណ្ឋាន មានសណ្ឋានតាមទីដែលតាំងនៅ ពោលដោយទិសកើតក្នុងទិសខាងលើ ពោលដោយឱកាស តាំងនៅពេញរន្ធច្រមុះ តែមិនតាំងនៅសព្វកាល កាលណាសត្វទាំងឡាយយំ ឬជាអ្នកមានធាតុកម្រើកដែលកើតឡើងដោយអាហារស្លែង ឬឧតុប្រែប្រួល កាលនោះ ខួរក្បាលដល់នូវភាពជាស្លេស្ម ទើបឃ្លាតចាកទីនោះ មកតាមពិតាន ហើយតាំងនៅក្នុងរន្ធច្រមុះ ឬរមែងហូរចេញទៅ ប្រៀបដូចបុគ្គលខ្ចប់នូវទឹកដោះជូរដោយស្លឹកឈូក ហើយយកបន្លាចោះខាងក្រោម ពេលនោះ ទឹកដោះជូរក៏ហូរចេញតាមប្រហោងនោះ ហើយធ្លាក់ទៅខាងក្រៅ ដូច្នោះ ។

ព្រះយោគីកំណត់ទឹកសម្បោរជាអារម្មណ៍ គប្បីកំណត់ដោយអំណាចនៃទឹកសម្បោរដែលតាំងនៅពេញច្រមុះនោះឯង ពោលដោយការកំណត់ កំណត់ដោយចំណែកដែលជាសម្បោរ នេះជាសភាគបរិច្ឆេទរបស់ទឹកសម្បោរ ចំណែកវិសភាគបរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។

ពាក្យថា ទឹករម្អិល បានដល់ ទឹករម្អិលដែលមានក្លិនស្អុយ ខាងក្នុងសន្លាក់របស់រាងកាយ ទឹករម្អិលនោះពោលដោយពណ៌ មានពណ៌ដូចជ័រផ្កា

កណិការ ពោលដោយសណ្ឋាន មានសណ្ឋានតាមដែលតាំងនៅ ពោលដោយទិស កើតក្នុងទិសទាំងពីរ ពោលដោយឱកាស តាំងនៅត្រង់ទី-តទាំង ១០៨ កន្លែង ដែលធ្វើកិច្ច គឺការបន្ទក់លាបទី-តនៃឆ្អឹងទាំងឡាយឲ្យសម្រេច ទឹករម្អិលនោះរបស់បុគ្គលណាមានតិច កាលបុគ្គលនោះក្រោកឡើង ឬអង្គុយចុះ ឈានទៅខាងមុខ ឬថយមកខាងក្រោយ បត់អង្គុញ លាត សណ្ដូក ឆ្អឹងទាំងឡាយក៏លាន់ឮ កដៈ កដៈ ដូចមនុស្សដែលផ្ទាត់ម្រាមដៃ កាលធ្វើដំណើរឆ្ងាយប្រមាណ ១ យោជន៍ ឬ ២ យោជន៍ វាយោធាតុរមែងកម្រើក រាងកាយរមែងជាទុក្ខ តែទឹករម្អិលរបស់បុគ្គលណាមានច្រើន ឆ្អឹងទាំងឡាយមិនឮសំឡេង កដៈ កដៈ ក្នុងពេលក្រោកឡើង និងអង្គុយចុះជាដើម កាលដើរផ្លូវឆ្ងាយ វាយោធាតុក៏មិនកម្រើក រាងកាយក៏មិនជាទុក្ខ ។ ពោលដោយការកំណត់ កំណត់ដោយចំណែកដែលជាទឹករម្អិល នេះជាសភាគបរិច្ឆេទរបស់ទឹករម្អិល ចំណែកវិសភាគបរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។

ពាក្យថា ទឹកមូត្រ ពោលដោយពណ៌ មានពណ៌ដូចទឹកក្បុង ដែលធ្វើអំពីសណ្ដែករាជមាស ពោលដោយសណ្ឋាន មានសណ្ឋានដូចទឹកនៅក្នុងក្អមដែលគេផ្កាប់មាត់ ពោលដោយទិស កើតក្នុងទិសខាងក្រោម ពោលដោយឱកាស តាំងនៅខាងក្នុងតម្រងបស្សាវៈ ថង់នៃបស្សាវៈ លោកហៅថាតម្រងបស្សាវៈ ។ ក្នុងតម្រងទាំងនោះ ទឹកមូត្ររមែងហូរចេញអំពីសរីរៈ តែផ្លូវដែលចូលទៅរបស់ទឹកមូត្រមិនប្រាកដ ចំណែកផ្លូវដែលចេញរមែងប្រាកដប្រៀបដូចទឹកជ្រាំ ដែលជ្រាបចូលក្នុងថ្នាំងទឹកអំបិល គឺថ្នាំងដែលមានសាច់

គ្រោតគ្រាត ដែលគេបិទមាត់បោះទៅក្នុងទឹកជ្រាំ ផ្លូវចូលរបស់ទឹកមូត្រមិនប្រាកដ ដូច្នោះ ។ ម្យ៉ាងទៀត ក្នុងតម្រងបស្សាវៈពេញហើយដោយទឹកមូត្រ ការខ្វល់ខ្វាយរបស់សត្វទាំងឡាយ ទើបកើតឡើងថា អញនឹងនោម ដូច្នេះ ។ ពោលដោយការកំណត់ កំណត់ដោយខាងក្នុងនៃតម្រងបស្សាវៈ និងដោយចំណែកដែលជាទឹកមូត្រ នេះជាសភាគបរិច្ឆេទរបស់ទឹកមូត្រ ចំណែកវិសភាគបរិច្ឆេទ ដូចគ្នានឹងសក់នោះឯង ។

កាលព្រះយោគាវចរកំណត់កោដ្ឋាសទាំងឡាយ មានសក់ជាដើម ដោយពណ៌ សណ្ឋាន ទិស ឱកាស និងការកំណត់យ៉ាងនេះហើយ កាលមនសិការជាបដិកូល ៥ យ៉ាង ដោយពណ៌ សណ្ឋាន ក្លិន ទីអាស្រ័យ និងឱកាស ដោយន័យជាដើមថា ដោយលំដាប់ ដោយមិនលឿនពេក ដោយមិនយឺតពេក ពិចារណាកាយនេះ ដោយអំណាចការឈានកន្លងបញ្ញត្តិថា ក្នុងកាយនេះ មានសក់ជាដើម ធម៌ទាំងពួងនោះ ក៏រមែងប្រាកដ មិនមុន មិនក្រោយ ប្រៀបដូចបុគ្គលដែលមានភ្នែកល្អ សម្លឹងមើលកម្រងផ្កា ៣២ ពណ៌ ដែលគេដោតដោយអំបោះតែមួយ ផ្កាទាំងឡាយរមែងប្រាកដមិនមុន មិនក្រោយ ដូច្នោះ ដោយហេតុនោះ ទើបខ្ញុំពោលក្នុងកថានៃមនសិការកោសលថា កាលព្រះយោគាវចរអ្នកផ្តើមកម្មដ្ឋានដំបូង មនសិការថា សក់ មនសិការ ក៏ទៅរហូតដល់កោដ្ឋាសចុងក្រោយថា ទឹកមូត្រនោះឯង បើព្រះយោគាវចរបង្អោនមនសិការទៅខាងក្រៅខ្វះសោត កាលកោដ្ឋាសទាំងពួងប្រាកដច្បាស់ហើយ ក្នុងលំដាប់នោះ មនុស្ស និងសត្វទាំងឡាយ ដែលដើរទៅមក ក៏លះបង់នូវ

អាការថាជាសត្វ ប្រាកដដល់ព្រះយោគាវចរនោះ ដោយជាគំនរនៃកោដ្ឋាស ប៉ុណ្ណោះ ឯអាហារ មានទឹក និងបាយជាដើម ដែលសត្វទាំងនោះលេបចូលទៅ ក៏រមែងប្រាកដហាក់បីដូចរបស់ដែលគេដាក់ចូលទៅក្នុងគំនរនៃកោដ្ឋាស ។ លំដាប់នោះ កាលព្រះយោគាវចរមនសិការរឿយៗ ថា បដិកូល បដិកូល ដោយមនសិការកោសល មានការរំលងលំដាប់ជាដើម អប្បនាក៏រមែងកើតឡើងដោយលំដាប់ ។ ក្នុងការកើតឡើងនៃអប្បនានោះ ការប្រាកដនៃកោដ្ឋាស មានសក់ជាដើម ដោយអំណាចនៃពណ៌ សណ្ឋាន ទិស ឱកាស និងការកំណត់ជាឧគ្គហនិមិត្ត ។ ការប្រាកដដោយអាការនៃកោដ្ឋាសទាំងពួង ដោយអំណាចនៃបដិកូលជាបដិភាគនិមិត្ត ។ កាលព្រះយោគាវចរទទួលអារម្មណ៍បដិភាគនិមិត្តនោះ មកមនសិការត្រិះរិះរឿយៗ នាមក្ខន្ធ ៤ ក៏នឹងមានបដិកូលជាអារម្មណ៍ អប្បនារមែងប្រព្រឹត្តទៅដោយអំណាចនៃបឋមជ្ឈាន ។ ក្នុងចំណែកខាងដើម ចិត្តមានបរិកម្ម និងឧបចារៈប្រព្រឹត្តទៅដោយវិតក្ក វិចារ បីតិសហគតៈដោយសោមនស្ស រមែងមានបដិកូលជានិមិត្ត សូម្បីអប្បនាក៏មានវិតក្ក វិចារ បីតិសហគតៈដោយសោមនស្សនោះឯង ។ តែបើពោលដោយលំដាប់នៃភូមិ អប្បនានោះ ជាមហគ្គតៈ ជារូបាវចរ ។ សោមនស្សរមែងកើតឡើង ព្រោះភាពជាអ្នកមានប្រក្រតីឃើញអានិសង្សក្នុងអារម្មណ៍ដែលជាបដិកូលនោះ ។ម្យ៉ាងទៀត សោមនស្សនោះ រមែងកើតឡើងដោយកម្លាំងនៃអារម្មណ៍តែមួយជាមួយគ្នា ចំណែកទុតិយជ្ឈានជាដើម មិនបានកើតឡើងក្នុងអារម្មណ៍ដែលជាបដិកូលនោះ សួរថា ព្រោះហេតុអ្វី ឆ្លើយថា

ព្រោះភាពជាអារម្មណ៍គ្រោតគ្រាត ។ ពិតហើយ បដិកូលនេះ ជាអារម្មណ៍គ្រោតគ្រាត ទើបទុតិយជ្ឈានជាដើមមិនកើតឡើង ។ ក្នុងអធិការនេះ ភាពជាឯកគ្គតានៃចិត្ត រមែងកើតបានដោយកម្លាំងនៃវិតក្កប៉ុណ្ណោះ មិនបានកើតឡើងដោយការឈានកន្លងវិតក្កឡើយ នេះជាកម្មដ្ឋានកថាដោយអំណាចនៃសមថៈ ។

គប្បីជ្រាបកម្មដ្ឋានដូចពណ៌នាមកនេះ ដោយអំណាចសាធារណៈដោយមិនប្លែកគ្នា ។ ពិតហើយ ព្រះយោគាវចរប្រាថ្នានឹងចម្រើនកម្មដ្ឋាននេះ រៀនយកកម្មដ្ឋានហើយ គប្បីទន្ទេញហើយទន្ទេញទៀតដោយវាចានូវនិមិត្តនៃពណ៌ និមិត្តនៃសណ្ឋាន និមិត្តនៃទិស និមិត្តនៃឱកាស និងនិមិត្តនៃការកំណត់របស់កោដ្ឋាសទាំងឡាយ មានសក់ជាដើម ក្នុងពេលដែលស្វាធ្យាយនោះឯង ហើយមនសិការតែកោដ្ឋាសមួយថា កោដ្ឋាសនេះ ដូចគ្នានឹងវត្ថុនេះ ដូច្នេះហើយធ្វើការស្វាធ្យាយដោយ ៣ វិធី ។ សួរថា គប្បីធ្វើការស្វាធ្យាយដូចម្តេច ឆ្លើយថា នឹងពោលក្នុងតចបញ្ចកៈមុន គប្បីធ្វើការស្វាធ្យាយដោយកោដ្ឋាសទាំងនេះអស់កន្លះខែ គឺដោយអនុលោម ៥ ថ្ងៃ ដោយន័យដែលពោលហើយខាងដើមនោះឯង ដោយបដិលោម ៥ ថ្ងៃ និងដោយអនុលោមបដិលោម ៥ ថ្ងៃ ។ បន្ទាប់អំពីនោះ គប្បីទៅកាន់សម្នាក់របស់អាចារ្យ រៀនយកវក្កបញ្ចកៈ ហើយគប្បីធ្វើនូវការស្វាធ្យាយអស់កន្លះខែ ដោយទំនងនោះឯង ។ បន្ទាប់អំពីនោះ គប្បីធ្វើការស្វាធ្យាយកោដ្ឋាសទាំង ១០ នោះ រួមបញ្ចូលគ្នាអស់កន្លះខែ គប្បីរៀនយកតែកោដ្ឋាសនីមួយៗ ក្នុងបប្ផាសបញ្ចកៈជាដើមទៀត ហើយធ្វើការស្វាធ្យាយអស់កន្លះខែ បន្ទាប់អំពីនោះ គប្បីធ្វើការ

ស្វាធ្យាយក្នុងកោដ្ឋាសទាំង ១៥ នោះ អស់កន្លះខែ ។ គប្បីធ្វើការស្វាធ្យាយមត្ថលុង្គបញ្ចកៈអស់កន្លះខែ បន្ទាប់អំពីនោះ គប្បីធ្វើការស្វាធ្យាយនូវកោដ្ឋាសទាំង ២០ នោះអស់កន្លះខែ ។ គប្បីធ្វើការស្វាធ្យាយមេទឆក្កៈអស់កន្លះខែ បន្ទាប់អំពីនោះ គប្បីធ្វើការស្វាធ្យាយនូវកោដ្ឋាស ២៦ នោះ រួមគ្នាអស់កន្លះខែ គប្បីធ្វើនូវការស្វាធ្យាយមុត្តឆក្កៈអស់កន្លះខែ បន្ទាប់អំពីនោះ គប្បីធ្វើការស្វាធ្យាយកោដ្ឋាសទាំង ៣២ រួមគ្នាអស់កន្លះខែ គប្បីធ្វើការស្វាធ្យាយ ៦ ខែយ៉ាងនេះ ដោយអាការដូច្នេះ ។

ក្នុងកម្មដ្ឋាននោះ ភិក្ខុដែលមានឧបនិស្ស័យដល់ព្រមហើយ ជាអ្នកមានបញ្ញារៀនកម្មដ្ឋាននោះឯង កោដ្ឋាសទាំងឡាយរមែងប្រាកដ ។ រមែងមិនប្រាកដដល់ភិក្ខុរូបខ្លះ ដោយហេតុនោះ ភិក្ខុនោះ មិនគប្បីលះនូវសេចក្តីព្យាយាម ដោយគិតថា កោដ្ឋាសទាំងឡាយ មិនប្រាកដដល់អញ ដូច្នេះ ។ កោដ្ឋាសទាំងឡាយ មានប្រមាណប៉ុនណាប្រាកដ គប្បីកំណត់យកកោដ្ឋាសមានប្រមាណប៉ុណ្ណោះ ធ្វើនូវការស្វាធ្យាយចុះ ។

ម្យ៉ាងទៀត អាចារ្យកាលនឹងប្រាប់កម្មដ្ឋានយ៉ាងនេះ មិនគួរប្រាប់ដល់បុគ្គលដែលមានបញ្ញាច្រើន និងបុគ្គលដែលមានបញ្ញាតិច គួរប្រាប់ដល់បុគ្គលអ្នកមានបញ្ញាកណ្តាល ព្រោះថា អាចារ្យទាំងឡាយកំណត់បែបផែន ៦ ខែ សម្រាប់បុគ្គលអ្នកមានប្រាជ្ញាជាកណ្តាល ។ ចំណែកកោដ្ឋាសទាំងឡាយរបស់ភិក្ខុណា សូម្បីមានប្រមាណប៉ុណ្ណោះ មិនទាន់ប្រាកដ ភិក្ខុនោះ ក៏គប្បីធ្វើការស្វាធ្យាយតទៅនោះឯង និងមិនកំណត់បែបផែន ៦ ខែ ធ្វើការស្វាធ្យាយ

មិនគួរគប្បីកំណត់រាល់ៗ ៦ ខែ ធ្វើការស្វាធ្យាយទៅ ។ កាលភិក្ខុនោះធ្វើការស្វាធ្យាយ មិនគប្បីពិចារណាដោយពណ៌ មិនគប្បីមនសិការលក្ខណៈ គប្បីធ្វើការស្វាធ្យាយដោយអំណាចនៃកោដ្ឋាសប៉ុណ្ណោះ ។ សូម្បីអាចារ្យសោត ក៏មិនគប្បីប្រាប់កំណត់ចុះមកថា ចូរអ្នកធ្វើការស្វាធ្យាយដោយអំណាចនៃពណ៌ ដូច្នេះ ។

កាលប្រាប់កំណត់ តើនឹងមានទោសអ្វី ការខុសក្លាំងក្លាត់ដោយការសម្គាល់ខុសក្នុងវត្ថុដែលបុគ្គលនោះគប្បីដល់ព្រម រមែងមាន ព្រោះបើអាចារ្យប្រាប់ថា ចូរធ្វើការស្វាធ្យាយដោយអំណាចនៃពណ៌ដូច្នេះសោត កាលភិក្ខុនេះធ្វើយ៉ាងនោះ កម្មដ្ឋានមិនប្រាកដដោយពណ៌ រមែងប្រាកដដោយអំណាចបដិកូល ឬដោយអំណាចនៃធាតុសោត ពេលនោះ ភិក្ខុនោះក៏នឹងសម្គាល់ថា នេះមិនមែនកម្មដ្ឋាន និងមិនមែនលក្ខណៈកម្មដ្ឋាន ភិក្ខុនោះ នឹងកំណត់កាន់យកចំពោះពាក្យដែលអាចារ្យប្រាប់ហើយប៉ុណ្ណោះ ។ បើអាចារ្យប្រាប់ថា ចូរលោកធ្វើការស្វាធ្យាយកម្មដ្ឋាននេះ ដោយអំណាចនៃបដិកូលដូច្នេះសោត កាលភិក្ខុនោះធ្វើយ៉ាងនោះ កម្មដ្ឋានមិនប្រាកដដោយបដិកូល រមែងប្រាកដដោយពណ៌ ឬដោយធាតុសោត ពេលនោះ ភិក្ខុនោះក៏នឹងសម្គាល់ថា នេះមិនមែនកម្មដ្ឋាន មិនមែនលក្ខណៈកម្មដ្ឋាន នឹងកំណត់កាន់យកចំពោះពាក្យដែលអាចារ្យប្រាប់ហើយប៉ុណ្ណោះ បើអាចារ្យប្រាប់ថា ចូរអ្នកធ្វើការស្វាធ្យាយដោយអំណាចនៃធាតុសោត កាលភិក្ខុនោះធ្វើយ៉ាងនោះ កម្មដ្ឋានមិនប្រាកដដោយធាតុ រមែងប្រាកដដោយពណ៌ ឬដោយបដិកូលសោត ពេលនោះ

ភិក្ខុនោះ រមែងសម្គាល់ថា នេះមិនមែនកម្មដ្ឋាន មិនមែនលក្ខណៈនៃកម្មដ្ឋាន នឹងកំណត់កាន់យកចំពោះពាក្យដែលអាចារ្យប្រាប់ហើយប៉ុណ្ណោះ នេះជាទោសក្នុងពាក្យដែលអាចារ្យពោលកំណត់ ។

អាចារ្យគប្បីប្រាប់ដូចម្តេច អាចារ្យអ្នកប្រាប់កម្មដ្ឋាន គប្បីប្រាប់ថា ចូរធ្វើការស្វាធ្យាយដោយអំណាចនៃកោដ្ឋាស ដូច្នេះ សេចក្តីនេះ ដូចម្តេច គឺអាចារ្យគប្បីប្រាប់ថា ចូរអ្នកធ្វើការស្វាធ្យាយដោយកោដ្ឋាសថា សក់ រោម ជាដើម បើភិក្ខុនោះ ធ្វើនូវការស្វាធ្យាយដោយអំណាចនៃកោដ្ឋាសយ៉ាងនេះ កម្មដ្ឋានប្រាកដដោយពណ៌សោត ពេលនោះ ភិក្ខុនោះគប្បីប្រាប់ដល់អាចារ្យអ្នកឲ្យឱវាទថា ខ្ញុំធ្វើការស្វាធ្យាយអាការ ៣២ ដោយអំណាចនៃកោដ្ឋាស តែកម្មដ្ឋាននោះប្រាកដដល់ខ្ញុំដោយពណ៌ ដូច្នេះ អាចារ្យមិនគប្បីពោលជំទាស់ថា នុ៎ះមិនមែនកម្មដ្ឋាន មិនមែនលក្ខណៈរបស់កម្មដ្ឋាន គ្រាន់តែដូចកម្មដ្ឋាន ដូច្នេះ តែគប្បីពោលថា សាធុ សប្បុរស ក្នុងកាលមុន អ្នកធ្លាប់បរិកម្មក្នុងវណ្ណកសិណមក កម្មដ្ឋាននេះឯង ជាសប្បាយរបស់អ្នក ចូរអ្នកធ្វើការស្វាធ្យាយដោយអំណាចនៃពណ៌នោះឯង សូម្បីភិក្ខុនោះក៏គួរធ្វើការស្វាធ្យាយដោយអំណាចនៃពណ៌នោះឯង ។

កាលភិក្ខុនោះធ្វើយ៉ាងនេះ រមែងបាននូវវណ្ណកសិណ ៤ ក្នុងខាងក្នុង គឺនីលកសិណ បីតកសិណ លោហិតកសិណ និងឱទាតកសិណ សេចក្តីនេះដូចម្តេច គឺកាលភិក្ខុនោះ មនសិការពណ៌ត្រង់សក់ រោម ប្រមាត់ និងក្នុងពណ៌ខ្មៅនៃកែវភ្នែកថា **នីលំ នីលំ** ខៀវ ខៀវ ឈានដែលជាចតុក្កន័យ

ឬបញ្ចកន័យរមែងកើតឡើង ភិក្ខុនោះធ្វើឈានឲ្យជាបាទ ផ្តើមតាំងវិបស្សនាហើយ រមែងសម្រេចអរហត្ត កាលភិក្ខុនោះមនសិការពណ៌របស់ខ្ញាញ់ខាប់ និងក្នុងពណ៌លឿងនៃភ្នែកថា **បីតកំ បីតកំ** លឿង លឿង ឈានដែលជាចតុក្កន័យ ឬបញ្ចកន័យរមែងកើតឡើង ភិក្ខុនោះ ធ្វើឈានឲ្យជាបាទ ផ្តើមតាំងវិបស្សនាហើយ រមែងសម្រេចអរហត្ត ។ កាលភិក្ខុនោះមនសិការពណ៌នៃសាច់ ឈាម និងក្នុងទីពណ៌ក្រហមនៃភ្នែកថា **លោហិតំ លោហិតំ** ក្រហម ក្រហម ឈានដែលជាចតុក្កន័យ ឬបញ្ចកន័យរមែងកើតឡើង ភិក្ខុនោះធ្វើឈានឲ្យជាបាទ ផ្តើមវិបស្សនាហើយ រមែងសម្រេចអរហត្ត ។ កាលភិក្ខុនោះមនសិការពណ៌ត្រង់ក្រចក ធ្មេញ ស្បែក ឆ្អឹង និងក្នុងទីមានពណ៌សនៃភ្នែកថា **ឱទាតំ ឱទាតំ** ស ស ឈានដែលជាចតុក្កន័យ ឬបញ្ចកន័យរមែងកើតឡើង ភិក្ខុនោះធ្វើឈានឲ្យជាបាទ ផ្តើមតាំងវិបស្សនាបានហើយ រមែងសម្រេចអរហត្ត ។ សេចក្តីនេះ ជាការចេញទៅរបស់ភិក្ខុដែលមានចិត្តតាំងមាំហើយ ដោយអំណាចនៃពណ៌ រហូតដល់អរហត្ត ។

ភិក្ខុដទៃទៀត កាលធ្វើនូវការស្វាធ្យាយ ដោយអំណាចនៃកោដ្ឋាសកម្មដ្ឋានរមែងប្រាកដដោយបដិកូល ពេលនោះ ភិក្ខុនោះគប្បីប្រាប់ដល់អាចារ្យអ្នកឲ្យឱវាទ អាចារ្យក៏មិនគប្បីពោលជំទាស់ថា នុ៎ះមិនមែនកម្មដ្ឋាន មិនមែនលក្ខណៈរបស់កម្មដ្ឋាន គ្រាន់តែដូចកម្មដ្ឋានដូច្នេះ តែគប្បីប្រាប់ថា សាធុសប្បុរស ក្នុងកាលមុន អ្នកធ្លាប់ប្រកបព្យាយាមក្នុងបដិកូលមនសិការ មកកម្មដ្ឋាននេះ ជាសប្បាយរបស់អ្នក ចូរអ្នកធ្វើការស្វាធ្យាយដោយអំណាចនៃ

បដិកូលនោះឯង ។ ភិក្ខុនោះ ក៏គួរធ្វើនូវការស្វាធ្យាយដោយអំណាចនៃបដិកូល កាលភិក្ខុនោះធ្វើការស្វាធ្យាយ ដោយអំណាចនៃបដិកូលយ៉ាងនេះថា ឈ្មោះថា សក់ទាំងឡាយ ជារបស់មិនស្អាត មិនគួរពេញចិត្ត មានក្លិនស្អុយ គួរខ្ពើម ជារបស់បដិកូល ដូច្នេះ បឋមជ្ឈាន រមែងកើតឡើងក្នុងអារម្មណ៍បដិកូលបាន ។ ភិក្ខុនោះធ្វើឈានឲ្យជាបាទ ផ្តើមវិបស្សនាហើយរមែងសម្រេចអរហត្ត សេចក្តីនេះ ជាការចេញទៅរបស់ភិក្ខុដែលមានចិត្តតាំងមាំហើយ ដោយអំណាចនៃបដិកូល រហូតដល់អរហត្ត ។

ភិក្ខុដទៃទៀត ធ្វើនូវការស្វាធ្យាយដោយអំណាចនៃកោដ្ឋាស កម្មដ្ឋានរមែងប្រាកដដោយធាតុ ។ សួរថា កម្មដ្ឋាន កាលប្រាកដដោយធាតុ រមែងប្រាកដដូចម្តេច ឆ្លើយថា នឹងអធិប្បាយអំពីសក់ជាបឋម កាលបើប្រាកដ រមែងប្រាកដហាក់បីដូចដើមស្មៅដុះលើដំបូក ។ រោមទាំងឡាយរមែងប្រាកដហាក់បីដូចស្បូវភ្លាំងទាំងឡាយដែលដុះត្រង់ស្រុកចាស់ ។ ក្រចកទាំងឡាយ ប្រាកដហាក់បីដូចគ្រាប់ស្រគំដែលគេដោតត្រង់ចុងកំណាត់ឈើ ។ ធ្មេញទាំងឡាយរមែងប្រាកដហាក់បីដូចជាគ្រាប់ឃ្លោក ដែលគេដោតត្រង់ដីឥដ្ឋ ។ ស្បែកប្រាកដ ហាក់បីដូចស្បែកគោស្រស់ ដែលគេស្រោបឈើតូច ឬស្រោបត្រង់ស្នូករបស់ពិណ ។ សាច់ប្រាកដដូចដីឥដ្ឋដែលគេបូកលាបត្រង់ជញ្ជាំងផ្ទះ ។ សរសៃទាំងឡាយ រមែងប្រាកដដូចវល្លិដែលចងទព្វសម្ភារ ។ ឆ្អឹង រមែងប្រាកដហាក់បីដូចជាទព្វសម្ភាររបស់ជញ្ជាំងផ្ទះ ដែលគេលើកឡើងតម្កល់ ។ ខួរក្នុងឆ្អឹង រមែងប្រាកដហាក់បីដូចបណ្តូលផ្តៅដែលគេរោលភ្លើង ញាត់ក្នុង

បំពង់ឫស្សីធំ ។ កោដ្ឋាសទាំង ៦ គឺទាច បេះដូង ថ្លើម វាវ ក្រពះ និង សួត រមែងប្រាកដដូចរោងសម្លាប់សត្វ ។ ពោះវៀនធំប្រវែង ៣២ ហត្ថ ប្រាកដដូចពស់ផ្ទះដែលគេសម្លាប់ហើយ ដាក់ក្នុងស្នូកឈាម ។ ពោះវៀនតូច រមែងប្រាកដដូចខ្សែតូច ដែលគេដេរសំពត់សម្រាប់ជូតជើង អាហារថ្មី ប្រាកដដូចអង្ករដែលគេដាក់ក្នុងសំពត់ស្តើង ។ អាហារចាស់ ប្រាកដដូចដីឥដ្ឋ ដែលគេញាត់ក្នុងបំពង់ឫស្សី ។ ខួរក្នុងក្បាល ប្រាកដដូចម្សៅអង្ករ ៤ ដុំ ដែលគេប្រឡាច់ហើយតម្កល់ ។ អាបោធាតុ ១២ រមែងប្រាកដដូចទឹកដែលពេញដោយទឹក ១២ កែវ ដែលគេតម្រៀបគ្នា ។ ពេលនោះ ភិក្ខុនោះ គប្បីប្រាប់ដល់អាចារ្យអ្នកឲ្យឱវាទ អាចារ្យមិនគប្បីពោលជំទាស់ថា នុ៎ះមិនមែនកម្មដ្ឋាន មិនមែនលក្ខណៈរបស់កម្មដ្ឋាន គ្រាន់តែដូចកម្មដ្ឋាន ដូច្នេះ តែគប្បីប្រាប់ថា សាធុ សប្បុរស ក្នុងកាលមុន អ្នកធ្លាប់ធ្វើសេចក្តីព្យាយាម ក្នុងធាតុមនសិការមក កម្មដ្ឋាននោះឯងជាសប្បាយរបស់អ្នក ចូរអ្នកធ្វើការស្វាធ្យាយដោយអំណាចនៃធាតុចុះ ។ ភិក្ខុនោះ ក៏គួរធ្វើការស្វាធ្យាយដោយអំណាចនៃធាតុនោះឯង ។

ក្នុងសេចក្តីនោះ វិធីស្វាធ្យាយដោយមាតិកា គប្បីមនសិការដូចតទៅនេះ ភិក្ខុក្នុងធម្មវិន័យនេះ រមែងមនសិការថា សក់ទាំងឡាយ កើតត្រង់ស្បែកក្បាល សក់នោះ មិនដឹងថា អញកើតត្រង់ស្បែកក្បាល ស្បែកក្បាលសោត មិនដឹងថា សក់ទាំងឡាយកើតក្នុងអញ វត្ថុទាំងនេះ មិនមានការគិត ជាអព្យាកត ជារបស់ទទេ ជាសភាវៈរឹង នេះជាបឋវីធាតុ ។ មនសិការថា

រោមទាំងឡាយ កើតត្រង់ស្បែកដែលស្រោបសរីរៈ រោមទាំងនោះ មិនដឹងថា អញកើតត្រង់ស្បែកស្រោបសរីរៈ សូម្បីស្បែកស្រោបសរីរៈសោត ក៏មិនដឹងថា រោមទាំងឡាយកើតក្នុងអញ វត្ថុទាំងនេះ ក៏មិនមានការគិត ។ ក្រចកទាំងឡាយកើតត្រង់ចុងម្រាមទាំងឡាយ ក្រចកទាំងនោះ មិនដឹងថា អញកើតត្រង់ចុងម្រាមទាំងឡាយ សូម្បីចុងម្រាមទាំងឡាយសោត ក៏មិនដឹងថា ក្រចកទាំងឡាយកើតក្នុងអញ វត្ថុទាំងនេះ ក៏មិនមានការគិត ។ ធ្មេញទាំងឡាយកើតត្រង់ឆ្អឹងចង្កា ធ្មេញទាំងនេះ មិនដឹងថា អញកើតត្រង់ឆ្អឹងចង្កា សូម្បីឆ្អឹងចង្កាសោត ក៏មិនដឹងថា ធ្មេញទាំងឡាយកើតក្នុងអញ វត្ថុទាំងនេះ ក៏មិនមានការគិត ។ ស្បែក មិនដឹងថា អញស្រោបសរីរៈ សូម្បីសរីរៈសោតក៏មិនដឹងថា អញត្រូវស្បែកស្រោប វត្ថុទាំងនេះ ក៏មិនមានការគិត ។ សាច់មិនដឹងថា អញបូកលាបសរីរៈ សូម្បីសរីរៈក៏មិនដឹងថា អញត្រូវសាច់បូកលាប វត្ថុនេះ ក៏មិនមានការគិត ។ សរសៃមិនដឹងថា អញចងគ្រោងឆ្អឹង គ្រោងឆ្អឹងសោតក៏មិនដឹងថា អញត្រូវបណ្ដាញនៃសរសៃចង វត្ថុនេះ ក៏មិនមានការគិត ។ ឆ្អឹងក្បាល មិនដឹងថា អញតាំងនៅលើឆ្អឹង-ក ឆ្អឹង-កសោតក៏មិនដឹងថា ឆ្អឹងក្បាលតាំងនៅលើអញ ឆ្អឹង-កក៏មិនដឹងថា អញតាំងនៅលើឆ្អឹងទ្រូងខ្នង ឆ្អឹងទ្រូងខ្នង ឆ្អឹងចង្កេះ ឆ្អឹងភ្លៅ ឆ្អឹងស្មង ឆ្អឹង-កជើង មិនដឹងថា អញតាំងនៅលើឆ្អឹងកែងជើង សូម្បីឆ្អឹងកែងជើងសោត ក៏មិនដឹងថា អញលើកឆ្អឹងកជើងតម្កល់ទុក ។បេ។ ឆ្អឹង-ក មិនដឹងថា អញលើកឆ្អឹងក្បាលតម្កល់ទុក ។

ឆ្អឹងទាំងឡាយ តាំងនៅដោយទីបំផុតគ្នា តាមលំដាប់ បន្ទាប់អំពីនេះ ក្នុងទី-តមិនមែនតិច សរសៃណាមួយ មិនបានចងឆ្អឹងនេះ ក៏មិនមានការគិត ដូចជាអង្កត់ឧស ជាសភាវៈដែលជរាជាស់តឿនហើយ ។

ខួរក្នុងឆ្អឹង មិនមានការគិត ទាច ។បេ។ ខួរក្នុងក្បាល ក៏មិនមានការគិត ជាអព្យាកត ជារបស់ទទេ រីង គ្រោតគ្រាត ជាបឋវីធាតុ ដូច្នេះ ធ្វើទុកក្នុងចិត្តថា ប្រមាត់ ស្លេស្ម ។បេ។ ទឹកមូត្រ មិនមានការគិត ជាអព្យាកត ជារបស់ទទេ ជាសភាវៈប្រមូលផ្តុំ ជាអាបោធាតុ ជ្រួតជ្រាបទៅ ។

កាលព្រះយោគាវចរកំណត់មហាភូតរូបទាំងពីរយ៉ាងនេះ តេជោធាតុជាច្រើន រមែងប្រាកដត្រង់ឧទរ វាយោធាតុជាច្រើន ប្រាកដត្រង់ប្រមុះ ។ កាលកំណត់មហាភូតរូបទាំង ៤ នេះ ឧបាទាយរូបរមែងប្រាកដ ។ ឈ្មោះថាមហាភូតរូប រមែងកំណត់បានដោយឧបាទាយរូប ឧបាទាយរូបក៏កំណត់បានដោយមហាភូតរូប ។ ប្រៀបដូចពន្លឺកំណត់បានដោយស្រមោល ស្រមោលក៏កំណត់បានដោយពន្លឺយ៉ាងណា មហាភូតរូបក៏យ៉ាងនោះឯង កំណត់បានដោយឧបាទាយរូប ឧបាទាយរូបក៏កំណត់បានដោយមហាភូតរូប ។ លំដាប់នោះកាលភិក្ខុនោះ កំណត់រូបក្ខន្ធថា មហាភូតរូប ៤ ឧបាទាយរូប ២៣ ជារូបក្ខន្ធយ៉ាងនេះ អរូបក្ខន្ធក៏រមែងប្រាកដ ដោយអំណាចនៃអាយតនៈ និងទ្វារ ។ ការកំណត់រូប និងអរូប គឺខន្ធ ៥ ដោយប្រការដូច្នេះ ។ ខន្ធ ៥ គឺអាយតនៈ ១២ អាយតនៈ ១២ គឺធាតុ ១៨ ព្រោះហេតុនោះ ភិក្ខុគប្បីកំណត់នាម

*និងរូប ធ្វើឲ្យជាពីរចំណែក ដោយអំណាចនៃខន្ធ អាយតនៈ និងធាតុ ឲ្យហាក់បីដូចជាពុះនូវគូនៃកំពីងត្នោត ដូច្នោះ ។*

*ភិក្ខុនោះ ពិចារណាថា នាមរូបនេះ កើតឡើងព្រោះមិនមានហេតុ មិនមានបច្ច័យ ក៏មិនមែន កើតឡើងព្រោះមានហេតុ មានបច្ច័យ អ្វីហ្ន៎ ជាហេតុជាបច្ច័យរបស់នាមរូបនោះ ទើបកំណត់បច្ច័យនៃនាមរូបនោះថា នាមរូបកើតឡើងព្រោះអវិជ្ជាជាបច្ច័យ ព្រោះតណ្ហាជាបច្ច័យ ព្រោះកម្មជាបច្ច័យ ព្រោះអាហារជាបច្ច័យ ដូច្នេះហើយ ឈានកន្លងនូវសេចក្តីសង្ស័យក្នុងកាលទាំង ៣ ថា ក្នុងអតីតកាលក្តី ក្នុងអនាគតកាលក្តី ក្នុងកាលឥឡូវនេះក្តី បច្ច័យទាំងឡាយ និងធម៌ដែលកើតឡើងព្រោះបច្ច័យទាំងឡាយ កើតឡើងក្រៅអំពីនេះ មិនមានសត្វ ឬបុគ្គលឡើយ មានតែគំនរនៃសង្ខារសុទ្ធៗ ប៉ុណ្ណោះ ដូច្នេះ វិបស្សនានេះ មានសង្ខារជាគ្រឿងកំណត់ ទើបឈ្មោះថា* **ញាតបរិញ្ញា** *។ កាលភិក្ខុកំណត់សង្ខារហើយ តាំងនៅយ៉ាងនេះ ឬសគល់ក្នុងសាសនារបស់ព្រះទសពលរបស់ភិក្ខុនោះ ឈ្មោះថា ឈមចុះហើយ ឈ្មោះថា បានទូវទីពឹងហើយ ភិក្ខុនោះ ឈ្មោះថា ព្រះចូឡសោតាបន្នដែលមានគតិទៀង ។ ភិក្ខុនោះ បាននូវឧតុជាទីសប្បាយ បុគ្គលជាទីសប្បាយ ភោជនជាទីសប្បាយ និងធម៌ជាទីសប្បាយយ៉ាងនោះហើយ អង្គុយដោយភ្នែនមួយដ៏ប្រសើរ លើអាសនៈមួយ ពិចារណាសង្ខារទាំងឡាយ លើកឡើងកាន់ត្រៃលក្ខណ៍ដោយលំដាប់នៃវិបស្សនា រមែងកាន់យកអរហត្តបានដូច្នេះឯង សេចក្តីនេះ ជាការចេញទៅរបស់ភិក្ខុដែលមានចិត្តតាំងមាំ ដោយអំណាចនៃធាតុ រហូតដល់*

អរហត្ត ។

ចំណែកភិក្ខុណា កម្មដ្ឋានមិនប្រាកដដោយពណ៌ ដោយបដិកូល ដោយសុញ្ញតៈ ភិក្ខុនោះមិនគប្បីអន្ទយលះបង់កម្មដ្ឋានចោល ដោយគិតថា កម្មដ្ឋានមិនប្រាកដដល់អញ តែគប្បីធ្វើសេចក្ដីព្យាយាមមនសិការក្នុងកោដ្ឋាសតទៅដោយពិត ។ បានឮថា ព្រះថេរៈក្នុងកាលមុន ពោលថា មនសិការកោដ្ឋាសប៉ុណ្ណោះជាប្រមាណ ។ កាលភិក្ខុនោះ ធ្វើការស្វាធ្យាយដោយអំណាចនៃកោដ្ឋាសរឿយៗ យ៉ាងនេះ កោដ្ឋាសទាំងឡាយរមែងស្ទាត់ សួរថា ក្នុងកាលណា កោដ្ឋាសទាំងឡាយ ឈ្មោះថា ស្ទាត់ ឆ្លើយថា ក្នុងកាលណា គ្រាន់តែរំពឹងថា សក់ មនសិការ ក៏រត់ទៅដល់កោដ្ឋាសចុងក្រោយ គឺខួរក្នុងក្បាល គ្រាន់តែរំពឹងថា ខួរក្នុងក្បាល មនសិការក៏រត់មកដល់កោដ្ឋាសខាងដើម គឺសក់ ពេលនោះ កោដ្ឋាស ៣២ រមែងប្រាកដដល់ភិក្ខុនោះ ប្រៀបដូចបុរសដែលមានចក្ខុសម្លឹងមើលផ្កា ៣២ ពណ៌ ដែលដោតដោយអំបោះ ១ សរសៃ ឬថា សម្លឹងមើលសសរ ៣២ ដើម ដែលដាំតាមលំដាប់ផ្កា ៣២ ពណ៌ ឬសសរ ៣២ ដើម រមែងប្រាកដតាមលំដាប់ ដូច្នោះ ។ សត្វតិរច្ឆានទាំងឡាយក្ដី មនុស្សទាំងឡាយក្ដី ដែលត្រាច់ទៅ រមែងមិនប្រាកដដល់ព្រះយោគាវចរនោះថាជាសត្វ រមែងប្រាកដថាជាកោដ្ឋាសទាំងឡាយ ខាទនីយៈ ភោជនីយៈ ក៏រមែងប្រាកដហាក់បីដូចរបស់ ដែលគេដាក់ចូលទៅក្នុងរវាងកោដ្ឋាស ចាប់តាំងពីកោដ្ឋាសទាំងឡាយស្ទាត់ជំនាញហើយ ភិក្ខុនោះ នឹងរួចផុតបានដោយមាតិកា ១ ក្នុងមាតិកាទាំង ៣ គឺពណ៌ បដិកូល

*និងសុញ្ញត: ។ កម្មដ្ឋានរមែងប្រាកដដោយពណ៌ ឬដោយបដិកូល ឬដោយសុញ្ញត: ចាប់តាំងអំពីកោដ្ឋាសទាំងឡាយស្ទាត់ជំនាញហើយ ក៏នឹងរួចផុតដោយមាតិកា ១ ក្នុងមាតិកាទាំង ៣ ប្រៀបដូចស្ត្រីដែលត្រូវការចៀនទំប្រាថ្នានូវទំផ្កាណាមួយ ក៏ចៀនទំផ្កានោះៗ បានអំពីម្សៅដែលខ្លួនប្រជាប់ហើយ ឬប្រៀបដូចបុគ្គលផ្ទៀងផ្ទាំងពេញដោយទឹក ដែលគេតម្កល់ក្នុងទីដែលស្មើគ្នាផ្ទែកណាមួយ ទឹកក៏ហូរចេញតាមផ្ទែកនោះៗ ឯង ដូច្នោះ កាលភិក្ខុប្រាថ្នាដោយពណ៌ ប្រាថ្នាដោយបដិកូល ឬប្រាថ្នាដោយសុញ្ញត: កម្មដ្ឋានក៏នឹងប្រាកដបានដោយពិត នេះឈ្មោះថា ឧគ្គហសន្ធិ មានប្រមាណប៉ុណ្ណោះ ភិក្ខុដែលតាំងនៅក្នុងឧគ្គហសន្ធិហើយ សម្រេចអរហត្តហួសនឹងរាប់បាន ។*

*ម្យ៉ាងទៀត កម្មដ្ឋានរបស់ភិក្ខុណាមិនប្រាកដក្នុងឧគ្គហសន្ធិ ភិក្ខុនោះរៀនយកកម្មដ្ឋានហើយ បើអាចារ្យនៅក្នុងអាវាសណា អាវាសនោះ ជាសប្បាយដល់លោកសោត ទុំះជាការល្អ តែបើមិនបានដូច្នោះ គប្បីនៅក្នុងទីដែលជាសប្បាយ ។ កាលអាស្រ័យនៅ គប្បីវៀរវិហារដែលជាទោស ១៨ កន្លែង[១] ហើយនៅក្នុងសេនាសនៈដែលប្រកបដោយអង្គ ៥[២] សូម្បីភិក្ខុនោះក៏គប្បីប្រកបដោយអង្គ ៥ ។ បន្ទាប់អំពីនោះ ភិក្ខុត្រឡប់អំពីបិណ្ឌបាត ក្រោយអំពីឆាន់ភត្តហើយ គប្បីទៅកាន់ទីសម្រាកក្នុងពេលយប់ ឬទីសម្រាកក្នុងពេលថ្ងៃ ហើយមនសិការកម្មដ្ឋាន គប្បីមនសិការដូចម្តេច គឺគប្បីមនសិការកម្មដ្ឋានដោយលំដាប់អំពីខាងដើម តាមន័យដែលពោលហើយ មិនគប្បី*

---

១-២- *សេចក្តីពិស្តារ សូមមើលវិសុទ្ធិមគ្គ ។*

មនសិការវៀរកម្មដ្ឋានមួយក្នុងចន្លោះ ។ កាលភិក្ខុមនសិការកម្មដ្ឋាន ដោយលំដាប់ គឺមនសិការកម្មដ្ឋានដោយលំដាប់ថា សក់ រោមជាដើម ដូច្នេះ រមែងមិនវិនាសចាកកម្មដ្ឋាន និងរមែងសោយលោកុត្តរធម៌ ៩ ប្រការ ដែលដូចគ្នានឹងអានិសង្សនៃប្រាសាទ ប្រៀបដូចបុរសដែលឈានឡើងជណ្ដើរ ៣២ កាំ ដោយលំដាប់កាំ ឡើងកាន់ប្រាសាទ និងសោយអានិសង្សរបស់ប្រាសាទ ដូច្នោះ ។ម្យ៉ាងទៀត កាលមនសិការដោយលំដាប់ មិនគប្បីមនសិការដោយរហ័សពេក មិនគប្បីមនសិការដោយយឺតពេក ព្រោះថាកាលមនសិការរហ័សពេក កម្មដ្ឋានស្អាតក៏ពិត តែកម្មដ្ឋានមិនជាក់ច្បាស់ ។ ក្នុងសេចក្ដីនេះ គប្បីជ្រាបសេចក្ដីឧបមាដោយន័យដែលពោលហើយខាងដើមនោះឯង កាលមនសិការយឺតពេក កម្មដ្ឋាននឹងមិនដល់ទីបំផុត រមែងសាបសូន្យក្នុងចន្លោះនោះឯង ប្រៀបដូចបុគ្គលដើរផ្លូវ ៣ យោជន៍ ព្រោះដាក់ចិត្តក្នុងម្លប់ដែលត្រជាក់ ចាប់តាំងពីទីដែលចេញទៅហើយ រមែងជួបម្លប់ត្រជាក់សប្បាយ ក៏សម្រាក ជួបសាច់ដែលជាទីសប្បាយ ក៏តម្រង់ខ្នង ជួបស្រះបោក្ខរណីក្នុងព្រៃ រមែងផឹក រមែងងូត ជួបភ្នំ ក៏ឡើងទៅមើលទីដែលគួរត្រេកអររបស់ភ្នំ ជួបសីហៈ ឬខ្លាធំ ខ្លាដំបង រមែងត្រូវសត្វសម្លាប់ក្នុងរវាងនោះឯង ឬថា ពួកចោររមែងប្លន់ រមែងសម្លាប់យ៉ាងណា កាលមនសិការយឺតពេក ក៏ដូច្នោះឯង កម្មដ្ឋានមិនដល់ទីបំផុត រមែងវិនាសទៅក្នុងចន្លោះ ព្រោះហេតុនោះ ក្នុងមួយថ្ងៃ ភិក្ខុគប្បីមនសិការ ៣០ ដង ដោយមិនយឺតពេក មិនលឿនពេក ដូច្នេះ ។

ក្នុងពេលព្រឹក គប្បីធ្វើការស្វាធ្យាយ ១០ ដង ពេលថ្ងៃ ១០ ដង ពេលល្ងាច ១០ ដង ការមិនធ្វើ មិនគួរ ដូចការក្រាក់ឃើត មិនលុបមុខ ក៏មិនគួរ ការមិនទំពាស៊ីនូវខាទនីយៈ និងភោជនីយៈ ក៏មិនគួរ គួរញ៉ាំងកិច្ចនេះឲ្យប្រព្រឹត្តទៅ កិច្ចនេះឯងមិនធ្វើ រំលងចំណែកមួយមិនគួរឡើយ កាលធ្វើ ទើបកាន់យកប្រយោជន៍ធំតាំងនៅបាន ប្រៀបដូចបុគ្គលមានស្រែ ៣ ស្រែមួយបានស្រូវ ៨ កុម្ភៈ គឺ ៤០០ ថាំង ស្រែមួយបានស្រូវ ១៦ កុម្ភៈ គឺ ៨០០ ថាំង ស្រែមួយបានស្រូវ ៣២ កុម្ភៈ គឺ ១៦០០ ថាំង បុគ្គលនោះមិនអាចធ្វើស្រែទាំង ៣ បាន គប្បីបោលស្រែ ២ ហើយធ្វើស្រែមួយដែលបានផល ៣២ កុម្ភៈប៉ុណ្ណោះ គឺគប្បីធ្វើការភ្ជួរ ការសាបព្រោះ ការប្រតកាត់ជាដើមក្នុងស្រែទី ៣ នោះឯង ។ ស្រែទី ៣ នោះឯង នឹងឲ្យផលតាំងឡើង ក្នុងស្រែ ២ ក្រៅអំពីនេះដល់បុរសនោះ ( ទើបអាចទូទាត់ក្នុងស្រែពីរ ដែលមិនបានធ្វើ ) យ៉ាងណា សេចក្តីនេះ ក៏យ៉ាងនោះឯង ភិក្ខុលះការងារដ៏សេស មានការលុបមុខជាដើមហើយ គប្បីធ្វើកម្មក្នុងទីនេះដោយពិត ការមិនធ្វើមិនគួរ កាលធ្វើទើបកាន់យកប្រយោជន៍ធំតាំងនៅ ព្រោះហេតុនោះ ទើបឈ្មោះថា មជ្ឈិមប្បដិទា លោកពោលហើយ ដោយពាក្យមានប្រមាណប៉ុណ្ណោះ ។

ភិក្ខុបដិបត្តិយ៉ាងនេះ គប្បីការពារនូវការរាយមាយបាន ព្រោះថា ភិក្ខុលះបង់កម្មដ្ឋានហើយ កាលចិត្តដល់នូវការរាយមាយទៅខាងក្រៅ រមែងសាបសូន្យចាកកម្មដ្ឋាន រមែងមិនអាចឈានកន្លងនូវវដ្តភ័យ ប្រៀបដូចបុរស

ម្នាក់ញុំាងអ្នកជទែទឲ្យសងបំណុល ១០០០ បានប្រាក់ហើយ ធ្វើដំណើរមក ក្នុងរវាងផ្លូវ ឈានឡើងកាន់ស្ពានឈើដែលដើរបានតែម្នាក់ ដែលគេដាក់ឆ្លង ជ្រោះភ្នំដ៏ជ្រៅ មានក្រពើ មករ និងអារក្សទឹកមីដេរដាស បុគ្គលនោះ មិន ប្រយ័ត្នជើង ដែលឈានទៅ សម្លឹងមើលក្នុងទីផ្សេងៗ រអិលធ្លាក់ទៅជា អាហាររបស់ក្រពើជាដើម យ៉ាងណា ភិក្ខុនេះ ក៏យ៉ាងនោះឯង លះកម្មដ្ឋាន ហើយ ចិត្តរបស់ខ្លួន ដល់នូវការរាយមាយទៅខាងក្រៅ រមែងសាបសូន្យ ចាកកម្មដ្ឋាន រមែងមិនអាចឈានកន្លងវដ្តភ័យបាន ។

ក្នុងសេចក្តីនេះ មានឧបមេយ្យដូចតទៅនេះថា កាលភិក្ខុរៀនកម្មដ្ឋាន ក្នុងសម្នាក់របស់អាចារ្យ ប្រៀបដូចកាលបុរសញុំាងអ្នកជទែទឲ្យសងបំណុល ១០០០ បានប្រាក់មក ។ សង្សារវដ្ត ប្រៀបដូចជ្រោះភ្នំដ៏ជ្រៅក្នុងរវាងផ្លូវ ទុក្ខធំ មានវដ្តៈជាមូល ប្រៀបដូចកាលដែលបុរសនោះ ត្រូវក្រពើជាដើម ខាំហើយ វិថិនៃការស្វាធ្យាយរបស់ភិក្ខុនេះ ប្រៀបដូចស្ពានឈើដែលដើរ បានតែម្នាក់ គប្បីជ្រាបថា ភាពដែលភិក្ខុនេះលះបង់កម្មដ្ឋាន ចិត្តរាយមាយ ទៅខាងក្រៅ សាបសូន្យចាកកម្មដ្ឋាន មិនអាចឈានកន្លងវដ្តភ័យបាន ប្រៀប ដូចកាលដែលបុរសនោះ ឈានឡើងកាន់ស្ពានឈើ ដែលដើរបានតែម្នាក់ ហើយមិនប្រយ័ត្នជើងដែលឈានដើរទៅ រវល់តែសម្លឹងមើលក្នុងទីផ្សេងៗ រអិលធ្លាក់ទៅ ដល់នូវភាពជាអាហាររបស់ក្រពើជាដើម ព្រោះហេតុនោះ ព្រះយោគាវចរ គប្បីមនសិការសក់ទាំងឡាយ កាលមនសិការសក់ទាំងឡាយ ហើយ ក៏ហាមមិនឲ្យចិត្តុប្បាទរាយមាយទៅខាងក្រៅ គប្បីមនសិការដោយ

ចិត្តដ៏បរិសុទ្ធនោះឯងថា រោម ក្រចក ធ្មេញ ស្បែក កាលមនសិការយ៉ាងនេះ រមែងមិនសាបសូន្យចាកកម្មដ្ឋាន រមែងឈានកន្លងវិជ្ជភ័យបាន ។ ក្នុងសេចក្តីនេះ បណ្ឌិតគប្បីត្រឡប់ឧបមាខាងដើមនោះឯង ហើយជ្រាបឧបមេយ្យតទៅ ។ គប្បីជ្រាបថា ការដែលភិក្ខុឈ្លាសវៃ មនសិការសក់ទាំងឡាយ ហាមមិនឲ្យចិត្តរាយមាយទៅខាងក្រៅហើយ មនសិការដោយចិត្តបរិសុទ្ធនោះឯងថា រោម ក្រចក ធ្មេញ ស្បែក ដូច្នេះ មិនឲ្យសាបសូន្យចាកកម្មដ្ឋាន ទើបឈានកន្លងវិជ្ជភ័យបាន ប្រៀបដូចបុរសឈ្លាសវៃ ញ៉ាំងអ្នកជំទៃឲ្យសងបំណុល ១០០០ បានប្រាក់ហើយ ឈានឡើងកាន់ស្ពានឈើ រៀបចំគ្រឿងស្លៀកដណ្តប់ ធ្វើកាយឲ្យមានធាតុរឹង ទៅដល់ត្រើយនាយដោយសួស្តី ។ កាលភិក្ខុនោះ ហាមឃាត់នូវសេចក្តីរាយមាយខាងក្រៅយ៉ាងនេះហើយ គប្បីមនសិការដោយការឈានកន្លងបញ្ញត្តិ ដោយន័យដែលពោលហើយខាងដើមនោះឯង គឺគប្បីលះបង់នូវបញ្ញត្តិថា សក់ រោម ហើយតាំងសតិថា បដិកូល បដិកូល ដូច្នេះ ។ កម្មដ្ឋានដំបូងនោះឯង មិនទាន់ប្រាកដដោយភាពជាបដិកូល ។ ដរាបណាកម្មដ្ឋានមិនទាន់ប្រាកដដោយភាពជាបដិកូល ដរាបនោះ ក៏មិនគប្បីលះបញ្ញត្តិ ។ កាលណាកម្មដ្ឋានប្រាកដដោយភាពជាបដិកូល កាលនោះ គប្បីលះនូវបញ្ញត្តិ មនសិការថា បដិកូល ដូច្នេះ ។ ភិក្ខុកាលធ្វើ គប្បីមនសិការកម្មដ្ឋានដោយភាពជាបដិកូល ដោយអាការ ៥ យ៉ាង តាមន័យដែលពោលហើយខាងដើមនោះឯង ព្រោះថាក្នុងតចបញ្ចកៈ រមែងបាននូវភាពជាបដិកូលទាំង ៥ យ៉ាង ដោយអំណាចនៃ

ពណ៌ សណ្ឋាន ក្លិន ទីអាស្រ័យ និងឱកាសនោះឯង ។ ក្នុងកម្មដ្ឋានដ៏សេស ភិក្ខុបានបដិកូលណាមួយ ក៏គប្បីឲ្យមនសិការប្រព្រឹត្តទៅ ដោយអំណាចនៃបដិកូលនោះៗ ។ បណ្តាកោដ្ឋាសទាំងនោះ កោដ្ឋាស ៥ មានសក់ជាដើម ដល់នូវការរាប់ថាជាសុភនិមិត្ត ជាទីតាំងនៃរាគៈ ជាឥដ្ឋារម្មណ៍ ឈ្មោះថាសត្វ ដែលទៅត្រេកអរពួកណាមួយ សត្វទាំងអស់នោះ រមែងត្រេកអរក្នុងកោដ្ឋាស ៥ នេះ តែភិក្ខុនេះរមែងញ៉ាំងខ្លួនឲ្យសម្រេចអប្បនាក្នុងកោដ្ឋាសដែលជាទីតាំងនៃសេចក្តីត្រេកអររបស់មហាជនថា ជារបស់បដិកូលបាន ។ ចាប់តាំងអំពីការសម្រេចនូវអប្បនាក្នុងកោដ្ឋាសទាំង ៥ នោះ បន្ទាប់អំពីកោដ្ឋាសនោះទៅ ភិក្ខុនោះជាអ្នកមិនលំបាក ដែលនឹងសម្រេចអប្បនានោះឡើយ ។ ក្នុងសេចក្តីនោះ គប្បីជ្រាបសេចក្តីឧបមាដូចតទៅ

ប្រៀបដូចនាយខ្មាន់ធ្នូដ៏ឈ្លាស ឲ្យព្រះរាជាប្រោសប្រណីហើយ បានស្រុកសួយដែលមានតម្លៃមួយសែន សៀតអាវុធ ៥ យ៉ាងទៅក្នុងស្រុកនោះ ក្នុងរវាងផ្លូវជួបចោរ ៣២ នាក់ បណ្តាចោរទាំងនោះ បុគ្គលនោះគប្បីសម្លាប់មេចោរទាំង ៥ នាក់ ចាប់តាំងអំពីចោរទាំងនោះត្រូវសម្លាប់ហើយ ក្នុងចោរទាំងនោះ ចោរពីរនាក់ ឈ្មោះថា រត់ទៅក្នុងផ្លូវជាមួយគ្នាមិនមាន យ៉ាងណា ឧបមេយ្យនេះ គប្បីជ្រាបយ៉ាងនោះ ។ កាលដែលភិក្ខុនេះ រៀននូវកម្មដ្ឋានក្នុងសម្នាក់អាចារ្យ ប្រៀបដូចកាលដែលនាយខ្មាន់ធ្នូ ធ្វើឲ្យព្រះរាជាប្រោសប្រាណហើយ បានស្រុកសួយ ។ កោដ្ឋាស ៣២ ប្រៀបដូចចោរ ៣២ នាក់ កោដ្ឋាស ៥ មានសក់ជាដើម ប្រៀបដូចមេចោរ ៥ នាក់ ។ កាលដែល

ភិក្ខុនេះ សម្រេចអប្បនាក្នុងតបបញ្ចក: ដែលជាទីតាំងនៃការត្រេកអររបស់សត្វទាំងឡាយថា ជារបស់បដិកូល ដូច្នេះ ប្រៀបដូចកាលដែលមេចោរទាំង ៥ ត្រូវសម្លាប់ហើយ គប្បីជ្រាបថា ការសម្រេចអប្បនារបស់ភិក្ខុដែលមិនលំបាក ក្នុងកោដ្ឋាសដ៏សេសនោះឯង ប្រៀបដូចកាលដែលពួកចោរដ៏សេសរត់ទៅ ដោយត្រឹមតែការទះដៃរបស់នាយខ្មាន់ធ្នូប៉ុណ្ណោះ ។ ភិក្ខុឈានកន្លងបញ្ញត្តិយ៉ាងនេះ គប្បីឲ្យមនសិការប្រព្រឹត្តទៅដោយការលែងតាមលំដាប់ គឺកាលមនសិការសក់ទាំងឡាយដដែលៗ នោះឯង កាលស្ទាត់ក្នុងសក់ទាំងឡាយហើយ គប្បីបញ្ជូនសតិទៅក្នុងរោមទាំងឡាយ ដរាបណារោមមិនទាន់ប្រាកដ ដរាបនោះ ក៏គប្បីមនសិការថា សក់ សក់ តែកាលណា រោមទាំងឡាយកំពុងប្រាកដ កាលនោះ គប្បីវៀរសក់ទាំងឡាយ ហើយឲ្យសតិចូលទៅតម្កល់មាំក្នុងរោមទាំងឡាយ ។ ក្នុងកោដ្ឋាសទាំងឡាយ មានក្រចកជាដើម គប្បីឲ្យមនសិការប្រព្រឹត្តទៅយ៉ាងនេះ ។ ក្នុងសេចក្តីនេះ គប្បីជ្រាបឧបមាដូចតទៅ

ឧបមាដូចឈ្លើង កាលទឹងទៅ មិនទាន់បានទីពឹងខាងមុខដរាបណា ដរាបនោះ ក៏មិនទាន់លែងទីដែលខ្លួនតោងខាងក្រោយ តែកាលណាបានទីពឹងខាងមុខ កាលនោះ ក៏លើកកន្ទុយឡើងទៅតោងក្បែរមាត់យ៉ាងណា សេចក្តីនេះក៏យ៉ាងនោះឯង ភិក្ខុកាលមនសិការសក់ដដែលៗ នោះឯង ថ្មឹកក្នុងសក់ហើយ គប្បីបញ្ជូនសតិទៅក្នុងរោម ដរាបណារោមមិនទាន់ប្រាកដ ដរាបនោះ គប្បីមនសិការថា សក់ សក់ ពេលណា រោមប្រាកដ ពេលនោះ គប្បី

លះបង់សក់ ហើយតម្កល់សតិក្នុងរោម ។ ក្នុងកោដ្ឋាសទាំងឡាយ មាន ក្រចកជាដើម គប្បីឲ្យមនសិការប្រព្រឹត្តទៅយ៉ាងនេះ ។

កាលមនសិការប្រព្រឹត្តទៅយ៉ាងនេះ គប្បីធ្វើមនសិការកោសលតាម ដែលពោលហើយថា អប្បនាកើតឡើងបានឲ្យដល់ព្រម សេចក្តីនេះដូចម្តេច សេចក្តីថា អប្បនាកម្មដ្ឋាននេះ កាលមនសិការរមែងឲ្យដល់អប្បនាបាន ។ ដំបូង អប្បនាមិនទាន់ប្រាកដ ។ ពិតហើយ កាលភិក្ខុត្រឹមតែគិតថា សក់ ចិត្តដែលធ្លាប់ចម្រើនកម្មដ្ឋានមកហើយ ក្នុងអារម្មណ៍ផ្សេងៗ ក្នុងសង្សារវដ្ត ដែលមិនមានទីបំផុត ក៏នឹងស្ទុះតាមទំនងនៃក្រសែ ការស្វាធ្យាយទៅតាំងនៅ ត្រង់ខួរក្នុងក្បាល កាលភិក្ខុគ្រាន់តែគិតថា ខួរក្នុងក្បាល ចិត្តក៏ស្ទុះតាមទំនង នៃក្រសែការស្វាធ្យាយ មកតាំងនៅត្រង់សក់ ។ កាលមនសិការម្តងហើយ ម្តងទៀត កោដ្ឋាសនោះៗ រមែងប្រាកដ សតិក៏តាំងមាំ តាំងនៅ ប្រព្រឹត្តទៅ ។ ដោយហេតុនោះ កោដ្ឋាសណាមួយប្រាកដក្រៃលែងជាង គប្បីធ្វើសេចក្តី ព្យាយាម ក្នុងកោដ្ឋាសនោះៗ ដោយទ្វេគុណ ហើយគប្បីសម្រេចអប្បនា ។ ចាប់តាំងពីកាលដែលសម្រេចអប្បនាហើយយ៉ាងនេះ ភិក្ខុនោះ រមែងសម្រេច អប្បនាក្នុងកោដ្ឋាសដ៏សេសបានដោយមិនលំបាក ក្នុងសេចក្តីនេះ គប្បីជ្រាប ឧបមាដូចស្វាក្នុងព្រៃត្នោត ។

ម្យ៉ាងទៀត ក្នុងសេចក្តីនេះ គប្បីជ្រាបការប្រកបសេចក្តីយ៉ាងនេះថា ស្វាអាស្រ័យនៅក្នុងព្រៃត្នោត ៣២ ដើម នាយព្រានត្រូវការចាប់ស្វានោះ ទើប ឈរនៅក្បែរដើមត្នោត ។ ក្នុងទីបំផុត បានធ្វើសំឡេងដេញបន្លើល ស្វាមាន

ជាតិមានះ លោតទៅកាន់ដើមត្នោតនោះៗ ហើយឈប់ត្រង់ដើមត្នោតខាងចុង ព្រានទៅកាន់ទីនោះហើយ ក៏ធ្វើសំឡេងបន្លឺល ។ ស្វាក៏លោតមកឈប់ត្រង់ដើមត្នោតដំបូងនោះវិញ ស្វានោះ ត្រូវព្រានតាមដេញរឿយៗ អស់កម្លាំងក៏ឈប់ត្រង់ដើមត្នោតនោះៗ ក្នុងកាលដែលព្រានធ្វើសំឡេងដេញ ទើបលោត កាលស្វាអស់កម្លាំងមែនទែន ទើបឱបកំពូលត្នោតមួយយ៉ាងណែន ត្រូវព្រានបាញ់ដោយធ្នូ ចាប់មកក៏មិនគេចទៅ ក្នុងសេចក្ដីនោះ កោដ្ឋាស ៣២ ប្រៀបដូចដើមត្នោត ៣២ ដើម ចិត្ត ប្រៀបដូចស្វា ព្រះយោគាវចរប្រៀបដូចព្រាន កាលដែលព្រះយោគាវចរគ្រាន់តែអាវជ្ជនៈថា សក់ ភាពដែលចិត្តជាប់ចម្រើនកម្មដ្ឋានហើយ ក្នុងអារម្មណ៍ផ្សេងៗ ក្នុងសង្សារវដ្ត ដែលមិនមានទីបំផុត ស្ទុះតាមទំនងនៃក្រសែការស្វាធ្យាយ ទៅតាំងនៅត្រង់ខួរក្នុងក្បាល ប្រៀបដូចកាលដែលស្វាមានជាតិដែលប្រកបដោយមានះ ក្នុងខណៈដែលត្រូវព្រានព្រៃឈរក្បែរដើមត្នោត ធ្វើសំឡេងបន្លឺល ក៏គេចទៅឈប់ត្រង់ដើមត្នោតខាងចុង កាលព្រះយោគាវចរត្រឹមតែគិតថា ខួរក្នុងក្បាល ការដែលចិត្តស្ទុះតាមទំនងនៃក្រសែការស្វាធ្យាយ មកតាំងនៅត្រង់សក់ ប្រៀបដូចកាលដែលស្វានៅត្រង់ដើមត្នោតខាងចុង លុះត្រូវនាយព្រានធ្វើសំឡេងបន្លឺល ក៏លោតត្រឡប់មកឈប់ត្រង់ដើមត្នោតទីមួយវិញ កាលដែលព្រះយោគាវចរមនសិការម្ដងហើយម្ដងទៀត កាលកោដ្ឋាសនោះៗ ប្រាកដ សតិនឹងតាំងមាំប្រព្រឹត្តទៅ ប្រៀបដូចកាលដែលស្វានោះ ត្រូវនាយព្រានដេញតាមរឿយៗ អស់កម្លាំង ក៏ក្រោកឡើងក្នុងខណៈដែលត្រូវនាយព្រានបន្លឺល ។

កាលកោដ្ឋាសណាប្រាកដក្រៃលែងជាង គឺច្បាស់ជាង ហើយសឹមធ្វើមនសិការក្នុងកោដ្ឋាសនោះឲ្យទ្វេគុណរហូតសម្រេចអប្បនា ប្រៀបដូចកាលដែលស្វាទោះបីត្រូវព្រានបាញ់ដោយព្រួញ ចាប់ខ្លួនមក ក៏មិនគេចទៅ ដូច្នោះ ។ ក្នុងកោដ្ឋាសទាំងនោះ ចាប់តាំងពីសម្រេចអប្បនាហើយ នឹងសម្រេចអប្បនាក្នុងកោដ្ឋាសដ៏សេសបានដោយមិនលំបាកឡើយ ព្រោះហេតុនោះ ព្រះយោគាវចរ គប្បីអាវជ្ជនៈ គប្បីប្រមូលមក គប្បីនឹករឿយៗ ថា បដិកូល បដិកូល ។ កាលធ្វើយ៉ាងនេះ នាមក្ខន្ធ ៤ រមែងមានអារម្មណ៍បដិកូល ព្រះយោគាវចរនោះ រមែងសម្រេចអប្បនាបាន ។ ពាក្យទាំងពួងថា បុព្វភាគចិត្តទាំងឡាយ មានវិតក្ក វិចារ ពោល គឺបរិកម្ម និងឧបចារៈជាដើម ដូចគ្នានឹងពាក្យដែលពោលហើយខាងដើមនោះឯង តែកាលមនសិការកោដ្ឋាស ១ បឋមជ្ឈាន ១ ប៉ុណ្ណោះ រមែងកើតឡើង កាលមនសិការចំពោះកោដ្ឋាសនីមួយៗ បឋមជ្ឈាន ៣២ រមែងកើតឡើង ។ រឿងបញ្ហាដែលចាប់ដៃមកពោល ក៏ប្រើក្នុងទីនេះបាន ។

បទថា **សោ តំ និមិត្តំ** បានដល់ ភិក្ខុនោះ ...នូវនិមិត្តនៃកម្មដ្ឋាននោះ ។ បទថា **អាសេវតិ** បានដល់ រមែងសេព រមែងសមគប់ ។ បទថា **ភាវេតិ** បានដល់ រមែងឲ្យចម្រើន ។ បទថា **ពហុលីករោ** បានដល់ ធ្វើរឿយៗ ។ បទថា **ស្វាវត្ថិតំ វវត្ថបេតិ** បានដល់ ធ្វើនូវការកំណត់ឲ្យល្អ ។ បទថា **ពហិទ្ធា កាយេ ចិត្តំ ឧបសំហរតិ** សេចក្តីថា កាលធ្វើយ៉ាងនេះហើយ រមែងបង្អោន គឺរមែងឲ្យចិត្តទៅ រមែងបញ្ជូនចិត្តរបស់ខ្លួនទៅក្នុងកាយរបស់

អ្នកដទៃខាងក្រៅ ។

បទថា **អត្ថិស្ស កាយេ** បានដល់ មាននៅក្នុងកាយរបស់បុគ្គលនោះ ។ បទថា **អជ្ឈត្តពហិទ្ធា កាយេ ចិត្តំ ឧបសំហរតិ** សេចក្ដីថា រមែងបង្អោនចិត្តទៅក្នុងកាយរបស់ខ្លួនតាមកាលដែលគួរ បង្អោនចិត្តទៅក្នុងកាយរបស់អ្នកដទៃ តាមកាលដែលគួរ ។

បទថា **អត្ថិ កាយេ** នេះ លោកមិនបំណងយកកាយរបស់ខ្លួន និងកាយរបស់អ្នកដទៃដោយចំណែកមួយនោះឡើយ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **អត្ថិ កាយេ** ។

ក្នុងសេចក្ដីដទៃ កាលព្រះយោគាវចរធ្វើបរិកម្មថា បដិកូល ក្នុងសរីរៈដែលមានជីវិតរបស់ខ្លួន អប្បនាក្ដី ឧបចារៈក្ដី រមែងកើតឡើង កាលធ្វើបរិកម្មថា បដិកូល ក្នុងសរីរៈដែលមានជីវិតរបស់អ្នកដទៃ អប្បនាមិនកើតឧបចារៈក៏មិនកើត ។ សួរថា បដិកូលទាំងពីរ រមែងកើតក្នុងអសុភ ១០ មិនមែនឬ ឆ្លើយថា ពិត ព្រោះអសុភ ១០ នោះ តាំងនៅក្នុងចំណែកអនុបាទិន្នកសង្ខារ ហេតុនោះ អប្បនាក្ដី ឧបចារៈក្ដី ទើបកើតឡើងបានក្នុងអសុភទាំង ១០ នោះ ចំណែកបដិកូលក្នុងសរីរៈរបស់អ្នកដទៃនេះ តាំងនៅក្នុងចំណែកឧបាទិន្នកសង្ខារ ដោយហេតុនោះឯង ទើបអប្បនា និងឧបចារៈទាំងពីរមិនកើតក្នុងទីនេះ វិបស្សនា ពោល គឺការតាមឃើញអសុភ គប្បីជ្រាបថា ជាភាវនា ។ សួរថា ក្នុងសេចក្ដីនេះ លោកហៅថា ដូចម្ដេច ឆ្លើយថា លោកហៅថា សមថវិបស្សនា ។ ឥឡូវនេះ គប្បីជ្រាបបកិណ្ណកៈដែល

ទូទៅ ដល់មនសិការទាំងពួង ក្នុងទីនេះដូចតទៅ ពិតហើយ

គប្បីជ្រាបវិនិច្ឆ័យក្នុងកោដ្ឋាសមានសក់ជាដើមនោះ ដោយនិមិត្ត ដោយលក្ខណៈ ដោយធាតុ ដោយសុញ្ញតៈ និងដោយខន្ធជាដើម ។

ក្នុងសេចក្ដីនោះ ពាក្យថា ដោយនិមិត្ត បានដល់ ព្រះយោគាវចររមែងកំណត់អាការ ៣២ ដោយកោដ្ឋាស ដោយអំណាចនៃនិមិត្ត ១៦០ ក្នុងអាការ ៣២ គឺសក់ មាននិមិត្ត ៥ បានដល់ វណ្ណនិមិត្ត គឺនិមិត្តនៃពណ៌ សណ្ឋាននិមិត្ត គឺនិមិត្តនៃទ្រង់ទ្រាយ ទិសានិមិត្ត គឺនិមិត្តនៃទិស ឱកាស-និមិត្ត គឺនិមិត្តនៃទីតាំងនៅ និងបរិច្ឆេទនិមិត្ត គឺនិមិត្តនៃការកំណត់ ។ ក្នុងរោមជាដើម ក៏មានន័យដូច្នេះឯង ។

ពាក្យថា ដោយលក្ខណៈ បានដល់ ព្រះយោគាវចររមែងមនសិការអាការ ៣២ ដោយលក្ខណៈ ដោយអំណាចនៃលក្ខណៈ ១២៨ ក្នុងអាការ ៣២ គឺសក់មានលក្ខណៈ ៤ បានដល់ **ថទ្ធត្តលក្ខណំ** មានការរឹងជាលក្ខណៈ **អាពន្ធត្តលក្ខណំ** មានការប្រមូលផ្ដុំជាលក្ខណៈ **ឧណ្ហត្តលក្ខណំ** មានការក្ដៅជាលក្ខណៈ **វិត្ថម្ភនលក្ខណំ** មានការពង្រីកខ្លួនជាលក្ខណៈ សូម្បីក្នុងរោមជាដើម ក៏មានន័យដូចគ្នា ។

ពាក្យថា ដោយធាតុ បានដល់ ព្រះយោគាវចររមែងកំណត់អាការ ៣២ ដោយធាតុ ដោយអំណាចនៃធាតុ ១២៨ ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ បុរសនេះ មានធាតុ ៤ ដូច្នេះ ក្នុងអាការ ៣២ គឺសក់មានធាតុ ៤ បានដល់ សភាពរឹង ជាបឋវីធាតុ សភាពប្រមូលផ្ដុំ ជាអាបោធាតុ

សភាពក្តៅ ជាតេជោធាតុ ការពង្រីកខ្លួន ជាវាយោធាតុ ។ ក្នុងពោមជាដើម ក៏មានន័យដូចគ្នា ។

ពាក្យថា ដោយសុញ្ញតៈ បានដល់ ព្រះយោគាវចរ រមែងពិចារណា ឃើញនូវអាការ ៣២ ដោយអំណាចនៃសុញ្ញតៈ ៩៦ ក្នុងអាការ ៣២ គឺ សក់ មានសុញ្ញតៈ ៣ គឺ **អត្តសុញ្ញតា** ទទេចាកខ្លួន ១ **អត្តនិយសុញ្ញតា** ទទេចាកវត្ថុដែលជារបស់ខ្លួន ១ **និច្ចភាវសុញ្ញតា** ទទេចាកភាពជារបស់ទៀង ១ ព្រោះអត្ថថា សក់ទាំងឡាយទទេចាកខ្លួន ១ ចាកវត្ថុជារបស់ខ្លួន ១ ចាកភាពទៀង ១ ចាកភាពមាំមួន ១ ចាកភាពស្ថិតស្ថេរ ១ ចាកធម៌ដែលមិនប្រែប្រួល ១ ។ ក្នុងពោមជាដើម ក៏ន័យនេះឯង ។

ពាក្យថា ដោយខន្ធជាដើម គប្បីជ្រាបវិនិច្ឆ័យក្នុងសេចក្តីនេះថា កាលព្រះយោគាវចរកំណត់កោដ្ឋាសទាំងអស់ មានសក់ជាដើម ក្នុងអាការ ៣២ ដោយអំណាចនៃខន្ធជាដើម គឺសក់ទាំងឡាយជាខន្ធប៉ុន្មាន ជាអាយតនៈប៉ុន្មាន ជាធាតុប៉ុន្មាន ជាសច្ចៈប៉ុន្មាន និងជាសតិប្បដ្ឋានប៉ុន្មានជាដើម ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងកាយានុបស្សនា ៣ យ៉ាងដោយពិស្តារ ចែកជាកាយខាងក្នុងជាដើមយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់ប្រារព្ធពាក្យថា **អនុបស្សី** ជាដើម ដើម្បីចែកសម្តែងបទថា **កាយានុបស្សី វិហរតិ អាតាបី សម្បជានោ** ជាដើម ។

ក្នុងសេចក្តីនោះ ដើម្បីសម្តែងអនុបស្សនាដែលជាហេតុឲ្យព្រះយោគាវចរ ឈ្មោះថា **កាយានុបស្សី** នោះ ទើបត្រាស់ថា សំណួរថា ចុះបណ្តា

ពាក្យទាំងនោះ ការពិចារណា តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ដូច្នេះ ជាដើម ។ ក្នុងបទថា **អាសាបី** ជាដើម ក៏ន័យនេះនោះឯង ។ ពាក្យថា **បញ្ញា បជានធា** ជាដើម គប្បីជ្រាបដោយន័យដែលពោលក្នុងអដ្ឋកថានៃចិត្តុប្បាទកណ្ឌខាងដើមនោះឯង ។

ពាក្យទាំងពួងថា **ឧបេតោ** ជាដើម ជាវេវចនៈនៃគ្នានិងគ្នានោះឯង ។ ម្យ៉ាងទៀត ឈ្មោះថា **ឧបេតោ** ដោយអំណាចនៃអាសេវនៈ គឺការសេព ។ ឈ្មោះថា **សមុបេតោ** ព្រោះចូលដល់ដោយល្អដោយអំណាចនៃភាវនា ។ ពាក្យជាគូៗ គ្នាថា **ឧចាគតោ** និង **សមុចាគតោ ឧបបន្នោ** និង **សម្បន្នោ** ក៏ន័យនេះដូចគ្នា ។ តែក្នុងទីនេះ គប្បីជ្រាបការភ្ជាប់សេចក្តីយ៉ាងនេះថា ឈ្មោះថា **សមន្នាគតោ** ព្រោះធ្វើឲ្យច្រើន ។ សូម្បីបទថា **ឥមិនា អាសាបេន ឧបេតោ** ជាដើម ក៏ន័យនេះឯង ។

ក្នុងបទថា **វិហរតិ** ព្រះមានព្រះភាគ កាលទ្រង់សម្តែងដោយទេសនាបុគ្គលាធិដ្ឋាន ទើបត្រាស់ពាក្យថា **ឥរិយតិ** ជាដើម ដោយមិនធ្វើពាក្យសួរថា បណ្តាពាក្យទាំងនោះ ការនៅ តើដូចម្តេច ។ អត្ថនៃពាក្យនោះ មានដូចតទៅ ឈ្មោះថា **ឥរិយតិ** ព្រោះភាពជាអ្នកដល់ព្រមដោយឥរិយាបថ ៤ ណាមួយ ។ ឈ្មោះថា **វត្តតិ** ព្រោះប្រព្រឹត្តទៅដោយរទេះ គឺកាយដែលប្រព្រឹត្តទៅដោយឥរិយាបថទាំង ៤ នោះ ។ ឈ្មោះថា **ចាលេតិ** ព្រោះការកម្ចាត់ឥរិយាបថមួយដែលជាទុក្ខ ដោយឥរិយាបថដទៃហើយ រក្សាសរីរៈដោយភាពជាអ្នកតាំងនៅស្ថិតស្ថេរ ។ ឈ្មោះថា **យបេតិ** ព្រោះមិនតាំងនៅ

ក្នុងឥរិយាបថមួយ ហើយប្រព្រឹត្តទៅដោយឥរិយាបថទាំងពួង ។ ឈ្មោះថា **យាបេតិ** ព្រោះញុំាងកាយឲ្យប្រព្រឹត្តទៅ ដោយឥរិយាបថនោះៗ គឺដោយប្រការនោះៗ ។ ឈ្មោះថា **ចរតិ** ព្រោះឲ្យរាងកាយប្រព្រឹត្តទៅអស់កាលយូរ ។ ឈ្មោះថា **វិហរតិ** ព្រោះប្តូរឥរិយាបថដោយឥរិយាបថហើយនាំជីវិតទៅ ។

បទថា **ស្វេវ កាយោ លោកោ** សេចក្តីថា ភិក្ខុមានប្រក្រតីតាមឃើញកាយក្នុងកាយណា កាយនោះឯង ឈ្មោះថា លោក ព្រោះអត្ថថាបែកធ្លាយទៅ ។ តែព្រោះអភិជ្ឈា និងទោមនស្ស ដែលបុគ្គលលះបានក្នុងកាយ បុគ្គលនោះ ឈ្មោះថា រមែងលះបានក្នុងវេទនាជាដើមនោះឯង ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ឧបាទានក្ខន្ធទាំង ៥ ឈ្មោះថា លោក ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **សន្តា** ជាដើម ឈ្មោះថា **សន្តា** ព្រោះស្ងប់ហើយដោយអំណាចនៃនិរោធ ។ ឈ្មោះថា **សមិតា** ព្រោះរម្ងាប់ហើយដោយភាវនា ។ ឈ្មោះថា **វូបសន្តា** ដោយអំណាចការចូលទៅស្ងប់ ព្រោះការមិនប្រព្រឹត្តទៅ ដោយការកំណត់ដឹងវត្ថុ ( កាយ ) ។ ឈ្មោះថា **អត្ថង្គតា** ព្រោះដល់ហើយនូវការនៅតាំងមិនបាន ពោល គឺរោធ ។ ឈ្មោះថា **អព្ភត្ថង្គតា** ព្រោះដល់នូវការរលត់យ៉ាងក្រៃលែង ដ្បិតកម្ចាត់ការកើតរឿយៗ បាន ។ បទថា **អប្បិតា** បានដល់ ត្រូវធ្វើឲ្យវិនាសទៅ អធិប្បាយថា មិនឲ្យមានតទៅ ដូច្នេះក៏មាន ។ បទថា **ព្យប្បិតា** បានដល់ ត្រូវធ្វើឲ្យវិនាសទៅដោយល្អ អធិប្បាយថា មិនឲ្យមានតទៅឡើយ ដូច្នេះក៏មាន ។

ឈ្មោះថា **សោសិតា** ព្រោះឲ្យរីងស្ងួតដោយប្រការដែលកិលេសទាំងឡាយមិនហូរតាមទៅ ។ ឈ្មោះថា **វិសោសិតា** ព្រោះរីងស្ងួតដោយល្អ អធិប្បាយថា ត្រូវធ្វើឲ្យស្ងួតហើយ ។ ឈ្មោះថា **ព្យន្តី កតា** ព្រោះទីបំផុតត្រូវធ្វើឲ្យប្រាសទៅហើយ ។

ក្នុងអធិការនេះ គប្បីជ្រាបថា ការបរិហារកាយរបស់អ្នកបដិបត្តិកម្មដ្ឋាន ដោយការនៅដោយកម្មដ្ឋាន ព្រះមានព្រះភាគត្រាស់ដោយអនុបស្សនា សម្មប្បធាន ទ្រង់ត្រាស់ដោយព្យាយាមដុតកិលេស ឧបាយជាគ្រឿងបរិហារកម្មដ្ឋាន ទ្រង់ត្រាស់ដោយសតិសម្បជញ្ញៈ ។ ម្យ៉ាងទៀត សមថៈដែលបានដោយអំណាចនៃកាយានុបស្សនា ទ្រង់ត្រាស់ដោយសតិ ។ វិបស្សនាទ្រង់ត្រាស់ដោយសម្បជញ្ញៈ ផលនៃភាវនាទ្រង់ត្រាស់ដោយការកម្ចាត់អភិជ្ឈា និងទោមនស្ស ៕

## អដ្ឋកថាកាយានុបស្សនានិទ្ទេស ចប់

# អដ្ឋកថា

## វេទនានុបស្សនានិទ្ទេស

[ ១៨៧-១៩០ ] ក្នុងវេទនានុបស្សនានិទ្ទេស គប្បីជ្រាបដូចគ្នានឹងពាក្យដែលពោលហើយខាងដើម ដោយន័យដែលពោលហើយនោះឯង ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **សុខំ វេទនំ វេទយមានោ** ជាដើមដូចតទៅ បទថា **សុខំ វេទនំ** អធិប្បាយថា កាលសោយសុខវេទនា ដែលប្រព្រឹត្តទៅផ្លូវកាយ ឬផ្លូវចិត្ត ក៏ដឹងច្បាស់ថា អាត្មាអញ សោយសុខវេទនាដូច្នេះ ។

ក្នុងសេចក្ដីនេះ ប្រៀបដូចទារកទាំងឡាយ សូម្បីនៅដេកផ្ងារក្នុងវេលាបៅដោះជាដើម កាលសោយសុខវេទនា ក៏រមែងដឹងថា អញសោយសុខវេទនាក៏ពិត តែព្រះមានព្រះភាគ មិនបានត្រាស់សំដៅយកការដឹងបែបនោះ ព្រោះថា ការដឹងបែបនោះ រមែងមិនលះសត្តូបលទ្ធិ គឺការយល់ឃើញថា សត្វ ទាំងមិនមែនកម្មដ្ឋាន ឬមិនមែនការចម្រើនសតិប្បដ្ឋាន តែការដឹងរបស់ភិក្ខុនេះ រមែងលះសត្តូបលទ្ធិ រមែងដកនូវសត្តសញ្ញា ទាំងជាកម្មដ្ឋានផង ជាការចម្រើនសតិប្បដ្ឋានផង ព្រោះថា ព្រះមានព្រះភាគត្រាស់សេចក្ដីនេះ សំដៅយកការសោយដែលប្រកបដោយការដឹងយ៉ាងនេះថា អ្នកណាសោយវេទនា វេទនារបស់អ្នកណា វេទនាមានអ្វីជាហេតុ ដូច្នេះ ។

ក្នុងបញ្ហាទាំងនោះ ពាក្យថា អ្នកណាសោយវេទនា បានដល់ បុគ្គលណាមួយ គឺសត្វ ឬបុគ្គល រមែងសោយវេទនាមិនមាន ។ ពាក្យថា វេទនារបស់អ្នកណា បានដល់ មិនមែនវេទនារបស់អ្នកណា ទោះជាសត្វ ឬបុគ្គលក៏ដោយ ។ ពាក្យថា វេទនាមានអ្វីជាហេតុ បានដល់ វេទនានោះឯង មាន

វត្ថុជាអារម្មណ៍ ព្រោះហេតុនោះ បុគ្គលនោះជ្រាបច្បាស់យ៉ាងនេះថា វេទនានោះឯង រមែងសោយ ព្រោះធ្វើវត្ថុនៃសុខជាដើមនោះៗ ឲ្យជាអារម្មណ៍ តែព្រោះកាន់យកការប្រព្រឹត្តទៅនៃវេទនានោះ ក៏មានត្រឹមតែជាវោហារថា អញសោយវេទនា ដូច្នេះ កាលធ្វើវត្ថុឲ្យជាអារម្មណ៍យ៉ាងនេះហើយ កាលកំណត់ថា វេទនារមែងសោយ គប្បីជ្រាបថា បុគ្គលនោះ រមែងជ្រាបច្បាស់ថា អញសោយសុខវេទនា ដូច្នេះ ដូចព្រះថេរៈមួយអង្គ ត្រង់ចិត្តលបពិត ។

បានឮថា ព្រះថេរៈក្នុងកាលដែលលោកមានអាពាធ ដេកសោយទុក្ខ-វេទនាដ៏ខ្លាំងក្លា ត្រឡប់ទៅត្រឡប់មក ភិក្ខុកំលោះមួយអង្គមកសួរថា បពិត្រលោកម្ចាស់ៗ ឈឺត្រង់ណា ព្រះថេរៈឆ្លើយថា អាវុសោ ឈ្មោះថា ទីឈឺដែលជាចំណែកត្រង់ណាមិនមាន ខ្ញុំសោយវេទនា ព្រោះធ្វើវត្ថុឲ្យជាអារម្មណ៍ ។ ភិក្ខុកំលោះសួរថា ចាប់តាំងពីកាលដែលលោកម្ចាស់ជ្រាបយ៉ាងនេះ ការអត់ធ្មត់មិនគួរឬ ព្រះថេរៈពោលថា ខ្ញុំនឹងអត់ធ្មត់ ទើបភិក្ខុកំលោះពោលថា ការអត់ធ្មត់ជាការល្អ ព្រះថេរៈក៏អត់សង្កត់ហើយ ។ ខ្យល់ផ្សាយទៅរហូតដល់ពោះដូង បានធ្វើពោះវៀនធំឲ្យចេញមកគរលើគ្រែដេក ព្រះថេរៈឲ្យភិក្ខុកំលោះមើល ហើយពោលថា អាវុសោ អត់ធ្មត់បែបនេះ គួរហើយឬនៅ ។ ភិក្ខុកំលោះក៏នៅស្ងៀម ។ ព្រះថេរៈប្រកបវីរិយសមាធិ ហើយសម្រេចអរហត្តព្រមដោយបដិសម្ភិទា ជាព្រះអរហន្តសមសីសី បរិនិព្វានហើយ ។

កាលសោយទុក្ខវេទនា ។បេ។ កាលសោយអទុក្ខមសុខវេទនា មិនមានអាមិស ក៏ដឹងច្បាស់ថា អញសោយអទុក្ខមសុខវេទនាមិនមានអាមិស

ដូចកាលសោយសុខវេទនា ដូច្នោះ ។ ព្រះមានព្រះភាគ កាលត្រាស់ដឹងកម្មដ្ឋានហើយ កាលនឹងត្រាស់រូបកម្មដ្ឋាន ទើបត្រាស់ដោយអំណាចនៃវេទនា ដោយប្រការដូច្នេះ ។

ពិតហើយ កម្មដ្ឋានមាន ២ យ៉ាង គឺរូបកម្មដ្ឋាន និងអរូបកម្មដ្ឋាន ។ កម្មដ្ឋាននោះឯង ហៅថា **រូបបរិគ្គហោ** គឺការកំណត់រូបខន្ធ **អរូបបរិគ្គហោ** គឺការកំណត់អរូបខន្ធ ។ ក្នុងកម្មដ្ឋាន ២ នោះ ព្រះមានព្រះភាគកាលត្រាស់រូបកម្មដ្ឋាន ទើបត្រាស់ការកំណត់ធាតុ ៤ ដោយអំណាចនៃមនសិការដោយសង្ខេបខន្ធ ដោយពិស្តារខន្ធ ។ ការធ្វើមនសិការទាំងពីរនោះ ខ្ញុំក៏សម្តែងដោយអាការទាំងពួង ក្នុងវិសុទ្ធិមគ្គនោះឯង ។ ព្រះមានព្រះភាគកាលត្រាស់អរូបកម្មដ្ឋាន រមែងត្រាស់ដោយអំណាចនៃវេទនាដោយច្រើន ។

ម្យ៉ាងទៀត ការប្រកាន់មាំក្នុងអរូបកម្មដ្ឋាន មាន ៣ យ៉ាង គឺដោយអំណាចនៃផស្សៈ ១ ដោយអំណាចនៃវេទនា ១ និងដោយអំណាចនៃចិត្ត ១ សេចក្តីនេះដូចម្តេច គឺកាលព្រះយោគាវចរកំណត់រូបកម្មដ្ឋានដោយសង្ខេប ឬដោយពិស្តារ ការដែលចិត្ត និងចេតសិកធ្លាក់ទៅក្នុងអារម្មណ៍គ្រាដំបូងនោះ ផស្សៈដែលប៉ះខ្ទប់នូវអារម្មណ៍នោះកើតឡើង រមែងប្រាកដដល់ព្រះយោគាវចររូបខន្ធ ។ វេទនាដែលសោយអារម្មណ៍នោះ កើតឡើង រមែងប្រាកដដល់ព្រះយោគាវចររូបខន្ធ ។ វិញ្ញាណដែលកំណត់ដឹងអារម្មណ៍នោះ កើតឡើង រមែងប្រាកដដល់ព្រះយោគាវចររូបខន្ធ ។

ក្នុងការប្រកាន់មាំ ៣ យ៉ាងនោះ ផស្សៈរមែងប្រាកដដល់ភិក្ខុណា

សូម្បីភិក្ខុនោះ រមែងកំណត់ធម៌ពួក ៥ មានផស្សៈជាដើមនោះឯងថា មិនមែនផស្សៈតែម្យ៉ាងប៉ុណ្ណោះទេកើតឡើង សូម្បីវេទនាដែលសោយនូវអារម្មណ៍នោះឯង ក៏កើតឡើងព្រមដោយផស្សៈនោះ សញ្ញាដែលចាំនូវអារម្មណ៍នោះ ចេតនាដែលគិតនូវអារម្មណ៍នោះ វិញ្ញាណដែលដឹងនូវអារម្មណ៍នោះ ក៏រមែងកើតឡើង ដោយផស្សៈនោះ ។ វេទនារមែងប្រាកដដល់ភិក្ខុណា ភិក្ខុនោះរមែងកំណត់ធម៌ពួក ៥ មានផស្សៈជាដើមនោះឯងថា មិនមែនវេទនាតែម្យ៉ាងប៉ុណ្ណោះដែលកើតឡើង សូម្បីផស្សៈដែលប៉ះខ្ទប់នូវអារម្មណ៍នោះឯង រមែងកើតឡើងព្រមដោយវេទនានោះ សញ្ញា ដែលចាំនូវអារម្មណ៍នោះ ចេតនាដែលគិតនូវអារម្មណ៍នោះ វិញ្ញាណដែលដឹងច្បាស់នូវអារម្មណ៍នោះ ក៏រមែងកើតឡើងព្រមដោយវេទនានោះ ។ វិញ្ញាណរមែងប្រាកដដល់ភិក្ខុណា ភិក្ខុនោះក៏រមែងកំណត់ធម៌ពួក ៥ មានផស្សៈជាដើមនោះឯងថា មិនមែនវិញ្ញាណតែម្យ៉ាងប៉ុណ្ណោះកើតឡើង សូម្បីផស្សៈដែលប៉ះខ្ទប់នូវអារម្មណ៍នោះឯងរមែងកើតឡើងជាមួយវិញ្ញាណនោះ សូម្បីវេទនាដែលសោយនូវអារម្មណ៍នោះ សូម្បីសញ្ញាដែលចាំនូវអារម្មណ៍នោះ សូម្បីចេតនាដែលគិតនូវអារម្មណ៍នោះ ក៏រមែងកើតឡើងព្រមដោយវិញ្ញាណនោះ ។

កាលភិក្ខុនោះពិចារណាថា ធម៌ពួក ៥ មានផស្សៈជាដើមនេះ អាស្រ័យអ្វី ភិក្ខុនោះរមែងជ្រាបច្បាស់ថា អាស្រ័យវត្ថុ ឈ្មោះថា វត្ថុ គឺករជកាយដែលលោកពោលសំដៅយកវត្ថុ គឺករជកាយ ( ក្នុងទីឃនិកាយ សីលក្ខន្ធវគ្គ ) ថា ក៏ឯវិញ្ញាណរបស់អាត្មាអញនេះសោត អាស្រ័យនៅក្នុងកាយនេះ

ជាប់នៅក្នុងកាយនេះ ដូច្នេះ ។ កាលពោលដោយអត្ថ ករជកាយនោះ គឺមហាភូតរូប និងឧបាទាយរូបទាំងឡាយ ។ ក្នុងសេចក្តីនេះ ព្រះយោគាវចរ រមែងឃើញនាមរូបនោះឯងយ៉ាងនេះថា វត្ថុជារូប ធម៌ពួក ៥ មានផស្សៈជាដើមជានាម ដូច្នេះ ។ រូបក្នុងទីនេះ គឺរូបក្ខន្ធ នាម គឺអរូបក្ខន្ធ ៤ ព្រោះហេតុនោះ ទើបនាមរូបត្រឹមតែជាខន្ធ ៥ ព្រោះថា ខន្ធ ៥ ក្រៅអំពីនាមរូប ឬនាមរូបក្រៅអំពីខន្ធ ៥ រមែងមិនមាន ។ ភិក្ខុនោះពិចារណាថា ខន្ធទាំងឡាយនោះ មានអ្វីជាហេតុដូច្នេះ រមែងឃើញថា មានអវិជ្ជាជាដើមជាហេតុ ក្នុងលំដាប់នោះ ទើបលើកឡើងកាន់ត្រៃលក្ខណ៍ ដោយអំណាចនៃនាមរូបមួយអន្លើដោយបច្ច័យថា នេះជាបច្ច័យ នេះជាបច្ចយុប្បន្ន សត្វ ឬបុគ្គលដទៃមិនមាន មានត្រឹមតែគំនរនៃសង្ខារសុទ្ធៗ ប៉ុណ្ណោះ ដូច្នេះ ។ ពិចារណាឃើញថា ជាអនិច្ចំ ទុក្ខំ អនត្តាដោយលំដាប់នៃវិបស្សនាត្រាច់ទៅ ។ ភិក្ខុនោះ សង្ឃឹមនូវការចាក់ធ្លុះថា អញនឹងចាក់ធ្លុះក្នុងថ្ងៃនេះ អញនឹងចាក់ធ្លុះក្នុងថ្ងៃនេះ ដូច្នេះ បានឧតុជាទីសប្បាយ បុគ្គលជាទីសប្បាយ ភោជនជាទីសប្បាយ និងធម្មសវនៈជាទីសប្បាយ ក្នុងថ្ងៃបែបនោះហើយ អង្គុយដោយភ្នែនមួយនោះឯង ញ៉ាំងវិបស្សនាឲ្យដល់ទីបំផុត ហើយតាំងនៅក្នុងអរហត្ត ព្រះមានព្រះភាគត្រាស់កម្មដ្ឋានដល់ជនទាំង ៣ ពួកនេះ រហូតដល់អរហត្ត ដោយប្រការដូច្នេះ ។

ក្នុងទីនេះ ព្រះមានព្រះភាគ កាលត្រាស់អរូបកម្មដ្ឋាន ក៏ត្រាស់ដោយអំណាចនៃវេទនា ។ ពិតហើយ អរូបកម្មដ្ឋាន ដែលព្រះមានព្រះភាគត្រាស់

ដោយអំណាចនៃផស្សៈ ឬដោយអំណាចនៃវិញ្ញាណ រមែងមិនប្រាកដដូចគ្នានឹងងងឹត កម្មដ្ឋាននោះ រមែងប្រាកដដោយអំណាចនៃវេទនា សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះការកើតឡើងនៃវេទនាទាំងឡាយរមែងប្រាកដ ព្រោះថា ការកើតឡើងនៃសុខវេទនា និងទុក្ខវេទនាទាំងឡាយប្រាកដ គឺក្នុងកាលណាសុខវេទនាកើតឡើង ធ្វើឲ្យសរីរៈទាំងមូលរញ្ជួយញាប់ញ័រ ជ្រួតជ្រាបផ្សាយទៅ ហាក់បីដូចឲ្យទំពាស៊ីនូវសប្បិដែលជម្រះហើយរាប់រយដង ដូចឲ្យលាបនូវប្រេងដែលចម្រាញ់រាប់រយដង ដូចឲ្យរលត់នូវការក្តៅក្រហាយដោយទឹករាប់ពាន់ក្អម រមែងឲ្យបន្លឺវាចាថា សុខហ្ន៎ សុខហ្ន៎ ។ ក្នុងកាលណាទុក្ខវេទនាកើតឡើង ក៏ធ្វើឲ្យសរីរៈទាំងមូល រញ្ជួយញាប់ញ័រជ្រួតជ្រាបផ្សាយទៅ ហាក់បីដូចបុគ្គលចូលទៅកាន់អំបែងដែលក្តៅ ដូចស្រោចដោយទឹកទង់ដែងដែលរលាយហើយ ហាក់បីដូចគប់ភ្លើងដែលដាក់ចូលទៅក្នុងស្មៅ និងដើមឈើធំដែលស្ងួតក្នុងព្រៃ ធ្វើឲ្យកន្ទក់កន្ទេញថា ទុក្ខ ពិតហ្ន៎ ទុក្ខពិតហ្ន៎ ។ ការកើតឡើងនៃសុខវេទនា និងទុក្ខវេទនា រមែងប្រាកដដោយប្រការដូច្នេះ ។

ចំណែកអទុក្ខមសុខវេទនា ចង្អុលបង្ហាញឲ្យឃើញបានដោយលំបាក មិនជាក់ច្បាស់ ដូចងងឹត តែរមែងប្រាកដដល់អ្នកកាន់យកដោយន័យថា អទុក្ខមសុខវេទនានោះ ជាអាការកណ្តាល ដោយអំណាចនៃការបដិសេធនូវសេចក្តីត្រេកអរ និងមិនត្រេកអរ ព្រោះសេចក្តីសុខ និងសេចក្តីទុក្ខប្រាសទៅ ប្រៀបដូចអ្វី ប្រៀបដូចព្រានម្រឹគ តាមស្នាមជើងម្រឹគដែលគេចទៅត្រង់

ចន្លោះដុំថ្ម ឃើញតែស្នាមជើងម្រឹគត្រង់ខាងអាយ និងខាងនាយនៃថ្ម មិនឃើញត្រង់កណ្តាល ក៏ជ្រាបបានដោយន័យថា ម្រឹគនេះ ឡើងត្រង់ទីនេះ ចុះត្រង់ទីនោះ ត្រង់កណ្តាល ម្រឹគនឹងជាន់លើដុំថ្មដោយប្រទេសត្រង់នេះ យ៉ាងណា សេចក្តីនោះក៏យ៉ាងនោះ ព្រោះថា ការកើតឡើងនៃសុខវេទនា រមែងប្រាកដហាក់បីដូចស្នាមជើង ត្រង់ផែនដីក្នុងទីដែលម្រឹគឡើងទៅ ការកើតឡើងនៃទុក្ខវេទនារមែងប្រាកដ ដូចស្នាមជើងក្នុងទីដែលម្រឹគឈានចុះ អទុក្ខមសុខវេទនានេះ រមែងប្រាកដដល់បុគ្គលដែលកាន់យកដោយន័យថា អទុក្ខមសុខវេទនា ជាអាការកណ្តាល ដោយអំណាចនៃការបដិសេធនូវការត្រេកអរ និងមិនត្រេកអរ ព្រោះការប្រាសចាកសុខ និងទុក្ខវេទនា ហាក់បីដូចកាន់យកដោយន័យថា ម្រឹគនេះ ឡើងលើដុំថ្មនេះ ចុះទៅត្រង់នោះ ត្រង់កណ្តាលដុំថ្ម ម្រឹគដើរទៅយ៉ាងនេះ ។

ព្រះមានព្រះភាគ កាលត្រាស់រូបកម្មដ្ឋានមុនហើយ កាលត្រាស់អរូប-កម្មដ្ឋានក្នុងកាលជាខាងក្រោយយ៉ាងនេះ ទើបប្តូរទៅសម្តែងដោយអំណាចនៃវេទនា ទ្រង់សម្តែងយ៉ាងនេះ ក្នុងសតិប្បដ្ឋានវិភង្គនេះតែម្យ៉ាងប៉ុណ្ណោះក៏មិនមែន ទ្រង់សម្តែងរូបកម្មដ្ឋានមុនហើយ ទ្រង់សម្តែងអរូបកម្មដ្ឋានប្តូរទៅដោយអំណាចនៃវេទនាក្នុងកាលជាក្រោយ ក្នុងសូត្រទាំងឡាយជាអនេក គឺក្នុងទីឃនិកាយ មានមហានិទានសូត្រ សក្កប្បញ្ហសូត្រ មហាសតិប្បដ្ឋានសូត្រ ក្នុងមជ្ឈិមនិកាយ មានសតិប្បដ្ឋានសូត្រ ចូឡតណ្ហាសង្ខយសូត្រ មហា-តណ្ហាសង្ខយសូត្រ ចូឡវេទល្លសូត្រ រដ្ឋបាលសូត្រ មាគណ្ឌិយសូត្រ

ធាតុវិភង្គ អានេញ្ជសប្បាយសូត្រ ក្នុងសំយុត្តនិកាយ មានចូឡនិទានសូត្រ រក្ខោបមសូត្រ បរិវីមំសនសូត្រ វេទនាសំយុត្តទាំងអស់ ។ ក្នុងសតិប្បដ្ឋានវិភង្គនេះ ព្រះមានព្រះភាគត្រាស់រូបកម្មដ្ឋានមុន ហើយទ្រង់ប្តូរមកសំដែងអរូបកម្មដ្ឋាន ដោយអំណាចនៃវេទនាក្នុងកាលជាក្រោយ ដូចក្នុងសូត្រនោះៗ ឯង ។

ក្នុងបទថា **សុខំ វេទនំ** ជាដើមនោះ គប្បីជ្រាបការសំដែងនូវការដឹងម្យ៉ាងទៀតដូចតទៅ បទថា **សុខំ វេទនំ វេទយាមីតិ បជានាតិ** អធិប្បាយថា ភិក្ខុនោះសោយនូវសុខវេទនា រមែងដឹងច្បាស់ថា អញសោយនូវសុខវេទនា ព្រោះមិនមានទុក្ខវេទនា ក្នុងខណៈនៃសុខវេទនា ដោយហេតុនោះ ក្នុងសេចក្តីនោះ បុគ្គលនោះ រមែងជ្រាបក្នុងសុខវេទនានេះថា ព្រោះឥឡូវនេះ មិនមានទុក្ខវេទនាដែលធ្លាប់មានអំពីមុន និងព្រោះខាងមុខអំពីនេះក៏មិនមានសុខវេទនានេះ ឈ្មោះថា វេទនា ក៏ជាវត្ថុមិនទៀង មិនស្ថិតស្ថេរមានការប្រែប្រួលទៅជាធម្មតា ដូច្នេះ ។

សមដូចព្រះមានព្រះភាគត្រាស់ ( ក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក ) ថា ម្នាលអគ្គិវេស្សនៈ សម័យណា បុគ្គលទទួលសុខវេទនា សម័យនោះមិនទទួលទុក្ខវេទនា មិនទទួលអទុក្ខមសុខវេទនាទេ ក្នុងសម័យនោះ ទទួលចំពោះតែសុខវេទនា ។ ម្នាលអគ្គិវេស្សនៈ សម័យណា បុគ្គលទទួលទុក្ខវេទនា ។បេ។ បុគ្គលទទួលអទុក្ខមសុខវេទនា សម័យនោះ មិនទទួលសុខវេទនា មិនទទួលទុក្ខវេទនាទេ សម័យនោះ ទទួលចំពោះតែអទុក្ខមសុខ-

វេទនា ។ ម្នាលអគ្គិវេស្សនៈ សុខវេទនាជារបស់មិនទៀង ជារបស់ដែលសង្ខារតាក់តែងកើតឡើងហើយ មានកិរិយាអស់ទៅ និងសូន្យទៅជាធម្មតា មានកិរិយាក្លាយទៅ ទាំងមានកិរិយារលត់ទៅវិញជាធម្មតា ។ ម្នាលអគ្គិវេស្សនៈ ទុក្ខវេទនា ។បេ។ ម្នាលអគ្គិវេស្សនៈ សូម្បីអទុក្ខមសុខវេទនា ក៏ជារបស់មិនទៀង ជារបស់ដែលសង្ខារតាក់តែងកើតឡើង ។បេ។ និងរលត់ទៅជាធម្មតា ។ ម្នាលអគ្គិវេស្សនៈ អរិយសាវកអ្នកបានស្តាប់ហើយ កាលឃើញយ៉ាងនេះ រមែងនឿយណាយចាកសុខវេទនាផង នឿយណាយចាកទុក្ខវេទនាផង នឿយណាយចាកអទុក្ខមសុខទេវនាផង កាលបើនឿយណាយហើយ រមែងប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេក ចិត្តរមែងរួចចាកកិលេស កាលចិត្តរួចចាកកិលេសហើយ ញាណក៏កើតឡើងច្បាស់ថា ចិត្តរួចស្រឡះហើយ ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌បាននៅចប់ហើយ កិច្ចដែលគួរធ្វើ បានធ្វើរួចស្រេចហើយ កិច្ចដទៃក្រៅពីនេះមិនមានឡើយ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **សាមិសំ វា សុខំ** ជាដើមដូចតទៅ គេហស្សិតសោមនស្សវេទនា ៦ ដែលអាស្រ័យអាមិស គឺកាមគុណ ៥ ឈ្មោះថា សុខវេទនាប្រកបដោយអាមិស ។ នេក្ខម្មស្សិតសោមនស្សវេទនា ៦ ឈ្មោះថា សុខវេទនាមិនប្រកបដោយអាមិស ។ គេហស្សិតទោមនស្សវេទនា ៦ ឈ្មោះថា ទុក្ខវេទនាប្រកបដោយអាមិស ។ នេក្ខម្មស្សិតទោមនស្សវេទនា ៦ ឈ្មោះថា ទុក្ខវេទនាមិនប្រកបដោយអាមិស ។ គេហស្សិត-

ឧបេក្ខាវេទនា ៦ ឈ្មោះថា អទុក្ខមសុខវេទនា ប្រកបដោយអាមិស ។ នេក្ខម្មស្សិតឧបេក្ខាវេទនា ៦ ឈ្មោះថា អទុក្ខមសុខវេទនា មិនប្រកបដោយអាមិស ។ ការចែកវេទនាទាំងនោះ មកហើយក្នុងបាលីឧបរិបណ្ណាសក នោះឯង ។

បទថា **សោ តំ និមិត្តំ** បានដល់ ភិក្ខុនោះ ...នូវនិមិត្តនៃវេទនានោះ ។ បទថា **ពហិទ្ធា វេទនាសុ** បានដល់ ក្នុងវេទនាទាំងឡាយរបស់បុគ្គលដទៃ ។

បទថា **សុខំ វេទនំ វេទយមានំ** បានដល់ ដឹងបុគ្គលដទៃកំពុងសោយសុខវេទនា ។ បទថា **អជ្ឈត្តពហិទ្ធា** បានដល់ បង្អោនចិត្តទៅក្នុងវេទនាទាំងឡាយរបស់ខ្លួនតាមកាលគួរ របស់អ្នកដទៃតាមកាលគួរ ។ ព្រោះក្នុងវារៈនេះ មិនបានកំណត់ខ្លួន មិនបានកំណត់អ្នកដទៃ ហេតុនោះ ដើម្បីទ្រង់សម្តែងត្រឹមតែការកំណត់វេទនាប៉ុណ្ណោះ ទើបព្រះមានព្រះភាគត្រាស់ថា ភិក្ខុក្នុងសាសនានេះ កាលទទួលសុខវេទនា ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខវេទនា ។ សេចក្តីដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ក្នុងសេចក្តីនេះ លោកពោលវិបស្សនាសុទ្ធៗ នោះឯង ។

**អដ្ឋកថាវេទនានុបស្សនានិទ្ទេស ចប់**

# អដ្ឋកថា

## ចិត្តានុបស្សនានិទ្ទេស

[ ១៩១-១៩៤ ] ក្នុងចិត្តានុបស្សនានិទ្ទេស គប្បីជ្រាបដូចគ្នានឹងពាក្យដែលពោលហើយខាងដើម ដោយន័យដែលពោលហើយនោះឯង ។

បទថា **សរាគំ** ក្នុងបទថា **សរាគំ វា ចិត្តំ** ជាដើម បានដល់ចិត្តដែលសហគតៈដោយលោភៈ ៨ ដួង ។ បទថា **វីតរាគំ** បានដល់ ចិត្តខាងលោកិយដែលជាកុសល និងអព្យាកត តែព្រោះការពិចារណានេះ មិនមែនធម្មសមោធាន ហេតុនោះ ទើបមិនបានលោកុត្តរចិត្ត សូម្បីតែមួយបទក្នុងទីនេះ ។ អកុសលចិត្តពួកណាប្រព្រឹត្តទៅជាមួយរាគៈជាដើម ដែលព្រះយោគាវចរលះបានដោយអំណាចនៃកិលេសដែលតាំងនៅ ក្នុងឋានៈជាមួយគ្នានៃការលះអកុសលចិត្តទាំងនោះ លោកក៏មិនកាន់យក ព្រោះមិនបានក្នុងបទទាំងពីរនេះដោយត្រង់ ។ អកុសលចិត្ត ៤ ដ៏សេស មិនទាក់ទងជាមួយបទមុន និងបទក្រោយ ។

បទថា **សទោសំ** បានដល់ ចិត្តដែលសហគតៈដោយទោមនស្ស ២ ដួង ។ បទថា **វីតទោសំ** បានដល់ ចិត្តខាងលោកិយដែលជាកុសល និងអព្យាកត ។ អកុសលចិត្ត ១០ ដ៏សេស មិនទាក់ទងជាមួយបទមុន និងបទក្រោយ ។

បទថា **សមោហំ** បានដល់ ចិត្ត ២ យ៉ាង គឺចិត្តដែលសហគតៈដោយវិចិកិច្ឆា និងចិត្តដែលសហគតៈដោយឧទ្ធច្ចៈ ។ តែព្រោះមោហៈ រមែងកើតឡើងក្នុងអកុសលចិត្តទាំងពួង ហេតុនោះ អកុសលចិត្តដ៏សេស រមែងប្រព្រឹត្ត

ទៅក្នុងទីនេះទាំងអស់ ។ ពិតហើយ អកុសលចិត្ត ១២ ដួង លោកកាន់យក ហើយក្នុងទុកៈនេះឯង ។ បទថា **វីតមោហំ** បានដល់ ចិត្តខាងលោកិយ ដែលជាកុសល និងអព្យាកត ។

បទថា **សង្ខិត្តំ** បានដល់ ចិត្តដែលធ្លាក់ទៅក្នុងថីនមិទ្ធៈ ។ ពិតហើយ ចិត្តនោះ ឈ្មោះថា រួញរាហើយ ។ បទថា **វិក្ខិត្តំ** បានដល់ ចិត្តដែលសហគតៈដោយឧទ្ធច្ចៈ ។ ពិតហើយ ចិត្តនោះ ឈ្មោះថា ចិត្តរាយមាយទៅហើយ ។

បទថា **មហគ្គតំ** បានដល់ រូបាវចរចិត្ត និងអរូបាវចរចិត្ត ។ បទថា **អមហគ្គតំ** បានដល់ កាមាវចរចិត្ត ។

បទថា **សឧត្តរំ** បានដល់ កាមាវចរចិត្ត ។ បទថា **អនុត្តរំ** បានដល់ រូបាវចរចិត្ត និងអរូបាវចរចិត្ត ។ មួយាងទៀត ក្នុងចិត្តទាំងពីរនេះ សឧត្តរចិត្ត បានដល់ រូបាវចរចិត្ត  អនុត្តរចិត្ត បានដល់ អរូបាវចរចិត្តនោះឯង ។

បទថា **សមាហិតំ** បានដល់ ចិត្តរបស់បុគ្គលដែលមានអប្បនាសមាធិ ឬឧបចារសមាធិ ។ បទថា **អសមាហិតំ** បានដល់ ចិត្តដែលវៀរចាកសមាធិទាំងពីរ ។ បទថា **វិមុត្តំ** បានដល់ ចិត្តដែលរួចផុតហើយដោយតទង្គវិមុត្តិ និងវិក្ខម្ភនវិមុត្តិ ។

*បទថា* **អវិមុត្តំ** *បានដល់ ចិត្តដែលវៀរចាកវិមុត្តិទាំងពីរ ។ ចំណែក សមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និងនិស្សរណវិមុត្តិ មិនមានឱកាសក្នុងទីនេះ ។ បទថា* **សរាគមស្ស ចិត្តំ** *បានដល់ ចិត្តរបស់បុគ្គលនោះប្រព្រឹត្តទៅ ជាមួយរាគៈ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ព្រោះមានន័យ តាមដែលពោលមកហើយខាងដើមនោះឯង ។ ក្នុងសេចក្តីនេះ លោកពោល វិបស្សនាសុទ្ធៗ ដូច្នេះឯង ។៚*

## អដ្ឋកថាចិត្តានុបស្សនានិទ្ទេស ចប់

# អដ្ឋកថា
## ធម្មានុបស្សនានិទ្ទេស
## នីវរណបព្វៈ

[ ១៩៥-២០៣ ] ដោយពាក្យមានប្រមាណប៉ុណ្ណេះ ព្រះមានព្រះភាគទ្រង់ត្រាស់ការកំណត់រូបក្ខន្ធដោយកាយានុបស្សនា ត្រាស់ការកំណត់វេទនាខន្ធដោយវេទនានុបស្សនា ត្រាស់ការកំណត់វិញ្ញាណក្ខន្ធដោយចិត្តានុបស្សនា នោះឯង ព្រោះហេតុនោះ ឥឡូវនេះ ដើម្បីនឹងត្រាស់ការកំណត់សញ្ញាខន្ធនិងសង្ខារក្ខន្ធ ដោយកាន់យកមាតិកានៃសម្បយុត្តធម៌ សម្តែងធម្មានុបស្សនាទើបត្រាស់ថា **កថញ្ច ភិក្ខុ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **សន្តំ** បានដល់ កាលកាមច្ឆន្ទៈខាងក្នុងចិត្តមានដោយអំណាចនៃការប្រាកដរឿយៗ ។ បទថា **អសន្តំ** បានដល់ មិនមានដោយអំណាចនៃការមិនប្រាកដ ឬថា ព្រោះលះបានហើយ ។ បទថា **យថា ច** បានដល់ កាមច្ឆន្ទៈ នឹងកើតឡើងដោយហេតុណា ។ បទថា **តញ្ច បជានាតិ** បានដល់ រមែងជ្រាបច្បាស់នូវហេតុនោះ ។ គប្បីជ្រាបអត្ថក្នុងបទទាំងពួង ដោយន័យនេះឯង ។

ក្នុងបទទាំងនោះ កាមច្ឆន្ទៈកើតឡើង ព្រោះអយោនិសោមនសិការក្នុងសុភនិមិត្ត ។ ឈ្មោះថា **សុភនិមិត្ត** សូម្បីវត្ថុដែលស្អាត ក៏ជាសុភនិមិត្ត សូម្បីអារម្មណ៍ដែលស្អាតក៏ជាសុភនិមិត្ត ។

ឈ្មោះថា **អយោនិសោមនសិការ** គឺមិនមនសិការក្នុងឧបាយ

មនសិការខុសផ្លូវ គឺមនសិការក្នុងវត្ថុដែលមិនទៀង ថាទៀង ឬក្នុងវត្ថុដែលជាទុក្ខ ថាជាសុខ ឬក្នុងវត្ថុដែលមិនមែនតួខ្លួន ថាជាតួខ្លួន ឬក្នុងវត្ថុដែលមិនស្អាត ថាស្អាត ដូច្នេះ ។ កាលញុំាងមនសិការនោះឲ្យប្រព្រឹត្តទៅច្រើនក្នុងធម៌ទាំង ៤ នោះ កាមច្ឆន្ទៈរមែងកើតឡើង ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ មានតែសុភនិមិត្ត និងការធ្វើឲ្យច្រើននូវអយោនិសោមនសិការក្នុងសុភនិមិត្តនោះ នេះធម៌ជាអាហាររបស់កាមច្ឆន្ទៈ ដែលមិនទាន់កើត ឲ្យកើតឡើង ឬរបស់កាមច្ឆន្ទៈដែលកើតឡើងហើយ ឲ្យរឹងរឹតតែកើតច្រើនឡើង ដូច្នេះ ។

ម្យ៉ាងទៀត កាមច្ឆន្ទៈនោះ លះបានដោយយោនិសោមនសិការ ក្នុងអសុភនិមិត្ត ។ ឈ្មោះថា **អសុភនិមិត្ត** សូម្បីក្នុងវត្ថុដែលមិនស្អាត ក៏ជាអសុភនិមិត្ត សូម្បីអារម្មណ៍ថាមិនស្អាតក៏ជាអសុភនិមិត្ត ។ ឈ្មោះថា **យោនិសោមនសិការ** គឺមនសិការក្នុងឧបាយ មនសិការត្រូវផ្លូវ គឺមនសិការក្នុងវត្ថុដែលមិនទៀង ថាមិនទៀង ឬក្នុងវត្ថុដែលជាទុក្ខ ថាជាទុក្ខ ឬក្នុងវត្ថុដែលមិនមែនអត្តា ថាជាអនត្តា ឬក្នុងវត្ថុដែលមិនស្អាត ថាមិនស្អាត ដូច្នេះ ។ កាលញុំាងមនសិការនោះឲ្យប្រព្រឹត្តទៅច្រើនក្នុងធម៌ទាំង ៤ នោះ រមែងលះកាមច្ឆន្ទៈបាន ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ មានតែអសុភនិមិត្ត និងការធ្វើនូវយោនិសោមនសិការឲ្យច្រើន ក្នុងអសុភនិមិត្តនោះ នេះធម៌ដែល

មិនមែនជាអាហារបស់កាមច្ឆន្ទៈ ដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់កាមច្ឆន្ទៈដែលកើតហើយ ឲ្យរឹងរឹតតែកើតច្រើនឡើង ដូច្នេះ ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះនូវកាមច្ឆន្ទៈ **អសុភនិមិត្តស្ស ឧគ្គហោ** ការកាន់យកនូវនិមិត្តថាមិនស្អាត ១ **អសុភភាវនានុយោគោ** ការប្រកបរឿយៗ ក្នុងអសុភភាវនា ១ **ឥន្ទ្រិយេសុ គុត្តទ្វារតា** ភាពជាអ្នកមានទ្វារគ្រប់គ្រងហើយក្នុងឥន្ទ្រិយទាំងឡាយ ១ **ភោជនេ មត្តញ្ញុតា** ភាពជាអ្នកស្គាល់ប្រមាណក្នុងភោជន ១ **កល្យាណមិត្តតា** ភាពជាអ្នកមានកល្យាណមិត្ត ១ **សប្បាយកថា** ពោលពាក្យ ឬស្តាប់ពាក្យជាទីសប្បាយ ១ ។

ពិតហើយ កាលព្រះយោគាវចររៀនយកអសុភនិមិត្ត ១០ យ៉ាងក្តី រមែងលះកាមច្ឆន្ទៈបាន កាលចម្រើនអសុភក្តី កាលមានទ្វារដែលបិទហើយក្នុងឥន្ទ្រិយទាំងឡាយក្តី កាលជាអ្នកដឹងប្រមាណក្នុងការបរិភោគអាហារ ព្រោះកាលឱកាសនៃពំនូតបាយ ៤-៥ មាត់មាន គឺសល់ ៤-៥ មាត់ទៀតឆ្អែត ក៏ផឹកទឹកជំនួស ហើយឲ្យជីវិតប្រព្រឹត្តទៅដោយប្រក្រតីក្តី រមែងលះកាមច្ឆន្ទៈបាន ដោយហេតុនោះ ទើបលោកពោល ( ក្នុងខុទ្ទកនិកាយ ថេរគាថា ) ថា

> ភិក្ខុឈប់បរិភោគ ៤ ឬ ៥ ពំនូត ( ក្នុងកាលជិតឆ្អែត )
> ហើយគប្បីផឹកទឹក នេះជាការល្មមដល់កិរិយានៅជាសុខ នៃភិក្ខុ
> អ្នកមានចិត្តស្ងប់ទៅរក ( ព្រះនិព្វាន ) ដូច្នេះ ។

កាលសេពគប់កល្យាណមិត្តដែលត្រេកអរក្នុងអសុភភាវនា ដូចគ្នានឹងព្រះតិស្សត្ថេរដែលចម្រើនអសុភកម្មដ្ឋាន ក៏រមែងលះកាមច្ឆន្ទៈបាន ។ រមែងលះកាមច្ឆន្ទៈបានដោយសប្បាយកថា ដែលអាស្រ័យអសុភ ១០ ក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើម ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅ ដើម្បីលះកាមច្ឆន្ទៈ ដូច្នេះ ។ ភិក្ខុនោះ រមែងជ្រាបច្បាស់ថា កាមច្ឆន្ទៈដែលលះបានហើយ ដោយធម៌ទាំង ៦ ប្រការនេះ មិនកើតតទៅ ដោយអរហត្តមគ្គ ។

ព្យាបាទកើតឡើង ព្រោះអយោនិសោមនសិការក្នុងបដិឃនិមិត្ត ។ ក្នុងពាក្យទាំងនោះ សូម្បីបដិឃៈក៏ឈ្មោះថា បដិឃនិមិត្ត អារម្មណ៍ក្នុងបដិឃៈក៏ឈ្មោះថា បដិឃនិមិត្ត អយោនិសោមនសិការ មានលក្ខណៈដូចគ្នាក្នុងទីទាំងពួងនោះឯង កាលញ៉ាំងមនសិការនិមិត្តនោះឲ្យប្រព្រឹត្តទៅច្រើនក្នុងនិមិត្តនោះ ព្យាបាទរមែងកើតឡើង ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ បដិឃនិមិត្ត ( និមិត្តនាំឲ្យបង្អៀតបង្អល់ចិត្ត ) រមែងមាន ការធ្វើទុកក្នុងចិត្តខុសទំនង និងធ្វើឲ្យក្រាស់ក្រែលក្នុងបដិឃនិមិត្តនោះ នេះជាអាហារ ដែលញ៉ាំងព្យាបាទមិនទាន់កើតឡើង ឲ្យកើតឡើង ឬញ៉ាំងព្យាបាទដែលកើតឡើងហើយ ឲ្យរឹតតែកើតធំទូលាយទៅ ដូច្នេះ ។

ម្យ៉ាងទៀត ព្យាបាទនោះ លះបានដោយមេត្តាចេតោវិមុត្តិ ។ ក្នុងពាក្យទាំងនោះ អប្បនាក្តី ឧបចារៈក្តី រមែងគួរក្នុងពាក្យដែលលោកពោលថា មេត្តា

តែពាក្យថា ចេតោវិមុត្តិ បានដល់ អប្បនាប៉ុណ្ណោះ ។ យោនិសោមនសិការ មានលក្ខណៈតាមដែលពោលហើយនោះឯង ។ កាលញ៉ាំងមនសិការឲ្យប្រព្រឹត្តទៅច្រើន ក្នុងមេត្តាចេតោវិមុត្តិនោះ រមែងលះព្យាបាទបាន ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ មានតែចេតោវិមុត្តិ និងការធ្វើទុកដាក់យោនិសោមនសិការឲ្យច្រើន ក្នុងមេត្តាចេតោវិមុត្តិនោះ[1] នេះធម៌ដែលមិនមែនជាអាហាររបស់ព្យាបាទដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ព្យាបាទ ដែលកើតហើយ ឲ្យរីងរឹតតែកើតច្រើនឡើង ដូច្នេះ ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះព្យាបាទ **មេត្តា-និមិត្តស្ស ឧគ្គហោ** ការកាន់យកនិមិត្តក្នុងមេត្តា ១ **មេត្តាភាវនានុយោគោ** ការប្រកបរឿយៗ ក្នុងមេត្តាភាវនា ១ **កម្មស្សកតាបច្ចវេក្ខណា** ការពិចារណាកម្មស្សកតា គឺសត្វមានកម្មជារបស់ខ្លួន ១ **បដិសង្ខានពហុលីកតា** ការធ្វើនូវការពិចារណាឲ្យច្រើន ១ **កល្យាណមិត្តតា** ភាពជាអ្នកមានកល្យាណ-មិត្ត ១ **សប្បាយកថា** ពោលពាក្យ ឬស្តាប់ពាក្យជាទីសប្បាយ ១ ។

ពិតហើយ កាលរៀនទូវមេត្តា ដោយអំណាចនៃការផ្សាយទៅកាន់ទិស ដោយចំពោះ និងមិនចំពោះណាមួយ រមែងលះព្យាបាទបាន កាលចម្រើនមេត្តា ដោយអំណាចនៃការផ្សាយទៅកាន់ទិស ដោយចំពោះ និងមិនចំពោះ ក៏រមែងលះព្យាបាទបាន ។ កាលពិចារណាកម្មស្សកតារបស់ខ្លួន និងរបស់

---

១- បិដកខ្មែរ មានតែ ចេតោវិមុត្តិ ។

អ្នកដទៃយ៉ាងនេះថា អ្នកក្រោធនឹងគេហើយ តើនឹងធ្វើអ្វី អាចញ៉ាំងគុណ មានសីលជាដើមរបស់គេឲ្យវិនាសបានឬ អ្នកមកដោយកម្មរបស់ខ្លួន អ្នកនឹងទៅដោយកម្មរបស់ខ្លួននោះឯង មិនមែនឬ ឈ្មោះថា សេចក្តីក្រោធនឹងអ្នកដទៃ រមែងដូចគ្នានឹងបុគ្គលដែលចាប់រងើកភ្លើង ដែលប្រាសចាកអណ្តាត ចាប់នូវដុំដែកក្តៅ និងលាមកជាដើមហើយ គ្រវែងទៅកាន់អ្នកដទៃ សេចក្តីក្រោធរបស់គេ តើនឹងធ្វើអ្វី អាចញ៉ាំងគុណ មានសីលជាដើមរបស់អ្នកឲ្យវិនាសបានឬ បុគ្គលនោះមកដោយកម្មរបស់ខ្លួន ក៏នឹងទៅដោយកម្មរបស់ខ្លួនប៉ុណ្ណោះ សេចក្តីក្រោធនេះ នឹងធ្លាក់ទៅលើបុគ្គលនោះពិតប្រាកដ ដូចគ្នានឹងរបស់ដែលបុគ្គលរៀបទទួលភ្ញៀវ ហើយភ្ញៀវមិនទទួល ឬដូចបុគ្គលបាចធូលីទៅច្រាសខ្យល់ ដូច្នោះ ក៏រមែងលះព្យាបាទបាន ។ កាលតាំងនៅក្នុងការពិចារណាកម្មស្សកតាទាំងពីរយ៉ាងហើយ តាំងនៅក្នុងការពិចារណា រមែងលះព្យាបាទបាន កាលសេពគប់កល្យាណមិត្តដែលត្រេកអរក្នុងមេត្តាភាវនា ដូចគ្នានឹងព្រះអស្សគុត្តត្ថេរ រមែងលះព្យាបាទបាន ។ រមែងលះព្យាបាទបានដោយសប្បាយកថា ដែលអាស្រ័យនូវមេត្តាក្នុងឥរិយាបថទាំងឡាយ មានការឈរនិងការអង្គុយជាដើម ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះព្យាបាទ ដូច្នេះ ។ ភិក្ខុនោះរមែងជ្រាបច្បាស់ថា ព្យាបាទដែលលះដោយធម៌ទាំង ៦ ប្រការនេះ មិនកើតតទៅ ដោយអនាគាមិមគ្គ ។

ថីនមិទ្ធៈ រមែងកើតឡើង ព្រោះអយោនិសោមនសិការក្នុងធម៌ទាំង

ឡាយ មានអរតិជាដើម ។ សេចក្តីអផ្សុក ឈ្មោះថា **អរតិ** ការខ្ជិលប្រអូស ផ្លូវកាយ ឈ្មោះថា **តន្ទី** ។ ការពត់កាយ ឈ្មោះថា **វិជម្ភិកា** ។ ការស្រវឹងព្រោះភត្ត ការក្រវល់ក្រវាយព្រោះភត្ត ឈ្មោះថា **ភត្តសម្មទោ** ។ អាការរួញរានៃចិត្ត ឈ្មោះថា **ចេតសោ លីនត្តំ** ។ កាលធ្វើអយោនិសោមនសិការឲ្យប្រព្រឹត្តទៅច្រើនក្នុងធម៌ មានអរតិជាដើមនេះ ថីនមិទ្ធៈ រមែងកើតឡើង ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( សំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ សេចក្តីធុញទ្រាន់ សេចក្តីខ្ជិល មឹតពត់កាយ ពុលបាយ រួញរាចិត្តរមែងមាន ការធ្វើទុកក្នុងចិត្តខុសទំនង និងការធ្វើឲ្យក្រាស់ក្រែលក្នុងការទាំងនោះ នេះជាអាហារដែលញ៉ាំងថីនមិទ្ធៈ មិនទាន់កើតឡើងឲ្យកើតឡើង ឬញ៉ាំងថីនមិទ្ធៈដែលកើតឡើងហើយ ឲ្យរឹតតែកើតធំទូលាយទៅ ដូច្នេះ ។

ម្យ៉ាងទៀត ថីនមិទ្ធៈនោះ លះបានដោយយោនិសោមនសិការក្នុងអារម្ភធាតុជាដើម ។ សេចក្តីព្យាយាមដំបូង ឈ្មោះថា **អារម្ភធាតុ** សេចក្តីព្យាយាមដែលមានកម្លាំងច្រើនជាងអារម្ភធាតុនោះ ព្រោះកម្ចាត់នូវការខ្ជិលប្រអូសបានហើយ ឈ្មោះថា **និក្កមធាតុ** ។ សេចក្តីព្យាយាមដ៏មានកម្លាំងជាងនិក្កមធាតុនោះ ព្រោះញ៉ាំញីឋានៈដទៃៗ ឈ្មោះថា **បរក្កមធាតុ** ។ កាលញ៉ាំងមនសិការឲ្យប្រព្រឹត្តទៅច្រើនក្នុងសេចក្តីព្យាយាម ៣ ប្រភេទនេះ រមែងលះនូវថីនមិទ្ធៈបាន ដោយហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ក្នុង ( សំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ មានតែការតាំង

ផ្ដើម ការខ្នះខ្នែង ការប្រឹងប្រែង និងការធ្វើទូវយោនិសោមនសិការឲ្យច្រើន ក្នុងការតាំងផ្ដើមជាដើមនោះ នេះធម៌មិនមែនជាអាហាររបស់ថីនមិទ្ធៈ ដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ថីនមិទ្ធៈដែលកើតហើយ ឲ្យរឹងរឹតតែកើតច្រើនឡើង ដូច្នេះ ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះថីនមិទ្ធៈ គឺ **អតិភោជនេ និមិត្តគ្គាហោ** ការកាន់យកនិមិត្តក្នុងអតិភោជន គឺការបរិភោគច្រើន ១ **ឥរិយាបថសម្បរិវត្តនតា** ការផ្លាស់ប្ដូរឥរិយាបថ ១ **អាលោកសញ្ញាមនសិការោ** មនសិការក្នុងអាលោកសញ្ញា ១ **អព្ភោកាសវាសោ** ការនៅកណ្ដាលវាល ១ **កល្យាណមិត្តតា** ភាពជាអ្នកមានកល្យាណមិត្ត ១ **សប្បាយកថា** ពោលពាក្យ ឬស្ដាប់ពាក្យជាទីសប្បាយ ១ ។

កាលព្រះយោគាវចរកាន់យកនិមិត្តក្នុងអតិភោជនថា កាលភិក្ខុបរិភោគអាហារ ដូចអាហារហត្ថកព្រាហ្មណ៍ កុត្តវមិតកព្រាហ្មណ៍ តត្រវដ្ដកព្រាហ្មណ៍ អលំសាដកព្រាហ្មណ៍ កាកមាសកព្រាហ្មណ៍[១] ហើយអង្គុយបំពេញសមណធម៌ ក្នុងទីសម្រាកពេលថ្ងៃ និងពេលយប់ ថីនមិទ្ធៈ រមែងមកគ្របសង្កត់ ហាក់បីដូចត្រូវដំរីធំសង្កត់ តែភិក្ខុមានប្រក្រតីវៀរអាហារ ៤-៥ ពំនូត ហើយ

---

១- ព្រាហ្មណ៍ទី ១ បរិភោគអាហាររហូតមិនអាចក្រោកឯងបាន ត្រូវបោះដៃឲ្យអ្នកដទៃទាញក្រោកឡើង ព្រាហ្មណ៍ទី ២ បរិភោគរហូតដល់ក្អួត ព្រាហ្មណ៍ទី ៣ បរិភោគរហូតមិនអាចក្រោកឡើងបាន ដេកននៀលក្នុងទីនោះ ព្រាហ្មណ៍ទី ៤ បរិភោគរហូតប៉ោងពោះ មិនអាចស្លៀកសំពត់បាន ព្រាហ្មណ៍ទី ៥ បរិភោគរហូតបាយដល់មាត់ល្មមក្អែកចឹកបាន ។

ផឹកទឹក ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ថីនមិទ្ធៈរមែងមិនមាន រមែងលះថីនមិទ្ធៈបាន ។ ថីនមិទ្ធៈ រមែងគ្របសង្កត់ក្នុងឥរិយាបថណា កាលផ្លាស់ប្តូរឥរិយាបថដទៃអំពីនោះក្តី មនសិការពន្លឺនៃព្រះចន្ទ ពន្លឺនៃប្រទីប ពន្លឺនៃភ្លើងក្នុងពេលរាត្រី និងពន្លឺព្រះអាទិត្យក្នុងពេលថ្ងៃក្តី កាលនៅក្នុងទីវាលក្តី កាលសេពគប់កល្យាណមិត្តដែលលះថីនមិទ្ធៈ ដូចគ្នានឹងព្រះមហាកស្សបត្ថេរក្តី រមែងលះថីនមិទ្ធៈបាន រមែងលះថីនមិទ្ធៈបានដោយសប្បាយកថា ដែលអាស្រ័យធុតង្គក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើម ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះថីនមិទ្ធៈ ដូច្នេះ ។ ភិក្ខុនោះ រមែងជ្រាបច្បាស់ថា ថីនមិទ្ធៈដែលលះដោយធម៌ទាំង ៦ ប្រការនេះ មិនកើតឡើងតទៅ ដោយអរហត្តមគ្គ ។

ឧទ្ធច្ចកុក្កុច្ចៈកើតឡើង ព្រោះអយោនិសោមនសិការ ព្រោះការមិនចូលទៅស្ងប់នៃចិត្ត ។ អាការនៃចិត្តដែលមិនចូលទៅស្ងប់ ឈ្មោះថា **អវូបសម** តែបើពោលដោយអត្ថ ពាក្យថា **អវូបសម** នេះ គឺឧទ្ធច្ចកុក្កុច្ចៈនោះឯង កាលញ៉ាំងអយោនិសោមនសិការ ក្នុងឧទ្ធច្ចកុក្កុច្ចៈនោះឲ្យប្រព្រឹត្តទៅច្រើន ឧទ្ធច្ច-កុក្កុច្ចៈរមែងកើតឡើង ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ សេចក្តីមិនស្ងប់ចិត្តរមែងមាន ការធ្វើទុកក្នុងចិត្តមិនត្រូវទំនង និងការធ្វើឲ្យក្រាស់ក្រែលក្នុងរឿងនោះ នេះជាអាហារដែលញ៉ាំងឧទ្ធច្ចកុក្កុច្ចៈ មិនទាន់កើតឡើង ឲ្យកើតឡើង ឬញ៉ាំងឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើងហើយ ឲ្យរឹតតែកើតជំទូលាយទៅ ដូច្នេះ ។

ម្យ៉ាងទៀត ឧទ្ធច្ចកុក្កុច្ចៈនោះ លះបានដោយយោនិសោមនសិការ ព្រោះការស្ងប់នៃចិត្ត ពោល គឺសមាធិ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ មានតែការស្ងប់ស្ងាត់ចិត្ត និងការធ្វើទុកក្នុងចិត្តដោយយោនិសោមនសិការឲ្យច្រើន ក្នុងការស្ងប់ស្ងាត់ចិត្តនោះ នេះធម៌ដែលមិនមែនជាអាហាររបស់ឧទ្ធច្ចកុក្កុច្ចៈ ដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ឧទ្ធច្ចកុក្កុច្ចៈដែលកើតហើយ ឲ្យរឹងរឹតតែកើតច្រើនឡើង ដូច្នេះ ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះឧទ្ធច្ចកុក្កុច្ចៈ គឺ **ពហុស្សុតតា** ភាពជាពហូសូត ១ **បរិបុច្ឆកតា** ភាពជាអ្នកសាកសួរដោយជុំវិញ ១ **វិនយេ បកតញ្ញុតា** ភាពជាអ្នកជំនាញក្នុងព្រះវិន័យ ១ **វុឌ្ឍសេវិតា** គប់រកបុគ្គលដែលចម្រើន ១ **កល្យាណមិត្តតា** ភាពជាអ្នកមានកល្យាណមិត្ត ១ **សប្បាយកថា** ពោលពាក្យ ឬស្តាប់ពាក្យជាទីសប្បាយ ១ ។

ពិតហើយ កាលព្រះយោគាវចររៀន ១ និកាយ ២ និកាយ ៣ និកាយ ៤ និកាយ ៥ និកាយ ដោយអំណាចពុទ្ធវចនៈ និងដោយអំណាចអដ្ឋកថា ក៏រមែងលះឧទ្ធច្ចកុក្កុច្ចៈបាន ដោយភាពជាអ្នកស្តាប់ច្រើនក្តី កាលជាអ្នកច្រើនដោយការសាកសួរដល់វត្ថុដែលគួរ និងមិនគួរក្តី កាលជាអ្នកជំនាញក្នុងវិនយបញ្ញត្តិ ព្រោះភាពជាអ្នកជំនាញដែលខ្លួនប្រព្រឹត្តហើយក្តី កាលចូលទៅរកព្រះថេរៈដែលជាធំ ជាអ្នកចម្រើនក្តី កាលសេពគប់កល្យាណមិត្តដែលទ្រទ្រង់វិន័យ ដូចព្រះឧបាលិត្ថេរក្តី រមែងលះឧទ្ធច្ចកុក្កុច្ចៈបាន ។ រមែង

លះឧទ្ធច្ចកុក្កុច្ចៈបានដោយសប្បាយកថា ដែលអាស្រ័យវត្ថុដែលគួរ និងមិនគួរ ក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះឧទ្ធច្ចកុក្កុច្ចៈ ដូច្នេះ ។ ភិក្ខុនោះ រមែងជ្រាបច្បាស់ថា ឧទ្ធច្ចៈដែលលះដោយធម៌ទាំង ៦ ប្រការនេះ មិនកើតតទៅទៀតដោយអរហត្តមគ្គ កុក្កុច្ចៈលះបានដោយធម៌ ៦ ប្រការនេះ មិនកើតតទៅទៀត ដោយអនាគាមិមគ្គ ។

វិចិកិច្ឆាកើតឡើង ព្រោះអយោនិសោមនសិការក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃសេចក្ដីសង្ស័យ ។ វិចិកិច្ឆានោះ ព្រោះភាពជាហេតុនៃសេចក្ដីសង្ស័យរឿយៗ ទើបឈ្មោះថា ធម៌ជាទីតាំងនៃសេចក្ដីសង្ស័យ កាលធ្វើអយោនិសោមនសិការឲ្យប្រព្រឹត្តទៅច្រើន ក្នុងធម៌ដែលជាទីតាំងនៃសេចក្ដីសង្ស័យនោះ វិចិកិច្ឆារមែងកើតឡើង ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលជាទីតាំងនៃវិចិកិច្ឆា រមែងមានការធ្វើទុកក្នុងចិត្តមិនត្រូវទំនង និងការធ្វើឲ្យក្រាស់ក្រែលក្នុងធម៌ទាំងនោះ នេះជាអាហារដែលញុំាងវិចិកិច្ឆាមិនទាន់កើតឡើង ឲ្យកើតឡើង ឬញុំាងវិចិកិច្ឆាដែលកើតឡើងហើយ ឲ្យរឹតតែកើតធំទូលាយទៅ ដូច្នេះ ។

ម្យ៉ាងទៀត វិចិកិច្ឆានោះ លះបានដោយយោនិសោមនសិការក្នុងកុសលធម៌ជាដើម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ មានពួកធម៌ជា

កុសល និងអកុសល ពួកធម៌ដែលប្រកបដោយទោស និងឥតទោស ពួកធម៌ដែលថោកទាប និងថ្លៃថ្លា ពួកធម៌ជាចំណែកខ្មៅ និងស និងការធ្វើទុកយោនិសោមនសិការឲ្យច្រើន ក្នុងធម៌ទាំងនោះ នេះធម៌មិនមែនជាអាហាររបស់វិចិកិច្ឆា ដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់វិចិកិច្ឆាដែលកើតហើយ ឲ្យរឹងរឹតតែកើតច្រើនឡើង ដូច្នេះ ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះវិចិកិច្ឆា គឺ **ពហុស្សុតតា** ភាពជាពហូសូត ១ **បរិបុច្ឆកតា** ភាពជាអ្នកសាកសួរដោយជុំវិញ ១ **វិនយេ បកតញ្ញុតា** ភាពជាអ្នកជំនាញក្នុងព្រះវិន័យ ១ **អធិមោក្ខពហុលតា** ភាពជាអ្នកច្រើនដោយអធិមោក្ខ ១ **កល្យាណមិត្តតា** ភាពជាអ្នកមានកល្យាណមិត្ត ១ **សប្បាយកថា** ពោលពាក្យ ឬស្តាប់ពាក្យជាទីសប្បាយ ១ ។

ពិតហើយ កាលព្រះយោគាវចររៀន ១ និកាយ ២ និកាយ ៣ និកាយ ៤ និកាយ ៥ និកាយ ដោយអំណាចពុទ្ធវចនៈ និងដោយអំណាចអដ្ឋកថា រមែងលះវិចិកិច្ឆាបាន ដោយភាពជាអ្នកស្តាប់ច្រើនក្តី កាលប្រារព្ធនូវព្រះរតនត្រ័យ ជាអ្នកច្រើនដោយការសាកសួរក្តី ជាអ្នកជំនាញក្នុងការប្រព្រឹត្តវិន័យក្តី កាលច្រើនដោយអធិមោក្ខ ពោល គឺការជឿម៉ាំក្នុងព្រះរតនត្រ័យក្តី

កាលសេពគប់នូវកល្យាណមិត្ត ដូចគ្នានឹងព្រះថេរៈឈ្មោះវក្កលិ ដែលជាអ្នកបង្អោនទៅដោយសទ្ធាក្តី រមែងលះវិចិកិច្ឆាបាន ។ រមែងលះវិចិកិច្ឆាបានដោយសប្បាយកថា ដែលអាស្រ័យគុណរបស់ព្រះរតនត្រ័យ ក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះវិចិកិច្ឆា ដូច្នេះ ភិក្ខុនោះ រមែងជ្រាបច្បាស់ថា វិចិកិច្ឆាដែលលះបានដោយធម៌ទាំង ៦ ប្រការនេះ មិនកើតឡើងតទៅទៀត ដោយសោតាបត្តិមគ្គ ៕

**អដ្ឋកថានីវរណបព្វៈ ចប់**

# ពោជ្ឈង្គបព្វៈ

*គប្បីជ្រាបវិនិច្ឆ័យក្នុងពោជ្ឈង្គបព្វៈដូចតទៅ បទថា* **សន្តំ** *បានដល់មានដោយអំណាចនៃការបានចំពោះ ។ បទថា* **អសន្តំ** *បានដល់ មិនមានដោយអំណាចនៃការមិនបានចំពោះ ។ ក្នុងបទថា* **យថា ច អនុប្បន្នស្ស** *ជាដើម សតិសម្ពោជ្ឈង្គកើតឡើងយ៉ាងនេះ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ធម៌ជាទីតាំងនៃសតិសម្ពោជ្ឈង្គ រមែងមានការធ្វើទុកក្នុងចិត្តត្រូវទំនងនឹងធ្វើឲ្យក្រាស់ក្រែលក្នុងធម៌ទាំងនោះ នេះជាអាហារនាំសតិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ឲ្យកើតឡើង ឬនាំសតិសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ឲ្យរឹងរឹតតែចម្រើនពេញលេញឡើងបាន ដូច្នេះ ។*

*បណ្តាពាក្យទាំងនោះ សតិនោះឯង ឈ្មោះថា ធម៌ដែលជាទីតាំងនៃសតិសម្ពោជ្ឈង្គ ។ យោនិសោមនសិការ មានលក្ខណៈតាមដែលពោលហើយនោះឯង ។ កាលញ៉ាំងយោនិសោមនសិការនោះឲ្យប្រព្រឹត្តទៅច្រើនក្នុងធម៌ដែលជាទីតាំងនៃសតិសម្ពោជ្ឈង្គនោះ សតិសម្ពោជ្ឈង្គ រមែងកើតឡើង ។*

*មួយយ៉ាងទៀត ធម៌ ៤ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃសតិសម្ពោជ្ឈង្គ គឺ* **សតិសម្បជញ្ញំ** *សតិសម្បជញ្ញៈ ១* **មុដ្ឋស្សតិបុគ្គលបរិវជ្ជនតា** *ភាពជាអ្នកវៀរចាកបុគ្គលដែលមិនមានស្មារតី ១* **ឧបដ្ឋិតស្សតិបុគ្គលសេវនតា** *ភាពជាអ្នកសេពគប់បុគ្គលដែលមានស្មារតីមាំទាំ ១* **តទធិមុត្តតា** *ភាពជាអ្នកបង្អោនចិត្តទៅក្នុងសតិសម្ពោជ្ឈង្គនោះ ១ ។*

ពិតហើយ សតិសម្ពោជ្ឈង្គ រមែងកើតឡើងដោយសតិសម្បជញ្ញៈក្នុងឋានៈទាំង ៧ មានការឈានទៅខាងមុខជាដើម ដោយការវៀរបុគ្គលដែលមិនមានស្មារតី ដូចក្អែកដែលលាក់អាហារ ( ហើយក៏ភ្លេច ) ដោយការសេពគប់បុគ្គលដែលមានសតិតាំងមាំ ដូចគ្នានឹងព្រះតិស្សទត្តត្ថេរ និងព្រះអភយត្ថេរ និងដោយភាពជាអ្នកមានចិត្តបង្អោនទៅ ទោរទន់ទៅ ឈមទៅដើម្បីឲ្យសតិកើតឡើង ក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើម ។ ភិក្ខុនោះ រមែងជ្រាបច្បាស់ថា សតិសម្ពោជ្ឈង្គដែលកើតឡើងដោយហេតុ ៤ យ៉ាងនេះ រមែងចម្រើនបរិបូណ៌ដោយអរហត្តមគ្គ ។

ធម្មវិចយសម្ពោជ្ឈង្គកើតឡើងយ៉ាងនេះ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ មានពួកធម៌ជាកុសល ឬអកុសល ។បេ។ ពួកធម៌ជាចំណែកខ្មៅ ឬស និងការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញាឲ្យច្រើនក្នុងធម៌ទាំងនោះ នេះធម៌ជាអាហាររបស់ធម្មវិចយសម្ពោជ្ឈង្គ ដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ធម្មវិចយសម្ពោជ្ឈង្គ ដែលកើតហើយឲ្យចម្រើនបរិបូណ៌ ដូច្នេះ ។

ម្យ៉ាងទៀត ធម៌ ៧ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃធម្មវិចយសម្ពោជ្ឈង្គ គឺ **បរិបុច្ឆកតា** ភាពជាអ្នកសាកសួរ ១ **វត្ថុវិសទកិរិយា** ការធ្វើវត្ថុឲ្យស្អាត ១ **ឥន្ទ្រិយសមត្តបដិបាទនា** ការធ្វើឥន្ទ្រិយឲ្យស្មើគ្នា ១ **ទុប្បញ្ញបុគ្គលបរិវជ្ជនា** វៀរចាកបុគ្គលដែលមានបញ្ញាថោកថយ ១ **បញ្ញវន្តបុគ្គលសេវនា** សេពគប់បុគ្គលដែលមានបញ្ញាល្អ ១ **គម្ភីរ-**

**វញ្ញាណាចរិយបច្ចវេក្ខណា** *ពិចារណាការប្រព្រឹត្តដោយញាណដ៏ជ្រាលជ្រៅ ១* **តទធិមុត្តតា** *ជាអ្នកបង្អោនចិត្តទៅក្នុងធម្មវិចយសម្ពោជ្ឈង្គនោះ ១ ។*

*បណ្តាធម៌ទាំងនោះ ពាក្យថា ភាពជាអ្នកសាកសួរ បានដល់ ភាពជាបុគ្គលច្រើនដោយការសាកសួរអាស្រ័យអត្ថនៃខន្ធ ធាតុ អាយតនៈ ឥន្ទ្រិយ ពល ពោជ្ឈង្គ អង្គនៃមគ្គ ឈាន សមថៈ និងវិបស្សនា ។*

*ពាក្យថា ការធ្វើវត្ថុឲ្យស្អាត បានដល់ ការធ្វើវត្ថុទាំងខាងក្នុង និងខាងក្រៅឲ្យស្អាត ព្រោះថា កាលណា សក់ ក្រចក រោមទាំងឡាយរបស់ភិក្ខុនោះវែង ឬរាងកាយរបស់ភិក្ខុនោះ មានទោសច្រើន ប្រឡាក់ដោយញើសក្អែល កាលនោះ ឈ្មោះថា វត្ថុខាងក្នុងមិនស្អាត មិនបរិសុទ្ធ ។ កាលណា ចីពររបស់ភិក្ខុនោះចាស់ សៅហ្មង មានក្លិនអាក្រក់ ឬសេនាសនៈស្មោកគ្រោក កាលនោះ ឈ្មោះថា វត្ថុខាងក្រៅមិនស្អាត មិនបរិសុទ្ធ ហេតុនោះ ភិក្ខុនោះ គប្បីធ្វើវត្ថុខាងក្នុងឲ្យស្អាត ដោយការកោរសក់ជាដើម ឬដោយការធ្វើសរីរៈឲ្យស្រាល ដោយការជម្រះខាងលើ ជម្រះខាងក្រោមជាដើមដោយការងូតទឹក ។ គប្បីធ្វើវត្ថុខាងក្រៅឲ្យស្អាត មានការដេរ ការបោក ការជ្រលក់ និងការប្រោះព្រំជាដើម ព្រោះថា កាលវត្ថុខាងក្នុង និងវត្ថុខាងក្រៅណាមួយមិនស្អាត ញាណក្នុងចិត្ត និងចេតសិកដែលកើតឡើងហើយ ក៏មិនផូរផង់ មិនបរិសុទ្ធ ប្រៀបដូចពន្លឺនៃអណ្តាតប្រទីប ដែលកើតឡើងព្រោះអាស្រ័យប្រឆេះ និងប្រេងនៃគោម ឬប្រទីបដែលមិនបរិសុទ្ធ ដូច្នោះ តែបើវត្ថុខាងក្នុង និងខាងក្រៅស្អាត ញាណក្នុងចិត្ត និងចេតសិកដែលកើតឡើង*

ហើយ ក៏ផូរផង់បរិសុទ្ធ ប្រៀបដូចពន្លឺនៃអណ្ដាតប្រទីប ដែលកើតឡើង ព្រោះអាស្រ័យប្រឆេះ និងប្រេងនៃប្រទីប ដូច្នោះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ការធ្វើវត្ថុឲ្យស្អាត រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃធម្មវិចយសម្ពោជ្ឈង្គ ដូច្នេះ ។

ការធ្វើឥន្ទ្រិយទាំងឡាយ មានសទ្ធាជាដើមឲ្យស្មើគ្នា ឈ្មោះថា ការធ្វើឥន្ទ្រិយឲ្យស្មើគ្នា ។ បើសទ្ធិន្ទ្រិយរបស់ភិក្ខុនោះក្លៀវក្លា ឥន្ទ្រិយក្រៅពីនេះទន់ខ្សោយសោត ពេលនោះ វីរិយិន្ទ្រិយ ក៏មិនអាចធ្វើកិច្ច គឺផ្គងសតិន្ទ្រិយក៏មិនអាចធ្វើកិច្ចតាំងមាំ សមាធិន្ទ្រិយក៏មិនអាចធ្វើកិច្ច គឺការមិនរាយមាយ បញ្ញិន្ទ្រិយ ក៏មិនអាចធ្វើកិច្ច គឺការឃើញ ព្រោះហេតុនោះ សទ្ធិន្ទ្រិយមានកម្លាំងខ្លាំងក្លា គប្បីបន្ថយដោយការពិចារណាសភាវធម៌ ឬកាលមនសិការដោយប្រការណា សទ្ធិន្ទ្រិយមានកម្លាំង ក៏គប្បីបន្ថយដោយមិនមនសិការដោយប្រការនោះ ។ ក្នុងសេចក្ដីនេះ មានរឿងរបស់ព្រះវក្កលិត្ថេរជាឧទាហរណ៍ ។ បើវីរិយិន្ទ្រិយមានកម្លាំងសោត ពេលនោះ សទ្ធិន្ទ្រិយក៏មិនអាចធ្វើកិច្ច គឺបង្អោនចិត្តជឿបាន ឥន្ទ្រិយក្រៅអំពីនោះ ក៏មិនអាចធ្វើកិច្ចមានកិច្ចដែលក្រៅអំពីនេះ ( គឺមិនធ្វើកិច្ចរៀងៗ ខ្លួន ) ព្រោះហេតុនោះ គប្បីឲ្យវីរិយិន្ទ្រិយនោះថយចុះ ដោយការចម្រើនបស្សទ្ធិសម្ពោជ្ឈង្គជាដើម ។ ក្នុងសេចក្ដីនេះ ក៏គប្បីសម្ដែងរឿងរបស់ព្រះសោណត្ថេរជាឧទាហរណ៍ ។ សូម្បីក្នុងឥន្ទ្រិយដ៏សេស ក៏ដូច្នោះ គឺកាលឥន្ទ្រិយមួយមានកម្លាំង ក៏គប្បីជ្រាបថាឥន្ទ្រិយក្រៅអំពីនេះ មិនអាចធ្វើកិច្ចរបស់ខ្លួន ។

បើពោលដោយពិសេសក្នុងទីនេះ បណ្ឌិតទាំងឡាយសរសើរនូវការស្មើគ្នានៃសទ្ធា និងបញ្ញា នៃសមាធិ និងវីរិយៈ ព្រោះថា បុគ្គលមានសទ្ធាខ្លាំងក្លា តែបញ្ញាទន់ខ្សោយ រមែងជាអ្នកជ្រះថ្លាក្នុងវត្ថុដែលមិនមែនជាហេតុ ។ បុគ្គលមានបញ្ញាខ្លាំងក្លា បើសទ្ធាទន់ខ្សោយ រមែងធ្លាក់ទៅក្នុងចំណែកពួកនៃជនអ្នកអួតអាង រមែងជាអ្នកកែមិនបាន ហាក់បីដូចរោគធ្ងន់ ដែលកើតអំពីថ្នាំ ព្យាបាលមិនបាន ដូច្នោះ គឺមានត្រឹមតែចិត្តុប្បាទនោះឯងសុះទៅថា ជាកុសល តែមិនធ្វើបុណ្យទាំងឡាយ មានទានជាដើម រមែងកើតក្នុងនរក តែព្រោះភាពដែលឥន្ទ្រិយទាំងឡាយស្មើគ្នា ទើបបុគ្គលនោះជ្រះថ្លាក្នុងវត្ថុដែលជាហេតុនោះឯង ។ មួយវិញទៀត កោសជ្ជៈ រមែងគ្របសង្កត់បុគ្គលដែលមានសមាធិក្លៀវក្លា មានវីរិយៈទន់ខ្សោយ ព្រោះភាពដែលសមាធិជាចំណែកនៃកោសជ្ជៈ ។ ឧទ្ធច្ចៈ រមែងគ្របសង្កត់បុគ្គលដែលមានវីរិយៈខ្លាំងក្លា តែមានសមាធិទន់ខ្សោយ ព្រោះភាពដែលវីរិយៈជាបក្ខពួកនៃឧទ្ធច្ចៈ តែសមាធិដែលវីរិយៈប្រកបល្អហើយ រមែងមិនបានធ្លាក់ទៅក្នុងកោសជ្ជៈ ។ វីរិយៈដែលសមាធិប្រកបល្អហើយ ក៏រមែងមិនបានធ្លាក់ទៅក្នុងឧទ្ធច្ចៈ ព្រោះហេតុនោះ ព្រះយោគាវចរគប្បីធ្វើឥន្ទ្រិយទាំងពីរនោះឲ្យស្មើគ្នា ព្រោះថា អប្បនាកើតឡើង ព្រោះការស្មើគ្នានៃឥន្ទ្រិយទាំងពីរ ។ មួយវិញទៀត សទ្ធាដ៏មានកម្លាំងក៏រមែងគួរសម្រាប់បុគ្គលបំពេញសមាធិ គឺកាលបុគ្គលនោះ ជឿមាំទាំយ៉ាងនោះ នឹងសម្រេចអប្បនាបាន ។

ក្នុងសមាធិ និងបញ្ញា ឯកគ្គតាមានកម្លាំង ទើបគួរដល់អ្នកបំពេញ

សមាធិ ព្រោះបុគ្គលនោះ នឹងសម្រេចអប្បនាបានដោយអាការយ៉ាងនោះ ។ សម្រាប់អ្នកបំពេញវិបស្សនា បញ្ញាមានកម្លាំង ទើបគួរ ព្រោះបុគ្គលនោះ នឹងដល់នូវការចាក់ធ្លុះនូវលក្ខណៈបានដោយអាការយ៉ាងនោះ ។ តែព្រោះ សមាធិ និងបញ្ញាទាំងពីរស្មើគ្នា ទើបអប្បនាមានដោយពិត ។ ចំណែកសតិ មានកម្លាំងក្នុងទីទាំងពួង ទើបគួរ ព្រោះថា សតិរមែងរក្សាចិត្តមិនឲ្យធ្លាក់ ទៅកាន់ឧទ្ធច្ចៈ ព្រោះអំណាចនៃសទ្ធា វីរិយៈ និងបញ្ញាដែលជាចំណែកនៃ ឧទ្ធច្ចៈ និងរក្សាចិត្តមិនឲ្យធ្លាក់ទៅកាន់កោសជ្ជៈ ព្រោះសមាធិ ជាចំណែកនៃ កោសជ្ជៈ ព្រោះហេតុនោះ សតិនោះ ព្រះយោគាវចរគប្បីប្រាថ្នាក្នុងទីទាំង ពួង ដូចការផ្សំរសដោយអំបិលក្នុងសម្លទាំងពួង និងដូចអមាត្យដែលធ្វើ ការងារក្នុងរាជកិច្ចទាំងពួង ដោយហេតុនោះ ទើបលោកពោលថា សតិ ព្រះ មានព្រះភាគត្រាស់ថា ជាគុណជាត ចាំបាច់ក្នុងទីទាំងពួង ព្រោះហេតុអ្វី ព្រោះចិត្តមានសតិជាទីពឹង និងមានសតិជាគ្រឿងប្រាកដ វៀរចាកសតិហើយ ការលើក និងការសង្កត់ចិត្ត ក៏មិនមាន ។

ការវៀរឲ្យឆ្ងាយចាកបុគ្គលដែលមានបញ្ញាថោកថយ គឺមិនមានបញ្ញា ឈមចុះក្នុងប្រភេទនៃខន្ធជាដើម ឈ្មោះថា វៀរចាកបុគ្គលដែលមានបញ្ញាថោក ថយ ។ ការគប់រកបុគ្គលប្រកបដោយឧទយព្វយប្បញ្ញា ដែលកំណត់នូវ លក្ខណៈ នូវបញ្ញាល្អ ឈ្មោះថា ការសេពគប់បុគ្គលដែលមានបញ្ញា ។ ការ ពិចារណានូវប្រភេទនៃធម៌ដ៏ជ្រាលជ្រៅ ដែលប្រព្រឹត្តទៅក្នុងធម៌ដោយបញ្ញា ដ៏ជ្រាលជ្រៅ ដែលប្រព្រឹត្តទៅក្នុងធម៌ដ៏ជ្រាលជ្រៅ មានខន្ធជាដើម ឈ្មោះថា

*ការពិចារណាប្រព្រឹត្តទៅដោយញាណដែលជ្រាលជ្រៅ ។ ភាពជាអ្នកមានចិត្តបង្អោនទៅ ទោរទន់ទៅ ឈមទៅ ដើម្បីញុំាងធម្មវិចយសម្ពោជ្ឈង្គឲ្យកើតឡើងក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើម ឈ្មោះថា ការបង្អោនចិត្តទៅក្នុងធម្មវិចយសម្ពោជ្ឈង្គនោះ ។ ភិក្ខុនោះរមែងជ្រាបច្បាស់ថា ធម្មវិចយសម្ពោជ្ឈង្គនោះ ដែលកើតឡើងហើយយ៉ាងនេះ រមែងបរិបូណ៌ដោយអរហត្តមគ្គ ។*

*វីរិយសម្ពោជ្ឈង្គ រមែងកើតឡើងយ៉ាងនេះ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ធាតុ គឺសេចក្តីផ្តួចផ្តើម ធាតុ គឺសេចក្តីព្យាយាម ធាតុ គឺសេចក្តីខ្នះខ្នែង ប្រឹងប្រែង រមែងមាន ការធ្វើទុកក្នុងចិត្តត្រូវទំនងនឹងធ្វើឲ្យក្រាស់ក្រែលក្នុងធាតុទាំងនោះ នេះជាអាហារនាំវីរិយសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឲ្យកើតឡើង ឬនាំវីរិយ-សម្ពោជ្ឈង្គ ដែលកើតឡើងហើយ ឲ្យរឹងរឹតតែចម្រើនពេញលេញឡើងបាន ដូច្នេះ ។*

*ម្យ៉ាងទៀត ធម៌ ១១ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃវីរិយសម្ពោជ្ឈង្គ គឺ* **អបាយភយបច្ចវេក្ខណតា** *ភាពជាអ្នកពិចារណាភ័យក្នុងអបាយ ១* **អានិសំសទស្សាវិតា** *ភាពជាអ្នកឃើញអានិសង្សនៃសេចក្តីព្យាយាម ១* **គមនវីថិបច្ចវេក្ខណតា** *ភាពជាអ្នកពិចារណាវីថិដែលដើរទៅ ១* **បិណ្ឌបាតាបចាយនតា** *ភាពជាអ្នកប្រព្រឹត្តអើពើចំពោះបិណ្ឌបាត ១* **ទាយជ្ជមហត្តបច្ចវេក្ខណតា** *ភាពជាអ្នកពិចារណានូវភាពជាធំក្រៃលែង*

នៃភាពជាទាយាទ ១ **សត្ថុមហត្តបច្ចវេក្ខណតា** ភាពជាអ្នកពិចារណានូវភាពជាធំក្រៃលែងរបស់ព្រះសាស្តា ១ **ជាតិមហត្តបច្ចវេក្ខណតា** ភាពជាអ្នកពិចារណាភាពជាធំក្រៃលែងនៃជាតិ ១ **សព្រហ្មចារិមហត្តបច្ចវេក្ខណតា** ភាពជាអ្នកពិចារណាភាពជាធំក្រៃលែងនៃសព្រហ្មចារី ១ **កុសីតបុគ្គល-បរិវជ្ជនតា** ភាពជាអ្នកវៀរចាកបុគ្គលខ្ជិលច្រអូស ១ **អារទ្ធវីរិយបុគ្គល-សេវនតា** ភាពជាអ្នកសេពគប់បុគ្គលដែលមានសេចក្តីព្យាយាមផ្តើមហើយ ១ **តទធិមុត្តតា** ភាពជាអ្នកបង្អោនចិត្តទៅក្នុងវីរិយៈនោះ ១ ។

ក្នុងបទទាំងនោះ វីរិយសម្ពោជ្ឈង្គរមែងកើតឡើងដល់បុគ្គលពិចារណានូវភ័យក្នុងអបាយយ៉ាងនេះថា ក្នុងកាលដែលសោយទុក្ខធំ ចាប់អំពីកម្មករណៈដោយចំណង ៥ យ៉ាង ក្នុងនរកទាំងឡាយក្តី ក្នុងកាលដែលត្រូវចាប់ដោយគ្រឿងដាក់ មានអន្ទាក់ និងលបជាដើម ក្នុងកំណើតសត្វតិរច្ឆានក្តី ក្នុងកាលដែលនៅជាសត្វអូសរទេះ ត្រូវគេចាក់ដោយគ្រឿងប្រហារ មានជន្ទួញ និងបន្លាស្រួចជាដើមក្តី ក្នុងកាលដែលជាបុគ្គលស្រេកឃ្លានរាប់ពាន់ឆ្នាំជាអនេកក្តី មួយពុទ្ធន្តរក្តី ក្នុងកាលដែលសោយទុក្ខ មានត្រូវខ្យល់ ត្រូវកម្តៅថ្ងៃជាដើម ដោយអត្តភាពដែលមានត្រឹមតែឆ្អឹង និងស្បែក មានអត្តភាពធំខ្ពស់ប្រមាណ ៦០ ហត្ថ ៨០ ហត្ថ ក្នុងពួកអសុរឈ្មោះកាលកញ្ជិកក្តី មិនអាចឲ្យវីរិយ-សម្ពោជ្ឈង្គកើតឡើងបាន នៃភិក្ខុ កាលនេះឯង ជាកាលសមគួររបស់អ្នកដើម្បីធ្វើនូវសេចក្តីព្យាយាម ។

វីរិយសម្ពោជ្ឈង្គ រមែងកើតឡើងដល់បុគ្គលពិចារណាឃើញអានិសង្ស

យ៉ាងនេះថា បុគ្គលខ្ជិលច្រអូស មិនអាចបានលោកុត្តរធម៌ ៩ អ្នកមានសេចក្តីព្យាយាមប្រារព្ធហើយប៉ុណ្ណោះ ដែលអាចបាន នេះជាអានិសង្សនៃសេចក្តីព្យាយាម ។

វីរិយសម្ពោជ្ឈង្គ រមែងកើតឡើងដល់បុគ្គលពិចារណាវិថីនៃការដើរទៅយ៉ាងនេះថា ព្រះយោគាវចរនោះ គប្បីដើរទៅតាមផ្លូវដែលព្រះសម្មាសម្ពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះមហាសាវកទាំងឡាយរបស់ព្រះពុទ្ធ ដើរទៅហើយនោះឯង ព្រោះផ្លូវនេះ បុគ្គលខ្ជិលច្រអូសមិនអាចដើរទៅបាន ។

វីរិយសម្ពោជ្ឈង្គ រមែងកើតឡើងដល់បុគ្គលដែលពិចារណានូវការប្រព្រឹត្តអើពើចំពោះបិណ្ឌបាតយ៉ាងនេះថា ជនពួកណា រមែងទំនុកបម្រុងអ្នកដោយបិណ្ឌបាតជាដើម មនុស្សទាំងនោះមិនមែនញាតិ មិនមែនជាទាសកម្មកររបស់អ្នកឡើយ ទាំងមិនបានឲ្យបិណ្ឌបាតជាដើមដែលប្រណីតដល់អ្នក ដោយគិតថា ពួកយើងអាស្រ័យលោកម្ចាស់រស់នៅ ដូច្នេះ ដោយពិតនោះ គេសង្ឃឹមផលធំនៃការធ្វើរបស់ខ្លួនទើបឲ្យ សូម្បីព្រះសាស្តាក៏ទ្រង់មិនទតឃើញដោយអាការយ៉ាងនេះថា ភិក្ខុនេះ បរិភោគបច្ច័យទាំងនេះហើយ នឹងជាអ្នកមានរាងកាយរឹងមាំ នៅជាសុខ ដោយពិត ទ្រង់អនុញ្ញាតបច្ច័យទាំងឡាយដល់អ្នក ដោយទ្រង់បំណងថា ភិក្ខុនេះ បរិភោគបច្ច័យទាំងនេះហើយ ធ្វើនូវសមណធម៌ ហើយនឹងឆ្លងផុតវដ្តទុក្ខ ឥឡូវនេះ ភិក្ខុនោះខ្ជិលច្រអូស មិនប្រព្រឹត្តអើពើចំពោះបិណ្ឌបាត ព្រោះភិក្ខុដែលមានសេចក្តីព្យាយាម ដែលផ្តើមហើយប៉ុណ្ណោះ ឈ្មោះថា មានការប្រព្រឹត្តអើពើចំពោះបិណ្ឌបាត ក្នុង

សេចក្ដីនេះ មានរឿងព្រះថេរៈឈ្មោះមហាមិត្ត ជាឧទាហរណ៍ ។

បានឮថា ព្រះថេរៈអាស្រ័យក្នុងគុហារបស់អ្នកស្រែ ក្នុងស្រុកដែលជាទីគោចររបស់លោក ឧបាសិកាម្នាក់ បដិបត្តិបម្រើព្រះថេរៈដូចបុត្រ ថ្ងៃមួយឧបាសិកានោះកាលទៅព្រៃ ទើបប្រាប់ធីតាថា នែកូន អង្ករចាស់នៅក្នុងទីឈ្មោះនោះ ទឹកដោះ ទឹកដោះថ្លា ទឹកអំពៅនៅត្រង់ទីនោះ ចូរនាងចម្អិនភត្ត មួយអន្ទើដោយសប្បិ និងទឹកអំពៅប្រគេនក្នុងពេលដែលលោកម្ចាស់មិត្តៈដែលជាបងប្រុសរបស់នាងនិមន្តមក ហើយចូរនាងបរិភោគ ដូច្នេះ ។ ធីតាពោលថា ចុះម៉ែវិញបានអ្វីបរិភោគ ឧបាសិកាពោលថា ម៉ែបរិភោគភត្តដែលសល់ចម្អិនអំពីម្សិលមិញនេះជាមួយបន្លែត្រាំ កូនស្រីពោលថា ចុះពេលថ្ងៃត្រង់ ម៉ែបានអ្វីបរិភោគ មាតាពោលថា ចូរនាងយកបន្លែត្រាំដាក់ចូលក្នុងបបរចុងអង្ករដែលមានរសជូរ ហើយតម្កល់ទុកចុះ ។ ព្រះថេរៈដណ្ដប់ចីវរ នាំបាត្រចេញមក បានឮសំឡេងនោះ ទើបទូន្មានខ្លួនឯងថា បានឮថា មហាឧបាសិកាបរិភោគភត្តដែលសល់ពីម្សិលមិញ ជាមួយបន្លែត្រាំ ពេលថ្ងៃ បរិភោគបបរជូរ មួយអន្ទើដោយបន្លែត្រាំ តែឧបាសិកាប្រាប់អង្ករចាស់ជាដើម ដើម្បីប្រយោជន៍ដល់អញ មហាឧបាសិកានោះឯងមិនបានសង្ឃឹមស្រែ ចម្ការ បាយ និងសំពត់ ព្រោះអាស្រ័យអ្នកឡើយ តែឧបាសិកាប្រាថ្នាសម្បត្តិ ៣ ទើបឲ្យ អ្នកមិនអាចឲ្យសម្បត្តិទាំងនោះដល់ឧបាសិកាទេឬ ឯបិណ្ឌបាតនេះ អ្នកនៅមានរាគៈ ទោសៈ មោហៈ មិនគួរបរិភោគឡើយ កាលទូន្មានខ្លួនហើយ ក៏ដាក់បាត្រក្នុងស្បោក ដោះក្ដុំ ចូលទៅកាន់គុហារបស់អ្នកស្រែនោះឯង ដាក់

បាត្រក្រោមគ្រែ ពាក់ចីវរត្រង់ខ្សែស្បៀងហើយ អង្គុយអធិដ្ឋានព្យាយាមថា បើអញមិនសម្រេចអរហត្ត នឹងមិនចេញអំពីទីនេះឡើយ ដូច្នេះ ជាអ្នកមិនប្រមាទអស់កាលយូរ ជាភិក្ខុមាំទាំហើយ ចម្រើននូវវិបស្សនា សម្រេចអរហត្តក្នុងពេលមុនភត្តនោះឯង ជាព្រះខីណាស្រព ញញឹមហើយ អង្គុយដូចផ្កាឈូករីក ដូច្នោះ ។ ទេវតាដែលអាស្រ័យនៅត្រង់ដើមឈើ ក្បែរមាត់គុហា បន្លឺឧទានថា

បពិត្របុរសអាជានេយ្យ ខ្ញុំសូមនមស្ការលោក បពិត្របុរសដ៏ឧត្តម ខ្ញុំសូមនមស្ការលោក បពិត្រលោកនិរទុក្ខ បុគ្គលណាអស់អាសវៈហើយ បុគ្គលនោះ ជាទក្ខិណេយ្យបុគ្គល ដូច្នេះ ។

ហើយពោលបន្តថា បពិត្រលោកម្ចាស់ ស្រីចាស់ប្រគេនភិក្ខាដល់ព្រះអរហន្តដូចលោកម្ចាស់ដែលចូលទៅបិណ្ឌបាត នឹងផុតចាកទុក្ខ ដូច្នេះ ។ ព្រះថេរៈក្រោកឡើងហើយ បើកទ្វារចេញទៅ មើលពេលវេលាជ្រាបថា នៅព្រឹកនៅឡើយ ទើបកាន់បាត្រ និងចីវរចូលទៅកាន់ស្រុក ។ ទារិការៀបចំអាហារស្រេចហើយ ក៏បើកទ្វារ អង្គុយរង់ចាំមើល គិតថា បងប្រុសរបស់អញនឹងមកឥឡូវនេះ បងប្រុសរបស់អញ នឹងមកឥឡូវនេះ ។ កាលព្រះថេរៈមកដល់ទ្វារផ្ទះ ទារិកានោះក៏ទទួលបាត្រ ហើយធ្វើឲ្យពេញដោយបាយដែលលាយទឹកដោះ ផ្សំដោយសប្បិ និងទឹកអំពៅ ហើយដាក់ក្នុងដៃព្រះថេរៈ ព្រះថេរៈធ្វើអនុមោទនាថា ចូររស់នៅជាសុខចុះ ហើយចៀសចេញទៅ ស្ដ្រីទារិកានោះ ក៏ឈរមើលព្រះថេរៈ ។

ក្នុងវេលានោះ ពណ៌សម្បុររបស់ព្រះថេរៈបរិសុទ្ធក្រៃពេក ឥន្រ្ទិយទាំងឡាយថ្លូវផង់ ទឹកមុខក៏ថ្លា ដូចផ្លែត្នោតទុំដែលជ្រុះអំពីធ្លាយ ដូច្នោះ ។ មហាឧបាសិកា ត្រឡប់មកអំពីព្រៃ សួរធីតាថា នែកូន បងប្រុសរបស់នាងមកហើយឬ ធីតានោះបានប្រាប់ការប្រព្រឹត្តទៅទាំងពួងនោះ មហាឧបាសិកាជ្រាបថា ថ្ងៃនេះ កិច្ចនៃបព្វជិតរបស់កូនអញ ដល់ទីបំផុតហើយ ទើបពោលថា នែកូន បងប្រុសរបស់នាងត្រេកអរក្រៃលែង មិននឿយណាយក្នុងព្រះពុទ្ធសាសនា ។

វិរិយសម្ពោជ្ឈង្គ រមែងកើតឡើងដល់បុគ្គលពិចារណាភាពក្រៃលែងនៃភាពជាទាយាទថា ឈ្មោះថា មត៌ករបស់ព្រះសាស្តា គឺអរិយទ្រព្យទាំង ៧ នោះ ធំក្រៃលែង មត៌កនោះ ដែលបុគ្គលខ្ជិលច្រអូសមិនអាចទទួលបានទេ ដូចមាតាបិតា ធ្វើបុត្រដែលបដិបត្តិខុស ឲ្យមានខាងក្រៅថា បុគ្គលនេះ មិនមែនកូនរបស់ខ្ញុំ បុត្រនោះ រមែងមិនបានមត៌ក ដោយកាលដែលអនិច្ចកម្មទៅនៃមាតាបិតា យ៉ាងណា បុគ្គលខ្ជិលច្រអូសក៏យ៉ាងនោះ រមែងមិនបានមត៌ក គឺអរិយទ្រព្យនេះ បុគ្គលមានសេចក្តីព្យាយាមប្រារព្ធហើយនោះឯង ទៅបានដូច្នេះ ។

វិរិយសម្ពោជ្ឈង្គ រមែងកើតឡើងដល់បុគ្គលពិចារណានូវភាពជាធំរបស់ព្រះសាស្តាយ៉ាងនេះថា ព្រះសាស្តារបស់អ្នកធំក្រៃលែង លោកធាតុមួយម៉ឺនក៏ញាប់ញ័រ ក្នុងពេលដែលព្រះសាស្តារបស់អ្នក ទ្រង់បដិសន្ធិក្នុងគភ៌មាតា សូម្បីក្នុងពេលទ្រង់ចេញបួស ក្នុងពេលត្រាស់ដឹង ក្នុងពេលសម្តែងធម្មចក្រ

ក្នុងពេលធ្វើយមកប្បាដិហារ្យ ក្នុងកាលយាងចុះអំពីទេវលោក ក្នុងកាលដាក់ព្រះជន្មាយុសង្ខារ ក្នុងកាលបរិនិព្វានសោត ការដែលអ្នកបួស ក្នុងសាសនារបស់ព្រះសាស្តាបែបនេះហើយ ជាអ្នកខ្ជិលច្រអូស គួរឬ ដូច្នេះ ។

វិរិយសម្ពោជ្ឈង្គ រមែងកើតឡើងដល់បុគ្គលពិចារណានូវភាពជាធំនៃជាតិយ៉ាងនេះថា បើពោលដោយជាតិ ឥឡូវនេះ អ្នកមិនមែនជាជាតិថោកថយ គឺប្រសូតក្នុងព្រះរាជវង្សរបស់ព្រះបាទឱក្កាករាជ ដែលមកដោយមហាសម្មតិវង្ស ដែលមិនលាយឡំដោយវង្សដទៃ ជាចៅរបស់ព្រះបាទសិរិសុទ្ធោទនមហារាជ និងព្រះនាងមហាមាយាទេវី ជាប្អូនរបស់ព្រះរាហុលកុមារ ការដែលអ្នកជារាជបុត្ររបស់ព្រះជិនសីហៈបែបនោះ ហើយជាអ្នកខ្ជិលច្រអូសសមគួរហើយឬ ។

វិរិយសម្ពោជ្ឈង្គ រមែងកើតឡើងដល់បុគ្គលដែលពិចារណានូវភាពជាធំនៃសព្រហ្មចារីយ៉ាងនេះថា ព្រះសារីបុត្ត ព្រះមោគ្គល្លាន ព្រះអសីតិមហាសាវកទាំងឡាយ ចាក់ធ្លុះនូវលោកុត្តរធម៌បានដោយសេចក្តីព្យាយាមប៉ុណ្ណោះ ខ្លួនអ្នកប្រព្រឹត្តទៅតាមផ្លូវរបស់សព្រហ្មចារីទាំងនោះ ឬមិនប្រព្រឹត្តទៅទេ ។

វិរិយសម្ពោជ្ឈង្គ រមែងកើតឡើងដល់បុគ្គលដែលវៀរអ្នកខ្ជិលច្រអូស គឺលះបង់នូវសេចក្តីព្យាយាមផ្លូវកាយ និងចិត្ត ដូចពស់ថ្លាន់លេបចំណី រួចដេក ដល់អ្នកសេពគប់បុគ្គលអ្នកប្រារព្ធសេចក្តីព្យាយាម មានខ្លួនបញ្ជូនទៅហើយ មានចិត្តបង្អោនទៅ ទោរទន់ទៅ ឈមទៅ ដើម្បីឲ្យវិរិយៈកើតឡើងក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើម ។ កិច្ចនោះ

ជ្រាបច្បាស់ថា វីរិយសម្ពោជ្ឈង្គនោះ កើតឡើងហើយយ៉ាងនេះ រមែងចម្រើនបរិបូណ៌ដោយអរហត្តមគ្គ ។

បីតិសម្ពោជ្ឈង្គកើតឡើងយ៉ាងនេះ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ធម៌ជាទីតាំងនៃបីតិសម្ពោជ្ឈង្គ រមែងមានការធ្វើទុកក្នុងចិត្តត្រូវទំនង និងធ្វើឲ្យក្រាស់ក្រែល ក្នុងធម៌ទាំងនោះ នេះជាអាហារនាំបីតិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ឲ្យកើតឡើង ឬនាំបីតិសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យចម្រើនធំទូលាយ ពេញបរិបូណ៌ក្រៃលែងឡើងដូច្នេះ ។

ក្នុងសេចក្ដីនោះ បីតិនោះឯង ឈ្មោះថា ធម៌ជាទីតាំងនៃបីតិសម្ពោជ្ឈង្គ ការធ្វើទុកក្នុងចិត្តដើម្បីឲ្យបីតិនោះកើតឡើង ឈ្មោះថា យោនិសោមនសិការ ។

ម្យ៉ាងទៀត ធម៌ ១១ ប្រការ ប្រព្រឹត្តទៅដើម្បីការកើតឡើងនៃបីតិសម្ពោជ្ឈង្គ គឺ **ពុទ្ធានុស្សតិ** រឭកដល់គុណព្រះពុទ្ធ ១ **ធម្មានុស្សតិ** រឭកដល់គុណព្រះធម៌ ១ **សង្ឃានុស្សតិ** រឭកដល់គុណព្រះសង្ឃ ១ **សីលានុស្សតិ** រឭកដល់គុណរបស់សីល ១ **ចាគានុស្សតិ** រឭកដល់គុណរបស់ទាន ១ **ទេវតានុស្សតិ** រឭកដល់គុណរបស់ទេវតា ១ **ឧបសមានុស្សតិ** រឭកដល់គុណរបស់សេចក្ដីស្ងប់ គឺព្រះនិព្វាន ១ **លូខបុគ្គលបរិវជ្ជនតា** ភាពជាអ្នកវៀរចាកបុគ្គលដែលមានចិត្តសៅហ្មង ១ **សិនិទ្ធបុគ្គលសេវនតា** ភាពជាអ្នកគប់រកបុគ្គលដែលមានចិត្តផូរផង់ ១ **បសាទនីយសុត្តន្តបច្ចវេក្ខណតា** ភាពជាអ្នកពិចារណាព្រះសូត្រ ដែលជាទីតាំងនៃសេចក្ដី

ជ្រះថ្លា ១ **តទធិមុត្តតា** ភាពជាអ្នកបង្អោនចិត្តទៅក្នុងបីតិសម្ពោជ្ឈង្គនោះ ១ ។

ពិតហើយ កាលរឭកដល់គុណរបស់ព្រះពុទ្ធ បីតិសម្ពោជ្ឈង្គក៏នឹងកើតផ្សាយទៅពេញសរីរៈទាំងមូល រហូតដល់ឧបចារសមាធិ ។ កាលរឭកដល់គុណរបស់ព្រះធម៌ និងព្រះសង្ឃ ក៏ដូចគ្នា ។ កាលបព្វជិតពិចារណាចតុប្បារិសុទ្ធិសីល ដែលរក្សាមិនឲ្យពព្រុសពពាលអស់កាលយូរក្តី កាលគ្រហស្ថពិចារណាសីល ៥ សីល ១០ ក្តី បីតិសម្ពោជ្ឈង្គរមែងកើតឡើង កាលបព្វជិតពិចារណាដល់ចាគៈថា អញបានឲ្យភោជនដ៏ប្រណីត ដល់សព្រហ្មចារីក្នុងកាលកើតទុព្ភិក្ខភ័យជាដើមក្តី គ្រហស្ថកាលពិចារណាដល់ទាន ដែលឲ្យហើយ ដល់អ្នកមានសីលក្នុងកាលបែបនោះក្តី បីតិសម្ពោជ្ឈង្គ រមែងកើតឡើង ។ ទេវតាប្រកបដោយគុណទាំងឡាយណា រមែងដល់ភាពជាទេវតា កាលពិចារណានូវភាពដែលគុណទាំងឡាយបែបនោះមានក្នុងខ្លួន បីតិសម្ពោជ្ឈង្គ ក៏កើតឡើង ។ កាលកិលេសដែលសង្កត់ហើយដោយសមាបត្តិថា កិលេសទាំងឡាយមិនកើតឡើងអស់ ៦០ ឆ្នាំខ្លះ ៧០ ឆ្នាំខ្លះ ដូច្នេះក្តី បីតិសម្ពោជ្ឈង្គរមែងកើតឡើង កាលវៀរបុគ្គលដែលមានចិត្តសៅហ្មង គឺបុគ្គលមានសេចក្តីសៅហ្មងដែលសន្សំហើយ ដោយមិនធ្វើនូវការគោរពក្នុងការមើលព្រះចេតិយ មើលដើមពោធិ៍ និងមើលព្រះថេរៈ ដូចគ្នានឹងធូលីលើខ្នងលា ព្រោះមិនមានសេចក្តីជ្រះថ្លា ស្រឡាញ់ក្នុងព្រះពុទ្ធជាដើមក្តី កាលសេពគប់បុគ្គលដែលមានចិត្តផូរផង់ មានចិត្តទន់ភ្លន់ ច្រើនទៅដោយសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធជាដើមក្តី បីតិសម្ពោជ្ឈង្គ រមែងកើតឡើង ។ កាលពិចារណាព្រះសូត្រ

ដែលជាទីតាំងនៃសេចក្ដីជ្រះថ្លា ដែលសម្ដែងដល់គុណរបស់ព្រះរតនត្រ័យ បីតិសម្ពោជ្ឈង្គរមែងកើតឡើង កាលមានចិត្តបង្អោនទៅ ទោរទន់ទៅ ឈមទៅដើម្បីឲ្យបីតិកើតឡើងក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើម បីតិសម្ពោជ្ឈង្គក៏កើតឡើង ភិក្ខុនោះ រមែងជ្រាបច្បាស់ថា បីតិសម្ពោជ្ឈង្គកើតឡើងហើយយ៉ាងនេះ រមែងបរិបូណ៌ដោយអរហត្តមគ្គ ។

បស្សទ្ធិសម្ពោជ្ឈង្គកើតឡើងយ៉ាងនេះ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ សេចក្ដីស្ងប់កាយ សេចក្ដីស្ងប់ចិត្ត រមែងមានការធ្វើទុកក្នុងចិត្តត្រូវទំនង និងធ្វើឲ្យក្រាស់ក្រែលក្នុងសេចក្ដីស្ងប់ទាំងនោះ នេះជាអាហារនាំបស្សទ្ធិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ឲ្យកើតឡើង ឬនាំបស្សទ្ធិសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យចម្រើនជំទូលាយពេញបរិបូណ៌ក្រៃលែងឡើង ដូច្នេះ ។

ម្យ៉ាងទៀត ធម៌ ៧ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃបស្សទ្ធិសម្ពោជ្ឈង្គ គឺ **បណីតភោជនសេវនតា** ភាពជាអ្នកសេពភោជនដែលប្រណីត ១ **ឧតុសុខសេវនតា** ភាពជាអ្នកសេពឧតុជាទីសប្បាយ ១ **ឥរិយាបថសុខសេវនតា** ភាពជាអ្នកសេពឥរិយាបថជាទីសប្បាយ ១ **មជ្ឈត្តបយោគតា** ភាពជាអ្នកប្រកបសេចក្ដីព្យាយាមជាកណ្ដាល ១ **សារទ្ធកាយបុគ្គលបរិវជ្ជនតា** ភាពជាអ្នកវៀរបុគ្គលដែលមានកាយសោប់សល់ ១ **បស្សទ្ធិកាយបុគ្គលសេវនតា** ភាពជាអ្នកសេពគប់បុគ្គល ដែលមានចិត្តស្ងប់ ១ **តទធិមុត្តតា** ភាពជាអ្នកបង្អោនចិត្តទៅក្នុងបស្សទ្ធិ-

សម្ពោជ្ឈង្គនោះ ១ ។

ពិតហើយ កាលបរិភោគភោជនដែលជាសប្បាយ ប្រណីត ជាទីពេញចិត្តក្តី កាលសេពនូវឧតុដែលជាទីសប្បាយក្នុងរដូវទាំងឡាយដែលរងា និងក្តៅក្តី កាលសេពឥរិយាបថដែលជាសប្បាយ ក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើមក្តី បស្សទ្ធិសម្ពោជ្ឈង្គរមែងកើតឡើង តែបុគ្គលណា មានជាតិជាមហាបុរស រមែងជាអ្នកអត់ធន់ក្នុងឧតុ និងឥរិយាបថទាំងពួងនោះឯង លោកមិនបានពោលសំដៅយកបុគ្គលដែលមានជាតិជាមហាបុរសនោះឡើយ ។ បុគ្គលណា មានសភាពត្រូវចំណែកគ្នា និងមិនត្រូវចំណែកគ្នា កាលបុគ្គលនោះឯង វៀរឧតុ និងឥរិយាបថដែលមិនត្រូវចំណែកគ្នា ហើយសេពឧតុ និងឥរិយាបថដែលត្រូវចំណែកគ្នា បស្សទ្ធិសម្ពោជ្ឈង្គរមែងកើតឡើង ។ ការពិចារណានូវកម្មស្សកតារបស់ខ្លួនផងអ្នកដទៃផង លោកហៅថា ការប្រកបសេចក្តីព្យាយាមជាកណ្តាល បស្សទ្ធិសម្ពោជ្ឈង្គ រមែងកើតដោយសេចក្តីព្យាយាមដែលជាកណ្តាលនេះ ។ បុគ្គលណាបៀតបៀនអ្នកដទៃដោយដុំថ្មជាដើម កាលវៀរបុគ្គលដែលមានកាយរសាប់រសល់បែបនេះ បស្សទ្ធិសម្ពោជ្ឈង្គ រមែងកើតឡើង ។ កាលសេពគប់បុគ្គលដែលមានកាយស្ងប់ហើយ មានដៃ និងជើងសង្រួមហើយ បស្សទ្ធិសម្ពោជ្ឈង្គ រមែងកើតឡើង កាលមានចិត្តបង្អោនទៅ ទោរទន់ទៅ ឈមទៅដើម្បីឲ្យបស្សទ្ធិកើតក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើម ។ បស្សទ្ធិសម្ពោជ្ឈង្គ រមែងកើតឡើង ភិក្ខុនោះ រមែងជ្រាបច្បាស់

ថា បស្សទ្ធិសម្ពោជ្ឈង្គនោះ ដែលកើតឡើងហើយយ៉ាងនេះ រមែងបរិបូណ៌ដោយអរហត្តមគ្គ ។

សមាធិសម្ពោជ្ឈង្គកើតឡើងយ៉ាងនេះ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ហេតុនៃការតាំងចិត្តមាំ ហេតុមិនរាយមាយ រមែងមានការធ្វើទុកក្នុងចិត្តត្រូវទំនង និងការធ្វើឲ្យក្រាស់ក្រែលក្នុងហេតុទាំងនោះ នេះជាអាហារនាំសមាធិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើងឲ្យកើតឡើង ឬនាំសមាធិសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យចម្រើនធំទូលាយ ពេញបរិបូណ៌ក្រៃលែងឡើង ដូច្នេះ ។ ក្នុងសេចក្តីនេះ សមថៈនោះឈ្មោះថា សមថនិមិត្ត និងឈ្មោះថា អព្យគ្គនិមិត្ត ព្រោះអត្ថថា មិនរាយមាយ ។

ម្យ៉ាងទៀត ធម៌ ១១ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃសមាធិសម្ពោជ្ឈង្គ គឺ **វត្ថុវិសទកិរិយតា** ភាពជាអ្នកធ្វើវត្ថុឲ្យស្អាត ១ **ឥន្ទ្រិយសមត្តបដិបាទនតា** ភាពជាអ្នកធ្វើឥន្ទ្រិយឲ្យស្មើគ្នា ១ **និមិត្តកុសលតា** ភាពជាអ្នកឈ្លាសក្នុងនិមិត្ត ១ **សមយេ ចិត្តស្ស បគ្គណ្ហនតា** ភាពជាអ្នកលើកចិត្តក្នុងសម័យ ១ **សមយេ ចិត្តស្ស និគ្គហណនតា** ភាពជាអ្នកសង្កត់ចិត្តក្នុងសម័យ ១ **សមយេ សម្បហំសនតា** ភាពជាអ្នកឲ្យចិត្តត្រេកអរក្នុងសម័យ ១ **សមយេ អជ្ឈុបេក្ខណតា** ភាពជាអ្នកដាក់ចិត្តព្រងើយក្នុងសម័យ ១ **អសមាហិតបុគ្គលបរិវជ្ជនតា** ភាពជាអ្នកវៀរបុគ្គលដែលមានចិត្តមិនតាំងមាំ ១ **សមាហិតបុគ្គលសេវនតា** ភាពជាអ្នក

សេពគប់បុគ្គលដែលមានចិត្តតាំងមាំ ១ **ឈានវិមោក្ខបច្ចវេក្ខណតា** ភាពជាអ្នកពិចារណាឈានវិមោក្ខ ១ **តទធិមុត្តតា** ភាពជាអ្នកបង្អោនចិត្តទៅក្នុងសមាធិសម្ពោជ្ឈង្គនោះ ១ ។

ក្នុងធម៌ទាំងនោះ ពាក្យថា ភាពជាអ្នកធ្វើវត្ថុឲ្យស្អាត និងភាពជាអ្នកធ្វើឥន្ទ្រិយឲ្យស្មើគ្នា គប្បីជ្រាបដោយន័យដែលពោលហើយនោះឯង ។ ភាពជាអ្នកឈ្លាសក្នុងការរៀនកសិណនិមិត្ត ឈ្មោះថា ភាពជាអ្នកឈ្លាសក្នុងនិមិត្ត ។ ពាក្យថា ភាពជាអ្នកលើកចិត្តក្នុងសម័យ គឺសម័យណាចិត្តរួញរាដោយការព្យាយាមធូរថយជាដើម សម័យនោះ ត្រូវលើកចិត្តនោះឲ្យតាំងឡើងដោយធម្មវិចយសម្ពោជ្ឈង្គ វីរិយសម្ពោជ្ឈង្គ និងបីតិសម្ពោជ្ឈង្គ ។ ពាក្យថា ភាពជាអ្នកសង្កត់ចិត្តក្នុងសម័យ គឺក្នុងសម័យណាចិត្តរាយមាយដោយការប្រារព្ធព្យាយាមច្រើនពេកជាដើម សម័យនោះ ត្រូវសង្កត់ចិត្តនោះឲ្យតាំងឡើងដោយបស្សទ្ធិសម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គ និងឧបេក្ខាសម្ពោជ្ឈង្គ ។ ពាក្យថា ភាពជាអ្នកឲ្យចិត្តត្រេកអរក្នុងសម័យ គឺក្នុងសម័យណា ចិត្តមិនមានអស្សាទៈ ព្រោះភាពជាអ្នកប្រកបដោយបញ្ញាទន់ខ្សោយ ឬព្រោះមិនសម្រេចសេចក្តីសុខ ដែលកើតអំពីការចូលទៅស្ងប់ ក្នុងសម័យនោះ ត្រូវដាស់តឿនចិត្តដោយការពិចារណាសង្វេគវត្ថុ ៨ ប្រការ ។ ឈ្មោះថា សង្វេគវត្ថុ ៨ គឺជាតិ ជរា ព្យាធិ មរណៈ រួមជា ៤ អបាយទុក្ខជាទី ៥ វដ្តមូលកទុក្ខក្នុងអតីតជាទី ៦ វដ្តមូលកទុក្ខក្នុងអនាគតជាទី ៧ អាហារបរិយេដ្ឋិមូលកទុក្ខក្នុងបច្ចុប្បន្នជាគម្រប់ ៨ និងធ្វើសេចក្តីជ្រះថ្លាឲ្យកើតឡើង

ដោយការរឭកដល់គុណព្រះរតនត្រ័យ នេះហៅថា ភាពជាអ្នកឲ្យចិត្តត្រេកអរក្នុងសម័យ ។ ឈ្មោះថា ភាពជាអ្នកដាក់ចិត្តព្រងើយក្នុងសម័យ គឺក្នុងសម័យណា ចិត្តអាស្រ័យកិច្ចបដិបត្តិដោយប្រពៃ មិនរួញរា មិនរាយមាយ មានអស្សាទប្រព្រឹត្តទៅល្អក្នុងអារម្មណ៍ ក្នុងសមថវិថី ក្នុងសម័យនោះ មិនចាំបាច់ខ្វល់ខ្វាយក្នុងការលើកចិត្ត ការសង្កត់ចិត្ត និងការញុំាងចិត្តឲ្យត្រេកអរប្រៀបដូចសារថី មិនចាំបាច់ខ្វល់ខ្វាយក្នុងសេះទាំងឡាយ ដែលរត់ទៅល្អហើយដូច្នោះ នេះលោកហៅថា ភាពជាអ្នកដាក់ចិត្តព្រងើយក្នុងសម័យ ។ ឈ្មោះថា ភាពជាអ្នកវៀរបុគ្គលដែលមានចិត្តមិនតាំងមាំ គឺការវៀរឆ្ងាយចាកបុគ្គលដែលមានចិត្តរាយមាយ ដែលមិនសម្រេចឧបចារៈ ឬអប្បនា ។ ឈ្មោះថា ភាពជាអ្នកសេពគប់បុគ្គលដែលមានចិត្តតាំងមាំ គឺការសេព ការគប់រក ការចូលទៅសេពគប់បុគ្គលដែលមានចិត្តតាំងមាំដោយឧបចារៈ ឬអប្បនា ។ ឈ្មោះថា ភាពជាអ្នកបង្អោនចិត្តទៅក្នុងសមាធិសម្ពោជ្ឈង្គនោះ គឺភាពជាអ្នកមានចិត្តបង្អោនទៅ ទោរទន់ទៅ ឈមទៅដើម្បីឲ្យសមាធិកើតឡើង ក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើម ព្រោះសមាធិ-សម្ពោជ្ឈង្គនោះ រមែងកើតឡើងដោយកិច្ចបដិបត្តិយ៉ាងនេះ ។ ភិក្ខុនោះជ្រាបច្បាស់ថា សមាធិសម្ពោជ្ឈង្គនោះ កើតឡើងហើយយ៉ាងនេះ រមែងបរិបូណ៌ដោយអរហត្តមគ្គ ។

ឧបេក្ខាសម្ពោជ្ឈង្គ កើតឡើងយ៉ាងនេះ ( ក្នុងសំយុត្តនិកាយ មហា-វារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ធម៌ជាទីតាំងនៃឧបេក្ខាសម្ពោជ្ឈង្គ រមែង

មានការធ្វើទុកក្នុងចិត្តត្រូវទំនង និងការធ្វើឲ្យក្រាស់ក្រែលក្នុងធម៌ទាំងនោះ នេះជាអាហារនាំឧបេក្ខាសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ឲ្យកើតឡើង ឬនាំឧបេក្ខាសម្ពោជ្ឈង្គដែលកើតឡើងហើយ ឲ្យចម្រើនធំទូលាយ ពេញបរិបូណ៌ក្រៃលែងឡើង ដូច្នេះ ។ ក្នុងសេចក្តីនោះ ឧបេក្ខានោះឯង ឈ្មោះថា ធម៌ជាទីតាំងនៃឧបេក្ខាសម្ពោជ្ឈង្គ ។

ម្យ៉ាងទៀត ធម៌ ៥ ប្រការ ប្រព្រឹត្តទៅដើម្បីការកើតឡើងនៃឧបេក្ខា-សម្ពោជ្ឈង្គ គឺ **សត្តមជ្ឈត្តតា** ភាពជាអ្នកព្រងើយក្នុងសត្វ ១ **សង្ខារ-មជ្ឈត្តតា** ភាពជាអ្នកព្រងើយក្នុងសង្ខារ ១ **សត្តសង្ខារកេលាយន-បុគ្គលបរិវជ្ជនតា** ភាពជាអ្នកវៀរបុគ្គលដែលប្រកាន់សត្វ និងសង្ខារ ១ **សត្តសង្ខារមជ្ឈត្តបុគ្គលសេវនតា** ភាពជាអ្នកសេពគប់បុគ្គលដែលព្រងើយក្នុងសត្វ និងសង្ខារ ១ **តទធិមុត្តតា** ភាពជាអ្នកបង្អោនចិត្តទៅក្នុងឧបេក្ខា-សម្ពោជ្ឈង្គនោះ ១ ។

បណ្តាធម៌ទាំងនោះ ព្រះយោគាវចររមែងធ្វើការព្រងើយក្នុងសត្វ ឲ្យតាំងឡើង ដោយអាការ ២ យ៉ាង គឺដោយការពិចារណាកម្មស្សកតាយ៉ាងនេះថា ខ្លួនអ្នកមកដោយកម្មរបស់ខ្លួន ហើយក៏នឹងទៅដោយកម្មរបស់ខ្លួននោះឯង បុគ្គលនេះក៏មកដោយកម្មរបស់ខ្លួន ហើយក៏នឹងទៅដោយកម្មរបស់ខ្លួនដូចគ្នា អ្នកជាប់ជំពាក់ក្នុងអ្នកណា និងដោយការពិចារណាភាពមិនមែនជាសត្តយ៉ាងនេះថា ពោលដោយបរមត្ថ សត្វមិនមានឡើយ អ្នកជាប់ជំពាក់ក្នុងអ្នកណាហ្ន៎ ។

ព្រះយោគាវចរ រមែងធ្វើនូវការព្រងើយក្នុងសង្ខារ ឲ្យតាំងឡើងដោយអាការ ២ យ៉ាង គឺដោយការពិចារណាភាពជាវត្ថុ ដែលមិនមានម្ចាស់យ៉ាងនេះថា ចីវរនេះ ចូលដល់ការប្រែប្រួលទៅនៃពណ៌ និងចូលដល់ភាពជារបស់ចាស់ជាំគ្រាំគ្រា ដោយលំដាប់ ។ ហើយនឹងក្លាយជាកំណាត់សំពត់សម្រាប់ជូតជើង ហើយក៏នឹងជាវត្ថុដែលគេគប្បីយកចុងឈើច្រត់ក្តិះចោល បើម្ចាស់របស់ចីវរនោះគប្បីមានសោត ម្ចាស់របស់ចីវរនោះ ក៏មិនគប្បីឲ្យចីវរនោះវិនាសទៅយ៉ាងនេះ និងដោយការពិចារណាភាពជារបស់មួយជួរខណៈយ៉ាងនេះថា ចីវរនេះមិនស្ថិតស្ថេរ ជារបស់មួយជួរខណៈ ។ មួយ៉ាងទៀត ក្នុងចីវរយ៉ាងណា គប្បីធ្វើការប្រកបក្នុងបរិក្ខារទាំងឡាយ មានបាត្រជាដើម ក៏យ៉ាងនោះចុះ ។

ក្នុងពាក្យថា ភាពជាអ្នកវៀរបុគ្គលដែលប្រកាន់សត្វ និងសង្ខារ អធិប្បាយថា បុគ្គលណាជាគ្រហស្ថ រមែងប្រកាន់នូវកូនប្រុសស្រីជាដើម របស់ខ្លួននោះឯងថា ជារបស់អញ បើជាបព្វជិត រមែងប្រកាន់អន្តេវាសិក និងបុគ្គលដែលរួមឧបជ្ឈាយ៍ជាដើមរបស់ខ្លួននោះឯងថា ជារបស់អញ បុគ្គលនោះរមែងធ្វើកិច្ចទាំងឡាយ មានការកោរសក់ ដេរចីវរ បោក ជ្រលក់ និងការអប់បាត្រជាដើម ឲ្យដល់ជនទាំងនោះដោយដៃរបស់ខ្លួននោះឯង កាលមិនឃើញជនដែលជាទីស្រឡាញ់នោះ សូម្បីតែមួយស្របក់ក៏គិតថា សាមណេររូបនោះទៅណា ភិក្ខុរូបនោះទៅណា ហើយនឹងសម្លឹងរកមើលក្នុងទីផ្សេងៗ ដូចម្រឹគស្មាន់ បែរទៅខាងនោះខាងនេះ សម្លឹងមើល ក្រែងមានភ័យ សូម្បីត្រូវបុគ្គលដទៃសូមថា សូមលោកម្ចាស់បញ្ជូនអ្នកនេះ មកដើម្បីជួយ

ប្រយោជន៍ក្នុងការកោរសក់ជាដើមបានមួយស្របក់ ដូច្នេះ ក៏មិនឲ្យដោយពោលថា សូម្បីពួកយើងគង់មិនឲ្យបុគ្គលនោះធ្វើការងារដើម្បីពួកយើង អ្នកនាំគេទៅឲ្យលំបាក នេះឈ្មោះថា ការប្រកាន់សត្វ ។

ចំណែកបុគ្គលណា រមែងប្រកាន់វត្ថុទាំងឡាយ មានចីវរ បាត្រ ផ្តិល និងឈើប្រត់មនុស្សប្រាស់ជាដើមថាជារបស់អញ បុគ្គលនោះ រមែងមិនឲ្យបុគ្គលដទៃពាល់ត្រូវសូម្បីដោយដៃ កាលអ្នកដទៃសូមខ្ចីម្តងម្កាល ក៏ពោលថា សូម្បីខ្ញុំក៏ថ្នមវត្ថុនេះ មិនហ៊ានប្រើប្រាស់ ខ្ញុំនឹងឲ្យលោកបានដូចម្តេច នេះឈ្មោះថា ការប្រកាន់សង្ខារ ។

តែបុគ្គលណាដាក់ខ្លួនជាកណ្តាល គឺព្រងើយក្នុងវត្ថុទាំងពីរនោះ នេះឈ្មោះថា ព្រងើយក្នុងសត្វ និងសង្ខារ ។

ឧបេក្ខាសម្ពោជ្ឈង្គនេះ រមែងកើតឡើងដល់បុគ្គលដែលវៀរឆ្ងាយចាកបុគ្គលអ្នកប្រកាន់សត្វ និងសង្ខារបែបនេះខ្លះ រមែងកើតដល់បុគ្គលដែលព្រងើយក្នុងសត្វ និងសង្ខារខ្លះ រមែងកើតឡើងដល់បុគ្គលដែលមានចិត្តបង្អោនទៅ ទោរទន់ទៅ ឈមទៅ ដើម្បីឲ្យឧបេក្ខាសម្ពោជ្ឈង្គនោះ កើតឡើងក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើមខ្លះ ដូចពណ៌នាមក ដូច្នេះ ។ ភិក្ខុនោះ រមែងជ្រាបច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គនោះ ដែលកើតឡើងហើយយ៉ាងនេះ រមែងចម្រើនបរិបូណ៌ដោយអរហត្តមគ្គ ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថាពោជ្ឈង្គបព្វៈ ចប់**

ក្នុងបព្វៈទាំងពីរ គឺនីវរណបព្វៈ និងពោជ្ឈង្គបព្វៈនេះ ទ្រង់ត្រាស់ដល់វិបស្សនាសុទ្ធៗ ដោយប្រការដែលពណ៌នាមក សតិប្បដ្ឋានទាំង ៤ នេះ រមែងបានក្នុងចិត្តផ្សេងៗ ក្នុងចំណែកខាងដើម ព្រោះថា ព្រះយោគាវចរកំណត់កាយដោយចិត្តម្យ៉ាង កំណត់វេទនាដោយចិត្តម្យ៉ាង រមែងកំណត់ចិត្តដោយចិត្តម្យ៉ាង រមែងកំណត់ធម៌ទាំងឡាយដោយចិត្តម្យ៉ាង តែក្នុងខណៈនៃលោកុត្តរមគ្គ សតិប្បដ្ឋាន ៤ រមែងបានក្នុងចិត្តមួយដួងប៉ុណ្ណោះ ។ ពិតហើយ សតិសម្បយុត្តដោយវិបស្សនារបស់បុគ្គល ដែលកំណត់កាយមកតាំងអំពីដើម ឈ្មោះថា **កាយានុបស្សនា** បុគ្គលដែលប្រកបដោយសតិនោះ ឈ្មោះថា **កាយានុបស្សី** សតិដែលសម្បយុត្តដោយមគ្គក្នុងខណៈនៃមគ្គរបស់បុគ្គលដែលខ្វល់ខ្វាយក្នុងវិបស្សនា ហើយសម្រេចអរិយមគ្គ ឈ្មោះថា **កាយានុបស្សនា** បុគ្គលដែលប្រកបដោយសតិនោះ ឈ្មោះថា **កាយានុបស្សី** ។ សតិដែលសម្បយុត្តដោយវិបស្សនារបស់បុគ្គលដែលកំណត់វេទនា ដែលកំណត់ចិត្ត ដែលកំណត់ធម៌ទាំងឡាយមកហើយ ឈ្មោះថា **វេទនានុបស្សនា ចិត្តានុបស្សនា ធម្មានុបស្សនា** បុគ្គលដែលប្រកបដោយសតិនោះ ឈ្មោះថា **វេទនានុបស្សី ចិត្តានុបស្សី ធម្មានុបស្សី** ។ សតិដែលសម្បយុត្តដោយមគ្គ ក្នុងខណៈនៃមគ្គរបស់បុគ្គលដែលខ្វល់ខ្វាយក្នុងវិបស្សនា ហើយសម្រេចអរិយមគ្គ ឈ្មោះថា **វេទនានុបស្សនា ចិត្តានុបស្សនា ធម្មានុបស្សនា** បុគ្គលដែលប្រកបដោយសតិនោះ ឈ្មោះថា **វេទនានុបស្សី ចិត្តានុបស្សី ធម្មានុបស្សី** ។ ទេសនាបុគ្គលាធិដ្ឋាន ចប់ត្រឹមប៉ុណ្ណោះ ។

*សតិដែលកំណត់កាយដែលជាគ្រឿងលះវិបល្លាស ក្នុងកាយថាជារបស់ស្អាត រមែងសម្រេចដោយមគ្គ ព្រោះហេតុនោះ ទើបសតិនោះ ឈ្មោះថា* **កាយានុបស្សនា** *សតិដែលកំណត់វេទនាដែលជាគ្រឿងលះវិបល្លាស ក្នុងវេទនាថាជាសុខ រមែងសម្រេចដោយមគ្គ ព្រោះហេតុនោះ ទើបសតិនោះ ឈ្មោះថា* **វេទនានុបស្សនា** ។ *សតិដែលកំណត់ចិត្តដែលជាគ្រឿងលះវិបល្លាសក្នុងចិត្តថាជាសភាវៈទៀង រមែងសម្រេចដោយមគ្គ ព្រោះហេតុនោះ ទើបសតិនោះឈ្មោះថា* **ចិត្តានុបស្សនា** ។ *សតិដែលកំណត់ធម៌ដែលជាគ្រឿងលះវិបល្លាសក្នុងធម៌ទាំងឡាយថាជាអត្តា រមែងសម្រេចដោយមគ្គ ព្រោះហេតុនោះ ទើបសតិនោះ ឈ្មោះថា* **ធម្មានុបស្សនា** *ដោយប្រការដូច្នេះ សតិដែលសម្បយុត្តដោយមគ្គតែម្យ៉ាងប៉ុណ្ណោះ រមែងបានឈ្មោះ ៤ យ៉ាង ព្រោះអត្ថថា ញុំាងកិច្ច ៤ យ៉ាងឲ្យសម្រេច ដោយហេតុនោះ ទើបខ្ញុំពោលថា ក្នុងខណៈនៃលោកុត្តរមគ្គ សតិប្បដ្ឋាន ៤ រមែងបានក្នុងចិត្តតែមួយដូចប៉ុណ្ណោះ* ។ល។

## អធិប្បាយសុត្តន្តភាជនីយ ចប់

# អភិធម្មបិដក

## អភិធម្មភាជនីយ

[ ២០៤ ] សតិប្បដ្ឋាន ៤ ។ គឺភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយក្នុងកាយ ១ ពិចារណានូវវេទនាក្នុងវេទនាទាំងឡាយ ១ ពិចារណានូវចិត្តក្នុងចិត្ត ១ ពិចារណានូវធម៌ក្នុងធម៌ទាំងឡាយ ១ ។

[ ២០៥ ] ចុះភិក្ខុពិចារណានូវកាយក្នុងកាយ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដៈ ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ( ភិក្ខុនេះ ) ឈ្មោះថា ពិចារណានូវកាយក្នុងកាយ ក្នុងសម័យនោះ ការរឭក ការនឹកឃើញ ។បេ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សតិប្បដ្ឋាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិប្បដ្ឋាន ។ ចុះភិក្ខុពិចារណានូវវេទនាក្នុងវេទនាទាំងឡាយ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដៈ ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ( ភិក្ខុនេះ ) ឈ្មោះថា ពិចារណានូវវេទនាក្នុងវេទនាទាំងឡាយ ក្នុងសម័យនោះ ការនឹករឭក ការនឹកឃើញ ។បេ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សតិប្បដ្ឋាន ធម៌ទាំងឡាយ

ដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិប្បដ្ឋាន ។ ចុះភិក្ខុពិចារណានូវចិត្តក្នុងចិត្ត តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកៈ ជាគ្រឿងដល់នូវការសន្សំ ( នូវកិលេសវដ្ដៈ ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ( ភិក្ខុនេះ ) ឈ្មោះថា ពិចារណានូវចិត្តក្នុងចិត្ត ក្នុងសម័យនោះ ការរឭក ការនឹកឃើញ ។បេ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សតិប្បដ្ឋាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិប្បដ្ឋាន ។ ចុះភិក្ខុពិចារណានូវធម៌ក្នុងធម៌ទាំងឡាយ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកៈ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដៈ ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ( ភិក្ខុនេះ ) ឈ្មោះថា ពិចារណានូវធម៌ក្នុងធម៌ទាំងឡាយ ក្នុងសម័យនោះ ការរឭក ការនឹកឃើញ ។បេ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សតិប្បដ្ឋាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិប្បដ្ឋាន ។ បណ្ដាធម៌ទាំងនោះ សតិប្បដ្ឋាន តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកៈ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដៈ ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំង

ឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈានជាទុក្ខាបដិបទាទន្ធាភិញ្ញា ( ភិក្ខុនេះ ) ឈ្មោះថា ពិចារណានូវធម៌ក្នុងធម៌ទាំងឡាយ ក្នុងសម័យនោះ ការរឭក ការនឹកឃើញ ។បេ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សតិប្បដ្ឋាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថាប្រកបដោយសតិប្បដ្ឋាន ។

[ ២០៦ ] សតិប្បដ្ឋាន ៤ ។ ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយក្នុងកាយ ១ ពិចារណានូវវេទនាក្នុងវេទនាទាំងឡាយ ១ ពិចារណានូវចិត្តក្នុងចិត្ត ១ ពិចារណានូវធម៌ក្នុងធម៌ទាំងឡាយ ១ ។

[ ២០៧ ] ចុះភិក្ខុពិចារណានូវកាយក្នុងកាយ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកៈ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្តៈ ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈក៏មាន ។បេ។ អវិក្ខេបៈក៏មាន ធម៌ទាំងនេះ ជាកុសល ភិក្ខុស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចម្រើនហើយ ( ភិក្ខុនេះ ) ឈ្មោះថា ពិចារណានូវកាយក្នុងកាយ ក្នុងសម័យនោះ ការរឭក ការនឹកឃើញ ។បេ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គជាអង្គមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សតិប្បដ្ឋាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះ

ជា ប្រកបដោយសតិប្បដ្ឋាន ។ ចុះភិក្ខុពិចារណានូវវេទនាក្នុងវេទនាទាំងឡាយ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកៈ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្តៈ ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈក៏មាន ។បេ។ អវិក្ខេបៈក៏មាន ធម៌ទាំងនេះ ជាកុសល ភិក្ខុស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចម្រើនហើយ ( ភិក្ខុនេះ ) ឈ្មោះថាពិចារណានូវវេទនាក្នុងវេទនាទាំងឡាយ ក្នុងសម័យនោះ ការរឭក ការរឭកឃើញ ។បេ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សតិប្បដ្ឋាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិប្បដ្ឋាន ។ ចុះភិក្ខុពិចារណានូវចិត្តក្នុងចិត្ត តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកៈ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្តៈ ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈក៏មាន ។បេ។ អវិក្ខេបៈក៏មាន ធម៌ទាំងនេះ ជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក

ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចម្រើនហើយ ( ភិក្ខុនេះ ) ឈ្មោះថា ពិចារណានូវចិត្តក្នុងចិត្ត ក្នុងសម័យនោះ ការរឭក ការនឹកឃើញ ។បេ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សតិប្បដ្ឋាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិប្បដ្ឋាន ។ ចុះភិក្ខុពិចារណានូវធម៌ក្នុងធម៌ទាំងឡាយ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកៈ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្តៈ ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈក៏មាន ។បេ។ អវិក្ខេបៈក៏មាន ធម៌ទាំងនេះ ជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចម្រើនហើយ ( ភិក្ខុនេះ ) ឈ្មោះថា ពិចារណានូវធម៌ក្នុងធម៌ទាំងឡាយ ក្នុងសម័យនោះ ការរឭក ការនឹកឃើញ ។បេ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សតិប្បដ្ឋាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិប្បដ្ឋាន ។ បណ្តាធម៌ទាំងនោះ សតិប្បដ្ឋាន តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកៈ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្តៈ ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវ

បឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈក៏មាន ។បេ។ អវិក្ខេបៈក៏មាន ធម៌ទាំងនេះ ជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចម្រើនហើយ ( ភិក្ខុនេះ ) ឈ្មោះថា ពិចារណានូវធម៌ក្នុងធម៌ទាំងឡាយ ក្នុងសម័យនោះ ការរឭក ការនឹកឃើញ ។បេ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សតិប្បដ្ឋាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិប្បដ្ឋាន ។

## អភិធម្មភាជនីយ ចប់

# អដ្ឋកថា

## អភិធម្មភាជនីយ

[ ២០៤-២០៧ ] សតិប្បដ្ឋាន មានកាយានុបស្សនាទាំងអស់ជាដើម ព្រះមានព្រះភាគ ទ្រង់សម្តែងត្រឹមមាតិការបស់ន័យនៃទេសនា ដែលចែកហើយក្នុងធម្មសង្គណី តែទ្រង់មិនបានតាំងជាបែបផែន ដូចក្នុងលោកិយ-សតិប្បដ្ឋានទាំងឡាយ មានកាយជាដើមជាអារម្មណ៍ ព្រោះក្នុងអភិធម្ម-ភាជនីយ ទ្រង់ប្រារព្ធទេសនា ដោយអំណាចនៃលោកុត្តរសតិប្បដ្ឋាន ។

គប្បីជ្រាបប្រភេទរបស់ន័យក្នុងអភិធម្មភាជនីយដូចតទៅ គប្បីជ្រាបដូចម្តេច ក្នុងកាយានុបស្សនា ក្នុងការតាំងមាំដោយឈាន ក្នុងសោតាបត្តិមគ្គ មាន ១០ ន័យ ដោយអំណាចនៃចតុក្កន័យ និងបញ្ចកន័យនីមួយៗ ២ ក្នុងឋានៈទាំង ៥ នេះ គឺសុទ្ធិកបដិបទា សុទ្ធិកសុញ្ញតា សុញ្ញតបដិបទា សុទ្ធិ-កអប្បណិហិត អប្បណិហិតបដិបទា រួមជាចតុក្កៈ ៥ ន័យ និងបញ្ចកៈ ៥ ន័យ ក្នុងការតាំងមាំទាំងឡាយដ៏សេសក៏យ៉ាងនោះ ព្រោះហេតុនោះ ក្នុងការតាំងមាំ[១] ២០ ទើបមាន ២០០ ន័យ ក្នុង ២០០ ន័យនោះ គុណនឹងអធិបតី ៤ ជា ៨០០ ន័យ ទើបន័យទាំងពួងមាន ១០០០ ន័យ គឺសុទ្ធិកន័យ មាន ២០០ ន័យ សាធិបតិន័យ ៨០០ ន័យ ដោយប្រការដូច្នេះ ។ ក្នុងវេទនា-នុបស្សនាជាដើម និងក្នុងសុទ្ធិកសតិប្បដ្ឋាន ក៏ដូចគ្នា ព្រោះហេតុនោះ ទើប

---

១- ក្នុងការតាំងមាំ គឺមហាន័យ ២០ គឺឈាន មគ្គ សតិប្បដ្ឋាន សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពល ពោជ្ឈង្គ សច្ចៈ សមថវិបស្សនា ធម៌ ខន្ធ អាយតនៈ ធាតុ អាហារ ផស្សៈ វេទនា សញ្ញា ចេតនា ចិត្តាភិនិវេសៈ ។

*ក្នុងសោតាបត្តិមគ្គមាន ៥០០០ ន័យ ។ ម្យ៉ាងទៀត ក្នុងសោតាបត្តិមគ្គ យ៉ាងណា សូម្បីក្នុងមគ្គដ៏សេសក៏យ៉ាងនោះ គឺក្នុងកុសលមាន ២០០០០ ន័យ ។ ក្នុងវិបាកគុណនឹង ៣ អំពីន័យរបស់កុសលនោះ ដោយចែកជា សុញ្ញតៈ អប្បណិហិត និងអនិមិត្ត ទើបជា ៦០០០០ ន័យ ព្រោះហេតុនោះ និទ្ទេសនៃអភិធម្មភាជនីយ មាន ២ យ៉ាង ដោយអំណាចនិទ្ទេសនៃសតិប្បដ្ឋាន ដែលជាកុសល និងវិបាក គឺជាការញ៉ាំងកិច្ចរបស់ខ្លួនឲ្យសម្រេចម្យ៉ាង ជាកិច្ច ដែលសម្រេចដោយល្អម្យ៉ាង និងមាន ១០ ប្រភេទ ដោយអំណាចនៃនិទ្ទេសវារ ១០ គឺខាងកុសល ៥ ខាងវិបាក ៥ ដោយអំណាចនៃកាយានុបស្សនា ជាដើម និងដោយអំណាចនៃសុទ្ធិកៈដែលទើបប្រជាប់ហើយ ដោយន័យ ៨០០០០ ន័យយ៉ាងនេះ ដោយប្រការដូច្នេះ ។*

## អដ្ឋកថាអភិធម្មភាជនីយ ចប់

# អភិធម្មបិដក

## បញ្ហាបុច្ឆកៈ

[ ២០៨ ] សតិប្បដ្ឋាន ៤ គឺភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់អភិជ្ឈា និងទោមនស្ស ក្នុងលោក ១ ពិចារណានូវវេទនាក្នុងវេទនាទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់អភិជ្ឈា និងទោមនស្ស ក្នុងលោក ១ ពិចារណានូវចិត្តក្នុងចិត្ត មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់អភិជ្ឈា និងទោមនស្ស ក្នុងលោក ១ ពិចារណានូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្ស ក្នុងលោក ១ ។ បណ្តាសតិប្បដ្ឋានទាំង ៤ សតិប្បដ្ឋានជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។បេ។ ជាសរណៈប៉ុន្មាន ជាអរណៈប៉ុន្មាន ។

[ ២០៩ ] សតិប្បដ្ឋាន ៤ ជាកុសលក៏មាន ជាអព្យាក្រឹតក៏មាន ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ជាវិបាកក៏មាន ជាធម៌មានវិបាកជាប្រក្រតី តែមិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន តែមិនសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មងក៏មាន ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន ប្រឡំដោយបីតិក៏មាន ប្រឡំដោយសុខក៏មាន ប្រឡំដោយឧបេក្ខា

ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុដែលមិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនាក៏មាន ដល់នូវការមិនសន្សំក៏មាន មិនដល់នូវការសន្សំកពូនឡើង ទាំងមិនដល់នូវការមិនសន្សំក៏មាន ជាសេក្ខៈក៏មាន ជាអសេក្ខៈ ដែលមិនមានប្រមាណ មានអារម្មណ៍ប្រមាណមិនបាន ជាធម៌ដ៏ប្រសើរក៏មាន មានសភាពត្រូវ និងទៀងក៏មាន មិនទៀង ដែលមានមគ្គជាអារម្មណ៍ក៏មាន មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន មិនគួរពោលថា មានមគ្គជាហេតុផង ថាមានមគ្គជាអធិបតីផងក៏មាន កើតឡើងហើយក៏មាន មិនទាន់កើតឡើងហើយក៏មាន បម្រុងនឹងកើតឡើងក៏មាន ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្ន តែមិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថាមានអារម្មណ៍ជាអនាគតផង ថាមានអារម្មណ៍ជាបច្ចុប្បន្នផងក៏មាន ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ជាខាងក្នុង ទាំងខាងក្រៅ ដែលមានអារម្មណ៍ជាខាងក្រៅ មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ក៏មាន ។

[ ២១០ ] សតិប្បដ្ឋាន ៤ មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ប្រកបដោយហេតុ មិនគួរពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុទេ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុ មិនគួរពោលថាជាហេតុ ទាំងប្រកបដោយហេតុឡើយ គ្រាន់តែប្រកបដោយហេតុ តែមិនមែនហេតុ មិនមែនហេតុ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ ។ សតិប្បដ្ឋាន ៤ ប្រកបដោយបច្ច័យ ត្រូវបច្ច័យតាក់តែង មិនប្រកបដោយការឃើញ មិន

ប្រកបដោយការប៉ះពាល់ មិនមានរូប ជាលោកុត្តរ គួរដឹងដោយវិញ្ញាណណាមួយ មិនគួរដឹងដោយវិញ្ញាណណាមួយ ។ សតិប្បដ្ឋាន ៤ មិនមែនអាសវៈ មិនមានអាសវៈ ប្រាសចាកអាសវៈ មិនគួរពោលថា ជាអាសវៈទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈផងថា ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈផងទេ មិនគួរពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈផងថា ប្រកបដោយអាសវៈ តែមិនមែនអាសវៈផងឡើយ គឺជាធម៌ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ។ សតិប្បដ្ឋាន ៤ មិនមែនសញ្ញោជនៈ ។បេ។ មិនមែនគន្ថៈ ។បេ។ មិនមែនឱឃៈ ។បេ។ មិនមែនយោគៈ ។បេ។ មិនមែននីវរណៈ ។បេ។ មិនមែនបរាមាស ។បេ។ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ មិនមែនចិត្ត ជាចេតសិក ប្រកបដោយចិត្ត ច្រឡំដោយចិត្ត តាំងឡើងដោយចិត្ត កើតជាមួយនឹងចិត្ត ប្រព្រឹត្តទៅតាមចិត្តច្រឡំ ទាំងតាំងឡើងដោយចិត្ត ច្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្តច្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត ជាខាងក្រៅ មិនមែនឧបាទាដែលកិលេស មានតណ្ហាជាដើមមិនកាន់យក ។ សតិប្បដ្ឋាន ៤ មិនមែនឧបាទាន ។បេ។ មិនមែនកិលេស ។បេ។ មិនគួរលះដោយទស្សនៈ មិនគួរ

លះដោយភាវនា មានហេតុ មិនគួរលះដោយទស្សនៈ មានហេតុ មិនគួរលះដោយភាវនា ប្រកបដោយវិតក្កក៏មាន មិនមានវិតក្កក៏មាន ប្រកបដោយវិចារក៏មាន មិនមានវិចារក៏មាន ប្រកបដោយបីតិក៏មាន មិនមានបីតិក៏មាន ប្រទ្បំដោយបីតិក៏មាន មិនប្រទ្បំដោយបីតិក៏មាន ប្រទ្បំដោយសុខក៏មាន មិនប្រទ្បំដោយសុខក៏មាន ប្រទ្បំដោយឧបេក្ខាក៏មាន មិនប្រទ្បំដោយឧបេក្ខា តែមិនមែនកាមាវចរ មិនមែនរូបាវចរ មិនមែនអរូបាវចរ ជាអបរិយាបន្នក៏មាន ជានិយ្យានិកៈក៏មាន ជាអនិយ្យានិកៈក៏មាន ជានិយតៈក៏មាន ជាអនិយតៈ ជាអនុត្តរៈ ជាអរណៈក៏មាន ។

បញ្ហាបុច្ឆកៈ ចប់

សតិប្បដ្ឋានវិភង្គ ចប់

# អដ្ឋកថា

## បញ្ហាបុច្ឆកៈ

[ ២០៨-២១០ ] ក្នុងបញ្ហាបុច្ឆកៈ គប្បីជ្រាបភាពដែលសតិប្បដ្ឋានជាកុសលជាដើម ដោយទំនងនៃព្រះបាលីនោះឯង ។ ក្នុងអារម្មណត្តិកៈ សតិប្បដ្ឋានទាំងអស់នោះ ជាអប្បមាណារម្មណៈប៉ុណ្ណោះ ព្រោះប្រារព្ធនិព្វាន ដែលជាអប្បមាណធម៌ មិនជាមគ្គារម្មណៈ តែជាមគ្គហេតុកៈ ដោយអំណាចនៃសហជាតហេតុ ជាមគ្គាធិបតីក្នុងការចម្រើនមគ្គ ព្រោះធ្វើវិរិយៈ ឬវីមំសាឲ្យជាប្រធាន មិនគប្បីពោលថាជាមគ្គាធិបតី ព្រោះចម្រើនមគ្គ ដែលធ្វើឆន្ទៈ ឬចិត្តឲ្យជាប្រធាន ក្នុងកាលនៃផលក៏មិនគប្បីពោលដូចគ្នា ។ ក្នុងអតីតជាដើម ក៏មិនគប្បីពោលដោយភាពជាឯការម្មណៈ តែព្រោះព្រះនិព្វានជាពហិទ្ធាធម៌ ទើបឈ្មោះថា **ពហិទ្ធារម្មណា** ព្រោះហេតុនោះ សតិប្បដ្ឋានដែលជាលោកុត្តរ ដែលសម្រេចហើយនោះឯង ព្រះមានព្រះភាគត្រាស់ក្នុងបញ្ហាបុច្ឆកៈនេះ ដោយប្រការដូច្នេះ ។ ពិតហើយ ព្រះសម្មាសម្ពុទ្ធត្រាស់សតិប្បដ្ឋាន ដែលជាលោកិយ និងលោកុត្តរ លាយឡំគ្នាក្នុងសុត្តន្តភាជនីយនោះឯង តែក្នុងអភិធម្មភាជនីយ និងបញ្ហាបុច្ឆកៈនេះ ត្រាស់លោកុត្តរតែម្យ៉ាង ។ សតិប្បដ្ឋានវិភង្គនេះ ព្រះមានព្រះភាគក៏នាំចេញចែកសម្តែងហើយ ៣ បរិវត្ត គឺសុត្តន្តភាជនីយ អភិធម្មភាជនីយ និងបញ្ហាបុច្ឆកៈ ដូចពណ៌នាមក ដូច្នេះឯង ៕៚

**អដ្ឋកថាបញ្ហាបុច្ឆកៈ ចប់**

**អដ្ឋកថាសតិប្បដ្ឋានវិភង្គ ចប់**

# អភិធម្មបិដក

## សម្មប្បធានវិភង្គ

[ ២១១ ] សម្មប្បធាន ៤ គឺភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ១ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ១ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង ១ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលកើតហើយ ឲ្យស្ថិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាល ធំទូលាយ ចម្រើនពេញលេញ ១ ។

[ ២១២ ] ចុះភិក្ខុញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើតឡើង តើដូចម្តេច ។ អកុសលមូល ៣ គឺលោភៈ ទោសៈ មោហៈ និងពួកកិលេស ដែលស្ថិតនៅជាមួយនឹងអកុសលមូលនោះ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ដែលប្រកបដោយកិលេសនោះ កាយកម្ម វចីកម្ម មនោកម្ម ដែលតាំងឡើងដោយខន្ធនោះ ធម៌ទាំងនេះ ហៅថា អកុសលធម៌ដ៏លាមក ដែលមិនទាន់កើតឡើង ។ ភិក្ខុញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងអកុសលធម៌ដ៏លាមកទាំងនេះ

ដែលមិនទាន់កើត មិនឲ្យកើតឡើង ដោយប្រការដូច្នេះ ។

[ ២១៣ ] ត្រង់ពាក្យថា ញុំាងឆន្ទៈឲ្យកើត មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ ឆន្ទៈ តើដូចម្ដេច ។ សេចក្ដីប្រាថ្នា ភាពនៃបុគ្គលមានសេចក្ដីប្រាថ្នា ភាពនៃបុគ្គលប្រាថ្នាដើម្បីធ្វើ សេចក្ដីប្រាថ្នាធម៌ជាកុសលណា នេះហៅថា ឆន្ទៈ ភិក្ខុញុំាងឆន្ទៈនេះឲ្យកើត ឲ្យលូតលាស់ ឲ្យដុះដាល ឲ្យតាំងឡើង ឲ្យចម្រើនឡើង ឲ្យកើតឡើង ព្រោះហេតុនោះ ទើបពោលថា ញុំាងឆន្ទៈឲ្យកើត ។

[ ២១៤ ] ត្រង់ពាក្យថា សង្វាត មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ សេចក្ដីសង្វាត តើដូចម្ដេច ។ សេចក្ដីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈណា នេះហៅថា សេចក្ដីសង្វាត ភិក្ខុជាអ្នកព្រមព្រៀង មូលមិត្រ ចូលទៅជិត អែបនែប កៀកកើយ ប្រជិតប្រជី ប្រកបព្រម ដោយសេចក្ដីសង្វាតនេះ ព្រោះហេតុនោះ ទើបពោលថា សង្វាត ។

[ ២១៥ ] ត្រង់ពាក្យថា ប្រារព្ធព្យាយាម មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ ការព្យាយាម តើដូចម្ដេច ។ សេចក្ដីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈណា នេះហៅថា ការព្យាយាម ភិក្ខុប្រារព្ធ កាន់យកត្រូវ គប់រក អប់រំ ធ្វើឲ្យច្រើន នូវការព្យាយាមនេះ ព្រោះហេតុនោះ ទើបពោលថា ប្រារព្ធព្យាយាម ។

[ ២១៦ ] ត្រង់ពាក្យថា ផ្គងចិត្ត មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ ចិត្ត តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។

មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា ចិត្ត ភិក្ខុផ្គង តម្រង់ ជ្រោមជ្រែង ទប់ទល់ទុកនូវចិត្តនេះ ព្រោះហេតុនោះ ទើបពោលថា ផ្គងចិត្ត ។

[ ២១៧ ] ត្រង់ពាក្យថា ប្រឹងប្រែង មានសេចក្តីថា បណ្តាពាក្យទាំងនោះ ការប្រឹងប្រែង តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈណា នេះហៅថា ការប្រឹងប្រែង ភិក្ខុជាអ្នកព្រមព្រៀង ។បេ។ ប្រកបព្រម ដោយការប្រឹងប្រែងនេះ ព្រោះហេតុនោះ ទើបពោលថា ប្រឹងប្រែង ។

[ ២១៨ ] ចុះភិក្ខុញុំាងឆន្ទៈ ឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ តើដូចម្តេច ។ អកុសលមូល ៣ គឺលោភៈ ទោសៈ មោហៈ និងពួកកិលេស ដែលស្ថិតនៅជាមួយនឹងអកុសលមូលនោះ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ដែលប្រកបដោយកិលេសនោះ កាយកម្ម វចីកម្ម មនោកម្ម ដែលតាំងឡើងដោយខន្ធនោះ ធម៌ទាំងនេះ ហៅថា ពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ។ ភិក្ខុញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ទាំងនេះ ដែលកើតឡើងហើយ ដោយប្រការដូច្នេះ ។

[ ២១៩ ] ត្រង់ពាក្យថា ញុំាងឆន្ទៈឲ្យកើត មានសេចក្តីថា បណ្តាបទ

ទាំងនោះ ឆន្ទៈ តើដូចម្ដេច ។ សេចក្ដីប្រាថ្នា ភាពនៃបុគ្គលមានសេចក្ដីប្រាថ្នា ភាពនៃបុគ្គលអ្នកប្រាថ្នាដើម្បីធ្វើ សេចក្ដីប្រាថ្នាធម៌ជាកុសលណា នេះហៅថា ឆន្ទៈ ភិក្ខុញុំាងឆន្ទៈនេះឲ្យកើត ឲ្យលូតលាស់ ឲ្យដុះដាល ឲ្យតាំងឡើង ឲ្យចម្រើនឡើង ឲ្យកើតឡើង ព្រោះហេតុនោះ ទើបពោលថា ញុំាងឆន្ទៈឲ្យកើត ។

[ ២២០ ] ត្រង់ពាក្យថា សង្វាត មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ សេចក្ដីសង្វាត តើដូចម្ដេច ។ សេចក្ដីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈណា នេះហៅថា សេចក្ដីសង្វាត ភិក្ខុជាអ្នកព្រមព្រៀង ។បេ។ ប្រកបព្រមដោយសេចក្ដីសង្វាតនេះ ព្រោះហេតុនោះ ទើបពោលថា សង្វាត ។

[ ២២១ ] ត្រង់ពាក្យថា ប្រារព្ធព្យាយាម មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ ការព្យាយាម តើដូចម្ដេច ។ សេចក្ដីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈណា នេះហៅថា ការព្យាយាម ភិក្ខុប្រារព្ធ កាន់យកត្រូវ គប់រក អប់រំ ធ្វើឲ្យច្រើន នូវការព្យាយាមនេះ ព្រោះហេតុនោះ ទើបពោលថា ប្រារព្ធព្យាយាម ។

[ ២២២ ] ត្រង់ពាក្យថា ផ្គងចិត្ត មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ ចិត្ត តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោ-វិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា ចិត្ត ភិក្ខុផ្គង តម្រង់ ជ្រោមជ្រែង ទប់ទល់ទុក នូវចិត្តនោះ ព្រោះហេតុនោះ ទើបពោលថា ផ្គងចិត្ត ។

[ ២២៣ ] ត្រង់ពាក្យថា ប្រឹងប្រែង មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ ការប្រឹងប្រែង តើដូចម្ដេច ។ សេចក្ដីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត

។បេ។ សម្មាវាយាមៈណា នេះហៅថា ការប្រឹងប្រែង ភិក្ខុជាអ្នកព្រមព្រៀង ។បេ។ ប្រកបព្រម ដោយការប្រឹងប្រែងនេះ ព្រោះហេតុនោះ ទើបពោលថា ប្រឹងប្រែង ។

[ ២២៤ ] ចុះភិក្ខុញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង តើដូចម្ដេច ។ បណ្ដាធម៌ទាំងនោះ ពួកកុសលធម៌ ដែលមិនទាន់កើតឡើង តើដូចម្ដេច ។ កុសលមូល ៣ គឺអលោភៈ អទោសៈ អមោហៈ និងវេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ដែលប្រកបដោយកុសលមូលនោះ កាយកម្ម វចីកម្ម មនោកម្ម ដែលតាំងឡើងដោយខន្ធនោះ ធម៌ទាំងនេះហៅថា ពួកកុសលធម៌ ដែលមិនទាន់កើតឡើង ។ ភិក្ខុញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ទាំងនេះ ដែលមិនទាន់កើត ឲ្យកើតឡើង ដោយប្រការដូច្នេះ ។

[ ២២៥ ] ត្រង់ពាក្យថា ញុំាងឆន្ទៈឲ្យកើត ។បេ។ ត្រង់ពាក្យថា សង្វាត ។បេ។ ត្រង់ពាក្យថា ប្រារព្ធព្យាយាម ។បេ។ ត្រង់ពាក្យថា ផ្គងចិត្ត ។បេ។ ត្រង់ពាក្យថា ប្រឹងប្រែង មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ ការប្រឹងប្រែង តើដូចម្ដេច ។ សេចក្ដីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈណា នេះហៅថា ការប្រឹងប្រែង ភិក្ខុជាអ្នកព្រមព្រៀង ។បេ។ ប្រកបព្រម ដោយការប្រឹងប្រែងនេះ ព្រោះហេតុនោះ ទើបពោលថា ប្រឹងប្រែង ។

[ ២២៦ ] ចុះភិក្ខុញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត

ប្រឹងប្រែង ដើម្បីញ៉ាំងពួកកុសលធម៌ ដែលកើតហើយ ឲ្យស្ថិតនៅ មិនឲ្យវិនាស ឲ្យរីងរឹតតែដុះដាល ធំទូលាយ ចម្រើន ពេញលេញ តើដូចម្ដេច ។ បណ្ដាធម៌ទាំងនោះ ពួកកុសលធម៌ ដែលកើតឡើងហើយ តើដូចម្ដេច ។ កុសលមូល ៣ គឺអលោភៈ អទោសៈ អមោហៈ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ដែលប្រកបដោយកុសលមូលនោះ កាយកម្ម វចីកម្ម មនោកម្ម ដែលតាំងឡើងដោយខន្ធនោះ ធម៌ទាំងនេះ ហៅថា ពួកកុសលធម៌ ដែលកើតឡើងហើយ ។ ភិក្ខុញ៉ាំងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញ៉ាំងកុសលធម៌ទាំងនេះ ដែលកើតហើយ ឲ្យស្ថិតនៅ មិនឲ្យវិនាស ឲ្យរីងរឹតតែដុះដាល ធំទូលាយ ចម្រើន ពេញលេញ ដោយប្រការដូច្នេះ ។

[ ២២៧ ] ពាក្យថា ឲ្យស្ថិតនៅ គឺការស្ថិតនៅណា នុ៎ះឈ្មោះថា សេចក្ដីមិនវិនាស ឯសេចក្ដីមិនវិនាសណា នុ៎ះឈ្មោះថា ការរីងរឹតតែដុះដាលឡើង ការរីងរឹតតែដុះដាលឡើងណា នោះឈ្មោះថា ធំទូលាយ ការធំទូលាយណា នុ៎ះឈ្មោះថា ការចម្រើន ការចម្រើនណា នុ៎ះឈ្មោះថា ការពេញលេញ ។

[ ២២៨ ] ត្រង់ពាក្យថា ញុំាងឆន្ទៈឲ្យកើត ។បេ។ ត្រង់ពាក្យថា សង្វាត ។បេ។ ត្រង់ពាក្យថា ប្រារព្ធព្យាយាម ។បេ។ ត្រង់ពាក្យថា ផ្គងចិត្ត ។បេ។ ត្រង់ពាក្យថា ប្រឹងប្រែង សេចក្តីថា បណ្តាពាក្យទាំងនោះ ការប្រឹងប្រែង តើដូចម្តេច សេចក្តីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈ ណា នេះហៅថា ប្រឹងប្រែង ភិក្ខុជាអ្នកព្រមព្រៀង ។បេ។ ប្រកបព្រមដោយ ការប្រឹងប្រែងនេះ ព្រោះហេតុនោះ ទើបពោលថា ប្រឹងប្រែង ។

សុត្តន្តភាជនីយ ចប់

# អដ្ឋកថា

## សម្មប្បធានវិភង្គ

## សុត្តន្តភាជនីយ

[ ២១១-២២៨ ] ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងសម្មប្បធានវិភង្គ ដែលជាលំដាប់នៃសតិប្បដ្ឋានវិភង្គនេះដូចតទៅ

បទថា **ចត្តារោ** ជាពាក្យកំណត់ចំនួន ដោយពាក្យនោះ ព្រះមានព្រះភាគទ្រង់សម្ដែងការកំណត់សម្មប្បធានថា មិនតិចជាងនោះ មិនច្រើនជាងនោះ ដូច្នេះ ។ បទថា **សម្មប្បធានា** បានដល់ សេចក្ដីព្យាយាមដែលជាហេតុ សេចក្ដីព្យាយាមដែលជាឧបាយ សេចក្ដីព្យាយាមដោយយោនិសោ ។

បទថា **ឥធ ភិក្ខុ** បានដល់ ភិក្ខុដែលបដិបត្តិក្នុងសាសនានេះ ។ បទថា **អនុប្បន្នានំ** បានដល់ ដែលមិនទាន់កើតឡើង ។ បទថា **បាបកានំ** បានដល់ ដ៏លាមក ។ បទថា **អកុសលានំ ធម្មានំ** បានដល់ ធម៌ទាំងឡាយដែលជាអកុសល ក្នុងអត្ថថា មិនឈ្លាស ។ បទថា **អនុប្បាទាយ** បានដល់ ដើម្បីមិនឲ្យកើតឡើង ។ បទថា **ឆន្ទំ ជនេតិ** បានដល់ រមែងញ៉ាំងឆន្ទៈក្នុងកុសល ពោល គឺភាពជាអ្នកប្រាថ្នាដើម្បីធ្វើឲ្យកើត គឺឲ្យកើតឡើង ។ បទថា **វាយមតិ** បានដល់ រមែងធ្វើសេចក្ដីប្រឹងប្រែង ប្រកបព្យាយាម ។ បទថា **វីរិយំ អារភតិ** បានដល់ ធ្វើសេចក្ដីព្យាយាម ដែលប្រព្រឹត្តទៅផ្លូវកាយនិងផ្លូវចិត្ត ។

បទថា **ចិត្តំ បគ្គណ្ហាតិ** បានដល់ រមែងកើតឡើងដោយសេចក្ដី

ព្យាយាមដែលជាសហជាតនោះឯង ។ បទថា **បទហតិ** បានដល់ រមែងធ្វើសេចក្តីព្យាយាមដែលជាប្រធាន ។ម្យ៉ាងទៀត ទាំង ៤ បទនេះ គប្បីប្រកបដោយការសេព ការចម្រើន ការធ្វើឲ្យច្រើន និងការធ្វើឲ្យជាប់តគ្នាដោយលំដាប់ ។

បទថា **ឧប្បន្នានំ ចាបកានំ** បានដល់ បាបធម៌ដែលដល់នូវពាក្យដែលបុគ្គលមិនគួរពោលថា មិនទាន់កើតឡើង ។ បទថា **បហានាយ** បានដល់ ដើម្បីការលះបង់ ។ បទថា **អនុប្បន្នានំ កុសលានំ ធម្មានំ** បានដល់ កុសលធម៌ដែលកើតអំពីការឈ្លាស ដែលមិនទាន់កើតឡើង ។

បទថា **ឧប្បាទាយ** បានដល់ ដើម្បីឲ្យកើតឡើង ។ បទថា **ឧប្បន្នានំ** បានដល់ ដែលកើតឡើងហើយ ។ បទថា **ឋិតិយា** បានដល់ ដើម្បីការតាំងនៅ ។ បទថា **អសម្មោសាយ** បានដល់ ដើម្បីការមិនសូន្យទៅ ។ បទថា **ភយ្យោភាវាយ** បានដល់ ដើម្បីការចម្រើនរឿយៗ ។ បទថា **វេបុល្លាយ** បានដល់ ដើម្បីភាពធំទូលាយ ។ បទថា **ភាវនាយ** បានដល់ ដើម្បីសេចក្តីចម្រើន ។ បទថា **ចារិបូរិយា** បានដល់ ដើម្បីប្រយោជន៍ដល់ភាពបរិបូណ៌ ។

នេះជាការចែកអត្ថ ដែលប្រកបដោយបទចំពោះ ដោយអំណាចនៃឧទ្ទេសវារ នៃសម្មប្បធាន ៤ ប៉ុណ្ណេះ ។

ឥឡូវនេះ ដើម្បីសម្តែងចែកបទទាំងនោះដោយលំដាប់ ទើបព្រះមានព្រះភាគទ្រង់ផ្តើមនិទ្ទេសវារដោយន័យថា **កថញ្ច ភិក្ខុ អនុប្បន្នានំ** ជាដើម ។ ក្នុងនិទ្ទេសវារនោះ បទណាដូចគ្នានឹងបទដែលមានមកហើយក្នុងធម្មសង្គណី

ខាងដើម បទនោះ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងកិច្ចពណ៌នាធម្មសង្គណីនោះចុះ តែបទណាមិនទាន់មកក្នុងធម្មសង្គណីនោះ បទនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងឆន្ទនិទ្ទេសដូចតទៅ

បទថា **យោ ឆន្ទោ** បានដល់ ឆន្ទៈ ដោយអំណាចនៃការតាំងនូវការពេញចិត្តឯណា ។ បទថា **ឆន្ទិកតា** បានដល់ ភាពជាអ្នកប្រកបដោយឆន្ទៈ ឬអាការនៃការធ្វើឆន្ទៈ ។ បទថា **កត្តុកម្យតា** បានដល់ ភាពជាអ្នកប្រាថ្នាដើម្បីធ្វើ ។ បទថា **កុសលោ** បានដល់ អ្នកឈ្លាស ។ បទថា **ធម្មច្ឆន្ទោ** បានដល់ ឆន្ទៈក្នុងសភាវៈ ។ ពិតហើយ ឈ្មោះថា ឆន្ទៈនេះ មានប្រការផ្សេងៗ ច្រើនយ៉ាង គឺតណ្ហាឆន្ទៈ ទិដ្ឋិឆន្ទៈ វីរិយឆន្ទៈ ធម្មច្ឆន្ទៈ ។

ក្នុងឆន្ទៈទាំងនោះ បទថា **ធម្មច្ឆន្ទោ** លោកបំណងយកឆន្ទៈក្នុងធម៌ដែលជាកុសល របស់បុគ្គលប្រាថ្នាដើម្បីធ្វើក្នុងទីនេះ ។ បទថា **ឥមំ ឆន្ទំ ជនេតិ** បានដល់ អ្នកធ្វើនូវឆន្ទៈនោះឯង ឈ្មោះថា ញុំាងឆន្ទៈឲ្យកើត ។ បទថា **សញ្ជនេតិ** ទ្រង់បន្ថែមបទឧបសគ្គ ។ បទថា **ឧដ្ឋបេតិ** បានដល់ អ្នកធ្វើឆន្ទៈនោះឯង ឈ្មោះថា រមែងឲ្យឆន្ទៈតាំងឡើង ។ បទថា **សមុដ្ឋបេតិ** ទ្រង់បន្ថែមបទឧបសគ្គ ។ បទថា **និព្វត្តេតិ** បានដល់ អ្នកធ្វើឆន្ទៈយ៉ាងនោះ ឈ្មោះថា រមែងឲ្យឆន្ទៈនោះកើតឡើង ។ បទថា **អភិនិព្វត្តេតិ** ទ្រង់បន្ថែមបទឧបសគ្គ ។

ម្យ៉ាងទៀត ភិក្ខុធ្វើឆន្ទៈនោះឯង ឈ្មោះថា **ឆន្ទំ ជនេតិ** អ្នកធ្វើឆន្ទៈនោះឯងឲ្យជាប់តគ្នាទៅ ឈ្មោះថា **សញ្ជនេតិ** ភិក្ខុលើកឡើងទៀតនូវឆន្ទៈ

ដែលធ្លាក់ទៅហើយដោយអន្តរាយណាមួយ ឈ្មោះថា **ឧដ្ឋបេតិ** គឺក្តាំង ធនុះឲ្យដល់នូវការតាំងមាំជាប់តគ្នាទៅ ឈ្មោះថា **សមុដ្ឋបេតិ** គឺក្នុងធ្វើធនុះនោះឲ្យប្រាកដ ឈ្មោះថា **និព្វត្តេតិ** គឺក្នុងឲ្យធនុះកើតឡើង ដោយភាពជាធំក្រៃលែង ព្រោះការមិនរាថយ និងព្រោះការមិនរួញរាប្រព្រឹត្តទៅ ឈ្មោះថា **អភិនិព្វត្តេតិ** ។

ក្នុងវីរិយនិទ្ទេស ព្រះយោគាវចរធ្វើសេចក្តីព្យាយាមនោះឯង ឈ្មោះថា **វីរិយំ អារភតិ** ។ បទទី ២ ( **សមារភតិ** ) ទ្រង់បន្ថែមបទឧបសគ្គ ។ កាលធ្វើសេចក្តីព្យាយាមនោះឯង ឈ្មោះថា **អាសេវតិ** និង **ភាវេតិ** ។ កាលធ្វើនូវសេចក្តីព្យាយាមរឿយៗ ឈ្មោះថា **ពហុលីករោតិ** ។ កាលផ្តើមធ្វើនោះឯង ឈ្មោះថា **អារភតិ** ។ កាលធ្វើរឿយៗ ឈ្មោះថា **សមារភតិ** ។ កាលសេពដោយអំណាចនៃភាវនា ឈ្មោះថា **អាសេវតិ** ។ កាលឲ្យចម្រើន ឈ្មោះថា **ភាវេតិ** ។ កាលធ្វើវត្ថុនោះឯងក្នុងកិច្ចទាំងពួងឲ្យច្រើន គប្បីជ្រាបថា **ពហុលីករោតិ** ។

ក្នុងនិទ្ទេសនៃការផ្គងចិត្ត ព្រះយោគាវចរអ្នកប្រកបដោយការផ្គងនូវការព្យាយាម ឈ្មោះថា **ចិត្តំ បគ្គណ្ហាតិ** អធិប្បាយថា លើកចិត្តឡើង ។ កាលផ្គងចិត្តរឿយៗ ឈ្មោះថា **សម្បគ្គណ្ហាតិ** ។ ចិត្តដែលបុគ្គលផ្គងដោយល្អ រមែងមិនធ្លាក់ទៅដោយប្រការណា កាលឧបត្ថម្ភឋានៈដោយប្រការនោះ ដោយការឧបត្ថម្ភដោយសេចក្តីព្យាយាម ឈ្មោះថា **ឧបត្ថម្ភេតិ** ។ កាលឧបត្ថម្ភចិត្ត ដែលលោកឧបត្ថម្ភហើយរឿយៗ ដើម្បីភាពមាំទាំ ឈ្មោះថា

**បច្ចុបន្នម្ភេតិ ។**

ក្នុងនិទ្ទេសនៃបទថា **ឋិតិយា** ព្រះមានព្រះភាគដើម្បីទ្រង់សម្តែងថា ពាក្យទាំងអស់ មានពាក្យថា **អសម្មោស** ជាដើម ជាវេវចនៈរបស់ពាក្យថា ទើបត្រាស់ពាក្យជាដើមថា ការស្ថិតនៅណា នុ៎ះឈ្មោះថា សេចក្តីមិនវិនាស ។ ពិតហើយ ក្នុងសេចក្តីនេះ ទោះបីពោលថា បទក្រោយៗ ជាពាក្យអធិប្បាយសេចក្តីរបស់បទមុនៗ និងបទមុនៗ ជាពាក្យអធិប្បាយសេចក្តីរបស់បទខាងក្រោយ ដូច្នេះក៏គួរ ។ ពាក្យដ៏សេស ក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។ នេះជាកិច្ចពណ៌នាតាមព្រះបាលីប៉ុណ្ណេះ ។

គប្បីជ្រាបវិនិច្ឆ័យកថាក្នុងព្រះបាលីដូចតទៅ

ពិតហើយ សម្មប្បធានកថានេះ មាន ២ យ៉ាង គឺជាលោកិយម្យ៉ាង ជាលោកុត្តរម្យ៉ាង ។ ក្នុង ២ បទនោះ សម្មប្បធានដែលជាលោកិយ រមែងមានក្នុងបុព្វភាគទាំងអស់ ។ សម្មប្បធាននោះ គប្បីជ្រាបក្នុងខណៈដែលជាលោកិយមគ្គ ដោយបរិយាយនៃកស្សបសំយុត្ត ។

សមដូចលោកពោលក្នុងកស្សបសំយុត្តនោះថា អាវុសោ សម្មប្បធាននេះ មាន ៤ សម្មប្បធាន ៤ តើដូចម្តេច ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ធ្វើនូវសេចក្តីព្យាយាមដុតកម្តៅកិលេស ដោយគិតថា ពួកអកុសលធម៌ដ៏លាមក មិនទាន់កើតឡើងដល់អាត្មាអញ កាលបើកើតឡើងគប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ធ្វើសេចក្តីព្យាយាមដុតកម្តៅកិលេស ដោយគិតថា ពួកអកុសលធម៌ដ៏លាមក កើតឡើងដល់អាត្មាអញហើយ

កាលបើអាត្មាអញមិនបានលះបង់ចេញទេ គប្បីប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ធ្វើសេចក្តីព្យាយាមដុតកម្តៅកិលេស ដោយគិតថា ពួកកុសល-ធម៌ ដែលមិនទាន់កើតឡើងដល់អាត្មាអញ កាលបើមិនទាន់កើតឡើង គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ធ្វើសេចក្តីព្យាយាមដុតកម្តៅកិលេស ដោយគិតថា ពួកកុសលធម៌ដែលកើតឡើងដល់អាត្មាអញហើយ កាលបើរលត់ទៅវិញ គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដូច្នេះ ។

ក្នុងពាក្យថា ពួកកុសលធម៌ ដែលមិនទាន់កើតឡើងដល់អាត្មាអញនេះ បានដល់ សមថៈ វិបស្សនា និងមគ្គ ។ សមថៈ វិបស្សនានោះឯង ឈ្មោះថា ពួកកុសលធម៌ដែលកើតឡើងហើយ ។ ចំណែកមគ្គកើតម្តងហើយ ក៏រលត់ទៅ ឈ្មោះថា គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ក៏មិនមែន ព្រោះថា មគ្គនោះ ឲ្យបច្ច័យដល់ផលនោះឯង ហើយក៏រលត់ទៅ ។

ម្យ៉ាងទៀត លោកពោលថា ក្នុងបទមុន គប្បីកាន់យកចំពោះសមថៈ វិបស្សនា សេចក្តីនោះ មិនគួរ ។ ក្នុងសេចក្តីនោះ ដើម្បីអធិប្បាយឲ្យជាក់ច្បាស់នូវអត្ថថា សមថៈ វិបស្សនាដែលកើតឡើងហើយ កាលរលត់ទៅ រមែងមិនប្រព្រឹត្តទៅ ដើម្បីវត្ថុមិនមែនប្រយោជន៍ ។

គប្បីជ្រាបរឿងដូចតទៅនេះ បានឮថា ព្រះថេរៈទីណាស្រែពមួយអង្គ ជាមួយសាមណេរអ្នកកាន់កណ្ណៈដែលបានសមាបត្តិ មកកាន់មហាវិហារអំពីជនបទ ដោយគិតថា អញនឹងថ្វាយបង្គំមហាចេតិយ និងមហាពោធិព្រឹក្ស ដូច្នេះហើយ ចូលទៅកាន់វិហារបរិវេណ ។ កាលមហាភិក្ខុសង្ឃថ្វាយបង្គំ

ព្រះចេតិយនៅក្នុងពេលល្ងាច លោកមិនបានចេញទៅដើម្បីថ្វាយបង្គំព្រះចេតិយ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះព្រះទីណាស្រេពទាំងឡាយ ជាអ្នកគោរពក្នុងព្រះរតនត្រ័យច្រើន ព្រោះហេតុនោះ កាលភិក្ខុសង្ឃថ្វាយបង្គំហើយចៀសចេញទៅ ទើបព្រះថេរៈគិតថា ក្នុងពេលដែលមនុស្សទាំងឡាយបរិភោគអាហារពេលល្ងាច អញនឹងមិនឲ្យបុគ្គលណាដឹង សូម្បីតែសាមណេរហើយនឹងទៅថ្វាយបង្គំព្រះចេតិយ ដូច្នេះហើយ ចេញទៅតែម្នាក់ឯង ។

សាមណេរគិតថា ព្រោះហេតុអ្វីហ្ន៎ ទើបព្រះថេរៈជាបុគ្គលតែឯង ទៅក្នុងពេលដែលមិនសមគួរ អញនឹងជ្រាបហេតុនោះ ទើបដើរតាមអំពីក្រោយឧបជ្ឈាយ៍របស់ខ្លួនចេញទៅ ។ ព្រះថេរៈមិនបានពិចារណា ទើបមិនដឹងការមករបស់សាមណេរ ហើយឡើងទៅកាន់លានព្រះមហាចេតិយតាមផ្លូវទិសខាងត្បូង សាមណេរក៏ឡើងទៅតាមផ្លូវនោះដូចគ្នា ។ ព្រះថេរៈសម្លឹងព្រះមហាចេតិយហើយ កាន់យកបីតិដែលមានពុទ្ធគុណជាអារម្មណ៍ សមោធានមកនូវពុទ្ធគុណដោយចិត្ត ជាអ្នកត្រេកអរហើយ ត្រេកអរក្រៃលែងហើយថ្វាយបង្គំព្រះមហាចេតិយ ។ សាមណេរឃើញអាការ គឺកិរិយាដែលថ្វាយបង្គំរបស់ព្រះថេរៈ ទើបគិតថា ឧបជ្ឈាយ៍របស់អញមានចិត្តជ្រះថ្លាក្រៃលែងថ្វាយបង្គំ លោកបានផ្កាហើយ គប្បីធ្វើការបូជាឬ ដូច្នេះ កាលព្រះថេរៈថ្វាយបង្គំក្រោកឡើងហើយ ក៏ផ្គងអញ្ជលីលើសិរសា ឈរសម្លឹងមើលព្រះមហា-ចេតិយ សាមណេរក៏គ្រហែមឲ្យព្រះថេរៈជ្រាបភាពដែលខ្លួនមកហើយ ។

ព្រះថេរៈងាកមើលហើយសួរថា អ្នកមកពីអង្កាល់ សាមណេរប្រាប់ថា

បពិត្រលោកម្ចាស់ ក្នុងកាលដែលលោកម្ចាស់ថ្វាយបង្គំព្រះចេតិយ លោកម្ចាស់មានចិត្តជ្រះថ្លាក្រៃលែង ថ្វាយបង្គំព្រះចេតិយ លោកម្ចាស់បានផ្កាទាំងឡាយហើយ គប្បីបូជាឬ ព្រះថេរៈពោលថា អើសាមណេរ ខ្ញុំនឹងបូជា ឈ្មោះថា ទីបញ្ចុះព្រះធាតុ មានប្រមាណប៉ុណ្ណេះក្នុងទីដទៃ ដូចក្នុងព្រះចេតិយនេះមិនមាន មហាស្តូបបែបនេះ មិនដូចស្តូបដទៃ អ្នកណាមួយបានផ្កាហើយ មិនគប្បីបូជានោះ ។

សាមណេរប្រាប់ថា បពិត្រលោកម្ចាស់ បើយ៉ាងនោះសូមលោកម្ចាស់បង្អង់សិន ខ្ញុំនឹងនាំផ្កាមក ហើយចូលឈានក្នុងខណៈនោះឯង ទៅកាន់ព្រៃហិមពាន្តដោយឫទ្ធិ កាន់យកផ្កាទាំងឡាយដែលដល់ព្រមដោយពណ៌ និងក្លិន ដាក់ពេញធម្មក្រកហើយ កាលព្រះថេរៈទៅអំពីមុខខាងត្បូង មិនទាន់ដល់មុខទិសខាងកើត សាមណេរក៏មក ហើយប្រគេនធម្មក្រកដែលដាក់ផ្កាក្នុងដៃ ( ព្រះថេរៈ ) ហើយប្រាប់ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់បូជាចុះ ។ ព្រះថេរៈពោលថា សាមណេរ ផ្ការបស់អ្នកតិចពេក សាមណេរប្រាប់ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ នឹកដល់គុណទាំងឡាយរបស់ព្រះមានព្រះភាគ ហើយបូជាចុះ ។

ព្រះថេរៈឈានឡើងទៅតាមជណ្តើរ ត្រង់ទិសខាងលិចហើយ ផ្តើមធ្វើការបូជាដោយផ្កា ក្នុងវេទបូជាខាងក្នុងចេតិយ ។ ផ្ទៃនៃវេទបូជាក៏ពេញដោយផ្កាទាំងឡាយ ផ្កាទាំងឡាយក៏ធ្លាក់ទៅកាន់ផ្ទៃខាងក្រោម មានកម្ពស់ស្មើក្បាលជង្គង់ បន្ទាប់អំពីនោះ ព្រះថេរៈក៏ចុះទៅក្រោម ហើយបូជាខាង

ក្រោយរបៀងព្រះចេតិយ របៀងនោះ ក៏ពេញដោយជុំវិញហើយ ។ ព្រះថេរៈជ្រាបភាពដែលផ្កាទាំងនោះពេញជុំវិញហើយ ទើបពោយផ្កាក្នុងផ្ទៃខាងក្រោម ហើយទើបនិមន្តទៅ ។ លានព្រះចេតិយទាំងមូល ក៏មានផ្កាពេញជុំវិញហើយ កាលលានព្រះចេតិយមានផ្កាពេញជុំវិញហើយ ទើបព្រះថេរៈពោលថា សាមណេរ ផ្កាមិនទាន់អស់ឡើយ សាមណេរប្រាប់ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ផ្កាប់ធម្មក្រក ព្រះថេរៈក៏ផ្កាប់មាត់ធម្មក្រកហើយរលាស់ ផ្កាទាំងឡាយ ក៏អស់ទៅក្នុងកាលនោះ ។

ព្រះថេរៈ ឲ្យធម្មក្រកដល់សាមណេរហើយ ធ្វើប្រទក្សិណព្រះចេតិយនិមន្តទៅតាមកំពែងប្រមាណ ៦០ ហត្ថ ថ្វាយបង្គំក្នុងទិសទាំង ៤ ខណៈដែលកំពុងនិមន្តទៅកាន់បរិវេណ គិតថា សាមណេរនេះមានឫទ្ធិច្រើន អាចរក្សាឥទ្ធានុភាពនេះបានដែរឬទេហ្ន៎ ក្នុងលំដាប់នោះក៏ជ្រាបថា សាមណេរនេះមិនអាចរក្សាឥទ្ធានុភាពបាន ទើបពោលនឹងសាមណេរថា នែសាមណេរឥឡូវនេះ អ្នកមានឫទ្ធិច្រើន តែក្នុងកាលចុងក្រោយ ឫទ្ធិបែបនេះ នឹងវិនាសទៅ អ្នកនឹងផឹកទឹកបាយដែលស្រីតម្បាញភ្នែកខ្វាក់ម្ខាង យកដៃច្របាច់ហើយដូច្នេះ ។ ឫទ្ធិដែលវិនាសទៅនេះ ជាកំហុសក្នុងរបស់វ័យក្មេង ។ សាមណេរនោះសង្វេគដោយពាក្យរបស់ឧបជ្ឈាយ៍ ហើយក៏មិនបានពោលសូមកម្មដ្ឋានថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ប្រាប់កម្មដ្ឋានដល់ខ្ញុំ ដូច្នេះ ។ តែគិតថា ឧបជ្ឈាយ៍របស់អញនិយាយអ្វី បាននិមន្តទៅហើយ ដូចបុគ្គលមិនបានឮនូវពាក្យនោះ ។

ព្រះថេរៈកាលថ្វាយបង្គំព្រះចេតិយ និងមហាពោធិ៍ហើយ ឲ្យសាមណេរកាន់បាត្រ និងចីវរ បានទៅកាន់មហាវិហារ ឈ្មោះកុដេឡិតិស្សៈដោយលំដាប់ សាមណេរមិនធ្លាប់ដើរតាមឧបជ្ឈាយ៍ទៅបិណ្ឌបាត ទើបសួរព្រះថេរៈថា បពិត្រលោកម្ចាស់ៗ ទៅកាន់ស្រុកណា កាលជ្រាបថា ឥឡូវនេះឧបជ្ឈាយ៍របស់ខ្លួននឹងដល់ទ្វារស្រុកហើយ ទើបកាន់បាត្រ និងចីវររបស់ខ្លួន និងរបស់ឧបជ្ឈាយ៍មកតាមអាកាស ប្រគេនបាត្រ និងចីវរដល់ព្រះថេរៈហើយ ទើបចូលទៅដើម្បីបិណ្ឌបាត ។ ព្រះថេរៈ បានពោលដាស់តឿនសាមណេរអស់កាលទាំងពួងថា សាមណេរ អ្នកកុំធ្វើយ៉ាងនេះ ឈ្មោះថា ឫទ្ធិរបស់បុថុជ្ជន ជាសភាវៈញាប់ញ័រ មិនពិតប្រាកដ បានទូវអារម្មណ៍ មានរូបជាដើមដែលជាអសប្បាយហើយ រមែងវិនាសទៅដោយហេតុត្រឹមបន្តិចបន្តួចប៉ុណ្ណោះ កាលសមាបត្តិដែលមានវិនាសទៅហើយ បុថុជ្ជនទាំងឡាយ រមែងមិនអាចតាំងមាំ ក្នុងការនៅប្រព្រឹត្តព្រហ្មចរិយៈ ដូច្នេះ ។ សាមណេរគិតថា ឧបជ្ឈាយ៍របស់អញនិយាយអ្វី មិនប្រាថ្នានឹងស្តាប់ ធ្វើយ៉ាងនោះឯង ។ ព្រះថេរៈកាលធ្វើការថ្វាយបង្គំព្រះចេតិយដោយលំដាប់ហើយ ទៅកាន់វិហារ ឈ្មោះកម្ពុបេទុវិហារ ។ កាលព្រះថេរៈនៅក្នុងវិហារនោះ សាមណេរក៏នៅតែធ្វើយ៉ាងនោះ ។

ថ្ងៃមួយ កូនស្រីរបស់ជាងតម្បាញម្នាក់មានរូបស្អាត តាំងនៅក្នុងបឋមវ័យ ចេញអំពីស្រុកកម្ពុបេទុះហើយ ចុះកាន់ស្រះឈូក ស្រែកច្រៀងបេះផ្កាឈូក ។ ក្នុងសម័យនោះ សាមណេរហោះខាងលើស្រះឈូក ស្តាប់

សំឡេងច្រៀងរបស់ស្ត្រីហើយ ហាក់ដូចសត្វល្អិតក្អែកខ្វាក់ ជាប់ចិត្តក្នុងរស ផ្អែម ក្នុងខណៈនោះ ឫទ្ធិក៏អន្តរធានទៅ សាមណេរហាក់ដូចក្អែកបាក់ស្លាប ដូច្នោះ តែដោយកម្លាំងនៃសមាបត្តិនៅមាន សាមណេរមិនធ្លាក់ទៅក្នុងទឹកក្នុង ស្រះនោះ បានឈរហើយត្រង់ប្រាំងនៃស្រះឈូក ហាក់ដូចសំឡីរកាដែលធ្លាក់ ចុះមកយឺតៗ ដូច្នោះ ។ សាមណេរប្រញាប់ត្រឡប់មកដោយរហ័ស ប្រគេន បាត្រ និងចីវរដល់ឧបជ្ឈាយ៍ហើយ ក៏ត្រឡប់ទៅ ។ ព្រះមហាថេរៈមិនបាន ពោលពាក្យណាមួយ ដោយគិតថា នឹងពោលទៅអ្វីរឿងនោះ អាត្មាអញ ឃើញហើយ សាមណេរទោះបីអញឃាត់ក៏មិនត្រឡប់ ទើបនិមន្តទៅបិណ្ឌ-បាត ។ ចំណែកសាមណេរបានទៅឈរត្រង់ប្រាំងនៃស្រះឈូក រង់ចាំកូន ស្រីជាងតម្បាញនោះឡើងមក ។

សូម្បីធីតានោះ ក៏ឃើញសាមណេរដែលទៅតាមអាកាស និងត្រឡប់ មកឈរ ក៏ជ្រាបបានថា សាមណេរនេះអាស្រ័យអញទើបអផ្សុក ដូច្នេះ ទើបពោលថា នៃសាមណេរ សូមលោកម្ចាស់ចៀសចេញទៅ សាមណេរ នោះក៏ចៀសចេញទៅ ធីតាជាងតម្បាញក៏ឡើងអំពីស្រះ ស្លៀកដណ្តប់សំពត់ ហើយ ចូលទៅរកសាមណេរសួរថា តើមានរឿងអ្វីឬ សាមណេរនោះបានប្រាប់ សេចក្តីនោះហើយ ធីតានោះសម្តែងទោសក្នុងការនៅគ្រប់គ្រងផ្ទះ ដោយ ហេតុជាច្រើន និងសម្តែងអានិសង្សក្នុងការនៅប្រព្រឹត្តព្រហ្មចរិយៈ ដាស់ តឿន ក៏មិនអាចឲ្យសាមណេរនោះបន្ទោបង់ការអផ្សុកបាន ទើបគិតថា សាមណេរនេះ វិនាសចាកឫទ្ធិបែបនេះព្រោះអញ ឥឡូវនេះ អញមិនគួរ

បោះបង់ ដូច្នេះ ទើបពោលថា សូមឈរក្នុងទីនេះសិន ហើយត្រឡប់ទៅផ្ទះ បានប្រាប់រឿងនោះដល់ឪពុកម្តាយរបស់នាង ។

មាតាបិតាបានទៅហើយ ឲ្យឱវាទដល់សាមណេរ មានប្រការផ្សេងៗ បានពោលពាក្យដែលមិនស្វាគមន៍ថា លោកម្ចាស់ កុំសម្គាល់ថា ពួកខ្ញុំមានត្រកូលខ្ពស់ ពួកខ្ញុំទាំងអស់គ្នាជាជាងតម្បាញ លោកម្ចាស់មិនអាចធ្វើការងាររបស់ជាងតម្បាញបានឡើយ សាមណេរពោលថា នែឧបាសក ឈ្មោះថាគ្រហស្ថត្រូវធ្វើអ្វីមួយ ទោះជាការងាររបស់ជាងតម្បាញ ឬជាការងាររបស់ជាងផែងក៏ដោយ តើមានបញ្ហាអ្វីដោយការងារនេះ សូមអ្នកកុំហួងហែងសំពត់ស្លៀកឡើយ ។ ជាងតម្បាញបានឲ្យសំពត់សាដកដែលក្រវាត់ចង្កេះ ហើយនាំទៅកាន់ផ្ទះលើកធីតាឲ្យ ។

មាណពនោះ រៀនការងាររបស់ជាងតម្បាញហើយ ធ្វើការងារត្រង់រោងជាងតម្បាញ ជាមួយពួកជាងតម្បាញទាំងឡាយ ។ ស្រីទាំងឡាយរបស់ក្រុមគ្រួសារដទៃ រៀបចំអាហារហើយ នាំមកអំពីព្រលឹម តែភរិយារបស់មាណពនោះ មិនទាន់មក កាលជនទាំងឡាយដែលជាកម្មករបរិភោគអាហារ មាណពនោះ នៅអង្គុយរវៃអំបោះនៅឡើយ ភរិយារបស់គេមកក្នុងកាលឯក្រោយ ។ លំដាប់នោះ មាណពនោះក៏សម្តុតភរិយាដោយពាក្យថា នាងមកយឺតម៉្លេះ ។

ធម្មតាមាតុគ្រាមជ្រាបចិត្ត ដែលបុគ្គលណាមួយមានសេចក្តីស្រឡាញ់ក្នុងខ្លួនហើយ រមែងសម្គាល់បុគ្គលទាំងឡាយ សូម្បីជាស្តេចចក្រពត្តិថា

*ហាក់ដូចជាទាសៈ ព្រោះហេតុនោះ ទើបស្រីនោះពោលយ៉ាងនេះថា ក្នុងផ្ទះរបស់ជនដទៃមានឧស បន្លែ អំបិលជាដើមដែលសន្សំហើយ សូម្បីពួកជាងតម្បាញដែលនាំរបស់អំពីខាងក្រៅមកឲ្យក៏មាន ឯខ្ញុំម្នាក់ឯង អ្នកក៏មិនដឹងថា ក្នុងផ្ទះរបស់ខ្ញុំ របស់នេះមាន របស់នេះមិនមាន បើអ្នកត្រូវការចូរបរិភោគ បើមិនត្រូវការកុំបរិភោគឡើយ ។ មាណពនោះក្រោធហើយ ដោយគិតថា ស្រីនេះមិនមែនគ្រាន់តែនាំអាហារមកយឺតតែម្យ៉ាង នៅហ៊ានស៊ិកសៀតអញដោយវាចានេះ កាលមិនឃើញគ្រឿងប្រហារដទៃ ទើបចាប់ត្រល់សម្រាប់តម្បាញនោះឯង ហើយគ្រវែងទៅ ។ ស្រីនោះឃើញត្រល់សោត់មកក៏គេចបន្តិច ។ ធម្មតាត្រល់មានចុងស្រួច កាលស្រីនោះកំពុងគេច ចុងត្រល់ក៏ចំត្រង់កែវភ្នែក នាងប្រញាប់យកដៃទាំងពីរខ្ទប់ភ្នែក ។ ឈាមហូរចេញអំពីភ្នែកដែលបែក ។*

*មាណពនោះ រឭកដល់ពាក្យឧបជ្ឈាយ៍បានក្នុងពេលនោះ ទើបទ្រហោយំដោយសំឡេងខ្លាំងថា ឧបជ្ឈាយ៍របស់អញសំដៅយកហេតុនេះថា ក្នុងអនាគត អញនឹងផឹកទឹកបាយដែលស្រីតម្បាញភ្នែកខ្វាក់ម្ខាង យកដៃច្របាច់ឥឡូវនេះ ហេតុនេះជាហេតុដែលព្រះថេរៈឃើញហើយ ឱលោកម្ចាស់ ឃើញកាលវែងហ្ន៎ ។ ជាងតម្បាញទាំងឡាយលួងលោមថា អ្នកកុំយំឡើយ ធម្មតាភ្នែកបែកហើយ ទោះបីបុគ្គលយំ ក៏មិនអាចធ្វើភ្នែកឲ្យជាប្រក្រតីបាន មាណពនោះពោលថា ខ្ញុំមិនមែនយំព្រោះហេតុនេះឡើយ ដែលពិត ខ្ញុំយំ សំដៅដល់រឿងនេះ ហើយទើបប្រាប់ការប្រព្រឹត្តទៅទាំងអស់ ដោយលំដាប់ ។*

សមថៈ វិបស្សនាដែលកើតឡើងហើយ កាលរលត់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីវត្ថុមិនជាប្រយោជន៍ ដូចពណ៌នាមកនេះ ។

មានរឿងមួយទៀត ភិក្ខុប្រមាណ ៣០ រូប ថ្វាយបង្គំព្រះមហាចេតិយដ៏ល្អហើយ ក៏ចុះកាន់ផ្លូវធំកាត់ព្រៃជ្រៅ ក្នុងរវាងផ្លូវ បានជួបបុរសម្នាក់ដែលធ្វើការងារក្នុងចម្ការ ដែលភ្លើងឆេះកំពុងមក ។ រាងកាយរបស់បុរសនោះ ប្រឡាក់ដោយធ្យូង ។ សំពត់កាសាវៈមួយផ្ទាំងដែលប្រឡាក់ធ្យូងដែលគាត់ជ្រៀបក្លៀកស្លៀកហើយ កាលបុគ្គលណាម្នាក់សម្លឹងមើលបុរសនោះ ប្រាកដហាក់បីដូចជង្គត់ឈើដែលត្រូវភ្លើងឆេះ ។ បុរសនោះធ្វើការងារទាំងកណ្ដាលថ្ងៃស្រេចហើយ ទើបលើកបាច់ឧសដែលភ្លើងឆេះពាក់កណ្ដាលដាក់លើស្មា មានសក់កន្ទ្រើងដើរក្បែរផ្លូវ មកឈប់ត្រង់មុខភិក្ខុទាំងឡាយ ។

ពួកសាមណេរឃើញហើយ ក៏មើលមុខគ្នាពោលថា ន៎ុះឪរបស់លោកឯង ន៎ុះជីតារបស់លោកឯង ន៎ុះអ៊ំរបស់លោកឯងដូច្នេះ សើចហើយ សួរថា នែឧបាសក អ្នកឈ្មោះអ្វី ។

បុរសនោះកាលត្រូវសួរដល់ឈ្មោះ ក៏មានការក្ដៅក្រហាយចិត្ត ទម្លាក់បាច់ឧសចោល រៀបចំសំពត់ស្លៀក ថ្វាយបង្គំព្រះមហាថេរៈហើយ ពិតថាបពិត្រលោកម្ចាស់ សូមលោកម្ចាស់ឈប់សិន ។ ព្រះថេរៈទាំងឡាយបានឈប់ហើយ ពួកសាមណេរដែលមកចំពោះមុខព្រះថេរៈទាំងឡាយ ក៏នៅតែធ្វើការសើចលេង ។ បុរសនោះពោលថា បពិត្រលោកម្ចាស់ៗ ឃើញរូបខ្ញុំហើយ សើច យល់ថា ពួកអញដល់ទីបំផុតហើយ ដោយហេតុមានប្រមាណ

ប៉ុណ្ណោះឬ ក្នុងកាលមុន ខ្ញុំក៏ជាសមណៈដូចលោកម្ចាស់ទាំងឡាយនោះឯង សូម្បីតែឯកគ្គតាចិត្តរបស់ពួកលោកម្ចាស់ ក៏មិនមាន ចំណែកខ្ញុំ ជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើនក្នុងសាសនានេះ ខ្ញុំធ្វើអាកាសឲ្យជាផែនដី ធ្វើផែនដីឲ្យជាអាកាស កាន់យកផ្លូវឆ្ងាយធ្វើឲ្យជិត កាន់យកធ្វើផ្លូវជិត ធ្វើឲ្យឆ្ងាយ ខ្ញុំទៅមួយពាន់ចក្កវាឡដោយមួយរំពេច តែឥឡូវនេះ សូមលោកម្ចាស់ទាំងឡាយមើលដៃរបស់ខ្ញុំ ដែលដូចគ្នានឹងដៃស្វា កាលពីមុន ខ្ញុំអង្គុយក្នុងលោកនេះ យកដៃទាំងពីរស្ទាបព្រះចន្ទ និងព្រះអាទិត្យបាន ខ្ញុំអង្គុយហើយ ធ្វើព្រះចន្ទ និងព្រះអាទិត្យឲ្យដូចជាកំណល់សម្រាប់លាងជើងក៏បាន ឫទ្ធិរបស់ខ្ញុំបែបនេះអន្តរធានទៅហើយ ដោយសេចក្តីប្រមាទ សូមលោកម្ចាស់ទាំងឡាយកុំប្រមាទ ព្រោះសត្វទាំងឡាយដែលដល់នូវសេចក្តីវិនាសបែបនេះ ដ្បិតសេចក្តីប្រមាទ សត្វទាំងឡាយជាអ្នកមិនប្រមាទ នឹងធ្វើទីបំផុតនៃជាតិ ជរា និងមរណៈបាន ព្រោះហេតុនោះ សូមលោកម្ចាស់ទាំងឡាយ ធ្វើខ្ញុំឲ្យជាអារម្មណ៍ហើយ សូមជាអ្នកមិនប្រមាទចុះ កាលគំរាមហើយ បានឲ្យនូវឱវាទ ។

កាលបុរសនោះពោលយ៉ាងនោះឯង ភិក្ខុសាមណេរទាំង ៣០ អង្គនោះ ដល់នូវសេចក្តីសង្វេគហើយចម្រើនវិបស្សនា ក៏សម្រេចអរហត្តក្នុងទីនោះឯង ។

សមថៈ វិបស្សនាដែលកើតឡើងហើយយ៉ាងនេះ កាលវិនាសទៅ បណ្ឌិតគប្បីជ្រាបថា រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដូចពណ៌នាមកដូច្នេះ ។ វិនិច្ឆ័យលោកិយសម្មប្បធានកថា មានប្រមាណប៉ុណ្ណោះសិន ។

ក្នុងខណៈលោកុត្តរមគ្គ សេចក្ដីព្យាយាមនោះតែម្យ៉ាងនោះឯង រមែងបានឈ្មោះ ៤ យ៉ាង ដោយអំណាចនៃការញ៉ាំងកិច្ច ៤ យ៉ាងឲ្យសម្រេច ។

បណ្ដាបទទាំងនោះ បទថា **អនុប្បន្នានំ** បានដល់ អកុសលធម៌ដ៏លាមក ដែលមិនទាន់កើតឡើង ដោយអំណាចនៃការមិនប្រាកដ ឬដោយអំណាចនៃអារម្មណ៍ដែលមិនធ្លាប់សេព ។ ពិតហើយ កាលពោលដោយប្រការដទៃក្នុងសង្សារ ដែលមិនមានទីបំផុតខាងដើម និងខាងចុង ឈ្មោះថា អកុសលធម៌ដ៏លាមក ដែលមិនធ្លាប់កើតឡើង មិនមាន ឯអកុសលធម៌ដ៏លាមក ដែលមិនទាន់កើតឡើង កាលកើត គឺអកុសលធម៌ដ៏លាមកទាំងនោះឯង កើតឡើង កាលលះ គឺអកុសលធម៌ដ៏លាមកទាំងនោះឯង ។

ក្នុងបទថា **អនុប្បន្នានំ** នោះ កិលេសទាំងឡាយ រមែងមិនប្រាកដដោយអំណាចនៃវត្តរបស់ភិក្ខុរូបខ្លះ គឺរមែងមិនប្រាកដដល់ភិក្ខុរូបខ្លះ ដោយអំណាចនៃវត្តណាមួយនៃគន្ថៈ ធុតង្គ សមាធិ វិបស្សនា នវកម្ម និងភព ។ កិលេសទាំងឡាយ រមែងមិនប្រាកដដោយអំណាចនៃវត្តដូចម្ដេច ។ ភិក្ខុរូបខ្លះ ដែលជាអ្នកដល់ព្រមដោយវត្តមាន កាលភិក្ខុនោះធ្វើនូវវត្តតូចៗ ៨២ មហាវត្ត ១៤ និងចេតិយង្គណវត្ត ពោធិយង្គណវត្ត បានីយវត្ត មាឡវត្ត ឧបោសថាគារវត្ត អាគន្តុកវត្ត និងគមិកវត្តនោះឯង កិលេសទាំងឡាយ រមែងមិនបានឱកាស ។ ក្នុងកាលដទៃទៀត កាលភិក្ខុលះបង់វត្ត មានវត្តដាច់ហើយត្រាច់ទៅ កិលេសទាំងឡាយ អាស្រ័យអយោនិសោមនសិការ និងការលះបង់សតិហើយ រមែងកើតឡើង ។ កិលេសទាំងឡាយ ដែលមិន

ទាន់កើតឡើង ដោយអំណាចនៃការមិនប្រាកដ ឈ្មោះថា រមែងកើតឡើងបាន ដោយអាការយ៉ាងនេះ ។

ភិក្ខុរូបខ្លះ ប្រកបក្នុងការរៀនសូត្រ កាន់យកពុទ្ធវចនៈ ១ និកាយខ្លះ ២ និកាយខ្លះ ៣ និកាយខ្លះ ៤ និកាយខ្លះ ៥ និកាយខ្លះ កាលភិក្ខុនោះឯងរៀន ស្វាធ្យាយ គិត ប្រាប់ សម្ដែង ប្រកាស នូវព្រះត្រៃបិដក គឺពុទ្ធ-វចនៈ ដោយអំណាចនៃអត្ថ ដោយអំណាចនៃបាលី ដោយអំណាចនៃអនុសន្ធិ ដោយអំណាចនៃបទដើម និងបទចុង កិលេសទាំងឡាយមិនបានឱកាស ។ តែក្នុងកាលដទៃទៀត ភិក្ខុនោះលះបង់នូវការសិក្សា ជាអ្នកខ្ជិលច្រអូសត្រាច់ទៅ កិលេសទាំងឡាយ អាស្រ័យអយោនិសោមនសិការ និងការលះបង់សតិហើយ រមែងកើតឡើង ។ កិលេសទាំងឡាយ ដែលមិនទាន់កើតឡើង ដោយអំណាចនៃការមិនប្រាកដ ឈ្មោះថា រមែងកើតឡើងបាន ដោយប្រការយ៉ាងនេះ ។

ម្យ៉ាងទៀត ភិក្ខុរូបខ្លះ ជាអ្នកទ្រទ្រង់ធុតង្គ សមាទានធុតង្គគុណ ១៣ ។ កាលភិក្ខុនោះបរិហារធុតង្គគុណទាំងឡាយ កិលេសទាំងឡាយមិនបានឱកាស តែក្នុងកាលដទៃទៀត ភិក្ខុនោះ លះបង់នូវធុតង្គទាំងឡាយហើយ វិលមកដើម្បីភាពជាអ្នកប្រាថ្នាច្រើន ត្រាច់ទៅ កិលេសទាំងឡាយអាស្រ័យនូវអយោនិសោមនសិការ និងការលះបង់សតិហើយ រមែងកើតឡើង ។ កិលេសទាំងឡាយ ដែលមិនទាន់កើតឡើង ដោយអំណាចនៃការមិនប្រាកដ ឈ្មោះថា រមែងកើតឡើងបាន ដោយអាការយ៉ាងនេះ ។

ភិក្ខុរបខ្លះ ជាអ្នកជំនាញក្នុងសមាបត្តិ ៨ ភិក្ខុនោះនៅក្នុងអំណាចនៃអាវជ្ជនវសីជាដើម ក្នុងបឋមជ្ឈានជាដើម កិលេសទាំងឡាយ រមែងមិនបានឱកាស ។ តែក្នុងកាលដទៃទៀត ភិក្ខុនោះសាបសូន្យចាកឈាន ឬលះបង់ឈានចោលក្តី ជាអ្នកប្រកបរឿយៗ ក្នុងការនិយាយពាក្យឥតប្រយោជន៍ជាដើម កិលេសទាំងឡាយអាស្រ័យអយោនិសោមនសិការ និងការលះបង់សតិហើយ រមែងកើតឡើង ។ កិលេសទាំងឡាយដែលមិនទាន់កើតឡើងដោយអំណាចនៃការមិនប្រាកដ ឈ្មោះថា រមែងកើតឡើងបាន ដោយអាការយ៉ាងនេះ ។

ភិក្ខុរបខ្លះ ជាអ្នកបដិបត្តិវិបស្សនា ធ្វើនូវកម្មក្នុងអនុបស្សនា ៧ ឬមហាវិបស្សនា ១៨ ប្រព្រឹត្តទៅ កាលភិក្ខុនោះ បដិបត្តិយ៉ាងនោះ កិលេសទាំងឡាយរមែងមិនបានឱកាស តែក្នុងកាលដទៃទៀត ភិក្ខុនោះលះបង់នូវកម្មនៃវិបស្សនា ជាអ្នកច្រើនដោយការធ្វើរាងកាយឲ្យរឹងប៉ឹង កិលេសទាំងឡាយអាស្រ័យអយោនិសោមនសិការ និងការលះបង់សតិហើយ រមែងកើតឡើង កិលេសទាំងឡាយដែលមិនទាន់កើតឡើង ដោយអំណាចនៃការមិនប្រាកដ ឈ្មោះថា រមែងកើតឡើងបាន ដោយអាការយ៉ាងនេះ ។

ភិក្ខុរបខ្លះ ជានវកម្មិក គឺជាអ្នកកសាង រមែងធ្វើរោងឧបោសថ និងរោងភត្តជាដើម កាលភិក្ខុនោះគិតដល់ឧបករណ៍ ក្នុងរោងឧបោសថទាំងនោះជាដើម កិលេសទាំងឡាយ រមែងមិនបានឱកាស តែក្នុងកាលដទៃទៀត កាលនវកម្មរបស់ភិក្ខុនោះសម្រេចហើយ ឬជាអ្នកលះបង់នវកម្មហើយ កិលេស

ទាំងឡាយអាស្រ័យអយោនិសោមនសិការ និងការលះបង់សតិហើយ រមែង កើតឡើង កិលេសទាំងឡាយដែលមិនទាន់កើតឡើង ដោយអំណាចនៃការ មិនប្រាកដ ឈ្មោះថា រមែងកើតឡើងបាន ដោយអាការយ៉ាងនេះ ។

ភិក្ខុរូបខ្លះ មកអំពីព្រហ្មលោក ជាសត្វបរិសុទ្ធ កិលេសទាំងឡាយ មិនបានឱកាស ព្រោះមិនមានការសេព ។ តែក្នុងកាលដទៃទៀត បុគ្គលនោះ មានការសេពដែលបានហើយ កិលេសទាំងឡាយ អាស្រ័យអយោនិសោ-មនសិការ និងការលះបង់សតិ រមែងកើតឡើង ។ កិលេសទាំងឡាយដែល មិនទាន់កើតឡើង ដោយអំណាចនៃការមិនប្រាកដ ឈ្មោះថា រមែងកើត ឡើងបាន ដោយអាការយ៉ាងនេះ ។

គប្បីជ្រាបថា កិលេសទាំងឡាយមិនទាន់កើតឡើង ដោយអំណាចនៃ ការមិនប្រាកដ ដូចពណ៌នាមក ដូច្នេះ ។

អកុសលធម៌ដ៏លាមកដែលមិនទាន់កើតឡើង ដោយអំណាចនៃអារម្មណ៍ ដែលមិនធ្លាប់សេព តើដូចម្តេច ។

ភិក្ខុរូបខ្លះ ក្នុងសាសនានេះ បានអារម្មណ៍ មានអារម្មណ៍ជាទីពេញចិត្ត ជាដើមដែលមិនធ្លាប់សេព ។ កិលេសទាំងឡាយ មានរាគៈជាដើមអាស្រ័យ អយោនិសោមនសិការ និងការលះបង់សតិក្នុងអារម្មណ៍នោះហើយ រមែង កើតឡើងដល់ភិក្ខុនោះបាន ។ កិលេសទាំងឡាយ ដែលមិនទាន់កើតឡើង ដោយអំណាចនៃអារម្មណ៍ដែលមិនធ្លាប់សេព ឈ្មោះថា រមែងកើតឡើងបាន ដោយអាការយ៉ាងនេះ ។ តែក្នុងខណៈនៃលោកុត្តរមគ្គ វីរិយៈមានមួយ

*ប៉ុណ្ណោះ កិលេសទាំងឡាយ ដែលមិនទាន់កើតឡើងយ៉ាងនេះ ដែលគប្បីកើតឡើង រមែងមិនកើតឡើងបានដោយប្រការណា សេចក្តីព្យាយាម រមែងធ្វើកិច្ច គឺការញុំាងកិលេសទាំងនោះ មិនឲ្យកើតឡើង និងរមែងធ្វើកិច្ច គឺការលះបង់កិលេសទាំងនោះ ដែលកើតឡើងហើយ ឲ្យសម្រេចដោយប្រការនោះ ព្រោះហេតុនោះ ក្នុងបទថា* **ឧប្បន្នានំ ចាបកានំ** *នេះ ទើបបានឧប្បន្ន គឺកិលេសដែលកើតឡើងហើយ ៤ យ៉ាង គឺវត្តមានុប្បន្ន ១ ភុត្វាវិគតុប្បន្ន ១ ឱកាសកតុប្បន្ន ១ ភូមិលទ្ធុប្បន្ន ១ ។*

*បណ្តាឧប្បន្នធម៌ទាំង ៤ នោះ កិលេសពួកណាមាន ជាសភាវៈដល់ព្រមដោយឧប្បាទជាដើម នេះឈ្មោះថា* **វត្តមានុប្បន្ន** *( កើតឡើងប្រព្រឹត្តទៅក្នុងខណៈទាំង ៣ ) ។ កាលកម្មស៊ុះទៅហើយ វិបាកសោយរសនៃអារម្មណ៍ហើយ រលត់ទៅ ឈ្មោះថា* **ភុត្វា វិគត** *( សេពហើយប្រាសទៅ ) ។ កម្មដែលកើតឡើងហើយរលត់ទៅ ឈ្មោះថា* **ភុត្វា វិគត** *។ ទាំងពីរយ៉ាងនេះ រមែងដល់នូវការរាប់ថា* **ភុត្វា វិគតុប្បន្ន** *( កើតឡើង សេពអារម្មណ៍ហើយរលត់ទៅ ) ។ កម្មដែលជាកុសល និងអកុសល ហាមវិបាកនៃកម្មដទៃហើយ ឲ្យឱកាសដល់វិបាករបស់ខ្លួន កាលកម្មធ្វើឱកាសហើយយ៉ាងនេះ វិបាកដែលកើតឡើងតាំងអំពីកាលធ្វើឱកាស លោកហៅថា* **ឧប្បន្ន** *នេះឈ្មោះថា* **ឱកាសកតុប្បន្ន** *( កើតឡើងធ្វើឱកាស ឲ្យដល់ខ្លួន ) ។*

*ចំណែកបញ្ចក្ខន្ធ ឈ្មោះថា ភូមិនៃវិបស្សនា បញ្ចក្ខន្ធទាំងនោះ មិនគប្បីពោលថា ជាអតីត អនាគត ឬបច្ចុប្បន្ន ព្រោះថា កិលេសទាំងឡាយ*

សូម្បីដេកត្រាំហើយក្នុងអតីតក្ខន្ធទាំងឡាយ រមែងជាសភាវៈដែលលះមិនបាន សូម្បីទាក់ទងហើយក្នុងអនាគតក្ខន្ធទាំងឡាយ ក្នុងបច្ចុប្បន្នក្ខន្ធទាំងឡាយក៏ដូចគ្នា នេះឈ្មោះថា **ភូមិលទ្ធុប្បន្ន** ( កើតឡើងក្នុងភូមិដែលខ្លួនបានហើយ ) ។

ដោយហេតុនោះ ទើបអាចារ្យទាំងឡាយក្នុងកាលមុនពោលថា កិលេសទាំងឡាយដែលមិនទាន់បានដកឡើងក្នុងភូមិនោះៗ រមែងដល់នូវការរាប់ថាជា **ភូមិលទ្ធុប្បន្ន** ដូច្នេះ ។

ឧប្បន្នធម៌មាន ៤ យ៉ាងទៀត គឺសមុទាចារុប្បន្ន ១ អារម្មណាធិគហិតុប្បន្ន ១ អវិក្ខម្ភិតុប្បន្ន ១ អសមុគ្ឃាដិតុប្បន្ន ១ ។ ក្នុង ៤ យ៉ាងនោះ កិលេសទាំងឡាយដែលកំពុងប្រព្រឹត្តទៅក្នុងឥឡូវនេះ ទុំះឯងឈ្មោះថា **សមុទាចារុប្បន្ន** ។

កាលបុគ្គលបើកភ្នែកម្ដងហើយ កាន់យកអារម្មណ៍ធ្វើឲ្យជានិមិត្ត កិលេសទាំងឡាយក្នុងខណៈដែលខ្លួន តាមរឭកដល់ហើយរឭកដល់ទៀត ។ បុគ្គលណាម្នាក់ មិនគប្បីពោលថា នឹងមិនកើតឡើង ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះភាពជាអ្នកកាន់យកនូវអារម្មណ៍ ។ តើលោកពោលដូចម្ដេច ។ លោកពោលប្រៀបថា ត្រង់ទីដែលត្រូវប៉ូវថៅចាំងហើយចាំងទៀតរបស់ដើមឈើ ដែលមានទឹកដោះ ( ជ័រ ) បុគ្គលណាម្នាក់ មិនគួរពោលថា ទឹកដោះនឹងមិនចេញយ៉ាងណា ក្នុងសេចក្ដីនេះ ឈ្មោះថា **អារម្មណាធិគហិតុប្បន្ន** ក៏យ៉ាងនោះ ។

*ចំណែកឯកិលេសដែលមិនទាន់បានសង្កត់ដោយសមាបត្តិ បុគ្គលណាម្នាក់មិនគប្បីពោលថា កិលេសទាំងនោះនឹងមិនកើតឡើងក្នុងទីឈ្មោះនោះ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមិនបានសង្កត់សង្កិន ។ តើលោកពោលដូចម្តេច លោកពោលថា បើបុគ្គលគប្បីយកប៉ូវថៅ ស្ទោះដើមឈើដែលមានទឹកដោះ បុគ្គលណាម្នាក់ក៏មិនគប្បីពោលថា ទឹកដោះមិនគប្បីហូរចេញក្នុងទីឈ្មោះនេះ យ៉ាងណា សេចក្តីនេះ ឈ្មោះថា* **អវិក្ខម្ភិតុប្បន្ន** *ក៏យ៉ាងនោះ ។*

*បណ្ឌិតគប្បីអធិប្បាយពាក្យថា កិលេសដែលមិនបានដកឡើងហើយដោយមគ្គ មិនគប្បីពោលថា នឹងមិនកើតឡើងដល់បុគ្គលដែលកើតក្នុងភវគ្គភូមិ ឲ្យពិស្តារដោយន័យមុននោះឯង នេះឈ្មោះថា* **អសមុគ្ឃាដិតុប្បន្ន ។**

*បណ្តាឧប្បន្ន គឺកិលេសដែលកើតឡើងហើយ ឧប្បន្ន ៤ យ៉ាងដែលមគ្គមិនគប្បីសម្លាប់ គឺវត្តមានុប្បន្ន ១ ភុត្វាវិគតុប្បន្ន ១ ឱកាសកតុប្បន្ន ១ សមុទាចារុប្បន្ន ១ ។*

*ឧប្បន្នដែលមគ្គគប្បីសម្លាប់ ៤ យ៉ាង គឺភូមិលទ្ធុប្បន្ន ១ អារម្មណាធិគហិតុប្បន្ន ១ អវិក្ខម្ភិតុប្បន្ន ១ អសមុគ្ឃាដិតុប្បន្ន ១ ។*

*ពិតហើយ មគ្គកាលកើតឡើង រមែងលះកិលេសទាំងនេះ តែមគ្គនោះ លះកិលេសទាំងឡាយណា កិលេសទាំងនោះ បុគ្គលមិនគប្បីពោលថា ជាអតីត អនាគត ឬបច្ចុប្បន្ន ។ សេចក្តីនេះ សមដូចលោកពោល ( ក្នុង*

ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ) ថា បើលះកិលេសដែលកន្លងហើយ មានតែញ៉ាំងកិលេសដែលអស់ហើយឲ្យអស់ ញ៉ាំងកិលេសដែលរលត់ហើយ ឲ្យរលត់ ញ៉ាំងកិលេសដែលសាបសូន្យហើយ ឲ្យសាបសូន្យ ញ៉ាំងកិលេសដែលវិនាសហើយ ឲ្យវិនាស គឺថា កិលេសជាតណាកន្លងហើយ មិនមានទេ លះកិលេសជាតនោះឬ ។ បើលះកិលេសដែលមិនទាន់មក មានតែលះកិលេសដែលមិនទាន់កើត លះកិលេសដែលមិនទាន់ដុះ លះកិលេសដែលមិនទាន់ផុសឡើង លះកិលេសដែលមិនទាន់កើតប្រាកដ គឺថា កិលេសជាតណា ដែលមិនទាន់មកមិនមានទេ លះកិលេសជាតនោះឬ ។ បើលះកិលេសដែលកើតចំពោះមុខ មានតែភិក្ខុអ្នកត្រេកអរ លះរាគៈ អ្នកប្រទូស្ត លះទោសៈ អ្នកវង្វេង លះមោហៈ អ្នកប្រកួតប្រកាន់ លះមានះ អ្នកស្ទាបអង្អែល លះទិដ្ឋិ អ្នកមានចិត្តរាយមាយ លះឧទ្ធច្ចៈ អ្នកដល់នូវការមិនដាច់ស្រេច លះវិចិកិច្ឆា អ្នកមានព្យាយាម លះអនុស័យ គឺថា ធម៌ខ្មៅ និងធម៌ស តែងជាប់គ្នាជាគូប្រព្រឹត្តទៅ មគ្គភាវនាប្រកបដោយសេចក្តីសៅហ្មងដោយធម៌ទាំងពីរនោះឬ ។ បើដូច្នោះ មានតែមគ្គភាវនាមិនមានការធ្វើឲ្យជាក់ច្បាស់នូវផលមិនមាន ការលះកិលេសមិនមាន ការត្រាស់ដឹងធម៌មិនមានឬ ។ មិនមែនដូច្នោះទេ មគ្គភាវនាមាន ។បេ។ ការត្រាស់ដឹងនូវធម៌មាន ឧបមាដូចអ្វី ដូចជាដើមឈើចំទង់ ។បេ។ ដែលមិនទាន់កើតប្រាកដ ក៏លែងកើតប្រាកដដូច្នេះ ។

ដើមឈើដែលមិនទាន់មានផ្លែ មកហើយក្នុងព្រះបាលី ដោយប្រការ

ដូច្នេះ ម្យ៉ាងទៀត គួរសម្តែងដើមឈើដែលមានផ្លែ ។

ឧបមាដូចដើមស្វាយចំទន់ដែលមានផ្លែ មនុស្សទាំងឡាយ គប្បីបរិភោគផ្លែទាំងឡាយរបស់ដើមស្វាយនោះ បេះផ្លែទាំងឡាយដ៏សេសដាក់ពេញកំប្រោង ។ ក្នុងលំដាប់នោះ បុរសដទៃគប្បីកាន់យកដឹងកាប់ដើមស្វាយនោះ ដោយហេតុនោះ ផ្លែទាំងឡាយ របស់ដើមស្វាយដែលជាអតីតនោះ ក៏មិនបានវិនាស ផ្លែទាំងឡាយរបស់ស្វាយដែលជាអនាគត និងបច្ចុប្បន្ន ក៏មិនវិនាសទៅ ព្រោះថា ផ្លែស្វាយដែលជាអតីត ពួកមនុស្សក៏បរិភោគហើយ ផ្លែស្វាយដែលជាអនាគត ក៏មិនទាន់កើតឡើង បុគ្គលណាម្នាក់ មិនអាចបំផ្លាញបាន ។ តែក្នុងសម័យណា ដើមស្វាយនោះត្រូវកាត់ផ្តាច់ហើយ ក្នុងសម័យនោះ ផ្លែស្វាយទាំងនោះរមែងមិនមាន ព្រោះហេតុនោះ សូម្បីផ្លែស្វាយដែលជាបច្ចុប្បន្ន ក៏មិនវិនាសទៅ បើដើមស្វាយមិនបានកាត់ទៅហើយសោត ផ្លែស្វាយឯណាអាស្រ័យរសដី និងអាស្រ័យរសទឹកហើយ ក៏គប្បីកើតទៀត ផ្លែស្វាយទាំងនោះដែលមិនទាន់កើតនោះឯង រមែងមិនកើតឡើង ដែលមិនទាន់ផុសនោះឯង រមែងមិនផុសឡើង ដែលមិនទាន់ប្រាកដនោះឯង រមែងមិនប្រាកដ យ៉ាងណា មគ្គក៏យ៉ាងនោះ រមែងលះកិលេសទាំងឡាយ មានអតីតជាដើម ក៏មិនមែន ទាំងមិនលះក៏មិនមែន ព្រោះថាកាលខន្ធទាំងឡាយដែលមគ្គមិនទាន់បានកំណត់ដឹងហើយ ការកើតឡើងនៃកិលេសពួកណាគប្បីមាន ព្រោះភាពដែលខន្ធទាំងឡាយដែលមគ្គកំណត់ដឹងហើយ កិលេសដែលមិនទាន់កើតទាំងនោះឯង រមែងមិនកើតឡើង ដែលមិន

ទាន់ផុសនោះឯង រមែងមិនផុសឡើង ដែលមិនទាន់ប្រាកដនោះឯង រមែងមិនប្រាកដ ។

បណ្ឌិតគប្បីចង្អុលបង្ហាញនូវអត្ថនេះ ដោយថ្នាំដែលស្ត្រីមានកូនខ្ចីផឹកដើម្បីមិនប្រសូតបុត្រទៀត និងដោយថ្នាំដែលអ្នកជំងឺផឹកដើម្បីព្យាបាលរោគ ។ មគ្គរមែងលះកិលេសពួកណា កិលេសទាំងនោះ បណ្ឌិតមិនគប្បីពោលថា ជាអតីត អនាគត ឬបច្ចុប្បន្នដូចពណ៌នាមក ដូច្នេះ ។ ម្យ៉ាងទៀត មគ្គរមែងមិនលះកិលេសទាំងឡាយក៏មិនមែន តែមគ្គ លះកិលេសពួកណា ព្រះមានព្រះភាគសំដៅយកកិលេសទាំងនោះ ទើបត្រាស់ថា **ឧប្បន្នានំ បាបកានំ** ជាដើម ។

មគ្គ រមែងលះកិលេសតែម្យ៉ាងក៏មិនមែន ឧបាទិន្នកន្ធទាំងឡាយណា គប្បីកើតឡើង ព្រោះកិលេសទាំងឡាយមិនទាន់បានលះ មគ្គរមែងលះសូម្បីឧបាទិន្នកន្ធទាំងនោះឯងផងដែរ សមដូចពាក្យដែលលោកពោល ( ក្នុងខុទ្ទកនិកាយ ចូឡនិទ្ទេស ) ថា ធម៌ទាំងឡាយណា គឺនាម និងរូប គប្បីកើតក្នុងសង្សារ មានទីបំផុតខាងដើម ដែលគេមិនអាចដឹងបាន វៀរលែងតែកំណើត ៧ ចេញ ធម៌ទាំងនុ៎ះ រលត់ រម្ងាប់ ដល់នូវការវិនាស ស្ងប់រម្ងាប់ ក្នុងសោតាបត្តិមគ្គនោះ ព្រោះកិរិយារលត់អភិសង្ខារវិញ្ញាណ ដោយសោតាបត្តិមគ្គញាណ ។ សេចក្តីពិស្តារ បណ្ឌិតគប្បីជ្រាប ។ មគ្គ ឈ្មោះថា រមែងចេញទៅចាកឧបាទិន្នកន្ធ និងអនុបាទិន្នកន្ធ ដោយប្រការដូច្នេះ ។ បើពោលដោយអំណាចនៃភពហើយ សោតាបត្តិមគ្គ រមែងចេញទៅអំពី

អបាយកព ។ សកទាគាមិមគ្គ រមែងចេញទៅចាកសុគតិកពចំណែកខ្លះ អនាគាមិមគ្គ រមែងចេញទៅចាកសុគតិកាមកព អរហត្តមគ្គ រមែងចេញទៅចាករូបកព និងអរូបកព ។

អាចារ្យទាំងឡាយរមែងពោលថា អរហត្តមគ្គ រមែងចេញទៅចាកកព ទាំងអស់ដូច្នេះក៏មាន ។ សួរថា បើដូច្នោះ ក្នុងខណៈនៃមគ្គ ភាវនារមែងមាន ដើម្បីធ្វើកុសលធម៌ដែលមិនទាន់កើតឡើង ឲ្យកើតឡើងដូចម្ដេច ឬមាន ដើម្បីការតាំងនៅនៃកុសលធម៌ ដែលកើតឡើងហើយដូចម្ដេច ។ ឆ្លើយថា ភាវនារមែងមាន ព្រោះការប្រព្រឹត្តទៅនៃមគ្គនោះឯង ។ ពិតហើយ មគ្គ កាលកំពុងប្រព្រឹត្តទៅ លោកពោលថា មិនកើតហើយ ព្រោះមគ្គនោះ មិន ធ្លាប់កើតឡើងហើយក្នុងកាលមុន ដូចជនទាំងឡាយ ដែលទៅកាន់ទីមិនធ្លាប់ ទៅ ឬសោយអារម្មណ៍ដែលខ្លួនមិនធ្លាប់សោយហើយ បុគ្គលនោះ រមែង ពោលថា ពួកយើងមកហើយកាន់ទីដែលមិនធ្លាប់មក ឬពោលថា រមែង ទទួលអារម្មណ៍ដែលមិនធ្លាប់ទទួល ។ ម្យ៉ាងទៀត ការប្រព្រឹត្តទៅនៃមគ្គ ឯណា ការប្រព្រឹត្តទៅនេះ ឈ្មោះថា ការតាំងនៅ ព្រោះហេតុនោះ ការ ពោលថា រមែងចម្រើនមគ្គដើម្បីការតាំងនៅដូច្នេះ ក៏គួរ ។

ក្នុងខណៈនៃលោកុត្តរមគ្គ សេចក្តីព្យាយាមរបស់ភិក្ខុនេះ រមែងបាន ឈ្មោះ ៤ យ៉ាង ដែលមានពាក្យថា **អនុប្បន្នានំ ឲាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ** ជាដើម ដូចពណ៌នាមកដូច្នេះ នេះជាសម្មប្បធានកថា ក្នុងខណៈនៃលោកុត្តរមគ្គ ។ ព្រះមានព្រះភាគទ្រង់សម្តែងសម្មប្បធាន ដែលលាយឡំដោយលោកិយ និងលោកុត្តរ ក្នុងសុត្តន្តភាជនីយនេះ ដោយប្រការដូច្នេះ ។ល។

**អដ្ឋកថាសុត្តន្តភាជនីយ ចប់**

# អភិធម្មបិដក

## អភិធម្មភាជនីយ

[ ២២៩ ] សម្មប្បធាន ៤ គឺភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ១ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ១ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង ១ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលកើតហើយ ឲ្យស្ថិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាល ធំទូលាយ ចម្រើន ពេញលេញ ១ ។

[ ២៣០ ] ចុះភិក្ខុញុំាងឆន្ទៈ ឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេស ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ភិក្ខុញុំាងឆន្ទៈ ឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ។

[ ២៣១ ] ត្រង់ពាក្យថា ញុំាងឆន្ទៈឲ្យកើត មានសេចក្តីថា បណ្តាពាក្យទាំងនោះ ឆន្ទៈ តើដូចម្តេច ។ សេចក្តីប្រាថ្នា ភាពនៃបុគ្គលមានសេចក្តីប្រាថ្នា ភាពនៃបុគ្គលប្រាថ្នាដើម្បីធ្វើ សេចក្តីប្រាថ្នាធម៌ជាកុសលណា នេះហៅថា ឆន្ទៈ ភិក្ខុញុំាងឆន្ទៈនេះ ឲ្យកើត ឲ្យលូតលាស់ ឲ្យដុះដាល ឲ្យតាំងឡើង ឲ្យចម្រើន ឲ្យកើតឡើង ព្រោះហេតុនោះ ទើបពោលថា ញុំាងឆន្ទៈឲ្យកើត ។

[ ២៣២ ] ត្រង់ពាក្យថា សង្វាត មានសេចក្តីថា បណ្តាពាក្យទាំងនោះ សេចក្តីសង្វាត តើដូចម្តេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីឱហាត សង្វាត ខិតខំ ព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ខ្មីឃ្មាត ខ្នះខ្នែង ខ្ជាប់ខ្ជួនមិនបន្ធូរបន្ថយ មិនដាក់ចោលនូវសេចក្តីប្រាថ្នា មិនទម្លាក់ធុរៈចេញ ផ្គងទុកនូវធុរៈ វីរិយៈ វីរិយិន្ទ្រិយ វីរិយពល សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សេចក្តីសង្វាត ភិក្ខុជាអ្នកព្រមព្រៀង មូលមិត្រ ចូលទៅជិត អែបនែប កៀកកើយ ប្រជិតប្រជី ប្រកបព្រមដោយសេចក្តីសង្វាតនេះ ព្រោះហេតុនោះ ទើបពោលថា សង្វាត ។

[ ២៣៣ ] ត្រង់ពាក្យថា ប្រារព្ធព្យាយាម មានសេចក្តីថា បណ្តាពាក្យទាំងនោះ ការព្យាយាម តើដូចម្តេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា ការព្យាយាម ភិក្ខុប្រារព្ធ កាន់យកត្រូវ គប់រក អប់រំ ធ្វើឲ្យច្រើន នូវការព្យាយាមនេះ ព្រោះហេតុនោះ ទើបពោលថា ប្រារព្ធព្យាយាម ។

[ ២៣៤ ] ត្រង់ពាក្យថា ផ្គងចិត្ត មានសេចក្តីថា បណ្តាពាក្យទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោ-វិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា ចិត្ត ភិក្ខុ ផ្គង តម្រង់ ជ្រោមជ្រែង ទប់ទល់ទុកនូវចិត្តនេះ ព្រោះហេតុនោះ ទើបពោលថា ផ្គងចិត្ត ។

[ ២៣៥ ] ត្រង់ពាក្យថា ប្រឹងប្រែង មានសេចក្តីថា បណ្តាពាក្យទាំងនោះ សម្មប្បធាន តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មប្បធាន ពួកធម៌ដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្មប្បធាន ។

[ ២៣៦ ] ចុះភិក្ខុ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្តៈ ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ភិក្ខុ ឈ្មោះថា ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ។

[ ២៣៧ ] ត្រង់ពាក្យថា ញុំាងឆន្ទៈឲ្យកើត ។បេ។ ត្រង់ពាក្យថា សង្វាត ។បេ។ ត្រង់ពាក្យថា ប្រារព្ធព្យាយាម ។បេ។ ត្រង់ពាក្យថា ផ្គងចិត្ត ។បេ។

ត្រង់ពាក្យថា ប្រឹងប្រែង មានសេចក្តីថា បណ្តាពាក្យទាំងនោះ សម្មប្បធាន តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈ វិរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មប្បធាន ពួកធម៌ដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្មប្បធាន ។

[ ២៣៨ ] ចុះភិក្ខុញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលមិនទាន់កើតឲ្យកើតឡើង តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្តៈ ) ដើម្បីលះបង់នូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ភិក្ខុឈ្មោះថា ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង ។

[ ២៣៩ ] ត្រង់ពាក្យថា ញុំាងឆន្ទៈឲ្យកើត ។បេ។ ត្រង់ពាក្យថា សង្វាត ។បេ។ ត្រង់ពាក្យថា ប្រារព្ធព្យាយាម ។បេ។ ត្រង់ពាក្យថា ផ្គងចិត្ត ។បេ។ ត្រង់ពាក្យថា ប្រឹងប្រែង មានសេចក្តីថា បណ្តាពាក្យទាំងនោះ សម្មប្បធាន តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មា-វាយាមៈ វិរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មប្បធាន ពួកធម៌ដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្មប្បធាន ។

[ ២៤០ ] ចុះភិក្ខុញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត

ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលកើតហើយ ឲ្យស្ថិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាល ធំទូលាយ ចម្រើន ពេញលេញ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យា-និកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដៈ ) ដើម្បីលះបង់នូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមជ្ឈានភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ភិក្ខុឈ្មោះថា ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលកើតហើយ ឲ្យស្ថិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាល ធំទូលាយ ចម្រើន ពេញលេញ ។

[ ២៤១ ] ត្រង់ពាក្យថា ឲ្យស្ថិតនៅ គឺការស្ថិតនៅណា នុ៎ះឈ្មោះថា សេចក្តីមិនវិនាស ឯសេចក្តីមិនវិនាសណា នុ៎ះឈ្មោះថា ការរឹងរឹតតែដុះដាលឡើង ការរឹងរឹតតែដុះដាលឡើងណា នុ៎ះឈ្មោះថា ធំទូលាយ ការធំទូលាយណា នុ៎ះឈ្មោះថា ការចម្រើន ការចម្រើនណា នុ៎ះឈ្មោះថា ការពេញលេញ ។

[ ២៤២ ] ត្រង់ពាក្យថា ញុំាងឆន្ទៈឲ្យកើត មានសេចក្តីថា បណ្តាពាក្យទាំងនោះ ឆន្ទៈ តើដូចម្តេច ។ សេចក្តីប្រាថ្នា ភាពនៃបុគ្គលមានសេចក្តីប្រាថ្នា ភាពនៃបុគ្គលអ្នកប្រាថ្នាដើម្បីធ្វើ សេចក្តីប្រាថ្នាធម៌ ជាកុសលណា នេះហៅថា ឆន្ទៈ ភិក្ខុញុំាងឆន្ទៈនេះឲ្យកើត ឲ្យលូតលាស់ ឲ្យដុះដាល ឲ្យតាំងឡើង ឲ្យចម្រើនឡើង ឲ្យកើតឡើង ព្រោះហេតុនោះ ទើបពោលថា

ញុំាងឆន្ទៈឲ្យកើត ។

[ ២៨៣ ] ត្រង់ពាក្យថា សង្ឃាត មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ សេចក្ដីសង្ឃាត តើដូចម្ដេច ។ សេចក្ដីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈ គឺវិរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សេចក្ដីសង្ឃាត ភិក្ខុជាអ្នកព្រមព្រៀង ។បេ។ ប្រកបព្រមដោយសេចក្ដីសង្ឃាតនេះ ព្រោះហេតុនោះ ទើបពោលថា សង្ឃាត ។

[ ២៨៤ ] ត្រង់ពាក្យថា ប្រារព្ធព្យាយាម មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ ការព្យាយាម តើដូចម្ដេច ។ សេចក្ដីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈ វិរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា ការព្យាយាម ភិក្ខុប្រារព្ធ កាន់យកត្រូវ គប់រក អប់រំ ធ្វើឲ្យច្រើន នូវការព្យាយាមនេះ ព្រោះហេតុនោះ ទើបពោលថា ប្រារព្ធព្យាយាម ។

[ ២៨៥ ] ត្រង់ពាក្យថា ផ្គងចិត្ត មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ ចិត្ត តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោ-វិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា ចិត្ត ភិក្ខុផ្គង តម្រង់ ជ្រោមជ្រែង ទប់ទល់ទុកនូវចិត្តនេះ ព្រោះហេតុនោះ ទើបពោលថា ផ្គងចិត្ត ។

[ ២៨៦ ] ត្រង់ពាក្យថា ប្រឹងប្រែង មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ សម្មប្បធាន តើដូចម្ដេច ។ សេចក្ដីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈ វិរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មប្បធាន ពួកធម៌ដ៏សេស ដែលប្រកបដោយសម្មប្បធាន ( ក៏

ឈ្មោះថា សម្មប្បធានដែរ ) ។

[ ២៤៧ ] បណ្តាពាក្យទាំងនោះ សម្មប្បធាន តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដៈ ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ សេចក្តីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មប្បធាន ពួកធម៌ដ៏សេសក៏ឈ្មោះថា ប្រកបដោយសម្មប្បធាន ។

**អភិធម្មភាជនីយ ចប់**

# អដ្ឋកថា

## អភិធម្មភាជនីយ

[ ២២៩-២៤៧ ] ក្នុងសម្មប្បធានដែលទ្រង់ចែកក្នុងធម្មសង្គណី ទ្រង់សម្តែងត្រឹមតែមាតិកាន័យរបស់ទេសនាប៉ុណ្ណោះ តែក្នុងអភិធម្មភាជនីយ ទ្រង់សម្តែងសម្មប្បធានទាំងអស់ ។ ក្នុងអធិការនេះ គប្បីជ្រាបន័យដែលផ្សេងគ្នាថា សួរថា គប្បីជ្រាបដូចម្តេច ឆ្លើយថា ក្នុងសម្មប្បធានទី ១ ក្នុងការតាំងមាំដោយឈាន ក្នុងសោតាបត្តិមគ្គមាន ១០ ន័យ ដោយអំណាចនៃចតុក្កន័យនីមួយៗ ២ ក្នុងឋានៈទាំង ៥ នេះ គឺសុទ្ធិកប្បដិបទា សុទ្ធិកសុញ្ញតា សុញ្ញតប្បដិបទា សុទ្ធិកអប្បណិហិតា អប្បណិហិតបដិបទា ។ ក្នុងការតាំងមាំទាំងឡាយ ដ៏សេសក៏យ៉ាងនោះ ព្រោះហេតុនោះ ក្នុងការតាំងមាំ ២០ ន័យ ទើបមាន ២០០ ។ ទាំង ២០០ ន័យនោះ គុណនឹងអធិបតី ៤ ជា ៨០០ ន័យ ។ ន័យទាំងអស់ គឺសុទ្ធិកន័យ ២០០ និងសាធិបតិន័យ ៨០០ ទើបជា ១ ពាន់ន័យ ដោយប្រការដូច្នេះ ។

ក្នុងទុតិយសម្មប្បធានជាដើម និងក្នុងសុទ្ធិកសម្មប្បធានក៏ដូចគ្នា ព្រោះហេតុនោះ ទើបសោតាបត្តិមគ្គ មាន ៥ ពាន់ន័យ ។ ក្នុងសោតាបត្តិមគ្គ

យ៉ាងណា ក្នុងធម៌ដ៏សេសក៏យ៉ាងនោះ ហេតុនោះ ទើបជា ២ ម៉ឺនន័យ ដោយអំណាចនៃកុសលនោះឯង ។ តែក្នុងវិបាក កិច្ចដែលគប្បីធ្វើដោយសម្មប្បធានទាំងឡាយ មិនមាន ព្រោះហេតុនោះ វារៈពោលដោយវិបាក ព្រះមានព្រះភាគមិនបានកាន់យក ដូច្នេះឯង ។ ក្នុងអភិធម្មភាជនីយនេះ សម្មប្បធាន គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ចំពោះលោកុត្តរ ដែលកើតហើយប៉ុណ្ណោះ ។l៚

**អដ្ឋកថា អភិធម្មភាជនីយ ចប់**

# អភិធម្មបិដក

## បញ្ហាបុច្ឆកៈ

[ ២៤៨ ] សម្មប្បធាន ៤ គឺភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ១ ញុំាងឆន្ទៈ ឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ១ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង ១ ញុំាងឆន្ទៈ ឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលកើតហើយ ឲ្យស្ថិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាលធំទូលាយ ចម្រើន ពេញលេញ ។ បណ្ដាសម្មប្បធានទាំង ៤ សម្មប្បធានជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។បេ។ ជាសរណៈប៉ុន្មាន ជាអរណៈប៉ុន្មាន ។

[ ២៤៩ ] សម្មប្បធាន ៤ ជាកុសលតែមួយយ៉ាង ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនា តែមានវិបាកធម៌ជាប្រក្រតី ដែលកិលេស មានតណ្ហាជាដើមមិនកាន់យក ទាំងមិនជាប្រយោជន៍ដល់ឧបាទាន មិនសៅហ្មង ទាំងមិនគួរដល់សេចក្ដីសៅហ្មងក៏មាន ប្រកបដោយវិតក្ក ប្រកបដោយវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក មិនមានវិចារក៏មាន ប្រកបដោយបីតិក៏មាន ប្រកបដោយសុខក៏មាន ប្រកបដោយឧបេក្ខា តែមិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា

មានហេតុ មិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដៈ ) ជារបស់សេក្ខបុគ្គល មានប្រមាណមិនបាន មានអារម្មណ៍ប្រមាណមិនបាន ដ៏ឧត្ដម មានសភាពត្រូវ និងទៀងមិនមានមគ្គជាអារម្មណ៍ មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន មិនគួរពោលថា មានមគ្គជាអធិបតីក៏មាន ដែលកើតឡើងហើយក៏មាន មិនទាន់កើតហើយក៏មាន មិនគួរពោលថា បម្រុងនឹងកើតទេ ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្ន តែមិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថាមានអារម្មណ៍អនាគតផង ថាមានអារម្មណ៍ជាបច្ចុប្បន្នផងក៏មាន ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ជាខាងក្នុង និងខាងក្រៅ មានអារម្មណ៍ជាខាងក្រៅ មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ក៏មាន ។

[ ២៥០ ] សម្មប្បធាន ៤ មិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ប្រកបដោយហេតុ មិនគួរពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុទេ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុ មិនគួរពោលថា ជាហេតុ ទាំងប្រកបដោយហេតុឡើយ គ្រាន់តែប្រកបដោយហេតុ តែមិនមែនហេតុ មិនមែនហេតុ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ ។ សម្មប្បធាន

៤ ប្រកបដោយបច្ច័យ ត្រូវបច្ច័យតាក់តែង មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ មិនមានរូប ជាលោកុត្តរ គួរដឹងដោយវិញ្ញាណណាមួយ មិនគួរដឹងដោយវិញ្ញាណណាមួយ ។ សម្មប្បធាន ៤ មិនមែនជាអាសវៈ មិនមានអាសវៈ ប្រាសចាកអាសវៈ មិនគួរពោលថា អាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ជាប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈផងទេ មិនគួរពោលថា អាសវៈ ទាំងប្រកបដោយអាសវៈផង ជាប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផងឡើយ គឺជាធម៌ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ។ សម្មប្បធាន ៤ មិនមែនសញ្ញោជនៈ ។បេ។ មិនមែនគន្ថៈ ។បេ។ មិនមែនឱឃៈ ។បេ។ មិនមែនយោគៈ ។បេ។ មិនមែននីវរណៈ ។បេ។ មិនមែនបរាមាស ។បេ។ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ មិនមែនចិត្ត ជាចេតសិក ប្រកបដោយចិត្ត ប្រឡំដោយចិត្ត តាំងឡើងដោយចិត្ត កើតជាមួយនឹងចិត្ត ប្រព្រឹត្តទៅតាមចិត្ត ប្រឡំ ទាំងតាំងឡើងដោយចិត្ត ប្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត ប្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត ជាខាងក្រៅ មិនមែនឧបាទា ដែលកិលេស មានតណ្ហាជាដើម មិនកាន់យក ។ សម្មប្បធាន ៤ មិនមែនឧបាទាន ។បេ។ មិនមែនកិលេស

។បេ។ មិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុ មិនគួរលះដោយទស្សនៈ មានហេតុ មិនគួរលះដោយភាវនា ប្រកបដោយវិតក្កក៏មាន មិនមានវិតក្កក៏មាន ប្រកបដោយវិចារក៏មាន មិនមានវិចារក៏មាន ប្រកបដោយបីតិក៏មាន មិនមានបីតិក៏មាន ប្រកបដោយបីតិក៏មាន មិនប្រកបដោយបីតិក៏មាន ប្រកបដោយសុខក៏មាន មិនប្រកបដោយសុខក៏មាន ប្រកបដោយឧបេក្ខាក៏មាន មិនប្រកបដោយឧបេក្ខា តែមិនមែនកាមាវចរ មិនមែនរូបាវចរ មិនមែនអរូបាវចរ ជាអបរិយាបន្ន ជានិយ្យានិកៈ ជានិយតៈ ជាអនុត្តរៈ ជាអរណៈក៏មាន ។

បញ្ហាបុច្ឆកៈ ចប់

សម្មប្បធានវិភង្គ ចប់

# អដ្ឋកថា

## បញ្ហាបុច្ឆកៈ

[ ២៤៨-២៥០ ] ក្នុងបញ្ហាបុច្ឆកៈ គប្បីជ្រាបសម្មប្បធានទាំងឡាយ ជាកុសលជាដើម តាមគន្លងព្រះបាលីនោះឯង តែក្នុងអារម្មណត្តិកៈទាំងឡាយ សម្មប្បធានទាំងអស់នោះ ជាអប្បមាណារម្មណៈប៉ុណ្ណោះ ព្រោះប្រារព្ធព្រះនិព្វានដែលជាអប្បមាណធម៌ប្រព្រឹត្តទៅ មិនជាមគ្គារម្មណៈ តែជាមគ្គហេតុកៈ ដោយអំណាចនៃសហជាតហេតុ ។ ក្នុងកាលចម្រើនមគ្គ ធ្វើវីមំសា ឲ្យជាធំជាមគ្គាធិបតី ។ ក្នុងមគ្គភាវនា ដែលមានឆន្ទៈ និងចិត្តជាធំ មិនគប្បីពោលថា ជាមគ្គាធិបតី ក្នុងវេលាចម្រើនមគ្គដែលមានវីរិយៈជាធំ ក៏ពោលមិនបានថា ជាមគ្គាធិបតី ឬមិនមែនជាមគ្គាធិបតី ព្រោះមិនមានការព្យាយាមដទៃ ។ ក្នុងអតីតារម្មណៈ ពោលមិនបានដោយភាពជាអារម្មណ៍ណាជាដើម សម្មប្បធានទាំងនោះ ឈ្មោះថា ជាពហិទ្ធារម្មណៈ ព្រោះព្រះនិព្វានជាអារម្មណ៍ខាងក្រៅ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់សម្មប្បធានទាំងឡាយដែលជាលោកុត្តរដែលកើតឡើងហើយប៉ុណ្ណោះ ដោយប្រការដូច្នេះ ។ ពិតហើយ សុត្តន្តភាជនីយ ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សម្មប្បធានទាំងឡាយជាលោកិយផង លោកុត្តរផងលាយឡំគ្នា តែក្នុងអភិធម្មភាជនីយ និងបញ្ហាបុច្ឆកៈ ទ្រង់ត្រាស់ថាជាលោកុត្តរប៉ុណ្ណោះ ។ សូម្បីក្នុងសម្មប្បធានវិភង្គនេះ ព្រះមានព្រះភាគក៏ទ្រង់នាំចេញ ចែកសម្តែងហើយជា ៣ បរិវដ្តៈយ៉ាងនេះ ដោយប្រការដូច្នេះ ៕៚

**អដ្ឋកថាបញ្ហាបុច្ឆកៈ ចប់**

**អដ្ឋកថាសម្មប្បធានវិភង្គ ចប់**

# អភិធម្មបិដក

## ឥទ្ធិបាទវិភង្គ

[ ២៥១ ] ឥទ្ធិបាទ ៤ គឺភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ១ ចម្រើននូវឥទ្ធិបាទ ប្រកបដោយវិរិយសមាធិ និងបធានសង្ខារ ១ ចម្រើននូវឥទ្ធិបាទ ប្រកបដោយចិត្តសមាធិ និងបធានសង្ខារ ១ ចម្រើននូវឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិ និងបធានសង្ខារ ១ ។

[ ២៥២ ] ចុះភិក្ខុចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ តើដូចម្តេច ។ បើភិក្ខុធ្វើឆន្ទៈឲ្យជាអធិបតី រមែងបាននូវសមាធិ បាននូវភាពនៃចិត្តមានអារម្មណ៍មូលតែមួយ នេះហៅថា ឆន្ទសមាធិ ។ ភិក្ខុនោះ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតហើយ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលកើតហើយ ឲ្យស្ថិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាល ធំទូលាយ ចម្រើន ពេញលេញ ធម៌ទាំងនេះហៅថា បធានសង្ខារ ។ ឆន្ទសមាធិនេះផង បធានសង្ខារនេះផង ដល់នូវការរាប់ថា ឆន្ទសមាធិ និងបធានសង្ខារ ព្រោះប្រមូលរួបរួមនូវធម៌នោះ ក្នុងទីជា

មួយគ្នា ដោយប្រការដូច្នេះ ។

[ ២៥៣ ] បណ្ដាធម៌ទាំងនោះ ឆន្ទៈ តើដូចម្ដេច ។ សេចក្ដីប្រាថ្នា ភាពនៃបុគ្គលមានសេចក្ដីប្រាថ្នា ភាពនៃបុគ្គលប្រាថ្នាដើម្បីធ្វើ ការប្រាថ្នាធម៌ជាកុសលណា នេះហៅថា ឆន្ទៈ ។ បណ្ដាធម៌ទាំងនោះ សមាធិ តើដូចម្ដេច ។ ការតាំងនៅ ការខ្ជាប់ខ្ជួន ការស្ថិតនៅស៊ប់ ការមិនឃ្លេងឃ្លោង ការមិនរាយមាយ ភាពនៃចិត្តមិនឃ្លេងឃ្លោង ការស្ងប់រម្ងាប់ សមាធិន្ទ្រិយ សមាធិពល សម្មាសមាធិណា នៃចិត្ត នេះហៅថា សមាធិ ។ បណ្ដាធម៌ទាំងនោះ បធានសង្ខារ តើដូចម្ដេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ការឱហាត សង្វាត ខិតខំ ព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ខ្មីឃ្មាត ខ្នះខ្នែង សេចក្ដីសង្វាតមិនបន្ធូរបន្ថយ មិនដាក់ចោលនូវសេចក្ដីប្រាថ្នា មិនទម្លាក់ធុរៈចេញ ផ្គងទុកនូវធុរៈ វីរិយៈ វីរិយិន្ទ្រិយ វីរិយពល សម្មាវាយាមៈណា នេះហៅថា បធានសង្ខារ ។ ភិក្ខុជាអ្នកព្រមព្រៀង មូលមិត្រ ចូលទៅជិតអែបនែប កៀកកើយ ប្រជិតប្រជី ប្រកបព្រម ដោយឆន្ទៈនេះផង ដោយសមាធិនេះផង ដោយបធានសង្ខារនេះផង ព្រោះហេតុនោះ ទើបពោលថា ប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ដោយប្រការដូច្នេះ ។

[ ២៥៤ ] ពាក្យថា ឥទ្ធិ បានដល់ ការសម្រេច ការសម្រេចព្រម អាការសម្រេច អាការសម្រេចព្រម ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ កិរិយាធ្វើឲ្យជាក់ច្បាស់ ការបានគ្រប់គ្រាន់ នូវធម៌ទាំងឡាយនោះ ។ ពាក្យថា ឥទ្ធិបាទ គឺវេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ

វិញ្ញាណក្ខន្ធ របស់បុគ្គលមានសភាពដូច្នោះ ។ ពាក្យថា ចម្រើននូវឥទ្ធិបាទ គឺភិក្ខុគប់រក អប់រំ ធ្វើឲ្យច្រើន នូវធម៌ទាំងនោះ ព្រោះហេតុនោះ ទើបពោល ថា ចម្រើននូវឥទ្ធិបាទ ។

[ ២៥៥ ] ចុះភិក្ខុចម្រើននូវឥទ្ធិបាទ ប្រកបដោយវីរិយសមាធិ និង បធានសង្ខារ តើដូចម្តេច ។ បើភិក្ខុធ្វើវីរិយៈឲ្យជាអធិបតី រមែងបាននូវសមាធិ បាននូវភាពនៃចិត្តមានអារម្មណ៍មូលតែមួយ នេះហៅថា វីរិយសមាធិ ។ ភិក្ខុ នោះ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បី ញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ដើម្បី លះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតហើយ ។បេ។ ដើម្បីញុំាងពួក កុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង ។បេ។ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធ ព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលកើតហើយ ឲ្យស្ថិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាល ធំទូលាយ ចម្រើន ពេញលេញ ធម៌ទាំងនេះ ហៅថា បធានសង្ខារ ។ វីរិយសមាធិ នេះផង បធានសង្ខារទាំងនេះផង ដល់នូវការរាប់ថា វីរិយសមាធិ និងបធាន-សង្ខារ ព្រោះប្រមូលរួបរួមនូវធម៌នោះ ក្នុងទីជាមួយគ្នា ដោយប្រការដូច្នេះ ។

[ ២៥៦ ] បណ្តាធម៌ទាំងនោះ វីរិយៈ តើដូចម្តេច ។ ការប្រារព្ធ ព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈណា នេះហៅថា វីរិយៈ ។ បណ្តាធម៌ទាំងនោះ សមាធិ តើដូចម្តេច ។ ការតាំងនៅ ការខ្ជាប់ខ្ជួន ការ ស្ថិតនៅស៊ប់ ការមិនឃ្លេងឃ្លោង ការមិនរាយមាយ ភាពនៃចិត្តមិនឃ្លេង

ឃោន ការស្ងប់រម្ងាប់ សមាធិន្ទ្រិយ សមាធិពល សម្មាសមាធិណា នៃចិត្ត នេះហៅថា សមាធិ ។ បណ្តាធម៌ទាំងនោះ បធានសង្ខារ តើដូចម្តេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈណា នេះហៅថា បធានសង្ខារ ។ ភិក្ខុជាអ្នកព្រមព្រៀង ។បេ។ ប្រកបព្រមដោយវីរិយៈនេះផង ដោយសមាធិនេះផង ដោយបធានសង្ខារនេះផង ព្រោះហេតុនោះ ទើបហៅថា ប្រកបដោយវីរិយសមាធិ និងបធានសង្ខារ ដោយប្រការដូច្នេះ ។

[ ២៥៧ ] ត្រង់ពាក្យថា ឥទ្ធិ បានដល់ ការសម្រេច ការសម្រេចព្រម អាការសម្រេច អាការសម្រេចព្រម ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ កិរិយាធ្វើឲ្យជាក់ច្បាស់ ការបានគ្រប់គ្រាន់នូវធម៌ទាំងឡាយនោះ ។ ពាក្យថា ឥទ្ធិបាទ គឺវេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ របស់បុគ្គលមានសភាពដូច្នេះ ។ ពាក្យថា ចម្រើននូវឥទ្ធិបាទ គឺភិក្ខុគប់រក អប់រំ ធ្វើឲ្យច្រើន នូវធម៌ទាំងឡាយនោះ ព្រោះហេតុនោះ ទើបពោលថា ចម្រើននូវឥទ្ធិបាទ ។

[ ២៥៨ ] ចុះភិក្ខុចម្រើននូវឥទ្ធិបាទ ប្រកបដោយចិត្តសមាធិ និងបធានសង្ខារ តើដូចម្តេច ។ បើភិក្ខុធ្វើចិត្តឲ្យជាអធិបតី រមែងបាននូវសមាធិ បាននូវភាពនៃចិត្តមានអារម្មណ៍មូលតែមួយ នេះហៅថា ចិត្តសមាធិ ។ ភិក្ខុនោះ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតហើយ ។បេ។ ដើម្បីញុំាង

កុសលធម៌ទាំងឡាយ ដែលមិនទាន់កើត ឲ្យកើតឡើង ។បេ។ ញ៉ាំងឆន្ទៈ ឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញ៉ាំងពួក កុសលធម៌ ដែលកើតហើយ ឲ្យស្ថិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាល ធំទូលាយ ចម្រើន ពេញលេញ ធម៌ទាំងនេះ ហៅថា បធានសង្ខារ ។ ចិត្តសមាធិនេះផង បធានសង្ខារនេះផង ដល់នូវការរាប់ថា ចិត្តសមាធិ និង បធានសង្ខារ ព្រោះប្រមូលរួបរួមនូវធម៌នោះ ក្នុងទីជាមួយគ្នា ដោយប្រការ ដូច្នេះ ។

[ ២៥៩ ] បណ្ដាពាក្យទាំងនោះ ចិត្ត តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹង អារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណ នោះណា នេះហៅថា ចិត្ត ។ បណ្ដាធម៌ទាំងនោះ សមាធិ តើដូចម្ដេច ។ ការតាំងនៅនៃចិត្ត ។បេ។ សម្មាសមាធិណា នេះហៅថា សមាធិ ។ បណ្ដា ធម៌ទាំងនោះ បធានសង្ខារ តើដូចម្ដេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅ ក្នុងចិត្ត ។បេ។ សម្មាវាយាមៈណា នេះហៅថា បធានសង្ខារ ។ ភិក្ខុជាអ្នក ព្រមព្រៀង ។បេ។ ប្រកបព្រមដោយចិត្តនេះផង ដោយសមាធិនេះផង ដោយបធានសង្ខារនេះផង ព្រោះហេតុនោះ ទើបពោលថា ចិត្តសមាធិ និង បធានសង្ខារ ដោយប្រការដូច្នេះ ។

[ ២៦០ ] ពាក្យថា ឥទ្ធិ បានដល់ ការសម្រេច ការសម្រេចព្រម អាការសម្រេច អាការសម្រេចព្រម ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ កិរិយាធ្វើឲ្យជាក់ច្បាស់ ការបានគ្រប់គ្រាន់ នូវ

ធម៌ទាំងឡាយនោះ ។ ពាក្យថា ឥទ្ធិបាទ គឺវេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ របស់បុគ្គលមានសភាពដូច្នោះ ។ ពាក្យថា ចម្រើននូវឥទ្ធិបាទ គឺភិក្ខុគប់រក អប់រំ ធ្វើឲ្យច្រើន នូវធម៌ទាំងនោះ ព្រោះហេតុនោះ ទើបពោលថា ចម្រើននូវឥទ្ធិបាទ ។

[ ២៦១ ] ចុះភិក្ខុចម្រើននូវឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិ និងបធានសង្ខារ តើដូចម្តេច ។ បើភិក្ខុធ្វើនូវវីមំសា ឲ្យជាអធិបតី រមែងបាននូវសមាធិ បាននូវភាពនៃចិត្តមានអារម្មណ៍មូលតែមួយ នេះហៅថា វីមំសាសមាធិ ។ ភិក្ខុនោះ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតហើយ ។បេ។ ដើម្បីញុំាងពួកកុសលធម៌ដែលមិនទាន់កើត ឲ្យកើតឡើង ។បេ។ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ដែលកើតហើយ ឲ្យស្ថិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាលធំទូលាយ ចម្រើន ពេញលេញ ធម៌ទាំងនេះ ហៅថា បធានសង្ខារ ។ វីមំសាសមាធិនេះផង បធានសង្ខារទាំងនេះផង ដល់នូវការរាប់ថា វីមំសាសមាធិ និងបធានសង្ខារ ព្រោះប្រមូលរួបរួមនូវធម៌នោះ ក្នុងទីជាមួយគ្នាដោយប្រការដូច្នេះ ។

[ ២៦២ ] បណ្តាធម៌ទាំងនោះ វីមំសា តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិណា នេះហៅថា វីមំសា ។

បណ្តាធម៌ទាំងនោះ សមាធិ តើដូចម្តេច ។ ការតាំងនៅនៃចិត្ត ។បេ។ សម្មា-សមាធិណា នេះហៅថា សមាធិ ។ បណ្តាធម៌ទាំងនោះ បធានសង្ខារ តើដូចម្តេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈណា នេះហៅថា បធានសង្ខារ ។ ភិក្ខុជាអ្នកព្រមព្រៀង ។បេ។ ប្រកបព្រមដោយវីមំសានេះផង ។បេ។ ដោយសមាធិនេះផង ដោយបធានសង្ខារនេះផង ព្រោះហេតុនោះ ទើបពោលថា ប្រកបព្រមដោយវីមំសាសមាធិ និងបធានសង្ខារដោយប្រការដូច្នេះ ។

[ ២៦៣ ] ពាក្យថា ឥទ្ធិ បានដល់ ការសម្រេច ការសម្រេចព្រម អាការសម្រេច អាការសម្រេចព្រម ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ កិរិយាធ្វើឲ្យជាក់ច្បាស់ ការបានគ្រប់គ្រាន់ នូវធម៌ទាំងឡាយនោះ ។ ពាក្យថា ឥទ្ធិបាទ គឺវេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ របស់បុគ្គលមានសភាពដូច្នោះ ។ ពាក្យថា ចម្រើននូវឥទ្ធិបាទ គឺភិក្ខុគប់រក អប់រំ ធ្វើឲ្យច្រើននូវធម៌ទាំងនោះ ព្រោះហេតុនោះ ទើបពោលថា ចម្រើននូវឥទ្ធិបាទ ។

## សុត្តន្តភាជនីយ ចប់

# អដ្ឋកថា

# ឥទ្ធិបាទវិភង្គ

## សុត្តន្តភាជនីយ

[ ២៥១-២៦៣ ] ឥឡូវនេះ ដើម្បីជ្រាបវិនិច្ឆ័យក្នុងឥទ្ធិបាទវិភង្គ ដែលជាលំដាប់បន្តអំពីសម្មប្បធានវិភង្គនោះដូចតទៅ

បទថា **ចត្តារោ** ជាពាក្យកំណត់ចំនួន ។ ក្នុងបទថា **ឥទ្ធិបាទា** នេះ ឈ្មោះថា **ឥទ្ធិ** ព្រោះអត្ថថា រមែងរុងរឿង អធិប្បាយថា រុងរឿងដោយល្អ គឺសម្រេច ។ ម្យ៉ាងទៀត សត្វទាំងឡាយដែលសម្រេច ដែលចម្រើន រមែងសម្រេច រមែងដល់នូវភាពជាបុគ្គលប្រសើរដោយសភាវៈនេះ ព្រោះហេតុនោះ ទើបសភាវៈនោះ ឈ្មោះថា **ឥទ្ធិ** ។ ពោលដោយអត្ថទី ១ **បាទ** គឺ **ឥទ្ធិ** ឈ្មោះថា **ឥទ្ធិបាទ** អធិប្បាយថា ជាចំណែកមួយរបស់ឥទ្ធិ ពោលដោយអត្ថទី ២ ឈ្មោះថា **ឥទ្ធិបាទ** ព្រោះជាជើងនៃឫទ្ធិ ។ ពាក្យថា **បាទ** បានដល់ ជាទីអាស្រ័យ គឺជាឧបាយគ្រឿងសម្រេច ។ ពិតហើយ ព្រោះសត្វទាំងឡាយរមែងដល់នូវឥទ្ធិ ពោល គឺគុណវិសេសដែលខ្ពស់ឡើងៗ ដោយឧបាយជាគ្រឿងសម្រេចនោះ ហេតុនោះ ទើបហៅថា **បាទ** ។ បណ្ឌិតគប្បីជ្រាបអត្ថក្នុងពាក្យថា **ចត្តារោ ឥទ្ធិបាទា** នេះ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីទ្រង់ចែកសម្ដែងឥទ្ធិបាទទាំងនោះ

ទើបត្រាស់ពាក្យថា **ឥធ ភិក្ខុ** ជាដើម ។ បណ្តាពាក្យទាំងនោះ ពាក្យថា **ឥធ ភិក្ខុ** បានដល់ ភិក្ខុក្នុងសាសនានេះ ។ ក្នុងបទថា **ឆន្ទសមាធិបធានសង្ខារសមន្នាគតំ** នេះ បានដល់ សមាធិដែលមានឆន្ទៈជាហេតុ ឬដែលក្រៃលែងដោយឆន្ទៈ ឈ្មោះថា **ឆន្ទសមាធិ**។ បទថា **ឆន្ទសមាធិ** នេះ ជាឈ្មោះនៃសមាធិដែលបានចំពោះហើយ ព្រោះធ្វើកត្តុកម្យតាឆន្ទៈឲ្យជាអធិបតី ។ សង្ខារទាំងឡាយដែលជាប្រធាន ឈ្មោះថា **បធានសង្ខារ**។ បទថា **បធានសង្ខារា** នេះ ជាឈ្មោះរបស់សេចក្តីព្យាយាមដែលជាសម្មប្បធាន ដែលញុំាងកិច្ច ៤ យ៉ាងឲ្យសម្រេច ។ បទថា **សមន្នាគតំ** បានដល់ ចូលទៅដល់ហើយដោយឆន្ទសមាធិ និងបធានសង្ខារទាំងឡាយ ។ បទថា **ឥទ្ធិបាទំ** អធិប្បាយថា គំនរនៃចិត្ត និងចេតសិកដ៏សេស ឈ្មោះថា ជាបាទ ព្រោះអត្ថថា ជាទីតាំងមាំនៃឆន្ទសមាធិ និងបធានសង្ខារទាំងឡាយ ដែលសម្បយុត្តដោយកុសលចិត្ត មានឧបចារជ្ឈានជាដើម ដែលដល់នូវការរាប់ថា **ឥទ្ធិ** ដោយបរិយាយនៃការសម្រេច គឺដោយអត្ថនៃការសម្រេច ឬដោយបរិយាយនេះថា សត្វទាំងឡាយ សម្រេច ចម្រើន រមែងសម្រេច រមែងដល់នូវភាពជាបុគ្គលប្រសើរ ដោយសភាវៈនេះ ដូច្នេះ ។ ពិតហើយ ពាក្យថា **ឥទ្ធិបាទ** ដែលលោកពោលខាងដើមថា វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធរបស់បុគ្គលដែលសម្រេចធម៌ទាំងនោះឯណា ពាក្យនោះ រមែងពាល់ត្រូវដោយអត្ថនេះ ។ ក្នុងពាក្យដ៏សេសទាំងឡាយ គប្បីជ្រាបអត្ថដោយន័យនេះ ។ បណ្ឌិតគប្បីជ្រាបអត្ថដែលលោកពោលថា សមាធិដែលបានចំពោះហើយ ព្រោះធ្វើឆន្ទៈឲ្យជា

*អធិបតី ឈ្មោះថា* **ឆន្ទសមាធិ** *យ៉ាងណា សមាធិដែលបានចំពោះហើយ ព្រោះធ្វើវីរិយៈ ចិត្ត វីមំសាឲ្យជាអធិបតី លោកក៏ហៅថា* **វីរិយសមាធិ ចិត្តសមាធិ វីមំសាសមាធិ** *ក៏យ៉ាងនោះ ។*

*ឥឡូវនេះ ព្រះមានព្រះភាគដើម្បីទ្រង់ចែកសម្តែងបទទាំងឡាយ មានឆន្ទសមាធិជាដើម ទើបត្រាស់បទថា* **កថញ្ច ភិក្ខុ** *ជាដើម ។ បណ្តាបទទាំងនោះ បទថា* **ឆន្ទញ្ចេ ភិក្ខុ អធិបតឹ ករិត្វា** *សេចក្តីថា បើភិក្ខុធ្វើឆន្ទៈឲ្យជាអធិបតី ធ្វើឆន្ទៈឲ្យជាធំ ធ្វើឆន្ទៈឲ្យជាធុរៈ ធ្វើឆន្ទៈឲ្យជាប្រធានហើយ បានចំពោះនូវសមាធិ គឺឲ្យសមាធិកើតឡើង អធិប្បាយថា សមាធិនេះ ដែលកើតឡើងហើយយ៉ាងនេះ លោកហៅថា* **ឆន្ទសមាធិ ។** *ក្នុងបទទាំងឡាយ មានបទថា* **វីរិយញ្ចេ** *ជាដើម ក៏ន័យនេះដូចគ្នា ។ វីរិយៈដែលញុំាងកិច្ច ៤ ឲ្យសម្រេច ពោល គឺបធានសង្ខាររបស់ភិក្ខុដែលចម្រើននូវឥទ្ធិបាទ លោកពោលហើយដោយពាក្យមានប្រមាណប៉ុណ្ណេះថា* **ឥមេ វុច្ចន្តិ បធានសង្ខារា** *( ធម៌ទាំងនេះ ហៅថា បធានសង្ខារ ) ។ បទថា* **តទេកជ្ឈំ អភិសញ្ញូហិត្វា** *អធិប្បាយថា ធ្វើសភាវៈទាំងអស់នោះ ឲ្យជាគំនរតែមួយ ។ បទថា* **សង្ខ្យំ គច្ឆតិ** *អធិប្បាយថា ឆន្ទសមាធិបធានសង្ខារនេះ បណ្ឌិតគប្បីជ្រាបថា រមែងមានឈ្មោះហៅតែមួយ ។*

*ឥឡូវនេះ ព្រះមានព្រះភាគដើម្បីទ្រង់ចែកសម្តែងធម៌ មានឆន្ទៈជាដើម ដែលប្រជុំក្នុងពាក្យថា ឆន្ទសមាធិបធានសង្ខារនេះ ទើបផ្តើមបទថា* **តត្ថ កតមោ ឆន្ទោ** *ជាដើម ។ ពាក្យនោះ មានអត្ថងាយយល់ហើយ ។*

បទថា **ឧបេតោ ហោតិ** បានដល់ គំនរនៃធម៌ ពោល គឺឥទ្ធិបាទ ជាសភាវៈដែលចូលដល់ហើយ ។ បទថា **តេសំ ធម្មានំ** បានដល់ ធម៌មាន ឆន្ទៈជាដើម ដែលសម្បយុត្តដោយបធានសង្ខារទាំងនោះ ។

បទទាំងពួង មានបទថា **ឥទ្ធិ សមិទ្ធិ** ជាដើម ជាវេវចនៈរបស់បទថា **និប្ផត្តិ** នោះឯង ។ កាលបើយ៉ាងនោះ ទើបលោកហៅថា **ឥទ្ធិ** ព្រោះអត្ថថា រមែងសម្រេច ។ ឥទ្ធិដែលសម្បូរហើយ ឈ្មោះថា **សមិទ្ធិ** ម្យ៉ាងទៀត បទថា **សមិទ្ធិ** នេះ ជាពាក្យដែលបន្ថែមបទឧបសគ្គ ។ អាការនៃការសម្រេច ឈ្មោះថា **ឥជ្ឈនា** ។ បទថា **សមិជ្ឈនា** ជាពាក្យដែលបន្ថែមបទឧបសគ្គ ឯសេចក្ដីបានដោយអំណាចនៃការប្រាកដក្នុងសន្តានរបស់ខ្លួន ឈ្មោះថា **លាភោ** ។ ការបាននូវធម៌ដែលវិនាសទៅហើយ ដោយអំណាចនៃការផ្ដើមសេចក្ដីព្យាយាមទៀត ឈ្មោះថា **បដិលាភោ** ។ ម្យ៉ាងទៀត បទថា **បដិលាភោ** នេះ ជាពាក្យដែលបន្ថែមបទឧបសគ្គ ។ បទថា **បត្តិ** បានដល់ ការសម្រេច ។ ការសម្រេចដោយល្អ ដោយអំណាចនៃការមិនវិនាស ព្រោះហេតុនោះ ទើបឈ្មោះថា **សម្បត្តិ** ។ បទថា **ផុសនា** បានដល់ ការពាល់ត្រូវដោយអំណាចនៃការបានទៀត ។ បទថា **សច្ឆិកិរិយា** បានដល់ ការធ្វើឲ្យជាក់ច្បាស់ដោយបដិលាភនោះឯង ។ បទថា **ឧបសម្បទា** បណ្ឌិតគប្បីជ្រាបថា ការចូលដល់ដោយបដិលាភដូចគ្នា ។ បទថា **យថាភូតស្ស** បានដល់ របស់បុគ្គលដែលប្រាកដហើយដោយអាការនេះ អធិប្បាយថា បុគ្គលដែលបានចំពោះហើយនូវធម៌ មានឆន្ទៈទាំងនោះជាដើម ហើយតាំងនៅ ។ ខន្ធទាំង ៤ ព្រះមានព្រះភាគ

ត្រាស់ហើយដោយបទថា **វេទនាក្ខន្ធោ** ជាដើម ដោយធ្វើឆន្ទៈជាដើមខាងក្នុង ។ បទថា **តេ ធម្មា** បានដល់ អរូបក្ខន្ធទាំង ៤ នោះ ។ ម្យ៉ាងទៀត ពាក្យនេះ លោកពោលដល់ធម៌ទាំង ៣ មានឆន្ទៈជាដើម ( ឆន្ទៈ សមាធិ បធានសង្ខារ ) ។ បទថា **អាសេវតិ** ជាដើម មានអត្ថតាមដែលពោលហើយនោះឯង ក្នុងនិទ្ទេសនៃឥទ្ធិបាទដ៏សេស បណ្ឌិតគប្បីជ្រាបអត្ថដោយន័យនេះដូចគ្នា ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះ លោកពោលដូចម្ដេច គប្បីជ្រាបដូច្នេះថា លោកពោលកម្មដ្ឋានដែលដល់ទីបំផុតរបស់ភិក្ខុ ៤ ពួក គឺភិក្ខុពួក ១ អាស្រ័យឆន្ទៈ កាលការសម្រេចប្រយោជន៍មានដោយឆន្ទៈ ក្នុងកុសលធម៌នៃភាពជាអ្នកប្រាថ្នាដើម្បីធ្វើ លោកក៏ធ្វើឆន្ទៈឲ្យជាធំ ធ្វើឆន្ទៈឲ្យជាធុរៈ ធ្វើឆន្ទៈឲ្យជាប្រធាន ដោយការគិតថា អញនឹងញុំាងលោកុត្តរធម៌ឲ្យកើត អញមិនមានការធ្ងន់ចិត្ត ក្នុងការធ្វើលោកុត្តរធម៌នោះឲ្យកើតឡើងឡើយ ហើយទើបធ្វើលោកុត្តរធម៌ឲ្យកើតឡើង ។ ភិក្ខុពួកមួយអាស្រ័យវីរិយៈ ភិក្ខុពួកមួយអាស្រ័យចិត្ត ភិក្ខុពួកមួយអាស្រ័យបញ្ញា កាលការសម្រេចប្រយោជន៍មានដោយបញ្ញា ភិក្ខុនោះ ក៏ធ្វើបញ្ញាឲ្យជាធំ ធ្វើបញ្ញាឲ្យជាធុរៈ ធ្វើបញ្ញាឲ្យជាប្រធាន ដោយការគិតថា អញនឹងញុំាងលោកុត្តរធម៌ឲ្យកើតឡើង អញមិនមានការធ្ងន់ចិត្ត ក្នុងការធ្វើលោកុត្តរធម៌នោះឲ្យកើតឡើងឡើយ ហើយទើបធ្វើលោកុត្តរធម៌ឲ្យកើតឡើង ។

សេចក្ដីនេះដូចម្ដេច ដូចបុត្ររបស់អមាត្យ ៤ នាក់ ប្រាថ្នាឋានន្តរ

ហើយត្រាច់ទៅ បុរសម្នាក់អាស្រ័យការបម្រើ បុរសម្នាក់អាស្រ័យសេចក្តីក្លាហាន បុរសម្នាក់អាស្រ័យជាតិ បុរសម្នាក់អាស្រ័យចំណេះដឹង ។ សេចក្តីនេះដូចម្តេច គឺបុត្រអមាត្យទាំងនោះ បុរសទី ១ គិតថា កាលការសម្រេចប្រយោជន៍មាន ព្រោះបុគ្គលធ្វើនូវការមិនប្រមាទក្នុងការបម្រើ អញនឹងបានឋានន្តរនោះ ហើយអាស្រ័យក្នុងការបម្រើ ។ បុរសទី ២ មានសេចក្តីមិនប្រមាទក្នុងការបម្រើហើយ ថែមទាំងគិតថា បុគ្គលខ្លះ កាលសង្គ្រាមកើតឡើង រមែងមិនអាចតាំងមាំ ឯប្រទេសជាយដែនរបស់ព្រះរាជានឹងបះបោរពិត កាលប្រទេសជាយដែនបះបោរហើយ អញនឹងធ្វើការងារត្រង់នឹមនៃរថធ្វើព្រះរាជាឲ្យពេញព្រះហឫទ័យហើយ ក៏នឹងព្រះរាជទានឋានន្តរនោះ ហើយទើបអាស្រ័យភាពជាអ្នកក្លាហាន ។ បុរសទី ៣ គិតថា ទោះបីជាអ្នកក្លាហានខ្លះ ជាអ្នកមានជាតិថោកទាប មនុស្សទាំងឡាយ កាលជ្រើសរើសជាតិកំណើត ឲ្យឋានន្តរ នឹងឲ្យដល់អញ ហើយទើបអាស្រ័យជាតិ ។ បុរសទី ៤ គិតថា បុគ្គលខ្លះសូម្បីមានជាតិត្រកូល តែមិនមានចំណេះដឹង កាលកិច្ចដែលគប្បីធ្វើដោយចំណេះដឹងកើតឡើងហើយ អាត្មាអញ ព្រះរាជានឹងព្រះរាជទានឋានន្តរនោះ ហើយទើបអាស្រ័យចំណេះដឹង ។ បុត្ររបស់អមាត្យទាំងអស់នោះ ដល់ហើយនូវឋានន្តរដោយកម្លាំងនៃភាវៈដែលជាទីអាស្រ័យរៀងៗ ខ្លួន ។

ក្នុងភិក្ខុទាំងនោះ ភិក្ខុអាស្រ័យឆន្ទៈ កាលការសម្រេចប្រយោជន៍មានដោយឆន្ទៈក្នុងកុសលធម៌នៃភាពជាអ្នកប្រាថ្នាដើម្បីធ្វើ ទើបធ្វើឆន្ទៈឲ្យជាធំ ធ្វើ

ឆន្ទៈឲ្យជាធុរៈ ធ្វើឆន្ទៈឲ្យជាប្រធាន ដោយគិតថា អញនឹងញ៉ាំងលោកុត្តរធម៌ឲ្យកើតឡើង អញមិនមានការធុញចិត្ត ក្នុងការធ្វើលោកុត្តរធម៌ឲ្យកើតឡើង ហើយទើបធ្វើលោកុត្តរធម៌ឲ្យកើតឡើង បណ្ឌិតគប្បីឃើញដូចបុត្ររបស់អមាត្យ ដែលមិនប្រមាទក្នុងការបម្រើហើយបានឋានន្តរៈ ដូចព្រះរដ្ឋបាល ។ ពិតហើយ ព្រះរដ្ឋបាលត្ថេរនោះ ធ្វើឆន្ទៈឲ្យជាធុរៈហើយ ញ៉ាំងលោកុត្តរធម៌ឲ្យកើតឡើង ។

ភិក្ខុដែលធ្វើវិរិយៈឲ្យជាធំ ធ្វើវិរិយៈឲ្យជាធុរៈ ធ្វើវិរិយៈឲ្យជាប្រធាន ហើយញ៉ាំងលោកុត្តរធម៌ឲ្យកើតឡើង បណ្ឌិតគប្បីឃើញដូចគ្នានឹងបុត្រអមាត្យ ដែលញ៉ាំងព្រះរាជាឲ្យពេញព្រះហឫទ័យ ដោយភាពជាអ្នកក្លាហាន ហើយក៏បានទូវឋានន្តរ ដូចព្រះសោណត្ថេរ ពិតហើយ ព្រះសោណត្ថេរនោះ ធ្វើវិរិយៈឲ្យជាធុរៈ ហើយញ៉ាំងលោកុត្តរធម៌ឲ្យកើតឡើង ។

ភិក្ខុធ្វើចិត្តឲ្យជាធំ ធ្វើចិត្តឲ្យជាធុរៈ ធ្វើចិត្តឲ្យជាប្រធាន ហើយញ៉ាំងលោកុត្តរធម៌ឲ្យកើតឡើង បណ្ឌិតគប្បីឃើញដូចគ្នានឹងបុត្រអមាត្យដែលបានឋានន្តរ ព្រោះការដល់នូវជាតិ ដូចព្រះសម្ភូតត្ថេរ ។ ពិតហើយ ព្រះសម្ភូតៈនោះ ធ្វើចិត្តឲ្យជាធុរៈ ហើយញ៉ាំងលោកុត្តរធម៌ឲ្យកើតឡើង ។

ភិក្ខុដែលធ្វើវីមំសាឲ្យជាធំ ធ្វើវីមំសាឲ្យជាធុរៈ ធ្វើវីមំសាឲ្យជាប្រធាន ហើយញ៉ាំងលោកុត្តរធម៌ឲ្យកើតឡើង បណ្ឌិតគប្បីឃើញដូចគ្នានឹងបុត្រអមាត្យ ដែលបានទូវឋានន្តរ ព្រោះអាស្រ័យចំពោះដឹង ដូចព្រះមោឃរាជត្ថេរ ។ ពិតហើយ ព្រះមោឃរាជត្ថេរនោះ ធ្វើវីមំសាឲ្យជាធុរៈហើយ ញ៉ាំងលោកុត្តរធម៌

ឲ្យកើតឡើង ។

ម្យ៉ាងទៀត ក្នុងអធិការនេះ ធម៌ទាំង ៣ ពោល គឺឆន្ទៈ សមាធិ និង បធានសង្ខារ ជាឥទ្ធិផង ជាឥទ្ធិបាទផង ចំណែកខន្ធ ៤ ដែលសម្បយុត្តជាមួយគ្នាដ៏សេស ជាឥទ្ធិប៉ុណ្ណោះ ។ ធម៌ទាំង ៣ ពោល គឺវីរិយៈ ចិត្ត វីមំសា នីមួយៗ រួមជាមួយសមាធិ និងបធានសង្ខារ រមែងជាឥទ្ធិផង ជាឥទ្ធិបាទផង ចំណែកខន្ធ ៤ ដែលសម្បយុត្តដ៏សេស ជាឥទ្ធិបាទប៉ុណ្ណោះ ។ នេះជាកថាពោលដោយការមិនប្លែកគ្នាប៉ុណ្ណោះ ។

ម្យ៉ាងទៀត បើពោលដោយការផ្សេងគ្នា ឆន្ទៈ ឈ្មោះថា ឥទ្ធិ នាមក្ខន្ធ ៤ ដែលអប់រំហើយដោយឆន្ទធុរៈ ឈ្មោះថា **ឆន្ទិទ្ធិបាទ** ។ ធម៌ទាំង ២ គឺ សមាធិ និងបធានសង្ខារ រមែងចូលទៅក្នុងឆន្ទិទ្ធិបាទ ដោយអំណាចនៃសង្ខារក្ខន្ធ ។ ទោះបីពោលថា ធម៌ទាំង ២ នោះចូលទៅហើយក្នុងបាទដូច្នេះ ក៏គួរដូចគ្នា ក្នុងធម៌ទាំងនោះឯង សមាធិ ឈ្មោះថា **ឥទ្ធិ** ខន្ធ ៤ ដែលអប់រំហើយដោយសមាធិធុរៈ ឈ្មោះថា **សមាធិទ្ធិបាទ** ។ ធម៌ទាំង ២ គឺឆន្ទៈ និងបធានសង្ខារ រមែងចូលទៅក្នុងសមាធិទ្ធិបាទ ដោយអំណាចជាសង្ខារក្ខន្ធ ទោះបីពោលថា ធម៌ទាំង ២ នោះ ចូលទៅហើយក្នុងបាទដូច្នេះក៏គួរដូចគ្នា ។ ក្នុងធម៌ទាំងនោះឯង បធានសង្ខារ ឈ្មោះថា **ឥទ្ធិ** ខន្ធ ៤ ដែលអប់រំហើយដោយបធានសង្ខារ ឈ្មោះថា **បធានសង្ខារិទ្ធិបាទ** ។ ធម៌ទាំង ២ គឺឆន្ទៈ និងសមាធិ រមែងចូលទៅក្នុងបធានសង្ខារិទ្ធិបាទ ដោយអំណាចនៃសង្ខារក្ខន្ធ ។ ទោះបីពោលថា ធម៌ ២ នោះចូលទៅហើយ ក្នុងបាទដូច្នេះក៏គួរ

ដូចគ្នា ។

ក្នុងធម៌ទាំងនោះ វិរិយៈ ឈ្មោះថា **ឥទ្ធិ** ចិត្ត ឈ្មោះថា **ឥទ្ធិ** វីមំសា ឈ្មោះថា **ឥទ្ធិ** ។បេ។ ទោះបីពោលថា ធម៌ទាំង ២ នោះ ចូលទៅហើយក្នុងបាទដូច្នេះក៏គួរដូចគ្នា ។ នេះឈ្មោះថា កថាដោយការប្លែកគ្នា ។

ក្នុងអធិការនេះ រឿងថ្មីមិនមាន លោកធ្វើពាក្យដែលព្រមទទួលមកហើយនោះឯង ឲ្យមានអត្ថជាក់ច្បាស់ក្រៃលែងឡើង ។ គឺអ្វី គឺធម៌ ៣ បានដល់ ឆន្ទៈ សមាធិ បធានសង្ខារ ជាឥទ្ធិក៏បាន ជាឥទ្ធិបាទក៏បាន ចំណែកខន្ធ ៤ ដែលសម្បយុត្តដ៏សេស ត្រឹមតែជាឥទ្ធិបាទប៉ុណ្ណោះ ។ ពិតហើយ ធម៌ទាំង ៣ នេះ កាលសម្រេច រមែងសម្រេចព្រមជាមួយខន្ធ ៤ ដែលសម្បយុត្តគ្នានោះឯង វៀរចាកខន្ធ ៤ ដែលសម្បយុត្តគ្នាហើយ មិនសម្រេចបានឡើយ ។ម្យ៉ាងទៀត ខន្ធ ៤ ដែលសម្បយុត្តគ្នា ឈ្មោះថា **ឥទ្ធិ** ព្រោះអត្ថថា សម្រេច ឈ្មោះថាជា **បាទ** ព្រោះអត្ថថា ជាទីតាំង ។ បទថា **ឥទ្ធិ** ឬបទថា **ឥទ្ធិបាទោ** មិនមែនជាឈ្មោះរបស់ធម៌ដទៃណាឡើយ គឺជាឈ្មោះរបស់ខន្ធ ៤ ដែលសម្បយុត្តគ្នានោះឯង ។ ធម៌ទាំង ៣ គឺវិរិយៈ សមាធិ បធានសង្ខារ ចិត្ត សមាធិ បធានសង្ខារ វីមំសា សមាធិ បធានសង្ខារ ។បេ។ ក៏ជាឈ្មោះរបស់ខន្ធ ៤ នោះឯង ។

ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបថា ចំណែកខាងដើម ឈ្មោះថា **ឥទ្ធិបាទ** ចំណែកបន្ទាប់មកទៀត ឈ្មោះថា **ឥទ្ធិ** គប្បីសម្តែងអត្ថនេះ ដោយឧបចារៈ ឬវិបស្សនា ។

ពិតហើយ បរិកម្មរបស់បឋមជ្ឈាន ឈ្មោះថា **ឥទ្ធិបាទ** ។ បឋមជ្ឈាន ឈ្មោះថា **ឥទ្ធិ** ។ បរិកម្មនៃទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន អាកាសានញ្ចាយតនៈ វិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ នេវសញ្ញានាសញ្ញាយតនៈ ឈ្មោះថា **ឥទ្ធិបាទ** នេវសញ្ញានាសញ្ញាយតនៈ ឈ្មោះថា **ឥទ្ធិ** ។ វិបស្សនានៃសោតាបត្តិមគ្គ ឈ្មោះថា **ឥទ្ធិបាទ** សោតាបត្តិមគ្គ ឈ្មោះថា **ឥទ្ធិ** ។ វិបស្សនានៃសកទាគាមិមគ្គ អនាគាមិមគ្គ អរហត្តមគ្គ ឈ្មោះថា **ឥទ្ធិបាទ** អរហត្តមគ្គ ឈ្មោះថា **ឥទ្ធិ** ។ ការសម្តែងដោយការបានបន្តទៀតក៏គួរដូចគ្នា ។ ពិតហើយ បឋមជ្ឈាន ឈ្មោះថា **ឥទ្ធិបាទ** ទុតិយជ្ឈាន ឈ្មោះថា **ឥទ្ធិ** ទុតិយជ្ឈាន ឈ្មោះថា **ឥទ្ធិបាទ** តតិយជ្ឈាន ឈ្មោះថា **ឥទ្ធិ** ។បេ។ អនាគាមិមគ្គ ឈ្មោះថា **ឥទ្ធិបាទ** អរហត្តមគ្គ ឈ្មោះថា **ឥទ្ធិ** ។

សួរថា ឈ្មោះថា **ឥទ្ធិ** ព្រោះអត្ថដូចម្តេច ឈ្មោះថា **បាទ** ព្រោះអត្ថដូចម្តេច ឆ្លើយថា ឈ្មោះថា **ឥទ្ធិ** ព្រោះអត្ថថា ការសម្រេចនោះឯង ឈ្មោះថា **បាទ** ព្រោះអត្ថថា ជាទីតាំងនោះឯង ។ ដោយប្រការយ៉ាងនេះ ពាក្យថា **ឥទ្ធិ** ឬពាក្យថា **ឥទ្ធិបាទ** ក្នុងទីនេះ ទើបមិនមែនជាឈ្មោះរបស់ធម៌អ្វីដទៃ តែជាឈ្មោះរបស់ខន្ធ ៤ ដែលសម្បយុត្តគ្នានោះឯង ។

*កាលខ្ញុំពោលហើយយ៉ាងនេះ អាចារ្យទាំងឡាយ ទើបពោលពាក្យនេះថា បើពាក្យនេះគប្បីជាឈ្មោះរបស់ខន្ធ ៤ នោះឯងសោត ព្រះសាស្ដាក៏មិនគប្បីនាំនូវឈ្មោះឧត្តរចូឡភាជនីយមកដាក់ខាងមុខ ក្នុងឧត្តរចូឡភាជនីយ ព្រះមានព្រះភាគត្រាស់ថា ឆន្ទៈប៉ុណ្ណោះ ឈ្មោះថា* **ឆន្ទិទ្ធិបាទ** *វិរិយៈប៉ុណ្ណោះ ចិត្តប៉ុណ្ណោះ វីមំសាប៉ុណ្ណោះឈ្មោះថា* **វីមំសិទ្ធិបាទ** *ដូច្នេះ ។ ចំណែកអាចារ្យពួកខ្លះពោលថា សភាវៈដែលមិនសម្រេច ឈ្មោះថា* **ឥទ្ធិ** *សភាវៈដែលសម្រេចហើយ ឈ្មោះថា* **ឥទ្ធិបាទ** *ដូច្នេះ ។ ខ្ញុំបដិសេធពាក្យរបស់អាចារ្យទាំងនោះហើយ ទើបធ្វើការសន្និដ្ឋានថា សភាវៈដែលសម្រេចហើយ ដែលត្រូវត្រៃលក្ខណ៍ពាល់ត្រូវហើយ ឈ្មោះថា* **ឥទ្ធិ** *ក៏បាន ឈ្មោះថា* **ឥទ្ធិបាទ** *ក៏បាន ។ ក្នុងសុត្តន្តភាជនីយនេះ ព្រះមានព្រះភាគ ត្រាស់ឥទ្ធិបាទទាំងឡាយដែលជាលោកិយផង លោកុត្តរផងលាយឡំគ្នា ដូចពណ៌នាមកដូច្នេះ ។l*

**អដ្ឋកថាសុត្តន្តភាជនីយ ចប់**

# អភិធម្មបិដក

## អភិធម្មភាជនីយ

[ ២៦៤ ] ឥទ្ធិបាទ ៤ គឺភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ១ ចម្រើននូវឥទ្ធិបាទ ប្រកបដោយវីរិយសមាធិ និងបធានសង្ខារ ១ ចម្រើននូវឥទ្ធិបាទ ប្រកបដោយចិត្តសមាធិ និងបធានសង្ខារ ១ ចម្រើននូវឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិ និងបធានសង្ខារ ១ ។

[ ២៦៥ ] ចុះភិក្ខុចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្តៈ ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ភិក្ខុ ឈ្មោះថា ចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ។

[ ២៦៦ ] បណ្តាធម៌ទាំងនោះ ឆន្ទៈ តើដូចម្តេច ។ សេចក្តីប្រាថ្នា ភាពនៃបុគ្គលមានសេចក្តីប្រាថ្នា ភាពនៃបុគ្គលប្រាថ្នាដើម្បីធ្វើ ការប្រាថ្នាធម៌ជាកុសលណា នេះហៅថា ឆន្ទៈ ។ បណ្តាធម៌ទាំងនោះ សមាធិ តើដូចម្តេច ។ ការតាំងនៅនៃចិត្ត ។បេ។ សម្មាសមាធិ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សមាធិ ។ បណ្តាធម៌ទាំងនោះ បធានសង្ខារ តើដូចម្តេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។

សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះ ហៅថា បធានសង្ខារ ។ ភិក្ខុជាអ្នកព្រមព្រៀង ។បេ។ ប្រកបព្រមដោយ ឆន្ទៈនេះផង ដោយសមាធិនេះផង ដោយបធានសង្ខារនេះផង ព្រោះហេតុ នោះ ទើបពោលថា ប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ដោយប្រការ ដូច្នេះ ។

[ ២៦៧ ] ពាក្យថា ឥទ្ធិ បានដល់ ការសម្រេច ការសម្រេចព្រម អាការសម្រេច អាការសម្រេចព្រម ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ កិរិយាធ្វើឲ្យជាក់ច្បាស់ ការបានគ្រប់គ្រាន់នូវធម៌ ទាំងឡាយនោះ ។ ពាក្យថា ឥទ្ធិបាទ គឺការពាល់ត្រូវ ។បេ។ ការផ្គងទុក សេចក្ដីមិនរាយមាយ របស់បុគ្គលមានសភាពដូច្នោះ ។ ពាក្យថា ចម្រើននូវ ឥទ្ធិបាទ គឺភិក្ខុគប់រក អប់រំ ធ្វើឲ្យច្រើន នូវធម៌ទាំងនោះ ព្រោះហេតុនោះ ទើបពោលថា ចម្រើននូវឥទ្ធិបាទ ។

[ ២៦៨ ] ចុះភិក្ខុចម្រើននូវឥទ្ធិបាទ ប្រកបដោយវីរិយសមាធិ និង បធានសង្ខារ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវ លោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវ កិលេសវដ្ដៈ ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាក កាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ភិក្ខុ ឈ្មោះថា ចម្រើននូវឥទ្ធិបាទ ប្រកបដោយវីរិយសមាធិ និងបធានសង្ខារ ។

[ ២៦៩ ] បណ្ដាធម៌ទាំងនោះ វីរិយៈ តើដូចម្ដេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា វីរិយៈ ។ បណ្ដាធម៌ទាំងនោះ សមាធិ តើដូចម្ដេច ។ ការតាំងនៅនៃចិត្ត ។បេ។ សម្មាសមាធិ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សមាធិ ។ បណ្ដាធម៌ទាំងនោះ បធានសង្ខារ តើដូចម្ដេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា បធានសង្ខារ ។ ភិក្ខុជាអ្នកព្រមព្រៀង ។បេ។ ប្រកបព្រមដោយវីរិយៈនេះផង ដោយសមាធិនេះផង ដោយបធានសង្ខារនេះផង ព្រោះហេតុនោះ ទើបពោលថា ប្រកបដោយវីរិយសមាធិ និងបធានសង្ខារ ដោយប្រការដូច្នេះ ។

[ ២៧០ ] ពាក្យថា ឥទ្ធិ គឺបានដល់ការសម្រេច ការសម្រេចព្រម អាការសម្រេច អាការសម្រេចព្រម ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ កិរិយាធ្វើឲ្យជាក់ច្បាស់ ការបានគ្រប់គ្រាន់នូវធម៌ទាំងឡាយនោះ ។ ពាក្យថា ឥទ្ធិបាទ គឺការពាល់ត្រូវ ការផ្គងទុក សេចក្ដីមិនរាយមាយ របស់បុគ្គលមានសភាពដូច្នោះ ។ ពាក្យថា ចម្រើននូវឥទ្ធិបាទ គឺភិក្ខុគប់រក អប់រំ ធ្វើឲ្យច្រើន នូវធម៌ទាំងឡាយនោះ ព្រោះហេតុនោះ ទើបពោលថា ចម្រើននូវឥទ្ធិបាទ ។

[ ២៧១ ] ចុះភិក្ខុចម្រើននូវឥទ្ធិបាទ ប្រកបដោយចិត្តសមាធិ និង

បធានសង្ខារ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដៈ ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ភិក្ខុ ឈ្មោះថា ចម្រើននូវឥទ្ធិបាទ ប្រកបដោយចិត្តសមាធិនិងបធានសង្ខារ ។

[ ២៧២ ] បណ្ដាធម៌ទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា ចិត្ត ។ បណ្ដាធម៌ទាំងនោះ សមាធិ តើដូចម្តេច ។ ការតាំងនៅនៃចិត្ត ។បេ។ សម្មាសមាធិ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សមាធិ ។ បណ្ដាធម៌ទាំងនោះ បធាន-សង្ខារ តើដូចម្តេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មា-វាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា បធានសង្ខារ ។ ភិក្ខុជាអ្នកព្រមព្រៀង ។បេ។ ប្រកបព្រមដោយចិត្តនេះផង ដោយសមាធិនេះផង ដោយបធានសង្ខារនេះផង ព្រោះហេតុនោះ ទើបពោលថា ប្រកបដោយចិត្តសមាធិ និងបធានសង្ខារ ដោយប្រការដូច្នេះ ។

[ ២៧៣ ] ពាក្យថា ឥទ្ធិ បានដល់ ការសម្រេច ការសម្រេចព្រម អាការសម្រេច អាការសម្រេចព្រម ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ កិរិយាធ្វើឲ្យជាក់ច្បាស់ ការបានគ្រប់គ្រាន់ នូវធម៌

ទាំងឡាយនោះ ។ ពាក្យថា ឥទ្ធិបាទ គឺការពាល់ត្រូវ ។បេ។ ការផ្គងទុក សេចក្ដីមិនរាយមាយ របស់បុគ្គលមានសភាពដូច្នោះ ។ ពាក្យថា ចម្រើន នូវឥទ្ធិបាទ គឺភិក្ខុគប់រក អប់រំ ធ្វើឲ្យច្រើន នូវធម៌ទាំងឡាយនោះ ព្រោះហេតុនោះ ទើបពោលថា ចម្រើននូវឥទ្ធិបាទ ។

[ ២៧៤ ] ចុះភិក្ខុចម្រើននូវឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិ និង បធានសង្ខារ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដ: ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ភិក្ខុ ឈ្មោះថា ចម្រើននូវឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិ និង បធានសង្ខារ ។

[ ២៧៥ ] បណ្ដាធម៌ទាំងនោះ វីមំសា តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា វីមំសា ។ បណ្ដាធម៌ទាំងនោះ សមាធិ តើដូចម្ដេច ។ ការតាំងនៅនៃចិត្ត ។បេ។ សម្មាសមាធិ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សមាធិ ។ បណ្ដាធម៌ទាំងនោះ បធានសង្ខារ តើដូចម្ដេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា បធានសង្ខារ ។ ភិក្ខុ ជាអ្នកព្រមព្រៀង មូលមិត្រ

ចូលទៅជិត អែបនែប កៀកកើយ ប្រជិតប្រជី ប្រកបព្រមដោយវីមំសានេះផង ដោយសមាធិនេះផង ដោយបធានសង្ខារនេះផង ព្រោះហេតុនោះ ទើបពោលថា ប្រកបដោយវីមំសាសមាធិ និងបធានសង្ខារ ដោយប្រការដូច្នេះ ។

[ ២៧៦ ] ពាក្យថា ឥទ្ធិ បានដល់ ការសម្រេច ការសម្រេចព្រម អាការសម្រេច អាការសម្រេចព្រម ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ កិរិយាធ្វើឲ្យជាក់ច្បាស់ ការបានគ្រប់គ្រាន់ នូវធម៌ទាំងឡាយនោះ ។ ពាក្យថា ឥទ្ធិបាទ គឺការពាល់ត្រូវ ។បេ។ ការផ្គងទុកសេចក្ដីមិនរាយមាយ របស់បុគ្គលមានសភាពដូច្នោះ ។ ពាក្យថា ចម្រើននូវឥទ្ធិបាទ គឺភិក្ខុគប់រក អប់រំ ធ្វើឲ្យច្រើន នូវធម៌ទាំងឡាយនោះ ព្រោះហេតុនោះ ទើបពោលថា ចម្រើននូវឥទ្ធិបាទ ។

[ ២៧៧ ] ឥទ្ធិបាទ ៤ យ៉ាង គឺឆន្ទិទ្ធិបាទ ១ វីរិយិទ្ធិបាទ ១ ចិត្តិទ្ធិបាទ ១ វីមំសិទ្ធិបាទ ១ ។

[ ២៧៨ ] បណ្ដាឥទ្ធិបាទទាំងនោះ ឆន្ទិទ្ធិបាទ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដៈ ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ សេចក្ដីប្រាថ្នា ភាពនៃបុគ្គលមានសេចក្ដីប្រាថ្នា ភាពនៃបុគ្គលប្រាថ្នាដើម្បីធ្វើ ការប្រាថ្នាធម៌ជា

កុសលណា នេះហៅថា ឆន្ទិទ្ធិបាទ ពួកធម៌ដ៏សេស ក៏ឈ្មោះថា ប្រកប ដោយឆន្ទិទ្ធិបាទ ។

[ ២៧៩ ] បណ្ដាឥទ្ធិបាទទាំងនោះ វីរិយិទ្ធិបាទ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដៈ ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា វីរិយិទ្ធិបាទ ពួកធម៌ដ៏សេស ក៏ឈ្មោះថា ប្រកបដោយវីរិយិទ្ធិបាទ ។

[ ២៨០ ] បណ្ដាឥទ្ធិបាទទាំងនោះ ចិត្តិទ្ធិបាទ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដៈ ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ចិត្ត សេចក្ដីដឹង

អារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណធាតុនោះណា នេះហៅថា ចិត្តិទ្ធិបាទ ពួកធម៌ដ៏សេស ក៏ឈ្មោះថា ប្រកបដោយចិត្តិទ្ធិបាទ ។

[ ២៨១ ] បណ្តាឥទ្ធិបាទទាំងនោះ វីមំសិទ្ធិបាទ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដ: ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ បញ្ញា ការដឹងច្បាស់ ។បេ។ អមោហ: ធម្មវិចយ: សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា វីមំសិទ្ធិបាទ ពួកធម៌ដ៏សេស ក៏ឈ្មោះថា ប្រកបដោយវីមំសិទ្ធិបាទ ។

**អភិធម្មភាជនីយ ចប់**

# អដ្ឋកថា

## អភិធម្មភាជនីយ

[ ២៦៤-២៨១ ] ក្នុងអភិធម្មភាជនីយ មានអត្ថងាយយល់ហើយ បណ្ឌិតគប្បីរាប់ចំនួន ក្នុងអភិធម្មភាជនីយនោះ ។ ពិតហើយ ក្នុងឋានៈដែលព្រះមានព្រះភាគត្រាស់ហើយថា ភិក្ខុក្នុងធម្មវិន័យនេះ ចម្រើនឥទ្ធិបាទដែលប្រកបដោយឆន្ទៈ សមាធិ បធានសង្ខារ ដូច្នេះ ទើបលោកចែកលោកុត្តរជា ៤០០០ ន័យ សូម្បីក្នុងវិរិយសមាធិជាដើម ក៏ន័យនេះដូចគ្នា ។ ដោយទំនងនេះ ក្នុងឧត្តរចូឡភាជនីយ ទើបលោកចែកឥទ្ធិបាទទាំងអស់ជា ៣ ម៉ឺន ២ ពាន់ន័យ ( ៣២០០០ ) ដោយអំណាចចតុក្កៈ ៨ គឺក្នុងឆន្ទិទ្ធិបាទ ៤ ពាន់ន័យ ក្នុងវិរិយចិត្តវីមំសា នីមួយៗ ៤ ពាន់ន័យ ។ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគ ត្រាស់អភិធម្មភាជនីយនេះ ដែលប្រដាប់ចំពោះហើយ ដោយន័យ ៣២០០០ ន័យ ដោយអំណាចឥទ្ធិបាទទាំងឡាយ ដែលជាលោកុត្តរដែលកើតហើយនោះឯង ដូចពណ៌នាមក ដូច្នេះ ។

**អដ្ឋកថាអភិធម្មភាជនីយ ចប់**

# អភិធម្មបិដក

## បញ្ហាបុច្ឆកៈ

[ ២៨២ ] ឥទ្ធិបាទ ៤ គឺភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ១ វីរិយសមាធិ ... ១ ចិត្តសមាធិ ... ១ ចម្រើននូវឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិ និងបធានសង្ខារ ១ ។ បណ្ដាឥទ្ធិបាទទាំង ៤ ឥទ្ធិបាទ ជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។បេ។ ជាសរណៈប៉ុន្មាន ជាអរណៈប៉ុន្មាន ។

[ ២៨៣ ] ឥទ្ធិបាទ ៤ ជាកុសលតែមួយយ៉ាង ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនា តែមានវិបាកជាធម៌ជាប្រក្រតី ដែលកិលេស មានតណ្ហាជាដើម មិនកាន់យក ទាំងមិនជាប្រយោជន៍ដល់ឧបាទាន មិនសៅហ្មង ទាំងមិនគួរដល់នូវសេចក្ដីសៅហ្មងក៏មាន ប្រកបដោយវិតក្កនិងវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក មិនមានវិចារក៏មាន ប្រឡំដោយបីតិក៏មាន ប្រឡំដោយសុខក៏មាន ប្រឡំដោយឧបេក្ខាដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាធម៌មានហេតុ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដៈ ) ជារបស់សេក្ខៈ ជាធម៌មានប្រមាណមិនមាន មានអារម្មណ៍ប្រមាណមិនមាន ជាធម៌ដ៏ឧត្ដម មានសភាពត្រូវ និងទៀង មិនមែនមានមគ្គជាអារម្មណ៍ មានមគ្គជាហេតុ មិនមែនមានមគ្គជាអធិបតីក៏មាន កើតឡើងហើយក៏មាន មិនទាន់កើតឡើង តែមិនគួរពោលថា បម្រុងនឹងកើតឡើងក៏មាន ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្ន

តែមិនគួរពោលថា មានអារម្មណ៍ជាអតីតផង ជាមានអារម្មណ៍ជាអនាគតផង ជាមានអារម្មណ៍ជាបច្ចុប្បន្នផងក៏មាន ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ខាងក្នុង ទាំងខាងក្រៅ មានអារម្មណ៍ជាខាងក្រៅ មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ក៏មាន ។

[ ២៨៤ ] វីមំសិទ្ធិបាទ ជាហេតុ ឥទ្ធិបាទ ៣ មិនមែនជាហេតុ ។ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ ប្រកបដោយហេតុ ។ វីមំសិទ្ធិបាទ ជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផង ឥទ្ធិបាទ ៣ មិនគួរពោលថាជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុទេ គឺគ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនជាហេតុ ។ វីមំសិទ្ធិបាទ ជាហេតុផង ប្រកបដោយហេតុផង ឥទ្ធិបាទ ៣ មិនគួរពោលថាជាហេតុ ទាំងប្រកបដោយហេតុឡើយ គ្រាន់តែប្រកបដោយហេតុ តែមិនមែនជាហេតុ ។ ឥទ្ធិបាទ ៣ មិនមែនជាហេតុ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ វីមំសិទ្ធិបាទ មិនគួរពោលថា មិនមែនជាហេតុ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុផង ជាមិនមែនជាហេតុ ទាំងឥតហេតុផង ។

[ ២៨៥ ] ឥទ្ធិបាទ ៤ ប្រកបដោយបច្ច័យ ត្រូវបច្ច័យតាក់តែង មិនប្រកបដោយការឃើញ មិនមានការប៉ះពាល់ ជាអរូប ជាលោកុត្តរ ដែលគប្បីដឹងដោយវិញ្ញាណណាមួយ ( មានចក្ខុវិញ្ញាណជាដើម ) មិនគប្បីដឹងដោយវិញ្ញាណណាមួយ ។ ឥទ្ធិបាទ ៤ មិនមែនអាសវៈ ទាំងមិនមានអាសវៈ ប្រាសចាកអាសវៈ មិនគួរពោលថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ជាប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈផងទេ

មិនគួរពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈផង ថាប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផងឡើយ គឺជាធម៌ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ។ ឥទ្ធិបាទ ៤ មិនមែនសញ្ញោជនៈ ។បេ។ មិនមែនគន្ថៈ ។បេ។ មិនមែនឱឃៈ ។បេ។ មិនមែនយោគៈ ។បេ។ មិនមែននីវរណៈ ។បេ។ មិនមែនបរាមាស ។បេ។

[ ២៨៦ ] ឥទ្ធិបាទ ៤ ប្រកបដោយអារម្មណ៍ ។ ឥទ្ធិបាទ ៣ មិនមែនចិត្ត ចិត្តិទ្ធិបាទ ជាចិត្ត ។ ឥទ្ធិបាទ ៣ ជាចេតសិក ចិត្តិទ្ធិបាទ មិនមែនចេតសិក ។ ឥទ្ធិបាទ ៣ ប្រកបដោយចិត្ត ចិត្តិទ្ធិបាទ មិនគួរពោលថា ប្រកបដោយចិត្តផង ថាប្រាសចាកចិត្តផងឡើយ ។ ឥទ្ធិបាទ ៣ ច្រឡំដោយចិត្ត ចិត្តិទ្ធិបាទ មិនគួរពោលថា ច្រឡំដោយចិត្តផង ថាមិនច្រឡំដោយចិត្តផងទេ ។ ឥទ្ធិបាទ ៣ តាំងឡើងអំពីចិត្ត ចិត្តិទ្ធិបាទ មិនមែនតាំងឡើងអំពីចិត្ត ។ ឥទ្ធិបាទ ៣ កើតជាមួយនឹងចិត្ត ចិត្តិទ្ធិបាទ មិនមែនកើតជាមួយនឹងចិត្ត ។ ឥទ្ធិបាទ ៣ ប្រព្រឹត្តទៅតាមចិត្ត ចិត្តិទ្ធិបាទ មិនមែនប្រព្រឹត្តទៅតាមចិត្ត ។ ឥទ្ធិបាទ ៣ ច្រឡំទាំងតាំងឡើងអំពីចិត្ត ចិត្តិទ្ធិបាទ មិនច្រឡំ មិនតាំងឡើងអំពីចិត្ត ។ ឥទ្ធិបាទ ៣ ច្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត ចិត្តិទ្ធិបាទ មិនច្រឡំ មិនតាំងឡើង មិនកើតជាមួយនឹងចិត្ត ។ ឥទ្ធិបាទ ៣ ច្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត ចិត្តិទ្ធិបាទ មិនច្រឡំ មិនតាំងឡើង មិនប្រព្រឹត្តទៅតាមចិត្ត ។ ឥទ្ធិបាទ ៣ ជាខាងក្រៅ ចិត្តិទ្ធិបាទ ជាខាងក្នុង ។ ឥទ្ធិបាទ ៤ មិនមែនឧបាទា ដែលកិលេស មានតណ្ហា និងទិដ្ឋិជាដើមមិនកាន់យកហើយ ។

[ ២៨៧ ] ឥទ្ធិបាទ ៤ មិនមែនឧបាទាន ។បេ។ មិនមែនកិលេស ។បេ។ មិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុ មិនគួរលះដោយទស្សនៈ មានហេតុ មិនគួរលះដោយភាវនា ប្រកបដោយវិតក្កក៏មាន មិនមានវិតក្កក៏មាន ប្រកបដោយវិចារក៏មាន មិនមានវិចារក៏មាន ប្រកបដោយបីតិក៏មាន មិនមានបីតិក៏មាន ប្រឡំដោយបីតិក៏មាន មិនប្រឡំដោយបីតិក៏មាន ប្រឡំដោយសុខក៏មាន មិនប្រឡំដោយសុខក៏មាន ប្រឡំដោយឧបេក្ខាក៏មាន មិនប្រឡំដោយឧបេក្ខា តែមិនមែនជាកាមាវចរ មិនមែនជារូបាវចរ មិនមែនជាអរូបាវចរ ជាអបរិយាបន្ន ជានិយ្យានិកៈ ជានិយតៈ ជាអនុត្តរៈ ជាអរណៈក៏មាន ។

បញ្ហាបុច្ឆកៈ ចប់

ឥទ្ធិបាទវិភង្គ ចប់

# អដ្ឋកថា

## បញ្ហាបុច្ឆកៈ

[ ២៨២-២៨៧ ] ក្នុងបញ្ហាបុច្ឆកៈ បណ្ឌិតគប្បីជ្រាបឥទ្ធិបាទទាំងឡាយជាកុសលជាដើម ដោយទំនងនៃព្រះបាលីនោះឯង ។ តែក្នុងអារម្មណត្តិកៈទាំងឡាយ ឥទ្ធិបាទទាំងអស់នេះ ជាអប្បមាណារម្មណៈប៉ុណ្ណោះ ព្រោះប្រារព្ធព្រះនិព្វានដែលជាអប្បមាណធម៌ ប្រព្រឹត្តទៅ មិនជាមគ្គារម្មណៈ ។ តែជាមគ្គហេតុកៈ ដោយអំណាចសហជាតហេតុ មិនជាមគ្គាធិបតី ព្រោះថាអធិបតី ៤ មិនធ្វើនូវគ្នានិងគ្នាឲ្យជាធំ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះភាពដែលខ្លួនឯងជាធំបំផុត ។

ឧបមាដូចរាជបុត្រ ៤ អង្គ មានជាតិស្មើគ្នា មានវ័យស្មើគ្នា មានកម្លាំងស្មើគ្នា មានសិប្បៈស្មើគ្នា រមែងមិនធ្វើនូវការឱនលំទោនដល់គ្នានិងគ្នា ព្រោះខ្លួនជាធំបំផុតយ៉ាងណា អធិបតីទាំង ៤ នេះ ក៏យ៉ាងនោះ រមែងមិនធ្វើនូវគ្នានិងគ្នាឲ្យជាធំ ព្រោះភាពដែលធម៌ទាំងនោះ នីមួយៗ ក៏ជាធំដូចគ្នា ព្រោះហេតុនោះ ទើបឥទ្ធិបាទទាំង ៤ នោះ មិនជាមគ្គាធិបតី ដោយចំណែកមួយនោះឯង ។ ក្នុងអតីតារម្មណៈជាដើម ក៏ពោលមិនបាន ក្នុងភាពជាអារម្មណ៍តែមួយ ។ ឥទ្ធិបាទទាំង ៤ នោះ ឈ្មោះថា ជាពហិទ្ធារម្មណ៍

ព្រោះព្រះនិព្វានជាធម៌ខាងក្រៅ ដូច្នេះឯង ។ ក្នុងបញ្ហាបុច្ឆកៈនេះ លោក ពោលឥទ្ធិបាទទាំងឡាយថា ជាលោកុត្តរដែលកើតឡើងហើយនោះឯង ។ ពិតហើយ ព្រះសម្មាសម្ពុទ្ធត្រាស់ឥទ្ធិបាទទាំងឡាយ ដែលជាលោកិយ និង លោកុត្តរលាយឡំគ្នា ក្នុងសុត្តន្តភាជនីយនោះឯង តែក្នុងអភិធម្មភាជនីយ និងក្នុងបញ្ហាបុច្ឆកៈ ត្រាស់ថា ជាលោកុត្តរតែម្យ៉ាង ។ ឥទ្ធិបាទវិភង្គនេះ ព្រះមានព្រះភាគក៏ទ្រង់នាំចេញចែកសម្តែងហើយជា ៣ បរិវដ្តៈយ៉ាងនេះ ដោយ ប្រការដូច្នេះឯង ។៚

**អដ្ឋកថាបញ្ហាបុច្ឆកៈ ចប់**

**អដ្ឋកថាឥទ្ធិបាទវិភង្គ ចប់**

# អភិធម្មបិដក

## ពោជ្ឈង្គវិភង្គ

[ ២៨៨ ] ពោជ្ឈង្គ ៧ គឺសតិសម្ពោជ្ឈង្គ ១ ធម្មវិចយសម្ពោជ្ឈង្គ ១ វីរិយសម្ពោជ្ឈង្គ ១ បីតិសម្ពោជ្ឈង្គ ១ បស្សទ្ធិសម្ពោជ្ឈង្គ ១ សមាធិសម្ពោជ្ឈង្គ ១ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។

[ ២៨៩ ] បណ្តាសម្ពោជ្ឈង្គទាំងនោះ សតិសម្ពោជ្ឈង្គ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានស្មារតី ប្រកបដោយស្មារតី និងបញ្ញាខាប់ខ្ជួន ដ៏ប្រសើរ ជាអ្នករឭក នឹកឃើញ នូវអំពើដែលខ្លួន ឬអ្នកដទៃធ្វើហើយអស់កាលយូរក្តី នូវពាក្យដែលខ្លួន ឬអ្នកដទៃនិយាយហើយ អស់កាលយូរក្តី នេះហៅថា សតិសម្ពោជ្ឈង្គ ។ ភិក្ខុនោះ ជាអ្នកមានស្មារតី មានសភាពដូច្នោះ រមែងពិនិត្យ សង្កេតនូវធម៌នោះ ដោយបញ្ញា រមែងដល់នូវការពិចារណាជុំវិញ នេះហៅថា ធម្មវិចយសម្ពោជ្ឈង្គ ។ កាលភិក្ខុនោះ ពិនិត្យសង្កេត នូវធម៌នោះ ដោយបញ្ញា ដល់នូវការពិចារណាជុំវិញ វីរិយៈជាគុណដែលខ្លួនប្រារព្ធហើយ មិនរួញរាក៏មាន នេះហៅថា វីរិយសម្ពោជ្ឈង្គ ។ កាលភិក្ខុមានព្យាយាមប្រារព្ធហើយ បីតិប្រាសចាកអាមិស ក៏កើតឡើង នេះហៅថា បីតិសម្ពោជ្ឈង្គ ។ កាលភិក្ខុ មានចិត្តប្រកបដោយបីតិ កាយក៏ស្ងប់រម្ងាប់ចិត្តក៏ស្ងប់រម្ងាប់ នេះហៅថា បស្សទ្ធិសម្ពោជ្ឈង្គ ។ កាលភិក្ខុ មានកាយស្ងប់រម្ងាប់ មានសេចក្តីសុខ ចិត្តក៏តម្កល់នៅមាំ នេះហៅថា សមាធិសម្ពោជ្ឈង្គ ។ ភិក្ខុនោះ ជាអ្នកពិចារណា ឃើញដោយប្រពៃ នូវចិត្តដែលតម្កល់ទុកល្អមានសភាពដូច្នោះ នេះហៅថា ឧបេក្ខាសម្ពោជ្ឈង្គ ។

[ ២៩០ ] ពោជ្ឈង្គ ៧ គឺសតិសម្ពោជ្ឈង្គ ១ ធម្មវិចយសម្ពោជ្ឈង្គ ១ វីរិយសម្ពោជ្ឈង្គ ១ បីតិសម្ពោជ្ឈង្គ ១ បស្សទ្ធិសម្ពោជ្ឈង្គ ១ សមាធិសម្ពោជ្ឈង្គ ១ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។

[ ២៩១ ] បណ្ដាសម្ពោជ្ឈង្គទាំងនោះ សតិសម្ពោជ្ឈង្គ តើដូចម្ដេច ។ សតិក្នុងធម៌ទាំងឡាយ ខាងក្នុងក៏មាន សតិក្នុងធម៌ទាំងឡាយ ខាងក្រៅក៏មាន ។ បើសតិក្នុងធម៌ទាំងឡាយ ខាងក្នុង មានក្នុងកាលណា សតិសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។ បើសតិក្នុងធម៌ទាំងឡាយ ខាងក្រៅ មានក្នុងកាលណា សតិសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។

[ ២៩២ ] បណ្ដាសម្ពោជ្ឈង្គទាំងនោះ ធម្មវិចយសម្ពោជ្ឈង្គ តើដូចម្ដេច ។ ការសង្កេតក្នុងធម៌ទាំងឡាយ ខាងក្នុងក៏មាន ការសង្កេតក្នុងធម៌ទាំងឡាយ ខាងក្រៅក៏មាន ។ បើការសង្កេតក្នុងធម៌ទាំងឡាយ ខាងក្នុង មានក្នុងកាលណា ធម្មវិចយសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។ បើការសង្កេតក្នុងធម៌ទាំងឡាយ ខាងក្រៅ មានក្នុងកាលណា ធម្មវិចយសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។

[ ២៩៣ ] បណ្ដាសម្ពោជ្ឈង្គទាំងនោះ វីរិយសម្ពោជ្ឈង្គ តើដូចម្ដេច ។ វីរិយៈប្រព្រឹត្តទៅក្នុងកាយក៏មាន វីរិយៈប្រព្រឹត្តទៅក្នុងចិត្តក៏មាន ។ បើវីរិយៈ

ប្រព្រឹត្តទៅក្នុងកាយ មានក្នុងកាលណា វីរិយសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។ បើវីរិយៈប្រព្រឹត្តទៅក្នុងចិត្ត មានក្នុងកាលណា វីរិយសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។

[ ២៩៤ ] បណ្តាសម្ពោជ្ឈង្គទាំងនោះ បីតិសម្ពោជ្ឈង្គ តើដូចម្តេច ។ បីតិប្រកបដោយវិតក្ក ប្រកបដោយវិចារក៏មាន បីតិមិនមានវិតក្ក មិនមានវិចារក៏មាន ។ បើបីតិប្រកបដោយវិតក្ក ប្រកបដោយវិចារ មានក្នុងកាលណា បីតិសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។ បើបីតិមិនមានវិតក្ក មិនមានវិចារ មានក្នុងកាលណា បីតិសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។

[ ២៩៥ ] បណ្តាសម្ពោជ្ឈង្គទាំងនោះ បស្សទ្ធិសម្ពោជ្ឈង្គ តើដូចម្តេច ។ កាយប្បស្សទ្ធិ ( សេចក្តីស្ងប់កាយ ) ក៏មាន ចិត្តប្បស្សទ្ធិ ( សេចក្តីស្ងប់ចិត្ត ) ក៏មាន ។ បើកាយប្បស្សទ្ធិ មានក្នុងកាលណា បស្សទ្ធិសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។ បើចិត្តប្បស្សទ្ធិ មានក្នុងកាលណា បស្សទ្ធិសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។

[ ២៩៦ ] បណ្តាសម្ពោជ្ឈង្គទាំងនោះ សមាធិសម្ពោជ្ឈង្គ តើដូចម្តេច ។ សមាធិប្រកបដោយវិតក្ក ប្រកបដោយវិចារក៏មាន សមាធិមិនមានវិតក្ក មិន

មានវិចារក៏មាន ។ បើសមាធិប្រកបដោយវិតក្ក ប្រកបដោយវិចារ មានក្នុងកាលណា សមាធិសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។ បើសមាធិមិនមានវិតក្ក មិនមានវិចារ មានក្នុងកាលណា សមាធិសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។

[ ២៩៧ ] បណ្តាសម្ពោជ្ឈង្គទាំងនោះ ឧបេក្ខាសម្ពោជ្ឈង្គ តើដូចម្តេច ។ ឧបេក្ខាក្នុងធម៌ទាំងឡាយ ខាងក្នុងក៏មាន ឧបេក្ខាក្នុងធម៌ទាំងឡាយ ខាងក្រៅក៏មាន ។ បើឧបេក្ខាក្នុងធម៌ទាំងឡាយ ខាងក្នុង មានក្នុងកាលណា ឧបេក្ខាសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។ បើឧបេក្ខាក្នុងធម៌ទាំងឡាយ ខាងក្រៅ មានក្នុងកាលណា ឧបេក្ខាសម្ពោជ្ឈង្គ ក៏ប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ក្នុងកាលនោះដែរ ។

[ ២៩៨ ] ពោជ្ឈង្គ ៧ គឺសតិសម្ពោជ្ឈង្គ ១ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ បណ្តាសម្ពោជ្ឈង្គទាំងនោះ សតិសម្ពោជ្ឈង្គ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ចម្រើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់

អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវនិរោធ ជាគ្រឿងឈមទៅកាន់ការលះ ចម្រើននូវធម្មវិចយសម្ពោជ្ឈង្គ ចម្រើននូវវីរិយសម្ពោជ្ឈង្គ ចម្រើននូវបីតិសម្ពោជ្ឈង្គ ចម្រើននូវបស្សទ្ធិសម្ពោជ្ឈង្គ ចម្រើននូវសមាធិ-សម្ពោជ្ឈង្គ ចម្រើននូវឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្ដីស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវនិរោធ ជាគ្រឿងឈមទៅកាន់ការលះ ។

សុត្តន្តភាជនីយ ចប់

# អដ្ឋកថា

# ពោជ្ឈង្គវិភង្គ

## សុត្តន្តភាជនីយ

[ ២៨៨-២៩៨ ] ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងពោជ្ឈង្គវិភង្គ ដែលជាលំដាប់បន្ទអំពីឥទ្ធិបាទវិភង្គដូចតទៅ

បទថា **សត្ត** ជាពាក្យកំណត់ចំនួន ។ បទថា **ពោជ្ឈង្គា** មានវិគ្គហៈថា ឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថថា ជាអង្គនៃបញ្ញាជាគ្រឿងត្រាស់ដឹង ឬជាអង្គនៃព្រះសាវកដែលត្រាស់ដឹង ។ លោកអធិប្បាយពាក្យនេះថា ធម្មសាមគ្គីនេះ ហៅថា **ពោធិ** ព្រោះធ្វើពាក្យអធិប្បាយថា អរិយសាវក រមែងត្រាស់ដឹងដោយធម្មសាមគ្គី ពោល គឺសតិ ធម្មវិចយៈ វីរិយៈ បីតិ បស្សទ្ធិ សមាធិ និងឧបេក្ខាដែលកើតឡើងក្នុងខណៈនៃលោកុត្តរមគ្គឯណា ដែលជាបដិបក្ខចំពោះឧបទ្រវ គឺអន្តរាយមិនមែនតិច មានការរួញរា ការរាយមាយ ការតាំងនៅនៃទុក្ខ ការកពូន គឺប្រមូលមកនូវទុក្ខ ដែលមានការប្រកាន់មាំក្នុងកាមសុខ អត្តកិលមថានុយោគ ឧច្ឆេទទិដ្ឋិ សស្សតទិដ្ឋិជាដើម ។

ពាក្យថា រមែងត្រាស់ដឹង បានដល់ ធម្មសាមគ្គីនោះ រមែងតាំងឡើង ( ភ្ញាក់ ) អំពីការដេកលក់នៃការបន្តរបស់កិលេស ។ ម្យ៉ាងទៀត ពាក្យថា រមែងត្រាស់ដឹង បានដល់ រមែងចាក់ធ្លុះនូវសច្ចៈទាំង ៤ ឬរមែងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាននោះឯង ។ ឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថថា ជាអង្គ

*នៃបញ្ញាជាគ្រឿងត្រាស់ដឹង ពោល គឺធម្មសាមគ្គីនោះ ដូចអង្គនៃឈាន និង អង្គនៃមគ្គជាដើមក៏បាន ។ ព្រះអរិយសាវកនេះ លោកហៅថា* **ពោធិ** *( អ្នក ត្រាស់ដឹង ) ព្រោះធ្វើពាក្យអធិប្បាយថា រមែងត្រាស់ដឹងដោយធម្មសាមគ្គី មានប្រការតាមដែលពោលមកនោះ ព្រោះអត្ថថា ជាអង្គនៃអរិយសាវកអ្នក ត្រាស់ដឹងនោះ ដូចអង្គនៃសេនា អង្គនៃរថជាដើម ។ ដោយហេតុនោះ ទើប ព្រះអដ្ឋកថាចារ្យទាំងឡាយពោលថា ឈ្មោះថា* **ពោជ្ឈង្គ** *ព្រោះអត្ថថា ជាអង្គនៃបុគ្គលត្រាស់ដឹង ដូច្នេះឯង ។*

*ម្យ៉ាងទៀត ពាក្យថា ពោជ្ឈង្គ ដែលឈ្មោះថា ពោជ្ឈង្គ ព្រោះអត្ថ ដូចម្ដេច សេចក្ដីនេះ បណ្ឌិតគប្បីជ្រាបអត្ថនៃពោជ្ឈង្គ ដោយន័យរបស់គម្ពីរ បដិសម្ភិទានេះថា សំណួរត្រង់ពាក្យថា ពោជ្ឈង្គ តើពោជ្ឈង្គដោយអត្ថថា ដូចម្ដេច ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុប្រព្រឹត្តទៅព្រមក្នុងការត្រាស់ ដឹង ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង ឈ្មោះថា ពោជ្ឈង្គ ព្រោះ ហេតុត្រាស់ដឹងតាម ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងចំពោះ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងព្រម ដូច្នេះក៏បាន ។*

*គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា* **សតិសម្ពោជ្ឈង្គ** *ជាដើមដូចតទៅ ពោជ្ឈង្គដែលបណ្ឌិតសរសើរហើយផង ជាធម្មជាតល្អផង ឈ្មោះថា* **សម្ពោជ្ឈង្គ** *។ សម្ពោជ្ឈង្គ គឺសតិនោះឯង ឈ្មោះថា* **សតិសម្ពោជ្ឈង្គ** *( ពោជ្ឈង្គដ៏សេសក៏ដូចគ្នា ) ។ បណ្ដាសម្ពោជ្ឈង្គទាំងនោះ សតិសម្ពោជ្ឈង្គ មានការប្រាកដជាលក្ខណៈ ធម្មវិចយសម្ពោជ្ឈង្គ មានការពិចារណាជា*

លក្ខណៈ វីរិយសម្ពោជ្ឈង្គ មានការផ្គងជាលក្ខណៈ បីតិសម្ពោជ្ឈង្គ មានការផ្សាយទៅជាលក្ខណៈ បស្សទ្ធិសម្ពោជ្ឈង្គ មានការស្ងប់ជាលក្ខណៈ សមាធិសម្ពោជ្ឈង្គ មានការមិនរាយមាយជាលក្ខណៈ ឧបេក្ខាសម្ពោជ្ឈង្គ មានការសម្លឹងព្រងើយជាលក្ខណៈ ។ ក្នុងសម្ពោជ្ឈង្គទាំងនោះ ព្រះមានព្រះភាគត្រាស់សតិសម្ពោជ្ឈង្គមុន ព្រោះសតិសម្ពោជ្ឈង្គ ជាធម៌មានឧបការៈដល់សម្ពោជ្ឈង្គទាំងអស់ ដូចព្រះបាលី ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សតិជាគ្រឿងសម្រេចប្រយោជន៍គ្រប់យ៉ាង ដូច្នេះ ។ ខាងមុខអំពីនេះទៅ ការប្រកបមេបទដោយលំដាប់យ៉ាងនេះឯង មកហើយក្នុងព្រះបាលី ( មជ្ឈិមនិកាយ ឧបរិបណ្ណាសក ) ដោយន័យជាដើមថា ភិក្ខុនោះ ជាអ្នកមានស្មារតី ដូច្នោះ ក៏ជ្រើសរើស ត្រិះរិះ ដល់នូវកិរិយាល្បងនូវធម៌នោះដោយប្រាជ្ញា ដូច្នេះជាដើម ។

សួរថា ព្រះមានព្រះភាគត្រាស់ពោជ្ឈង្គ ៧ ប៉ុណ្ណោះ មិនច្រើន មិនតិចជាងនេះ ព្រោះហេតុអ្វី ឆ្លើយថា ព្រោះជាបដិបក្ខចំពោះការរួញរា និងឧទ្ធច្ចៈ ព្រោះជាធម៌មានប្រយោជន៍ក្នុងទីទាំងពួង ។ ពិតហើយ ក្នុងពោជ្ឈង្គទាំងនេះ ពោជ្ឈង្គ ៣ គឺធម្មវិចយៈ វីរិយៈ បីតិ ជាបដិបក្ខចំពោះការរួញរា ដូចព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ បើចិត្តរួញរាក្នុងសម័យណា សម័យនោះ ជាកាលគួរនឹងចម្រើនធម្មវិចយសម្ពោជ្ឈង្គ ជាកាលគួរនឹងចម្រើនវីរិយសម្ពោជ្ឈង្គ ជាកាលគួរនឹងចម្រើនបីតិសម្ពោជ្ឈង្គ ដូច្នេះ ។ ពោជ្ឈង្គ ៣ គឺបស្សទ្ធិ សមាធិ

ឧបេក្ខា ជាបដិបក្ខចំពោះឧទ្ធច្ចៈ ដូចព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្ត-និកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ បើចិត្តរាយមាយក្នុងសម័យណា សម័យនោះ ជាកាលគួរនឹងចម្រើនបស្សទ្ធិសម្ពោជ្ឈង្គ ជាកាលគួរនឹងចម្រើនសមាធិសម្ពោជ្ឈង្គ ជាកាលគួរនឹងចម្រើនឧបេក្ខាសម្ពោជ្ឈង្គ ដូច្នេះ ។ មួយវិញទៀត ក្នុងពោជ្ឈង្គទាំង ៧ នោះ ពោជ្ឈង្គ ១ គឺសតិ ឈ្មោះថា ជាប្រយោជន៍ក្នុងទីទាំងពួង ព្រោះបុគ្គលចាំបាច់ប្រាថ្នាក្នុងទីទាំងពួង ប្រៀបដូចអំបិល និងគ្រឿងទេស ចាំបាច់ក្នុងសម្លគ្រប់យ៉ាង និងប្រៀបដូចអមាត្យដែលធ្វើការងារទាំងអស់ក្នុងរាជកិច្ចទាំងពួង ដូចព្រះដ៏មានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សតិជាគ្រឿងសម្រេចប្រយោជន៍គ្រប់យ៉ាង ដូច្នេះ ។ បាលីថា **សព្វត្ថកំ** ដូច្នេះក៏មាន ។ ពាក្យទាំងពីរនោះ មានអធិប្បាយថា គប្បីប្រាថ្នាក្នុងទីទាំងពួង គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ពោជ្ឈង្គ ៧ ប៉ុណ្ណោះ ព្រោះជាបដិបក្ខចំពោះការរួញរា និងឧទ្ធច្ចៈ និងព្រោះជាធម៌មានប្រយោជន៍ក្នុងទីទាំងពួង ដូចពណ៌នាមក ដូច្នេះឯង ។

ឥឡូវនេះ ដើម្បីសម្តែងហេតុនៃការផ្សេងគ្នានៃពោជ្ឈង្គទាំងនោះ ដោយអំណាចនៃកិច្ចរៀងៗ ខ្លួន ក្នុងអារម្មណ៍មួយប៉ុណ្ណោះ ទើបព្រះមានព្រះភាគទ្រង់ផ្តើមពាក្យថា **តត្ថ កតមោ សតិសម្ពោជ្ឈង្គោ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **ឥធ ភិក្ខុ** បានដល់ ភិក្ខុក្នុងសាសនានេះ ។ បទថា **សតិមា ហោតិ** បានដល់ ជាអ្នកមានសតិ ដូចបុគ្គលមានបញ្ញា

ព្រោះប្រកបដោយបញ្ញា បុគ្គលមានយស ព្រោះប្រកបដោយយស បុគ្គលមានទ្រព្យ ព្រោះប្រកបដោយទ្រព្យ ដូច្នោះ អធិប្បាយថា ជាអ្នកដល់ព្រមហើយដោយសតិ ។ បទថា **បរមេន** បានដល់ ឧត្តម ។ ពិតហើយ សតិនិងបញ្ញានោះ ឈ្មោះថា ជាធម៌ដ៏ក្រៃលែង ជាធម៌ដ៏ឧត្តម ជាធម៌ប្រសើរបំផុត ព្រោះជាធម៌អនុលោមតាមព្រះនិព្វានដែលជាបរមត្ថសច្ច និងមគ្គសច្ច ។ បញ្ញា ហៅថា **នេបក្ក** ក្នុងបទថា **សតិនេបក្កេន** មានអធិប្បាយថា ដោយសតិ និងដោយបញ្ញា ។ សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់សង្គ្រោះបញ្ញាក្នុងការចែកបទនៃសតិនេះ ឆ្លើយថា ទ្រង់សង្គ្រោះដើម្បីសម្ដែងភាពដែលសតិកម្លាំង ។ ពិតហើយ សតិ រមែងកើតព្រមជាមួយបញ្ញាក៏បាន សតិនោះ កាលកើតព្រមជាមួយបញ្ញា រមែងមានកម្លាំង កាលកើតវៀរចាកបញ្ញា រមែងមានកម្លាំងខ្សោយ ដោយហេតុនោះ ទើបព្រះមានព្រះភាគទ្រង់កាន់យកបញ្ញាផង ដើម្បីសម្ដែងនូវភាពដែលសតិសម្បយុត្តនោះ ជាសភាវៈមានកម្លាំង ។

ឧបមាដូចរាជមហាមាត្យ ២ នាក់ ឈរក្នុងទិសទាំងពីរ បណ្ដាមហាមាត្យទាំង ២ នោះ មហាមាត្យម្នាក់ពព្រះរាជបុត្រឈរ មហាមាត្យម្នាក់ទៀត ឈរតាមធម្មតារបស់ខ្លួន ។ ក្នុងមហាមាត្យទាំងនោះ មហាមាត្យដែលពព្រះរាជបុត្រឈរ រមែងជាអ្នកមានអំណាច ដោយអំណាចរបស់ខ្លួនផង ដោយអំណាចរបស់ព្រះរាជបុត្រផង មហាមាត្យដែលឈរតាមធម្មតារបស់ខ្លួន មិនមានអំណាចស្មើនឹងអមាត្យដែលពព្រះរាជបុត្រនោះ យ៉ាងណា សេចក្ដីនោះ

ក៏យ៉ាងនោះឯង សតិដែលកើតឡើងជាមួយបញ្ញា ប្រៀបដូចមហាមាត្យដែលពព្រះរាជបុត្រឈរ សតិកើតឡើងវៀរចាកបញ្ញា ប្រៀបដូចមហាមាត្យដែលឈរតាមធម្មតារបស់ខ្លួន ។ ក្នុងអមាត្យទាំងនោះ អមាត្យដែលពព្រះរាជបុត្រឈរ ជាអ្នកមានអំណាច ដោយអំណាចនៃខ្លួនខ្លះ ដោយអំណាចរបស់ព្រះរាជបុត្រខ្លះ យ៉ាងណា សតិដែលកើតឡើង មួយអន្លើដោយបញ្ញា ក៏រមែងជាសភាវៈមានកម្លាំងយ៉ាងនោះ ។ មហាមាត្យដែលនៅតាមធម្មតារបស់ខ្លួន ជាអ្នកមិនមានអំណាចស្មើដោយអំណាច របស់មហាមាត្យដែលពព្រះរាជបុត្រឈរ យ៉ាងណា សតិកើតឡើង វៀរចាកបញ្ញា រមែងមានកម្លាំងទន់ខ្សោយក៏យ៉ាងនោះ ព្រោះហេតុនោះ ដើម្បីសម្តែងភាពដែលសតិជាសភាវៈមានកម្លាំង ទើបព្រះមានព្រះភាគ ទ្រង់កាន់យកបញ្ញាផង ។

បទថា **ចិរកតម្បិ** បានដល់ វត្ត កសិណមណ្ឌល ឬកសិណបរិកម្ម ដែលធ្វើយូរៗ ដោយកាយរបស់ខ្លួន ឬរបស់អ្នកដទៃ ។ បទថា **ចិរភាសិតម្បិ** បានដល់ ធម្មកថា ឬការវិនិច្ឆ័យក្នុងកម្មដ្ឋានច្រើន ដែលតាំងនៅក្នុងមាតិកានៃវត្ត ឬធម្មកថានោះឯង ដែលតាំងនៅក្នុងវិមុត្តាយតនសីសៈ ដែលខ្លួន ឬអ្នកដទៃពោលយូរហើយដោយវាចា ។ បទថា **សរិតា ហោតិ** បានដល់ ជាអ្នករឭកដល់ចំណែកនៃអរូបធម៌ ដែលញុំាងកាយវិញ្ញត្តិ និងវចីវិញ្ញត្តិនោះ ឲ្យតាំងឡើងព្រមហើយ ប្រព្រឹត្តទៅហើយថា វត្តនេះ កើតឡើងហើយយ៉ាងនេះ រលត់ទៅហើយយ៉ាងនេះ ។ បទថា **អនុស្សរិតា** បានដល់ រឭកបានរឿយៗ ។ បទថា **អយំ វុច្ចតិ សតិសម្ពោជ្ឈង្គោ** បានដល់ សតិ

ដែលសម្បយុត្តដោយវិបស្សនា ដែលសម្ពោជ្ឈង្គដ៏សេសឲ្យតាំងឡើង ដែលកើតឡើងហើយយ៉ាងនេះ ព្រះមានព្រះភាគត្រាស់ហៅថា សតិសម្ពោជ្ឈង្គ ។

បទថា **សោ តថា សតោ វិហរន្តោ** បានដល់ ភិក្ខុនោះ ជាអ្នកមានស្មារតី ដោយសតិដែលកើតឡើងហើយ ដោយអាការយ៉ាងនោះ ។ បទថា **តំ ធម្មំ** បានដល់ ធម៌ មានប្រការតាមដែលពោលហើយខាងដើម ដែលធ្វើយូរហើយ ដែលពោលយូរហើយនោះ ។ បទថា **បញ្ញាយ បវិចិនតិ** បានដល់ ពិចារណាដោយបញ្ញាថា នេះមិនទៀង ជាទុក្ខ ជាអនត្តា ។ បទថា **បវិចរតិ** បានដល់ ញ៉ាំងបញ្ញាឲ្យពិចារណាក្នុងធម៌នោះថា ជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ។ បទថា **បរិវីមំសំ អាបជ្ជតិ** បានដល់ រមែងដល់នូវការសម្លឹងមើល គឺពិចារណា ។ បទថា **អយំ វុច្ចតិ** បានដល់ ជាវិបស្សនាញាណ ដែលញ៉ាំងពោជ្ឈង្គឲ្យកើតឡើង មានប្រការតាមដែលពោលហើយនេះ ហៅថា ធម្មវិចយសម្ពោជ្ឈង្គ ។

បទថា **តស្ស តំ ធម្មំ** បានដល់ ដែលភិក្ខុនោះ ពិចារណាធម៌នោះដែលមានប្រការតាមដែលពោលហើយខាងដើម ។ បទថា **អារទ្ធំ ហោតិ** បានដល់ ជាការព្យាយាមដ៏បរិបូណ៌ ជាការព្យាយាមដែលភិក្ខុនោះផ្គងហើយ ។ បទថា **អសល្លីនំ** បានដល់ ឈ្មោះថា ការមិនរួញរា ព្រោះការព្យាយាមដែលប្រារព្ធហើយនោះឯង ។ បទថា **អយំ វុច្ចតិ** បានដល់ សេចក្តីព្យាយាមដែលញ៉ាំងពោជ្ឈង្គឲ្យតាំងឡើង ដែលសម្បយុត្តដោយវិបស្សនានេះហៅថា វីរិយសម្ពោជ្ឈង្គ ។

បទថា **និរាមិសា** បានដល់ មិនមានអាមិស គឺបរិសុទ្ធ ព្រោះមិនមានអាមិស គឺកាម អាមិស គឺលោក និងអាមិស គឺវដ្តៈ ។ បទថា **អយំ វុច្ចតិ** បានដល់ បីតិដែលញ៉ាំងពោជ្ឈង្គឲ្យតាំងឡើង ដែលសម្បយុត្តដោយវិបស្សនា នេះហៅថា បីតិសម្ពោជ្ឈង្គ ។

បទថា **បីតិមនស្ស** បានដល់ ដែលមានចិត្តសម្បយុត្តដោយបីតិ ។ បទថា **កាយោបិ បស្សម្ភតិ** បានដល់ នាមកាយ ពោល គឺខន្ធ ៣ គឺវេទនា សញ្ញា សង្ខារ រមែងស្ងប់រម្ងាប់ ព្រោះការស្ងប់រម្ងាប់ទៅនូវការក្តៅក្រហាយ គឺកិលេស ។ បទថា **ចិត្តម្បិ** បានដល់ សូម្បីវិញ្ញាណក្ខន្ធ ក៏រមែងស្ងប់រម្ងាប់យ៉ាងនោះដូចគ្នា ។ បទថា **អយំ វុច្ចតិ** បានដល់ បស្សទ្ធិ ដែលញ៉ាំងពោជ្ឈង្គឲ្យកើតឡើង ដែលសម្បយុត្តដោយវិបស្សនានេះ ហៅថា បស្សទ្ធិសម្ពោជ្ឈង្គ ។

បទថា **បស្សទ្ធកាយស្ស សុខិនោ** បានដល់ ដែលដល់សេចក្តីសុខដោយសេចក្តីសុខដែលកើតឡើង ព្រោះកាយស្ងប់រម្ងាប់ហើយ ។ បទថា **សមាធិយតិ** បានដល់ រមែងតាំងមាំដោយប្រពៃ គឺជាសភាវៈមិនញាប់ញ័រតាំងនៅក្នុងអារម្មណ៍ ដូចសម្រេចអប្បនា ។ បទថា **អយំ វុច្ចតិ** បានដល់ ភាពដែលចិត្តមានអារម្មណ៍តែមួយ ដែលញ៉ាំងពោជ្ឈង្គឲ្យកើតឡើង ដែលសម្បយុត្តដោយវិបស្សនា នេះហៅថា សមាធិសម្ពោជ្ឈង្គ ។

បទថា **តថា សមាហិតំ** បានដល់ តាំងមាំដោយសមាធិ ដូចការសម្រេចអប្បនានោះ ។ បទថា **សាធុកំ អជ្ឈុបេក្ខិតា ហោតិ** បានដល់

*ជាអ្នកសម្លឹងយ៉ាងល្អ គឺជាសភាវៈមិនព្យាយាមក្នុងការលះ និងការចម្រើនធម៌ទាំងនោះ ទើបឈ្មោះថា រមែងសម្លឹងមើល ។ បទថា* **អយំ វុច្ចតិ** *បានដល់ អាការនៃភាពជាកណ្តាលដែលជាសភាវធម៌ញុំាងពោជ្ឈង្គ ៦ មិនឲ្យរួញរា មិនឲ្យឈានកន្លង ឲ្យសម្រេច នេះហៅថា ឧបេក្ខាសម្ពោជ្ឈង្គ ។*

*សួរថា ដោយពាក្យមានប្រមាណប៉ុណ្ណេះ ពាក្យណាមួយ ឈ្មោះថាជាពាក្យដែលព្រះមានព្រះភាគត្រាស់ហើយ ឆ្លើយថា ព្រះមានព្រះភាគត្រាស់ពោជ្ឈង្គទាំងឡាយ មានកិច្ច លក្ខណៈផ្សេងៗ មានវិបស្សនាជាចំណែកខាងដើម ក្នុងខណៈនៃចិត្តមួយដួង មិនមុនមិនក្រោយ ដូច្នេះ ។*

**ន័យទី ១ ចប់**

*ឥឡូវនេះ ពោជ្ឈង្គ ៧ រមែងជាពោជ្ឈង្គ ១៤ ដោយបរិយាយណា ព្រះមានព្រះភាគ កាលទឹងសម្តែងន័យទី ២ ដើម្បីទ្រង់ប្រកាសនូវបរិយាយនៃពោជ្ឈង្គ ១៤ ន័យ ទើបត្រាស់បទថា* **សត្ត ពោជ្ឈង្គា** *ជាដើមទៀត ។ ក្នុងន័យទី ២ នោះ គប្បីជ្រាបកិច្ចពណ៌នាបទដោយលំដាប់ដូចតទៅ*

*បទថា* **អជ្ឈត្តំ ធម្មេសុ សតិ** *បានដល់ សតិដែលកើតឡើងដល់បុគ្គលដែលកំណត់ជុំវិញសង្ខារទាំងឡាយដែលជាខាងក្នុង ។ បទថា* **ពហិទ្ធា ធម្មេសុ សតិ** *បានដល់ សតិដែលកើតឡើងដល់បុគ្គលដែលកំណត់សង្ខារទាំងឡាយជាខាងក្រៅ ។ បទថា* **យទបិ** *លោកកែជា* **យាបិ** ។ *បទថា* **តទបិ** *លោកកែជា* **សាបិ** ។ *បទថា* **អភិញ្ញាយ** *បានដល់ ដើម្បីប្រយោជន៍*

ដល់ការដឹងក្រៃលែង នូវធម៌ដែលគួរដឹងក្រៃលែង ។

មគ្គ ព្រះមានព្រះភាគត្រាស់ហៅថា **សម្មោធិ** ក្នុងបទថា **សម្មោធាយ** អធិប្បាយថា ដើម្បីប្រយោជន៍ដល់មគ្គផល ។

តណ្ហា ព្រះមានព្រះភាគត្រាស់ហៅថា **វាន** ក្នុងបទថា **និព្វានាយ** តណ្ហានោះ មិនមានក្នុងសភាវៈនោះ ព្រោះហេតុនោះ ទើបសភាវៈនោះ ហៅថា **និព្វាន** អធិប្បាយថា រមែងប្រព្រឹត្តទៅព្រមដើម្បីនិព្វាននោះ ដើម្បីអសង្ខតៈ ដើម្បីអមតធាតុ ដើម្បីការធ្វើឲ្យជាក់ច្បាស់ ដូច្នេះ ក្នុងធម្មវិចយសម្ពោជ្ឈង្គ ក៏ន័យនេះឯង ។

បទថា **កាយិកំ វីរិយំ** បានដល់ សេចក្ដីព្យាយាមដែលកើតឡើងហើយ ដល់បុគ្គលដែលអធិដ្ឋាននូវការបង្ក្រម ។ បទថា **ចេតសិកំ** បានដល់ សេចក្ដីព្យាយាមដែលកើតឡើងហើយ វៀរកាយបយោគយ៉ាងនេះថា ដរាបណាចិត្តរបស់អាត្មាអញ មិនរួចផុតចាកអាសវៈទាំងឡាយ ដោយការមិនប្រកាន់មាំហើយ អញនឹងមិនទម្លាយភ្នែននេះដរាបនោះ ។ បទថា **កាយបស្សទ្ធិ** បានដល់ ការស្ងប់រម្ងាប់នូវការក្រវល់ក្រវាយនៃខន្ធទាំង ៣ ។ បទថា **ចិត្តបស្សទ្ធិ** បានដល់ ការស្ងប់រម្ងាប់នូវការក្រវល់ក្រវាយរបស់វិញ្ញាណក្ខន្ធ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងឧបេក្ខាសម្ពោជ្ឈង្គ ដូចគ្នានឹងសតិសម្ពោជ្ឈង្គនោះឯង ។

ក្នុងន័យនេះ ព្រះមានព្រះភាគត្រាស់ពោជ្ឈង្គ ៧ លាយដោយលោកិយនិងលោកុត្តរ ។

ចំណែកព្រះថេរៈក្នុងកាលមុនទាំងឡាយ ពោលហើយថា ដោយន័យមានប្រមាណប៉ុណ្ណោះ ពាក្យដែលពោលហើយ មិនទាន់ប្រាកដច្បាស់ ទើបបែកសម្ដែងតទៅ ។ ពិតហើយ ធម៌ទាំង ៣ គឺសតិ បវិចយៈ ( ធម្មវិចយៈ ) ឧបេក្ខា ក្នុងធម៌ខាងក្នុងទាំងនោះជាលោកិយប៉ុណ្ណោះ ព្រោះខ្លួន គឺធម៌ទាំង ៣ មានខន្ធជាអារម្មណ៍ ។ សេចក្ដីព្យាយាមផ្លូវកាយ ( វីរិយៈ ) ដែលមិនទាន់សម្រេចមគ្គក៏ដូចគ្នា គឺនៅជាលោកិយ ចំណែកបីតិ និងសមាធិ ដែលមិនមានវិតក្ក មិនមានវិចារ ជាលោកុត្តរ ធម៌ដ៏សេស ជាលោកិយផងលោកុត្តរផងលាយឡំគ្នា ។ ក្នុងពោជ្ឈង្គទាំងនោះ សតិ បវិចយៈ ឧបេក្ខា ក្នុងធម៌ទាំងឡាយដែលជាខាងក្នុង ជាអជ្ឈត្តារម្មណៈ ចំណែកសតិ បវិចយៈ ឧបេក្ខា ដែលជាលោកុត្តរ ជាពហិទ្ធារម្មណៈ ព្រោះហេតុនោះ កុំបីប្រកបសតិ បវិចយៈ និងឧបេក្ខាទាំងនោះថា ជាលោកុត្តរ បណ្ឌិតកាលពោលថា សូម្បីសេចក្ដីព្យាយាមដែលកើតឡើង ដោយការប្រកបការចង្ក្រម ជាលោកិយ ក៏មិនធ្ងន់ចិត្ត ។ សួរថា បីតិ និងសមាធិ ដែលមិនមានវិតក្ក មិនមានវិចារ ក្នុងកាលដូចម្ដេច ជាលោកុត្តរប៉ុណ្ណោះ ឆ្លើយថា ខាងដើម បីតិសម្ពោជ្ឈង្គ រមែងបានក្នុងកាមាវចរ ។ បីតិមិនមានវិតក្ក មិនមានវិចារ រមែងមិនបាន ។ បីតិដែលមិនមានវិតក្ក មិនមានវិចារ រមែងបានក្នុងរូបាវចរ ។ តែបីតិ-សម្ពោជ្ឈង្គ រមែងមិនបាន ( ក្នុងរូបាវចរ ) ។ បីតិរមែងមិនបានដោយប្រការទាំងពួងក្នុងអរូបាវចរ ។ ក្នុងអធិការនេះ លោកបដិសេធបីតិ សូម្បីដែលបាន ព្រោះកាន់យកវត្ថុដែលមិនបាន ។ បីតិសម្ពោជ្ឈង្គ ដែលមិនមានវិតក្ក មិនមាន

វិចារនេះ ជាសភាវៈផុតហើយចាកកាមាវចរ ចាករូបាវចរ ចាកអរូបាវចរ ព្រោះហេតុនោះ ទើបលោកពោលថា ជាលោកុត្តរ ដែលកើតឡើងហើយនោះឯង ។

សមាធិសម្ពោជ្ឈង្គ ក៏រមែងបានក្នុងកាមាវចរដូចគ្នា ។ សមាធិ មិនមានវិតក្ក មិនមានវិចារ រមែងមិនបាន ។ សមាធិដែលមិនមានវិតក្ក មិនមានវិចារ រមែងបានក្នុងរូបាវចរ និងអរូបាវចរ ។ ចំណែកសមាធិសម្ពោជ្ឈង្គ រមែងមិនបាន ។ តែក្នុងអធិការនេះ លោកបដិសេធសមាធិ ដែលបានព្រោះកាន់យកវត្ថុដែលមិនបាន ។ សមាធិដែលមិនមានវិតក្ក មិនមានវិចារនេះ ជាសភាវៈផុតហើយចាកកាមាវចរ ចាករូបាវចរ ចាកអរូបាវចរ ទើបលោកពោលថា ជាលោកុត្តរដែលកើតឡើងហើយនោះឯង ។

ម្យ៉ាងទៀត បណ្ឌិតគប្បីកាន់យកលោកិយ ហើយធ្វើឲ្យជាលោកុត្តរ គប្បីកាន់យកលោកុត្តរ ហើយធ្វើឲ្យជាលោកិយក៏បាន ព្រោះថា វេលាដែលចម្រើនសតិ បរិចយៈ ឧបេក្ខា ក្នុងធម៌ខាងក្នុង ឲ្យជាលោកុត្តរក៏មាន ។ ក្នុងអធិការនេះ មានព្រះសូត្រជាឧទាហរណ៍ថា

ម្នាលអាវុសោទាំងឡាយ យើងរមែងពោលអជ្ឈត្តវិមោក្ខថា ជាទីអស់ទៅនៃឧបាទានទាំងពួង អាសវៈទាំងឡាយនេះរបស់យើងនោះ រមែងមិនដេកត្រាំយ៉ាងនេះដូច្នេះ[១] ។ ព្រោះហេតុនោះ ដោយសូត្រនេះ សតិ បរិចយៈ

---

១- ក្នុងសូត្រនេះ មានសេចក្តីប្រហែលគ្នានឹងសូត្រក្នុងសំយុត្តនិកាយ និទានវគ្គ បិ. ៣១ លេខឃ្នាប ១១៣ ។

*ឧបេក្ខា ទើបជាលោកុត្តរ ។ តែក្នុងកាលណា សេចក្តីព្យាយាមផ្លូវកាយ ដែលកើតឡើងដោយការប្រកបការដើរចង្ក្រមមិនទាន់ស្ងប់នោះឯង វិបស្សនា រមែងបន្តទៅកាន់មគ្គក្នុងកាលនោះ សេចក្តីព្យាយាមនោះ រមែងជាលោកុត្តរ ។*

*ម្យ៉ាងទៀត ព្រះថេរៈពួកណាពោលថា មិនគួរបដិសេធពោជ្ឈង្គ ដែលកើតឡើងក្នុងកសិណជ្ឈាន អានាបានជ្ឈាន និងព្រហ្មវិហារជ្ឈាន បីតិ-សម្ពោជ្ឈង្គ និងសមាធិសម្ពោជ្ឈង្គ ដែលមិនមានវិតក្ក មិនមានវិចារ ក្នុងវាទៈរបស់ព្រះថេរៈទាំងនោះ រមែងជាលោកិយ ។*

## ន័យទី ២ ចប់

*ឥឡូវនេះ កាលទ្រង់សម្តែងន័យទី ៣ ដែលប្រព្រឹត្តទៅដោយអំណាចនៃការចម្រើនពោជ្ឈង្គទាំងឡាយ ទើបព្រះមានព្រះភាគត្រាស់ថា* **សត្ត ពោជ្ឈង្គា** *ជាដើមទៀត ។ ក្នុងបទទាំងនោះ មានការអធិប្បាយបទដោយលំដាប់ដូចតទៅ*

*បទថា* **ភាវេតិ** *បានដល់ រមែងឲ្យចម្រើន គឺរមែងឲ្យកើតឡើងក្រៃលែង ក្នុងសន្តានរបស់ខ្លួនរឿយៗ ។ បទថា* **វិវេកនិស្សិតំ** *បានដល់ ដែលអាស្រ័យវិវេក ។ បទថា* **វិវេកោ** *បានដល់ ការស្ងាត់ ។ វិវេកនេះមាន ៥ យ៉ាង គឺតទង្គវិវេក ១ វិក្ខម្ភនវិវេក ១ សមុច្ឆេទវិវេក ១ បដិ-បស្សទ្ធិវិវេក ១ និស្សរណវិវេក ១ ។ បណ្តាវិវេកទាំងនោះ វិបស្សនាឈ្មោះថា* **តទង្គវិវេក** ។ *សមាបត្តិ ៨ ឈ្មោះថា* **វិក្ខម្ភនវិវេក** ។ *មគ្គ*

ឈ្មោះថា **សមុច្ឆេទវិវេក** ។ ផល ឈ្មោះថា **បដិបស្សទ្ធិវិវេក** ។ ព្រះនិព្វាន ដែលលះនូវនិមិត្តទាំងពួង ឈ្មោះថា **និស្សរណវិវេក** ។ ក្នុងបទថា **វិវេក-និស្សិតំ** គឺដែលអាស្រ័យនូវវិវេក ៥ ប្រការនេះ បណ្ឌិតគប្បីជ្រាបសេចក្តីនេះថា ព្រះយោគីរមែងចម្រើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវតទង្គ-វិវេក អាស្រ័យនូវសមុច្ឆេទវិវេក អាស្រ័យនូវនិស្សរណវិវេក ដោយប្រការដូច្នេះ ។ ពិតហើយ ព្រះយោគីនេះ ប្រកបរឿយៗ ដោយការប្រកបក្នុងការចម្រើនសតិសម្ពោជ្ឈង្គ ក្នុងខណៈនៃវិបស្សនា រមែងចម្រើនសតិ-សម្ពោជ្ឈង្គ ដែលអាស្រ័យតទង្គវិវេកដោយកិច្ច អាស្រ័យនិស្សរណវិវេកដោយអធ្យាស្រ័យ តែក្នុងកាលនៃមគ្គ រមែងចម្រើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យសមុច្ឆេទវិវេកដោយកិច្ច អាស្រ័យនិស្សរណវិវេកដោយអារម្មណ៍ ។

អាចារ្យមួយពួកពោលថា អាស្រ័យវិវេកទាំង ៥ យ៉ាងក៏មាន ។ ពិតហើយ អាចារ្យទាំងនោះ លើកពោជ្ឈង្គទាំងឡាយឡើង ក្នុងខណៈដែលវិបស្សនា មគ្គ និងផល មានកម្លាំងតែម្យ៉ាង ក៏មិនមែន ពួកលោកគង់លើកឡើងក្នុងកសិណជ្ឈាន អានាបានជ្ឈាន អសុភជ្ឈាន និងព្រហ្មវិហារជ្ឈាន ដែលជាបាទនៃវិបស្សនា ។ ម្យ៉ាងទៀត ព្រះអដ្ឋកថាចារ្យទាំងឡាយ ក៏មិនបដិសេធ ព្រោះហេតុនោះ តាមមតិរបស់អាចារ្យទាំងនោះ ព្រះយោគីរមែងចម្រើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យវិក្ខម្ភនវិវេកដោយកិច្ច ក្នុងខណៈដែលឈានទាំងនោះ ប្រព្រឹត្តទៅនោះឯង ។ ម្យ៉ាងទៀត ក្នុងខណៈនៃវិបស្សនា លោកពោលថា ចម្រើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យ

និស្សរណវិវេកដោយអធ្យាស្រ័យ យ៉ាងណា សូម្បីនឹងពោលថា ចម្រើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យបដិបស្សទ្ធិវិវេកដូច្នេះ ក៏គួរ ។ ក្នុងបទថា **វិរាគនិស្សិតំ** គឺអាស្រ័យនូវការប្រាសចាកតម្រេកជាដើម ន័យនេះដូចគ្នា ។

ពិតហើយ វិរាគៈជាដើមក៏មានវិវេកជាអត្ថនោះឯង ។ ម្យ៉ាងទៀត ក្នុងវោស្សគ្គៈ គឺការលះ ឬការដេក មានត្រឹម ២ យ៉ាង គឺបរិច្ចាគវោស្សគ្គៈ និងបក្ខន្ទនវោស្សគ្គៈ ។ ក្នុង ២ វោស្សគ្គៈនោះ ការលះកិលេសដោយអំណាចនៃតទង្គវិវេក ក្នុងខណៈនៃវិបស្សនា និងដោយអំណាចនៃសមុច្ឆេទវិវេកក្នុងខណៈនៃមគ្គ ឈ្មោះថា **បរិច្ចាគវោស្សគ្គ** ។ ការស្ទុះទៅកាន់ព្រះនិព្វានដោយការបង្អោនទៅកាន់ព្រះនិព្វាននោះ ក្នុងខណៈនៃវិបស្សនា តែក្នុងខណៈនៃមគ្គ ការស្ទុះទៅកាន់ព្រះនិព្វាន ដោយការធ្វើឲ្យជាអារម្មណ៍ ឈ្មោះថា **បក្ខន្ទនវោស្សគ្គ** ។ ទាំងពីរវោស្សគ្គៈនោះ រមែងគួរក្នុងន័យអធិប្បាយលោកិយ និងលោកុត្តរលាយឡំគ្នានេះ ។ ពិតហើយ សតិសម្ពោជ្ឈង្គនេះរមែងលះកិលេសទាំងឡាយ ដោយប្រការតាមដែលពោលហើយផង រមែងស្ទុះទៅកាន់និព្វានផង ដូច្នេះ ។

បទថា **វោស្សគ្គបរិណាមឹ** បានដល់ ដែលបង្អោនទៅ និងបង្អោនទៅហើយ ដើម្បីការលះបង់តាមពាក្យទាំងអស់នេះ មានពាក្យអធិប្បាយថា ដល់ទីបំផុត នឹងដល់ទីបំផុតហើយ ។ ពិតហើយ សតិសម្ពោជ្ឈង្គ រមែងសម្រេចផលដើម្បីការលះ ដែលមានការលះកិលេស និងដើម្បីការលះបង់ ដែលមានការស្ទុះទៅកាន់ព្រះនិព្វាន យ៉ាងណា សតិសម្ពោជ្ឈង្គនោះ រមែងដល់នូវទីបំផុតជុំវិញ យ៉ាងណា ភិក្ខុដែលប្រកបរឿយៗ ក្នុងការចម្រើនសម្ពោជ្ឈង្គនេះ រមែងញ៉ាំងសតិសម្ពោជ្ឈង្គនោះឲ្យចម្រើនក៏យ៉ាងនោះ ។ ក្នុងពោជ្ឈង្គដ៏សេស ក៏ន័យនេះឯង ។ ក្នុងន័យនេះ ព្រះមានព្រះភាគក៏ត្រាស់ពោជ្ឈង្គទាំងឡាយដែលជាលោកិយ និងលោកុត្តរលាយឡំគ្នា ។ល។

## អដ្ឋកថាសុត្តន្តភាជនីយ ចប់

# អភិធម្មបិដក

## អភិធម្មភាជនីយ

[ ២៩៩ ] ពោជ្ឈង្គ ៧ គឺសតិសម្ពោជ្ឈង្គ ១ ។បេ។ ឧបេក្ខា-សម្ពោជ្ឈង្គ ១ ។ បណ្តាធម៌ទាំងនោះ ពោជ្ឈង្គ ៧ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដៈ ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ពោជ្ឈង្គ ៧ យ៉ាង គឺ សតិសម្ពោជ្ឈង្គ ១ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ក៏កើតមាន ។

[ ៣០០ ] បណ្តាសម្ពោជ្ឈង្គទាំងនោះ សតិសម្ពោជ្ឈង្គ តើដូចម្តេច ។ ការរឭក ការនឹកឃើញ ។បេ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សតិសម្ពោជ្ឈង្គ ។

[ ៣០១ ] បណ្តាសម្ពោជ្ឈង្គទាំងនោះ ធម្មវិចយសម្ពោជ្ឈង្គ តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណានូវធម៌ ការយល់ត្រូវ ធម្មវិចយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា ធម្មវិចយសម្ពោជ្ឈង្គ ។

[ ៣០២ ] បណ្តាសម្ពោជ្ឈង្គទាំងនោះ វីរិយសម្ពោជ្ឈង្គ តើដូចម្តេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈ វីរិយ-សម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា វីរិយ-សម្ពោជ្ឈង្គ ។

[ ៣០៣ ] បណ្តាសម្ពោជ្ឈង្គទាំងនោះ បីតិសម្ពោជ្ឈង្គ តើដូចម្តេច ។ សេចក្តីឆ្អែតចិត្ត សេចក្តីរីករាយ សេចក្តីសប្បាយ សេចក្តីស្រួល ការស្រស់ស្រាយ ការញញឹមញញែម អំណរ ការអណ្តែតអណ្តូង សេចក្តីត្រេកអរនៃចិត្ត បីតិសម្ពោជ្ឈង្គណា នេះហៅថា បីតិសម្ពោជ្ឈង្គ ។

[ ៣០៤ ] បណ្តាសម្ពោជ្ឈង្គទាំងនោះ បស្សទ្ធិសម្ពោជ្ឈង្គ តើដូចម្តេច ។ សេចក្តីស្ងប់ សេចក្តីរម្ងាប់ ការស្ងប់ ការរម្ងាប់ ភាពនៃការស្ងប់រម្ងាប់ នៃវេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ បស្សទ្ធិសម្ពោជ្ឈង្គណា នេះហៅថា បស្សទ្ធិសម្ពោជ្ឈង្គ ។

[ ៣០៥ ] បណ្តាសម្ពោជ្ឈង្គទាំងនោះ សមាធិសម្ពោជ្ឈង្គ តើដូចម្តេច ។ ការតាំងនៅនៃចិត្ត ។បេ។ ការតម្កល់ចិត្តដោយប្រពៃ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សមាធិសម្ពោជ្ឈង្គ ។

[ ៣០៦ ] បណ្តាសម្ពោជ្ឈង្គទាំងនោះ ឧបេក្ខាសម្ពោជ្ឈង្គ តើដូចម្តេច ។ ការរំពឹងឃើញ អាការរំពឹងឃើញ ការរំពឹងឃើញជាក់ ភាពនៃចិត្តតាំងនៅជាកណ្តាល ឧបេក្ខាសម្ពោជ្ឈង្គណា នេះហៅថា ឧបេក្ខាសម្ពោជ្ឈង្គ ។

ធម៌ទាំងនេះ ហៅថា ពោជ្ឈង្គ ៧ យ៉ាង ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្ពោជ្ឈង្គទាំង ៧ ។

[ ៣០៧ ] ពោជ្ឈង្គ ៧ យ៉ាង គឺសតិសម្ពោជ្ឈង្គ ១ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ បណ្តាសម្ពោជ្ឈង្គទាំងនោះ សតិសម្ពោជ្ឈង្គ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិក-

ធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដៈ ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ការរឭក ការនឹកឃើញ ។បេ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សតិសម្ពោជ្ឈង្គ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិសម្ពោជ្ឈង្គ ។បេ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយធម្មវិចយសម្ពោជ្ឈង្គ ។បេ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយវីរិយសម្ពោជ្ឈង្គ ។បេ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយបីតិ-សម្ពោជ្ឈង្គ ។បេ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយបស្សទ្ធិ-សម្ពោជ្ឈង្គ ។បេ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសមាធិ-សម្ពោជ្ឈង្គ ។ បណ្ដាសម្ពោជ្ឈង្គទាំងនោះ ឧបេក្ខាសម្ពោជ្ឈង្គ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យា-និកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដៈ ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ការរំពឹងឃើញ អាការរំពឹងឃើញ ការរំពឹងឃើញជាក់ ភាពនៃចិត្តតាំងនៅជាកណ្ដាល ឧបេក្ខាសម្ពោជ្ឈង្គណា នេះហៅថា ឧបេក្ខាសម្ពោជ្ឈង្គ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឧបេក្ខាសម្ពោជ្ឈង្គ ។

[ ៣០៨ ] ពោជ្ឈង្គ ៧ យ៉ាង គឺសតិសម្ពោជ្ឈង្គ ១ ។បេ។ ឧបេក្ខា-

សម្ពោជ្ឈង្គ ១ ។ បណ្ដាធម៌ទាំងនោះ ពោជ្ឈង្គ ៧ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដៈ ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចម្រើនហើយ ក្នុងសម័យនោះ ពោជ្ឈង្គ ៧ គឺសតិសម្ពោជ្ឈង្គ ១ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ ១ ក៏កើតមាន ។ បណ្ដាសម្ពោជ្ឈង្គទាំងឡាយនោះ សតិសម្ពោជ្ឈង្គ តើដូចម្ដេច ។ ការរឭក ការនឹកឃើញ ។បេ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សតិសម្ពោជ្ឈង្គ ។បេ។ បណ្ដាសម្ពោជ្ឈង្គទាំងនោះ ឧបេក្ខាសម្ពោជ្ឈង្គ តើដូចម្ដេច ។ ការរំពឹងឃើញ អាការរំពឹងឃើញ ការរំពឹងឃើញជាក់ ភាពនៃចិត្តតាំងនៅជាកណ្ដាល ឧបេក្ខា-សម្ពោជ្ឈង្គណា នេះហៅថា ឧបេក្ខាសម្ពោជ្ឈង្គ ។ ធម៌ទាំងនេះ ហៅថា ពោជ្ឈង្គ ៧ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្ពោជ្ឈង្គ ៧ ។

[ ៣០៩ ] ពោជ្ឈង្គ ៧ យ៉ាង គឺសតិសម្ពោជ្ឈង្គ ១ ។បេ។ ឧបេក្ខា-សម្ពោជ្ឈង្គ ១ ។ បណ្ដាសម្ពោជ្ឈង្គទាំងនោះ សតិសម្ពោជ្ឈង្គ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌

ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដៈ ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះ ជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចម្រើនហើយ ក្នុងសម័យនោះ ការរឭក ការនឹកឃើញ ។បេ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សតិ-សម្ពោជ្ឈង្គ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិសម្ពោជ្ឈង្គ ។បេ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយធម្មវិចយសម្ពោជ្ឈង្គ ។បេ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយវីរិយសម្ពោជ្ឈង្គ ។បេ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយបីតិសម្ពោជ្ឈង្គ ។បេ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយបស្សទ្ធិសម្ពោជ្ឈង្គ ។បេ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសមាធិសម្ពោជ្ឈង្គ ។ បណ្ដាសម្ពោជ្ឈង្គទាំងនោះ ឧបេក្ខាសម្ពោជ្ឈង្គ តើដូចម្ដេច ។ ក្នុងសម័យណា

កិច្ចក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្តៈ ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះ ជាកុសល កិច្ចស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចម្រើនហើយ ក្នុងសម័យនោះ ការរំពឹងឃើញ អាការរំពឹងឃើញ ការរំពឹងឃើញជាក់ ភាពនៃចិត្តតាំងនៅជាកណ្តាល ឧបេក្ខាសម្ពោជ្ឈង្គណា នេះហៅថា ឧបេក្ខាសម្ពោជ្ឈង្គ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឧបេក្ខាសម្ពោជ្ឈង្គ ។

**អភិធម្មភាជនីយ ចប់**

# អដ្ឋកថា

## អភិធម្មភាជនីយ

[ ២៩៩-៣០៩ ] ក្នុងអភិធម្មភាជនីយ មាន ២ ន័យ ដោយអំណាចនៃការសួរឆ្លើយ ពោជ្ឈង្គទាំង ៧ ដោយរួមគ្នា និងដោយអំណាចនៃការសួរឆ្លើយ ពោជ្ឈង្គទាំង ៧ ដោយបែកគ្នា ។ គប្បីជ្រាបអត្ថវណ្ណនានៃពោជ្ឈង្គទាំងនោះ ដោយន័យដែលខ្ញុំពោលហើយខាងដើមនោះឯង ។ ចំណែកក្នុងនិទ្ទេសនៃឧបេក្ខាសម្ពោជ្ឈង្គ ឈ្មោះថា **ឧបេក្ខា** ដោយអំណាចនៃការព្រងើយ ។ អាការនៃការព្រងើយ ឈ្មោះថា **ឧបេក្ខនា** ។ ឈ្មោះថា **ឧបេក្ខា** ព្រោះអត្ថថា រមែងសម្លឹង រមែងមិនចោទសួរនូវធម៌ទាំងឡាយ ដែលកំពុងប្រព្រឹត្តទៅដោយល្អ ដែលគួរដល់ការសម្លឹង ។ ឈ្មោះថា **ឧបេក្ខនា** ព្រោះអត្ថថា ញុំាងបុគ្គលឲ្យចូលទៅកាន់ភាពព្រងើយ ។ កិរិយាដែលព្រងើយដ៏ក្រៃលែង ដោយកិរិយាដែលព្រងើយជាលោកិយ ដែលដល់នូវភាពជាពោជ្ឈង្គ ឈ្មោះថា **អជ្ឈុបេក្ខនា** ។ ភាវៈនៃភាពជាកណ្តាល ដោយការដល់នូវសេចក្តីព្យាយាម ឈ្មោះថា **មជ្ឈត្តតា** លោកពោលថា **មជ្ឈត្តតា ចិត្តស្ស** ក៏ដើម្បីសម្តែងថា ភាពជាកណ្តាលនោះ ជារបស់ចិត្ត មិនមែនរបស់សត្វ ដូច្នេះ ។ នេះជាកិច្ចពណ៌នាតាមលំដាប់ ក្នុងអភិធម្មភាជនីយនេះ ។

បណ្ឌិតគប្បីរាប់ន័យក្នុងអភិធម្មភាជនីយនោះ ព្រោះថា អភិធម្មភាជនីយនេះ លោកចែកន័យជា ៤០០០ ន័យ គឺក្នុងមគ្គមួយមាន ១០០០ ន័យ ក្នុងការសាកសួរ និងការឆ្លើយ ពោជ្ឈង្គទាំង ៧ រួមគ្នា ។ ក្នុងការសួរ ការឆ្លើយញែកសេចក្តីនីមួយៗ ពោជ្ឈង្គទាំង ៧ មាន ៤ ពួក ចាត់ជា ២ ម៉ឺន ៨

*ពាន់ន័យ គឺដោយអំណាចពោដ្ឋវគ្គនីមួយៗ ៤០០០ ន័យ ២៨០០០ ន័យទាំងនោះ រួមជាមួយ ៤០០០ ន័យខាងដើម ៣ ម៉ឺន ២ ពាន់ន័យ ព្រោះហេតុនោះ ក្នុងអភិធម្មភាជនីយន័យទាំងអស់ ចែកជា ៣២០០០ ន័យ ជាកុសលនោះឯង ។ តែព្រោះពោជ្ឈង្គទាំងឡាយ រមែងបានក្នុងខណៈនៃផលនិងសាមញ្ញផល រមែងមានហេតុជាកុសល ព្រោះហេតុនោះ ដើម្បីសម្តែងពោជ្ឈង្គក្នុងផលទាំងនោះ ទើបទ្រង់បន្ថែមវិបាកន័យដោយបែបផែនដែលជាខាងដើម ក្នុងកុសលនិទ្ទេសនោះឯង ។ ន័យរបស់វិបាកនោះ មាន ២ យ៉ាង ដោយអំណាចការសួរ និងការឆ្លើយរួមគ្នា និងដោយអំណាចនៃការសួរ និងការឆ្លើយបែកគ្នា ។ ពាក្យដ៏សេស ក្នុងអភិធម្មភាជនីយនេះ គប្បីជ្រាបដោយន័យដែលពោលហើយខាងដើមនោះឯង ។ ចំណែកក្នុងវិបាកន័យ បណ្ឌិតគប្បីគុណនឹង ៣ ដោយកុសល ដូច្នេះ ៕*

## អដ្ឋកថាអភិធម្មភាជនីយ ចប់

# អភិធម្មបិដក

## បញ្ហាបុច្ឆកៈ

[ ៣១០ ] ពោជ្ឈង្គ ៧ គឺសតិសម្ពោជ្ឈង្គ ១ ធម្មវិចយសម្ពោជ្ឈង្គ ១ វីរិយសម្ពោជ្ឈង្គ ១ បីតិសម្ពោជ្ឈង្គ ១ បស្សទ្ធិសម្ពោជ្ឈង្គ ១ សមាធិសម្ពោជ្ឈង្គ ១ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ បណ្ដាសម្ពោជ្ឈង្គទាំង ៧ ពោជ្ឈង្គជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។បេ។ ជាសរណៈប៉ុន្មាន ជាអរណៈប៉ុន្មាន ។

[ ៣១១ ] ពោជ្ឈង្គ ៧ ជាកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។ បីតិសម្ពោជ្ឈង្គ ប្រកបដោយសុខវេទនា ពោជ្ឈង្គ ៦ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។ ពោជ្ឈង្គ ៧ ជាវិបាកក៏មាន មានវិបាកធម៌ជាប្រក្រតី មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ជាធម៌មិនសៅហ្មងទាំងមិនគួរដល់សេចក្ដីសៅហ្មងក៏មាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារក៏មាន មិនមានវិតក្កៈ មានត្រឹមតែវិចារក៏មាន មិនមានវិតក្កៈ មិនមានវិចារក៏មាន ។ បីតិសម្ពោជ្ឈង្គ មិនប្រកបដោយបីតិ តែប្រកបដោយសុខ មិនប្រកបដោយឧបេក្ខា ពោជ្ឈង្គ ៦ ប្រកបដោយបីតិក៏មាន ប្រកបដោយសុខក៏មាន ប្រកបដោយឧបេក្ខាក៏មាន ។ ពោជ្ឈង្គ ៧ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា មានហេតុ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា មិនដល់នូវការសន្សំ ( នូវកិលេសវដ្ដៈ ) ក៏មាន មិនដល់នូវការសន្សំ ( នូវកិលេសវដ្ដៈ ) ទាំងមិនដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដៈ )

ក៏មាន ជារបស់សេក្ខៈក៏មាន ជារបស់អសេក្ខៈ មានប្រមាណមិនបាន មានអារម្មណ៍ប្រមាណមិនបាន ជាសភាពឧត្តមក៏មាន មានសភាពត្រូវ និងទៀងក៏មាន មិនទៀង មិនមានមគ្គជាអារម្មណ៍ក៏មាន មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន មិនគួរពោលថា មានមគ្គជាហេតុផង ថាមានមគ្គជាអធិបតីផងក៏មាន កើតឡើងហើយក៏មាន មិនទាន់កើតឡើងក៏មាន បម្រុងនឹងកើតឡើងក៏មាន ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្ន តែមិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថាមានអារម្មណ៍ជាអនាគតផង ថាមានអារម្មណ៍ជាបច្ចុប្បន្នផងក៏មាន ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ទាំងខាងក្នុង ទាំងខាងក្រៅ មានអារម្មណ៍ជាខាងក្រៅ មិនប្រកបដោយការឃើញទាំងមិនប្រកបដោយការប៉ះពាល់ក៏មាន ។

[ ៣១២ ] ធម្មវិចយសម្ពោជ្ឈង្គ ជាហេតុ ពោជ្ឈង្គ ៦ មិនមែនហេតុ ។ ពោជ្ឈង្គ ៧ ប្រព្រឹត្តទៅជាមួយនឹងហេតុ ទាំងប្រកបដោយហេតុ ។ ធម្មវិចយ-សម្ពោជ្ឈង្គ ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ ពោជ្ឈង្គ ៦ មិនគួរពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុទេ គឺគ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនជាហេតុ ។ ធម្មវិចយសម្ពោជ្ឈង្គ ជាហេតុ ទាំងប្រកបដោយហេតុ ពោជ្ឈង្គ ៦ មិនគួរពោលថា ជាហេតុ ទាំងប្រកបដោយហេតុឡើយ គឺគ្រាន់តែប្រកបដោយហេតុ តែមិនមែនជាហេតុ ។ ពោជ្ឈង្គ ៦ មិនមែនហេតុ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ ធម្មវិចយសម្ពោជ្ឈង្គ មិនគួរពោលថា មិនមែនហេតុ គ្រាន់តែប្រព្រឹត្តទៅ ជាមួយនឹងហេតុផង ថា

មិនមែនហេតុ ទាំងឥតហេតុ ដូច្នេះផងទេ ។

[ ៣១៣ ] ពោជ្ឈង្គ ៧ ប្រកបដោយបច្ច័យ ត្រូវបច្ច័យតាក់តែង មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ មិនមានរូប ជាលោកុត្តរ ដែលគប្បីដឹងដោយវិញ្ញាណណាមួយ ដែលមិនគប្បីដឹងដោយវិញ្ញាណណាមួយ ។ មិនមែនអាសវៈ ទាំងមិនមានអាសវៈ ប្រាសចាកអាសវៈ មិនគួរពោលថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ថាប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈផងឡើយ មិនគួរពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈផង ថាប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផងទេ គឺប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ។ មិនមែនសញ្ញោជនៈ ។បេ។ មិនមែនគន្ថៈ ។បេ។ មិនមែនឱឃៈ ។បេ។ មិនមែនយោគៈ ។បេ។ មិនមែននីវរណៈ ។បេ។ មិនមែនបរាមាស ។បេ។ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ មិនមែនចិត្ត ជាចេតសិក ប្រកបដោយចិត្ត ប្រឡំដោយចិត្ត តាំងឡើងអំពីចិត្ត កើតជាមួយនឹងចិត្ត ប្រព្រឹត្តទៅតាមចិត្ត ប្រឡំ ទាំងតាំងឡើងអំពីចិត្ត ប្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត ប្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តតាមនូវចិត្ត ជាខាងក្រៅ មិនមែនឧបាទា មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យកហើយ ។ មិនមែនឧបាទាន ។បេ។ មិនមែនកិលេស ។បេ។

[ ៣១៤ ] ពោជ្ឈង្គ ៧ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា មានហេតុ មិនគួរលះដោយទស្សនៈ មានហេតុ មិនគួរលះដោយភាវនា

ប្រកបដោយវិតក្កក៏មាន មិនមានវិតក្កក៏មាន ប្រកបដោយវិចារក៏មាន មិនមានវិចារក៏មាន ។ បីតិសម្ពោជ្ឈង្គ មិនមានបីតិ ពោជ្ឈង្គ ៦ ប្រកបដោយបីតិក៏មាន មិនមានបីតិក៏មាន ។ បីតិសម្ពោជ្ឈង្គ មិនប្រកបដោយបីតិ ពោជ្ឈង្គ ៦ ប្រកបដោយបីតិក៏មាន មិនប្រកបដោយបីតិក៏មាន ។ បីតិ-សម្ពោជ្ឈង្គ ប្រកបដោយសុខ ពោជ្ឈង្គ ៦ ប្រកបដោយសុខក៏មាន មិនប្រកបដោយសុខក៏មាន ។ បីតិសម្ពោជ្ឈង្គ មិនប្រកបដោយឧបេក្ខា ពោជ្ឈង្គ ៦ ប្រកបដោយឧបេក្ខាក៏មាន មិនប្រកបដោយឧបេក្ខាក៏មាន ។ ពោជ្ឈង្គ ៧ មិនមែនកាមាវចរ មិនមែនរូបាវចរ មិនមែនអរូបាវចរ ជាអបរិយាបន្ន ជានិយ្យានិកៈក៏មាន ជាអនិយ្យានិកៈក៏មាន ជានិយតៈក៏មាន ជាអនិយតៈ ជាអនុត្តរៈ ជាអរណៈក៏មាន ។

បញ្ហាបុច្ឆកៈ ចប់

ពោជ្ឈង្គវិភង្គ ចប់

# អដ្ឋកថា

## បញ្ហាបុច្ឆកៈ

[ ៣១០-៣១៤ ] ក្នុងបញ្ហាបុច្ឆកៈ បណ្ឌិតគប្បីជ្រាបភាពដែលពោជ្ឈង្គទាំងឡាយ ដែលជាកុសលជាដើម ដោយទំនងនៃព្រះបាលីនោះឯង ។ ឯក្នុងអារម្មណត្តិកៈទាំងឡាយ ពោជ្ឈង្គទាំងអស់នេះ ជាអប្បមាណារម្មណៈប៉ុណ្ណោះ ព្រោះប្រារព្ធព្រះនិព្វានដែលជាអប្បមាណៈ ប្រព្រឹត្តទៅ មិនជាមគ្គារម្មណៈ ។ តែក្នុងបញ្ហាបុច្ឆកៈនេះ ពោជ្ឈង្គដែលជាកុសល ជាមគ្គហេតុកៈ ដោយអំណាចនៃសហជាតហេតុ ។ ពោជ្ឈង្គទាំងនោះ ក្នុងវេលាចម្រើនមគ្គ ធ្វើវិរិយៈ ឬវីមំសាឲ្យជាធំ ជាមគ្គាធិបតី ក្នុងការចម្រើនមគ្គដែលមានឆន្ទៈ ឬចិត្តជាធំ ពោលមិនបានថា ជាមគ្គាធិបតីក្នុងខណៈនៃផលក៏ពោលមិនបានដូចគ្នា ។ ក្នុងអតីតារម្មណៈជាដើម ក៏ពោលមិនបានដោយភាពជាអារម្មណ៍ មិនបានត្រឹមតែមួយ តែឈ្មោះថា ជាពហិទ្ធារម្មណៈ ព្រោះព្រះនិព្វានជាធម៌ខាងក្រៅ ព្រោះហេតុនោះ ក្នុងបញ្ហាបុច្ឆកៈនេះ ទើបព្រះមានព្រះភាគត្រាស់ពោជ្ឈង្គទាំងឡាយជាលោកុត្តរ ដែលកើតឡើងហើយនោះឯងដោយប្រការដូច្នេះ ។ ពិតហើយ ពោជ្ឈង្គដែលជាលោកិយ ព្រះសម្មាសម្ពុទ្ធ

ត្រាស់ក្នុងន័យទីមួយនៃសុត្តន្តភាជនីយនោះឯង ក្នុងន័យទី ២ និងទី ៣ ត្រាស់ពោជ្ឈង្គដែលជាលោកិយ និងលោកុត្តរលាយឡំគ្នា ។ ក្នុងន័យទី ៤ នៃអភិធម្មភាជនីយក្តី និងក្នុងបញ្ហាបុច្ឆកៈក្តី ត្រាស់ពោជ្ឈង្គជាលោកុត្តរប៉ុណ្ណោះ ។ ពោជ្ឈង្គវិភង្គនេះ ទ្រង់នាំចេញចែកសម្តែងហើយ ដោយបរិវដ្តៈ ៣ ដូចពណ៌នាមក ដូច្នេះឯង ៕

**អដ្ឋកថាបញ្ហាបុច្ឆកៈ ចប់**

**អដ្ឋកថាពោជ្ឈង្គវិភង្គ ចប់**

# អភិធម្មបិដក

## មគ្គវិភង្គ

[ ៣១៥ ] អរិយមគ្គ មានអង្គ ៨ ។ មគ្គ មានអង្គ ៨ គឺអ្វីខ្លះ ។ គឺ សម្មាទិដ្ឋិ សម្មាសង្កប្ប សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ។

[ ៣១៦ ] បណ្តាអរិយមគ្គទាំងនោះ សម្មាទិដ្ឋិ តើដូចម្តេច ។ ការដឹងក្នុងកងទុក្ខ ការដឹងក្នុងទុក្ខសមុទ័យ ការដឹងក្នុងទុក្ខនិរោធ ការដឹងក្នុងទុក្ខ-និរោធគាមិនីបដិបទា នេះហៅថា សម្មាទិដ្ឋិ ។

[ ៣១៧ ] បណ្តាអរិយមគ្គទាំងនោះ សម្មាសង្កប្ប តើដូចម្តេច ។ ការត្រិះរិះក្នុងការចេញចាកកាម ការត្រិះរិះក្នុងការមិនព្យាបាទ ការត្រិះរិះក្នុងការមិនបៀតបៀន នេះហៅថា សម្មាសង្កប្ប ។

[ ៣១៨ ] បណ្តាអរិយមគ្គទាំងនោះ សម្មាវាចា តើដូចម្តេច ។ ចេតនាជាហេតុវៀរចាកមុសាវាទ ចេតនាជាហេតុវៀរចាកបិសុណាវាចា ចេតនាជាហេតុវៀរចាកផរុសវាចា ចេតនាជាហេតុវៀរចាកសម្ផប្បលាបៈ នេះហៅថា សម្មាវាចា ។

[ ៣១៩ ] បណ្តាអរិយមគ្គទាំងនោះ សម្មាកម្មន្តៈ តើដូចម្តេច ។ ចេតនាជាហេតុវៀរចាកបាណាតិបាត ចេតនាជាហេតុវៀរចាកអទិន្នាទាន ចេតនាជាហេតុវៀរចាកកាមេសុមិច្ឆាចារ នេះហៅថា សម្មាកម្មន្តៈ ។

[ ៣២០ ] បណ្តាអរិយមគ្គទាំងនោះ សម្មាអាជីវៈ តើដូចម្តេច ។

អរិយសាវកក្នុងសាសនានេះ លះបង់ការចិញ្ចឹមជីវិតខុស សម្រេចជីវិត ដោយការចិញ្ចឹមជីវិតត្រូវ នេះហៅថា សម្មាអាជីវៈ ។

[ ៣២១ ] បណ្តាអរិយមគ្គទាំងនោះ សម្មាវាយាមៈ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈ ( សេចក្តីប្រាថ្នា ) ឲ្យកើតឡើង សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ញុំាងឆន្ទៈឲ្យកើតឡើង សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ញុំាងឆន្ទៈឲ្យកើតឡើង សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង ញុំាងឆន្ទៈឲ្យកើតឡើង សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលកើតឡើងហើយ ឲ្យស្ថិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាល ធំទូលាយ ចម្រើន ពេញលេញ នេះហៅថា សម្មាវាយាមៈ ។

[ ៣២២ ] បណ្តាអរិយមគ្គទាំងនោះ សម្មាសតិ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ពិចារណានូវវេទនាក្នុងវេទនាទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ពិចារណានូវចិត្តក្នុងចិត្ត មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុង

លោក ពិចារណានូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក នេះហៅថា សម្មាសតិ ។

[ ៣២៣ ] បណ្តាអរិយមគ្គទាំងនោះ សម្មាសមាធិ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈានប្រកបដោយវិតក្កៈ ប្រកបដោយវិចារ មានបីតិ និងសុខ ដែលកើតអំពីវិវេក ព្រោះរម្ងាប់នូវវិតក្កៈ និងវិចារ ចូលកាន់ទុតិយជ្ឈាន ជាទីផូរផង់ក្នុងសន្តាន មានភាពនៃចិត្តដ៏ប្រសើរ មិនមានវិតក្កៈ មិនមានវិចារ មានបីតិ និងសុខ ដែលកើតអំពីសមាធិ ព្រោះការវិនាសនៃបីតិ ជាបុគ្គលព្រងើយផង មានសតិ និងសម្បជញ្ញៈផង រមែងទទួលនូវសុខដោយនាមកាយផង ចូលកាន់តតិយជ្ឈាន ដែលព្រះអរិយៈទាំងឡាយតែងសរសើរថា បុគ្គលដែលបានតតិយជ្ឈាន តែងមានចិត្តព្រងើយ ជាអ្នកមានស្មារតី នៅជាសុខ ព្រោះការលះបង់សុខផង ព្រោះការលះបង់ទុក្ខផង ព្រោះការវិនាសទៅនៃសោមនស្ស និងទោមនស្សក្នុងកាលមុនផង លោកក៏ចូលកាន់ចតុត្ថជ្ឈាន ដែលឥតទុក្ខឥតសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា នេះហៅថា សម្មា-សមាធិ ។

[ ៣២៤ ] អរិយមគ្គមានអង្គ ៨ ។ អរិយមគ្គមានអង្គ ៨ គឺអ្វីខ្លះ ។ គឺសម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មា-វាយាមៈ សម្មាសតិ សម្មាសមាធិ ។

[ ៣២៥ ] បណ្តាអរិយមគ្គទាំងនោះ សម្មាទិដ្ឋិ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ចម្រើនសម្មាទិដ្ឋិ ដែលអាស្រ័យវិវេក អាស្រ័យការប្រាសចាកតម្រេក អាស្រ័យនិរោធ ឈមទៅក្នុងការលះបង់ ។បេ។ ចម្រើនសម្មាសង្កប្ប ។បេ។ ចម្រើនសម្មាវាចា ។បេ។ ចម្រើនសម្មាកម្មន្តៈ ។បេ។ ចម្រើនសម្មា-អាជីវៈ ។បេ។ ចម្រើនសម្មាវាយាមៈ ។បេ។ ចម្រើនសម្មាសតិ ។បេ។ ចម្រើនសម្មាសមាធិ ដែលអាស្រ័យវិវេក អាស្រ័យការប្រាសចាកតម្រេក អាស្រ័យនិរោធ ឈមទៅក្នុងការលះបង់ ។

សុត្តន្តភាជនីយ ចប់

# អដ្ឋកថា

# មគ្គង្គវិភង្គ

## សុត្តន្តភាជនីយ

[ ៣១៥-៣២៥ ] ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងមគ្គវិភង្គ ដែលជាលំដាប់បន្ទាប់អំពីពោជ្ឈង្គវិភង្គនោះដូចតទៅ

ក្នុងបទទាំងពួង មានបទថា **អរិយោ អដ្ឋង្គិកោ មគ្គោ** ជាដើម បណ្ឌិតគប្បីជ្រាបដោយន័យដែលខ្ញុំពោលហើយ ក្នុងនិទ្ទេសទុក្ខនិរោធគាមិនីបដិបទា ក្នុងសច្ចវិភង្គនោះឯង ។ ក្នុងន័យទី ២ ដែលព្រះមានព្រះភាគទ្រង់ចែកសម្តែងដោយចំពោះហើយ ដោយអំណាចនៃការវនា ពាក្យទាំងពួងថា **សម្មាទិដ្ឋឹ ភាវេតិ វិវេកនិស្សិតំ** ជាដើម គប្បីជ្រាបដោយន័យដែលបានពោលហើយ ក្នុងពោជ្ឈង្គវិភង្គនោះឯង ។ សុត្តន្តភាជនីយនេះពោលដោយអំណាចរបស់ន័យទាំងពីរ ព្រះមានព្រះភាគ ក៏ត្រាស់ទាំងជាលោកិយ និងលោកុត្តរលាយឡំគ្នានោះឯង ។ល។

### អដ្ឋកថាសុត្តន្តភាជនីយ ចប់

# អភិធម្មបិដក

## អភិធម្មភាជនីយ

[ ៣២៦ ] មគ្គមានអង្គ ៨ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ បណ្តាធម៌ទាំងនោះ មគ្គមានអង្គ ៨ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដៈ ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ មគ្គមានអង្គ ៨ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិក៏កើតមាន ។

[ ៣២៧ ] បណ្តាអរិយមគ្គទាំងនោះ សម្មាទិដ្ឋិ តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការសង្កេតនូវធម៌ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាទិដ្ឋិ ។

[ ៣២៨ ] បណ្តាអរិយមគ្គទាំងនោះ សម្មាសង្កប្ប តើដូចម្តេច ។ សេចក្តីត្រិះរិះ ការរិះគិត ការនឹកក្នុក ការរំពឹង ការជញ្ជឹង ការលើកចិត្តឡើង សម្មាសង្កប្ប ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាសង្កប្ប ។

[ ៣២៩ ] បណ្តាអរិយមគ្គទាំងនោះ សម្មាវាចា តើដូចម្តេច ។ ការវៀរ ការចៀសវាង ការវៀរស្រឡះ ការងាកចេញចាកវចីទុច្ចរិត ៤ គឺការមិនសាង ការមិនធ្វើ ការមិនប្រព្រឹត្ត ការមិនល្មើសឲ្យហួសដែន ការសម្លាប់ហេតុ ( ដោយអរិយមគ្គ ) សម្មាវាចា ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាវាចា ។

[ ៣៣០ ] បណ្ដាអរិយមគ្គទាំងនោះ សម្មាកម្មន្តៈ តើដូចម្ដេច ។ ការវៀរ ការចៀសវាង ការវៀរស្រឡះ ការងាកចេញចាកកាយទុច្ចរិត ៣ គឺការមិនសាង ការមិនធ្វើ ការមិនប្រព្រឹត្ត ការមិនល្មើសឲ្យហួសដែន ការសម្លាប់ហេតុ ( ដោយអរិយមគ្គ ) សម្មាកម្មន្តៈ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាកម្មន្តៈ ។

[ ៣៣១ ] បណ្ដាអរិយមគ្គទាំងនោះ សម្មាអាជីវៈ តើដូចម្ដេច ។ ការវៀរ ការចៀសវាង ការវៀរស្រឡះ ការងាកចេញចាកមិច្ឆាអាជីវៈ គឺការមិនសាង ការមិនធ្វើ ការមិនប្រព្រឹត្ត ការមិនល្មើសឲ្យហួសដែន ការសម្លាប់ហេតុ ( ដោយអរិយមគ្គ ) សម្មាអាជីវៈ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាអាជីវៈ ។

[ ៣៣២ ] បណ្ដាអរិយមគ្គទាំងនោះ សម្មាវាយាមៈ តើដូចម្ដេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈ វិរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាវាយាមៈ ។

[ ៣៣៣ ] បណ្ដាអរិយមគ្គទាំងនោះ សម្មាសតិ តើដូចម្ដេច ។ ការរឭក ការនឹកឃើញ ។បេ។ សម្មាសតិ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាសតិ ។

[ ៣៣៤ ] បណ្ដាអរិយមគ្គទាំងនោះ សម្មាសមាធិ តើដូចម្ដេច ។ ការស្ថិតនៅនៃចិត្ត ។បេ។ សម្មាសមាធិ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាសមាធិ ។ នេះហៅថា មគ្គមានអង្គ

៨ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមគ្គមានអង្គ ៨ ។

[ ៣៣៥ ] មគ្គមានអង្គ ៥ គឺសម្មាទិដ្ឋិ សម្មាសង្កប្ប សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ។ បណ្តាធម៌ទាំងនោះ មគ្គមានអង្គ ៨ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្តៈ ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ មគ្គមានអង្គ ៥ គឺសម្មាទិដ្ឋិ សម្មាសង្កប្ប សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ក៏រមែងមាន ។ បណ្តាអរិយមគ្គទាំងនោះ សម្មាទិដ្ឋិ តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការសង្កេតនូវធម៌ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាទិដ្ឋិ ។ បណ្តាអរិយមគ្គទាំងនោះ សម្មាសង្កប្ប តើដូចម្តេច ។ សេចក្តីត្រិះរិះ ការរិះគិត ការទឹកក្នុក ។បេ។ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាសង្កប្ប ។ បណ្តាអរិយមគ្គទាំងនោះ សម្មាវាយាមៈ តើដូចម្តេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាវាយាមៈ ។ បណ្តាអរិយមគ្គទាំងនោះ សម្មាសតិ តើដូចម្តេច ។ ការរឭក ការទឹកឃើញ ។បេ។ សម្មាសតិ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាសតិ ។ បណ្តាអរិយមគ្គទាំងនោះ សម្មាសមាធិ តើដូចម្តេច ។ ការ

*ស្ថិតនៅនៃចិត្ត ។បេ។ សម្មាសមាធិ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាសមាធិ ។ នេះហៅថា មគ្គមានអង្គ ៥ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមគ្គមានអង្គ ៥ ។*

*[ ៣៣៦ ] មគ្គមានអង្គ ៥ គឺសម្មាទិដ្ឋិ សម្មាសង្កប្ប សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ។ បណ្តាអរិយមគ្គទាំងនោះ សម្មាទិដ្ឋិ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្តៈ ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការសង្កេតនូវធម៌ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាទិដ្ឋិ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្មាទិដ្ឋិ ។បេ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្មាសង្កប្ប ។បេ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្មាវាយាមៈ ។បេ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្មាសតិ ។ បណ្តាអរិយមគ្គទាំងនោះ សម្មាសមាធិ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្តៈ ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ការ*

ស្ថិតនៅនៃចិត្ត ។បេ។ សម្មាសមាធិ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាសមាធិ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្មាសមាធិ ។

[ ៣៣៧ ] មគ្គមានអង្គ ៨ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ បណ្ដាធម៌ទាំងនោះ មគ្គមានអង្គ ៨ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដៈ ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះ ជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចម្រើនហើយ ក្នុងសម័យនោះ មគ្គមានអង្គ ៨ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ក៏កើតមាន នេះហៅថា មគ្គមានអង្គ ៨ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមគ្គមានអង្គ ៨ ។

[ ៣៣៨ ] មគ្គមានអង្គ ៥ គឺសម្មាទិដ្ឋិ សម្មាសង្កប្ប សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ។ បណ្ដាធម៌ទាំងនោះ មគ្គមានអង្គ ៥ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដៈ ) ដើម្បីលះទិដ្ឋិទាំងឡាយ

ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលបឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ អវិក្ខេបៈ ក៏កើតមាន ធម៌ទាំងនេះ ជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចម្រើនហើយ ក្នុងសម័យនោះ មគ្គមានអង្គ ៥ គឺសម្មាទិដ្ឋិ សម្មាសង្កប្ប សម្មា-វាយាមៈ សម្មាសតិ សម្មាសមាធិក៏កើតមាន នេះហៅថា មគ្គមានអង្គ ៥ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមគ្គមានអង្គ ៥ ។

[ ៣៣៩ ] មគ្គមានអង្គ ៥ គឺសម្មាទិដ្ឋិ សម្មាសង្កប្ប សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ។ បណ្តាអរិយមគ្គទាំងនោះ សម្មាទិដ្ឋិ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្តៈ ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះ ជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចម្រើនហើយ ក្នុងសម័យនោះ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការសេង្កេតនូវធម៌ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់

បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាទិដ្ឋិ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្មាទិដ្ឋិ ។បេ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្មាសង្កប្ប ។បេ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្មាវាយាមៈ ។បេ។ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្មាសតិ ។ បណ្ដាអរិយមគ្គទាំងនោះ សម្មាសមាធិ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ដៈ ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះ ជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចម្រើនហើយ ក្នុងសម័យនោះ ការស្ថិតនៅនៃចិត្ត ការតាំងនៅ ការតាំងនៅស៊ប់ សេចក្ដីមិនរសេមរសាម សេចក្ដីមិនរាយមាយ ភាពនៃចិត្តមិនរវើរវាយ សមថៈ សមាធិន្ទ្រិយ សមាធិពល សម្មាសមាធិ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាសមាធិ ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្មាសមាធិ ។

**អភិធម្មភាជនីយ ចប់**

# អដ្ឋកថា

## អភិធម្មភាជនីយ

[ ៣២៦-៣៣៩ ] ក្នុងអភិធម្មភាជនីយ ព្រះមានព្រះភាគមិនត្រាស់បទថា **អរិយោ** តែត្រាស់បទថា **អដ្ឋង្គិកោ មគ្គោ** ដូច្នេះ ។ ទោះបីមិនត្រាស់ថា **អរិយ** ក្តី មគ្គមានអង្គ ៨ នេះ ក៏ជាអរិយមគ្គដោយពិត ដូចបុត្ររបស់ព្រះរាជាដែលមុទ្ធាភិសេកហើយ ដែលកើតក្នុងព្រះឧទររបស់ព្រះទេវីដែលមុទ្ធាភិសេកហើយ បុគ្គលណាម្នាក់មិនពោលថា រាជបុត្រ ក៏នៅតែជារាជបុត្រនោះឯង យ៉ាងណា សូម្បីអរិយមគ្គនេះ ព្រះមានព្រះភាគមិនបានត្រាស់ពាក្យថា **អរិយ** ក៏គប្បីជ្រាបថា ជាអរិយមគ្គដោយពិត ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងសច្ចវិភង្គនោះឯង ។

ក្នុងបញ្ចង្គិកវារ ទោះបីមិនត្រាស់ថា មគ្គមានអង្គ ៨ ក៏គប្បីជ្រាបថា មគ្គនោះ មានអង្គ ៨ ដូចគ្នា ព្រោះថា លោកុត្តរមគ្គ ឈ្មោះថា ប្រកបដោយអង្គ ៥ មិនមាន ។ នេះជាអដ្ឋកថាដែលឃើញស្មើគ្នារបស់អាចារ្យទាំងឡាយក្នុងអភិធម្មភាជនីយនេះ ។ ចំណែកអាចារ្យវិតណ្ឌវាទី ( អាចារ្យអ្នកមានប្រក្រតីពោលជំទាស់ ) ពោលថា សូម្បីលោកុត្តរមគ្គ ឈ្មោះថា ប្រកបដោយអង្គ ៨ មិនមាន តែប្រកបដោយអង្គ ៥ ប៉ុណ្ណោះ ត្រូវឆ្លើយថា ចូរនាំសូត្រមកអាង អាចារ្យវិតណ្ឌវាទីនោះ កាលមិនឃើញសូត្រដទៃពិតៗ ក៏នឹងនាំចំណែកនៃសូត្រអំពីមហាសឡាយតនសូត្រនេះ មកអាងថា សេចក្តីយល់ឃើញណា របស់បុគ្គលមានសភាពដូច្នោះ សេចក្តីយល់ឃើញនោះ

របស់បុគ្គលនោះ ឈ្មោះថា សេចក្តីយល់ឃើញត្រូវ សេចក្តីត្រិះរិះណា ... សេចក្តីព្យាយាមណា ... ការរឭកណា ... ការតាំងចិត្តនឹងណា របស់បុគ្គលមានសភាពដូច្នោះ ការតាំងចិត្តនឹងនោះ របស់បុគ្គលនោះ ឈ្មោះថា ការតាំងចិត្តនឹងត្រូវ ។ បុគ្គលនោះឯង ឈ្មោះថា មានកាយកម្ម វចីកម្ម និងអាជីវៈដ៏បរិសុទ្ធល្អ ក្នុងកាលមុនពិត ដូច្នេះ ។

លំដាប់នោះ គប្បីសួរអាចារ្យវិតណ្ឌវាទីថា ចូរនាំបទនៃសូត្របន្ទាប់មកទៀត ។ បើអាចារ្យវិតណ្ឌវាទីនាំសូត្រមកអាងបាននោះជាការល្អ បើនាំមកអាងមិនបាន ភិក្ខុគប្បីនាំមកឯងថា វាទៈរបស់អាចារ្យវិតណ្ឌវាទីនោះបែកខ្ញែកអំពីពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ដែលត្រាស់ថា អដ្ឋង្គិកមគ្គដ៏ប្រសើរនេះ របស់បុគ្គលនោះ រមែងដល់នូវការពេញបរិបូណ៌ ដោយការនាយ៉ាងនេះឯង ដូច្នេះ ។ ក្នុងលោកុត្តរមគ្គ ឈ្មោះថា ប្រកបដោយអង្គ ៥ មិនមាន មានតែប្រកបដោយអង្គ ៨ ប៉ុណ្ណោះ ។

ឯអង្គ ៣ គឺកាយកម្ម វចីកម្ម និងអាជីវៈ រមែងជាធម៌បរិសុទ្ធហើយប្រព្រឹត្តទៅក្នុងកាលមុន តែរមែងជាធម៌បរិសុទ្ធក្រៃលែង ក្នុងខណៈនៃលោកុត្តរមគ្គនោះឯង ។ សួរថា បើដូច្នោះ ពាក្យថា មគ្គប្រកបដោយអង្គ ៥ នេះ ព្រះមានព្រះភាគទ្រង់កាន់យកហើយដើម្បីប្រយោជន៍អ្វី ឆ្លើយថា ដើម្បីសម្តែងកិច្ចដ៏ក្រៃលែង ។ ពិតហើយ ក្នុងសម័យណា រមែងលះមិច្ឆាវាចា រមែងញុំាងសម្មាវាចាឲ្យបរិបូណ៌ ក្នុងសម័យនោះ សម្មាកម្មន្តៈ សម្មាអាជីវៈ ឈ្មោះថា រមែងមិនមាន ។ អង្គទាំង ៥ នេះ ជាអង្គប្រព្រឹត្តទៅនោះឯង

រមែងលះមិច្ឆាវាចា ឯសម្មាវាចា រមែងបរិបូណ៌ឯង ដោយអំណាចនៃវិរតិ ។ ក្នុងសម័យណា រមែងលះមិច្ឆាកម្មន្តៈ រមែងញ៉ាំងសម្មាកម្មន្តៈឲ្យបរិបូណ៌ ក្នុងសម័យនោះ សម្មាវាចា និងសម្មាអាជីវៈ មិនមាន ។ អង្គទាំង ៥ នេះ ជាអង្គប្រព្រឹត្តទៅនោះឯង រមែងលះមិច្ឆាកម្មន្តៈ ឯសម្មាកម្មន្តៈ រមែងបរិបូណ៌ឯង ដោយអំណាចនៃវិរតិ ។ ក្នុងសម័យណា លះមិច្ឆាអាជីវៈ រមែងញ៉ាំងសម្មាអាជីវៈឲ្យបរិបូណ៌ ក្នុងសម័យនោះ មិនមានសម្មាវាចា និងសម្មា-កម្មន្តៈ ។ អង្គទាំង ៥ នេះ ជាអង្គប្រព្រឹត្តទៅនោះឯង រមែងលះមិច្ឆាអាជីវៈ ឯសម្មាអាជីវៈ រមែងបរិបូណ៌ឯង ដោយអំណាចនៃវិរតិ ។ ដើម្បីសម្តែងអង្គជាគ្រឿងប្រព្រឹត្តទៅទាំង ៥ នេះ ជាអង្គពិសេសដោយកិច្ច ទើបព្រះមានព្រះភាគទ្រង់កាន់យក សព្វថា មគ្គមានអង្គ ៥ ដូច្នេះ ។

ពិតហើយ ក្នុងលោកុត្តរមគ្គ រមែងប្រកបដោយអង្គ ៨ ប៉ុណ្ណោះ មិនបានឈ្មោះថា ប្រកបដោយអង្គ ៥ ។ បើមានពាក្យសួរថា ពួកលោកពោលថា មគ្គរួមជាមួយសម្មាវាចាជាដើម ប្រកបដោយអង្គ ៨ សម្មាវាចា មានចេតនា ៤ សម្មាកម្មន្តៈ មានចេតនា ៣ សម្មាអាជីវៈ មានចេតនា ៧ ព្រោះហេតុនោះ ពួកលោកនឹងពោលដោះស្រាយដូចម្តេច អំពីវិរតិដែលមានចេតនាច្រើននេះ ព្រោះហេតុនោះ ទើបលោកុត្តរមគ្គ ប្រកបដោយអង្គ ៥ ប៉ុណ្ណោះ ។ ឆ្លើយថា ពួកខ្ញុំនឹងផុតបានអំពីវិរតិចេតនាច្រើន និងពោលថា លោកុត្តរមគ្គ ប្រកបដោយអង្គ ៨ នោះឯង ។ ខាងដើម គប្បីសួរបុគ្គលនោះថា លោកសួច្យគម្ពីរមហាចត្តារីសកៈឬទេ បើបុគ្គលនោះឆ្លើយថា មិន

បានសួរឡើយទេ គប្បីពោលនឹងបុគ្គលនោះថា លោកមិនជ្រាប ព្រោះមិនធ្លាប់សួរ ។ បើបុគ្គលនោះពោលថា ខ្ញុំធ្លាប់សួរ ក៏គប្បីពោលនឹងបុគ្គលនោះថា ចូរនាំសូត្រមកអាន បើបុគ្គលនោះ នាំសូត្រមកអានបាននោះជាការល្អ បើមិននាំមក ក៏គប្បីនាំមកឯងអំពីឧបរិបណ្ណាសកដូចតទៅ

ម្នាលភិក្ខុទាំងឡាយ សម្មាវាចា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតសម្តែងនូវសម្មាវាចា ថាមានពីរយ៉ាង ម្នាលភិក្ខុទាំងឡាយ សម្មាវាចា ប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យ ឲ្យផលជាឧបធិក្កិលេស ក៏មាន ម្នាលភិក្ខុទាំងឡាយ សម្មាវាចាដ៏ប្រសើរ មិនមានអាសវៈ ជាលោកុត្តរ ជាអង្គនៃមគ្គក៏មាន ។ ម្នាលភិក្ខុទាំងឡាយ សម្មាវាចា ប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យ ឲ្យផលជាឧបធិក្កិលេស តើដូចម្តេច ។ ការវៀរចាកមុសាវាទ វៀរចាកវាចាញុះញង់ វៀរចាកវាចាអាក្រក់ វៀរចាកពាក្យឥតប្រយោជន៍ ម្នាលភិក្ខុទាំងឡាយ នេះ ឈ្មោះថា សម្មាវាចា ប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យ ឲ្យផលជាឧបធិក្កិលេស ។ ម្នាលភិក្ខុទាំងឡាយ សម្មាវាចាដ៏ប្រសើរ មិនមានអាសវៈ ជាលោកុត្តរ ជាអង្គនៃមគ្គ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ការតម ចៀស គេច វៀរចាក វចីទុច្ចរិតទាំង ៤ ប្រការ របស់បុគ្គលមានចិត្តជាអរិយៈ មានចិត្តឥតអាសវៈ បរិបូណ៌ដោយអរិយមគ្គ ចម្រើននូវអរិយមគ្គ ម្នាលភិក្ខុទាំងឡាយ នេះ ឈ្មោះថា សម្មាវាចាដ៏ប្រសើរ មិនមានអាសវៈ ជាលោកុត្តរ ជាអង្គនៃមគ្គ ។បេ។ ម្នាលភិក្ខុទាំងឡាយ សម្មាកម្មន្តៈ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ តថាគត

សម្តែងនូវសម្មាកម្មន្តៈ ថាមានពីរយ៉ាង ។បេ។ ឲ្យផលជាឧបធិក្កិលេស ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ សម្មាកម្មន្តៈដ៏ប្រសើរ មិនមានអាសវៈ ជាលោកុត្តរ ជាអង្គនៃមគ្គ តើដូចម្តេច ។បេ។ ម្នាលភិក្ខុទាំងឡាយ សម្មាអាជីវៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតសម្តែងនូវសម្មាអាជីវៈ ថាមានពីរយ៉ាង ។បេ។ ឲ្យផលជាឧបធិក្កិលេសក៏មាន ។ ម្នាលភិក្ខុទាំងឡាយ សម្មាអាជីវៈដ៏ប្រសើរ មិនមានអាសវៈ ជាលោកុត្តរ ជាអង្គនៃមគ្គ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ការតម ចៀស គេច វៀរចាកមិច្ឆាអាជីវៈ របស់បុគ្គលមានចិត្តជាអរិយៈ មានចិត្តមិនមានអាសវៈ បរិបូណ៌ដោយអរិយមគ្គ ចម្រើននូវអរិយមគ្គ ម្នាលភិក្ខុទាំងឡាយ នេះ ឈ្មោះថា សម្មាអាជីវៈដ៏ប្រសើរ មិនមានអាសវៈ ជាលោកុត្តរ ជាអង្គនៃមគ្គ ដូច្នេះ ។

ក្នុងសូត្រនេះ ទ្រង់វៀរនីមួយៗ គឺអំពីវចីទុច្ចរិត ៤ កាយទុច្ចរិត ៣ និងមិច្ឆាអាជីវៈ ព្រះមានព្រះភាគត្រាស់យ៉ាងនេះថា ដ៏ប្រសើរ មិនមានអាសវៈ ជាលោកុត្តរ ជាអង្គនៃមគ្គ ក្នុងឋានៈនេះ ភាពដែលវិរតិ មានចេតនាច្រើននឹងមានអំពីណា មគ្គប្រកបដោយអង្គ ៥ នឹងមានអំពីណា ព្រះសូត្រនេះ សម្តែងដល់លោកដែលមិនពេញចិត្តថា លោកុត្តរមគ្គ ប្រកបដោយអង្គ ៨ បើអាចារ្យវិតណ្ឌវាទីកំណត់បាន ដោយហេតុមានប្រមាណប៉ុណ្ណេះសោត ក៏ជាការល្អ បើកំណត់មិនបាន គប្បីនាំហេតុដទៃមកដើម្បីឲ្យយល់ព្រម ។

ពិតហើយ ព្រះមានព្រះភាគ ត្រាស់ពាក្យនេះ ( ក្នុងទីឃនិកាយ មហាវគ្គ ) ថា ម្នាលសុភទ្ទ អរិយមគ្គមានអង្គ ៨ មិនមានក្នុងធម្មវិន័យ

ណា សមណៈទី ១ ក្តី មិនមានក្នុងធម្មវិន័យនោះ ។បេ។ ម្នាលសុភទ្ទ អរិយមគ្គប្រកបដោយអង្គ ៨ មានតែក្នុងធម្មវិន័យនេះឯង ម្នាលសុភទ្ទ សមណៈ ( ទី ១ ) ក៏មានតែក្នុងសាសនានេះ ។បេ។ បរប្បវាទ ( វាទៈនៃគ្រូដទៃ ) អំពីសម្នាក់នៃបុគ្គលដទៃ រមែងសូន្យចាកពួកសមណៈ ( នេះ ) ដូច្នេះ ។ មគ្គប្រកបដោយអង្គ ៨ មកហើយក្នុងសូត្រដទៃ ក៏មានជាអនេកពរយ ។

ក្នុងកថាវត្ថុប្បករណ៍ សកវាទីអាចារ្យ ក៏បានពោលអាងពុទ្ធវចនៈថា អដ្ឋង្គិកមគ្គ ប្រសើរជាងមគ្គទាំងឡាយ បទ គឺអរិយសច្ច ៤ ប្រសើរជាងសច្ចៈទាំងឡាយ ធម៌ មានរាគៈទៅប្រាសហើយ ប្រសើរជាងធម៌ទាំងឡាយ ព្រះមានព្រះភាគ ព្រះអង្គមានចក្ខុ ប្រសើរជាងសត្វជើងពីរទាំងឡាយ ដូច្នេះ ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ មគ្គឈ្មោះថា ប្រកបដោយអង្គ ៨ ។

បើបុគ្គលនោះ មិនយល់ដោយហេតុមានប្រមាណប៉ុណ្ណេះសោត គប្បីបញ្ជូនភិក្ខុនោះទៅដោយពាក្យថា ចូរលោកទៅកាន់វិហារធាន់បបរចុះ ការដែលនឹងពោលហេតុផលឲ្យច្រើនជាងនេះ ជាអហេតុៈដូច្នេះ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ។

ក្នុងទីនេះ បណ្ឌិតគប្បីរាប់ន័យទាំងឡាយដូច្នេះ

ក្នុងមគ្គទាំង ៤ លោកចែកជា ៤០០០ ន័យ ក្នុងការសួររួមគ្នា ធ្វើយ

*រួមគ្នា ក្នុងមគ្គប្រកបដោយអង្គ ៨ ក្នុងមគ្គប្រកបដោយអង្គ ៥ ក្នុងការសួរ រួមគ្នា ឆ្លើយរួមគ្នា លោកចែក ៤០០០ ន័យ តែក្នុងការសួរញែកគ្នា និង ការឆ្លើយញែកគ្នា លោកចែកនីមួយៗ ៤០០០ ន័យ សង្គ្រោះចូលក្នុងអង្គ ទាំង ៥ ទើបជា ២ មុឺនន័យ ។ មយ៉ាងទៀត ន័យទាំងអស់ លោកចែកក្នុង មគ្គវិភង្គ ២ មុឺន ៨ ពាន់ន័យ គឺ ៨០០០ ន័យក្នុងកាលមុន រួមជាមួយនឹង ២០០០ ន័យខាងក្រោយនេះ ដោយប្រការដូច្នេះ ។ ន័យទាំងនោះឯងជា លោកុត្តរ ដែលកើតឡើងហើយ ជាកុសលប៉ុណ្ណោះ ចំណែកក្នុងវិបាក បណ្ឌិតគប្បីគុណនឹង ៣ ដោយកុសលនោះឯង ៕*

**អដ្ឋកថាអភិធម្មភាជនីយ ចប់**

# អភិធម្មបិដក

## បញ្ហាបុច្ឆកៈ

[ ៣៨០ ] អរិយមគ្គមានអង្គ ៨ ។ អរិយមគ្គមានអង្គ ៨ គឺអ្វីខ្លះ ។ សម្មាទិដ្ឋិ សម្មាសង្កប្ប សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ។ បណ្តាអរិយមគ្គទាំង ៨ អង្គមគ្គជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។បេ។ ជាសរណៈប៉ុន្មាន ជាអរណៈប៉ុន្មាន ។

[ ៣៨១ ] អង្គមគ្គ ៨ ជាកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។ សម្មា-សង្កប្ប ប្រកបដោយសុខវេទនា អង្គមគ្គ ៧ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។ អង្គមគ្គ ៨ ជាវិបាកក៏មាន មានវិបាកធម៌ជាប្រក្រតី ដែលមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ជាធម៌មិនសៅហ្មងទាំងមិនគួរដល់សេចក្តីសៅហ្មងក៏មាន ។ សម្មាសង្កប្ប មិនមានវិតក្ក មានត្រឹមតែវិចារ អង្គមគ្គ ៧ ប្រកបដោយវិតក្ក ប្រកបដោយវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក មិនមានវិចារក៏មាន ។ សម្មាសង្កប្ប ប្រឡំដោយបីតិ ប្រឡំដោយសុខ តែមិនប្រឡំដោយឧបេក្ខា អង្គមគ្គ ៧ ប្រឡំដោយបីតិក៏មាន ប្រឡំដោយសុខក៏មាន ប្រឡំដោយឧបេក្ខាក៏មាន ។ អង្គមគ្គ ៨ មិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុ មិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្តៈ ) ក៏មាន មិនដល់នូវការសន្សំ

ទាំងមិនដល់នូវការមិនសន្សំក៏មាន ជារបស់សេក្ខៈក៏មាន ជារបស់អសេក្ខៈ មានប្រមាណមិនបាន មានអារម្មណ៍ប្រមាណមិនបាន ជាសភាពដ៏ឧត្តមក៏មាន មានសភាពត្រូវ និងទៀងក៏មាន មានសភាពមិនទៀង មិនមែនមានមគ្គជាអារម្មណ៍ក៏មាន មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន មិនគួរពោលថា មានមគ្គជាហេតុផង ថាមានមគ្គជាអធិបតីផងក៏មាន កើតឡើងហើយក៏មាន មិនទាន់កើតឡើងក៏មាន បម្រុងនឹងកើតឡើងក៏មាន ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្ន តែមិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថាមានអារម្មណ៍ជាអនាគតផង ថាមានអារម្មណ៍ជាបច្ចុប្បន្នផងក៏មាន ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ទាំងខាងក្នុង ទាំងខាងក្រៅ មានអារម្មណ៍ជាខាងក្រៅ មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ក៏មាន ។

[ ៣៨២ ] សម្មាទិដ្ឋិ ជាហេតុ អង្គមគ្គ ៧ មិនមែនហេតុ ។ អង្គមគ្គ ៨ ប្រព្រឹត្តទៅជាមួយនឹងហេតុ ប្រកបដោយហេតុ ។ សម្មាទិដ្ឋិ ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ អង្គមគ្គ ៧ មិនគួរពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុទេ គឺគ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនជាហេតុ ។ សម្មាទិដ្ឋិ ជាហេតុ ទាំងប្រកបដោយហេតុ អង្គមគ្គ ៧ មិនគួរពោលថា ជាហេតុ ទាំងប្រកបដោយហេតុដូច្នេះឡើយ គឺគ្រាន់តែប្រកបដោយហេតុ តែមិនមែនជាហេតុ ។ អង្គមគ្គ ៧ មិនមែនហេតុ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ សម្មាទិដ្ឋិ មិនគួរពោលថា មិនមែនហេតុ គ្រាន់តែប្រព្រឹត្តទៅ ជា

មួយនឹងហេតុផង ថាមិនមែនហេតុ ទាំងឥតហេតុផងឡើយ ។

[ ៣៨៣ ] អដ្ឋមគ្គ ៨ ប្រកបដោយបច្ច័យ ត្រូវបច្ច័យតាក់តែង មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ មិនមានរូប ជាលោកុត្តរ គប្បីដឹងដោយវិញ្ញាណណាមួយ មិនគប្បីដឹងដោយវិញ្ញាណណាមួយ ។ អដ្ឋមគ្គ ៨ មិនមែនអាសវៈ មិនមានអាសវៈ ប្រាសចាកអាសវៈ មិនគួរពោលថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ថាប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈផងឡើយ មិនគួរពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈផង ថាប្រកបដោយអាសវៈ តែមិនមែនអាសវៈផងទេ គឺប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ។ អដ្ឋមគ្គ ៨ មិនមែនសញ្ញោជនៈ ។បេ។ មិនមែនគន្ថៈ ។បេ។ មិនមែនឱឃៈ ។បេ។ មិនមែនយោគៈ ។បេ។ មិនមែននីវរណៈ ។បេ។ មិនមែនបរាមាស ។បេ។ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ មិនមែនចិត្ត ជាចេតសិក ប្រកបដោយចិត្ត ប្រឡំដោយចិត្ត កើតឡើងអំពីចិត្ត កើតជាមួយនឹងចិត្ត ប្រព្រឹត្តទៅតាមចិត្ត ប្រឡំ ទាំងកើតឡើងអំពីចិត្ត ប្រឡំ ទាំងតាំងឡើង ទាំងកើតឡើង ជាមួយនឹងចិត្ត ប្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត ជាខាងក្រៅ មិនមែនឧបាទា មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក ។ មិនមែនឧបាទាន ។បេ។ មិនមែនកិលេស ។បេ។

[ ៣៨៤ ] អដ្ឋមគ្គ ៨ មិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុ មិនគួរលះដោយទស្សនៈ មានហេតុ មិនគួរលះដោយភាវនា ។

សម្មាសង្កប្ប មិនមានវិតក្ក អង្គមគ្គ ៧ ប្រកបដោយវិតក្កក៏មាន មិនមានវិតក្កក៏មាន ។ សម្មាសង្កប្ប ប្រកបដោយវិចារ អង្គមគ្គ ៧ ប្រកបដោយវិចារក៏មាន មិនមានវិចារក៏មាន ។ សម្មាសង្កប្ប ប្រកបដោយបីតិ អង្គមគ្គ ៧ ប្រកបដោយបីតិក៏មាន មិនមានបីតិក៏មាន ។ សម្មាសង្កប្ប ប្រកបដោយបីតិ អង្គមគ្គ ៧ ប្រកបដោយបីតិក៏មាន មិនប្រកបដោយបីតិក៏មាន ។ សម្មាសង្កប្ប ប្រកបដោយសុខ អង្គមគ្គ ៧ ប្រកបដោយសុខក៏មាន មិនប្រកបដោយសុខក៏មាន ។ សម្មាសង្កប្ប មិនប្រកបដោយឧបេក្ខា អង្គមគ្គ ៧ ប្រកបដោយឧបេក្ខាក៏មាន មិនប្រកបដោយឧបេក្ខាក៏មាន ។ មិនមែនកាមាវចរ មិនមែនរូបាវចរ មិនមែនអរូបាវចរ ជាអបរិយាបន្ន ជានិយ្យានិកៈក៏មាន ជាអនិយ្យានិកៈក៏មាន ជានិយតៈក៏មាន ជាអនិយតៈ ជាអនុត្តរៈ ជាអរណៈក៏មាន ។

បញ្ហាបុច្ឆកៈ ចប់

មគ្គវិភង្គ ចប់

# អដ្ឋកថា

## បញ្ហាបុច្ឆកៈ

[ ៣៨០-៣៨៤ ] ក្នុងបញ្ហាបុច្ឆកៈ ភាពដែលអង្គនៃមគ្គ ជាកុសល ជាដើម បណ្ឌិតគប្បីជ្រាបដោយទំនងព្រះបាលីនោះឯង តែក្នុងអារម្មណត្តិកៈ អង្គនៃមគ្គទាំងអស់នេះ ជាអប្បមាណារម្មណៈប្រព្រឹត្តទៅ ។ ព្រោះប្រារព្ធព្រះនិព្វាន ដែលជាអប្បមាណធម៌ប្រព្រឹត្តទៅ ។ មិនជាមគ្គារម្មណៈ ព្រោះមគ្គ និងផល រមែងធ្វើមគ្គឲ្យជាអារម្មណ៍ ។ ក្នុងបញ្ហាបុច្ឆកៈនេះ អង្គនៃមគ្គដែលជាកុសលទាំងឡាយ ជាមគ្គហេតុកៈ ដោយអំណាចនៃសហជាតហេតុ ។ ក្នុងកាលចម្រើនមគ្គ ធ្វើវិរិយៈ ឬវីមង្សាឲ្យជាធំ ជាមគ្គាធិបតី ក្នុងការចម្រើនមគ្គ ដែលមានឆន្ទៈ និងចិត្តជាធំ ពោលមិនបានថា ជាមគ្គធិបតីក្នុងវេលានៃផលចិត្ត ក៏ពោលមិនបានដូចគ្នា ។ ក្នុងអតីតារម្មណ៍ជាដើម ក៏មិនគប្បីពោលដោយភាពជាអារម្មណ៍ត្រឹមតែមួយ ។ តែរមែងឈ្មោះថាជាពហិទ្ធារម្មណៈបាន ព្រោះព្រះនិព្វាន ជាធម៌ខាងក្រៅ ព្រោះហេតុនោះ ក្នុងបញ្ហាបុច្ឆកៈនេះ ព្រះមានព្រះភាគក៏ត្រាស់អង្គនៃមគ្គដែលជាលោកុត្តរ ដែលកើតឡើងហើយនោះឯងយ៉ាងនេះ ។ អង្គនៃមគ្គដែលជាលោកិយ និងលោកុត្តរ ព្រះសម្មាសម្ពុទ្ធត្រាស់ក្នុងសុត្តន្តភាជនីយប៉ុណ្ណោះ ឯក្នុងអភិធម្មភាជនីយ និងបញ្ហាបុច្ឆកៈ ទ្រង់ត្រាស់ថា ជាលោកុត្តរតែម្យ៉ាង មគ្គវិភង្គនេះ ទ្រង់នាំចេញចែកសម្តែងហើយជា ៣ បរិវដ្ដៈយ៉ាងនេះ ដោយប្រការដូច្នេះ ៕៚

**អដ្ឋកថាបញ្ហាបុច្ឆកៈ ចប់**

**អដ្ឋកថាមគ្គង្គវិភង្គ ចប់**

# អភិធម្មបិដក

## ឈានវិភង្គ

[ ៣៨៥ ] ភិក្ខុក្នុងសាសនានេះ ជាអ្នកសង្រួមក្នុងបាតិមោក្ខសំវរៈ សម្រេចឥរិយាបថ បរិបូណ៌ដោយអាចារ និងគោចរ ឃើញភ័យក្នុងទោសទាំងឡាយ មានប្រមាណតិច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ មានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយ ជាអ្នកដឹងប្រមាណក្នុងភោជន ប្រកបរឿយៗ ក្នុងការព្យាយាមជាគ្រឿងភ្ញាក់រឭក ក្នុងពេលមុនរាត្រី និងក្រោយរាត្រី ប្រកបរឿយៗ ក្នុងការព្យាយាមចម្រើននូវធម៌ទាំងឡាយ ជាចំណែកនៃការត្រាស់ដឹង ជាប់មិនដាច់ ចាស់ក្លា ។ ភិក្ខុនោះ ជាអ្នកធ្វើសេចក្តីដឹងខ្លួន ក្នុងការដើរទៅមុខ និងការឈានថយក្រោយ ធ្វើសេចក្តីដឹងខ្លួន ក្នុងការក្រឡេកមើលទៅមុខ និងការក្រឡេកមើលទៅទិសផ្សេងៗ ធ្វើសេចក្តីដឹងខ្លួន ក្នុងការបត់ដៃជើង និងការលាតដៃជើង ធ្វើសេចក្តីដឹងខ្លួន ក្នុងការទ្រទ្រង់សង្ឃាដី បាត្រ និងចីវរ ធ្វើសេចក្តីដឹងខ្លួន ក្នុងការបរិភោគភោជន ការផឹកទឹក ការទំពាស៊ីខាទនីយៈ និងការជញ្ជក់ ( នូវភេសជ្ជៈ មានសប្បិជាដើម ) ធ្វើសេចក្តីដឹងខ្លួន ក្នុងការបន្ទោបង់ឧច្ចារបស្សាវៈ ធ្វើសេចក្តីដឹងខ្លួន ក្នុងការដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ឡើង និយាយ ឬការស្ងៀម ។ ភិក្ខុនោះ គប់រកទីសេនាសនៈដ៏ស្ងាត់ គឺព្រៃតូច គល់ឈើ ភ្នំ ជ្រោះភ្នំ គុហាភ្នំ ព្រៃស្មសាន ព្រៃញៀតស្បាត ទីវាល គំនរចំបើង ទីមិនមានសំឡេង ទីមិនគឹកកង ទីប្រាសចាកខ្យល់ដែលកើតអំពីសរីរៈនៃជន ទីស្ងាត់កំបាំងរបស់មនុស្ស ទីសមគួរដល់ការពួនសម្ងំ ។ ភិក្ខុនោះ ទៅកាន់ព្រៃក្តី ទៅកាន់ម្លប់

ឈើក្តី ទៅកាន់ផ្ទះស្ងាត់ក្តី អង្គុយផ្គត់ភ្នែន តាំងកាយឲ្យត្រង់ តម្កល់សតិឲ្យមានមុខឆ្ពោះទៅរក ( កម្មដ្ឋាន ) ។ ភិក្ខុនោះ លះបង់អភិជ្ឈាក្នុងលោក មានចិត្តប្រាសចាកអភិជ្ឈា ជម្រះចិត្តឲ្យស្អាតចាកអភិជ្ឈា លះបង់ព្យាបាទ និងសេចក្តីប្រទូស្ត មានចិត្តមិនព្យាបាទ មានសេចក្តីអនុគ្រោះ នូវប្រយោជន៍ដល់សត្វមានជីវិតទាំងអស់ ជម្រះចិត្តឲ្យស្អាតចាកព្យាបាទ និងសេចក្តីប្រទូស្ត លះបង់ថីនមិទ្ធៈ ជាអ្នកប្រាសចាកថីនមិទ្ធៈ មានសេចក្តីសម្គាល់ជាពន្លឺ ជាអ្នកមានសតិ និងសម្បជញ្ញៈ ជម្រះចិត្តឲ្យស្អាតចាកថីនមិទ្ធៈ លះបង់ឧទ្ធច្ចកុក្កុច្ចៈ ជាអ្នកមិនរាយមាយ មានចិត្តស្ងប់រម្ងាប់ខាងក្នុងសន្តាន ជម្រះចិត្តឲ្យស្អាតចាកឧទ្ធច្ចកុក្កុច្ចៈ លះបង់វិចិកិច្ឆា ជាអ្នកឆ្លងចាកវិចិកិច្ឆា មិនមានសេចក្តីងឿងឆ្ងល់ ក្នុងកុសលធម៌ទាំងឡាយ ជម្រះចិត្តឲ្យស្អាតចាកវិចិកិច្ឆា ។ ភិក្ខុនោះ លុះលះបង់នីវរណៈទាំង ៥ នេះ ដែលជាគ្រឿងសៅហ្មងនៃចិត្ត ដែលធ្វើបញ្ញាឲ្យមានកម្លាំងថយ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលកាន់បឋមជ្ឈាន ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានបីតិ និងសុខ ដែលកើតអំពីវិវេក ភិក្ខុនោះ ព្រោះរម្ងាប់វិតក្កៈ និងវិចារៈ ក៏ចូលកាន់ទុតិយជ្ឈាន ជាធម្មជាតកើតមានខាងក្នុងសន្តាន ប្រកបដោយសេចក្តីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិ និងសុខ ដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ភិក្ខុនោះ ព្រោះនឿយណាយចាកបីតិផង ប្រកបដោយឧបេក្ខាផង មានស្មារតីដឹងខ្លួនផង ទទួលសុខដោយនាមកាយផង ក៏ចូលកាន់តតិយជ្ឈាន ដែលព្រះ

អរិយៈទាំងឡាយតែងសរសើរថា បុគ្គលដែលបានតតិយជ្ឈាន ជាអ្នកប្រកប ដោយឧបេក្ខា មានស្មារតីនៅជាសុខ ភិក្ខុនោះ ព្រោះលះសុខផង ព្រោះលះ ទុក្ខផង ព្រោះអស់ទៅនៃសោមនស្ស និងទោមនស្ស ក្នុងកាលមុនផង ក៏ចូល កាន់ចតុត្ថជ្ឈាន ជាធម្មជាតមានអារម្មណ៍មិនមែនទុក្ខ មិនមែនសុខ គឺឧបេក្ខា មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ភិក្ខុនោះ ព្រោះកន្លងរូបសញ្ញា ព្រោះអស់ទៅ នៃបដិឃសញ្ញា ព្រោះការមិនធ្វើទុកក្នុងចិត្ត នូវនានត្តសញ្ញា ដោយសព្វគ្រប់ ក៏ចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយបរិកម្មថា អាកាសមិនមានទី បំផុត ភិក្ខុនោះ ព្រោះកន្លងអាកាសានញ្ចាយតនជ្ឈាន ដោយសព្វគ្រប់ ក៏ចូល កាន់វិញ្ញាណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត ភិក្ខុនោះ ព្រោះកន្លងវិញ្ញាណញ្ចាយតនជ្ឈាន ដោយសព្វគ្រប់ ក៏ចូលកាន់អាកិញ្ចញ្ញា-យតនជ្ឈាន ដោយបរិកម្មថា វត្ថុតិចតួចមិនមាន ភិក្ខុនោះ ព្រោះកន្លង អាកិញ្ចញ្ញាយតនជ្ឈាន ដោយសព្វគ្រប់ ក៏ចូលកាន់នេវសញ្ញានាសញ្ញា-យតនជ្ឈាន ។

**មាតិកា ចប់**

# អដ្ឋកថា

# ឈានវិភង្គ

## អធិប្បាយមាតិកា

[ ៣៤៥ ] ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងឈានវិភង្គ ដែលជាលំដាប់បន្ទាប់អំពីមគ្គវិភង្គនោះដូចតទៅ

ខាងដើមនេះ ព្រះមានព្រះភាគ ទ្រង់តាំងមាតិកានៃសុត្តន្តភាជនីយទាំងអស់មុន ។ ក្នុងមាតិកាទាំងនោះ បទថា **ឥធ** ជាបទសម្តែងលម្អិតដល់ពាក្យប្រៀនប្រដៅដែលពិត ដោយអាស្រ័យបុគ្គលដែលសម្បូរដោយការដល់ព្រមក្នុងករណីយកិច្ចដែលជាចំណែកខាងដើម ដែលញុំាងឈានមានប្រការទាំងពួងឲ្យកើតឡើងផង ជាការបដិសេធភាពជាយ៉ាងនោះរបស់សាសនាដទៃផង ។ សេចក្តីនេះ សមដូចព្រះសាស្តាត្រាស់ ( ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ សមណៈទី ១ ក៏មានក្នុងធម្មវិន័យនេះ ។បេ។ បរប្បវាទ ( លទ្ធិ ) ទាំងឡាយ សូន្យចាកពួកសមណៈដទៃ ដូច្នេះ ។

បទថា **ភិក្ខុ** ជាបទសម្តែងដល់បុគ្គល ដែលញុំាងឈានទាំងនោះឲ្យកើតឡើង ។ បទថា **បាតិមោក្ខសំវរសំវុតោ** នេះ ជាបទចង្អុលបង្ហាញដល់ភាពដែលភិក្ខុនោះ តាំងមាំក្នុងបាតិមោក្ខសំវរៈ ។

បទថា **វិហរតិ** នេះ ជាពាក្យអធិប្បាយ ដល់ភាពដែលភិក្ខុនោះ ជាអ្នកដល់ព្រមដោយការនៅ សមគួរដល់ភាពយ៉ាងនោះ ។ បទថា **អាចារ-**

**គោចរសម្បន្នោ** *នេះ ជាការសម្តែងថា ភិក្ខុនោះ មានធម៌ដែលជាឧបការៈដល់បាតិមោក្ខសំវរៈក្នុងខាងដើម និងដល់ការប្រកបរឿយៗ នូវឈានជាន់ខ្ពស់ ។*

*បទថា* **អណុមត្តេសុ វជ្ជេសុ ភយទស្សាវី** *នេះ ជាពាក្យលម្អិតដល់ភាពដែលភិក្ខុនោះ មានការមិនឃ្លាតចាកបាតិមោក្ខជាធម្មតា ។ បទថា* **សមាទាយ** *នេះ ជាពាក្យសម្តែងដល់ការកាន់យកសិក្ខាបទទាំងឡាយរបស់ភិក្ខុនោះ ដោយមិនសេសសល់ ។ បទថា* **សិក្ខតិ** *នេះ ជាពាក្យសម្តែងដល់ភាពដែលភិក្ខុនោះ ជាអ្នកដល់ព្រមដោយសិក្ខា ។ បទថា* **សិក្ខាបទេសុ** *នេះ ជាពាក្យសម្តែងដល់ធម៌ដែលភិក្ខុនោះគប្បីសិក្សា ។ បទថា* **ឥន្ទ្រិយេសុ** *នេះ ជាពាក្យសម្តែងដល់ភូមិនៃទ្វារដែលភិក្ខុគ្រប់គ្រងហើយ ។ អាចារ្យទាំងឡាយពោលថា ពាក្យនេះ ជាពាក្យសម្តែងដល់ឱកាស ដែលបុគ្គលគួររក្សាដូច្នេះក៏មាន ។ បទថា* **គុត្តទ្វារោ** *នេះ ជាពាក្យសម្តែងដល់ភាពដែលភិក្ខុនោះ ជាបុគ្គលមានការរក្សា ដែលសង្រួមល្អហើយក្នុងទ្វារទាំង ៦ ។ បទថា* **ភោជនេមត្តញ្ញូ** *នេះ ជាពាក្យសម្តែងដល់ភាពដែលភិក្ខុនោះ មានគុណ មានសេចក្តីសន្តោសជាដើម ។ បទថា* **បុព្វរត្តាបររត្តំ ជាគរិយានុយោគមនុយុត្តោ** *នេះ ជាពាក្យសម្តែងដល់ហេតុរបស់ភិក្ខុនោះ ។*

*បទថា* **សាតច្ចំ នេបក្កំ** *នេះ ជាពាក្យសម្តែងដល់ភាពដែលភិក្ខុនោះជាអ្នកធ្វើសេចក្តីព្យាយាមឲ្យជាប់តគ្នាទៅ ដោយសេចក្តីព្យាយាមដែលកំណត់ហើយដោយបញ្ញា ។ បទថា* **ពោធិបក្ខិកានំ ធម្មានំ ភាវនានុយោគមនុ-**

**យុត្តោ** នេះ ជាពាក្យសម្តែងដល់ការដឹងដែលជាចំណែកនៃការចាក់ដោះដោយកិច្ចបដិបត្តិរបស់ភិក្ខុនោះ ។

បទថា **សោ អភិក្កន្តេ ។បេ។ តុណ្ហីភាវេ សម្បជានការី ហោតិ** នេះ ជាពាក្យសម្តែងដល់ភាពដែលភិក្ខុនោះ ជាអ្នកប្រកបហើយ ដោយសតិសម្បជញ្ញៈ ក្នុងទីទាំងពួង ។ បទថា **សោ វិវិត្តំ សេនាសនំ ភជតិ** នេះ ជាពាក្យសម្តែងដល់ភាពដែលភិក្ខុនោះ កាន់យកសេនាសនៈដ៏សមគួរ ។

បទថា **អរញ្ញំ ។បេ។ បដិសល្លានសារុប្បំ** នេះ ជាពាក្យសម្តែងដល់ប្រភេទសេនាសនៈ ដែលមិនមានទោស និងអានិសង្សនៃសេនាសនៈនោះ ។ បទថា **សោ អរញ្ញគតោ វា** នេះ ជាពាក្យសម្តែងដល់ភាពដែលភិក្ខុនោះ ជាអ្នកប្រកបហើយដោយសេនាសនៈ មានប្រការតាមដែលពោលហើយនោះ ។ បទថា **និសីទតិ** នេះ ជាពាក្យសម្តែងដល់ឥរិយាបថដ៏សមគួរដល់សេចក្តីព្យាយាម របស់ភិក្ខុនោះ ។ បទថា **បរិមុខំ សតឹ ឧបដ្ឋបេត្វា** នេះ ជាពាក្យសម្តែងដល់ការប្រារព្ធព្យាយាមរបស់ភិក្ខុនោះ ។ បទថា **សោ អភិជ្ឈំ លោកេ បហាយ** ជាដើម ជាពាក្យសម្តែងដល់ការលះនីវរណៈដោយការប្រកបរឿយៗ នូវកម្មដ្ឋានរបស់ភិក្ខុនោះ ។ កាលភិក្ខុនោះ លះនីវរណៈបានហើយនោះឯង ។ បទថា **វិវិច្ចេវ កាមេហិ** ជាដើម ជាពាក្យសម្តែងដល់ការកើតឡើងនៃឈានដោយលំដាប់ ។

ម្យ៉ាងទៀត បទថា **ឥធ ភិក្ខុ** បានដល់ ភិក្ខុដែលញុំាងឈានឲ្យកើតឡើងក្នុងសាសនានេះ ក្នុងឥឡូវនេះ ព្រោះភិក្ខុដែលញុំាងឈានឲ្យកើតឡើង

*គប្បីជម្រះសីល ៤ ឲ្យបរិសុទ្ធ ហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីបរិសុទ្ធវិសេសនៃបាតិមោក្ខសំវរសីល ដោយពាក្យនេះថា ជាអ្នកសង្រួមក្នុងបាតិមោក្ខសំវរៈ ។*

*ព្រះមានព្រះភាគ ត្រាស់សម្តែងអាជីវបារិសុទ្ធិសីល ដោយពាក្យថា* **អាចារគោចរសម្បន្នោ** *ជាដើម ។ ទ្រង់សម្តែងសីលទាំងពីររបស់ភិក្ខុនោះ ដោយមិនសេសសល់ ដោយបទនេះថា* **សមាទាយ សិក្ខតិ សិក្ខាបទេសុ ។** *ទ្រង់សម្តែងឥន្ទ្រិយសំវរសីលដោយបទនេះថា* **ឥន្ទ្រិយេសុ គុត្តទ្វារោ ។** *ទ្រង់សម្តែងបច្ចយសន្និស្សិតសីល ដោយបទនេះថា* **ភោជនេ មត្តញ្ញូ ។** *ទ្រង់សម្តែងធម៌ទាំងឡាយ ដែលមានឧបការៈនៃការចម្រើនឈានរបស់ភិក្ខុ ដែលតាំងនៅហើយក្នុងសីលដោយបទនេះថា* **បុព្វរត្តាបររត្តំ** *ជាដើម ។ ទ្រង់សម្តែងការប្រកបដោយល្អ ក្នុងសតិសម្បជញ្ញៈ ដោយការមិនសាបសូន្យទៅនៃធម៌ទាំងឡាយនោះ និងទាំងការមិនវិនាសសាបសូន្យនៃកម្មដ្ឋាន ដោយបទថា* **សោ អភិក្កន្តេ** *ជាដើម ។ ទ្រង់សម្តែងការកាន់យកសេនាសនៈដែលសមគួរដល់ភាវនា ដោយបទថា* **សោ វិវិត្តំ** *ជាដើម ។ ទ្រង់សម្តែងឥរិយាបថដែលសមគួរដល់ឈាន និងការផ្តើមចម្រើននូវឈាន របស់ភិក្ខុ*

*ដែលចូលទៅអាស្រ័យសេនាសនៈនោះ ដោយបទថា* **សោ អរញ្ញគតោ វា** *ជាដើម ។ ទ្រង់សម្តែងការលះនូវធម៌ដែលជាសត្រូវដល់ឈាន ដោយការផ្តើមចម្រើនឈាន ដោយបទថា* **សោ អភិជ្ឈំ** *ជាដើម ។ ទ្រង់សម្តែងលំដាប់នៃការកើតឡើងរបស់ឈានទាំងអស់ របស់កិក្ខុដែលមានធម៌ជាសត្រូវដល់ឈានដែលលះបង់ហើយយ៉ាងនេះ ដោយបទថា* **សោ ឥមេ បញ្ច នីវរណេ បហាយ** *ជាដើម ដូច្នេះឯង ។*

## អធិប្បាយមាតិកា ចប់

# អភិធម្មបិដក

## សុត្តន្តភាជនីយ

[ ៣៤៦ ] ត្រង់ពាក្យថា នេះ គឺក្នុងការឃើញនេះ ក្នុងការគាប់ចិត្តនេះ ក្នុងការចូលចិត្តនេះ ក្នុងការប្រកាន់នេះ ក្នុងធម៌នេះ ក្នុងវិន័យនេះ ក្នុងធម៌និងវិន័យនេះ ក្នុងពាក្យជាប្រធាននេះ ក្នុងព្រហ្មចរិយៈនេះ ក្នុងសាសនានៃព្រះសាស្តានេះ ព្រោះហេតុនោះ ទើបពោលថា នេះ ។

[ ៣៤៧ ] ត្រង់ពាក្យថា ភិក្ខុ គឺឈ្មោះថា ភិក្ខុ ព្រោះឈ្មោះ ឈ្មោះថា ភិក្ខុ ព្រោះការបព្ជជ្ជា ឈ្មោះថា ភិក្ខុ ព្រោះសូម ឈ្មោះថា ភិក្ខុ ព្រោះជាអ្នកសូម ឈ្មោះថា ភិក្ខុ ព្រោះជាអ្នកចូលទៅកាន់ទីត្រាច់ទៅដើម្បីសូម ឈ្មោះថា ភិក្ខុ ព្រោះជាអ្នកទ្រទ្រង់សំពត់កាត់ដាច់ ឈ្មោះថា ភិក្ខុ ព្រោះទម្លាយអកុសលធម៌ទាំងឡាយដ៏លាមក ឈ្មោះថា ភិក្ខុ ព្រោះហេតុទម្លាយអកុសល-ធម៌ទាំងឡាយដ៏លាមក ឈ្មោះថា ភិក្ខុ ព្រោះការលះកិលេសទាំងឡាយដោយចំណែក ឈ្មោះថា ភិក្ខុ ព្រោះការលះកិលេសទាំងឡាយដោយមិនមានចំណែក បុគ្គលជាសេក្ខៈ ឈ្មោះថា ភិក្ខុ បុគ្គលជាអសេក្ខៈ ឈ្មោះថា ភិក្ខុ បុគ្គលជាសេក្ខៈក៏មិនមែន ជាអសេក្ខៈក៏មិនមែន ឈ្មោះថា ភិក្ខុ បុគ្គលប្រសើរ ឈ្មោះថា ភិក្ខុ បុគ្គលចម្រើន ឈ្មោះថា ភិក្ខុ បុគ្គលផូរផង់ ឈ្មោះថា ភិក្ខុ បុគ្គលមានខ្លឹម ឈ្មោះថា ភិក្ខុ បុគ្គលដែលសង្ឃព្រមព្រៀងគ្នា ឲ្យឧបសម្បទា ដោយញត្តិចតុត្ថកម្ម ដែលមិនកម្រើកគួរដល់ហេតុ ឈ្មោះថា ភិក្ខុ ។

[ ៣៤៨ ] ត្រង់ពាក្យថា បាតិមោក្ខ បានដល់ សីល ការតាំងមាំ កិច្ចខាងដើម ការប្រព្រឹត្ត ការសង្រួម ការរារាំង ប្រធាន ប្រមុខ នៃការដល់នូវកុសលធម៌ទាំងឡាយ ។ ពាក្យថា សំវរៈ គឺការមិនកន្លង ដែលប្រព្រឹត្តទៅក្នុងកាយ ការមិនកន្លង ដែលប្រព្រឹត្តទៅក្នុងវាចា ការមិនកន្លង ដែលប្រព្រឹត្តទៅក្នុងកាយ និងក្នុងវាចា ។ ពាក្យថា ជាអ្នកសង្រួម គឺជាអ្នកព្រមព្រៀង មូលមិត្រ ចូលទៅជិត អែបនែប កៀកកើយ ប្រជិតប្រជី ប្រកបព្រមដោយការសង្រួមក្នុងបាតិមោក្ខនេះ ព្រោះហេតុនោះ ទើបពោលថា ជាអ្នកសង្រួមក្នុងបាតិមោក្ខសំវរៈ ។

[ ៣៤៩ ] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺសម្រេច ប្រព្រឹត្ត រក្សារស់នៅ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ត្រាច់ទៅ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[ ៣៥០ ] ត្រង់ពាក្យថា បរិបូណ៌ដោយអាចារ និងគោចរ អធិប្បាយថា អាចារក៏មាន អនាចារក៏មាន ។ បណ្ដាអាចារ និងអនាចារនោះ អនាចារតើដូចម្ដេច ។ ការប្រព្រឹត្តកន្លង ប្រកបដោយកាយ ការប្រព្រឹត្តកន្លង ប្រកបដោយវាចា ការប្រព្រឹត្តកន្លង ប្រកបដោយកាយ និងវាចា នេះហៅថា អនាចារ សូម្បីភាពនៃភិក្ខុទ្រុស្តសីលទាំងអស់ ក៏ឈ្មោះថា អនាចារ គឺភិក្ខុខ្លះ ក្នុងសាសនានេះ ចិញ្ចឹមជីវិត ដោយការឲ្យឫស្សីខ្លះ ឲ្យស្លឹកឈើខ្លះ ឲ្យផ្កាឈើខ្លះ ឲ្យផ្លែឈើខ្លះ ឲ្យគ្រឿងលម្អិតសម្រាប់លាបខ្លះ ឲ្យឈើស្ទន់ខ្លះ ដោយភាពជាអ្នកបន្ទាបបន្ទន់កាយខ្លះ ដោយការពោលវាចាដូចជាសម្លសណ្ដែកបាយ

ខ្លះ ដោយការបីថ្នមកូនរបស់ត្រកូលខ្លះ ដោយការបម្រើត្រកូលដោយកម្លាំងស្មងខ្លះ ដោយមិច្ឆាអាជីវៈណាមួយ ដែលព្រះពុទ្ធទ្រង់តិះដៀលហើយខ្លះ នេះហៅថា អនាចារ ។ បណ្តាអនាចារ និងអាចារនោះ អាចារ តើដូចម្តេច ។ ការមិនប្រព្រឹត្តកន្លង ប្រកបដោយកាយ ការមិនប្រព្រឹត្តកន្លង ប្រកបដោយវាចា ការមិនប្រព្រឹត្តកន្លង ប្រកបដោយកាយ និងវាចា នេះហៅថា អាចារ សូម្បីការសង្រួមក្នុងសីលទាំងអស់ ក៏ឈ្មោះថា អាចារ គឺភិក្ខុខ្លះ ក្នុងសាសនានេះ មិនចិញ្ចឹមជីវិត ដោយការឲ្យឫស្សី មិនចិញ្ចឹមជីវិត ដោយការឲ្យស្លឹកឈើ មិនចិញ្ចឹមជីវិត ដោយការឲ្យផ្កាឈើ មិនចិញ្ចឹមជីវិត ដោយការឲ្យផ្លែឈើ មិនចិញ្ចឹមជីវិត ដោយការឲ្យគ្រឿងលម្អិតសម្រាប់លាប មិនចិញ្ចឹមជីវិត ដោយការឲ្យឈើស្ទន់ មិនចិញ្ចឹមជីវិត ដោយការបន្ទាបបន្ទន់កាយ មិនចិញ្ចឹមជីវិត ដោយការពោលវាចា ដូចជាសម្លស់ណ្តែកបាយ មិនចិញ្ចឹមជីវិត ដោយការបីថ្នមកូនរបស់ត្រកូល មិនចិញ្ចឹមជីវិត ដោយការបម្រើត្រកូលដោយកម្លាំងស្មង មិនចិញ្ចឹមជីវិត ដោយមិច្ឆាអាជីវៈណាមួយ ដែលព្រះពុទ្ធទ្រង់តិះដៀលហើយ នេះហៅថា អាចារ ។ ពាក្យថា គោចរ មានសេចក្តីថា គោចរក៏មាន អគោចរក៏មាន ។ បណ្តាគោចរ និងអគោចរនោះ អគោចរ តើដូចម្តេច ។ ភិក្ខុខ្លះ ក្នុងសាសនានេះ ជាអ្នកត្រាច់ទៅកាន់ទីនៃស្ត្រីពេស្យាខ្លះ ត្រាច់ទៅកាន់ទីនៃស្ត្រីមេម៉ាយខ្លះ ត្រាច់ទៅកាន់ទីនៃស្ត្រីក្រមុំខ្លះ ត្រាច់ទៅកាន់ទីនៃមនុស្សបណ្ឌកខ្លះ ត្រាច់ទៅកាន់ទីនៃភិក្ខុនីខ្លះ ត្រាច់ទៅកាន់រោងសុរាខ្លះ ជាអ្នកប្រឡូកប្រឡំដោយពួកស្តេច ដោយពួកមហាមាត្យរបស់ស្តេច ដោយពួកតិរ្ថិយ

ដោយពួកសាវ័ករបស់តិរ្ថិយ ឬដោយការប្រឡូកប្រឡំនឹងគ្រហស្ថ មិនសមគួរ មួយទៀត ត្រកូលណាដែលមិនមានសទ្ធា មិនជ្រះថ្លា មិនមែនជាអណ្តូង ជាអ្នកជេរប្រទេចផ្តាសា មិនប្រាថ្នាសេចក្តីចម្រើន មិនប្រាថ្នាប្រយោជន៍ មិនប្រាថ្នាសេចក្តីសប្បាយ មិនប្រាថ្នាសេចក្តីក្សេមចាកយោគៈ ដល់ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកាឡើយ ភិក្ខុនោះ ចូលចិត្តគប់រក ចូលទៅជិតកាន់ត្រកូលទាំងឡាយមានសភាពដូច្នោះ នេះហៅថា អគោចរ ។ បណ្តាគោចរ និងអគោចរទាំងនោះ គោចរ តើដូចម្តេច ។ ភិក្ខុខ្លះ ក្នុងសាសនានេះ ជាអ្នកមិនត្រាច់ទៅកាន់ទីនៃស្ត្រីពេស្យា មិនត្រាច់ទៅកាន់ទីនៃស្ត្រីមេម៉ាយ មិនត្រាច់ទៅកាន់ទីនៃស្ត្រីក្រមុំ មិនត្រាច់ទៅកាន់ទីនៃមនុស្សបណ្ឌក មិនត្រាច់ទៅកាន់ទីនៃភិក្ខុនី មិនត្រាច់ទៅកាន់រោងសុរា ជាអ្នកមិនប្រឡូកប្រឡំដោយពួកស្តេច ដោយពួកមហាមាត្យរបស់ស្តេច ដោយពួកតិរ្ថិយ ដោយពួកសាវ័ករបស់តិរ្ថិយ ឬដោយការប្រឡូកប្រឡំនឹងគ្រហស្ថ មិនសមគួរ មួយទៀត ត្រកូលណាមានសទ្ធា ជ្រះថ្លា ជាអណ្តូង រុងរឿងដោយសំពត់កាសាវៈ ដែលផ្សព្វផ្សាយដោយខ្យល់នៃឥសី ជាអ្នកប្រាថ្នាសេចក្តីចម្រើន ប្រាថ្នាប្រយោជន៍ ប្រាថ្នាសេចក្តីសប្បាយ ប្រាថ្នាព្រះនិព្វានជាធម៌ក្សេមចាកយោគៈ ដល់ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ភិក្ខុនោះ ចូលចិត្តគប់រក ចូលទៅជិត កាន់ត្រកូលទាំងឡាយមានសភាពដូច្នោះ នេះហៅថា គោចរ ។ ភិក្ខុ ជាអ្នកព្រមព្រៀង ។បេ។ ប្រកបព្រមដោយអាចារនេះផង ដោយគោចរនេះផង ព្រោះហេតុនោះ ទើបពោលថា ភិក្ខុនោះ បរិបូណ៌ដោយអាចារ និងគោចរ ។

[ ៣៥១ ] ត្រង់ពាក្យថា ឃើញភ័យ ក្នុងទោសទាំងឡាយមានប្រមាណតិច មានសេចក្តីថា បណ្តាពាក្យទាំងនោះ ទោសមានប្រមាណតិច តើដូចម្តេច ។ ទោសទាំងឡាយណា មានប្រមាណតិច ស្តួចស្តើង ស្រាល ដល់នូវអំពើស្រាល គួរធ្វើសេចក្តីសង្រួម គួរធ្វើការប្រយ័ត្ន គួរធ្វើការកើតឡើងនៃចិត្តជាទោសជាប់ចំពោះដោយមនសិការ ទាំងនេះ ហៅថា ទោសមានប្រមាណតិច ភិក្ខុ ជាអ្នកឃើញទោស ក្នុងទោសទាំងឡាយ មានប្រមាណតិចនេះផង ឃើញភ័យផង ឃើញកំហុសផង ឃើញការរលាស់ខ្លួនចេញផង ព្រោះហេតុនោះ ទើបពោលថា ឃើញភ័យ ក្នុងទោសទាំងឡាយ មានប្រមាណតិច ។

[ ៣៥២ ] ត្រង់ពាក្យថា សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ មានសេចក្តីថា បណ្តាពាក្យទាំងនោះ សិក្ខា តើដូចម្តេច ។ សិក្ខា មាន ៤ គឺ ភិក្ខុសិក្ខារបស់ពួកភិក្ខុ ១ ភិក្ខុនីសិក្ខារបស់ពួកភិក្ខុនី ១ ឧបាសកសិក្ខារបស់ពួកឧបាសក ១ ឧបាសិកាសិក្ខារបស់ពួកឧបាសិកា ១ ទាំងនេះ ហៅថា សិក្ខា បុគ្គលសមាទានក្នុងសិក្ខាទាំងឡាយនេះ ដោយសព្វគ្រប់ អស់កាលទាំងពួង ដោយប្រការទាំងពួង អស់កិច្ចគ្រប់យ៉ាង មិនមានសល់ ឥតសេសសល់ ហើយប្រព្រឹត្ត ព្រោះហេតុនោះ ទើបពោលថា សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ។

[ ៣៥៣ ] ត្រង់ពាក្យថា មានទ្វារគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយ អធិប្បាយថា ភាពនៃបុគ្គលអ្នកមានទ្វារគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយក៏មាន ភាពនៃបុគ្គលអ្នកមានទ្វារមិនគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយក៏មាន ។

បណ្តាធម៌ទាំងនោះ ភាពនៃបុគ្គលអ្នកមានទ្វារមិនគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយភ្នែកហើយ ជាអ្នកកាន់យកនូវនិមិត្ត កាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈា និងទោមនស្ស គប្បីជាប់តាម នូវបុគ្គលជាអ្នកមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមចក្ខុន្ទ្រិយណា មិនប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ មិនរក្សាចក្ខុន្ទ្រិយ មិនដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក ។បេ។ ធុំក្លិនដោយច្រមុះ ។បេ។ លិទ្ធភ្លក្សរសដោយអណ្តាត ។បេ។ ពាល់ត្រូវផ្សព្វដោយកាយ ។បេ។ ដឹងច្បាស់នូវធម៌ដោយចិត្តហើយ ជាអ្នកកាន់យកនូវនិមិត្ត ជាអ្នកកាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈា និងទោមនស្ស គប្បីជាប់តាមនូវបុគ្គលជាអ្នកមិនសង្រួមមនិន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមមនិន្ទ្រិយណា មិនប្រតិបត្តិដើម្បីសង្រួមមនិន្ទ្រិយនោះ មិនរក្សាមនិន្ទ្រិយ មិនដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ការមិនថែទាំ មិនគ្រប់គ្រង មិនរក្សា មិនសង្រួម នូវឥន្ទ្រិយទាំង ៦ នេះណា នេះហៅថា ភាពនៃបុគ្គលមានទ្វារមិនគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយ ។ បណ្តាធម៌ទាំងនោះ ភាពនៃបុគ្គលអ្នកមានទ្វារគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយ តើដូចម្តេច ។ ភិក្ខុខះ ក្នុងសាសនានេះ ឃើញរូបដោយភ្នែកហើយ ជាអ្នកមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈា និងទោមនស្ស គប្បីជាប់តាមនូវបុគ្គលជាអ្នកមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយ

នោះ រក្សាចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក ។បេ។ ធុំក្លិនដោយច្រមុះ ។បេ។ លិទ្ធភក្សរសដោយអណ្តាត ។បេ។ ពាល់ត្រូវផ្សព្វដោយកាយ ។បេ។ ដឹងច្បាស់នូវធម៌ ដោយចិត្តហើយ ជាអ្នកមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈា និងទោមនស្ស គប្បីជាប់តាមនូវបុគ្គល ជាអ្នកមិនសង្រួមមនិន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមមនិន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមមនិន្ទ្រិយនោះ រក្សាមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ការថែទាំ គ្រប់គ្រង រក្សាសង្រួម នូវឥន្ទ្រិយទាំង ៦ នេះណា នេះហៅថា ភាពនៃបុគ្គលអ្នកមានទ្វារគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយ ។ ភិក្ខុ ជាអ្នកព្រមព្រៀង ។បេ។ ប្រកបព្រមដោយភាពនៃខ្លួន ជាអ្នកមានទ្វារគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយនេះ ព្រោះហេតុនោះ ទើបពោលថា មានទ្វារគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយ ។

[ ៣៥៤ ] ត្រង់ពាក្យថា អ្នកដឹងប្រមាណ ក្នុងភោជន អធិប្បាយថា ការដឹងប្រមាណ ក្នុងភោជនក៏មាន ការមិនដឹងប្រមាណ ក្នុងភោជនក៏មាន ។ បណ្តាធម៌ទាំងនោះ ការមិនដឹងប្រមាណ ក្នុងភោជន តើដូចម្តេច ។ ភិក្ខុខ្លះ ក្នុងសាសនានេះ មិនបានពិចារណាដោយឧបាយ ហើយបរិភោគអាហារ ដើម្បីលេង ដើម្បីស្រវឹង ដើម្បីប្រដាប់ ដើម្បីស្អិតស្អាង សេចក្តីមិនសន្តោស សេចក្តីមិនដឹងប្រមាណ សេចក្តីមិនពិចារណា ក្នុងភោជននោះណា នេះហៅថា ការមិនដឹងប្រមាណ ក្នុងភោជន ។ បណ្តាធម៌ទាំងនោះ ការដឹងប្រមាណ ក្នុងភោជន តើដូចម្តេច ។ ភិក្ខុខ្លះ ក្នុងសាសនានេះ ពិចារណាដោយឧបាយ

ហើយ បរិភោគអាហារ មិនមែនដើម្បីលេង មិនមែនដើម្បីស្រវឹង មិនមែនដើម្បីប្រដាប់ មិនមែនដើម្បីស្អិតស្អាង ( គឺបរិភោគ ) ដើម្បីតាំងនៅនៃកាយនេះ ដើម្បីញុំាងជីវិតឲ្យប្រព្រឹត្តទៅ ដើម្បីកម្ចាត់បង់សេចក្តីលំបាក ដើម្បីអនុគ្រោះព្រហ្មចារ្យ គឺអាត្មាអញ នឹងបន្ទោបង់វេទនាចាស់ផង នឹងញុំាងវេទនាថ្មី មិនឲ្យកើតឡើងផង ការត្រាច់ទៅក្តី សេចក្តីមិនមានទោស មានមិនប្រអូសកាយជាដើមក្តី កិរិយានៅជាសុខ ( ដោយឥរិយាបថទាំង ៤ ) ក្តី នឹងមានដល់អាត្មាអញ សេចក្តីសន្តោស សេចក្តីដឹងប្រមាណ សេចក្តីពិចារណាក្នុងភោជនទោះណា នេះហៅថា ការដឹងប្រមាណក្នុងភោជន ។ ភិក្ខុជាអ្នកព្រមព្រៀង ។បេ។ ប្រកបព្រមដោយសេចក្តីដឹងប្រមាណ ក្នុងភោជននេះ ព្រោះហេតុនោះ ទើបពោលថា អ្នកដឹងប្រមាណក្នុងភោជន ។

[ ៣៥៥ ] ចុះភិក្ខុជាអ្នកប្រកបរឿយៗ ក្នុងការព្យាយាម ជាគ្រឿងភ្ញាក់រឭក ក្នុងពេលមុនរាត្រី និងក្រោយរាត្រី តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ញុំាងចិត្តឲ្យស្អាត ចាកធម៌ទាំងឡាយដែលរាំង ដោយការដើរទៅមក ដោយការអង្គុយ អស់មួយថ្ងៃ ញុំាងចិត្តឲ្យស្អាត ចាកធម៌ទាំងឡាយដែលរាំង ដោយការដើរទៅមក ដោយការអង្គុយ អស់បឋមយាមនៃរាត្រី សម្រេចសីហសេយ្យា ដោយចំហៀងខាងស្តាំ អស់មជ្ឈិមយាមនៃរាត្រី តម្រួតជើងដោយជើង ជាអ្នកមានស្មារតី ដឹងខ្លួន ធ្វើទុកក្នុងចិត្ត ចំពោះឧដ្ឋានសញ្ញា ហើយក្រោកក្នុងបច្ឆិមយាមនៃរាត្រី ញុំាងចិត្តឲ្យស្អាត ចាកធម៌ទាំងឡាយដែលរាំង ដោយការដើរ ដោយការអង្គុយ ភិក្ខុជាអ្នកប្រកបរឿយៗ ក្នុងការ

ព្យាយាមជាគ្រឿងភ្ញាក់រឭក ក្នុងពេលមុនរាត្រី និងក្រោយរាត្រី យ៉ាងនេះឯង ។

[ ៣៥៦ ] ត្រង់ពាក្យថា ជាប់មិនដាច់ បានដល់ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សេចក្តីព្យាយាមត្រូវ ប្រព្រឹត្តទៅក្នុងចិត្ត ។ ពាក្យថា ចាស់ក្លា បានដល់ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការសង្កេតនូវធម៌ សេចក្តីយល់ត្រូវ ។

[ ៣៥៧ ] ត្រង់ពាក្យថា ប្រកបរឿយៗ ក្នុងការព្យាយាមចម្រើន នូវធម៌ទាំងឡាយ ជាចំណែកនៃការត្រាស់ដឹង មានសេចក្តីថា បណ្តាធម៌ទាំងនោះ ពួកធម៌ជាចំណែកនៃការត្រាស់ដឹង តើដូចម្តេច ។ ពោជ្ឈង្គ ៧ គឺសតិ-សម្ពោជ្ឈង្គ ធម្មវិចយសម្ពោជ្ឈង្គ វិរិយសម្ពោជ្ឈង្គ បីតិសម្ពោជ្ឈង្គ បស្សទ្ធិ-សម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គ ឧបេក្ខាសម្ពោជ្ឈង្គ នេះហៅថា ធម៌ជាចំណែកនៃការត្រាស់ដឹង ភិក្ខុគប់រក អប់រំ ធ្វើឲ្យច្រើនចំពោះពួកធម៌ ជាចំណែកនៃការត្រាស់ដឹងទាំងនេះ ព្រោះហេតុនោះ ទើបពោលថា ប្រកបរឿយៗ ក្នុងការព្យាយាម ចម្រើននូវធម៌ទាំងឡាយ ជាចំណែកនៃការត្រាស់ដឹង ។

[ ៣៥៨ ] ចុះភិក្ខុជាអ្នកធ្វើសេចក្តីដឹងខ្លួន ក្នុងការដើរទៅមុខ និងការដើរថយក្រោយ ធ្វើសេចក្តីដឹងខ្លួនក្នុងការក្រឡេកមើលទៅមុខ និងការក្រឡេកមើលទៅទិសផ្សេងៗ ធ្វើសេចក្តីដឹងខ្លួន ក្នុងការបត់ដៃ ជើង និងការលាតដៃជើង ធ្វើសេចក្តីដឹងខ្លួន ក្នុងការទ្រទ្រង់សង្ឃាដី បាត្រ និងចីវរ ធ្វើសេចក្តីដឹងខ្លួន ក្នុងការបរិភោគភោជន ការផឹកទឹក ការទំពាស៊ីខាទនីយៈ និងការ

ជញ្ជាប់ ( កេសជ្ជៈ ) ធ្វើសេចក្តីដឹងខ្លួន ក្នុងការបន្ទោបង់ឧច្ចារៈ បស្សាវៈ ធ្វើសេចក្តីដឹងខ្លួន ក្នុងការដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ឡើង និយាយ ឬការស្ងៀម តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ឈានដើរទៅមុខ មានស្មារតីដឹងខ្លួន ឈានថយក្រោយ មានស្មារតីដឹងខ្លួន ក្រឡេកមើលទៅមុខ មានស្មារតីដឹងខ្លួន ក្រឡេកមើលទៅទិសផ្សេងៗ មានស្មារតីដឹងខ្លួន បត់ដៃជើង មានស្មារតីដឹងខ្លួន លាតដៃជើង មានស្មារតីដឹងខ្លួន ជាអ្នកមានស្មារតី ធ្វើសេចក្តីដឹងខ្លួន ការទ្រទ្រង់សង្ឃាដី បាត្រ និងចីវរ ជាអ្នកមានស្មារតី ធ្វើសេចក្តីដឹងខ្លួន ក្នុងការបរិភោគ ការផឹក ការទំពាស៊ី ការជញ្ជាប់ ជាអ្នកមានស្មារតី ធ្វើសេចក្តីដឹងខ្លួន ក្នុងការបន្ទោបង់ឧច្ចារៈ បស្សាវៈ ជាអ្នកមានស្មារតី ធ្វើសេចក្តីដឹងខ្លួន ក្នុងការដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ឡើង និយាយ និងការស្ងៀម ។ ពាក្យថា មានស្មារតី សេចក្តីថា បណ្តាធម៌ទាំងនោះ ស្មារតីតើដូចម្តេច ។ ការរឭក ការនឹកឃើញ ការរឭកចំពោះ សតិ សេចក្តីរឭក សេចក្តីចាំបាន សេចក្តីមិនភ្លេច សេចក្តីមិនវង្វេង គឺសតិ សតិន្ទ្រិយ សតិពល សម្មាសតិណា នេះហៅថា ស្មារតី ។ ពាក្យថា អ្នកដឹងខ្លួន មានសេចក្តីថា បណ្តាធម៌ទាំងនោះ ការដឹងខ្លួន តើដូចម្តេច បញ្ញា ការដឹងច្បាស់ ការរំពឹង ការពិនិត្យ ការពិចារណាធម៌ ការកំណត់ ការកត់សម្គាល់ ការកំណត់ចំពោះ ភាពជាបណ្ឌិត ការឈ្លាសវៃ គំនិតដ៏ល្អិត គំនិតទូលាយ ការពិចារណាឃើញច្បាស់ បញ្ញាដូចជាផែនដី បញ្ញាធ្លុះធ្លាយ បញ្ញានំទៅ បញ្ញាឃើញវិសេស សេចក្តីដឹងខ្លួន សភាពដូចជាជន្ទញ គឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល កាំបិត

គឺបញ្ញា ប្រាសាទ គឺបញ្ញា ពន្លឺ គឺបញ្ញា រស្មី គឺបញ្ញា គ្រឿងបំភ្លឺ គឺបញ្ញា កែវ គឺបញ្ញា ការមិនវង្វេង ការពិចារណាធម៌ សេចក្តីឃើញត្រូវណា នេះ ហៅថា សេចក្តីដឹងខ្លួន ។ ភិក្ខុជាអ្នកព្រមព្រៀង ។បេ។ ប្រកបព្រមហើយ ដោយសតិនេះផង ដោយសម្បជញ្ញៈនេះផង ដោយប្រការដូច្នេះ ។ ភិក្ខុឈាន ដើរទៅមុខ មានស្មារតីដឹងខ្លួន ឈានថយក្រោយ មានស្មារតីដឹងខ្លួន ក្រឡេក មើលទៅមុខ មានស្មារតីដឹងខ្លួន ក្រឡេកមើលទៅទិសផ្សេងៗ មានសេចក្តីដឹង ខ្លួន បត់ដៃជើង មានស្មារតីដឹងខ្លួន លាតដៃជើង មានស្មារតីដឹងខ្លួន មានស្មារតី ធ្វើសេចក្តីដឹងខ្លួន ក្នុងការទ្រទ្រង់សង្ឃាដី បាត្រ និងចីវរ មានស្មារតី ធ្វើ សេចក្តីដឹងខ្លួន ក្នុងការបរិភោគ ការផឹក ការទំពាស៊ីខាទនីយៈ និងការ ជញ្ជាប់ មានស្មារតី ធ្វើសេចក្តីដឹងខ្លួន ក្នុងការបន្ទោបង់ឧច្ចារៈ បស្សាវៈ មានស្មារតី ធ្វើសេចក្តីដឹងខ្លួន ក្នុងការដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ ឡើង និយាយ ឬការស្ងៀម ។

[ ៣៥៩ ] ត្រង់ពាក្យថា ស្ងាត់ សេចក្តីថា បើសេនាសនៈ នៅក្នុងទីជិត តែសេនាសនៈនោះ មិនច្រឡូកច្រឡំដោយពួកគ្រហស្ថ និងពួកបព្វជិត ព្រោះ ហេតុនោះ ទីនោះ ឈ្មោះថា ស្ងាត់ ។ បើសេនាសនៈនៅក្នុងទីឆ្ងាយ តែ សេនាសនៈនោះ មិនច្រឡូកច្រឡំដោយពួកគ្រហស្ថ និងពួកបព្វជិត ព្រោះ ហេតុនោះ ទីនោះ ឈ្មោះថា ស្ងាត់ ។

[ ៣៦០ ] ត្រង់ពាក្យថា សេនាសនៈ គឺគ្រែ ឈ្មោះថា សេនាសនៈ តាំង ឈ្មោះថា សេនាសនៈ ពូក ឈ្មោះថា សេនាសនៈ ខ្នើយ ឈ្មោះថា

សេនាសនៈ វិហារ ឈ្មោះថា សេនាសនៈ អឌ្ឍយោគ ឈ្មោះថា សេនាសនៈ ប្រាសាទ ឈ្មោះថា សេនាសនៈ ប៉ម ឈ្មោះថា សេនាសនៈ រោង ឈ្មោះថា សេនាសនៈ ទីពួន ឈ្មោះថា សេនាសនៈ គុហា ឈ្មោះថា សេនាសនៈ គល់ឈើ ឈ្មោះថា សេនាសនៈ គុម្ពប្ញស្សី ក៏ឈ្មោះថា សេនាសនៈ ពុំនោះសោត ពួកភិក្ខុដើរចូលទៅក្នុងទីណា ទីទាំងអស់នុ៎ះ ក៏ឈ្មោះថា សេនាសនៈដែរ ។

[ ៣៦១ ] ត្រង់ពាក្យថា គប់រក គឺភិក្ខុ រមែងគប់រក ឈមទៅ ចូលចិត្ត អាស្រ័យ ពឹងពាក់ ចំពោះសេនាសនៈដ៏ស្ងាត់នេះ ព្រោះហេតុនោះ ទើបពោលថា គប់រក ។

[ ៣៦២ ] ត្រង់ពាក្យថា ព្រៃ គឺទីទាំងអស់នុ៎ះ ដែលចេញផុតអំពីសសរគោលខាងក្រៅ ឈ្មោះថា ព្រៃ ។

[ ៣៦៣ ] ត្រង់ពាក្យថា គល់ឈើ គឺគល់ឈើហ្នឹងឯង ។ ភ្នំ គឺភ្នំប្រាកដមែន ។ ជ្រោះ គឺជ្រោះប្រាកដមែន ។ គុហាភ្នំ គឺគុហាភ្នំប្រាកដមែន ។ ព្រៃស្មសាន គឺព្រៃស្មសានប្រាកដមែន ។ ទីវាល គឺទីវាលប្រាកដមែន ។ គំនរចំបើង គឺគំនរចំបើងប្រាកដមែន ។

[ ៣៦៤ ] ពាក្យថា ព្រៃញៀតស្បាត នុ៎ះជាឈ្មោះនៃសេនាសនៈទាំងឡាយដែលឆ្ងាយ ។ ពាក្យថា ព្រៃញៀតស្បាត នុ៎ះជាឈ្មោះនៃសេនាសនៈទាំងឡាយ ដែលជាដងព្រៃ ។ ពាក្យថា ព្រៃញៀតស្បាត នុ៎ះជាឈ្មោះនៃសេនាសនៈទាំងឡាយ ដែលគួរខ្លាច ។ ពាក្យថា ព្រៃញៀតស្បាត នុ៎ះជា

ឈ្មោះនៃសេនាសនៈទាំងឡាយ ដែលប្រកបដោយសេចក្ដីព្រឺរោម ។ ពាក្យថា ព្រៃញៀតស្បាត នុ៎ះជាឈ្មោះនៃសេនាសនៈទាំងឡាយ ដែលមានក្នុងទីបំផុត ។ ពាក្យថា ព្រៃញៀតស្បាត នុ៎ះជាឈ្មោះនៃសេនាសនៈទាំងឡាយ ដែលមិនមែនជាឧបចារៈរបស់មនុស្ស ។ ពាក្យថា ព្រៃញៀតស្បាត នុ៎ះជាឈ្មោះនៃសេនាសនៈទាំងឡាយ ដែលបុគ្គលសម្ងំនៅបានដោយក្រ ។

[ ៣៦៥ ] ត្រង់ពាក្យថា ទីមិនមានសំឡេង គឺថា បើសេនាសនៈនៅក្នុងទីជិត តែសេនាសនៈនោះ មិនច្រឡូកច្រឡំដោយពួកគ្រហស្ថ និងពួកបព្វជិត ព្រោះហេតុនោះ ទីនោះ ឈ្មោះថា ទីមិនមានសំឡេង ។ បើសេនាសនៈនៅក្នុងទីឆ្ងាយ តែសេនាសនៈនោះ មិនច្រឡូកច្រឡំដោយពួកគ្រហស្ថ និងពួកបព្វជិត ព្រោះហេតុនោះ ទីនោះឈ្មោះថា ទីមិនមានសំឡេង ។

[ ៣៦៦ ] ត្រង់ពាក្យថា ទីមិនគឹកកង គឺទីណាមិនមានសំឡេង ទីនោះឈ្មោះថា ទីមិនគឹកកង ទីណាមិនគឹកកង ទីនោះ ឈ្មោះថា ទីប្រាសចាកខ្យល់ដែលកើតអំពីសរីរៈនៃជន ទីណាដែលប្រាសចាកខ្យល់ កើតអំពីសរីរៈនៃជន ទីនោះ ឈ្មោះថា ទីស្ងាត់កំបាំងរបស់មនុស្ស ទីណាដែលស្ងាត់កំបាំងរបស់មនុស្ស ទីនោះ ឈ្មោះថា ទីសមគួរដល់ការពួនសម្ងំ ។

[ ៣៦៧ ] ត្រង់ពាក្យថា ទៅកាន់ព្រៃក្ដី ទៅកាន់ម្លប់ឈើក្ដី ទៅកាន់ផ្ទះស្ងាត់ក្ដី គឺភិក្ខុជាអ្នកនៅក្នុងព្រៃក្ដី នៅក្រោមម្លប់ឈើក្ដី នៅក្នុងផ្ទះស្ងាត់ក្ដី ។

[ ៣៦៨ ] ត្រង់ពាក្យថា អង្គុយផ្គត់ភ្នែន គឺភិក្ខុជាអ្នកអង្គុយផ្គត់ភ្នែន ។

[ ៣៦៩ ] ត្រង់ពាក្យថា តាំងកាយឲ្យត្រង់ គឺភិក្ខុជាអ្នកមានកាយត្រង់

ស្ថិតនៅ តម្កល់នៅមាំមួន ។

[ ៣៧០ ] ត្រង់ពាក្យថា តម្កល់សតិឲ្យមានមុខឆ្ពោះទៅរក ( កម្មដ្ឋាន ) សេចក្ដីថា បណ្ដាធម៌ទាំងនោះ សតិ តើដូចម្ដេច ។ ការរឭក ការនឹកឃើញ ។បេ។ សេចក្ដីរឭកត្រូវណា នេះហៅថា សតិ សតិនេះ ដែលបុគ្គលតម្កល់ទុកហើយ តាំងទុកល្អហើយ ត្រង់ទីបំផុតនៃច្រមុះក្ដី ត្រង់និមិត្តនៃមាត់ក្ដី ព្រោះហេតុនោះ ទើបពោលថា តម្កល់សតិឲ្យមានមុខឆ្ពោះទៅរក ( កម្មដ្ឋាន ) ។

[ ៣៧១ ] ត្រង់ពាក្យថា លះបង់អភិជ្ឈាក្នុងលោក មានសេចក្ដីថា បណ្ដាធម៌ទាំងនោះ អភិជ្ឈា តើដូចម្ដេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្តណា នេះហៅថា អភិជ្ឈា ។ បណ្ដាធម៌ទាំងនោះ លោក តើដូចម្ដេច ។ ឧបាទានក្ខន្ធទាំង ៥ ឈ្មោះថា លោក នេះហៅថា លោក ។ អភិជ្ឈានេះ ជាធម្មជាតស្ងប់ម្ងាប់ រលត់ ខ្ចាត់ចេញ វិនាស សាបសូន្យ ខូតខាត ហិនហោច រីង ស្ងួត ធ្វើឲ្យអស់ទៅក្នុងលោកនេះ ព្រោះហេតុនោះ ទើបពោលថា លះបង់អភិជ្ឈាក្នុងលោក ។

[ ៣៧២ ] ត្រង់ពាក្យថា មានចិត្តប្រាសចាកអភិជ្ឈា មានសេចក្ដីថា បណ្ដាធម៌ទាំងនោះ ចិត្ត តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា ចិត្ត ចិត្តនេះ ជាធម្មជាតមានអភិជ្ឈាទៅប្រាសហើយ ព្រោះហេតុនោះ ទើបពោលថា មានចិត្តប្រាសចាកអភិជ្ឈា ។

[ ៣៧៣ ] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺសម្រេច ប្រព្រឹត្ត រក្សា

រស់នៅ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ត្រាច់ទៅ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[ ៣៧៤ ] ត្រង់ពាក្យថា ជម្រះចិត្តឲ្យស្អាតចាកអភិជ្ឈា មានសេចក្ដីថា បណ្ដាធម៌ទាំងនោះ អភិជ្ឈា តើដូចម្ដេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងណានៃចិត្ត នេះហៅថា អភិជ្ឈា ។ បណ្ដាធម៌ទាំងនោះ ចិត្ត តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា ចិត្ត ។ ភិក្ខុញ៉ាំងចិត្តនេះឲ្យស្អាត ឲ្យបរិសុទ្ធ ឲ្យផូរផង់ ឲ្យរួច ឲ្យរួចស្រឡះ ឲ្យរបូតចេញ ចាកអភិជ្ឈានេះ ព្រោះហេតុនោះ ទើបពោលថា ជម្រះចិត្តឲ្យស្អាតចាកអភិជ្ឈា ។

[ ៣៧៥ ] ត្រង់ពាក្យថា លះបង់ព្យាបាទ និងសេចក្ដីប្រទូស្ត អធិប្បាយថា ព្យាបាទក៏មាន សេចក្ដីប្រទូស្តក៏មាន ។ បណ្ដាធម៌ទាំងនោះ ព្យាបាទ តើដូចម្ដេច ។ សេចក្ដីគុំកួន ចងគំនុំ ថ្នាំងថ្នាក់ អាក់អន់ កម្រើក ញាប់ញ័រ កម្រើកខ្លាំង ខឹង ខឹងខ្លាំង ខឹងខ្លាំងក្រៃពេកនៃចិត្ត ចង្អៀតចិត្ត ប្រទូស្តក្នុងចិត្ត ក្រោធ អាការក្រោធ ភាពក្រោធ ខឹង អាការខឹង ភាពខឹង ចង្អៀតចិត្ត អាការចង្អៀតចិត្ត ភាពចង្អៀតចិត្ត ស្រពន់ចិត្ត អាក់អន់ចិត្ត ភាពនៃចិត្តកាចសេចក្ដីខឹង ភាពនៃចិត្តមិនត្រេកអរណា នេះហៅថា ព្យាបាទ ។ បណ្ដាធម៌ទាំងនោះ សេចក្ដីប្រទូស្ត តើដូចម្ដេច ។ សេចក្ដីព្យាបាទ គឺសេចក្ដីប្រទូស្ត សេចក្ដីប្រទូស្ត គឺសេចក្ដីព្យាបាទ ។ ព្យាបាទនេះផង សេចក្ដីប្រទូស្តនេះផង ជាធម៌ស្ងប់រម្ងាប់ រលត់ ខ្ចាត់ចេញ វិនាស សាបសូន្យ ខូចខាត ហិនហោច

រឹង ស្ងួត ធ្វើឲ្យអស់ទៅ ព្រោះហេតុនោះ ទើបពោលថា លះព្យាបាទ និង សេចក្ដីប្រទូស្ដ ។

[ ៣៧៦ ] ត្រង់ពាក្យថា មានចិត្តមិនព្យាបាទ សេចក្ដីថា បណ្ដាធម៌ ទាំងនោះ ចិត្ត តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា ចិត្ត ចិត្តនេះ ជាធម្មជាតមិនគុំកួន ព្រោះហេតុនោះ ទើបពោលថា មានចិត្តមិនព្យាបាទ ។

[ ៣៧៧ ] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺសម្រេច ។បេ។ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[ ៣៧៨ ] ត្រង់ពាក្យថា ជម្រះចិត្តឲ្យស្អាតចាកព្យាបាទ និងសេចក្ដី ប្រទូស្ដ អធិប្បាយថា ព្យាបាទក៏មាន សេចក្ដីប្រទូស្ដក៏មាន ។ បណ្ដាធម៌ទាំង នោះ ព្យាបាទ តើដូចម្ដេច ។ សេចក្ដីគុំកួន ចងគំនុំ ថ្នាំងថ្នាក់ អាក់អន់ កម្រើក ញាប់ញ័រ កម្រើកខ្លាំង ខឹង ខឹងខ្លាំង ខឹងខ្លាំងក្រៃពេកនៃចិត្ត ចង្អៀតចិត្ត ប្រទូស្ដ ក្នុងចិត្ត ក្រោធ អាការក្រោធ ភាពក្រោធ ខឹង អាការខឹង ភាពខឹង ចង្អៀត ចិត្ត អាការចង្អៀតចិត្ត ភាពចង្អៀតចិត្ត ស្រពន់ចិត្ត អាក់អន់ចិត្ត ភាពនៃចិត្ត កាច សេចក្ដីខឹង ភាពនៃចិត្តមិនត្រេកអរណា នេះហៅថា ព្យាបាទ ។ បណ្ដា ធម៌ទាំងនោះ សេចក្ដីប្រទូស្ដ តើដូចម្ដេច ។ សេចក្ដីព្យាបាទ គឺសេចក្ដីប្រទូស្ដ សេចក្ដីប្រទូស្ដ គឺសេចក្ដីព្យាបាទ ។ បណ្ដាធម៌ទាំងនោះ ចិត្ត តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើត អំពីវិញ្ញាណនោះណា នេះហៅថា ចិត្ត ។ កិច្ចញុំាងចិត្តនេះឲ្យស្អាត ឲ្យបរិសុទ្ធ

ឲ្យផូរផង់ ឲ្យរួច ឲ្យរួចស្រឡះ ឲ្យរបូតចេញចាកព្យាបាទ និងសេចក្ដីប្រទូស្ត ព្រោះហេតុនោះ ទើបពោលថា ជម្រះចិត្តឲ្យស្អាតចាកព្យាបាទ និងសេចក្ដីប្រទូស្ត ។

[ ៣៧៩ ] ត្រង់ពាក្យថា លះបង់ថីនៈ និងមិទ្ធៈ សេចក្ដីថា ថីនៈក៏មាន មិទ្ធៈក៏មាន ។ បណ្ដាធម៌ទាំងនោះ ថីនៈ តើដូចម្ដេច ។ ភាពនៃចិត្តមិនស្រួល ភាពនៃចិត្តមិនគួរដល់ការនៃកម្ម អាការក្រាញ អាការកៀចក្រាញ ការរួញរា អាការរួញរា ភាពនៃចិត្តរួញរា ការរួញថយ អាការរួញថយ ភាពនៃចិត្តរួញថយណា នេះហៅថា ថីនៈ ។ បណ្ដាធម៌ទាំងនោះ មិទ្ធៈ តើដូចម្ដេច ។ ភាពនៃកាយមិនស្រួល ភាពនៃកាយមិនគួរដល់ការនៃកម្ម សេចក្ដីងងុយ ការងោកងក់ ការលេតសូន្យខាងក្នុង ការជ្រប់ចុះ ការលក់ ការស្រពោនចុះ ការលក់ស៊ប់ អាការលក់ ភាពនៃការលក់ណា នេះហៅថា មិទ្ធៈ ។ ថីនៈនេះផង មិទ្ធៈនេះផង ជាធម្មជាតស្ងប់រម្ងាប់ រលត់ ខ្ចាត់ចេញ វិនាស សាបសូន្យ ខូចខាត ហិនហោច រីង ស្ងួត ធ្វើឲ្យអស់ទៅ ព្រោះហេតុនោះ ទើបពោលថា លះបង់ថីនៈ និងមិទ្ធៈ ។

[ ៣៨០ ] ពាក្យថា ជាអ្នកប្រាសចាកថីនៈ និងមិទ្ធៈ ដូច្នេះ ព្រោះភាពនៃថីនៈ និងមិទ្ធៈនោះ លោកលះបង់ ខ្ចាក់ចេញ រួចស្រឡះ បន្សាត់បង់ រលាស់ចេញ បន្សាត់បង់ ទាំងរលាស់ចេញអស់ហើយ ព្រោះហេតុនោះ ទើបពោលថា ជាអ្នកប្រាសចាកថីនៈ និងមិទ្ធៈ ។ ពាក្យថា សម្រេចឥរិយាបថ ។បេ។ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[ ៣៨១ ] ត្រង់ពាក្យថា មានសេចក្តីសម្គាល់ជាពន្លឺ សេចក្តីថា បណ្តាពាក្យទាំងនោះ សេចក្តីសម្គាល់ តើដូចម្តេច ។ សញ្ញា អាការសម្គាល់ ភាពនៃការសម្គាល់ណា នេះហៅថា សេចក្តីសម្គាល់ សញ្ញានេះ ជាពន្លឺដែលរបើកហើយ បរិសុទ្ធ ផូរផង់ ព្រោះហេតុនោះ ទើបពោលថា មានសេចក្តីសម្គាល់ជាពន្លឺ ។

[ ៣៨២ ] ត្រង់ពាក្យថា ជាអ្នកមានសតិ និងសម្បជញ្ញៈ សេចក្តីថា បណ្តាធម៌ទាំងនោះ សតិ តើដូចម្តេច ។ ការរឭក ការនឹកឃើញ ។បេ។ ការរឭកត្រូវណា នេះហៅថា សតិ ។ បណ្តាធម៌ទាំងនោះ សម្បជញ្ញៈ តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការសង្កេតនូវធម៌ ការយល់ត្រូវណា នេះហៅថា សម្បជញ្ញៈ ។ ភិក្ខុជាអ្នកព្រមព្រៀង ។បេ។ ប្រកបព្រមដោយសតិនេះផង ដោយសម្បជញ្ញៈនេះផង ព្រោះហេតុនោះ ទើបពោលថា អ្នកមានសតិ និងសម្បជញ្ញៈ ។

[ ៣៨៣ ] ត្រង់ពាក្យថា ជម្រះចិត្តឲ្យស្អាត ចាកថីនៈ និងមិទ្ធៈ សេចក្តីថា ថីនៈក៏មាន មិទ្ធៈក៏មាន ។ បណ្តាធម៌ទាំងនោះ ថីនៈ តើដូចម្តេច ។ ភាពនៃចិត្តមិនស្រួល ។បេ។ ភាពនៃចិត្តរួញថយណា នេះហៅថា ថីនៈ ។ បណ្តាធម៌ទាំងនោះ មិទ្ធៈ តើដូចម្តេច ។ ភាពនៃកាយមិនស្រួល ។បេ។ ភាពនៃការលក់ណា នេះហៅថា មិទ្ធៈ ។ បណ្តាពាក្យទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា ចិត្ត ។ ភិក្ខុញុំាងចិត្តនេះឲ្យស្អាត ឲ្យបរិសុទ្ធ

ឲ្យផូរផង់ ឲ្យរួច ឲ្យរួចស្រឡះ ឲ្យរបូតចេញ ចាកថីនៈ និងមិទ្ធៈនេះ ព្រោះហេតុនោះ ទើបពោលថា ជម្រះចិត្តឲ្យស្អាត ចាកថីនៈ និងមិទ្ធៈ ។

[ ៣៨៤ ] ត្រង់ពាក្យថា លះបង់ឧទ្ធច្ចៈ និងកុក្កុច្ចៈ សេចក្តីថា ឧទ្ធច្ចៈក៏មាន កុក្កុច្ចៈក៏មាន ។ បណ្តាធម៌ទាំងនោះ ឧទ្ធច្ចៈ តើដូចម្តេច ។ សេចក្តីអណ្តែតអណ្តូងនៃចិត្ត ការមិនស្ងប់រម្ងាប់ ការរាយមាយនៃចិត្ត ភាពនៃចិត្តភ្ញាក់ផ្អើលណា នេះហៅថា ឧទ្ធច្ចៈ ។ បណ្តាធម៌ទាំងនោះ កុក្កុច្ចៈ តើដូចម្តេច ។ សេចក្តីសម្គាល់ថាគួរ ក្នុងវត្ថុដែលមិនគួរ សម្គាល់ថាមិនគួរ ក្នុងវត្ថុដែលគួរ សម្គាល់ថាជាទោស ក្នុងវត្ថុដែលមិនមានទោស សម្គាល់ថាមិនមានទោស ក្នុងវត្ថុដែលជាទោស សេចក្តីរពឹស អាការរពឹស ភាពនៃចិត្តរពឹស សេចក្តីក្តៅក្រហាយនៃចិត្ត សេចក្តីសាំញុាំនៃចិត្តណា នេះហៅថា កុក្កុច្ចៈ ។ ឧទ្ធច្ចៈនេះផង កុក្កុច្ចៈនេះផង ជាធម៌ស្ងប់រម្ងាប់ រលត់ ខ្ជាត់ចេញ វិនាស សាបសូន្យ ខូចខាត ហិនហោច រីង ស្ងួត ធ្វើឲ្យអស់ទៅ ព្រោះហេតុនោះ ទើបពោលថា លះបង់ឧទ្ធច្ចៈ និងកុក្កុច្ចៈ ។

[ ៣៨៥ ] ពាក្យថា ជាអ្នកមិនរាយមាយ ដូច្នេះ ព្រោះភាពនៃឧទ្ធច្ចៈ និងកុក្កុច្ចៈនោះ លោកលះបង់ ខ្ជាក់ចេញ រួចស្រឡះ បន្សាត់បង់ រលាស់ចោល ព្រោះហេតុនោះ ទើបពោលថា ជាអ្នកមិនរាយមាយ ។

[ ៣៨៦ ] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺសម្រេច ។បេ។ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[ ៣៨៧ ] ត្រង់ពាក្យថា ខាងក្នុងសន្តាន បានដល់ ធម្មជាតដែលជាក់

ច្បាស់ខាងក្នុងសន្ដាន ។ ពាក្យថា មានចិត្តស្ងប់រម្ងាប់ សេចក្ដីថា បណ្ដាពាក្យទាំងនោះ ចិត្ត តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា ចិត្ត ចិត្តនេះ ជាធម្មជាតស្ងប់រម្ងាប់ រលត់ ខ្ចាត់ចេញខាងក្នុងសន្ដាន ព្រោះហេតុនោះ ទើបពោលថា មានចិត្តស្ងប់រម្ងាប់ខាងក្នុងសន្ដាន ។

[ ៣៨៨ ] ត្រង់ពាក្យថា ជម្រះចិត្តឲ្យស្អាតចាកឧទ្ធច្ចៈ និងកុក្កុច្ចៈ សេចក្ដីថា ឧទ្ធច្ចៈក៏មាន កុក្កុច្ចៈក៏មាន ។ បណ្ដាធម៌ទាំងនោះ ឧទ្ធច្ចៈ តើដូចម្ដេច ។ សេចក្ដីអណ្ដែតអណ្ដូងនៃចិត្ត ការមិនស្ងប់រម្ងាប់ ការរាយមាយនៃចិត្ត ភាពនៃចិត្តភ្ញាក់ផ្អើលណា នេះហៅថា ឧទ្ធច្ចៈ ។ បណ្ដាធម៌ទាំងនោះ កុក្កុច្ចៈ តើដូចម្ដេច ។ សេចក្ដីសម្គាល់ថាគួរ ក្នុងវត្ថុដែលមិនគួរ ។បេ។ សេចក្ដីសាំញ៉ាំនៃចិត្តណា នេះហៅថា កុក្កុច្ចៈ ។ បណ្ដាធម៌ទាំងនោះ ចិត្ត តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោវិញ្ញាណ-ធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា ចិត្ត ។ ភិក្ខុញុំាងចិត្តនេះ ឲ្យស្អាត ឲ្យបរិសុទ្ធ ឲ្យផូរផង់ ឲ្យរួច ឲ្យរួចស្រឡះ ឲ្យរបូតចេញចាកឧទ្ធច្ចៈ និងកុក្កុច្ចៈនេះ ព្រោះហេតុនោះ ទើបពោលថា ជម្រះចិត្តឲ្យស្អាតចាកឧទ្ធច្ចៈ និងកុក្កុច្ចៈ ។

[ ៣៨៩ ] ត្រង់ពាក្យថា លះបង់វិចិកិច្ឆា សេចក្ដីថា បណ្ដាធម៌ទាំងនោះ វិចិកិច្ឆា តើដូចម្ដេច ។ ការងឿងឆ្ងល់ អាការងឿងឆ្ងល់ ភាពងឿងឆ្ងល់ ការប្រាសចាកគំនិត ការសន្ទិះសង្ស័យ ការកន្ត្រែកចិត្ត ការបែកផ្លូវពីរ ការសង្ស័យ

ការកាន់យកចំណែកច្រើនយ៉ាង ការអន្ទីអន្ទែ ការអល់អែក ការមិនកាន់យកជាកំណត់ ភាពនៃចិត្តរឹងត្អឹង ការរសេមរសាមនៃចិត្តណា នេះហៅថា វិចិកិច្ឆា ។ វិចិកិច្ឆានេះ ជាធម្មជាតស្ងប់រម្ងាប់ រលត់ ខ្ចាត់ចេញ វិនាសសាបសូន្យ ខូចខាត ហិនហោច រីង ស្ងួត ធ្វើឲ្យអស់ទៅ ព្រោះហេតុនោះ ទើបពោលថា លះបង់វិចិកិច្ឆា ។

[ ៣៩០ ] ត្រង់ពាក្យថា ជាអ្នកឆ្លងផុតចាកវិចិកិច្ឆា គឺភិក្ខុជាអ្នកឆ្លង ឆ្លងឡើង ឆ្លងកាត់ នូវវិចិកិច្ឆានេះ ហើយទៅកាន់ត្រើយ ដល់ត្រើយ ព្រោះហេតុនោះ ទើបពោលថា ជាអ្នកឆ្លងផុតចាកវិចិកិច្ឆា ។

[ ៣៩១ ] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺសម្រេច ។បេ។ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[ ៣៩២ ] ត្រង់ពាក្យថា អ្នកមិនមានសេចក្តីងឿងឆ្ងល់ ក្នុងពួកធម៌ជាកុសល គឺភិក្ខុមិនងឿងឆ្ងល់ មិនសន្ទិះ ក្នុងពួកធម៌ជាកុសល ដោយវិចិកិច្ឆានេះ គឺជាអ្នកមិនសង្ស័យ ឥតមានសេចក្តីងឿងឆ្ងល់ ប្រាសចាកសេចក្តីសង្ស័យ ព្រោះហេតុនោះ ទើបពោលថា អ្នកមិនមានសេចក្តីងឿងឆ្ងល់ក្នុងពួកធម៌ជាកុសល ។

[ ៣៩៣ ] ត្រង់ពាក្យថា ជម្រះចិត្តឲ្យស្អាតចាកវិចិកិច្ឆា សេចក្តីថា បណ្តាធម៌ទាំងនោះ វិចិកិច្ឆា តើដូចម្តេច ។ ការងឿងឆ្ងល់ អាការងឿងឆ្ងល់ ភាពនៃសេចក្តីងឿងឆ្ងល់ ។បេ។ ភាពនៃចិត្តរឹងត្អឹង ការរសេមរសាមនៃចិត្តណា នេះហៅថា វិចិកិច្ឆា ។ បណ្តាធម៌ទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត

សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា ចិត្ត ។ កិច្ចញុំាងចិត្តនេះឲ្យស្អាត ឲ្យបរិសុទ្ធ ឲ្យផូរផង់ ឲ្យរួច ឲ្យរួចស្រឡះ ឲ្យរបូតចេញចាកវិចិកិច្ឆានេះ ព្រោះហេតុនោះ ទើបពោលថា ជម្រះចិត្តឲ្យស្អាតចាកវិចិកិច្ឆា ។

[ ៣៩៤ ] ត្រង់ពាក្យថា លះបង់នីវរណៈទាំង ៥ នេះ សេចក្តីថា នីវរណៈទាំង ៥ នេះ ជាធម៌ស្ងប់រម្ងាប់ រលត់ ខ្ចាត់ចេញ វិនាស សាបសូន្យ ខូចខាត ហិនហោច រីង ស្ងួត ធ្វើឲ្យអស់ទៅ ព្រោះហេតុនោះ ទើបពោលថា លះបង់នីវរណៈទាំង ៥ នេះ ។

[ ៣៩៥ ] ត្រង់ពាក្យថា ជាគ្រឿងសៅហ្មងនៃចិត្ត គឺនីវរណៈទាំង ៥ នេះ ជាគ្រឿងសៅហ្មងនៃចិត្ត ។

[ ៣៩៦ ] ត្រង់ពាក្យថា ជាគ្រឿងធ្វើបញ្ញាឲ្យមានកម្លាំងថយ គឺបញ្ញាដែលមិនទាន់កើត ក៏មិនកើតឡើងផង បញ្ញាដែលកើតឡើងហើយ ក៏រលត់ទៅវិញផង ព្រោះនីវរណៈទាំង ៥ នេះ ព្រោះហេតុនោះ ទើបពោលថា ជាគ្រឿងធ្វើបញ្ញាឲ្យមានកម្លាំងថយ ។

[ ៣៩៧ ] ត្រង់ពាក្យថា ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ សេចក្តីថា បណ្តាធម៌ទាំងនោះ កាមទាំងឡាយ តើដូចម្តេច ។ ឆន្ទៈ ឈ្មោះថា កាម រាគៈ ឈ្មោះថា កាម ឆន្ទរាគៈ ឈ្មោះថា កាម ការត្រិះរិះ ឈ្មោះថា កាម រាគៈ ឈ្មោះថា កាម ការត្រិះរិះ និងរាគៈ ឈ្មោះថា កាម កិលេសទាំងនេះ ហៅថា កាម ។ បណ្តាធម៌ទាំងនោះ ពួកធម៌ជា

អកុសល តើដូចម្ដេច ។ កាមច្ឆន្ទៈ ព្យាបាទ ថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ចៈ វិចិកិច្ឆា ពួកកិលេសទាំងនេះ ហៅថា អកុសលធម៌ ។ ភិក្ខុជាអ្នកស្ងាត់ចាកកាមទាំងនេះផង ចាកអកុសលធម៌ទាំងនេះផង ព្រោះហេតុនោះ ទើបពោលថា ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ដោយប្រការដូច្នេះ ។

[ ៣៩៨ ] ត្រង់ពាក្យថា ប្រកបដោយវិតក្ក ប្រកបដោយវិចារ មានសេចក្ដីថា វិតក្កក៏មាន វិចារក៏មាន ។ បណ្ដាធម៌ទាំងនោះ វិតក្ក តើដូចម្ដេច ។ ការត្រិះរិះ ការរិះគិត តម្រិះ រំពឹង ជញ្ជឹង ការលើកឡើងនូវចិត្ត សម្មាសង្កប្បណា នេះហៅថា វិតក្ក ។ បណ្ដាធម៌ទាំងនោះ វិចារ តើដូចម្ដេច ។ ការត្រួតត្រា ពិចារណា ពិចារណារឿយៗ ពិនិត្យមើល សម្រឹងរឿយៗ នៃចិត្ត សង្កេតឃើញរឿយៗ នៃចិត្តណា នេះហៅថា វិចារ ។ ភិក្ខុជាអ្នកព្រមព្រៀង ។បេ។ ប្រកបព្រមដោយវិតក្កនេះផង ដោយវិចារនេះផង ព្រោះហេតុនោះ ទើបពោលថា ប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយប្រការដូច្នេះ ។

[ ៣៩៩ ] ត្រង់ពាក្យថា កើតក្នុងវិវេក គឺវិតក្ក វិចារ បីតិ សុខ ឯកគ្គតានៃចិត្ត ធម៌ទាំងនោះកើត ដុះដាល លូតលាស់ ចម្រើន កើតប្រាកដក្នុងវិវេកនេះ ព្រោះហេតុនោះ ទើបពោលថា កើតក្នុងវិវេក ។

[ ៤០០ ] ត្រង់ពាក្យថា បីតិ និងសុខ សេចក្ដីថា បីតិក៏មាន សុខក៏មាន ។ បណ្ដាធម៌ទាំងនោះ បីតិ តើដូចម្ដេច ។ សេចក្ដីឆ្អែតចិត្ត រីករាយសប្បាយ ស្រស់ស្រាយ ញញឹម ស្រស់បស់ ត្រេកអរ អណ្ដែតអណ្ដូងភាពនៃចិត្តត្រេកអរណា នេះហៅថា បីតិ ។ បណ្ដាធម៌ទាំងនោះ សុខ តើ

ដូចម្ដេច ។ សេចក្ដីត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីសុខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ជាទីត្រេកអរ ជាសុខ ដែលកើតអំពីចេតោសម្ផស្ស សុខវេទនាជាទីត្រេកអរ ដែលកើតអំពីចេតោសម្ផស្សណា នេះ ហៅថា សុខ ។ សេចក្ដីសុខនេះ ជាធម្មជាតប្រព្រឹត្តទៅជាមួយ កើតជាមួយ ប្រឡំ ប្រកបដោយបីតិនេះ ព្រោះហេតុនោះ ទើបពោលថា បីតិ និងសុខ ។

[ ៤០១ ] ត្រង់ពាក្យថា បឋម គឺទីមួយ ដោយលំដាប់នៃកិរិយារាប់បុគ្គលរមែងចូលកាន់ឈានទីមួយនេះ ព្រោះហេតុនោះ ទើបពោលថា បឋម ។

[ ៤០២ ] ត្រង់ពាក្យថា ឈាន គឺវិតក្ក វិចារ បីតិ សុខ ឯកគ្គតានៃចិត្ត ។

[ ៤០៣ ] ត្រង់ពាក្យថា ចូល គឺការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការបំពេញនូវបឋមជ្ឈាន។

[ ៤០៤ ] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺសម្រេច ។បេ។ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[ ៤០៥ ] ត្រង់ពាក្យថា ព្រោះរម្ងាប់នូវវិតក្ក និងវិចារ សេចក្ដីថា វិតក្កក៏មាន វិចារក៏មាន ។ បណ្ដាធម៌ទាំងនោះ វិតក្ក តើដូចម្ដេច ។ ការត្រិះរិះ ការរិះគិត ។បេ។ សម្មាសង្កប្បណា នេះហៅថា វិតក្ក ។ បណ្ដាធម៌ទាំងនោះ វិចារ តើដូចម្ដេច ។ ការត្រួតត្រា ពិចារណា ពិចារណារឿយៗ ពិនិត្យមើល សម្រឹងរឿយៗ នៃចិត្ត សង្កេតឃើញរឿយៗ នៃចិត្តណា នេះ ហៅថា វិចារ ។ វិតក្កនេះផង វិចារនេះផង ជាធម៌ស្ងប់រម្ងាប់ រលត់ ខ្ចាត់

ចេញ វិនាស សាបសូន្យ ខូចខាត ហិនហោច រីង ស្ងួត ធ្វើឲ្យអស់ទៅ ព្រោះហេតុនោះ ទើបពោលថា ព្រោះរម្ងាប់នូវវិតក្ក និងវិចារ ដោយប្រការដូច្នេះ ។

[ ៤០៦ ] ត្រង់ពាក្យថា ខាងក្នុងសន្តាន គឺជាក់ច្បាស់ខាងក្នុងសន្តាន ។ ពាក្យថា ជ្រះថ្លាស៊ប់ គឺសទ្ធា អាការជឿ អាការចុះចិត្តស៊ប់ សេចក្តីជ្រះថ្លាក្រៃលែង ។

[ ៤០៧ ] ត្រង់ពាក្យថា មានសភាពជាចិត្តខ្ពស់ឯក បានដល់ ការស្ថិតនៅនៃចិត្ត ។បេ។ សម្មាសមាធិ ។

[ ៤០៨ ] ត្រង់ពាក្យថា មិនមានវិតក្ក មិនមានវិចារ សេចក្តីថា វិតក្កក៏មាន វិចារក៏មាន ។ បណ្តាធម៌ទាំងនោះ វិតក្ក តើដូចម្តេច ។ ការត្រិះរិះ ការរិះគិត ។បេ។ សម្មាសង្កប្បណា នេះហៅថា វិតក្ក ។ បណ្តាធម៌ទាំងនោះ វិចារ តើដូចម្តេច ។ ការត្រួតត្រា ពិចារណា ពិចារណារឿយៗ ពិនិត្យមើលសម្រឹងរឿយៗ នៃចិត្ត សង្កេតឃើញរឿយៗ នៃចិត្តណា នេះហៅថា វិចារ ។ វិតក្កនេះផង វិចារនេះផង ជាធម៌ស្ងប់រម្ងាប់ រលត់ ខ្ចាត់ចេញ វិនាស សាបសូន្យ ខូចខាត ហិនហោច រីង ស្ងួត ធ្វើឲ្យអស់ទៅ ព្រោះហេតុនោះ ទើបពោលថា មិនមានវិតក្ក មិនមានវិចារ ដោយប្រការដូច្នេះ ។

[ ៤០៩ ] ត្រង់ពាក្យថា កើតក្នុងសមាធិ គឺសេចក្តីជ្រះថ្លាស៊ប់ បីតិ សុខ ឯកគ្គតានៃចិត្ត ធម៌ទាំងនោះ កើត ដុះដាល លូតលាស់ ចម្រើន កើតប្រាកដហើយ ក្នុងសមាធិនេះ ព្រោះហេតុនោះ ទើបពោលថា កើតក្នុងសមាធិ ។

[ ៤១០ ] ត្រង់ពាក្យថា បីតិ និងសុខ សេចក្ដីថា បីតិក៏មាន សុខក៏មាន ។ បណ្ដាធម៌ទាំងនោះ បីតិ តើដូចម្ដេច ។ បីតិ ( សេចក្ដីឆ្អែតចិត្ត ) ការរីករាយ ។បេ។ ភាពនៃចិត្តត្រេកអរណា នេះហៅថា បីតិ ។ បណ្ដាធម៌ទាំងនោះ សុខ តើដូចម្ដេច ។ សេចក្ដីត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សុខវេទនា នេះហៅថា សុខ ។ សុខនេះ ជាធម្មជាតប្រព្រឹត្តទៅជាមួយ កើតជាមួយ ប្រឡំ ប្រកបដោយបីតិនេះ ព្រោះហេតុនោះ ទើបពោលថា បីតិ និងសុខ ។

[ ៤១១ ] ត្រង់ពាក្យថា ទុតិយៈ គឺគម្រប់ពីរ ដោយលំដាប់ នៃកិរិយារាប់ បុគ្គលចូលកាន់ឈានទីពីរនេះ ព្រោះហេតុនោះ ទើបឈ្មោះថា ទុតិយៈ ។

[ ៤១២ ] ត្រង់ពាក្យថា ឈាន គឺសេចក្ដីជ្រះថ្លាស៊ប់ បីតិ សុខ ឯកគ្គតានៃចិត្ត ។

[ ៤១៣ ] ត្រង់ពាក្យថា ចូល គឺការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការបំពេញនូវទុតិយជ្ឈាន ។

[ ៤១៤ ] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺសម្រេច ។បេ។ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[ ៤១៥ ] ត្រង់ពាក្យថា ព្រោះនឿយណាយចាកបីតិ សេចក្ដីថា បណ្ដាធម៌ទាំងនោះ បីតិ តើដូចម្ដេច ។ សេចក្ដីឆ្អែតចិត្ត រីករាយ សប្បាយ ស្រស់ស្រាយ ស្រស់បស់ ញញឹម ត្រេកអរ អណ្ដែតអណ្ដូង ភាពនៃចិត្ត ត្រេកអរណា នេះហៅថា បីតិ បីតិនេះ ជាធម្មជាតស្ងប់រម្ងាប់ រលត់ ខ្ចាត់ ចេញ វិនាស សាបសូន្យ ខូចខាត ហិនហោច រីង ស្ងួត ធ្វើឲ្យអស់ទៅ

ព្រោះហេតុនោះ ទើបពោលថា ព្រោះនឿយណាយចាកបីតិ ។

[ ៤១៦ ] ត្រង់ពាក្យថា ប្រកបដោយឧបេក្ខា សេចក្តីថា បណ្តាធម៌ទាំងនោះ ឧបេក្ខា តើដូចម្តេច ។ ការព្រងើយកន្តើយ អាការព្រងើយកន្តើយ អាការសម្លឹងឃើញជាក់ ភាពនៃចិត្តជាកណ្តាលណា នេះហៅថា ឧបេក្ខា បុគ្គលជាអ្នកព្រមព្រៀង ។បេ។ ប្រកបដោយឧបេក្ខានេះ ព្រោះហេតុនោះ ទើបពោលថា ប្រកបដោយឧបេក្ខា ។

[ ៤១៧ ] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺសម្រេច ។បេ។ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[ ៤១៨ ] ត្រង់ពាក្យថា មានស្មារតី ដឹងខ្លួន ។ បណ្តាពាក្យទាំងនោះ ស្មារតី តើដូចម្តេច ។ ការរឭក ការនឹកឃើញ ។បេ។ ការរឭកត្រូវណា នេះហៅថា ស្មារតី ។ បណ្តាពាក្យទាំងនោះ ការដឹងខ្លួន តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការសង្កេតនូវធម៌ សេចក្តីឃើញត្រូវណា នេះហៅថា ការដឹងខ្លួន ។ បុគ្គលជាអ្នកព្រមព្រៀង ។បេ។ ប្រកបព្រមដោយស្មារតីនេះផង ដោយការដឹងខ្លួននេះផង ព្រោះហេតុនោះ ទើបពោលថា មានស្មារតី ដឹងខ្លួន ។

[ ៤១៩ ] ត្រង់ពាក្យថា ទទួលសុខដោយនាមកាយ ។ បណ្តាពាក្យទាំងនោះ សុខ តើដូចម្តេច ។ សេចក្តីត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ ជាទីត្រេកអរ ជាសុខ ដែលកើតអំពីចេតោសម្ផស្ស សុខវេទនា ជាទីត្រេកអរ ដែលកើតអំពីចេតោ-

សម្ផស្សណា នេះហៅថា សុខ ។ បណ្ដាពាក្យទាំងនោះ នាមកាយ តើដូចម្ដេច ។ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ នេះហៅថា នាមកាយ ។ បុគ្គលទទួលសេចក្ដីសុខនេះ ដោយនាមកាយនេះ ព្រោះហេតុនោះ ទើបពោលថា ទទួលសុខដោយនាមកាយ ។

[ ៤២០ ] ត្រង់ពាក្យថា ព្រះអរិយៈទាំងឡាយ តែងសរសើរនូវបុគ្គល អ្នកព្រមព្រៀងដោយតតិយជ្ឈាននោះ សេចក្ដីថា បណ្ដាពាក្យទាំងនោះ ព្រះអរិយៈទាំងឡាយ តើដូចម្ដេច ។ ព្រះពុទ្ធទាំងឡាយក្ដី សាវកនៃព្រះពុទ្ធទាំងឡាយក្ដី ហៅថា ព្រះអរិយៈ ពួកព្រះអរិយៈទាំងនោះ សរសើរ សម្ដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យរាក់ ប្រកាស នូវបុគ្គលអ្នកព្រមព្រៀង ដោយតតិយជ្ឈាននេះ ព្រោះហេតុនោះ ទើបពោលថា ព្រះអរិយៈទាំងឡាយ តែងសរសើរនូវបុគ្គលអ្នកព្រមព្រៀង ដោយតតិយជ្ឈាននោះ ។

[ ៤២១ ] ត្រង់ពាក្យថា ជាអ្នកប្រកបដោយឧបេក្ខា មានស្មារតីនៅជាសុខ សេចក្ដីថា បណ្ដាពាក្យទាំងនោះ ឧបេក្ខា តើដូចម្ដេច ។ ការព្រងើយកន្ដើយ អាការព្រងើយកន្ដើយ អាការសម្លឹងឃើញជាក់ ភាពនៃចិត្តតាំងនៅជាកណ្ដាលណា នេះហៅថា ឧបេក្ខា ។ បណ្ដាពាក្យទាំងនោះ ស្មារតី តើដូចម្ដេច ។ ការរឭក ការនឹកឃើញ ។បេ។ ការរឭកត្រូវណា នេះហៅថា ស្មារតី ។ បណ្ដាពាក្យទាំងនោះ សុខ តើដូចម្ដេច ។ សេចក្ដីត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីសុខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ ជាទីត្រេកអរ ជាសុខ ដែលកើតអំពីចេតោសម្ផស្ស សុខវេទនា ជាទីត្រេកអរ ដែលកើតអំពីចេតោ-

សម្ផស្ស នេះហៅថា សុខ ។ បុគ្គលប្រកបដោយឧបេក្ខានេះផង ដោយស្មារតីនេះផង ដោយសុខនេះផង ហើយសម្រេចឥរិយាបថ ប្រព្រឹត្ត រក្សា រស់នៅ ញុំាងជីវិតឲ្យរស់នៅ ត្រាច់ទៅ សម្រាកនៅ ព្រោះហេតុនោះ ទើបពោលថា ជាអ្នកប្រកបដោយឧបេក្ខា មានស្មារតី នៅជាសុខ ។

[ ៤២២ ] ត្រង់ពាក្យថា តតិយៈ គឺជាគម្រប់បី ដោយលំដាប់នៃកិរិយារាប់ បុគ្គលចូលកាន់តតិយជ្ឈាននេះ ព្រោះហេតុនោះ ទើបឈ្មោះថា តតិយៈ ។

[ ៤២៣ ] ត្រង់ពាក្យថា ឈាន គឺឧបេក្ខា សតិ សម្បជញ្ញៈ សុខ ឯកគ្គតានៃចិត្ត ។

[ ៤២៤ ] ត្រង់ពាក្យថា ចូល គឺការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការបំពេញនូវតតិយជ្ឈាន ។

[ ៤២៥ ] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺសម្រេច ។បេ។ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[ ៤២៦ ] ត្រង់ពាក្យថា ព្រោះលះបង់សុខផង ព្រោះលះបង់ទុក្ខផង សេចក្ដីថា សុខក៏មាន ទុក្ខក៏មាន ។ បណ្ដាពាក្យទាំងនោះ សុខ តើដូចម្ដេច ។ សេចក្ដីត្រេកអរ ប្រព្រឹត្តទៅក្នុងកាយ សេចក្ដីសុខ ប្រព្រឹត្តទៅក្នុងកាយ ការទទួលអារម្មណ៍ ជាទីត្រេកអរ ជាសុខ ដែលកើតអំពីកាយសម្ផស្ស សុខវេទនា ជាទីត្រេកអរ ដែលកើតអំពីកាយសម្ផស្សណា នេះហៅថា សុខ ។ បណ្ដាធម៌ទាំងនោះ ទុក្ខ តើដូចម្ដេច ។ សេចក្ដីមិនត្រេកអរ ប្រព្រឹត្តទៅក្នុង

កាយ សេចក្ដីទុក្ខ ប្រព្រឹត្តទៅក្នុងកាយ ការទទួលអារម្មណ៍ មិនជាទីត្រេកអរ ជាទុក្ខ ដែលកើតអំពីកាយសម្ផស្ស ទុក្ខវេទនា មិនជាទីត្រេកអរ ដែលកើតអំពីកាយសម្ផស្សណា នេះហៅថា ទុក្ខ ។ សុខនេះផង ទុក្ខនេះផង ជាធម៌ស្ងប់រម្ងាប់ រលត់ ខ្ចាត់ចេញ វិនាស សាបសូន្យ ខូចខាត ហិនហោច រីងស្ងួត ធ្វើឲ្យអស់ទៅ ព្រោះហេតុនោះ ទើបពោលថា ព្រោះលះបង់សុខផង ព្រោះលះបង់ទុក្ខផង ។

[ ៤២៧ ] ត្រង់ពាក្យថា ព្រោះវិនាសទៅនៃសោមនស្ស និងទោមនស្ស ក្នុងកាលមុន សេចក្ដីថា សោមនស្សក៏មាន ទោមនស្សក៏មាន ។ បណ្ដាធម៌ទាំងនោះ សោមនស្ស តើដូចម្ដេច ។ សេចក្ដីត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីសុខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ ជាទីត្រេកអរ ជាសុខ ដែលកើតអំពីចេតោសម្ផស្ស សុខវេទនា ជាទីត្រេកអរ ដែលកើតអំពីចេតោ-សម្ផស្សណា នេះហៅថា សោមនស្ស ។ បណ្ដាធម៌ទាំងនោះ ទោមនស្ស តើដូចម្ដេច ។ សេចក្ដីមិនត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីទុក្ខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ មិនជាទីត្រេកអរ ជាទុក្ខ ដែលកើតអំពីចេតោ-សម្ផស្ស ទុក្ខវេទនា មិនជាទីត្រេកអរ ដែលកើតអំពីចេតោសម្ផស្សណា នេះហៅថា ទោមនស្ស ។ សោមនស្សនេះផង ទោមនស្សនេះផង ជាធម៌ស្ងប់រម្ងាប់ រលត់ ខ្ចាត់ចេញ វិនាស សាបសូន្យ ខូចខាត ហិនហោច រីង ស្ងួត ធ្វើឲ្យអស់ទៅ ក្នុងកាលមុន ព្រោះហេតុនោះ ទើបពោលថា ព្រោះវិនាសទៅនៃសោមនស្ស និងទោមនស្ស ក្នុងកាលមុន ។

[ ៤២៨ ] ត្រង់ពាក្យថា មិនជាទុក្ខ មិនជាសុខ គឺសេចក្ដីត្រេកអរក៏មិនមែន សេចក្ដីមិនត្រេកអរក៏មិនមែន ដែលប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ មិនជាទុក្ខ មិនជាសុខ ដែលកើតអំពីចេតោសម្ផស្ស អទុក្ខមសុខ-វេទនា ដែលកើតអំពីចេតោសម្ផស្សណា ព្រោះហេតុនោះ ទើបពោលថា មិនជាទុក្ខ មិនជាសុខ ។

[ ៤២៩ ] ត្រង់ពាក្យថា មានសតិដ៏បរិសុទ្ធដោយឧបេក្ខា សេចក្ដីថា បណ្ដាធម៌ទាំងនោះ ឧបេក្ខា តើដូចម្ដេច ។ ការព្រងើយកន្តើយ អាការព្រងើយកន្តើយ អាការសម្លឹងឃើញជាក់ ភាពនៃចិត្តតាំងនៅជាកណ្ដាលណា នេះហៅថា ឧបេក្ខា ។ បណ្ដាពាក្យទាំងនោះ សតិ តើដូចម្ដេច ។ ការរឭករឭកឃើញ ។បេ។ ការរឭកត្រូវណា នេះហៅថា សតិ ។ សតិនេះ ជាធម្មជាតបើក បរិសុទ្ធ ផូរផង់ ដោយឧបេក្ខានេះ ព្រោះហេតុនោះ ទើបពោលថា មានសតិដ៏បរិសុទ្ធ ដោយឧបេក្ខា ។

[ ៤៣០ ] ត្រង់ពាក្យថា ចតុត្ថៈ គឺជាគម្រប់ ៤ ដោយលំដាប់ នៃកិរិយារាប់ បុគ្គលចូលកាន់ឈានទី ៤ នេះ ព្រោះហេតុនោះ ទើបឈ្មោះថា ចតុត្ថៈ ។

[ ៤៣១ ] ត្រង់ពាក្យថា ឈាន គឺឧបេក្ខា សតិ ឯកគ្គតានៃចិត្ត ។

[ ៤៣២ ] ត្រង់ពាក្យថា ចូល គឺការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការបំពេញនូវចតុត្ថជ្ឈាន ។

[ ៤៣៣ ] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺសម្រេច ។បេ។ សម្រាក

ទៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[ ៤៣៤ ] ត្រង់ពាក្យថា ព្រោះកន្លងរូបសញ្ញា ដោយសព្វគ្រប់ សេចក្តីថា បណ្តាធម៌ទាំងនោះ រូបសញ្ញា តើដូចម្តេច ។ ការសម្គាល់ អាការសម្គាល់ ភាពនៃការសម្គាល់ណា របស់បុគ្គលអ្នកចូលកាន់រូបសមាបត្តិក្តី របស់បុគ្គលអ្នកប្រកប ( ដោយរូបសមាបត្តិ ) ក្តី របស់បុគ្គលអ្នកនៅជាសុខក្នុងបច្ចុប្បន្ន ( ដោយរូបាវចរសមាបត្តិ ) ក្តី នេះហៅថា រូបសញ្ញា បុគ្គលកន្លង ប្រព្រឹត្តកន្លង ឈានកន្លង នូវរូបសញ្ញាទាំងនេះ ព្រោះហេតុនោះ ទើបពោលថា ព្រោះកន្លងរូបសញ្ញា ដោយសព្វគ្រប់ ។

[ ៤៣៥ ] ត្រង់ពាក្យថា ព្រោះវិនាសទៅ នៃបដិឃសញ្ញាទាំងឡាយ សេចក្តីថា បណ្តាធម៌ទាំងនោះ បដិឃសញ្ញា តើដូចម្តេច ។ រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា នេះហៅថា បដិឃសញ្ញា បដិឃសញ្ញាទាំងនេះ ជាធម៌ស្ងប់រម្ងាប់ រលត់ ខ្ចាត់ចេញ វិនាស សាបសូន្យ ខូចខាត ហិនហោច រីង ស្ងួត ធ្វើឲ្យអស់ទៅ ព្រោះហេតុនោះ ទើបពោលថា ព្រោះវិនាសទៅ នៃបដិឃសញ្ញាទាំងឡាយ ។

[ ៤៣៦ ] ត្រង់ពាក្យថា ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា សេចក្តីថា បណ្តាធម៌ទាំងនោះ នានត្តសញ្ញា តើដូចម្តេច ។ ការសម្គាល់ អាការសម្គាល់ ភាពនៃការសម្គាល់ណា របស់បុគ្គលអ្នកមិនចូលកាន់ ( រូបសមាបត្តិ ) ជាអ្នកព្រមព្រៀងដោយមនោធាតុក្តី ព្រមព្រៀងដោយមនោវិញ្ញាណធាតុក្តី នេះហៅថា នានត្តសញ្ញា បុគ្គលមិនធ្វើទុកក្នុងចិត្ត នូវនានត្តសញ្ញាទាំងនេះ ព្រោះ

ហេតុនោះ ទើបពោលថា ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ។

[ ៤៣៧ ] ត្រង់ពាក្យថា អាកាសមិនមានទីបំផុត សេចក្តីថា បណ្តាធម៌ទាំងនោះ អាកាស តើដូចម្តេច ។ កន្លែងណា ដែលមិនអាចក្ករាស់បាន អាកាស ទីឥតទើស ទីអាកាស ទីចន្លោះ វាល មិនប៉ះពាល់ ដោយមហាភូតរូបទាំង ៤ នេះហៅថា អាកាស ភិក្ខុតម្កល់ តាំងទុកនូវចិត្ត ក្នុងអាកាសនោះ ផ្សាយចិត្តទៅកាន់ទី ដែលមិនមានទីបំផុត ព្រោះហេតុនោះ ទើបពោលថា អាកាសមិនមានទីបំផុត ។

[ ៤៣៨ ] ត្រង់ពាក្យថា អាកាសានញ្ចាយតនៈ បានដល់ ពួកធម៌ គឺ ចិត្ត និងចេតសិក របស់បុគ្គលអ្នកចូលកាន់អាកាសានញ្ចាយតនជ្ឈានក្តី របស់បុគ្គលអ្នកប្រកប ( ដោយអាកាសានញ្ចាយតនជ្ឈាន ) ក្តី របស់បុគ្គលអ្នកនៅជាសុខ ក្នុងបច្ចុប្បន្ន ( ដោយអាកាសានញ្ចាយតនជ្ឈាន ) ក្តី ។

[ ៤៣៩ ] ត្រង់ពាក្យថា ចូល គឺការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការបំពេញនូវអាកាសានញ្ចាយតនជ្ឈាន ។

[ ៤៤០ ] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺសម្រេច ។បេ។ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[ ៤៤១ ] ត្រង់ពាក្យថា ព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង គឺភិក្ខុជាអ្នកកន្លង ប្រព្រឹត្តកន្លង ឈានកន្លង នូវអាកាសានញ្ចាយតនជ្ឈាននោះ ព្រោះហេតុនោះ ទើបពោលថា ព្រោះកន្លងនូវ

អាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ។

[ ៤៤២ ] ត្រង់ពាក្យថា វិញ្ញាណមិនមានទីបំផុត គឺភិក្ខុធ្វើទុកក្នុងចិត្ត ចំពោះអាកាសនោះឯង ដែលពាល់ត្រូវដោយវិញ្ញាណ ផ្សាយទៅកាន់ទីមិនមានទីបំផុត ព្រោះហេតុនោះ ទើបពោលថា វិញ្ញាណមិនមានទីបំផុត ។

[ ៤៤៣ ] ត្រង់ពាក្យថា វិញ្ញាណញ្ចាយតនៈ បានដល់ ពួកធម៌ គឺចិត្តនិងចេតសិក របស់បុគ្គលអ្នកចូលកាន់វិញ្ញាណញ្ចាយតនជ្ឈានក្តី របស់បុគ្គលអ្នកប្រកប ( ដោយវិញ្ញាណញ្ចាយតនជ្ឈាន ) ក្តី របស់បុគ្គលអ្នកនៅជាសុខក្នុងបច្ចុប្បន្ន ( ដោយវិញ្ញាណញ្ចាយតនជ្ឈាន ) ក្តី ។

[ ៤៤៤ ] ត្រង់ពាក្យថា ចូល គឺការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការបំពេញនូវវិញ្ញាណញ្ចាយតនជ្ឈាន ។

[ ៤៤៥ ] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺសម្រេច ។បេ។ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[ ៤៤៦ ] ត្រង់ពាក្យថា ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនៈ ដោយប្រការទាំងពួង គឺភិក្ខុជាអ្នកកន្លង ប្រព្រឹត្តកន្លង ឈានកន្លង នូវវិញ្ញាណញ្ចាយតនជ្ឈាននេះ ព្រោះហេតុនោះ ទើបពោលថា ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ។

[ ៤៤៧ ] ត្រង់ពាក្យថា វត្ថុតិចតួចមិនមាន គឺភិក្ខុចម្រើនទូទៅ ចម្រើនវិសេស នូវវិញ្ញាណនោះឯង ធ្វើឲ្យបាត់វិញ្ញាណ រមែងឃើញថា វត្ថុតិចតួច

មិនមាន ព្រោះហេតុនោះ ទើបពោលថា វត្ថុតិចតួចមិនមាន ។

[ ៤៤៨ ] ត្រង់ពាក្យថា អាកិញ្ចញ្ញាយតនៈ បានដល់ ពួកធម៌ គឺចិត្ត និងចេតសិក របស់បុគ្គលអ្នកចូលកាន់អាកិញ្ចញ្ញាយតនជ្ឈានក្តី របស់បុគ្គលអ្នកប្រកប ( ដោយអាកិញ្ចញ្ញាយតនជ្ឈាន ) ក្តី របស់បុគ្គលអ្នកនៅជាសុខក្នុងបច្ចុប្បន្ន ( ដោយអាកិញ្ចញ្ញាយតនជ្ឈាន ) ក្តី ។

[ ៤៤៩ ] ត្រង់ពាក្យថា ចូល គឺការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការបំពេញនូវអាកិញ្ចញ្ញាយតនជ្ឈាន ។

[ ៤៥០ ] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺសម្រេច ។បេ។ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[ ៤៥១ ] ត្រង់ពាក្យថា ព្រោះកន្លងនូវអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង គឺភិក្ខុជាអ្នកកន្លង ប្រព្រឹត្តកន្លង ឈានកន្លង នូវអាកិញ្ចញ្ញាយតនជ្ឈាននេះ ព្រោះហេតុនោះ ទើបពោលថា ព្រោះកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ។

[ ៤៥២ ] ត្រង់ពាក្យថា នេវសញ្ញីនាសញ្ញី គឺភិក្ខុធ្វើទុកក្នុងចិត្ត នូវអាកិញ្ចញ្ញាយតនជ្ឈាននោះឯង ដោយល្អិត ចម្រើននូវសមាបត្តិមានសង្ខារសេសនៅ ព្រោះហេតុនោះ ទើបពោលថា នេវសញ្ញីនាសញ្ញី ។

[ ៤៥៣ ] ត្រង់ពាក្យថា នេវសញ្ញានាសញ្ញាយតនៈ បានដល់ ពួកធម៌ គឺចិត្ត និងចេតសិក របស់បុគ្គលអ្នកចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈានក្ដី របស់បុគ្គលអ្នកប្រកប ( ដោយនេវសញ្ញានាសញ្ញាយតនជ្ឈាន ) ក្ដី របស់បុគ្គលអ្នកនៅជាសុខក្នុងបច្ចុប្បន្ន ( ដោយនេវសញ្ញានាសញ្ញាយតនជ្ឈាន ) ក្ដី ។

[ ៤៥៤ ] ត្រង់ពាក្យថា ចូល គឺការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការបំពេញនូវនេវសញ្ញា-នាសញ្ញាយតនជ្ឈាន ។

[ ៤៥៥ ] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺសម្រេច ប្រព្រឹត្ត រក្សារស់នៅ ញុំាងជីវិតឲ្យរស់នៅ ត្រាច់ទៅ សម្រាកនៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

## សុត្តន្តភាជនីយ ចប់

# អដ្ឋកថា

# សុត្តន្តភាជនីយ

## អធិប្បាយ និទ្ទេស

[ ៣៤៦-៤៥៥ ] ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីនឹងសម្តែងចែកមាតិកាតាមដែលទ្រង់តាំងឡើង ទើបផ្តើមបទថា **ឥធាតិ ឥមិស្សា ទិដ្ឋិយា** ជាដើម ។ ក្នុងនិទ្ទេសទាំងនោះ ពាក្យប្រៀនប្រដៅរបស់ព្រះសព្វញ្ញុពុទ្ធ ពោលគឺត្រៃសិក្ខា ព្រះមានព្រះភាគត្រាស់ ១០ បទ មានបទថា **ឥមិស្សា ទិដ្ឋិយា** ជាដើម ។

ពិតហើយ ពាក្យប្រៀនប្រដៅនោះ ព្រះមានព្រះភាគត្រាស់ហៅថា **ទិដ្ឋិ** ព្រោះពាក្យប្រៀនប្រដៅនោះ ព្រះមានព្រះភាគត្រាស់ដឹងហើយ ទ្រង់ឃើញហើយ ទើបត្រាស់ហៅថា **ខន្តិ** ដោយអំណាចនៃការពេញចិត្តក្នុងពាក្យប្រៀនប្រដៅនោះឯង ត្រាស់ហៅថា **រុចិ** ដោយអំណាចនៃការត្រេកអរក្នុងពាក្យប្រៀនប្រដៅនោះ ត្រាស់ហៅថា **លទ្ធិ** ដោយអំណាចនៃការកាន់យកក្នុងពាក្យប្រៀនប្រដៅនោះ ត្រាស់ហៅថា **ធម្ម** ព្រោះអត្ថថា ជាសភាវៈ ត្រាស់ហៅថា **វិន័យ** ព្រោះអត្ថថា គួរដល់ការសិក្សា ត្រាស់ហៅថា **ធម្មវិន័យ** ដោយអត្ថទាំងពីរនោះ អត្ថទាំងពីរនោះ ត្រាស់ហៅថា **ធម្មវចន** ដោយអំណាចនៃពាក្យដែលទ្រង់ត្រាស់ហើយ ត្រាស់ហៅថា **ព្រហ្មចរិយ** ព្រោះអត្ថថា ជាការប្រព្រឹត្តធម៌ដែលប្រសើរបំផុត ត្រាស់ហៅថា **សត្ថុសាសន**

ដោយអំណាចនៃការឲ្យនូវការប្រៀនប្រដៅ ព្រោះហេតុនោះ ទើបក្នុងបទថា **ឥមិស្សា ទិដ្ឋិយា** ជាដើម បណ្ឌិតគប្បីជ្រាបសេចក្តីយ៉ាងនេះ ក្នុងទិដ្ឋិរបស់ព្រះសម្ពុទ្ធនេះ ក្នុងខន្តីរបស់ព្រះសម្ពុទ្ធនេះ ក្នុងរុចិរបស់ព្រះសម្ពុទ្ធនេះ ក្នុងលទ្ធិរបស់ព្រះសម្ពុទ្ធនេះ ក្នុងធម៌របស់ព្រះសម្ពុទ្ធនេះ ក្នុងវិន័យរបស់ព្រះសម្ពុទ្ធនេះ ក្នុងធម៌វិន័យរបស់ព្រះសម្ពុទ្ធនេះ ។

ក្នុងបាវចនារបស់ព្រះសម្ពុទ្ធនេះ ក្នុងព្រហ្មចរិយៈរបស់ព្រះសម្ពុទ្ធនេះ ក្នុងពាក្យប្រៀនប្រដៅរបស់ព្រះសម្ពុទ្ធនេះ ដែលត្រាស់ ( ក្នុងវិនយបិដក ចូឡវគ្គ ) ហើយយ៉ាងនេះថា ម្នាលព្រះនាងគោតមី ព្រះនាងគប្បីដឹងនូវធម៌ទាំងឡាយណាថា ធម៌ទាំងនេះ ប្រព្រឹត្តទៅ ដើម្បីការប្រកបដោយតម្រេក មិនប្រព្រឹត្តទៅ ដើម្បីការប្រាសចាកតម្រេក ប្រព្រឹត្តទៅ ដើម្បីការប្រកបក្នុងវដ្តៈ មិនប្រព្រឹត្តទៅ ដើម្បីការប្រាសចាកការប្រកបក្នុងវដ្តៈ ប្រព្រឹត្តទៅ ដើម្បីការសន្សំកិលេសវដ្តៈ មិនប្រព្រឹត្តទៅ ដើម្បីប្រាសចាកការសន្សំកិលេសវដ្តៈ ប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នាច្រើន មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នាតិច ប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសន្តោស មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីសន្តោស ប្រព្រឹត្តទៅ ដើម្បីការប្រឡូកប្រឡំដោយពួក មិនប្រព្រឹត្តទៅ ដើម្បីការស្ងប់ស្ងាត់ចាកពួក ប្រព្រឹត្តទៅ ដើម្បីសេចក្តីខ្ជិលច្រអូស មិនប្រព្រឹត្តទៅ ដើម្បីប្រារព្ធសេចក្តីព្យាយាម ប្រព្រឹត្តទៅ ដើម្បីឲ្យគេចិញ្ចឹមបានដោយក្រ មិនប្រព្រឹត្តទៅ ដើម្បីឲ្យគេចិញ្ចឹមបានដោយងាយ ម្នាលព្រះនាងគោតមី ព្រះនាងគប្បីចងចាំដោយចំណែកមួយថា នេះមិនមែនជាធម៌

នេះមិនមែនជាវិន័យ នេះមិនមែនជាពាក្យប្រដៅរបស់ព្រះសាស្ដាទេ ម្នាល ព្រះនាងគោតមី មួយវិញទៀត ព្រះនាងគប្បីដឹងនូវធម៌ណាថា ធម៌ទាំងនេះ ប្រព្រឹត្តទៅ ដើម្បីការប្រាសចាកតម្រេក មិនប្រព្រឹត្តទៅ ដើម្បីការប្រកប ដោយតម្រេក ។បេ។ ប្រព្រឹត្តទៅ ដើម្បីឲ្យគេចិញ្ចឹមបានដោយងាយ មិន ប្រព្រឹត្តទៅ ដើម្បីឲ្យគេចិញ្ចឹមបានដោយក្រ ម្នាលព្រះនាងគោតមី ព្រះនាង គប្បីចងចាំដោយចំណែកមួយថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅ របស់ព្រះសាស្ដាហើយ ដូច្នេះ ។

ម្យ៉ាងទៀត ពាក្យប្រៀនប្រដៅទាំងអស់ ពោល គឺត្រៃសិក្ខានេះ ឈ្មោះ ថា **ទិដ្ឋិ** ព្រោះភាពជាធម៌ដែលព្រះមានព្រះភាគទ្រង់ឃើញហើយ ព្រោះជា បច្ច័យដល់សម្មាទិដ្ឋិ និងព្រោះជាខាងដើមរបស់សម្មាទិដ្ឋិ ។ ឈ្មោះថា **ខន្តិ** ដោយអំណាចនៃការអត់ធន់របស់ព្រះមានព្រះភាគ ។ ឈ្មោះថា **រុចិ** ដោយ អំណាចនៃការពេញចិត្តរបស់ព្រះមានព្រះភាគ និងឈ្មោះថា **លទ្ធិ** ដោយ អំណាចនៃការកាន់យករបស់ព្រះមានព្រះភាគ ។

សភាវៈណា ទ្រទ្រង់នូវសត្វដែលប្រព្រឹត្តធម៌របស់ខ្លួន មិនឲ្យធ្លាក់ទៅ ក្នុងអបាយទាំងឡាយ ព្រោះហេតុនោះ ទើបសភាវៈនោះ ឈ្មោះថា **ធម៌** ។ សភាវៈនោះឯង ឈ្មោះថា **វិន័យ** ព្រោះអត្ថថា នាំចេញនូវសភាវៈដែលជា ចំណែកនៃសង្កិលេស ។ ធម៌នោះផង វិន័យនោះផង ឈ្មោះថា **ធម្មវិន័យ** ។

ម្យ៉ាងទៀត ឈ្មោះថា **ធម្មវិន័យ** ព្រោះអត្ថថា ជាសភាវៈកម្ចាត់នូវ អកុសលធម៌ទាំងឡាយ ដោយកុសលធម៌ទាំងឡាយ ដោយហេតុនោះឯង

*ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលព្រះនាងគោតមី មួយវិញទៀត ព្រះនាងគប្បីដឹងនូវធម៌ណាថា ធម៌ទាំងនេះ ប្រព្រឹត្តទៅ ដើម្បីការប្រាសចាកតម្រេក មិនប្រព្រឹត្តទៅ ដើម្បីការប្រកបដោយតម្រេក ។បេ។ ម្នាលព្រះនាងគោតមី ព្រះនាងគប្បីចងចាំដោយចំណែកមួយថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្ដាហើយ ដូច្នេះ ។*

*ម្យ៉ាងទៀត ឈ្មោះថា* **ធម្មវិន័យ** *ព្រោះអត្ថថា ជាការទូន្មានដោយធម៌ មិនមែនទូន្មានដោយអាជ្ញា មានដំបងជាដើមឡើយ ។ ពិតហើយ ដូចព្រះមានព្រះភាគត្រាស់ ( ក្នុងវិនយបិដក ចូឡវគ្គ ) ថា*

*ជនពួកមួយ តែងទូន្មាន ( ដំរី ) ដោយដំបងខ្លះ ដោយកង្វេរខ្លះ ដោយរំពាត់ខ្លះ ( ចំណែក ) ព្រះពុទ្ធ ដែលព្រះអង្គស្វែងរកនូវគុណធំ ឥតមានដំបង ឥតមានគ្រឿងសស្ត្រាអ្វីទេ តែអាចទូន្មានហត្ថិនាគបាន ដូច្នេះ ។*

*និងព្រះតម្រាស់ ( ក្នុងវិនយបិដក មហាវគ្គ ) ថា*

*ហេតុដូចម្ដេច ក៏មានសេចក្ដីប្រណែននឹងពួកអ្នកប្រាជ្ញ ដែលជាអ្នកណែនាំសត្វដោយធម៌ ( នោះឯង ) ដូច្នេះ ។*

*ម្យ៉ាងទៀត ការទូន្មានដោយធម៌ ឈ្មោះថា* **ធម្មវិន័យ ។** *ពិតហើយ ការទូន្មាន គឺវិន័យនេះ រមែងប្រព្រឹត្តទៅ ដើម្បីធម៌ដែលមិនមានទោស ទាំងមិនប្រព្រឹត្តទៅ ដើម្បីភោគៈ និងអាមិសក្នុងភព ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាត ) ថា ម្នាលភិក្ខុទាំង*

ឡាយ តថាគតនឹងប្រព្រឹត្តព្រហ្មចរិយធម៌នេះ ដើម្បីកុហកមហាជនក៏ទេ ដូច្នេះ ។ បណ្ឌិតគប្បីធ្វើឲ្យពិស្តារ ។ សូម្បីព្រះបុណ្ណត្ថេរក៏បានពោល ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលអាវុសោ ព្រហ្មចរិយធម៌ ដែលខ្ញុំប្រព្រឹត្តក្នុងសម្នាក់ព្រះមានព្រះភាគ ដើម្បីអនុបាទាបរិនិព្វានទេតើ ដូច្នេះ ។

ម្យ៉ាងទៀត ឈ្មោះថា **វិន័យ** ព្រោះអត្ថថា នាំវត្ថុវិសេសទៅ ។ វិន័យដោយធម៌ ក៏ឈ្មោះថា **ធម្មវិន័យ** ។ ពិតហើយ ធម្មវិន័យនេះ រមែងឲ្យចេញចាកសង្ខារធម៌ ឬសោកាទិធម៌ ហើយនាំទៅកាន់ព្រះនិព្វានវិសេស ។ ម្យ៉ាងទៀត វិន័យរបស់ព្រះពុទ្ធអ្នកមានធម៌ មិនមែនរបស់មេលទ្ធិទាំងឡាយឡើយ ព្រោះហេតុនោះ ទើបឈ្មោះថា **ធម្មវិន័យ** ។ ពិតហើយ ព្រះមានព្រះភាគទ្រង់ជាម្ចាស់នៃធម៌ វិន័យរបស់ព្រះមានព្រះភាគជាម្ចាស់នៃធម៌នោះ ។

ម្យ៉ាងទៀត ព្រោះធម៌ទាំងឡាយនោះ ជាធម៌គប្បីដឹងក្រៃលែង ជាធម៌គប្បីកំណត់ដឹង ជាធម៌គប្បីលះ ជាធម៌គប្បីចម្រើន និងជាធម៌គប្បីធ្វើឲ្យជាក់ច្បាស់ ហេតុនោះ ទើបវិន័យក្នុងធម៌ទាំងឡាយនេះ មិនមែនវិន័យក្នុងសត្វទាំងឡាយ មិនមែនវិន័យក្នុងជីវៈទាំងឡាយ ព្រោះហេតុនោះ ទើបឈ្មោះថា **ធម្មវិន័យ** ។

ឈ្មោះថា **ធាវចន** ព្រោះអត្ថថា ជាប្រធានជាងពាក្យរបស់ជនដទៃ ព្រោះជាពាក្យដែលដល់ព្រមដោយអត្ថ និងព្យញ្ជនៈជាដើម ។ ពាក្យជាប្រធាននោះឯង ឈ្មោះថា **ធាវចន** ។ ឈ្មោះថា **ព្រហ្មចរិយ** ព្រោះជាចរិយាដ៏ប្រសើរ ជាងចរិយាទាំងពួង ។ ឈ្មោះថា **សត្ថុសាសន** ព្រោះអត្ថថា ជា

ពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគនោះ ជាគ្រូរបស់ទេវតា និងមនុស្ស ទាំងឡាយ ។ មួយវិញទៀត ឈ្មោះថា **សត្ថុសាសន** ព្រោះអត្ថថា ពាក្យប្រៀន ប្រដៅក៏ជាសាស្តា ។ ពិតហើយ ព្រះធម្មវិន័យនោះឯង ហៅថា ជាសាស្តា ដូចបាលីថា លុះអំណើះតអំពីតថាគតទៅ ធម៌ និងវិន័យនោះ ជាគ្រូរបស់ អ្នកទាំងឡាយ ដូច្នេះជាដើម ព្រោះហេតុនោះ គប្បីជ្រាបអត្ថនៃពាក្យទាំង នោះ ដោយប្រការដូច្នេះ ។

ព្រោះភិក្ខុអ្នកញុំាងឈាន មានប្រការទាំងពួងឲ្យកើតឡើង ប្រាកដក្នុង សាសនានេះ មិនបានប្រាកដក្នុងសាសនាដទៃ ហេតុនោះ គប្បីជ្រាបថា ព្រះ មានព្រះភាគទ្រង់ធ្វើនិយាមក្នុងទីនោះៗ ដោយបទថា **ឥមិស្សា ខោ ឥមស្មឹ ខោ** ។ សេចក្តីនេះ ជាពាក្យអធិប្បាយមាតិកាបទនិទ្ទេស ក្នុងបទថា **ឥធ** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងភិក្ខុនិទ្ទេសដូចតទៅ បទថា **សមញ្ញាយ** បាន ដល់ ជាភិក្ខុដោយបញ្ញត្តិ គឺដោយវោហារ ។ ពិតហើយ បុគ្គលខ្លះ រមែង ប្រាកដថាជាភិក្ខុ ព្រោះសម្មតិនោះឯង ។ ពិតហើយ ជនទាំងឡាយ កាល រាប់ចំនួនភិក្ខុទាំងឡាយ ក្នុងពេលនិមន្តជាដើម រមែងរួមសាមណេរផង ហើយពោលថា មានភិក្ខុមួយរយ មានភិក្ខុមួយពាន់ ដូច្នោះ ។

បទថា **បដិញ្ញាយ** បានដល់ ដោយប្តេជ្ញារបស់ខ្លួន ។ ពិតហើយ បុគ្គលខ្លះ រមែងជាភិក្ខុដោយប្តេជ្ញា ។ គប្បីជ្រាបការកើតឡើងនៃបទថា ព្រោះ ប្តេជ្ញានោះ ក្នុងពាក្យជាដើមយ៉ាងនេះថា អ្នកណានៅក្នុងទីនេះ មានពាក្យ ប្តេជ្ញាថា នែអាវុសោ ខ្ញុំជាភិក្ខុ ។ ពាក្យប្តេជ្ញានេះ ឈ្មោះថា ប្រកបដោយ

ធម៌ ជាពាក្យដែលព្រះអានន្ទពោលហើយ ។ ម្យ៉ាងទៀត ក្នុងពេលរាត្រី ភិក្ខុទាំងឡាយសូម្បីទ្រទ្រង់សីល ដើរបញ្ច្រាសផ្លូវមក កាលមានអ្នកសួរថា អ្នកណានៅក្នុងទីនេះ រមែងពោលដោយបញ្ញាដែលមិនប្រកបដោយធម៌ គឺដែលមិនពិតថា ខ្ញុំ ជាភិក្ខុ ដូច្នេះ ។

បទថា **ភិក្ខតិ** បានដល់ រមែងសូម ។ ពិតហើយ បុគ្គលខ្លះ រមែងសូម រមែងស្វះស្វែង រមែងស្វែងរកនូវភិក្ខាបានក្តី មិនបានក្តី នូវភិក្ខានោះដោយពិត បុគ្គលនោះ ឈ្មោះថា **ភិក្ខុ** ព្រោះអត្ថថា សូម ។ បទថា **ភិក្ខកោ** ( អ្នកសូម ) ព្រះមានព្រះភាគបន្ថែមបទព្យញ្ជនៈ អធិប្បាយថា ឈ្មោះថា **ភិក្ខុ** ព្រោះសូមជាធម្មតា ។

បទថា **ភិក្ខាចរិយំ អជ្ឈុបគតោ** ឈ្មោះថា **ភិក្ខាចរិយំ អជ្ឈុ-បគតោ** ព្រោះចូលដល់ភិក្ខាចារ ដែលព្រះពុទ្ធជាដើមចូលដល់ហើយ ។ ពិតហើយ បុគ្គលខ្លះ លះនូវគំនរភោគៈតិចខ្លះ ច្រើនខ្លះ បួសជាបព្វជិត ជាអ្នកមិនមានផ្ទះ លះនូវការចិញ្ចឹមជីវិតដោយកសិកម្ម និងគោរក្ខកម្មជាដើម ហើយជាអ្នកចូលដល់ភិក្ខាចារ ដោយភេទនោះឯង ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **ភិក្ខុ** ។ ម្យ៉ាងទៀត បុគ្គលណាបរិភោគភត្តដែលគេនាំមកដោយអម្រែក ក្នុងកណ្តាលវិហារ ព្រោះភាពជាបុគ្គលមានជីវិតទាក់ទងដោយបុគ្គលដទៃ ជាអ្នកចូលដល់ភិក្ខាចារ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **ភិក្ខុ** ។ ម្យ៉ាងទៀត បុគ្គលណាជាអ្នកចូលដល់ភិក្ខាចារ អាស្រ័យដុំបាយ ព្រោះកើតឧស្សាហៈក្នុងបព្វជ្ជា ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា

**ភិក្ខុ** ។

បុគ្គលណា ទ្រទ្រង់សំពត់ ដែលត្រូវទម្លាយ គឺធ្វើឲ្យថយតម្លៃ ថយនូវសម្ផស្ស ថយនូវពណ៌ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា ទ្រទ្រង់នូវសំពត់ដែលត្រូវទម្លាយ ។ ក្នុងការទម្លាយតម្លៃសម្ផស្ស និងពណ៌នោះ គប្បីជ្រាបការទម្លាយតម្លៃដោយការកាត់ដោយកាំបិត ។ ពិតហើយ ផ្ទាំងសំពត់ដែលមានតម្លៃរាប់ពាន់ កាលបុគ្គលកាត់ឲ្យជាកំណាត់តូចធំ ដោយកាំបិតហើយ រមែងជាសំពត់ថយតម្លៃ រមែងមិនបានតម្លៃត្រឹមពាក់កណ្ដាលនៃតម្លៃដើម ។ គប្បីជ្រាបការទម្លាយសម្ផស្ស ដោយការដេរដោយអំបោះ ។ ពិតហើយ ផ្ទាំងសំពត់ សូម្បីមានសម្ផស្សសប្បាយ ត្រូវដេរដោយអំបោះហើយ រមែងជាសំពត់ខូចនូវសម្ផស្ស រមែងដល់នូវភាពជាសំពត់ មានសម្ផស្សគ្រោតគ្រាត ។ គប្បីជ្រាបការទម្លាយពណ៌ដោយប្រេះនៃម្ជុលជាដើម ។ ពិតហើយ ផ្ទាំងសំពត់ សូម្បីស្អាតល្អហើយ រមែងជាផ្ទាំងសំពត់ដែលត្រូវទម្លាយដោយមន្ទិលនៃម្ជុល ចាប់តាំងអំពីការដេរ ដោយប្រឡាក់ញើសក្អែលធូលីរបស់ដៃជាដើម និងក្នុងទីបំផុតដោយការជ្រលក់ ការធ្វើកប្បៈ រមែងខុសទៅអំពីពណ៌ដើម ។ បុគ្គលណា ទ្រទ្រង់នូវសំពត់ដែលត្រូវទម្លាយហើយ ព្រោះការទ្រទ្រង់នូវសំពត់ដែលត្រូវទម្លាយ ដោយអាការ ៣ យ៉ាងនេះ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **ភិក្ខុ** ។ ម្យ៉ាងទៀត បុគ្គលណា ទ្រទ្រង់នូវសំពត់ដែលត្រូវទម្លាយហើយ ដោយហេតុត្រឹមតែការទ្រទ្រង់នូវសំពត់កាសាវៈ ដែលជាវិសភាគៈ អំពីសំពត់របស់គ្រហស្ថ ព្រោះហេតុនោះ

បុគ្គលនោះ ឈ្មោះថា **ភិក្ខុ** ។

ឈ្មោះថា **ភិក្ខុ** ព្រោះកំពុងទម្លាយនូវបាបអកុសលទាំងឡាយ គឺ ឈ្មោះថា **ភិក្ខុ** ព្រោះកំពុងទម្លាយនូវកិលេស ៥ ដោយសោតាបត្តិមគ្គ ។ ឈ្មោះថា **ភិក្ខុ** ព្រោះកំពុងទម្លាយនូវកិលេស ៤ ដោយសកទាគាមិមគ្គ ។ ឈ្មោះថា **ភិក្ខុ** ព្រោះកំពុងទម្លាយនូវកិលេស ៤ ដោយអនាគាមិមគ្គ ។ ឈ្មោះថា **ភិក្ខុ** ព្រោះកំពុងទម្លាយនូវកិលេស ៨ ដោយអរហត្តមគ្គ ។

ព្រះមានព្រះភាគ ទ្រង់សម្តែងបុគ្គលដែលតាំងនៅក្នុងមគ្គ ៤ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

ចំណែកបុគ្គលដែលតាំងនៅក្នុងផល ៤ ទ្រង់សម្តែងដោយពាក្យថា **ភិន្នត្តា** ។ ពិតហើយ ព្រះសោតាបន្ន ទម្លាយកិលេស ៥ យ៉ាង ដោយសោតាបត្តិមគ្គ ហើយតាំងនៅ ។ ព្រះសកទាគាមី ទម្លាយកិលេស ៤ ដោយសកទាគាមិមគ្គ ហើយតាំងនៅ ។ ព្រះអនាគាមី ទម្លាយកិលេស ៤ ដោយអនាគាមិមគ្គ ហើយតាំងនៅ ។ ព្រះអរហន្ត ទម្លាយកិលេស ៨ ដោយអរហត្តមគ្គ ហើយទាំងនៅ ។ ព្រះអរិយបុគ្គលដែលតាំងនៅក្នុងផល ៤ យ៉ាងនេះ ឈ្មោះថា **ភិក្ខុ** ព្រោះទម្លាយបាបអកុសលធម៌ទាំងឡាយហើយ ដោយប្រការដូច្នេះ ។

ក្នុងបទថា **ឱធិសោ កិលេសានំ បហានា** បទថា **ឱធិ** មាន ២ យ៉ាង **មគ្គោធិ** និង **កិលេសោធិ** ។ ព្រំដែន ឈ្មោះថា **ឱធិ** ក្នុងឱធិ ២ នោះ ព្រះសោតាបន្ន ឈ្មោះថា **ភិក្ខុ** ព្រោះលះកិលេសចំណែកខ្លះដោយ **មគ្គោធិ** ។

ពិតហើយ ព្រះសោតាបន្ននោះ លះកិលេសដោយឱធិមួយប៉ុណ្ណោះ ក្នុងទាំង ៤ មិនមែនលះដោយមគ្គទាំង ៤ ។ សូម្បីក្នុងព្រះសកទាគាមី និងព្រះអនាគាមី ក៏ន័យនេះដូចគ្នា ។ ព្រោះព្រះសោតាបន្ន ឈ្មោះថា **ភិក្ខុ** ព្រោះលះកិលេសចំណែកខ្លះ ដោយ **កិលេសោធិ** ។ ពិតហើយ ព្រះសោតាបន្ននោះ លះកិលេសដោយឱធិ ក្នុងកិលេសដែលលោកគួរលះប៉ុណ្ណោះ មិនមែនលះទៅម្ដងទាំងអស់ ។ ចំណែកព្រះអរហន្ត ឈ្មោះថា **ភិក្ខុ** ព្រោះលះកិលេសដោយមិនចំពោះ ។ ពិតហើយ ព្រះអរហន្ត លះកិលេសដោយមិនចំពោះ ដោយមគ្គ ៤ មិនមែនលះដោយព្រំដែននៃមគ្គតែមួយឡើយ ។ម្យ៉ាងទៀត ក្នុងកិលេសដែលគប្បីលះ លោកលះដោយមិនមានចំណែកសេសសល់ឡើយ ព្រោះថា ដែននៃកិលេសណាមួយ ឈ្មោះថា តាំងនៅមិនមាន ។ ព្រះអរហន្ត ឈ្មោះថា **ភិក្ខុ** ព្រោះលះកិលេសទាំងឡាយដោយមិនចំពោះ ដោយចំណែកទាំងពីរ ដូចពណ៌នាមក ដូច្នេះ ។

គប្បីជ្រាបវិគ្គហៈក្នុងបទថា **សេក្ខោ** ដូចតទៅ ព្រះអរិយបុគ្គល ៧ និងកល្យាណបុថុជ្ជន ដែលនៅសិក្សាសិក្ខា ៣ នៅឡើយ ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **សេក្ខ** ។ ព្រះសេក្ខៈណាមួយ ក្នុងលោកទាំងនោះ គប្បីជ្រាបថាជា **ភិក្ខុ** ។

ឈ្មោះថា **អសេក្ខោ** ព្រោះអត្ថថា មិនចាំបាច់សិក្សា ។ ព្រះខីណាស្រពឈានកន្លងសេក្ខធម៌ហើយ តាំងនៅក្នុងអគ្គផល ហៅថា **អសេក្ខ** ព្រោះមិនមានសេក្ខធម៌ ដែលគប្បីសិក្សាឲ្យក្រៃលែងជាងនោះ ។

*ភិក្ខុបុថុជ្ជនដ៏សេស កំពុងសិក្សាសិក្ខា ៣ ក៏មិនមែន សិក្សាហើយក៏មិនមែន ព្រោះហេតុនោះ គប្បីជ្រាបថា ភិក្ខុបុថុជ្ជននោះ ជាសេក្ខៈក៏មិនមែន ជាអសេក្ខៈក៏មិនមែន ។ ឈ្មោះថា* **ភិក្ខុ** *ព្រោះការសម្រេចធម៌ដ៏ប្រសើរនេះ គឺសីលដ៏ប្រសើរ សមាធិដ៏ប្រសើរ បញ្ញាដ៏ប្រសើរ វិមុត្តិដ៏ប្រសើរ តាំងនៅ ។*

*បុគ្គលមិនលាមក ឈ្មោះថា* **ភទ្រោ** *( បុគ្គលចម្រើន ) ។ ពិតហើយ តាំងអំពីកល្យាណបុថុជ្ជន រហូតដល់ព្រះអរហន្ត រមែងដល់នូវការរាប់ថា ជា* **ភិក្ខុ** *ដែលតាំងនៅក្នុងធម៌ស្អាត ព្រោះប្រកបដោយសីលដ៏ស្អាត សមាធិដ៏ស្អាត បញ្ញាដ៏ស្អាត វិមុត្តិដ៏ស្អាត វិមុត្តិញ្ញាណទស្សនៈដ៏ស្អាត ។*

*ភិក្ខុដែលផូរផង់ ឈ្មោះថា* **មណ្ឌោ** *( ផូរផង់ ) ។ អធិប្បាយថា បុគ្គលមិនល្អក់ មានសេចក្ដីផូរផង់វិសេស ដូចភាពផូរផង់របស់សប្បិ ។*

*បទថា* **សារោ** *គប្បីជ្រាបថា ឈ្មោះថា បុគ្គលប្រកបដោយធម៌ជាខ្លឹម ឈ្មោះថា* **ភិក្ខុ** *ព្រោះប្រកបដោយខ្លឹម គឺសីលជាដើមនោះឯង ដូចសំពត់ពណ៌ខៀវ ព្រោះប្រកបដោយពណ៌ខៀវ ។ ម្យ៉ាងទៀត ព្រះខីណាស្រព ប៉ុណ្ណោះ គប្បីជ្រាបថា ឈ្មោះថា ជាអ្នកមានធម៌ជាខ្លឹម ព្រោះប្រាសចាកកិលេសដែលឥតខ្លឹម ។*

*ម្យ៉ាងទៀត ក្នុងពាក្យថា ព្រះមានព្រះភាគត្រាស់ដល់ព្រះសេក្ខៈ ៧ ក្នុងឋានៈ ៣ គឺឈ្មោះថា* **ភិក្ខុ** *ព្រោះទម្លាយអកុសលធម៌ទាំងឡាយ ឈ្មោះថា* **ភិក្ខុ** *ព្រោះការលះកិលេសទាំងឡាយដោយចំណែក បុគ្គលជាសេក្ខៈ ឈ្មោះថា* **ភិក្ខុ** *ដូច្នេះ ។ ព្រះមានព្រះភាគ ត្រាស់ដល់ព្រះខីណាស្រព*

ប៉ុណ្ណោះ ក្នុងឋានៈទាំង ៥ នេះ គឺឈ្មោះថា **ភិក្ខុ** ព្រោះហេតុទម្លាយអកុសលធម៌ទាំងឡាយដ៏លាមក ឈ្មោះថា **ភិក្ខុ** ព្រោះការលះកិលេសទាំងឡាយដោយមិនមានចំណែក បុគ្គលជាអសេក្ខៈ ឈ្មោះថា **ភិក្ខុ** បុគ្គលប្រសើរ ឈ្មោះថា **ភិក្ខុ** បុគ្គលផូរផង់ ឈ្មោះថា **ភិក្ខុ** ។ ព្រះមានព្រះភាគត្រាស់បុថុជ្ជនប៉ុណ្ណោះក្នុងបទនេះថា បុគ្គលជាសេក្ខៈក៏មិនមែន ជាអសេក្ខៈក៏មិនមែន ។ ទ្រង់ត្រាស់ដល់បុគ្គលទាំងនេះ គឺកល្យាណបុថុជ្ជន ព្រះសេក្ខៈ ៧ ពួក និងព្រះខីណាស្រព ក្នុងឋានៈដ៏សេស ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងភិក្ខុដោយសញ្ញាជាដើមយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្តែងអំណាចនៃឧបសម្បទា ទើបត្រាស់ថា **សមគ្គេន សង្ឃេន** ជាដើម ។ ក្នុងបទទាំងនោះ បទថា **សមគ្គេន សង្ឃេន** បានដល់ ចូលដល់ហើយនូវភាពជាអ្នកព្រមព្រៀងក្នុងកម្មឯណានីមួយ ព្រោះកម្មដែលកំណត់យ៉ាងទាប ត្រូវមានភិក្ខុជាគម្រប់ ៥ ភិក្ខុដែលធ្វើសង្ឃកម្មមកហើយ ព្រោះនាំឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈមក និងព្រោះមិនមានការជំទាស់របស់ភិក្ខុដែលនៅចំពោះមុខ ។ បទថា **ញត្តិចតុត្ថេន** បានដល់ កម្មដែលសង្ឃគប្បីធ្វើដោយអនុស្សាវនា ៣ ដង និងដោយញត្តិ ១ ដង ។ បទថា **កម្មេន** បានដល់ ដោយវិន័យកម្មដែលប្រកបដោយធម៌ ។ បទថា **អកុប្បេន** បានដល់ ចូលដល់ភាពជាកម្មដែលធ្វើឲ្យកម្រើកមិនបាន ដែលមិនត្រូវជំទាស់ ព្រោះដល់ព្រមដោយវត្ថុសម្បត្តិ ញត្តិសម្បត្តិ អនុស្សាវនាសម្បត្តិ សីមាសម្បត្តិ និងបរិសទសម្បត្តិ ។ បទថា **ឋានារហេន** បានដល់

គួរដល់ហេតុ គួរដល់សត្ថុសាសនៈ ។

បុគ្គលចូលដល់ហើយ គឺសម្រេចហើយនូវភាវៈខាងលើ ឈ្មោះថា **ឧបសម្បន្ន** ។ ពិតហើយ ភាពជាភិក្ខុ ឈ្មោះថា ភាវៈខាងលើ ព្រះមានព្រះភាគត្រាស់ហៅភាវៈខាងលើថា **ឧបសម្បន្ន** ព្រោះជាអ្នកដល់ព្រមដោយកម្ម តាមដែលពោលមកហើយ ។ ដោយបទថា **ឧបសម្បន្ន** នេះ ព្រះមានព្រះភាគត្រាស់ឧបសម្បទា ៨ យ៉ាង ពួកណា គឺឧបសម្បទា ៨ យ៉ាងនេះថា ឯហិភិក្ខុឧបសម្បទា ១ សរណគមនឧបសម្បទា ១ ឱវាទបដិគ្គហណឧបសម្បទា ១ បញ្ហាព្យាករណឧបសម្បទា ១ គរុធម្មបដិគ្គហណឧបសម្បទា ១ ទូតេនឧបសម្បទា ១ អដ្ឋវាចិកាឧបសម្បទា ១ ញត្តិចតុត្ថកម្មឧបសម្បទា ១ ។

បណ្ដាឧបសម្បទាទាំងនោះ ឧបសម្បទា ៣ គឺញត្តិចតុត្ថកម្មឧបសម្បទា ១ ទូតេនឧបសម្បទា ១ អដ្ឋវាចិកាឧបសម្បទា ១ ទាំងនេះប៉ុណ្ណោះមាំទាំឯឧបសម្បទាដ៏សេស មានត្រឹមតែសម័យព្រះពុទ្ធគង់ព្រះជន្មនៅប៉ុណ្ណោះ ។ បណ្ដាឧបសម្បទាទាំងនោះ ក្នុងទីនេះ លោកបំណងយកញត្តិចតុត្ថកម្មឧបសម្បទាតែម្យ៉ាង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃបាតិមោក្ខសំវរៈ បទថា **ចាតិមោក្ខំ** បានដល់ សីលដែលជាសិក្ខាបទ ។ ពិតហើយ សីល គឺសិក្ខាបទប៉ុណ្ណោះ ព្រះមានព្រះភាគត្រាស់ថា បាតិមោក្ខ ព្រោះបុគ្គលណា គ្រប់គ្រងរក្សាសីល គឺសិក្ខាបទប៉ុណ្ណោះ សីលនោះ រមែងញុំាងបុគ្គលនោះឲ្យរួចផុត រមែងដោះចាក

ទុក្ខទាំងឡាយ មានទុក្ខក្នុងអបាយជាដើម ។

បទថា **សីលំ បតិដ្ឋា** ជាដើម ជាវេវចនៈរបស់បទថា **ចាតិមោក្ខ** នោះឯង ។ ក្នុងពាក្យទាំងនោះ ពាក្យថា **សីល** នេះ ជាវេវចនៈរបស់បាតិមោក្ខ ដែលសម្រេចព្រមជាមួយការបញ្ចប់កម្មវាចាក៏ពិត តែពោលដោយធម៌ ធម៌ទាំងឡាយមានចេតនាជាដើមរបស់បុគ្គលដែលវៀរចាកបាណាតិបាតជាដើម ឬបុគ្គលញុំាងវត្តបដិបត្តិឲ្យពេញ គប្បីជ្រាបថា សេចក្តីនោះ ក៏ជាសីល ។ សមដូចព្រះសារីបុត្តពោលក្នុងបដិសម្ភិទាថា សំណួរថា អ្វី ឈ្មោះថា សីល ចេតនា ឈ្មោះថា សីល ចេតសិក ឈ្មោះថា សីល សេចក្តីសង្រួម ឈ្មោះថា សីល ការមិនប្រព្រឹត្តកន្លង ឈ្មោះថា សីល ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ចេតនារបស់បុគ្គលដែលវៀរចាកបាណាតិបាតជាដើម ឬការញុំាងវត្តបដិបត្តិឲ្យពេញ ឈ្មោះថា ចេតនាជាសីល ។

ការវៀររបស់បុគ្គលដែលវៀរចាកបាណាតិបាតជាដើម ឈ្មោះថា ចេតសិកជាសីល ។ ម្យ៉ាងទៀត ចេតនាដែលប្រព្រឹត្តទៅក្នុងកម្មបថ ៧ របស់បុគ្គលដែលលះបាណាតិបាតជាដើម ក៏ឈ្មោះថា ចេតនាជាសីល ។ ក្នុងសំយុត្តនិកាយ មហាវារវគ្គ លោកពោលធម៌ គឺការមិនលោភ មិនព្យាបាទ និងសម្មាទិដ្ឋិដោយន័យជាដើមថា បុគ្គលលះអភិជ្ឈា នៅដោយចេតនាប្រាសចាកសេចក្តីលោភ ដូច្នេះ ក៏ឈ្មោះថា ចេតសិកសីល ។

ក្នុងពាក្យថា សេចក្តីសង្រួម ឈ្មោះថា សីល គប្បីជ្រាបការសង្រួម ៥ គឺបាតិមោក្ខសំវរៈ ១ សតិសំវរៈ ១ ញាណសំវរៈ ១ ខន្តិសំវរៈ ១

វីរិយសំវរៈ ១ ។ ការផ្សេងគ្នានៃការសង្រួមទាំងនោះ លោកពោលក្នុងបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គ ។

ពាក្យថា ការមិនប្រព្រឹត្តកន្លង ឈ្មោះថា សីល អធិប្បាយថា ការមិនឈានកន្លង ដែលប្រព្រឹត្តទៅផ្លូវកាយ និងវាចារបស់បុគ្គលដែលសមាទានសីលហើយ ។

ពាក្យថា សេចក្តីសង្រួម ឈ្មោះថា សីល ការមិនប្រព្រឹត្តកន្លង ឈ្មោះថា សីល នេះឯង គប្បីជ្រាបថា ជាសីលដោយត្រង់ ។ ពាក្យថា ចេតនា ឈ្មោះថា សីល ចេតសិក ឈ្មោះថា សីល គប្បីជ្រាបថា ជាសីលដោយអម ព្រោះភិក្ខុ ឈ្មោះថា រមែងតាំងមាំក្នុងសាសនា ដោយបាតិមោក្ខសំវរសីល ហេតុនោះ ទើបបាតិមោក្ខសំវរសីលនោះ ព្រះមានព្រះភាគត្រាស់ថា **បតិដ្ឋា** គឺការតាំងមាំ ដូច្នេះ ។

ភិក្ខុតាំងមាំនៅក្នុងសីលនេះ ឬកុសលធម៌ទាំងឡាយប៉ុណ្ណោះ រមែងតាំងមាំនៅក្នុងសីលនេះ ព្រោះហេតុនោះ ទើបសីលឈ្មោះថា **បតិដ្ឋា** ។

សេចក្តីនេះ គប្បីជ្រាបដោយអំណាចព្រះសូត្រ ( សំយុត្តនិកាយ សគាថវគ្គ ) ថា

នរជនមានប្រាជ្ញា បានតាំងមាំក្នុងសីល ហើយចម្រើននូវសមាធិចិត្ត និងវិបស្សនាបញ្ញា ជាអ្នកមានព្យាយាមដុតកម្តៅកិលេស ប្រកបដោយបារិហារិយប្បញ្ញា ជាអ្នកឃើញភ័យក្នុងសង្សារ បុគ្គលនោះ ទើបកាប់ឆ្ការនូវតណ្ហាជាគ្រឿងចាក់ស្រែះនេះបាន ដូច្នេះ ។

និងព្រះសូត្រថា មហាបពិត្រ សីលជាទីតាំងនៃកុសលធម៌ទាំងពួង ។ និងសូត្រថា មហាបពិត្រ កាលបុគ្គលអាស្រ័យសីលហើយ កុសលធម៌ទាំងពួង រមែងមិនវិនាសទៅដោយជុំវិញ ដូច្នេះជាដើម ។

សីលនោះ ឈ្មោះថា កិច្ចខាងដើម ព្រោះអត្ថថា កើតឡើងមុន សមដូចព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលឧត្តិយៈ បើដូច្នោះ ក្នុងសាសនានេះ ចូរអ្នកជម្រះនូវដើមនៃកុសលធម៌ទាំងឡាយសិន ។ ចុះអ្វី ជាដើមនៃកុសលធម៌ទាំងឡាយ ។ គឺសីលស្អាតល្អ ១ ទិដ្ឋិត្រង់ ១ ដូច្នេះ ។

ប្រៀបដូចមេជាងអ្នកសាងនគរ មានបំណងនឹងសាងនគរ រមែងជម្រះផ្ទៃដីរបស់នគរមុន ក្រោយមក ទើបបែងចែកទីសាងនគរ ដោយកំណត់យកផ្លូវ និងផ្លូវបែកជា ៤ ជាដើមហើយ ទើបសាងនគរ យ៉ាងណា ព្រះយោគាវចរ ក៏យ៉ាងនោះ រមែងជម្រះសីលតាំងអំពីខាងដើមនោះឯងឲ្យបរិសុទ្ធ ខាងក្រោយអំពីនោះ រមែងធ្វើឲ្យជាក់ច្បាស់នូវសមថៈ វិបស្សនា មគ្គ ផល និងព្រះនិព្វាន ។

ម្យ៉ាងទៀត ប្រៀបដូចជាងជ្រលក់ បោកគក់សំពត់ដោយទឹកក្បុង ៣ យ៉ាង កាលសំពត់ស្អាតល្អហើយ ទើបជ្រលក់ដោយពណ៌ផ្សេងៗ តាមប្រាថ្នា យ៉ាងណា ឬថា វិចិត្រករជាអ្នកឈ្លាស ប្រាថ្នានឹងគូររូប រមែងធ្វើការតាក់តែងទាំងសំពត់សម្រាប់គូរជាមុន បន្ទាប់អំពីនោះ ទើបគូររូប យ៉ាងណា ព្រះយោគាវចរក៏យ៉ាងនោះដូចគ្នា ជម្រះសីលអំពីខាងដើមឲ្យបរិសុទ្ធ

បន្ទាប់អំពីនោះ ក៏ធ្វើឲ្យជាក់ច្បាស់នូវសមថៈ និងវិបស្សនាជាដើម ព្រោះហេតុនោះ ទើបសីល ទ្រង់ត្រាស់ថា កិច្ចខាងដើម ដូច្នេះ ។

សីលនោះ ឈ្មោះថា ការប្រព្រឹត្ត ព្រោះជាធម្មជាតដូចគ្នានឹងជើងជាគ្រឿងដើរទៅ ពិតហើយ ជើង ព្រះមានព្រះភាគត្រាស់ហៅថាជា **ចរណ** ដូចសភាវៈនៃការតាក់តែងឲ្យដើរទៅកាន់ទិស រមែងមិនកើតដល់បុរសដែលមានជើងកំបុតហើយ រមែងកើតដល់បុរសដែលមានជើងគ្រប់គ្រាន់នោះឯងយ៉ាងណា សេចក្តីនេះក៏យ៉ាងនោះ សីលរបស់បុគ្គលណាបែកធ្លាយហើយដាច់ហើយ មិនសម្បូរហើយ ការប្រព្រឹត្តទៅនៃញាណដើម្បីសម្រេចព្រះនិព្វាន ក៏រមែងមិនសម្រេចដល់បុគ្គលនោះ ។ ចំណែកសីលនោះ របស់បុគ្គលណា មិនបែក មិនដាច់ បរិបូណ៌ហើយ ការប្រព្រឹត្តទៅនៃញាណដើម្បីសម្រេចព្រះនិព្វាន រមែងសម្រេចដល់បុគ្គលនោះ ព្រោះហេតុនោះទើបសីល ព្រះមានព្រះភាគត្រាស់ថា ការប្រព្រឹត្ត ដូច្នេះ ។

សីលនោះ ឈ្មោះថា **សញ្ញមោ** ដោយអំណាចនៃការសង្រួម ឈ្មោះថា **សំវរោ** ដោយអំណាចនៃការរវាំង ។ ដោយហេតុទាំងពីរនេះ ទើបព្រះមានព្រះភាគត្រាស់ថា សីលជាការសង្រួម និងជាការរវាំង ដូច្នេះ ។

គប្បីជ្រាបអត្ថនៃពាក្យក្នុងទីនេះដូចតទៅ សភាវៈណា គ្រប់គ្រងនូវការអន្ទះអន្ទែង ដោយឈានកន្លង ឬញុំាងបុគ្គលឲ្យសង្រួម គឺមិនឲ្យបុគ្គលនោះអន្ទះអន្ទែង ដោយអំណាចការឈានកន្លង ព្រោះហេតុនោះ ទើបសភាវៈនោះឈ្មោះថា **សញ្ញមោ** ។ សភាវៈណា រវាំង គឺរាំងនូវទ្វារដែលចូលទៅនៃ

ការកន្លងល្មើស ព្រោះហេតុនោះ ទើបសការៈនោះ ឈ្មោះថា **សំវរោ** ។

បទថា **មុខំ** បានដល់ ជាធម៌ឧត្តម ឬជាប្រធាន ដូចអាហារ ៤ យ៉ាង(១) របស់សត្វទាំងឡាយ ចូលទៅតាមមាត់ហើយ រមែងផ្សាយទៅកាន់អវយវៈតូចធំ យ៉ាងណា កុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៤ របស់ព្រះយោគី ក៏យ៉ាងនោះ ចូលទៅតាមមាត់ គឺសីលហើយ រមែងញ៉ាំងនូវការសម្រេចនៃប្រយោជន៍ឲ្យបរិបូណ៌ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **មុខំ** ដូច្នេះ ។

ឈ្មោះថា **បាមោក្ខំ** ព្រោះអត្ថថា ឲ្យសម្រេចប្រយោជន៍ដោយភាពជាប្រមុខ អធិប្បាយថា ជាធម្មជាតដល់មុន ជាធម្មជាតប្រសើរបំផុត ជាប្រធាន ។ បទថា **កុសលានំ ធម្មានំ សមាបត្តិយា** បណ្ឌិតគប្បីជ្រាបថា សីលជាប្រមុខ ជាធម្មជាតដល់មុន ជាធម្មជាតដ៏ប្រសើរបំផុត ជាប្រធាន ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវកុសល ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។

បទថា **កាយិកោ អវីតិក្កមោ** បានដល់ កាយសុចរិត ៣ យ៉ាង ។ បទថា **វាចសិកោ** បានដល់ វចីសុចរិត ៤ ។ បទថា **កាយិកវាចសិកោ** ព្រះមានព្រះភាគទ្រង់រួមសម្ដែងអាជីវដ្ឋមកសីល ដោយការមិនកន្លងល្មើសតាមផ្លូវកាយ និងវាចានេះ ។

បទថា **សំវុតោ** បានដល់ ដែលគេបិទហើយ អធិប្បាយថា មាន

---

១- អាហារ ៤ យ៉ាង គឺរបស់ទំពា របស់បរិភោគ របស់ទិលភ្លក្ស និងរបស់សម្រាប់ហិត ( ដីកា ) ។

ឥន្ទ្រិយដែលសង្រួមហើយ គឺមានឥន្ទ្រិយដែលបិទហើយ ដូចស្រុកមានទ្វារបិទហើយ លោក ហៅថា ស្រុកដែលគេបិទហើយ ស្រុកដែលគេការពារហើយ យ៉ាងណា ក្នុងសេចក្តីនេះក៏យ៉ាងនោះ ភិក្ខុមានឥន្ទ្រិយសង្រួមហើយ ព្រះមានព្រះភាគត្រាស់ថា **សំវុតោ** ។

បទថា **បាតិមោក្ខសំវរេន** បានដល់ ដោយបាតិមោក្ខ និងសំវរៈ ។ ម្យ៉ាងទៀត បានដល់ ដោយសំវរៈ ពោល គឺបាតិមោក្ខ ។ បទថា **ឧបេតោ** ជាដើម មានអត្ថដូចពោលហើយនោះឯង ។ ព្រះមានព្រះភាគត្រាស់ការនៅដោយឥរិយាបថរបស់ភិក្ខុ ដែលតាំងនៅក្នុងបាតិមោក្ខសំវរសីល ដោយបទទាំង ៧ មានពាក្យថា **វិហរតិ** ជាដើម ។

ក្នុងនិទ្ទេសនៃអាចារ និងគោចរ ព្រះមានព្រះភាគ ទ្រង់បំណងនឹងត្រាស់ដល់អាចាររបស់សមណៈ គោចររបស់សមណៈ ទើបទ្រង់លើកបទថា **អាចារគោចរសម្បន្នោ** មានអធិប្បាយថា អាចារក៏មាន អនាចារក៏មាន ក៏ពិត តែដូចបុរសអ្នកឈ្លាសក្នុងផ្លូវ កាលប្រាប់ផ្លូវ ក៏ពោលថា ចូរអ្នកបោះបង់ផ្លូវខាងឆ្វេង កាន់យកផ្លូវខាងស្តាំ រមែងប្រាប់ផ្លូវដែលមានភ័យ ផ្លូវដែលខុស ដែលបុគ្គលគប្បីលះបង់ជាមុន ខាងក្រោយ ទើបប្រាប់ផ្លូវដ៏ក្សេម ផ្លូវដែលត្រង់ ដែលបុគ្គលគប្បីកាន់យក យ៉ាងណា សេចក្តីនេះក៏យ៉ាងនោះឯង ព្រះធម្មរាជា ដូចគ្នានឹងបុរសដែលឈ្លាសក្នុងផ្លូវ ទ្រង់បំណងប្រាប់អនាចារ ដែលព្រះពុទ្ធទ្រង់វៀរហើយ ដែលបុគ្គលគប្បីលះបង់មុន ទ្រង់ប្រាប់អាចារខាងក្រោយ ទើបត្រាស់ថា **តត្ថ កតមោ អនាចារោ**

ជាដើម ។ ពិតហើយ ផ្លូវដែលបុគ្គលប្រាប់ហើយ គប្បីទៅដល់ ឬមិនដល់ក៏បាន ចំណែកផ្លូវដែលព្រះតថាគតប្រាប់ហើយ ជាផ្លូវមិនខុស ជាផ្លូវមិនភ្លាំងភ្លាត់ រមែងប្រជុំចុះក្នុងនគរ គឺព្រះនិព្វាននោះឯង ដូចវជិរាវុធ ដែលព្រះឥន្ទ្រទ្រង់គ្រវែងទៅហើយ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ ) ថា ម្នាលតិស្សៈ ពាក្យថា បុរសស្ទាត់ក្នុងផ្លូវនោះ ជាឈ្មោះរបស់ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ដូច្នេះ ។

ម្យ៉ាងទៀត ព្រោះការប្រកបសេចក្ដីព្យាយាមក្នុងកល្យាណធម៌ រមែងជាធម៌ដែលសម្បូរដល់បុគ្គលដែលមានបាបធម៌លះហើយ ប្រៀបដូចការទ្រទ្រង់នូវគ្រឿងប្រដាប់ មានកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាបជាដើម ជារបស់សមគួរដល់បុគ្គលដែលជម្រះញើសក្អែល និងមន្ទិលហើយ ដោយការងូតទឹក ព្រមទាំងកក់ក្បាល ហេតុនោះ ព្រះមានព្រះភាគទ្រង់បំណងនឹងប្រាប់អនាចារ ដែលបុគ្គលគប្បីលះមុន ដូចញើសក្អែល និងមន្ទិល ដែលបុគ្គលគួរជម្រះ ខាងក្រោយ ទើបប្រាប់អាចារដែលប្រៀបដូចការទ្រទ្រង់នូវគ្រឿងប្រដាប់ មានផ្កាកម្រង គ្រឿងក្រអូប និងគ្រឿងលាបជាដើម របស់បុគ្គលជម្រះញើសក្អែល និងមន្ទិលហើយ ទើបត្រាស់ថា **តត្ថ កតមោ អនាចារោ** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **កាយិកោ វីតិក្កមោ** បានដល់ កាយទុច្ចរិត ៣ ។ បទថា **វាចសិកោ វីតិក្កមោ** បានដល់ វចីទុច្ចរិត ៤ ។ បទថា **កាយិកវាចសិកោ វីតិក្កមោ** បានដល់ ទុច្ចរិតទាំង ២ គឺកាយ-

ទុច្ចរិត ៣ និងវចីទុច្ចរិត ៤ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងការឈាន
កន្លងអាជីវដ្ឋមកសីលនោះឯង ដោយអាការយ៉ាងនេះ ព្រោះបុគ្គលប្រព្រឹត្ត
អនាចារតាមផ្លូវកាយ និងវាចាតែម្យ៉ាងប៉ុណ្ណោះក៏មិនមែន រមែងប្រព្រឹត្ត
សូម្បីផ្លូវចិត្តផងដែរ ហេតុនោះ ដើម្បីទ្រង់សម្តែងសេចក្តីនោះ ទើបព្រះមាន
ព្រះភាគត្រាស់ថា **សព្វម្បិ ទុស្សីល្យំ អនាចារោ** ដូច្នេះ ។

ក្នុងសេចក្តីនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងចែកអនាចារ
ឯណាទីមួយ ទើបត្រាស់បទថា **ឥធេកច្ចោ វេឡុទានេន** ជាដើម ។

បណ្តាបទទាំងនោះ បទថា **វេឡុទានេន** បានដល់ ការឲ្យឫស្សី ដែល
ជាហេតុនៃបច្ច័យ ៤ ពិតហើយ ភិក្ខុមិនគួរឲ្យឫស្សីដែលដុះឯងក្នុងវត្ត ឬ
ឫស្សីដែលនាំមកអំពីព្រៃ រក្សាដល់ពួកឧបដ្ឋាក ដោយគិតថា ពួកគេនឹង
ឲ្យបច្ច័យ ៤ ដល់អញដោយអាការយ៉ាងនេះ ព្រោះថា ភិក្ខុកាលចិញ្ចឹមជីវិត
យ៉ាងនេះ ឈ្មោះថា រស់នៅដោយការស្វែងរកដែលមិនប្រកបដោយធម៌ ជា
មិច្ឆាអាជីវៈ ។ ភិក្ខុនោះឯង រមែងត្រូវនូវពាក្យនិន្ទាក្នុងបច្ចុប្បន្ន រមែងធ្លាក់
ទៅក្នុងអបាយក្នុងភពខាងមុខ ។ ភិក្ខុនោះ កាលឲ្យឫស្សីដែលជារបស់ចំពោះ
ខ្លួន ដើម្បីសង្គ្រោះត្រកូល រមែងត្រូវអាបត្តិទុក្កដឈ្មោះកុលទូសកៈ កាល
ឲ្យឫស្សីដែលជារបស់អ្នកដទៃដោយថេយ្យចិត្ត សង្ឃគប្បីកាត់អាបត្តិតាម
តម្លៃទ្រព្យ ។ ឯការឲ្យឫស្សីដែលជារបស់សង្ឃ ក៏ន័យនេះដូចគ្នា បើភិក្ខុឲ្យ
ឫស្សីនោះ ព្រោះភាពដែលខ្លួនជាធំ ភិក្ខុក៏ត្រូវអាបត្តិ ព្រោះលះគរុភណ្ឌ ។

ឈើប្រភេទណាជាគរុភណ្ឌ ប្រភេទណាមិនជាគរុភណ្ឌ គប្បីជ្រាបដូច

តទៅនេះថា ឫស្សីណា មិនបានដាំ កើតឡើងឯងមុន ឫស្សីនោះជាគរុភណ្ឌ ក្នុងទីដែលសង្ឃកំណត់ប៉ុណ្ណោះ ក្រៅអំពីនោះ មិនជាគរុភណ្ឌ ។ ឫស្សីក្នុងទីដែលត្រូវដាំ ជាគរុភណ្ឌទាំងអស់គ្រប់ប្រការ ឫស្សីនោះ លោកកំណត់ដោយប្រមាណ ។ ពិតហើយ ឫស្សីប្រមាណប៉ុនទាឡវិល្លិប្រេង ចាត់ជាគរុភណ្ឌ តូចជាងនោះមិនជាគរុភណ្ឌ ។ម្យ៉ាងទៀត ភិក្ខុដែលត្រូវការដោយទាឡវិល្លិប្រេង ឬត្រូវការឈើប្រត់ គប្បីធ្វើផាតិកម្ម ( ការដោះដូរ ) កាន់យកចុះ ។ ផាតិកម្មជារបស់មានតម្លៃស្មើគ្នា ឬមានតម្លៃច្រើនជាងរមែងគួរ តិចជាងមិនគួរឡើយ ។ ផាតិកម្មដោយការធ្វើការងារ ត្រឹមតែដងទឹក ឬត្រឹមតែធ្វើដោយការជម្រះស្មៅបន្តិចបន្តួច មិនគួរ បើធ្វើវត្ថុដែលជាថាវរៈ គួរ ព្រោះហេតុនោះ ការដែលភិក្ខុកោយកក់ឡើងអំពីស្រះទឹកក្ដី ឲ្យក្រាលផែនដីត្រង់ជណ្ដើរក្ដី ធ្វើទីដែលមិនស្មើឲ្យស្មើក្ដី ហើយកាន់យក គួរ ។ បើនាំឫស្សីដែលមិនបានធ្វើផាតិកម្មមកប្រើប្រាស់ ភិក្ខុដែលអាស្រ័យនៅក្នុងទីនោះឯង គប្បីប្រើប្រាស់ កាលភិក្ខុចៀសចេញទៅហើយ គប្បីធ្វើនូវរបស់នោះឲ្យជារបស់សង្ឃហើយទៅចុះ កាលភិក្ខុមិនមានស្មារតី កាន់យកទៅ កាលទៅហើយក្នុងទីណាឮកបាន គប្បីនាំត្រឡប់មកសងក្នុងទីនោះ បើភ័យមានក្នុងរវាងផ្លូវ គប្បីដាក់វត្ថុនោះក្នុងវិហារ ដែលខ្លួនទៅដល់ហើយទៅចុះ ។ ពួកមនុស្សទៅកាន់វិហារសូមឫស្សី ភិក្ខុទាំងឡាយមិនអាចឲ្យបាន ដោយប្រាប់ថា នុ៎ះជារបស់សង្ឃ បើពួកអ្នកស្រុកសូមរឿយៗ ឬគំរាមក្នុងពេលនោះ ភិក្ខុទាំងឡាយគប្បីពោលថា ចូរអ្នកទាំងឡាយធ្វើទណ្ឌកម្ម ( ធ្វើការងារដើម្បីដោះដូរ )

ហើយកាន់យកចុះ គួរ ឈ្មោះថា ការឲ្យឫស្សី មិនមាន ។ បើពួកមនុស្ស ទាំងនោះប្រគេនវត្ថុ មានកាំបិត និងពូថៅជាដើម ឬខាទនីយៈ ភោជនីយៈ ដើម្បីធ្វើឲ្យជាទណ្ឌកម្ម មិនគួរទទួល ។ ក្នុងអដ្ឋកថាព្រះវិន័យពោលថា ពួកមនុស្សត្រូវភ្លើងឆេះផ្ទះ កាន់យកទៅ ភិក្ខុមិនគួរហាម ។

បើខូតកើតឡើងត្រង់គុម្ពឫស្សីរបស់សង្ឃ កាលមិនមានអ្នកណាគោះឫស្សីនោះវិនាសទៅ សង្ឃគប្បីធ្វើដូចម្តេច សង្ឃគប្បីប្រាប់ពួកមនុស្សក្នុងពេលដែលទៅភិក្ខាចារ បើពួកគេមិនប្រាថ្នាជួយធ្វើ គប្បីពោលថា ពួកលោកនឹងបានចំណែកស្មើគ្នា បើពួកគេមិនត្រូវការ គប្បីពោលថា ពួកអ្នកនឹងបាន ២ ចំណែក បើពួកគេមិនប្រាថ្នាសូម្បីដោយអាការយ៉ាងនេះ ប្រយោជន៍ដោយឫស្សីដែលវិនាសហើយនេះមិនមាន គប្បីប្រាប់ថា កាលពួកអ្នកមានពេល ចូរពួកអ្នកធ្វើទណ្ឌកម្មកាប់ឫស្សី ហើយយកចុះ ។ ឈ្មោះថា ការឲ្យឫស្សី មិនមាន សូម្បីគុម្ពឫស្សីត្រូវភ្លើងឆេះក្តី ឬត្រូវទឹកកួចទៅក្តី ក៏ន័យនេះដូចគ្នា ។

កថាមគ្គនេះឯង ក៏បានក្នុងដើមឈើទាំងឡាយ ។ សម្រាប់ដើមឈើមានប្រមាណប៉ុនដងដែកចារ ក៏ចាត់ជាគរុភណ្ឌបាន ។ ភិក្ខុឲ្យកាត់ដើមឈើដែលជារបស់សង្ឃមិនសូមអនុញ្ញាតសង្ឃជាមុន រមែងបានដើម្បីធ្វើអាវាសដែលជារបស់សង្ឃ តែដើម្បីដោះនូវវាទៈគប្បីសូមអនុញ្ញាតហើយសឹមធ្វើ ។

សួរថា ភិក្ខុឲ្យកាត់ដើមឈើរបស់សង្ឃ មិនសូមអនុញ្ញាតអំពីសង្ឃមុន គួរធ្វើអាវាសចំពោះបុគ្គលដែរឬទេ ឆ្លើយថា មិនគួរ ។ ការពោលដោយហត្ថកម្មយ៉ាងខ្ពស់ ភិក្ខុរមែងបានត្រឹមតែទីតម្កល់គ្រែក្នុងកុដិមួយខ្នង ក្នុងកុដិ

៣ ខ្នង ភិក្ខុមានសិទ្ធិបានមួយខ្នង ។ បើទ្រព្យសម្ភារជារបស់បុគ្គល ផ្ទៃដីជារបស់សង្ឃ ភិក្ខុធ្វើកុដិមួយខ្នងរមែងបានចំណែកស្មើគ្នា ។ ក្នុងកុដិ ២ ខ្នង លោកគួរបានមួយខ្នង ។ សួរថា កាលដើមឈើដែលជារបស់សង្ឃ បៀតបៀនអាវាស ( លំនៅ ) របស់សង្ឃ ភិក្ខុមិនសូមអនុញ្ញាតអំពីសង្ឃជាមុន ឲ្យនាំចេញទៅ តើគួរដែរឬទេ ឆ្លើយថា គួរ តែដើម្បីកាត់នូវគន្លងនៃវាទៈ គួរសូមអនុញ្ញាតសង្ឃមុនហើយ សឹមនាំចេញទៅ ។ បើលាភផលរបស់សង្ឃអាស្រ័យដើមឈើមាន ក៏មិនគួរនាំចេញទៅ ។

កាលដើមឈើដែលជារបស់ចំពោះបុគ្គល បៀតបៀនអាវាសដែលជារបស់សង្ឃ គប្បីប្រាប់ដល់ម្ចាស់ដើមឈើ ។ បើម្ចាស់ឈើមិនប្រាថ្នានឹងនាំចេញទៅ គប្បីឲ្យបុគ្គលកាប់មុន ហើយសឹមនាំចេញទៅ បើគេប្រាប់ថា សូមលោកម្ចាស់សងដើមឈើដល់ខ្ញុំ គប្បីឲ្យគេវាយតម្លៃដើមឈើនោះ ហើយឲ្យទ្រព្យតាមតម្លៃ បើដើមឈើដែលជារបស់សង្ឃ បៀតបៀនលំនៅរបស់បុគ្គលក្តី ដើមឈើដែលជារបស់បុគ្គលបៀតបៀនអាវាសរបស់បុគ្គលក្តី ក៏មានន័យដូចគ្នា ។

កថាមគ្គក្នុងវល្លិមានដូចតទៅនេះ ក្នុងទីណាវល្លិគេធ្វើការលក់ដូរ ជារបស់ក្រ ក្នុងទីនោះ ចាត់ជាគរុភណ្ឌ បើវល្លិនោះប្រវែងកន្លះលូក ( មួយហត្ថ ) ចាត់ជាគរុភណ្ឌ កំណាត់វល្លិខ្លីជាងនោះ មិនជាគរុភណ្ឌ ។

ក្នុងការឲ្យស្លឹកឈើជាដើម បណ្ឌិតគប្បីជ្រាបពាក្យទាំងពួង មានពាក្យថា **បត្តទានេន** ជាដើម ដោយន័យដែលពោលហើយក្នុងការឲ្យឫស្សីនោះ

ឯង ។ គប្បីជ្រាបវិនិច្ឆ័យក្នុងការឲ្យស៊ីកឈើនេះដោយភាពជាគរុភណ្ឌដូចតទៅ ពិតហើយ ស៊ីកឈើដែលជនទាំងឡាយលក់ដូរក្នុងទីណា ជនទាំងឡាយ មានអ្នកធ្វើគម្ពីរជាដើម រមែងទិញយកដើម្បីប្រយោជន៍ដល់ការធ្វើជាគម្ពីរ ជាដើម ( ស៊ីករឹត ) ក្នុងទីដែលរកបានដោយក្របែបនោះ ចាត់ជាគរុភណ្ឌ នោះឯង ។ វិនិច្ឆ័យនេះជាវិនិច្ឆ័យក្នុងស៊ីករលួសផ្អុង និងស៊ីកត្នោតដែលធ្វើ ជាគ្រឿងប្រដាប់ត្រចៀកមុន ។ ក្នុងស៊ីកត្នោត បណ្ឌិតគប្បីពោលក្នុងឋានៈ នេះដូចគ្នា ។ ពិតហើយ ក្នុងស៊ីកត្នោត ត្នោតណាកើតឯង ក្នុងទីដែលសង្ឃ កំណត់នោះឯង ចាត់ជាគរុភណ្ឌ ក្រៅអំពីនោះ មិនចាត់ជាគរុភណ្ឌ ត្នោត ដែលសង្ឃដាំ ចាត់ជាគរុភណ្ឌទាំងអស់ ។ ស៊ីករឹតទទេ ដោយហោចមាន ប្រមាណ ៨ ធ្នាប់ ជាប្រមាណរបស់គរុភណ្ឌ ។ ស្មៅ ក៏គប្បីអនុលោមក្នុង សេចក្តីនេះដូចគ្នា ។ ក្នុងទីណា ស្មៅមិនមាន ទីនោះ ជនទាំងឡាយរមែង ប្រក់ដោយស្មៅជំណោកទន្សាយ ដោយចំបើង និងដោយស៊ីកដូងជាដើម ព្រោះហេតុនោះ ស្មៅជំណោកទន្សាយជាដើមនោះ សង្គ្រោះជាស្មៅនោះឯង ព្រោះហេតុនោះ ក្នុងស្មៅជំណោកទន្សាយ និងចំបើងជាដើម ស្មៅណាមួយ មានប្រមាណមួយក្តាប់ និងក្នុងស៊ីកដូងជាដើមមួយក្តាប់ ដែលបុគ្គលប្រគេន សង្ឃ ឬក្នុងទីកើតរបស់សង្ឃ ឬស្មៅដែលកើតឯងក្នុងវាលស្មៅរបស់សង្ឃ ខាងក្រៅអារាម ជារបស់ដែលសង្ឃគ្រប់គ្រងរក្សា ចាត់ជាគរុភណ្ឌ ។ កាល ការងាររបស់សង្ឃ និងការងាររបស់ចេតិយ ដែលសង្ឃធ្វើសម្រេចហើយ ការឲ្យស្មៅចំណែកដែលសល់នោះ ក្នុងការងារចំពោះបុគ្គល ក៏គួរ ។ ក្នុង

ឬស្សីដែលពោលហើយខាងដើម ក៏ន័យនេះដូចគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការឲ្យផ្កាដូចតទៅនេះ គរុភណ្ឌដែលសង្ឃកំណត់យ៉ាងនេះថា ភិក្ខុទាំងឡាយបេះផ្កាត្រង់ដើមឈើទាំងឡាយ មានប្រមាណប៉ុណ្ណេះ ចូរបង្អោនទៅក្នុងតម្លៃនៃបបរ និងភត្ត ផ្កាត្រង់ដើមឈើទាំងឡាយមានប្រមាណប៉ុណ្ណេះ ចូរបង្អោនទៅក្នុងការជួសជុលសេនាសនៈ ។ សាមណេរទាំងឡាយ បេះផ្កាទាំងឡាយខាងក្រៅធ្វើឲ្យជាគំនរ ភិក្ខុប្រកបដោយអង្គ ៥ រាប់ចំនួនភិក្ខុសង្ឃហើយ បែងជាចំណែកៗ ភិក្ខុនោះ មិនចាំបាច់សូមអនុញ្ញាតអំពីសង្ឃជាមុន រមែងចែកដល់បរិស័ទដែលមកហើយបាន ។ម្យ៉ាងទៀត ភិក្ខុអ្នកចែកនោះ សង្ឃមិនបានសន្មត គប្បីសូមអនុញ្ញាតសង្ឃហើយ ធ្វើនូវការចែកចុះ ។

សួរថា ភិក្ខុអាចឲ្យផ្កាទាំងឡាយដល់អ្នកណា មិនគួរឲ្យដល់អ្នកណា ឆ្លើយថា ភិក្ខុនាំផ្កាទៅកាន់ផ្ទះរបស់មាតាបិតាក្តី ឬប្រើបុគ្គលឲ្យហៅមាតាបិតាមកអំពីផ្ទះក្តី ភិក្ខុនោះរមែងបានដើម្បីនឹងឲ្យដោយពាក្យថា លោកទាំងឡាយ ចូរបូជាព្រះរតនត្រ័យ មិនមែនឲ្យដើម្បីជាគ្រឿងប្រដាប់ ។ ភិក្ខុមិនគួរនាំទៅឲ្យដល់ញាតិដ៏សេសទាំងឡាយ គួរឲ្យបុគ្គលហៅមកហើយ ឲ្យដោយពាក្យថា លោកទាំងឡាយ ចូរធ្វើការបូជា ដូច្នេះ ។ ភិក្ខុមិនគប្បីប្រាថ្នានូវការតបស្នង គប្បីឲ្យដល់ជនដ៏សេស ដែលមកកាន់លំនៅជាទីបូជា ។ ឈ្មោះថា ការឲ្យផ្កា រមែងមិនមាន ។ ក្នុងវិហារមានផ្ការីកច្រើន ភិក្ខុដែលត្រាច់បិណ្ឌបាតឃើញពួកមនុស្សហើយ គប្បីពោលថា ក្នុងវិហារមានផ្កាច្រើន ចូរពួកអ្នក

បូជា ដូច្នេះ ។ ទោស រមែងមិនមាន ព្រោះត្រឹមតែវាចា តែភិក្ខុមានចិត្តគិតថា ពួកមនុស្សកាន់យកខាទនីយៈ ភោជនីយៈហើយ នឹងមកដូច្នេះ មិនគួរពោល ។ បើភិក្ខុនោះនិយាយ មិនគួរឆាន់ខាទនីយភោជនីយៈ ។ មនុស្សទាំងឡាយសួរតាមធម្មតាថា ផ្កាទាំងឡាយមានក្នុងវិហារឬ និងពោលបន្តថា ពួកខ្ញុំនឹងមកកាន់វិហារក្នុងថ្ងៃឈ្មោះនោះ សូមលោកម្ចាស់ទាំងឡាយ កុំឲ្យពួកសាមណេរបេះផ្កាទាំងឡាយ ដូច្នេះ តែពួកភិក្ខុភ្លេចប្រាប់សាមណេរ ពួកសាមណេរក៏បេះផ្កាទាំងឡាយគរជាគំនរ កាលពួកមនុស្សចូលទៅរកភិក្ខុពោលថា បពិត្រលោកម្ចាស់ ក្នុងថ្ងៃឈ្មោះនោះ ពួកខ្ញុំប្រាប់ដល់លោកម្ចាស់ហើយថា កុំឲ្យសាមណេរបេះផ្កា លោកម្ចាស់ទាំងឡាយមិនឃាត់ ភិក្ខុគប្បីពោលថា អាត្មាភ្លេច ផ្កាទាំងឡាយសាមណេរបេះហើយនោះឯង មិនទាន់បានធ្វើការបូជានៅឡើយ មិនគួរពោលថា ចូរលោកកាន់យក ចូរបូជា ។ បើភិក្ខុពោល ក៏មិនគួរបរិភោគអាមិស ។

ភិក្ខុដទៃប្រាប់ដល់ពួកសាមណេរថា មនុស្សទាំងឡាយនៅក្នុងស្រុកនោះប្រាប់ថា ពួកលោកកុំបេះផ្កា សូម្បីពួកមនុស្សនាំអាមិសមកប្រគេន និងពោលថា មនុស្សរបស់ពួកខ្ញុំមិនមានច្រើន សូមលោកម្ចាស់ប្រាប់សាមណេរឲ្យជួយបេះផ្កាជាមួយពួកខ្ញុំចុះ ពួកភិក្ខុគប្បីពោលថា ឧបាសក សាមណេរទាំងឡាយមានភិក្ខាហើយ ពួកសាមណេរក៏មិនទៅកាន់ទីស្វែងរកភិក្ខា នឹងដឹងឯងនោះឯង ។ ការដែលគ្រហស្ថបាននូវន័យមានប្រមាណប៉ុណ្ណេះហើយ ធ្វើសាមណេរឲ្យដូចបុត្ត ឬបងប្រុស ប្អូនប្រុស ឲ្យជួយបេះផ្កាទាំងឡាយ រមែង

មិនមានទោស ឈ្មោះថា ការឲ្យនូវផ្កា រមែងមិនមាន ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការឲ្យផ្លែឈើដូចតទៅនេះ ផ្លែឈើដែលសង្ឃកំណត់ហើយ ដូចគ្នានឹងផ្កានោះឯង ចាត់ជាគរុភណ្ឌ ។ កាលមានផ្លែឈើតូចធំច្រើនក្នុងវិហារ ពួកមនុស្សមានជំងឺមកសូម ភិក្ខុទាំងឡាយគិតថា ផ្លែឈើទាំងនោះជារបស់សង្ឃ ទើបមិនខ្វល់ខ្វាយដើម្បីឲ្យ ។ ពួកមនុស្សក្តៅក្រហាយ រមែងជេរ រមែងបរិភាស ក្នុងសេចក្តីនេះ ភិក្ខុគប្បីធ្វើដូចម្តេច ។

ភិក្ខុទាំងឡាយ គប្បីដាក់ច្បាប់កំណត់ដោយផ្លែឈើទាំងឡាយ ឬដើមឈើទាំងឡាយថា អ្នកទាំងឡាយមិនគប្បីហាមពួកមនុស្ស ដែលកាន់យកផ្លែឈើទាំងឡាយមានប្រមាណប៉ុណ្ណេះ ត្រង់ដើមឈើឈ្មោះនោះ ឬបុគ្គលកាន់យកផ្លែឈើទាំងឡាយក្នុងដើមឈើទាំងឡាយ មានចំនួនប៉ុណ្ណេះ ។

ម្យ៉ាងទៀត ពួកចោរ ឬពួកជនដែលជាធំ កាន់យកដោយកម្លាំងបាយ មិនគប្បីហាម ព្រោះថា ជនទាំងនោះខឹងក្រោធហើយ គប្បីញុំាំងវិហារទាំងមូលឲ្យវិនាសក៏បាន តែភិក្ខុគប្បីប្រាប់ដល់ទោស ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការឲ្យលម្អិតសម្រាប់ដុសធ្មេញដូចតទៅ លម្អិតសម្រាប់ដុសធ្មេញ ដែលគេវាយ ឬបុកហើយ មិនជាគរុភណ្ឌ សម្បកឈើដែលគេមិនទាន់បុកនោះឯង ជាគរុភណ្ឌ ។ លម្អិតសម្រាប់ដុសធ្មេញដែលឆ្អិនហើយ ដោយទឹកជ្រលក់ រមែងគួរដល់បុគ្គលអ្នកមានជំងឺ លម្អិតសម្រាប់ដុសធ្មេញណាមួយ រមែងគួរដល់អ្នកជំងឺទាំងអស់ ។ ដីឥដ្ឋក៏គួរសង្គ្រោះពោលក្នុងទីនោះឯង ។ ពិតហើយ ដីឥដ្ឋក្នុងទីណាដែលជារបស់រកបានដោយក្រ ក្នុងទីនោះឯង ចាត់ជា

គរុភណ្ឌ ដីឥដ្ឋនោះយ៉ាងតូចបំផុត មានប្រមាណប៉ុនស្លាអំពៅ ទម្ងន់ ៣០ បលៈនោះឯង បើតូចជាងនោះ មិនជាគរុភណ្ឌ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការឲ្យឈើស្ទន់ដូចតទៅ ឈើស្ទន់ដែលគេមិនទាន់កាត់ ជាគរុភណ្ឌ ភារៈអំពីសង្ឃក្នុងការធ្វើឈើស្ទន់ រមែងដល់សាមណេរពួកណា សាមណេរទាំងនោះ រមែងមិនបានដើម្បីឲ្យដល់អាចារ្យ និងឧបជ្ឈាយ៍របស់ខ្លួនដោយចែកចំពោះ ។ តែសាមណេរទាំងឡាយណា ទទួលភារៈដែលកំណត់ថា គប្បីនាំឈើស្ទន់មានប្រមាណប៉ុណ្ណេះមក សាមណេរទាំងនោះ រមែងបានដើម្បីប្រគេនឈើស្ទន់ ចំណែកដែលលើសដល់អាចារ្យ និងឧបជ្ឈាយ៍ ។ ភិក្ខុមួយរូប មិនគួរកាន់យកឈើស្ទន់ច្រើន អំពីរោងឈើស្ទន់ គប្បីកាន់យកមួយប៉ុណ្ណោះរាល់ៗ ថ្ងៃ ។ ភិក្ខុកាលបែកទៅតែម្នាក់ឯង គប្បីរាប់ពួកភិក្ខុហើយ កាន់យកឈើស្ទន់តាមចំនួនដែលដល់លំដាប់ខ្លួន ហើយទៅ ។ បើអាគន្តុកភិក្ខុទាំងឡាយមកក្នុងវិហារនោះ ឬកាលលោកចៀសទៅកាន់ទិស គប្បីសងឈើស្ទន់ក្នុងទីដែលចាប់យកមកនោះឯង ដែលកាន់យកបាននោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ចាដុកម្យតាយ** ជាដើមដូចតទៅនេះ ព្រះមានព្រះភាគ ត្រាស់ហៅពាក្យសរសើរដើម្បីឲ្យគេស្រឡាញ់ ព្រោះតាំងខ្លួនទាបដូចជាទាសៈខ្លះ ព្រោះធ្វើពាក្យដែលភ្ជាំងភ្ជាត់របស់អ្នកដទៃឲ្យប្រាកដច្បាស់ខ្លះថា ភាពបន្ទាបបន្ទន់កាយ ។

បទថា **មុគ្គសូបយតា** នេះ ជាឈ្មោះរបស់អ្នកចិញ្ចឹមជីវិតដោយការ

*ពោល លាយលេង លាយមែន ដូចគ្នានឹងសម្ងស់ណ្ដែកបាយ ។ ធម្មតាកាល គេស្ងស់ណ្ដែកបាយៗ ចំនួនច្រើនឆ្អិន ចំនួនតិចមិនឆ្អិន យ៉ាងណា សេចក្ដីនេះក៏យ៉ាងនោះដូចគ្នា ភិក្ខុចិញ្ចឹមជីវិតដោយការពោល លាយលេង លាយមែន រមែងនិយាយកុហកច្រើន និយាយពិតតិច ។*

*ម្យ៉ាងទៀត ឈ្មោះថា សម្ងស់ណ្ដែកបាយ រមែងចូលបានជាមួយអាហារគ្រប់យ៉ាង យ៉ាងណា សេចក្ដីនេះក៏យ៉ាងនោះ ឈ្មោះថា វាចារបស់បុគ្គលដែលនិយាយលាយលេង លាយមែន រមែងចូលបានគ្រប់មនុស្ស ។ វាចានោះ តាំងនៅក្នុងក្រសែនៃពាក្យដែលខ្លួនប្រាថ្នាហើយប្រាថ្នាទៀត ដូចផ្លូវបែកជាបួន ដោយហេតុនោះ ភាពដែលបុគ្គលនោះ ពោលមុសានោះ ព្រះមានព្រះភាគត្រាស់ហៅថា វាចាដូចជាសម្ងស់ណ្ដែកបាយ ។*

*ភាពជាការងាររបស់បុគ្គលបីថ្មមកូនរបស់ត្រកូល ឈ្មោះថា* **ធារិ-ភជយតា** *។ ពិតហើយ ការងាររបស់បុគ្គលអ្នកចិញ្ចឹមក្មេង ឈ្មោះថា* **ធារិភជយំ** *។ ភាពនៃបុគ្គលអ្នកចិញ្ចឹមក្មេងនោះ ឈ្មោះថា* **ធារិភជយតា** *។ បទថា* **ធារិភជយតា** *នោះ ជាឈ្មោះរបស់បុគ្គលដែលញ៉ាំងក្មេងឲ្យលេងដោយការធ្វើនូវគ្រឿងប្រដាប់ជាដើម ។*

*បទថា* **ជង្ឃបេសនិកំ** *បានដល់ ការនាំដំណឹងទៅ និងនាំត្រឡប់មករបស់គ្រហស្ថនោះៗ ក្នុងទីទាំងឡាយ មានចន្លោះស្រុក និងចន្លោះប្រទេសជាដើម ។ ពិតហើយ ឈ្មោះថា ការបម្រើត្រកូលដោយកម្លាំងស្នែងនេះ គួរដោយអំណាចនៃការទទួលដំណឹងរបស់មាតាបិតាជាដើម ឬរបស់ជនអ្នកបម្រើ*

មាតាបិតានៃភិក្ខុនោះ ហើយទៅក្នុងទីណាមួយ ការនាំដំណឹងរបស់មេជាងអ្នកធ្វើចេតិយរបស់សង្ឃ ឬរបស់ខ្លួន គួរ ។ ម្យ៉ាងទៀត ពួកមនុស្សប្រាប់ថា ពួកខ្ញុំនឹងថ្វាយទាន នឹងធ្វើការបូជា សូមលោកម្ចាស់ប្រាប់ដល់ភិក្ខុសង្ឃ ដូច្នេះក្តី ពួកប្រគេនបិណ្ឌបាតក្តី ភេសជ្ជៈក្តី ចីវរក្តី ដោយពោលថា សូមលោកម្ចាស់ទាំងឡាយប្រគេនដល់ព្រះថេរៈឈ្មោះនោះ ដូច្នេះក្តី ពួកមនុស្សប្រគេនវត្ថុទាំងឡាយ មានកម្រងផ្កា គ្រឿងក្រអូប និងគ្រឿងលាបជាដើម ឬទង់ជ័យ និងទង់ផ្កាលាជាដើម ដោយប្រាប់ថា បពិត្រលោកម្ចាស់ទាំងឡាយ សូមលោកម្ចាស់ធ្វើការបូជាក្នុងវិហារ ដូច្នេះក្តី ការនាំដំណឹងទាំងអស់របស់ជនទាំងនោះទៅ គួរ មិនឈ្មោះថា ការបម្រើត្រកូលដោយកម្លាំងស្មង ។ ភិក្ខុកាន់យកដំណឹងរបស់ជនទាំងឡាយដ៏សេស ក្រៅអំពីនោះ ទោសរមែងមានគ្រប់ជំហាន ។

បទថា **អញ្ញតរញ្ញតរេន** បានដល់ ដោយអាជីវៈឯណានីមួយនៃការងារទាំងឡាយ មានការឲ្យឫស្សីជាដើមនោះ ឬដោយអាជីវៈណាមួយនៃការងារជាគ្រឿងចិញ្ចឹមជីវិត ដែលជាមិច្ឆាជីវៈនៃកម្មបែបនេះ គឺវេជ្ជកម្ម ភណ្ឌាគារិកកម្ម គឺការយាមឃ្លាំងផ្សារ គឺឲ្យដុំបាយប្រាថ្នាវត្ថុតបស្នង កម្ម គឺការឲ្យបម្រើដោយរបស់ដែលកើតឡើងដល់សង្ឃ និងដល់ចេតិយ ដោយមិនសមគួរ ។

បទថា **ពុទ្ធបដិកុដ្ឋេន** បានដល់ ដែលព្រះពុទ្ធទាំងឡាយទ្រង់តិះដៀលហើយ រង្កៀសហើយ ។ បទថា **អយំ វុច្ចតិ** បានដល់ អាការទាំងពួងនេះ

ព្រះសម្ពុទ្ធត្រាស់ហៅថា អនាចារ ។ បណ្ឌិតគប្បីជ្រាបអាចារនិទ្ទេស ដោយន័យដែលផ្ទុយគ្នាតាមដែលពោលហើយនោះឯង ។ ក្នុងគោចរនិទ្ទេស បណ្ឌិតគប្បីជ្រាបហេតុ ក្នុងការពោលដល់អគោចរមុន ដោយន័យដែលធ្លាប់ពោលហើយនោះឯង ។

ក្នុងបទទាំងនោះ បទថា **គោចរោ** បានដល់ ដែលគួរចូលទៅដើម្បីការបិណ្ឌបាតជាដើម ឈ្មោះថា **គោចរ** ដែលមិនសមគួរចូលទៅ ឈ្មោះថា **អគោចរ** ។

ការត្រាច់ទៅក្នុងសម្នាក់របស់ស្រីពេស្យា មានដល់ភិក្ខុនោះ ព្រោះហេតុនោះ ទើបភិក្ខុនោះ ឈ្មោះថា ជាអ្នកត្រាច់ទៅកាន់ទីនៃស្រីពេស្យា អធិប្បាយថា ទីដែលបុគ្គលគប្បីចូលទៅ ដោយអំណាចសេចក្ដីស្និទ្ធស្នេហ៍ ។ ក្នុងអធិការនេះ ស្រីទាំងឡាយចិញ្ចឹមជីវិតដោយរូប ឈ្មោះថា ស្រីពេស្យា ភិក្ខុចូលទៅដោយអំណាចជាអ្នកប្រព្រឹត្តខុសបានដោយងាយ ព្រោះសេចក្ដីស្នេហ៍ស្និទ្ធដោយអាការណាមួយនោះឯង ឈ្មោះថា ជាអ្នកត្រាច់ទៅកាន់ទីនៃស្រីពេស្យា ព្រោះហេតុនោះ ភិក្ខុនោះចូលទៅដោយអាការយ៉ាងនេះ មិនគួរ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះជាការវិបត្តិក្នុងការរក្សា ។ ពិតហើយ សមណធម៌របស់ភិក្ខុដែលចូលទៅដោយអាការយ៉ាងនេះ សូម្បីលោកគ្រប់គ្រងរក្សាហើយអស់កាលយូរ រមែងវិនាសទៅ ដោយហេតុបន្តិចបន្តួចនោះឯង ។ បើសមណធម៌របស់លោកមិនវិនាស ក៏នឹងបានទទួលនូវការតិះដៀល ។ ម្យ៉ាងទៀត ភិក្ខុកាលចូលទៅដោយអំណាចនៃការទទួលទក្ខិណា

គប្បីផ្គង់ស្មារតី ហើយចូលទៅ ។ ស្រីប្តីស្លាប់ ឬស្រីដែលប្តីលែង លោកហៅថា ស្រីមេម៉ាយ ស្រីចាស់ដែលមិនបានរៀបការ ឈ្មោះថា ក្រមុំចាស់ ។

បទថា **បណ្ឌកា** បានដល់ ខ្ទើយដែលមានវាចាអាស្រ័យលោកាមិស មានកិលេសក្រាស់ មានការក្តៅក្រហាយមិនស្ងប់ ទោសក្នុងការចូលទៅរកជនទាំងអស់នោះ គប្បីជ្រាបដោយន័យដែលពោលហើយនោះឯង ។ ក្នុងភិក្ខុនីទាំងឡាយ ក៏មានន័យដូច្នេះ ។

មួយវិញទៀត ធម្មតាភិក្ខុត្រូវប្រព្រឹត្តព្រហ្មចរិយៈឲ្យច្រើន ភិក្ខុនីទាំងឡាយក៏ដូចគ្នា ។ ភិក្ខុ និងភិក្ខុនីទាំងនោះ រមែងញុំាងសមណធម៌ដែលខ្លួនរក្សាគ្រប់គ្រងហើយ ឲ្យវិនាសទៅ ដោយអំណាចនៃការស្និទ្ធស្នាលនូវគ្នានិងគ្នា ដោយថ្ងៃបន្តិចបន្តួចនោះឯង តែការដែលភិក្ខុទៅសួរជំងឺ គួរ ។ ភិក្ខុឲ្យផ្កាទាំងឡាយដើម្បីការបូជាខ្លះ ដើម្បីឲ្យឱវាទខ្លះ គួរដូចគ្នា ។

រោងសុរា ឈ្មោះថា **បានាគារំ** រោងសុរានោះ រមែងមិនស្ងាត់ចាកអ្នកលេងសុរា ដែលធ្វើអន្តរាយចំពោះព្រហ្មចរិយៈ ។ ក្នុងរោងសុរានោះ ភិក្ខុទាំងឡាយមិនគួរចូលទៅជាមួយអ្នកលេងសុរាទាំងនោះ ដោយអំណាចនៃការសេពគប់អ្នកលេង ព្រោះអន្តរាយរបស់ព្រហ្មចរិយៈមាន ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **សំសដ្ឋោ វិហរតិ រាជូហិ** ជាដើម ដូចតទៅនេះ ព្រះរាជាទាំងឡាយណាអភិសេកហើយក្តី មិនទាន់អភិសេកក្តី រមែងសិក្សាក្នុងភាពជាព្រះរាជា ជនទាំងនោះ ក៏ឈ្មោះថា រាជា ។

បទថា **រាជមហាមត្តា** បានដល់ អ្នកប្រកបដោយភាពជាធំ ដូចគ្នា

នឹងការងារធំរបស់ព្រះរាជា ។ បទថា **តិត្ថិយា** បានដល់ អ្នកបួសខាងក្រៅព្រះពុទ្ធសាសនាដែលមានមិច្ឆាទិដ្ឋិ ។ បទថា **តិត្ថិយសាវកា** បានដល់ អ្នកទំនុកបម្រុងបច្ច័យដល់ពួកតិរ្ថិយទាំងនោះ ដោយអំណាចសេចក្តីស្រឡាញ់ អធិប្បាយថា ជាអ្នកប្រឡូកប្រឡំជាមួយជនទាំងនោះ ។

បទថា **អននុលោមិកេន គិហិសំសគ្គេន** បានដល់ សភាវៈដែលទាក់ទងនឹងចំណែកផ្ទុយគ្នាដែលមិនអនុលោមតាមសិក្ខា ៣ ដែលឈ្មោះថាការប្រឡូកប្រឡំដែលមិនសមគួរ ជាគ្រឿងឲ្យដល់អន្តរាយចំពោះព្រហ្មចរិយៈឈានកន្លងបញ្ញត្តិ និងសេចក្តីវិនាសដោយជុំវិញ ចាកការជុសខាត់ ។ សេចក្តីនេះដូចម្តេច សេចក្តីថា ភាពជាអ្នកមានសេចក្តីសោករួមគ្នា មានសេចក្តីសុខទុក្ខរួមជាមួយព្រះរាជា និងមហាមាត្យរបស់ព្រះរាជា ការចាប់ផ្តើមធ្វើដោយខ្លួនឯង ក្នុងកាលមានករណីយកិច្ចកើតឡើង ការប្រព្រឹត្តគាប់ចិត្តជាឯកច្ឆន្ទឬការស្និទ្ធស្នាល មានចិត្តច្រើនដោយសេចក្តីស្រឡាញ់ ដែលនាំមកនូវភាវៈនៃសេចក្តីប្រព្រឹត្តគាប់ចិត្តជាឯកច្ឆន្ទ មួយអន្លើដោយតិរ្ថិយ និងសាវកតិរ្ថិយទាំងឡាយ ។ ក្នុងអធិការនេះ ការប្រឡូកប្រឡំជាមួយព្រះរាជា និងអមាត្យរបស់ព្រះរាជា រមែងធ្វើអន្តរាយចំពោះព្រហ្មចរិយៈ ការប្រឡូកប្រឡំជាមួយតិរ្ថិយ និងសាវករបស់តិរ្ថិយទាំងឡាយ រមែងធ្វើអន្តរាយ គឺការកាន់យកលទ្ធិរបស់ជនទាំងនោះ តែភិក្ខុដែលអាចចូលទៅទម្លាយវាទៈរបស់តិរ្ថិយ និងសាវករបស់តិរ្ថិយ ហើយឲ្យកាន់យកលទ្ធិរបស់ខ្លួន ចូលទៅរក គួរ ។

ឥឡូវនេះ ដើម្បីសម្តែងអគោចរដោយបរិយាយដទៃទៀត ទើបព្រះ

*មានព្រះភាគផ្ដើមបទថា* **យានិ វា បន តានិ កុលានិ** *ជាដើម ។*

*បណ្ដាបទទាំងនោះ បទថា* **អស្សទ្ធានិ** *បានដល់ មិនមានសទ្ធា ក្នុងព្រះពុទ្ធជាដើម គឺមិនជឿថា ព្រះពុទ្ធជាសព្វញ្ញូ ព្រះធម៌ជានេយ្យានិកៈ ព្រះសង្ឃជាអ្នកបដិបត្តិល្អហើយ ដូច្នេះ ។*

*បទថា* **អប្បសន្នានិ** *បានដល់ មិនអាចធ្វើចិត្តឲ្យថ្លូវថ្លង់ មិនឲ្យល្អក់កករ ។ បទថា* **អក្កោសកបរិភាសកានិ** *បានដល់ ការជេរ និងការបរិភាស អធិប្បាយថា រមែងជេរដោយអក្កោសវត្ថុ ១០ យ៉ាងនេះថា ឯងជាចោរ ជាបុគ្គលពាល ជាបុគ្គលវង្វេង ជាអូដ្ឋ ជាគោ ជាលា ជាអ្នកកើតក្នុងអបាយ ជាសត្វនរក ជាសត្វតិរច្ឆាន សុគតិមិនមានដល់លោកឡើយ មានតែទុគ្គតិប៉ុណ្ណោះដែលសង្ឃឹម ដូច្នេះ ។ម្យ៉ាងទៀត រមែងបរិភាសដោយការសម្ដែងវត្ថុគួរខ្លាចយ៉ាងនេះថា ណ្ហើយចុះ ឥឡូវនេះ អញនឹងវាយអា នឹងចងអា នឹងសម្លាប់អា ។*

*បទថា* **អនត្ថកាមានិ** *បានដល់ រមែងមិនប្រាថ្នាប្រយោជន៍ គឺរមែងប្រាថ្នាសេចក្ដីវិនាសនោះឯង ។ បទថា* **អហិតកាមានិ** *បានដល់ រមែងប្រាថ្នាវត្ថុមិនជាប្រយោជន៍ប៉ុណ្ណោះ គឺមិនប្រាថ្នាប្រយោជន៍ ។ បទថា* **អផាសុកកាមានិ** *បានដល់ រមែងមិនប្រាថ្នាផាសុក គឺរមែងប្រាថ្នាតែអផាសុកប៉ុណ្ណោះ ។ បទថា* **អយោគក្ខេមកាមានិ** *បានដល់ រមែងមិនប្រាថ្នាដែនក្សេមចាកយោគៈ ៤ ដែលមិនមានភ័យ គឺរមែងប្រាថ្នាដែនដែលប្រព្រឹត្តទៅជាមួយភ័យនោះឯង ។ សូម្បីសាមណេរទាំងឡាយ ក៏រមែងដល់នូវការ*

សង្គ្រោះក្នុងបទថា **ភិក្ខូនំ** នេះ ។ សូម្បីសិក្ខមានា និងសាមណេរីទាំងឡាយ ក៏ដល់នូវការសង្គ្រោះចូលក្នុងបទថា **ភិក្ខុនីនំ** នេះដែរ ។ ពិតហើយ ត្រកូលទាំងនោះ ឈ្មោះថា ជាអ្នកប្រាថ្នាតែសេចក្ដីវិនាសដល់បរិស័ទទាំង ៤ គឺដល់ជនទាំងឡាយដែលបួសឧទ្ទិសចំពោះព្រះមានព្រះភាគទាំងអស់ និងអ្នកដល់សរណគមន៍ ។

បទថា **តថារូបានិ កុលានិ** បានដល់ ត្រកូលទាំងឡាយ មានត្រកូលនៃក្សត្រជាដើមបែបនេះ ។ បទថា **សេវតិ** បានដល់ អាស្រ័យចិញ្ចឹមជីវិត ។ បទថា **ភជតិ** បានដល់ ចូលទៅរក ។ បទថា **បយិរុបាសតិ** បានដល់ ចូលទៅរករឿយៗ ។ បទថា **អយំ វុច្ចតិ** បានដល់ គោចរដែលមិនសមគួរមានប្រការទាំង ៣ គឺគោចរ មានស្រីពេស្យា នៃគោចរក្នុងសម្នាក់របស់ស្រីពេស្យាជាដើម គោចរ មានព្រះរាជានៃបុគ្គលប្រឡូកប្រឡំជាមួយព្រះរាជាជាដើម គោចរ មានត្រកូលរបស់បុគ្គលមិនមានសទ្ធានៃបុគ្គលគប់រកត្រកូលមិនមានសទ្ធាជាដើម បណ្ឌិតគប្បីជ្រាបថា ជាអគោចរ ។ ភាពជាគោចររបស់ភិក្ខុនោះ គប្បីជ្រាបដោយបរិយាយនេះ ។ គោចរ មានស្រីពេស្យាជាដើម គប្បីជ្រាបថា ជាអគោចរ ព្រោះជាគោចរអាស្រ័យបញ្ចកាមគុណមុន ដូចពាក្យដែលព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ចុះទីមិនមែនជាទីគោចរ ជាដែននៃបុគ្គលដទៃ តើដូចម្ដេច ។ គឺកាមគុណទាំង ៥ នេះឯង ដូច្នេះ ។ គោចរ មានព្រះរាជាជាដើម គប្បីជ្រាបថា ជាអគោចរ ព្រោះមិនជាឧបនិស្ស័យនៃការប្រកបព្យាយាមរឿយៗ

*ក្នុងឈាន និងព្រោះជាហេតុនៃការសង្ស៊ីមលាភសក្ការៈ ការមិននាំទៅកាន់សេចក្ដីចម្រើន ការបំផ្លាញ និងទិដ្ឋិវិបត្តិ ។ គោចរ មានត្រកូលរបស់អ្នកមិនមានសទ្ធាជាដើម គប្បីជ្រាបថា ជាអគោចរ ព្រោះនាំមកនូវសេចក្ដីវិនាសសទ្ធា និងការតក់ស្លុតនៃចិត្ត ។*

*ក្នុងគោចរនិទ្ទេស បទថា* **ឥធ ឯកច្ចោ** *ជាដើម បណ្ឌិតគប្បីជ្រាបដោយអំណាចនៃពាក្យដែលជាបដិបក្ខ ចំពោះពាក្យដែលពោលហើយ ។ បទទាំងឡាយ មានបទថា* **ឱបានភូតានិ** *ជាដើម បទថា* **ឱបានភូតានិ** *បានដល់ ដូចអណ្ដូងទឹក គឺដូចគ្នានឹងផ្ទះរបស់ចិត្តមហាមាត្យដែលភិក្ខុសង្ឃគួរចូលទៅតាមសប្បាយ ដូចស្រះបោក្ខរណីដែលជីកត្រង់ផ្លូវធំមានមុម ៤ ។ បានឮថា ត្រង់ផ្ទះរបស់មហាមាត្យនោះ គេប្រកបសសរប្រាប់កាល ( សសរកំណត់ស្រមោលពេលវេលា ) ឈ្មោះថា ការខ្វះខាតដោយបច្ច័យ រមែងមិនមានដល់ភិក្ខុ ដែលមកដល់ទ្វារផ្ទះរបស់មហាមាត្យនោះ ។ ក្នុងថ្ងៃទីមួយៗ បុរសនោះចំណាយប្រាក់ ៦០ កហាបណៈ ដើម្បីការប្រព្រឹត្តទៅនៃភេសជ្ជៈនោះឯង ។*

*បទថា* **កាសាវបជ្ជោតានិ** *បានដល់ មានឱកាសឯណាមួយនៃរស្មីរបស់សំពត់កាសាវៈទាំងឡាយ ដែលភិក្ខុ និងភិក្ខុនីស្លៀកដណ្ដប់ហើយនោះឯង ដូចគ្នានឹងត្រកូលសេដ្ឋីឈ្មោះភូតបាល ។ បទថា* **ឥសិវាតបដិវាតានិ** *បានដល់ មានការផ្សាយទៅប្រាសខ្យល់ ឬអកុសលដែលកម្ចាត់បានហើយដោយខ្យល់នៃចីវររបស់ឥសីទាំងឡាយ ពោល គឺភិក្ខុ និងភិក្ខុនី ដែលចូល*

*ស្រុក និងចេញអំពីស្រុក និងដោយខ្យល់នៃសរីរៈ ដែលកើតអំពីការបត់អង្គុញ លាតសណ្តូកជាដើម ។*

*គប្បីជ្រាបវិនិច្ឆ័យក្នុងឧទ្ទេសនៃបទថា* **អណុមត្តេសុ វជ្ជេសុ ភយ-ទស្សាវី** *ដូចតទៅនេះ បទថា* **អណុមត្តា** *បានដល់ មានប្រមាណដ៏តូច ។ បទថា* **វជ្ជា** *បានដល់ ទោសជាគ្រឿងប្រទូស្តទាំងឡាយ ។ បទថា* **យានិ តានិ វជ្ជានិ** *បានដល់ ឈ្មោះថា ទោសទាំងឡាយនោះ ព្រោះអត្ថថា ជាវត្ថុដែលបណ្ឌិតគប្បីតិះដៀល ។ បទថា* **អប្បមត្តកានិ** *បានដល់ មានប្រមាណតិចតួច គឺមានប្រមាណបន្តិចបន្តួច ។ បទថា* **ឱរមត្តកានិ** *បានដល់ ឈ្មោះថា មានប្រមាណស្តួចស្តើង ព្រោះមានប្រមាណទាបបំផុត ជាងចំនួនដែលតិច ។ បទថា* **លហុសានិ** *បានដល់ ជារបស់ស្រាល ។ បទថា* **លហុសម្មតានិ** *បានដល់ ដែលសត្វលោកសន្មតថាជាទោសស្រាល ។ បទថា* **សំយមករណីយានិ** *បានដល់ ការសម្តែងដែលភិក្ខុគប្បីធ្វើដោយការសង្រួម ។ បទថា* **សំវរករណីយានិ** *បានដល់ គប្បីធ្វើដោយការសង្រួម គឺការសម្តែងដែលភិក្ខុនោះគប្បីធ្វើដោយការសង្រួម ។ បទថា* **ចិត្តុប្បាទក-រណីយានិ** *បានដល់ ការសម្តែងដែលភិក្ខុនោះ គប្បីធ្វើដោយត្រឹមតែចិត្តុប្បាទ ។ បទថា* **មនសិការបដិពទ្ធានិ** *បានដល់ ការសម្តែងដែលភិក្ខុគប្បីធ្វើដោយហេតុត្រឹមតែនឹកដោយចិត្តនោះឯង ។*

*ការសម្តែងទាំងនោះដូចម្តេច គប្បីជ្រាបថា ព្រះសុមត្ថេរ ដែលមានប្រក្រតីនៅក្នុងទិវាវិហារ លោកពោលថា ហេតុត្រឹមតែចិត្តុប្បាទ ដែលឲ្យ*

ដល់នូវការមិនមានអាបត្តិ រមែងបរិសុទ្ធដោយហេតុត្រឹមតែបង្អោនចិត្តថា អញនឹងមិនធ្វើកម្មបែបនេះទៀត ឈ្មោះថា ពោលដល់ការធ្វើ ( អាបត្តិ ) ឲ្យជាក់ច្បាស់ដោយការអធិដ្ឋាននេះ ។

ព្រះបូឡនាគត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដក ដែលជាអន្តេវាសិករបស់លោកនោះពោលថា បទនេះ ជាបទភាជនីយបាតិមោក្ខសំវរសីលនោះឯង ព្រោះហេតុនោះ អាបត្តិទុក្កដ និងទុព្ភាសិតដែលស្រាលជាងទោសទាំងពួង គប្បីជ្រាបថា ជាទោសក្នុងទីនេះ ឈ្មោះថា ជាការពោលដល់ការធ្វើឲ្យជាក់ច្បាស់ ដោយការចេញចាកអាបត្តិនោះ ។

បទថា **ឥតិ ឥមេសុ** បានដល់ ទាំងនេះ មានប្រការយ៉ាងនេះ ។ បទថា **វជ្ជទស្សាវី** បានដល់ មានប្រក្រតីឃើញទោស ដោយភាពជាទោស ។ បទថា **ភយទស្សាវី** បានដល់ មានប្រក្រតីឃើញដោយភាពជាភ័យ ព្រោះជាហេតុនៃភ័យ ៤ យ៉ាង ។ បទថា **អាទីនវទស្សាវី** នេះ បានដល់ មានប្រក្រតីឃើញដោយភាពជាទោស មានប្រការផ្សេងៗ នោះ គឺដោយការនាំមកនូវការនិន្ទាក្នុងលោកនេះ ដោយមានទុក្ខជាផលខាងមុខ ដោយធ្វើអន្តរាយចំពោះគុណក្នុងខាងលើ និងព្រោះឲ្យកើតនូវការក្តៅក្រហាយ ។

បទថា **និស្សរណទស្សាវី** បានដល់ មានប្រក្រតីឃើញទោសក្នុងការរលាស់ខ្លួនចេញនូវទោសនោះ ។ ក្នុងអធិការនេះ ការរលាស់ខ្លួនចេញ តើដូចម្តេច ក្នុងអាចរិយត្ថេរវាទពោលជាបឋមថា កាលមានការឲ្យដល់នូវអនាបត្តិ ការធ្វើឲ្យជាក់ច្បាស់ដោយការអធិដ្ឋាន ឈ្មោះថា ការរលាស់ខ្លួន

ចេញ ក្នុងឱវាទរបស់ព្រះថេរៈដែលជាអន្តេវាសិក ។ ពោលថា កាលមានការឲ្យដល់នូវអាបត្តិ ការធ្វើឲ្យជាក់ច្បាស់ដោយការចេញចាកអាបត្តិ ឈ្មោះថា វលាស់ខ្លួនចេញ ។ ក្នុងបទថា **អណុមត្តេសុ វជ្ជេសុ ភយទស្សាវី** នោះ ភិក្ខុបែបនេះ ឈ្មោះថា រមែងឃើញទោសទាំងឡាយ ដែលមានប្រមាណតិច ដោយភាពជាទោស ដោយភាពជាភ័យ ដើម្បីសម្តែងនូវប្រមាណតិចនោះ លោកពោលន័យដូចតទៅនេះ ឈ្មោះថា **បរមាណុ** ១ ឈ្មោះថា **អណុ** ១ ឈ្មោះថា **តជ្ជារី** ១ ឈ្មោះថា **រថរេណុ** ១ ឈ្មោះថា **លិក្ខា** ១ ឈ្មោះថា **"កា** ១ ឈ្មោះថា **ធញ្ញមាស** ១ ឈ្មោះថា **អង្គុលៈ** ១ ឈ្មោះថា **វិទត្ថិ** ១ ឈ្មោះថា **រតនៈ** ១ ឈ្មោះថា **យដ្ឋិ** ១ ឈ្មោះថា **ឧសភៈ** ១ ឈ្មោះថា **គាវុត** ១ ឈ្មោះថា **យោជនៈ** ១ ។

បណ្តាឈ្មោះទាំងនោះ ឈ្មោះថា **បរមាណុ** ជាចំណែកនៃអាកាស គឺចំណែកតូចបំផុតដែលមិនអាចឃើញដោយភ្នែកសាច់បាន ឃើញបានដោយទិព្វចក្ខុប៉ុណ្ណោះ ។ ឈ្មោះថា **អណុ** គឺវត្ថុដែលប្រាកដវិលនៅក្នុងរស្មីនៃព្រះអាទិត្យដែលចាំងទៅតាមប្រហោងជញ្ជាំង ប្រហោងសោ ។ ឈ្មោះថា **តជ្ជារី** គឺវត្ថុដែលបែកត្រង់ផ្លូវគោ ផ្លូវមនុស្ស និងផ្លូវរទេះ ហើយហុយឡើងជាប់ត្រង់ចំហៀងទាំងពីរ ។ ឈ្មោះថា **រថរេណុ** រមែងជាប់ត្រង់រថនោះៗ ឯង ។ ឈ្មោះថា **លិក្ខា** ជាដើម ប្រាកដច្បាស់ហើយ ។

ក្នុងពាក្យទាំងនេះ គប្បីជ្រាបប្រមាណដូច្នេះថា ៣៦ បរមាណុ ជា ១ អណុ ៣៦ អណុ ជា ១ តជ្ជារី ៣៦ តជ្ជារី ជា ១ រថរេណុ ( ល្អងរថ )

៣៦ រថរេណុ ជា ១ លិក្ខា ( ពងចៃ ) ៧ លិក្ខា ជា ១ ឩកា ( ខ្ទួនចៃ ) ៧ ឩកា ជា ១ ធញ្ញមាស ( គ្រាប់ស្រូវ ) ៧ ធញ្ញមាស ជា ១ អង្គុលៈ ( ធ្នាំងដៃ ) ១២ អង្គុលៈ ជា ១ វិទត្ថិ ( ចំអាម ) ២ វិទត្ថិ ជា ១ រតនៈ ( ហត្ថ ) ៧ រតនៈ ជា ១ យដ្ឋិ ( ឈើប្រត់ ) ២០ យដ្ឋិ ជា ១ ឧសភៈ ៨០ ឧសភៈ ជា ១ គាវុត ( សម្រែកគោ ) ៤ គាវុត ជា ១ យោជន៍ ។

ភ្នំសិនេរុរាជមានកម្ពស់ ១៦៨០០០ យោជន៍ ដោយយោជន៍នោះ ។

ភិក្ខុណាអាចឃើញនូវទោសមានប្រមាណតិច ឲ្យដូចគ្នានឹងសិនេរុរាជ ដែលមានកម្ពស់ ១៦៨០០០ យោជន៍បាន ។ ភិក្ខុនេះ បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា រមែងឃើញទោសទាំងឡាយដែលមានប្រមាណតិច ដោយភាពជាភ័យ ភិក្ខុណាអាចឃើញអាបត្តិត្រឹមតែទុក្កដ ទុព្ភាសិត ដែលស្រាលជាងទោសទាំងពួង ឲ្យដូចគ្នានឹងអាបត្តិបឋមបារាជិក ភិក្ខុនេះ បណ្ឌិតគប្បីជ្រាបថា ឃើញទោសទាំងឡាយ មានប្រមាណតិច ដោយភាពជាទោស ដោយភាពជាភ័យ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃបទថា **សមាទាយ សិក្ខតិ សិក្ខាបទេសុ** ដូចតទៅ

បទថា **ភិក្ខុសិក្ខា** បានដល់ សិក្ខាដែលភិក្ខុទាំងឡាយគប្បីសិក្សា ។ ភិក្ខុសិក្ខានោះ ទូទៅដល់ភិក្ខុនីខ្លះ មិនទូទៅខ្លះ ទោះជាយ៉ាងនោះ ក៏ឈ្មោះថា **ភិក្ខុសិក្ខា** នោះឯង ។ បទថា **ភិក្ខុនីសិក្ខា** បានដល់ សិក្ខាដែលភិក្ខុនីទាំងឡាយគប្បីសិក្សា ។ ភិក្ខុនីសិក្ខានោះ ទូទៅដល់ភិក្ខុទាំងឡាយខ្លះ មិន

ទូទៅខ្លះ ឈ្មោះថា **ភិក្ខុនីសិក្ខា** នោះឯង ។ ក្នុងសិក្ខារបស់សាមណេរ សិក្ខមានា និងសាមណេរីទាំងឡាយ ក៏សង្គ្រោះក្នុងភិក្ខុសិក្ខា និងភិក្ខុនីសិក្ខា នោះឯង ។

បទថា **ឧបាសកសិក្ខា** បានដល់ សិក្ខាដែលឧបាសកទាំងឡាយគប្បីសិក្សា ។ សិក្ខារបស់ឧបាសកនោះ រមែងគួរដោយអំណាចនៃសីល ៥ សីល ១០ ។ បទថា **ឧបាសិកាសិក្ខា** បានដល់ សិក្ខាដែលឧបាសិកាទាំងឡាយគប្បីសិក្សា ។ សិក្ខានោះ រមែងគួរដោយអំណាចនៃសីល ៥ សីល ១០ ។

បណ្ដាសិក្ខាទាំងនោះ សិក្ខារបស់ភិក្ខុ និងភិក្ខុនី រមែងគួររហូតដល់អរហត្តមគ្គ ។ សិក្ខារបស់ឧបាសក និងឧបាសិកា រមែងគួររហូតដល់អនាគាមិមគ្គ ។ ក្នុងបទថា **សមាទាយ សិក្ខតិ សិក្ខាបទេសុ** នោះ ភិក្ខុនេះរមែងសិក្សាក្នុងសិក្ខាបទ ដែលខ្លួនគប្បីរក្សាប៉ុណ្ណោះ ។ ឯសិក្ខាដ៏សេសព្រះមានព្រះភាគត្រាស់ដើម្បីសម្ដែងអត្ថនៃសិក្ខាបទ ដោយអំណាចនៃការលើកឡើងអធិប្បាយ ។

បទថា **ឥតិ ឥមាសុ សិក្ខាសុ** បានដល់ ក្នុងសិក្ខាទាំងឡាយនេះមានប្រការយ៉ាងនេះ ។ បទថា **សព្វេន សព្វំ** បានដល់ សិក្ខាទាំងពួង ដោយការសមាទានសិក្ខាទាំងពួង ។ បទថា **សព្វថា សព្វំ** បានដល់ សិក្ខាទាំងពួង ដោយអាការដែលគប្បីសិក្ខា ។

បទថា **អសេសំ និស្សេសំ** បានដល់ ឈ្មោះថា **អសេសំ** ព្រោះមិន

*មានចំណែកសល់ ឈ្មោះថា* **និស្សេសំ** *ព្រោះធ្វើសិក្ខាបទសូម្បីដែលដាច់ហើយ ដោយការភ្លេចស្មារតី ឲ្យជាប្រក្រតីវិញ ។ បទថា* **សមាទាយ វត្តតិ** *បានដល់ សមាទានហើយ កាន់យកហើយប្រព្រឹត្ត ។ បទថា* **តេន វុច្ចតិ** *បានដល់ សមាទានសិក្ខាទាំងពួងនេះហើយ ដោយអាការដែលគប្បីសិក្សា រមែងសិក្សា រមែងឲ្យពេញ ដោយហេតុណា ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា* **សមាទាយ សិក្ខតិ សិក្ខាបទេសុ** *ដូច្នេះ ។*

*គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃពួក ២ មានបទថា* **ឥន្ទ្រិយេសុ គុត្តទ្វារោ ភោជនេ មត្តញ្ញូ** *ជាដើមដូចតទៅ*

*ក្នុងបទដំបូង គប្បីជ្រាបប្រយោជន៍នៃធម៌ ដែលជាចំណែកខ្មៅដោយន័យដែលខ្ញុំពោលហើយ ក្នុងអាចារនិទ្ទេសនោះឯង ។ ក្នុងបទថា* **តត្ថ កតមា ឥន្ទ្រិយេសុ អគុត្តទ្វារតា** *ជាដើម ពាក្យណាដែលគួរពោល ពាក្យទាំងអស់នោះ ខ្ញុំបានពោលហើយ ក្នុងនិក្ខេបកណ្ឌវណ្ណនានោះឯង ។*

*គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃបទថា* **ជាគរិយានុយោគ** *ដូចតទៅ ក្នុងបទថា* **បុព្វរត្តាបររត្តំ** *នេះ ខាងដើមនៃរាត្រី ពោល គឺកណ្តាលយប់ ឈ្មោះថា* **បុព្វរត្ត** *។ ព្រះមានព្រះភាគទ្រង់កំណត់បឋមយាម និងវេលាខាងក្រោយកត្ត ដោយសព្ទថា* **បុព្វរត្ត** *នេះ ។ ខាងក្រោយនៃរាត្រី ឈ្មោះថា* **អបររត្ត** *។ ទ្រង់កំណត់បច្ឆិមយាម និងវេលាមុនកត្តដោយសព្ទថា* **អបររត្ត** *នេះ ។ ចំណែកមជ្ឈិមយាម ទ្រង់មិនកំណត់ ព្រោះជាឱកាសសម្រាប់ដេក និងការបន្ទោបង់នូវភាពនឿយហត់របស់ភិក្ខុនោះ ។*

បទថា **ជាគរិយានុយោគំ** បានដល់ ការប្រកបរឿយៗ របស់បុគ្គលភ្ញាក់រឭក ដែលឈ្មោះថា **ជាគរិយ** ។ បទថា **អនុយុត្តោ ហោតិ** បានដល់ ជាអ្នកប្រកបរឿយៗ ជាអ្នកខ្វល់ខ្វាយនូវការសេពសេចក្ដីចម្រើន ពោល គឺការប្រកបរឿយៗ នោះ ។ បទថា **ឥធ ភិក្ខុ ទិវសំ** ក្នុងនិទ្ទេសដែលមានពាក្យថា ភិក្ខុក្នុងសាសនានេះ ... អស់មួយថ្ងៃ រហូតដល់ពាក្យថា ក្នុងពេលមុនរាត្រី និងក្រោយរាត្រីនោះ ព្រះមានព្រះភាគទ្រង់កំណត់ថ្ងៃមួយ ចែកចេញជា ៣ ចំណែក គឺពេលព្រឹក ពេលថ្ងៃត្រង់ និងពេលល្ងាច ។

បទថា **ចង្កមេន និសជ្ជាយ** បានដល់ ភិក្ខុ កាលនៅដោយឥរិយាបថទាំងពីរនេះ រមែងជម្រះចិត្តចាកអាវរណៈ គឺចាកធម៌ដែលជាគ្រឿងរារាំងមិនឲ្យសម្រេចសេចក្ដីល្អ ចាកនីវរណៈទាំង ៥ ឬចាកអកុសលធម៌ទាំងអស់ គឺរមែងជម្រះចិត្ត រមែងដោះចិត្តចាកអកុសលធម៌ទាំងនោះ ។ ម្យ៉ាងទៀត ការឈរ ទ្រង់មិនប្រារព្ធដល់ក្នុងអធិការនេះក៏ពិត តែគប្បីកាន់យកការឈរនោះឯងផងដែរ ព្រោះអាស្រ័យរវាងការដើរ និងការអង្គុយ ។ បទថា **បឋមយាមំ** បានដល់ ក្នុងបឋមយាមទាំងមូល ។ បទថា **មជ្ឈិមយាមំ** បានដល់ ក្នុងមជ្ឈិមយាម ពោល គឺចំណែកទាំង ៦ របស់ពេលយប់ និងពេលថ្ងៃ ។

ក្នុងបទថា **សីហសេយ្យំ** នេះ បានដល់ សេយ្យា ៤ យ៉ាង គឺ **កាមភោគីសេយ្យា** គឺការដេកដូចអ្នកបរិភោគកាម ១ **បេតសេយ្យា** គឺការដេកដូចប្រេត ១ **សីហសេយ្យា** គឺការដេកដូចសីហៈ ១ **តថាគតសេយ្យា**

*គឺការដេកដូចព្រះតថាគត ១ ។*

*ក្នុងការដេកទាំងនោះ ការដេកដោយព្រះបាលី ( អង្គុត្តរនិកាយ ចតុក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកបរិភោគកាមច្រើនតែដេកផ្អៀងទៅខាងឆ្វេង ដូច្នេះ នេះឈ្មោះថា ការដេកបែបអ្នកបរិភោគកាម ។ ពិតហើយ បណ្តាអ្នកបរិភោគកាមទាំងនោះ ឈ្មោះថា ដេកផ្អៀងទៅខាងស្តាំ ដោយច្រើនមិនមាន ។*

*ការដេកដូចព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ ពួកប្រេត[១]ច្រើនតែដេកផ្ងារ ដូច្នេះ នេះឈ្មោះថា ការដេកបែបប្រេត ។ ពិតហើយ ពួកប្រេតមានតែរាងឆ្អឹងមិនអាចដេកផ្អៀងម្ខាងបាន ព្រោះខ្លួនមានសាច់ និងឈាមតិច ទើបដេកផ្ងារប៉ុណ្ណោះ ។*

*ការដេកដូចព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ សីហមិគរាជ សម្រេចការដេកដោយខាងៗ ស្តាំ ។បេ។ រមែងត្រេកអរ ដូច្នេះ នេះឈ្មោះថា ការដេកបែបសីហៈ ។ ពិតហើយ សីហៈដែលជាមិគរាជ ដាក់ជើងមុខទាំងពីរមួយកន្លែង ដាក់ជើងក្រោយទាំងពីរមួយកន្លែង យកកន្ទុយដាក់ក្នុងរវាងភ្លៅ ហើយកំណត់ឱកាស ទាំងជើងមុខ ជើងក្រោយ និងកន្ទុយដែលខ្លួនដាក់ហើយ ទើបដេក ដាក់ក្បាលលើជើងមុខទាំងពីរ ព្រោះភាពដែលខ្លួនជាអ្នកមានអំណាចច្រើន ទោះបីដេកអស់មួយថ្ងៃ ភ្ញាក់ឡើងក៏មិនតក់ស្លុត កាលក្រោកឡើង ក៏អើតក្បាលកំណត់មើលឱកាស នៃជើងមុខជាដើមតាមដែល*

---

១- បិដកខ្មែរ ជាមនុស្សស្លាប់ ។

ខ្លួនដាក់ បើអវយវៈណាមួយឃ្លៀតទៅអំពីទីដើម មានចិត្តមិនត្រេកអរដោយគិតថា លក្ខណៈបែបនេះ មិនសមគួរដល់ជាតិ មិនគួរដល់ភាពក្លាហានរបស់អ្នក ហើយក៏ដេកក្នុងទីនោះឯង មិនចេញទៅរកអាហារ បើជើងមុខជាដើមដែលខ្លួនតម្កល់ហើយ មិនឃ្លាតខុសប្រក្រតី រមែងជាអ្នកមានចិត្តត្រេកអរដោយគិតថា អាការនេះសមគួរដល់ជាតិ និងភាពជាអ្នកក្លាហាន ហើយក្រោកឡើង សម្ដែងលីលារបស់សីហៈ រលាស់កេសរត្រង់ក បន្លឺសីហនាទ ៣ ដងហើយ ទើបចេញទៅស្វែងរកអាហារ ។

ម្យ៉ាងទៀត ការដេកប្រកបដោយឈានទី ៤ ព្រះមានព្រះភាគត្រាស់ហៅថា ការដេកបែបព្រះតថាគត ។ ក្នុងបណ្ដាការដេកទាំងនោះ ការដេកបែបសីហៈ មកហើយក្នុងពាក្យថា **សីហសេយ្យំ** នេះ ។ ពិតហើយ ការដេកបែបសីហៈនេះ ជាការដេកដ៏ប្រសើរ ព្រោះជាឥរិយាបថខ្ពង់ខ្ពស់ដោយតេជះ ។

បទថា **បាទេ បាទំ** បានដល់ ដាក់ជើងឆ្វេងតម្រួតលើជើងស្ដាំ ។ បទថា **អច្ចាធាយ** បានដល់ តម្រួតលើគ្នា គឺដាក់ជើងឲ្យវែងខ្លីជាងគ្នាបន្តិច ព្រោះថា កាល-កជើងប៉ះនឹងកជើង ឬជន្គង់ប៉ះជន្គង់ ទុក្ខវេទនារមែងកើតឡើងរឿយៗ ចិត្តមិនជាឯកគ្គតាផង ការដេកក៏មិនជាផាសុកផង ។ ការដេកនោះ ក្បាលជន្គង់ក្ដី កជើងក្ដី មិនប៉ះគ្នាដោយអាការណា កាលដាក់ជើងហួសគ្នាបន្តិច ដោយអាការនោះហើយ ទុក្ខវេទនា រមែងមិនកើតឡើង ចិត្តរមែងជាឯកគ្គតាផង ការដេកក៏ជាផាសុកផង ដោយហេតុនោះ ទើបព្រះមាន

*ព្រះភាគត្រាស់ថា តម្រួតជើងដោយជើង ដូច្នេះ ។*

*បទថា* **សតោ សម្បជានោ** *បានដល់ ជាអ្នកប្រកបដោយសតិ និង បញ្ញាជាគ្រឿងដឹងព្រម ។ សតិសម្បជញ្ញៈដែលភិក្ខុកំណត់កាន់យកល្អហើយ ព្រះមានព្រះភាគត្រាស់ដោយបទថា* **សតោ សម្បជានោ** *នេះ ។*

*បទថា* **ឧដ្ឋានសញ្ញំ មនសិករិត្វា** *បានដល់ តម្កល់សញ្ញាក្នុងការ ក្រោកឡើង គឺកំណត់កាលដែលគប្បីក្រោកឡើងក្នុងចិត្តយ៉ាងនេះថា អញ នឹងក្រោកឡើងក្នុងវេលាឈ្មោះនោះ ។ ពិតហើយ កាលធ្វើយ៉ាងនេះហើយ ដេកក៏អាចក្រោកឡើងតាមពេលដែលកំណត់នោះឯង ។*

*បទថា* **សាតច្ចំ នេបក្កំ** *អធិប្បាយថា ភិក្ខុប្រកបហើយ ប្រកបរឿយៗ ហើយញ៉ាំងវីរិយៈ ពោល គឺសេចក្ដីព្យាយាមជាប់តគ្នាទៅ ព្រោះគប្បីញ៉ាំង សេចក្ដីព្យាយាមនោះឲ្យប្រព្រឹត្តទូទៅជាប់តគ្នា និងនូវបញ្ញា ពោល គឺបញ្ញា ដែលរក្សានូវខ្លួន ព្រោះដល់នូវការចាស់ដោយជុំវិញ កាលញ៉ាំងវីរិយៈ និងបញ្ញាឲ្យប្រព្រឹត្តទៅនោះឯង ឈ្មោះថា ប្រកបរឿយៗ ក្នុងជាគរិយា- នុយោគ ។ ក្នុងទីនេះ ព្រះមានព្រះភាគត្រាស់ការព្យាយាម ដែលលាយ ដោយលោកិយ និងលោកុត្តរ ។ សូម្បីបញ្ញាក៏មានគតិដូចវីរិយៈនោះឯង ។ អធិប្បាយថា បញ្ញាក្នុងវីរិយៈដែលជាលោកិយ ក៏ជាលោកិយ បញ្ញាក្នុង វីរិយៈដែលជាលោកុត្តរ ក៏ជាលោកុត្តរ ។*

*បទថា* **ពោធិបក្ខិយានំ ធម្មានំ** *បានដល់ ធម៌ទាំងឡាយដែលប្រព្រឹត្ត ទៅក្នុងចំណែកនៃមគ្គញ្ញាណ ពោល គឺបញ្ញាជាគ្រឿងត្រាស់ដឹងនូវសច្ចៈទាំង*

៤ ។ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ព្រះមានព្រះភាគទ្រង់រួមពោធិបក្ខិយ-ធម៌ទាំង ៣៧ កាលទ្រង់សម្តែងអង្គនៃការត្រាស់ដឹងនោះឯង ដែលអាចប្រព្រឹត្តទៅដោយកាពតែមួយ ក្នុងអារម្មណ៍មួយនៃការនៃទាជាលោកិយ ទើបត្រាស់បទថា **សត្ត ពោជ្ឈង្គា** ជាដើម ។ ពោធិបក្ខិយធម៌ទាំងនោះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ជាលោកិយផង លោកុត្តរផង លាយឡំគ្នា ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ព្រោះមានន័យដូចខ្ញុំពោលហើយខាងដើមនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃបទថា **អភិក្កន្តេ** ជាដើម ការឈានទៅខាងមុខ ព្រះមានព្រះភាគត្រាស់ថា **អភិក្កន្ត** ក្នុងបទថា **អភិក្កន្តេ បដិក្កន្តេ** នេះ ។ ការឈានមកខាងក្រោយ ហៅថា **បដិក្កន្ត** ។ **អភិក្កន្ត** និង **បដិក្កន្ត** ទាំងពីរនេះ រមែងបានក្នុងឥរិយាបថទាំង ៤ គឺនឹងពោលអំពីឥរិយាបថដើរមុន កាលបង្អោនកាយដើរទៅខាងមុខ ឈ្មោះថា **អភិក្កន្ត** ការត្រឡប់ថយមក ឈ្មោះថា **បដិក្កន្ត** ។ ក្នុងឥរិយាបថឈរ កំពុងឈរនោះឯង កាលឱនកាយទៅខាងមុខ ឈ្មោះថា **អភិក្កន្ត** កាលពត់កាយទៅខាងក្រោយ ឈ្មោះថា **បដិក្កន្ត** ។ ក្នុងឥរិយាបថអង្គុយ កំពុងអង្គុយនោះឯង មានមុខចំពោះចំណែកខាងមុខនៃអាសនៈ បង្អោនកាយទៅ ឈ្មោះថា **អភិក្កន្ត** ។ ផ្អែកកាយទៅកាន់ប្រទេសចំណែកខាងក្រោយ ឈ្មោះថា **បដិក្កន្ត** ។ ក្នុងឥរិយាបថដេក ក៏ន័យនេះឯង ។

បទថា **សម្បជានការី ហោតិ** បានដល់ ជាអ្នកមានប្រក្រតីធ្វើកិច្ច

*ទាំងពួងដោយសម្បជញ្ញៈ ឬជាបុគ្គលមានប្រក្រតីធ្វើនូវសម្បជញ្ញៈ ។ ពិតហើយ ភិក្ខុនោះ រមែងធ្វើនូវសម្បជញ្ញៈនោះឯង ក្នុងឥរិយាបថទាំងឡាយមានការឈានទៅខាងមុខជាដើម គឺរមែងជាបុគ្គលមិនវៀរចាកសម្បជញ្ញៈក្នុងឥរិយាបថណាមួយឡើយ ព្រោះសម្បជញ្ញៈនោះ សម្បយុត្តដោយសតិនោះឯង ព្រោះហេតុនោះ ក្នុងនិទ្ទេសនៃឈានវិភង្គនេះ ទើបត្រាស់ថា* **សតោ សម្បជានោ អភិក្កមតិ សតោ សម្បជានោ បដិក្កមតិ** *ដូច្នេះ ។ ពិតហើយ ភិក្ខុនេះ ឈានទៅខាងមុខ ឬថយមកខាងក្រោយ ឈ្មោះថា ជាអ្នកមិនភ្លេចស្មារតី មានសម្បជញ្ញៈ ភិក្ខុដែលប្រកបដោយសតិ មានការដឹងខ្លួនព្រមដោយបញ្ញានោះឯង រមែងឈានទៅខាងមុខផង រមែងឈានមកខាងក្រោយផង ។ ភិក្ខុនោះញុំាងសម្បជញ្ញៈ ៤ យ៉ាង ឲ្យឈមចុះក្នុងឥរិយាបថទាំងពួង មានការឈានទៅខាងមុខជាដើម ។ ពិតហើយ សម្បជញ្ញៈនេះមាន ៤ យ៉ាង គឺសាត្ថកសម្បជញ្ញៈ ១ សប្បាយសម្បជញ្ញៈ ១ គោចរ-សម្បជញ្ញៈ ១ អសម្មោហសម្បជញ្ញៈ ១ ។*

*បណ្តាសម្បជញ្ញៈទាំងនោះ ចិត្តគិតឈានទៅខាងមុខកើតឡើងហើយ មិនទាន់ទៅដោយអំណាចរបស់ចិត្តនោះឯង កំណត់វត្ថុដែលជាប្រយោជន៍ និងមិនជាប្រយោជន៍ថា អញទៅក្នុងទីនោះបានប្រយោជន៍អ្វីហ្ន៎ ប្រយោជន៍នឹងមាន ឬមិនមានហ្ន៎ ទើបកាន់យកតែវត្ថុដែលជាប្រយោជន៍ ឈ្មោះថា* **សាត្ថកសម្បជញ្ញៈ** *។*

*ក្នុងពាក្យទាំងនោះ ពាក្យថា ប្រយោជន៍ បានដល់ សេចក្តីចម្រើន*

ដោយធម៌ ដោយអំណាចការឃើញចេតិយ ការឃើញពោធិព្រឹក្ស ការឃើញព្រះសង្ឃ ការឃើញព្រះថេរៈ ការឃើញអសុភជាដើម ។ ពិតហើយ ភិក្ខុឃើញចេតិយ ឬពោធិព្រឹក្សហើយ ញ៉ាំងបីតិ មានពុទ្ធគុណជាអារម្មណ៍ឲ្យកើតឡើង ឬឃើញព្រះសង្ឃហើយ ធ្វើបីតិ មានព្រះសង្ឃជាអារម្មណ៍ឲ្យកើតឡើង ពិចារណានូវបីតិនោះឯង ដោយការអស់ទៅ រមែងសម្រេចអរហត្តបាន ។ បុគ្គលឃើញព្រះថេរៈទាំងឡាយ តាំងនៅក្នុងឱវាទរបស់លោកទាំងនោះ ឬឃើញអសុភហើយ ញ៉ាំងបឋមជ្ឈាន ក្នុងអសុភនោះឲ្យកើតឡើងហើយ ពិចារណាវត្ថុទាំងនោះឯង ដោយការអស់ទៅ សូន្យទៅ រមែងសម្រេចអរហត្តបាន ព្រោះហេតុនោះ ទើបការឃើញវត្ថុទាំងនោះ ឈ្មោះថាមានប្រយោជន៍ ។

ម្យ៉ាងទៀត អាចារ្យពួកខ្លះពោលថា ការចម្រើនដោយអាមិស ក៏ឈ្មោះថា ជាប្រយោជន៍ដូចគ្នា ព្រោះភាពដែលខ្លួនអាស្រ័យវត្ថុនោះហើយ បដិបត្តិដើម្បីយកព្រហ្មចរិយៈនេះ ។

ការដែលភិក្ខុកំណត់សប្បាយ និងអសប្បាយ ហើយកំណត់យកតែសប្បាយ ឈ្មោះថា **សប្បាយសម្បជញ្ញៈ** ។ សេចក្ដីនេះដូចម្ដេច គឺការឃើញព្រះចេតិយដែលប្រព្រឹត្តទៅជាមួយប្រយោជន៍មុន បើបរិស័ទប្រជុំគ្នាក្នុងរវាងផ្លូវ ១២ យោជន៍ ដើម្បីធ្វើការបូជាធំដល់ព្រះចេតិយ ស្ត្រីក្ដី បុរសក្ដី ប្រដាប់តាក់តែងតាមសម្បត្តិរបស់ខ្លួន ហាក់បីដូចរូបគំនូរ នាំគ្នាត្រាច់ទៅក្នុងទីបែបនេះ សេចក្ដីលោភរបស់ភិក្ខុនោះៗ រមែងកើត ព្រោះអារម្មណ៍ដែលគួរ

ពេញចិត្ត បដិឃៈ រមែងកើត ព្រោះអារម្មណ៍ដែលមិនពេញចិត្ត មោហៈ រមែងកើត ព្រោះការមិនពិចារណា ។

ម្យ៉ាងទៀត ភិក្ខុនោះ រមែងត្រូវអាបត្តិកាយសំសគ្គៈ ឬមានអន្តរាយដល់ជីវិត និងព្រហ្មចរិយៈ ។ ស្ថានទីបែបនោះ រមែងជាអសប្បាយ ។ តែជាសប្បាយ ព្រោះមិនមានអន្តរាយ មានប្រការតាមដែលពោលហើយ ដោយប្រការដូច្នេះ ។ ក្នុងការមើលពោធិព្រឹក្ស ក៏ន័យនេះដូចគ្នា ។

ក្នុងការមើលព្រះសង្ឃ ក៏ប្រព្រឹត្តទៅដោយប្រយោជន៍ បើពួកមនុស្សធ្វើបារាំជុំក្នុងរវាងស្រុក ហើយស្តាប់ធម៌អស់រាត្រី ការប្រជុំរបស់ជន និងអន្តរាយរមែងមានតាមប្រការដែលពោលហើយនោះឯង ។ ស្ថានទីបែបនោះជាអសប្បាយ ។ ជាសប្បាយ ព្រោះការមិនមានអន្តរាយ ដោយប្រការដូច្នេះ ។ ក្នុងការឃើញព្រះថេរៈទាំងឡាយ ដែលមានបរិស័ទច្រើន ក៏ន័យនេះឯង ។

ការឃើញអសុភក៏មានប្រយោជន៍ ។ ដើម្បីសម្តែងប្រយោជន៍ក្នុងអសុភនោះ មានរឿងជាឧទាហរណ៍ដូចតទៅ

បានឮថា ភិក្ខុកំលោះមួយរូប នាំសាមណេរធ្វើដំណើរទៅដើម្បីរកឈើស្ទន់ ។ សាមណេរដើរទៅខាងមុខភិក្ខុ ហើយចុះកាន់ផ្លូវឃើញអសុភ ញ៉ាំងបឋមជ្ឈានឲ្យកើតឡើង ធ្វើឈាននោះឯងឲ្យជាបាទនៃវិបស្សនា ពិចារណានូវសង្ខារទាំងឡាយ ធ្វើផល ៣ ឲ្យជាក់ច្បាស់ហើយ កំណត់កម្មដ្ឋានដើម្បីមគ្គខាងលើ ។ ចំណែកភិក្ខុកំលោះ កាលមិនឃើញសាមណេរនោះ ទើប

ស្រែកហៅថា អឺ សាមណេរ ។ សាមណេរនោះគិតថា តាំងពីអញបួស មក ឈ្មោះថា ឲ្យភិក្ខុហៅពីរដង មិនមានដល់អាត្មាអញឡើយ ក្នុងថ្ងៃដទៃ អញនឹងញុំាងគុណវិសេសខាងលើឲ្យកើតឡើង ដូច្នេះ ទើបឆ្លើយថា ករុណា លោកម្ចាស់ ដូច្នេះ ភិក្ខុកំលោះក៏ពោលថា មក សាមណេរៗ នោះមក ហើយដោយពាក្យមួយមាត់ប៉ុណ្ណោះ ហើយទើបប្រាប់ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទៅផ្លូវនេះ ហើយសម្លឹងទៅខាងមុខមួយស្របក់ ក្នុងទីដែល ខ្ញុំឈរ ។ ភិក្ខុនោះ ធ្វើយ៉ាងនោះហើយ សម្រេចគុណវិសេស ដែល សាមណេរសម្រេចហើយនោះឯង ។ អសុភមួយ មានប្រយោជន៍ដល់ជន ទាំងពីរដោយអាការយ៉ាងនេះ ។

ម្យ៉ាងទៀត អសុភរបស់មាតុគ្រាម ជាអសប្បាយដល់បុរស ឯអសុភ របស់បុរស ជាអសប្បាយដល់មាតុគ្រាម ។ ការកំណត់សប្បាយថា វត្ថុ ដែលជាសភាគៈគ្នា ទើបជាសប្បាយ ឈ្មោះថា **សប្បាយសម្បជញ្ញៈ** ។

ម្យ៉ាងទៀត ការដែលភិក្ខុកំណត់សប្បាយដែលមានប្រយោជន៍យ៉ាង នេះហើយ រៀនយកគោចរ ពោល គឺកម្មដ្ឋានដែលសមនឹងចរិតរបស់ខ្លួន ក្នុងកម្មដ្ឋាន ៣៨ យ៉ាង ហើយកាន់យកកម្មដ្ឋាននោះឯង ត្រាច់ទៅក្នុងទី គោចរ ដើម្បីភិក្ខាចារ ឈ្មោះថា **គោចរសម្បជញ្ញៈ** ។

បណ្ឌិតគប្បីជ្រាបពួក ៤ ដើម្បីការជាក់ច្បាស់នៃគោចរសម្បជញ្ញៈនោះ ដូចតទៅនេះ

ភិក្ខុរបខ្លះក្នុងសាសនានេះ នាំកម្មដ្ឋានទៅ តែមិននាំត្រឡប់មក ១ ភិក្ខុ

រូបខ្លះ នាំត្រឡប់មក តែមិននាំទៅ ១ ភិក្ខុរូបខ្លះ មិននាំទៅផង មិននាំត្រឡប់មកផង ១ ភិក្ខុរូបខ្លះ នាំទៅផង នាំត្រឡប់មកផង ១ ។

បណ្តាភិក្ខុទាំងនោះ ភិក្ខុណាជម្រះចិត្តឲ្យបរិសុទ្ធចាកធម៌ទាំងឡាយដែលជាគ្រឿងរារាំងអស់ ១ ថ្ងៃ ដោយការដើរចង្ក្រម ដោយការអង្គុយក្នុងបឋមយាមនៃរាត្រីយ៉ាងនោះ ក្នុងមជ្ឈិមយាម សម្រេចការដេក ក្នុងបច្ឆិមយាម លោកក៏ញុំាងកាលឲ្យកន្លងទៅដោយការអង្គុយ ការដើរចង្ក្រម ការធ្វើវត្ត គឺបោសលានព្រះចេតិយ លានពោធិព្រឹក្សអំពីព្រលឹម ស្រោចពោធិព្រឹក្ស តម្កល់ទឹកឆាន់ ទឹកប្រើប្រាស់ សមាទានប្រព្រឹត្តខន្ធកវត្តទាំងពួង មានអាចរិយវត្ត ឧបជ្ឈាយវត្តជាដើម ជម្រះរាងកាយហើយ ក៏ចូលទៅកាន់សេនាសនៈ ប្តូរឥរិយាបថ ២-៣ ដង ត្រង់ទីអង្គុយ ឲ្យកម្តៅកើតឡើងហើយ ប្រកបកម្មដ្ឋានរឿយៗ ក្រោកឡើងក្នុងពេលដែលត្រូវត្រាច់បិណ្ឌបាត កាន់បាត្រ និងចីវរ ជាមួយកម្មដ្ឋានដែលជាសីសៈនោះឯង ចេញអំពីសេនាសនៈ មនសិការកម្មដ្ឋានយ៉ាងនោះ ទៅកាន់លានព្រះចេតិយ បើកម្មដ្ឋានជាពុទ្ធានុស្សតិសោត មិនលះកម្មដ្ឋាននោះ ចូលទៅកាន់លានព្រះចេតិយ បើមានកម្មដ្ឋានដទៃ ឈរត្រង់ជើងជណ្តើរ ផ្អាកកម្មដ្ឋាននោះ ដូចរបស់ដែលកាន់មកដោយដៃ កាន់យកបីតិដែលមានពុទ្ធគុណជាអារម្មណ៍ ឈានឡើងកាន់លានព្រះចេតិយ ធ្វើប្រទក្សិណចេតិយធំ ៣ ជុំ ហើយគប្បីថ្វាយបង្គំក្នុងទីទាំង ៤ គប្បីធ្វើប្រទក្សិណចេតិយតូចយ៉ាងនោះឯង ហើយគប្បីថ្វាយបង្គំក្នុងទីទាំង ៨ ។ កាលភិក្ខុថ្វាយបង្គំចេតិយហើយ មកដល់លានពោធិព្រឹក្ស

គប្បីសម្ដែងការឱនថ្វាយបង្គំពោធិព្រឹក្ស ដូចការនៅក្នុងទីចំពោះព្រះភក្ត្រ ព្រះមានព្រះភាគ ។

ភិក្ខុនោះ ថ្វាយបង្គំចេតិយ និងពោធិព្រឹក្សហើយ ក៏កាន់យកកម្មដ្ឋានដែលខ្លួនផ្ទាកហើយ ដូចបុគ្គលទៅកាន់ទីដែលខ្លួនទុករបស់ ហើយយកដៃកាន់យករបស់ដែលខ្លួនទុកហើយ ដូច្នោះ ដោយកម្មដ្ឋានសីសៈនោះឯងដណ្ដប់ចីវរក្នុងទីជិតស្រុក ហើយចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ ក្នុងកាលនោះ ពួកមនុស្សឃើញភិក្ខុនោះហើយ ក៏នាំគ្នាក្រោកឡើងទទួលដោយគិតថា លោកម្ចាស់របស់ពួកយើងមកហើយ ដូច្នេះ ទទួលបាត្រ និមន្តឲ្យអង្គុយត្រង់រោងឆាន់ ឬត្រង់ផ្ទះ ប្រគេនបបរ លាងជើង លាបប្រេង ដរាបដែលភត្តមិនទាន់សម្រេច អង្គុយខាងមុខសួរបញ្ហាខ្លះ ប្រាថ្នាជាអ្នកស្ដាប់ធម៌ខ្លះ ។

ព្រះអដ្ឋកថាចារ្យទាំងឡាយពោលថា បើពួកមនុស្សមិនត្រូវការឲ្យភិក្ខុពោលធម៌ ធម្មតាធម្មកថាដើម្បីការសង្គ្រោះប្រជុំជន ភិក្ខុនោះគប្បីធ្វើនោះឯងពិតហើយ ធម្មតាធម្មកថាដែលផុតចាកកម្មដ្ឋាន មិនមាន ។ ព្រោះហេតុនោះភិក្ខុឆាន់អាហារដោយកម្មដ្ឋានសីសៈនោះឯងស្រេចហើយ ពោលអនុមោទនាភិក្ខុនោះដែលមនុស្សទាំងឡាយតាមជូនដំណើរទៅ ចេញទៅអំពីស្រុកហើយឲ្យមនុស្សទាំងនោះត្រឡប់ ហើយដើរទៅតាមផ្លូវ ។ លំដាប់នោះ សាមណេរនិងភិក្ខុទាំងឡាយចេញទៅកាន់ស្រុកមុន មានភត្តកិច្ចដែលធ្វើហើយខាងក្រៅស្រុកនោះឯង ឃើញភិក្ខុនោះកំពុងនិមន្តមក ក៏នាំគ្នាទៅទទួលៗ បាត្រ និង

ចីវររបស់លោក ។

បានឮថា ភិក្ខុក្នុងកាលមុនមិនបានជ្រើសរើសថា បុគ្គលនេះជាឧបជ្ឈាយ៍របស់អញ បុគ្គលនេះជាអាចារ្យរបស់អញ ហើយធ្វើវត្ត គឺរមែងធ្វើការកំណត់ដល់ភិក្ខុទាំងឡាយដែលនិមន្តមកប៉ុណ្ណោះ ។

សាមណេរ និងភិក្ខុកំលោះទាំងនោះ សួរភិក្ខុនោះថា បពិត្រលោកម្ចាស់ ពួកមនុស្សទាំងនោះ ត្រូវជាអ្វីនឹងលោកម្ចាស់ ទាក់ទងនឹងខ្សែស្រឡាយខាងមាតា ឬខាងបិតា ។ ភិក្ខុនោះឆ្លើយថា ពួកអ្នកឃើញដូចម្តេចទើបសួរ ពួកសាមណេរ និងភិក្ខុកំលោះទាំងនោះឆ្លើយថា ពួកខ្ញុំឃើញការស្រឡាញ់រាប់អានរបស់ជនទាំងនោះ មានច្រើនក្នុងលោកម្ចាស់ ភិក្ខុនោះ ពោលសរសើរគុណរបស់មនុស្សទាំងនោះថា អើ អាវុសោទាំងឡាយ កម្ម សូម្បីមាតាបិតារបស់ខ្ញុំ ធ្វើបានលំបាក តែមនុស្សទាំងនេះធ្វើដល់ពួកយើងបានងាយ បាត្រនិងចីវររបស់ពួកយើងក៏ជារបស់មនុស្សទាំងនោះឯង ដោយអានុភាពរបស់ជនទាំងនោះ ទើបពួកយើងមិនស្គាល់ភ័យក្នុងពេលមានភ័យ មិនដឹងដល់ការអត់ឃ្លាន ក្នុងវេលាស្រុកកើតអត់ឃ្លាន ជនទាំងឡាយដែលមានឧបការៈដល់ពួកយើងបែបនេះ រមែងមិនមាន ហើយទើបទៅ ។ ភិក្ខុនេះ លោកហៅថា នាំកម្មដ្ឋានទៅ តែមិននាំត្រឡប់មក ។

ម្យ៉ាងទៀត ភិក្ខុណាធ្វើវត្តបដិបត្តិ តាមដែលពោលហើយអំពីព្រលឹមភ្លើងធាតុកើតអំពីកម្ម រមែងដុតកម្តៅ លះបង់អនុបាទិន្នករូប ហើយកាន់យកឧបាទិន្នករូប ( ភ្លើងធាតុកើតអំពីកម្មដុតពោលក្រពះ ) ញើសទាំងឡាយ

រមែងហួរចេញអំពីសរីរៈ កម្មដ្ឋានឡើងកាន់វិថិមិនបាន ។ ភិក្ខុនោះ កាន់យកបាត្រ និងចីវរអំពីព្រលឹម ថ្វាយបង្គំចេតិយដោយរហ័ស ចូលទៅកាន់ស្រុកក្នុងពេលដែលជាទីចេញទៅរបស់ហ្វូងគោនោះឯង ដើម្បីភិក្ខា គឺបបរ បានបបរហើយ នាំទៅកាន់អាសនសាលាហើយឆាន់ ។ លំដាប់នោះ តេជោធាតុកើតអំពីកម្មរបស់ភិក្ខុនោះ ក៏បោះបង់ឧបាទិន្នករូប កាន់យកអនុបាទិន្នករូប ត្រឹមតែហុតបបរ ២ ឬ ៣ មាត់ ។ ភិក្ខុនោះដល់នូវការរម្ងាត់សេចក្ដីក្ដៅក្រហាយដែលកើតអំពីតេជោធាតុបាន ដូចងូតទឹកមួយរយក្អម ឆាន់បបរដោយកម្មដ្ឋានសីសៈ លាងបាត្រ និងមាត់ហើយ មនសិការកម្មដ្ឋាន ក្នុងរវាងភត្តត្រាច់ទៅបិណ្ឌបាត ក្នុងទីដ៏សេស ឆាន់អាហារដោយកម្មដ្ឋានសីសៈ ចាប់តាំងពីកាលនោះមក ក៏កាន់យកកម្មដ្ឋានដែលប្រាកដអស់កាលដែលត្រឡប់មក ភិក្ខុនេះ ហៅថា នាំកម្មដ្ឋានត្រឡប់មក តែមិននាំទៅ ។

ភិក្ខុបែបនេះ ឆាន់បបរហើយប្រារព្ធវិបស្សនា សម្រេចអរហត្តក្នុងព្រះពុទ្ធសាសនាច្រើនហួសនឹងរាប់ ។ ក្នុងសីហឡទ្វីបនោះឯង ក្នុងអាសនសាលាក្នុងស្រុកនោះៗ អាសនៈដែលពួកភិក្ខុអង្គុយឆាន់បបរហើយ មិនសម្រេចអរហត្ត មិនមាន ។

ភិក្ខុណា ជាអ្នកមានប្រក្រតីនៅដោយសេចក្ដីប្រមាទ មានធុរៈដាក់ចុះហើយ ទម្លាយវត្តទាំងពួងហើយ មានចិត្តជាប់ជំពាក់ក្នុងចំណងរបស់ចិត្ត ៥ យ៉ាង គឺនីវរណៈ ៥ មិនមានសញ្ញាក្នុងកម្មដ្ឋានថា កម្មដ្ឋានមាន ដូច្នេះហើយ ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ជាអ្នកប្រឡូកប្រឡំហើយ ដោយ

ការប្រឡូកប្រឡំដោយគ្រហស្ថដែលមិនសមគួរ ត្រាច់ទៅផង ឆាន់អាហារផង ជាអ្នកទទេចេញទៅ ភិក្ខុបែបនេះ ហៅថា មិននាំកម្មដ្ឋានទៅ មិននាំកម្មដ្ឋានត្រឡប់ ។

ចំណែកភិក្ខុណាដែលលោកពោលថា ភិក្ខុនេះ រមែងនាំកម្មដ្ឋានទៅផង នាំត្រឡប់មកផង ដូច្នេះ បណ្ឌិតគប្បីជ្រាបភិក្ខុនោះ ដោយអំណាចនៃវត្តរបស់ភិក្ខុដែលបដិបត្តិកម្មដ្ឋានទាំងទៅ ទាំងមក ។

ពិតហើយ កុលបុត្រទាំងឡាយដែលប្រាថ្នាប្រយោជន៍ បួសក្នុងសាសនាហើយ នៅរួមគ្នា ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ៣០ ឆ្នាំខ្លះ ៤០ ឆ្នាំខ្លះ ៥០ ឆ្នាំខ្លះ ១០០ ឆ្នាំខ្លះ រមែងធ្វើកតិកាវត្តថា អាវុសោទាំងឡាយ ពួកលោកមិនបានបួសដើម្បីគេចបំណុល មិនបានបួសគេចអំពីភ័យ មិនបានបួសដើម្បីចិញ្ចឹមជីវិត តែពួកលោកជាអ្នកប្រាថ្នាដើម្បីផុតចាកទុក្ខ ទើបបួសក្នុងសាសនានេះ ព្រោះហេតុនោះ បើកិលេសកើតឡើងក្នុងពេលដើរ ចូរពួកលោកសង្កត់សង្កិនទូវកិលេសក្នុងខណៈដើរនោះឯង កិលេសកើតឡើងក្នុងការឈរ អង្គុយដេក ក៏ចូរសង្កត់កិលេសក្នុងពេលឈរ អង្គុយ ដេកនោះឯង ដូច្នេះ ។

ភិក្ខុទាំងនោះ កាលធ្វើកតិកាវត្តយ៉ាងនេះហើយ កាលទៅបិណ្ឌបាត រមែងមនសិការកម្មដ្ឋានដោយសញ្ញានៃដុំថ្ម ដែលមានក្នុងរវាងកន្លះឧសភៈខ្លះ ១ ឧសភៈខ្លះ កន្លះគាវុតខ្លះ ១ គាវុតខ្លះ ។ បើកិលេសរបស់អ្នកណាម្នាក់កើតឡើងក្នុងខណៈដើរសោត បុគ្គលនោះ រមែងសង្កត់កិលេសក្នុងទីនោះឯង ។ កាលមិនអាចសង្កត់កិលេសបាន ភិក្ខុនោះ ក៏ឈប់ កាលបើ

ដូច្នោះ ភិក្ខុដែលមកខាងក្រោយ ក៏ត្រូវឈប់ផងដែរ ។ ភិក្ខុដែលឈប់មុន ដាស់តឿនខ្លួនថា ភិក្ខុនេះ ដឹងវិតក្ករបស់អញដែលកើតឡើង សេចក្ដីនេះ មិនសមគួរដល់អ្នក ញុំាងវិបស្សនាឲ្យចម្រើន ឈានចុះកាន់អរិយភូមិ ។ ភិក្ខុកាលមិនអាចធ្វើយ៉ាងនោះ រមែងអង្គុយចុះ កាលបើយ៉ាងនោះ ភិក្ខុដែលមកខាងក្រោយ ក៏រមែងអង្គុយដែរ ពាក្យដ៏សេសក៏ន័យនេះឯង ។ កាលភិក្ខុមិនអាចឈានចុះកាន់អរិយភូមិ ក៏មនសិការកម្មដ្ឋានសង្កត់កិលេសនោះ ហើយក៏ក្រោកនិមន្តទៅ ។ ភិក្ខុនោះ មិនលើកជើងដោយចិត្តប្រាសចាកកម្មដ្ឋាន បើលើកជើងដោយចិត្តដែលប្រាសចាកកម្មដ្ឋានសោត លោកក៏ត្រឡប់ទៅកាន់ទីដើម ហើយដើរមកសាជាថ្មី ដូចព្រះថេរៈឈ្មោះមហាផុស្សទេវៈ ដែលនៅត្រង់អាលិន្ទកប្រទេស ។

បានឮថា ព្រះថេរៈអង្គនោះ បំពេញគតបច្ចាគតវត្តនោះឯង អស់ ១៩ វស្សា បានឮថា ពួកមនុស្សអ្នកភ្ជួរស្រែ ព្រោះស្រូវ បោកស្រូវ ធ្វើនូវការងារផ្សេងៗ ក្នុងរវាងផ្លូវ ឃើញព្រះថេរៈនិមន្តទៅយ៉ាងនោះ ក៏សន្ទនាគ្នាយ៉ាងសុខសាន្តថា ព្រះថេរៈអង្គនេះ ត្រឡប់ទៅ ត្រឡប់មក ប្រហែលជាលោកវង្វេងផ្លូវ ឬភ្លេចអ្វីទេដឹងហ្ន៎ ដូច្នេះ ។

ព្រះថេរៈមិនអើពើក្នុងពាក្យទាំងនោះ ធ្វើសមណធម៌ដោយចិត្តប្រកបដោយកម្មដ្ឋាននោះឯង សម្រេចអរហត្តក្នុងរវាងវស្សាទី ២០ ។ ក្នុងថ្ងៃដែលលោកសម្រេចអរហត្ត ទេវតាដែលអាស្រ័យនៅខាងចុងទីចង្ក្រមរបស់លោក បានឈរធ្វើប្រទីបឲ្យភ្លឺរុងរឿងដោយម្រាមដៃទាំងឡាយ ឯមហារាជទាំង ៤

និងសក្កទេវរាជ មួយអន្លើដោយសហម្បតីព្រហ្ម ក៏មកកាន់ទីបម្រើ ។

ព្រះថេរៈឈ្មោះមហាតិស្សៈ ជាអ្នកមានប្រក្រតីនៅព្រៃ ឃើញពន្លឺនោះ ក៏សួរព្រះថេរៈក្នុងថ្ងៃទី ២ ថា កាលពីយប់ មានពន្លឺក្នុងសម្នាក់របស់អាវុសោ ទុំះជាពន្លឺអ្វី ។ ព្រះថេរៈកាលពោលបន្ទប់ ក៏ពោលយ៉ាងនេះថា ធម្មតាពន្លឺ ជាពន្លឺប្រទីបក៏មាន ជាពន្លឺកែវមណីក៏មាន ។ លំដាប់នោះ ត្រូវព្រះថេរៈដេញ ដោលថា លោកម្ចាស់បិទបាំងឬ ទើបទទួលថា ពិត ហើយក៏ប្រាប់ ។

ម្យ៉ាងទៀត ដូចគ្នានឹងរឿងរបស់ព្រះមហានាគត្ថេរដែលនៅក្នុងកាឡ-វល្លិមណ្ឌប ។ បានឮថា ព្រះមហានាគត្ថេរអង្គនោះ បំពេញគតបច្ចាគតវត្ត បានអធិដ្ឋានឥរិយាបថត្រឹមតែការឈរ និងការចង្រ្កមប៉ុណ្ណោះ អស់ ៧ ឆ្នាំ ដោយគិតថា ខាងដើម អញនឹងបូជាមហាបធាន គឺការព្យាយាមធំរបស់ ព្រះមានព្រះភាគ ដូច្នេះ បន្ទាប់មក ក៏បំពេញគតបច្ចាគតវត្ត អស់ ១៦ ឆ្នាំ ទើបសម្រេចអរហត្ត ។

ព្រះមហានាគនោះ លើកជើងឡើងដោយចិត្តដែលប្រកបដោយកម្មដ្ឋាន នោះឯង កាលលើកជើងដោយចិត្តដែលប្រាសចាកកម្មដ្ឋាន ក៏ត្រឡប់ទៅ កាន់ទីដើម កាលទៅកាន់ទីជិតស្រុកហើយ ឈរក្នុងប្រទេសដែលពួកមនុស្ស សង្ស័យថា ទុំះជាមេគោឬហ្ន៎ ឬក៏ជាបព្វជិត ជណ្តប់ចីវរ លាងបាត្រ ដោយ ទឹកអំពីកុណ្ឌីដែលត្បៀតត្រង់ក្លៀកមក ហើយបៀមទឹកមួយមាត់ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា កាលមនុស្សទាំងឡាយមកដើម្បីប្រគេនភិក្ខា ឬដើម្បី ថ្វាយបង្គំ កាលរាយមាយទៅក្រៅអំពីកម្មដ្ឋាន កុំបីមាន សូម្បីត្រឹមតែពាក្យ

ថា ចូរពួកអ្នកមានអាយុវែង ដូច្នេះ ។

ភិក្ខុនោះត្រូវមនុស្សទាំងឡាយសួរដល់ការរាប់ថ្ងៃថា បពិត្រលោកម្ចាស់ ថ្ងៃនេះជាថ្ងៃអ្វី ឬសួរដល់ចំនួនភិក្ខុ ឬសួរបញ្ហា ក៏លេបទឹកហើយប្រាប់ បើអ្នកសួរដល់ថ្ងៃជាដើមមិនមាន ក្នុងពេលចេញទៅអំពីស្រុក ក៏ខ្ជាក់ទឹកចោលត្រង់ទ្វារស្រុកនោះឯង ត្រឡប់ទៅកាន់វត្ត ។ ម្យ៉ាងទៀត ដូចរឿងភិក្ខុ ៥០ រូប ដែលចាំវស្សាក្នុងកលម្ពតិត្ថវិហារ ។

បានឮថា ភិក្ខុទាំងនោះ បានធ្វើកតិកាវត្តក្នុងថ្ងៃ ១៥ កើត ខែអាសាឍ ថា ពួកយើងបើមិនទាន់សម្រេចអរហត្ត មិនគប្បីសន្ទនាគ្នា ដូច្នេះ ។ ម្យ៉ាងទៀត ភិក្ខុទាំងនោះ កាលចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ធ្វើនូវការបៀមទឹកមួយមាត់ហើយទើបចូលទៅ កាលត្រូវសួរដល់ថ្ងៃជាដើម ក៏បដិបត្តិដោយន័យដែលពោលហើយ ។ ពួកមនុស្សឃើញទឹកដែលខ្ជាក់ចោលក្នុងទីនោះ ក៏ជ្រាបថា ថ្ងៃនេះ លោកម្ចាស់របស់យើងមក ១ អង្គ ឬ ២ អង្គ ដូច្នេះ ។ មនុស្សទាំងនោះ គិតថា លោកម្ចាស់ទាំងនេះ មិននិយាយជាមួយពួកយើងប៉ុណ្ណោះឬ ឬមួយមិននិយាយរកគ្នា ដូច្នេះ បើពួកលោកមិននិយាយរកគ្នានិងគ្នាសោត លោកពិតជាទាស់ទែងគ្នា ចូរពួកយើងមក អ្នកទាំងឡាយ ចូរមកយើងនឹងឲ្យភិក្ខុទាំងនោះខមាទោសដល់គ្នានិងគ្នា ដូច្នេះ ។ ពួកមនុស្សទាំងអស់ នាំគ្នាទៅកាន់វិហារ បណ្ដាភិក្ខុ ៥០ រូប ភិក្ខុសូម្បីពីររូប ក៏មិននៅក្នុងទីជាមួយគ្នា ។ ក្នុងមនុស្សទាំងនោះ បុរសអ្នកមានបញ្ញាម្នាក់ពោលក្នុងពេលនោះថា នែលោកដ៏ចម្រើនទាំងឡាយ លំនៅរបស់អ្នកទាស់ទែងគ្នា មិនមាន

សភាពបែបនេះ លានព្រះចេតិយក្តី លានមហាពោធិព្រឹក្សក្តី ដែលលោកម្ចាស់ទាំងនេះបោសសម្អាតល្អហើយ អំបោសទាំងឡាយ លោកក៏ទុកដាក់រៀបរយ ទឹកឆាន់ក្តី ទឹកប្រើប្រាស់ក្តី លោកបានតម្កល់យ៉ាងល្អ ដូច្នេះ ពួកមនុស្សទាំងនោះ ក៏នាំគ្នាត្រឡប់ទៅអំពីទីនោះឯង ។

ភិក្ខុទាំងនោះសម្រេចអរហត្តក្នុង ៣ ខែនោះឯង បវារណាហើយ នូវវិសុទ្ធិបវារណា ក្នុងថ្ងៃមហាបវារណា ។

ភិក្ខុកាលលើកដើងឡើងដោយចិត្ត ដែលប្រកបដោយកម្មដ្ឋាននោះឯង ទៅកាន់ទីជិតស្រុក ហើយធ្វើការបៀមទឹកមួយមាត់ ដូចព្រះមហានាគត្ថេរដែលអាស្រ័យនៅត្រង់កាឡវល្លិមណ្ឌប និងដូចភិក្ខុ ៥០ រូបដែលចាំវស្សាក្នុងកលម្ពតិត្ថវិហារយ៉ាងនេះហើយ កំណត់ផ្លូវទាំងឡាយ ដើរទៅកាន់ផ្លូវដែលមិនមានពួកជនទាស់គ្នា មិនមានអ្នកលេងសុរា មិនមានអ្នកលេងល្បែងមិនមានដំរីកាច សេះកាចជាដើម ។ កាលលោកត្រាច់ទៅក្នុងស្រុកដើម្បីបិណ្ឌបាត្រ មិនគួរទៅដោយរួសរាន់ ដូចជនដែលមានធុរៈប្រញាប់ ព្រោះថាឈ្មោះថា បិណ្ឌបាតិកធុតង្គណាមួយ ដែលប្រញាប់ប្រញាល់មិនមាន ។ ជាអ្នកមិនញាប់ញ័រ គឺមិនប្រញាប់ប្រញាល់ដើរទៅ ដូចរទេះដែលដឹកទឹកពេញបរទៅក្នុងទីមិនរាបស្មើ ។ ភិក្ខុដែលចូលទៅកាន់ចន្លោះស្រុក គួរវង់ចាំពេលសមគួរដល់កត្ត ដើម្បីកំណត់ដល់បុគ្គលដែលបំណងនឹងឲ្យ ឬមិនឲ្យ ទទួលភិក្ខាហើយ អន្តយក្នុងស្រុកក្តី អន្តយក្រៅស្រុកក្តី មកកាន់វិហារក្តី អន្តយក្នុងឱកាសដែលសមគួរតាមផាសុក មនសិការកម្មដ្ឋាន ញ៉ាំងបដិកូលសញ្ញា

ក្នុងអាហារឲ្យកើតឡើង ពិចារណាអាហារនោះ ដោយអំណាចនៃការប្រៀបធៀបនឹងប្រេងបន្តក់ភ្លៅរទេះក្តី សំពត់រុំដំបៅក្តី សាច់កូនក្តី ហើយឆាន់អាហារប្រកបដោយអង្គ ៨ មិនមែនដើម្បីលេង មិនមែនដើម្បីស្រវឹង មិនមែនដើម្បីប្រដាប់ មិនមែនដើម្បីតាក់តែង គ្រាន់តែធ្វើកាយនេះ ឲ្យតាំងនៅប្រព្រឹត្តទៅ ដើម្បីរម្ងាប់បង់នូវសេចក្តីក្រវល់ក្រវាយ ដើម្បីអនុគ្រោះព្រហ្មចរិយៈ ដោយមនសិការថា អញនឹងកម្ចាត់វេទនាចាស់ នឹងមិនឲ្យវេទនាថ្មីកើតឡើង ការប្រព្រឹត្តទៅ ការមិនមានទោស ការនៅជាផាសុក នឹងមានដល់អញ ។

កាលឆាន់ស្រេចហើយ ធ្វើកិច្ចដោយទឹកហើយ ញុំាងសេចក្តីស្រវឹងក្នុងភត្តឲ្យស្ងប់ត្រឹមមួយស្របក់ហើយ មនសិការដល់កម្មដ្ឋាននោះឯង ក្នុងវេលាខាងក្រោយភត្ត បុរិមយាម និងមជ្ឈិមយាម ដូចមនសិការនូវកម្មដ្ឋានក្នុងពេលមុនភត្ត ដូច្នោះ ភិក្ខុនេះ លោកហៅថា នាំកម្មដ្ឋានទៅ និងនាំកម្មដ្ឋានត្រឡប់មក ។

ភិក្ខុអ្នកបំពេញគតបច្ចាគតវត្ត ពោល គឺការនាំកម្មដ្ឋានទៅ និងនាំកម្មដ្ឋានត្រឡប់នេះ បើភិក្ខុមានឧបនិស្ស័យដល់ព្រមហើយ រមែងសម្រេចអរហត្តក្នុងបឋមវ័យនោះឯង បើមិនសម្រេចក្នុងបឋមវ័យ ក៏នឹងសម្រេចក្នុងមជ្ឈិមវ័យ បើមិនសម្រេចក្នុងមជ្ឈិមវ័យ ក៏នឹងសម្រេចក្នុងបច្ឆិមវ័យ បើមិនសម្រេចបច្ឆិមវ័យ ក៏នឹងសម្រេចក្នុងមរណសម័យ បើមិនសម្រេចក្នុងមរណសម័យកើតជាទេវបុត្រហើយ រមែងសម្រេច បើជាទេវបុត្រហើយ មិនសម្រេច បើ

គ្មានព្រះពុទ្ធកើតឡើងក្នុងលោក ភិក្ខុនោះ នឹងធ្វើឲ្យជាក់ច្បាស់នូវបច្ចេក-ពោធិញ្ញាណ បើមិនធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ រមែងជាខិប្បា-ភិញ្ញា ក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះសម្ពុទ្ធ ដូចព្រះពាហិយទារុចីរិយត្ថេរ ឬនឹងបានជាអ្នកមានបញ្ញាច្រើន ដូចព្រះសារីបុត្តត្ថេរ ឬមានឫទ្ធិច្រើន ដូចព្រះមហាមោគ្គល្លានត្ថេរ ឬជាអ្នកទ្រទ្រង់នូវធុតង្គគុណ ដូចព្រះមហាកស្សបត្ថេរ ឬជាអ្នកមានទិព្វចក្ខុ ដូចព្រះអនុរុទ្ធត្ថេរ ឬជាអ្នកទ្រទ្រង់ព្រះវិន័យ ដូចព្រះឧបាលិត្ថេរ ឬជាធម្មកថិក ដូចព្រះបុណ្ណមន្តានីបុត្តត្ថេរ ឬជាអ្នកនៅព្រៃជាវត្ត ដូចព្រះរេវតត្ថេរ ឬជាពហុស្សូត ដូចព្រះអានន្ទត្ថេរ ឬជាអ្នកប្រាថ្នាចំពោះការសិក្សា ដូចព្រះរាហុលត្ថេរដែលជាពុទ្ធបុត្រ ។ ក្នុងកម្មដ្ឋានដែលប្រកបដោយពួក ៤ នេះ ភិក្ខុណានាំកម្មដ្ឋានទៅផង និងនាំកម្មដ្ឋានត្រឡប់មកផង គោចរ-សម្បជញ្ញៈរបស់លោក ឈ្មោះថា ដល់កំពូល ដោយប្រការដូច្នេះ ។

ការមិនវង្វេងក្នុងឥរិយាបថទាំងឡាយ មានការឈានទៅខាងមុខជាដើម ឈ្មោះថា **អសម្មោហសម្បជញ្ញៈ** បណ្ឌិតគប្បីជ្រាបសេចក្តីនោះដូចតទៅ

ក្នុងធម្មវិន័យនេះ កាលឈានទៅខាងមុខ ឬថយមកខាងក្រោយ មិនវង្វេង ដូចបុថុជ្ជនអន្ធពាលវង្វេងក្នុងឥរិយាបថទាំងឡាយ មានការឈានទៅខាងមុខជាដើមថា ខ្លួនរមែងឈានទៅមុខ ការឈានទៅសម្រេចបានដោយខ្លួន ឬថា អញរមែងឈានទៅ ការឈានទៅសម្រេចបានដោយអញ ដូច្នេះ កាលមានចិត្តកើតឡើងថា អញនឹងឈានទៅ ដូច្នេះ វាយោធាតុ ដែលមានចិត្តជាសមុដ្ឋានញ៉ាំងការកម្រើកឲ្យកើត រមែងកើតឡើងដោយចិត្តនោះឯង ។

ដោយអាការយ៉ាងនេះ គ្រាន់ត្តឹងដែលសន្មតថា កាយនេះ រមែងឈានទៅ ដោយអំណាចនៃការផ្សាយទៅរបស់វាយោធាតុ ដែលកើតអំពីការធ្វើរបស់ចិត្ត កាលគ្រាន់ត្តឹងដែលសន្មតថា កាយនោះ ឈានទៅយ៉ាងនេះ ក្នុងការលើកជើងនីមួយៗ ធាតុទាំងពីរ គឺបឋវីធាតុ អាបោធាតុ មានប្រមាណតិចតួច មានកម្លាំងតិច ធាតុពីរក្រៅអំពីនេះ គឺវាយោធាតុ និងតេជោធាតុ មានប្រមាណច្រើន មានកម្លាំងច្រើន ។ ក្នុងការឈានទៅ និងការឈានទៅស៊ប់ក៏ដូចគ្នា ។ ក្នុងការដាក់ជើងចុះ ធាតុពីរ គឺតេជោធាតុ វាយោធាតុ មានប្រមាណតិច មានកម្លាំងតិច ធាតុពីរក្រៅអំពីនេះ មានប្រមាណច្រើន មានកម្លាំងច្រើន ។ ក្នុងការដាក់ជើងចុះ និងការដាក់ជើងស៊ប់ក៏ដូចគ្នា ។ ក្នុងការឈានទៅមុខនេះ រូបធម៌ និងអរូបធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងការលើកជើងឡើងនោះ រមែងមិនដល់នូវការលើកជើងឡើងស៊ប់ ។ រូបធម៌ និងអរូបធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងខណៈឈានជើងទៅនោះ រមែងមិនដល់នូវការឈានទៅស៊ប់ ។ រូបធម៌ និងអរូបធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងខណៈឈានទៅស៊ប់ រមែងមិនដល់នូវការដាក់ជើងចុះ ។ រូបធម៌ និងអរូបធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងខណៈដាក់ជើងចុះ រមែងមិនដល់នូវការដាក់ជើងចុះស៊ប់ ។ រូបធម៌ និងអរូបធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងខណៈដាក់ជើងចុះស៊ប់ រមែងមិនដល់នូវការលើកជើង ។ រូបធម៌ និងអរូបធម៌ទាំងឡាយ ក្នុងការឈានទៅខាងមុខនោះៗ ឯង ដំណាក់កាលនីមួយៗ តំណនីមួយៗ ចំណែកនីមួយៗ រមែងបែកធ្លាយទៅ ដូចគ្រាប់ល្ង

ដែលគេដាក់ក្នុងអំបែងក្តៅ រមែងផុះ បដៈ បដៈ ដូច្នោះ ។ ក្នុងការប្រព្រឹត្ត ទៅបែបនេះ បុគ្គលណាម្នាក់ រមែងឈានទៅឬ ជាការឈានទៅរបស់បុគ្គល ណាម្នាក់ឬ ដែលពិត ពោលដោយបរមត្ថហើយ ជាការប្រព្រឹត្តទៅរបស់ ធាតុទាំងឡាយប៉ុណ្ណោះ ជាការឈររបស់ធាតុទាំងឡាយ ជាការអង្គុយរបស់ ធាតុទាំងឡាយ ជាការដេករបស់ធាតុទាំងឡាយ សេចក្តីថា ជាអាការនៃ ធាតុទាំងឡាយប៉ុណ្ណោះ ។ ដ្បិតថា ក្នុងកោដ្ឋាសនោះៗ ចិត្តមួយដួងរមែង កើតឡើង ចិត្តមួយដួងរមែងរលត់ទៅ មួយអន្លើដោយដោយរូបទាំងឡាយ រមែងប្រព្រឹត្តទៅ ដូចក្រសែទឹកដែលទាក់ទងតាមគ្នាទៅមិនដាច់ខ្សែ ដូច្នោះ ។ ការមិនវង្វេងក្នុងឥរិយាបថទាំងឡាយ មានការឈានទៅខាងមុខជាដើម ដោយអាការយ៉ាងនេះ ឈ្មោះថា **សម្មោហសម្បជញ្ញៈ** ដូច្នេះឯង ។ អត្ថនៃ បទថា **អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ** មានប្រមាណប៉ុណ្ណោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អាលោកិតេ វិលោកិតេ** ដូចតទៅនេះ ការសម្លឹងមើលខាងមុខ ឈ្មោះថា **អាលោកិត** ការសម្លឹងមើលទិសតូច ទិសធំទាំងឡាយ ឈ្មោះថា **វិលោកិត** ។ ការសម្លឹងមើលទិសដទៃៗ ដោយអំណាចនៃការសម្លឹងខាងក្រោម ខាងលើ ខាងក្រោយ ឈ្មោះថា **ឱលោកិត** មើលខាងក្រោម **ឧល្លោកិត** មើលខាងលើ **អបលោកិត** មើល ខាងក្រោម ។ ការមើល ៣ យ៉ាងនោះ លោកមិនបានកាន់យកក្នុងបទថា **អាលោកិតេ វិលោកិតេ** នេះ ព្រោះថា ការមើល ២ យ៉ាងនេះ ព្រះមាន ព្រះភាគកាន់យកហើយ ដោយអំណាចនៃភាពសមគួរ ។ ម្យ៉ាងទៀត បើ

ពោលដោយមាតិកា ដែលជាប្រធានហើយ ការមើលទាំង ៣ យ៉ាងនោះ ក៏រួមក្នុងបទថា **អាលោកិតេ វិលោកិតេ** នេះឯង ។

ក្នុងបណ្តាការមើលទាំងនោះ កាលចិត្តកើតឡើងថា អញនឹងសម្លឹងមើលខាងមុខ ដូច្នេះ មិនបានសម្លឹងមើលដោយអំណាចត្រឹមតែចិត្តប៉ុណ្ណោះ ត្រូវកំណត់កាន់យកប្រយោជន៍ផង ទើបឈ្មោះថា **សាត្ថកសម្បជញ្ញៈ** ។

សាត្ថកសម្បជញ្ញៈនោះ បណ្ឌិតគប្បីជ្រាបដោយធ្វើព្រះនន្ទឲ្យជាបន្ទាល់ ដូច្នេះ ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទៅ ( ក្នុងអង្គុត្តរ-និកាយ អដ្ឋកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ បើនន្ទភិក្ខុរមិលមើលទៅទិសខាងកើត លុះតែប្រមូលនូវហេតុទាំងអស់ដោយចិត្ត ទើបនន្ទភិក្ខុរមិលមើលនូវទិសខាងកើត ដោយគំនិតថា អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈា និងទោមនស្ស នឹងមិនជាប់តាមអាត្មាអញ ដែលកំពុងរមិលមើលទិសខាងកើតយ៉ាងនេះ ។ ព្រោះហេតុនោះ ក្នុងសាសនានេះ ទើបនន្ទភិក្ខុឈ្មោះថា ជាអ្នកមានសេចក្តីដឹងខ្លួនក្នុងធម៌ ដែលប្រព្រឹត្តទៅដោយប្រយោជន៍[១] ក្នុងការគ្រប់គ្រងទ្វារនោះ ។ ម្នាលភិក្ខុទាំងឡាយ បើនន្ទភិក្ខុរមិលមើលទិសខាងលិច រមិលមើលទិសខាងជើង រមិលមើលទិសខាងត្បូង ងើយមើលទៅទិសខាងលើ ឱនមើលទិសខាងក្រោម ងាកមើលទៅទិសជាលំដាប់ លុះតែប្រមូលនូវហេតុទាំងអស់ដោយចិត្ត ទើបនន្ទភិក្ខុងាកមើលនូវ

១- បិដកខ្មែរ មិនមានពាក្យថា ក្នុងធម៌ដែលប្រព្រឹត្តទៅដោយប្រយោជន៍ ព្រោះបាលីមិនមានពាក្យថា សាត្ថក ឯបាលីរបស់អដ្ឋកថា មាន ។

ទិសជាលំដាប់ ដោយគិតថា អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈា និងទោមនស្ស នឹងមិនជាប់តាមអាត្មាអញ ដែលកំពុងឆាកមើលទិសជាលំដាប់ ។ ព្រោះហេតុនោះ ក្នុងសាសនានេះ ទើបទន្ទុភិក្ខុ ឈ្មោះថា ជាអ្នកមានសេចក្តីជីងខ្លួន ក្នុងការគ្រប់គ្រងទ្វារយ៉ាងនេះ ដូច្នេះ ។

ម្យ៉ាងទៀត ក្នុងបទថា **អាលោកិតេ វិលោកិតេ** នេះ បណ្ឌិតគប្បីជ្រាបការប្រព្រឹត្តទៅដោយប្រយោជន៍ និងការប្រព្រឹត្តទៅនៃសប្បាយ ដោយអំណាចនៃការឃើញព្រះចេតិយជាដើម តាមដែលពោលហើយនោះឯង ។ គោចរសម្បជញ្ញៈ គឺការមិនលះកម្មដ្ឋាននោះឯង ព្រោះហេតុនោះ ភិក្ខុអ្នកចម្រើនកម្មដ្ឋាន មានខន្ធ ធាតុ អាយតនៈ ជាអារម្មណ៍ គួរធ្វើការសម្លឹងមើលខាងមុខ សម្លឹងមើលក្នុងទីផ្សេងៗ ដោយអំណាចនៃកម្មដ្ឋានរបស់ខ្លួននោះឯង ឬថា បុគ្គលចម្រើនកម្មដ្ឋាន មានកសិណជាដើម គួរធ្វើការសម្លឹងមើលទៅខាងមុខ និងការសម្លឹងមើលទៅកាន់ទីផ្សេងៗ ដោយមានកម្មដ្ឋានជាធំនោះឯង ។ ឈ្មោះថា អត្តាខាងក្នុងជាអ្នកសម្លឹងមើលទៅមុខ ឬសម្លឹងមើលក្នុងទីផ្សេងៗ មិនមាន ។ តែកាលចិត្តកើតឡើងថា អញនឹងមើលទៅមុខ វាយោធាតុដែលមានចិត្តជាសមុដ្ឋាន ញុំាងការកម្រើកឲ្យកើតដោយចិត្តនោះឯង ត្របកភ្នែកខាងក្រោមក៏ទាញមកក្រោម ត្របកភ្នែកខាងលើក៏ទាញឡើងលើ ដោយអំណាចនៃការផ្សាយទៅរបស់វាយោធាតុ ដែលជាការធ្វើរបស់ចិត្ត ។ បុគ្គលណាម្នាក់ ឈ្មោះថា បើកភ្នែកដោយគ្រឿងយន្ត មិនមាន ។ ក្នុងលំដាប់នោះ ចក្ខុវិញ្ញាណក៏កើតឡើង ញុំាងទស្សនកិច្ចឲ្យសម្រេច

ការដឹងយ៉ាងនេះ ឈ្មោះថា **អសម្មោហសម្បជញ្ញៈ** ក្នុងបទថា **អាលោកិតេ វិលោកិតេ** នេះ ។

ម្យ៉ាងទៀត គប្បីជ្រាបអសម្មោហសម្បជញ្ញៈក្នុងទីនេះ ដោយអំណាចនៃភាពជាមូលបរិញ្ញាអាគន្តុកៈ និងតាវកាលិកៈដូចតទៅ

ពោលដោយមូលបរិញ្ញា គឺការដឹងជុំវិញដោយមូល ជាមុនដូច្នេះថា ភវង្គចិត្ត អាវជ្ជនចិត្ត ចក្ខុវិញ្ញាណចិត្ត សម្បដិច្ឆន្នចិត្ត សន្តីរណចិត្ត វោដ្ឋព្វនចិត្ត បន្ទាប់អំពីនោះ ជវនចិត្ត រមែងកើតជាគម្រប់ ៧ ។

បណ្តាចិត្តទាំងនោះ ភវង្គចិត្ត រមែងញ៉ាំងកិច្ចដែលជាចំណែកនៃឧបបត្តិភពឲ្យសម្រេចប្រព្រឹត្តទៅ ។ កិរិយាមនោធាតុ ញ៉ាំងភង្គចិត្តឲ្យកន្លងទៅហើយ ទើបញ៉ាំងអាវជ្ជនកិច្ចឲ្យសម្រេចប្រព្រឹត្តទៅ ព្រោះការរលត់ទៅនៃកិរិយាមនោធាតុនោះ ទើបចក្ខុវិញ្ញាណចិត្ត ញ៉ាំងទស្សនកិច្ចឲ្យសម្រេចប្រព្រឹត្តទៅ ព្រោះការរលត់ទៅនៃចក្ខុវិញ្ញាណចិត្តនោះ ទើបវិបាកមនោធាតុ ញ៉ាំងសម្បដិច្ឆន្នកិច្ចឲ្យសម្រេចប្រព្រឹត្តទៅ ព្រោះការរលត់ទៅនៃវិបាកមនោធាតុនោះ ទើបវិបាកមនោវិញ្ញាណធាតុ ញ៉ាំងសន្តីរណកិច្ចឲ្យសម្រេចប្រព្រឹត្តទៅ ព្រោះការរលត់ទៅនៃវិបាកមនោវិញ្ញាណធាតុនោះ ទើបកិរិយាមនោវិញ្ញាណធាតុ ញ៉ាំងវោដ្ឋព្វនកិច្ចឲ្យសម្រេចប្រព្រឹត្តទៅ ព្រោះការរលត់ទៅនៃកិរិយាមនោវិញ្ញាណធាតុនោះ ជវនចិត្តក៏ស្ទុះទៅ ៧ ខណៈ ។ ក្នុងជវនចិត្តទាំងនោះ ក្នុងជវនទីមួយៗ មិនមានការសម្លឹងមើលទៅមុខ ឬការ

សម្លឹងមើលទៅកាន់ទីផ្សេងៗ ថា នេះស្ត្រី នេះបុរស ដោយអំណាចនៃការត្រេកអរ មិនត្រេកអរ និងការវង្វេង ក្នុងជវនចិត្តដួងទី ២ ។បេ។ ក្នុងជវនចិត្តដួងទី ៧ ក៏យ៉ាងនោះ ។ កាលជវនចិត្តទាំងនោះបែកធ្លាយទៅ ដោយអំណាចនៃអារម្មណ៍ខ្ពស់ទាបៗ ដូចទាហានក្នុងលានចម្បាំង ការសម្លឹងមើលទៅមុខ ឬការសម្លឹងមើលទៅកាន់ទីផ្សេងៗ ថា នេះជាស្រី នេះជាប្រុស ដោយអំណាចនៃការត្រេកអរជាដើម ទើបមាន ។ បណ្ឌិតគប្បីជ្រាបអសម្មោហសម្បជញ្ញៈ ក្នុងទីនេះ ដោយអំណាចនៃមូលបរិញ្ញា ដោយប្រការដូច្នេះ ។

( ពោលដោយអាគន្តុកៈ គឺដោយអំណាចនៃភាពដូចជាភ្ញៀវដូច្នេះ )

ក្នុងចក្ខុទ្វារ កាលរូបមកកាន់គន្លងហើយ បន្ទាប់អំពីភវង្គចលនៈ កាលចិត្តទាំងឡាយ មានអាវជ្ជនចិត្តជាដើម កើតឡើងដោយអំណាចនៃការញុំាងកិច្ចរៀងៗ ខ្លួនឲ្យសម្រេច ហើយរលត់ទៅក្នុងទីបំផុត ជវនចិត្តក៏កើតឡើង ជវនចិត្តនោះ រមែងកើតក្នុងចក្ខុទ្វារ ដែលជាផ្ទះរបស់អាវជ្ជនចិត្តជាដើមដែលកើតឡើងមុន ដូចបុរសដែលជាភ្ញៀវ កាលបុរសជាភ្ញៀវនោះចូលទៅដើម្បីសូមរបស់ណាមួយក្នុងផ្ទះរបស់អ្នកដទៃ មិនគួរប្រទូស្តក្នុងម្ចាស់របស់ផ្ទះ ដែលអង្គុយស្ងៀម យ៉ាងណា កាលអាវជ្ជនចិត្តជាដើមដែលមិនត្រេកអរ មិនប្រទូស្ត និងមិនវង្វេងក្នុងចក្ខុទ្វារដែលជាផ្ទះរបស់អាវជ្ជនចិត្តជាដើម ការត្រេកអរ ការប្រទូស្ត ការវង្វេង ក៏មិនគួរមាន យ៉ាងនោះ គប្បីជ្រាបអសម្មោហសម្បជញ្ញៈ ដោយអំណាចនៃភាពជាអាគន្តុកៈ ដូចពណ៌នាមក

ដូច្នេះ ។

( ពោលដោយភាពជាតាវកាលិកៈ គឺធម៌មួយជួរខណៈ ដូច្នេះថា )

ចិត្តទាំងឡាយ មានអាវជ្ជនចិត្តជាបរិយោសានពួកណា រមែងកើតឡើងក្នុងចក្ខុទ្វារ ចិត្តទាំងនោះ និងសម្បយុត្តធម៌ទាំងឡាយ រមែងបែកធ្លាយទៅក្នុងទីនោះៗ ឯង រមែងមិនឃើញនូវគ្នានិងគ្នា ព្រោះហេតុនោះ ចិត្តក្រៅអំពីនេះឈ្មោះថា ជាតាវកាលិកៈ គឺជាធម៌មួយជួរខណៈ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងសេចក្ដីនោះដូចតទៅ

កាលពួកមនុស្សទាំងពួងក្នុងផ្ទះមួយស្លាប់ហើយ ឈ្មោះថា ការត្រេកអរក្រៃលែងក្នុងការរាំច្រៀងជាដើម មិនគួរមានដល់បុគ្គលដ៏សេស ដែលនៅតែម្នាក់ឯង ដែលគេក៏នឹងស្លាប់ក្នុងខណៈនោះឯង ( ដែរ ) យ៉ាងណា ក្នុងទ្វារមួយ ក៏យ៉ាងនោះដូចគ្នា កាលអាវជ្ជនចិត្តជាដើម មួយអន្លើដោយសម្បយុត្តធម៌រលត់ទៅហើយ ក្នុងទីនោះៗ ឯង ឈ្មោះថា ការត្រេកអរក្រៃលែងដោយអំណាចនៃការត្រេកអរ មិនត្រេកអរ និងការវង្វេង មិនគួរមានហើយដល់ជវនចិត្តដ៏សេស ដែលនឹងមានការរលត់ទៅក្នុងខណៈនោះឯង ។ គប្បីជ្រាបអសម្មោហសម្បជញ្ញៈ ដោយអំណាចភាពជាធម៌មួយជួរខណៈ ដូចពណ៌នាមកនេះ ។

ម្យ៉ាងទៀត គប្បីជ្រាបអសម្មោហសម្បជញ្ញៈនោះ ដោយអំណាចនៃការពិចារណាដោយភាពជាខន្ធ អាយតនៈ ធាតុ និងបច្ច័យ ។ ពិតហើយ ក្នុងការពិចារណាដោយភាពជាខន្ធនោះ មានដូចតទៅ

ចក្ខុ និងរូបទាំងឡាយ ជារូបក្ខន្ធ ចក្ខុវិញ្ញាណដែលធ្វើទស្សនកិច្ច ជាវិញ្ញាណក្ខន្ធ វេទនាដែលសម្បយុត្តជាមួយចក្ខុវិញ្ញាណនោះ ជាវេទនាខន្ធ សញ្ញាជាសញ្ញាខន្ធ ផស្សៈជាដើម ជាសង្ខារក្ខន្ធ ។

ដោយប្រការដូច្នេះ ការមើលទៅខាងមុខ និងការមើលក្នុងទិសផ្សេងៗ ទើបប្រាកដឡើងបាន ព្រោះការប្រជុំគ្នានៃខន្ធទាំង ៥ នេះ ។ ក្នុងទីនេះ តើមានបុគ្គលណាម្នាក់សម្លឹងមើលទៅខាងមុខ និងសម្លឹងមើលទៅកាន់ទិសផ្សេងៗ នោះ ដោយទំនងដូចគ្នានេះ ក្នុងការពិចារណាដោយភាពជាអាយតនៈនោះ ដូច្នេះ គឺ

ចក្ខុ ជាចក្ខាយតនៈ រូប ជារូបាយតនៈ ចក្ខុវិញ្ញាណដែលធ្វើទស្សនកិច្ច ជាមនាយតនៈ ធម៌ដែលសម្បយុត្តជាមួយចក្ខុវិញ្ញាណ មានវេទនាជាដើម ជាធម្មាយតនៈ ។

ដោយប្រការដូច្នេះ ការមើលទៅខាងមុខ និងការមើលទៅកាន់ទិសផ្សេងៗ ទើបប្រាកដឡើងបាន ព្រោះការប្រជុំគ្នានៃអាយតនៈទាំង ៤ នេះ ។ ក្នុងទីនេះ តើមានអ្នកណាម្នាក់ ដែលសម្លឹងមើលខាងមុខ ឬសម្លឹងមើលក្នុងទិសផ្សេងៗ នោះ ។

ដោយទំនងដូចគ្នា ក្នុងការពិចារណាដោយភាពជាធាតុនោះ មានដូចតទៅ ចក្ខុ ជាចក្ខុធាតុ រូប ជារូបធាតុ ចក្ខុវិញ្ញាណដែលធ្វើទស្សនកិច្ច ជាចក្ខុវិញ្ញាណធាតុ ធម៌ មានវេទនាជាដើម ដែលសម្បយុត្តដោយចក្ខុវិញ្ញាណនោះ ជាធម្មធាតុ ។

ដោយប្រការយ៉ាងនេះ ការសម្លឹងមើលខាងមុខ និងការសម្លឹងមើលក្នុងទិសផ្សេងៗ ទើបប្រាកដឡើងបាន ព្រោះការប្រជុំគ្នានៃធាតុទាំង ៤ នោះ ក្នុងទីនេះ តើមានបុគ្គលណាម្នាក់ សម្លឹងមើលទៅមុខ ឬសម្លឹងមើលក្នុងទិសផ្សេងៗ នោះ ។ ដោយទំនងដូចគ្នានេះ ក្នុងការពិចារណាដោយភាពជាបច្ច័យ មានដូចតទៅ

ចក្ខុ ជានិស្សយប្បច្ច័យ រូប ជាអារម្មណប្បច្ច័យ អាវជ្ជនចិត្ត ជាអានន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អានន្តរូបនិស្សយប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ អាលោកៈ ជាឧបនិស្សយបច្ច័យ វេទនាជាដើម ជាសហជាតប្បច្ច័យ ។

ដោយប្រការដូច្នេះ ការសម្លឹងមើលទៅខាងមុខ និងការសម្លឹងមើលទៅកាន់ទិសផ្សេងៗ ទើបប្រាកដឡើងបាន ព្រោះការប្រជុំគ្នានៃបច្ច័យទាំងឡាយនេះ ។ ក្នុងទីនេះ តើមានបុគ្គលណាម្នាក់ ជាអ្នកសម្លឹងមើលទៅខាងមុខ និងសម្លឹងមើលក្នុងទិសផ្សេងៗ នោះ ។ គប្បីជ្រាបអសម្មោហសម្បជញ្ញៈ ក្នុងបទថា **អាលោកិតេ វិលោកិតេ** នេះ ដោយអំណាចនៃការពិចារណាជាខន្ធ អាយតនៈ ធាតុ និងភាពជាបច្ច័យដូចពណ៌នាមក ដូច្នេះ ។

បទថា **សមិញ្ជិតេ បសារិតេ** បានដល់ ជាអ្នកដឹងច្បាស់ដោយប្រក្រតី ក្នុងការលាតអង្គុញ បត់សណ្តូកនូវអវយវៈដូចតទៅ

បទថា **សមិញ្ជិតេ បសារិតេ** បានដល់ ការបត់អវយវៈចូល និងការលាអវយវៈចេញនៃសន្ធាក់ទាំងឡាយ ។ ក្នុងទីនេះ ការដែលភិក្ខុមិនធ្វើ

ការបត់អន្ទុញ និងការលាតសណ្ដូកអវយវៈ ដោយអំណាចនៃចិត្តប៉ុណ្ណោះ ហើយកំណត់ដល់វត្ថុដែលជាប្រយោជន៍ និងវត្ថុមិនមែនប្រយោជន៍ ព្រោះការបត់អន្ទុញ និងការលាតសណ្ដូកដៃ និងជើងជាបច្ច័យ ហើយកំណត់កាន់យកតែប្រយោជន៍ក្នុងការបត់ចូល លាចេញនោះ បានឈ្មោះថា **សាត្ថកសម្បជញ្ញៈ** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសេចក្ដីនេះដូចតទៅ

កាលភិក្ខុនោះ បត់ ឬលា ដៃ និងជើងយូរពេក ទុក្ខវេទនារមែងកើតឡើងគ្រប់ៗ ខណៈ ចិត្តមិនជាឯកគ្គតា កម្មដ្ឋានរមែងធ្លាក់ទៅ ភិក្ខុនោះរមែងមិនសម្រេចគុណវិសេស ។

បើភិក្ខុនោះ បត់អវយវៈចូលក្នុងកាលដែលសមគួរ កាលលាអវយវៈចេញក្នុងពេលដែលគួរ ទុក្ខវេទនាទាំងនោះ រមែងមិនកើត ចិត្តរមែងមានអារម្មណ៍តែមួយ កម្មដ្ឋានរមែងដល់នូវការផ្សាយទៅ ភិក្ខុនោះរមែងសម្រេចគុណវិសេស បណ្ឌិតគប្បីជ្រាបការកំណត់វត្ថុដែលជាប្រយោជន៍ និងមិនមែនប្រយោជន៍យ៉ាងនេះ ។

កាលប្រយោជន៍ មានការកំណត់សប្បាយ និងអសប្បាយ ហើយកាន់តែសប្បាយ ឈ្មោះថា **សប្បាយសម្បជញ្ញៈ** ។

ក្នុងសប្បាយសម្បជញ្ញៈនោះ មានន័យដូចតទៅនេះ បានឮថា ភិក្ខុកំលោះទាំងឡាយស្វាធ្យាយពុទ្ធវចនៈ ត្រង់លានព្រះមហាចេតិយ ភិក្ខុនីទាំងឡាយ កំពុងស្ដាប់ធម៌ខាងក្រោយភិក្ខុកំលោះនោះ ។ បណ្ដាភិក្ខុទាំងនោះ

ភិក្ខុកំលោះមួយរូប លាដៃចេញទៅ ត្រូវកាយភិក្ខុនីហើយ ជាហេតុឲ្យលោកលាសិក្ខាទៅជាគ្រហស្ថ ។ ភិក្ខុមួយរូបទៀត លាជើង ក៏ទៅប៉ះគំនរភ្លើង ភ្លើងឆេះជើងរបស់លោករហូតដល់ឆ្អឹង ។ ភិក្ខុមួយរូបទៀត សណ្តូកទៅត្រង់ដំបូក ត្រូវអាសិរពិសខាំហើយ ។ ភិក្ខុមួយរូបទៀត លាដៃទៅត្រង់ខ្សែស្បៀង ត្រូវពស់ខៀវចឹកហើយ ព្រោះហេតុនោះ ភិក្ខុមិនគប្បីលាដៃ លាជើងក្នុងទីអសប្បាយបែបនេះ គួរលាក្នុងទីសប្បាយ ។ នេះឈ្មោះថា **សប្បាយសម្បជញ្ញៈ** ក្នុងសេចក្តីនេះ ។

គោចរសម្បជញ្ញៈ បណ្ឌិតគប្បីសម្តែងរឿងព្រះមហាថេរៈដូចតទៅនេះ បានឮថា ព្រះមហាថេរៈអង្គុយសម្រាកក្នុងទីសម្រាកពេលថ្ងៃ សន្ទនាជាមួយនឹងអន្តេវាសិកទាំងឡាយ ខ្វះស្មារតី បត់ដៃចូលមកដោយរហ័ស ហើយក៏ដកដៃត្រឡប់មកដាក់ក្នុងទីដើម ហើយបត់ចូលសន្សឹមៗ មក ។ ពួកអន្តេវាសិកសួរថា ព្រោះហេតុអ្វី ទើបលោកម្ចាស់បត់ដៃចូលមកដោយរហ័ស ហើយដកដៃមកដាក់កន្លែងដើម បត់ចូលម្តងទៀត ដោយសន្សឹមៗ ព្រះថេរៈឆ្លើយថា អើអាវុសោទាំងឡាយ ចាប់តាំងពីខ្ញុំផ្តើមមនសិការកម្មដ្ឋាន ខ្ញុំមិនធ្លាប់លះកម្មដ្ឋានបត់ដៃចូលមក តែឥឡូវនេះ ខ្ញុំកំពុងសន្ទនាជាមួយពួកលោក លះនូវកម្មដ្ឋាន បត់ដៃចូលមក ព្រោះហេតុនោះ ទើបខ្ញុំដកដៃត្រឡប់មកដាក់កន្លែងដើម ហើយបត់ចូលសាជាថ្មី ។ ពួកអន្តេវាសិកទាំងនោះ នាំគ្នាឲ្យសាធុការថា សាធុ លោកម្ចាស់ ធម្មតាភិក្ខុ គប្បីជាបុគ្គលដូចលោកម្ចាស់នោះឯង ។ ការមិនលះកម្មដ្ឋាននោះឯង គប្បីជ្រាបថា គោចរសម្បជញ្ញៈ

*ក្នុងបទថា* **សមិញ្ជិតេ បសារិតេ** *នេះ ដោយអាការយ៉ាងនេះ ។*

*ឈ្មោះថា អត្តាក្នុងខាងក្នុង ដែលជាអ្នកបត់អវយវៈចូល ឬលាអវយវៈចេញ មិនមាន ។ ការកំណត់ថា ការបត់អវយវៈចូល ការលាអវយវៈចេញ រមែងមានដោយការផ្សាយទៅនៃវាយោធាតុ ដែលជាការធ្វើរបស់ចិត្ត មានប្រការតាមដែលពោលហើយ ដូចរូបមនុស្សយន្តកម្រើកដៃជើងបាន ដោយអំណាចនៃការទាញអំបោះ គប្បីជ្រាបថា* **អសម្មោហសម្បជញ្ញ** *ក្នុងបទថា* **សមិញ្ជិតេ បសារិតេ** *នេះ ។*

*ក្នុងបទថា* **សង្ឃាដិបត្តចីវរធារណេ** *នេះ ការប្រើប្រាស់សង្ឃាដី និងចីវរ ដោយអំណាចនៃការស្លៀកដណ្តប់ និងការប្រើប្រាស់បាត្រ ដោយអំណាចនៃការទទួលភិក្ខាជាដើម ឈ្មោះថា* **ធារណេ** *។ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងការទ្រទ្រង់នូវសំពត់សង្ឃាដី និងចីវរ ក្នុងបទថា* **សង្ឃាដិបត្ត-ចីវរធារណេ** *នេះប៉ុណ្ណេះ ។ កាលបើអាមិសរបស់ភិក្ខុដែលស្លៀកដណ្តប់ហើយ ត្រាច់ទៅដើម្បីបិណ្ឌបាត និងប្រយោជន៍ មានប្រការដូចព្រះមានព្រះភាគត្រាស់ដោយន័យជាដើមថា ដើម្បីការឆោរនូវត្រជាក់នោះឯង ឈ្មោះថា ប្រយោជន៍ ។ បណ្ឌិតគប្បីជ្រាបថា ជាសាត្ថកសម្បជញ្ញៈ ដោយអំណាចនៃប្រយោជន៍នោះ ។*

*ម្យ៉ាងទៀត ចីវរស្តើង ជាសប្បាយដល់ភិក្ខុដែលមានប្រក្រតីក្តៅ មានកម្លាំងថមថយ ។ ចីវរសាច់ក្រាស់ ឬពីរជាន់ ជាសប្បាយដល់ភិក្ខុដែលមានប្រក្រតីរងា ក្រៅអំពីនេះជាអសប្បាយ ។ បុគ្គលមានចីវរចាស់គ្រាំគ្រា*

ជាអសប្បាយដូចគ្នា ដល់ភិក្ខុរបខ្វះ ព្រោះថា ចីវរចាស់ផ្ទាំងនោះ រមែងធ្វើបលិពោធដល់ភិក្ខុ ព្រោះលំបាកក្នុងការជួសជុលជាដើម ដោយទំនងដូចគ្នា ចីវរដែលពួកចោរចង់បាន មានសំពត់ត្បាញដោយសូត្រ រោមសត្វ សំពត់ទុកូលជាដើម ក៏ជាអសប្បាយ ។ ពិតហើយ សំពត់បែបនោះ រមែងធ្វើអន្តរាយដល់ការនៅ ឬធ្វើអន្តរាយចំពោះជីវិតរបស់ភិក្ខុដែលនៅតែម្នាក់ឯងក្នុងព្រៃ ។ ម្យ៉ាងទៀត បើពោលដោយត្រង់ហើយ ចីវរណាកើតឡើងដោយអំណាចនៃមិច្ឆាជីវៈ មានការទាយនិមិត្តជាដើម និងចីវរណា កាលភិក្ខុប្រើប្រាស់ អកុសលធម៌ទាំងឡាយចម្រើន កុសលធម៌សាបសូន្យទៅ ចីវរនោះជាអសប្បាយ ។ ក្រៅអំពីនេះ ជាសប្បាយ ។

ក្នុងបទថា **សង្ឃាដិបត្តចីវរធារណេ** នេះ ឈ្មោះថា គប្បីជ្រាបថា ជាអសប្បាយសម្បជញ្ញៈ ដោយអំណាចនៃការទ្រទ្រង់សំពត់សង្ឃាដី និងចីវរដែលជាសប្បាយនោះ ។ គោចរសម្បជញ្ញៈ គប្បីជ្រាបថា មិនលះបង់កម្មដ្ឋានដូចគ្នា ។

ឈ្មោះថា អត្តាណាមួយខាងក្នុង ធ្វើការដណ្តប់ចីវរមិនមាន តែការដណ្តប់ចីវរ រមែងមានដោយអំណាចនៃការផ្សាយទៅរបស់វាយោធាតុ ដែលជាការធ្វើរបស់ចិត្ត មានប្រការតាមដែលពោលហើយនោះឯង ក្នុងការទ្រទ្រង់ចីវរនោះ សូម្បីចីវរក៏មិនមានចេតនា សូម្បីកាយក៏មិនមានចេតនា ចីវរក៏មិនដឹងថា អញស្រោបកាយ កាយសោតក៏មិនដឹងថា អញត្រូវចីវរស្រោបដូច្នេះ ។ ធាតុទាំងឡាយនោះឯង រមែងបិទបាំងនូវពួកនៃធាតុជាមួយគ្នា ដូច

ការខ្ចប់សៀវភៅដោយកំណាត់សំពត់ចាស់ៗ ព្រោះហេតុនោះ ការដែលភិក្ខុបានចីវរដែលល្អមក ក៏មិនគប្បីសោមនស្ស បានចីវរដែលមិនល្អមក ក៏មិនគប្បីទោមនស្ស ដូចក្នុងទីទាំងឡាយ មានដំបូក និងដើមឈើធំជាដើម បុគ្គលណាម្នាក់ធ្វើសក្ការៈដោយវត្ថុទាំងឡាយ មានផ្កាកម្រង គ្រឿងក្រអូប ផ្សែងក្រអូប និងសំពត់ជាដើម បុគ្គលណាម្នាក់ មិនធ្វើសក្ការៈ ដោយការគ្រវែងដោយលាមក មូត្រ កក់ ឬប្រទូស្តដោយដំបង និងសស្ត្រាជាដើម និងដើមឈើជាដើមនោះ រមែងមិនសោមនស្ស មិនទោមនស្ស ដោយហេតុនោះយ៉ាងណា ភិក្ខុនោះក៏យ៉ាងនោះ បាននូវចីវរល្អ ក៏មិនធ្វើនូវការពេញចិត្ត បាននូវចីវរមិនល្អ ក៏មិនធ្វើនូវការមិនពេញចិត្ត ។ បណ្ឌិតគប្បីជ្រាបថា អសម្មោហ-សម្បជញ្ញៈ ក្នុងការស្លៀកដណ្តប់ចីវរនេះ ដោយអំណាចនៃការពិចារណាដែលប្រព្រឹត្តទៅហើយ ដោយអាការយ៉ាងនេះ ដោយប្រការដូច្នេះ ។

ក្នុងការទ្រទ្រង់បាត្រ គប្បីជ្រាបថា ជាសាត្ថកសម្បជញ្ញៈ ដោយអំណាចប្រយោជន៍ ដែលភិក្ខុមិនកាន់យកបាត្រដោយរហ័សពេក ទៅហើយគួរបាន ព្រោះការកាន់យកបាត្រជាបច្ច័យយ៉ាងនេះថា អញកាន់យកបាត្រនេះហើយត្រាច់ទៅដើម្បីបិណ្ឌបាតនឹងបានភិក្ខា បាត្រធ្ងន់ ជាអសប្បាយដល់ភិក្ខុដែលមានរាងកាយស្គម មិនមានកម្លាំង ។ បាត្រដែលមានពក ៤ ឬដែលលាងឲ្យស្អាតបានដោយក្រ ជាអសប្បាយដល់ភិក្ខុរបខ្វះ បាត្រដែលភិក្ខុធ្វើការសម្អាតមិនល្អ មិនសមគួរដល់ភិក្ខុ ។ បលិពោធរមែងមានដល់លោកដែលលាងបាត្រនោះ ។ម្យ៉ាងទៀត បាត្រមានពណ៌ដូចកែវមណី ដែលជាទី

តាំងនៃលោកៈ ជាអសប្បាយ ដូចន័យដែលពោលក្នុងរឿងចីវរនោះឯង ។ បាត្រណា ដែលបានមកដោយអំណាចនៃការទាយនិមិត្តជាដើមក្តី បាត្រណា កាលលោកប្រើប្រាស់ អកុសលធម៌ទាំងឡាយចម្រើន កុសលធម៌ទាំងឡាយ វិនាសក្តី បាត្រនេះ ជាអសប្បាយដោយចំណែកមួយ ។ បាត្រក្រៅអំពីនេះ ជាសប្បាយ ។

ការទ្រទ្រង់បាត្រនេះ បណ្ឌិតគប្បីជ្រាបថា ជាសប្បាយសម្បជញ្ញៈ ដោយអំណាចនៃបាត្រដែលជាសប្បាយនោះ គប្បីជ្រាបថា ជាគោចរ-សម្បជញ្ញៈ ដោយមិនលះកម្មដ្ឋាននោះឯង ។

ឈ្មោះថា តួខ្លួនណាមួយនៅខាងក្នុង កាន់នូវបាត្រមិនមាន ព្រោះថា ការកាន់បាត្រ រមែងមានដោយអំណាចការផ្សាយទៅរបស់វាយោធាតុ ដែលជាការធ្វើរបស់ចិត្ត មានប្រការតាមដែលពោលហើយនោះឯង ។

ក្នុងឋានៈបែបនេះ បាត្រក៏មិនមានចេតនា ដៃក៏មិនមានចេតនា បាត្រមិនដឹងថា អញត្រូវដៃកាន់ ដៃសោតក៏មិនដឹងថា បាត្រត្រូវអញកាន់ហើយដូច្នេះ ធាតុទាំងឡាយនោះឯង រមែងកាន់នូវធាតុផងគ្នា ដូចការប្រើអណ្តើដែកថ្ពៀបបាត្រក្នុងភ្លើង ។ គប្បីជ្រាបអសម្មោហសម្បជញ្ញៈ ក្នុងពាក្យថា ការទ្រទ្រង់នូវបាត្រនេះ ដោយអំណាចនៃការពិចារណា ការប្រព្រឹត្តទៅហើយ ដោយអាការយ៉ាងនេះ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត បុរសដែលពោរពេញដោយករុណា ឃើញជនអនាថា មានដៃ និងជើងកំបុតហើយ មានឈាម និងខ្ទុះហូរចេញមក មួយអន្ទើដោយ

ជន្លូវ អំពីមុខដំបៅ ដែលដេរជាសហើយដោយរុយខៀវ ត្រង់សាលាមនុស្ស អនាថា ទើបឲ្យសំពត់ផ្ទាំងតូច សម្រាប់រុំដំបៅ និងថ្នាំសម្រាប់ព្យាបាល មួយអន្ទើដោយអំបែងដើម្បីមនុស្សអនាថាទាំងនោះ ។ ក្នុងទ្រព្យទាំងនោះ អ្នកខ្លះបានសំពត់រុំដំបៅសាច់ម៉ដ្ឋ អ្នកខ្លះបានសំពត់សាច់គ្រោតគ្រាត សូម្បីអំបែងសម្រាប់ដាក់ថ្នាំ បុគ្គលខ្លះបានអំបែងល្អ បុគ្គលខ្លះបានអំបែងអាក្រក់ ជនទាំងនោះ រមែងមិនត្រេកអរ មិនទោមនស្សក្នុងរបស់ទាំងនោះ ព្រោះថា សេចក្តីត្រូវការរបស់ជនទាំងនោះ ដោយសំពត់ត្រឹមតែរុំដំបៅប៉ុណ្ណោះ ឯអំបែង ក៏ត្រឹមតែជារបស់ដាក់ថ្នាំនោះឯង យ៉ាងណា សេចក្តីនេះ ក៏យ៉ាងនោះ ភិក្ខុណាកំណត់ចីវរដូចសំពត់រុំដំបៅ កំណត់ គឺពិចារណាបាត្រ ដូចអំបែងស្មោរថ្នាំ កំណត់ភិក្ខាដែលបានហើយក្នុងបាត្រដូចថ្នាំក្នុងអំបែង ភិក្ខុនេះ បណ្ឌិតគប្បីជ្រាបថា ជាអ្នកមានប្រក្រតីធ្វើសម្បជញ្ញៈដ៏ឧត្តម ដោយអសម្មោហសម្បជញ្ញៈក្នុងការទ្រទ្រង់សំពត់សង្ឃាដី បាត្រ និងចីវរនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អសិតេ** ជាដើមដូចតទៅនេះ

បទថា **អសិតេ** បានដល់ ការបរិភោគដុំបាយដែលធ្លាក់ក្នុងបាត្រជាដើម ។ បទថា **បីតេ** បានដល់ ក្នុងការហុតបបរជាដើម ។ បទថា **ខាយិតេ** បានដល់ ក្នុងការខាំទំពាអាហាររឹងដែលធ្វើដោយម្សៅជាដើម ។ បទថា **សាយិតេ** បានដល់ ការលិទ្ធភក្សរសទឹកឃ្មុំ និងទឹកអំពៅជាដើម ។ ក្នុងការបរិភោគអាហារជាដើមនោះ ប្រយោជន៍ទាំង ៨ យ៉ាង ដែលព្រះមានព្រះភាគត្រាស់ដោយន័យថា អញនឹងមិនបរិភោគដើម្បីលេងជាដើម ឈ្មោះ

ថា ប្រយោជន៍ ។ គប្បីជ្រាបសាត្ថកសម្បជញ្ញៈ ដោយអំណាចនៃការបរិភោគដែលជាប្រយោជន៍នោះ ។

បណ្តាអាហារទាំងឡាយដែលអាក្រក់ ដែលប្រណីត មានរសល្វីង រសផ្អែមជាដើម ភិក្ខុណាមិនមានផាសុកដោយអាហារប្រភេទណា អាហារនោះចាត់ជាអសប្បាយដល់ភិក្ខុនោះ ។ ម្យ៉ាងទៀត អាហារណាដែលភិក្ខុបានមកដោយអំណាចនៃការទាយនិមិត្តជាដើមក្តី អាហារណា កាលភិក្ខុឆាន់ អកុសលធម៌ទាំងឡាយចម្រើន កុសលធម៌ទាំងឡាយវិនាសទៅក្តី អាហារនោះៗជាអសប្បាយដោយចំណែកមួយនោះឯង អាហារដែលផ្ទុយគ្នា តាមដែលពោលមក ជាសប្បាយ ។ ក្នុងទីនេះ គប្បីជ្រាបថា ជាសប្បាយសម្បជញ្ញៈដោយអំណាចនៃការបរិភោគអាហារដែលជាសប្បាយនោះៗ ឯង ។ គប្បីជ្រាបថា ជាគោចរសម្បជញ្ញៈ ដោយអំណាចនៃការមិនលះបង់កម្មដ្ឋាននោះឯង ។

ឈ្មោះថា តួខ្លួនណាមួយខាងក្នុង ជាអ្នកបរិភោគមិនមាន ដ្បិតថា ឈ្មោះថា ការទទួលបាត្រ រមែងមានព្រោះការផ្សាយទៅនៃវាយោធាតុ ដែលជាការធ្វើរបស់ចិត្ត មានប្រការដូចពោលហើយនោះឯង ។ ឈ្មោះថា ការលូកដៃក្នុងបាត្រ រមែងមានព្រោះការផ្សាយទៅនៃវាយោធាតុ ដែលជាការធ្វើរបស់ចិត្តនោះឯង ។ ការធ្វើពំនូតបាយ ការលើកដុំបាយដាក់ចូលក្នុងមាត់ ការបើកមាត់ រមែងមានព្រោះការផ្សាយទៅរបស់វាយោធាតុ ដែលជាការធ្វើរបស់ចិត្តនោះឯង មិនមានបុគ្គលណាបញ្ឆារដោយគ្រឿងចក្រ ឬដោយគ្រឿង

យន្តណាមួយឡើយ ការដាក់ពំនូតបាយក្នុងមាត់ ការដែលធ្មេញខាងក្រៅធ្វើកិច្ចសម្រេចដូចអង្រែ ការដែលធ្មេញខាងក្រោមធ្វើកិច្ចឲ្យសម្រេចដូចត្បាល់ ការដែលអណ្តាតធ្វើកិច្ចឲ្យសម្រេចដូចដៃ មានដោយការផ្សាយទៅរបស់វាយោធាតុ ដែលជាការធ្វើរបស់ចិត្តនោះឯង ។ បន្ទាប់អំពីនោះ ទឹកមាត់ថ្លាត្រង់ចុងអណ្តាត ទឹកមាត់ខាប់ត្រង់គល់អណ្តាត រមែងផ្សើមអាហារក្នុងទីនោះៗ ។ ដុំបាយនោះប្រមូលដោយដៃ គឺអណ្តាត ត្រង់ត្បាល់ គឺធ្មេញខាងក្រោម ផ្សើមដោយទឹកមាត់ បុកល្អិតហើយដោយធ្មេញខាងលើ ឈ្មោះថា បុគ្គលណាម្នាក់ដែលឲ្យចូលទៅខាងក្នុងដោយស្លាបព្រា ឬវែក មិនមាន ។ អាហារនោះ រមែងចូលទៅ ដោយវាយោធាតុ ដោយវាយោធាតុប៉ុណ្ណោះ ។ ឈ្មោះថា បុគ្គលណាម្នាក់ ដែលធ្វើនូវរន្ធេលចំបើង ហើយទ្រនូវពំនូតបាយដែលចូលទៅ មិនមាន ពំនូតបាយនោះ តាំងនៅបានដោយអំណាចវាយោ-ធាតុប៉ុណ្ណោះ បុគ្គលណា ឈ្មោះថា ធ្វើនូវចង្ក្រានដុតភ្លើងដាំបាយយ៉ាងនោះក៏មិនមាន តេជោធាតុនោះឯង រមែងញ៉ាំងអាហារនោះៗ ឲ្យឆ្អិន ។ ឈ្មោះថា បុគ្គលណាម្នាក់ នាំអាហារដែលឆ្អិនហើយ ចេញទៅខាងក្រៅដោយកំណាត់ឈើ ឬចុងឈើប្រត់ក៏មិនមាន វាយោធាតុនោះឯង រមែងនាំចេញទៅ ដោយប្រការដូច្នេះ ទើបពោលបានថា វាយោធាតុរមែងនាំអាហារនោះឲ្យចូលទៅខាងក្នុង រមែងឲ្យរំកិលទៅ រមែងទ្រអាហារនោះ រមែងប្របល់ រមែងធ្វើឲ្យបែកជាលម្អិត រមែងឲ្យស្ងួត និងរមែងឲ្យចេញទៅខាងក្រៅ ។ បឋវីធាតុរមែងទ្រនូវអាហារ រមែងប្របល់ រមែងធ្វើឲ្យបែកជាលម្អិត រមែងឲ្យស្ងួត

និងរមែងនាំចេញទៅខាងក្រៅ ។ អាបោធាតុ រមែងធ្វើអាហារឲ្យស្អិត ធ្វើឲ្យសើម រមែងរក្សាឲ្យស្រស់ ។ តេជោធាតុ រមែងឲ្យអាហារដែលចូលទៅខាងក្នុងឆ្អិន ។ អាកាសធាតុ រមែងជាផ្លូវនៃអាហារធ្លាក់ទៅ ។ វិញ្ញាណធាតុអាស្រ័យប្រកបសេចក្ដីព្យាយាមដោយប្រពៃ ក្នុងទីនោះៗ ហើយបរិភោគអាហារ ។

បណ្ឌិតគប្បីជ្រាបថា ជាអសម្មោហសម្បជញ្ញៈ ក្នុងការបរិភោគជាដើមនេះ ដោយអំណាចការពិចារណា ដែលប្រព្រឹត្តទៅហើយ ដោយអាការយ៉ាងនេះ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ក្នុងទីនេះ គប្បីជ្រាបថា ជាអសម្មោហសម្បជញ្ញៈ ដោយការពិចារណានូវភាពជារបស់បដិកូល ១០ យ៉ាង គឺដោយការដើរទៅ ១ ដោយការស្វែងរក ១ ដោយការបរិភោគ ១ ដោយទីអាស្រ័យ ១ ដោយការសន្សំ ១ ដោយភាពជារបស់មិនទាន់រលួយ ១ ដោយភាពជារបស់រលួយហើយ ១ ដោយភាពជាផល ១ ដោយការហូរចេញ ១ ដោយការប្រឡាក់ប្រឡូស ១ ។ ចំណែកពាក្យពិស្ដារដោយភាពជាបដិកូលនេះ បណ្ឌិតគប្បីសិក្សាក្នុងគម្ពីរវិសុទ្ធិមគ្គ ត្រង់និទ្ទេសនៃអាហារបដិកូលសញ្ញាឯណោះ ។

បទថា **ឧច្ចារបស្សាវកម្មេ** បានដល់ ក្នុងការបន្ទោបង់ឧច្ចារៈ និងបស្សាវៈ ។ ក្នុងទីនេះ កាលបុគ្គលណា មិនធ្វើនូវការបន្ទោបង់ឧច្ចារបស្សាវៈក្នុងពេលដែលគួរហើយ ញើសទាំងឡាយរមែងហូរចេញអំពីសរីរៈ ភ្នែកទាំងពីររមែងស្រវាំង ចិត្តមិនតាំងមាំ រោគផ្សេងៗ រមែងកើតឡើង ។ តែកាលធ្វើ

នូវការបន្ទោបង់តាមប្រក្រតីហើយ ហេតុទាំងពួងនោះ រមែងមិនកើតឡើង ដូច្នេះ នេះជាអធិប្បាយក្នុងការបន្ទោបង់ឧច្ចារបស្សាវៈ ។ គប្បីជ្រាបថា ជាសាត្ថកសម្បជញ្ញៈ ដោយអំណាចនៃការបន្ទោបង់ឧច្ចារបស្សាវៈនោះ ។ម្យ៉ាងទៀត កាលធ្វើនូវការបន្ទោបង់នូវឧច្ចារបស្សាវៈក្នុងទីដែលមិនគួរ រមែងត្រូវអាបត្តិ រមែងវិនាសបាកយស រមែងជាអន្តរាយចំពោះជីវិតក៏បាន ។ កាលធ្វើការបន្ទោបង់ក្នុងទីដែលគួរ ហេតុទាំងអស់នោះ រមែងមិនកើតឡើង ។ ព្រោះហេតុនោះ នេះឈ្មោះថា សប្បាយ ក្នុងពាក្យថា **ឧច្ចារបស្សាវកម្មេ** នេះ ។ គប្បីជ្រាបថា ជាសប្បាយសម្បជញ្ញៈ ដោយអំណាចនៃសប្បាយនោះ ។ គប្បីជ្រាបថា ជាគោចរសម្បជញ្ញៈ ដោយអំណាចនៃការមិនលះកម្មដ្ឋាននោះឯង ។

ឈ្មោះថា អត្តាណាមួយក្នុងខាងក្នុង ធ្វើនូវការបន្ទោបង់ឧច្ចារបស្សាវៈមិនមាន ។ ការបន្ទោបង់ឧច្ចារបស្សាវៈ រមែងមានដោយការផ្សាយទៅនៃវាយោធាតុ ជាការធ្វើរបស់ចិត្តនោះឯង ។ ឧបមាដូចបូសដែលទុំហើយ ព្រោះការបែកទៅនៃបូសនោះ ខ្ទុះ និងឈាមក៏ហូរចេញ ដោយមិនចាំបាច់បំណងឲ្យហូរ វាក៏ហូរចេញ យ៉ាងណា ឬដូចទឹក រមែងហូរចេញអំពីភាជនៈដែលបុគ្គលធ្វើឲ្យធ្លុះហើយ ទោះបីមិនបំណងឲ្យទឹកនោះចេញ យ៉ាងណា ឧច្ចារៈដែលសន្សំហើយក្នុងក្រពះ ឬបស្សាវៈដែលសន្សំហើយក្នុងតម្រងបស្សាវៈ ក៏យ៉ាងនោះ ត្រូវបៀតបៀនដោយកម្លាំងខ្យល់ ក៏រមែងចេញទៅទោះបីមិនបំណងឲ្យចេញ ។ ឧច្ចារបស្សាវៈដែលហូរចេញយ៉ាងនេះ មិនមែន

ជារបស់អត្តានៃភិក្ខុនោះ មិនមែនជារបស់អ្នកដទៃ ឧច្ចារបស្សាវៈនោះ ជារបស់បដិកូល ដែលហូរចេញអំពីសរីរៈប៉ុណ្ណោះ ប្រៀបដូចអ្វី ប្រៀបដូចបុគ្គលចាក់ទឹកចាស់ចេញអំពីក្អមទឹក ទឹកចាស់នោះ ក៏មិនមែនជារបស់ក្អមទឹកនោះផង មិនមែនជារបស់អ្នកដទៃផង ទឹកចាស់នោះ ត្រឹមតែជាការថែរក្សាប៉ុណ្ណោះ ។ ក្នុងសេចក្តីនេះ បណ្ឌិតគប្បីជ្រាបថា ជាអសម្មោហសម្បជញ្ញៈ ដោយអំណាចការពិចារណា ដែលប្រព្រឹត្តទៅហើយ ដោយអាការយ៉ាងនេះ ដោយប្រការដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **គតេ** ជាដើមដូចតទៅនេះ

បទថា **គតេ** បានដល់ ក្នុងការទៅ ។ បទថា **ឋិតេ** បានដល់ ក្នុងការឈរ ។ បទថា **និសិន្នេ** បានដល់ ក្នុងការអង្គុយ ។ បទថា **សុត្តេ** បានដល់ ក្នុងការដេក ។

ក្នុងការដើរជាដើមនោះ បណ្ឌិតគប្បីជ្រាបការធ្វើសម្បជញ្ញៈដោយន័យដែលពោលក្នុងការឈានទៅមុខជាដើមនោះឯង ។

ក្នុងបទថា **គតេ** ជាដើមនេះ មានន័យម្យ៉ាងទៀតដូចតទៅនេះ

សេចក្តីសន្និបថា ភិក្ខុមួយរូបដើរទៅ ក៏ដើរគិតរឿងដទៃ ត្រិះរិះរឿងដទៃ ភិក្ខុមួយរូបទៀត មិនលះបង់កម្មដ្ឋាន ដើរទៅដោយទំនងនោះ ភិក្ខុមួយរូប កាលឈរ អង្គុយ ដេក ក៏គិតរឿងដទៃ ត្រិះរិះរឿងដទៃ ។ ចំណែកភិក្ខុមួយរូបទៀត មិនលះបង់កម្មដ្ឋាន ក្នុងកាលដែលឈរផង អង្គុយផង ដេកផង ។

កម្មដ្ឋានរមែងមិនប្រាកដដោយហេតុ មានប្រមាណប៉ុណ្ណេះ ព្រោះហេតុនោះ ទើបបោរាណាចារ្យទាំងឡាយ សម្តែងដោយការចង្រ្កម ។ ពិតហើយ ភិក្ខុណា ឈានចុះកាន់ទីចង្រ្កម ភិក្ខុឈរក្នុងទីបំផុតនៃទីចង្រ្កម ក៏កំណត់កម្មដ្ឋាន ។ លោកកំណត់យ៉ាងនេះថា រូបធម៌ និងនាមធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងទីបំផុតនៃទីចង្រ្កមទិសខាងកើត មិនទាន់ដល់ខាងចុងទីចង្រ្កមទិសខាងលិច រលត់ទៅហើយក្នុងទីនោះឯង រូបធម៌ និងនាមធម៌ទាំងឡាយ ប្រព្រឹត្តទៅក្នុងទីបំផុតនៃទីចង្រ្កមទិសខាងលិច មិនទាន់ដល់ខាងចុងនៃទីចង្រ្កមទិសខាងកើត រលត់ទៅហើយក្នុងទីនោះឯង ។ រូបធម៌ និងនាមធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងកណ្តាលនៃទីចង្រ្កម មិនទាន់ដល់ទីបំផុតទាំងសងខាង រលត់ទៅហើយក្នុងទីនោះឯង ។ រូបធម៌ និងនាមធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងការដើរចង្រ្កម មិនទាន់ដល់ការឈរ រលត់ហើយក្នុងទីនោះឯង ។ រូបធម៌ និងនាមធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងការឈរ មិនទាន់ដល់ការអង្គុយ រលត់ទៅហើយក្នុងទីនោះឯង ។ រូបធម៌ និងនាមធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងការអង្គុយ មិនទាន់ដល់ការដេក រលត់ទៅហើយក្នុងទីនោះឯង រមែងញ៉ាំងចិត្តឲ្យធ្លាក់ចុះកាន់ភវង្គ ។ កាលក្រោកចេញទៅ ក៏កាន់យកកម្មដ្ឋាននោះឯង ហើយក្រោកចេញទៅ ។ ភិក្ខុនេះ ឈ្មោះថា ជាអ្នកដឹងច្បាស់ដោយប្រក្រតី ក្នុងបទថា ការដើរជាដើម ។

ចំណែកកម្មដ្ឋានក្នុងការដេកលក់ មិនជាក់ច្បាស់យ៉ាងនេះ ។ កម្មដ្ឋានដែលមិនជាក់ច្បាស់ ភិក្ខុមិនគួរធ្វើ ព្រោះហេតុនោះ ភិក្ខុណាអាចត្រឹមណា

ក៏ដើរ ឈរ អង្គុយហើយត្រឹមនោះ កាលដេក កំណត់យ៉ាងនេះហើយ សឹមដេក គឺលោកកំណត់យ៉ាងនេះថា កាយមិនមានចេតនា គ្រែក៏មិនមានចេតនា កាយមិនដឹងថា អញដេកលើគ្រែ គ្រែសោត ក៏មិនដឹងថា កាយដេកលើអញ កាយមិនមានចេតនា ដេកហើយលើគ្រែដែលមិនមានចេតនា រមែងញុំាងចិត្តឲ្យធ្លាក់ចុះកាន់ភវង្គ កាលភ្ញាក់ ក៏កាន់យកកម្មដ្ឋាននោះឯង រមែងភ្ញាក់ ។ ភិក្ខុនេះ ឈ្មោះថា ជាអ្នកដឹងច្បាស់ដោយប្រក្រតី ក្នុងការដេកដូច្នេះ ។

បទថា **ជាគរិតេ** បានដល់ ក្នុងការភ្ញាក់ ។ ក្នុងសេចក្តីនេះ កាលមិនមានចិត្តដែលប្រព្រឹត្តទៅឲ្យសម្រេចការធ្វើ ឈ្មោះថា ការភ្ញាក់មិនទាន់មាន ភិក្ខុកាលកំណត់ថា កាលមានការប្រើចិត្តដែលប្រព្រឹត្តទៅឲ្យសម្រេចការធ្វើ ឈ្មោះថា ការភ្ញាក់រមែងមាន ឈ្មោះថា ជាអ្នកដឹងច្បាស់ដោយប្រក្រតី ក្នុងការភ្ញាក់ ។ ម្យ៉ាងទៀត ភិក្ខុចែកពេលយប់ និងពេលថ្ងៃជា ៦ ផ្នែក ភ្ញាក់រឭក ៥ ផ្នែក ឈ្មោះថា ជាអ្នកដឹងច្បាស់ដោយប្រក្រតី ក្នុងការភ្ញាក់ ។

បទថា **ភាសិតេ** បានដល់ ក្នុងការនិយាយ ។ ក្នុងសេចក្តីនេះ កាលសទ្ទាយតនៈ ដែលជាឧបាទាយរូបមិនប្រព្រឹត្តទៅ ឈ្មោះថា ការនិយាយមិនមាន ។ ភិក្ខុកំណត់ថា កាលសទ្ទាយតនៈប្រព្រឹត្តទៅ ការនិយាយរមែងមាន ឈ្មោះថា ជាអ្នកដឹងច្បាស់ដោយប្រក្រតី ក្នុងការនិយាយ ។ ភិក្ខុសម្តែងធម៌ដោយវិមុត្តាយតនសីសៈក្តី លះនូវតិរច្ឆានកថា ៣២ ហើយពោលកថាដែលអាស្រ័យកថាវត្ថុ ១០ ក្តី ជាអ្នកដឹងច្បាស់ដោយប្រក្រតី ក្នុងការ

និយាយ ។

បទថា **តុណ្ហីភាវេ** បានដល់ ក្នុងការមិននិយាយ ។ ក្នុងសេចក្តីនេះ កាលសទ្ទាយតនៈដែលជាឧបាទាយរូបប្រព្រឹត្តទៅ ឈ្មោះថា ការស្ងៀមមិនមាន ។ ភិក្ខុកំណត់ថា កាលសទ្ទាយតនៈមិនប្រព្រឹត្តទៅ ការស្ងៀមរមែងមិនមាន ឈ្មោះថា ជាអ្នកដឹងច្បាស់ដោយប្រក្រតី ក្នុងការស្ងៀម ។ បណ្តាអារម្មណកម្មដ្ឋាន ៣៨ ប្រការនោះ ( វៀរអាកាស និងអលោកកសិណ ) ភិក្ខុកាន់យកកម្មដ្ឋានតាមការពេញចិត្ត អង្គុយក្តី ចូលទុតិយជ្ឈានក្តី ឈ្មោះថា ជាអ្នកដឹងច្បាស់ដោយប្រក្រតី ក្នុងការអង្គុយនោះឯង ។

ម្យ៉ាងទៀត ក្នុងនិទ្ទេសនៃឈានវិភង្គនេះ ឥរិយាបថមួយមកក្នុងទីពីរកន្លែង គឺឥរិយាបថនោះ បណ្ឌិតគប្បីជ្រាបថា ក្នុងបទថា **អភិក្កន្តេ បដិក្កន្តេ** ខាងដើមនេះ ព្រះមានព្រះភាគ ត្រាស់ដោយអំណាចការដើរផ្លូវឆ្ងាយរបស់ភិក្ខុដែលដើរទៅកាន់ស្រុក ដើម្បីបិណ្ឌបាត និងដើរត្រឡប់មក ក្នុងបទថា **គតេ ឋិតេ និសិន្នេ** នេះ ទ្រង់ត្រាស់ដោយអំណាចឥរិយាបថ គឺការឈានជើងទៅបន្តិចបន្តួចក្នុងវិហារ ( វត្ត ) ។

បទទាំងអស់ មានបទថា **តត្ថ កតមា សតិ** មានអត្ថងាយយល់ហើយ ។ សួរថា ព្រះមានព្រះភាគទ្រង់សម្តែងប្រយោជន៍អ្វី ដោយបទថា **សោ វិវិត្តំ** ឆ្លើយថា សម្តែងសេនាសនៈដែលជាសប្បាយ ដែលជាវិថិនៃការប្រកបសេចក្តីព្យាយាម ដែលជាទីចូលទៅអង្គុយរបស់ភិក្ខុនោះ ។

ពិតហើយ គុណទាំងឡាយមានប្រមាណប៉ុណ្ណោះ របស់ភិក្ខុណា មាន

ខាងក្នុង ភិក្ខុនោះ សមគួរនៅព្រៃ តែបើគុណទាំងនោះ មិនមានដល់ភិក្ខុណា ភិក្ខុនោះ មិនគួរនៅព្រៃឡើយ ។ ការនៅព្រៃរបស់ភិក្ខុបែបនេះ រមែងដូចគ្នានឹងការនៅក្នុងព្រៃរបស់សត្វសាហាវទាំងឡាយ មានស្វាខ្មៅ ខ្លាឃ្មុំ ខ្លារខិន ខ្លាដំបងជាដើម ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះភិក្ខុនោះ តាំងនៅក្នុងសេចក្តីប្រាថ្នាហើយ ទើបចូលទៅ ដ្បិតថា ប្រយោជន៍ណាមួយដែលមានការនៅព្រៃជាហេតុ រមែងមិនមានដល់ភិក្ខុនោះ ភិក្ខុនោះ ប្រទូស្តអ្នកនៅព្រៃផង ប្រទូស្តព្រៃផង មិនញ៉ាំងសេចក្តីជ្រះថ្លាឲ្យកើតឡើងដល់ព្រះពុទ្ធសាសនា ។ ចំណែកភិក្ខុណា មានគុណមានប្រមាណប៉ុណ្ណេះក្នុងខាងក្នុង ភិក្ខុនោះ រមែងសមគួរនៅព្រៃ ព្រោះថា ភិក្ខុនោះ អាស្រ័យការនៅព្រៃ ផ្តើមវិបស្សនាហើយ កាន់យកអរហត្ត បរិនិព្វាន ឈ្មោះថា រមែងធ្វើព្រៃទាំងមូលឲ្យស្អាត ធ្វើសីសៈនៃព្រៃ ( ការគិតរបស់អ្នកនៅព្រៃ ) ទាំងឡាយឲ្យស្អាត ធ្វើពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រីទាំងមូល ឲ្យផ្សាយចេញទៅ ព្រោះហេតុនោះ ព្រះសាស្តា កាលទ្រង់សម្តែងនូវសេនាសនៈដែលជាសប្បាយ ដែលជាវិថីនៃសេចក្តីព្យាយាម ដែលជាទីចូលទៅអន្ទយរបស់ភិក្ខុបែបនេះ ទើបត្រាស់ពាក្យជាដើមថា **សោ វិវិត្តំ សេនាសនំ ភជតិ** ប្រែថា ភិក្ខុនោះ គប់រកសេនាសនៈដ៏ស្ងាត់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិវិត្តំ** បានដល់ ជាសេនាសនៈស្ងាត់ មានសំឡេងតិច គឺមានសំឡេងអ៊ូអរតិច ដើម្បីសម្តែងសេចក្តីនោះ ព្រះសាស្តាទ្រង់ត្រាស់ថា **តញ្ច អនាកិណ្ណំ** តែសេនាសនៈនោះមិនច្របូកច្របល់ជាដើម ។

បណ្តាបទទាំងនោះ បទថា **អនាភិណ្ណំ** បានដល់ មិនប្រឡូកប្រឡំ គឺមិនត្រូវបៀតបៀន ។ ក្នុងទីនេះ ការអាស្រ័យភូមិ អាស្រ័យព្រៃ អាស្រ័យស្ទឹងដោយជុំវិញប្រមាណ ១ គាវុតក្តី កន្លះយោជន៍ក្តី នៃសេនាសនៈណា បុគ្គលណាម្នាក់មិនអាចចូលទៅក្នុងវេលាដែលមិនសមគួរ សេនាសនៈនេះ ឈ្មោះថា មិនប្រឡូកប្រឡំសូម្បីក្នុងទីជិត ។ សេនាសនៈណាឆ្ងាយ មានប្រមាណកន្លះយោជន៍ ឬប្រមាណមួយយោជន៍ សេនាសនៈនេះ ឈ្មោះថា មិនប្រឡូកប្រឡំក្នុងទីឆ្ងាយ ។

ភិក្ខុរមែងដេក និងអង្គុយក្នុងទីនេះ ព្រោះហេតុនោះ ទើបទីនេះ ឈ្មោះថា សេនាសនៈរបស់ភិក្ខុ ។ ដើម្បីសម្តែងប្រភេទនៃសេនាសនៈនោះ ទើបព្រះមានព្រះភាគត្រាស់ថា **មញ្ចោ** គ្រែ **បីឋំ** តាំងជាដើម ។

បណ្តាបទទាំងនោះ បទថា **មញ្ចោ** បានដល់ គ្រែ ៤ យ៉ាង គឺគ្រែដែលគេបញ្ចូលមេទៅក្នុងជំណាប់ជើង ១ គ្រែដែលមានមេជាប់នឹងជើង ១ គ្រែដែលមានជើងដូចជាជើងក្តាម ១ គ្រែដែលមានជើងចុច ឬគ្រែដែលគេបញ្ចូលជើងទៅក្នុងជំណាប់មេ ១ ។ តាំងក៏ដូចគ្នា ។

បទថា **ភិសី** បានដល់ ពូក ៥ យ៉ាង គឺពូកដែលគេញាត់ដោយរោមសត្វ ១ ពូកដែលគេញាត់សម្បកឈើ ១ ពូកដែលគេញាត់កំណាត់សំពត់ ១ ពូកដែលគេញាត់ស្មៅ ១ ពូកដែលគេញាត់ស្លឹកឈើ ១ ។

ខ្នើយកើយក្បាល ព្រះមានព្រះភាគត្រាស់ថា **ពិម្ពោហនំ** ។ ខ្នើយនោះពោលដោយចំណែកទទឹង មានប្រមាណ ១ ចំអាម ៤ ធ្នាប់ សមគួរ ។

ចំណែកបណ្តាយ ប្រមាណសមគួរដល់ទទឹងរបស់គ្រែ ។ បទថា **វិហារោ** បានដល់ សេនាសនៈដែលលោកសម្តែង គឺសេនាសនៈដែលជាទីសម្រាកក្នុងពេលថ្ងៃ និងទីសម្រាកក្នុងពេលយប់ ក្នុងខាងក្នុងនោះឯង ធ្វើឲ្យជាផ្លូវបរិហារដោយជុំវិញ ។ បទថា **អឌ្ឍយោគោ** បានដល់ ផ្ទះដែលមានដំបូលកោងដូចស្លាបគ្រុឌ ។ បទថា **បាសាទោ** បានដល់ ប្រាសាទវែង ដែលគេធ្វើមានកំពូលពីរ ឬមានហោជាងពីរ ។ បទថា **អដ្ដោ** បានដល់ ទីសម្រាកពិសេស មាន ៤-៥ ជាន់ មានជញ្ជាំងកដោយឥដ្ឋ ដើម្បីការពារសត្រូវមានព្រះរាជា ដែលជាសត្រូវនឹងគ្នាជាដើម ។ បទថា **មាឡោ** បានដល់ រោងមូល ដូចគ្នានឹងរោងឆាន់អាហារ ។ ក្នុងអដ្ឋកថាព្រះវិន័យ លោកពោលថា ជាប្រាសាទដែលមានមុខ ៤ សង្គ្រោះចូលក្នុងប្រាសាទដែលមានកំពូល ១ ។ បទថា **លេណំ** បានដល់ សេនាសនៈដែលគេជីកភ្នំធ្វើ ឬសេនាសនៈដែលគេកជញ្ជាំងឡើងធ្វើក្នុងទីដែលគ្រប់គ្រាន់ ដែលជាញកភ្នំ ។ បទថា **គុហា** បានដល់ ស្នាមប្រេះនៃផែនដី ដែលសមគួរអុជប្រទីបទាំងពេលយប់និងពេលថ្ងៃ ឬគុហានៃភ្នំ ឬគុហានៃផែនដី ។ បទថា **រុក្ខមូលំ** បានដល់ ដែលគេព័ទ្ធ ឬមិនបានព័ទ្ធខាងក្រោមដើមឈើ ។ បទថា **វេឡុគុម្ពោ** បានដល់ គុម្ពឫស្សី ។ បទថា **យត្ថ វា បន ភិក្ខូ បដិក្កមន្តិ** បានដល់ វៀរគ្រែជាដើមទាំងនោះចេញ ក្នុងទីណា ពួកភិក្ខុប្រជុំគ្នា ឬទីណា ជាទីគួរប្រជុំរបស់ភិក្ខុទាំងនោះ ទីទាំងអស់នោះ ក៏ចាត់ជាសេនាសនៈ ។

បទថា **ភជតិ** បានដល់ ចូលដល់ ។ ក្នុងបទថា **សម្ភជតិ** នោះ បាន

ដល់ ជាបុគ្គលមិនក្តៅក្រហាយ ដោយអំណាចនៃការត្រេកអរក្រៃលែង ក្នុងសេនាសនៈនោះ ទើបឈ្មោះថា ចូលដល់ដោយល្អ ។ បទថា **សេវតិ** បានដល់ រមែងសេពដោយអំណាចនៃការនៅអាស្រ័យ ។ បទថា **និសេវតិ** បានដល់ មិនជាបុគ្គលក្តៅក្រហាយ ចូលអាស្រ័យហើយសេព ។ បទថា **សំសេវតិ** បានដល់ កាលញ៉ាំងសេនាសនវត្តឲ្យដល់ព្រម សេពដោយប្រពៃ ។

ឥឡូវនេះ ដើម្បីសម្តែងប្រភេទនៃបទថា **វិវិត្តំ** នោះ ទើបព្រះមានព្រះភាគត្រាស់បទថា **អរញ្ញំ រុក្ខមូលំ** ជាដើម ។ ក្នុងបទថា **អរញ្ញំ** ពាក្យថា **អរញ្ញំ** មកហើយដោយបរិយាយរបស់ព្រះវិន័យមុនថា ទីដ៏សេស វៀរស្រុក និងឧបចារស្រុក ហៅថា ព្រៃ ។ មកហើយ ដោយបរិយាយនៃព្រះសូត្រ សំដៅដល់ភិក្ខុដែលនៅព្រៃថា សេនាសនៈ ឈ្មោះថា នៅក្នុងព្រៃ គឺសេនាសនៈតាំងនៅក្នុងទីផុត ៥០០ ជួរធ្នូ ។ ព្រះវិន័យ និងព្រះសូត្រទាំងពីរ ឈ្មោះថា បរិយាយទេសនា ។ ចំណែកព្រះអភិធម្ម ឈ្មោះថា និប្បរិយាយទេសនា គឺទេសនាដោយត្រង់ ។ ដើម្បីសម្តែងព្រៃ ដោយបរិយាយនៃព្រះអភិធម្ម ទើបព្រះមានព្រះភាគត្រាស់ថា **និក្ខមិត្វា ពហិ ឥន្ទខីលា** ដូច្នេះ អធិប្បាយថា ចេញទៅខាងក្រៅអំពីសសរខឿន ។

ព្រះមានព្រះភាគត្រាស់ថា **រុក្ខមូលំយេវ រុក្ខមូលំ** ជាដើម ព្រោះរុក្ខមូលជាដើម យល់បានងាយដោយប្រក្រតី ។ ម្យ៉ាងទៀត ក្នុងសេចក្តីនេះ ពាក្យថា **រុក្ខមូល** បានដល់ គល់ឈើដែលស្ងាត់ មានម្លប់ត្រាស់ឯណានីមួយ បទថា **បព្វតំ** បានដល់ ភ្នំថ្ម ។ ពិតហើយ ក្នុងសេចក្តីនេះ កាលភិក្ខុធ្វើកិច្ច

ដោយទឹកក្នុងស្រះ ឬត្រពាំងដែលមានផ្កាសម្រេចហើយ អន្ទុយសម្រាកត្រង់ម្លប់ឈើដ៏ត្រជាក់ កាលទិដ្ឋភាពកំពុងប្រាកដ ត្រូវខ្យល់ត្រជាក់បក់មក ចិត្តរមែងស្ងប់ ។ វិនិច្ឆ័យក្នុងបទថា **កន្ទរំ** ដូចតទៅ ទឹក ព្រះមានព្រះភាគត្រាស់ហៅថា **កំ** ។ សួរថា ប្រទេសនៃភ្នំដែលញែកចេញទៅដោយទឹកហៅថា អ្វី ឆ្លើយថា ហៅថា ជ្រោះ ។ អាចារ្យពួកខ្លះពោលថា ទីនោះ ជាទីជម្រាលខ្លះ ជាចន្លុះខ្លះ ។ ពិតហើយ ក្នុងទីនោះ មានគ្រាប់ខ្សាច់ពណ៌ដូចប្រាក់ ជនព្រៃនោះ ដូចគ្នានឹងវត្ថុដែលគ្របដណ្តប់ដោយកែវមណី ខាងលើទឹកដូចគ្នានឹងគំនរកែវមណីហូរចេញមក ។ កាលភិក្ខុឈានចុះកាន់ស្នាមបែកបែបនេះ ផឹកទឹកដែលគួរផឹក ធ្វើខ្លួនឲ្យត្រជាក់ សប្បាយ ធ្វើគំនរខ្សាច់ឲ្យខ្ពស់ក្រាលសំពត់បង្សុកូលចីវរ ហើយអង្គុយធ្វើសមណធម៌ ចិត្តរបស់លោករមែងស្ងប់ ។ បទថា **គិរិគុហំ** បានដល់ គុហាក្នុងរវាងភ្នំទាំងពីរ ឬក្នុងភ្នំមួយមានល្អាងធំ ដូចគ្នានឹងឧមង្គ ។ លក្ខណៈនៃស្មសាន ខ្ញុំពោលហើយក្នុងបករណ៍ ឈ្មោះវិសុទ្ធិមគ្គ ។

បទថា **វនបត្ថំ** បានដល់ ទីក្រៅអំពីស្រុក មិនមែនជាទីជិតរបស់ពួកមនុស្ស គឺក្នុងទីដែលមិនមានការភ្ជួរ មិនមានការសាបព្រោះ ។ ដោយហេតុនោះឯង ក្នុងនិទ្ទេសនៃសេនាសនៈស្ងាត់នេះ ទើបព្រះមានព្រះភាគត្រាស់ថា ព្រៃញៀតស្បាតជាដើម ។ ម្យ៉ាងទៀត ព្រោះសេនាសនៈ មានគល់ឈើជាដើម ទ្រង់ចែកសម្តែងព្រៃនេះប្រភេទតែមួយប៉ុណ្ណោះ ហេតុនោះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់មិនបានអធិប្បាយព្រៃនោះតាមលំដាប់នៃ

*ពាក្យដែលទ្រង់តាំង តែទ្រង់អធិប្បាយខាងក្រោយនៃពាក្យទាំងពួង ។*

*បទថា* **អព្ភោកាសំ** *បានដល់ ទីដែលមិនមានអ្វីបិទបាំង ។ ភិក្ខុបំណង ក្នុងទីបែបនេះ ត្រូវធ្វើឲ្យជាបង្អា គឺបាំងដោយចីវរហើយនៅក្នុងទីបែបនេះ ។ បទថា* **បលាលបុញ្ជំ** *បានដល់ ពំនូកចំបើង ។ ពិតហើយ ភិក្ខុទាញចំបើង ចេញអំពីពំនូកចំបើងធំ ហើយធ្វើឲ្យជាលំនៅ ដូចគ្នានឹងញកក្នំ និងគុហា ។ ទោះបីភិក្ខុយកចំបើងដាក់លើគុម្ពឈើជាដើម ហើយអង្គុយខាងក្រោម ធ្វើ សមណធម៌ក៏បាន ។ ពាក្យនេះ លោកសំដៅយកសេនាសនៈ គឺពំនូកចំបើង នោះឯង ។*

*ក្នុងនិទ្ទេសពោលដោយព្រៃញៀតស្បាត បទថា* **សលោមហំសានំ** *បានដល់ សេនាសនៈដែលគួរភ័យខ្លាចបែបនេះ កាលចូលទៅហើយ ការ ព្រឺរោមក៏កើតឡើង ។*

*បទថា* **បរិយន្តានំ** *បានដល់ ឈ្មោះថា សេនាសនៈដែលតាំងនៅចុង ដែន ព្រោះជាសេនាសនៈឆ្ងាយ ។ បទថា* **ន មនុស្សូបចារានំ** *បានដល់ សេនាសនៈដែលតាំងនៅហួសជាយព្រៃដែលពួកមនុស្ស គប្បីចូលទៅធ្វើ ការភ្ជួរ និងការសាបព្រោះ ( ទីដែលហួសតំបន់ដែលមនុស្សសាបព្រោះ ) ។ បទថា* **ទុរភិសម្ភវានំ** *បានដល់ សេនាសនៈដែលបុគ្គលមិនបាននូវសេចក្តី ត្រេកអរក្នុងវិវេក មិនអាចសង្កត់ចិត្តនៅអាស្រ័យបាន ។*

*គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេស នៃទីមិនមានសំឡេងបៀតបៀនជាដើម ដូចតទៅនេះ បទថា* **អប្បសទ្ទំ** *បានដល់ មានសំឡេងតិច ដោយសំឡេង*

និយាយ ។

បទថា **អប្បនិគ្ឃោសំ** បានដល់ មានសំឡេងកងរំពងតិច ដោយសំឡេងអ៊ូអររបស់អ្នកនគរ ។ ព្រោះសព្ទទាំងពីរនេះដូចគ្នាជាយអត្ថ ហេតុនោះ ទើបក្នុងនិទ្ទេសនៃ **អបនិគ្ឃោសំ** នេះ ព្រះមានព្រះភាគត្រាស់ថា ទីណា មិនមានសំឡេង ទីនោះ ឈ្មោះថា ទីមិនគឹកកង ដូច្នេះ ។

បទថា **វិជនវាតំ** បានដល់ វៀរចាកខ្យល់នៃសរីរៈរបស់ជនដែលសញ្ចរមកខាងក្រោយ ។ ព្រះបាលីថា **វិជនវាទំ** ដូច្នេះក៏មាន ។ អធិប្បាយថា វៀរហើយចាកការពោលរបស់ជនដែលនៅខាងក្នុង ព្រោះសេនាសនៈណា មានសំឡេងអ៊ូអរតិច សេនាសនៈនោះឯង រមែងវៀរហើយចាកការសញ្ចររបស់មនុស្ស និងចាកវាទៈរបស់មនុស្ស ហេតុនោះ ទើបក្នុងនិទ្ទេសនៃព្រះបាលីនេះ ព្រះមានព្រះភាគត្រាស់ថា ទីណា មិនគឹកកង ទីនោះឈ្មោះថា ទីប្រាសចាកខ្យល់ដែលកើតអំពីសរីរៈនៃជន ដូច្នេះ ។

បទថា **មនុស្សរាហាសេយ្យកំ** បានដល់ ជាទីតាំងនៃការធ្វើនូវកាពកំបាំងរបស់ពួកមនុស្ស ។ ព្រោះសេនាសនៈនោះ វៀរចាកការសញ្ចររបស់ជន ដោយហេតុនោះ ទើបក្នុងនិទ្ទេសនៃព្រះបាលីនេះ ព្រះមានព្រះភាគត្រាស់ថា ទីណា ដែលប្រាសចាកខ្យល់កើតអំពីសរីរៈនៃជន ទីនោះ ឈ្មោះថា ទីស្ងាត់កំបាំងរបស់មនុស្ស ដូច្នេះ ។

បទថា **បដិសល្លានសារុប្បំ** បានដល់ ជាសេនាសនៈសមគួរដល់វិវេក ។ ព្រោះសេនាសនៈនោះ ជាទីអាស្រ័យ ធ្វើនូវការកំបាំងរបស់ពួក

*មនុស្សដោយពិតប្រាកដនោះឯងមាន ព្រោះហេតុនោះ ទើបក្នុងនិទ្ទេសនៃព្រះបាលីនេះ ព្រះមានព្រះភាគត្រាស់ថា ទីណា ដែលស្ងាត់កំបាំងរបស់មនុស្ស ទីនោះ ឈ្មោះថា ទីសមគួរដល់ការពួនសម្ងំ ដូច្នេះ ។*

*សេនាសនៈ គឺព្រៃ លោកពោលហើយក្នុងនិទ្ទេសនៃពាក្យថា* **អរញ្ញគតា** *ជាដើមនោះឯង ។ សេនាសនៈ គឺគល់ឈើក៏ដូចគ្នា ។ ចំណែកសេនាសនៈទាំងអស់ដ៏សេស សង្គ្រោះដោយសុញ្ញាគារ ។*

*បទថា* **បល្លង្កំ អាភុជិត្វា** *បានដល់ ការអង្គុយពត់ភ្នែនដោយជុំវិញ ។ បទថា* **ឧជុំ កាយំ បណិធាយ** *បានដល់ តាំងសរីរៈកំណាត់ខាងលើឲ្យត្រង់ គឺញ៉ាំងឆ្អឹងទ្រនង់ខ្នងទាំង ១៨ ឲ្យចុងទល់គ្នា ។ ពិតហើយ កាលភិក្ខុនោះអង្គុយយ៉ាងនេះ ស្បែក សាច់ និងសរសៃទាំងឡាយ មិនវៀច ។ ពេលនោះ វេទនាដែលគប្បីកើតឡើងគ្រប់ៗ ខណៈ ព្រោះការបង្អោនទៅនៃអវយវៈទាំងនោះ រមែងមិនកើតឡើងដល់ភិក្ខុនោះ ។ កាលទុក្ខវេទនាទាំងនោះមិនកើតឡើង ចិត្តរបស់ភិក្ខុនោះ រមែងជាធម្មជាតស្ងប់ កម្មដ្ឋានមិនធ្លាក់ទៅ រមែងដល់នូវការចម្រើន ។ សូម្បីបទថា* **ឧជុកោ ហោតិ កាយោ ឋិតោ បណិហិតោ** *នេះ ព្រះមានព្រះភាគ ក៏ត្រាស់សំដៅយកសេចក្ដីនេះដូចគ្នា ។*

*បទថា* **បរិមុខំ សតឹ ឧបដ្ឋបេត្វា** *បានដល់ តម្កល់សតិឲ្យមានមុខឆ្ពោះទៅកាន់កម្មដ្ឋាន ។ម្យ៉ាងទៀត អធិប្បាយថា ធ្វើសតិក្នុងទីជិតមាត់ ។ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា សតិនេះ ដែលបុគ្គលតម្កល់ហើយ តាំងល្អហើយ ត្រង់ទីបំផុតនៃច្រមុះក្ដី ត្រង់និមិត្តនៃមាត់ក្ដី ។ ក្នុង*

បទថា **មុខនិមិត្តំ** នេះ បណ្ឌិតគប្បីឃើញនូវប្រទេស ត្រង់កណ្តាលនៃបបូរមាត់ខាងលើ គឺទីដែលខ្យល់ច្រមុះរមែងប៉ះ ។ ម្យ៉ាងទៀត សព្ទថា **បរិ** មានការកំណត់ជាអត្ថ ។ បទថា **មុខំ** មានការនាំចេញទៅជាអត្ថ ។ បទថា **សតិ** មានការតាំងមាំជាអត្ថ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **បរិមុខំ សតឹ** ដូច្នេះ ។ បណ្ឌិតគប្បីជ្រាបអត្ថយ៉ាងនេះក្នុងសេចក្តីនេះ ដោយន័យដែលពោលហើយ ក្នុងបដិសម្ភិទាមគ្គនោះឯង ។ ក្នុងសេចក្តីនេះ មានសេចក្តីសង្ខេប ដូច្នេះថា ធ្វើសតិទៅកាន់អារម្មណ៍ដែលកំណត់ហើយ ។

អភិជ្ឈានិទ្ទេស មានអត្ថងាយយល់ហើយ ។

គប្បីជ្រាបកិច្ចពណ៌នាដោយសង្ខេប ក្នុងអភិជ្ឈានិទ្ទេសដូចតទៅនេះ បទថា **អភិជ្ឈំ លោកេ បហាយ** បានដល់ ឧបាទានក្ខន្ធ ៥ ឈ្មោះថា លោក ព្រោះអត្ថថា វិនាស និងបែកធ្លាយ ព្រោះហេតុនោះ ក្នុងសេចក្តីនេះ គប្បីជ្រាបអត្ថដូចតទៅនេះ លោកលះរាគៈ ក្នុងឧបាទានក្ខន្ធ ៥ ហើយ សង្កត់សង្កិនកាមច្ឆន្ទៈ ។

បទថា **វិគតាភិជ្ឈេន** បានដល់ ឈ្មោះថា កាលអភិជ្ឈាទៅប្រាសហើយ ព្រោះលះបានហើយដោយអំណាចនៃវិក្ខម្ភនប្បហាន អធិប្បាយថា ដូចគ្នាដោយចក្ខុវិញ្ញាណក៏មិនមែន ។

បទថា **អភិជ្ឈាយ ចិត្តំ បរិសោធេតិ** បានដល់ រមែងជម្រះចិត្តចាកអភិជ្ឈា អធិប្បាយថា អភិជ្ឈានោះ រមែងបណ្តោយនូវចិត្តនោះ កាលបណ្តោយហើយ រមែងមិនកាន់យកនូវចិត្តនោះទៀត ដោយប្រការណា ភិក្ខុនោះ រមែង

*ធ្វើដោយប្រការនោះ ។ ក្នុងបទនិទ្ទេសទាំងឡាយ គប្បីជ្រាបអត្ថនៃពាក្យថា ឲ្យស្អាតចាកអភិជ្ឈានោះ យ៉ាងនេះថា កាលសេពឈ្មោះថា* **សោធេតិ** *( ឲ្យស្អាត ) ការបម្រើន ឈ្មោះថា* **វិសោធេតិ** *ការធ្វើឲ្យច្រើន ឈ្មោះថា* **បរិសោធេតិ** *ក្នុងបទថា* **មោចេតិ** *ជាដើម ក៏មានន័យដូចគ្នា ។ បណ្ឌិតគប្បីជ្រាបអត្ថដោយន័យនេះឯង សូម្បីបទទាំងឡាយ មានបទថា* **ព្យាបាទ-បទោសំ បហាយ** *ជាដើម ។ ចិត្ត រមែងព្យាបាទដោយធម្មជាតនេះ គឺរមែងលះប្រក្រតី ដូចគ្នានឹងនំកុម្មាសផ្អូមជាដើម ព្រោះហេតុនោះ ទើបធម្មជាតនេះ ឈ្មោះថា* **ព្យាបាទ** ។

*ចិត្តណា រមែងទម្លាយ ឬធ្វើឲ្យវិនាស ឬរមែងវិនាសទៅ ព្រោះដល់នូវការប្រែប្រួល ព្រោះហេតុនោះ ទើបចិត្តនោះ ឈ្មោះថា* **បទោសោ** ។

*ពាក្យទាំងពីរនេះ ជាឈ្មោះនៃសេចក្តីក្រោធដោយពិត ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា* **យោ ព្យាបាទោ សោ បទោសោ យោ បទោសោ សោ ព្យាបាទោ** *ប្រែថា សេចក្តីព្យាបាទ គឺសេចក្តីប្រទូស្ត សេចក្តីប្រទូស្ត គឺសេចក្តីព្យាបាទ ។ ព្រោះសព្វនេះ ទ្រង់លើកឡើងសម្តែងហើយដោយអំណាចនៃការសង្គ្រោះវត្ថុទាំងពួង ព្រោះហេតុនោះ ទើបទ្រង់មិនត្រាស់ថា មានសេចក្តីអនុគ្រោះនូវប្រយោជន៍ដល់សត្វមានជីវិតទាំងអស់ តែត្រាស់ថា មានចិត្តមិនព្យាបាទត្រឹមតែប៉ុណ្ណោះ ។*

*អាពាធនៃចិត្ត ឈ្មោះថា* **ថីន** *អាពាធនៃចេតសិក ឈ្មោះថា* **មិទ្ធ** ។ *ថីនៈផង មិទ្ធៈផង ហៅថា* **ថីនមិទ្ធ** ។

បទថា **សន្តា ហោន្តិ** បានដល់ ធម៌ទាំងពីរ គឺថីនមិទ្ធៈនេះ ឈ្មោះថា ស្ងប់ហើយ ព្រោះស្ងប់ហើយដោយនិរោធ ។ ក្នុងទីនេះ លោកធ្វើការចែកពាក្យដោយសំដៅយកថីនមិទ្ធៈនេះ ។

បទថា **អាលោកសញ្ញី** បានដល់ ដែលប្រកបដោយសញ្ញាបរិសុទ្ធ ដែលមាននីវរណៈទៅប្រាសហើយ ដើម្បីចាំនូវពន្លឺដែលខ្លួនឃើញហើយ ក្នុងរាត្រីខ្លះ ក្នុងពេលថ្ងៃខ្លះ ។ បទថា **សតោ សម្បជានោ** បានដល់ បុគ្គលដែលប្រកបដោយសតិ និងញាណ ពាក្យទាំងពីរនេះ ព្រះមានព្រះភាគត្រាស់ព្រោះជាឧបការៈដល់អាលោកសញ្ញា ។ ក្នុងកាលជាអ្នកប្រាសចាកថីនមិទ្ធៈ បទថា **ចត្តត្តា** ជាដើម ជាវេវចនៈនៃគ្នានិងគ្នា ក្នុងនិទ្ទេសបទនៃអាលោក-សញ្ញា ។

បណ្តាបទទាំងនោះ បទថា **ចត្តត្តា** បានដល់ ព្រោះជាហេតុដែលភិក្ខុនោះលះបង់ហើយ ។ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ ម្យ៉ាងទៀត ក្នុងបទទាំងនេះថា សូម្បីបទថា **ចត្តត្តា** នេះ ព្រះមានព្រះភាគ ត្រាស់ដោយអំណាចនៃការលះដោយសភាវៈរបស់ខ្លួន ។ បទថា **វន្តត្តា** នេះត្រាស់ដោយអំណាចនៃការសម្តែងភាពមិនប្រកាន់ ។ បទថា **មុត្តត្តា** នេះត្រាស់ដោយអំណាចនៃការរួចផុតចាកការបន្ត ។ បទថា **បហីនត្តា** នេះត្រាស់ដោយអំណាចភាពមិនមានទីតាំងក្នុងទីណាមួយ របស់បុគ្គលអ្នករួចផុតហើយ ។ បទថា **បដិនិស្សដ្ឋត្តា** នេះ ត្រាស់ដោយអំណាចការសម្តែងការលះបង់នូវថីនមិទ្ធៈ ដែលប្រកាន់មកក្នុងកាលមុន ។ ម្យ៉ាងទៀត អធិប្បាយ

ថា ព្រោះលះបង់ហើយដោយការរួចផុត គឺព្រោះគ្រប់សង្កត់ លះបង់ដោយអំណាចនៃភាវនា ។ បទថា **បហីនបដិនិស្សដ្ឋត្តា** បានដល់ ការលះបង់ហើយ ដោយប្រការដែលលះបានដោយអំណាចនៃការសង្កត់សង្កិន គឺរមែងមិនឲ្យការបន្តកើតឡើងរឿយៗ ។ បទថា **អាលោកា ហោតិ** បានដល់ មានរស្មី ។ ឈ្មោះថា **វិវដា** ព្រោះអត្ថថា មិនមានគ្រឿងរាំង ។ ឈ្មោះថា **បរិសុទ្ធា** ព្រោះអត្ថថា មិនមានឧបក្កិលេស ។ ឈ្មោះថា **បរិយោទាតា** ព្រោះអត្ថថា ភ្លឺត្រចះត្រចង់ ។

ក្នុងបទថា **ឧទ្ធច្ចកុក្កុច្ចំ** នេះ អាការដែលមិនស្ងប់ ឈ្មោះថា **ឧទ្ធច្ច** ការប្រព្រឹត្តខុសព្រោះវត្ថុ ព្រោះមិនពិនិត្យពិចារណាក្នុងអារម្មណ៍ ឈ្មោះថា **កុក្កុច្ច** ។ ក្នុងបទថា **ឧទ្ធច្ចកុក្កុច** នេះ បណ្ឌិតគប្បីជ្រាបការញែកពាក្យក្នុងបទថា **សន្តា ហោន្តិ** ដោយន័យមុននោះឯង ។

បទថា **តិណ្ណវិចិកិច្ឆោ** បានដល់ ឆ្លងហើយ ឈានកន្លងហើយ នូវវិចិកិច្ឆា តាំងនៅ ។ ក្នុងនិទ្ទេសនៃបទនោះ បទថា **តិណ្ណវិចិកិច្ឆោ** គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **តិណ្ណោ** នេះ ព្រះមានព្រះភាគ ក៏ត្រាស់ដោយអំណាចនៃការសម្តែងដល់ការមិនលិចចុះក្នុងវិចិកិច្ឆា ។ បទថា **ឧត្តិណ្ណោ** នេះ ទ្រង់ត្រាស់ហើយ ដោយអំណាចការសម្តែងដល់ការឈានកន្លងនូវវិចិកិច្ឆានោះ ។ បទថា **និត្តិណ្ណោ** នេះ ទ្រង់ត្រាស់ដោយអំណាចនៃការសម្តែងវិចិកិច្ឆានោះ ដែលខ្លួនឆ្លងនូវឧបទ្រពទាំងឡាយបានហើយ ព្រោះគ្រប់សង្កត់ដោយអំណាចភាវនា ។ បទថា **បារង្គតោ** បានដល់ ដល់នូវត្រើយវិចិកិច្ឆា

*គឺមិនមានវិចិកិច្ឆា ។ បទថា* **ឆារមនុប្បត្តោ** *បានដល់ ដល់នូវត្រៃយនោះ ឯងដោយការប្រកបសេចក្តីព្យាយាមក្នុងការនោរឿយៗ គឺសម្តែងថា បដិបទា មានផលយ៉ាងនេះដល់ភិក្ខុនោះ ។*

*បទថា* **អកថំកថី** *បានដល់ វៀរចាកការសង្ស័យយ៉ាងនេះថា នេះអ្វី នេះអ្វី ។ បទថា* **កុសលេសុ ធម្មេសុ** *បានដល់ ក្នុងធម៌ដែលមិនមានទោសទាំងឡាយ ។ បទថា* **ន កង្ខតិ** *បានដល់ មិនញ៉ាំងនូវសេចក្តីសង្ស័យឲ្យកើតឡើងថា ធម៌ទាំងនេះ ជាកុសលឬហ្ន៎ ។ បទថា* **ន វិចិកិច្ឆតិ** *បានដល់ មិនក្រ មិនលំបាក ដើម្បីវិនិច្ឆ័យធម៌ទាំងនោះដោយសភាវៈ ។ បទថា* **អកថំកថី ហោតិ** *បានដល់ ជាអ្នកវៀរចាកសេចក្តីសង្ស័យថា កុសលធម៌ទាំងនេះដូចម្តេចហ្ន៎ ។ បទថា* **និក្កថំកថី វិគតកថំកថោ** *ជាវេវចនៈនៃបទថា* **អកថំកថី** *នោះឯង ។ ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបវចនត្ថៈក្នុងព្រះបាលីនោះដូចតទៅ*

*ភិក្ខុណាចេញទៅហើយចាកសេចក្តីសង្ស័យ ព្រោះហេតុនោះ ទើបភិក្ខុនោះ ឈ្មោះថា* **និក្កថំកថី** ។ *សេចក្តីសង្ស័យរបស់ភិក្ខុនោះ ទៅប្រាសហើយ ព្រោះហេតុនោះ ទើបភិក្ខុនោះ ឈ្មោះថា* **វិគតកថំកថោ** ។

*បទថា* **ឧបក្កិលេសេ** *បានដល់ ឧបក្កិលេស ។ ពិតហើយ នីវរណៈទាំង ៥ នោះ ចូលដល់ចិត្តហើយ នឹងធ្វើចិត្តនោះឲ្យសៅហ្មង ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា* **ឧបក្កិលេសេ** *ដូច្នេះ ។*

*បទថា* **បញ្ញាយ ទុព្វលីករណេ** *បានដល់ ព្រោះនីវរណៈទាំង ៥*

នោះ កាលកើតឡើងហើយ រមែងមិនឲ្យនូវការកើតឡើងនៃបញ្ញាដែលជាលោកិយ និងបញ្ញាដែលជាលោកុត្តរ ដែលមិនទាន់កើតឡើងផង ចូលទៅកាត់នូវសមាបត្តិ ៨ អភិញ្ញា ៥ ដែលកើតឡើងហើយឲ្យធ្លាក់ទៅផង ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ជាគ្រឿងធ្វើបញ្ញាឲ្យមានកម្លាំងថយ ដូច្នេះ ។ បទថា **អនុប្បន្នា ចេវ បញ្ញា ន ឧប្បជ្ជតិ ឧប្បន្នា ច បញ្ញា និរុជ្ឈតិ** នេះ ព្រះមានព្រះភាគត្រាស់សំដៅយកអត្ថនោះឯង ។ ពាក្យទាំងពួងដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ព្រោះមានអត្ថដូចខ្ញុំប្រកាសហើយខាងដើម ក្នុងទីនោះៗ ឯង ។

ពាក្យដែលខ្ញុំគប្បីពោលក្នុងនិទ្ទេសទាំងឡាយ មានពាក្យថា **វិវិច្ចេវ កាមេហិ** ជាដើម ពាក្យនោះ ខ្ញុំបានពោលហើយក្នុងរូបាវចរនិទ្ទេស ក្នុងចិត្តុប្បាទកណ្ឌខាងដើមនោះឯង និងពោលក្នុងទីនោះៗ ក្នុងនិទ្ទេសនេះ ក្នុងឈានវិភង្គនោះឯង ។ ពិតហើយ ក្នុងសេចក្តីនេះ មានសេចក្តីសង្ខេបដូច្នេះ ក្នុងនិទ្ទេសនៃទុតិយជ្ឈាន តតិយជ្ឈាន និងចតុត្ថជ្ឈានទាំងឡាយ ព្រះមានព្រះភាគត្រាស់ខាងដើមថា ឈានប្រកបដោយអង្គ ៣ ឈានប្រកបដោយអង្គ ២ ត្រឹមតែម៉្យាង យ៉ាងណា ឈាននោះៗ ព្រះមានព្រះភាគមិនបានត្រាស់យ៉ាងនោះ ទ្រង់កាន់យកអង្គទាំង ៣ នោះ និងសេចក្តីផូរផង់ជាដើមដោយអមអំពីព្រះបាលីថា **អជ្ឈត្តំ សម្បសាទនំ** ជាដើម ទ្រង់លើកឡើងសម្តែងហើយដោយន័យថា ត្រង់ពាក្យថា ឈាន គឺសេចក្តីជ្រះថ្លាស៊ប់ បីតិ សុខ ឯកគ្គតានៃចិត្ត ដូច្នេះជាដើម ។

*ក្នុងបទនិទ្ទេសថា* **យន្តំ អរិយា អាចិក្ខន្តិ** *ពាក្យទាំងអស់ មានពាក្យថា* **អាចិក្ខន្តិ ទេសេន្តិ** *ជាដើម ជាវេវចនៈនៃគ្នានិងគ្នាក៏ពិត តែបណ្ឌិតគប្បីជ្រាបសេចក្តីយ៉ាងនេះថា ព្រះអរិយៈរមែងពោលសរសើរដោយអំណាចនៃឧទ្ទេស មានបទថា* **ឧបេក្ខកោ សតិមា សុខវិហារី** *ជាដើម ទ្រង់រមែងសរសើរដោយអំណាចនៃឧទ្ទេស ទ្រង់រមែងសម្តែងដោយអំណាចនៃនិទ្ទេស ទ្រង់រមែងបញ្ញត្តដោយអំណាចនៃបដិនិទ្ទេស ព្រោះតាំងនូវអត្ថដោយប្រការនោះៗ ឈ្មោះថា តាំង កាលសម្តែងហេតុនៃអត្ថនោះៗ ឈ្មោះថា បើក កាលសម្តែងនូវការចែកបទព្យញ្ជនៈ ឈ្មោះថា ចែក កាលនាំចេញនូវភាពនៃអត្ថត្រូវបើកផ្ងារ និងភាពនៃអត្ថជ្រាលជ្រៅ ញ៉ាំងទីពឹងដល់ញាណនៃអ្នកស្តាប់ទាំងឡាយឲ្យកើតឡើង ឈ្មោះថា ធ្វើឲ្យរាក់ កាលកម្ចាត់ងងឹតក្នុងការមិនដឹងរបស់អ្នកស្តាប់ទាំងឡាយ ដោយអាការទាំងអស់នេះ ឈ្មោះថា ប្រកាស ។*

*ក្នុងនិទ្ទេសនៃបទថា* **សមតិក្កម** *បណ្ឌិតគប្បីជ្រាបសេចក្តីយ៉ាងនេះថា ឈ្មោះថា* **អតិក្កមន្តោ** *ព្រោះចេញចាកធម៌នោះៗ ក្នុងទីនោះៗ ។ ឈ្មោះថា* **វីតិក្កន្តោ** *ព្រោះសម្រេចភូមិខាងលើ ។ ឈ្មោះថា* **សមតិក្កន្តោ** *ព្រោះមិនវិនាសចាកឈាននោះ ។l៚*

**អដ្ឋកថាសុត្តន្តភាជនីយ ចប់**

# អភិធម្មបិដក

## អភិធម្មភាជនីយ

[ ៤៥៦ ] ឈាន ៤ យ៉ាង គឺបឋមជ្ឈាន ១ ទុតិយជ្ឈាន ១ តតិយជ្ឈាន ១ ចតុត្ថជ្ឈាន ១ ។

[ ៤៥៧ ] បណ្តាឈានទាំងនោះ បឋមជ្ឈាន តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន មានបឋវីកសិណ ( ជាអារម្មណ៍ ) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៥ គឺវិតក្ក វិចារ បីតិ សុខ ចិត្តេកគ្គតាក៏កើតមាន នេះហៅថា បឋមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៥៨ ] បណ្តាឈានទាំងនោះ ទុតិយជ្ឈាន តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់វិតក្កនិងវិចារ ។បេ។ ចូលកាន់ទុតិយជ្ឈាន មានបឋវីកសិណ ( ជាអារម្មណ៍ ) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៣ គឺបីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា ទុតិយជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៥៩ ] បណ្តាឈានទាំងនោះ តតិយជ្ឈាន តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះនឿយណាយចាកបីតិ ។បេ។ ចូលកាន់តតិយជ្ឈាន មានបឋវីកសិណ ( ជាអារម្មណ៍ ) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺសុខ ចិត្តេកគ្គតា

ក៏កើតមាន នេះហៅថា តតិយជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៦០ ] បណ្ដាឈានទាំងនោះ ចតុត្ថជ្ឈាន តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះលះបង់នូវសុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន មានបឋវីកសិណ ( ជាអារម្មណ៍ ) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ ឧបេក្ខា ចិត្តេកគ្គតាក៏កើតមាន នេះហៅថា ចតុត្ថជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៦១ ] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន មានបឋវីកសិណ ( ជាអារម្មណ៍ ) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៥ គឺវិតក្ក វិចារ បីតិ សុខ ចិត្តេកគ្គតាក៏កើតមាន នេះហៅថា បឋមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៦២ ] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ចូលកាន់ទុតិយជ្ឈាន មិនមានវិតក្ក មានត្រឹមតែវិចារ មានបីតិ និងសុខ កើតអំពីសេចក្ដីស្ងាត់ មានបឋវីកសិណ ( ជាអារម្មណ៍ ) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៤ គឺវិចារ បីតិ សុខ ចិត្តេកគ្គតាក៏កើតមាន នេះហៅថា ទុតិយជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៦៣ ] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់វិតក្កៈ និងវិចារ ។បេ។ ចូលកាន់តតិយជ្ឈាន មានបឋវីកសិណ ( ជាអារម្មណ៍ ) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៣ គឺបីតិ សុខ ចិត្តេកគ្គតាក៏កើតមាន នេះហៅថា តតិយជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៦៤ ] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះនឿយណាយចាកបីតិផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន មានបឋវីកសិណ ( ជាអារម្មណ៍ ) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺសុខ ចិត្តេកគ្គតាក៏កើតមាន នេះហៅថា ចតុត្ថជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៦៥ ] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះលះបង់សុខផង ។បេ។ ចូលកាន់បញ្ចមជ្ឈាន មានបឋវីកសិណ ( ជាអារម្មណ៍ ) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺឧបេក្ខា ចិត្តេកគ្គតាក៏កើតមាន នេះហៅថា បញ្ចមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៦៦ ] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងអរូបភព កន្លងនូវអាកិញ្ចញ្ញាយតនៈ ដែលប្រឡំដោយនេវសញ្ញានាសញ្ញាយតនសញ្ញាដោយប្រការទាំងពួង ព្រោះលះបង់សុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺឧបេក្ខា

ចិត្តេកគ្គតាក៏កើតមាន នេះហៅថា ចតុត្ថជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៦៧ ] ឈាន ៤ គឺបឋមជ្ឈាន ១ ទុតិយជ្ឈាន ១ តតិយជ្ឈាន ១ ចតុត្ថជ្ឈាន ១ ។

[ ៤៦៨ ] បណ្តាឈានទាំងនោះ បឋមជ្ឈាន តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកម្មកិលេស ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៥ គឺវិតក្ក វិចារ បីតិ សុខ ចិត្តេកគ្គតាក៏កើតមាន នេះហៅថា បឋមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៦៩ ] បណ្តាឈានទាំងនោះ ទុតិយជ្ឈាន តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកម្មកិលេស ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ព្រោះរម្ងាប់នូវវិតក្ក និងវិចារ ។បេ។ ចូលកាន់ទុតិយជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៣ គឺបីតិ សុខ ចិត្តេកគ្គតាក៏កើតមាន នេះហៅថា ទុតិយជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៧០ ] បណ្តាឈានទាំងនោះ តតិយជ្ឈាន តើដូចម្តេច ។ ក្នុង

សម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកម្មក្កិលេស ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ព្រោះនឿយណាយចាកបីតិផង ។បេ។ ចូលកាន់តតិយជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺសុខ ចិត្តេកគ្គតាក៏កើតមាន នេះហៅថា តតិយជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៧១ ] បណ្តាឈានទាំងនោះ ចតុត្ថជ្ឈាន តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកម្មក្កិលេស ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ព្រោះលះសុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ជាទុក្ខាបដិ-បទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺឧបេក្ខា ចិត្តេកគ្គតាក៏កើតមាន នេះហៅថា ចតុត្ថជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៧២ ] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកម្មក្កិលេស ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៥ គឺវិតក្ក វិចារ បីតិ សុខ ចិត្តេកគ្គតាក៏កើតមាន នេះហៅថា បឋមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៧៣ ] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកម្មកិលេស ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ( លុះស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយ ) ចូលកាន់ទុតិយជ្ឈាន មិនមានវិតក្ក មានត្រឹមតែវិចារ មានបីតិ និងសុខ កើតក្នុងវិវេក ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៤ គឺវិចារ បីតិ សុខ ចិត្តេកគ្គតាក៏កើតមាន នេះហៅថា ទុតិយជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៧៤ ] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកម្មកិលេស ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ព្រោះរម្ងាប់វិតក្ក និងវិចារ ។បេ។ ចូលកាន់តតិយជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៣ គឺបីតិ សុខ ចិត្តេកគ្គតាក៏កើតមាន នេះហៅថា តតិយជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៧៥ ] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកម្មកិលេស ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ព្រោះនឿយណាយចាកបីតិផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺសុខ ចិត្តេកគ្គតាក៏កើតមាន នេះហៅថា ចតុត្ថជ្ឈាន

ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៧៦ ] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកម្មកិលេស ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ព្រោះលះបង់សុខផង ។បេ។ ចូលកាន់បញ្ចមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺឧបេក្ខា ចិត្តេកគ្គតាក៏កើតមាន នេះហៅថា បញ្ចមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៧៧ ] ឈាន ៤ គឺបឋមជ្ឈាន ១ ទុតិយជ្ឈាន ១ តតិយជ្ឈាន ១ ចតុត្ថជ្ឈាន ១ ។

[ ៤៧៨ ] បណ្ដាឈានទាំងនោះ បឋមជ្ឈាន តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន មានបឋវីកសិណ ( ជាអារម្មណ៍ ) ហើយសម្រាកនៅ ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ អវិក្ខេបៈ ( ការមិនរាយមាយ ) ក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថា ជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ជាវិបាក មានបឋវីកសិណ ( ជាអារម្មណ៍ ) ហើយសម្រាកនៅ ព្រោះភាពនៃកម្ម ជារូបាវចរកុសលនោះឯង ដែលលោកធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ ឈានមានអង្គ ៥ គឺ វិតក្ក វិចារ បីតិ សុខ ចិត្តេកគ្គតាក៏កើតមាន នេះហៅថា បឋមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៧៩ ] បណ្តាឈានទាំងនោះ ទុតិយជ្ឈាន តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់វិតក្ក និងវិចារ ។បេ។ ចូលកាន់ទុតិយជ្ឈាន មានបឋវីកសិណ ( ជាអារម្មណ៍ ) ហើយសម្រាកនៅ ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ អវិក្ខេបៈ ក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថា ជាកុសល ព្រោះរម្ងាប់វិតក្ក និងវិចារ ។បេ។ ចូលកាន់ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ ចូលកាន់បញ្ចមជ្ឈាន ជាវិបាក ព្រោះភាពនៃកម្មជារូបាវចរកុសលនោះឯង ដែលលោកធ្វើហើយ សន្សំហើយ មានបឋវីកសិណ ( ជាអារម្មណ៍ ) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺឧបេក្ខា ចិត្តេកគ្គតាក៏កើតមាន នេះហៅថា បញ្ចមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។បេ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងអរូបភព កន្លងអាកិញ្ចញ្ញាយតនៈ ដែលប្រឡំដោយនេវសញ្ញា-នាសញ្ញាយតនសញ្ញា ដោយប្រការទាំងពួង ព្រោះលះបង់សុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ហើយសម្រាកនៅ ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថា ជាកុសល កន្លងអាកិញ្ចញ្ញា-យតនៈ ដែលប្រឡំដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ដោយប្រការទាំងពួង ព្រោះលះសុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ជាវិបាក ព្រោះភាពនៃកម្មជាអរូបាវចរកុសលនោះឯង ដែលលោកធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺឧបេក្ខា ចិត្តេកគ្គតាក៏កើតមាន នេះហៅថា

ចតុត្ថជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៨០ ] ឈាន ៤ គឺបឋមជ្ឈាន ១ ទុតិយជ្ឈាន ១ តតិយជ្ឈាន ១ ចតុត្ថជ្ឈាន ១ ។

[ ៤៨១ ] បណ្តាឈានទាំងនោះ បឋមជ្ឈាន តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកម្មកិលេស ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថា ជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ជាវិបាក ព្រោះភាពនៃឈានជាលោកុត្តរកុសលនោះឯង ដែលលោកធ្វើហើយ អប់រំហើយ ជាទុក្ខាបដិ-បទាទន្ធាភិញ្ញា ជាសុញ្ញតៈ ក្នុងសម័យនោះ ឈានមានអង្គ ៥ គឺវិតក្កៈ វិចារ បីតិ សុខ ចិត្តេកគ្គតាក៏កើតមាន នេះហៅថា បឋមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៨២ ] បណ្តាឈានទាំងនោះ ទុតិយជ្ឈាន តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ព្រោះរម្ងាប់វិតក្កៈ និងវិចារ ។បេ។ ចូលកាន់ទុតិយជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ អវិក្ខេបៈ ក៏

កើតមាន ធម៌ទាំងនេះ ឈ្មោះថា ជាកុសល ព្រោះរម្ងាប់វិតក្ក និងវិចារ ។បេ។ ចូលកាន់បឋមជ្ឈាន ។បេ។ ចូលកាន់បញ្ចមជ្ឈាន ជាវិបាក ព្រោះភាពនៃឈាន ជាលោកុត្តរកុសលនោះឯង ដែលលោកធ្វើហើយ អប់រំហើយ ជាទុក្ខាបដិ-បទាទន្ធាភិញ្ញា ជាសុញ្ញតៈ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺឧបេក្ខា ចិត្តេកគ្គតាក៏កើតមាន នេះហៅថា បញ្ចមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៨៣ ] ឈាន ៤ គឺបឋមជ្ឈាន ១ ទុតិយជ្ឈាន ១ តតិយជ្ឈាន ១ ចតុត្ថជ្ឈាន ១ ។

[ ៤៨៤ ] បណ្តាឈានទាំងនោះ បឋមជ្ឈាន តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនរូបាវចរជ្ឈាន ជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនជាកម្មវិបាក ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន មានបឋវីកសិណ ( ជាអារម្មណ៍ ) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៥ គឺ វិតក្ក វិចារ បីតិ សុខ ចិត្តេកគ្គតាក៏កើតមាន នេះហៅថា បឋមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៨៥ ] បណ្តាឈានទាំងនោះ ទុតិយជ្ឈាន តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនរូបាវចរជ្ឈាន ជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនជាកម្មវិបាក ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ព្រោះរម្ងាប់វិតក្ក និងវិចារ ។បេ។ ចូលកាន់ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន

។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បញ្ចមជ្ឈាន មានបឋវីកសិណ ( ជាអារម្មណ៍ ) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ ឧបេក្ខា ចិត្តេកគ្គតាក៏កើតមាន នេះហៅថា បញ្ចមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។បេ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនអរូបាវចរជ្ឈាន ជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនជាកម្មវិបាក ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន កន្លងនូវអាកិញ្ចញ្ញាយតនៈ ដែលប្រឡំដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ដោយប្រការទាំងពួង ព្រោះលះសុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺឧបេក្ខា ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា ចតុត្ថជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

## អភិធម្មភាជនីយ ចប់

# អដ្ឋកថា

## អភិធម្មភាជនីយ

[ ៤៥៦-៤៨៥ ] ព្រះមានព្រះភាគទ្រង់តាំងបែបផែន ក្នុងអភិធម្មភាជនីយ ដោយន័យដែលមកហើយ ក្នុងចិត្តុប្បាទកណ្ឌខាងដើមនោះឯង ព្រោះហេតុនោះ ក្នុងអភិធម្មភាជនីយនេះ បណ្ឌិតគប្បីជ្រាបអត្ថនៃឈានទាំងឡាយ ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ដោយអំណាចនៃធម៌ដែលជាកុសល វិបាក និងកិរិយា ដោយន័យដែលពោលក្នុងចិត្តុប្បាទកណ្ឌនោះឯង អត្ថទាំងអស់ ទោះបីផ្សេងគ្នា ដោយអត្ថ មានសុទ្ធិកនវកៈជាដើម ក៏ដូចគ្នានឹងន័យដែលពោលហើយ ក្នុងចិត្តុប្បាទកណ្ឌដូចគ្នា ។ល។

**អដ្ឋកថាអភិធម្មភាជនីយ ចប់**

# អភិធម្មបិដក

## បញ្ហាបុច្ឆកៈ

[ ៤៨៦ ] ឈាន ៤ គឺភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈ និងវិចារ មានបីតិ និងសុខកើតក្នុងវិវេក ភិក្ខុព្រោះរម្ងាប់វិតក្កៈ និងវិចារហើយ ក៏ចូលកាន់ទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តាន ប្រកបដោយសេចក្តីជ្រះថ្លា គឺសទ្ធា មានភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារ មានតែបីតិ និងសុខដែលកើតក្នុងសមាធិ គឺបឋមជ្ឈាន ព្រោះនឿយណាយចាកបីតិផង ប្រកបដោយឧបេក្ខាផង មានសតិ និងសម្បជញ្ញៈផង ទទួលសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយ តែងសរសើរនូវបុគ្គលដែលព្រមព្រៀងដោយតតិយជ្ឈាននោះថា បុគ្គលប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខ ដូច្នេះ ព្រោះតតិយជ្ឈានណា ក៏ចូលកាន់តតិយជ្ឈាននោះ ព្រោះលះសុខផង ព្រោះលះទុក្ខផង ព្រោះវិនាសទៅនៃសោមនស្ស និងទោមនស្ស ក្នុងកាលមុនផង ហើយចូលកាន់ចតុត្ថជ្ឈាន មានអារម្មណ៍មិនមែនទុក្ខ មិនមែនសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ។ បណ្តាឈានទាំង ៤ ឈានជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។បេ។ ជាសរណៈប៉ុន្មាន ជាអរណៈប៉ុន្មាន ។

[ ៤៨៧ ] ឈានជាកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។ ឈាន ៣ ប្រកបដោយសុខវេទនា វៀរលែងតែសុខវេទនា ដែលកើតក្នុងឈានទ៉ុះចេញ ឈានទី ៤ ប្រកបដោយអទុក្ខមសុខវេទនា វៀរលែងតែអទុក្ខម-

សុខវេទនាដែលកើតក្នុងឈានទាំង៤ចេញ ។ ឈានជាវិបាកក៏មាន មានវិបាកធម៌ជាប្រក្រតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតីក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក តែជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន មិនសៅហ្មង តែគួរដល់សេចក្ដីសៅហ្មងក៏មាន មិនសៅហ្មង ទាំងមិនគួរដល់សេចក្ដីសៅហ្មងក៏មាន ។ ឈានទី ១ ប្រកបដោយវិតក្ក ប្រកបដោយវិចារ វៀរលែងតែវិតក្ក និងវិចារ ដែលកើតក្នុងឈានទាំង៤ចេញ ឈាន ៣ មិនមានវិតក្ក មិនមានវិចារ ។ ឈាន ២ ប្រឡំដោយបីតិ វៀរលែងតែបីតិដែលកើតក្នុងឈានទាំង៤ចេញ ឈាន ៣ ប្រឡំដោយសុខ វៀរលែងតែសុខដែលកើតក្នុងឈានទាំង៤ចេញ ឈានទី ៤ ប្រឡំដោយឧបេក្ខា វៀរលែងតែឧបេក្ខាដែលកើតក្នុងឈានទាំង៤ចេញ ។ ឈានដែលមិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា មានហេតុ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះ ដោយភាវនា ដល់នូវការសន្សំ ( នូវកម្មកិលេស ) ក៏មាន ដល់នូវការមិនសន្សំក៏មាន មិនដល់នូវការសន្សំ ទាំងមិនដល់នូវការមិនសន្សំក៏មាន ជារបស់សេក្ខបុគ្គលក៏មាន ជារបស់អសេក្ខបុគ្គលក៏មាន មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គលក៏មាន ដល់នូវសភាពធំក៏មាន មិនមានប្រមាណក៏មាន ។ ឈាន ៣ មិនគួរពោលថា មានអារម្មណ៍

តូចផង ថាមានអារម្មណ៍ដល់នូវសភាពធំផងឡើយ មានអារម្មណ៍ប្រមាណមិនបានក៏មាន មិនគួរពោលថា មានអារម្មណ៍មិនមានប្រមាណក៏មាន ឈានទី ៤ មានអារម្មណ៍តូចថ្មារក៏មាន មានអារម្មណ៍ដល់នូវសភាពធំក៏មាន មានអារម្មណ៍មិនមានប្រមាណក៏មាន មិនគួរពោលថា មានអារម្មណ៍តូចថ្មារផង ថាមានអារម្មណ៍ដល់នូវភាពធំផង ថាមានអារម្មណ៍មិនមានប្រមាណផងក៏មាន ។ ឈានជាកណ្តាលក៏មាន ឧត្តមក៏មាន មានសភាពត្រូវ និងទៀងក៏មាន មានសភាពមិនទៀងក៏មាន ឈាន ៣ មិនមានមគ្គជាអារម្មណ៍ តែមានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន មិនគួរពោលថា មានមគ្គជាហេតុផង ថាមានមគ្គជាអធិបតីផងក៏មាន ឈានទី ៤ មានមគ្គជាអារម្មណ៍ក៏មាន មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន មិនគួរពោលថា មានមគ្គជាអារម្មណ៍ផង ថាមានមគ្គជាហេតុផង ថាមានមគ្គជាអធិបតីផងក៏មាន ។ ឈានដែលកើតហើយក៏មាន មិនទាន់កើតក៏មាន បម្រុងនឹងកើតក៏មាន ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏មាន ។ ឈាន ៣ មិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថាមានអារម្មណ៍ជាអនាគតផង ថាមានអារម្មណ៍ជាបច្ចុប្បន្នផងឡើយ ឈានទី ៤ មានអារម្មណ៍ជាអតីតក៏មាន មានអារម្មណ៍ជាអនាគតក៏មាន មានអារម្មណ៍ជាបច្ចុប្បន្នក៏មាន មិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថាមានអារម្មណ៍ជាអនាគតផង ថាមានអារម្មណ៍ជាបច្ចុប្បន្នផងក៏មាន ។ ឈានខាងក្នុងក៏មាន ខាងក្រៅក៏មាន ទាំងខាងក្នុងទាំងខាងក្រៅក៏មាន ។ ឈាន ៣ មានអារម្មណ៍ខាងក្រៅ ឈានទី ៤ មាន

អារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ខាងក្នុង និងខាងក្រៅក៏មាន មិនគួរពោលថា មានអារម្មណ៍ខាងក្នុងផង ថាមានអារម្មណ៍ខាងក្រៅផង ថាមានអារម្មណ៍ខាងក្នុង និងខាងក្រៅផងក៏មាន ។ ឈានមិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ ។

[ ៤៨៨ ] ពួកឈានមិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ប្រកបដោយហេតុ មិនគួរពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុទេ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុ មិនគួរពោលថា ជាហេតុ ទាំងប្រកបដោយហេតុឡើយ គ្រាន់តែប្រកបដោយហេតុ តែមិនមែនហេតុ គឺមិនមែនហេតុ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ ។ ពួកឈានប្រកបដោយបច្ច័យ ត្រូវបច្ច័យតាក់តែង មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ ឥតរូប ជាលោកិយក៏មាន ជាលោកុត្តរក៏មាន ដែលបុគ្គលគប្បីដឹងដោយវិញ្ញាណណាមួយ ដែលបុគ្គលមិនគប្បីដឹងដោយវិញ្ញាណណាមួយក៏មាន ។ ពួកឈានមិនមែនអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន មិនមានអាសវៈ ទាំងប្រាសចាកអាសវៈ តែមិនគួរពោលថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈក៏មាន មិនគួរពោលថា ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈក៏មាន មិនគួរពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈផង ថាប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផងក៏មាន ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន ប្រាស

បាកអាសវៈ ទាំងមិនមានអាសវៈក៏មាន ។ ពួកឈាន មិនមែនសំយោជនៈ ។បេ។ មិនមែនគន្ថៈ ។បេ។ មិនមែនឱឃៈ ។បេ។ មិនមែនយោគៈ ។បេ។ មិនមែននីវរណៈ ។បេ។ មិនមែនបរាមាស ។បេ។ ពួកឈានប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ មិនមែនចិត្ត ជាចេតសិក ប្រកបដោយចិត្ត ច្រឡំដោយចិត្ត តាំងឡើងអំពីចិត្ត កើតជាមួយនឹងចិត្ត ប្រព្រឹត្តទៅតាមនូវចិត្ត ច្រឡំ ទាំងតាំងឡើងអំពីចិត្ត ច្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត ច្រឡំ ទាំងប្រព្រឹត្តទៅតាមចិត្ត ជាខាងក្រៅ មិនមែនឧបាទា មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយក៏មាន មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយក៏មាន ។ ពួកឈាន មិនមែនឧបាទាន ។បេ។ មិនមែនកិលេស ។បេ។

[ ៤៨៩ ] ពួកឈាន មិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុ មិនគួរលះដោយទស្សនៈ ។ ឈានទី ១ ប្រកបដោយវិតក្ក វៀរលែងតែវិតក្កដែលកើតក្នុងឈាននុ៎ះចេញ ឈាន ៣ មិនមានវិតក្កទេ ។ ឈានទី ១ ប្រកបដោយវិចារ វៀរលែងតែវិចារដែលកើតក្នុងឈាននុ៎ះចេញ ឈាន ៣ មិនមានវិចារទេ ។ ឈាន ២ ប្រកបដោយបីតិ វៀរលែងតែ

បីតិដែលកើតក្នុងឈានទុំះចេញ ឈាន ២ មិនមានបីតិទេ ។ ឈាន ២ ប្រទ្បំដោយបីតិ វៀរលែងតែបីតិដែលកើតក្នុងឈានទុំះចេញ ឈាន ២ មិនប្រទ្បំដោយបីតិទេ ។ ឈាន ៣ ប្រទ្បំដោយសុខ វៀរលែងតែសុខដែលកើតក្នុងឈានទុំះចេញ ឈានទី ៤ មិនប្រទ្បំដោយសុខទេ ។ ឈានទី ៤ ប្រទ្បំដោយឧបេក្ខា វៀរលែងតែឧបេក្ខាដែលកើតក្នុងឈានទុំះចេញ ឈាន ៣ មិនប្រទ្បំដោយឧបេក្ខាទេ ។ ពួកឈានមិនមែនជាកាមាវចរ តែជារូបាវចរក៏មានមិនមែនរូបាវចរក៏មាន ។ ឈាន ៣ មិនមែនអរូបាវចរ ឈានទី ៤ ជាអរូ-បាវចរក៏មាន មិនមែនអរូបាវចរក៏មាន ។ ពួកឈានជាបរិយាបន្នក៏មាន ជាអបរិយាបន្នក៏មាន ជានិយ្យានិកៈក៏មាន ជាអនិយ្យានិកៈក៏មាន ជានិយតៈក៏មាន ជាអនិយតៈក៏មាន ជាសឧត្តរៈក៏មាន ជាអនុត្តរៈ ជាអរណៈក៏មាន ។

បញ្ហាបុច្ឆកៈ ចប់

ឈានវិភង្គ ចប់

# អដ្ឋកថា

## បញ្ហាបុច្ឆកៈ

[ ៤៨៦-៤៨៩ ] ក្នុងបញ្ហាបុច្ឆកៈ បណ្ឌិតគប្បីជ្រាបភាពដែលឈាន ទាំងឡាយជាកុសលជាដើម តាមទំនងនៃព្រះបាលីនោះឯង តែនៅក្នុង អារម្មណត្តិកៈ គឺពួក ៣ នៃអារម្មណ៍ ឈានទាំងនោះ គប្បីជ្រាបថា មិន គប្បីពោលដោយភាពជាអារម្មណ៍ មានបរិត្តារម្មណ៍ជាដើម ព្រោះឈានទាំង ៣ មាននិមិត្តជាអារម្មណ៍ ។ ចំណែកក្នុងបញ្ហាបុច្ឆកៈនេះ ឈានទាំងនោះ ជាលោកុត្តរ ជាអប្បមាណារម្មណៈ គប្បីមានក្នុងខណៈនៃមគ្គ ឬក្នុងខណៈ នៃផល ។ ក្នុងបទថា **ចតុត្ថំ ឈានំ សិយា បរិត្តារម្មណំ** នេះ ពោល ដោយកុសលហើយ ចតុត្ថជ្ឈានមាន ១៣ ប្រភេទ គឺចតុត្ថជ្ឈានដែលជាបាទ នៃធម៌ទាំងពួង ១ ចតុត្ថជ្ឈានដែលឲ្យសម្រេចឥទ្ធិវិធិ ១ ចតុត្ថជ្ឈានដែលឲ្យ សម្រេចទិព្វសោតញ្ញាណ ១ ចតុត្ថជ្ឈានដែលឲ្យសម្រេចចេតោបរិយញ្ញាណ ១ ចតុត្ថជ្ឈានដែលឲ្យសម្រេចបុព្វេនិវាសញ្ញាណ ១ ចតុត្ថជ្ឈានដែលឲ្យ សម្រេចទិព្វចក្ខុញ្ញាណ ១ ចតុត្ថជ្ឈានដែលឲ្យសម្រេចយថាកម្មូបគញ្ញាណ ១ ចតុត្ថជ្ឈានដែលឲ្យសម្រេចអនាគតំសញ្ញាណ ១ ចតុត្ថជ្ឈានដែលឲ្យសម្រេច អាកាសានញ្ចាយតនជ្ឈានជាដើម មាន ៤ និងចតុត្ថជ្ឈានដែលជាលោកុត្តរ ១ ។

ក្នុងឈានទាំងនោះ ចតុត្ថជ្ឈានដែលជាបាទក្នុងធម៌ទាំងពួង ជា នវត្តព្វារម្មណ៍តែម្យ៉ាង គឺមានអារម្មណ៍ដែលមិនគប្បីពោល ។

កាលភិក្ខុបង្អោនកាយទៅដោយអំណាចនៃចិត្ត ចតុត្ថជ្ឈានដែលឲ្យសម្រេចឥទ្ធិវិធិ ឈ្មោះថា **បរិត្តារម្មណា** ព្រោះមានកាយជាអារម្មណ៍ ក្នុងខណៈដែលធ្វើបាដិហារ្យ ដោយកាយមិនប្រាកដ ។ កាលបង្អោនចិត្តទៅដោយអំណាចនៃកាយ ធ្វើបាដិហារ្យដោយកាយដែលប្រាកដទៅកាន់ព្រហ្មលោក ចតុត្ថជ្ឈានដែលឲ្យសម្រេចឥទ្ធិ ឈ្មោះថា **មហគ្គតារម្មណា** ព្រោះមានចិត្តក្នុងសមាបត្តិជាអារម្មណ៍ ។

ចតុត្ថជ្ឈានដែលឲ្យសម្រេចទិព្វសោតញ្ញាណ ឈ្មោះថា **បរិត្តារម្មណា** ព្រោះមានសំឡេងជាអារម្មណ៍ ។

ចតុត្ថជ្ឈានដែលឲ្យសម្រេចចេតោបរិយញ្ញាណ ជាបរិត្តារម្មណ៍ ក្នុងខណៈដែលដឹងចិត្តជាកាមាវចរ ជាមហគ្គតារម្មណៈ ក្នុងខណៈដឹងចិត្តដែលជារូបាវចរ និងអរូបាវចរ ជាអប្បមាណារម្មណៈ ក្នុងខណៈដែលដឹងចិត្តជាលោកុត្តរ ។ បុថុជ្ជនដែលបានចេតោបរិយញ្ញាណ រមែងដឹងចិត្តរបស់បុថុជ្ជនទាំងឡាយប៉ុណ្ណោះ រមែងមិនដឹងចិត្តរបស់ព្រះអរិយៈទាំងឡាយ ព្រះសោតាបន្នរមែងដឹងចិត្តរបស់ព្រះសោតាបន្ន និងបុថុជ្ជនទាំងឡាយ ព្រះសកទាគាមីរមែងដឹងចិត្តរបស់ព្រះសកទាគាមី និងបុគ្គលដែលមានភូមិទាបជាង ព្រះអនាគាមី រមែងដឹងចិត្តរបស់ព្រះអនាគាមី និងរបស់បុគ្គល ៣ ពួក ដែលមានភូមិទាបជាង ព្រះខីណាស្រព រមែងដឹងចិត្តរបស់ជនទាំងអស់ ។

ចតុត្ថជ្ឈានដែលឲ្យសម្រេចជាបុព្វេនិវាសញ្ញាណ ជាបរិត្តារម្មណៈ ក្នុងខណៈដែលរឭកដល់ខន្ធដែលជាកាមាវចរ ជាមហគ្គតារម្មណៈ ក្នុងខណៈ

ដែលតាមរឭកដល់ខន្ធដែលជារូបាវចរ និងអរូបាវចរ ជាអប្បមាណារម្មណៈ ក្នុងកាលដែលតាមរឭកថា ក្នុងអតីតកាល ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះខីណាស្រពទាំងឡាយ ចម្រើនមគ្គហើយ ធ្វើឲ្យជាក់ច្បាស់នូវផល ដូច្នេះ ជានវត្តព្វារម្មណៈ ក្នុងពេលដែលតាមរឭកដល់ឈ្មោះ និងគោត្រ ។

ចតុត្ថជ្ឈានដែលជាទិព្វចក្ខុញ្ញាណ ឈ្មោះថា **បរិត្តារម្មណា** ព្រោះមានពណ៌ជាអារម្មណ៍ ។ ចតុត្ថជ្ឈានដែលឲ្យសម្រេចយថាកម្មូបគញ្ញាណ ជាបរិត្តារម្មណៈ ក្នុងខណៈដែលរឭកដល់កម្មជាកាមាវចរ ជាមហគ្គតារម្មណៈ ក្នុងខណៈរឭកដល់កម្មដែលជារូបាវចរ និងអរូបាវចរ ។

ចតុត្ថជ្ឈានដែលឲ្យសម្រេចអនាគតំសញ្ញាណ ជាបរិត្តារម្មណៈ ក្នុងកាលដែលដឹងការកើតឡើងក្នុងកាមធាតុ ក្នុងអនាគតកាល ជាមហគ្គតារម្មណៈ ក្នុងកាលដែលដឹងការកើតឡើងក្នុងរូបភព និងអរូបភព ជាអប្បមាណារម្មណៈ ក្នុងការដឹងថា ក្នុងអនាគតកាល ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះខីណាស្រពទាំងឡាយ នឹងចម្រើនមគ្គ នឹងសម្រេចផល ដូច្នេះ ជានវត្តព្វារម្មណៈ ក្នុងកាលដែលរឭកដល់ឈ្មោះ និងគោត្រ ដោយន័យជាដើមថា ក្នុងអនាគតកាល នឹងមានព្រះរាជាព្រះនាមសង្ខៈ ។

ចតុត្ថជ្ឈានដែលឲ្យសម្រេចអាកាសានញ្ចាយតនៈ និងអាកិញ្ចញ្ញាយតនៈ ជានវត្តព្វារម្មណៈ ។

ចតុត្ថជ្ឈានដែលឲ្យសម្រេចវិញ្ញាណញ្ចាយតនៈ និងនេវសញ្ញានាសញ្ញាយតនៈ ជាមហគ្គតារម្មណៈ ។

ចតុត្ថជ្ឈានដែលជាលោកុត្តរ ជាអប្បមាណារម្មណៈ ។

ពោលដោយកិរិយា ចតុត្ថជ្ឈាននោះឯង មានការកំណត់អារម្មណ៍តាមឈានទាំង ១២ នោះ ។

បទថា **តីណិ ឈានានិ ឧមគ្គារម្មណា** បានដល់ បច្ចវេក្ខណញ្ញាណ ឬចេតោបរិយញ្ញាណជាដើម គប្បីធ្វើមគ្គឲ្យជាអារម្មណ៍បាន ។ ឈានទាំង ៣ មិនជាមគ្គារម្មណៈ ព្រោះមិនប្រព្រឹត្តទៅយ៉ាងនោះ តែគប្បីជាមគ្គហេតុកៈ ដោយអំណាចនៃសហជាតហេតុ ។ ជាមគ្គាធិបតី ដោយការចម្រើនមគ្គដែលមានវិរិយៈជាប្រធាន ឬមានវីមំសាជាប្រធាន ។ តែមិនគប្បីពោលថា ជាមគ្គាធិបតី ក្នុងកាលដែលមានឆន្ទៈ និងចិត្តជាប្រធាន និងក្នុងកាលនៃផល ។

ក្នុងបទថា **ចតុត្ថំ ឈានំ** នេះ ពោលដោយកុសលក្នុងចតុត្ថជ្ឈាន ១៣ មិនគប្បីពោលថា ចតុត្ថជ្ឈានដែលឲ្យសម្រេចសព្វត្ថបាទកៈ ឥទ្ធិវិធ ទិព្វសោតញ្ញាណ ទិព្វចក្ខុញ្ញាណ យថាកម្មូបគញ្ញាណ និងចតុត្ថជ្ឈានដែលជាអរូប ៤ យ៉ាង ថាជាមគ្គារម្មណៈជាដើម ។ ចំណែកចតុត្ថជ្ឈានដែលជាចេតោបរិយញ្ញាណ បុព្វេនិវាសញ្ញាណ អនាគតំសញ្ញាណ ជាមគ្គារម្មណៈ តែមិនគប្បីពោលថា ជាមគ្គហេតុកៈ ឬមគ្គាធិបតី ។ លោកុត្តរជ្ឈាន មិនជាមគ្គារម្មណៈ តែក្នុងកាលចម្រើនមគ្គដែលមានវិរិយៈ និងវីមំសាជាធំ មិនគប្បីពោលថា ជាមគ្គាធិបតី ក្នុងកាលចម្រើនមគ្គដែលមានឆន្ទៈ និងចិត្តជាធំ និងក្នុងកាលនៃផល ។ បើពោលដោយកិរិយាហើយ ក្នុងឈាន ១២ ក៏ន័យនេះដូចគ្នា ។

បទថា **តីណិ ឈានានិ ន វត្តព្វា** បណ្ឌិតគប្បីជ្រាបថា ឈាន ៣ មិនគប្បីពោលថា ជាអតីតារម្មណៈជាដើម ព្រោះមិនប្រារព្ធធម៌ណាមួយ ក្នុងអតីតជាដើម ឲ្យប្រព្រឹត្តទៅ ។

បទថា **ចតុត្ថំ ឈានំ** បានដល់ បើពោលដោយកុសល សព្វត្ថ-បាទកចតុត្ថជ្ឈាន ដែលជាបាទនៃឈានទាំងអស់ ក្នុងចតុត្ថជ្ឈាន ១៣ ជានវត្តព្វារម្មណៈប៉ុណ្ណោះ ។

ចតុត្ថជ្ឈានដែលជាឥទ្ធិវិធ ជាអតីតារម្មណៈ ព្រោះមានចិត្តក្នុងសមាបត្តិជាអារម្មណ៍ ក្នុងការបង្អោនចិត្តដោយអំណាចកាយ ជាអនាគតារម្មណ៍ ក្នុងកាលអធិដ្ឋានថា ក្នុងអនាគតកាល សូមផ្កាទាំងនេះ កុំបីស្វិតស្រពោន ប្រទីបទាំងឡាយកុំបីរលត់ គំនរភ្លើងមួយ ចូរតាំងឡើង ភ្នំ ចូរតាំងឡើងដោយល្អដូច្នេះ ។ ជាបច្ចុប្បន្នារម្មណ៍ ព្រោះមានកាយជាអារម្មណ៍ ក្នុងកាលបង្អោនកាយទៅ ដោយអំណាចនៃចិត្ត ។

ចតុត្ថជ្ឈានដែលឲ្យសម្រេចទិព្វសោតញ្ញាណ ឈ្មោះថា **បច្ចុប្បន្នា-រម្មណា** ព្រោះមានសំឡេងជាអារម្មណ៍ ។

ចតុត្ថជ្ឈានដែលឲ្យសម្រេចចេតោបរិយញ្ញាណ ជាអតីតារម្មណៈ ក្នុងកាលដែលដឹងចិត្តដែលកើតឡើងហើយ រលត់ទៅខាងក្នុង ៧ ថ្ងៃ ក្នុងអតីតកាល ជាអនាគតារម្មណ៍ ក្នុងកាលដឹងចិត្តដែលកើតឡើងខាងក្នុង ៧ ថ្ងៃ ក្នុងអនាគតកាល ។ ពិតហើយ ព្រះមានព្រះភាគទ្រង់ប្រកាសការប្រព្រឹត្តទៅនៃចេតោបរិយញ្ញាណនោះឯង ដោយព្រះសូត្រ ( ក្នុងអង្គុត្តរនិកាយ

តិកនិបាត ) នេះថា មនោសង្ខារទាំងឡាយរបស់បុគ្គលដ៏ចម្រើននេះ តាំងទុកហើយ យ៉ាងណា បុគ្គលដ៏ចម្រើន និងត្រិះរិះនូវវិតក្កឈ្មោះឯណោះ អំពីលំដាប់នៃចិត្តនេះ ។ បុគ្គលនោះ ទោះបីទាយច្រើន ហេតុដែលទាយដូច្នោះនោះ ក៏មិនក្លាត់ ដូច្នេះ ។ ជាបច្ចុប្បន្នារម្មណ៍ ក្នុងកាលប្រារព្ធបច្ចុប្បន្នប្រព្រឹត្តទៅ ដោយអំណាចអទ្ធានបច្ចុប្បន្ន និងសន្តតិបច្ចុប្បន្ន ។ ក្នុងសេចក្តីនេះ គប្បីជ្រាបរឿងពិស្តារដោយន័យដែលពោលហើយ ក្នុងកិច្ចពណ៌នាអដ្ឋកថាកណ្ឌខាងដើមនោះឯង ។

ចតុត្ថជ្ឈានដែលជាបុព្វេនិវាសញ្ញាណជាអតីតារម្មណ៍ ក្នុងកាលតាមរឭកដល់អតីតក្ខន្ធ ជានវត្តព្វារម្មណ៍ ក្នុងកាលតាមរឭកដល់ឈ្មោះ និងគោត្រ ។

ចតុត្ថជ្ឈានដែលឲ្យសម្រេចទិព្វចក្ខុ ឈ្មោះថា **បច្ចុប្បន្នារម្មណា** ព្រោះមានពណ៌ជាអារម្មណ៍ ។

ចតុត្ថជ្ឈានដែលឲ្យសម្រេចយថាកម្មូបគញាណ រមែងធ្វើអតីតកម្មប៉ុណ្ណោះឲ្យជាអារម្មណ៍ ព្រោះហេតុនោះ ទើបឈ្មោះថា **អតីតារម្មណា** ។

ចតុត្ថជ្ឈានដែលឲ្យសម្រេចអនាគតំសញ្ញាណជាអនាគតារម្មណ៍ ក្នុងកាលតាមរឭកដល់ខន្ធដែលជាអនាគត ជានវត្តព្វារម្មណ៍ ក្នុងកាលតាមរឭកដល់ឈ្មោះ និងគោត្រ ។

អាកាសានញ្ចាយតនចតុត្ថជ្ឈាន និងអាកិញ្ចញ្ញាយតនចតុត្ថជ្ឈាន ជានវត្តព្វារម្មណ៍ប៉ុណ្ណោះ ។

*វិញ្ញាណញ្ចាយតនចតុត្ថជ្ឈាន និងនេវសញ្ញានាសញ្ញាយតនចតុត្ថជ្ឈាន ជាអតីតារម្មណ៍ប៉ុណ្ណោះ ។*

*លោកុត្តរចតុត្ថជ្ឈាន ជានវត្តព្វារម្មណ៍ប៉ុណ្ណោះ ។*

*ពោលដោយកិរិយាក្នុងចតុត្ថជ្ឈាន ១២ ក៏ន័យនេះដូចគ្នា ។*

*បទថា* **តីណិ ឈានានិ ពហិទ្ធារម្មណា** *បានដល់ ឈ្មោះថា* **ពហិទ្ធារម្មណា** *ព្រោះប្រារព្ធនិមិត្តដែលជាខាងក្រៅអំពីខាងក្នុងឲ្យប្រព្រឹត្តទៅ ។ សួម្បីក្នុងបទថា* **ចតុត្ថំ ឈានំ** *នេះ បើពោលដោយកុសលហើយ បានចតុត្ថជ្ឈាន ១៣ ដូច្នេះ គឺ*

*ចតុត្ថជ្ឈានដែលជាបាទក្នុងធម៌ទាំងពួង ជាពហិទ្ធារម្មណ៍ ។*

*ចតុត្ថជ្ឈានដែលឲ្យសម្រេចឥទ្ធិវិធ ឈ្មោះថា* **អជ្ឈត្តារម្មណា** *ព្រោះមានកាយ និងចិត្តរបស់ខ្លួននោះឯងជាអារម្មណ៍ ក្នុងកាលបង្អោនចិត្តទៅដោយអំណាចរបស់កាយខ្លះ ក្នុងកាលបង្អោនកាយទៅ ដោយអំណាចរបស់ចិត្តខ្លះ ជាពហិទ្ធារម្មណ៍ ក្នុងកាលដែលប្រព្រឹត្តទៅដោយន័យថា ភិក្ខុនោះរមែងនិម្មិតនូវរូបដ៏ខាងក្រៅ ដូច្នេះជាដើម ។*

*ចតុត្ថជ្ឈានដែលឲ្យសម្រេចទិព្វសោតញ្ញាណ ជាអជ្ឈត្តារម្មណ៍ ក្នុងកាលដែលភិក្ខុនោះមានសំឡេង ដែលមានក្នុងផ្ទៃរបស់ខ្លួនជាអារម្មណ៍ ជាពហិទ្ធារម្មណ៍ ក្នុងកាលភិក្ខុនោះ មានសំឡេងរបស់អ្នកដទៃជាអារម្មណ៍ ជាអជ្ឈត្តពហិទ្ធារម្មណ៍ ដោយអំណាចមានសំឡេងទាំងពីរជាអារម្មណ៍ ។*

*ចតុត្ថជ្ឈានដែលឲ្យសម្រេចចេតោបរិយញ្ញាណ ជាពហិទ្ធារម្មណ៍*

តែម្យ៉ាង ។

ចតុត្ថជ្ឈានដែលឲ្យសម្រេចបុព្វេនិវាសញ្ញាណ ជាអជ្ឈត្តារម្មណ៍ ក្នុងកាលតាមរឭកដល់ខន្ធរបស់ខ្លួន ជាពហិទ្ធារម្មណ៍ ក្នុងកាលតាមរឭកដល់ខន្ធទាំងឡាយរបស់បុគ្គលដទៃ ក្នុងកាលតាមរឭកដល់ឈ្មោះ និងគោត្រ ។

ចតុត្ថជ្ឈានដែលឲ្យសម្រេចទិព្វចក្ខុញ្ញាណ ជាអជ្ឈត្តារម្មណ៍ ក្នុងកាលដែលមានរូបរបស់ខ្លួនជាអារម្មណ៍ ជាពហិទ្ធារម្មណ៍ ក្នុងកាលមានរូបរបស់បុគ្គលដទៃជាអារម្មណ៍ ជាអជ្ឈត្តពហិទ្ធារម្មណ៍ ដោយអំណាចមានរូបទាំងពីរជាអារម្មណ៍ ។

ចតុត្ថជ្ឈានដែលឲ្យសម្រេចយថាកម្មុបគញ្ញាណ ជាអជ្ឈត្តារម្មណ៍ ក្នុងកាលដឹងកម្មរបស់ខ្លួន ជាពហិទ្ធារម្មណ៍ ក្នុងកាលដឹងកម្មរបស់អ្នកដទៃ ជាអជ្ឈត្តពហិទ្ធារម្មណ៍ ដោយអំណាចនៃកាលដឹងកម្មទាំងពីរ ។

ចតុត្ថជ្ឈានដែលឲ្យសម្រេចអនាគតំសញ្ញាណ ជាអជ្ឈត្តារម្មណ៍ ក្នុងកាលដឹងការកើតឡើងក្នុងអនាគតរបស់ខ្លួន ជាពហិទ្ធារម្មណ៍ ក្នុងកាលតាមរឭកដល់ខន្ធរបស់អ្នកដទៃ និងក្នុងកាលតាមរឭកដល់ឈ្មោះ និងគោត្រ ជាអជ្ឈត្តពហិទ្ធារម្មណ៍ ដោយអំណាចក្នុងកាលតាមដឹងការកើតឡើង និងក្នុងការតាមរឭកទាំងពីរនោះ ។

អាកាសានញ្ចាយតនចតុត្ថជ្ឈាន ជាពហិទ្ធារម្មណ៍ ។

អាកិញ្ចញ្ញាយតនចតុត្ថជ្ឈាន ជានវត្តព្វារម្មណ៍ ។

វិញ្ញាណញ្ចាយតនចតុត្ថជ្ឈាន និងនេវសញ្ញានាសញ្ញាយតន-

ចតុត្ថជ្ឈាន ជាអជ្ឈត្តារម្មណ៍ ។

លោកុត្តរចតុត្ថជ្ឈាន ជាពហិទ្ធារម្មណ៍ប៉ុណ្ណោះ ។

ពោលដោយកិរិយាក្នុងឈានទាំង ១២ ក៏ន័យនេះដូចគ្នា ។

ម្យ៉ាងទៀត ក្នុងឈានវិភង្គនេះ ព្រះសម្ពុទ្ធត្រាស់ឈានទាំងឡាយ ជាមិស្សកៈ គឺជាលោកិយ និងជាលោកុត្តរ ច្នាស់គ្នានោះឯង ក្នុងសុត្តន្តភាជនីយខ្វះ ក្នុងអភិធម្មភាជនីយខ្វះ ក្នុងបញ្ហាបុច្ឆកៈខ្វះ ពិតហើយ ន័យទាំង ៣ នោះ ឈ្មោះថា ឯកបរិច្ឆេទនោះឯង ព្រោះន័យទាំង ៣ នោះ ជាធម៌ដែលលាយឡំគ្នាក្នុងភូមិទាំង ៣ ។ ឈានវិភង្គនេះ ព្រះមានព្រះភាគ ទ្រង់នាំចែកសម្ដែងហើយ ៣ បរិវដ្ដៈ ដូចពណ៌នាមក ដូច្នេះ ។៚

## បញ្ហាបុច្ឆកៈ ចប់

## អដ្ឋកថាឈានវិភង្គ ចប់

# អភិធម្មបិដក

## អប្បមញ្ញាវិភង្គ

[ ៤៩០ ] អប្បមញ្ញា ៤ យ៉ាង ។ គឺភិក្ខុក្នុងសាសនានេះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិស ១ ផ្សាយទៅកាន់ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹង គឺទិសតូច មានចិត្តប្រកបដោយមេត្តា ដ៏ធំទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង ហើយសម្រាកនៅ ១ ។ ភិក្ខុមានចិត្តប្រកបដោយករុណា ផ្សាយទៅកាន់ទិស ១ ផ្សាយទៅកាន់ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹង គឺទិសតូច មានចិត្តប្រកបដោយករុណា ដ៏ធំទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង ហើយសម្រាកនៅ ១ ។ ភិក្ខុមានចិត្តប្រកបដោយមុទិតា ផ្សាយទៅកាន់ទិស ១ ផ្សាយទៅកាន់ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹង គឺទិសតូច មានចិត្តប្រកបដោយមុទិតា ដ៏ធំទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង ហើយសម្រាកនៅ ១ ។ ភិក្ខុមានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិស ១ ផ្សាយទៅកាន់ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិស

ខាងលើ ទិសខាងក្រោម ទិសទទឹង គឺទិសតូច មានចិត្តប្រកបដោយឧបេក្ខា ដ៏ធំទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង ហើយសម្រាកនៅ ១ ។

[ ៤៩១ ] ចុះភិក្ខុមានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិស ១ តើដូចម្តេច ។ បុគ្គលឃើញបុគ្គលម្នាក់ ជាទីស្រឡាញ់ ជាទីពេញចិត្ត គប្បីផ្សាយមេត្តា យ៉ាងណា ភិក្ខុរមែងផ្សាយមេត្តា ចំពោះពួកសត្វទាំងពួង ក៏យ៉ាងនោះឯង ។

[ ៤៩២ ] បណ្តាអប្បមញ្ញាទាំងនោះ មេត្តា តើដូចម្តេច ។ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោវិមុត្តិ ( ការរួចស្រឡះចាកព្យាបាទដោយអំណាចចិត្ត ) ណា ចំពោះពួកសត្វ នេះហៅថា មេត្តា ។ បណ្តាធម៌ទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហទយៈ បណ្ឌរ ( ធម្មជាតដ៏ផូរផង់ ) មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា ចិត្ត ។ ចិត្តនេះ ជាធម្មជាតទៅជាមួយគ្នា កើតជាមួយគ្នា ច្រឡំគ្នា ប្រកបព្រមដោយមេត្តានេះ ព្រោះហេតុនោះ ទើបពោលថា មានចិត្តប្រកបដោយមេត្តា ។ ពាក្យថា ទិស ១ គឺទិសខាងកើតក្តី ទិសខាងលិចក្តី ទិសខាងជើងក្តី ទិសខាងត្បូងក្តី ទិសខាងលើក្តី ទិសខាងក្រោមក្តី ទិសទទឹងក្តី ទិសផ្សេងៗ ក្តី ។ ពាក្យថា ផ្សាយ គឺផ្សាយចិត្តទៅ បញ្ជូនចិត្តទៅ ។

ពាក្យថា សម្រាកនៅ គឺសម្រេចឥរិយាបថ ប្រព្រឹត្ត រក្សា រស់នៅ ញុំាងជីវិតឲ្យរស់នៅ ត្រាច់ទៅ សម្រាន្តនៅ ព្រោះហេតុនោះ ទើបពោលថា សម្រាកនៅ ។ ពាក្យថា ទិសទី ២ ក៏ដូចគ្នា គឺផ្សាយចិត្តទៅកាន់ទិស ១ យ៉ាងណា ផ្សាយចិត្តទៅកាន់ទិសទី ២ ទិសទី ៣ ទិសទី ៤ ទិសខាងលើ ទិសខាងក្រោម ទិសទទឹង ទិសផ្សេងៗ ក៏យ៉ាងនោះដែរ ។ ពាក្យថា ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង មានសេចក្តីថា ពាក្យថា ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង នុ៎ះជាពាក្យរួបរួមសត្វទាំងពួង ទាំងអស់ រាល់រូប គ្រប់រូប មិនមានសល់ ឥតសេសសល់ ។ ពាក្យថា មានចិត្តប្រកបដោយមេត្តា សេចក្តីថា បណ្តាអប្បមញ្ញាទាំងនោះ មេត្តា តើដូចម្តេច ។ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោវិមុត្តិណា ចំពោះពួកសត្វ នេះហៅថា មេត្តា ។ បណ្តាធម៌ទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាជ្ញា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា ចិត្ត ។ ចិត្តនេះ ជាធម្មជាតទៅជាមួយគ្នា កើតជាមួយគ្នា ច្រឡំគ្នា ប្រកបព្រមដោយមេត្តានេះ ព្រោះហេតុនោះ ទើបពោលថា មានចិត្តប្រកបដោយមេត្តា ។ ពាក្យថា ទូលាយ គឺគុណជាតណាដ៏ទូលាយ គុណជាតនោះ ដល់នូវភាពជាធំ គុណជាតណា ដល់នូវភាពជាធំ គុណជាតនោះ មិនមានប្រមាណ គុណជាតណា មិនមានប្រមាណ សភាវៈនោះ មិនមានពៀរ

សភាវៈណា មិនមានពៀរ សភាវៈនោះ មិនមានព្យាបាទ ។ ពាក្យថា ផ្សាយ គឺផ្សាយចិត្តទៅ បញ្ជូនចិត្តទៅ ។ ពាក្យថា សម្រាកនៅ គឺសម្រេចឥរិយាបថ ។បេ។ សម្រាន្តនៅ ព្រោះហេតុនោះ ទើបពោលថា សម្រាកនៅ ។

[ ៤៩៣ ] ចុះភិក្ខុមានចិត្តប្រកបដោយករុណា ផ្សាយទៅកាន់ទិស ១ តើដូចម្តេច ។ បុគ្គលឃើញបុគ្គលម្នាក់ ជាអ្នកក្រីក្រ ដល់នូវសេចក្តីលំបាក ហើយផ្សាយករុណា យ៉ាងណា ភិក្ខុផ្សាយករុណា ចំពោះពួកសត្វទាំងពួង ក៏យ៉ាងនោះឯង ។

[ ៤៩៤ ] បណ្តាធម៌ទាំងនោះ ករុណា តើដូចម្តេច ។ ការអាណិត អាការអាណិត ភាពនៃការអាណិត ការអាណិតអាសូរ ចេតោវិមុត្តិណា ចំពោះពួកសត្វ នេះហៅថា ករុណា ។ បណ្តាធម៌ទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា ចិត្ត ។ ចិត្តនេះ ជាធម្មជាតទៅជាមួយគ្នា កើតជាមួយគ្នា ច្រឡំគ្នា ប្រកបព្រមដោយករុណានេះ ព្រោះហេតុនោះ ទើបពោលថា មានចិត្តប្រកបដោយករុណា ។ ពាក្យថា ទិស ១ គឺទិសខាងកើតក្តី ទិសខាងលិចក្តី ទិសខាងជើងក្តី ទិសខាងត្បូងក្តី ទិសខាងលើក្តី ទិសខាងក្រោមក្តី ទិសទទឹងក្តី ទិសផ្សេងៗ ក្តី ។ ពាក្យថា ផ្សាយ គឺផ្សាយចិត្តទៅ បញ្ជូនចិត្តទៅ ។ ពាក្យថា សម្រាកនៅ គឺសម្រេចឥរិយាបថ ប្រព្រឹត្ត រក្សា រស់នៅ ញុំាងជីវិតឲ្យរស់នៅ ត្រាច់ទៅ សម្រាន្តនៅ ព្រោះហេតុនោះ ទើបពោលថា សម្រាកនៅ ។ ពាក្យថា ទិសទី ២ ក៏ដូចគ្នា

គឺផ្សាយចិត្តទៅកាន់ទិស ១ យ៉ាងណា ផ្សាយចិត្តទៅកាន់ទិសទី ២ ទិសទី ៣ ទិសទី ៤ ទិសខាងលើ ទិសខាងក្រោម ទិសទទឹង ទិសផ្សេងៗ ក៏យ៉ាងនោះដែរ ។ ពាក្យថា ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វលោកទាំងអស់ ក្នុងទីទាំងពួង មានសេចក្តីថា ពាក្យថា ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង នុ៎ះជាពាក្យប្រមូលសត្វទាំងពួង ទាំងអស់ រាល់រូបគ្រប់រូប មិនមានសល់ ឥតសេសសល់ ។ ពាក្យថា មានចិត្តប្រកបដោយករុណា សេចក្តីថា បណ្តាអប្បមញ្ញាទាំងនោះ ករុណា តើដូចម្តេច ។ ការអាណិត អាការអាណិត ភាពនៃការអាណិត ការអាណិតអាសូរ ចេតោវិមុត្តិណា ចំពោះពួកសត្វ នេះហៅថា ករុណា ។ បណ្តាធម៌ទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា ចិត្ត ។ ចិត្តនេះ ជាធម្មជាតទៅជាមួយគ្នា កើតជាមួយគ្នា ច្រឡំគ្នា ប្រកបព្រមដោយករុណានេះ ព្រោះហេតុនោះ ទើបពោលថា មានចិត្តប្រកបដោយករុណា ។ ពាក្យថា ទូលាយ គឺគុណជាតណាដ៏ទូលាយ គុណជាតនោះ ដល់នូវភាពជាធំ គុណជាតណា ដល់នូវភាពជាធំ គុណជាតនោះ មានប្រមាណមិនបាន គុណជាតណា មិនមានប្រមាណ សភាវៈនោះ មិនមានពៀរ សភាវៈណា មិនមានពៀរ សភាវៈនោះ មិនមានព្យាបាទ ។ ពាក្យថា ផ្សាយ គឺផ្សាយចិត្តទៅ បញ្ជូនចិត្តទៅ ។ ពាក្យថា សម្រាកនៅ គឺសម្រេចឥរិយាបថ ។បេ។ សម្រាន្តនៅ ព្រោះហេតុ

នោះ ទើបពោលថា សម្រាកនៅ ។

[ ៤៩៥ ] ចុះភិក្ខុ មានចិត្តប្រកបដោយមុទិតា ផ្សាយទៅកាន់ទិស ១ តើដូចម្តេច ។ បុគ្គលឃើញបុគ្គលម្នាក់ ជាទីស្រឡាញ់ ជាទីពេញចិត្ត ហើយជាអ្នករីករាយ យ៉ាងណា ភិក្ខុផ្សាយមុទិតា ចំពោះពួកសត្វទាំងពួង ក៏យ៉ាងនោះឯង ។

[ ៤៩៦ ] បណ្តាអប្បមញ្ញាទាំងនោះ មុទិតា តើដូចម្តេច ។ ការរីករាយ អាការរីករាយ ភាពនៃការរីករាយ ការស្រស់ស្រាយ ចេតោវិមុត្តិណា ចំពោះពួកសត្វ នេះហៅថា មុទិតា ។ បណ្តាធម៌ទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណណា នេះហៅថា ចិត្ត ។ ចិត្តនេះ ជាធម្មជាតទៅជាមួយគ្នា កើតជាមួយគ្នា ប្រឡំគ្នា ប្រកបព្រមដោយមុទិតានេះ ព្រោះហេតុនោះ ទើបពោលថា មានចិត្តប្រកបដោយមុទិតា ។ ពាក្យថា ទិស ១ គឺទិសខាងកើតក្តី ទិសខាងលិចក្តី ទិសខាងជើងក្តី ទិសខាងត្បូងក្តី ទិសខាងលើក្តី ទិសខាងក្រោមក្តី ទិសទទឹងក្តី ទិសផ្សេងៗ ក្តី ។ ពាក្យថា ផ្សាយ គឺផ្សាយចិត្តទៅ បញ្ជូនចិត្តទៅ ។ ពាក្យថា សម្រាកនៅ គឺសម្រេចឥរិយាបថ ។បេ។ សម្រាន្តនៅ ព្រោះហេតុនោះ ទើបពោលថា សម្រាកនៅ ។ ពាក្យថា ទិសទី ២ ក៏ដូចគ្នា គឺផ្សាយចិត្តទៅកាន់ទិស ១ យ៉ាងណា ផ្សាយចិត្តទៅកាន់ទិសទី ២ ទិសទី ៣ ទិសទី ៤ ទិសខាងលើ ទិសខាងក្រោម ទិសទទឹង ទិសផ្សេងៗ ក៏យ៉ាងនោះដែរ ។ ពាក្យថា ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការ

យកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង មានសេចក្តីថា ពាក្យថា ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង នុ៎ះជាពាក្យប្រមូលសត្វទាំងពួង ទាំងអស់ រាល់រូប គ្រប់រូប មិនមានសល់ ឥតសេសសល់ ។ ពាក្យថា មានចិត្តប្រកបដោយមុទិតា សេចក្តីថា បណ្តាអប្បមញ្ញាទាំងនោះ មុទិតា តើដូចម្តេច ។ ការរីករាយ អាការរីករាយ ភាពនៃការរីករាយ ការស្រស់ស្រាយ ចេតោវិមុត្តិណា ចំពោះពួកសត្វ នេះហៅថា មុទិតា ។ បណ្តាធម៌ទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា ចិត្ត ។ ចិត្តនេះ ជាធម្មជាតទៅជាមួយគ្នា កើតជាមួយគ្នា ច្រឡំគ្នា ប្រកបព្រមដោយមុទិតានេះ ព្រោះហេតុនោះ ទើបពោលថា មានចិត្តប្រកបដោយមុទិតា ។ ពាក្យថា ទូលាយ គឺគុណជាតណាដ៏ទូលាយ គុណជាតនោះ ដល់នូវភាពជាធំ គុណជាតណា ដល់នូវភាពជាធំ គុណជាតនោះ មិនមានប្រមាណ គុណជាតណា មិនមានប្រមាណ សភាវៈនោះ មិនមានពៀរ សភាវៈណា មិនមានពៀរ សភាវៈនោះ មិនមានព្យាបាទ ។ ពាក្យថា ផ្សាយ គឺផ្សាយចិត្តទៅ បញ្ជូនចិត្តទៅ ។ ពាក្យថា សម្រាកនៅ គឺសម្រេចឥរិយាបថ ។បេ។ សម្រាន្តនៅ ព្រោះហេតុនោះ ទើបពោលថា សម្រាកនៅ ។

[ ៤៩៧ ] ចុះភិក្ខុ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិស ១ តើដូចម្តេច ។ បុគ្គលឃើញបុគ្គលម្នាក់ ជាទីពេញចិត្តក៏មិនមែន មិនជាទីពេញ

ចិត្តក៏មិនមែន ហើយជាអ្នកព្រងើយកន្តើយ យ៉ាងណា ភិក្ខុផ្សាយឧបេក្ខា ចំពោះសត្វទាំងពួង យ៉ាងនោះឯង ។

[ ៤៩៨ ] បណ្តាអប្បមញ្ញាទាំងនោះ ឧបេក្ខា តើដូចម្តេច ។ ការព្រងើយ អាការព្រងើយ ភាពនៃការព្រងើយ ការគោះគើយ ចេតោវិមុត្តិណា ចំពោះពួកសត្វ នេះហៅថា ឧបេក្ខា ។ បណ្តាធម៌ទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា ចិត្ត ។ ចិត្តនេះ ជាធម្មជាតទៅជាមួយគ្នា កើតជាមួយគ្នា ច្រឡំគ្នា ប្រកបព្រមដោយឧបេក្ខានេះ ព្រោះហេតុនោះ ទើបពោលថា មានចិត្តប្រកបដោយឧបេក្ខា ។ ពាក្យថា ទិស ១ គឺទិសខាងកើតក្តី ទិសខាងលិចក្តី ទិសខាងជើងក្តី ទិសខាងត្បូងក្តី ទិសខាងលើក្តី ទិសខាងក្រោមក្តី ទិសទទឹងក្តី ទិសផ្សេងៗ ក្តី ។ ពាក្យថា ផ្សាយ គឺផ្សាយចិត្តទៅ បញ្ជូនចិត្តទៅ ។ ពាក្យថា សម្រាកនៅ គឺសម្រេចឥរិយាបថ ។បេ។ សម្រាន្តនៅ ព្រោះហេតុនោះ ទើបពោលថា សម្រាកនៅ ។ ពាក្យថា ទិសទី ២ ក៏ដូចគ្នា គឺផ្សាយចិត្តទៅកាន់ទិស ១ យ៉ាងណា ទិសទី ២ ទិសទី ៣ ទិសទី ៤ ទិសខាងលើ ទិសខាងក្រោម ទិសទទឹង ឬទិសផ្សេងៗ ក៏យ៉ាងនោះដែរ ។ ពាក្យថា ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង មានសេចក្តីថា ពាក្យថា ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង នុ៎ះជាពាក្យរួបរួមសត្វទាំងពួងទាំងអស់ រាល់រូប គ្រប់រូប មិនសល់

ឥតសេសសល់ ។ ពាក្យថា មានចិត្តប្រកបដោយឧបេក្ខា សេចក្តីថា បណ្តា អប្បមញ្ញាទាំងនោះ ឧបេក្ខា តើដូចម្តេច ។ ការព្រងើយ អាការព្រងើយ ភាពនៃការព្រងើយ ការតោះតើយ ចេតោវិមុត្តិណា ចំពោះពួកសត្វ នេះហៅថា ឧបេក្ខា ។ បណ្តាធម៌ទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា ចិត្ត ។ ចិត្តនេះ ជាធម្មជាតទៅជាមួយគ្នា កើតជាមួយគ្នា ច្រឡំគ្នា ប្រកបព្រមដោយឧបេក្ខានេះ ព្រោះហេតុនោះ ទើបពោលថា មានចិត្តប្រកបដោយឧបេក្ខា ។ ពាក្យថា ទូលាយ គឺគុណជាតណាដ៏ទូលាយ គុណជាតនោះ ដល់នូវភាពជាធំ គុណជាតណា ដល់នូវភាពជាធំ គុណជាតនោះ មិនមានប្រមាណ គុណជាតណា មិនមានប្រមាណ សភាវៈនោះ មិនមានពៀរ សភាវៈណា មិនមានពៀរ សភាវៈនោះ មិនមានព្យាបាទ ។ ពាក្យថា ផ្សាយ គឺផ្សាយចិត្តទៅ បញ្ជូនចិត្តទៅ ។ ពាក្យថា សម្រាកនៅ គឺសម្រេចឥរិយាបថ ។បេ។ សម្រាន្តនៅ ព្រោះហេតុនោះ ទើបពោលថា សម្រាកនៅ ។

សុត្តន្តភាជនីយ ចប់

# អដ្ឋកថា

# អប្បមញ្ញាវិភង្គ

## សុត្តន្តភាជនីយ

[ ៩៩០-៩៩៨ ] ឥឡូវនេះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងអប្បមញ្ញា-វិភង្គ ក្នុងលំដាប់នៃឈានវិភង្គនោះដូចតទៅ

បទថា **ចតស្សោ** ជាពាក្យកំណត់ចំនួន ។ បទថា **អប្បមញ្ញាយោ** បានដល់ ឈ្មោះថា អប្បមញ្ញាទាំងឡាយ ព្រោះអំណាចនៃការផ្សាយទៅមិនមានប្រមាណ ។ ពិតហើយ អប្បមញ្ញាទាំងនោះ រមែងផ្សាយទៅកាន់សត្វទាំងឡាយ មិនមានប្រមាណ ដោយអំណាចនៃអារម្មណ៍ ឬរមែងផ្សាយទៅកាន់សត្វសូម្បីមួយ ដោយអំណាចនៃការផ្សាយទៅ ដែលមិនមានចំណែកសេសសល់ ព្រោះហេតុនោះ ទើបខ្ញុំពោលថា ឈ្មោះថា អប្បមញ្ញា ព្រោះអំណាចនៃការផ្សាយទៅ មិនមានប្រមាណ ។ បទថា **ឥធ ភិក្ខុ** បានដល់ ភិក្ខុក្នុងសាសនានេះ ។ បទថា **មេត្តាសហគតេន** បានដល់ ប្រកបដោយមេត្តា ។ បទថា **ចេតសា** បានដល់ ដោយចិត្ត ។ បទថា **ឯកំ ទិសំ** បានដល់ ទិសមួយ ។ ពាក្យនេះ ព្រះមានព្រះភាគត្រាស់សំដៅយកសត្វ ដែលភិក្ខុកំណត់ដំបូងដោយអំណាចនៃការផ្សាយទៅកាន់សត្វ ដែលទាក់ទងដោយទិសមួយ ។

បទថា **ផរិត្វា** បានដល់ ពាល់ត្រូវហើយ គឺធ្វើឲ្យជាអារម្មណ៍ ។ បទថា **វិហរតិ** បានដល់ ឲ្យវិហារធម៌ប្រព្រឹត្តទៅក្នុងឥរិយាបថ ដែលខ្ជួនតាំងមាំហើយ ដោយព្រហ្មវិហារ ។ បទថា **តថា ទុតិយំ** អធិប្បាយថា រមែងផ្សាយទៅកាន់សត្វក្នុងទិសទាំងឡាយ មានទិសខាងកើតជាដើម ទិសណាមួយ ក្នុងទិសទី ២ ទិសទី ៣ ទិសទី ៤ ដោយលំដាប់ ក៏យ៉ាងនោះដូចគ្នា ។ បទថា **ឥតិ ឧទ្ធំ** មានពាក្យអធិប្បាយថា ទិសខាងលើ ក៏ន័យនេះដូចគ្នា ។ បទថា **អធោ តិរិយំ** បានដល់ ទិសខាងក្រោមក្តី ទិសទទឹងក្តី គប្បីផ្សាយមេត្តាទៅយ៉ាងនោះឯង ។ម្យ៉ាងទៀត ក្នុងពាក្យថា ទិសខាងលើ ទិសខាងក្រោម បទថា **អធោ** នេះ បានដល់ ទិសខាងក្រោម ។ បទថា **តិរិយំ** បានដល់ ទិសតូច អធិប្បាយថា ភិក្ខុញ៉ាំងចិត្ត ដែលសហគតៈដោយមេត្តាឲ្យផ្សាយទៅខ្លះ ឲ្យស្ទុះត្រឡប់មកខ្លះ ក្នុងទិសទាំងពួង ដោយអាការយ៉ាងនេះ ប្រៀបដូចសារថីឲ្យសេះស្ទុះទៅមកក្នុងទីលានសេះ ព្រោះហេតុនោះទើបព្រះមានព្រះភាគទ្រង់សម្តែងការកំណត់ទិសនីមួយៗ ហើយផ្សាយដោយចំពោះ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។ បទថា **សព្វធិ** ជាដើម ត្រាស់ដើម្បីសម្តែងការផ្សាយទៅដោយមិនចំពោះ ។

ក្នុងបទទាំងនោះ បទថា **សព្វធិ** បានដល់ ក្នុងសត្វលោកទាំងពួង ។ បទថា **សព្វត្តតាយ** មានពាក្យអធិប្បាយថា ព្រោះជាអ្នកមានចិត្តស្មើគ្នាដោយមិនធ្វើការបែងចែកក្នុងសត្វទាំងពួង មានសត្វថោកទាប កណ្តាលខ្ពង់ខ្ពស់ មិនមែនជាមិត្ត មិនមែនជាសត្រូវជាដើម ចាកភាពជាដើមថា

នេះជាសត្វដទៃ ។

ម្យ៉ាងទៀត បទថា **សព្វត្តតាយ** នេះ បានដល់ មានចិត្តទាំងអស់ មិនរាយមាយទៅខាងក្រៅ សូម្បីបន្តិចបន្តួច ។ បទថា **សព្វាវន្តំ** បានដល់ មានសត្វទាំងពួង អធិប្បាយថា ប្រកបដោយសត្វលោកទាំងពួង ។ បទថា **លោកំ** បានដល់ លោក គឺពួកសត្វ ។ ក្នុងអធិការនេះ ទ្រង់ត្រាស់ថា មានមេត្តាដដែលទៀត ព្រោះសម្តែងដោយអមយ៉ាងនេះថា **វិបុលេន** ជាដើម ។ ម្យ៉ាងទៀត សព្ទថា **តថា** ក្តី **ឥតិ** ក្តី ព្រះមានព្រះភាគមិនបានត្រាស់ដដែល ក្នុងការផ្សាយទៅដោយមិនចំពោះនេះ ដូចត្រាស់ក្នុងការផ្សាយមេត្តាចិត្តទៅដោយចំពោះ ព្រោះហេតុនោះ ទើបត្រាស់ថា **មេត្តា-សហគតេន ចេតសា** ដដែលទៀត ។ ម្យ៉ាងទៀត បទថា **មេត្តាសហ-គតេន ចេតសា** នេះ ត្រាស់ដោយអំណាចនៃពាក្យនិគម គឺពាក្យដែលត្រាស់សរុបសេចក្តី ។

ម្យ៉ាងទៀត ក្នុងបទថា **វិបុលេន** នេះ បណ្ឌិតគប្បីជ្រាបភាពដែលមេត្តាបរិបូណ៌ដោយអំណាចនៃការផ្សាយទៅ ។ មេត្តាចិត្តនោះ ជាចិត្តទូលាយដោយអំណាចភូមិ ។ មេត្តាចិត្តនោះ ជាចិត្តមិនមានប្រមាណ ដោយអំណាចនៃការធ្វើឲ្យស្ទាត់ជំនាញ និងគប្បីជ្រាបថា ជាចិត្តមិនមានប្រមាណ ដោយអំណាចនៃការធ្វើសត្វឲ្យជាអារម្មណ៍ ។ មេត្តាចិត្តនោះ ជាចិត្តមិនមានពៀរ ព្រោះលះនូវធម៌ដែលជាសត្រូវ គឺការបៀតបៀន ។ មេត្តាចិត្តនោះ ជាចិត្តមិនមានព្យាបាទ ព្រោះលះទោមនស្ស អធិប្បាយថា ជាចិត្តមិនមានទុក្ខ ដូច្នេះ ។

អត្ថដែលបានពណ៌នានេះ ជាអត្ថនៃមាតិកាដែលព្រះមានព្រះភាគទ្រង់តាំងដោយន័យថា **មេត្តាសហគតេន ចេតសា** ជាដើមប្រមាណប៉ុណ្ណោះ ។

ឥឡូវនេះ ក្នុងបទភាជនីយ ដែលព្រះមានព្រះភាគត្រាស់ដោយន័យថា **កថញ្ច ភិក្ខវេ មេត្តាសហគតេន ចេតសា** ជាដើម ព្រោះកម្មដ្ឋាននេះជាសប្បាយដល់បុគ្គលដែលជាទោសចរិត ព្រោះហេតុនោះ មេត្តានេះដល់អប្បនា ព្រោះបុគ្គលបែបណា ដើម្បីសម្តែងបុគ្គលបែបនោះ ដែលជាទីតាំងនៃមេត្តា ទើបព្រះមានព្រះភាគត្រាស់ថា **សេយ្យថាបិ នាម ឯកំ បុគ្គលំ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **សេយ្យថាបិ នាម** ជានិបាត ចុះក្នុងអត្ថនៃឧបមា អធិប្បាយថា ប្រៀបដូច ... បុគ្គលណាម្នាក់ ។ បទថា **បិយំ** បានដល់ ជាទីតាំងនៃការស្រឡាញ់ ។ បទថា **មនាបំ** បានដល់ បុគ្គលអ្នកធ្វើសេចក្តីចម្រើនឲ្យដល់ហទយៈ ។

ក្នុងបុគ្គលទាំងនោះ ឈ្មោះថា **បិយំ** ព្រោះធ្លាប់នៅរួមគ្នាក្នុងកាលមុន ឬព្រោះមានឧបការៈដល់គ្នានិងគ្នាក្នុងបច្ចុប្បន្ន ។ ឈ្មោះថា **មនាបំ** ព្រោះប្រកបដោយសីលគុណជាដើម ។

ម្យ៉ាងទៀត គប្បីជ្រាបភាពជាទីស្រឡាញ់ ព្រោះទាន និងសមានត្តតា គប្បីជ្រាបភាពជាទីពេញចិត្ត ព្រោះបិយវាចា និងអត្ថចរិយា ។

ក្នុងទីនេះ ការលះព្យាបាទរបស់បុគ្គលនោះ រមែងមានព្រោះភាពដែលបុគ្គលនោះ ជាបុគ្គលជាទីស្រឡាញ់ បន្ទាប់អំពីនោះ មេត្តាក៏រមែងផ្សាយទៅ

*បានដោយងាយ ការព្រងើយ រមែងមិនតាំងនៅ ព្រោះភាពជាអ្នកពេញចិត្ត ហិរិឱត្តប្បៈ រមែងតាំងឡើងបន្ទាប់អំពីនោះ មេត្តា ហិរិ ឱត្តប្បៈ តាមរក្សាហើយ រមែងមិនវិនាស ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ធ្វើបុគ្គលឲ្យជាឧបមាហើយ ទើបត្រាស់ពាក្យនេះថា* **បិយំ មនាបំ** *ដូច្នេះ ។*

*បទថា* **មេត្តាយេយ្យ** *បានដល់ គប្បីផ្សាយមេត្តាទៅ អធិប្បាយថា គប្បីធ្វើមេត្តា គឺគប្បីញ៉ាំងមេត្តាឲ្យប្រព្រឹត្តទៅក្នុងបុគ្គលនោះ ។ បទថា* **ឯវមេវ សព្វេ សត្តេ** *អធិប្បាយថា គប្បីផ្សាយមេត្តាទៅកាន់បុគ្គលជាទីស្រឡាញ់ យ៉ាងណា រមែងផ្សាយមេត្តាដែលដល់អប្បនា ដែលចូលដល់ភាពជាវសីក្នុងបុគ្គលនោះ ទៅកាន់សត្វទាំងពួង សូម្បីជាកណ្តាល និងជាអ្នកមានពៀរដោយលំដាប់ ក៏យ៉ាងនោះ ។*

*បទថា* **មេត្តិ មេត្តាយនា** *ជាដើម មានអត្ថដូចពោលហើយនោះឯង ។ បទថា* **វិទិសំ វា** *ជាពាក្យដែលព្រះមានព្រះភាគត្រាស់ហើយ ដើម្បីឲ្យអត្ថនៃបទថា* **តិរិយំ វា** *នេះជាក់ច្បាស់ ។*

*បទថា* **ផរិត្វា** *បានដល់ ពាល់ត្រូវហើយ ដោយអំណាចធ្វើឲ្យជាអារម្មណ៍ ។ បទថា* **អធិមុញ្ចិត្វា** *បានដល់ បង្អោនទៅ ដោយភាពជាចិត្តដែលក្រៃលែង អធិប្បាយថា បង្អោនទៅហើយ ឱនទៅល្អហើយ បញ្ជូនទៅល្អហើយ ឲ្យផ្សាយទៅហើយដោយល្អ យ៉ាងណា បង្អោនចិត្តទៅហើយ ក៏យ៉ាងនោះ ។*

*ក្នុងនិទ្ទេសនៃបទថា* **សព្វធិ** *ជាដើម បទទាំង ៣ នេះ សង្គ្រោះក្នុង*

សត្វទាំងពួង ព្រោះហេតុនោះ ដើម្បីសម្តែងអត្ថនៃបទទាំងនោះ ដោយភាពតែមួយ ទើបត្រាស់ថា **សព្វេន សព្វំ** ជាដើម ។ អត្ថនៃបទទាំងនោះ ខ្ញុំពោលហើយនោះឯង ។

ក្នុងនិទ្ទេសនៃបទថា **វិបុលា** ជាដើម ក៏ព្រោះមេត្តាចិត្តណា ជាធម្មជាតដល់អប្បនា ជាចិត្តបរិបូណ៌ដោយអំណាចផ្សាយទៅកាន់សត្វមិនមានទីបំផុត ចិត្តនោះ ឈ្មោះថា ជាចិត្តទូលាយ ដោយអំណាចនៃភូមិដោយកំណត់ ។ ចិត្តណា ជាចិត្តទូលាយ ចិត្តនោះ ឈ្មោះថា ជាចិត្តមិនមានប្រមាណ ដោយអំណាចនៃអារម្មណ៍មិនមានប្រមាណ ។ ចិត្តណា ប្រមាណមិនបាន ចិត្តនោះ ឈ្មោះថា មិនមានពៀរ ដោយអំណាចការទម្លាយកិលេស ដែលធ្វើឲ្យជាសត្រូវចំពោះគ្នា ចិត្តណា មិនមានពៀរ ចិត្តនោះ ឈ្មោះថា មិនមានព្យាបាទ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **យំ វិបុលំ តំ មហគ្គតំ** ជាដើម ។

ម្យ៉ាងទៀត ក្នុងបទថា **អវេរោ អព្យាបជ្ឈោ** នេះ ទ្រង់ត្រាស់ដោយបរិយាយនៃលិង្គវិបល្លាស ។ ម្យ៉ាងទៀត ទ្រង់ប្រើសព្ទថា **អវេរោ អព្យា-បជ្ឈោ** នេះ ចូលជាមួយ **មនោ** សព្ទ ដូចចិត្តណាមិនមានប្រមាណ **មន** គឺចិត្តនោះ ឈ្មោះថា មិនមានពៀរ ចិត្តណា មិនមានពៀរ ចិត្តនោះ ឈ្មោះថា មិនមានព្យាបាទ ដូច្នេះ ។

ម្យ៉ាងទៀត ក្នុងពាក្យថា **យំ វិបុលំ តំ មហគ្គតំ** ជាដើមនេះ បណ្ឌិតគប្បីជ្រាបថា បទក្រោយៗ អធិប្បាយបទមុនៗ ឬថា បទមុនៗ អធិប្បាយ

បទក្រោយៗ ដូច្នេះក៏បាន ។

បទថា **សេយ្យថាបិ ឆាមំ ឯកំ បុគ្គលំ ទុគ្គតំ ទុរូបេតំ** នេះ ព្រះមានព្រះភាគត្រាស់ដើម្បីសម្តែងបុគ្គល ដែលជាទីតាំងនៃករុណា ។ ពិតហើយ ភាពនៃករុណាដែលមានកម្លាំង រមែងកើតក្នុងបុគ្គលបែបនេះ ។

ក្នុងបទទាំងនោះ បទថា **ទុគ្គតំ** បានដល់ ដល់នូវការដល់ព្រមដោយទុក្ខ ។ បទថា **ទុរូបេតំ** បានដល់ ដែលប្រកបដោយកាយទុច្ចរិតជាដើម ។ម្យ៉ាងទៀត គប្បីជ្រាបអត្ថក្នុងសេចក្តីនោះថា បុគ្គលតាំងនៅក្នុងភាពជាបុគ្គលងងឹត ដោយអំណាចនៃគតិវិបត្តិ ត្រកូលវិបត្តិ ភោគវិបត្តិជាដើម ឈ្មោះថាទុគ្គតៈ បុគ្គលតាំងនៅក្នុងភាពជាអ្នកងងឹតក្នុងភពខាងមុខ ព្រោះប្រកបដោយទុច្ចរិតជាដើម ឈ្មោះថា **ទុរូបេត** ។

បទថា **ឯកំ បុគ្គលំ បិយំ មនាបំ** នេះ ព្រះមានព្រះភាគត្រាស់ដើម្បីសម្តែងបុគ្គលដែលជាទីតាំងនៃមុទិតា ។ ក្នុងសេចក្តីនេះ គប្បីជ្រាបថាបុគ្គលដែលតាំងនៅក្នុងភាពជាអ្នករុងរឿង ដោយអំណាចនៃគតិសម្បត្តិត្រកូលសម្បត្តិ និងភោគសម្បត្តិជាដើម ឈ្មោះថា **បិយ** ។ បុគ្គលដែលតាំង

*នៅក្នុងកាលុងវៀង ក្នុងកពខាងមុខ ព្រោះខ្លួនប្រកបកាយសុចរិតជាដើម ឈ្មោះថា* **មនាប** ។

*បទថា* **នេវ មនាបំ ន អមនាបំ** *នេះ ព្រះសាស្តាត្រាស់ដើម្បីសម្តែងបុគ្គលដែលជាទីតាំងនៃឧបេក្ខា ។ ក្នុងសេចក្តីនេះ គប្បីជ្រាបថា ឈ្មោះថា* **នេវ មនាបោ** *ព្រោះខ្លួនមិនមែនដល់ព្រមដោយភាពជាមិត្ត ។ ឈ្មោះថា* **ន អមនាបោ** *ព្រោះខ្លួនមិនមែនដល់ព្រមដោយភាពជាអមិត្ត ។ ពាក្យណា នៅសេសសល់ ដែលគប្បីពោលក្នុងទីនេះ ពាក្យទាំងអស់ ខ្ញុំពោលហើយក្នុងចិត្តុប្បាទកណ្ឌខាងដើមនោះឯង ។*

*សូម្បីវិធីចម្រើនការនារបស់កម្មដ្ឋានទាំងនេះ ខ្ញុំក៏បានពោលហើយដោយពិស្តារ ក្នុងវិសុទ្ធិមគ្គនោះឯង ។៚*

## អដ្ឋកថាសុត្តន្តភាជនីយ ចប់

# អភិធម្មបិដក

## អភិធម្មភាជនីយ

[ ៤៩៩ ] អប្បមញ្ញា ៤ យ៉ាង គឺមេត្តា ១ ករុណា ១ មុទិតា ១ ឧបេក្ខា ១ ។

[ ៥០០ ] បណ្តាអប្បមញ្ញាទាំងនោះ មេត្តា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ប្រកបដោយមេត្តា ក្នុងសម័យនោះ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោវិមុត្តិណា នេះហៅថា មេត្តា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមេត្តា ។ បណ្តាអប្បមញ្ញាទាំងនោះ មេត្តា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់នូវវិតក្ក និងវិចារ ។បេ។ ចូលកាន់ទុតិយជ្ឈាន ប្រកបដោយមេត្តា ក្នុងសម័យនោះ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោវិមុត្តិណា នេះហៅថា មេត្តា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមេត្តា ។ បណ្តាអប្បមញ្ញាទាំងនោះ មេត្តា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះនឿយណាយចាកបីតិផង ។បេ។ ចូលកាន់តតិយជ្ឈាន ប្រកបដោយមេត្តា ក្នុងសម័យនោះ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោវិមុត្តិណា នេះហៅថា មេត្តា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមេត្តា ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព

ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ប្រកបដោយមេត្តា ក្នុងសម័យនោះ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោវិមុត្តិណា នេះហៅថា មេត្តា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមេត្តា ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ចូលកាន់ទុតិយជ្ឈាន មិនមានវិតក្ក មានត្រឹមតែវិចារ មានបីតិនិងសុខកើតក្នុងវិវេក ប្រកបដោយមេត្តា ក្នុងសម័យនោះ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោវិមុត្តិណា នេះហៅថា មេត្តា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមេត្តា ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់នូវវិតក្ក និងវិចារ ។បេ។ ចូលកាន់តតិយជ្ឈាន ប្រកបដោយមេត្តា ក្នុងសម័យនោះ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោ-វិមុត្តិណា នេះហៅថា មេត្តា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមេត្តា ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះនឿយណាយចាកបីតិផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ប្រកបដោយមេត្តា ក្នុងសម័យនោះ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោវិមុត្តិណា នេះហៅថា មេត្តា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមេត្តា ។

[ ៥០១ ] បណ្ដាអប្បមញ្ញាទាំងនោះ ករុណា តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាម

ទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ប្រកបដោយករុណា ក្នុងសម័យនោះ ការអាណិត អាការអាណិត ភាពនៃការអាណិត ការអាណិតអាសូរ ចេតោ-វិមុត្តិណា នេះហៅថា ករុណា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយករុណា ។ បណ្តាអប្បមញ្ញាទាំងនោះ ករុណា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់វិតក្ក និងវិចារ ។បេ។ ចូលកាន់ទុតិយជ្ឈាន ប្រកបដោយករុណា ក្នុងសម័យនោះ ការអាណិត អាការអាណិត ភាពនៃការអាណិត ការអាណិតអាសូរ ចេតោវិមុត្តិណា នេះហៅថា ករុណា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយករុណា ។ បណ្តាអប្បមញ្ញាទាំងនោះ ករុណា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះនឿយណាយចាកបីតិផង ។បេ។ ចូលកាន់តតិយជ្ឈាន ប្រកបដោយករុណា ក្នុងសម័យនោះ ការអាណិត អាការអាណិត ភាពនៃការអាណិត ការអាណិតអាសូរ ចេតោវិមុត្តិណា នេះហៅថា ករុណា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយករុណា ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ប្រកបដោយករុណា ក្នុងសម័យនោះ ការអាណិត អាការអាណិត ភាពនៃការអាណិត ការអាណិតអាសូរ ចេតោវិមុត្តិណា នេះហៅថា ករុណា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយករុណា ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ចូលកាន់

ទុតិយជ្ឈាន មិនមានវិតក្ក មានត្រឹមតែវិចារ មានបីតិ និងសុខ កើតក្នុងវិវេក ប្រកបដោយករុណា ក្នុងសម័យនោះ ការអាណិត អាការអាណិត ភាពនៃការអាណិត ការអាណិតអាសូរ ចេតោវិមុត្តិណា នេះហៅថា ករុណា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយករុណា ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់វិតក្ក និងវិចារ ។បេ។ ចូលកាន់តតិយជ្ឈាន ប្រកបដោយករុណា ក្នុងសម័យនោះ ការអាណិត អាការអាណិត ភាពនៃការអាណិត ការអាណិតអាសូរ ចេតោវិមុត្តិណា នេះហៅថា ករុណា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយករុណា ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះនឿយណាយចាកបីតិផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ប្រកបដោយករុណា ក្នុងសម័យនោះ ការអាណិត អាការអាណិត ភាពនៃការអាណិត ការអាណិតអាសូរ ចេតោវិមុត្តិណា នេះហៅថា ករុណា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយករុណា ។

[ ៥០២ ] បណ្តាអប្បមញ្ញាទាំងនោះ មុទិតា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ប្រកបដោយមុទិតា ក្នុងសម័យនោះ ការរីករាយ អាការរីករាយ ភាពនៃការរីករាយ ការស្រស់ស្រាយ ចេតោវិមុត្តិណា នេះហៅថា មុទិតា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថាប្រកបដោយមុទិតា ។ បណ្តាអប្បមញ្ញាទាំងនោះ មុទិតា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនា

នេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់វិតក្ក និងវិចារ ។បេ។ ចូលកាន់ទុតិយជ្ឈាន ប្រកបដោយមុទិតា ក្នុងសម័យនោះ ការរីករាយ អាការរីករាយ ភាពនៃការរីករាយ ការស្រស់ស្រាយ ចេតោវិមុត្តិណា នេះហៅថា មុទិតា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមុទិតា ។ បណ្តាអប្បមញ្ញាទាំងនោះ មុទិតា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះនឿយណាយចាកបីតិផង ។បេ។ ចូលកាន់តតិយជ្ឈាន ប្រកបដោយមុទិតា ក្នុងសម័យនោះ ការរីករាយ អាការរីករាយ ភាពនៃការរីករាយ ការស្រស់ស្រាយ ចេតោវិមុត្តិណា នេះហៅថា មុទិតា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមុទិតា ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ប្រកបដោយមុទិតា ក្នុងសម័យនោះ ការរីករាយ អាការរីករាយ ភាពនៃការរីករាយ ការស្រស់ស្រាយ ចេតោវិមុត្តិណា នេះហៅថា មុទិតា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមុទិតា ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ចូលកាន់ទុតិយជ្ឈាន មិនមានវិតក្ក មានត្រឹមតែវិចារ មានបីតិ និងសុខ កើតអំពីសេចក្តីស្ងប់ស្ងាត់ ប្រកបដោយមុទិតា ក្នុងសម័យនោះ ការរីករាយ អាការរីករាយ ភាពនៃការរីករាយ ការស្រស់ស្រាយ ចេតោវិមុត្តិណា នេះហៅថា មុទិតា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមុទិតា ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុង

រូបភព ព្រោះរម្ងាប់វិតក្ក និងវិចារ ។បេ។ ចូលកាន់តតិយជ្ឈាន ប្រកបដោយមុទិតា ក្នុងសម័យនោះ ការរីករាយ អាការរីករាយ ភាពនៃការរីករាយ ការស្រស់ស្រាយ ចេតោវិមុត្តិណា នេះហៅថា មុទិតា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមុទិតា ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះនឿយណាយចាកបីតិផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ប្រកបដោយមុទិតា ក្នុងសម័យនោះ ការរីករាយ អាការរីករាយ ភាពនៃការរីករាយ ការស្រស់ស្រាយ ចេតោវិមុត្តិណា នេះហៅថា មុទិតា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមុទិតា ។

[ ៥០៣ ] បណ្តាអប្បមញ្ញាទាំងនោះ ឧបេក្ខា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះលះបង់សុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ប្រកបដោយឧបេក្ខា ក្នុងសម័យនោះ ការព្រងើយ អាការព្រងើយ ភាពនៃការព្រងើយ ការតោះតើយ ចេតោវិមុត្តិណា នេះហៅថា ឧបេក្ខា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឧបេក្ខា ។

[ ៥០៤ ] អប្បមញ្ញា ៤ យ៉ាង គឺមេត្តា ១ ករុណា ១ មុទិតា ១ ឧបេក្ខា ១ ។

[ ៥០៥ ] បណ្តាអប្បមញ្ញាទាំងនោះ មេត្តា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ប្រកបដោយមេត្តា ក្នុងសម័យនោះ

ផស្សៈក៏កើតមាន ។បេ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថា ជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ជាវិបាក ប្រកបដោយមេត្តា ព្រោះភាពនៃកម្មជារូបាវចរកុសលនោះឯង ដែលលោកធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោវិមុត្តិណា នេះហៅថា មេត្តា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមេត្តា ។ បណ្តាអប្បមញ្ញាទាំងនោះ មេត្តា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់វិតក្ក និងវិចារ ។បេ។ ចូលកាន់ទុតិយជ្ឈាន ប្រកបដោយមេត្តា ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថា ជាកុសល ភិក្ខុព្រោះរម្ងាប់វិតក្ក និងវិចារ ។បេ។ ចូលកាន់ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ជាវិបាក ប្រកបដោយមេត្តា ព្រោះភាពនៃកម្មជារូបាវចរកុសលនោះឯង ដែលលោកធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោវិមុត្តិណា នេះហៅថា មេត្តា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមេត្តា ។

[ ៥០៦ ] បណ្តាអប្បមញ្ញាទាំងនោះ ករុណា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ប្រកបដោយករុណា ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថាជាកុសល

ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ជាវិបាក ប្រកប ដោយករុណា ព្រោះភាពនៃកម្មជារូបាវចរកុសលនោះឯង ដែលលោកធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ ការអាណិត អាការអាណិត ភាពនៃការអាណិត ការអាណិតអាសូរ ចេតោវិមុត្តិណា នេះហៅថា ករុណា ធម៌ទាំងឡាយ ដ៏សេស ក៏ឈ្មោះថា ប្រកបដោយករុណា ។ បណ្តាអប្បមញ្ញាទាំងនោះ ករុណា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់វិតក្ក និងវិចារ ។បេ។ ចូលកាន់ទុតិយជ្ឈាន ប្រកបដោយករុណា ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ អវិក្ខេបៈ ក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថា ជាកុសល ភិក្ខុ ព្រោះរម្ងាប់វិតក្ក និង វិចារ ។បេ។ ចូលកាន់ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ជាវិបាក ប្រកបដោយករុណា ព្រោះភាពនៃកម្មជារូបា-វចរកុសលនោះឯង ដែលលោកធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ ការ អាណិត អាការអាណិត ភាពនៃការអាណិត ការអាណិតអាសូរ ចេតោវិមុត្តិ ណា នេះហៅថា ករុណា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកប ដោយករុណា ។

[ ៥០៧ ] បណ្តាអប្បមញ្ញាទាំងនោះ មុទិតា តើដូចម្តេច ។ ក្នុងសម័យ ណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាម ទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ប្រកបដោយមុទិតា ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនោះ ឈ្មោះថា ជាកុសល

ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ជាវិបាក ប្រកបដោយមុទិតា ព្រោះភាពនៃកម្មជារូបាវចរកុសលនោះឯង ដែលលោកធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ ការរីករាយ អាការរីករាយ ភាពនៃការរីករាយ ការស្រស់ស្រាយ ចេតោវិមុត្តិណា នេះហៅថា មុទិតា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមុទិតា ។ បណ្តាអប្បមញ្ញាទាំងនោះ មុទិតា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់វិតក្ក និងវិចារ ។បេ។ ចូលកាន់ទុតិយជ្ឈាន ប្រកបដោយមុទិតា ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថា ជាកុសល ភិក្ខុ ព្រោះរម្ងាប់វិតក្ក និងវិចារ ។បេ។ ចូលកាន់ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ជាវិបាក ប្រកបដោយមុទិតា ព្រោះភាពនៃកម្មជារូបាវចរកុសលនោះឯង ដែលលោកធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ ការរីករាយ អាការរីករាយ ភាពនៃការរីករាយ ការស្រស់ស្រាយ ចេតោវិមុត្តិណា នេះហៅថា មុទិតា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមុទិតា ។

[ ៥០៨ ] បណ្តាអប្បមញ្ញាទាំងនោះ ឧបេក្ខា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះលះសុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ប្រកបដោយឧបេក្ខា ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ អវិក្ខេបៈក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថា ជាកុសល ភិក្ខុ ព្រោះលះសុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ជាវិបាក ប្រកបដោយ

ឧបេក្ខា ព្រោះភាពនៃកម្មជារូបាវចរកុសលនោះឯង ដែលលោកធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ ការព្រងើយ អាការព្រងើយ ភាពនៃការព្រងើយ ការតោះតើយ ចេតោវិមុត្តិណា នេះ ហៅថា ឧបេក្ខា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឧបេក្ខា ។

[ ៥០៩ ] អប្បមញ្ញា ៤ យ៉ាង គឺមេត្តា ១ ករុណា ១ មុទិតា ១ ឧបេក្ខា ១ ។

[ ៥១០ ] បណ្តាអប្បមញ្ញាទាំងនោះ មេត្តា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនរូបាវចរជ្ឈាន ជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនកម្មវិបាក គឺជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ប្រកបដោយមេត្តា ក្នុងសម័យនោះ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោវិមុត្តិណា នេះហៅថា មេត្តា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយមេត្តា ។ បណ្តាអប្បមញ្ញាទាំងនោះ មេត្តា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនរូបាវចរជ្ឈាន ជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនកម្មវិបាក គឺជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន ព្រោះរម្ងាប់វិតក្ក និងវិចារ ។បេ។ ចូលកាន់ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ប្រកបដោយមេត្តា ក្នុងសម័យនោះ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោវិមុត្តិណា នេះហៅថា មេត្តា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកប

ដោយមេត្តា ។ បណ្តាអប្បមញ្ញាទាំងនោះ ករុណា តើដូចម្តេច ។បេ។ បណ្តាអប្បមញ្ញាទាំងនោះ មុទិតា តើដូចម្តេច ។បេ។ បណ្តាអប្បមញ្ញាទាំងនោះ ឧបេក្ខា តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនរូបាវចរជ្ឈាន ជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនកម្មវិបាក គឺជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន ព្រោះលះសុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ប្រកបដោយឧបេក្ខា ក្នុងសម័យនោះ ការព្រងើយ អាការព្រងើយ ភាពនៃការព្រងើយ ការតោះតើយ ចេតោវិមុត្តិណា នេះហៅថា ឧបេក្ខា ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឧបេក្ខា ។

អភិធម្មភាជនីយ ចប់

# អដ្ឋកថា

## អភិធម្មភាជនីយ

[ ៤៩៩-៥១០ ] *អភិធម្មភាជនីយនេះ ពោលដោយកុសលត្តិ ដោយវិបាកត្តិ ដោយកិរិយាត្តិ ព្រះមានព្រះភាគទ្រង់ចែកហើយ ដោយន័យដែលចែកក្នុងចិត្តុប្បាទកណ្ឌខាងដើមនោះឯង ។ អត្ថនៃអភិធម្មភាជនីយនោះបណ្ឌិតគប្បីជ្រាបដោយន័យដែលខ្ញុំពោលហើយ ក្នុងចិត្តុប្បាទកណ្ឌ ។*

**អដ្ឋកថាអភិធម្មភាជនីយ ចប់**

# អភិធម្មបិដក

## បញ្ហាបុច្ឆកៈ

[ ៥១១ ] អប្បមញ្ញា ៤ យ៉ាង ។ គឺភិក្ខុក្នុងសាសនានេះ មានចិត្ត ប្រកបដោយមេត្តា ផ្សាយទៅកាន់ទិស ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹង គឺទិសតូច មានចិត្តប្រកបដោយមេត្តា ជាចិត្តធំទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង ១ ។ ភិក្ខុ មានចិត្តប្រកបដោយករុណា ផ្សាយទៅកាន់ទិស ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹង គឺទិសតូច មានចិត្តប្រកបដោយករុណា ជាចិត្តធំទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង ១ ។ ភិក្ខុ មានចិត្តប្រកបដោយមុទិតា ផ្សាយទៅកាន់ទិស ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹង គឺទិសតូច មានចិត្តប្រកបដោយមុទិតា ជាចិត្តធំទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង ១ ។ ភិក្ខុ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិស ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹង គឺទិសតូច មានចិត្តប្រកបដោយ

ឧបេក្ខា ជាចិត្តធំទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង ១ ។ បណ្តាអប្បមញ្ញា ៤ យ៉ាង អប្បមញ្ញាជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។បេ។ ជាសរណៈប៉ុន្មាន ជាអរណៈប៉ុន្មាន ។

[ ៥១២ ] ពួកអប្បមញ្ញា ជាកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។ អប្បមញ្ញា ៣ ប្រកបដោយសុខវេទនា ឧបេក្ខា ប្រកបដោយអទុក្ខមសុខ-វេទនា ។ អប្បមញ្ញា ជាវិបាកក៏មាន មានវិបាកធម៌ជាប្រក្រតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតីក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនបានកាន់យក តែជាប្រយោជន៍ដល់ឧបាទាន ដែលមិនសៅហ្មង តែគួរដល់សេចក្តីសៅហ្មងក៏មាន ។ អប្បមញ្ញា ៣ ប្រកបដោយវិតក្ក ប្រកបដោយវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក មិនមានវិចារក៏មាន ឧបេក្ខា មិនមានវិតក្ក មិនមានវិចារ ។ អប្បមញ្ញា ៣ ប្រឡំដោយបីតិក៏មាន ប្រឡំដោយសុខ តែមិនប្រឡំដោយឧបេក្ខាក៏មាន មិនគួរពោលថា ប្រឡំដោយបីតិក៏មាន ឧបេក្ខា ប្រឡំដោយឧបេក្ខា ។ ពួកអប្បមញ្ញា មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា មានហេតុ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា ដល់នូវការសន្សំ ( នូវកម្មកិលេស ) ក៏មាន

មិនដល់នូវការសន្សំ ទាំងមិនដល់នូវការមិនសន្សំ មិនមែនរបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល ដល់នូវភាពធំ មិនគួរពោលថា មានអារម្មណ៍ដ៏តូចឆ្មារផង ថាមានអារម្មណ៍ដល់នូវភាពធំផង ថាមានអារម្មណ៍មិនមានប្រមាណផង ជាកណ្តាល ជាសភាពមិនទៀង មិនគួរពោលថា មានមគ្គជាអារម្មណ៍ផង ថាមានមគ្គជាហេតុផង ថាមានមគ្គជាអធិបតីផងក៏មាន ដែលកើតហើយក៏មាន មិនទាន់កើតក៏មាន បម្រុងនឹងកើតក៏មាន ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្ន តែមិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថាមានអារម្មណ៍ជាអនាគតផង មានអារម្មណ៍ជាបច្ចុប្បន្នផងក៏មាន ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ជាខាងក្នុង និងខាងក្រៅ មានអារម្មណ៍ជាខាងក្រៅ មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ក៏មាន ។

[ ៥១៣ ] មេត្តា ជាហេតុ អប្បមញ្ញា ៣ មិនមែនហេតុ ។ ពួកអប្បមញ្ញាប្រព្រឹត្តទៅជាមួយនឹងហេតុ ប្រកបដោយហេតុ ។ មេត្តា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ អប្បមញ្ញា ៣ មិនគួរពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុទេ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុ ។ មេត្តា ជាហេតុ ទាំងប្រកបដោយហេតុ អប្បមញ្ញា ៣ មិនគួរពោលថា ជាហេតុ ទាំងប្រកបដោយហេតុទេ គ្រាន់តែប្រកបដោយហេតុ តែមិនមែនហេតុ ។ អប្បមញ្ញា ៣ មិនមែនហេតុ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ មេត្តា មិនគួរពោលថា មិនមែនហេតុ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុផង ថាមិនមែនហេតុ ទាំងឥតមានហេតុ ដូច្នេះផង ។

[ ៥១៤ ] ពួកអប្បមញ្ញា ប្រកបដោយបច្ច័យ ត្រូវបច្ច័យតាក់តែង មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ ឥតរូប ជាលោកិយ ដែលគប្បីដឹងដោយវិញ្ញាណណាមួយ ដែលមិនគប្បីដឹងដោយវិញ្ញាណណាមួយ ។ ពួកអប្បមញ្ញា មិនមែនអាសវៈ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ ប្រាសចាកអាសវៈ មិនគួរពោលថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈឡើយ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈ មិនគួរពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈផង ថាប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផងទេ ប្រាសចាកអាសវៈ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ ។ ពួកអប្បមញ្ញា មិនមែនសំយោជនៈ ។បេ។ មិនមែនគន្ថៈ ។បេ។ មិនមែនឱឃៈ ។បេ។ មិនមែនយោគៈ ។បេ។ មិនមែននីវរណៈ ។បេ។ មិនមែនបរាមាស ។បេ។ ប្រកបដោយអារម្មណ៍ មិនមែនចិត្ត ជាចេតសិក ប្រកបដោយចិត្ត ប្រឡំដោយចិត្ត តាំងឡើងដោយចិត្ត កើតជាមួយនឹងចិត្ត ប្រព្រឹត្តទៅតាមចិត្ត ប្រឡំ ទាំងតាំងឡើងដោយចិត្ត ប្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត ប្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត ជាខាងក្រៅ មិនមែនឧបាទា មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកក៏មាន មានកម្ម ប្រកបដោយកិលេស មានតណ្ហាជាដើមមិនបានកាន់យកក៏មាន ។ មិនមែនឧបាទាន ។បេ។ មិនមែនកិលេស ។បេ។

[ ៥១៥ ] ពួកអប្បមញ្ញា មិនគួរលះដោយទស្សនៈ មិនគួរលះដោយ

ភាវនា មានហេតុ មិនគួរលះដោយទស្សនៈ មានហេតុ មិនគួរលះដោយភាវនា ។ អប្បមញ្ញា ៣ ប្រកបដោយវិតក្កក៏មាន មិនមានវិតក្កក៏មាន ឧបេក្ខា មិនមានវិតក្ក ។ អប្បមញ្ញា ៣ ប្រកបដោយវិចារក៏មាន មិនមានវិចារក៏មាន ឧបេក្ខា មិនមានវិចារ ។ អប្បមញ្ញា ៣ ប្រកបដោយបីតិក៏មាន មិនមានបីតិក៏មាន ឧបេក្ខា មិនមានបីតិ ។ អប្បមញ្ញា ៣ ប្រទ្បាំដោយបីតិក៏មាន មិនប្រទ្បាំដោយបីតិក៏មាន ឧបេក្ខា មិនប្រទ្បាំដោយបីតិ ។ អប្បមញ្ញា ៣ ប្រទ្បាំដោយសុខ ឧបេក្ខា មិនប្រទ្បាំដោយសុខ ។ ឧបេក្ខា ប្រទ្បាំដោយឧបេក្ខា អប្បមញ្ញា ៣ មិនប្រទ្បាំដោយឧបេក្ខា ។ អប្បមញ្ញា មិនមែនកាមាវចរ តែជារូបាវចរ មិនមែនអរូបាវចរ តែជាបរិយាបន្ន ជាអនិយ្យានិកៈ ជាអនិយតៈ ជាសឧត្តរៈ ជាអរណៈ ។

បញ្ហាបុច្ឆកៈ ចប់

អប្បមញ្ញាវិភង្គ ចប់

# អដ្ឋកថា

## បញ្ហាបុច្ឆកៈ

[ ៥១១-៥១៥ ] ក្នុងបញ្ហាបុច្ឆកៈ បណ្ឌិតគប្បីជ្រាបភាពដែលធម៌ទាំងឡាយ មានមេត្តាជាដើម ជាកុសលជាដើម ដោយទំនងនៃព្រះបាលីនោះឯង ។ តែក្នុងអារម្មណត្តិកៈ អប្បមញ្ញា ៤ ជានវត្តព្វារម្មណៈ ក្នុងតិកៈទាំង ៣ ។ ក្នុងអជ្ឈត្តារម្មណត្តិកៈ អប្បមញ្ញា ៤ ជាពហិទ្ធារម្មណៈ គឺជាអារម្មណ៍ខាងក្រៅ ។

ម្យ៉ាងទៀត ក្នុងអប្បមញ្ញាវិភង្គនេះ ដែលព្រះសម្មាសម្ពុទ្ធត្រាស់អប្បមញ្ញាទាំងឡាយជាលោកិយតែម្យ៉ាង ក្នុងសុត្តន្តភាជនីយក្តី ក្នុងអភិធម្មភាជនីយក្តី ក្នុងបញ្ហាបុច្ឆកៈក្តី ។ ពិតហើយ ន័យទាំង ៣ នេះ កំណត់បានតែមួយដូចគ្នា ព្រោះអប្បមញ្ញាទាំងនោះ ត្រឹមតែជាលោកិយ ។ សូម្បីអប្បមញ្ញាវិភង្គនិទ្ទេសនេះ ព្រះមានព្រះភាគទ្រង់ក៏នាំចេញ ចែកសម្តែងហើយ ជាបរិវដ្តៈ ៣ ដូចពណ៌នាមក ដូច្នេះ ។ល។

បញ្ហាបុច្ឆកៈ ចប់

អប្បមញ្ញាវិភង្គ ចប់

សម្មោហវិនោទនី អដ្ឋកថាវិភង្គ ចប់

# ក្បាលទី ៦៨

# អភិធម្មបិដក ចាលីប្រែ -៨១

## សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ

### បច្ចយាការវិភង្គ


| | |
|---|---|
| អភិធម្មបិដក បច្ចយាការវិភង្គ ...... ...... ............ ...... ...... .... | ២ |
| អដ្ឋកថាបដិច្ចសមុប្បាទវិភង្គ ...... ...... ............ ...... ...... .... | ៩ |
| អវិជ្ជានិទ្ទេស ...... ...... ...... ...... ...... ...... ...... ...... ...... .... | ២៩ |
| សង្ខារនិទ្ទេស ...... ...... ...... ...... ...... ...... ...... ...... ...... .... | ៣៧ |
| វិញ្ញាណនិទ្ទេស ...... ...... ...... ...... ...... ...... ...... ...... ...... .... | ៥៦ |
| នាមរូបនិទ្ទេស ...... ...... ...... ...... ...... ...... ...... ...... ...... .... | ៩២ |
| សឡាយតននិទ្ទេស ...... ...... ...... ...... ...... ...... ...... ...... ...... .... | ១០១ |
| ផស្សនិទ្ទេស ...... ...... ...... ...... ...... ...... ...... ...... ...... .... | ១០៨ |
| វេទនានិទ្ទេស ...... ...... ...... ...... ...... ...... ...... ...... ...... .... | ១១២ |
| តណ្ហានិទ្ទេស ...... ...... ...... ...... ...... ...... ...... ...... ...... .... | ១១៤ |
| ឧបាទាននិទ្ទេស ...... ...... ...... ...... ...... ...... ...... ...... ...... .... | ១១៧ |
| ភវនិទ្ទេស ...... ...... ...... ...... ...... ...... ...... ...... ...... .... | ១២៣ |
| ជាតិជរាមរណាទិនិទ្ទេស ...... ...... ...... ...... ...... ...... ...... .... | ១៣៣ |
| អធិប្បាយភវចក្ក ១២ ...... ...... ...... ...... ...... ...... ...... .... | ១៣៥ |
| អភិធម្មបិដក អភិធម្មភាជនីយ ...... ...... ...... ...... ...... ...... ...... .... | ១៥៨ |
| អដ្ឋកថាអភិធម្មភាជនីយ ...... ...... ...... ...... ...... ...... ...... .... | ១៦៨ |

បច្ចយចតុក្កៈ ...... ...... ...... ...... ...... ...... ...... .... ១៦៩
ហេតុចតុក្កៈ ...... ...... ...... ...... ...... ...... ...... .... ១៨០
សម្បយុត្តចតុក្កៈ ...... ...... ...... ...... ...... ...... ...... .... ១៨៣
អញ្ញមញ្ញចតុក្កៈ ...... ...... ...... ...... ...... ១៨៣
សង្ខារាទិមូលកនយមាតិកា ...... ...... ...... ...... ...... ១៨៤
អភិធម្មបិដក អកុសលនិទ្ទេស ...... ...... ...... ...... ...... ១៨៧
អដ្ឋកថាអកុសលនិទ្ទេស ...... ...... ...... ...... ...... ២៣៤
អភិធម្មបិដក កុសលនិទ្ទេស ...... ...... ...... ...... ...... ២៤០
អដ្ឋកថាកុសលនិទ្ទេស ...... ...... ...... ...... ...... ២៥០
អភិធម្មបិដក អព្យាកតនិទ្ទេស ...... ...... ...... ...... ...... ២៥២
អដ្ឋកថាអព្យាកតនិទ្ទេស ...... ...... ...... ...... ...... ២៧២
អភិធម្មបិដក អវិជ្ជាមូលកកុសលនិទ្ទេស ...... ...... ...... ...... ...... ២៧៤
អដ្ឋកថាអវិជ្ជាមូលកកុសលនិទ្ទេស ...... ...... ...... ...... ...... ២៨៥
អភិធម្មបិដក កុសលមូលកវិបាកនិទ្ទេស ...... ...... ...... ...... ...... ២៨៧
អដ្ឋកថាកុសលមូលកវិបាកនិទ្ទេស ...... ...... ...... ...... ...... ២៩២

## សតិប្បដ្ឋានវិភង្គ

អភិធម្មបិដក សតិប្បដ្ឋានវិភង្គ ...... ...... ...... ...... ...... ២៩៤
អដ្ឋកថាសុត្តន្តភាជនីយឧទ្ទេសវារ ...... ...... ...... ...... ...... ៣១៥
អធិប្បាយឧទ្ទេសនៃវេទនានុបស្សនាជាដើម ...... ...... ...... ...... ...... ៣៣១
អធិប្បាយកាយានុបស្សនានិទ្ទេស ...... ...... ...... ...... ...... ៣៣៤
អដ្ឋកថាវេទនានុបស្សនានិទ្ទេស ...... ...... ...... ...... ...... ៤១០
អដ្ឋកថាចិត្តានុបស្សនានិទ្ទេស ...... ...... ...... ...... ...... ៤២០
អដ្ឋកថាធម្មានុបស្សនានិទ្ទេស ...... ...... ...... ...... ...... ៤២៣

នីវរណបព្វៈ ...... ...... ...... ...... ...... ...... ...... ៤២៣

ពោជ្ឈង្គបព្វៈ ...... ...... ...... ...... ...... ...... ...... ៤៣៦

អភិធម្មបិដក អភិធម្មភាជនីយ ...... ...... ...... ...... ...... ...... ៤៦១

អដ្ឋកថាអភិធម្មភាជនីយ ...... ...... ...... ...... ...... ...... ...... ៤៦៧

អភិធម្មបិដក បញ្ហាបុច្ឆកៈ ...... ...... ...... ...... ...... ...... ...... ៤៦៩

អដ្ឋកថាបញ្ហាបុច្ឆកៈ ...... ...... ...... ...... ...... ...... ...... ៤៧៣


## សម្មប្បធានវិភង្គ


អភិធម្មបិដក សម្មប្បធានវិភង្គ ...... ...... ...... ...... ...... ...... ...... ៤៧៤

អដ្ឋកថាសម្មប្បធានវិភង្គ ...... ...... ...... ...... ...... ...... ...... ៤៨១

អភិធម្មបិដក អភិធម្មភាជនីយ ...... ...... ...... ...... ...... ...... ...... ៥០៨

អដ្ឋកថាអភិធម្មភាជនីយ ...... ...... ...... ...... ...... ...... ...... ៥១៥

អភិធម្មបិដក បញ្ហាបុច្ឆកៈ ...... ...... ...... ...... ...... ...... ...... ៥១៧

អដ្ឋកថាបញ្ហាបុច្ឆកៈ ...... ...... ...... ...... ...... ...... ...... ៥២១


## ឥទ្ធិបាទវិភង្គ


អភិធម្មបិដក ឥទ្ធិបាទវិភង្គ ...... ...... ...... ...... ...... ...... ...... ៥២២

អដ្ឋកថាឥទ្ធិបាទវិភង្គ ...... ...... ...... ...... ...... ...... ...... ៥២៩

អភិធម្មបិដក អភិធម្មភាជនីយ ...... ...... ...... ...... ...... ...... ...... ៥៤០

អដ្ឋកថាអភិធម្មភាជនីយ ...... ...... ...... ...... ...... ...... ...... ៥៤៨

អភិធម្មបិដក បញ្ហាបុច្ឆកៈ ...... ...... ...... ...... ...... ...... ...... ៥៤៩

អដ្ឋកថាបញ្ហាបុច្ឆកៈ ...... ...... ...... ...... ...... ...... ...... ៥៥៣


## ពោជ្ឈង្គវិភង្គ


អភិធម្មបិដក ពោជ្ឈង្គវិភង្គ ...... ...... ...... ...... ...... ...... ...... ៥៥៥

អដ្ឋកថាពោជ្ឈង្គវិភង្គ ...... ...... ...... ...... ...... ...... ...... ៥៦០

អភិធម្មបិដក អភិធម្មភាជនីយ ...... ...... ...... ...... ...... ...... ...... ៥៧៦
អដ្ឋកថាអភិធម្មភាជនីយ ...... ...... ...... ...... ...... ...... ...... ៥៨២
អភិធម្មបិដក បញ្ហាបុច្ឆក: ...... ...... ...... ...... ...... ...... ...... ៥៨៤
អដ្ឋកថាបញ្ហាបុច្ឆក: ...... ...... ...... ...... ...... ...... ...... ៥៨៨

## មគ្គវិភង្គ

អភិធម្មបិដក មគ្គវិភង្គ ...... ...... ...... ...... ...... ...... ...... ៥៩០
អដ្ឋកថាមគ្គវិភង្គ ...... ...... ...... ...... ...... ...... ...... ៥៩៤
អភិធម្មបិដក អភិធម្មភាជនីយ ...... ...... ...... ...... ...... ...... ...... ៥៩៥
អដ្ឋកថាអភិធម្មភាជនីយ ...... ...... ...... ...... ...... ...... ...... ៦០២
អភិធម្មបិដក បញ្ហាបុច្ឆក: ...... ...... ...... ...... ...... ...... ...... ៦០៩
អដ្ឋកថាបញ្ហាបុច្ឆក: ...... ...... ...... ...... ...... ...... ...... ៦១៣

## ឈានវិភង្គ

អភិធម្មបិដក ឈានវិភង្គ ...... ...... ...... ...... ...... ...... ...... ៦១៤
អដ្ឋកថាឈានវិភង្គ ...... ...... ...... ...... ...... ...... ...... ៦១៧
អភិធម្មបិដក សុត្តន្តភាជនីយ ...... ...... ...... ...... ...... ...... ...... ៦២២
អដ្ឋកថាសុត្តន្តភាជនីយ ...... ...... ...... ...... ...... ...... ...... ៦៥៨
អភិធម្មបិដក អភិធម្មភាជនីយ ...... ...... ...... ...... ...... ...... ...... ៧៦០
អដ្ឋកថាអភិធម្មភាជនីយ ...... ...... ...... ...... ...... ...... ...... ៧៧១
អភិធម្មបិដក បញ្ហាបុច្ឆក: ...... ...... ...... ...... ...... ...... ...... ៧៧២
អដ្ឋកថាបញ្ហាបុច្ឆក: ...... ...... ...... ...... ...... ...... ...... ៧៧៨

## អប្បមញ្ញាវិភង្គ

អភិធម្មបិដក អប្បមញ្ញាវិភង្គ ...... ...... ...... ...... ...... ...... ...... ៧៨៧
អដ្ឋកថាអប្បមញ្ញាវិភង្គ ...... ...... ...... ...... ...... ...... ...... ៧៩៦

អភិធម្មបិដក អភិធម្មភាជនីយ ...... ...... ...... ...... ...... ...... ...... ៨០៤
អដ្ឋកថាអភិធម្មភាជនីយ ...... ...... ...... ...... ...... ...... ...... ៨១៥
អភិធម្មបិដក បញ្ហាបុច្ឆកៈ ...... ...... ...... ...... ...... ...... ...... ៨១៦
អដ្ឋកថាបញ្ហាបុច្ឆកៈ ...... ...... ...... ...... ...... ...... ...... ៨២១